# ប្រវត្តិសាស្ត្រកម្ពុជា







រៀបរៀងដោយ៖ ទង់ សុជា៉
ឈុប សុខា
២០២១

CAMBODIA
RESEARCH CREATIVITY INNOVATION
គាំទ្រថវិកាលើការរៀបរៀង និពន្ធ និងកែលម្អដោយ
មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍

# ប្រវត្តិសាស្ត្រកម្ពុជា

រៀបរៀងដោយ៖ ទង់ សុធារ៉ា
ឈុប សុខា
២០២១

គាំទ្រថវិកាលើការរៀបរៀង និពន្ធ និងកែលម្អដោយ
មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍

# សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
# មហាវិទ្យាល័យសង្គមសាស្ត្រ-មនុស្សសាស្ត្រ
# ដេប៉ាតឺម៉ង់ប្រវត្តិវិទ្យា

## គណៈកម្មការនិពន្ធ

| | |
|---|---|
| ១. លោកបណ្ឌិត វង់ សុជាវ៉ា | ប្រធានដេប៉ាតឺម៉ង់ប្រវត្តិវិទ្យា |
| ២. លោក ណុប សុខា | អនុប្រធានដេប៉ាតឺម៉ង់ប្រវត្តិវិទ្យា |

## គណៈកម្មការត្រួតពិនិត្យ

| | |
|---|---|
| ១. លោក ជា វិធូរ | អនុប្រធានដេប៉ាតឺម៉ង់ប្រវត្តិវិទ្យា |
| ២. លោក ថា លាងអាង | សាស្ត្រាចារ្យដេប៉ាតឺម៉ង់ប្រវត្តិវិទ្យា |
| ៣. លោក គួង គានី | សាស្ត្រាចារ្យដេប៉ាតឺម៉ង់ប្រវត្តិវិទ្យា |
| ៤. លោក អ៊ី ប៊ុនលី | សាស្ត្រាចារ្យដេប៉ាតឺម៉ង់ប្រវត្តិវិទ្យា |

# មុទ្ទកថា

ដំណើរអភិវឌ្ឍនៃព្រះរាជាណាចក្រកម្ពុជានៅក្នុងយុគសម័យទំនើបនេះ ជាមេរៀនដ៏ជោគជ័យបំផុតមួយដែលចាប់ឫសគល់ចេញពីការបញ្ចប់របបប្រល័យពូជសាសន៍ ការបញ្ចប់សង្គ្រាម ការផ្សះផ្សារជាតិ ការកសាងមូលដ្ឋានរឹងមាំនៃសន្តិភាពនិងស្ថិរភាព និងការអភិវឌ្ឍសេដ្ឋកិច្ច។ នៅក្រោយពេលដែលសន្តិភាពត្រូវបានកើតឡើងដោយបរិបូរណ៍នៅឆ្នាំ១៩៩៨ កម្ពុជាទទួលកំណើនសេដ្ឋកិច្ចខ្ពស់ គឺប្រមាណ ៨% ក្នុងមួយឆ្នាំ។ លើសពីនេះទៀត អត្រានៃភាពក្រីក្រត្រូវបានកាត់បន្ថយពីប្រមាណ៥៣% នៅឆ្នាំ២០០៤ មកនៅទាបជាង១០% នៅឆ្នាំ២០១៩។ ដំណើរនៃការអភិវឌ្ឍជាតិជាសកម្មភាពដែលបន្តទៅមុខជាប់ជានិច្ច ហើយគោលនយោបាយថ្មីៗដែលមានលក្ខណៈអន្តរវិស័យគ្រប់ដណ្ដប់ ក៏កំពុងលេចរូបរាងឡើង ដើម្បីតម្រង់ទិសកម្ពុជាឆ្ពោះទៅកាន់ប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងឈានឡើងជាប្រទេសមានប្រាក់ចំណូលខ្ពស់ នៅឆ្នាំ២០៥០។ ការប្រែប្រួលឆាប់រហ័សនៃនិម្មាបនកម្មពិភពលោកនិងតំបន់ រួមទាំងទំនាក់ទំនងភូមិសាស្ត្រនយោបាយ បានផ្តល់កាលានុវត្តភាពសម្រាប់ការអភិវឌ្ឍឧស្សាហកម្មនៅកម្ពុជា ដែលត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាមូលដ្ឋានគ្រឹះនៃកំណើនសេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងបន្តពង្រឹង និងអភិវឌ្ឍវិស័យអប់រំឆ្ពោះទៅរកការស្រាវជ្រាវ និងនវានុវត្តន៍ ដើម្បីពង្រឹងសមត្ថភាពនិងជំនាញរបស់ធនធានមនុស្សនៅកម្ពុជា ឱ្យស្របទៅនឹងបរិបទថ្មីនៃការអភិវឌ្ឍ ជាពិសេសការពង្រឹងសហគ្រិនភាពក្នុងការរៀបចំម៉ូដែលធុរកិច្ចថ្មីៗ។ ដើម្បីចាប់យកកាលានុវត្តភាពពីបដិវត្តន៍ឧស្សាហកម្មទី៤ និងសេដ្ឋកិច្ចឌីជីថលដែលកំពុងផុសផុលឡើង ប្រព័ន្ធអេកូឡូហ្ស៊ីដែលបង្កលក្ខណៈអំណោយផលដល់ការបង្កើតថ្មី នវានុវត្តន៍ ការស្រាវជ្រាវ និងអភិវឌ្ឍន៍ត្រូវតែមានការកែលម្អ។

បណ្ដាប្រទេសនៅទ្វីបអាស៊ីកំពុងនាំមុខក្នុងការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ ដោយមានភាគហ៊ុនប្រមាណ៤៤% នៃការវិនិយោគទាំងមូលរបស់ពិភពលោក។ ប្រទេសចិនកំពុងបន្តកសាងហេដ្ឋារចនាសម្ព័ន្ធនៃការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ ក៏ដូចជាសមត្ថភាពមនុស្ស។ ផ្ទុយទៅវិញ ប្រទេសនៅទ្វីបអាមេរិកខាងត្បូង និងអាហ្វ្រិក កំពុងស្ថិតនៅឆ្ងាយពីការវិនិយោគនេះ ហើយជាលទ្ធផលប្រទេសទាំងនោះក៏ពុំមានកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ដែរ។ ទុនវិនិយោគសរុបលើការស្រាវជ្រាវ និងអភិវឌ្ឍរបស់ប្រទេសនៅទ្វីបអាមេរិកខាងត្បូងនិងអាហ្វ្រិក មានប្រមាណ៥%នៃការវិនិយោគទាំងមូលរបស់ពិភពលោក ក្នុងពេលដែលតំបន់ទាំង២នេះមានប្រជាជនប្រមាណ២០%នៃប្រជាជនពិភពលោក។ ប្រទេសចំនួន៦ដែលមានលំដាប់ខ្ពស់ជាងគេនៅក្នុងការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ រួមមានសហរដ្ឋអាមេរិក ចិន ជប៉ុន អាល្លឺម៉ង់ ឥណ្ឌា និងកូរ៉េខាងត្បូង ដែលស្មើនឹងប្រមាណ៧០%នៃទុនវិនិយោគសរុបរបស់ពិភពលោក។

តើចំណេះដឹង ផលិតផល និងសេវាកម្មថ្មីទាំងនេះកើតឡើងពីអ្វី? ហើយកើតឡើងដោយរបៀបណា? ព្រះរាជាណាចក្រកម្ពុជាកំពុងតែកសាងមូលដ្ឋានសម្រាប់ការត្រៀមខ្លួនទទួល និងប្រកួតប្រជែងក្នុងយុគសម័យបដិវត្តឧស្សាហកម្មទី៤ នៅក្នុងសេដ្ឋកិច្ចដែលផ្អែកលើពុទ្ធិ ហើយដែលប្រការនេះ

ចាំបាច់តម្រូវឱ្យពលរដ្ឋកម្ពុជា ត្រូវក្លាយខ្លួនជាពលរដ្ឋឌីជីថល ពលរដ្ឋសកល និងពលរដ្ឋដែលប្រកបដោយការទទួលខុសត្រូវ ដែលមានសមត្ថភាពក្នុងការផលិត ចែកចាយ និងប្រើប្រាស់ពុទ្ធិដើម្បីទទួលមនុញ្ញផល និងរួមចំណែកក្នុងកំណើន។ ធនាគារពិភពលោកបានធ្វើការកត់សម្គាល់តាំងពីឆ្នាំ ២០០២នូវបម្លាស់ប្តូរនៃមូលដ្ឋានសេដ្ឋកិច្ច ពីសេដ្ឋកិច្ចដែលពឹងផ្អែកលើកម្លាំងពលកម្ម និងធនធានអតិកម្ម (Labour and Resource Based Economy) ទៅកាន់សេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិ (Knowledge Based-Economy) ដែលក្នុងន័យនេះ ពុទ្ធិគឺជាគន្លឹះនៃការអភិវឌ្ឍ។ អាស្រ័យហេតុនេះ នៅលើគន្លងដែលកម្ពុជាកំពុងធ្វើដំណើរឆ្ពោះទៅកាន់សេដ្ឋកិច្ចឌីជីថល សង្គមកម្ពុជាត្រូវតែមានសមត្ថភាពក្នុងការផលិត ជ្រើសរើស បន្សាំ បង្កើតមុខរបរ និងប្រើប្រាស់ពុទ្ធិ ដើម្បីរក្សានិរន្តរភាពនៃកំណើន និងកែលម្អជីវភាពរស់នៅ។ សមត្ថភាពទាំងនេះ អាចកើតឡើងនៅពេលពលរដ្ឋកម្ពុជាមានឱកាសក្នុងការទទួលបានបទពិសោធន៍ពីការស្រាវជ្រាវ ការបណ្តុះគំនិតច្នៃប្រឌិត និងការស្វែងរកនវានុវត្តន៍។

កំណែទម្រង់វិស័យអប់រំ គឺជាការត្រួសត្រាយមាគ៌ាសម្រាប់ដំណើរឆ្ពោះទៅកាន់សង្គមប្រកបដោយពុទ្ធិ និងប្រជាពលរដ្ឋប្រកបដោយភាពរស់រវើក។ តាមរយៈមូលដ្ឋានអប់រំ សង្គមប្រកបដោយពុទ្ធិនឹងប្រមូលផ្តុំ បង្កើត និងចែករំលែក ទៅកាន់សមាជិកក្នុងសង្គមនូវសម្បទាអប់រំ ពិសេសគឺពុទ្ធិសម្បទាក្នុងបុព្វហេតុនៃមនុស្សជាតិនិងឧត្តមប្រយោជន៍នៃប្រទេស។ សង្គមប្រកបដោយពុទ្ធិ គឺពុំគ្រាន់តែជាសង្គមដែលសម្បូរព័ត៌មានប៉ុណ្ណោះទេ តែជាសង្គមដែលប្រជាពលរដ្ឋអាចធ្វើបរិវត្តកម្មពីព័ត៌មានទៅជាមូលធនប្រកបដោយប្រសិទ្ធភាព។ ការរីកចម្រើនទៅមុខជាលំដាប់នៃបច្ចេកវិទ្យានិងតំណភ្ជាប់ បានពង្រីកព្រំដែននៃការចូលទៅកាន់ និងការទទួលបានព័ត៌មានជាសកល ហើយដែលក្នុងន័យនេះ ការអប់រំនឹងបន្តវិវត្តទៅមុខនិងមានការផ្លាស់ប្តូរ។ សង្គមមួយដែលមានអំណាន និងរបាប់ជាបុរេលក្ខខណ្ឌនៃជីវភាពប្រចាំថ្ងៃនៃប្រជាពលរដ្ឋ ពេលនោះបំណិននៃអំណាន និពន្ធ និងការគណនាលេខនព្វន្ត គឺជាចលករនៃការរៀនរបស់សិស្ស។ ធាតុដ៏ចម្បងមួយដែលស្ថិតនៅក្នុងការកសាងសង្គមដែលប្រកបដោយពុទ្ធិគឺសៀវភៅសិក្សា ហើយការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សាជាប្រចាំ គឺជានវានុវត្តន៍នៃវិស័យអប់រំដែលនាំទៅរកការសិក្សាពេញមួយជីវិត ការអភិវឌ្ឍសម្បទាអប់រំ និងការចែករំលែកចំណេះដឹង។ មូលដ្ឋានអប់រំ ជាពិសេសគឺគ្រឹះស្ថានឧត្តមសិក្សាត្រូវមានតួនាទីដែលប្រកបដោយការឆ្លើយតប ចំពោះតម្រូវការខាងលើនេះ។ សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំត្រូវបន្តសិក្សាជាប់ជានិច្ច តាមរយៈការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ហើយដែលសៀវភៅសិក្សាទាំងនេះនឹងក្លាយជាស្ពាននៃទំនាក់ទំនងរវាងនវានុវត្តន៍នៃបច្ចេកវិទ្យា និងការរៀននិងបង្រៀននៅក្នុងថ្នាក់រៀន។

សង្គមប្រកបដោយពុទ្ធិ ក៏ជាសង្គមដែលបណ្តុះឱ្យមានរចនាសម្ព័ន្ធទន់នៃសេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិដែរ។ ឧទាហរណ៍ជាក់ស្តែងនៃបែបផែននេះរួមមាន Silicon Valley នៃសហរដ្ឋអាមេរិក សួនឧស្សាហកម្មវិស្វកម្មអាកាសយានយន្តនិងយានយន្តនៅទីក្រុង Munich ប្រទេសអាល្លឺម៉ង់ តំបន់ជីវបច្ចេកវិទ្យានៅក្រុង Hyderabad ប្រទេសឥណ្ឌា តំបន់ផលិតគ្រឿងអេឡិចត្រូនិកនិងសារគមនាគមន៍ឌីជីថលនៅទីក្រុង Seoul ប្រទេសកូរ៉េខាងត្បូង ក៏ដូចជាសួនឧស្សាហកម្មថាមពល និងឥន្ទនគីមីសាស្ត្រនៃប្រទេសប្រេស៊ីល ហើយក៏នៅមានទីក្រុងនៃប្រទេសជាច្រើនទៀតនៅលើពិភពលោក។ លក្ខណៈសម្បត្តិ

នៃទីក្រុងទាំងនេះគឺការប្រើប្រាស់និន្នាការនៃការអភិវឌ្ឍដែលជំរុញ និងតម្រង់ទិសដោយចំណេះដឹង ហើយដែលចំណេះដឹងទាំងនោះកើតចេញជាដំបូងពីការវិនិយោគទៅលើគ្រឹះស្ថានឧត្តមសិក្សា ស្ថាប័នស្រាវជ្រាវ មជ្ឈមណ្ឌលឧត្តមភាពនៃជំនាញជាន់ខ្ពស់ ការប្រកួតប្រជែងដោយគុណាធិបតេយ្យ និងជាពិសេសគឺការបណ្តុះវប្បធម៌អំណាននិងនិពន្ធសៀវភៅ។ ល្បឿននៃការរីកចម្រើនផ្នែកពុទ្ធិ និងបច្ចេកវិទ្យាកំពុងមានសន្ទុះលឿនជាងអ្វីដែលសិស្ស និងនិស្សិតអាចទទួលបានពីគ្រូនៅគ្រឹះស្ថានសិក្សា ដែលធ្វើឱ្យគោលដៅនៃការអប់រំនៅពេលបច្ចុប្បន្ននេះ មានការប្រឈមខ្លាំងជាងពេលណាទាំងអស់។ ឧទាហរណ៍ ក្នុងមួយឆ្នាំមានសៀវភៅជាង២,២លានចំណងជើង ត្រូវបានសរសេរនិងបោះពុម្ព ដែលក្នុងនោះប្រទេសចិនមាន ៤៤០ពាន់ ចំណែកឯសហរដ្ឋអាមេរិកមាន៣០៥ពាន់ និងប្រទេសរុស្ស៊ីមាន១២០ពាន់ចំណងជើង។

ខណៈពេលដែលបច្ចេកវិទ្យាកំពុងរីកចម្រើនជារៀងរាល់ថ្ងៃ មធ្យោបាយសម្រាប់អំណានក៏មានច្រើនជម្រើសសម្រាប់សិស្ស-និស្សិត និងសាធារណៈជន រួមមានការអានសៀវភៅ ការអានលើឧបករណ៍អេឡិចត្រូនិក ការអានដោយប្រើទូរសព្ទវៃឆ្លាត និងការអានលើកុំព្យូទ័រ ដែលសុទ្ធសឹងជាមធ្យោបាយសំខាន់ៗដែលនាំអ្នកអានទាំងឡាយឱ្យសម្រេចគោលបំណងអានរបស់ខ្លួន។ ម្យ៉ាងវិញទៀត អំណានដោយប្រើមធ្យោបាយបច្ចេកវិទ្យាទំនើប ចំណាយពេលតិច ងាយស្រួលអាន និងជួយដល់បរិស្ថានមួយកម្រិតទៀត។ នាពេលបច្ចុប្បន្ន សិស្ស-និស្សិត និងសាធារណៈជនកម្ពុជាដែលស្រឡាញ់អំណានកំពុងតែប្រើប្រាស់មធ្យោបាយអំណានទាំងនេះ។ បើយើងក្រឡេកមើលទៅប្រទេសជឿនលឿន ទោះបីជាបច្ចេកវិទ្យារីកចម្រើនខ្លាំងយ៉ាងណា អំណានតាមរយៈសៀវភៅនៅតែមានសន្ទុះដដែល។ ម្យ៉ាងវិញទៀត បច្ចេកវិទ្យាអានបែបទំនើបតាមរយៈឧបករណ៍ទំនើប អាស្រ័យលើលទ្ធភាពនៃធនធានអប់រំឌីជីថល និងមាតិកាឌីជីថលគ្រប់គ្រាន់ដែលបានផលិត និងបង្ហោះចែកចាយសម្រាប់អំណាន។

ក្នុងបរិបទកម្ពុជា ជាពិសេសក្នុងបរិការណ៍នៃការផ្ទុះរីករាលដាលនៃជំងឺកូវីដ-១៩ ក្រសួងអប់រំ យុវជន និងកីឡា បានជំរុញឱ្យមានបរិវត្តកម្មឌីជីថលនៅក្នុងអេកូស៊ីស្តែមនៃការអប់រំ ជាពិសេសការអប់រំតាមប្រព័ន្ធអេឡិចត្រូនិក និងការអប់រំពីចម្ងាយដើម្បីលើកកម្ពស់អំណាន តាមរយៈការផលិតមាតិកាឌីជីថលដែលមានភាពចម្រុះ ការកសាងសមត្ថភាពផ្នែកតំណភ្ជាប់និងវេទិកាឌីជីថល ការពង្រីកវិសាលភាពនៃមជ្ឈមណ្ឌលទិន្នន័យ និងការលើកកម្ពស់គុណភាពនៃការផលិតធនធានអប់រំឌីជីថល គួបផ្សំជាមួយការចែកសន្លឹកកិច្ចការឱ្យសិស្សយកទៅរៀននៅផ្ទះ និងការចុះទៅជួបជាមួយសិស្សជាបណ្តុំនៅតាមសហគមន៍។ ក្នុងន័យលើកកម្ពស់អំណាន និងភាពសម្បូរបែបនៃធនធានសៀវភៅសិក្សា ឱ្យកាន់តែមានប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធិ និងផ្តល់ឱកាសអំណានកាន់តែច្រើនថែមទៀតដល់សិស្សានុសិស្ស និស្សិត និងសាធារណៈជន ក្រសួងអប់រំ យុវជន និងកីឡាលើកទឹកចិត្តនូវចំណុចមួយចំនួនដូចខាងក្រោម៖

១. សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំ សូមបន្តនិងបង្កើនការបោះពុម្ពស្នាដៃបន្ថែមទៀត ដើម្បីធ្វើឱ្យធនធានសម្រាប់អំណានកាន់តែសម្បូរបែប ជាពិសេសធនធានអំណានជាខេមរភាសា

២. គ្រឹះស្ថានឧត្តមសិក្សា សូមផ្តល់លទ្ធភាពគ្រប់បែបយ៉ាង ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ និងនិស្សិតគ្រប់កម្រិតសិក្សាអាចចូលរួមអាន និងសិក្សាស្រាវជ្រាវតាមគ្រប់លទ្ធភាពជាមួយធនធានអំណាន ជាពិសេសការរៀបចំឱ្យមានពេលវេលាសម្រាប់សហសិក្សា និងអំណានក្នុងបណ្ណាល័យ
៣. សាស្ត្រាចារ្យតាមមុខវិជ្ជា និងអ្នកស្រាវជ្រាវតាមជំនាញឬវិស័យ ត្រូវរៀបចំដំណើរការរៀនបង្រៀន និងស្រាវជ្រាវដែលមានដាក់បញ្ចូលកិច្ចការស្វ័យសិក្សា សហសិក្សា ឬការស្រាវជ្រាវបណ្ណាល័យដែលតម្រូវឱ្យនិស្សិត ត្រូវអាននិងស្រាវជ្រាវជាមួយធនធានអំណាន
៤. គ្រឹះស្ថានឧត្តមសិក្សា និងមជ្ឈមណ្ឌលស្រាវជ្រាវ ត្រូវខិតខំឱ្យអស់លទ្ធភាពក្នុងការបង្កើតបណ្ណាល័យ មជ្ឈមណ្ឌលរក្សាឯកសារ ឬមជ្ឈមណ្ឌលអប់រំឌីជីថលជាដើម ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់និងនិស្សិតគ្រប់កម្រិតសិក្សាអាចទទួលបាន និងស្វែងរកប្រភពសម្រាប់អំណានកាន់តែសម្បូរបែប និងមានភាពបត់បែន ឆ្លើយតបតាមតម្រូវការអ្នកអាន
៥. និស្សិតគ្រប់កម្រិតសិក្សាត្រូវខិតខំនិងចំណាយពេលអាន និងចាត់ទុកវប្បធម៌ និងអកប្បកិរិយាអំណានជាផ្នែកមួយ នៃពេលវេលានិងភាពស៊ីវិល័យនៃជីវិតប្រចាំថ្ងៃ
៦. បងប្អូនជនរួមជាតិ ដែលជាមាតាបិតា ឬអ្នកអាណាព្យាបាល សូមជួយជំរុញនិងបង្កលក្ខណៈកាន់តែច្រើនថែមទៀត ជាពិសេសការលៃលកចំណាយនៅក្នុងគ្រួសារសម្រាប់ការទិញសម្ភារៈសិក្សា សៀវភៅអាន និងឧបករណ៍សម្រាប់អំណានដល់កូនៗ ដែលចាត់ទុកជាការវិនិយោគមួយដ៏សំខាន់ សម្រាប់ បង្កើនចំណេះដឹង និងអនាគតរបស់ពួកគេ។

ដោយមានការគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅឆ្នាំ២០២០ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ដែលហៅកាត់ថា "មូលនិធិ ស.គ.ន." និងហៅជាភាសាអង់គ្លេសថា The Research Creativity and Innovation Fund ដែលហៅកាត់ជាភាសាអង់គ្លេសថា "RCI Fund"។ គោលដៅចម្បងនៃមូលនិធិនេះ គឺរួមចំណែកលើកកម្ពស់វប្បធម៌នៃការស្រាវជ្រាវ បំផុសគំនិតច្នៃប្រឌិត និងជំរុញការធ្វើនវានុវត្ត ដើម្បីជាប្រយោជន៍ដល់វិស័យអប់រំ យុវជន និងកីឡា ដែលឆ្លើយតបទៅនឹងទីផ្សារពលកម្ម និងសាកលភាវូបនីយកម្ម។ មូលនិធិ ស.គ.ន. បានសម្រេចកំណត់ប្រធានបទ ជាអាទិភាពសម្រាប់ការគាំទ្រដោយមូលនិធិចំនួន៣ រួមមានឌីជីថលនីយកម្មសម្រាប់បដិវត្តឧស្សាហកម្ម៤.០ (Digitalization for IR.4.0) ការស្រាវជ្រាវអនុវត្តលើវិស័យកសិកម្ម (Applied Agricultural Research) និងការស្រាវជ្រាវគរុកោសល្យសតវត្សទី២១ (21st Century Pedagogy Research)។

ដោយមានការធ្វើអាទិភាពរូបនីយកម្មទៅលើទិសដៅ នៃការប្រើប្រាស់ថវិកាមូលនិធិសម្រាប់ឆ្នាំ២០២០ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា បានផ្តល់ការគាំទ្រដល់ការ **រៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សា (Text book) ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា។** គោលបំណងនៃការរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា គឺដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រីកសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូនដល់និស្សិត

ដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ លើសពីនេះទៀត ការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា មានគោលដៅដូចខាងក្រោម ៖

- ឆ្លើយតបជាបន្ទាន់ចំពោះការខ្វះខាតធនធានសិក្សា ដែលជាតម្រូវការសិក្សារបស់និស្សិតនៅកម្រិតឧត្តមសិក្សា
- លើកកម្ពស់ទំនើបភាវូបនីយកម្ម និងឧត្តមានុវត្តន៍នៃការរៀននិងបង្រៀន និងការស្រាវជ្រាវនៅលើមុខវិជ្ជា កម្មវិធីសិក្សា ឬមុខជំនាញជាក់លាក់
- បង្កើនភាពស៊ីជម្រៅក្នុងការកសាងវិជ្ជាជីវៈនិងបទពិសោធន៍សម្រាប់ឋានៈសាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវ
- រួមចំណែកដល់ការកសាងភាពជាសហគមន៍វិជ្ជាជីវៈ ការចែករំលែកបទពិសោធន៍ និងវប្បធម៌នៃការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា។

ក្រសួងអប់រំ យុវជន និងកីឡា បានវាយតម្លៃខ្ពស់ចំពោះការបោះជំហានប្រកបដោយមនសិការវិជ្ជាជីវៈនៃគ្រឹះស្ថានឧត្តមសិក្សា និងបុគ្គលិកអប់រំទាំងអស់ ក្នុងការរៀបចំ រៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រឹងសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូននិស្សិតដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ សៀវភៅសិក្សាជាផ្នែកមួយនៃការទទួលស្គាល់គុណភាពអប់រំនៃគ្រឹះស្ថានឧត្តមសិក្សា និងជាធនធានសិក្សាដែលជាមូលដ្ឋានមួយដ៏សំខាន់ ក្នុងការគាំទ្រដល់ការបង្រៀន និងរៀន ហើយត្រូវមានបរិមាណគ្រប់គ្រាន់ ឆ្លើយតបទៅនឹងកម្មវិធីអប់រំ និងតម្រូវការសិក្សាស្រាវជ្រាវ។ ជាគោលការណ៍ គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ ត្រូវមានសៀវភៅសិក្សាដែលប្រើជាគោលសម្រាប់មុខវិជ្ជានីមួយៗ។ ចំនួនសៀវភៅសិក្សាដែលគ្រប់គ្រាន់សម្រាប់ការស្រាវជ្រាវ និងការសិក្សារបស់និស្សិត ត្រូវមានយ៉ាងតិចមួយចំណងជើងក្នុងមួយមុខវិជ្ជា ហើយត្រូវតម្កល់យ៉ាងតិច២ច្បាប់ នៅក្នុងបណ្ណាល័យ ឬអាចរកបានតាមប្រព័ន្ធអេឡិចត្រូនិក។ ក្រសួងអប់រំ យុវជន និងកីឡា លើកទឹកចិត្តបន្ថែមទៀតជូនដល់គ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនដែលបានស្នើសុំថវិកាមូលនិធិរួច សូមចូលរួមបន្ថែមទៀតដើម្បីបង្កើនចំនួនចំណងជើងសៀវភៅ។ ចំណែកគ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនដែលពុំទាន់បានដាក់ពាក្យស្នើសុំសូមចូលរួម ដើម្បីជាគុណប្រយោជន៍ដល់តម្រូវការដ៏ទទូច និងថ្លៃថ្លានៃនិស្សិតកម្ពុជាក្នុងការសិក្សា និងស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។

## សេចក្តីបញ្ជាក់
## នៃមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍

សៀវភៅសិក្សានេះជាលទ្ធផលនៃការស្នើសុំអនុវត្តថវិកាមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ក្នុងគម្រោង**រៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា។** សៀវភៅសិក្សានេះ ត្រូវបានរៀបរៀង និពន្ធ ឬកែលម្អដោយមានការធានាអះអាងថាជាស្នាដៃរបស់អ្នកនិពន្ធផ្ទាល់ និងបានឆ្លងកាត់ត្រួតពិនិត្យ ផ្តល់យោបល់ និងវាយតម្លៃដោយក្រុមប្រឹក្សាអប់រំ ក្រុមប្រឹក្សាស្រាវជ្រាវ ឬក្រុមប្រឹក្សាដែលមានតម្លៃស្មើនៃគ្រឹះស្ថានឧត្តមសិក្សា និងតាមរយៈកិច្ចសន្យាដែលបានធ្វើឡើង និងដែលបានតម្កល់ទុកនៅមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍។ រាល់ខ្លឹមសារ ការបកស្រាយ និងរូបភាព គឺជាជំហរនិងទស្សនៈផ្ទាល់របស់អ្នកនិពន្ធ ហើយពុំឆ្លុះបញ្ចាំង ឬជាតំណាងដល់មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ នៃក្រសួងអប់រំ យុវជន និងកីឡាឡើយ។

# អារម្ភកថា

សៀវភៅនេះត្រូវបានរៀបរៀងឡើងក្រោមការឧបត្ថម្ភគាំទ្ររបស់មូលនិធិស្រាវជ្រាវ គំនិតឆ្នៃប្រឌិត និងនវានុវត្តន៍សម្រាប់ទុកជាសៀវភៅសិក្សាគោលដើម្បីបម្រើឲ្យការរៀន និងបង្រៀនមុខវិជ្ជាប្រវត្តិសាស្ត្រកម្ពុជាក្នុងដេប៉ាតឺម៉ង់ប្រវត្តិវិទ្យានៃមហាវិទ្យាល័យសង្គមសាស្ត្រ-មនុស្សសាស្ត្រនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ សៀវភៅនេះផ្ដល់ជូនអ្នកសិក្សានូវចំណេះដឹងស្ដីអំពីព្រឹត្តិការណ៍នានា ដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា ចាប់តាំងពីសម័យបុរាណរហូតដល់សម័យទំនើប ដែលអាចសមល្មមឲ្យអ្នកសិក្សាប្រវត្តិសាស្ត្រទាំងឡាយមានមូលដ្ឋានគ្រឹះរឹងមាំក្នុងការសិក្សាបន្ត ឬស្រាវជ្រាវបន្ថែម ឬក្នុងការប្រកបការងារផ្សេងៗក្នុងវិជ្ជាជីវៈរបស់ខ្លួន។ មិនតែប៉ុណ្ណោះ សៀវភៅនេះក៏អាចចាត់ទុកជាឯកសារពិគ្រោះសម្រាប់អ្នកស្នេហាប្រវត្តិសាស្ត្រផងដែរ។

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំបាទ វង់ សុជាា៉ និង ណុប សុខា ជាសាស្ត្រាចារ្យដេប៉ាតឺម៉ង់ប្រវត្តិវិទ្យានៃមហាវិទ្យាល័យសង្គមសាស្ត្រ-មនុស្សសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងជាអ្នករៀបរៀងសៀវភៅសិក្សាគោលដែលមានចំណងជើងថា "ប្រវត្តិសាស្ត្រកម្ពុជា"។ ខ្ញុំបាទសូមសម្ដែងនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ និងសូមគោរពថ្លែងអំណរគុណ និងដឹងគុណយ៉ាងជ្រាលជ្រៅចំពោះ៖

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានផ្ដល់ថវិកាមកក្រសួងអប់រំ ដើម្បីបង្កើតជាមូលនិធិសម្រាប់គាំទ្រដល់ការសរសេរសៀវភៅសិក្សាសម្រាប់កម្រិតឧត្តមសិក្សារបស់ខ្ញុំបាទនេះ។

- ក្រសួងអប់រំ យុវជន និងកីឡា ដែលមាន ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី ហង់ជួន ណារ៉ុន ជាប្រមុខ ដែលលោកបានដឹកនាំបង្កើតមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ឡើង ដើម្បីគាំទ្រទាំងស្រុងដល់ដំណើរការសរសេរសៀវភៅនេះ ដែលជាចំណែកមួយក្នុងបេសកកម្មកំណែទម្រង់វិស័យអប់រំឧត្តមសិក្សារបស់លោក។

- ឯកឧត្តមបណ្ឌិត សាន វឌ្ឍនា អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ដែលក្នុងនាមលោកជាតំណាងមូលនិធិ លោកបានយកអស់កម្លាំងកាយចិត្ត ជួយចាត់ចែងនិងជ្រោមជ្រែងយ៉ាងពេញទំហឹង ព្រមទាំងផ្ដល់ជាអនុសាសន៍និងដំណោះស្រាយនានា ដើម្បីជំនះនូវរាល់ឧបសគ្គដែលកើតមានក្នុងដំណើរការសរសេរសៀវភៅនេះ។

- ឯកឧត្តមបណ្ឌិត ជេត ជាលី សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដែលបានយកអស់កម្លាំងកាយចិត្ត ព្រមទាំងពេលវេលាដ៏មមាញឹកនិងមានតម្លៃរបស់លោកក្នុងការជួយលើកទឹកចិត្ត ជួយខ្នះខ្នែងដោះស្រាយ និងផ្ដល់អនុសាសន៍ដ៏ត្រឹមត្រូវ ក៏ដូចជាបង្កលក្ខណៈងាយស្រួលនានា ទាំងផ្នែករដ្ឋបាល និងទាំងផ្នែកបច្ចេកទេស ដើម្បីឲ្យដំណើរការរៀបរៀងសៀវភៅនេះបានប្រព្រឹត្តទៅដោយរលូនរហូតចប់ចុងចប់ដើម។

- លោក លួន ពេជ្របូរី និង អស់លោក-លោកស្រី ជាក្រុមការងារសម្របសម្រួលទាំងអស់របស់មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ដែលបានយកអស់កម្លាំងកាយចិត្ត ជួយឈឺឆ្អាលក្នុងការដោះស្រាយបញ្ហាប្រឈមនានាយ៉ាងសស្រាក់សស្រាំជាទីបំផុត ដោយមិនត្អូញត្អែរ និងមិនខ្លាចនឿយហត់ ដើម្បីឲ្យការសរសេរសៀវភៅនេះប្រព្រឹត្តទៅដោយរលូន។

- ឯកឧត្តមបណ្ឌិត ស្រ៊ីវ ថារិទ្ធ អ្នកសម្របសម្រួលសាលាក្រោយឧត្តម និង លោកបណ្ឌិត សុខ សិរី អនុប្រធានការិយាល័យស្រាវជ្រាវ ដែលតែងជួយឈឺឆ្អាល ជួយសម្របសម្រួល និងផ្ដល់សេវាសម្រាប់ការប្រជុំបច្ចេកទេសនានាតាមអនឡាញតាំងពីដើមរៀងមក។

- អស់លោក-លោកស្រី ជាសមាជិក-សមាជិកាគណៈកម្មការអភិវឌ្ឍសៀវភៅសិក្សា ក៏ដូចជាគណៈកម្មការត្រួតពិនិត្យសៀវភៅសិក្សារបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដែលបានជួយផ្ដល់ធាតុចូលដល់សៀវភៅនេះឲ្យកាន់តែមានគុណភាពប្រសើរថែមទៀត។

- ជាចុងក្រោយ និងជាពិសេស លោក ធូ វណ្ណេ ប្រធានការិយាល័យស្រាវជ្រាវនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដែលតែងជួយផ្ដល់ធាតុចូលចំពោះរាល់ឯកសារការងារ ទាំងផ្នែករដ្ឋបាលនិងទាំងផ្នែកបច្ចេកទេស លោកថែមទាំងជួយសម្រួលរាល់បញ្ហាប្រឈមនានាយ៉ាងដឹតដល់បំផុត ដោយមិនប្រកាន់ពេលវេលា និងដោយចិត្តជ្រះថ្លា រហូតការសរសេរសៀវភៅនេះទទួលបានជោគជ័យជាស្ថាពរ។

# មាតិកា


បុព្វកថា ........ i
សេចក្តីបញ្ជាក់ ........ vi
អារម្ភកថា ........ vii
សេចក្តីថ្លែងអំណរគុណ ........ viii
**មេរៀនទី 1 សេចក្តីផ្តើមប្រវត្តិសាស្ត្រខ្មែរ** ........ 1
1. សេចក្តីផ្តើម ........ 1
1.1. និយមន័យប្រវត្តិវិទ្យា ........ 1
1.2. តួនាទី និងសារៈសំខាន់នៃប្រវត្តិវិទ្យា ........ 3
1.3. ផលប៉ះពាល់នៃប្រវត្តិវិទ្យា ........ 9
**មេរៀនទី 2 បុរេប្រវត្តិសាស្ត្រខ្មែរ** ........ 10
1. វប្បធម៌សម័យបុរេប្រវត្តិសាស្ត្រខ្មែរ ........ 10
1.1. ស្ថានីយបុរេប្រវត្តិសាស្ត្រ ........ 10
1.2. ឧបករណ៍ប្រើប្រាស់ ........ 11
1.3. ជំនឿ ........ 12
1.4. ជីវភាពមនុស្សខ្មែរ ........ 13
1.5. ការវិវឌ្ឍន៍នៃផ្នត់គំនិត ........ 13
សេចក្តីសន្និដ្ឋាន ........ 14
**មេរៀនទី 3 ហ្វូណាន-ចេនឡា និងការបែកបាក់** ........ 15
1. ហ្វូណាន 富南 ........ 15
1.1. ទីតាំង ........ 15
1.2. រាជធានី ........ 16
1.3. អំពីពាក្យ ហ្វូណាន 扶南 ........ 18
2. ចេនឡា 真腊 ........ 19
3. សេដ្ឋកិច្ច និងនយោបាយ ........ 21
3.1. ការបង្កើតរដ្ឋ ........ 21
3.2. សេដ្ឋកិច្ច ........ 22
3.3. នយោបាយ ........ 23
4. ឥទ្ធិពលវប្បធម៌ឥណ្ឌា ........ 24
5. ប្រពៃណីទំនៀមទម្លាប់នគរភ្នំ-ចេនឡា និងការវិវត្តន៍ ........ 28
5.1. ការទុកដាក់សព ........ 28
5.2. ប្រពៃណីទំនៀមទម្លាប់ ........ 28
5.3. សីលធម៌-យុត្តិធម៌ ........ 29
6. សាសនា និងកសាងប្រាសាទ ........ 30
7. ការបែកបាក់នៅសតវត្សរ៍ទី៨ ........ 31

7.1. ចេនឡាដីគោក និងចេនឡាទឹកលិច ....................................................................................32
7.2. ព្រះមហារាជិនី ជយទេវី.....................................................................................................32
7.3. ផ្ទាលុកលុយចេនឡា មែនទេ?...............................................................................................33
**មេរៀនទី 4  សម័យអង្គរ ៖ ការកសាងអារ្យធម៌**.................................................................37
1. សេចក្ដីផ្ដើម ........................................................................................................................37
2. ព្រះបាទជយវម៌្មទី២ ក្នុងយុទ្ធនាការស្ដារប្រទេស ...................................................................38
3. នយោបាយផ្សះផ្សារជាតិ .....................................................................................................39
4. ធម្មភាពទេវរាជ ឬ លទ្ធិទេវរាជ..............................................................................................40
5. ស្ថាប័នរាជាភិសេក...............................................................................................................42
6. ស្ថាប័ននយោបាយកំពូល និងអង្គការរដ្ឋបាល .........................................................................43
6.1. ព្រះមហាក្សត្រ.....................................................................................................................43
6.2. ព្រះអគ្គមហេសី ...................................................................................................................46
6.3. រជ្ជទាយាទ ( យុវរាជ )..........................................................................................................46
6.4. ព្រះរាជបុត្រ និងរាជវង្សានុវង្ស .............................................................................................47
6.5. រដ្ឋាភិបាល និងប្រភេទរដ្ឋមន្ត្រី..............................................................................................47
6.6. មន្ត្រីជាទីប្រឹក្សា និងជំនួយកិច្ចការរដ្ឋ.......................................................................................49
6.7. ឋានន្តរស័ក្ដិមន្ត្រីរាជការ......................................................................................................53
7. រាជធានីយសោធរបុរៈ (ក្រុងអង្គរទី១-៣)...............................................................................54
8. ការលើករាជធានីទៅកោះកេរ្ដិ៍ (ឆោកគរគីរ).........................................................................55
9. ការកសាងប្រាសាទ និងបារាយណ៍ .......................................................................................55
10. បណ្ដាញគមនាគមន៍, សង្គមកិច្ច, អប់រំ ................................................................................56
11. បទប្បញ្ញត្តិខ្លះ និង សញ្ញាណទស្សនវិជ្ជាខ្មែរសម័យអង្គរ .........................................................59
12. ការប្រជែងខាងសាសនា និងការផ្លាស់ប្ដូរ ..............................................................................61
13. សង្គ្រាមវាតទឹកដី និងសង្គ្រាមជាមួយប្រទេសជិតខាង .............................................................62
13.1. សង្គ្រាមជាមួយចាម្ប ........................................................................................................62
13.2. សង្គ្រាមក្នុងស្រុករវាងខ្មែរនឹងខ្មែរ.........................................................................................65
13.3. សង្គ្រាមជាមួយសៀម ឬអយុធ្យា............................................................................................66
សេចក្ដីសន្និដ្ឋាន ....................................................................................................................68
**មេរៀនទី 5  ការលើករាជធានីមកតាំងនៅចតុមុខ** ...............................................................69
1. ទីបញ្ចប់សម័យអង្គរ..............................................................................................................69
2. ការធ្លាក់ចុះ និងការបោះបង់ចោលទីក្រុងអង្គរ .........................................................................70
3. ការតាំងទីក្រុងនៅទួលបាសាន-ការផ្លាស់រាជធានីទៅចតុមុខ.......................................................73
4. ជម្លោះផ្ទៃក្នុង ដើម្បីរាជសម្បត្តិ(២លើក) .................................................................................77
5. អន្តរាគមន៍របស់សៀមលើកដំបូង .........................................................................................79
6. ប្រភពឯកសារសហសម័យ.......................................................................................................79

**មេរៀនទី 6 សម័យលង្វែក និងការពង្រឹងអានុភាពជាតិឡើងវិញ**......81
1. ការកសាងបន្ទាយលង្វែក......81
2. ការកសាងឯកសារ ក្បួនខ្នាត ច្បាប់រដ្ឋ......82
3. ការកសាង និងការពង្រស់ទេវស្ថានបង្ការសត្រូវ និងវត្តអារាម......84
4. ទំនាក់ទំនងជាមួយជនជាតិអឺរ៉ុប......86
5. សង្គ្រាមជាមួយសៀម និងឡាវ......87
6. សន្ធិសញ្ញាមិត្តភាពជាមួយសៀម លើកដំបូង......89
7. ការបែកបាក់សាមគ្គីភាព ជាហេតុនៃការដួលរលំ......92
**មេរៀនទី 7 សម័យឧដុង្គ និងឥទ្ធិពលរបស់សៀម-យួនមកលើកម្ពុជា**......93
1. វិបត្តិរាជវង្សានុវង្ស......93
2. វប្បធម៌ពឹងប្រទេសជិតខាង ដើម្បីអំណាច......94
3. ការញុះញង់បំបែកបំបាក់ពីប្រទេសជិតខាង......98
4. អនិស្សរភាពរបស់ព្រះមហាក្សត្រ......100
4.1. ការលូកដៃរបស់ព័រទុយហ្គេក្នុងទំនាស់រាជវង្សខ្មែរ......103
4.2. ការគាបសង្កត់ និងបាត់បង់ទឹកដីដោយសន្សឹមៗ......104
4.3. ខេត្តខ្មែរដែលបាត់ទៅយួន និងសៀម......105
**មេរៀនទី 8 អារ្យធម៌ខ្មែរសម័យកណ្តាល**......109
1. កម្រងច្បាប់សម្រាប់គ្រប់គ្រងរដ្ឋដ៏ល្អ......109
2. ចំណេះដឹងខាងទ្រឹស្តីគ្រប់គ្រងរដ្ឋបែបឥណ្ឌា......113
3. ភារកិច្ចរបស់ព្រះរាជា......114
4. ភារកិច្ចអាមាត្យ-មន្ត្រី......117
5. វប្បធម៌ដែលផ្អែកលើព្រះពុទ្ធសាសនា......117
6. តើពុទ្ធសាសនាចូលមកកម្ពុជាតាមរបៀបណា?......121
7. រចនាសម្ព័ន្ធ និងច្បាប់ព្រះសង្ឃ......124
8. ការកសាងវប្បធម៌សន្តិភាព ៖ ការខិតខំបង្កើតឯកភាពជាតិឡើងវិញ......127
9. ស្នាដៃអក្សរសិល្ប៍ សាស្ត្រាល្បែង......128
10. ការបាត់បង់ធនធានមនុស្ស(ពលរដ្ឋ និងអ្នកចេះដឹង)......130
**មេរៀនទី 9 សម័យអាណានិគមបារាំង៖ នយោបាយបញ្ចៀសគ្រោះបាត់បង់ទឹកដី**......132
1. គំនិតផ្តួចផ្តើមទាក់ទងជាមួយបារាំង ដោយព្រះអង្គដួង......134
2. សន្ធិសញ្ញាអាណាព្យាបាល (១១សីហា១៨៦៣)......139
3. ដំណើរពីអាណាព្យាបាល ទៅជាអាណានិគម និងការបាត់បង់អំណាចរបស់ព្រះរាជាខ្មែរ......141
4. ការបះបោរ និងបាតុកម្មប្រឆាំងបារាំង......144
5. ការកាត់ទោសបាតុករខ្មែរ......146
6. ការជ្រើសរើសស្តេចឡើងសោយរាជ្យ......147
7. ការលុកលុយរបស់ជប៉ុន និងឯករាជ្យខ្មែរឆ្នាំ១៩៤៥......151

8. ម៉ូឌុសវីវ៉ង់ឌី និងឯករាជ្យខ្មែរ១៩៤៩ ....153
**មេរៀនទី 10 អភិក្រមទំនើបកម្មរបស់បារាំងនៅកម្ពុជា និងផលវិបាក** ....156
1. អភិក្រមទំនើបកម្ម ....156
1.1. កំណែទម្រង់រចនាសម្ព័ន្ធរដ្ឋបាល....156
1.2. នយោបាយសារពើពន្ធ ....159
1.3. ការអប់រំ....164
1.4. គមនាគមន៍....168
1.5. សង្គមកិច្ច និងសុខាភិបាល....168
1.6. គណបក្សនយោបាយ....169
1.7. រដ្ឋធម្មនុញ្ញដំបូងរបស់កម្ពុជា....171
2. វិបាកនៃទំនើបនីយកម្ម....172
2.1. ការនាំយួនចូលស្រុកខ្មែរ....172
2.2. ការចូលស្រុកខ្មែររបស់ពួកចិន....176
2.3. សេដ្ឋកិច្ច ....181
2.4. វប្បធម៌....182
សេចក្តីសន្និដ្ឋាន ....182
**មេរៀនទី 11 បញ្ហានយោបាយ និងសេដ្ឋកិច្ចសម័យសង្គមរាស្ត្រនិយម**....184
1. ការតស៊ូដើម្បីឯករាជ្យ....184
2. សន្និសីទហ្សឺណែវ ឆ្នាំ១៩៥៤ ....184
3. នយោបាយក្នុង និងក្រៅប្រទេស ....187
4. រឿងក្តីប្រាសាទព្រះវិហារ ....187
5. ជំនួយសហរដ្ឋអាមេរិក និងវិស័យសុខាភិបាល ....193
6. ការបះបោររបស់កសិករ និងការជ្រៀតចូលរបស់វៀតកុង ....198
7. វិបត្តិនយោបាយ និងសេដ្ឋកិច្ចជាតិចុងទសវត្សរ៍១៩៦០ ....200
**មេរៀនទី 12 របបសាធារណរដ្ឋខ្មែរ** ....203
1. ការទម្លាក់សម្តេច នរោត្តម សីហនុ....203
2. សង្គ្រាម និងការទម្លាក់គ្រាប់បែករបស់អាមេរិក....204
3. អំពើពុករលួយ ....205
4. រដ្ឋាភិបាលសាធារណរដ្ឋខ្មែរ....207
5. ថ្ងៃចុងក្រោយ នៃរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ....208
**មេរៀនទី 13 លទ្ធិកុំម្មុយនីស្ត ៖ របបកម្ពុជាប្រជាធិបតេយ្យ**....210
1. ការជម្លៀសប្រជាជន....211
2. រចនាសម្ព័ន្ធរដ្ឋាភិបាល ឬ អង្គការ....214
3. សហករណ៍ប្រមូលផ្តុំ....218
4. ការបែងចែកប្រភេទប្រជាពលរដ្ឋ ....220

5. ការសម្លាប់មនុស្ស ........................ 223
6. វិស័យសុខាភិបាល ........................ 230
**មេរៀនទី 14 លទ្ធិសង្គមនិយម៖ របបសាធារណរដ្ឋប្រជាមានិតកម្ពុជា** ........................ 231
1. រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ........................ 231
2. រដ្ឋាភិបាល និងរចនាសម្ព័ន្ធ ........................ 231
3. ជំនាញការវៀតណាម ........................ 232
4. សេដ្ឋកិច្ចសង្គមនិយម ........................ 232
5. ក-៥ ........................ 234
6. ការអប់រំ ........................ 235
7. ជំនួយបរទេស ........................ 235
8. ចលនាតស៊ូនៅតាមព្រំដែនខ្មែរ-ថៃ ........................ 236
9. ការដកថយរបស់កងទ័ពវៀតណាម ........................ 238
**មេរៀនទី 15 កិច្ចដំណើរការសន្តិភាព** ........................ 241
1. បរិការណ៍ពិភពលោកនៅចុងទសវត្សរ៍ឆ្នាំ១៩៨០ ........................ 241
2. រដ្ឋកម្ពុជា និងដំណើរការចរចាសន្តិភាព ........................ 241
3. ការអនុវត្តន៍កិច្ចព្រមព្រៀងសន្តិភាព ........................ 244
4. ការបង្កើតរដ្ឋាភិបាលចម្រុះក្រោយការបោះឆ្នោតឆ្នាំ១៩៩៣ ........................ 248
ផ្នែកឧបសម្ព័ន្ធ ........................ 251
កំណត់សម្គាល់ និងការប្រើប្រាស់នាមព្រះមហាក្សត្រខ្មែរនាសម័យបុរាណ តាមរយៈសិលាចារឹក ........................ 251
1. អំពីពាក្យ “វម៌្ម” varmma និង “វម៌្ម ទេវ” varmmadeva ........................ 251
1.1. ពាក្យ "វម៌្ម" varmma ........................ 251
1.2. ពាក្យ "វម៌្មទេវ" varmmadeva ........................ 253
1.3. នាមព្រះមហាក្សត្រហ្វូណាន ........................ 255
1.4. នាមព្រះមហាក្សត្រចេនឡា សម័យហ្វូណាន ........................ 256
1.5. នាមព្រះមហាក្សត្រសម័យចេនឡា ........................ 256
1.6. នាមព្រះមហាក្សត្រចេនឡាទឹកលិច ........................ 257
1.7. នាមព្រះមហាក្សត្រចេនឡាដីគោក ........................ 257
សេចក្តីសន្និដ្ឋាន ........................ 260
នាមព្រះមហាក្សត្រសម័យអង្គរ និងស្នាព្រះហស្ត ........................ 262
នាមព្រះមហាក្សត្រចុងសម័យអង្គរ តាមពង្សាវតារសតវត្សរ៍ទី១៩ ........................ 270
ព្រះមហាក្សត្រខ្មែរសម័យកណ្តាល និងអាណាព្យាបាល ........................ 272
ឯកសារពិគ្រោះដម្រើស ........................ 275

# មេរៀនទី 1 សេចក្តីផ្តើមប្រវត្តិសាស្ត្រខ្មែរ

## 1. សេចក្តីផ្តើម

តាំងពីសាខាចំណេះដឹងផ្នែក«ប្រវត្តិវិទ្យា/ប្រវត្តិសាស្ត្រ»នេះចាប់កំណើតឡើងដោយលោក ហេរ៉ូដូធីស Herodotus ជាអ្នកប្រាជ្ញជាតិក្រិកបុរាណនៅឆ្នាំ៤៣០មុនគ.ស.មក[1] អ្នកប្រាជ្ញជំនាញផ្នែកនេះបានប្រើវិធីផ្សេងៗគ្នាក្នុងការសរសេររឿងរ៉ាវប្រវត្តិសាស្ត្រ ដោយឆ្លុះបញ្ចាំងតាមគោលការណ៍ ឬទ្រឹស្តីខុសៗគ្នា ដែលជាហេតុនាំឲ្យមានអ្នកឲ្យនិយមន័យ ឬទ្រឹស្តីរបស់វាខុសៗពីគ្នាដែរ។ អញ្ចឹងហើយ បានជាទ្រឹស្តី ឬនិយមន័យនៃមុខវិជ្ជានេះ តែងតែមានការប្រែប្រួលខុសគ្នាជានិច្ចតាំងពីសតវត្សរ៍ទី៣មុនគ.ស.មក សូម្បីសៀវភៅចំណងជើងតែងមួយ គ្រាន់តែបោះពុម្ពផ្សាយមុនក្រោយគ្នាលេចពី៥០។ ហើយមុខវិជ្ជានេះ កាន់តែមានលក្ខណៈវិទ្យាសាស្ត្រ ឈរជើងយ៉ាងរឹងមាំនៅក្នុងជំនាញនៅកម្រិតសាកលវិទ្យាល័យ ចាប់ពីសតវត្សរ៍ទី១៨ រហូតមក។

### 1.1. និយមន័យប្រវត្តិវិទ្យា[2]

ប្រវត្តិវិទ្យាមាននិយមន័យច្រើន និងទ្រឹស្តីច្រើនប្លែកៗពីគ្នាបន្តិច ស្របទៅតាមគំនិតអភិវឌ្ឍន៍ក្នុងដំណាក់កាលនីមួយៗ,ការពិនិត្យសង្កេត និងមូលដ្ឋាននិន្នាការរបស់អ្នកប្រាជ្ញម្នាក់ៗ។ ជាឧទាហរណ៍នៅក្នុងវចនានុក្រមរបស់លោក *Noah Webster* តែមួយ គ្រាន់តែបោះពុម្ពនៅពេលផ្សេងគ្នា ក៏គេអាចឃើញបានថាខ្លឹមសារនិយមន័យរបស់វាត្រូវបានគេកែសម្រួល និងបន្ថែមជាច្រើនចំណុច ដូចជានៅឆ្នាំ១៨២៨ គាត់បានឱ្យនិយមន័យ "ប្រវត្តិសាស្ត្រថាជារឿងសច្ចភាពស្របតាមប្រជាជាតិ ឬរដ្ឋនានា, ជាការពិពណ៌នានូវព្រឹត្តិការណ៍តាមលំដាប់ ដែលវាបានកើតឡើង ដោយបញ្ជាក់ពីហេតុនិងផល។ ប្រវត្តិសាស្ត្រខុសពីទិន្នានុប្បវត្តិ(កំណត់ហេតុ)។ ទិន្នានុប្បវត្តិ ជាធម្មតាទាក់ទងនឹងការពិត និងព្រឹត្តិការណ៍ក្នុងឆ្នាំនីមួយៗដោយគ្មានការសង្កេតរបស់អ្នកកត់ត្រា នៅក្នុងលំដាប់កាលប្បវត្តិដោយផ្ទាល់។[3] តែមកដល់ឆ្នាំ១៩១៣ គេបានកែប្រែសម្រួលថា «ប្រវត្តិសាស្ត្រ ជាប្រព័ន្ធមួយដែលគេសរសេរពីរឿងរ៉ាវនៃព្រឹត្តិការណ៍ជាពិសេស ហើយដែលមានឥទ្ធិពលលើប្រជាជាតិមួយ, ស្ថាប័នមួយ, ស្សង់ ឬ សិល្បៈ និងជាធម្មតាត្រូវភ្ជាប់ទៅតាមការពន្យល់តាមបែបទស្សនវិជ្ជានៃហេតុទាំងឡាយរបស់វា, វាជារឿងពិតមួយ ក្នុងលក្ខណៈខុសពីប្រលោមលោក និងទិន្នានុប្បវត្តិផងដែរ ដែលទាក់ទងយ៉ាងសាមញ្ញជាមួយការពិត និងព្រឹត្តិការណ៍ទាំងឡាយក្នុងឆ្នាំនីមួយៗនៅក្នុងលំដាប់កាលប្បវត្តិយ៉ាងត្រឹមត្រូវ ខុសពីជីវប្រវត្តិដែលកត់ត្រាពីជីវិតរបស់បុគ្គលម្នាក់ និងខុសពីសារណាប្រវត្តិសាស្ត្រដែលតាក់តែងចេញពីបទពិសោធន៍, ការសង្កេត និងកំណត់ត្រាការចងចាំផ្ទាល់ខ្លួន»។[4]

តាមទ្រឹស្តីរបស់កាល់ម៉ាក្ស ប្រវត្តិសាស្ត្រនៃរបត់សង្គមដែលកើតមានតាំងពីដើមរហូតមក គឺជាប្រវត្តិសាស្ត្រនៃការតស៊ូវណ្ណៈ។ ជាការក្រោកឈរឡើងប្រឆាំងគ្នាទៅវិញទៅមក រវាងមនុស្សមានសេរីភាព និងខ្ញុំកញ្ជះគេ, អភិជន

---

[1] Herodotus (1987). *The History*, translated by David Gren. University of Chicago Press. ISBN 0-226-32770-1. pp. 37-38; and Arnold, John H. (2000). *History: A Very Short Introduction*. Oxford University Press. 17. ISBN 0-19-285352-fX.

[2] អត្ថបទនេះ យើងបានធ្វើតាមគំនិតរបស់បណ្ឌិតសភាចារ្យ ស៊ន សំណាង(២០០៥) ជាប្រធានរាជបណ្ឌិតសភាកម្ពុជា។

[3] The definition of history according to Noah Webster ...*www.christianparents.com/histdef.htm*

[4] HISTORY - Meaning and Definition of the Word - *www.hyperdictionary.com/dictionary/history*

និងជនសាមញ្ញ, ម្ចាស់ និងកសិករជាអ្នកបម្រើ, ថៅកែ និងកម្មករជំនាញ, បើនិយាយដោយខ្លី គឺអ្នកជិះជាន់គេ និងអ្នកត្រូវគេជិះជាន់។

> The history of all hitherto existing society is the history of class struggles. Freeman and slave, patrician and plebeian, lord and serf, guild-master and journeyman, in a word, oppressor and oppressed, stood in constant opposition to one another…[5]

អ្នកប្រាជ្ញអាល្លឺម៉ង់ ពាក់កណ្តាលសតវត្សរ៍ទី១៩ថា៖ ប្រវត្តិវិទ្យាជាការសិក្សាអំពីរឿងរ៉ាវពិតបទពិសោធន៍របស់មនុស្ស ជាការសិក្សាពីព្រឹត្តិការណ៍ និងសកម្មភាពទាំងឡាយរបស់មនុស្ស ជាមួយការពន្យល់នូវហេតុ និងផលនៃរឿងរ៉ាវទាំងឡាយ ដោយមិនធ្វើការកាត់សេចក្តីលើតួអង្គប្រវត្តិសាស្ត្រទាំងនោះឡើយ។

កាលពីដើមការបង្រៀនប្រវត្តិសាស្ត្រ គេសង្កត់ធ្ងន់តែទៅលើការពិត នៃប្រវត្តិសាស្ត្រនយោបាយ បែបដូចជាសង្គ្រាម និងរបាក្សត្រ។ ចំណែកការអប់រំប្រវត្តិវិទ្យានៅសហសម័យ គេបានសន្មតយកវិធីសាស្ត្រសមាហរណកាន់តែទូលំទូលាយជាងមុន ដើម្បីផ្តល់ឱ្យនិស្សិតនូវទស្សនៈដ៏ទូលំទូលាយមួយនៃចំណេះដឹងប្រវត្តិសាស្ត្រ ដែលរួមមានទិដ្ឋភាពខាងភូមិសាស្ត្រ,សាសនា,នរវិទ្យា,ទស្សនវិជ្ជា, សេដ្ឋកិច្ច, បច្ចេកវិទ្យា,សិល្បៈ និងសង្គមវិទ្យា។ ប៉ុន្តែ នៅក្នុងរង្វង់ស្បង់ដ៏ទូលំទូលាយនេះ ឆ្លុះបញ្ចាំងពីប្រវត្តិវិទ្យានៅក្នុងភាពស្រពិចស្រពិល ។ ដូច្នេះហើយ ទើបវាត្រូវគេបញ្ចូលនៅក្នុងបច្ចេកពាក្យកាន់តែទូលំទូលាយមួយទៀត គឺ "ការសិក្សាសង្គម"។[6]

ទោះជាយ៉ាងណាក្តី ក៏មុខវិជ្ជាប្រវត្តិវិទ្យា អាចឱ្យយើងយល់បានថា ជាការសិក្សាមួយបែបផ្អែកលើមូលដ្ឋានវិទ្យាសាស្ត្រក្នុងការស្រាវជ្រាវ វិភាគ និងសរសេរ ដោយអនុវត្តន៍តាមបទដ្ឋានមួយឯករាជ្យ ដែលយើងអាចសង្ខេបឱ្យខ្លីបានថា ៖ ក្នុងន័យងាយចងចាំ គេអាចនិយាយម្យ៉ាងទៀតថា "ប្រវត្តិសាស្ត្រ ជាការសិក្សាអំពីរឿងរ៉ាវបទពិសោធន៍របស់មនុស្ស ឬអតីតកាលរបស់មនុស្ស ឬ អំពីពត៌មានពីអតីត ដោយពឹងផ្អែកលើប្រភពឯកសារសរសេរ។" ដោយលើកលែងតែប្រវត្តិសាស្ត្រសហសម័យ ដែលវិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ អាចឱ្យគេធ្វើការសម្អាសជាមួយសាក្សីនៃព្រឹត្តិការណ៍បាន។

---

[5] Karl Marx and Friedrich Engels, *Selected Works in Three Volumes* (Moscow: Progress Publishers, 1983), I, pp. 108–9.

[6] Learning and thinking - World **History**/Geography- *www.studentsfriend.com/onhist/learning.html*


Herodotus (c. 484 BC – c. 425 BC), often considered the "father of history"


Fragment from the Histories VIII on Papyrus Oxyrhynchus 2099, early 2nd century AD



### 1.2. តួនាទី និងសារៈសំខាន់នៃប្រវត្តិវិទ្យា

ប្រវត្តិសាស្ត្រ ជាអត្តសញ្ញាណជាតិមួយដ៏សំខាន់របស់ប្រទេសនីមួយៗ។ ដោយសារ វាជាសំណេរស្តីពីវីរភាព និងអនុស្សាវរីយ៍រួមរបស់ប្រជាជាតិមួយដែលគ្មានប្រជាជាតិ ឬប្រទេសដទៃណាមានដូចៗ។ គ្មានប្រទេសណាមួយមិនយកចិត្តទុកដាក់ចងក្រង និងបង្ហាញដោយមោទនភាពនូវប្រវត្តិរបស់ខ្លួនឡើយ ជាពិសេស ចាប់ផ្តើមតាំងពីប្រវត្តិដើមកំណើតរៀងមក និងដំណើរអភិវឌ្ឍន៍របស់វា។ វាអាចក្លាយជានិមិត្តរូបបង្កើតជាការរួបរួមគ្នារបស់មនុស្សនៃ

ប្រទេស។ ដូច្នេះក្នុងនាមជាពលរដ្ឋ ពួកគេគ្រប់រូបត្រូវតែចេះ ដឹង និងស្គាល់ដំណើររឿងនៃប្រវត្តិសាស្ត្ររបស់ខ្លួនយ៉ាងហោចណាស់ ដើម្បីចៀសវាងនូវការប្រព្រឹត្តិជាន់ដានកំហុសច្រំដែលៗនៃអតីតកាលដែរ។[7]

ចំណែកការសិក្សានៅសាកលវិទ្យាល័យ និងការសិក្សាស្រាវជ្រាវជាន់ខ្ពស់វិញ វាគឺជាមុខវិជ្ជាសំខាន់មួយក្នុងចំណោមមុខវិជ្ជាសំខាន់ជាងគេចំនួនប្រាំ។ ព្រោះ ថាប្រវត្តិវិទ្យាជាយានសម្រាប់ធ្វើការស្វែងយល់អំពីពិភពមនុស្ស, វិទ្យាសាស្ត្រជាយានសម្រាប់ស្វែងយល់រូបរាងពិភពលោក, គណិតវិទ្យាស្វែងយល់ពិភពលោកខាងបរិមាណ, ភាសាជាយានសម្រាប់ធ្វើទំនាក់ទំនងគ្នាក្នុងពិភពលោក និងសិល្បៈជាយានសម្រាប់បញ្ចេញនូវអ្វីដែលជាការបង្កើតឡើងរបស់មនុស្ស។ លើសពីនេះទៀត គេបានចាត់ទុកមុខវិជ្ជាប្រវត្តិវិទ្យាថា មានសារៈសំខាន់ជាងគេ នាំមុខគេក្នុងចំណោមមុខវិជ្ជាទាំងប្រាំ។

"ប្រវត្តិវិទ្យា គឺជាវិជ្ជាល្អឥតខ្ចោះទាំងព្រម ដោយវាធ្វើឱ្យអ្នកប្រវត្តិសាស្ត្រមានភាពឈ្លាសវៃ ហើយគេបានទទួលរង្វាន់នោះ តាមរយៈភ្នែក និងព្រលឹង" បើតាមសំដីលោក កាលីឡេ។

ចំណេះដឹងប្រវត្តិសាស្ត្រមិនត្រឹមតែ"ធ្វើឱ្យយើងឆ្លាតនៅពេលអនាគតនោះទេ តែវាធ្វើឱ្យយើងឆ្លាតគ្រប់វេលា" បើតាមលោក Burckhardt ដែលជាអ្នកប្រវត្តិសាស្ត្រដ៏ល្បីម្នាក់បានអះអាង។ ដូច្នេះការរៀនប្រវត្តិសាស្ត្រធ្វើឱ្យមនុស្សមានគតិបណ្ឌិត សម្រាប់ត្រិះរិះពិចារណាគ្រប់ពេលវេលា។[8]

អ្នកនិពន្ធខ្សែភាពយន្តរឿង A Little Nonya នៃក្រុមហ៊ុន Media Corp (មេឌៀខប)របស់សិង្ហបុរីអះអាងថា "មនុស្សដែលមិនស្គាល់ប្រវត្តិរបស់ដូនតាខ្លួន ប្រៀបដូចជាស្លឹកឈើមួយសន្លឹក ដែលមិនដឹងថាខ្លួនកំពុងនៅលើដើមណាមួយ។" ទោះជាបណ្តាប្រទេសអភិវឌ្ឍន៍ក៏ដោយ ក៏គេនៅតែយកចិត្តទុកដាក់ចាត់ទុកប្រវត្តិវិទ្យា ជាមុខវិជ្ជាសិក្សាឯករាជ្យដ៏សំខាន់មួយ។ ព្រោះថា ការអភិវឌ្ឍន៍ប្រទេសមួយប្រកបដោយនិរន្តរភាព និងចីរភាព មិនអាចកាត់ផ្តាច់បានពីមេរៀនបទពិសោធន៍អតីតកាលបានឡើយ។

លោក រីឆាតហ្វុន វ៉េយសេកឃ័រ (*Richard Won Weisacker*) ប្រធានាធិបតីអាល្លឺម៉ង់ បានថ្លែងសុន្ទរកថានៅសភាអាល្លឺម៉ង់កាលពីថ្ងៃទី០៨ ខែឧសភា១៩៨៥ "សមូហភាពគ្មានពិរុទ្ធភាពអ្វីទាំងអស់ គឺបុគ្គលទេជាពិរុទ្ធជនឬជាជនគ្មានទោសពៃរ៍។ យើងត្រូវទទួលស្គាល់អតីតកាល ទោះបីកាលនោះ យើងនៅបឋមវ័យក្តី ហើយទោះបីជាយើងមានឈ្មោះ ឬគ្មានឈ្មោះជាពិរុទ្ធជនក្តី។ យើងបានរស់នៅជាមួយផលវិបាកនៃអតីតកាល ដែលយើងទទួលខុសត្រូវទាំងស្រុង។ យើងត្រូវតែជួយគ្នាឱ្យបានយល់ទាំងអស់គ្នាថា ការរក្សាអតីតកាលឱ្យរស់រវើកនោះ គឺមានសារៈសំខាន់ណាស់។ ទាំងនេះ មិនមែនជាការជំនះលើអតីតកាល ផ្លាស់ប្តូរកែប្រែអតីតកាលទេ។ ប៉ុន្តែ ជនដែលបិទភ្នែកមិនមើលអតីតកាល គឺជាជនខ្វាក់ក្នុងពេលបច្ចុប្បន្ន។ ជនដែលមិនចង់រំឭកនូវការឈឺចាប់ពីអតីតកាល ជននោះ នឹងពើបប្រទះនូវគ្រោះថ្នាក់សារជាថ្មីទៀត។

---

[7] នេះជាគំនិត និងការសិក្សាស្រាវជ្រាវរបស់អ្នករៀបរៀងផ្ទាល់ ដែលបានឃើញអ្នកប្រាជ្ញសង្គមវិទ្យា ចាត់ទុក "ប្រវត្តិសាស្ត្រ" របស់ប្រទេសនីមួយៗ ជាអត្តសញ្ញាណជាតិនៃប្រទេសទាំងនោះដែរ។

[8] Learning and thinking - World History/Geography- *www.studentsfriend.com/onhist/learning.html*

ក្នុងន័យនេះហើយ ទើបឯកឧត្តម អ៊ឹម សិទ្ធី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានអះអាងថា "ប្រជាពលរដ្ឋនៃប្រជាជាតិនីមួយៗ ត្រូវតែស្គាល់ច្បាស់ប្រវត្តិសាស្ត្ររបស់ខ្លួន ដើម្បីធ្វើជាបទពិសោធន៍ក្នុងការការពារ និងស្ថាបនាប្រទេសជាតិតទៅមុខទៀត។"[9]

ដោយសារប្រវត្តិសាស្ត្រជាតិ ជារបស់ពលរដ្ឋ(Citizen) ទាំងអស់គ្នា ដែលជាសមាជិកនៃប្រទេស ទើបវាអាចជាមេដែកធ្វើឱ្យពលរដ្ឋចេះរួបរួមសាមគ្គីគ្នាការពារវា, ពួកគេនឹងស្គាល់កាតព្វកិច្ចរបស់ខ្លួនជាពលរដ្ឋដែលត្រូវគោរព និងការពារច្បាប់រដ្ឋ ដើម្បីរួមចំណែកបំពេញកាតព្វកិច្ចជាអ្នកការពារ និងកសាងប្រទេស ដែលខុសពីភាពជាប្រជាជន(People) និងមនុស្សលោកទូទៅ (Human beings)។ ទន្ទឹមនោះ វាធ្វើឱ្យពលរដ្ឋស្គាល់ភាពសំខាន់នៃវប្បធម៌ចម្រុះ និងមានគំនិតសន្តិភាពនិយម, ចេះអត់អោនគ្នា, ស្រុះស្រួលគ្នា និងយោគយល់គ្នា។ ពីអតីតកាល, ប្រវត្តិសាស្ត្រប្រើប្រាស់ជាចំហយ៉ាងជាក់ស្តែងនៅក្នុងសង្គមផ្សេងៗគ្នា ដើម្បីបណ្តុះគំនិតក្មេងៗនូវអាកប្បកិរិយា និងសីលតម្លៃវិជ្ជមាន។ ជាឧទាហរណ៍ នៅចក្រភពអង់គ្លេសកាលពីដើមសតវត្សរ៍ទី២០,ប្រវត្តិវិទ្យាជាផ្នែកមួយនៃការអភិវឌ្ឍន៍គុណតម្លៃយ៉ាងពិសេសនៃគំនិតស្នេហាជាតិ និងភក្តីភាពចំពោះចក្រភព។ នាពេលបច្ចុប្បន្ននេះ, យើងមើលឃើញប្រវត្តិវិទ្យាដូចជា"កំពុងសម្តែងនូវមុខងារខាងសង្គម, កំពុងជួយដល់ការឃោសនារបស់បច្ចុប្បន្នភាពនិស្សិតក្នុងលក្ខណៈជាជនស្វ័យភាព នៅក្នុងសហគមន៍ប្រជាធិបតេយ្យសេរី ដែលអាចសម្រួលឱ្យការចូលរួមកាន់តែមានប្រសិទ្ធភាព"។ ប្រវត្តិវិទ្យាអាចធ្វើឱ្យកុមារយល់ដឹងពីបច្ចុប្បន្នភាពកាន់តែបានល្អ នៅក្នុងបរិបទប្រវត្តិសាស្ត្រ។ ប្រវត្តិវិទ្យាផ្តល់នូវឱកាសគ្រប់គ្រាន់ ដើម្បីអប់រំឱ្យក្លាយជាប្រជាពលរដ្ឋសកម្ម និងយល់ដឹងជ្រៅជ្រះ ដោយសារការអភិវឌ្ឍន៍ជំនាញពិចារណារិះគន់ជាច្រើនបែប ដែលគេត្រូវការពេញមួយជីវិត។[10]

ប្រវត្តិសាស្ត្រ មានប្រយោជន៍ខ្លាំងណាស់ដែរដល់ការអប់រំអន្តរវប្បធម៌ ដែលមានមូលដ្ឋានលើការទទួលស្គាល់នូវសីលធម៌ និងដែលត្រូវតែបង្ហាញពីយថាភាព, លទ្ធភាព និងភាពជាអថេរនៃគោលជំហរសីលធម៌ពិតប្រាកដមួយ។ វាមានន័យថា សីលធម៌ពហុនិយមអាចកាន់តែរីកចម្រើននៅក្នុងដំណើរការរៀនសូត្រសីលវិជ្ជារបស់បុគ្គល។ ដើម្បីសម្រេចបាននូវការអប់រំអន្តរវប្បធម៌ គេគួរតែយកឧទាហរណ៍នៃគម្រោងការមួយ ដែលបានអនុវត្តន៍នៅឆ្នាំ១៩៨៦ ក្នុងក្របខ័ណ្ឌនៃក្រុមប្រឹក្សាអឺរ៉ុប «ការអប់រំ និងការអភិវឌ្ឍន៍វប្បធម៌អ្នកចំណាកស្រុក» ដែលដឹកនាំដោយ ល្វី ផផ័រ បានកំណត់ន័យជាតុទាំង៤នៃវិធីសាស្ត្រអន្តរវប្បធម៌៖

១- សង្គមរបស់យើងកំពុងតែប្រែក្លាយជាសង្គមអន្តរវប្បធម៌កាន់តែខ្លាំងឡើង
២- គ្រប់វប្បធម៌មានគោលដើមពិសេសច្បាស់លាស់របស់ខ្លួន
៣- វប្បធម៌ចម្រុះគឺជារតនសម្បត្តិមួយដ៏មានសក្តានុពល
៤- វាគឺជាតម្រូវការមួយ ក្នុងការបញ្ចូលដោយចម្រុះរវាងវប្បធម៌ទាំងអស់ ដោយមិនលុបចោលនូវអត្តសញ្ញាណជាក់លាក់របស់វានីមួយៗ, ការដាក់អន្តរវប្បធម៌ទៅក្នុងបញ្ញត្តិ ដើម្បីបំលែងវានៅក្នុងការពិតនៃអន្តរវប្បធម៌មួយ(ស.ម. Council of Europe: Allemann-Ghionda, 1992)។[11]

---

[9] *រស្មីកម្ពុជា,* ឆ្នាំទី១៧, លេខ៥០៣២, ថ្ងៃពុធទី២៨ ខែតុលាឆ្នាំ២០០៩, ទំព័រ ខ៣។

[10] Cf. Carley Dalvarez (University of Hetfordshire, England), *The Contribution of History to Citizenship* Education, (1994), p. 1-6 -- *www.ex.ac.uk/historyresource/journal2/dalvarez.pdf*

[11] WHITE PAPER - National Histories in South-Eastern Europe and History of a United Europe ... Writing and Rewriting History in the Context of Balkan ...*www.houseofeurope.ro/paper.htm*

ប្រវត្តិវិទ្យា មានប្រយោជន៍ដល់ការអប់រំសន្តិភាព, ដោយសារវាមានគោលដៅរួមចំណែកដល់ការធ្វើឱ្យមាំមួនខាងចំណេះដឹង ដើម្បីកសាងជំនាញអនុវត្តន៍សំខាន់ៗ និងឥរិយាបថរបស់កូនសិស្ស។ការបង្កើតនូវឱកាសជួបប្រជុំគ្នាដោយគ្រោងទុក និងមិនបានគ្រោងទុកជាមុន ដើម្បីជំទាស់នឹងគំនិតប្រកាន់បក្សពួក, ដោយអភិវឌ្ឍន៍ចំណងមិត្តភាពដ៏គួរឱ្យជឿទុកចិត្តគ្នា, ការដឹងដោយខ្លួនឯង និងស្វែងរកគម្រោងការទាំងឡាយ ដែលហុចផលប្រយោជន៍ឱ្យគ្នាទៅវិញទៅមក។[12]

ប្រវត្តិវិទ្យាផ្តល់ប្រយោជន៍ដល់ការអប់រំវប្បធម៌អត់អោនគ្នា ចាប់តាំងពីមានការវាយប្រហារលើទីក្រុងវ៉ាស៊ីនតោន ថ្ងៃទី១១ កញ្ញា ២០០១ នោះមក សហរដ្ឋអាមេរិកបានចាប់ផ្តើមអំពាវនាវឱ្យមានកំណែទម្រង់នយោបាយ, សេដ្ឋកិច្ច និងអប់រំ នៅក្នុងបណ្តាប្រទេសអារ៉ាប់។ ប៉ុន្តែនៅអេស្ប៉ីបគេបានបញ្ចូលទៅក្នុងកម្មវិធីសិក្សារបស់កុមារនូវមេរៀនស្តីពី គោលការណ៍សិទ្ធិមនុស្ស និងការអត់អោន ឬសណ្តោសគ្នា តាំងពី៧ឆ្នាំមុនពេលផ្ទុះព្រឹត្តិការណ៍វាយប្រហារភេរវកម្មនៅថ្ងៃ១១កញ្ញា២០០១។ ថ្មីៗនេះ រដ្ឋមន្ត្រីក្រសួងអប់រំអេស៊ីប បានដកគ្រូបង្រៀនកាន់សាសនាឥស្លាមរាប់ពាន់នាក់ ពីតួនាទីបង្រៀនសិស្ស បន្ទាប់ពីបានទទួលរបាយការណ៍ពីភ្នាក់ងារសេវាកម្មសន្តិសុខ, ពីទីប្រឹក្សារបស់ក្រសួង និងបណ្តឹងពីមាតាបិតាសិស្ស។ លើនេះទៀត រដ្ឋមន្ត្រីអប់រំអេស៊ីបមានបំណងកែទម្រង់សៀវភៅសិក្សារបស់សិស្ស ដើម្បីជំរុញគំនិតអត់អោនខាងសាសនា និងបំបាត់ធនធានមនុស្សដែលនឹងធ្វើជាភេរវករ។ ប្រវត្តិសាស្ត្រសហសម័យរបស់កម្ពុជា បានបង្ហាញនូវគំរូដ៏ល្អបំផុត សម្រាប់បញ្ញត្តិនៃភាពអន់អោនគ្នានេះ ដោយសារតែមានការអត់អោនគ្នាខ្ពស់ ទើបយើងអាចរកសុខសន្តិភាព និងបង្កើតឱ្យមានការអភិវឌ្ឍន៍ជាតិបានរហូតដល់សព្វថ្ងៃនេះ។

ប្រវត្តិវិទ្យា ផ្តល់នូវការអប់រំភាពស្រុះស្រួលគ្នា និងការយោគយល់គ្នា, នៅក្នុងសន្និសីទស្តីពី«តើការបង្រៀនប្រវត្តិសាស្ត្រអាចពង្រឹងការស្រុះស្រួលគ្នា, យោគយល់គ្នា និងអត់អោនគ្នានៅក្នុងសង្គមបច្ចុប្បន្នតាមរបៀបណា?» ណាលឈិក, សាធារណរដ្ឋកាបារឌីណូបាលការ្យ, សហព័ន្ធរុស៊ី, ៥-៦តុលា២០០១, លោក បិន វ៉ល្យ, ប្រធានសមាគមប្រវត្តិសាស្ត្រនៃគណៈកម្មការអប់រំមធ្យមសិក្សា, រាជាណាចក្ររួមបានបង្ហាញគំនិតប្រឆាំងតទល់នឹងគ្រូប្រវត្តិសាស្ត្រនៅក្នុងរាជាណាចក្ររួម។ គាត់និយាយថា ២៥ឆ្នាំមុននេះ កង្វល់មួយចំនួនបានទាញឱ្យអ្នកអប់រំប្រវត្តិសាស្ត្រមានការទទួលខុសត្រូវជាទូទៅនៅក្នុងរាជាណាចក្ររួម។ ការកំពុងបន្តវាយប្រហារភេរវកម្មនៅក្នុងប្រទេសអៀរឡង់ខាងជើង បានបង្ហាញពីគ្រោះថ្នាក់នៃកង្វះការអត់អោន និងយោគយល់គ្នា។ ក្នុងន័យឆ្លើយតបចំពោះការប្រឆាំងជំទាស់គ្នាបែបនេះ, គ្រូបង្រៀនជាច្រើននៅក្នុងរាជាណាចក្ររួមបានកែលម្អវិធីសាស្ត្រមួយចំនួន។ ជាដំបូងគេបានកំពុងធ្វើផែនការការងារផ្នែកលើវង្វង់សំណួរគន្លឹះខ្លះៗ។ នេះមានន័យថា ជាជំនួសឱ្យការមើលឃើញប្រធានបទនៅក្នុងន័យតួនៃចំណេះដឹង ដែលគេនាំមកផ្តល់ឱ្យ ឬរៀន គេមើលឃើញថា ប្រធានបទប្រវត្តិសាស្ត្រទាំងឡាយដូចជា ការស៊ើបអង្កេត។ បញ្ហានេះលើកទឹកចិត្តក្មេងៗឱ្យធ្វើការក្នុងមាគ៌ាមួយ ដែលសង្កត់ធ្ងន់លើភស្តុតាង, ដែលវាយតម្លៃដោយការបកស្រាយខុសៗពីគ្នា, និងដែលត្រូវកាត់សេចក្តីក្នុងគំនិតនៃការស្រាវជ្រាវជាន់ខ្ពស់ ជាជាងគំនិតនយោបាយឬជំទាស់។ អញ្ចឹងហើយ គ្រូប្រវត្តិវិទ្យានៅក្នុងរាជាណាចក្ររួម បានកំពុងប្រើសំណួរដូច្នេះថា«តើហេតុអ្វី

[12] WHITE PAPER - National Histories in South-Eastern Europe and History of a United Europe ... *www.houseofeurope.ro/paper.htm*

ទើបអ្នកប្រវត្តិវិទ្យាមិនយល់ព្រម អំពីអ្វីដែលបណ្ដាលឱ្យកើតសង្គ្រាមត្រជាក់?» ជាជាង «នរណាបានបណ្ដាលឱ្យកើតសង្គ្រាមត្រជាក់?»។[13]

លើសនេះទៀត វាធ្វើឱ្យគេស្គាល់អំពីតម្លៃសំខាន់ៗនៃវប្បធម៌របស់ខ្លួន ដើម្បីឱ្យអ្នកសិក្សា ឬអ្នកអានមានមោទនភាពជាតិ ដែលអាចស្ដែងចេញជាការខិតខំសាងខ្លួនឯង ដើម្បីបន្តវេនរៀមច្បង ឬបុព្វបុរសខ្លួន និងថែរក្សាមរតកដែលបានទទួលឱ្យស្ថិតនៅគង់វង្ស។ យើងគួររំឭកថាអ្នកបោះពុម្ពផ្សាយសារពត៌មាននៅសហរដ្ឋអាមេរិកម្នាក់ បានសរសេរថា ៖"ប្រទេសនេះ (គឺសហរដ្ឋអាមេរិក) ត្រូវបានបង្កើតឡើងដោយមនុស្សអង់អាច និងមិនអាចរក្សាការពារដោយមនុស្សទ្រមក់បានឡើយ"។[14] ពាក្យមួយឃ្លានេះ ពិតជាបានជួយពង្រឹងដំហរស្មារតីនៃជនជាតិអាមេរិកសម័យក្រោយៗមកឱ្យនៅរឹងប៉ឹងជាប់ជានិច្ច។ ចំណែកប្រទេសកម្ពុជាវិញ ក៏ត្រូវបានបង្កើតដោយពួកមនុស្សប្រសើរខ្ពង់ខ្ពស់ និងមានលោហិតជាអ្នកខ្លាំងពូកែផងដែរ។

ដូច្នេះ ខ្មែរគប្បីមានមោទនភាពចំពោះកំណើតរបស់ខ្លួនជាខ្មែរទាំងអស់គ្នា។ មោទនភាពនេះជួយដាស់ស្មារតីខ្មែរឱ្យភ្ញាក់រឭកឡើងវិញ ឱ្យមានការប្ដេជ្ញាចិត្តជាថ្មី ខិតខំធ្វើការងារជាប្រយោជន៍ជាតិ និងលប់បំបាត់ជម្លោះដែលគ្មានន័យរវាងខ្មែរ និងខ្មែរ ដើម្បីអនាគតត្រចះត្រចង់នៃជាតិមាតុភូមិ និងរបស់កូនចៅខ្មែរជំនាន់ក្រោយៗទៀត។

ការបណ្ដុះមោទនភាពជាតិ អាចធ្វើបានតាមរយៈខ្លឹមសារសៀវភៅអួតសរសើរពីដូនតាខ្មែរ ដោយពួកអ្នកប្រាជ្ញបរទេសល្បីៗមួយចំនួន ដូចជា ៖

លោក ហ្សង់ ប៊ែណា (Jean Bernard) នៃបណ្ឌិតសភាបារាំងបានសរសេរសៀវភៅ «លោហិត និងប្រវត្តិសាស្ត្រ» (LE SANG ET L'HISTOIRE) ដែលនៅក្នុងនោះមានអត្ថបទមួយមានចំណងជើងថា៖ សម័យអង្គរនិងជាតុបង្កគោលិកាឈាមក្រហមពិសេសប្រភេទ *E* (Les temps d'Angkor et l'hémoglobine E)[15] ដែលក្នុងនោះលោកបានសរសេរថា ជាតុបង្កគោលិកាឈាមក្រហមពិសេសប្រភេទ E គឺពិតជាជាតុបង្កគោលិកាឈាមក្រហមរបស់ជនជាតិខ្មែរ។

លោកបានបន្តថា ៖ នៅសតវត្សទី១២ និងទី១៣ ព្រះមហាក្សត្រខ្មែរ តាំងខ្លួនព្រះអង្គជាអធិរាជចក្រវាល នៅសម័យនោះចក្រភពរបស់ព្រះអង្គមានទឹកដីយ៉ាងធំទូលាយ ដែលគ្របដណ្ដប់លើវាលទំនាបនិងដីសណ្ដទន្លេមេគង្គ, លើប្រទេសឡាវរហូតដល់ក្រុងវៀងច័ន្ទ, លើអាណាខេត្តខាងកើតនៃប្រទេសថៃ, លើទឹកដីមួយភាគនៃប្រទេសម៉ាឡេស៊ី, និងប្រទេសវៀតណាមបច្ចុប្បន្ន។

រជ្ជកាលរបស់ព្រះអង្គមានឈ្មោះល្បីល្បាញ ដោយសារការសង់ប្រាសាទជាច្រើនហើយប្រាសាទមួយចំនួនស្ថិតនៅក្នុងចំណោមស្នាដៃឯកនៃសិល្បៈខ្មែរ ចម្បាំងនានារបស់ព្រះអង្គ បានពង្រីកឥទ្ធិពលនៃសិល្បៈខ្មែរទៅលើភូមិភាគអាស៊ីអាគ្នេយ៍ ។ល។

---

[13] Mr Ben Walsh, *Teaching history in present day secondary schools for reconciliation, mutual understanding and tolerance: the example of the United Kingdom*, in Seminar on "How history teaching can strengthen reconciliation, mutual understanding and tolerance in present-day society", Russian Academy of Education, Moscow: New concepts in history education in secondary Education. www.coe.int/T/F/Coop%E9ration_culturelle/education/

[14] Max J. Herzberg, *This Is America*, Pocket Books, New York, 1950 : An unknown newspaper editor wrote: "*This country was founded by the bold and cannot be maintained by the timid* ".

[15] Jean Bernard, *Le sang et l'histoire*, Editions Buchet/Chastel, Paris, 1983, p. 46-49.

លោក ហ្សង់ ប៊ែណាបានធ្វើសេចក្តីសន្និដ្ឋានថា៖ *"វត្តមាននៃបុរាណប្រាសាទជាស្នាដៃស្ថាបត្យកម្មខ្មែរនៅក្នុងព្រៃព្រឹក្សា និងវត្តមាននៅក្នុងលោហិតរបស់ខ្មែរបច្ចុប្បន្ននូវធាតុបង្កគោលិកាឈាមក្រហមពិសេសប្រភេទ E ដែលបានបន្តមកជំនាន់ក្រោយៗអស់ពេលប្រាំបួនសតវត្សរ៍មកហើយនោះ ជាសក្ខីភាពជាក់ស្តែងនៃអរិយធម៌១របស់ប្រជាជន១ ដែលចង់នៅមានជីវិតគង់វង្សជារៀងរហូត"។*

ប្រជាជាតិខ្មែរពូកែទាំងប្រាជ្ញាពលកម្មនិងហត្ថពលកម្ម,តាមលោក Bernard-Philippe Groslier បានសរសេរថា៖ ក្នុងចំណោមគុណសម្បត្តិ ដែលខ្មែរមានប្រាជ្ញាពុំមែនអន់ជាងគេនោះឡើយហើយគួបផ្សំនឹងការប៉ិនប្រសប់ខាងហត្ថពលកម្ម ដែលគ្មានពីរ (Une habileté manuelle hors de pair)នៅសម័យមួយនោះខ្មែរបានក្លាយជាប្រជាជាតិខ្លាំងពូកែបំផុតនៅអាស៊ីអាគ្នេយ៍នេះ។[16] ខ្មែរមានសាកលវិទ្យាល័យតាំងពីសតវត្សរ៍ទី១១ និងមានចំណេះដឹងយ៉ាងទូលំទូលាយទាំងផ្នែកអក្សរសាស្ត្រ និងទស្សនវិជ្ជា។ យើងមានសិលាចារឹកជាច្រើន ដែលសរសេរទាំងភាសាខ្មែរបុរាណ, សំស្ក្រឹត និងបាលីយ៉ាងស្ទាត់ជំនាញ។ លើសពីនេះទៀតខ្មែរយើងចេះប្រើទស្សនវិជ្ជា ដោយបានប្រើគំនិតយ៉ាងវៃឆ្លាតមកធ្វើការបង្រួបបង្រួមជាតិ។ ជាក់ស្តែងនៅដើមសម័យអង្គរព្រះបាទជយវរ្ម័នទី២ បានប្រើលទ្ធិទេវរាជមកបង្រួបបង្រួមជាតិទាំងមូល ហើយរហូតមកដល់រាជ្យព្រះបាទជយវរ្ម័នទី៧ យើងក៏ឃើញទ្រង់ប្រើនូវគំនិតយ៉ាងវៃឆ្លាតរបស់ទ្រង់មកធ្វើការបង្រួបបង្រួមជាតិដែរ។ ជាសក្ខីកម្ម យើងឃើញប្រាសាទបាយ័នដែលបញ្ជាក់នូវប្រាជ្ញាយ៉ាងឈ្លាសវៃរបស់ទ្រង់ ក្នុងការធ្វើឱ្យមានឯកភាពនៅក្នុងប្រទេសរវាងអ្នកកាន់សាសនាខុសៗគ្នា។

លោក Adhémard LeClère បានបកប្រែអត្ថបទច្បាប់ខ្មែរជាច្រើនទៅជាភាសាបារាំង និងបោះពុម្ពផ្សាយនៅឆ្នាំ១៨៩៨ ដោយដាក់ចំណងជើងថា "Les codes cambodgiens"។ លោកបានឱ្យតម្លៃយ៉ាងខ្ពស់ថា ប្រទេសកម្ពុជាធ្លាប់ជាប្រទេសនីតិរដ្ឋមួយ ដែលធ្លាប់មានច្បាប់យ៉ាងសម្បូណ៌បែបសម្រាប់គ្រប់គ្រង តាំងពីមនុស្សរហូតដល់សត្វដូចជា ក្រមសេះ, ក្រមដំរី ឬក្រមចក្រី។

នៅក្នុងបុព្វកថា លោកបានសរសេរជាអាទិ៍ថា៖ កម្ពុជាធ្លាប់ជាប្រជាជាតិមួយដ៏ធំ ដែលយើងកោតសរសើរចំពោះអ្វីដែលគេបានធ្វើក្នុងអតីតកាល (Le Cambodge.. une nation qui fut un grand peuple et qui mérite et notre admiration pour ce qu'elle a fait dans le passé...)[17]។

មន្ត្រីរាជការខ្មែរពីមុន មាន"ក្រមទម្រង់ស័ក្តិ"សម្រាប់ណែនាំឱ្យមានវិន័យក្នុងការងារ និងមានសេចក្តីថ្លៃថ្នូរ, ថ្នាក់ក្រោមចេះគោរពថ្នាក់លើ, ឯថ្នាក់លើចេះគោរពថ្នាក់ក្រោម។ មេរៀនដ៏សំខាន់ដែលយើងអាចដកស្រង់ពីបទពិសោធន៍អតីតកាលនោះគឺការចេះប្រើភាសាប្រកបដោយសេចក្តីថ្លៃថ្នូរនៅគ្រប់ទីកន្លែង និងវិជ្ជាជីវៈឱ្យបានសក្តិសមនឹងកិត្តិយស និងតួនាទីរៀងៗខ្លួន។ ក្នុងករណីអ្នកណាម្នាក់ប្រើខុស នឹងត្រូវទទួលការផាកពិន័យជាប្រាក់ ដែលមានចែងពីចំនួនស្របតាមអង្គពហូស័ក្តិ។

បទពិសោធន៍ថ្មីៗនេះទៀត យើងឃើញនៅក្នុងកំណត់ត្រារបាយការណ៍មួយរបស់អ្នកដឹកនាំបារាំងមួយរូបថា៖ "សិស្សខ្មែររៀនពូកែជាងគេ នៅក្នុងចំណោមសិស្សចម្រុះជាតិនៅកូសាំងស៊ីន"។ នៅក្នុងសម័យអាណាព្យាបាលបារាំង រាល់ពេលប្រឡងយកមធ្យមសិក្សាប័ត្រនៅកូសាំងស៊ីន សិស្សខ្មែរតែងឈ្នះសិស្សវៀតណាម និងសិស្សបារាំង

[16] Cf. Bernard-Philippe Groslier, *Angkor, Hommes et Pierres,* Arthaud, Paris, 1965, p.12-13 : "Les Khmers: psychologie et mentalité".
[17] Cf. Adhémard Leclère, *Les Codes cambodgiens*, Paris, Ernest Leroux, Ed. 1898, Préface, p. VIII.

ជានិច្ច(Ce sont les élèves cambodgiens qui, régulièrement, tiennent la tête aux examens du baccalauréat en Cochinchine devant les Annamites et les Français)[18] ។

ដូច្នេះ ចំណុចទាំងឡាយដូចបានរៀបរាប់ហូរហែពីខាងលើមកនេះ ជាភស្តុតាងបញ្ជាក់ឱ្យឃើញថា ដូនតាខ្មែរ នៅតែជាមនុស្សខ្លាំងពូកែ គួរឱ្យកូនចៅជំនាន់ក្រោយយកគំរូតាមវីរភាព និងស្នាដៃដែលពួកគាត់សម្រេចបានកាលពីអតីតកាល។

### 1.3. **ផលប៉ះពាល់នៃប្រវត្តិវិទ្យា**

ចំពោះអ្នកមិនដឹងអំពីប្រវត្តិសាស្ត្ររបស់ខ្លួនវិញ តែងតែប្រព្រឹត្តិអំពើលាមក ដូចជា ធ្វើសកម្មភាពបំផ្លិចបំផ្លាញជាតិខ្លួនឯង, បន្ទាបបន្ថោកជាតិខ្លួនឯង, ធ្វើជាចោរលួចវត្ថុបុរាណ និងអ្នករកស៊ីជួញដូរខុសច្បាប់ បំបាត់ព្រលឹង និងអតីតកាលរបស់ជាតិខ្លួន, មើលងាយស្នាដៃរបស់ដូនតាខ្លួនឯង ដែលបានបង្កើតឡើងដោយកិច្ចខិតខំប្រឹងប្រែងព្យាយាម, ការបូជាជីវិត, ការអត់ធ្មត់ និងការប្រើប្រាស់នូវបញ្ញាញាណច្នៃប្រឌិតដ៏អស្ចារ្យទាំងអស់នោះ។

ម្យ៉ាងទៀត ខ្លឹមសារសៀវភៅប្រវត្តិសាស្ត្រ អាចធ្វើឱ្យអ្នកសិក្សា ឬអ្នកអានរងនូវផលប៉ះពាល់អវិជ្ជមានផងដែរ។ ប្រសិនបើគេមិនបានពិនិត្យពិច័យលើខ្លឹមសារ និងពិចារណាលើបញ្ហាចិត្តសាស្ត្រនៃការសរសេរពន្យល់ឱ្យបានសមស្រប និងប្រកបដោយន័យស្ថាបនានោះទេ។ ពោលគឺវាអាចធ្វើឱ្យអ្នកសិក្សា និងអ្នកអានបាក់ទឹកចិត្ត អស់សង្ឃឹម ប្រមាថមើលងាយ ឬខឹងសម្បារចំពោះទង្វើ ឬអត្តភាពរបស់ដូនតាខ្លួន ឬជាតិសាសន៍ដទៃដែលធ្លាប់មានទំនាក់ទំនងជាប្រវត្តិសាស្ត្រជាមួយគ្នា។

ហេតុនេះហើយបានជានៅប្រទេសជាច្រើន បានប្រជុំអ្នកប្រាជ្ញរបស់ខ្លួន ដើម្បីរកវិធីសរសេរប្រវត្តិសាស្ត្រ ឱ្យកាន់តែបម្រើផលប្រយោជន៍យុវជន និងសង្គមរបស់ខ្លួនឱ្យកាន់តែច្រើនឡើង និងប្រសើរឡើង។ដោយចៀសវាងនូវការណែនាំបណ្តុះនិន្នាការ ឬមនោគមវិជ្ជាប្រទូស្តរាយគ្នា ដើម្បីបង្កើត និងបង្កើនគំនិតដូចបានពោលខាងដើម។ ព្រោះថា ពិភពលោកកាន់តែរួមតូច គ្រប់ជាតិសាសន៍នៅលើផែនដី កាន់តែត្រូវការនូវសកម្មភាពទំនាក់ទំនងគ្នា សហប្រតិបត្តិ ការគ្នាកាន់តែខ្លាំងឡើង៕

[18] *Bulletin Mensuel du Comité de l'Asie Française*, 31ème année, *No. 286, Janvier 1931*, p. 25.

# មេរៀនទី 2 បុរេប្រវត្តិសាស្ត្រខ្មែរ

## 1. វប្បធម៌សម័យបុរេប្រវត្តិសាស្ត្រខ្មែរ

ជាទូទៅអ្នកប្រាជ្ញ បានធ្វើការបែងចែកកាលប្រវត្តិសាស្ត្រ ជាពីរផ្នែកធំៗ ៖ សម័យប្រវត្តិសាស្ត្រ ដែលរាប់ចាប់ពីពេលមានអក្សរសម្រាប់កត់ត្រាព្រឹត្តិការណ៍ និង សម័យបុរេប្រវត្តិសាស្ត្រ សំដៅលើសម័យកាលមិនទាន់មានឯកសារសំណេរ។ ការសិក្សាអំពីសម័យកាលនេះ ជាភារកិច្ចរបស់អ្នកបុរាណវិទ្យា ដែលត្រូវប្រើប្រាស់ទ្រឹស្តីវិទ្យាសាស្ត្រខាងបុរាណវិទ្យាមកសិក្សា។ ស្នាដៃអ្វីដែលបុរាណវិទូចងក្រងដោយផ្អែកលើប្រភពឧបករណ៍ប្រើប្រាស់ នៅសម័យមុនពេលមានកំណើតសំណេរ គេហៅថា បុរេប្រវត្តិសាស្ត្រ។

សម្រាប់ប្រទេសកម្ពុជា មានការឲ្យអត្ថន័យខ្វែងគ្នាច្រើនចំពោះកាលសម័យបុរេប្រវត្តិសាស្ត្រខ្មែរ។ លោកបណ្ឌិត មីសែល ត្រាណេ អះអាងថា « បុរេប្រវត្តិសាស្ត្រខ្មែរ ចាប់ផ្តើមឡើងតាំងពីប្រមាណជា៦៨០.០០០ឆ្នាំមុនគ្រិស្តសករាជ »។ លោកត្រឹង ងា « បុរេប្រវត្តិសាស្ត្រខ្មែរចាប់ពី ៤២៩០ឆ្នាំមុនគ្រិស្តសករាជ រហូតដល់ប្រហែលជាឆ្នាំ៥២នៃគ្រិស្តសករាជ » ។ ចំណែកឯលោក ដេវិឌ ឆាណ្ឌល័រ វិញហាក់ដូចជាស្របនឹងគំនិតរបស់លោកត្រឹង ងា ដែរ ដោយលោកពោលនៅដើមដំបូងនៃសៀវភៅរបស់លោកថា « តាមការប្រើប្រាស់កាបូន១៤ » ដែលជាវិធីមួយវាស់ជាតិវិទ្យុសកម្មដើម្បីកំណត់អាយុកាលនៅរូងភ្នំល្អាងស្ពាន ដែលជាស្ថានីយបុរេប្រវត្តិ គេដឹងថា មនុស្សចេះធ្វើក្អមឆ្នាំង បានមករស់នៅនឹងទីកន្លែងនោះតាំងពី៤២០០ឆ្នាំ មុនគ្រិស្តសករាជមកម៉្លេះ។ តាមការធ្វើកំណាយផ្នែកបុរាណវត្ថុវិទ្យា គេបានរកឃើញឧបករណ៍ប្រើប្រាស់ជាច្រើន ដែលបានបន្សល់ទុកដោយអ្នកប្រើប្រាស់ តាំងពីរាប់សែនឆ្នាំមុនគ្រិស្តសករាជទៅទៀត។

គេបានធ្វើការសន្និដ្ឋានថា អស់ពេលដ៏យូរអង្វែងមកហើយ ដែលបុព្វបុរសខ្មែរបានមករស់នៅលើទឹកដីកំណើតនេះ។

### 1.1. ស្ថានីយបុរេប្រវត្តិសាស្ត្រ

យើងមានស្ថានីយបុរេប្រវត្តិសាស្ត្រជាច្រើន ដែលផ្តល់ព័ត៌មានតាមរយៈកំណាយផ្នែកបុរាណវិទ្យា។ ស្ថានីយទាំងនោះមានដូចជា ៖

- **ស្រែស្បូវ** : នៅអាយុកាលប្រមាណ ៥០០០០០ឆ្នាំ បានបន្សល់ឧបករណ៍ប្រើប្រាស់ធ្វើពីថ្មបំបែក និងសំលៀងរបស់មនុស្សគ្មានអារ្យធម៌ ដែលមិនអាចឲ្យគេដឹងបានអំពីប្រភេទនៃក្រុមមនុស្សម្ចាស់ឧបករណ៍ទាំងនោះបានឡើយ។
- **ល្អាងស្ពាន-បាត់ដំបង** អាយុ៤២៩០ឆ្នាំ មុនគ.ស. ជាស្ថានីយបុរេប្រវត្តិចាស់ជាងគេរបស់ពួកមន-ខ្មែរ
- **ក្បាលរមាស-នៅក្នុងខេត្តកែប** អតីតខេត្តកំពត មានអាយុកាល ៣៤២០ឆ្នាំ មុនគ.ស.
- **ស្ថានីយភូមិមូល**-នៅតំបន់ដីក្រហមចំការកៅស៊ូ ពញាក្រែក, មេមត់ ឆ្លូង ខេត្តកំពង់ចាម មានអាយុកាល ១៥០០ឆ្នាំ មុនគ.ស.
- **សំរោងសែន**-នៅក្នុងតំបន់ទំនាបលិចទឹក៦ខែ គោក៦ខែ នៅក្នុងខេត្តកំពង់ឆ្នាំង មានអាយុកាលប្រមាណ ១២៨០ឆ្នាំ មុនគ.ស.
- **ម្លូព្រៃ**-នៅក្នុងខេត្តព្រះវិហារ អាយុកាលប្រមាណ៣០០ឆ្នាំមុនគ.ស.

- **អង្គរបុរី**-នៅវត្តគំនូរ ក្នុងអតីតកំពែងរាជធានីបុរាណ ក្នុងខេត្តតាកែវ មានអាយុកាលពី៤០០ឆ្នាំ មុនគ.ស. រហូតដល់៤០០នៃគ.ស. ជាតំបន់រងទឹកជំនន់ជន់លិច៦ខែ គោក៦ខែរៀងរាល់ឆ្នាំដែរ។
- **ស្នាយ**-បន្ទាយមានជ័យ ប្រមាណ ៦០០ឆ្នាំ មុនគ.ស. ដល់សតវត្សរ៍ទី៦
- **អូកែវ**(កម្ពុជាក្រោម)វៀតណាមខាងត្បូង (សម័យប្រវត្តិសាស្ត្រ សតវត្សរ៍ទី៣-៥)
- ស្ថានីយដទៃទៀតដែលសព្វថ្ងៃស្ថិតនៅក្នុងប្រទេសជិតខាង (ថៃ,វៀតណាម)




**1.2. ឧបករណ៍ប្រើប្រាស់**

មានដូចជា ៖ ដឹង (ជាតុជាច្រើន) , ពូថៅ, ចុងព្រួញ, កាំបិត, លំពែង, ពន្លួញស្រួច និងពន្លួញមានរងៀង, ផ្លែកណ្ដៀវ , កញ្ជើ, ថូ , ភាជន៍ , ឆ្នាំង, ស្គរ , គែន, ពុម្ពស្មិតធ្វើពីលោហធាតុរឹង ទូក, ច្បូក, ស្ន, ផ្លែសន្ទូច, ខ្សៀ, ត្រល់, ត្រសាល់ ។ ធ្យូង, សំណល់ផ្ទះបាយ និងសំបកខ្យង, គ្រុំ ជាដើម, អង្កាំ, ខ្សែក, កងដៃ, ការ, ក្រវិល, ក្រសាល់ត្រចៀក, បន្តោងខ្សែក, ចង្រ្កង-រូបសត្វពាហនៈ (ជាច្រើនប្រភេទ)

តាមរយៈឧបករណ៍ប្រើប្រាស់ទាំងអស់នេះ គេអាចវិភាគដឹងបានអំពីជំនឿ ជីវភាព និងការរីកចម្រើនខាងខួរក្បាលរបស់មនុស្សខ្មែរនៅសម័យនោះ។






ការប្រើប្រាស់ស្គរមហោធឹកសំរិទ្ធ និងទូក
រូបភាពទី១ : ទូកធ្លាក់លើស្គរមហោធឹក,ក្រចេះស្ទឹងត្រែង
រូបភាពទី២ : ខ្មែរលើ (កៅម៉ា)ពាក់រោមសត្វស្វាបដូចរូបនៅលើស្គរ កម្ពុជាក្រោម
រូបភាពទី៤ : មនុស្សជិះទូក ,ចានឈៀង ខេត្តឧត្តរមានជ័យ សៀមបច្ចុប្បន្ន

ប្រភព៖ ត្រាណេ, មីសែល (១៩៩៦), *ប្រវត្តិសាស្ត្រកម្ពុជាពីបុព្វសម័យដល់សតវត្សទី៨*,ភ្នំពេញ,រោងពុម្ព ដំរីស។

### 1.3. ជំនឿ

ជីវចលនិយម( Animism ) ដែលជាជំនឿទៅលើរបស់, វត្ថុ, ទីកន្លែង, រុក្ខជាតិ, ធម្មជាតិ, សំណង់ ឬអ្វីៗទាំងអស់នៅជុំវិញខ្លួនមនុស្ស សុទ្ធសឹងមានវិញ្ញាណ ឬព្រលឹង។ សូម្បីតែមនុស្សខ្លួនឯង ក៏មានព្រលឹងដែរ ហើយមនុស្សដឹងថាខ្លួនឯងមានព្រលឹង នៅពេលដេកយល់សប្តិ។ ហេតុនេះហើយទើបគេកប់សព ដោយមានដាក់ដង្វាយផ្សេងៗ មានក្អម ឬពួច វត្ថុប្រើប្រាស់, និងសែនព្រេន មានក្បាលជ្រូក មានដាក់កាក់មាសមួយសន្លឹកនៅក្នុងមាត់ និងបំពាក់គ្រឿងអលង្ការឲ្យខ្មោច សពខ្លះដាក់ក្នុងក្តារមឈូសកប់។



រូបភាពទី ១៣(ក,ខ)-១៧
សត្វខ្លីង ជប់ ខេត្តកំពង់ចាម និងគោជីជុត មកពីស្ថានីយម្លូព្រៃ, មេអំបៅសិរិទ្ធ, កង្កែបថ្មើមថ្ម និង ដីរសិរិទ្ធ, ភូមិស្នាយ, ខេត្តបន្ទាយមានជ័យ (២០០២)។


ឧបករណ៍នេសាទ
រូបភាទី១-២ : ពន្លួងឆ្អឹង,សំរោងសែន
រូបភាពទី៣-៤ : ផ្លែសន្ទូច បានឈៀង និងសំរោងសែន
រូបភាពទី៥-៦ : សំរោងសែន






គោរពលិង្គ និងព្រលឹងដូនតា  ហើយការគោរពនេះបានបន្សល់ទុករហូតដល់សព្វថ្ងៃ។ រណ្តាប់តំណាងមានជាពិសេសនៅក្នុងពិធីឆ្លងវ័យ ដូចជា កាត់សក់បង្កក់ឆ្មប, កោរជុក, បួស, ចូលម្លប់, រៀបការ និងពិធីបុណ្យចម្រើនព្រះជន្ម ឬឆាកមហាបង្សុកូល ឬចន្ទសុក្រគិរីសូត្រ  និងពិធីឡើងអ្នកតាសុំទឹកភ្លៀង។ ចាត់ទុករូងភ្នំ ឬគុហា ជាកន្លែងពិសិដ្ឋដែលអាចញ៉ាំងឲ្យគេសម្រេចអ្វីៗបាន ជាពិសេសធម៌ និងញាណ។

## 1.4. ជីវភាពមនុស្សខ្មែរ

មនុស្សបុរេប្រវត្តិចេះ ៖ បរបាញ់សត្វ, ផ្សាំងសត្វ, ធ្វើស្រូវចម្ការ, ធ្វើស្រែវស្សា, នេសាទ, ជក់ថ្នាំ និងដាំថ្នាំសម្រាប់ជក់ ព្រមទាំងប្រើប្រាស់វត្ថុផ្សេងៗពីលោហៈធាតុ ដូចជា កាក់, បន្តោង, កងដៃ, ការ, ទំហូ, ក្រវិល, អង្កាំជាដើម, ចេះដាំបាយហូប។ គេចេះលម្អកាយដោយគ្រឿងអលង្ការ, ត្បាញសំពត់សម្រាប់ស្លៀក, ប្រើឧបករណ៍ភ្លេង,ចេះប្រើទូក ។






BISHOP, Paul; PENNY, Dan; STARK, Miriam and SCOTT, Marian (2003) “Record of Paleoenvironments and Human Occupation at Angkor Borei, Mekong Delta,” *Southern Cambodia, Geoarchaeology: An International Journal*, Vol. 18, No. 3, 359–39 (2003), Wiley Periodicals Inc., Published online in Wiley Interscience.

## 1.5. ការវិវឌ្ឍន៍នៃផ្នត់គំនិត

មនុស្សបុរេប្រវត្តិចេះគូរគំនូរលម្អដោយប្រើពណ៌នៅលើកុលាលភាជន៍  និងរូងភ្នំដំបូងឡើយ គេអាចឃើញភស្តុតាងនេះនៅស្ថានីយល្អាងស្ពាន ឬនៅស្ថានីយក្បាលរមាស មនុស្សចេះយករូងភ្នំជាលំនៅ និងរស់ក្នុងជីវភាពជា

អ្នកបរបាញ់ និងបេះផ្លែឈើស្រាប់នៅក្នុងព្រៃ ។ ពេលនៅលើតំបន់ខ្ពង់រាប គេចេះធ្វើភូមិដ្ឋានផ្តុំគ្នា ដោយមានលើកកំពែងដីខ្ពស់ព័ទ្ធ បិទបាំងភូមិ ការពារភូមិ និងរស់នៅតាមរបៀបសេដ្ឋកិច្ចប្រមាញ់ផង និងដាំដុះផង។ ពេលមករស់នៅតំបន់វាលទំនាប ដូចជានៅ សំរោងសែន, ម្លូព្រៃ, គេចេះសង់ផ្ទះលើកជាជន្ទល់, ផ្សាំងសត្វ នេសាទ និងការដាំដុះ គឺធ្វើកសិកម្ម ដើម្បីរក្សាស្បៀងបម្រុងទុក។ គេចេះធ្វើស្រែវស្សាដោយមានគំនិតធ្វើនយោបាយទឹក..(ស្នាមព្រែកជីកបរមបុរាណ)។ ចេះប្រើ គោ, ក្របី, សម្រាប់ជួយជាកម្លាំងអូសទាញ, ចេះប្រើទូក ធ្វើនាវាចរណ៍, ចេះស្លលោហធាតុធ្វើឧបករណ៍សម្រាប់ប្រើប្រាស់។

## សេចក្តីសន្និដ្ឋាន

នៅលើទឹកដីនេះ មានវត្តមានជនជាតិដើមមករស់នៅតាំងពីយូរយារណាស់មកហើយ ដែលមានអាយុកាលយ៉ាងហោចណាស់៤២៩០ឆ្នាំមុនគ.ស.។

បើផ្អែកតាមជំនឿ ប្រពៃណីទំនៀមទម្លាប់ និងផ្នត់គំនិត រួមទាំងការអះអាងរបស់អ្នកប្រាជ្ញបារាំងថា «សង្គមខ្មែរក្នុងរយៈពេលរាប់ពាន់ឆ្នាំ រហូតដល់ការមកដល់របស់បារាំង មានការផ្លាស់ប្តូរ ឬប្រែប្រួលតិចតួចណាស់ »។ ម្ល៉ោះហើយជនជាតិដើមទាំងនោះ គួរតែជាបុព្វបុរសរបស់ជនជាតិខ្មែរសព្វថ្ងៃនេះ។ អរិយធម៌ដើមនេះ មានលក្ខណៈស្រដៀងគ្នានឹងអរិយធម៌របស់ជនជាតិដើមនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ដីគោក និងដីកោះទាំងមូល៕



# មេរៀនទី 3 ហ្វូណាន-ចេនឡា និងការបែកបាក់

គេចែកសម័យប្រវត្តិសាស្ត្រខ្មែរ នាមុនសម័យអង្គរជាពីរ គឺ៖

ទី១៖ ជាសម័យកាលហ្វូណាន[19] (ពីស.វទី១-ទី៦ នៃគ្រិស្តសករាជ) ប្រហែលឆ្នាំ៥២ - ៥៥០គ.ស.
ទី២៖ ជាសម័យកាល ចេនឡា (ពីចុងស.វទី៦ដល់ស.វទី៨ នៃគ.ស.) ឆ្នាំ៥៥០ - ៨០០គ.ស.

ប្រវត្តិសាស្ត្រខ្មែរនៅសម័យហ្វូណាន ត្រូវចងក្រងឡើងដោយពឹងផ្អែកលើប្រភពឯកសារចិនស្ទើរតែទាំងស្រុង ទើបគេអាចហៅសម័យនេះថាជា ប្រូតូប្រវត្តិសាស្ត្រ (Proto-history)។ ចំណែកសម័យចេនឡាគេបានដឹងឮតាមរយៈរបាយការណ៍ចិនតែបន្តិចបន្តួចប៉ុណ្ណោះនៅអំឡុងដើមសតវត្សរ៍ទី៨ តែសំណាងល្អ ដូនតាខ្មែរបានបន្សល់ទុកនូវសិលាចារឹកជាច្រើនផ្ទាំង ដែលអាចឱ្យគេដឹងបានយ៉ាងច្រើនអំពីប្រវត្តិសាស្ត្រពិតប្រាកដ ជាពិសេស នាមព្រះមហាក្សត្រខ្មែរល្បីៗសំខាន់ៗជាច្រើនអង្គ រហូតដល់សម័យអង្គរ។

ហេតុនេះពាក្យថា "ហ្វូណាន" និង"ចេនឡា" ជាពាក្យដែលចិនបានហៅនគរខ្មែរចាប់ពីសតវត្សរ៍ទី១នៃគ.ស ដល់ទី៦ និងពីទី៧ រហូតដល់ការមកដល់របស់ពួកអឺរ៉ុបនៅតំបន់នេះ។

## 1. ហ្វូណាន 富南

ហ្វូណាន ដែលត្រូវគេសន្មតថា ជាពាក្យចិនសរសេរត្រាបតាមការហៅរបស់ខ្មែរខ្លួនឯងថា "វ្នំ ឬស្ដេចភ្នំ ឬនគរភ្នំ" ត្រូវបានចាត់ទុកថា ជាសម័យកាលដំបូងនៅក្នុងប្រវត្តិសាស្ត្រកម្ពុជាដែលចាប់ផ្ដើមនៅសតវត្សរ៍ទី១នៃគ្រិស្តសករាជ។ ឈ្មោះ «ហ្វូណាន»" គេប្រទះឃើញតែក្នុងរបាយការណ៍ចិនប៉ុណ្ណោះ ស្តីអំពីទំនាក់ទំនងចិន និងហ្វូណាន ដែលចាប់ផ្តើមឡើងនៅសតវត្សរ៍ទី៣ ប្រហែលក្នុងគ្រិស្តសករាជ២៣០។ ឈ្មោះហ្វូណាន លេចឡើងចុងក្រោយនៅរវាងឆ្នាំ៦១៨-៦៤៩ ប្រហែលបានមកពីបេសកទូតហ្វូណានមួយក្រុមទៅកាន់ប្រទេសចិននៅឆ្នាំ៦២០-៦៣០។ សម័យកាលក្រោយមក ចិនបានប្រើឈ្មោះថា «ចេនឡា»។

### 1.1. ទីតាំង

ទីតាំងរបស់ហ្វូណាន បានមកពីរបាយការណ៍ចិន។ ពួកគេនិយាយថា ហ្វូណានមានចម្ងាយ៣០០០លី (១២០០គម) ខាងលិច លីនយី ដែលមានទីតាំងនៅវៀតណាមកណ្តាលភាគខាងជើង ហើយព្រំប្រទល់ភាគខាងត្បូងរបស់លីនយីជាប់នឹងហ្វូណាន។ ហ្វូណាន ក៏បានលាតសន្ធឹងតាមឈូងសមុទ្រដ៏ធំមួយដែរ ដែលមានចម្ងាយទទឹង៣០០០លី គឺពីកើតទៅលិច។ ចិនក៏បាននិយាយដែរថានៅហ្វូណានមានទន្លេធំមួយហូរពីបស្ចិម ឬភាគពាយ័ព្យចាក់ទៅសមុទ្រ។ ទន្លេនេះ ទំនងចង់និយាយអំពីទន្លេសាបមេគង្គនេះឯង។ ចំណែកតំបន់ធំមួយទៀតនៅខាងលិចហ្វូណាន ចិនហៅថា ទុន-ស៊ុន ដែលក្រោយមកគេដឹងថា នោះជាប្រទេសមន ដែលមាន ទីក្រុង ឬរាជធានីប្រាំ ។

[19] អានថា ហ្វូណាន បែបនេះទើបត្រឹមត្រូវតាមសំលេងភាសាចិន។ សូមមើល១៩៧៣, កំណត់ហេតុរបស់ ជីវតាក្វាន់ អំពីប្រពៃណីនៃអ្នកស្រុកចេនឡា, បោះពុម្ពផ្សាយលើកទី៣, បកប្រែជាភាសាខ្មែរ ដោយ លីធាមតេង, ទំព័រ៧៤ ។

របាយការណ៍ចិនអំពីហ្វូណាន ចាប់ផ្ដើមពីសតវត្សរ៍ទី៣។ ពេលនោះរដ្ឋអ៊ូ (Wu)របស់ចិនដែលស្ថិតនៅភាគខាងត្បូង និងនៅភាគអាគ្នេយ៍ កំពុងស្វែងរកផ្លូវសមុទ្រថ្មីកាត់តាមអាស៊ីអគ្នេយ៍ ទៅកាន់ឥណ្ឌា និងមជ្ឈិមបូព៌ា ក្នុងគោលបំណងដើម្បីប្រមូលទិញផលិតផលពីប្រទេសទាំងនោះ ក្នុងពេលដែលច្រកផ្លូវគោកពីចិនទៅឥណ្ឌាត្រូវបានបិទដោយគូប្រជែងចិន គឺរដ្ឋ វ៉ៃ និង រដ្ឋជិន។

បេសកទូតចិនដំបូងមកកាន់ហ្វូណានមានឈ្មោះ កងតៃ (Kang T'ai) និងជូយិង ដែលបានសរសេរកំណត់ហេតុយ៉ាងវែងអំពីហ្វូណាន។ កំណត់ដើមរបស់គាត់បានបាត់ទៅហើយ ប៉ុន្តែផ្នែកខ្លះត្រូវបានគេចម្លងទុកក្នុងប្រវត្តិសាស្ត្រចិនសម័យក្រោយ។ បញ្ហានៅក្នុងរបាយការណ៍ចិនទាំងនោះត្រូវគេសរសេរឡើងវិញរាល់សន្តតិវង្សនីមួយៗ ហើយនៅផ្នែកដែលនិយាយពីបរទេសត្រូវគេចម្លងឡើងវិញ ពេលខ្លះក៏មានការថែមថយ ឬលុបចោលដោយអ្នកចម្លង ដែលពួកគេនោះពុំមានចំណេះដឹងផ្ទាល់អំពីហ្វូណានទេ។ ដូច្នេះរឿងដដែលអំពីហ្វូណានមានលេចឡើងជាច្រើនដង ក្នុងសៀវភៅចិនផ្សេងៗគ្នា ដែលសរសេរចាប់ពីសតវត្សរ៍ទី៣ ដល់សតវត្សរ៍ទី១០ ដែលពុំដឹងថា តើការសរសេរឡើងវិញនោះផ្អែកលើមូលដ្ឋានរបាយការណ៍ថ្មីស្ដីអំពីហ្វូណាន ឬក៏បានមកពីការផ្លាស់ប្ដូរដែលកើតឡើងដោយអ្នកនិពន្ធចិននៅប្រទេសចិនទេ។

### 1.2. រាជធានី

អ្នកប្រាជ្ញបារាំង គឺលោក Paul Pelliot បានរកឃើញកំណត់ហេតុចិនចំនួន២១រឿង ដែលមានជំពូកនិយាយអំពីហ្វូណាន តែពុំបាននិយាយច្រើនទេអំពីរាជធានីរបស់ ហ្វូណាន។ សៀវភៅចិនមួយក្បាលសរសេរនៅសតវត្សរ៍ទី៧ បាននិយាយថា ទីក្រុងនេះមានចម្ងាយ៥០០លី(២០០គ.ម)ពីសមុទ្រ។ រីឯក្នុងរបាយការណ៍ចិនចុងក្រោយអំពីហ្វូណាន សរសេរក្នុងរាជវង្សថាំង(៦១៨-៩០៦) ពួកគេនិយាយថា រាជធានីនោះមានឈ្មោះថា ទិកមុក/dik-miuk ។ មានតែលោក Paul Pelliot និងលោក Etienne Aymonier ទេដែលបានគិតថា «អង្គរបុរី ជាទីតាំងប្រហាក់ប្រហែលនឹងដំណឹងនោះ» គឺនៅចន្លោះពីសមុទ្រ ឆ្ពោះទៅកាន់ទន្លេមេគង្គ ឬទន្លេបាសាក់។

លោក សឺដេស បានពន្យល់ថា ពាក្យ តូមូ-ទិកមុក គួរតែចិនហៅត្រាប់ពាក្យខ្មែរថា ទល្មាក់ ដែលក្លាយពីពាក្យ ទ្មាក់-អ្នកទាក់ ដែលចេញពីកិរិយាស័ព្ទដើមថា ទាក់ ។ ដោយសារល្បែងសំខាន់របស់ស្ដេចសម័យបុរាណ គឺការទាក់ដំរី ទើបគាត់សន្មត់ពាក្យ ទិកមុក-ទល្មាក់ ឬ ទ្មាក់ នោះឯងថា ទីក្រុងអ្នកទាក់ដំរី ។ តម្រុយនេះ នាំឱ្យគាត់ រំពឹងរកនៅក្នុងចំណោមឈ្មោះទីក្រុងទាំងឡាយជាភាសាសំស្ក្រឹត ដែលមានន័យដូចគ្នានេះ។ ពេលនោះ គាត់បានសន្មត់យកឈ្មោះទីក្រុងបុរាណមួយ គឺវ្យាធបុរៈ នៅសតវត្សរ៍ទី៧ដែលបានលេចឡើងនៅលើសិលាចារឹកវត្តព្រះធាតុប្រស្រីក្នុងស្រុកអូរាំងឪ ខេត្តកំពង់ចាម។ ព្រោះថា ឈ្មោះនេះមានន័យថា ទីក្រុងអ្នកទាក់ដំរី ដែរ។ តែតាមពិត នៅពេលលោក Michael Vickery ផ្ទៀងផ្ទាត់រឿងរ៉ាវនេះឡើងវិញ ឃើញថា ពាក្យ វ្យាធៈ ភាសាសំស្ក្រឹត គឺត្រូវនឹងភាសាបារាំងថា frapper ឬជាខ្មែរថា វាយ,ចាក់,កាប់,ទះ,តប់,ដំ ទៅវិញទេ។ វាមានន័យខុសគ្នាឆ្ងាយពីទាក់-ទ្មាក់-ទល្មាក់-តូមូ។ ក៏ប៉ុន្តែ បើទុកជាមានការលោតត្រដាងអំពីភាពខុសគ្នានៃអត្ថន័យរបស់ពាក្យទាំងពីរនេះក៏ដោយ ក៏លោកវិកឃើរី មិនបានបដិសេធថា រាជធានីរបស់ហ្វូណាន មិនមែនមានឈ្មោះថា វ្យាធបុរៈ ដែរ។

ការពិចារណារកទីតាំងរបស់ទីក្រុងនេះ នៅតែជាប្រធានបទសំខាន់រហូតដល់ពេលនេះ បើទោះបីជាតាំងពីយូរមកហើយលោក សឺដេស បានស្មានទុកថា វាប្រហែលជាស្ថិតនៅបាភ្នំក៏ដោយ។ គាត់ថា ទិកមុក /dik-miuk ស្ថិត

នៅបាភ្នំខេត្តព្រៃវែង[20] ដោយលោកប្រឹងពន្យល់អត្ថន័យតាមភាសាវិទ្យា គឺនៅតំបន់ក្បែរនោះនៅមានស្ថាននាមអនុស្សាវរីយ៍មួយចំនួនទាក់ទងនឹងដំរី ដូចជា ព្រៃដំរី, ក្បាលដំរី, ដំរីស្មុយ និងរោងដំរី។ ចំណែកសិលាចារឹកវត្តចក្រែតនាសតវត្សរ៍ទី១០ ដែលតាំងនៅជិតជើងភ្នំបាភ្នំ បានពិពណ៌នាអំពីការប្រតិស្ឋានព្រះសិវលិង្គឈ្មោះ វ្យាធបុរេស្វរៈ លើកំពូលភ្នំមួយ។ ភស្តុតាងនេះហើយ ដែលនាំឱ្យគាត់កាន់តែសង្ស័យថា ព្រះសិវលិង្គនោះឯង គួរតែត្រូវគេតម្កល់នៅលើភ្នំបាភ្នំតែម្តង។ ម្យ៉ាងទៀត តាមរបាយការណ៍អ្នកស្រាវជ្រាវខាងបុរាណវិទ្យាបង្ហាញថា នៅមានប្រាសាទមួយធ្វើអំពីឥដ្ឋ ដែលខូចខាតអស់នៅសល់តែខឿនមានទីតាំងនៅគោកខ្សាច់ ជើងភ្នំនោះឯង។[21]

ចាប់ពី១៩៩៦មក ការសិក្សាខាងបុរាណវិទ្យាបានចាប់ផ្តើមធ្វើទៅលើទីតាំងពីរ គឺនៅបាភ្នំ និងអង្គរបុរី ដោយបុរាណវិទូជប៉ុន និងអាមេរិករួមសហការដោយបុរាណវិទូខ្មែរនៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ។ កំណាយសាកល្បងនៅបាភ្នំ និងការពិនិត្យលើរូបថតពីអាកាស បាននាំឱ្យគេអះអាងថា នៅបាភ្នំគ្មានភស្តុតាងជាអតីតទីក្រុងបែបណាមួយនោះទេ។[22] ប៉ុន្តែកំណាយនៅវត្តគំនូរ និងការសិក្សាលើសំណល់បុរាណវត្ថុ និងរូបថតពីលើអាកាស នៅអង្គរបុរី បង្ហាញភស្តុតាងស្តីអំពីទីក្រុង ដែលមានចំណាស់តាំងពីមុនគ.ស. រហូតដល់យ៉ាងហោចណាស់សតវត្សរ៍ទី៧គ.ស.។ ត្រង់នេះប្រសិនបើគេធ្វើការពិចារណាឡើងវិញអត្ថន័យសិលាចារឹកវត្តចក្រែត ឃើញថា ភ្នំដែលគេតាំងអាទិទេពវ្យាធបុរេស្វរៈ អាចត្រូវនឹងភ្នំសិប្បនិមិត្តឈ្មោះបាទេព ឬក៏ភ្នំដារនៅអង្គរបុរីបានដែរ។ ចំណែកសិលាចារឹកបន្ទាយប្រាវ K. 222 នាសតវត្សរ៍ទី១១ដែលលោក សឺដេសធ្លាប់ពិភាក្សាម្តងរួចហើយនោះ[23] ផ្តល់ពត៌មានស្តីអំពីមន្ត្រីម្នាក់នៅស្រុកវ្រៃក្របាសនៃវ្យាធបុរៈ គឺលោញវ្រៃក្របាសវ្យាធបុរបានន័យថា លោញនៃស្រុកព្រៃក្របាសក្នុងដែនដីវ្យាធបុរៈ។ លោកសឺដេស យល់ថា ពាក្យនេះគ្រាន់តែចង់បញ្ជាក់ថា សូម្បីតែទឹកដីព្រៃក្របាស ក៏ស្ថិតនៅក្នុងអំឡុងដែនដីនៃនគរ វ្យាធបុរៈដែរ។ លើសនេះទៀតនៅសតវត្សរ៍ទី១៧ មានប្រភពមួយបញ្ជាក់ទាក់ទងនឹងតំបន់អង្គរបុរីនេះដែរថា ព្រៃក្របាសនគរាធិបតី គឺព្រៃក្របាសនៃរាជធានីធំជាងគេ ៗ[24] នៅសម័យក្រោយអង្គរ អតីតរាជធានីអង្គរបុរី ស្ថិតនៅក្នុងខេត្ត ឬ ស្រុកព្រៃក្របាស ចម្ងាយ២០គីឡូម៉ែត្រទិសខាងត្បូងពីទីប្រជុំជនផ្សារព្រៃល្វារបស់ស្រុកនេះ។

ហេតុដូច្នេះ បើទុកជាលោក ហ្សក សឺដេស មិនបានចាត់ទុកទិន្នន័យទាំងនេះជាភស្តុតាងយកជាការបាន ក៏គេនៅតែមើលឃើញថា វាអាចមានន័យថា រាជធានីវ្យាធបុរៈ ពិតជាត្រូវនឹងទីតាំងអង្គរបុរី ក្នុងអតីតខេត្ត-ស្រុកព្រៃកប្បាស ខេត្តតាកែវនេះបានដែរ។ ការអះអាងជាថ្មីនេះ មានលក្ខណៈស្របគ្នានឹងគំនិតរបស់លោក ល្វី ម៉ាឡឺរ៉េ *(Louis Malleret)* ដែលបានសង្ស័យថា អតីតទីក្រុងអង្គរបុរី គួរតែជារាជធានីរបស់ហ្វូណាននេះឯង តាំងពីទសវត្សរ៍១៩៥០មកម្ល៉េះ។

[20] Cf., *BEFEO,* XLVIII, pp. 1-6.

[21] Cf., *BEFEO,* XLVIII, pp. 209-220.

[22] ស.ម.,យ៉ាស៊ូស៊ី កូជូ និង ផេង ស៊ីថា, ១៩៩៥-៦, *សញ្ញាណដំបូងបុរេប្រវត្តិសាស្ត្រកម្ពុជា,* សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ។

[23] Cf., George Coedès, 1989, *Articles sur le pays khmer,* t. I, ed. Claude Jacques, Paris, EFEO, pp. 141-145 et *Inscriptions du Cambodge,* vol. II, Paris, EFEO, 1941, p. 331.

[24] Cf., George Coedès, 1937, *Inscriptions du Cambodge,* vol. I, Paris, EFEO, p.196, citée dans *Articles sur le pays khmer,* op. cit.

### 1.3. **អំពីពាក្យ ហ្វូណាន** 扶南

លោក ព្រូម ធ្លាប់ធ្វើការសិក្សាលើគ្រាប់ឈាមជនជាតិខ្មែរ និងព្នង។ គាត់ថា ជាតិពន្ធទាំងពីរនេះមានដើមកំណើតតែមួយដូចគ្នា។ ម្ល៉ោះហើយ ប្រហែលខ្មែរពីដើម ហៅខ្លួនឯងថា ព្នង ទើបពេលពួកចិនមកដល់ ឮខ្មែរជំនាន់នោះហៅខ្លួនឯងដូច្នោះ ក៏សរសេរគ្រាប់សូរតាម ទើបចេញជាពាក្យ ហ្វូណាន Funan/m ឬ ប៊ីយោ-ណាម Bio-nam នេះឡើង។

ចំណែកទ្រឹស្តីលោក ហ្សក សឺដេស បានពន្យល់ថា ចិនរាយការណ៍ថា ស្តេចហ្វូណានមានគោរម្យនាមជាគូឡុង ដែលចូលចិត្តយាងទៅធ្វើពិធីបូជាចំពោះព្រះផូតូលីនៅលើភ្នំមូតាន។ ព្រោះស្តេចធ្លាប់ជួបទេពនោះនៅលើភ្នំនោះឯង។ គាត់គិតថា ពាក្យចិនហៅ គូឡុង គឺគ្មានអ្វីក្រៅពីពាក្យ កុរុង ដែលមានន័យថាស្តេច របស់ខ្មែរតាំងពីបុរាណមកដល់សព្វថ្ងៃនោះទេ (កុរុង-ក្រុង)។ រីឯ ភ្នំនោះហើយ ដែលអាចក្លាយជារហស្សនាមរបស់ស្តេចពេលនោះ ដែលគេអាចហៅថា កុរុងវ្នំ ឬ ស្តេចភ្នំ។[25] ចៃដន្យ នៅកោះជ្វាសតវត្សរ៍ទី៨ ស្តេចនៅទីនោះ ដាក់រហស្សនាមរាជវង្សខ្លួនថាជា សៃលេន្ទ្រ ដែលមានន័យថា ស្តេចភ្នំ ដែរ។ ដូច្នេះលោក សឺដេស គិតថា ពាក្យ ហ្វូណាន Funan គួរតែជាសម្លេងដែលចិនគ្រាប់តាមពាក្យ វ្នំ vnam របស់ខ្មែរពេលនោះឯង។ ហេតុនេះហើយ ទើបអ្នកប្រាជ្ញខ្មែរជំនាន់មុនដែលបារាំងបង្រៀន ជឿជាក់លើរឿងនេះ ហើយនាំគ្នានិយមការបកប្រែពាក្យហ្វូណាន ថាជានគរភ្នំ វិញ ដែលមិនគួរឱ្យជឿបានឡើយ។

បញ្ហានេះ យើងជឿថា ហ្វូណាន 扶南 ជាឈ្មោះដែលចិនហៅខ្មែរ (Xenonym = ឈ្មោះដែលបរទេសហៅប្រទេស ឬមនុស្សនៃប្រទេសមួយផ្សេងទៀត)ដោយចង់មានន័យថា * *_អ្នកមានខាងត្បូង។ បើគេពិនិត្យមើលបញ្ហាបួនយ៉ាង ទី១-គឺការសរសេរចម្លងឡើងវិញជាច្រើនដងនូវរបាយការណ៍របស់ចិន ស្តីអំពីរឿងរ៉ាវនៅហ្វូណាន។ ជាពិសេស ឈ្មោះព្រះបាទហ៊ុនទៀន ដែលបានច្បាំងឈ្នះ និងយកព្រះនាងលីវយីធ្វើជាអគ្គមហេសី ត្រូវពួកចិនសរសេរប្តូរតួអក្សរទៅជាឈ្មោះ ហ៊ុនធេនផង និងហ៊ុនហួយផង។ ដូច្នេះ វាមិនអាចធានាថា អ្នកសរសេរចម្លងឡើងវិញនោះមិនបានកែអក្ខរាវិរុទ្ធដើមនៃពាក្យហ្វូណាន(Funan)_ ពីរព្យាង្គនេះបានឡើយ។ ទី២-បើពិចារណាលើទម្លាប់របស់មនុស្សលើលោកនេះហៅឈ្មោះជនជាតិដទៃ គេនឹងឃើញភស្តុតាងជាច្រើនថា នៅសម័យបុរាណប្រជាជាតិមួយតែងតែហៅជាតិពន្ធផ្សេងក្រៅពីខ្លួនដោយមិនចាំបាច់គោរពតាមពាក្យ ដែលជនជាតិដទៃនោះហៅខ្លួនឯងឡើយ។ ដូចជា ខ្មែរហៅវៀតណាមថាយួន, ហៅភារ័ត (Bhārat)ថាក្លិង្គ, ហៅអឺរ៉ុបថាបារាំង,ហៅចុងក័រថាចិនតាមសំស្រ្កឹត។ ចំណែកបារាំង ឬអង់គ្លេសហៅភារ័ត (Bhārat) ថា Inde ឬ India, វៀតណាមហៅសូវៀតថា លៀនសូ។ រីឯចិនហៅខ្មែរសម័យអង្គរថា **ចេនឡា** បើទុកជាជីវតាក្វាន់បញ្ជាក់ថា ជនជាតិនេះហៅខ្លួនឯងថា កាមពូចី ក៏ដោយ។[26] ទី៣-យើងកត់សម្គាល់ឃើញថា ស្ថាននាមភាគច្រើននៅភាគខាងត្បូងនៃប្រទេសចិន តែងតែមានឈ្មោះជាប់នឹងពាក្យ «ខាងត្បូង» ដែលចិនហៅថា 南 ណាន (ឬ ណាម)ជានិច្ច ដូចជាឈ្មោះ ណានជីង 南京 , យូណាន 云南 , ហឺណាន 河南 , ជាំងណាន 江南, ហៃណាន 海南 . និងវៀតណាម 越南 ជាដើម។ ហេតុនេះហើយ ពាក្យហ្វូណាន ឬហ្វុណាម គួរតែជាពាក្យដែលចិនហៅសម្គាល់ខ្មែរ និងសរសេរ ដោយមិនគ្រាប់តាមពាក្យខ្មែរហៅខ្លួនឯងឡើយ។ គ្រាន់តែព្យាង្គទីមួយនៃឈ្មោះនេះគ្មានន័យអ្វីឲ្យប្រាកដប្រជាឡើយ។ ទី៤-វៀតណាមមានទម្លាប់តាំងពី

---

[25] ស.ម., ត្រឹង ងា (១៩៧៣), ប្រវត្តិសាស្រ្តខ្មែរ, ភាគ១, ភ្នំពេញ, ទំព័រ៨០។

[26] ស.ម., ១៩៧៣, _កំណត់ហេតុរបស់ ជីវតាក្វាន់ អំពីប្រពៃណីនៃអ្នកស្រុកចេនឡា_, បោះពុម្ពផ្សាយលើកទី៣, បកប្រែជាភាសាខ្មែរ ដោយ លីធាមតេង, ទំព័រ៧៤។

បុរាណមកហៅខ្មែរថា ការមៀន (Cao Mien)ដែលមានន័យថាអ្នកមានខ្ពង់ខ្ពស់។[27] ប្រសិនបើ គេតាមដានពត៌មានពីប្រភពចិន ដែលតែងតែមានឥទ្ធិពលលើវៀតណាម បានពិពណ៌នាថា នៅហ្វូណានមានភោគទ្រព្យធម្មជាតិស្តុកស្តម្ភ, ក្នុងទឹកសំបូរត្រី លើដីគោកសំបូរសត្វព្រៃ និងមានសត្វស្លាបគ្រប់ប្រភេទលើសពីសត្វនៅស្រុកចិន អាកាសធាតុល្អងាយស្រួលរស់នៅ ដីមានជីរជាតិងាយស្រួលដាំដុះដំណាំ ជាប្រទេសដែលសំបូរទំនិញដែលចិនត្រូវការ និងបានក្លាយជាដៃគូពាណិជ្ជកម្មផ្តាច់មុខដ៏សំខាន់ជាមួយគ្នារហូតដល់ជិត៣០០ឆ្នាំ។ ក្រៅពីនេះ នៅក្នុងស្រុកនេះសំបូរទៅដោយផលិតផល ដែលទីផ្សារស្រុកចិននិយមចង់បាន។ ក្រោយមកនៅសតវត្សរ៍ទី១៦បព្វជិតគ្រិស្តសាសនាលោកសាន អាន្តូនីញ៉ូ បានសរសើរអំពីភាពសំបូររបស់កម្ពុជា[28] ដូចពួកបារាំង និងយួនឈ្មោះ ជឿងវិញគីដែរ។[29].ដូច្នេះព្យាង្គទី១ ដែលចិនបានសរសេរ ដំបូង គួរតែជាពាក្យ ហ្វុ ឬ ហ្វូ 富 ដែលមានន័យថា *សម្បូណ៌ទ្រព្យសម្បត្តិ* ឬ *អ្នកមាន* (Rich) ដូចគ្នានឹងគំនិតរបស់យួនបុរាណចំពោះខ្មែរដែរ ហើយពាក្យបន្ទាប់ថា *ណាន*.南*.* ឬ *ណាម* មានន័យថា *ខាងត្បូង* ដូចពាក្យ *វៀតណាម* ដែលមានន័យថា *វៀតខាងត្បូង* ដូច្នោះដែរ។ សរុបសេចក្តីមក បើតាមភាសាចិនកុកងឺ (Mandarin Chinese) នេះ ប្រហែលជាចិនហៅថា *ហ្វូណាន.*富南*.* ដោយឲ្យន័យថាជា *ប្រទេសអ្នកមានខាងត្បូង* ឬ *មហាសាលខាងត្បូង* (Rich South) *ទៅវិញទេ។*

**2. ចេនឡា** 真腊

បើតាមរបាយការណ៍ចិន បានឱ្យដឹងអំពីរដ្ឋដែលមានឈ្មោះថា ចេនឡា 真蠟 នៅដើមសតវត្សរ៍ទី៧។ ចេនឡាគឺពិតជារដ្ឋខ្មែរមួយផ្សេងទៀត ដែលចំណុះឱ្យរដ្ឋហ្វូណាន។ បើតាមការពន្យល់របស់លោក លី ជាមតេង ចេនឡា 真 (Pure) + 蠟 / 腊(Bee Wax)គួរតែមានន័យថា «ក្រមួនសុទ្ធ»។[30] ពោលគឺជាឈ្មោះ ដែលចិនដាក់ឱ្យទៅតាមការកត់សម្គាល់របស់ខ្លួន។ នោះប្រហែលមកពីចេនឡា មានផលិតផល«ក្រមួនសុទ្ធ»សម្រាប់ដោះដូរជាមួយពួកឈ្មួញចិនទើបចិនហៅឈ្មោះរដ្ឋនេះដូច្នេះ។ ចំណុចខុសគ្នាចម្បងរវាងហ្វូណាន និងចេនឡា គឺត្រង់ថា ចំណេះដឹងដែលយើងមានអំពីហ្វូណានភាគច្រើនបានមកពីចិន និងការសិក្សាបុរាណវិទ្យាពីសម័យបុរេប្រវត្តិសាស្ត្រ។ ចំណែករដ្ឋចេនឡាចិនកត់ត្រាបានតែបន្តិចបន្តួចប៉ុណ្ណោះ តែសម័យកាលចេនឡាដែលចិនថា បានចូលមកតពីសម័យនគរភ្នំនោះ យើងអាចសិក្សាបានកាន់តែច្បាស់ជាងសម័យហ្វូណាន ដោយសារការលេចឡើងយ៉ាងច្រើននៃឯកសារសិលាចារឹកនៅក្នុងស្រុក។

ចិនបាននិយាយក្នុងកំណត់ហេតុចុងក្រោយរបស់គេកាលពីសតវត្សរ៍ទី៧ថា ចេនឡា ដែលជាតំបន់ស្ថិតនៅខាងជើង និងជាអតីតសមន្តរដ្ឋរបស់ហ្វូណាន។ របាយការណ៍ចិនសរសេរថា ចេនឡាស្ថិតនៅក្រោមការគ្រប់គ្រងរបស់ហ្វូណាន បានវាយឈ្លានពានហ្វូណានក្រោមការដឹកនាំរបស់ស្តេចចិត្រសេន និងបុត្រារបស់ទ្រង់ឥសានវម៌្មទី១ នៅទីបញ្ចប់ចេនឡាឈ្នះ។ ចាប់ពីពេលនោះមកចិនបានប្រើឈ្មោះ″ចេនឡា″សម្រាប់ហៅឈ្មោះប្រទេសកម្ពុជា។

[27] ប៉ុន្តែព្រះភិក្ខុ ប៉ាងខាត់ បានសរសេរថា ការមៀន ដូច្នេះ។ ស.ម. ប៉ាង ខាត់, (១៩៥៧) ពុទ្ធសាសនា២៥០០, ពុទ្ធសាសនបណ្ឌិត្យ, ទំព័រ ???។ នៅទំព័រ៣២៦លោក ជឿងវិញគី សរសេរថា ពួកអាណ្ណាមហៅខ្មែរថា ²កៅមែន³ (Cao-mên)។ Cf., Pétrus Trüong Vinh-Ky, « Notice sur Le Royaume de Khmer ou de Kambodje », *Bulletin de la Société de Géographie,* tome VI (Juillet-Décembre 1863) : pp. 326-332.

[28] Cf., David Chandler, (2000). *A History of Cambodia,* 3rd Ed., Silkworm Books, Thailand, p. 87, (Khmer version, 3rd Ed. 2009-12, p. 101);

[29] ស.ម., ត្រឹងងា, ឯកសារដដែល, ទំព័រ ១០២-១០៣ និងជីវ តាក្វាន់, ឯកសារដដែល។ Pétrus Trüong-Vinh-Ký, “Notice sur le royaume de khmer ou de kambodje (1)” *Bulletin de la Société de Géographie,* t. VI (1863): 326-332.

[30] ស.ម., ១៩៧៣, *កំណត់ហេតុរបស់ ជីវតាក្វាន់...* ទំព័រ៧៤ ទំព័រ ៧៣-៥។

កាលបរិច្ឆេទចេនឡាដំបូងក្នុងរបាយការណ៍ចិន គឺឆ្នាំ៦១៦ និងការពោលអំពីឈ្មោះហ្វូណានចុងក្រោយបង្អស់ គឺនៅវាងឆ្នាំ៦២០-៦៤០។

ដូច្នេះទីតាំងចេនឡាគួរតែត្រូវនឹងខាងលិចនៃប្រទេសលិនយី លើដងទន្លេមេគង្គភាគខាងលើ។ មានការពិភាក្សារកទីតាំងរាជធានីរបស់ប្រទេសនេះ ដែលអាចមានអត្ថិភាពពីសតវត្សរ៍ទី៥ និងបានល្បីល្បាញនៅសតវត្សរ៍ទី៦។ ការកំណត់របស់លោក សឺដេស ដំបូងថា វាគួរតែនៅជិតវត្តភូ ដែលជាអតីតទីក្រុងកុរុក្សេត្ររបស់ស្តេចទេវានីកនៅសតវត្សរ៍ទី៥ និងបន្ទាប់មកជាទីក្រុងរបស់ស្តេចស្រុតវរ្ម័ន និងស្រេស្ឋវរ្ម័ន ជាបច្ឆាជនរបស់ឫសីកម្ពុ និងអប្សរមេរា ដែលបានបង្កើតទីក្រុងឈ្មោះស្រេស្ឋបុរៈនៅក្នុងតំបន់ជាមួយគ្នានោះដែរ។[31] បន្ទាប់មក លោក ប៉ុល ឡេវី បានធ្វើការសិក្សាអំពីស្ថានីយបុរាណវិទ្យានៅថលាបរិវ៉ាត់ ហើយបានសន្និដ្ឋានថា ទីនោះជាទីក្រុងភវបុរៈ របស់ស្តេចចេនឡានាមភវវរ្ម័នទី១។[32] ក្រោយមកទៀត លោក សឺដេស បានសន្និដ្ឋានថា ទីក្រុងភវបុរៈរបស់ចេនឡា គួរតែនៅក្បែរតំបន់អំពិលរលើង ឃុំចំណារលើស្រុកស្ទោងវិញ បើតាមសិលាចារឹកK. 162 នៅទីនោះ ។ ប៉ុន្តែ ចុងក្រោយនេះ លោក ក្លូដ ហ្សាក់ (Claude Jacques) និងលោក វិកឃើរី (Michael Vickery) បានសន្និដ្ឋានថា ទីក្រុងរបស់ចេនឡា គួរតែត្រូវនឹងអតីតទីតាំងសម្បូណ៌ព្រៃគុហ៍ ដែលនៅក្នុងរាជ្យព្រះបាទឥសានវរ្ម័នទី១ បានកសាងដោយដាក់ឈ្មោះទៅតាមព្រះនាមរបស់ព្រះអង្គថា ឥសានបុរៈ ហើយចុងក្រោយព្រះបាទភវវរ្ម័នទី២ កសាងបន្តទៀត ហើយដាក់នាមថា ភវបុរៈ ដូចគ្នានឹងបច្ឆាមរណនាមរបស់ព្រះអង្គដែរ។

សារៈសំខាន់របស់ប្រទេសចេនឡា បានលេចឡើងដោយសារក្នុងសៀវភៅប្រវត្តិសាស្ត្ររបស់លោកហ្សកសឺដេស និងត្រឹង ងា ដោយសារ ចិនបានចាប់ផ្តើមសរសេរក្នុងរបាយការណ៍របស់ខ្លួននៅដើមសតវត្សរ៍ទី៧ នោះថាបានវាយប្រហារហ្វូណាន នៅពេលនោះហើយដែលហ្វូណាន បញ្ជូនបេសកទូតសុំជំនួយទ័ពពីចិន៣ដង បន្តបន្ទាប់គ្នា ឆ្នាំ៥២៣-៥៤០។ ប៉ុន្តែលោក វីកឃើរី ថាវាមិនពិតទេ ពីបញ្ហាស្តីពីការប្រយុទ្ធគ្នារបស់ចេនឡាជាមួយអាណាចក្រភ្នំ ព្រោះលោកផ្អែកលើភស្តុតាងពីរ។ ទី១- ព្រះបាទភវវរ្ម័នទី១ ដែលគេនាំគ្នាថាជាស្តេចនៃប្រទេសចេនឡានៅពេលនោះ។ ដូចជា សិលាចារឹកប្រាសាទជ្រៃ K.149 បានឱ្យដឹងថាព្រះអង្គធ្លាប់ធ្វើអំណោយដល់ប្រាសាទនោះ ដែលជាភស្តុតាងថា ព្រះអង្គបានគ្រប់គ្រងភាគកណ្តាលនៃកម្ពុជារួចស្រេចហើយ មុនដំណាច់សតវត្សរ៍ទី៦។ មានសិលាចារឹកជាច្រើនបញ្ជាក់ថា ព្រះអង្គជាក្សត្រនៃរាជវង្សសោមវង្ស និងប្រហែលជាចៅ(នត្តា)របស់ព្រះបាទរុទ្រវរ្ម័ន។ ដូច្នេះ បើមានសង្គ្រាម គឺជារឿងស្របច្បាប់ដែលក្សត្រអង្គនេះធ្វើឡើងដើម្បីផ្តួលរំលំក្សត្រមួយអង្គទៀត ដែលជាសត្រូវព្រះអយ្យកោរបស់ខ្លួន។ ចំណែករឿងរ៉ាវបានពីសិលាចារឹកប្រាសាទតាព្រហ្ម ដែលគេបានបកប្រែថា ព្រះបាទភវវរ្ម័នទី១ ឡើងសោយរាជបានដោយសារព្រះមហេសីនាម កម្ពុជរាជលក្ស្មី ដែលជាស្តេចនៃចេនឡានោះ ត្រូវបានបដិសេធដោយលោក ក្លូត ហ្សាក់ នៅពេលគាត់អាន និងផ្ទៀងផ្ទាត់ការបកប្រែនោះឡើងវិញ។ ម៉្លោះហើយ ភវវរ្ម័នទី១ ជាបុត្រាព្រះបាទប្រថិវីន្ទ្រវរ្ម័ន និងជាចៅនៃស្តេចចក្រពត្តិ ឬសាវ៉កៅមនៃប្រទេសហ្វូណាន។ ទី២–គេសង្កេតឃើញសិលាចារឹកមួយនៅក្តីអង្គ ឬអង្គជំនីក(K.53)បានរៀបរៀបរាប់ពីក្រុមគ្រួសារមួយ ដែលជាមន្ត្រីជំនិតបម្រើព្រះរាជាអស់៥ជំនាន់ ចាប់តាំងរាជ្យ ព្រះបាទរុទ្រវរ្ម័នហូតមកដល់រាជ្យជយវរ្ម័នទី១។ ព្រឹត្តិការណ៍បែបនេះ គឺជារឿងកម្រនឹងកើតមានណាស់នៅសម័យបុរាណ។ ព្រោះអ្នកឈ្នះ ឬអ្នកស្នងតំណែងមិនស្របច្បាប់ មិនដែលទុកចិត្ត និងយកមន្ត្រីរបស់ស្តេចដែលជាសត្រូវ មកប្រើប្រាស់ឡើយ។

---

[31] Cf., *BEFEO*, XVIII(9), pp. 1-9.

[32] Cf., Paul Lévy, «Thala Bŏrivăt ou Stu'ṅ Trèṅ: sites de la capitale du souverain khmer Bhavavarman Ier», *Journal Asiatique* 258 (1970), pp. 113–129.

ផ្ទុយពីខ្លឹមសារឯកសារចិន ក្រោយពីហ្វូណាន លែងបន្សល់ភស្តុតាងចាប់ពីក្រោយរជ្ជកាលព្រះបាទរុទ្រវរ្ម័ន នៅចុងសតវត្សរ៍ទី៦គេឃើញមានសិលាចារឹករបស់ព្រះបាទភវវរ្ម័នទី១ និងចិត្រសេន-មហេន្ទ្រវរ្ម័ន ដែលជាបងប្អូនប្រុសបង្កើតនឹងគ្នា ដែលជាក្សត្រខាងសោមវង្សរបស់ហ្វូណាន។ ហើយឯកសារចិនថា ព្រះបាទចិត្រសេនជាមេទ័ពរបស់ភវវរ្ម័ន បានបន្តការវាតទីមកលើហ្វូណាន។ ដូច្នេះ សង្គ្រាមដែលចិនបានកត់ត្រានោះ គួរតែជាសង្គ្រាមដើម្បីដណ្តើមយកដែនដីកេរ្តិ៍របស់ដូនតាខ្លួន និងបង្រួបបង្រួមទឹកដីចេនឡាដែលខ្លួនកំពុងគ្រប់គ្រងជាមួយហ្វូណាន ដែលធ្លាប់ជាមជ្ឈមណ្ឌលរាជាធិរាជអំណាចកណ្តាល។

ចាប់តាំងពីដើមសតវត្សរ៍ទី៧ ក្នុងរាជ្យព្រះបាទ មហេន្ទ្រវរ្ម័ន, ឥសានវរ្ម័នទី១, ភវវរ្ម័នទី២, រហូតដល់ជយវរ្ម័នទី១ ការធ្វើសញ្ជ័យយកដែនដីនៅឯនាយខាងលិច និងពាយព្យ ដាក់ឱ្យនៅក្រោមអំណាចរាជាធិរាជដូចពេលមុន មិនទាន់បានសម្រេចនៅឡើយ។ លោក វិកឃើរី ថាមកដល់រជ្ជកាលព្រះបាទជយវរ្ម័នទី១ មានភស្តុតាងថា ដណ្តើមបានកាន់តែធំជាងពេលមុនៗ ហើយប្រហែលជាបានសម្រេចនៅក្នុងរជ្ជកាលព្រះមហាក្សត្រិយានី ជយទេវី នាចុងសតវត្សរ៍ទី៧ និងដើមទី៨។ ប៉ុន្តែ បើតាមសិលាចារឹក K. 1142 ដែលគេទើបសិក្សា គ្មានភស្តុតាងអ្វីដែលថា ទឹកដីចេនឡា មុនរាជ្យព្រះបាទជយវរ្ម័នទី១ មិនទាន់ឯកភាពដល់តំបន់ខាងជើងល្វោ-លពបុរីសព្វថ្ងៃនោះដែរ។[33]

## 3. សេដ្ឋកិច្ច និងនយោបាយ

### 3.1. ការបង្កើតរដ្ឋ

នៅខាងដើមបានរៀបរាប់រួចមកហើយ អំពីការចែកប្រវត្តិសាស្ត្រខ្មែរនាសម័យមុនអង្គរ។ នៅក្នុងសម័យកាលទី១ ជាសម័យកាលដែលទាក់ទងនឹងការបង្កើតរដ្ឋ ឬព្រះរាជាណាចក្រខ្មែរ។ តាមប្រភពឯកសារចិន ដែលនិទានអំពីប្រមុខអ្នកដឹកនាំខ្មែរដំបូងជាស្ត្រីឈ្មោះ លីវយី ទំនងការដឹកនាំរបស់ព្រះនាងមានរចនាសម្ព័ន្ធជា"រដ្ឋាភិបាល" មួយ ជាយន្តការគ្រប់គ្រងស្រុករួចស្រេចទៅហើយ។ បន្ទាប់ពីការអភិសេកជាមួយហ៊ុនទៀន ទំនងជាខាងនយោបាយ បានបន្ថែមយន្តការគ្រប់គ្រងកាន់តែមានប្រសិទ្ធភាពជាងមុន ដោយសារស្តេចអង្គនេះ បានទទួលឥទ្ធិពលនៃមនោគមវិជ្ជាគ្រប់គ្រងរដ្ឋរបស់ឥណ្ឌា។

បើគេពឹងផ្អែកលើឯកសារប្រវត្តិសាស្ត្រចិន ស្តីអំពីមន-ខ្មែរ និងបុរាណវត្ថុនានាដែលស្ថិតក្នុងភូមិភាគឥណ្ឌូចិនសព្វថ្ងៃនេះ គេអាចសង្កេតឃើញថាកុលសម្ព័ន្ធមន-ខ្មែរទាំងអស់មានតែជនជាតិមន-ខ្មែរ និងចាម្បទេ ដែលបានបង្កើតរដ្ឋមុនដំបូងគេបង្អស់។ កន្លងមកគេក្នុងសៀវភៅរបស់គាត់លោកត្រឹងងា ធ្លាប់គិតថា៖ នៅកំឡុងក្រោយការបែកបាក់របស់ហ្វូណាន "មន"បែកចេញពីខ្មែរ ហើយតាំងនគររបស់ខ្លួនឈ្មោះថា ទ្វារវតីនៅចុងសតវត្សរ៍ទី៦។ ប៉ុន្តែនៅតំបន់ក្បែរអនាគតទីក្រុងអយុធ្យាខាងត្បូងទីក្រុងលវោទ័យគឺលពបុរីប្រមាណ១០០គ.ម. នាដើមសតវត្សរ៍ទី៧ គេរកឃើញសិលាចារឹករបស់ព្រះបាទហស់វរ្ម័នដែលអះអាងថា ព្រះអង្គជារាជនត្តាព្រះបាទឥសានវរ្ម័នទី១។ សូមបញ្ជាក់ថា ក្នុងកុលសម្ព័ន្ធមន-ខ្មែរ មានតែខ្មែរទេដែលនៅមានរដ្ឋប្រជាជាតិរបស់ខ្លួនគង់វង្សស្ថិតស្ថេររហូតដល់សព្វថ្ងៃនេះ។

តាមទ្រឹស្តីចាស់ថា វប្បធម៌ អារ្យធម៌ឥណ្ឌាបានហូរចូលយ៉ាងសកម្មតាមរយៈអ្នកជំនួញឥណ្ឌា មកក្នុងតំបន់ឥណ្ឌូចិន ដែលឥណ្ឌាធ្លាប់ហៅថា សុវណ្ណភូមិ គឺ«ដែនដីមាស»។ តាមការស្រាវជ្រាវរបស់អ្នកប្រាជ្ញ G. សឺដេស

[33] Cf., Claude Jacques, *Claude Jacques, "Le pays khmer avant Angkor", dans Journal des savants, janvier-septembre*, 1986, pp. 56-95.

ការហូរចូលនៃវប្បធម៌-អារ្យធម៌ក្លិង្គ បណ្ដាលឱ្យមានការបង្កើតរដ្ឋជាច្រើន ពិសេសរដ្ឋខ្មែរក្នុងភូមិភាគនេះ។ ហ្វូណាន ដែលជាអាណាចក្រមួយយ៉ាងធំ បានកើតឡើងដោយការផ្ដុំគ្នានៃកុលសម្ព័ន្ធមន-ខ្មែរនានា ឬកូនសង្គមតូចៗទូទាំងផ្ទៃឥណ្ឌូចិន ដោយមានអំណាចកណ្ដាលជាគ្រឹះស្នូល។ ដូចរដ្ឋហ្វូណានដែរ ចេនឡានៅខាងជើងហ្វូណានកកើតឡើង ដោយការបង្រួបបង្រួមនៃកូនសង្គមតូចៗទាំងឡាយដោយកម្លាំងទ័ព និងឥទ្ធិពលព្រហ្មញ្ញសាសនាជាគ្រឹះ។

ការសិក្សាសិលាចារឹក, ឯកសារចិន និងវត្ថុបុរាណក្នុងអតីតអាណាចក្រខ្មែរ បង្ហាញឱ្យឃើញថា នៅសតវត្សរ៍ទី៥-៦ ប្រទេសកម្ពុជាបុរាណគ្រប់គ្រងដោយព្រះរាជវង្សានុវង្ស ឬសន្តតិវង្សខ្មែរពីរក្រុមខុសគ្នា។ ក្រុមទី១ តាំងរាជធានីនៅវ្យាធបុរៈសព្វថ្ងៃនៅអង្គរបុរី ខាងត្បូងស្រុកព្រៃកប្បាស ខេត្តតាកែវដែលជាទីតាំងទាប។ មួយក្រុមទៀតតាំងនៅប៉ែកខាងលើ ម្ដុំវត្តភូ ខេត្តចម្ប៉ាសាក់របស់ឡាវសព្វថ្ងៃ ដែលគេហៅថា «ស្រេស្ឋបុរៈ»បច្ចាជននៃវង្សកម្ពុ ដែលលោកសីដេសថា ពួកចេនឡា។ បន្ទាប់មកនៅសតវត្សរ៍ទី៨ បើតាមលោក វិកឃើរី (១៩៨៩)ថា អាណាចក្រដែលមានអំណាចទី២ ទំនងជានៅ "សម្ភុបុរៈ"ត្រូវនឹងតំបន់ស្រុកសម្បូណ៌ ខេត្តក្រចេះ និងមួយទៀតនៅតំបន់ជុំវិញបឹងទន្លេសាប។ ប៉ុន្តែបើតាមខ្ញុំសិក្សាសិលាចារឹកទើបរកឃើញថ្មីៗនៅស្រុកខ្មែរ និងស្រុកថៃសព្វថ្ងៃ ចាប់ពីរវាងជិតពាក់កណ្ដាលសតវត្សរ៍ទី៨ មានអាណាចក្រខ្មែរសំខាន់ៗ៤ផ្សេងគ្នា គឺសម្ភុបុរះ នៅក្រចេះ, អនិន្ទិតបុរៈនៅស្រុកសង្កែ ខេត្តបាត់ដំបង, វ្យាធបុរៈនៅខេត្តតាកែវ (Ka 4, Ka 63) និងអាណាចក្ររបស់ព្រះបាទជយសិង្ហវម៌្មនៅតាមដងទន្លេមូលនៅភូមិភាគឥសាននៃស្រុកថៃសព្វថ្ងៃ។

### 3.2. សេដ្ឋកិច្ច

តាមឯកសារចិន ដែលបាននិយាយអំពីសារៈសំខាន់នៃទីក្រុងកំពង់ផែសមុទ្រអូរអែវ និងការរកឃើញទីតាំងរាជធានីរបស់ហ្វូណាននៅអង្គរបុរី ដែលមានភូមិសាស្ត្រក្នុងតបន់ត្រូវលិចទឹក៦ខែ និងគោក៦ខែនោះ គេអាចសន្និដ្ឋានស្របគ្នាថា សេដ្ឋកិច្ចហ្វូណាន គួរតែពឹងផ្អែកលើវិស័យពាណិជ្ជកម្មជាធំ តាំងពីស.វ.៣-៦។ ចំណែកចេនឡាដែលបោះបង់ចោលនូវតំបន់អង្គរបុរីដ៏ពិបាករស់នៅនេះ ទៅតាំងនៅតំបន់ដីខ្ពស់ដែលសំបូរដោយវាលស្រែ និងស្លាកស្នាមប្រព័ន្ធបង្ហូរទឹក ជាសញ្ញាបង្ហាញថា សកម្មភាពកសិកម្មបានជំនួសតួនាទីពាណិជ្ជកម្មពីសម័យមុន។

កំណត់ហេតុចិនថា អាណាចក្រនគរភ្នំបានផលិតនូវទ្រព្យសម្បត្តិ ដូចជាមាស, ប្រាក់,ស្ពាន់, សំណបាហាំង,ភ្លុកដំរី, កុយរមាស, ក្រមួន, គុជ, គ្រឿងឈើក្រអូប។ល។ ធ្វើអង្កាំអំពីកែវស្លអង្កាំថ្ម, ចេះច្នៃមាសយ៉ាងប្រណិត ច្រើនសន្ធឹកសន្ធាប់ ខ្មែរសម័យនោះមានជំនាងជាងទងយ៉ាងស្ទាត់ជំនាញ,ខ្មែរប៉ិនប្រសព្វធ្វើចិញ្ចៀន,កងដៃ, ក្រវិល, អំពីមាស, ប្រាក់, ស្ពាន់, សំណ, ចានក្បានប្រាក់ខ្មែរប្រសប់សូន្យរូប ត្បាញសូត្រចរបាប់ និងស្លកែវ។ វឌ្ឍនភាពរបស់ហ្វូណាន បណ្ដាលមកពីពាណិជ្ជកម្មអន្តរជាតិ និងកសិកម្ម។ នៅសម័យនេះ,ខាងវិស័យពាណិជ្ជកម្ម ខ្មែរបានទាក់ទងនឹងឈ្មួញរ៉ូម៉ាំង និងក្រិច។ ការសន្និដ្ឋានបែបនេះ ដោយសារគេរកឃើញកាក់ធ្វើអំពីប្រាក់,សំណ,ទង់ដែង,មាស ជាពិសេសនៅកំពង់ផែអន្តរជាតិអុកអែវ, កំពង់ផែធំបំផុតរបស់ហ្វូណាននៅស្រុកអង្គរបុរី(តាកែវ) និងអ៊ូទង(ខេត្តស៊ុផាន់បុរី) សព្វថ្ងៃគេប្រទះឃើញកាក់បុរាណទាំងអស់នេះដែរ មានរូបព្រះអាទិត្យមួយកំណាត់រូបស្រីវត្ស រូបខ្យងស័ង្ខជាដើម។

ខឿនសេដ្ឋកិច្ចសម័យចេនឡាសំខាន់គឺ កសិកម្ម ពោលគឺធ្វើស្រែវស្សា,ចំការ និងច្បារដំណាំ, ការចិញ្ចឹមសត្វពាហនៈ,ផ្សាំងសត្វ និងនេសាទ។ ម្ល៉ោះហើយវឌ្ឍនភាពនៃវប្បធម៌ អារ្យធម៌នាសម័យនោះ មានការប្រែប្រួល ដោយសារការផ្លាស់ប្ដូរផ្លូវជំនួញតាមសមុទ្ររបស់ចិនចាប់ពីសតវត្សរ៍ទី៧។ សូម្បីតែទីក្រុងទឹកនៅអង្គរបុរី ដែលធ្លាប់មានអត្ថិភាពរាប់រយឆ្នាំមកហើយនោះ ក៏ត្រូវបោះបង់ចោល ហើយព្រះរាជាទៅកសាងមូលដ្ឋានទីក្រុងថ្មីមួយទៀត នៅតំបន់ដីគោកវិញត្រង់ឥសានបុរៈ តំបន់សម្បូណ៌ព្រៃគុហ៍សព្វថ្ងៃ។ លើសនេះទៀត ការប្រែប្រួលនេះ ជាការបង្ហាញ

ឱ្យឃើញថា  មកពីស្តេចចេនឡា  ជាអ្នកធ្លាប់រស់នៅស៊ាំជាមួយប្រពៃណីវប្បធម៌នៅលើដីគោក  ដែលគ្មានទឹកលិចរំខានដល់ទៅ៦ខែរៀងរាល់ឆ្នាំដូចស្តេចហ្វូណាន។

### 3.3. នយោបាយ

តាមសិលាចារឹកព្រះមហាក្សត្រហៅខ្លួនឯងជា រាជាធិរាជ មានន័យថា"ស្តេចនៃស្តេចទាំងឡាយ" គឺអនុវត្តន៍នយោបាយឱ្យមានក្សត្របុរីចំណុះជាច្រើន  ដែលមានស្តេចមួយអង្គៗសោយរាជ្យ  ក្រោមអំណាចរបស់ស្តេចមជ្ឈិមមួយអង្គ។ បុត្រាឬចៅរបស់ព្រះបាទហ៊ុនទៀន និងលីវយី ឈ្មោះ ហ៊ុន ប៉ាន់ហួង ត្រូវចិនកត់ត្រាថា បានទទួលបុព្វសិទ្ធិគ្រប់គ្រងនគរ៧ម្នាក់ឯង។  បន្ទាប់ពីគាត់ឡើងសោយរាជ្យ  ទីក្រុងទាំងអស់នោះត្រូវបានទៅកូន  និងចៅរបស់គាត់គ្រប់គ្រងជាបន្តទៀត។[34] នេះហើយជារចនាសម្ព័ន្ធត្រួតត្រាទឹកដី បែបស្តេចចក្រពត្តិ ឬ រាជាធិរាជ។ ក្នុងសម័យដ៏មហារុងរឿងនោះ ប្រទេសខ្មែរមានទឹកដីធំធេងអស្ចារ្យ ដែលលាតសន្ធឹងលើមួយភាគធំនៃអាស៊ីអាគ្នេយ៍ដីគោក គឺប្រទេសលាវ,សៀម(ថៃ), វៀតណាមខាងត្បូង,ព្រះរាជាណាចក្របច្ចុប្បន្នទាំងមូល ព្រមទាំងភាគខ្លះនៃប្រទេសភូមា និងជ្រោយម៉ាឡាយូ។ ព្រោះចិនបានកត់ត្រាថា បណ្តាកំពង់ផែចាប់ពីឆ្នេរសមុទ្ទចាម្ប ដល់ជ្រោយម៉ាឡេតំបន់ស៊ីងខ្លា និងឆ្នេរភាគខាងលិចនៃឧបទ្វីបនេះ  ខាងឆ្នេរសមុទ្ទបេងហ្គាល់សព្វថ្ងៃ  សុទ្ធតែស្ថិតក្រោមការត្រួតតារបស់ពួកហ្វូណាន។ តែប្រទេសកម្ពុជាសម័យមុនអង្គរពុំមានទម្រង់ជារដ្ឋផ្តាច់ការ និងប្រមូលផ្តុំតែមួយទេ។ ដោយសារជាក្សត្របុរីតូចៗជាច្រើន ដែលមាននយោបាយ និងការគ្រប់គ្រងផ្តាច់ការដូចៗគ្នា ស្តេចក្សត្របុរីទាំងនោះ យល់ថា ខ្លួនឯង ជាស្តេចចក្រពត្តិដែរ ហើយរស់នៅដោយឯករាជ្យ គ្រាន់តែបំពេញកាតព្វកិច្ចថ្វាយសួយសារអាករ ឬពលកំណែនដល់អធិរាជធំ តាមកាលកំណត់ប៉ុណ្ណោះ។

របៀបគ្រប់គ្រងប្រទេសខ្មែរ  របបនយោបាយខ្មែរ  គឺរបបរាជានិយមអធិរាជឬ"ស្តេចនៃស្តេចទាំងឡាយដែលគ្រប់គ្រងនគរចំណុះនានា"។  អធិរាជសោយរាជ្យដោយមានការឧបត្ថម្ភពីសំណាក់នាម៉ឺន,មន្ត្រីគ្រប់ជាន់ថ្នាក់, ព្រាហ្មណ៍បុរោហិត,ប្រជាពលរដ្ឋ។  ស្តេចជាម្ចាស់ផែនដីព្រះអង្គធ្វើអំណោយដីភូមិស្ថានដល់នាម៉ឺនឬព្រាហ្មណ៍សម្រាប់កសាងប្រាសាទ, អាស្រម, វត្តអារាមឬទេវស្ថាននានា។ សម័យចេនឡា ដែលជារបបរាជាធិបតេយ្យ ព្រះមហាក្សត្រិយ៍ខ្មែរមានអំណាចសំខាន់ៗបី គឺអំណាចនីតិប្បញ្ញត្តិ, អំណាចនីតិប្រតិបត្តិ និងតុលាការ។ ប៉ុន្តែព្រះអង្គមានអំណាចខាងសាសនាដែរ  ព្រះអង្គជាមេស្ថាប័នដ៏កំពូល។  ខឿនវប្បធម៌-អារ្យធម៌ខ្មែរនាសម័យចេនឡាពុំមានលក្ខណៈខុសប្លែកពីសម័យនគរភ្នំប៉ុន្មានទេ។ ព្រោះវាបានកើតចេញពីពុម្ព  ឬប្រភពតែមួយ  បើតាមការសង្កេតមើល  ផ្នែកសង្គមផ្នែកជំនឿសាសនា  ផ្នែកនយោបាយ រដ្ឋបាល និងទាំងផ្នែកស្ថាបត្យកម្ម។  ជនជាតិដែលរស់នៅក្នុងអាណាចក្រចេនឡា និងនគរភ្នំពិតជាជនជាតិខ្មែរតែមួយ ដែលមានភាសា និងវប្បធម៌ដូចគ្នា។

ខាងនយោបាយមានសញ្ញានៃការប្រើទ្រឹស្តីគ្រប់គ្រងរដ្ឋរបស់ឥណ្ឌាបុរាណដែលមានជាតុ៧[35]  ហើយដែលក្នុងនោះមានជាតុសំខាន់មួយគឺ សម្ព័ន្ធមិត្ត (*Alliance*) *ទើបសម័យហ្វូណាន*–ចេនឡា គេឃើញមានទំនាក់ទំនងការទូតជាមួយឥណ្ឌា, ចិន, ចាម្ប និងស្រីទ្វារវតីរបស់មននៅភាគខាងលិច បើតាមវត្ថុមានកាក់មាសឆ្លាក់អក្សរថា ស្រីទ្វារវតី ដែលគេបានរកឃើញនៅតំបន់អង្គរបុរី។

[34] សូមមើល, ត្រឹង ងា (១៩៧៣), ប្រវត្តិសាស្ត្រខ្មែរ, ការផ្សាយរបស់គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ២០០៣, ទំព័រ ៥០។

[35] ជាស្តេចផែនដីត្រូវមានរបស់៧យ៉ាង គឺស្វាមិន,អាមាត្យ,ជនបទ,ទុគ៌ៈ,ទណ្ឌៈ,កោសៈ និងមិត្រ (សូមមើលទំព័រ១២៥)។

ខ្មែរមានទំនាក់ទំនងតាមផ្លូវទូត និងពាណិជ្ជកម្មជាមួយចិន និងឥណ្ឌា។ ខ្មែរមាននាវាចម្បាំងតាំងពីសតវត្សរ៍ទី២នៃគ្រិស្តសករាជ។ ក្នុងរបាយការណ៍ចិនអំពីលីនយី, ចាម្ប និងហ្វូណាន និយាយថាប្រទេសទាំងពីរនេះមានព្រំប្រទល់ជាប់គ្នា។ ក្នុងឆ្នាំ២៧០-២៨០ ចិននិយាយថា ទាំងហ្វូណាន និងលិនយី បានវាយលុកខេត្តយ៉ាវ-ជី(Giao-Chi)របស់ចិន(វៀតណាមខាងជើង)។ ក្នុងរបាយការណ៍ចិននិយាយថានៅចុងសតវត្សរ៍ទី៥ មានបុត្រា ឬបក្សពួករបស់ជយវរ្ម័ នៅហ្វូណានបានដណ្តើមរាជបល្ល័ង្កស្តេចលីនយី ហើយព្រះបាទជយវរ្ម័ អ៊្វើរទាំប្រាប់ចិនថា ជននោះគឺជាសត្រូវរបស់ទ្រង់។

នៅរវាងឆ្នាំ៦០០ ស្តេចមហេន្ទ្រវរ្ម័ នៅកម្ពុជាបានបញ្ជូនមន្ត្រីព្រះអង្គឈ្មោះសិង្ហទេវៈ ទៅកាន់ប្រទេសចាម្បជាលក្ខណៈបេសកទូតមិត្តភាព (សិលាចារឹកK.53) ហើយនៅពាក់កណ្តាលសតវត្សរ៍ទី៧ មានព្រះអង្គម្ចាស់ចាម្បមួយអង្គបានយាងទៅកាន់ក្រុងភវៈ និងបានរៀបអភិសេកជាមួយបុត្រីស្តេចឥសានវរ្ម័ ព្រះនាមសាវ៌នី (សិលាចារឹកចាម្ប C. 96)។ ដូច្នេះ ទំនាក់ទំនងមិត្តភាពកម្ពុជា និងចាម្បមានតាំងពីយូរយារណាស់មកហើយ។

## 4. ឥទ្ធិពលវប្បធម៌ឥណ្ឌា

វប្បធម៌ឥណ្ឌានៅតំបន់អាស៊ីអាគ្នេយ៍ ក៏ដូចគ្នានឹងនៅប្រទេសកម្ពុជាដែរ។ នៅពេលណាមកដល់ប្រទេសនេះ គេអាចចំណាំបានដោយងាយ តាមរយៈអត្ថិភាពនៃមរតក ៖

-អក្សរ ដែលគេបាននាំមកពីឥណ្ឌាខាងត្បូង ក្នុងសម័យរាជវង្សបល្លវៈ នាសតវត្សរ៍ទី៥-៦ ហើយបានធ្វើការអភិវឌ្ឍន៍មកជាអក្សរខ្មែរ តែនៅរក្សាលំដាប់អក្សរក្រមភាពច្រើនរបស់ឥណ្ឌាបន្តដល់សព្វថ្ងៃ។

-ភាសា ជាពិសេសវត្តមានសំស្ក្រឹត ដែលជាភាសាសម្រាប់ក្រុមមនុស្សជាន់ខ្ពស់នៅស្រុកឥណ្ឌា។ បើទោះបីជា មកដល់សព្វថ្ងៃ ខ្មែរលែងចេះសរសេរអត្ថបទជាភាសាសំស្ក្រឹតទាំងស្រុងទៀតហើយក្តី ក៏ពាក្យស័ព្ទសំស្ក្រឹតដ៏ច្រើនសន្ធឹក នៅមានប្រើលាយឡំជាល្បាយក្នុងភាសាខ្មែរដែរ។ មានភស្តុតាងយ៉ាងច្រើនខាងចំណារអក្សរលើផ្ទាំងសិលា និងសត្រាស្លឹករឹត ដែលជាការយកគំរូ ឬលំនាំតាមឥណ្ឌាផងដែរ។

-សាសនា គឺមរតកសាសនាព្រាហ្មណ៍ និងព្រះពុទ្ធ ព្រមទាំងទ្រឹស្តីសាសនាទាំងនេះ នៅមានភស្តុតាងបន្សល់ទុកតាមរយៈប្រាសាទឥដ្ឋ និងថ្ម ព្រមទាំងសំណង់ពីឈើរហូតដល់សហសម័យ។

-បែបផែនសិល្បៈ,ស្ថាបត្យកម្ម, ចម្លាក់(វិកឃើរី ១៩៩៩), បដិមាសាស្ត្រ, តារាសាស្ត្រ និងសោភ័ណវិទ្យា ដូចគេឃើញនៅតាមប្រាសាទ រូបប្រតិមា និងក្បាច់ចម្លាក់លើសំណង់ទាំងឡាយ បង្ហាញនូវស្នាមគំនូស និងខ្លឹមសារតាមចំណេះដឹងព្រាហ្មណ៍អ្នកប្រាជ្ញឥណ្ឌា។ លើសនេះទៀត នៅមានឧបករណ៍សិល្បៈ ដូចជា គ្រឿងភ្លេង, គ្រឿងអលង្ការ ជាដើម និងក្រុមសិល្បករនៅតាមប្រាសាទសំខាន់ៗពីសម័យបុរាណ និងនៅតាមវត្តនៅសម័យថ្មី។

-អក្សរសាស្ត្រ និងទ្រឹស្តីគ្រប់គ្រងរដ្ឋបែបឥណ្ឌា បង្ហាញនូវការរៀនសូត្រតាមស្នាដៃកេរបស់ឥណ្ឌា ដូចជារឿងរាមកេរ្តិ៍, មហាភារតៈ, ទេវកថា, គំនិតរាជាធិរាជនិយម ជាដើម

-ទំនៀមទម្លាប់ខ្លះ ដូចជាការជួតក្បាលដោយក្រមា, ការចិញ្ចឹមសត្វ, ការរៀបចំពលីការបូជាពេលមានពិធីបុណ្យ, សែនព្រេន និងការបូជាផ្សេងៗ។ នៅសតវត្សរ៍ទី១៩ អ្នកស្រុកខ្មែរ ច្រើននៅស្លៀកពាក់តាមបែបឥណ្ឌា និងមានឥរិយាបថដូចឥណ្ឌាខ្លាំងជាងប្រជាជនជិតខាង ដូចជនជាតិយួន។ ប្រជាជនខ្មែរធ្លាប់ទទួលទានអាហារនឹងស្លាបព្រា ឬម្រាមដៃ ទូលឥវ៉ាន់ ចូលចិត្តជួតក្បាលច្រើនជាងពាក់មួកដួន និងចូលចិត្តស្លៀកសំពត់ចងក្បិនច្រើនជាងស្លៀកខោ។ គេគិតស្មានថា ជនជាតិឥណ្ឌាជាអ្នកបាននាំចូលមកនៅប្រទេសកម្ពុជានូវបច្ចេកទេសចិញ្ចឹមគោ តាំងពីយូរលង់មកហើយ ព្រោះការចិញ្ចឹមគោពុំសូវជាទម្លាប់នៅក្នុងតំបន់ដទៃទៀតនៃអាស៊ីអាគ្នេយ៍ទេ។

ការពិភាក្សា ដែលនៅតែគ្មានចម្លើយដាច់ខាតនោះ គឺថា តើរបៀបនៃការផ្សាយវប្បធម៌ឥណ្ឌា លើគ្រប់ផ្នែកទាំងអស់នេះ ប្រព្រឹត្តិទៅតាមរូបភាពបែបណា?

របៀបនៃការផ្សាយវប្បធម៌ឥណ្ឌា ដែលគេបានដឹងឮកន្លងមក មានសម្មតិកម្មច្រើន ដែលកើតឡើងពីការទិតៀនចំណុចខ្សោយគ្នាជាបន្តបន្ទាប់របស់អ្នកប្រាជ្ញម្នាក់ៗ។ ជាដំបូងនេះ យើងលើកយកសម្មតិកម្មរបស់លោក ហ្សក សឺដេស ដែលក្រសួងអប់រំជាតិបានយល់ស្របតាមមួយភាគធំ គឺ

- ព្រាហ្មណ៍ឥណ្ឌានិមន្តមកកម្ពុជា ដោយខ្លួនឯង
- ព្រាហ្មណ៍បង្រៀនទ្រឹស្តីសាសនា, បង្ហាត់ជំនាញខាងសំណង់ស្ថាបត្យកម្ម និងសិប្បកម្ម...
- ឈ្មួញឥណ្ឌារៀបការជាមួយនារីខ្មែរ-ផ្សាយប្រពៃណី,ទំនៀមទម្លាប់ដល់កូនចៅ
- ខ្មែរទទួលយកដោយសន្តិវិធី និងសតិសម្បជញ្ញៈរបស់ខ្លួន-គ្មានការបង្ខំឱ្យប្រកាន់យក

ស្រដៀងគ្នានេះមានទ្រឹស្តីថា ឥណ្ឌាភាវូបនីយកម្ម គឺជាការទទួលធាតុផ្សេងៗ នៃវប្បធម៌ឥណ្ឌាដែលខ្មែរបានជ្រើសរើស ឬយកនៅក្នុងកាលសម័យដ៏វែងមួយ បន្តបន្ទាប់គ្នាប្រហែលមួយសហស្សវត្សរ៍។ ដំណាក់កាលដំបូងនៃដំណើរការនេះ ឬទម្រង់ផ្សេងៗដែលខ្មែរបានយកនោះ គេនៅមិនទាន់ដឹងច្បាស់លាស់នៅឡើយទេ។ ប៉ុន្តែ ឥណ្ឌាភាវូបនីយកម្មបានធ្វើឱ្យប្រទេសកម្ពុជា មើលទៅដូចជាតំបន់មួយនៅឯនាយស្រុកឥណ្ឌា (Further India )អញ្ចឹងដែរ។

លោក Van Leur ដែលជាអ្នកប្រាជ្ញហូឡង់ដ៏ឆ្នើមមួយរូបខាងសិក្សាអំពីអាស៊ីអាគ្នេយ៍ បានអះអាងថា មានតែពួកព្រាហ្មណ៍ទេ ដែលអាចនាំយកវប្បធម៌ពិសិដ្ឋបែបនេះមកឱ្យអាស៊ីអាគ្នេយ៍ទាំងមូលបាន ដោយៈ

ព្រាហ្មណ៍ទទួលការអញ្ជើញដោយស្តេច, ព្រះអង្គម្ចាស់ ឬមន្ត្រីធំនៅក្នុងស្រុក។

មេដឹកនាំស្រុកអាយ ឱ្យព្រាហ្មណ៍បង្ហាត់កូនចៅខ្លួននូវចំណេះដឹងសាសនា ស្ថាបត្យកម្ម និងសិប្បកម្មផ្សេងៗ ពិសេសខាងចម្លាក់។

ព្រាហ្មណ៍ឡើងជាទីប្រឹក្សាអ្នកដឹកនាំ ទើបមានសំណង់ទីក្រុងតាមបែបឥណ្ឌា។

ព្រាហ្មណ៍ជាអ្នកចង្អុលបង្ហាញឱ្យគេសាងសង់ប្រាសាទឡើង ដើម្បីសាសនា។

ប៉ុន្តែគំនិតនេះ ត្រូវលោក Michael Vickery រិះគន់ និងបដិសេធចោល ដោយផ្អែកលើការពិចារណាចេញពីភស្តុតាងស្ថាបត្យកម្ម និងក្បាច់ចម្លាក់ នៅលើប្រាសាទនានានៅក្នុងតំបន់អាស៊ីអាគ្នេយ៍ទាំងមូល មិនមែនផ្តោតតែលើប្រាសាទនៅកម្ពុជាមួយ ថា ៖

ស្ថាបត្យកម្មប្រាសាទនៅស្រុកខ្មែរប្លែកពីឥណ្ឌា គ្រង់រចនាសម្ព័ន្ធ និងនិមិត្តរូបសំណង់។

ព្រាហ្មណ៍ប្រកាន់សីលធម៌ មិនអាចប្រើគេឱ្យច្នៃ ឬ បំលែងស្នាដៃរបស់ខ្លួន មកធ្វើវត្ថុថ្មីបានទេ។ សិស្សនីមួយៗត្រូវតែរៀនគ្រាប់តាមគ្រូគ្រប់យ៉ាង និងប្រកាន់យកទ្រឹស្តីរបស់គ្រូឱ្យខ្ជាប់ អនុវត្តន៍ដូចតៗគ្នា។

រូបចម្លាក់នៅតាមប្រាសាទមួយៗអាស៊ីអាគ្នេយ៍ ក៏ដូចនៅកម្ពុជា ឆ្លើយតបនឹងម៉ូតក្បាច់ចម្លាក់នៅលើប្រាសាទជាច្រើន ដែលសាងនៅទីកន្លែងខុសគ្នាៗនៅស្រុកឥណ្ឌា។

ដូច្នេះ ជាសន្និដ្ឋាន ប្រាសាទនៅអាស៊ីអាគ្នេយ៍ ក៏ដូចនៅកម្ពុជាដែរ មិនមែនកសាងតាមការបង្គាប់របស់ព្រាហ្មណ៍ឥណ្ឌានោះទេ។ ដូច្នេះ តើរបៀបនៃការផ្សាយវប្បធម៌ឥណ្ឌា? និង របៀបនៃការកសាងប្រាសាទនៅអាស៊ីអាគ្នេយ៍ ឬនៅកម្ពុជា ប្រព្រឹត្តទៅដូចម្តេច?

លោក **Michael Vickery**សន្និដ្ឋានថា ៖

អ្នកដឹកនាំស្រុកអោយដឹងអំពីអត្ថិភាព និងអំណាចរបស់ព្រាហ្មណ៍តាមរយៈអ្នកជំនួញចេញពីក្នុងស្រុករបស់ខ្លួន យករឿងរ៉ាវប្លែកៗនោះ មកនិទានប្រាប់។

ទើបអ្នកដឹកនាំទាំងនោះបញ្ជូនយុវអភិជនឱ្យទៅសិក្សាពីព្រាហ្មណ៍នៅស្រុកឥណ្ឌាតែម្ដង។

ពួកគេមុខជារៀនខាងទ្រឹស្ដីសាសនា, ជំនាញស្ថាបត្យកម្ម និងចម្លាក់ជាដើម។ ក្រៅពីការសិក្សាពួកគេអាចធ្វើដំណើរទស្សនាប្រាសាទនានា នៅរាយប៉ាយក្នុងស្រុកឥណ្ឌា។

ដូច្នេះ ពេលពួកគេត្រឡប់មកស្រុកវិញ ក៏យកចំណេះដឹងទាំងនោះមកអនុវត្តន៍ ដោយកសាងជាប្រាសាទដែលប្រើប្រាស់គំនិតច្នៃប្រឌិតផ្ទាល់ខ្លួន។ បើពុំដូច្នោះទេ គេគួរតែឃើញប្រាសាទក្នុងរចនាបថសិល្បៈ និងស្ថាបត្យកម្មរវាងអាស៊ីអាគ្នេយ៍ ឬស្រុកខ្មែរ និងឥណ្ឌា មានលក្ខណៈដូចៗគ្នាមិនខាន។ មិនមែន មានត្រឹមតែស្នាមត្រេដូចគ្នាទៅនឹងទ្រឹស្ដីវប្បធម៌ឥណ្ឌាអញ្ចឹងទេ។

អ្នកប្រាជ្ញប្រវត្តិសាស្ត្រខ្មែរកាលពីមុន បានអះអាងថា កម្ពុជាធ្លាប់មានស្ដេចជាជនជាតិឥណ្ឌាពីរអង្គដែលបានជួយជំរុញការសាបព្រោះវប្បធម៌ឥណ្ឌានៅក្នុងសង្គមខ្មែរ។ តើវប្បធម៌ឥណ្ឌាហូរចូលមកខ្មែរដំបូងដោយស្ដេចជនជាតិឥណ្ឌាឈ្មោះកៅណ្ឌិន្យ ដែលចិនហៅថាហ៊ុនទៀន, ហ៊ុនធេន ឬហ៊ុនហួយ តាំងពីសតវត្សរ៍ទី១មែនឬទេ?

លីវ-យី ទំនងជាមេដឹកនាំស្ត្រីនៅស្រុកហ្វូណានមែន ប៉ុន្ដែជនបរទេសឈ្មោះហ៊ុនទៀន(ឬហ៊ុនធេន,ហ៊ុនហួយ) ដែលអ្នកស្រាវជ្រាវមុនៗថាត្រូវនឹងភាសាសំស្ក្រឹត កៅណ្ឌិន្យ មកពីស្រុកឥណ្ឌានោះ ជារឿងមិនគួរឱ្យជឿបានឡើយ ប្រសិនបើគេពិចារណាឡើងវិញ លើហេតុផលមួយចំនួនដែលចិនបានកត់ត្រាក្នុងអំឡុងសម័យបុរាណនោះ (វិឃើរី ១៩៩៨)។

- ឯកសារចិនថា ចិនមិនចេះធ្វើសំពៅបើកមកកាន់អាស៊ីអាគ្នេយ៍ពីសតវត្សរ៍ទី៣-១០។ សំពៅសម្រាប់ធ្វើដំណើរនៅអំឡុងពេលនោះ ក៏គ្មានសំពៅរបស់ជនជាតិឥណ្ឌាសម្រាប់ធ្វើដំណើរដែរ (ពីអាស៊ីអាគ្នេយ៍ដល់ស្រីលង្កា)។

ដូច្នេះ តើធ្វើម្ដេចនឹងអាចឱ្យជឿថា ហ៊ុនទៀនលើកទ័ពពីឥណ្ឌា មកវាយដណ្ដើមយកហ្វូណានតាមជើងទឹកបាន បើនៅលើកោះស៊ូម៉ាត្រា លើជ្រោយម៉ាឡេស៊ី និងលើកោះជ្វា មានមនុស្សដែលពូកែខាងធ្វើនាវាចរណ៍តាមសមុទ្ទកំពុងរស់នៅទីនោះដែរ។

- មានឯកសារចិនចេះហៅកៅណ្ឌិន្យ ថា ក្យាវជិនយូ ជាពាក្យបីព្យាង្គដូចគ្នានៅសតវត្សរ៍ទី៥។ ដូច្នេះ បើចិនចេះហៅ កៅណ្ឌិន្យ ជាពាក្យបីព្យាង្គបែបនេះដែរ គេមិនគួរប្រើតែពីរព្យាង្គ ឬមួយព្យាង្គនោះទេ បើដូចការអះអាងរបស់លោក វិកឃើរី ថាពាក្យ ហ៊ុន ឬ ហ្វាន ហៅសម្គាល់ស្ដេចនៅអាស៊ីអាគ្នេយ៍ដីគោកពេលនោះ។ ម្យ៉ាងទៀត ឈ្មោះប្រទេសបី ក្យាវ, កិ និងហ្វូស៊ុន ដែលចិនថា ជាប្រទេសកំណើតរបស់ប្ដីលីវយីនោះ គេរកមិនឃើញថា វាត្រូវនឹងឈ្មោះស្រុកណាមួយនៅប្រទេសឥណ្ឌាឡើយ។

-ចិនកត់ត្រាយ៉ាងច្បាស់ថា នៅទសវត្សរ៍ឆ្នាំ២៣០ ឬ២៤០ ទើបរាជទូតដំបូងរបស់ឥណ្ឌាមកដល់ហ្វូណាន បន្ទាប់ពីខ្មែរបានទាក់ទងមុន។ ព្រឹត្តិការណ៍នោះកើតឡើងដំណាលគ្នានឹងការមកដល់នៃរាជទូតចិនឈ្មោះ កាំងថៃ និងជូយិង ដែលបានបន្សល់ទុករបាយការណ៍ដំបូងបំផុតរបស់ចិនស្ដីពីហ្វូណានដែរ។ ប្រសិនបើហ៊ុនទៀន មកពីឥណ្ឌាមែន គ្រាន់តែពេលវេលាកន្លងផុតមកប្រមាណ១០០ឆ្នាំ មិនគួរណាស្ដេចខ្មែរពេលនោះមិនបានដឹងពីរឿងស្រុកឥណ្ឌាឡើយ។

- កំណាយនៅអុកអែវ គ្មានវត្ថុសិល្បៈដែលសម្គាល់វត្តមាននៃឥទ្ធិពលវប្បធម៌ឥណ្ឌានៅអំឡុងមុនសតវត្សរ៍ទី៣ឡើយ។

ម្ល៉ោះហើយ ហ៊ុនទៀន ពិតជាមិនមែនជនជាតិឥណ្ឌាទេ តែគាត់អាចជាវរជនដែលមានដើមកំណើតចេញពីកោះណាមួយ នៅក្នុងពិភពរបស់ពួកអូស្ត្រូនេស្យាន នៅភាគខាងត្បូងហ្វូណាន ដែលធ្លាប់ទទួលឥទ្ធិពលវប្បធម៌ឥណ្ឌាដោយប្រយោលតាំងពីយូរយារមុនគ្រិស្តសករាជ តាមរយៈសកម្មភាពជំនួញ។ ព្រោះពួកនេះ ចេះធ្វើជំនួញជាមួយប្រទេសពៃរ្យតាំងពីសម័យមុនគ្រិស្តសករាជមកម្ល៉េះ។

ហេតុអ្វីក៏ត្រូវយករឿងនិទានសតវត្សរ៍ទី១០ នៅលើសិលាចារឹកបក្សីចាំក្រុង ស្តីអំពីដើមកំណើតសន្តតិវង្សសោមវង្ស ដែលចាប់ផ្តើមពីកៅណ្ឌិន្យ និងសោមា មកសន្មត់ឱ្យត្រូវគ្នានឹងតួអង្គព្រះបាទហ៊ុនទៀន-លីវយី ប្រហែលនៅសតវត្សរ៍ទី១បាន។ បើនៅសតវត្សរ៍ទី៥ ចិនបាននិយាយអំពីគាវធេនយូ ដែលអាចត្រូវជាកៅណ្ឌិន្យ នេះបានមកសោយរាជ្យនៅហ្វូណាន ហើយសិលាចារឹកប្រាសាទប្រាំល្វែងរបស់រាជទាយាទគុណវម៌្ម បង្ហើបឱ្យដឹងថា កៅណ្ឌិន្យជាក្សត្របុព្វបុរសរបស់ព្រះអង្គ ដែលអាចជាជីតា ឬតាទួតប៉ុណ្ណោះ។ ដូច្នេះ កៅណ្ឌិន្យ មែនទែន អាចមកពីឥណ្ឌា ធ្វើជាស្តេចហ្វូណាននៅអំឡុងសតវត្សរ៍ទី៥។ រឿងនេះគួរឱ្យជឿបាន ដោយសារបន្ទាប់ពីឥណ្ឌា និងខ្មែរ ស្គាល់គ្នា និងមានទំនាក់ទំនងទូតជាមួយគ្នារួចហើយ។ ចំណែកសោមា ដែលជាក្សត្រដើមខ្សែខាងសោមវង្ស និទានដោយសិលាចារឹកបក្សីចាំក្រុងនោះ ក៏គួរតែត្រូវជាអគ្គមហេសីរបស់កៅណ្ឌិន្យ ក្នុងតំណាងឱ្យជាតុអ្នកស្រុកអាយ។

ទំនងចាប់ពីស.វ.ទី៥ សិលាចារឹកប្រើអក្សរឥណ្ឌាភាគខាងត្បូង, ភាសាសំស្ក្រឹត និងឈ្មោះមនុស្សជាភាសាសំស្ក្រឹត បានលេចឡើង។ ប៉ុន្តែ ប្រភេទចំណេះដឹងវប្បធម៌ឥណ្ឌា អាចត្រូវផ្សព្វផ្សាយមកកម្ពុជាមុនកាលបរិច្ឆេទនេះ។

ពាណិជ្ជកម្មរវាងឥណ្ឌា និងប្រទេសកម្ពុជា ច្បាស់ជាបានចាប់ផ្តើមតាំងពីយូរមកហើយ មុនពេលដែលភាសាសំស្ក្រឹតបានជ្រាបចូលឧបទ្វីបឥណ្ឌា។ លោកប៉ូល មូស( Paul Mus )បានឱ្យយោបល់ថា ប្រទេសកម្ពុជា និងឥណ្ឌាខាងត្បូង ព្រមទាំងភូមិភាគបេងហ្គាល់មុខតែមានវប្បធម៌តែមួយហៅថា “វប្បធម៌អាស៊ីខ្យល់រដូវ” ដែលផ្អែកទៅលើអ្នកតា(ព្រះលិង្គ-ព្រលឹង)ដែលជួយឱ្យដំណាំឱ្យផលល្អ។ តាមធម្មតានៅតាមស្រុកភូមិ ដុំថ្មតំណាងឱ្យអ្នកតាទាំងនោះ មានរូបរាងដោយឯកឯងស្រដៀងនឹងលិង្គ ឬក៏ឆ្លាក់ដុំថ្មនោះជារូបលិង្គ។ អ្នកស្រុកមានជំនឿថា ការសែនព្រេនដល់ដុំថ្មដែលតំណាងឱ្យអ្នកតានេះ នឹងជួយឱ្យដីស្រែចំការមានជីវជាតិល្អ។ នេះពុំមែនមានតែនៅអាស៊ីប៉ុណ្ណោះទេ ដូចលោកមូស បានលើកឡើង អ្នកដំណើរជនជាតិឥណ្ឌា ដែលបានធ្វើដំណើរឆ្លងកាត់ប្រទេសកម្ពុជានឹងសម្គាល់ភ្លាមថា ជំនឿទាំងនេះជាជំនឿរបស់ឥណ្ឌា គឺជាការបូជាដល់ព្រះឥសូរឬដល់ព្រះជាយានៃព្រះឥសូរ។ របៀបដែលគេបូជាព្រះអាទិទេពឥណ្ឌា ក៏ដូចជាការសែនព្រេនអ្នកតាខ្មែរដែរ។

ប្រជាជនខ្មែរបានទទួលយកវប្បធម៌ឥណ្ឌាដោយខ្លួនឯង គឺមិនមែនដោយការបង្ខិតបង្ខំតាមរបៀបអាណានិគម ឬ ដោយមានការប្រើកម្លាំងជិះជាន់នោះទេ។ បុគ្គលជាតិឥណ្ឌា ច្រើនបានទទួលបុណ្យសក្តិពិសេស គឺដោយសារគេបានញ៉ាំងឱ្យអ្នកស្រុកជឿថា ខ្លួនសមនឹងទទួលនូវឋានៈនេះ។ ពួកឥណ្ឌាដែលបានធ្វើដំណើរផ្សងព្រេងដំបូងៗ បានជ្រៀតចូលក្នុងចំណោមប្រជាជនម្ចាស់ស្រុក។ ឥណ្ឌាភាវូបនីយកម្មមិនដែលបង្កើតវិបត្តិអត្តសញ្ញាណក្នុងចំណោមប្រជាជនខ្មែរទេ។ ខ្មែរមិនដែលប្រឆាំងនឹងឥណ្ឌាឡើយ។ នាបុរាណសម័យ ប្រទេសឥណ្ឌាមិនដែលជារដ្ឋតែមួយនោះទេ។ ឥណ្ឌាភាវូបនីយកម្ម បានផ្តល់ទម្រង់បែបបទ និងភាសាមួយដល់ពួកវរជនខ្មែរ តែពុំមែនជារឿងនយោបាយឡើយ។ រហូតដល់ពេលថ្មីៗនេះ គេបានយល់ថា អត្តសញ្ញាណជាតិខ្មែរ ជាផលបូកនៃការរៀបចំទាំងឡាយក្នុងសង្គម ដែលកើតមាននៅក្នុងប្រទេសកម្ពុជា។ ឥណ្ឌាភាវូបនីយកម្ម ឬទិដ្ឋភាពខ្លះៗនៃជីវិតរស់នៅប្រចាំថ្ងៃដែលគេទទួលស្គាល់ថា មានប្រភពមកពីឥណ្ឌា គឺជាផលបូក។ ការជះឥទ្ធិពលនៃវប្បធម៌ឥណ្ឌា មិនត្រូវបានគេចាត់ទុកជាហេតុផលមួយគួរឱ្យបារម្ភនោះឡើយ។

មានអ្នកប្រាជ្ញខ្លះ គិតថា ឥណ្ឌាបាននាំបម្លាស់ប្តូររបបនយោបាយស៊ីជម្រៅមួយដែលខ្មែរមាន គឺប្រពៃណីនិយមមេ ឬដែលគេហៅថា "មេនិយម"(មេជាធំ) ពីសំណាក់ជនជាតិខ្មែរ ឱ្យទៅរករបបរាជានិយមបែបឥណ្ឌា។ ការរៀបចំហេដ្ឋារចនាសម្ព័ន្ធដឹកនាំបែបឥណ្ឌា មានព្រះមហាក្សត្រប្រចាំទីតាំង ឬមណ្ឌលបំពេញតួនាទីជំនួសមេកន្ទ្រាញដែលជាអ្នកគ្រប់គ្រងទៅវិញ នាម៉ឺន មន្ត្រី ជាអ្នកជំនួយឱ្យព្រះមហាក្សត្រ។ ការអះអាងបែបនេះ ទំនងជាមិនពិតទេ ព្រោះប្រពៃណីមេនិយមនៅតែត្រូវគេអនុវត្តន៍សម្រាប់ការស្នងមរតក និងស្នងទ្រព្យសម្បត្តិក្នុងវង្សត្រកូលជាបន្តរហូតដល់សព្វថ្ងៃ។ ព្រះរាជាជាច្រើន អាចឡើងសោយរាជ្យបានតាមខ្សែខាងម្តាយ ហើយតំណែងសំខាន់ៗក្នុងរាជការ គេអាចទទួលស្នងពីឪពុកមកកូនប្រុសបើគ្រួសារព្រាហ្មណ៍វិញ ច្រើនតែតពីបងទៅប្អូនប្រុស, ពីមាទៅក្មួយប្រុសដែលជាកូនរបស់បង ឬប្អូនស្រី, ឬស្នងពីតាមីងមកចៅមីង ដែលជាកូនរបស់ក្មួយស្រីដែលជាកូនស្រីរបស់បង ឬប្អូនស្រីខ្លួន។

## 5. ប្រពៃណីទំនៀមទម្លាប់នគរភ្នំ-ចេនឡា និងការវិវត្តន៍

### 5.1. ការទុកដាក់សព

តាមប្រភពឯកសារចិន ថាការបូជាសពរបស់ជនជាតិខ្មែរ សម័យនគរភ្នំមានលក្ខណៈដូចនៅអាណាចក្រលិនយី (សំដៅលើប្រទេសមួយដែលចាម្បលេបយកនៅសតវត្សរ៍ទី៨)។ ពេលកាន់ទុក្ខ គេត្រូវកោរសក់, ពុកមាត់ និងយំស្រែកឮៗ។ ក្នុងពិធីរំលាយសព មាន៤យ៉ាង ជួនគេបោះសពក្នុងទឹកទន្លេ, ដុតសពដោយភ្លើង( ទំនៀមទម្លាប់ក្លិង្គ), កប់សពក្នុងដី, យកសពដាក់ចោលក្នុងព្រៃជ្រៅ( សត្វសាហាវស៊ី)។ ទម្លាប់ចុងក្រោយនេះ គេឃើញព្រះបាទអង្គឌួងនៅសតវត្សរ៍ទី១៩ បានទុកបណ្តាំបច្ឆាមរណៈបង្គាប់ឱ្យគេចៀរពន្លះសាច់ព្រះអង្គដាក់ទានឱ្យសត្វស៊ី ដើម្បីសងគុណដល់សត្វវិញ។ ការបូជាសពដោយភ្លើង ខ្មែរបុរាណប្រមូលធាតុនៅសល់ដាក់ក្នុងកោដិ ឬក្រឡ ហើយបិទមាត់កោដិនោះជិត (បិតដោយជ័រទឹក) ហើយយកទៅបោះក្នុងទន្លេ ឬកប់ក្រោមផ្ទាំងថ្មធម្មជាតិនៅតាមភ្នំ។ កោដិដែលគេសម្រាប់ដាក់ធាតុនោះ ស្តេចគេប្រើកោដិពីមាស ជាលោហធាតុតំណាងភាពបរិសុទ្ធ និងអមតៈ។ បើជាមន្ត្រីគេប្រើប្រាក់ ឬដីដុតប្រពៃណីកប់សពក្នុងដី មានទម្លាប់តាំងពីសម័យបុរេប្រវត្តិសាស្ត្រមកម្លេះ។

### 5.2. ប្រពៃណីទំនៀមទម្លាប់

សង្គមខ្មែរសម័យនគរភ្នំដែលតពីសម័យបុរេប្រវត្តិសាស្ត្រ និយមមេជាធំ (តាមកំណត់ហេតុចិន ហ្វូណានដើមឡើយដឹកនាំដោយព្រះនាងលីវយី) លទ្ធិមេនិយមបានធ្វើឱ្យស្ត្រីមានសេរីភាពយ៉ាងធំក្នុងជីវភាពរស់នៅ ដែលស្ត្រីមានសិទ្ធិស្វែងរកបុរសដែលខ្លួនពេញចិត្ត ដែលទំនៀមទម្លាប់នេះបានរលប់បាត់បន្តិចម្តងៗនៅពេលដែលឥណ្ឌាចូលស្រុក។ ដោយធ្វើឱ្យវប្បធម៌ស្ត្រីទៅដណ្តឹងប្រុស មានការផ្លាស់ប្តូរនៅសម័យចេនឡាទៅជាប្រុសទៅដណ្តឹងស្ត្រីវិញ បើតាមឯកសារចិនកត់ត្រា។ នេះជាការដើរផ្ទុយគ្នា ពីប្រពៃណីឥណ្ឌាដែលស្ត្រីនៅតែដណ្តឹងបុរសធ្វើប្តីរហូតដល់សព្វថ្ងៃ។ ទោះជាយ៉ាងណា ការស្នងរាជ្យ តំណែងក្នុងរាជការក្នុងគ្រួសារព្រាហ្មណ៍ ព្រមទាំងមរតកគ្រួសារ ជាពិសេសអចលនទ្រព្យរបស់គ្រួសារ គឺច្រើនតែធ្វើឡើងស្របច្បាប់បានតាមតែខ្សែស្រឡាយខាងស្រី។ បើស្នងមរតក គឺកូនស្រីជាអ្នកទទួល លើកលែងតែគ្រួសារខាងប្រុសជាកូនទោលក្នុងគ្រួសារ។ ប្រពៃណីនេះ មានបន្សល់ទុករហូតដល់សព្វថ្ងៃ។ នេះហើយជាចំណុចខុសគ្នាស្រឡះ ពីប្រពៃណីរបស់ពួកឥណ្ឌា និងចិន។

ចំពោះការបែងចែកមរតករបស់គ្រួសារ ក្រោយពីរៀបការរួចកូនត្រូវតែបែកផ្ទះពីឪពុកម្តាយទាំងសងខាង ដោយទទួលនូវទ្រព្យកេរ្តិ៍មួយចំនួនពីឪពុកម្តាយតាមស្ថានភាពគ្រួសារ។ កូននៅលីវត្រូវរស់នៅជាមួយ និងក្រោម

អាណាព្យាបាលរបស់ឪពុកម្តាយ។ បើឪពុកម្តាយស្លាប់អស់ ពេលមានកូននៅលីវក្នុងបន្ទុក ទ្រព្យសម្បត្តិត្រូវធ្លាក់ទៅកូនៗទាំងនោះ។ កូនដែលបែកផ្ទះមិនអាចមកទាមទារចែកកេរ្តិ៍បាន។ករណីឪពុកម្តាយស្លាប់អស់ ពេលគ្មានកូនក្នុងបន្ទុក ទ្រព្យសម្បត្តិនៅសល់ទាំងអស់ ត្រូវរាជការដកហូតយក។

ប្រសិនបើ គេមើលអត្ថបទសិលាចារឹកភាសាសំស្ក្រឹត អាចនាំឱ្យយល់ច្រឡំថា នៅកម្ពុជាពេលនោះមានវណ្ណៈសង្គម៤បែបនៅស្រុកឥណ្ឌា។ ម្យ៉ាងទៀត នៅលើសិលាចារឹកភាសាខ្មែរ ក៏មានបច្ចេកពាក្យមួយថាចតុជាំត ដែលលោក សឺដេស តែងបកប្រែដោយអេះអុញថា “វណ្ណៈទាំងបួន Quatre castes)” ជាញឹកញាប់ដែរ។ បញ្ហានេះ ជាហេតុធ្វើឱ្យអ្នកស្រាវជ្រាវជាច្រើន គិតសង្ស័យថា កម្ពុជាធ្លាប់មានវណ្ណៈបួនដែលប្រតិបត្តិមិនសូវតឹងរឹង។ តាមពិតពាក្យនេះ ពិបាកឱ្យជឿបានថា ជាពាក្យសម្គាល់វណ្ណៈ។ ប៉ុន្តែ បើក្រឡេកមើលពាក្យ វណ្ណ៍ៈ ជាពិសេសនៅក្នុងរាជ្យជយវម្ម័ទី២ ព្រះអង្គបានបង្កើតវណ្ណ៍ៈប្រាំពីរ សម្រាប់ធ្វើក្រុមជំនាញបម្រើព្រះអង្គបើតាមសិលាចារឹកប្រាសាទបេង K. 989[36] ហើយមកដល់រាជ្យព្រះបាទជយវម្ម័ទី៥ សតវត្សរ៍ទី១០ ពេលព្រះអង្គធ្វើពិធីសម្ពោធការសិក្សាមានវណ្ណៈប្រាំពីរ កំពុងចូលរួម ហើយពេលនោះដែរ ព្រះអង្គឱ្យគេបង្កើតវណ្ណៈពីរថែមទៀត ដែលធ្វើឱ្យវណ្ណៈនៅពេលនោះឡើងដល់ទៅ៩ ដែលលោក ហ្សក សឺដេស ថាវាទំនងជាមានន័យសម្គាល់ជាក្រុមសាជីវកម្ម (Corporations)ទៅវិញ។ បើពិនិត្យលើបញ្ហាផ្សេងៗជាច្រើនទៀត ទាក់ទងនឹងការតម្លើង និងទម្លាក់ឋានៈមនុស្សក្នុងសង្គមខ្មែរ ដែលតែងតែត្រូវអ្នកមានអំណាចធ្វើបានដោយងាយ និងការរៀបការដោយគ្មានប្រកាន់ដើមកំណើត អាចឱ្យយើងអះអាងបានថា នៅកម្ពុជាមិនដែលមានប្រព័ន្ធវណ្ណៈ (caste system) ដូចនៅស្រុកឥណ្ឌាឡើយ។

ជំនឿសាសនានៅសម័យចេនឡា អ្នកស្រុកមានការបែកគំនិតថ្មី ដោយគេចេះបង្កើតរូបព្រះវិស្ណុ-សិវៈរួមគ្នាជាទេពតែមួយអង្គទ្រង់ឈរ ហៅថា «ព្រះហរិហរៈ» ដែលមិនធ្លាប់មាននៅស្រុកឥណ្ឌា។

### 5.3. សីលធម៌-យុត្តិធម៌

ឯកសារចិនបាននិយាយអំពីអ្នកស្រុកហ្វូណាននិយមយុត្តិធម៌ និងសច្ចធម៌។ គេអាចធ្វើឱ្យមនុស្សមានសីលធម៌ប្រកបដោយប្រសិទ្ធភាព ដោយការប្រើយុទ្ធវិធីបែបចិត្តសាស្ត្រមួយ ធ្វើឱ្យអ្នកមានកំហុស ខ្លាចទារុណកម្មមិនហ៊ានប្រព្រឹត្តនូវកំហុស។ នៅក្នុងជីវភាពរស់នៅគេចាត់ទុកដៃស្តាំជាដៃបរិសុទ្ធ ឯដៃឆ្វេងជាដៃមិនបរិសុទ្ធ។ រាល់ព្រឹកគេលុបលាងមុខចាក់ធ្មេញ អានសៀវភៅសូត្រធម៌ដោយស្វាធ្យាយ។ នៅក្នុងសិលាចារឹកថា គេនិយមរាប់ញាតិដោយគេយកខ្សែស្រឡាយតាមម្តាយ។ ប៉ុន្តែក៏មានកំណត់ត្រាខ្លះរបស់ចិន បានបង្ហាប់អ្នកស្រុកហ្វូណានដែលថា ពេលធ្វើដំណើរចូលចិត្តសៀតអាវុធនៅនឹងចង្កេះ ហើយបើមានរឿងទាស់ទែងគ្នាបន្តិចបន្តួច ចូលចិត្តប្រឈ្លោះកាប់ចាក់គ្នាភ្លាមៗដែរ។

ក្នុងករណីរកយុត្តិធម៌ គេបានតម្រូវឱ្យជនជាប់ចោទ សាកល្បងលូកក្នុងវត្ថុរាវដាំពុះ, កាន់ដែកដុតក្តៅដើរឱ្យបាន៧ជំហាន, ស៊ីបាយពំនូតដែលគេបានសែកមន្តគាថារួច ដាក់តម្កល់មួយយប់នៅទេវស្ថាន, ដាក់ឱ្យសត្វស៊ី មានក្រពើ ឬខ្លា រួចចាំមើលបាតុភូតកើតឡើងបន្ទាប់ពីអនុវត្តន៍តាមវិធាន។ បើមិនរលាកដៃ, មិនមានឈាមហូរចេញពីមាត់ ឬរឹងមាត់និយាយមិនរួច, សត្វមិនស៊ីទេ គេចាត់ទុកជនសង្ស័យនោះ គ្មានកំហុស។ ចិនថា ថ្វីបើគេប្រើវិធីពិសោធន៍បែបនេះ តែអ្នកស្រុកនេះចេះមន្តអាគមធើតណាស់ ជនល្មើសកម្រមានសំណាងបានរួចខ្លួនឡើយ។

---

[36] Cf., George Coedès, 1964. *Inscriptions du Cambodge*, vol. VII, EFEO, Paris, pp. 164-189.

## 6. សាសនា និងកសាងប្រាសាទ

សាសនាខ្មែរនៅសម័យប្រវត្តិសាស្ត្រ មានលក្ខណៈសំយោគរវាងសាសនាមន-ខ្មែរដើមដែលមានការបូជាចំពោះព្រលឹងបុព្វបុរស និងធម្មជាតិជាមូលដ្ឋានឬ "ជីវចលនិយម"ជាមួយសាសនាក្លិង្គ គឺព្រហ្មញ្ញសាសនា។ ពុទ្ធសាសនារួមមានហីនយាន, មហាយាន និងពេជ្រយាន ដែលបានហូរចូលមកហ្វូណាន-ស្រុកខ្មែរ។ ព្រហ្មញ្ញសាសនា ដែលត្រូវបានគេនាំចូលមកស្រុកខ្មែរពីប្រទេសឥណ្ឌាប្រមាណចាប់សតវត្សរ៍ទី៣នៃគ.ស. បានឡើងជាជំនឿផ្លូវការរបស់ព្រះមហាក្សត្រខ្មែរ។នៅក្នុងព្រហ្មញ្ញសាសនា សន្តតិវង្សស្តេចនៅសម័យបុរាណ បូជាចំពោះព្រះសិវៈ ក្រោមរូបភាពនៃសិវលិង្គធ្វើអំពីមាស,ថ្ម,កែវ,ប្រាក់ និងដីដុតជាដើម។ ចំណែកតួអង្គស្តេច គេត្រូវចាត់ទុកខ្លួនឯងដូចជាព្រះវិស្ណុ-នារាយណ៍អវតារមកនៅលើផែនដី ដើម្បីធ្វើការប្រយុទ្ធ ដើម្បីការពារមនុស្សជាប្រជារាស្ត្ររបស់ខ្លួន។

ព្រះពុទ្ធសាសនា លេចឡើងនូវនិកាយទាំងពីរដែលគេហៅថា ហីនយាន និងមហាយាន ដែលសុទ្ធសឹងជាសាសនាបានកើតនៅប្រទេសឥណ្ឌានៅសម័យដើមមុនគ្រិស្តសករាជ។ សាសនានេះត្រូវបានជនជាតិខ្មែរគោរពបូជាជាខ្លាំងតាមរយៈអាទិទេពដែលមានធម៌ករុណា(ព្រះពោធិសត្វ)ព្រះពុទ្ធសាសនា មានលទ្ធិហីនយាន, ថេរវាទ និងមហាយានបានចូលប្រតិស្ឋាន ក្នុងអតីតនគរខ្មែរតាំងពីយ៉ាងហោចណាស់ក៏នៅពេលជំណាលគ្នានឹងព្រហ្មញ្ញសាសនាដែរ បើតាមកស្តុតាងបដិមាសាស្ត្រ។ នៅសតវត្សរ៍ទី៥-៦ ទំនងពុទ្ធសាសនានិកាយហីនយានមានតួនាទីយ៉ាងសំខាន់។ នៅលើសិលាចារឹកតាព្រហ្មភាសាសំស្ក្រឹតសតវត្សរ៍ទី៦ គេបាននមស្សការចំពោះព្រះជិន(ស្រី), ព្រះធម៌ និងព្រះសង្ឃដែលជាភ្នាក់ងារកាន់អំណាចខាងសាសនានេះ នៅមុនពេលគេនមស្សការចំពោះព្រះខាងព្រហ្មញ្ញសាសនា។ មានតែក្នុងនិកាយហីនយានទេ ដែលគេគោរពចំពោះសរណវត្ថុទាំងបីនេះ។ បើសាសនានិកាយមហាយានឃើញមានព្រះលាយចម្រុះជាមួយហីនយាន ដូចជានៅលើសិលាចារឹកប្រាសាទអំពិលរលើង K. 163 ក្នុងស្រុកស្ទោង ជាភាសាខ្មែរ គេធ្វើបទនមស្សការចំពោះត្រៃសរណគមន៍ មានជាអាទិ៍ ព្រះអវលោកេតិស្វរៈ, ព្រះសាស្តា ឬព្រះពុទ្ធ, និងព្រះស្រីអារ្យមេត្រី។ ក្រៅពីនេះ ក៏នៅមានសិលាចារឹកដែលធ្វើបទនមស្សការចំពោះព្រះលោកេស្វរៈ, ព្រះប្រាជ្ញាបារមីតា, ព្រះវជ្របាណិ។ ចំណែកសិលាចារឹកដទៃទៀត ដូចជា សិលាចារឹកព្រៃវៀរ ដែលជាចំណាររបស់ព្រះអរិយភិក្ខុសង្ឃពីរអង្គក្នុងត្រកូលក្សត្រ មិនបាននមស្សការចំពោះព្រះពុទ្ធ, ព្រះធម៌ព្រះសង្ឃឡើយ។ មានសិលាចារឹកសតវត្សរ៍ទី៧-៨ខ្លះទៀត សរសេរជាភាសាបាលី ដោយដកស្រង់គាថាពីក្នុងគម្ពីរព្រះត្រៃបិដក។ ក្នុងចំណោមនោះ មានគាថាមួយចារឹកលើខ្នងព្រះពុទ្ធរូបតែម្តង ដែលសព្វថ្ងៃគេដាក់តាំងនៅសារមន្ទីរហ្គីម៉េនាក្រុងប៉ារីស។

ហេតុអ្វីបានជាព្រះរាជាខ្មែរបុរាណទាំងឡាយ ខិតខំកសាងប្រាសាទប្រជែងគ្នា? បើតាមលោក ដេវីឌ ឆាណ្ឌល័រ (២០០៥)ថាការកសាងប្រាសាទដើម្បីឧទ្ទិសដល់ព្រះអង្គផ្ទាល់ និងទុកជាផ្នូររបស់ព្រះអង្គនៅពេលសោយទិវង្គត។ ការកសាងប្រាសាទ គឺជាតម្រូវការចាំបាច់សម្រាប់អ្នកមានជំនឿព្រហ្មញ្ញសាសនា ធ្វើជាលំនៅឋានសម្រាប់ពួកទេវៈ និងព្រលឹងបុគ្គលគួរគោរពដែលបានស្លាប់ទៅនិងបានឡើងឋានសួគ៌ (មិនមែនសម្រាប់តែព្រះរាជាប៉ុណ្ណោះទេ)ដើម្បីបង្ហាញពីភក្តីភាពរបស់អ្នករស់នៅចំពោះទេព និងបង្ហាញអំពីកិត្តិយសឬកេរ្តិ៍ឈ្មោះរបស់ខ្លួនឱ្យមនុស្សផងគ្នាបានមើលឃើញ និងកោតសរសើរ។ ប្រាសាទក៏ជាផ្នូរខ្មោច សម្រាប់ទុកព្រះអដ្ឋិធាតុរបស់ព្រះរាជា ឬស្ថាបនិកទាំងឡាយដែលជាម្ចាស់នៃសំណង់ផងដែរ។ ប្រាសាទខ្លះ ដូចជាប្រាសាទអង្គរវត្ត ជាកន្លែងសម្រាប់សង្កេតមើលផ្កាយផងដែរ?

តាមពិតចម្លើយនេះ គឺជាគំនិតទូទៅដែលគេពិចារណាទៅលើប្រាសាទទាំងអស់នៅសម័យអង្គរ។ តែទោះជាយ៉ាងណា គេឃើញថា វាតែងមានការទាក់ទងជាមួយជំនឿ ភក្តីភាព មុខមាត់ និងចំណេះដឹងរបស់មនុស្សបុរាណដែលគេអាចលម្អិតបានថា ៖ ដោយសារ

- កាន់គោរពសាសនាព្រាហ្មណ៍ និងព្រះពុទ្ធដែលនាំចូលមកពីឥណ្ឌា,
- ជាកន្លែងតម្កល់ព្រះសម្រាប់គោរពបូជា ត្រូវការសាងជម្រកគ្របពីលើ
- ជាជម្រករបស់ព្រះត្រូវមានគុណភាពល្អជាង និងជាប់យូរជាងជម្រករបស់មនុស្ស
- ជាជម្រកត្រូវមានបែបបទស្ថាបត្យកម្មឆើតល្អជាងជម្រករបស់មនុស្ស
- ជម្រកព្រះដំបូង គេចោះរូងភ្នំ បន្ទាប់មកធ្វើប្រាសាទពីថ្មភក់ពពុះ និងឥដ្ឋ ស្របតាមចំណេះដឹង និងបទពិសោធន៍ ពីជំនាន់មួយមកជំនាន់មួយ។
- ការរីកចម្រើនខាងគំនិតច្នៃប្រឌិត គេឃើញមានរចនាបថសំខាន់៤ បានលេចឡើងជាបន្តបន្ទាប់គឺភ្នំដារ, សំបូរ, ព្រៃក្មេង និងកំពង់ព្រះ។

តើសំណង់ទាំងនោះ បានផ្តល់ផលប្រយោជន៍អ្វីខ្លះ បានជាខិតខំនាំគ្នាកសាងឡើង? ចម្លើយ គឺថាក្រៅពីសម្រាប់គោរពបូជា ទេវស្ថានទាំងនោះផ្តល់ប្រយោជន៍ផ្សេងទៀត ដូចជា ៖

- សំណង់លើវាលរាបមានគូទឹក ព័ទ្ធជុំវិញ ឬស្រះទឹកសម្រាប់ស្តុកទឹកបម្រើដល់សហគមន៍នៅជុំវិញតំបន់ប្រាសាទ
- សំណង់លើភ្នំ គឺជាស្ថានដ៏ពិសិដ្ឋសម្រាប់គយគន់ផ្ទៃក្រោម ឬវាលរាប
- ជាកន្លែងប្រមូលផ្តុំកម្លាំងសហគមន៍ និងបង្កើនសាមគ្គីភាព
- មានប្រាសាទខ្លះជាកន្លែងតម្កល់សពមហាក្សត្រ ដូចជា សិវបុរះលើភ្នំបាយ៉ង់

មានប្រាសាទចំណាស់ពីបន្សល់ទុកដល់សព្វថ្ងៃនេះតាំងនៅលើភ្នំដារ ស្ថិតនៅខាងត្បូងរាជធានីអង្គរបុរីគេហៅថា "ប្រាសាទភ្នំដារ" ដែលស្ថិតនៅលើកំពូលភ្នំ។ ផ្នែកខាងលើប្រាសាទនេះត្រូវបានស្ថាបនាឡើងវិញ នៅចុងសតវត្សទី១០ មានតែផ្នែកខាងក្រោមនៃប្រាសាទនេះទេ ដែលនៅសល់តាំងពីសម័យហ្វូណាន។ នៅជម្រាលចង្កេះភ្នំនេះ មានសំណង់មួយទៀតឈ្មោះថាអាស្រមមហាឫសី គឺជាប្រាសាទចំណាស់មួយតាំងពីសម័យហ្វូណាន ស្ថាបនាឡើងពីវត្ថុធាតុដើមខុសពីធម្មតា គឺជាថ្មមួយប្រភេទរឹងយ៉ាងខ្លាំងហៅថា ថ្មបាសាល់។ នៅកម្ពុជា ថ្មសំណង់នេះ គេប្រទះឃើញមាននៅម្តុំវាំងខេត្តកំពង់ចាម និងក្រចេះ។ ពេលដែលបារាំងរកឃើញប្រាសាទនេះ ស្ទើរតែរលំទៅហើយ ពួកគេក៏បានជួសជុលឡើងវិញនៅឆ្នាំ១៩៣៥។ ប្រាសាទស្រដៀងគ្នានេះមួយទៀត គេឃើញមាននៅជើងភ្នំហាន់ជ័យជាប់មាត់ច្រាំងទន្លេមេគង្គ នៅខាងជើងក្រុងកំពង់ចាម ដែលមានឈ្មោះថា "គុកព្រះធាតុ"។

នៅសម័យចេនឡា ក៏ដូចជាសម័យនគរភ្នំដែរ ប្រាសាទជាច្រើន តូចធំ កសាងអំពីឥដ្ឋ និងថ្ម។ នៅសម័យដើមក៏មានកសាងប្រាសាទអំពីឈើផងដែរ ប៉ុន្តែពុកផុយអស់ទៅហើយ។ ស្ថាបត្យករខ្មែរនិយមប្រើឥដ្ឋច្រើនជាង នៅសម័យខាងដើមគេប្រើឥដ្ឋ, ថ្ម, ថ្មបាយក្រៀម, ថ្មភក់សម្រាប់ជាការកសាងបូជនីយដ្ឋាន ឬបុរាណដ្ឋាននៅសម័យនោះ។ ថ្វីត្បិតតែការកសាងប្រាសាទនៅសម័យមុនអង្គរនេះ គេនិយមប្រើឥដ្ឋជាងថ្មក៏ពិតមែន តែគេត្រូវការថ្ម យកមកប្រើប្រាស់ ធ្វើជាសសរស្តម្ភ,សសរពេជ្រ,ផ្តែរនិងពិសេសទៅទៀតនោះគឺបដិមាទេវរូប,លិង្គ,យោនី និងពុទ្ធរូប។ ការនិយមប្រើឥដ្ឋត្រូវបញ្ឈប់នៅសម័យព្រះបាទសូរ្យវម៌្មទី២ និងព្រះបាទជយវម៌្មទី៧ ដែលយើងបានឃើញហើយ គឺគេនិយមប្រើថ្មសុទ្ធក្នុងសំណង់ជំនួសឥដ្ឋវិញ។

## 7. ការបែកបាក់នៅសតវត្សរ៍ទី៨

ប្រហែលមួយសតវត្សរ៍ក្រោយមកទៀត កំណត់ហេតុចិនបានឱ្យដឹងថា ប្រទេសចេនឡាបានបែកជាពីរ ប្រហែលជាឆ្នាំ៧០៦ ដោយប្រទេសនេះមានសណ្ឋានដីពីធម្មជាតិខុសគ្នា មួយនៅតំបន់ខ្ពស់ និងមួយទៀតនៅតំបន់

វាលទំនាប ដែលលិចទឹកនៅរដូវវស្សា។ ចិនហៅប្រទេសទាំងពីរថា "ចេនឡាគោក" និង"ចេនឡាទឹកលិច"។ រឿងនេះផ្អែកលើការថ្លែងបញ្ជាក់ដោយគ្មានភស្តុតាងជាក់លាក់នៅក្នុងសៀវភៅ ប្រវត្តិសាស្ត្រថាំងថ្មី ចងក្រងឡើងវិញនៅសតវត្សរ៍ទី១១។ ចំណែកចេនឡាទឹកលិច ក្រោយមកមានក្សត្របុរីឯករាជ្យជាច្រើនទៀត បានលេចឡើង។

### 7.1. ចេនឡាដីគោក និងចេនឡាទឹកលិច

រីឯការដែលចិនកត់ត្រាថា ប្រទេសចេនឡាមានការបែកបាក់គ្នា គ្មានតឹកតាងណាមួយបង្ហាញថា តំបន់នៅខាងជើងភ្នំដងរែក ជាផ្នែកមួយនៃទឹកដីចេនឡា-កម្ពុជានោះទេ។ ព្រោះលោក ម៉ៃឃើល វិកឃើរី ជឿថា កម្ពុជាមិនមែនជារដ្ឋមួយរួបរួមទេ នៅសតវត្សរ៍ទី៧ បើតាមវត្តមាននៃសិលាចារឹកជាច្រើន ដែលបង្ហាញឱ្យឃើញតែស្រទាប់មន្ត្រីសំខាន់ពីរ ដែលមានឋានន្តរនាមជា "បោញ" និង"ម្រតាង" និងជាញឹកញាប់ពួកគេបង្ហាញអំពីខ្លួនឯងថា ជាអ្នកមានអំណាចធំជាងគេនៅក្នុងតំបន់នីមួយៗ។

លោក វិកឃើរី ជឿថា អាចមានតំបន់ពីរមែន បើតាមវត្តមានសិលាចារឹក គឺមួយនៅភាគខាងលើដែលមានមជ្ឈមណ្ឌលនៅសម្ភុបុរៈ ក្នុងតំបន់សំបូរខេត្តក្រចេះដែលអាចមានអំណាចគ្រប់គ្រងតំបន់នៅភាគខាងជើង ហើយមានមូលដ្ឋានបង្អែកសេដ្ឋកិច្ចលើវិស័យពាណិជ្ជកម្ម។ ចំណែកមួយទៀត តាំងនៅតាមវាលទំនាបលិចទឹកនៅរដូវវស្សា ដែលអាចជាប់មាត់បឹងទន្លេសាប។ ប៉ុន្តែមកដល់ពេលនេះ យើងជឿថា មជ្ឈមណ្ឌលសំខាន់នៃតំបន់ទី២នេះ គឺស្ថិតនៅអតីតរាជធានី អង្គរបុរី តែម្តង បើតាមសិលាចារឹកទ្រាំងតូច និងសិលាចារឹកកំពូលតានន់នៅលើកំពូលភ្នំមួយក្បែរភ្នំបាយ៉ង់ នាឆ្នាំ៧៦៣គ.ស.។

### 7.2. ព្រះមហារាជិនី ជយទេវី

ចំណែកការចាប់ផ្តើមពីសតវត្សរ៍ទី៨វិញ ពត៌មានសិលាចារឹកបានបង្ហាញដានហាក់ផ្ទុយពីប្រភពឯកសារចិន ត្រង់ឯកភាវូបនីយកម្មទឹកដីនៅក្រោមអំណាចរបស់អធិរាជិនីតែមួយ បានកាន់តែជោគជ័យនៅពាក់កណ្តាលទី១នៃសតវត្សរ៍ទី៨។ នោះ គឺការតម្លើងឋានៈកាន់តែខ្ពង់ខ្ពស់ជាងព្រះរាជាមុនៗរបស់ព្រះមហាក្សត្រិយានី ជយទេវី ដែលនៅលើសិលាចារឹកបារាយណ៍ទឹកថ្លា ហៅថា ធូលីជេងវ្រះកម្រតាងអញ ស្រីជយទេវី ។ ឋានន្តរនាមកាន់តែខ្ពង់ខ្ពស់ជាងព្រះមហាក្សត្រមុនៗបែបនេះ សម្គាល់ថា ព្រះនាងមានអំណាចធំជាងស្តេចប្រុសមុនៗ និងគ្រប់គ្រងដែនដីបានកាន់តែធំជាងមុន។ ឋានន្តរនាមបែបនេះត្រូវបានស្តេចចក្រពត្តិនៅសម័យអង្គរបន្តប្រើ យ៉ាងហោចណាស់រហូតដល់រជ្ជកាលព្រះបាទយសោវរ្ម័ទី១ដែរ។ លើសពីនេះទៀត ប្រវត្តិវិទូដដែលនេះ មានសុទិដ្ឋិនិយមអះអាងផ្ទុយពីអ្នកប្រាជ្ញមុនៗថា សម័យចេនឡានៅសតវត្សរ៍ទី៨ បានបន្សល់ទុកនូវសញ្ញាណថា ទឹកដីនៃប្រទេសនេះហាក់ដូចជាមានលក្ខណៈឯកភាពគ្នាច្រើនជាងសម័យមុនៗទៅវិញ បើទុកជាមានវត្តមានក្សត្រីបុរីធំៗមួយចំនួនក៏ដោយ ក៏លោក វិកឃើរី នៅតែគិតថាទឹកដីមុនរាជ្យព្រះនាងជយទេវី ទំនងជាមិនទាន់បង្រួបបង្រួមបានសម្រេចជាស្ថាពរនៅឡើយ។

ចំណុចសំខាន់មួយទៀតត្រង់ថា ការលេចឡើងក្នុងចំនួនតិច ឬគ្មានសិលាចារឹកក្នុងពេលណាមួយត្រូវអ្នកស្រាវជ្រាវខ្លះយល់ឃើញថា មកពីអំណាចស្តេចនៅអំឡុងពេលនោះខ្សោយ ហើយប្រទេសទំនងជាមិនមានការឯកភាពគ្នា។ ការយល់ឃើញបែបនេះ ត្រូវគេបដិសេធចោល ដោយសារភស្តុតាងជាក់ស្តែងនៅរាជ្យព្រះបាទជយវរ្ម័ទី២ និងទី៣ ជាបុត្រា កម្ពុជទេសពេលនោះ ពិតជាមានអំណាចខ្លាំងស្ថិតក្រោមការបង្រួបបង្រួម និងគ្រប់គ្រងដោយឯកភាពទឹកដីក្នុងវិសាលភាពដ៏ធំល្វឹងលើយ តែព្រះអង្គមិនបានបន្សល់ទុកសិលាចារឹកឱ្យកូនចៅជំនាន់ក្រោយបានដឹង

អំពីរាជកិច្ចរបស់ព្រះអង្គឡើយ។ គំរូបែបនេះ ប្រសិនបើគេប្រៀបធៀបមកសម័យកាលរបស់ព្រះនាងជយទេវីនៅដើមសតវត្សរ៍ទី៨វិញ ឃើញថាព្រះនាងពិតជាមានអំណាចធំ ទើបអាចហាមប្រាមពួកមន្ត្រីទាំងឡាយមិនឱ្យចារសិលាចារឹកផ្តេសផ្តាសបាន។

### 7.3. ជ្វាលុកលុយចេនឡា មែនទេ?

បើតាមប្រវត្តិសាស្ត្រប្រពៃណីថា នៅដើមពាក់កណ្តាលទី២នៃសតវត្សរ៍ទី៨នោះ ជ្វាបានលុកលុយដុតទីក្រុងសម្ភុបុរៈ និងចាប់ស្តេចខ្មែរ កាត់ព្រះសិរសាយកទៅថ្វាយស្តេចជ្វា។ មានមូលហេតុបីយ៉ាង ដែលនាំឱ្យអ្នកប្រវត្តិសាស្ត្រប្រពៃណីអះអាងដូច្នេះ ៖

លោក វិកឃើរី អះអាងថា នោះជាពត៌មានផ្អែកលើប្រភពរឿងព្រេងនិទានរបស់ជនជាតិអារ៉ាប់កាលពីស.វ.ទី១០ ហើយត្រូវប្រវត្តិវិទូឥណ្ឌូនេស៊ីយកមកពន្លាត និងបកស្រាយ ដើម្បីលើកកិត្យានុភាពប្រទេសជ្វាបុរាណ។ ដោយហេតុនោះអ្នកប្រាជ្ញមួយចំនួន ជាពិសេសលោក សឺដេស បានប៉ាន់ស្មានព្រឹត្តិការណ៍នៅកម្ពុជាភ្ជាប់ជាមួយចាម្ប និងយួនដែលនៅពេលជាមួយគ្នា ត្រូវពួកចោរសមុទ្ទជ្វាវាយប្រហារតាមឆ្នេរ។ យោងតាមកំណត់របស់ចិនស្ដីពីប្រទេសយួននិងចាម្ប ដែលត្រូវរងការវាយលុកច្រើនដង ដោយកប៉ាល់លើឆ្នេរសមុទ្រប្រទេសដីកោះទាំងនោះ ដែលក្នុងករណីមួយនោះ គេថាជា "កប៉ាល់ពួកជ្វា"។ ការវាយប្រហារទាំងនោះ កើតឡើងនៅឆ្នាំ៧៦៧ទៅលើប្រទេសយួន, ឆ្នាំ៧៧៤ និង៧៨៧ ទៅលើប្រទេសចាម្ប។

ផ្អែកតាមលោក ហ្សក សឺដេស ក្នុងការពិភាក្សារបស់គាត់អំពីជ្វា និង កម្ពុជា គាត់បានឱ្យសារៈសំខាន់យ៉ាងខ្លាំងដល់រាជវង្សជ្វា ហៅសៃលេន្ទ្រ ថាជារាជវង្សមួយខ្លាំងនៅដើមសតវត្សរ៍ទី៨ បានឈ្លានពានកម្ពុជា។ ប៉ុន្តែក្រោយមក រាជវង្សនេះបានចុះខ្សោយនៅចុងសតវត្សរ៍ទី៨។ ការរៀបរាប់របស់លោក សឺដេស នេះ បន្តសន្និដ្ឋានថា ប្រហែលដោយសារការចុះខ្សោយនៃរាជវង្សសៃលេន្ទ្រនៅដីកោះជ្វា(ជវា) ទើបជំរុញឱ្យស្តេចជយវម៌្មទី២ត្រលប់មកពីជ្វាវិញប្រហែលនៅឆ្នាំ៨០០ ដែលយើងមានភស្តុតាងជាច្រើនពាក់ព័ន្ធនឹងរាជ្យព្រះអង្គដំបូងថា ទ្រង់គ្រងរាជ្យនៅឆ្នាំ៨០២។

គាត់បានបន្តថា ចោរសមុទ្ទទាំងនោះ មិនអាចសន្មតថា មានប្រភពមកពីកោះជ្វានៃប្រទេសឥណ្ឌូនេស៊ីបានទេ។ ពីព្រោះ ពេលនោះអ្នកខ្លាំងខាងជើងទឹកនៅដីកោះ មិនមែនកោះជ្វាទេ តែជាកោះស៊ូម៉ាត្រានៃរាជាណាចក្រស្រីវិជ័យ ដែលមិនដែលចាប់អារម្មណ៍អ្វីក្រៅពីជំនួញ។ ហើយរឿងនិទាននោះ មិនអាចយកមកធ្វើជាការពិតប្រវត្តិសាស្ត្របានឡើយ។ រួមទាំងករណីថា ដើម្បីបង្រួមបង្រួមកម្ពុជទេស នៅចុងសតវត្សរ៍ទី៨ព្រះបាទជយវម៌្មទី២ បានយាងត្រឡប់មកពីជ្វាវិញនោះ គឺជាជ្វានៅប្រទេសឥណ្ឌូនេស៊ី។ បន្ទាប់ពីព្រះអង្គត្រូវជ្វាកៀរ ឬចាប់ជាឈ្លើយទៅទីនោះអស់ជាច្រើនឆ្នាំ។

ទោះជាយ៉ាងណា ការវាយប្រហារនេះជាការឆ្មក់វាយលុកតាមសមុទ្រ និងត្រូវបានបណ្តេញដោយពួកយួននិងចាម្បឱ្យដកថយទៅវិញយ៉ាងឆាប់រហ័ស ហើយក្នុងឆ្នាំនោះនៅកម្ពុជាកំពុងមានការបង្រួបបង្រួមដោយរាជវង្សក្នុងស្រុកផ្ទាល់។ រវាងឆ្នាំ៧៩០ សិលាចារឹកK.៥៨៣ ថាព្រះបាទជយវម៌្មទី២ គឺជាព្រះមហាក្សត្រមួយអង្គរួចស្រេចហើយ។ ព្រះអង្គ ទំនងកំពុងដឹកនាំតំបន់មួយផ្នែកនៅកម្ពុជា ដែលគេមិនស្គាល់ ដោយសារគ្មានសិលាចារឹកណាមួយបានបញ្ជាក់។

ប្រវត្តិវិទូជាច្រើននិយាយថា ព្រះបាទជយវម៌្មទី២ គឺជាស្តេចដែលបានចាប់ផ្តើមបង្រួបបង្រួមស្ថាប្រទេសឡើងវិញ នៅសតវត្សរ៍ទី៩។ ថ្វីបើគេជឿថាព្រះអង្គដើរតួនាទីសំខាន់យ៉ាងដូច្នេះមែន ប៉ុន្តែមានឯកសារតិចតួចណាស់

ដែលនិយាយពីព្រះរាជកិច្ចទ្រង់ក្នុងសម័យនោះ។ ក្នុងរជ្ជកាលព្រះអង្គ និងរាជបុត្រានៅប្រហែលជាគស៨០២ដល់ ៨៧៧ ពុំមានបន្សល់ទុកសិលាចារឹកទាល់តែសោះ។ សិលាចារឹកស្តុកកក់ធំចារនៅគស១០៥២ ចារឹកអំពីប្រវត្តិគ្រួសារមន្ត្រីជាន់ខ្ពស់មួយដែលនិយាយថា ពួកគេបានប្រមូលទ្រព្យសម្បត្តិទាំងអស់ ដើម្បីជួយទំនុកបម្រុងព្រះបាទជ័យវរ្ម័ទី២។ សិលាចារឹកនេះស្ថិតនៅភាគខាងកើតប្រទេសថៃ ជាប់ក្បែរព្រំប្រទល់ប្រទេសកម្ពុជា ជាទីតាំងផ្ទាល់មួយរបស់គ្រួសារនោះ នៅក្រោយរាជ្យព្រះអង្គប្រមាណជាង៥០ឆ្នាំ។ ពត៌មានដ៏សំខាន់មួយដែលបានពីសិលាចារឹកដដែលនេះ គឺថា "ស្តេចជយវរ្ម័ទី២យាងត្រឡប់ពីជ្វាមកកម្ពុជាវិញ" មុនពេលព្រះអង្គចាប់ផ្តើមយុទ្ធនាការបង្រួបបង្រួមប្រទេស ដើម្បីឡើងសោយរាជ្យជាសកល។ បន្ថែមលើសសិលាចារឹកនេះ គឺសិលាចារឹកវត្តសំរោង(K.៩៥៦) និយាយថាព្រះបាទជយវរ្ម័ទី២ បានបញ្ជាឱ្យគេធ្វើពិធីបុណ្យពិសេសម្យ៉ាងនៅរំដួល ដើម្បីសូមកុំឱ្យប្រទេសកម្ពុជាចំណុះជ្វា (លេងកំបិកម្មុជទេសនេះអាយត្តតជវាលេយ, លេងរ្វំអំបានវ្រះកម្មុជទេស បិជវាចាបលេយ, កំបិជវាអាក្រាន្តស្រុកខ្មែរ) ដែលត្រូវអ្នកប្រាជ្ញបរទេសសរសេរថា រក្សាប្រទេសឱ្យនៅឯករាជ្យពីជ្វា ឬកុំឱ្យជ្វាយកដាក់ជាចំណុះបានឡើយ(To keep Cambodia independent from Java)។ ដោយសារពាក្យត្រង់នេះហើយ ទើបធ្វើឱ្យមានការប៉ាន់ស្មានយ៉ាងច្រើន ចំពោះការឈ្លានពានពីសំណាក់ជ្វាមកលើកម្ពុជានាសតវត្សរ៍ទី៨។

ដើម្បីយល់ពីបញ្ហាជ្វាកាន់កាប់កម្ពុជា យើងត្រូវដឹងប្រវត្តិសាស្រ្តឥណ្ឌូនេស៊ីផងដែរ។ លោក សឺដេស បាននិយាយបំផ្លើសអំពីសារៈសំខាន់របស់រាជវង្សសៃលេន្ទ្រ(ស្តេចភ្នំ)។ ពួកគេ គឺរាជវង្សមួយក្រុមនៅក្នុងដែនដីមជ្ឈមណ្ឌលជ្វាកណ្តាលនៅសតវត្សរ៍ទី៨-៩។ ប៉ុន្តែមានកំណត់ហេតុផ្សេងៗទៀតពីរាជវង្ស ដែលមិនបានអះអាងថា ពួកគេជាសៃលេន្ទ្រទេ។ កំណត់ហេតុដំបូងពីរាជវង្សជ្វាកណ្តាលនៅលើដីកោះនោះ គឺសិលាចារឹកឆ្នាំ៧៣២ ដែលមានចារឹកអំពីស្តេចមួយអង្គព្រះនាម សញ្ជយ តែគេមិនហៅព្រះអង្គថា ជាសៃលេន្ទ្រទេ។ ក្រោយមក សិលាចារឹកមួយចំនួនបានបង្ហាញពីការរីកចម្រើនមជ្ឈមណ្ឌលជ្វាកណ្តាលពីសតវត្សរ៍ទី៨ ហើយនៅចុងសតវត្សរ៍ទី៨ និងក្នុងសតវត្សរ៍ទី៩ប្រាសាទធំៗជាច្រើនទាំងហិណ្ឌូ និងពុទ្ធសាសនាត្រូវបានស្ថាបនាឡើង។ ពួកគេបានអភិវឌ្ឍន៍រដ្ឋនៅកណ្តាលដីគោក ដោយមានទទួលឥទ្ធិពលសាសនា និងសិល្បៈច្រើនពីឥណ្ឌា នៅអំឡុងសតវត្សរ៍ទី៨-៩។ ប្រវត្តិសាស្រ្តឥណ្ឌូនេស៊ីបង្ហាញថា នៅសតវត្សរ៍ទី៨ ទាំងកោះជ្វា និងកោះស៊ូម៉ាត្រា(ស្រីវិជ័យ) គ្មានអំណាចគ្រប់គ្រាន់ ដើម្បីមកគ្របដណ្តប់មកលើកម្ពុជា និងចាប់ខ្លួនគ្រួសាររាជវង្សមួយចំនួន ដូចជាព្រះបាទជយវរ្ម័ទី២នោះទេ។ ទីតាំងតំបន់ជ្វាកណ្តាលដែលជាកន្លែងមានការរីកចម្រើន គឺស្ថិតនៅឆ្ងាយពីឆ្នេរសមុទ្រ ហើយក៏គ្មានផ្លូវទឹកល្អទៅកាន់ឆ្នេរសមុទ្រដែរ។ ទីនោះពុំមែនជាសង្គមពឹងផ្អែកលើពាណិជ្ជកម្មសមុទ្រទេ ប៉ុន្តែពឹងផ្អែកលើកសិកម្ម។ កោះជ្វាមិនមែនជាតំបន់មានអំណាចលើផ្លូវសមុទ្រ ដែលអាចចូលលុកលុយឈ្លានពានកម្ពុជាបានទេ។ នៅកោះស៊ូម៉ាត្រានៃស្រីវិជ័យ គេបានចាប់អារម្មណ៍លើការពង្រីកទំនាក់ទំនងឱ្យកាន់តែល្អជាមួយចិន ដោយសារមានផ្លូវត្រង់មួយពីឥណ្ឌូនេស៊ីទៅកាន់ប្រទេសចិនហើយគេមិនបានចាប់អារម្មណ៍នឹងការធ្វើសង្គ្រាមជាមួយកម្ពុជាទេ។ ផ្លូវពាណិជ្ជកម្មតាមសមុទ្រដោយត្រង់ផ្ទាល់នេះ កាន់តែមានសកម្មភាពក្រោយពីហ្វូណានចុះអន់ថយ ហើយកម្ពុជាសម័យចេនឡា ក៏ពុំបានប្រជែងដណ្តើមតួនាទីអ្វីជាមួយឥណ្ឌូនេស៊ីដែរ។

ជាការពិតជ្វា មានកំពង់ផែដែលចិនស្គាល់ និងបានបន្តសកម្មភាពពាណិជ្ជកម្មជាមួយចិន តាំងតែពីសតវត្សរ៍ទី៦។ យើងពុំដឹងថា តើកំពង់ផែទាំងនោះមានខ្លះស្ថិតនៅក្រោមអំណាចរាជវង្សកណ្តាលរបស់ជ្វាដែរឬទេ? យ៉ាងណាក៏ដោយកំពង់ផែបែបនោះពុំបានចាប់អារម្មណ៍ពីការវាយលុកកម្ពុជាឡើយ ពួកគេចាប់អារម្មណ៍លើការពង្រីកពាណិជ្ជកម្មកំពង់ផែជាមួយចិនទៅវិញទេ ។

មានកំពង់ផែមួយចំនួននៅជ្វា ហើយចិនបានទាក់ទងជាមួយពួកគេតាំងពីសតវត្សរ៍ទី៦។ពួកគេមានរដ្ឋតូចៗ ហើយមានតែតំបន់នៅតាមកំពង់ផែប៉ុណ្ណោះ ដែលចាប់អារម្មណ៍ជាមួយចិន។ ពួកគេគ្មានចំណាប់អារម្មណ៍ជាមួយកម្ពុជាទេ តាំងពីពេលហ្វូណានលែងមានសារៈសំខាន់។ ពួកគេគ្មានកម្លាំងយោធាគ្រប់គ្រាន់ និងសំពៅចម្បាំងធំៗ ដើម្បីបើកទៅឈ្លានពានប្រទេសនៅឯនាយសមុទ្រឡើយ។

រដ្ឋនៅមជ្ឈមណ្ឌលកណ្ដាលជ្វា ដែលពិតជាសៃលេន្ទ្រមែន ឬមិនមែននោះពុំបានចុះខ្សោយទេ នៅចុងសតវត្សរ៍ទី៨។ រដ្ឋនេះបន្តរីកលូតលាស់កាន់តែខ្លាំងពេញសតវត្សរ៍ទី៩-ទី១០ ហើយនៅពាក់កណ្ដាលទី១សតវត្សរ៍ទី១០ ស្ដេចជ្វា បានផ្លាស់រាជធានី ពីដីកណ្ដាលជ្វាទៅកាន់ឆ្នេរនៅខាងកើតជ្វាដែលជាកន្លែងមានកំពង់ផែល្អ។ ក្រោយមានតំបន់រួបរួមមួយនៅកណ្ដាល និងភាគខាងកើតកោះជ្វាបានអភិវឌ្ឍន៍ ជារដ្ឋមួយ ដែលមានអំណាចពឹងផ្អែកលើពាណិជ្ជកម្មផ្លូវសមុទ្រ។ សិលាចារឹកមួយចំនួនដែលរកឃើញនៅកោះជ្វាខាងកើតពីសម័យកាលនោះបង្ហាញឱ្យដឹងថា មានបរទេសជាច្រើនរួមទាំងខ្មែរផង បានមកដល់កំពង់ផែខាងកើតជ្វា ហើយទើបតែនៅក្រោយសតវត្សរ៍ទី១០ប៉ុណ្ណោះ ទើបជ្វាអាចមានអំណាចសេដ្ឋកិច្ច ឬ នយោបាយខ្លះលើដីគោក។

នៅសតវត្សរ៍ទី៨ ទាំងកោះជ្វា និងកោះស៊ូម៉ាត្រា(ស្រីវិជ័យ) គ្មានអំណាចគ្រប់គ្រាន់ ដើម្បីមកគ្របដណ្ដប់មកលើកម្ពុជា និងចាប់ខ្លួនគ្រួសាររាជវង្សមួយចំនួន ដូចជាព្រះបាទជយវរ្ម័ទី២នោះទេ។ នៅកោះជ្វា មជ្ឈមណ្ឌលវប្បធម៌ និងមហាក្សត្រនៅតែស្ថិតលើដីគោក ហើយកោះនេះមិនមែនជាតំបន់មានអំណាចលើផ្លូវសមុទ្រទេ។ នៅកោះស៊ូម៉ាត្រានៃស្រីវិជ័យ គេបានចាប់អារម្មណ៍លើការពង្រីកទំនាក់ទំនងឱ្យកាន់តែល្អជាមួយចិន ដោយសារមានផ្លូវត្រង់មួយពីឥណ្ឌូនេស៊ី ទៅកាន់ប្រទេសចិនហើយគេមិនបានចាប់អារម្មណ៍នឹងការធ្វើសង្គ្រាមជាមួយកម្ពុជាទេ។ ផ្លូវពាណិជ្ជកម្មតាមសមុទ្រដោយត្រង់ផ្ទាល់នេះ កាន់តែមានសកម្មភាពក្រោយពីហ្វូណានចុះអន់ថយ ហើយកម្ពុជាសម័យចេនឡា ក៏ពុំបានប្រជែងដណ្ដើមតួនាទីអ្វីជាមួយឥណ្ឌូនេស៊ីដែរ។

លោក សឺដេស គិតខុសថា ព្រះបាទជយវរ្ម័ទី២ យាងត្រឡប់មកពីជ្វានៅដើមសតវត្សរ៍ទី៩ដោយសារសៃលេន្ទ្រចុះខ្សោយ។ តាមពិត មជ្ឈមណ្ឌលកណ្ដាល ដែលពុំដឹងថាមានឈ្មោះសៃលេន្ទ្រដែរឬអត់នោះ បានបន្តរីកចម្រើនរហូតតាំងពីសតវត្សរ៍ទី៨ដល់ទី១០ ហើយស្របពេលជាមួយគ្នាក្នុងរាជ្យស្ដេចជយវរ្ម័ទី២ នេះដែរ។ ប្រទេសនេះរឹងមាំជាងនៅដើមសតវត្សរ៍ទី៨ទៅទៀត ដូចមានប្រាសាទបូរ៉ូបូឌួ និងប្រាមបាណន់ ដែលត្រូវគេកសាងនៅចុងសតវត្សរ៍ទី៨ និងនៅសតវត្សរ៍ទី៩ជាភស្តុតាងស្រាប់។ ក្រោយសតវត្សរ៍ទី១០ គឺជាពេលសមស្របបំផុត ដែលជ្វាប្រហែលអាចវាយលុកកម្ពុជា បើសិនជាគេមានបំណងយ៉ាងនោះមែន។[37]

សរុបសេចក្ដីមក រឿងជ្វាលុកលុយចេនឡា កាត់ក្បាលស្ដេចខ្មែរ និងចាប់រាជវង្សានុវង្សខ្មែរយកទៅស្រុកជ្វានៅសតវត្សរ៍ទី៨ គឺគ្រាន់តែជារឿងប្រឌិតមួយដែលគេពន្លាតចេញពីរឿងព្រេងនិទានរបស់ពួកអារ៉ាប់ដែលបានរំឭកឡើងវិញកាលពីសតវត្សរ៍ទី១០ប៉ុណ្ណោះ។ ហើយរឿងនេះ ត្រូវបានប្រវត្តិវិទូជាតិនិយមម្នាក់របស់ឥណ្ឌូនេស៊ី យកមករំលេចបន្ថែម ដើម្បីបង្ហាញអំពីអតីតកាលបែបយល់សប្តិ និងភាពមិនច្បាស់លាស់មួយនៃអំណាចរបស់កោះជ្វា មកលើអតីតចេនឡារបស់កម្ពុជាប៉ុណ្ណោះ។

---

[37] ប្រហែលដោយសារមូលហេតុអំណាចមហិមារបស់ជ្វាក្នុងសតវត្សរ៍ទី១១នោះហើយដែលនាំឱ្យគ្រួសារមន្ត្រីសំខាន់មួយរបស់ស្ដេចខ្មែរ ចារសិលាចារឹកស្ដុកកក់ធំឡើងដោយឱ្យតម្លៃដល់អំណាចជ្វា។ ព្រោះនៅពាក់កណ្ដាលសតវត្សរ៍ទី១១ ជ្វាជាប្រទេសមានអំណាចអន្តរជាតិខ្លាំង រដ្ឋាភិបាលមជ្ឈិមកំពុងមានទំនាក់ទំនងពាណិជ្ជកម្មផ្លូវសមុទ្រ និងកំពុងធ្វើពាណិជ្ជកម្មជាមួយកម្ពុជា។

ប្រទេស ដែលអាចបង្កបញ្ហាដល់កម្ពុជាក្នុងសតវត្សរ៍ទី៨ គឺចាម្ប កន្លែងដែលមជ្ឈមណ្ឌលអំណាចកណ្ដាលចាម្បផ្លាស់ពីជើងទៅត្បូងនៅបាណ្ឌុរង្គ រវាងឆ្នាំ៧៥០ ដល់៨៧០។ មជ្ឈមណ្ឌលកណ្ដាលថ្មីរបស់ចាម្បបានខិតជិតមជ្ឈមណ្ឌលកណ្ដាលកម្ពុជាពីមុន ពិសេសតំបន់ដែលគេប្រទះឃើញសិលាចារឹកដំបូងរបស់ព្រះបាទជយវម៌្មទី២ គឺ K.១៣៤។ ក្នុងសិលាចារឹកចាម្ប មានភស្តុតាងសង្គ្រាមរវាងចាម្បខាងត្បូង និងកម្ពុជា ក្រោយព្រះបាទជយវម៌្មគ្រងរាជ្យ។ ឯសិលាចារឹកសតវត្សរ៍ទី១០មួយទៀត K.៥៨៣ និយាយថា មេទ័ពជាបុត្ររបស់ស្ដេចជយវម៌្មទី២មួយអង្គព្រះនាម ឥន្ទ្រាយុធ បានវាយកំចាត់ពួកចាម្បឱ្យបរាជ័យ។ ដោយសារគេនៅតែហៅចាម្បថា ជវា (ជ្វា) ប្រហែលត្រង់នេះហើយ ដែលសិលាចារឹកចង់និយាយពាក់ព័ន្ធជាមួយព្រះបាទជយវម៌្មទី២ និងជ្វា។

និយាយរួម ពីនេះតទៅ គេគួរតែបំភ្លេចអំពីទំនាក់ទំនងកោះជ្វាជាមួយជយវម៌្មទី២។ ត្បិតព្រះអង្គបានចេញពីគ្រួសារសំខាន់មួយប្រហែលនៅ អនិន្ទិតបុរៈ ភាគខាងកើតមាត់បឹងទន្លេសាប និងត្រូវជាទិសអាគ្នេយ៍នៃអនាគតរាជធានីហរិហរាល័យ។ បើសិនជាព្រះអង្គមានទំនាក់ទំនងជាមួយបរទេសណាមួយ ប្រទេសនោះ គឺចាម្ប។ ដំណើរទៅទិសខាងជើងរបស់ព្រះអង្គពេលនោះ គឺដោយសារចាម្បខាងត្បូងមានអំណាចខ្លាំនិងអាចបង្កគ្រោះថ្នាក់ដល់កម្ពុជា។ ដូចសិលាចារឹកមួយដែលថា បុត្រព្រះអង្គព្រះនាម ឥន្ទ្រាយុទ្ធ បានធ្វើចម្បាំងប្រឆាំងនឹងចាម្ប។ នៅខាងប្រទេសចាម្បវិញនោះ មានសិលាចារឹកស្ដីពីមេទ័ពចាម្បម្នាក់ឈ្មោះ សេនាបតី បារ បានវាយឈ្លានពានកម្ពុជាក្នុងរជ្ជកាលព្រះបាទជយវម៌្មទី២។ ព្រះអង្គ បានចាប់ផ្ដើមសកម្មភាពនយោបាយប្រហែលនៅរវាងឆ្នាំ៧៨១ ព្រះអង្គបានបង្រួបបង្រួមទឹកដីផ្ទាល់ព្រះអង្គអនិន្ទិតបុរៈជាមួយសម្ភុបុរៈ ដែលជាតំបន់ក្រោមការគ្រប់គ្រងដោយគ្រួសាររាជវង្សក្សត្រីផ្ទាល់៕

# មេរៀនទី 4 សម័យអង្គរ ៖ ការកសាងអារ្យធម៌

## 1. សេចក្តីផ្តើម

អ្នកស្រាវជ្រាវតែងកំណត់សម័យអង្គរក្នុងប្រវត្តិសាស្ត្រខ្មែរថា ជាយុគសម័យដែលចាប់ផ្តើមនៅឆ្នាំ៨០២ និងចប់ទៅវិញនៅឆ្នាំ១៤៣២។ តាមការពិតឆ្នាំទាំងពីរនេះ មិនមែនជាការចាប់ផ្តើម ឬក៏ជាការបញ្ចប់ពិតប្រាកដនៃសម័យនោះឡើយ។ សម័យ "អង្គរ" ឬ "មហានគរ"នោះ ប្រហែលជាបានកើតឡើងនៅដើមសតវត្សរ៍ទី៩ និងបញ្ចប់នៅពេលព្រះបាទពញាយ៉ាតចាកចោលរាជធានីនេះ។

"អង្គរ"ជាពាក្យក្លាយពីពាក្យសំស្ក្រឹត"នគរ"ដែលមានន័យថា "ក្រុង,រាជធានី"។ ទោះបីជារាជធានីនេះត្រូវបានបោះបង់ចោលនៅសតវត្សរ៍ទី១៥ក៏ដោយ ក៏នៅឆ្នាំ១៥៧០ គេបានលើកទីក្រុងអង្គរជារាជបុរីសម្រាប់ព្រះរាជាគង់នៅឡើងវិញ។ ជាងនេះទៅទៀត ក្នុងចំណោមប្រាសាទថ្មសំខាន់ជាច្រើនទំនងជាប្រជាជនខ្មែរមិនបានបោះបង់ចោលទេ ជាពិសេសប្រាសាទអង្គរវត្ត ដោយសារប្រាសាទនេះជាកន្លែងតម្កល់ព្រះពុទ្ធបដិមា ដែលមានរចនាបថគ្រប់សម័យកាលពីសតវត្សរ៍ទី១៥ ដល់សតវត្សរ៍ទី១៩ ហើយក៏មានសិលាចារឹកនៅលើជញ្ជាំងប្រាសាទនេះ ដែលគេបានចារឹកឡើង នៅចុងឆ្នាំ១៧៤៧ថែមទៀតផង។ នៅពេលដែលសាសនទូត និងអ្នករុករកជនជាតិបារាំងបានប្រទះឃើញក្រុងអង្គរនាទសវត្សរ៍១៨៥០ ពួកគេឃើញថា មានវត្តអារាមខាងពុទ្ធសាសនាមួយនៅខាងក្នុងកំពែងប្រាសាទអង្គរវត្ត ដែលមានពលព្រះស្រីរតនត្រៃសួរពូជជាង១០០០នាក់នៅថែរក្សា។ ទោះជាយ៉ាងណាក៏ដោយ ក៏កាលបរិច្ឆេទដោយសន្មតខាងលើនេះ មានសារៈសំខាន់ដោយសារកាលបរិច្ឆេទទាំងនេះ ជាសញ្ញាប្រាប់ពីសម័យកាលរុងរឿងរបស់ប្រទេសកម្ពុជា ។ ក្នុងរយៈពេលជាង៦០០ឆ្នាំ ប្រទេសកម្ពុជា (តាមសិលាចារឹកហៅថា "កម្វុជទេស" គឺកម្ពុជទេស) គឺជាព្រះរាជាណាចក្រមានឥទ្ធិពលជាងគេបំផុតនៅអាស៊ីអាគ្នេយ៍ ដែលបានទាក់ទាញអ្នកទស្សនា និងសួយសារអាករមកពីតំបន់ឆ្ងាយៗ រហូតដល់ប្រទេសម៉ាឡេស៊ី និងប្រទេសភូមាបច្ចុប្បន្ន ព្រមទាំងមកពីតំបន់ខាងលិច ដែលក្រោយមកក្លាយជារដ្ឋថៃ។ ហើយពាក្យថា អង្គរ គឺជាពាក្យដែលគេសំដៅហៅឈ្មោះ អតីតរាជធានីខ្មែរ ដែលចាប់កសាងឡើងដំបូង ដោយព្រះបាទ យសោវរ្ម័ ទី១ គ.ស.៨៨៩-៩០០។

ទីក្រុងអង្គរ ដែលមានឈ្មោះដើមថា យសោធរបុរៈ កសាងឡើងជំនាន់នោះ គឺមានកំពែងដីព័ទ្ធជុំវិញ សព្វថ្ងៃនៅសល់ស្នាមខ្លះនៅទិសខាងត្បូងនិងខាងលិច ដែលមាន"ភ្នំបាខែង កម្ពស់ប្រហែល៦០មនៅចំកណ្តាល ដែលក្នុងសិលាចារឹកហៅថា ភ្នំកណ្តាល"។ ផ្ទុយទៅវិញ ចំពោះសម័យអង្គរ គឺគេមិនរាប់ចាប់តាំងពីរជ្ជកាលព្រះបាទ យសោវរ្ម័ ទេ គឺគេរាប់ចាប់តាំងពីរជ្ជកាលព្រះបាទ ជយវរ្ម័ទី២ នៅគ.ស.៨០២។ ទីក្រុងនេះមានការព្យាយាមកសាងអស់បួនដំណាក់កាល និងមានមូលដ្ឋានស្នូលនៅលើទីតាំងខុសគ្នាបន្តិចៗតែប៉ុណ្ណោះ។ ទីមួយ គឺយសសោធរបុរៈ ដែលមានភ្នំបាខែងជាផ្ចិត, ទីពីរ គឺជយេន្ទ្រនគរី ដែលមានប្រាសាទហេមស្រីង្គគិរី ឬ ប្រាសាទតាកែវ ជាផ្ចិតនៃទីក្រុង។ តែទីក្រុងនេះត្រូវបរាជ័យក្នុងការកសាងបង្ហើយ ព្រោះប្រាសាទស្នូលទីក្រុងត្រូវរន្ទះបាញ់ នាំឱ្យគេឈប់បន្តបង្ហើយសំណង់នៅក្នុងរាជ្យសូរ្យវរ្ម័ទី១។ម្ល៉ោះហើយ ឈ្មោះទីក្រុងអង្គរទី៣ដែលមានផ្ចិតនៅប្រាសាទបាពួនរបស់ព្រះបាទឧទយាទិត្យវរ្ម័ទី២ បានក្លាយទៅជា ទីក្រុងអង្គរទី២វិញ។ ទីក្រុងទី៤ ដែលគេសន្មតហៅជាទី៣ គឺយសោធរបុរៈ ដែលមានផ្ចិតនៅត្រង់ប្រាសាទបាយ័ន កសាងដោយព្រះបាទ ជយវរ្ម័ទី៧ បានបន្សល់កស្តុតាងយ៉ាងប្រត្យក្សរហូតដល់សព្វថ្ងៃនេះ ហើយដែលប្រាសាទទាំងឡាយ នៅក្នុងបរិវេណនេះ ត្រូវអ្នកស្រុកអាយហៅថា អង្គរធំ។

## 2. ព្រះបាទជ័យវរ្ម័នទី២ ក្នុងយុទ្ធនាការស្តារប្រទេស

ប្រវត្តិវិទូជាច្រើននិយាយថា ព្រះបាទជ័យវរ្ម័នទី២ គឺជាស្តេចដែលបានចាប់ផ្តើមបង្រួបបង្រួមស្តារប្រទេសឡើងវិញ នៅសតវត្សរ៍ទី៩ ហើយទ្រង់ក៏ជាស្ថាបនិកប្រវត្តិសាស្រ្តអង្គរដែរ។ ថ្វីបើគេជឿថាព្រះអង្គដើរតួនាទីសំខាន់យ៉ាងដូច្នេះមែន ប៉ុន្តែមានឯកសារតិចតួចណាស់ដែលនិយាយពីព្រះរាជកិច្ចទ្រង់ក្នុងសម័យនោះ។ ក្នុងរជ្ជកាលព្រះអង្គ និងរាជបុត្រានៅប្រហែលចន្លោះឆ្នាំ៨០២ ដល់ឆ្នាំ៨៧៧ ពុំមានបន្សល់ទុកសិលាចារឹកទាល់តែសោះ។ រាល់ព័ត៌មានរបស់ព្រះបាទជ័យវរ្ម័នទី២ បានពីសិលាចារឹកស្តុកកក់ធំ (K.២៣៥) និងសិលាចារឹកផ្សេងៗទៀត ដែលសរសេរនៅសម័យកាលជាង២០០ឆ្នាំក្រោយ។

បើតាមលោក សឺដេសថា ព្រះបាទជ័យវរ្ម័នទី២ សុគតនៅឆ្នាំ៨៥០? ក្រោយមកនៅក្នុងអត្ថបទសំខាន់មួយសរសេរនៅឆ្នាំ១៩៧២ ដោយលោកClaude Jacques គាត់បានលើកឡើងថា ព្រះបាទជ័យវរ្ម័នទី២ ពុំអាចមានព្រះជន្មរស់បានយូរដូចដែលលោក សឺដេស គិតនោះទេ គឺត្រឹមឆ្នាំ៨៣៤ប៉ុណ្ណោះ បើតាមសិលាចារឹកប្រាសាទគោកចក។ កាលបរិច្ឆេទនេះ អាចឱ្យព្រះបាទជ័យវរ្ម័នទី២ មានព្រះជន្មចំនួន ៨៤ព្រះវស្សា ឬតិចជាងនេះ។ ប្រសិនបើព្រះអង្គប្រសូត្រក្នុងអំឡុងឆ្នាំ៧៥០-៧៥៥ ។

សិលាចារឹក K.១៣៤ បាននិយាយនៅក្នុងផ្នែកភាសាសំស្រ្កឹតថា ព្រះបាទជ័យវរ្ម័នទី២ មានគោរម្យងារជាបរមេស្វរល្លកៈ "ជាទីស្រឡាញ់របស់បរមេស្វរៈ(ដែលជាឈ្មោះរបស់ព្រះឥសូរដ៏ខ្ពង់ខ្ពស់)" ដោយសារព្រះអង្គបានប្រតិស្ឋានអាទិទេពដាក់ព្រះនាមដូច្នេះនៅសម្ភុបុរៈនាឆ្នាំ៧៨១។ ហើយក្នុងសិលាចារឹកសម័យអង្គរ ពាក់ព័ន្ធនឹងព្រះអង្គក្រោយពេលចូលទិវង្គត ជាពិសេសសិលាចារឹកស្តុកកក់ធំដដែល គេហៅព្រះអង្គថា ព្រះបាទបរមេស្វរៈ ដែលមានន័យថា ស្តេចយាងទៅស្ថានព្រះបរមេស្វរៈ។ ឈ្មោះស្ថាននេះ ពិតជាដូចគ្នា នឹងឈ្មោះរបស់ព្រះឥសូរ ដែលព្រះអង្គគោរពបូជាពេលនៅមានព្រះជន្មនៅឡើយ។ ដូច្នេះហើយ, ទើបក្រោយពេលព្រះអង្គសុគត ត្រូវគេជឿថា ទ្រង់បានយាងទៅគង់នៅក្នុងស្ថានរបស់ព្រះឥសូរនោះឯង ក្នុងឋានៈជាអាទិទេព។ ចំណែកនៅលើផែនដី គេប្រតិស្ឋានស្ថាននាម "បរមេស្វរៈ"នេះ នៅត្រង់តួប៉មកណ្តាលជួរមុខនៃប្រាសាទព្រះគោ។

ព្រះអង្គ បានចាប់ផ្តើមសកម្មភាពនយោបាយប្រហែលនៅរវាងឆ្នាំ៧៨១ ព្រះអង្គបានបង្រួបបង្រួមទឹកដីផ្ទាល់ព្រះអង្គ គឺអនិន្ទិតបុរៈ[38]ជាមួយនឹងសម្ភុបុរៈ ដែលជាតំបន់ក្រោមការគ្រប់គ្រងដោយគ្រួសាររាជវង្សក្សត្រីផ្ទាល់។ ប្រទេសដែលបង្កបញ្ហាដល់កម្ពុជាក្នុងសតវត្សរ៍ទី៨ គឺចាម្ប កន្លែងដែលមជ្ឈមណ្ឌលអំណាចកណ្តាលចាម្បផ្លាស់ពីជើងទៅត្បូងនៅបាណ្ឌុរង្គ រវាងឆ្នាំ ៧៥០ ដល់ ៨៥០។ មជ្ឈមណ្ឌលកណ្តាលថ្មីរបស់ចាម្ប បានខិតជិតមជ្ឈមណ្ឌលកណ្តាលកម្ពុជាពីមុន ពិសេសតំបន់ដែលគេប្រទះឃើញសិលាចារឹកដំបូងរបស់ស្តេចជ័យវរ្ម័ន។ នៅខាងចាម្បវិញនោះមានសិលាចារឹកពីមេទ័ពចាម្បម្នាក់ឈ្មោះសេនាបតីបារ បានវាយឈ្លានពានកម្ពុជាក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី២។ ប្រហែលដោយសារ រឿងឈ្លានពាននោះហើយ ទើបសិលាចារឹកសតវត្សរ៍ទី១០មួយរបស់ខ្មែរ K.៨៥៣ និយាយ

---

[38] លោក វិកឃើរី ធ្លាប់គិតថា វ្យាធបុរៈទំនងជាទឹកដីកំណើតរបស់ព្រះអង្គ ដោយសារគាត់ជឿថា នាមព្រះបាទ ជ័យវរ្ម័ន នៅលើសិលាចារឹកព្រះធាតុបាស្រី នៅអូរាំងឪ ឆ្នាំ៧៧០ គឺជាព្រះបាទ ជ័យវរ្ម័នទី២ ។ តែបើយើងពិនិត្យមើលលើព័ត៌មានសិលាចារឹកថ្មីៗមួយចំនួនទៀត ការអះអាងបែនេះ នឹងអាចនាំឱ្យមានការរារែកមិនខាន។ ព្រោះនៅអំឡុងទសវត្សរ៍ឆ្នាំ៧៦០ មានព្រះបាទ ជ័យវរ្ម័ទេព មួយអង្គទៀត ដែលទំនងជាសោយរាជ្យនៅអង្គរបុរី។ ម្យ៉ាងទៀត សិលាចារឹកប្រាសាទគោកចក ថា ព្រះបាទជ័យវរ្ម័នទី៣ មានស្រុកកំណើតនៅអនិន្ទិតបុរៈដើមដែរ ដូចគ្នានឹងគ្រួសារព្រាហ្មណ៍សិវកៃវល្យ។ ប្រហែលដោយសារមានស្រុកកំណើតជាមួយគ្នា និងជាអ្នកមានឥទ្ធិពលនៅនគរឥន្រ្ទបុរៈផង ទើបព្រះបាទជ័យវរ្ម័នទី២ លើកព្រាហ្មណ៍រូបនេះ ឱ្យមានឋានៈដ៏ខ្ពង់ខ្ពស់។

ថា នៅរវាងឆ្នាំ៧៩០ មានមេទ័ពជាបុត្រាមួយអង្គ របស់ព្រះបាទជយវម៌្មទី២ ទ្រង់ព្រះនាម ឥន្រ្ទាយុធ បានវាយកំចាត់ពួកចាម្បឱ្យបរាជ័យ និងចាប់បានស្តេចចាម្បមួយអង្គមកជាមួយវិញផង។

ចំណុចខុសគ្នានៅត្រង់ថា សិលាចារឹកខ្មែរសតវត្សរ៍ទី១០ថា ជយវម៌្មទី២ និងបុត្រាធ្វើសង្រ្គាមជាមួយ"ចាម្ប" តែសិលាចារឹកស្តុកកក់ធំពាក់កណ្តាលសតវត្សរ៍ទី១១ ថា ជយវម៌្មទី២យាងត្រឡប់មកពី"ជវា"ឬ "ជ្វា"។ ដូច្នេះ តើចាម្ប និងជ្វា នេះជាកន្លែង ឬប្រទេសតែមួយ ឬយ៉ាងណា?

សិលាចារឹកស្តុកកក់ធំនិយាយថា ស្តេចជយវម៌្មទី២ យាងត្រឡប់ពីជ្វាមកកម្ពុជាវិញ មុនពេលព្រះអង្គចាប់ផ្តើមយុទ្ធនាការបង្រួបបង្រួមប្រទេស ដើម្បីឡើងសោយរាជ្យ។ សិលាចារឹកនេះ, សិលាចារឹកវត្តសំរោង(K.៩៥៦) និងសិលាចារឹកសប្បាក (K.១១៥៨) និយាយថាព្រះបាទជយវម៌្មទី២បានដឹកនាំពិធីបុណ្យពិសេសម្យ៉ាង ដើម្បីសូមកុំឱ្យប្រទេសកម្ពុជាចំណុះជ្វា (លេងកំបិកម្មុជទេសនេះអាយត្តតជវាលេយ, លេង្វំអំបានវ្រះកម្មុជទេសបិជវាចាបលេយ, កំបិជវាអាក្រាន្តស្រុកខ្មែរ) ដែលត្រូវអ្នកប្រាជ្ញបរទេសសរ-សេរថា រក្សាប្រទេសឱ្យនៅឯករាជ្យពីជ្វា ឬកុំឱ្យជ្វាយកដាក់ជាចំណុះបានឡើយ(To keep Cambodia independent from Java)។ ដោយសារពាក្យត្រង់នេះហើយ ទើបធ្វើឱ្យមានការប៉ាន់ស្មានយ៉ាងច្រើន ចំពោះការឈ្លានពានពីសំណាក់ជ្វាមកលើកម្ពុជានាសតវត្សរ៍ទី៨។

ដូចដែលបានបង្ហាញនៅចុងមេរៀនមុនថា កោះជ្វាគ្មានអំណាចលើចេនឡានោះទេ ផ្ទុយទៅវិញ អាចចាម្បភាគខាងត្បូងនៅសតវត្សរ៍ទី១១ត្រូវគេហៅថា ជវា ឬ យវទ្វីប ទើបនាំឱ្យប្រវត្តិវិទូច្រឡំទីតាំង។

### 3. នយោបាយផ្សះផ្សារជាតិ

#### +ការលើករាជធានីជាញឹកញាប់មុននឹងឡើងសោយរាជ្យ

តាមរយៈសិលាចារឹកស្តុកកក់ធំ (ពិធីលេហ), វត្តសំរោងនៅព្រៃវែង (ពិធីក្សាណសិទ្ធិ) និងសិលាចារឹកសប្បាកនៅប្រទេសថៃ(ពិធីតាំងព្រះពោធិសត្វលោកេស្វរះ៩អង្គ លើភ្នំអភយគិរីដើម) បានឱ្យដឹងថា ព្រះរាជា ជយវម៌្មទី២ប្រារព្ធធ្វើពិធីដ៏ធំចំនួនបីនៅទីកន្លែងខុសគ្នាក្នុងគោលបំណងប្រសិទ្ធី "កុំឱ្យប្រទេសកម្ពុជាចំណុះជវា ឬ កុំឱ្យជវាយកប្រទេសកម្ពុជាដាក់ជាចំណុះបាន"។ ពីដើមឡើយ ពាក្យ"ជវា"នោះ គេគិតថា ជាកោះជ្វានៅប្រទេសឥណ្ឌូនេស៊ីសព្វថ្ងៃ។ តែតាមលោក ម៉ៃឃើល វីកឃើរី ថា វាគួរតែជាប្រទេសចាម្បនៅត្រង់ផ្នែកខាងត្បូងដែលមានមូលដ្ឋាននៅបាណ្ឌុរង្គ ឬក្នុងខេត្តផាន់រ៉ាង នៃប្រទេសវៀតណាមកណ្តាលសព្វថ្ងៃ។

រាជកិច្ចលើកដំបូងរបស់ព្រះបាទ ជយវម៌្មទី២ គឺឡើងគ្រងរាជ្យនៅរាជធានី(នគរ)មួយឈ្មោះឥន្រ្ទបុរៈ ដែលគេសន្និដ្ឋានថាប្រហែលនៅក្នុងស្រុកត្បូងឃ្មុំ(ស្រុកពញាក្រែក) ខេត្តកំពង់ចាមសព្វថ្ងៃ ដែលជាទឹកដីកម្មសិទ្ធិរបស់ព្រាហ្មណ៍សិវកៃវល្យ។ បន្ទាប់ពីនោះព្រះអង្គបានផ្លាស់រាជធានីជាបន្តបន្ទាប់ទៅកាន់តំបន់អង្គរ ខេត្តសៀមរាបភាគខាងកើត និងកណ្តាលសព្វថ្ងៃ ដែលទំនងជាត្រូវគេហៅថា ខេត្តបូព៌ាទិស។ ក្រោយពីឱ្យដីឈ្មោះកុតិ ទៅគ្រួសារសិវកៃវល្យ ព្រះអង្គបានកសាងរាជធានីហរិហរាល័យឡើង ដែលសព្វថ្ងៃត្រូវនឹងតំបន់ប្រាសាទព្រៃមន្ទីរ, បាគង, ព្រះគោ និងលលៃ។ ជាបន្តបន្ទាប់មក ព្រះអង្គផ្លាស់ទៅបង្កើតនគរឈ្មោះ អមរេន្រ្ទបុរៈ ដែលគេសន្និដ្ឋានមិនទាន់ដាច់ស្រេចថា ស្ថិតនៅត្រង់ទីណាមួយក្នុងចំណោមកន្លែងសំខាន់បី គឺម្តុំបារាយណ៍ទឹកថ្លា, ភ្នំស្រុក និងប្រាសាទបន្ទាយឆ្មារ នៃអតីតខេត្តវិជយបុរៈ។ ចុងក្រោយ ព្រះអង្គផ្លាស់ទៅតាំងរាជធានីនៅលើមហេន្រ្ទបព៌ត ដែលត្រូវនឹងភ្នំគូលេន ជាទីកន្លែងដែលព្រះអង្គប្រារព្ធធ្វើពិធីលេហ ឬតាំងទេវរាជ។ គ្មានសិលាចារឹកដទៃទៀតនិយាយឱ្យពិស្តារជាងនេះឡើយ ក្រៅពីចារឹកស្តុកកក់ធំ។ ដោយសារការផ្លាស់រាជធានីបែបនេះ អ្នកប្រវត្តិសាស្រ្តស្ទើរតែគ្រប់គ្នាបានសន្និដ្ឋាន

ស្របគ្នាថាព្រះអង្គបានបំពេញរាជកិច្ចបង្រួមបង្រួមជាតិ មុនពេលប្រកាសឡើងសោយរាជ្យជាស្តេចចក្រពត្តិ។ បើពុំនោះទេ តើមូលហេតុអ្វី ដែលជំរុញឱ្យព្រះអង្គចាំបាច់លើករាជធានីជាច្រើនដំណាក់បែបនេះ ហើយមានអ្នកប្រវត្តិសាស្ត្រជាច្រើនទៀតនោះថែមទាំងបានបរិយាយពន្លាតបន្ថែមលើការផ្លាស់ប្តូររាជធានីនេះថែមទៀតផង។ បើតាមពិតទៅ ការសន្និដ្ឋានបែបនេះ ដោយសារផ្អែកលើមូលដ្ឋានពត៌មានថា កាលពីសតវត្សរ៍ទី៨ប្រទេសចេនឡាទាំងមូលគ្មានការឯកភាពគ្នាជាអាណាចក្រមួយរួបរួមគ្នាដូចកាលពីសតវត្សរ៍ទី៧។ ក៏ប៉ុន្តែយើងគិតថា ការសន្និដ្ឋាននេះមានលក្ខណៈត្រឹមត្រូវ បើទុកជាគ្មានឯកសារជាលាយលក្ខណ៍អក្សរណាមួយបានបញ្ជាក់ក៏ដោយ ។ ពីព្រោះយើងផ្អែកទៅលើភស្តុតាងមួយទៀត ដែលនឹងពិភាក្សានៅខាងក្រោម ។

**+ការតម្លើងឋានន្តរសក្តិឱ្យចៅហ្វាយស្រុកតាមរយៈបរមនាម**

ជាធម្មតាឋានន្តរនាម (Title Nouns) និងបរមនាម(Epithet nouns)មន្ត្រីនៅសម័យមុនអង្គរ គ្មានប្រើប្រាស់បច្ចេកពាក្យថា"វ្រះកម្រតាងអញ" ឬស្មើ "កម្រតេងអញ" (នៅសម័យអង្គរ) សម្រាប់ហៅសម្គាល់មន្ត្រីជាន់ខ្ពស់ឡើយ។ ផ្ទុយទៅវិញ ឋានន្តរនាមដ៏ខ្ពង់ខ្ពស់នេះសម្រាប់ប្រសិទ្ធិនាមឱ្យតែ"ព្រះមហាក្សត្រ" និង"អាទិទេព" ប៉ុណ្ណោះ។ ចំណែកបរមនាម"វម៌្ម" (=វរ្ម័ន) គេប្រើសម្រាប់តែឈ្មោះរបស់ព្រះរាជា ជា"អធិរាជ"តែមួយអង្គគត់។ មកដល់សម័យអង្គរ យើងកត់សម្គាល់ឃើញថា ឋានន្តរនាម និងបរមនាមដូចបានបង្ហាញខាងលើនេះ ត្រូវបានព្រះរាជាបំពាក់ឱ្យមន្ត្រីដែលមានឋានៈត្រឹមចៅហ្វាយខេត្ត ឬមួយក្រមការខេត្តនៅពេលនោះ។ ត្រង់នេះសរឱ្យឃើញថា ព្រះរាជាបានប្រើនយោបាយមួយលើកឋានៈ ឬទទួលស្គាល់ឋានៈរបស់ចៅហ្វាយខេត្តទាំងអស់នោះឱ្យស្មើនឹងឋានៈព្រះរាជា ឬក៏ស្តេចត្រាញ់មួយអង្គ នៅសម័យមុនអង្គរ។ នេះជានយោបាយដ៏ឈ្លាសវៃមួយ ដើម្បីលួងចិត្តពួកស្តេចត្រាញ់ទាំងឡាយឱ្យទទួលស្គាល់អំណាចរបស់ព្រះអង្គ។ ម្ល៉ោះហើយ ទ្រង់ក៏បានលើកខ្លួនឯងឡើងឋានៈជាស្តេចចក្រពត្តិ-ចក្រវត្តិន។ នយោបាយបែបនេះ យើងបានឃើញគេយកមកប្រើប្រាស់នៅសម័យសព្វថ្ងៃដែរ ដើម្បីធ្វើការបង្រួបបង្រួមជាតិ ដែលបានបែកបាក់គ្នាអស់ជាច្រើនទសវត្សរ៍មកហើយនោះ។ ដោយមូលហេតុរបស់វា បណ្តាលមកពីភាគីម្ខាងៗចង់ធ្វើធំ។ ដូច្នេះហើយ បានជានៅកម្ពុជា គេបានប្រគល់ឋានន្តរៈ"ឯកឧត្តម" ឱ្យមន្ត្រីជាន់ខ្ពស់រាប់រយនាក់។

## 4. ធម្មតាពទេវរាជ ឬ លទ្ធិទេវរាជ

សាច់រឿងសំខាន់នៅក្នុងសិលាចារឹកស្តុកកក់ធំ ទាក់ទងទៅនឹងឈ្មោះមួយដែលគេហៅថា ទេវរាជ។ សិលាចារឹកនេះនិយាយថា ស្តេចជយវម៌្មទី២បានយាងទៅមហេន្ទ្របវ៌ត (ភ្នំមហេន្ទ្រ) បើតាមសិលាចារឹកគុហាពងកេងកង គឺត្រូវនឹងភ្នំគូលែន និងបានប្រារព្ធពិធីបុណ្យនៅទីនោះ។

គោលបំណងនៃពិធីបុណ្យ"លេហ"នោះ គឺទីមួយសូមកុំឱ្យប្រទេសកម្ពុជាចំណុះជ្វា, ទីពីរដើម្បីប្រតិស្ឋាន ឬទេវាភិសេក ជាទេវរាជ ជាភាសាសំស្ក្រឹត ដែលជាប្រភេទ"ទេព" ម្យ៉ាងត្រូវនឹងភាសាខ្មែរថា កម្រតេងជគតតរាជ, ទីបី លើកឋានៈព្រះអង្គនឹងទាយាទទាំងអស់នៅពេលអនាគតឡើងជាស្តេចចក្រពត្តិ ឬ ចក្រវត្តិន ដែលប្រវត្តិវិទូខ្មែរនាំគ្នាបកប្រែពីភាសាបារាំងមកវិញថា ស្តេចចក្រវាឡ, ទីបួនព្រះរាជា និងព្រាហ្មណ៍ហិរណ្យទាម ដែលជាអ្នកធ្វើពិធីនេះបានតែងតាំងព្រាហ្មណ៍ សិវកៃវល្យ ដែលជាបុរោហិតទីមួយនៅពេលនោះ និងបច្ចាជនរបស់គាត់ទៅអនាគត ឱ្យទៅជាមន្ត្រីទទួលខុសត្រូវលើការងារថែរក្សា បូជាចំពោះ"អាទិទេពកំពូល"–ទេវរាជនោះ។ ត្រង់នេះបង្ហាញថា វាពិតជាសំខាន់ចំពោះគ្រួសារចារសិលាចារឹក បន្ទាប់ពីគេបានកាន់កាប់តំណែងដ៏សំខាន់នេះ និងថែរក្សាទុក កម្រតេងជគតតរាជ អស់រយៈកាលជាង២៥០ឆ្នាំមក។

### តើ ទេវរាជ/កម្រតេង ជគត ត រាជ គឺជាអ្វី ?

ប្រវត្តិវិទូជាច្រើន បានផ្តោតការយកចិត្តទុកដាក់តែលើផ្នែកភាសាសំស្ក្រឹតនៃសិលាចារឹកស្តុកកក់ធំ ហើយបានបកស្រាយពន្យល់ថា ទេវរាជ គឺស្តេចដែលដូចជាអាទិទេព ឬ មានអ្នកប្រាជ្ញខ្លះ ថាស្តេចនៃអាទិទេព=អាទិទេពច្បងគេ ដែលនោះគឺជាព្រះឥសូរនោះឯង, អាទិទេពរបស់ស្តេច ឬថា ស្តេច(នៃមនុស្ស គឺជាស្តេច) នៃទេពទាំងឡាយ ដែលនេះជាការយល់ខុសស្រឡះតែម្តង ព្រោះមនុស្សមិនអាចមានឋានៈដល់ទៅជាស្តេចនៃអាទិទេពបានឡើយ។ លោក សឺដេសនៅក្នុងសៀវភៅរបស់គាត់(*Indianized States*) ក៏បានគិតដែរថា "ទេវរាជ គឺជាប្រភេទសិវលិង្គម្យ៉ាងតំណាងឱ្យស្តេច ហើយស្តេចគ្រប់អង្គ ដែលគ្រងរាជ្យបន្ទាប់ពីព្រះបាទ ជយវម៌្ម បានស្ថាបនាប្រាសាទមួយកណ្តាលទីក្រុង ដើម្បីឧទ្ទិសចំពោះទេវរាជ"។ ប្រវត្តិវិទូផ្សេងទៀតធ្វើការពន្យល់ និងលើកសំណើខុសគ្នាតិចតួច ប៉ុន្តែពួកគេទាំងអស់នោះបានគិតតែទេវរាជក្នុងភាសាសំស្ក្រឹត ដោយជឿថា គឺជាសិវលិង្គម្យ៉ាងតំណាងឱ្យស្តេច។

បើសិនជា ពួកគេផ្តោតលើការយកចិត្តទុកដាក់លើផ្នែកភាសាខ្មែរនៃសិលាចារឹកស្តុកកក់ធំវិញនោះ ការពន្យល់របស់គេអាចផ្សេងពីនេះ។ ឈ្មោះជាភាសាខ្មែរ"កម្រតេងជគត តរាជ" ពុំមានទំនាក់ទំនងចំពោះព្រះឥសូរទេ។ ពាក្យនេះមានន័យថា កម្រតេង=ជាម្ចាស់ ឬអម្ចាស់,ជគត(ជាពាក្យសំស្ក្រឹត)=ពិភពលោក, ត=ដ៏,នៃ ឬជារបស់, រាជ(សំ.)=ស្តេច។ បើសរុបទៅពាក្យនេះមានន័យថាអម្ចាស់នៃលោកគឺជាស្តេច ។ ពាក្យសំស្ក្រឹត"ទេវរាជ"ពុំមានឃើញក្នុងសិលាចារឹកផ្សេងទៀតទេ។ ប៉ុន្តែពាក្យខ្មែរប្រហាក់ប្រហែលឬដូចគ្នា គេមានប្រទះឃើញនៅក្នុងសិលាចារឹក K.៨៤៣ និង K.៨៥៤ ក្នុងរាជ្យព្រះបាទជយវម៌្មទី៤ ឆ្នាំ៩២៨ដល់៩៤២(វ្រះកម្រតេងអញ/ជគត តរាជ) ហើយក្នុងK.៩០២/គ.ស ៩៨០ (កម្រតេងអញតរាជ) ឃ្លាទាំងនេះ ប្រហែលជារៀបរាប់អំពីស្ថាប័នសាសនាតែមួយ និងបានបង្ហាញតឹកតាងថាប្រភពដើមនៃពាក្យគឺជារបស់ខ្មែរ និងជាប្រភេទអាទិទេពដើមរបស់ខ្មែរ ហើយឈ្មោះនេះត្រូវបានប្រែជាភាសាសំស្ក្រឹតថា ទេវរាជ ដែលមានតែក្នុងស្តុកកក់ធំមួយប៉ុណ្ណោះ និងមិនមែនជាការបកប្រែដែលគាប់ប្រសើរទេ។

ការសិក្សាពីកម្រតេងជគតតរាជ ចុងក្រោយបង្អស់ដោយលោក *Claude Jacques* [39] បានបង្ហាញថា កម្រតេងជគតតរាជ ជាទេពការពារស្រុកម្យ៉ាងរបស់ខ្មែរ ដូចអ្នកតា មានអំណាចខ្លាំង ហើយមានកម្រតេងជគត តរាជលើសពីមួយក្នុងពេលតែមួយ។ ដំបូងលោក C. Jacques បានបង្ហាញតឹកតាងថា នៅកម្ពុជាសម័យបុរាណ ជគតិស្វរៈជាពាក្យសំស្ក្រឹតមួយទៀតមានន័យថា"ម្ចាស់នៃពិភពលោក" ដែលនៅប្រទេសឥណ្ឌាមានន័យថាព្រះសិវៈនៅកម្ពុជាមិនមែនមានន័យថាព្រះសិវៈទេ។ ព្រោះពាក្យនេះ នៅកម្ពុជាប្រើសម្រាប់ពុទ្ធបដិមា។ ជគទិស្វរៈ ជាការបកប្រែពីពាក្យខ្មែរ កម្រតេងជគត ។ ដូច្នេះកម្រតេងជគត គឺជាទេពពិសេសម្យ៉ាងរបស់ខ្មែរ។

លោក ក្លូដហ្សាក់ក៏បានបង្ហាញដែរថា ក្រៅពីកម្រតេងជគត មានទេពខ្មែរមុនៗដែលគេហៅថា កំស្តែងជគត ឧទាហរណ៍ កម្រតេង ជគត បឹង ថ្ម ដែលមើលទំនងដូចគ្នានឹងអ្នកតាម្យ៉ាងហើយគេក៏ហៅថា កំស្តែង ជគត បឹងថ្ម ដែរ។ នេះមានន័យថា កម្រតេង ជគត តរាជ ពិសេសម្យ៉ាង ជាអាទិទេពរបស់ខ្មែរសំខាន់ដូចអ្នកតាសម្រាប់ការពារស្តេច។ យើងពុំដឹងថា ទេពនោះមានរូបរាងដូចម្តេចទេ ក៏ប៉ុន្តែប្រហែលជាមិនមែនជាសិវលិង្គទេ។

ហេតុអ្វីខ្មែរយកពាក្យសំស្ក្រឹត"ជគត"មកប្រើ? លោកម៉ៃឃើល វីកឃើរី ថាដោយសារខ្មែរសម័យបុរាណពុំមានពាក្យសម្រាប់ពិភពលោកទាំងមូល ឬសូម្បីពាក្យសម្រាប់អាណាចក្រធំមួយ ដែលកើតមកពីការរួមបញ្ចូលអាណាចក្រតូចៗជាច្រើន ឬរដ្ឋតូចៗ។ ពាក្យខ្មែរតែមួយគត់ដែលគេប្រើគឺ ស្រុកដែលសម្គាល់ជាទឹកដីមួយតូច ហើយ

---

[39] "The Kamrateń Jagat ta Raja in Ancient Cambodia," *Indus Valley to Mekong Delta, Exploration in Epigraphy*, 1985.

មានន័យថា ជាជីសម្រាប់ស្តេចត្រាញ់ ឬបោញគ្រប់គ្រង។ ដូច្នេះពាក្យនេះពុំស័ក្តិសមនឹង"ទេព" ជាពិសេសសម្រាប់" ស្តេចអស្ចារ្យ"ដូចស្តេចសម័យអង្គរទេ។ សម័យមុនអង្គរក៏មានទេពស្រដៀងគ្នាខ្លះដែរ ដែលគេហៅថា វ្រះកម្រតាងអញ កម្រតាងស្រុក។ ឧទាហរណ៍ ក្នុងសិលាចារឹក K.៧៩ ហើយក្នុងសិលាចារឹកអង្គរ ពាក្យទាំងនេះក្លាយជា វ្រះកម្រតេងអញ-ជគត តរាជ ឬ កម្រតេងជគតតរាជ។

គេគួរចាប់អារម្មណ៍លើអត្ថបទចុងក្រោយមួយរបស់លោក សឺដេស ព្រោះគាត់ក៏មិនសូវជឿសាច់រឿងក្នុងសិលាចារឹកស្តុកកក់ធំដែរ។ គាត់បានគិតថា ការគោរពបូជាទៅលើ កម្រតេងជគតតរាជបានចាប់ផ្តើមពីរាជ្យព្រះបាទជយវម៌្មទី៤។ បើសិនរឿងនេះជាការពិតរឿងរ៉ាវអំពីរាជ្យជយវម៌្មទី២ ក្នុងសិលាចារឹកស្តុកកក់ធំ គឺជារឿងប្រលោមលោកនិទានមួយផ្សេងទៀត ។

ក្រៅពីលោក Claude Jacques និង សឺដេស មានអ្នកជំនាញអំពីកម្ពុជាសម័យបុរាណផ្សេងទៀត ដែលបច្ចុប្បន្ន បានដាស់តឿនដល់ការយកចិត្តទុកដាក់ទៅលើសិលាចារឹកស្តុកកក់ធំ។ ក្នុងអត្ថបទដែលរៀបរៀងបោះពុម្ពថ្មីក្នុងទស្សនាវដ្តីសិក្សាខ្មែរ ប្រវត្តិវិទូជប៉ុនគឺលោក Yoshiaki Ishuzawa បាននិយាយថាស្តុក-កក់ធំ "យោងទៅលើអតីតកាលសម័យ២៥០ឆ្នាំមុន.....គឺរាជ្យស្តេចជយវម៌្មទី២(៨០២-៨៥០) ដែលនិយាយអំពី "កម្រតេងជគត តរាជ" និងគ្រួសារសាច់ញាតិស្តុករន្សី ដែលគេពុំឃើញមានពាក្យទាំងពីរនេះ ក្នុងសិលាចារឹកផ្សេងទៀតទេ រហូតដល់រាជ្យស្តេចជយវម៌្មទី៤។

ទោះជាយ៉ាងណាក៏ដោយ លោកស្រី ពៅ សាវរស បានពន្យល់ថា កម្រតេងជគតតរាជ ឬទេវរាជបានន័យថា ព្រះច្បងគេ-ធំជាងគេ = ព្រះឥសូរ ។ ចំណែក ពាក្យ"-ទេវ" នៅខាងចុងឈ្មោះរបស់ស្តេចចក្រពត្តិនៅអង្គរ មិនមែនមានន័យថា "ព្រះមហាក្សត្រជាអាទិទេព" នោះទេ។ បើតាមភស្តុតាងសិលាចារឹកដែលបញ្ជាក់ពីស្ថានទេវលោកដែលព្រះមហាក្សត្រអង្គនីមួយៗបានយាងទៅ នៅក្រោយពេលចូលទីវង្គត។ ដូចជាសិលាចារឹកប្រាសាទព្រះវិហារ K. 380 W ថា «នៅទីនេះ មានសន្តានដែលចាំរក្សាគម្ពីរ(១៦)ពង្សាវតាររបស់វង្សត្រកូលកម្វុ និងអង្គព្រះរាជការ ជាគម្ពីរកេរ្តិ៍នៃព្រះមហាក្សត្រគ្រប់គ្រងផែនដី ចាប់ផ្តើមពីព្រះបាទស្រុតវម៌្មទេព រហូតដល់ព្រះកេ(១៧)រ្តិ៍ព្រះបាទសូរ្យវម៌្មទេព(ទី១) ដែលជារាជត្រកូលរបស់ព្រះបាទឥន្ទ្រវម៌្មទេព(ទី១) ដែលស្តេចបាន(១៨)យាងទៅឦស្វរលោក និងព្រះអគ្គមហេសី វីរលក្ស្មីនៅឯភូមិព្រិច ជាព្រះស្រុកនៃរាជត្រកូលព្រះបាទ(១៩) ហស៌វម៌្មទេព(ទី១)ដែលស្តេចបានយាងទៅ រុទ្រលោក និង ព្រះបាទឥសានវម៌្មទេព(ទី២) ដែលស្តេចបានយាងទៅបរមរុទ្រលោក»។ ដូច្នេះ បើព្រះអង្គជាអាទិទេពស្រាប់តាំងពីនៅមានព្រះជន្ម គេមិនចាំបាច់មានប្រពៃណីសរសេរបញ្ជាក់បែបនេះទេ។ ជាងនេះទៀត គេឃើញមន្ត្រីមួយចំនួនក៏អាចកសាងប្រាសាទ ឬប្រតិស្ឋានអាទិទេពដែលមាននាមថា កម្រតេងជគតតរាជ បានដែរ ដូចជាសិលាចារឹកតាកឹង K. 125 នៅសំបូរខេត្តក្រចេះ មាននិយាយពីនារីអភិជននាមកំស្តេងធិស្រីធូតាសិដែលជាព្រះញាតិព្រះបាទជយវម៌្មទី២បានកសាងកម្រតេងជគតតរាជនៅស្រឡាយចុង ។

## 5. **ស្ថាប័នរាជាភិសេក**

នៅក្នុងសិលាចារឹកស្តុកកក់ធំ បានឱ្យដឹងថា ព្រះបាទជយវម៌្មទី២បានទទួលការគាំទ្រ ពីគ្រួសារមួយនៅឥន្ទ្របុរៈ ដែលគេសន្និដ្ឋានថា ប្រហែលនៅតំបន់បន្ទាយព្រៃនគរ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាមសព្វថ្ងៃ។ ទឹកដីនៃគ្រួសារនេះ ជាកេរ្តិ៍តំណែលដែលប្រទានដោយស្តេចភវវម៌្មទី២ ដែលមានមរណនាមជា(កុរុង)ភវបុរៈ តែប្រវត្តិនៃក្រុមគ្រួសារនេះមានដើមកំណើតនៅអនិន្ទិតបុរៈ។ ក្រោយមកព្រះអង្គក៏បានលើកប្រមុខនៃក្រុមគ្រួសារសំខាន់មួយនេះ ឈ្មោះសិវកៃវល្យ ធ្វើជារាជបុរោហិត និងជារាជគ្រូរបស់ព្រះអង្គ។ ដោយសារ ព្រាហ្មណ៍សិវកៃវល្យ ជាអ្នកស្មោះត្រង់ភក្តី

ចំពោះព្រះអង្គ ទ្រង់បានលើកស្ថាប័នដ៏សំខាន់មួយ គឺកម្រតេង ជគត តរាជ និងកិច្ចការបម្រើទ្រង់ក្នុងព្រះបរមរាជវាំងឱ្យទៅក្រុមគ្រួសារនេះឯង ជាអ្នកគ្រប់គ្រង(ស្ថាប័នបារគូ និងមន្ត្រីវាំង)ដែលជាស្ថាប័នដ៏សំខាន់កាន់កាប់ពិធីបុណ្យបូជាផ្សេងៗ និងកិច្ចការនៅក្នុងវាំងទាំងអស់របស់ព្រះរាជា។

ការប្រសិទ្ធីតែងតាំងក្រុមគ្រួសារនេះ បានប្រព្រឹត្តទៅនៅពេលបន្ទាប់ពីព្រះបាទជយវរ្ម័ទី២ ធ្វើពិធីលេហនៅលើភ្នំមហេន្ទ្របព៌ត ក្រោមអធិបតីភាព របស់ព្រាហ្មណ៍ព្រឹទ្ធាចារ្យអ្នកប្រាជ្ញខាងព្រហ្មញ្ញសាសនាម្នាក់ ឈ្មោះហិរណ្យទាម ដែលអញ្ជើញមកពីស្រុកជនបទ។ ក្រៅពីប្រារព្ធធ្វើពិធីជានិមិត្តរូបក្នុងការរារាំងកុំឱ្យប្រទេសកម្ពុជាធ្លាក់ជាចំណុះជ្វា តាមគម្ពីរវិនាសិខៈ, តាំងកម្រតេងជគតតរាជ-ទេវរាជ, លើកឋានៈព្រះរាជាជាស្តេចចក្រពត្តិ = ចក្រពត្តិន = ចក្រវតិន, ព្រាហ្មណ៍នេះឯងបានបង្រៀនចំណេះដឹងគម្ពីរបួន គឺ វិនាសសិខៈ, នយោត្តរៈ, សំមោហៈ និង សិរស្ឆេទដល់ព្រាហ្មណ៍សិវកៃវល្យ ដើម្បីទុកឱ្យព្រាហ្មណ៍នេះយកទៅអនុវត្តន៍ក្នុងពិធីបុណ្យបូជាផ្សេងៗ នៅកម្រតេងជគតតរាជរបស់ព្រះរាជា។ មិនត្រឹមតែប៉ុណ្ណោះព្រះរាជា និងព្រាហ្មណ៍ហិរណ្យទាមបានប្រកក់ប្រសិទ្ធីប្រគល់ឱ្យព្រាហ្មណ៍សិវកៃវល្យនូវសិទ្ធិផ្តាច់មុខតសន្តតិវង្ស ក្នុងការកាន់កាប់កម្រតេងជគតតរាជ របស់ព្រះរាជាចាប់ពីពេលនោះតមក។

ក៏ប៉ុន្តែធម្មភាព ឬក៏បទប្បញ្ញត្តិនេះ ត្រូវបានព្រះរាជាក្រោយៗមកទៀត ធ្វើមិនដឹងមិនឮ និងបំភ្លេចចោល ជាពិសេសចាប់ពីរាជ្យព្រះបាទជយវរ្ម័ទី៦ ដែលស្តែងចេញដោយវត្តមាននៃព្រាហ្មណ៍បុរោហិតដ៏សំខាន់ម្នាក់នាមទិវាករបណ្ឌិត ដែលមិនមែនជាបច្ឆាជននៃសន្តានរបស់សិវកៃវល្យ។

## 6. ស្ថាប័ននយោបាយកំពូល និងអង្គការរដ្ឋបាល

### 6.1. ព្រះមហាក្សត្រ

ព្រះមហាក្សត្រជាអ្នកកាន់អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។ ព្រះអង្គ គឺជាស្តេចនៃស្តេចទាំងឡាយនៃស្តេចទាំងឡាយ(រាជាធិរាជ) ដោយសារព្រះអង្គរក្សាទុកឋានៈជាម្ចាស់ទឹកដីធំៗ(អាណាចក្រជាច្រើន) ដែលស្ថិតនៅចំណុះព្រះអង្គ។ ចំណែកនៅក្នុងការគ្រប់គ្រងប្រទេស ព្រះអង្គមាននាម៉ឺនសព្វមុខមន្ត្រីមួយមុខបួននាក់ៗ ជាយន្តការលើកិច្ចការរដ្ឋទាំងមូល។ ស្តេចត្រាញ់ដែនដីនីមួយៗនៅក្រោមចំណុះរបស់រាជាធិរាជ មានភារកិច្ចនាំសួយសារអាករថ្វាយព្រះអង្គជាប្រចាំ និងមានភារកិច្ចផ្តល់កម្លាំងពលកម្មកំណែនតាមតម្រូវការរបស់រាជាធិរាជ។ ក៏ប៉ុន្តែស្តេចត្រាញ់មានសិទ្ធិធ្វើអ្វីគ្រប់យ៉ាងលើដែនដីរបស់ខ្លួន និងមានរចនាសម្ព័ន្ធរដ្ឋបាលដូចគ្នានឹងរាជាធិរាជដែរ លើកលែងតែបញ្ហាប្រទានដីធ្លីធំៗ និងការកសាងសំណង់ធំៗ ទើបត្រូវទូលសុំព្រះរាជានុគ្រោះ ឬរាជានុញ្ញាតពីរាជាធិរាជ។ នយោបាយបែបនេះហើយ ដែលនាំឱ្យមានចលាចលក្នុងប្រទេសជាញឹកញាប់ នៅពេលរាជាធិរាជចូលទិវង្គត។ ព្រោះស្តេចត្រាញ់នីមួយៗដែលសុទ្ធសឹងជាសាច់ញាតិរបស់រាជាធិរាជមជ្ឈិម ឬជាអ្នកដែលមានអំណាចខាងយោធានាំគ្នាធ្វើការប្រជែងដណ្តើមអំណាចកណ្តាលរៀងៗខ្លួន ។

#### *ក-១- ព្រះមហាក្សត្រជាអ្នកបង្កើត និងការពារធម៌-ច្បាប់*

ព្រះអង្គមិនប្រព្រឹត្តិអំពើអយុត្តិធម៌ដោយសារតែសញ្ចេតនា និងប្រយោជន៍ឡើយ...។ ព្រះបាទជយវរ្ម័ទី៧ ដែលកាន់ពុទ្ធសាសនា បានលើកតំកើងច្បាប់ជានិច្ច។ តាមទស្សនៈហិណ្ឌូ"គោ"ជាតំណាងច្បាប់។ បើគោខូចជើងទាំងបីរបស់ខ្លួន ដោយសារកម្មពីជាតិមុន មានន័យថាស្រុកនៅក្នុងជាតិកាលី(កលិយុគ) ដែលពោរពេញទៅដោយអំពើអាក្រក់ ពេលនោះព្រះគោដើរបានដោយជើងតែមួយ។

ព្រះមហាក្សត្រជាអ្នកសង្គ្រោះតែមួយគត់ដល់ការរក្សាធម៌ ហើយធ្វើឱ្យដឹងពិការទាំងបីរបស់គោមានលក្ខណៈធម្មតាឡើងវិញ។ នៅសម័យមុនអង្គរ មានសិលាចារឹករំឭកដល់ព្រះបាទចិត្រសេន-មហេន្ទ្រវម៌្ម បានបញ្ជាក់ថា ព្រះរាជាអង្គនេះបានឱ្យសាងរូបព្រះគោធ្វើអំពីថ្ម ដើម្បីជានិមិត្តរូបនៃការរៀបចំច្បាប់សម្រាប់អនុវត្តន៍លើព្រះរាជាណាចក្ររបស់ព្រះអង្គ។ ចំណែកព្រះបាទ ជយវម៌្មទី៧ ក៏ជាព្រះមហាក្សត្ររក្សាការពារ"ធម៌" ដែលមានរូបព្រះគោជានិមិត្តរូបដែរ។ តាមទស្សនៈហិណ្ឌូ ច្បាប់មានប្រភពចេញពីគម្ពីរវេទ(ស្រុតិ), ប្រពៃណី(ស្មតិ), ទំនៀមទម្លាប់ល្អ(របស់សាស្ត្រាចារ្យ) និងការពេញចិត្ត(ស្វស្សប្រិយំអាត្មនៈ) ចំពោះអត្ថបទខ្មែរវិញ មានរំឭកសំខាន់ទៅស្រុតិ និងប្រពៃណី។

ព្រះរាជក្រិត្យរបស់ព្រះបាទរាជេន្ទ្រវម៌្ម ដែលអនុលោមតាមច្បាប់"ធម៌" មានខ្លឹមសារប្រពៃដូចស្រុតិ។ ឯព្រះបាទជយវម៌្មទី៥បានឈ្វេងយល់អំពីស្រុតិ និងប្រពៃណី ដើម្បីស្វែងរកនូវសច្ចធម៌។ អ្នកនិពន្ធសិលាចារឹក បានលើកតម្កើងព្រះបាទជយវម៌្មទី៧ ដែលជាព្រះមហាក្សត្រប្រកាន់ខ្ជាប់ខ្ជួននូវទ្រឹស្តីពុទ្ធនិយមថា ដោយព្រះអង្គមានញាណឈ្វេងយល់ស្រុតិ និងចេះដឹងយ៉ាងជ្រៅជ្រះពីប្រពៃណីស្មតិ ព្រះអង្គក្លាយទៅជាម្ចាស់បង្កើតលោក ដែលធ្វើឱ្យផែនដីមានភាពឧត្តមលើសពីអ្នកបង្កើតផែនដីទីមួយ(មនុ)។ ភារកិច្ចចម្បងរបស់ព្រះរាជា គឺការពារច្បាប់ "បើបំផ្លាញច្បាប់ ច្បាប់នឹងបំផ្លាញ(ដាក់ទណ្ឌកម្ម) បើការពារច្បាប់ ច្បាប់នឹងការពារវិញ។ អាស្រ័យហេតុនេះ ត្រូវជៀសវាងកុំបំផ្លាញច្បាប់ដោយអែងថា ច្បាប់ដែលត្រូវបំផ្លាញនោះ នឹងធ្វើឱ្យយើងទទួលអន្តរាយវិញ" ។

នៅសម័យអង្គរ គេឃើញមានអត្ថបទជាច្រើនដែលលើកពីអាជ្ញារបស់ព្រះរាជា ដាក់ប្រាសាទ និងទ្រព្យសម្បត្តិជាពិសេស អ្នកបម្រើ ពោលគឺ "ធម៌"ដែលព្រះអង្គអនុញ្ញាតឱ្យបង្កើតឡើង ឱ្យនៅជាឯករាជ្យ មិនចំណុះអាជ្ញាធរដែនដី, មិនឱ្យជាប់ពន្ធ និងមិនឱ្យជាប់កំណែនពលផ្សេងៗ។ អ្នកណាហ៊ានប្រឆាំងព្រះបញ្ជា នឹងត្រូវទទួលទណ្ឌកម្មដល់រាងកាយ។ អំណាចព្រះរាជាស្ថិតនៅលើការដាក់កំហិតឱ្យមានការអនុវត្តន៍តាម។ បទប្បញ្ញត្តិ គ្មានលក្ខណៈជាអំណាចនីតិប្បញ្ញត្តិទេ។ ជាទូទៅ មានត្រាស់បង្គាប់ឱ្យសាងប្រាសាទ ឬវិហារ ដោយមានរៀបរាប់ពីវត្ថុចាំបាច់សម្រាប់ការធ្វើពិធីបូជា, ការថែរក្សាអគារទាំងឡាយ, ការផ្គត់ផ្គង់អ្នកបម្រើ និងការប្រកាសឱ្យរួចពីពន្ធដារតែប៉ុណ្ណោះ។ ព្រះរាជបញ្ជា បញ្ជាក់ពីការបង្កើតវណ៌(វណ្ណៈ) ឬ សាជីវកម្មថ្មី ដែលត្រូវទទួលបន្ទុកលើមុខការផ្សេងៗគ្នា។ ខ្លះទៀត រំឭកពីបទបញ្ជារបស់ព្រះរាជាសម្រាប់ព្រះវិហារ ដែលព្រះអង្គកសាងឡើង។

ព្រះមហាក្សត្រជាអ្នកកាន់អំណាចតុលាការកំពូល ដែលផ្តន្ទាទោសដល់អ្នកប្រព្រឹត្តល្មើសទាំងឡាយ ដែលកាត់ក្តីនៅស្ថាននរក។ ការកាត់ក្តីរបស់យមរាជ មានលក្ខណៈឃោរឃៅ ចំណែកឯការកាត់ក្តីរបស់ព្រះមហាក្សត្រមានលក្ខណៈប្រកបដោយគុណធម៌ ជាម្ចាស់ និងជាអ្នកការពារប្រជារាស្ត្រ គេប្រដូចព្រះមហាក្សត្រទៅនឹងប្រជាបតី។ ព្រះអង្គបានរៀបចំសណ្តាប់ធ្នាប់សង្គម តាមញាណយល់ដឹង គឺស្រុតិ និងច្បាប់ប្រពៃណី(ស‡តិ)។ គេចាត់ទុកព្រះមហាក្សត្រជាអវតារបស់ព្រះហរិហរៈ។ ក្រៅពីឈ្មោះបញ្ចប់ដោយពាក្យ "ទេវៈ" ព្រះមហាក្សត្រភាគច្រើននៅសម័យអង្គរ តែងត្រូវឧទ្ទិសមរណនាមឱ្យ ដើម្បីបញ្ជាក់ពីស្ថានសួគ៌ដែលព្រះអង្គត្រូវទៅសោយសុខ បន្ទាប់ពីបញ្ចប់ភារកិច្ចរបស់ខ្លួននៅលើផែនដី។ នេះជាវិធីបញ្ជាក់ពីទេវភាពរបស់ព្រះមហាក្សត្រ។

លុះដល់ចុងសតវត្សរ៍ទី១២ ទស្សនៈទេវភាពត្រូវជំនួសដោយទស្សនៈពុទ្ធសាសនាវិញ។ គេលើកតម្កើងជយវម៌្មទី៧ ជាព្រះពុទ្ធសក្យមុនី ព្រះមាតារបស់ព្រះអង្គខាងប្រាជ្ញាបារមីតា ហើយព្រះបិតា ជាពោធិសត្វលោកេស្វរៈ។ សិលាចារឹកប្រាសាទព្រះខ័នបានរំឭកថា ព្រះបាទជយវម៌្មទី៧ បានតម្កល់ព្រះបដិមាជ័យពុទ្ធមហានាថចំនួន ២៣ នៅតាមទីក្រុងនានានៃព្រះរាជាណាចក្រ។ តាមអ្នកប្រាជ្ញបារាំងនាម ហ្សក សឺដេស ថា ការឧទ្ទិសនេះជាវិធីពុទ្ធរាជ

ដែលត្រូវបានអនុវត្តន៍ជំនួសវិធីតាំងសិវលិង្គ ដែលព្រះរាជាមុនបានអនុវត្តន៍(ឥន្ទ្រេស្វរៈ,យសោធរេស្វរៈ,សូរ្យវម៌េស្វរៈ)។ អ្នកសិក្សាជាច្រើនបានសន្និដ្ឋានថា ព្រះពុទ្ធរូបនាសម័យនោះ គឺតំណាងព្រះមហាក្សត្រជយវរ្ម័ទី៧។ លើសពីនេះ ព្រះមហាក្សត្រអង្គនេះ បានឱ្យគេស្ថាបនារូបបដិមាជាច្រើនតំណាង ឱ្យញាតិវង្ស និងអ្នកបម្រើផ្ទាល់ ឱ្យមានលក្ខណៈជាអវលោកេស្វរៈ ដែលជាពោធិសត្វពុទ្ធនិយម ។

### *ក-២- ព្រះមហាក្សត្រជាឥស្សរភាព*

រហូតមកដល់សម័យអង្គរ ព្រះមហាក្សត្រមានឋានៈខ្ពង់ខ្ពស់ដូចទេវៈនានានៅលើផែនដី។ ភាពឧត្តុង្គឧត្តមនេះ ទទួលឥទ្ធិពលពីសាសនាព្រាហ្មណ៍។ សម័យមុនអង្គរ ព្រះមហាក្សត្រត្រូវបានគេចាត់ទុកជាតំណាងទេវៈ ដែលជួយរំដោះមនុស្សលោកឱ្យរួចផុតពីទុក្ខភ័យនាយុគកាលី។ ដូចនេះ ព្រះមហាក្សត្រជាអវតាររបស់ព្រះ ដែលមកកើតជាមហាបុរសលើផែនដីក្នុងនាមជាបុគ្គលឥស្វរៈ=ឥស្សរៈ។ ព្រះបាទ សូរ្យវម៌្មទី១ ត្រូវគេប្រៀបធៀបដូចជាព្រះឥសៈ(=ឥស្វរៈ)លើផែនដី។ ដើម្បីធ្វើឱ្យទស្សនៈនេះកាន់តែមានភាពជាក់ស្តែង គេតែងធ្វើលិង្គមាសតំណាងព្រះមហាក្សត្រតម្កល់ទុកក្នុងតួប៉មនៃប្រាសាទភ្នំ ។

ដោយការប្រកាសខ្លួនជាតំណាងទេវះលើផែនដី ព្រះមហាក្សត្រខ្មែរមានលក្ខណៈជាម្ចាស់លើប្រជារាស្ត្ររបស់ខ្លួន។ ព្រះអង្គ បានបង្ហាញខ្លួនតាមបង្អួចប្រាសាទស្ថិតនៅពីលើស្រទាប់ខ្ពស់លើសប្រជារាស្ត្រដែលបានក្រាបថ្វាយបង្គំក្រាបក្បាលដល់ដី ដោយមិនអនុញ្ញាតឱ្យងើបមើលព្រះភ័ក្ត្រព្រះអង្គឡើយ។ សិលាចារឹកជាច្រើនបានបញ្ជាក់ថា ព្រះមហាក្សត្រជាព្រះបិតាប្រជារាស្ត្រ ហើយមានអំណាចជាគុរុលើប្រជារាស្ត្រ ស្ថិតខ្ពស់ដាច់ចេញពីប្រជារាស្ត្រ។ អ្នកណាមិនគោរពព្រះអង្គ ដែលជាគ្រូលើលោកទាំងមូល[40] អ្នកនោះនឹងគ្មានបានទទួលផលពីការធ្វើអំណោយ ការបូជា ឬពីដង្វាយផ្សេងៗសោះឡើយ។ លុះមកដល់រជ្ជកាលរបស់ព្រះបាទជយវម៌្មទី៧ ដែលលើកតម្កើងទស្សនៈពុទ្ធនិយម ទើបមានការវិវត្តន៍ដ៏សំខាន់ដែលធ្វើឱ្យព្រះមហាក្សត្រខិតមកជិតប្រជារាស្ត្ររបស់ខ្លួន។ ព្រះរាជាអង្គនេះ បានបង្ហាញពីការយកចិត្តទុកដាក់ប្រតិបត្តិតាមការប្រៀនប្រដៅរបស់ព្រះពុទ្ធ ដោយអនុវត្តនយោបាយយកចិត្តទុកដាក់ ចំពោះប្រជារាស្ត្រខ្មែរ ដែលគេពុំធ្លាប់ឃើញមាននៅក្នុងរជ្ជកាលមុនៗ។ អំណាចរបស់ព្រះអង្គ ស្ថិតនៅលើការប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវការគោរពធម៌ ឬច្បាប់ ដែលនាំឱ្យមានការចូលរួមផ្តល់ថាមពលនៃអំណាចរបស់ព្រះអង្គ ក្នុងការរៀបចំលើកស្ទួយការគ្រប់គ្រងកម្ពុជទេស ឱ្យមានកិត្យានុភាពឡើងវិញ។

ជានិច្ចកាលព្រះមហាក្សត្របានតំណាងឱ្យព្រះវិស្ណុ ក្នុងរូបភាពវិស្ណុត្រីវិក្រមដែលឈានតែបីជំហានអាចឆ្លងកាត់ចក្រវាឡទាំងមូល។ ព្រះមហាក្សត្រក៏ត្រូវមានលក្ខណៈជាអ្នកវាតយកទឹកដីនៃពិភពលោកទាំងមូលដែរ។ ដោយវិរភាពរបស់ព្រះបាទយសោវម៌្ម បានបោះជំហានយ៉ាងវែងប្រៀបដូច នរសិង្ហ គឺជាមនុស្ស-សីហៈដែលកំទេចសត្រូវដោយប្រើក្រញ៉ាំ និងធ្មេញចង្កូម ជាមធ្យោបាយ មានព្រះនេត្រជាគម្ពីរវេទ និងសំរែកដែលជាជោគជ័យលើចក្រវាឡទាំងបួន ហើយមានរោមកេសរដែលជាគុណធម៌ ។ សិលាចារឹកមួយបានរំឭកថា បុន្នាគវម៌្មបានធ្វើពិធីឧទ្ទិសរូបវិស្ណុចំនួន៧ដើម្បីរំឭកដល់បិតារបស់ព្រះអង្គព្រះនាមរុទ្រវម៌្ម ដែលជាតំណាងនៃវិស្ណុទេវៈ។ ប្រជារាស្ត្របានដឹងឮ និងស្គាល់ជាទូទៅថា ព្រះមហាក្សត្រកើតមកពីលោកបាលទាំង៨។ សិលាចារឹកប្រែរូបបានបញ្ជាក់ថា លោកបាលទាំងប្រាំបីបានក្លាយទៅជាព្រះមហាក្សត្រ។ អត្ថបទក្នុងអំឡុងឆ្នាំ១០៦០ បានបញ្ជាក់ថា ព្រះមហាក្សត្របានត្រូវគេលើកថា ជាព្រះច័ន្ទ្រ-អាទិត្យដែលមានតួនាទីដុត និងធ្វើឱ្យពិភពលោកត្រជាក់។ នៅសម័យអង្គរ ព្រះមហាក្សត្រមានការ

---

[40] នៅលើសិលាចារឹកប្រាសាទព្រះវិហារ K. 380 បន្ទាត់ទី១ មានគាថា *ឳំនមគ្គិវាទិក្យោគុរុក្សត្រីសូយ៌្យវម៌្មទេវ*='ឳំ!សូមនមស្សការចំពោះព្រះឥស្វរដ៏ជាគ្រូកំពូល ដូចព្រះបាទស្រីសូរ្យវម៌្ម"។

ប៉ិនប្រសប់ក្នុងការបំពេញភារកិច្ច ការពារពិភពលោកដូចជាព្រះឥន្រ្ទ ដើម្បីធ្វើឱ្យព្រះរាជាណាចក្រសម្បូណ៌សប្បាយ។ ព្រះអង្គធ្វើឱ្យមានភ្លៀងធ្លាក់ទៀងទាត់ពេល។ ព្រះអង្គបានកំចាត់បក្សពួកនៃព្រះរាជាជាសត្រូវទាំងឡាយ ដោយការអនុវត្តនយោបាយ(នយ+ឧបាយ)មានឫទ្ធិខ្ពស់ផុតព្រះឥន្រ្ទៈ។ ព្រះអង្គមានមុខងារនៅលើផែនដី ដូចគ្នានឹងព្រះឥន្រ្ទដែលគ្រប់គ្រងស្ថានសួគ៌។ ស្ថានទាំងពីរ(លើ-ក្រោម)គ្រប់គ្រងដោយអ្នកប្រកបដោយវីរភាពមិនអាចបំបាត់បាន ៖ ព្រះមហាក្សត្រគ្រងផែនដី(ព្រះកម្រតេងផ្ទៃករាំ) ចំណែកព្រះឥន្រ្ទគ្រប់គ្រងស្ថានត្រៃត្រឹង្ស ប្រកបដោយធនធានទឹក ហើយព្រះអង្គ ក៏ជាទេវៈតំណាងភោគទ្រព្យដ៏សម្បូណ៌ហូរហៀរដែរ។

ក្រៅពីនយោបាយដែលមានស្តេចមួយអង្គគ្រប់គ្រងលើដែនដីក្សត្របុរីតូចៗ ឬស្តេចត្រាញ់ជាច្រើនអង្គ រចនាសម្ព័ន្ធគ្រប់គ្រងអំណាចរបស់អធិរាជ នៅមានលក្ខណៈដូចខាងក្រោម ៖

### 6.2. ព្រះអគ្គមហេសី

ព្រះមហាក្សត្រខ្មែរសម័យអង្គរ មានមហេសីដែលគេពុំអាចកំណត់បានចំនួនច្បាស់លាស់ទេ។ ទោះជាយ៉ាងណាក៏ព្រះមហាក្សត្រត្រូវតែងតាំងព្រះរាជអគ្គមហេសី ដែលជួនកាលមានតួនាទីសំខាន់ក្នុងកិច្ចការប្រទេសជាតិ និងបានទទួលកិត្តិយសដោយមានពិធីអភិសេកផង ដូចសិលាចារឹកភិមានអាកាសបានបញ្ជាក់ថា ព្រះបាទជយវរ្ម័ទី៧ បានអភិសេកព្រះនាងឥន្រ្ទទេវីជាអគ្គមហេសី។ មន្រ្តីមួយចំនួន មានការទាក់ទងយ៉ាងជិតស្និតជាមួយព្រះមហាក្សត្រដោយលើកបុត្រីរបស់ខ្លួនឱ្យធ្វើជាមហេសី, ទេពី ឬស្រីស្នំ។ សិលាចារឹកបានរំឭកពីមន្រ្តីមួយដែលមានតំណែងសំខាន់បានថ្វាយបុត្រីរបស់ខ្លួនឱ្យព្រះបាទជយវរ្ម័ទី២ ។ អ្នកសញ្ជកនៃវ្រៃកន្លោងបានទទួលងារជាកម្រតេងអញ្ជនប្បតិន្រ្ទវរ្ម័ ដោយគាត់មានភក្តីភាពប្តូរផ្តាច់ចំពោះព្រះបាទសូរ្យវរ្ម័ទី១ ហើយប្អូនស្រីគាត់បានក្លាយជាអគ្រទេវីមានងារថា កម្រតេងអញ្ជនប្បតិន្រ្ទលក្ស្មី ហើយបានទទួលរង្វាន់កិត្តិយសជាច្រើន ដូចជាម្កុដ-ការទំហូ សំលៀកបំពាក់មាស អង្រឹងមាស...។ល។ សិលាចារឹកបន្ទាយស្រីបានរំលឹកពីបុត្រីច្បងនៃប្អូនស្រីរបស់មន្រ្តីជាន់ខ្ពស់ឈ្មោះ មធុរេន្រ្ទសូរ្យជាស្នំឯករបស់ព្រះមហាក្សត្រ។ ចំណែកបុត្រីនៃបុរោហិតព្រះបាទជយវរ្ម័ទី៧ បានធ្វើជាមហេសីរបស់ព្រះបាទជយវរ្ម័ទី៨។ ដោយសារការអនុវត្តគោលការណ៍យុទ្ធសាស្រ្តអាពាហ៍ពិពាហ៍នយោបាយ ជាធម្មតាមហេសីទាំងឡាយ ឬអគ្គមហេសីរបស់ព្រះមហាក្សត្រ ភាគច្រើនជាកូនស្រី ឬប្អូនស្រីនៃស្តេចត្រាញ់ដែលគ្រប់គ្រងភូមិភាគសំខាន់ៗទាំងឡាយនៃចក្រភព។

### 6.3. រជ្ជទាយាទ(យុវរាជ)

ឯកសារដ៏កម្រខ្លះ បានលើកពីសកម្មភាពរបស់ព្រះយុវរាជ។ ប្រវត្តិវិទូចិនបានរៀបរាប់ពីបេសកកម្មនៃព្រះយុវរាជខ្មែរ ដែលដឹកនាំគណប្រតិភូចំនួនពីររូបដែលជាញាតិវង្សទៅកាន់ប្រទេសចិននាសតវត្សរ៍ទី៨ (ចន្លោះឆ្នាំ ៧១៣-៧៥៥គ.ស)។ សិលាចារឹកចុះកាលបរិច្ឆេទ ៩៧០គស បញ្ជាក់ថា ក្នុងឋានៈជារជ្ជទាយាទជយវរ្ម័ទី៤ បាន(ឱ្យ)ដីមួយកន្លែងសម្រាប់សាងសង់ភូមិឱ្យបងថ្លៃ(ខ្លៃ)ប្រុស។ តាមឯកសារនេះ ព្រះយុវរាជមានទ្រព្យសម្បត្តិជាកម្មសិទ្ធផ្ទាល់ខ្លួន ដោយជួនកាលក្នុងនាទីជាមន្រ្តីរដ្ឋបាល មានសិទ្ធិសម្រេចប្រើប្រាស់ ចំណែកឯទ្រព្យទាំងនោះដោយពុំចាំបាច់សុំរាជានុញ្ញាតជាមុនទេ។ ជួនកាលក៏ត្រូវមានការយល់ព្រមពីព្រះមហាក្សត្រដែរ។ នៅដើមសតវត្សរ៍ទី១២ ព្រះបាទជយវរ្ម័ទី៦ បានតាំងប្អូនប្រុសជាយុវរាជ។[41] ក្រោយមរណភាពរបស់ព្រះអង្គនៅឆ្នាំ១១០៦គ.ស យុវរាជត្រូវឡើងស្នងរាជ្យបន្តដោយត្រូវអភិសេកជាមួយអគ្គមហេសីរបស់ព្រះអង្គ និងត្រូវជាបុត្រីព្រះបាទហស៌វរ្ម័ទី៣។

---

[41] Cf., George Coedès, 1989. *Articles sur le pays khmer*, t. I, ed., Claude Jaques, EFEO-Paris, 169-202.

ប៉ុន្តែដោយទ្រង់ចូលទិវង្គតមុនពេលរៀបអភិសេក ទើបរាជ្យសម្បត្តិបានទៅព្រះរៀមច្បង គឺព្រះបាទធរណីន្ទ្រវម៌្មទី១ វិញ។ អត្ថបទសិលាចារឹកបន្ទាយស្រី K. 569 ចុះកាលបរិច្ឆេទ១៣០៦គ.ស បានរៀបរាប់ឱ្យដឹងថា ព្រះបាទស្រីស្រីន្ទ្រវម៌្មទេវ ដែលជាបច្ឆាជនរបស់ព្រះបាទស្រេស្ឋវម៌្ម ត្រូវបានអភិសេកជាព្រះយុវរាជនៅក្នុងរជ្ជកាលរបស់ព្រះបាទជយវម៌្មទី៨ ដោយសារព្រះអង្គមានអគ្រមហេសីជាព្រះរាជបុត្រីច្បងរបស់ព្រះបាទជយវម៌្មទី៨ នាមព្រះភគវតីកម្រតេងអញស្រី ស្រីន្ទ្រភូបេចូឌា។

### 6.4. ព្រះរាជបុត្រ និងរាជវង្សានុវង្ស

បន្ទាប់ពីព្រះមហាក្សត្រ ព្រះរាជបុត្រា–បុត្រីមានឋានៈខ្ពស់ជាងមន្ត្រីដទៃទៀត។ ព្រះរាជបុត្រអាចចូលទៅក្នុងប្រាសាទលលៃតាមទ្វារធំ ចំណែកពួកព្រាហ្មណ៍ បុរោហិត និងមេទ័ពត្រូវដោះគ្រឿងអលង្ការចេញ មុនចូលទៅក្នុង។ ព្រះរាជបុត្រតែងទទួលមុខងារដ៏ខ្ពង់ខ្ពស់របស់រដ្ឋ។ រាល់ការប្រជុំសំខាន់ៗ សុទ្ធសឹងមានសេចក្តីបញ្ជាក់ថា មានការចូលរួមពីរាជបុត្រ។ ក៏ប៉ុន្តែ រាជបុត្រទាំងអស់ មិនប្រាកដថា នឹងបានឡើងសោយរាជ្យស្នងបិតាខ្លួននោះទេ។ ដូចជារាជបុត្ររបស់ព្រះបាទជយវម៌្មទី៣, ជយវម៌្មទី៥ជាដើម មិនបានស្នងរាជ្យពីបិតាខ្លួនឡើយ។ នៅក្នុងរជ្ជកាលព្រះបាទជយវម៌្មទី៧ ព្រះរាជបុត្រមួយអង្គបានទទួលមុខងារជាអភិបាលក្រុង"ល្វោ-លវោទយ"។ សិលាចារឹកបន្ទាយឆ្មារបានរំឭកពីការបំពេញតួនាទីយោធារបស់ព្រះរាជបុត្រមួយអង្គឈ្មោះ ស្រីន្ទ្រកុមារ ដែលប្រយុទ្ធជាមួយ"ភរតរាហុ"ដែលបានបះបោរដណ្តើមរាជ្យព្រះបាទយសោវម៌្មទី២ និង"កងទ័ពចាម"ទំនងជាក្នុងបេសកកម្មឈ្លានពានប្រទេសចាម្ប។ ក្នុងពិធីការខ្មែរអង្គរ ព្រះរាជបុត្រមានគោរម្យងារជា វ្រះកម្រតេងអញ ឬ វ្រះកំស្តេងអញ។ ចំណែករាជបុត្រាបុត្រី និងបងប្អូនរាជវង្សដទៃច្រើនទៀត មានគោរម្យងារជា កំស្តេង និងលោញ ។ នៅសតវត្សរ៍ទី១២ ព្រះរាជបុត្រស្រីន្ទ្រកុមារមានគោរម្យងារខ្លីជាស្តេច, សម្តេច(Stac, Samtac)។ ជួនកាលគេធ្វើរូបបដិមាតំណាងឱ្យ ឬឧទ្ទិសរូបបដិមាតាងព្រះរាជបុត្រ និងរាជវង្សានុវង្ស ដូចជានៅប្រាសាទបន្ទាយឆ្មារ, បាយ័ន, ព្រះខ័ន្ធ, តាព្រហ្ម, បន្ទាយក្តី និងតានៃ។ នៅក្នុងរជ្ជកាលព្រះបាទយសោវម៌្មទី១ ទោះជាមានឋានានុក្រមខ្ពស់យ៉ាងណាក៏ដោយ ព្រះរាជបុត្រដែលធ្វើអំពើល្មើសក៏នឹងត្រូវទទួលការពិន័យដែរ ។

### 6.5. រដ្ឋាភិបាល និងប្រភេទរដ្ឋមន្ត្រី

នៅសម័យមុនអង្គរព្រះមហាក្សត្រតែងចេញមកធ្វើសវនាការជាមួយមន្ត្រី និងប្រជារាស្ត្រនៅក្នុងរយៈពេល៣ថ្ងៃម្តង។ លោកជីវ តាក្វាន់ ក៏បានរៀបរាប់ពីសវនាការជាសាធារណៈរបស់ព្រះមហាក្សត្រខ្មែរនៅសម័យអង្គរដែរ។ ព្រះមហាក្សត្រមានមន្ត្រីជំនួយការរដ្ឋបាលយ៉ាងច្រើន ដែលគេអាចចែកចេញជាបួនឋានានុក្រម ៖ ឯក, ទោ, ត្រី, ចត្វា។ ក្នុងការចាត់ចែងកិច្ចការរដ្ឋ ព្រះមហាក្សត្របានត្រាស់បង្គាប់ទៅកាន់មន្ត្រីទាំង៤ក្រុមឱ្យអនុវត្តនូវសេចក្តីសម្រេចគ្រប់បែបយ៉ាងរបស់ព្រះមហាក្សត្រ។ មន្ត្រីទាំង៤ក្រុមនេះ មានចែងជាឋានានុក្រមដូចគ្នា។ នៅក្នុងការគ្រប់គ្រងរដ្ឋ ព្រះរាជា មហេសី ព្រះរាជទាយាទ និងព្រះរាជវង្សនុវង្សតែងបានទទួលឋានៈសំខាន់នៅក្នុងរដ្ឋបាលមជ្ឈិម ។

បើតាមការស្រាវជ្រាវរបស់លោក សាហៃ សច្ចិនន្ទ ស្តីអំពីស្ថាប័ននយោបាយ និងអង្គការរដ្ឋបាលខ្មែរសម័យអង្គរ បានបង្ហាញនូវមុខងារមន្ត្រីជាច្រើន ដែលមានលក្ខណៈស្ទើរតែដូចគ្នានឹងនៅប្រទេសឥណ្ឌាសម័យបុរាណដែរ។ តែទោះជាយ៉ាងណា ក៏យើងមិនឯកភាពជាមួយនឹងទ្រឹស្តីនោះទាំងស្រុងដែរ ដោយសារមានមុខមន្ត្រីជាច្រើន ដែលមិនដូចនៅស្រុកឥណ្ឌា ផ្ទុយទៅវិញគេគ្រាន់តែប្រើបច្ចេកពាក្យសំស្ក្រឹតរបស់ឥណ្ឌាប៉ុណ្ណោះ។ យើងឃើញមានមន្ត្រីជាន់ខ្ពស់ជាច្រើននាក់នៅធ្វើការអមព្រះរាជា ដែលមានដូចជា ៖

*១-ស្ថាប័នរាជកុលមហាមន្ត្រី (ធូលីជេងវ្រះកំស្តេងអញ)*

សិលាចារឹកសតវត្សរ៍ទី១០បានរំឭកជាលើកដំបូងនូវកំស្តេងអញរាជកុលមហាមន្ត្រី ដែលបម្រើការក្នុងរជ្ជកាលព្រះបាទហសវម៌្មទី១(៩២២គ.ស)។ព្រះរាជាបញ្ជាដល់មន្ត្រីនេះឱ្យសម្រេចកិច្ចការនានាទាំងខាងផ្នែករដ្ឋបាលស៊ីវិល ទាំងខាងផ្នែកកិច្ចការសាសនា រួមទាំងផ្តល់ដល់ស្ថាប័នសាសនានូវអភ័យឯកសិទ្ធិខាងពន្ធដារ។ កំស្តេងអញរាជកុលមហាមន្ត្រី អាចទទួលរាជបញ្ជាឱ្យស្តាប់ដឹងឮពីសកម្មភាពរកយុត្តិធម៌(ស្ថាបវ្យវហារ)នៅក្នុងសាលាក្តី(វ្រះសភា) ដែលកាត់សេចក្តីអ្នកប្រព្រឹត្តល្មើសនឹងក្រឹត្យក្រមវណ្ណាប់បូជារបស់ប្រាសាទ លើសនេះគាត់អាចសម្រេចដាក់ទណ្ឌកម្មអ្នកប្រព្រឹត្តល្មើសព្រះរាជបញ្ជាដែលជាម្ចាស់ផ្ទៃក្រោម។

អ្នកប្រាជ្ញបារាំងឈ្មោះ ហ្សក សឺដេសបានចាត់ទុកព្រះរាជកុលមហាមន្ត្រីក្នុងរជ្ជកាលរាជេន្ទ្រវម៌្មដែលជាទីប្រឹក្សាសម្រាប់រាជវង្សានុវង្សផង និងជាមន្ត្រីជាន់ខ្ពស់បំផុតដែលមានឋានៈដូចជានាយករដ្ឋមន្ត្រី។ មន្ត្រីជាន់ខ្ពស់នេះមានឥទ្ធិពលខ្លាំងនៅក្នុងរាជ្យនោះ និងក្នុងរជ្ជកាលក្រោយមក ដោយសារព្រះមហាក្សត្រមានវ័យក្មេងពេក។ ឋានៈនៃរាជកុលមហាមន្ត្រីនេះ មានសកម្មភាពយូរអង្វែងរាប់រយឆ្នាំ។ ចំណែកឋានៈនៃមន្ត្រីផ្សេងៗទៀត ច្រើនប្រែប្រួលដោយគ្មានឯកភាពយូរអង្វែងទេ។

បើតាមការកត់សម្គាល់ រាជកុលមហាមន្ត្រី គឺជាវរជនដែលមានដើមកំណើតនៅក្នុងចង្កោមរាជវង្សានុវង្សតែម្តង ហើយកិច្ចការរបស់គាត់ទំនងជាមានការទាក់ទងជាមួយក្រុមរាជវង្សានុវង្ស។

២-ស្ថាប័នអាចារ្យប្រធាន (ប្រមុខខាងសាសនា) ដែលមានសមាជិកបួនរូប ហើយអាចារ្យប្រធានទី១ ដែលតែងមានឋានន្តរស័ក្តិដ៏ខ្ពង់ខ្ពស់បន្ទាប់ពីព្រះរាជា គឺ ធូលីជេងវ្រះកម្រតេងអញ ។ បើពិនិត្យឱ្យហ្មត់ចត់ អាចារ្យប្រធានហាក់ដូចជា ប្រមុខនៃមេដឹកនាំខាងធម្មចក្រ ដែលត្រូវដើរទន្ទឹមគ្នានឹងអាណាចក្រ។

៣-ស្ថាប័នតុលាការ (ព្រះសភា) មានសមាជិក៤រូប

៤-ស្ថាប័ននគរបាល (គុណទោសទសី) មានសមាជិក៤រូប

៥-ស្ថាប័នព្រះឃ្លាំង មានសមាជិក៤រូប

៦-ស្ថាប័នមន្ត្រីវាំង (ខ្លោញលំវាង)

៧-ស្ថាប័នការពារ (មហាសេនាបតី)គឺមេទ័ពជាច្រើនអ្នកនៅជុំវិញព្រះរាជា និងចៅហ្វាយខេត្តទាំងឡាយដែលជាស្តេចត្រាញ់ និងជាអភិបាលខេត្តជម្មតា។

មេទ័ពជំនិតព្រះរាជាភាគច្រើន មានឋានន្តរនាម អ្នកសញ្ជក ។ មុខងារនេះមានបញ្ជាក់ដោយសិលាចារឹកក្នុងរជ្ជកាលព្រះបាទជយវម៌្មទី៥ ហើយក្រោយមកមានរំឭកយ៉ាងញឹកញាប់ពីមុខងារនេះ ចាប់ពីរជ្ជកាលព្រះបាទសូរ្យវម៌្មទី១។ លោក អែម៉ូនីញ៉េយល់ថា សញ្ជកជាមន្ត្រីហែហម និងការពារព្រះមហាក្សត្រផ្ទាល់។ នេះគឺសំដៅដល់មន្ត្រីជាន់ខ្ពស់ ជាជំនិតរបស់ព្រះអង្គ ឬដែលជាទីទុកព្រះទ័យរបស់ព្រះអង្គ។ សិលាចារឹកបន្ទាយឆ្មារបានរៀបរាប់ពី អ្នកសញ្ជក ដែលគោរពពាក្យសម្បថរបស់ខ្លួន(ប្រតិជ្ញា-ប្តេជ្ញា)បានបូជាជីវិតដើម្បីការពារព្រះអង្គម្ចាស់របស់ខ្លួន ក្នុងការធ្វើសង្គ្រាមទល់នឹងពួកបះបោរ និងសង្គ្រាមជាមួយចាម។ មន្ត្រីដែលជាសញ្ជកបានបំពេញកិច្ចការផ្សេងៗជាច្រើនទៀត ដូចទទួលបន្ទុកជាអធិការលើព្រះរាជកិច្ចក្នុងប្រាសាទលិង្គបុរៈ។ លោកហ្វីណូត៍ បានសន្និដ្ឋាន

ថា៖ ជាទូទៅគេឃើញថា សញ្ជកជាគោរម្យងារមន្ត្រីដែលជិតស្និតនឹងព្រះមហាក្សត្រ តែតាមរយៈសិលាចារឹកត្រពាំងរុន សញ្ជកមានតួនាទីធ្វើសវនាការដែលមានការចូលរួមពីមន្ត្រីសំខាន់ដូចជា អធិការលើគុណសម្បត្តិ-គុណវិបត្តិ(គុណទោសទសិ), អ្នកបង្រៀន(អាចារ្យប្រធាន), អ្នកសូត្រគម្ពីរធម្មសាស្ត្រ ជាទីប្រឹក្សាផ្នែកតុលាការ, ប្រធានឃ្លាំងទាំងបីថ្នាក់ និងអ្នករក្សាឯកសារ។ អ្នកសញ្ជក មានភារកិច្ចការពារសំណង់សាសនា។ សិលាចារឹកក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី១ បានបញ្ជាក់ពីកិច្ចការដកហូតអំណាចរដ្ឋបាលលើអាស្រមពីមន្ត្រីជាច្រើនប្រភេទ ហើយបានប្រគល់កិច្ចការនេះឱ្យនៅក្រោមអំណាច ខ្លោញពល និងអ្នកសញ្ជក ។ សិលាចារឹកក្នុងរជ្ជកាលព្រះបាទជយវរ្ម័នទី៥ បានរំឭកអ្នកសញ្ជក របស់ព្រះមហាក្សត្រដ៏សំខាន់ៗ។ នៅតាមថែវប្រាសាទអង្គរវត្តក្នុងចំណោមមន្ត្រីជាន់ខ្ពស់ ដែលដង្ហែព្រះមហាក្សត្របរមវិស្ណុលោក គេឃើញមានបញ្ជាក់ឈ្មោះផ្ទាល់ និងឈ្មោះផ្លូវការរបស់អ្នកសញ្ជកចំនួន១០នាក់។ គោរម្យងារអ្នកសញ្ជកនេះ មិនមែនសម្រាប់តែបុរសទេ គឺមានស្ត្រីជាច្រើនដែលបំពេញតួនាទីនេះ។ អ្នកសញ្ជក ភាគច្រើនអ្នកសញ្ជកមានគោរម្យងារផ្លូវការជា"វ្រះកម្រតេងអញ"។ ជាធម្មតាអ្នកសញ្ជក ក្រោយពីស្លាប់ត្រូវទទួលឋានន្តរនាម បច្ឆាមរណៈថា អំតេង ។

## 6.6. មន្ត្រីជាទីប្រឹក្សា និងជំនួយកិច្ចការរដ្ឋ

**ឧត្តមមន្ត្រីជំនួយការព្រះមហាក្សត្រ មានដូចជា ៖**

*ច-១-ព្រាហ្មណ៍បុរោហិត និង រាជហោតា*

មុខងារព្រាហ្មណ៍បុរោហិតមានលក្ខណៈបន្តពូជ។ សិលាចារឹកចុះកាលបរិច្ឆេទ១០៦៩គស បញ្ជាក់ថា ព្រះបាទជយវរ្ម័នទី២ បានបញ្ជាឱ្យមន្ត្រីជាន់ខ្ពស់ គឺម្រតាញប្រឹថិវិនរេន្ទ្រទៅរៀបចំស្រុកនានាឱ្យមានសន្តិភាព។ ព្រាហ្មណ៍បុរោហិតជាអ្នកពិនិត្យ និងផ្តល់ពត៌មានដល់ព្រះមហាក្សត្រពីតម្រូវការចាំបាច់សម្រាប់ការសាងសង់ប្រាសាទ។ ព្រាហ្មណ៍បុរោហិតមានតួនាទីសំខាន់ណាស់ក្នុងពិធីរាជាភិសេក ហើយមានឥទ្ធិពលក្នុងការជ្រើសរើសបុត្រស្នងរាជ្យ ក្នុងករណីមានបុត្រជាច្រើនដែលអាចទទួលបន្ទុកស្នងរាជ្យនេះ។ តាមសិលាចារឹកលង្វែក ព្រះបាទឧទយាទិត្យវរ្ម័នទី២ បានរៀបចំអភិសេកដោយមន្ត្រីរបស់ព្រះអង្គ ហើយក្រោយមកតាមសិលាចារឹកក្បាលស្ពាន បានឱ្យដឹងពីទំនាក់ទំនងរវាងព្រះអង្គជាមួយព្រះបាទសូរ្យវរ្ម័នទី១ថា ជា"បុត្រា និងបិតា"។ មន្ត្រីជាទីប្រឹក្សាសម្រាប់ព្រះមហាក្សត្រ ក្នុងការចាត់ចែងកិច្ចការរដ្ឋ បម្រើការនៅរាជធានី ហើយអាចគ្រប់គ្រងលើស្ថាប័ននៅតាមខេត្តនានា។ នៅក្នុងរជ្ជកាលរបស់ព្រះបាទជយវរ្ម័នទី៣ មន្ទីរពេទ្យទាំងអស់ស្ថិតក្រោមការគ្រប់គ្រងផ្ទាល់ពីមន្ត្រីនៅរាជធានី។ មន្ត្រីទីប្រឹក្សាមានឋានានុក្រមបន្ទាប់ពីព្រះមហាក្សត្រ ភាគច្រើនទទួលបាននូវគ្រឿងឥស្សរិយយសជាគ្រែស្នែងដងមាសមានកំពូលមួយ។ សិលាចារឹកថ្មល់បាវាយណ៍ បានបញ្ជាក់ថា ក្នុងពិធីនៅអាស្រម មានមន្ត្រីកិត្តយសចូលរួមតាមឋានានុក្រម បន្ទាប់ពីព្រះមហាក្សត្រគឺ ព្រាហ្មណ៍បុរោហិត ព្រះរាជបុត្រ និងមេទ័ព។ អាមាត្យម្នាក់ឈ្មោះ វាបធម្មាចារ្យ បានទទួលបញ្ជាឱ្យសួរចំលើយពួកគ្រាមវ្រឹទ្ធបួននាក់ អំពីវិសាលភាពដីស្រែ ហើយបានដាំបង្គោលជាព្រំសីមា។ ទោះជាងារ វាប ជាមន្ត្រីថ្នាក់ក្រោមក៏ដោយ ក៏អាមាត្យអាចជាមន្ត្រីបម្រើការរាជការ ដែលមានឋានានុក្រមតូច-ធំទៅតាមសមត្ថភាពដែរ ។

*ច-២-វ្រះគុរុ ឬរាជគ្រូ*

មុនសតវត្សរ៍ទី៩ យើងគ្មានពត៌មានច្បាស់លាស់ពីវ្រះគុរុទេ។ លុះមកដល់រជ្ជកាលព្រះជយវរ្ម័នទី២ ដែលជាមហាក្សត្រស្ថាបនិករបបរាជាធិបតេយ្យខ្មែរសម័យអង្គរ បានលើកព្រាហ្មណ៍ឈ្មោះសិវកៃវល្យៈ ធ្វើជាវ្រះគុរុ និងរាជបុរោហិតរបស់ព្រះអង្គ។ ព្រះរាជគុរុមានឋានន្តរនាមជាភាសាភាសាខ្មែរថា"ស្តេងអញ"។ នៅក្នុងអត្ថបទដដែលនេះ

វាមសិវៈដែលជាក្មួយរបស់សិវកៃវល្យៈ និងជាគ្រូឧបាធ្យាយរបស់ព្រះបាទឥន្ទ្រវម៌្ម បានបង្ហាត់បង្រៀនព្រះអង្គម្ចាស់យសោវរ៌ធន។ បន្ទាប់ពីបានឡើងគ្រងរាជ្យ ព្រះមហាក្សត្រអង្គនេះបានតម្លើងឋានៈវាមសិវៈ ជាវ្រះកម្រតេងវ្រះគុរុ។ វ្រះគុរុយជ្ញវរាហៈ បានបំពេញមុខងារដ៏សំខាន់នៅដើមរជ្ជកាលព្រះបាទជយវម៌្មទី៥ ដែលកាលឡើងគ្រងរាជ្យនៅឆ្នាំ៩៦៨ ព្រះអង្គមានវ័យក្មេងពេក ហើយកំពុងស្ថិតនៅក្នុងការសិក្សានៅឡើយ។ វ្រះគុរុបន្តបង្ហាត់បង្រៀនព្រះអង្គអស់រយៈពេល៦ឆ្នាំបន្ថែមទៀត គឺហូតដល់ឆ្នាំ៩៧៤ទើបព្រះអង្គរៀនចប់។ ចំណែកវ្រះគុរុរបស់ព្រះបាទសូរ្យវម៌្មទី១ឈ្មោះយោគីស្វរបណ្ឌិត មានកំណើតនៅភូមិវ្រុកំទ្វាតក្នុងស្រុកវ្យាធបុរៈ។ គុរុនេះជាកូនរបស់ព្រាហ្មណ៍ភានុវរ និងនាងសត្យវតី ដែលជាចៅស្រីរបស់ជយវម៌្មទី២។ ក្នុងឋានៈជាអ្នកបំពេញព្រះរាជកិច្ច គាត់ទទួលគោរម្យងារជាសំស្ក្រឹតថា "ទេវៈ" ដែលត្រូវនឹងភាសាខ្មែរថា "វ្រះកម្រតេងអញ"។ គាត់បានក្លាយជាបុត្រសុណិសារបស់ព្រះបាទសូរ្យវម៌្មទី១។

អតីតមន្ត្រីនៃពិធីទេវរាជឈ្មោះសទាសិវៈ-ជយេន្ទ្របណ្ឌិត ដែលជាគុរុរបស់ព្រះបាទឧទយាទិត្យវម៌្មទី២ ក៏ទទួលគោរម្យងារពីព្រះអង្គសឹងស្មើឋានៈព្រះមហាក្សត្រ គឺធូលីជេងវ្រះកម្រតេងអញ ក្នុងនាមជាអាចារ្យប្រធានថ្នាក់ទី១វិញ។ តាមសិលាចារឹកលង្វែកវ្រះកម្រតេងសង្ករបណ្ឌិតនៃគ្រួសារសប្តទេវកុល ក៏បម្រើការជាគុរុនៅក្នុងរជ្ជកាលព្រះឧទយាទិត្យវម៌្មទី២ដែរ។ ព្រោះគាត់មានការប៉ិនប្រសប់ក្នុងការធ្វើពិធីបូជាផ្សេងៗ ហើយគាត់ត្រូវបានទទួលមុខងារបន្តពីវ្រះគុរុជយេន្ទ្របណ្ឌិត។

តាមប្រវត្តិការងារជាបន្តបន្ទាប់ ក្នុងឋានៈជាវ្រះគុរុ ទិវាករបណ្ឌិត មានទេពកោសល្យអាចបំពេញតួនាទីជាវ្រះគុរុសម្រាប់ព្រះមហាក្សត្របីរជ្ជកាល គឺរជ្ជកាលព្រះបាទជយវម៌្មទី៦ ព្រះបាទធរណីន្ទ្រវម៌្មទី១ និងសូរ្យវម៌្មទី២នោះ។ គាត់កើតចេញពីស្រទាប់ក្រុមកម្ពាន្តរៈនៅភូមិវ្រុទ្នង ក្នុងស្រុកសទ្យា។ បន្ទាប់ពីបានបំពេញមុខងារសំខាន់ៗ នៅក្នុងរជ្ជកាលព្រះបាទឧទយាទិត្យវម៌្មទី២ និងហស៌វម៌្មទី៣ គាត់បានចូលរួមចាត់ចែងឱ្យព្រះបាទជយវម៌្មទី៦ បានកាន់អំណាចនៅឆ្នាំ១០៨០ ដោយមិនគិតពីព្រះរាជាដែលខ្លួនធ្លាប់បម្រើពីមុនទេ។ ព្រះបាទជយវម៌្មទី៦ បានលើកទិវាករជាវ្រះគុរុហើយប្រគល់នាទីឱ្យរៀបចំពិធីរាជាភិសេកព្រះអង្គ។ ចាប់ពីពេលនោះមកគាត់បានក្លាយទៅជាទីប្រឹក្សាផ្នែកសាសនាអស់រយៈពេល៤០ឆ្នាំ។ ព្រះបាទជយវម៌្មទី៦ បានប្រគល់គោរម្យងារគាត់ជា "ភគវតបាទកម្រតេងអញ" និងគ្រឿងឥស្សរិយសសម្រាប់ឋានៈថ្មីនេះ មានអង្រឹងស្នែងមាសក្លស់ពណ៌ស..។ គាត់បានរៀបចំរាជាភិសេកព្រះបាទធរណីន្ទ្រវម៌្មទី១ ដែលជាព្រះរៀមព្រះបាទជយវម៌្មទី៦។ ក្រោយមកគាត់បានគាំទ្ររដ្ឋប្រហារដឹកនាំដោយព្រះរាជនត្តាមីងនៅឆ្នាំ១១១៣។ គាត់បានរៀបចំឱ្យការឡើងកាន់អំណាចមិនប្រក្រតីរបស់ព្រះបាទសូរ្យវម៌្មទី២ មានលក្ខណៈស្របច្បាប់ដោយពិធីរាជាភិសេក ព្រះរាជាថ្មីបានតម្លើងឋានន្តរសក្តិគាត់កាន់តែខ្ពស់ជាងមុន គឺមានគោរម្យងារជា" ធូលីជេងវ្រះកម្រតេងអញ"។ នៅរជ្ជកាលព្រះបាទជយវម៌្មទី៧ មានការតម្កើងឋានៈវ្រះគុរុខ្លាំងលើសគេ។

វ្រះគុរុមានចែងលំដាប់ថ្នាក់។ វ្រះគុរុដែលល្បីឈ្មោះខ្លាំង មិនមានត្រកូលកើតពីវណ្ណៈព្រាហ្មណ៍ទេ តែច្រើនជាប់ព្រះញាតិវង្ស។ វ្រះគុរុមិនគ្រាន់តែតំណាងវណ្ណៈព្រាហ្មណ៍ និងក្សត្រប៉ុណ្ណោះទេ ថែមទាំងមានឥទ្ធិពលខ្លាំង ទាំងក្នុងមជ្ឈដ្ឋានសាសនា ទាំងក្នុងកិច្ចការរដ្ឋ។ វ្រះគុរុត្រូវបង្ហាត់បង្រៀន ព្រះអង្គម្ចាស់រជ្ជទាយាទ និងរៀបចំពិធីរាជាភិសេក។ គាត់ត្រូវធ្វើពិធីបូជាគ្រប់បែបយ៉ាងដើម្បីនឹងរក្សាទំនាក់ទំនង ស៊ីសង្វាក់គ្នារវាងអាទិទេព និងមនុស្ស។ ភ្លៀងដែលជាប្រភពរស់នៃសេចក្តីចម្រើនសំបូរសប្បាយរបស់ព្រះរាជាណាចក្រនឹងធ្លាក់បរិបូរកាលណា មានការរៀបចំពិធីបូជាបានល្អប្រសើរ។ វ្រះគុរុទទួលព្រះរាជបញ្ជាស្តីពីការកសាងប្រាសាទសម្រាប់សាសនា។ គាត់អាចបង្កើតក្រុមការងារថ្មី(វណ៌)(ជយវម៌្មទី៥) និងជ្រើសតាំងសមាជិកស្ថាបនិក។ វ្រះគុរុមិនមែនគ្រាន់តែបំពេញមុខងារខាងផ្នែកសាសនាទេ គាត់ថែមទាំងបម្រើកិច្ចការរដ្ឋបាលស៊ីវិលថែមទៀត។ គាត់ទទួលព្រះរាជបញ្ជាចាត់ចែងលើអំណាចជាទ្រព្យកម្មសិទ្ធិ និងទទួលបន្ទុកជាមន្ត្រីរៀបចំបោះគោលសីមា និងផ្ទេរសិទ្ធិដីឱ្យទៅម្ចាស់ផ្ទាល់។ សិលាចារឹករបស់ព្រះ

បាទសូរ្យវម៌្មទី១(K.843)បញ្ជាក់ពីវ្រះគុរុ ដែលជាប្រធានតុលាការលំដាប់ថ្នាក់ទី៣ ដើម្បីជូនពត៌មានដល់ព្រះមហាក្សត្រពីវិវាទក្នុងបញ្ហាដីជាច្រើនកន្លែង។ អត្ថបទមួយទៀតក្នុងរជ្ជកាលដដែលនេះ បញ្ជាក់ពីកម្រតេងអញវ្រះគុរុលំដាប់ថ្នាក់លេខ២ ដែលបានដឹងរឿងរ៉ាវ បានទទួលបន្ទុកការពារសំណង់របស់សមាជិកមង្គលាថ៌។ ដូចនេះវ្រះគុរុមានតួនាទីសំខាន់ណាស់ក្នុងកិច្ចការជាទីប្រឹក្សាព្រះមហាក្សត្រ ហើយទទួលបន្ទុកកិច្ចការរដ្ឋ និងសាសនា។ ព្រះគុរុដ៏ល្បីមានឋានៈសឹងស្មើព្រះមហាក្សត្រ ដូចជា វាគិន្ទ្របណ្ឌិត, ជយេន្ទ្របណ្ឌិត, ទិវាករបណ្ឌិត ជាដើមបានទទួលគោរម្យងារជា "ធូលីជេងវ្រះកម្រតេងអញ" ។

*ប-៣-បរិនាយក ឬ ទីប្រឹក្សា*

ទីប្រឹក្សាមានតួនាទីសំខាន់ក្នុងកិច្ចការរដ្ឋដែរ និងសុទ្ធតែជាអ្នកមានសមត្ថភាព និងមានចំណេះដឹងតាមគម្ពីរសាស្ត្រផ្សេងៗ ជាពិសេសធម្មសាស្ត្រ និងអថ៌សាស្ត្រ។ មានឧទាហរណ៍ជាច្រើន នៅក្នុងសិលាចារឹក ដោយអ្នកទាំងនោះតែងមាននាមបញ្ចប់ដោយពាក្យ"--បណ្ឌិត" ហើយពួកគេសុទ្ធសឹងជាអ្នកមានវោហាស័ព្ទក្បោះក្បាយ។

*ប-៤-សំវ៉ាធិការិ*

សិលាចារឹកក្នុងរជ្ជកាលព្រះបាទសូរ្យវម៌្មទី១ បានរំឭកពីវ្រះបុគ្គក ជាសភាដែលមានភារកិច្ចកំណត់ព្រំដែនដីវិស្ណុគ្រាម និងស្រុកជាកម្មសិទ្ធិរបស់ម្ចាស់ក្សត្រិវីរលក្ស្មី។ សិលាចារឹកចុះកាលបរិច្ឆេទ1228 Çaka (១៣០៦គស) បានរំឭកពីវ្រះកម្រតេងអញស្រីយសោធរបណ្ឌិត ដែលមានមុខងារជាសមូហសំវ៉ាធិការី ដែលជាមន្ត្រីជាន់ខ្ពស់។

*ប-៥-ស្រេស្និន*

ស្រេស្និន ជាគោរម្យងាររបស់មន្ត្រីជាន់ខ្ពស់ដែលទទួលបន្ទុករដ្ឋបាល។ លោក ហ្សក សឺដេសសន្និដ្ឋានថា ស្រេស្និន ដែលមានក្នុងសិលាចារឹកលលៃ មានន័យប្រហាក់ប្រហែលនឹងវណ៌ស្រេស្ឋនៅក្នុងសិលាចារឹកប្រាសាទតាកែវ ដែលជាប្រធានវណ្ណៈ។ តាមសិលាចារឹកសតវត្សរ៍ទី៧គ្រូរបស់ព្រះមហាក្សត្រ នួបាទិត្យ ត្រូវបានតែងតាំងជាប្រធានពាណិជ្ជករ(វណ៌ជានាមអធិបៈ)ដែលមានគោរម្យងារជាមហាស្រេស្ឋ។ លោកហ្សក សឺដេស យល់ថាវណ៌ជានាមអធិប៖ មានន័យត្រូវនឹងពាក្យខ្មែរថា ខ្លោញវណ៌ក។ សិលាចារឹកលពបុរី ចុះកាលបរិច្ឆេទឆ្នាំ ១០២២គស បានបញ្ជាក់ថា វ្រះស្រេស្និននាំព្រះរាជប្បញ្ញត្តិរបស់ព្រះបាទសូរ្យវម៌្មទី១ ទៅប្រគល់ដល់កន្លែងស្នាក់នៅរបស់ព្រះសង្ឃពុទ្ធសាសនា និងកន្លែងសម្នាក់របស់តាបសព្រាហ្មណ៍។ ចំណែកសិលាចារឹករបស់ព្រះបាទយសោវម៌្មទី១ បានរំឭកពីការពិន័យស្រេស្និមុខ្យ ដែលបំពានព្រះរាជបញ្ជាទាក់ទងនឹងប្រាសាទលលៃ ហើយត្រូវបង់ពិន័យជាមាសចំនួន២បល្លកន្លះ។

*ប-៦-វ្យាបារ*

នៅក្នុងរជ្ជកាលរបស់ព្រះបាទយសោវម៌្មទី១ មានមន្ត្រីមានគោរម្យងារជា វ្យាបារ។ ដល់រាជ្យព្រះបាទសូរ្យវម៌្មទី១ មានចារឹកឈ្មោះវ្រះកម្រតេងអញវ្យាបារជាច្រើនកន្លែង។ មន្ត្រីនេះ ទទួលបញ្ជាដាំគោលសីមាដីកម្មសិទ្ធិ។ ជួនកាលគេបន្ថែមលើគោរម្យងារមន្ត្រីខ្លះ ដោយពាក្យវ្យាបារនេះដូចខ្លោញឃ្លាំងវ្យាបារ។ អត្ថបទសិលាចារឹកមួយបានលើកពីមន្ត្រីបម្រើការងាររាជការ មានមុខងារជា វ្យាបារ អត្ថបទមួយទៀត បានលើកពីប្រធានតម្រួត វ្យាវហារិន ។

*ប-៧-អ្នករក្សាឯកសាររបស់ប្រទេស*

នៅក្នុងរជ្ជកាលរបស់ព្រះបាទសូរ្យវម៌្មទី១ មានមន្ត្រីស្រីម្នាក់ឈ្មោះស្រីសុកម្ម៉ាកំស្តេង ដែលរក្សាឯកសារនៅក្នុងប្រាសាទសិខរីស្វែរៈ(ព្រះវិហារ)អត្ថបទបញ្ជាក់ថា "មានគ្រួសារមួយថែរក្សាឯកសារ បានសរសេរកត់ត្រាទាំងអស់នូវដំណើររឿងទាក់ទងនឹងរាជាណាចក្រកម្ពុជា និងស្ថាប័ននៃរាជាណាចក្រ, ប្រវត្តិស្នាដៃព្រះមហាក្សត្រ ចាប់ពីព្រះបាទស្រុតវម៌្មរហូតមកដល់ព្រះបាទស្រីសូរ្យវម៌្មទេវៈទី១។ ឯកសារទាំងនេះបានកត់ត្រារក្សាទុកលើស្លឹករឹត ហើយតម្កល់ទុកក្នុងវិហារស្រីសិខរីស្វែរៈ(ព្រះវិហារ)ស្រីវ៎ទ្ធេស្វរៈ ហើយនឹងព្រះកន្លោង(ប្រហែលជាបណ្ណាល័យ)។ ដើម្បីតបស្នងគុណបំណាច់នេះព្រះមហាក្សត្រ បានប្រទានដល់សុកម្ម៉ានូវព្រះរាជទ្រព្យ និងស្រុករិភេទ ដែលត្រូវដូរឈ្មោះជា កុរុក្សេត្រ។

### *ប-៨-ប្រត្យយ*

ប្រត្យយៈ ឬរាជប្រត្យយៈ ជាភ្នាក់ងាររដ្ឋ ឬមនុស្សជាទីទំនុកទុកចិត្តរបស់មន្ត្រីណាមួយ ឬជាលេខាធិការ។ ក្នុងរជ្ជកាលព្រះបាទឧទយាទិត្យវម៌្មទី២ ស្តេងអញរាជប្រត្យយៈ បានកំណត់ព្រំសីមាកម្មសិទ្ធិរវាងឃ្លាំងផ្តល់ក្រមួន និងឃ្លាំងព្រះរាជទ្រព្យ។ ប្រត្យយៈទទួលបង្គាប់ពីមន្ត្រីជាន់ខ្ពស់របស់រដ្ឋ(រដ្ឋមន្ត្រី) ដើម្បីនាំព្រះរាជបញ្ជាទៅឱ្យអាជ្ញាធរមូលដ្ឋាន។ ប្រត្យយៈអាចជាភ្នាក់ងារមន្ត្រីរបស់រដ្ឋាភិបាល ឬជាភ្នាក់ងារទុកចិត្តរបស់មន្ត្រីជាន់ខ្ពស់ណាមួយ។ ឧទាហរណ៍ វ្រះកម្រតេងអញ ស្រីសមរាធិបតិវម៌្ម ជាប្រត្យយៈរបស់ម្រតាញខ្លោញភវបុរៈ។ សិលាចារឹកក្នុងរជ្ជកាលរបស់ព្រះបាទជយវម៌្មទី៥ បានបញ្ជាក់ពីវាបវ្រៃ ដែលជាប្រត្យយៈ ម៉ុតកធិន គឺជាមនុស្សដ៏គួរឱ្យទុកចិត្តដែលត្រូវទទួលគ្រប់គ្រងទ្រព្យបានមកពីមរតក។

ប្រត្យយឃ្លាំង ជាអ្នកទទួលគ្រប់គ្រងឃ្លាំងព្រះរាជទ្រព្យ។ ក្រៅពីនេះមានមន្ត្រីតូចតាចតាមលំដាប់ថ្នាក់ដូចតទៅ៖ ប្រធានវិចិត្រករ (សិល្បិន្ទ្រៈ), អ្នកកាន់ឆ្លិត(បមក), រាជបម្រើ-ក្មេងបម្រើ(កន្សែងបំរេ), រាជបម្រើព្រះក្រលាល្វង, ផ្ទាំក្រលាបន្ទំ និងគ្រូពេទ្យព្យាបាល ។ល។ ចាប់ពីរាជព្រះបាទជយវម៌្មទី២មក អ្នកបម្រើក្នុងព្រះរាជវាំង មាន៧ក្រុមខុសគ្នា(៧វណ្ណៈ) ហើយត្រូវថែមពីរក្រុមទៀតជាក្រុមអ្នកបួស គឺក្រុមវ្រះក្រលាអច្ឆ័នៈ និងកម្មាន្តរៈ ចាប់ពីរាជ្យព្រះបាទជយវម៌្មទី៥។

ម្យ៉ាងទៀតមន្ត្រីខាងកិច្ចការសាសនា ក៏មានលំដាប់ថ្នាក់ដូចមន្ត្រីរាជការដែរ។ ក្រោយពីមានចាត់ចែងពិធីទេវរាជ ក្នុងរជ្ជកាលព្រះបាទជយវម៌្មទី២មក ត្រកូលព្រាហ្មណ៍សិវកៃវល្យ ជាអ្នកទទួលផ្តាច់មុខបន្តសន្តានក្នុងការរៀបចំពិធីនេះ។ ព្រះរាជបុរោហិតអាចជាអ្នកបួស ឬជាគ្រហស្ថ។ចំណែកបុរោហិតទទួលមុខងារតាមតំណវង្សពីមាទៅក្មួយឬ ពីតាមីងទៅចៅមីងតាមខ្សែម្តាយ។ អាចារ្យ, អាចារ្យហោម, ចតុរាចារ្យ, អាចារ្យប្រធានសុទ្ធសឹងជាមន្ត្រីសាសនាតាមការតែងតាំង។

មុខងារមន្ត្រីនៅក្នុងរដ្ឋាភិបាល មានលក្ខណៈបន្តសន្តាន ទាំងមុខងារដែលទាក់ទងទៅនឹងសាសនា និងកិច្ចការស៊ីវិល។ មិនត្រឹមប៉ុណ្ណោះ សូម្បីរហស្សនាម ឬនាមបញ្ញត្តិរបស់គេ ក៏ត្រូវបំពាក់ ឬប្រកាន់យកតគ្នាដែរពីឪពុកទៅកូន ឬពីជីតាទៅចៅ។ ជាធម្មតាមន្ត្រីសំខាន់ៗនៅជុំវិញព្រះរាជា រួមមានទាំងបព្វជិត និងគ្រហស្ថ។ ដូនតារបស់លោកមេទ័ពក្នុងរជ្ជកាលព្រះបាទឧទយាទិត្យវម៌្មទី២ បានបម្រើព្រះរាជាសោយរាជ្យពីមុន។ គ្រួសារព្រាហ្មណ៍មធុសូទនៈជារាជបុរោហិតព្រះបាទជយវម៌្មទី២។ ត្រកូលនេះបានបម្រើមុខងារជាអ្នកកាន់ឧបករណ៍បក់រុយរបស់ជយវម៌្មទី៤ ហើយជាមេបញ្ជាការកងទ័ពក្នុងរជ្ជកាលព្រះបាទសូរ្យវម៌្មទី១។ សិលាចារឹកចុះកាលបរិច្ឆេទ១០៦០គ.ស. បានបញ្ជាក់ពីគ្រួសារមួយដែលមានមុខងារកាន់ឆ្លិតចាប់តាំងពីរជ្ជកាលព្រះបាទជយវម៌្មទី២។

### 6.7. ឋានន្តរស័ក្តិមន្ត្រីរាជការ

#### ធ-១-លក្ខណៈជ្រើសរើសមន្ត្រី ៖

តាមសិលាចារឹកមួយចំនួនរបស់ព្រះបាទជយវរ្ម័នទី៥ បានបញ្ជាក់ពីការបង្កើតវណ្ណៈពីរ គឺខ្នុកវ្រះក្រលាអច្ឆ៌នៈ និងកម្ម៌ាន្តរៈ ដោយសមាជិកមូលដ្ឋានជ្រើសរើសចេញពីក្រុមគ្រួសាររបស់អាចារ្យប្រធាន ហើយអ្នកទាំងនោះ ត្រូវព្រះអង្គបញ្ញត្តិទុកថា នឹងក្លាយទៅជាប្រភពធនធានមនុស្សតែមួយគត់សម្រាប់ជ្រើសរើសឱ្យចេញទៅធ្វើមន្ត្រីរាជការចាប់ពីពេលនោះតមក។ ចំណែកព្រះបាទសូរ្យវរ្ម័នទី១ បានជ្រើសរើសមន្ត្រី ដោយគិតពីពូជពង្ស-អាយុ ការងារបំពេញភារៈកិច្ច និងគុណសម្បត្តិផ្ទាល់។ បើតាមជីវតាក្វាន់ថា មន្ត្រីភាគច្រើន ជាពូជពង្សរបស់ស្តេច បើមានអ្នកខាងក្រៅចូលធ្វើដែរ ទាល់តែអ្នកនោះយកកូនស្រីទៅថ្វាយស្តេចធ្វើស្នំ។ តែតាមរយៈសិលាចារឹកមួយចំនួន ដូចជាសិលាចារឹកប្រាសាទគោកពោធិ៍ គេឃើញថា អាចចូលធ្វើមន្ត្រីបានដោយជូនវត្ថុមានតម្លៃឱ្យមន្ត្រីជាន់ខ្ពស់។ នោះប្រហែលជាប្រាក់ត្រូវបង់ឱ្យរាជការ បើសិនជារឿងអំពើសូកប៉ាន់ មន្ត្រីឋានន្តរនោមវាបទាំងនោះច្បាស់ជាមិនហ៊ានចារឹកលើថ្មឡើយ។

**ធ-២-ឋានានុក្រម ៖** តាមលោកជីវ តាក្វាន់(ចុងសវទី១៣) មន្ត្រីក្នុងព្រះរាជាណាចក្រកម្ពុជាមានឋានៈ៥យ៉ាង ៖ មន្ត្រីអង្គុយលើគ្រែស្នែងមាសមានបាំងក្លស់ដងមាសចំនួនបួន, មន្ត្រីអង្គុយលើគ្រែស្នែងមាសមានបាំងក្លស់ដងមាសចំនួនពីរ, មន្ត្រីអង្គុយលើគ្រែស្នែងមាសបាំងក្លស់ដងមាសចំនួនមួយ, មន្ត្រីអង្គុយលើគ្រែស្នែងប្រាក់បាំងក្លស់ដងមាសមួយ, បន្ទាប់មកទៀតមន្ត្រីគ្មានគ្រែស្នែងជិះតែបាំងក្លស់ដងមាសមួយ និងបាំងក្លស់ដងប្រាក់មួយ។

បើតាមពត៌មានពីសិលាចារឹកវិញ នៅសម័យអង្គរគេឃើញមានគ្រឿងឥស្សរិយសជាច្រើនបែប ដែលត្រូវប្រទានឱ្យទៅមន្ត្រីតាមលំដាប់ឋានានុក្រម ដូចជា៖ អង្រឹងស្នែងមាសចុងដងក្បាលនាគ ដែលមានកំពូលប្រាំ, កំពូលបី, កំពូលមួយ, មានក្លស់ដងមាស, ក្លស់ដងប្រាក់ ក្នុងចំនួនខុសៗគ្នា, ក្លស់ពណ៌ស, ក្លស់ធ្វើពីស្លាបក្ងោកត្បូងមួយ, ពានង្វាន់មាសរចនារំលេចដោយផ្កាឈូកដាក់ក្នុងប្រអប់ផ្កាឈូកស្រី, ផ្លិតស្លាបក្ងោក និងថូមួយ។ គេសង្កេតឃើញថា ក្នុងរជ្ជកាលរបស់ព្រះបាទសូរ្យវម្ម័ទី១ មន្ត្រីជាច្រើនទទួលគ្រឿងឥស្សរិយយសជាអង្រឹងស្នែងរចនាដោយក្បាលពស់។

#### ធ-៣-គោរម្យងារជាភាសាខ្មែរ ៖

គោរម្យងារជាភាសាខ្មែរសម្រាប់មន្ត្រីដែលបញ្ជាក់ក្នុងសិលាចារឹកមាន ៖ វាប, ឆ្លោញ, លោញ,ម្រតេញ, ម្រតាញ ឬម្រតាញខ៖ាញ, ស្តេញ-ស្តេង ឬស្តេងអញ, កំស្តេងអញ, វ្រះកំស្តេងអញ, ធូលីជេងកំស្តេងអញ, កម្រតេងអញ, វ្រះកម្រតេងអញ, ភគវតបាទកម្រតេងអញ, ធូលីជេងវ្រះកម្រតេងអញ.....។

នៅសតវត្សរ៍ទី១២ លោញ និងតេង សំដៅមនុស្សពេញសិទ្ធិដែលទទួលមុខងារជារាជការតូចតាច។ ក្នុងករណីខ្លះបានទទួលឋានៈខ្ពស់ដូចជា វ្រះកម្រតេង និងកំស្តេង។ ពួកឆ្លោញ និងវាប មានមុខងារមិនខ្ពស់ទេ។ ជួនកាលពួកខ្លះបានតែងតាំងជាមេភូមិ(ខ្លោញស្រុក) ជាឆ្មាំព្រះក្រលាបន្ទំ។ ម្រតាញខ្លោញជាគោរម្យងារខ្ពស់ជាងពួក˝ម្រតាញ˝ ។ អត្ថបទចុះកាលបរិច្ឆេទ៩១០គស បញ្ជាក់ថា ម្រតាញស្រីសត្យាស្រយ ជារដ្ឋមន្ត្រីសុរិយោធីរបស់ព្រះបាទយសោវម្ម័ ដែលបានទទួលគោរម្យងារ ជាម្រតាញខ្លោញ។ តាមការកត់សម្គាល់ គោរម្យងារម្រតាញដែលមានពាក្យខ្លោញ នៅខាងចុងភាគច្រើនតែងតែមានឋានៈជាមេគេឬប្រធានខាងផ្នែកអ្វីមួយ។ លោក អែម៉ូនីញ៉េ យល់ថា ពាក្យ˝ស្តេង˝ និង˝កំស្តេង˝ជាគោរម្យងារសម្រាប់វណ្ណៈព្រាហ្មណ៍។ ចំណែកអ្នកប្រាជ្ញ ហ្សក សឺដេសយល់ថាពាក្យកំស្តេង ដែលរំឭកក្នុងសិលាចារឹកប្រាសាទបេង ជាគោរម្យងារសម្រាប់បុរស ស្ត្រីមិនរើសមុខ។ តែជាធម្មតា˝កំស្តេង˝ច្រើនហៅពួក

អ្នកអង្គម្ចាស់ ឬព្រះអង្គម្ចាស់ទាំងឡាយដែលមិនទាន់កាន់កាប់មុខតំណែងជាន់ខ្ពស់នៅឡើយ។ គោរម្យងារស្តេង-ស្តេងអញ-កំស្តេងអញ-វ្រះកំស្តេងអញ-ធូលីជេងកំស្តេងអញ ជាលំដាប់ឋានានុក្រមនៃមន្ត្រីជាន់ខ្ពស់របស់ប្រទេស៖

ងារ កំស្តេងតូចជាង កំស្តេងអញ ៖ អត្ថបទសិលាចារឹកចុះកាលបរិច្ឆេទ៩៦៦គស រំឭកពីរាជកូលមហាមន្ត្រីមានងារជា"កំស្តេងអញ"។ ចំណែកមន្ត្រីម្នាក់ទៀតឈ្មោះវីរេន្ទ្រវិស័យ មានងារត្រឹម"កំស្តេង"។ ជាពិសេស គេឃើញពាក្យនេះសម្គាល់ព្រះបាទឦស្វរលោក(ឥន្ទ្រវម៌្មទី១)ជាកំស្តេងអញ ដោយហេតុថាជាញឹកញាប់គេប្រើពាក្យ«កំស្តេង» ជំនួសពាក្យ «កម្រតេង»។ តែជាទូទៅ កំស្តេងជាងារសម្រាប់មន្ត្រីជាន់ខ្ពស់នៃភូមិភាគផ្សេងៗ។

ងារវ្រះកម្រតេងអញ មានឋានៈខ្ពស់ជាងម្រតាញខ្លោញ និងកំស្តេង។ ឧទា.ម្រតាញខ្លោញ ទិវាករភដ្ដៈ បានត្រូវតម្លើងឋានន្តរស័ក្តិជា "វ្រះកម្រតេងអញ"។ ចំណែកកំស្តេងជយេន្ទ្របណ្ឌិតជាបុរោហិត បានត្រូវតម្លើងឋានន្តរស័ក្តិជា វ្រះកម្រតេងអញ ក្នុងរាជ្យសូរ្យវម៌្មទី១ និងជាធូលីជេងកម្រតេងអញ ក្នុងរជ្ជកាលព្រះបាទឧទយាទិត្យវម៌្មទី២។ នៅសម័យអង្គរយន្តការរដ្ឋបាលបានត្រូវពង្រីកយ៉ាងទូលំទូលាយ ហើយមន្ត្រីជាន់ខ្ពស់ខ្លះ បានទទួលគោរម្យងារជិតប្រហែលព្រះមហាក្សត្រ គឺមានងារជា"ភគវតបាទវ្រះកម្រតេងឬ ធូលីជើងវ្រះកម្រតេងអញ" ដូចជាព្រះរាជគ្រូរបស់ព្រះបាទឧទយាទិត្យវម៌្មទី២ ឈ្មោះ ជយេន្ទ្របណ្ឌិត និងទិវាករបណ្ឌិតដែលជារាជគ្រូរបស់ព្រះរាជា៥អង្គនេនៅចុងសតវត្សទី១១ និងដើមទី១២។ ក្នុងពិធីរាជាភិសេករបស់ព្រះបាទ ជយវម៌្មទី៦ ព្រះអង្គបានប្រទានឋានៈដល់ព្រាហ្មណ៍ទិវាករបណ្ឌិត ដែលមានងារ "វ្រះកម្រតេងអញ" ទៅជា "ភគវតបាទកម្រតេងអញ" បន្ទាប់មក ព្រះបាទសូរ្យវម៌្មទី២ បានរំលឹកឋានៈព្រាហ្មណ៍នេះជា "ធូលីជើងវ្រះកម្រតេងអញ"។ ព្រះរាជគ្រូរបស់ព្រះបាទ ជយវម៌្មទី៧ ឈ្មោះជយកិត្តិបណ្ឌិតក៏បានទទួលគោរម្យងារជា "ធូលីជេងវ្រះកម្រតេងអញ"នេះដែរ។

### 7. **រាជធានីយសោធរបុរៈ (ក្រុងអង្គរទី១-៣)**

ទីក្រុងស្រីយសោធរបុរៈ ជាទីក្រុងតំបន់អង្គរបច្ចុប្បន្ន ដែលបានចាប់ផ្តើមស្ថាបនាឡើងដោយព្រះបាទយសោវម៌្មទី១ បានបន្ទាប់ពីលើកចេញមកពីរាជធានីហរិហរាល័យនៅតំបន់រលួស-ព្រៃមន្ទីរ។ ទីក្រុងថ្មីស្រីយសោធរបុរៈ ត្រូវបានគេប្រើជាផ្លូវការរហូតដល់ចុងសម័យអង្គរ ហើយមកដល់សតវត្សទី១៩-២០ខ្មែរនិយមហៅថា អង្គរ, មហានគរ ឬអង្គរធំ។ ក្រោយមកអ្នកស្រាវជ្រាវបរទេស បាននាំគ្នាដាក់ឈ្មោះថា "អង្គរ" ដែលជាមហានគរ ឬនគរធំទី១នៅក្នុងប្រវត្តិសាស្ត្រខ្មែរ។ ។ ទីក្រុងអង្គរទី១នេះ មានការស្ថាបនាភ្នំបាខែងធ្វើជាប្រាសាទសក្ការបូជានៃស្នូលរាជធានី ដែលគេហៅថា "ភ្នំកណ្តាល ឬ មធ្យាទ្រិ"។ បើតាមសិលាចារឹកថ្នាលបារាយណ៍ ទំនងពីដំបូងឡើយ ទីក្រុងនេះគេដាក់ឈ្មោះ កម្ពុបុរី។ ក្រោយពេលព្រះបាទយសោវម៌្មទី១សុគត ទើបស្តេចជំនាន់ក្រោយដាក់ឈ្មោះទីក្រុងនេះថា ស្រីយសោធរបុរៈ វិញ តាមឈ្មោះស្ថាបនិក ដើម្បីរំឭកពីស្នាព្រះហស្តកេររបស់ព្រះអង្គ។ កំពែងគូរទឹក ត្រូវបានជីកព័ទ្ធជុំវិញព្រះរាជធានី ដើម្បីទុកការពារសត្រូវជិតឆ្ងាយ។ ប្រឡាយទឹកជាច្រើនជីកជាប់កាត់គ្នាចុះឡើងច្រវ៉ាត់ច្រវែងដូចក្រឡាចត្រង្គ តាមផែនការនយោបាយទឹក ដែលជាមធ្យោបាយមួយក្នុងការដឹកនាំទឹកបញ្ចូលទីក្រុង និងស្រែចម្ការសម្រាប់ប្រកបរបរកសិកម្ម។ ទីតាំងកណ្តាលនៃទីក្រុង ស្ថិតនៅលើភ្នំមួយដែលបច្ចុប្បន្នគេហៅថាភ្នំបាខែង។ ទីក្រុងនេះព័ទ្ធជុំវិញដោយជញ្ជាំង៤ជ្រុង ធំជាងទីក្រុងអង្គរចុងក្រោយដែលយើងឃើញសព្វថ្ងៃ។ អាទិទេពលើភ្នំបាខែង ជាសិវលិង្គដែលគេឱ្យឈ្មោះថា យសោធរេស្វរៈបើតាមសិលាចារឹកភ្នំបាខែងដែលនៅតោងជាប់នឹងស៊ុមទារខាងជើងមេទ្វារខាងកើតនៃតួប៉មកណ្តាល។

## 8. ការលើករាជធានីទៅកោះកេរ្តិ៍ (ឆោកគរគីរ)

ការលើករាជធានីនេះ គឺស្ថិតនៅក្នុងរជ្ជកាលព្រះបាទជយវរ្ម័ទី៤ ដែលឡើងសោយរាជ្យតំណាលគ្នានឹងព្រះបាទឥសានវរ្ម័ទី២ ឬនៅចុងរជ្ជកាលព្រះបាទហស៌វរ្ម័ទី១។ ការដែលព្រះអង្គលើករាជធានីទៅទីនោះមានអ្នកប្រាជ្ញខ្លះ ផ្តល់សម្មតិកម្មថា មកពីព្រះរាជាអង្គនេះចង់បង្ហាញពីសមត្ថភាពជាអធិរាជដែលខ្លាំងពូកែមួយអង្គដែរ។ ដោយសារពេលនោះ ត្រូវប្រជែងគ្នាជាមួយអធិរាជដែលត្រូវជាក្មួយ(ភាគនេយ្យោ?) របស់ទ្រង់។ ទោះជាយ៉ាងណានៅឆោកគគីរ ទ្រង់បានខិតខំកសាងទីក្រុងថ្មី និងប្រាសាទជាច្រើនដែលប្រកបដោយក្បាច់រចនាខុសប្លែកពីរចនាបថនៃស្ថាបត្យកម្មមុនៗ។ ដូចជាតាមរយៈសិលាចារឹកបី (បក្សីចាំក្រុង, ប្រាសាទអណ្តូង និងប្រាសាទដំរី) បានឱ្យដឹងថាព្រះអង្គបានកសាងសិវលិង្គស្វយម្ភូ(ពីធម្មជាតិ)ដ៏ធំមួយទំហំកម្ពស់៣៦ម៉ែត្រ ដែលគេមិនដឹងថានៅទីណា កាលពីលោកហ្សកសឺដេស កំពុងសិក្សាបកប្រែសិលាចារឹកទាំងនេះ។ បើតាមការសិក្សាស្រាវជ្រាវរបស់យើង សិវលិង្គស្វយម្ភូ ដែលព្រះរាជាអង្គនេះបានកសាង គឺត្រូវនឹងបូជនីយដ្ឋាន"ភ្នំព្រះធាតុ" នៅក្នុងស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំងសព្វថ្ងៃនេះ។ តែទោះជាយ៉ាងណាក៏ដោយ សំណង់ប្រាសាទរបស់ព្រះអង្គ ភាគច្រើនធ្វើមិនបានរួចរាល់ឡើយ។

ការសោយរាជ្យរបស់ព្រះបាទជយវរ្ម័ទី៤ បានសម្រេចស្ថាពរនៅក្រោយពេលព្រះបាទឥសានវរ្ម័ទី២ ចូលទិវង្គត។ ភាពស្របច្បាប់នៃរាជសម្បត្តិរបស់ព្រះអង្គ ដោយសារយកប្អូនស្រីព្រះបាទយសោវរ្ម័ធ្វើជាអគ្គមហេសី (K.905)។ ហើយព្រះរាជាទី២ដែលឡើងសោយរាជ្យបន្តពីព្រះអង្គ គឺព្រះបាទរាជេន្ទ្រវរ្ម័ដែលបានឡើងសោយរាជ្យនៅឆ្នាំ៩៤៤(K.71)[42] បានលើករាជធានីត្រឡប់មកយសោធរបុរៈវិញ។ ការបោះបង់ចោលរាជធានីនេះ ប្រហែលជាមកពីកត្តាភូមិសាស្ត្រមិនសូវអំណោយផលឱ្យ ជាពិសេសបញ្ហាសេដ្ឋកិច្ច ពាណិជ្ជកម្ម និងគមនាគមន៍។ ថ្វីបើទីនោះមានតំបន់ដីក្រហម ទឹកចេញពីក្នុងដីជាអចិន្ត្រៃយ៍ តែទំនងជានៅតែគ្មានស្បៀងអាហារគ្រប់គ្រាន់, ទឹកសម្រាប់ប្រើប្រាស់ផ្គត់ផ្គង់ទីក្រុង និងផ្លូវទឹក ដូចនៅតំបន់ជិតវាលទំនាបបឹងទន្លេសាប, ជាតំបន់ដែលដាច់ស្រយាលខ្លាំងពិបាកចរាចរទំនិញ។ ព្រោះថា ផ្លូវគមនាគមន៍ទៅកាន់ទីនោះ មានតែតាមផ្លូវគោក ហើយទំនងជាមានស្ថានភាពមិនល្អទៀតផង។

## 9. ការកសាងប្រាសាទ និងបារាយណ៍

នយោបាយសេដ្ឋកិច្ច និងវប្បធម៌ដ៏សំខាន់របស់ខ្មែរនាសម័យអង្គរ គឺការកសាងប្រាសាទ និងបារាយណ៍ដែលជារចនាសម្ព័ន្ធមានលក្ខណៈចំណុះគ្នាទៅវិញទៅមក ដែលប្រៀបប្រដូចទៅនឹងតម្រូវការព្រះអាទិត្យ និងព្រះចន្ទរបស់មនុស្សអញ្ចឹងដែរ។

ប្រាសាទមិនត្រឹមតែមាននាទីជាកន្លែងតម្កល់ទេវរូប ឬបដិមាជាទីសក្ការះសម្រាប់គោរពបូជាប៉ុណ្ណោះទេ ប៉ុន្តែជាកន្លែងមជ្ឈមណ្ឌលវប្បធម៌ និងសាសនាដ៏សំខាន់របស់ខ្មែរ។ ព្រោះថា ខ្មែរត្រូវការគោរព បន់ស្រន់ បួងសួងសូមសេចក្តីសុខពីអាទិទេពដែលខ្លួនគោរព។ នៅក្នុងសហគមន៍នីមួយៗ តែងតែមានប្រាសាទជាមជ្ឈមណ្ឌលសម្រាប់ការប្រមូលផ្តុំគ្នាប្រារព្ធធ្វើពិធីបុណ្យប្រពៃណីជាតិផ្សេងៗ និងជាកន្លែងផ្តល់នូវពត៌មាន ចំណេះដឹងដល់

[42] Cf., Inscription of Basak in the former Rumduol province K.71, stanza IV. George Coedès, 1942. *Inscriptions du Cambodge,* vol. II, EFEO, Hanoi, p. 60.

មនុស្សគ្រប់វ័យ ជួនកាលប្រាសាទត្រូវអមដោយអាស្រម ដែលជាសាលារៀន និងជារោងជាងសម្រាប់អប់រំ និងបណ្ដុះបណ្ដាលយុវវ័យផងដែរ។

ចំណែកបារាយណ៍ មានទំហំធំឬតូចអាស្រ័យទៅតាមធនធានរបស់សហគមន៍ និងស្ថាបនិកផ្ទាល់។ ម្ល៉ោះហើយ ប្រាសាទនីមួយៗ ជួនកាលគេជីកជាគូរទឹកព័ទ្ធជុំវិញក្នុងទ្រង់ទ្រាយតូច ហើយជួនកាលទៀតគូរទឹកនោះឯងក៏មានទំហំធំ ហើយសម្រាប់ប្រាសាទធំៗ ទោះបីជាធ្វើនៅលើភ្នំក្ដី គេតែងតែជីកជាស្រះធំមួយ(ទន្លេ)នៅក្បែរប្រាសាទដែលស្រះធំបែបនេះ គេច្រើនហៅថា បារាយណ៍នេះឯង។ ក្នុងចំណោមបារាយណ៍នៃប្រាសាទធំៗជាច្រើន ដែលបានបន្សល់ពីសម័យអង្គរ មានមួយនៅក្បែរទីរួមខេត្តកំពង់ចាម ដែលអ្នកស្រុកនៅចាំឈ្មោះដើមរបស់វា ដោយអ្នកស្រុកហៅស្រះធំនោះថា "ទន្លេអុំ"ដែលត្រូវបារាំងបង្ហោកសម្រាប់ធ្វើវាលវង់ប្រណាំងសេះ។ បារាយណ៍ ឬគូរទឹកនៃប្រាសាទជារចនាសម្ព័ន្ធមិនអាចខ្វះមួយណាបាន បើតាមទ្រឹស្ដីលោកធាតុនៃព្រហ្មណ៍សាសនា។ ព្រោះទ្រឹស្ដីនេះបានកំណត់ថា សាកលលោកទាំងមូល ហ៊ុំព័ទ្ធដោយមហាសមុទ្រ។ ម្ល៉ោះហើយការកសាងប្រាសាទត្រូវធ្វើឱ្យដូចគ្នានឹងនិមិត្តរូបលោកធាតុនេះឯង ដោយប្រាសាទជាទីបពិសិដ្ឋដែលជាទីលំនៅរបស់អាទិទេព ត្រូវតែព័ទ្ធជុំវិញដោយទឹកសមុទ្រដូច្នោះដែរ។ ក៏ប៉ុន្តែគូរទឹក ឬក៏បារាយណ៍មានមុខងារសំខាន់ណាស់សម្រាប់បម្រើជីវភាពរបស់ប្រាសាទ និងមនុស្សនៅក្នុងសហគមន៍ជុំវិញប្រាសាទ។ ព្រោះថា មនុស្ស និងសត្វមានជីវិតទាំងអស់ សុទ្ធសឹងតែត្រូវការទឹកសម្រាប់ផឹក និងប្រើប្រាស់។ ទឹកដែលដក់នៅក្នុងគូរទឹករបស់ប្រាសាទ កាន់តែមានតំលៃខ្លាំងនៅពេលរាំងស្ងួត ឬនៅរដូវប្រាំង។ ចំណែកបារាយណ៍ធំៗវិញ ក្លាយទៅជានយោបាយទឹកដ៏សំខាន់សម្រាប់កសិកម្មទាំងនៅរដូវប្រាំង និងនៅរដូវវស្សា។ ដូចជា បារាយណ៍ទឹកថ្លា, បារាយណ៍ឥន្ទ្រតដាក, បារាយណ៍យសោធរតដាក, ស្រះស្រង់, បារាយណ៍រហាល(នៅកោះកេរ្ដិ៍), បារាយណ៍លក្ស្មីន្ទ្រតដាក(ទឹកឆា), គូរទឹកប្រាសាទបាគង អង្គរវត្ត និងប្រាសាទនានានៅតំបន់រលួសខេត្តសៀមរាប ជាដើម។

ហេតុដូច្នេះហើយ បានជា សម័យអង្គរ ចុងសតវត្សរ៍ទី១២ គ្រាន់តែខ្ញុំបម្រើប្រាសាទព្រះខ័នមានចំនួន៣០៦៣៧២នាក់ក្នុងនោះរួមមានជនជាតិចាម, យួន, មនបាហ្គន និងមនលពបុរី ដែលត្រូវរស់នៅក្នុង១៣៥០០ភូមិដើម្បីធ្វើស្រែយកផលស្រូវចំនួន៤០០១២៦ខារី ឬ ៣៨២២៦,៤៤តោនក្នុងមួយឆ្នាំមកថ្វាយប្រាសាទ។ ហើយតាមការស្រាវជ្រាវថ្មីៗនេះថា នៅទីក្រុងអង្គរ អាចមានមនុស្សជាង១លាននាក់រស់នៅកាលពីសម័យនោះ។ នោះប្រហែលមិនមែនជាការបំផ្លើសឡើយ ព្រោះលោក ជីវ តាក្វាន់(១២៩៦) បានកត់ត្រាថា ប្រទេសខ្មែរនៅពេលនោះ"អាចធ្វើស្រែបានពីបីទៅបួនដងក្នុងមួយឆ្នាំ"។ បើគ្មានជោគជ័យក្នុងនយោបាយកសិកម្មទេ ទីក្រុងនេះមិនអាចមានទំហំប៉ុណ្ណោះ និងមានជីវិតដល់ទៅជាង៥០០ឆ្នាំនោះដែរ។

## 10. **បណ្ដាញគមនាគមន៍, សង្គមកិច្ច, អប់រំ**

ផ្លូវគមនាគមន៍ខ្មែរនាសម័យបុរាណ មាន៥ខ្សែ ដែលតភ្ជាប់ពីរាជធានីអង្គរទៅកាន់បណ្ដាខេត្តនានាបូករួមទាំងស្ពានថ្មបាយក្រៀម ដែលជាតម្រុយផ្លូវទាំងនោះ។ នៅសម័យអាណានិគមបារាំង ៗបានគិតថាផ្លូវទាំងនោះ សម្រាប់ទំនាក់ទំនងពាណិជ្ជកម្ម។ តើដូចបារាំងបានគិត ឬក៏ផ្លូវនោះគ្រាន់តែជាមធ្យោបាយសម្រាប់ត្រួតត្រាពលទ័ពរបស់អាណាចក្រខ្មែរសម័យនោះទេ? លោក ប្រ៊ុយណូ ប្រ៊ូគីយេ (Bruno Bruguier) វាយតម្លៃដោយគិតទៅលើបរិបទសង្គមដែលមាន"សង្គ្រាមជាអចិន្ត្រៃយ៍" ការប៉ាន់ស្មានថាផ្លូវទាំងនោះបម្រើផលប្រយោជន៍ឱ្យផ្នែកយោធា។ លោកបានពន្យល់ថា៖ "ជាការពិតណាស់ដែលថាព្រះមហាក្សត្រសម័យនោះ តំណាងឱ្យព្រះរាជាដែលមានចិត្តសណ្ដោសមេត្តាករុណា។ ប៉ុន្តែតាមពិតពុំមែនដូច្នេះឡើយ។ ព្រះមហាក្សត្រពង្រីកអំណាចគ្របដណ្ដប់នៅគ្រប់ទីកន្លែង ដើម្បី

ជានាឱ្យមានឯកភាពក្នុងការដឹកនាំអាណាចក្រដ៏ធំធេង។ លើសពីនេះទៅទៀត បើទោះបីគេស្គាល់ពុំបានស៊ីជម្រៅអំពីសេដ្ឋកិច្ចសម័យនោះក៏ពិតមែន តែការដឹកជញ្ជូនទំនិញតាមផ្លូវគោកមិនសូវសំខាន់ទេ ហើយប្រហែលជាគេចូលចិត្តធ្វើការដឹកជញ្ជូនតាមផ្លូវទឹកជាង"។

លោក ប្រ៊ុយណូ ប្រ៊ូគីយេ បានបញ្ជាក់បន្ថែមនៅក្នុងទស្សនាវដ្តីរបស់EFEOថា ស្ពានថ្មខ្មែរបុរាណ បានពីជាតុផ្សំផ្នែកស្ថាបត្យកម្ម និងជាពិសេសសភាពដូចគ្នានៃស្ពានផ្សេងៗនៅក្នុងអាណាចក្រកម្ពុជា។ លោកបានសរសេរថា៖ "ស្ពានថ្ម គឺជាស្ថាបត្យកម្មរួមមួយដែលមានភាពគួរឱ្យកត់សម្គាល់ ហើយកម្រមានស្ថាបត្យកម្មខ្មែរណាផ្សេងទៀតប្រដូចបានណាស់។ ដូច្នេះ គេគួរតែចោទជាសំណួរពីកម្មវត្ថុ និងការបង្កើតគម្រោងមួយដែលឈានទៅរកការរៀបចំការដ្ឋានស្ពានជាច្រើន ដែលនៅរាយជុំវិញអង្គរ ដោយយកគំរូតាមគ្នាបេះបិទពីមួយទៅមួយ"។

មូលដ្ឋានទី២ ដែលឱ្យគេធ្វើសេចក្តីសន្និដ្ឋាន ចំពោះតួនាទីផ្នែកយោធារបស់ស្ពានទាំងនោះ គឺវត្តមានស្ពានក្នុងបដិមាសាស្ត្រសម័យនោះ។ រូបចម្លាក់ក្រលោតទាបមួយ នៅប្រាសាទបាយ័ន ក៏ដូចជានៅប្រាសាទបន្ទាយឆ្មារបង្ហាញពីកងទ័ពកំពុងតែដើរឆ្លងកាត់ស្ពាន។ លោក ប្រ៊ុយណូ ប្រ៊ូគីយេយល់ថា តួនាទីនៃស្ពានគឺ"អនុញ្ញាតឱ្យកងទ័ពដ៏មានអានុភាព(វត្តមានសត្វដំរីអាចបញ្ជាក់បានយ៉ាងច្បាស់) ធ្វើដំណើរបំលាស់ទីប្រកបដោយប្រសិទ្ធភាព"។ លោកបានបន្តទៀតថា "នៅគ្រប់សម័យកាល រូបចម្លាក់ក្រលោតទាបនៅតាមជញ្ជាំងប្រាសាទអង្គរវត្ត បាយ័ន និងបន្ទាយឆ្មារ មិនត្រឹមតែបង្ហាញយើងពីរូបកងទ័ព ដែលមានវត្តមាននៅគ្រប់ទីកន្លែង ពិសេសទ័ពថ្មើរជើង ដែលមានសម្ភារៈចម្បាំងយ៉ាងសម្បូរបែប និងភាគច្រើនមានក្បួនរទេះពីក្រោយសម្រាប់ផ្គត់ផ្គង់ស្បៀង ហើយដែលគេអាចសន្និដ្ឋានថា ទ័ពទាំងនេះអាចចល័តបានគ្រប់រដូវកាល។ ការកសាងស្ពាននៅតាមតំបន់ជាយក្រុងអង្គរ ទំនងជាលទ្ធផលនៃគម្រោងមួយដែលត្រូវបានគេត្រិះរិះ ដើម្បីបង្កើតឡើង ហើយស្ពានថ្មទាំងនោះត្រូវបានសាងសង់ឡើង ដើម្បីជំនួសស្ពានឈើចាស់ៗដែលត្រូវបានដុតបំផ្លាញក្នុងពេលទ័ពចាមចូលកាន់កាប់អង្គរនៅឆ្នាំ១១៧៧ និងក្នុងគោលបំណងបង្កើតខ្សែក្រវាត់ការពាររាជធានី។ លោក ប្រ៊ូគីយេ សន្និដ្ឋានថា ទីក្រុងជាច្រើនបានងើបឡើងជាបន្តបន្ទាប់នៅតាមបណ្តោយផ្លូវនីមួយៗ ហើយបរិវេណជុំវិញស្ពានអាចជាបន្ទាយទាហានដែលស្ថិតនៅជាយក្រុងអង្គរ ស្នាមផ្លូវទាំងនោះមិនដឹងជាតម្រង់ឆ្ពោះទៅទីណាឱ្យប្រាកដទេ ហើយហាក់បីដូចជាជ្រៀតចូលមកក្នុងទីក្រុងយ៉ាងលំបាក លើសពីនោះគេឃើញមានកន្លែងស្តុកទឹកនៅជិត ឬទីតាំងបិតជិតព័ទ្ធជុំវិញដោយស្រះទឹកដូចជាបន្ទាយស្រះជាដើម។ ទាំងនេះនាំឱ្យយើងគិតថា សំណង់ស្ពានទាំងនោះប្រាសចាកពីក្របខ័ណ្ឌនៃប្រតិបត្តិការផ្សព្វផ្សាយមនោគមវិជ្ជានៅអង្គរ ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័ទី៧ ដើម្បីបម្រើឱ្យយុទ្ធសាស្ត្រគ្រប់គ្រងយោធាក្នុងអាណាខេត្ត រួមមានសំណង់អាគារមន្ទីរពេទ្យ រូបសំណាកព្រះមហាក្សត្រ ជំរំទ័ពជាដើម។

នៅសតវត្សរ៍ទី១៩ គេបានដឹងពីសារៈសំខាន់នៃបណ្តាញគមនាគមន៍ ក្នុងការវិវឌ្ឍន៍ប្រទេសមួយ។ អ្នករុករកជាតិបរទេស បានជួបប្រទះប្រាសាទធំៗដែលធ្វើឱ្យពួកគេមានការភ្ញាក់ផ្អើល រួមទាំងបណ្តាញផ្លូវគមនាគមន៍ខ្វាត់ខ្វែង ដែលសបញ្ជាក់ពីសក្តានុពលដ៏ធំធេងរបស់កម្ពុជា ក្នុងវិស័យសេដ្ឋកិច្ចឈានមុខគេក្នុងតំបន់។ វិសាលភាពនៃបណ្តាញគមនាគមន៍ គឺជាតឹកតាងមួយបញ្ជាក់ពីកិត្តិស័ព្ទដ៏ល្បីរន្ទឺរបស់អាណាចក្រខ្មែរសម័យបុរាណ។

ទាក់ទងនឹងបញ្ហាសង្គមកិច្ច, តាមរយៈសិលាចារឹកជាច្រើនបានឱ្យដឹងថា ព្រះរាជាខ្មែរនៅជំនាន់អង្គរ ខិតខំកសាងផ្ទះសំណាក់ ឬសាលាឆទាននៅតាមបណ្តោយផ្លូវសំខាន់ៗខាងលើ ដើម្បីបម្រើសេចក្តីត្រូវការស្នាក់នៅជាបណ្តោះអាសន្នរបស់អ្នកដំណើរ ។ ប្រភពសិលាចារឹក(រាជ្យព្រះបាទយសោវរ្ម័នទី១)បានឱ្យដឹងថា ព្រះអង្គបានកសាងសាលាសំណាក់នៅតាមបណ្តោយផ្លូវសំខាន់ៗក្នុងផ្ទៃប្រទេស យ៉ាងហោចណាស់ចំនួន១០២ ហើយរហូត

មកដល់រាជព្រះបាទជយវម៌្មទី៧ ក៏បានបញ្ជាក់អំពីសាលាសំណាក់របស់ព្រះអង្គនៅតាមបណ្តោយផ្លូវសំខាន់ៗនោះមានចំនួនដល់ទៅ១២១សាលា។ លើសនេះទៀតព្រះអង្គបានកសាងអរោគសាលា(មន្ទីរពេទ្យបុរាណ)នៅពាសពេញផ្ទៃនៃអាណាចក្រ។ តាមរយៈសិលាចារឹកសាយហ្វុង ដែលគេរកឃើញនៅជិតវៀងច័ន្ទប្រទេសឡាវ បានឱ្យដឹងថា ក្នុងមន្ទីរពេទ្យនីមួយៗ មានគ្រូពេទ្យជំនាញ ពីរនាក់ជាអ្នកទទួលខុសត្រូវ និងឧបការី ប្រមាណបួននាក់ ជាមួយនឹងការផ្គត់ផ្គង់ស្បៀងនិងថ្នាំបុរាណយ៉ាងច្រើនសន្ធឹកសន្ធាប់សម្រាប់បម្រើសេចក្តីត្រូវការក្នុងអរោគសាលានីមួយៗ។ ប្រជាពលរដ្ឋគ្រប់ឋានៈសង្គមទាំងអស់ ត្រូវបានអនុញ្ញាតឱ្យចូលទៅទទួលការព្យាបាលដោយមិនរើសអើង។ ដោយសារសមិទ្ធិផលដ៏អស្ចារ្យនេះ ធ្វើឱ្យអ្នកប្រវត្តិសាស្ត្រមួយចំនួនទាញសេចក្តីសន្និដ្ឋានយ៉ាងផ្តេសផ្តាសថា ព្រះបាទជយវម៌្មទី៧ ជាស្តេចគំលង់។ ព្រោះគេយល់ច្រឡំ បដិមា និមរាជ ដែលស្ថិតនៅលើទីលានស្តេចគំលង់ នៅទិសឦសានព្រះបរមរាជវាំងអង្គរធំថា ជារូបបដិមា តំណាងព្រះអង្គផ្ទាល់។ តាមពិតរូបនោះជារូបយមរាជដែលគេតែងតែដាក់ប្រតិស្ឋាននៅលើទីលានវាលព្រះមេរុ ឬឈាបនដ្ឋានសម្រាប់ដុតសពព្រះរាជវង្សានុវង្ស។

បើតាមកំណត់ហេតុរបស់ជីវ តាក្វាន់ដែលបានមកដល់អង្គរនៅឆ្នាំ១២៩៦ បានកត់ត្រាអំពីបញ្ហាផ្សេងៗនៅក្នុងសង្គមខ្មែរពេលនោះថា នៅពេលក្មេងស្រីស្ថិតក្នុងអាយុចន្លោះ១១-១៤ឆ្នាំ ត្រូវធ្វើពិធីសំខាន់មួយ ដែលតម្រូវឱ្យចូលទៅក្នុងបុស្បុកបិទជិតមួយ ដោយគេនិមន្តព្រះសង្ឃមួយអង្គចូលទៅអង្គុយមុនចាំនៅក្នុងនោះរួចជាស្រេច។ នោះជាពិធីចម្លងវ័យម្យ៉ាងសម្រាប់កូនស្រី បើមិនបានធ្វើពិធីនេះទេកូនស្រីមិនអាចត្រូវរៀបឱ្យមានគូស្រករបានទេទៅថ្ងៃក្រោយ។ ជីវតាក្វាន់ បានព្រលយពាក្យតាមពួកចិនដែលមកស្រុកខ្មែរមុនគាត់ថា ប្រហែលក្មេងស្រីទាំងនោះ ត្រូវបញ្ជូនចូលទៅឱ្យលោកសង្ឃរួមរ័ក្សផង។ ប៉ុន្តែតាមពិត នោះជាប្រពៃណីមួយដែលខ្មែរ និយមធ្វើតាមឥណ្ឌា ដោយក្នុងពិធីនោះ ត្រូវនាំកូនស្រីជំទើររបស់ខ្លួនទៅឱ្យលោកសង្ឃយកចង្អុលដៃលូកចាក់ទម្លាយព្រហ្មចារីយ៍ ហើយយកឈាមដែលប្រលាក់លើចង្អុលដៃនោះមកគូសនៅត្រង់ចន្លោះចិញ្ចើមអូសឡើងទៅលើថ្ងាសឱ្យនាងនោះ ដែលជូនកាលលោកសង្ឃនោះ ត្រូវគូសទាំងនៅលើថ្ងាសម្តាយនាងនោះផងដែរ។ នេះជាប្រពៃណីដែលគេជឿថា នាងសាមីខ្លួន និងម្តាយទទួលបាននូវបុណ្យ, មង្គល និងសិរីសួស្តី។[43] ចំពោះនារីខ្មែរជាមាតាទាំងឡាយ ក្រោយពីឆ្លងទន្លេរួចបានតែប៉ុន្មានម៉ោង អាចដើរទៅមុជទឹកស្ទឹង ឬដងទឹកពីស្ទឹងបាន។ តើគេប្រើថ្នាំសង្កូវអ្វីសម្រាប់គាំពារសុខភាព និងព្យាបាលជំងឺ?

ការអប់រំ នៅសម័យអង្គរ គឺជាការអប់រំចំណេះដឹងតាមរយៈសាសនាព្រាហ្មណ៍ ឬព្រះពុទ្ធសាសនា។ ចំណេះដឹងវិទ្យាសាស្ត្រទាំងឡាយនៅជំនាន់នោះ ត្រូវពឹងផ្អែកលើទ្រឹស្តីសាសនា ឬការបកស្រាយតាមបែបទស្សនវិជ្ជាសាសនា។ ម្ល៉ោះហើយសាលារៀននៅជំនាន់នោះ គឺជា"អាស្រម"របស់ពួកព្រាហ្មណ៍ ដែលស្ថិតនៅក្នុងបរិវេណប្រាសាទតែម្តង ហើយគ្រូបង្រៀននៅពេលនោះ គឺជាព្រាហ្មណ៍ ឬជាព្រះសង្ឃពុទ្ធសាសនា តាមរយៈសិលាចារឹកបានបង្ហាញថា មានគ្រូពីរប្រភេទ៖ គឺគ្រូដែលរង់ចាំបង្រៀននៅនឹងអាស្រមផ្ទាល់ដែលគេហៅថា អធ្យាបកៈ និង គុរុ ដែលជាព្រាហ្មណ៍ ឬក៏ជាបណ្ឌិត ដែលបាននិមន្តមកពីខាងក្រៅបរិវេណប្រាសាទ។

នៅក្នុងរាជ្យព្រះបាទយសោវម៌្ម សតវត្សរ៍ទី៩ ព្រះអង្គបានបង្កើតសាកលវិទ្យាល័យបីដ៏ល្បីល្បាញដែលមានឈ្មោះថា ៖

---

[43] Jean Pièrre Drège, a paper on the Sources of Chinese Reports and Ancient History of Cambodia, presented on October 14th, 2008 at National Museum of Phnom Penh. ១៩៧៣,*កំណត់ហេតុរបស់ ជីវតាក្វាន់ អំពីប្រពៃណីនៃអ្នកស្រុកចេនឡា*, បោះពុម្ពផ្សាយលើកទី៣, បកប្រែជាភាសាខ្មែរ ដោយ លី ធាមតេង។

-ព្រាហ្មណាស្រម (សាលាសម្រាប់និស្សិតដែលមានភក្តីភាពចំពោះព្រះឥសូរ)

-វៃស្ណវាស្រម (សាលាសម្រាប់និស្សិតដែលមានភក្តីភាពចំពោះព្រះវិស្ណុ ឬក៏ព្រះនារាយណ៍)

-សៅគតាស្រម (សាលាសម្រាប់និស្សិតដែលមានភក្តីភាពចំពោះព្រះពុទ្ធសាសនាមហាយាន នៅប្រាសាទបាតជុំ ក្បែរប្រាសាទក្រវ៉ាន់)

នៅមានសាកលវិទ្យាល័យមួយទៀតឈ្មោះ សិវាស្រម ដែលកសាងដោយព្រាហ្មណ៍សិវសោម និងវាមសិវៈ ដែលជារាជគ្រូរបស់ព្រះបាទឥន្ទ្រវម៌្មទី១ និងយសោវម៌្មទី១។

ក្រៅពីអាស្រមទាំងបីនេះ មានអាស្រមជាច្រើនទៀតដែលនៅរាយពាសពេញផ្ទៃនៃព្រះរាជាណាចក្រ ពិសេស នៅទីណាដែលមានប្រាសាទបុរាណ និងវត្តព្រះពុទ្ធសាសនា។ មកដល់រាជ្យព្រះបាទជ័យវម៌្មទី៧ មានសាកលវិទ្យាល័យយ៉ាងហោចណាស់បីសំខាន់, សាកលវិទ្យាល័យជ័យស្រី(ប្រាសាទព្រះខ័ន) សាកលវិទ្យាល័យរាជវិហារ (ប្រាសាទតាព្រហ្ម), សាកលវិទ្យាល័យនគេន្ទ្រទុង្គ, នរេន្ទ្រាស្រមគ្រប់គ្រង ដោយតិលកោត្តរៈ(បើតាម អៀនហារីស ថា ឈ្មោះនេះជាមហាវិទ្យាល័យទៅវិញទេ), សៅគតាស្រម នៅប្រាសាទបាតជុំ ដែលសុទ្ធសឹងជាសាកលវិទ្យាល័យពុទ្ធសាសនា។

## 11. បទបញ្ញត្តិខ្លះ និង សញ្ញាណទស្សនវិជ្ជាខ្មែរសម័យអង្គរ

បទបញ្ញតិដែលលើកមកនិយាយនៅពេលនេះ គឺទាក់ទងទៅនឹងភស្តុតាងធម្មនុញ្ញភាពដែលព្រះរាជាបានបង្កើតឡើង ក្រៅពីច្បាប់គោលសំខាន់សម្រាប់ការដឹកនាំក្នុងស្រុក ដែលមានដូចជា ៖ ធម៌សាស្ត្រ, យថាសាស្ត្រ, វេយ្យាករណ៍ និងក្រមជាច្រើនទៀត....។

- ការបង្កើតរបៀបគ្រប់គ្រងពីរបែប គឺអាណាចក្រ និងធម្មចក្រ ដែលមានអំណាចដាច់ពីគ្នា
- ការយកគំរូវីរភាព, ភក្តីភាព និងកត្តញ្ញូភាពជាគោល តាមទ្រឹស្តីអក្សរសិល្ប៍វីរកថា, ទេវកថា និងសាសនាកថាឥណ្ឌា ជាពិសេសរឿងរាមាយណ និងមហាភារត
- ការឱ្យតម្លៃលើគំនិតច្នៃប្រឌិតមិនឈប់ឈរ។
- ការឱ្យតម្លៃលើឯកទេសភាព គ្មានអ្នកណាម្នាក់ខ្លាំងពូកែដាច់គេអ្នកឈ្នះគេគ្រប់ជំនាញបានទេ ដូចអាទិទេពក្នុងព្រហ្មញ្ញសាសនាដូច្នោះដែរ គឺអាទិទេពមួយបង្ក្រាបមួយទៀតតគ្នា។
- ស្តេច, មន្ត្រី, អ្នកមាន និងប្រជារាស្ត្រ គិតផលប្រយោជន៍សាធារណៈជាធំ, ចំណាយទ្រព្យសម្បត្តិរបស់ខ្លួនបង្កើតធម៌ ដោយមិនបានបួងសួងសុំប្រយោជន៍សម្រាប់ខ្លួនឯងផ្ទាល់ តែបែរជាអំពាវនាវឱ្យមនុស្សទូទៅជួយថែរក្សាធម៌ បើអ្នកណាជួយធ្វើឱ្យធម៌គង់វង្សរីកចម្រើន នឹងបានឡើងស្ថានសួគ៌អស់ទាំងញាតិសន្តាន ហើយបើបំផ្លាញធម៌ឱ្យវិនាសអន្តរាយ ត្រូវធ្លាក់នរកអស់ទាំងញាតិសន្តាន។
- អ្នកថែរក្សាធម៌(សមិទ្ធិផល) នឹងបានទទួលផលបុណ្យដូចអ្នកកសាងដែរ។
- សភាវៈល្អ និងអាក្រក់សុទ្ធសឹងមានគុណសម្បត្តិ ក្នុងការប្រើឱ្យបំពេញភារកិច្ចបម្រើផលប្រយោជន៍ប្រទេសបានដូចគ្នា។
- បង្កើតនិមិត្តរូបសាមគ្គីភាព និងស្រុះស្រួលគ្នា ជានាគ្នាតាមរយៈសំណង់ស្ថាបត្យកម្មប្រាសាទ ដោយការដាក់ឱ្យសត្វទេពគ្រុឌ និងនាគប្រកៀកស្មាគ្នាការពារប្រាសាទ។
- ទុក្ខរបស់ប្រជារាស្ត្រមានទំហំធំធេងជាងទុក្ខរបស់ព្រះមហាក្សត្រផ្ទាល់ព្រះអង្គ (dehanān deha rogo yanmanorogo rujattarām rāṣṭra duḥkham hi bharṛuṇān duḥkhan duḥkhan tu nātmanaḥ)

- គេចាត់ទុក អារោគ្យសាលា=សមរភូមិធំ, អ្នកជំងឺ=សមរភូមិតូច, ជំងឺ=ខ្មាំងសត្រូវឈ្លានពាន, គ្រូពេទ្យ= យុទ្ធជន, ឱសថ=អាវុធ (គ្រូពេទ្យដែលជាយុទ្ធជនត្រូវប្រើឱសថជាអាវុធ, ប្រយុទ្ធកំចាត់សត្រូវឈ្លានពានគឺជំងឺបៀតបៀន ចេញពីសមរភូមិកាយរបស់អ្នកជំងឺ នៅតាមសមរភូមិធំៗទាំងឡាយ)។

តាមរយៈសិលាចារឹកK.៤៤៤ នៅកំពង់ស្វាយនិងសិលាចារឹក K.៨៦៨នៅទួលទងចាស់ ខេត្តបន្ទាយមានជ័យ បានឱ្យដឹងថា នៅថ្ងៃដែលព្រះរាជា ជយវម៌្មទី៥ ធ្វើពិធី"ព្រហ្មយជ្ញ មហាទ្វារ"សម្ពោធការបញ្ចប់ការសិក្សាជាមួយរាជគ្រូនៅឆ្នាំ៩៧៥ ទ្រង់បានប្រកាសបង្កើត វណ្ណៈ (ក្រុមការងារជំនាញ)ពីរបន្ថែមលើវណ្ណៈចំនួនប្រាំពីរ ដែលព្រះអង្គមានក្នុងពេលនោះ។ វណ្ណៈអ្នកបួសទាំងពីរនេះ គឺខ្ទុកព្រះក្រឡាអច៌្ចនៈ និង កម្មាន្តរៈ ដែលជ្រើសរើសសមាជិក ចេញពីក្រុមគ្រួសាររបស់អ្នកជំនាន់ក្រោយនៃសន្តានសិរីកៃវល្យហើយទ្រង់បញ្ញត្តិ សម្រាប់អ្នកធ្វើការងាររាជការតទៅអនាគត ត្រូវតែរើសចេញអំពីវណ្ណៈទាំងពីរនេះ។វណ្ណៈខ្ទុកព្រះក្រឡាអាច៌្ចនៈ ត្រូវគេពន្យល់ថា ជាក្រុមអ្នកដែលមានជំនាញខាងធ្វើខ្ទុក, កំបោរ និងជាអ្នករៀបចំវណ្ណាប់នៃពិធីសម្រាប់ធ្វើសក្ការបូជានៅតាមប្រាសាទនានា។ ចំណែកកម្មាន្តរៈ ត្រូវគេពិភាក្សា ហើយចាត់ទុកជាភ្នាក់ងារខាងរៀបចំចាត់ចែងពិធីបុណ្យសពសម្រាប់រាជវង្សានុវង្ស។ ពីព្រោះថា បច្ចេកពាក្យនេះឯងមានបន្សល់នៅក្នុងសង្គមឥណ្ឌានាសតវត្សរ៍ទី១៩ សម្រាប់ហៅក្រុមអ្នកប្រកបរបរធ្វើពិធីបុណ្យខ្មោច។ នៅក្នុងសិលាចារឹកដដែលនោះ ព្រះរាជាបានដាក់បញ្ញត្តិឱ្យសមាជិកជាស្ត្រីភេទនៃក្រុមគ្រួសារដដែលនេះ មានសិទ្ធិរៀបចំ និងធ្វើបុណ្យបូជា នៅតាមប្រាសាទនានា ក្នុងករណីណាគ្រួសារនេះ មិនមានសមាជិកជាមនុស្សប្រុស។ ស្ត្រីទាំងនោះបើកាលណារៀបឱ្យមានគូស្រករលុះត្រាតែប្តីនោះឯងជាអ្នកជឿនិងគោរពចំពោះព្រះឥសូរ។ នៅមានសិលាចារឹកជាច្រើនទៀតដែលបានបញ្ជាក់អំពីបទបញ្ញាតិទាំងឡាយ ទាក់ទងការលើកលែងពន្ធអាករផ្សេងៗ ចំពោះប្រាសាទ នឹងការកំណត់ចំពោះភូមិ ស្រុក និងដីធ្លីមួយចំនួនដែលត្រូវស្ថិតនៅចំណុះ ឬមួយត្រូវថ្វាយនូវភស្តុភារជាប្រចាំចំពោះប្រាសាទ។ សិលាចារឹកខ្លះទៀតបានកត់ត្រាអំពីការសម្រេចក្តី(សាលក្រម) របស់តុលាការក្រោមការបង្គាប់បញ្ជារបស់ព្រះមហាក្សត្រក្នុងការដោះស្រាយវិបត្តិ ឬក៏ទំនាស់ដីធ្លី។

ទាក់ទងនឹងបញ្ញត្តិទស្សនវិជ្ជារបស់ខ្មែរសម័យអង្គរ ត្រូវបានឆ្លុះបញ្ចាំងតាមរយៈអក្សរសាស្ត្រស្ថាបត្យកម្ម, ក្បាច់ចម្លាក់, និងអក្សរសិល្ប៍វីរះកថា។ និយាយអំពីអក្សរសាស្ត្រ ខ្មែរបានអភិវឌ្ឍន៍ទម្រង់ដើមនៃតួអក្សរបល្លវៈ ដែលខ្មែរបានយកជាគំរូតាំងពីសតវត្សរ៍ទី៣ និង៥មកនោះ ឱ្យក្លាយជាទម្រង់អក្សរដែលមានលក្ខណៈឯករាជ្យដាច់ចេញពីទម្រង់អក្សរបល្លវៈ។ អក្សរនេះព្រះរាជាខ្មែរ យសោវម៌្មទី១ បានឱ្យនាមថា៖ "កម្វុជាក្សរ" មានន័យថា អក្សរកម្ពុជា។ ចំណែកស្ថាបត្យកម្ម ខ្មែរបានច្នៃប្រឌិតបែបផែនរចនាសម្ព័ន្ធសំណង់ ឱ្យមានលក្ខណៈវឌ្ឍនភាព ដោយប្រើប្រាស់បណ្តុំនៃបទពិសោធន៍ពីការកសាងនៅជំនាន់ចាស់ ដើម្បីច្នៃប្រឌិតបែបផែនសំណង់និម្មាបនកម្មនៅពេលបន្ទាប់មកទៀត ឱ្យមានលក្ខណៈសម្បត្តិខាងសិល្បៈ កាន់តែល្អជាងមុន ដោយមិនស្ថិតនៅក្នុងរចនាសម្ព័ន្ធច្រំដែល។ ចំពោះក្បាច់ចម្លាក់ក៏មានការអភិវឌ្ឍន៍ឱ្យកាន់តែឆើត និងពោរពេញដោយខ្លឹមសារ ដែលបង្កប់ដោយន័យត្រង់ និងន័យធៀបនៅក្នុងនោះ។ ហេតុធ្វើឱ្យអ្នកស្រាវជ្រាវខាងសិល្បៈ, ស្ថាបត្យកម្ម, និងសំណង់សិក្សាបែងចែករចនាបថសិល្បៈ ជាក្រុម និងតាមកាលសម័យ ដែលជាការមួយ ធ្វើឱ្យអ្នកសិក្សាងាយចំណាំបានអំពីអាយុកាលនៃប្រាសាទណាមួយ ដែលមិនបានទុកសិលាចារឹក ឬពត៌មានជាលាយលក្ខណ៍អក្សរឱ្យគេបានដឹង។ ទាំងនេះ ជាសញ្ញាណនៃទស្សនវិជ្ជារបស់ជនជាតិខ្មែរដែលព្យាយាមកំណត់ និងអភិវឌ្ឍន៍អត្តសញ្ញាណកម្មសម្រាប់ប្រជាជាតិខ្លួនឯង ដោយមិនព្រមទទួលយកនូវធម្មនុញ្ញរបស់បរទេសទាំងដុលយកមកដាក់ និងធ្វើជារបស់ខ្លួន។

តាមរយៈក្បាច់ចម្លាក់រូបភាពដ៏សំខាន់នៅតាមជញ្ជាំងរោងទង នៃប្រាសាទអង្គរវត្ត និងបាយ័នបានបង្ហាញនូវទស្សនវិជ្ជាពីរប្រភេទ ដែលខ្មែរនៅសម័យអង្គរមាន និងជាមូលធម៌នៃសង្គមខ្មែរនៃសម័យអង្គរ។ នៅអង្គរវត្ត មាន

ចម្លាក់រឿងអក្សរសិល្ប៍ទេវកថា ចំនួនពីរដែលសំខាន់គឺរឿង រាមាយណៈ និងរឿងមហាភារតៈ លើសពីនោះទៀត មានឆាកប្រជែងគ្នា រវាងយក្ស និងទេវតា ដើម្បីកូរសមុទ្រទឹកដោះ យកទឹកអម្រឹត។ តាមរយៈរឿងរាមាយណៈដែលសម័យក្រោយយើងហៅថារឿងរាមកេរ្តិ៍ បង្ហាញឱ្យយើងដឹងយ៉ាងហោចណាស់អំពីវិធី នៃការដោះស្រាយជម្លោះ ដណ្តើមរាជ្យសម្បត្តិគ្នារបស់រាជ្យវង្សានុវង្សដោយសន្តិវិធី ដូចគំរូនៃការលះបង់រាជ្យសម្បត្តិរបស់ព្រះរាម និងតំលៃនៃសភាវៈល្អ និងសភាវៈអាក្រក់ ដែលតែងតែកើតមានចំពោះចិត្តគំនិតរបស់មនុស្សម្នាក់ៗ។ រឿងមហាភារតៈ បង្ហាញឱ្យឃើញអំពីភាពក្លៀវក្លារបស់តួអង្គយុវក្សត្រនៅក្នុងតួនាទីជាអ្នកប្រយុទ្ធ, វាតទី និងការការពារទឹកដី ដើម្បីជាគំរូដល់ក្សត្រាទាំងឡាយនៅជំនាន់អង្គរ។ ចំពោះឆាកកូរសមុទ្រទឹកដោះ បង្ហាញអំពីការប្រជែងគ្នារបស់មនុស្សល្អ និងមនុស្សអាក្រក់ដែលមានគោលដៅដូចគ្នាមួយ គឺយកទឹកអំម្រឹត ដែលនឹងផុះចេញអំពីការងារយ៉ាងលំបាក និងប្រកបដោយក្តីព្យាយាមមួយ។ រឿងនេះមានតំលៃត្រង់ការរួមគ្នារបស់សភាវៈអាក្រក់ និងសភាវៈល្អ បង្កើតបានជាលទ្ធផលវិជ្ជមានមួយ ដែលជាការឆ្លុះបញ្ចាំងពីការអាស្រ័យគ្នាទៅវិញទៅមករវាងមនុស្សល្អ និងមនុស្សអាក្រក់នៅក្នុងសង្គមមនុស្សពិត ហើយនិងតម្រូវការប្រើប្រាស់ឱកាសរបស់អ្នកដឹកនាំប្រទេស ក្នុងការទាញយកផលប្រយោជន៍ពីមនុស្សទាំងពីរប្រភេទ។

រីឯក្បាច់ចម្លាក់ផ្ទាំងរូបភាពនៅលើជញ្ជាំងថែវ នៃប្រាសាទបាយ័ន ឆ្លុះបញ្ចាំងឱ្យឃើញពីការឱ្យតំលៃទៅលើជីវភាពរស់នៅយ៉ាងសាមញ្ញរបស់អ្នកស្រុក និងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រពិត ដូចជាសង្គ្រាមជាមួយប្រទេសចាម្ប និងការរំលឹកអំពីវត្តមាននៃប្រាសាទសំខាន់ៗនានា នៅក្នុងផ្ទៃព្រះរាជាណាចក្រកម្ពុជា។ ចំពោះស្ថាបត្យកម្មប្រាសាទនោះវិញ បង្ហាញឱ្យឃើញនូវនយោបាយសមាហរណកម្មប្រជាជាតិ ដែលមានទំនាស់បដិវាទ ខាងទ្រឹស្តីសាសនាឱ្យស្រុះស្រួល ជានានឹងគ្នាជាដរាប។ តាមរយៈតួប៉មដែលមានមុខបួន ញញឹមបែរទៅគ្រប់ទិសទាំងបួន ត្រូវបានបញ្ជាក់នៅក្នុងសិលាចារឹកប្រាសាទជ្រុង នៅពេលដំណាលគ្នានឹងការសាងសង់នោះថា ជាតំណាងឱ្យព្រះពោធិសត្វលោកេស្វរៈ។ ប៉ុន្តែការអះអាងនេះ ពិតជាមិនទាន់គ្រប់គ្រាន់ឡើយ ព្រោះពុំមែនចេញពីគំនិតផ្ទាល់របស់អ្នកបញ្ជាឱ្យស្ថាបនា គឺព្រះបាទជយវរ្ម័នទី៧។ ម្ល៉ោះហើយមានការពិភាក្សា ដែលធ្វើឡើងដោយអ្នកប្រាជ្ញបរទេសជាច្រើននាក់ថា៖ កំពូលប្រាសាទបាយ័នដែលប្រកបដោយព្រះភ័ក្ត្រញញឹមបួននេះ គឺតំណាងឱ្យ"ទុម្ពុរុ"ដែលជាទេពឥសូរ ពេលមានឫទ្ធិអំណាចខ្លាំងក្លាបំផុត។ ភស្តុតាងមួយទៀត ដែលបង្ហាញនៅក្នុងរចនាសម្ព័ន្ធនៃរចនាបថសិល្បៈបាយ័ននេះដែរ គឺការដាក់ឱ្យនៅជាមួយគ្នា និងធ្វើជាមិត្តនឹងគ្នានូវសត្វគ្រុឌ និងសត្វនាគ ដែលជាសត្វទេពពីរប្រភេទ តែងតែឈ្លោះគ្នាជានិច្ចកាល។ ហេតុដូច្នេះ ប្រាសាទនេះឯង មានអត្ថន័យឆ្លើយតប ទាំងអ្នកមានជំនឿខាងពុទ្ធសាសនា និងទាំងអ្នកមានជំនឿខាងព្រហ្មញ្ញសាសនា ឱ្យមានការយោគយល់គ្នា, ស្រុះស្រួលគ្នាក្នុងសង្គមជីវភាពជាក់ស្តែង។

## 12. ការប្រជែងខាងសាសនា និងការផ្លាស់ប្តូរ

នាសម័យអង្គរ ព្រះរាជាណាចក្រខ្មែរដែលជាមហានគរ ប្រកបដោយវប្បធម៌ដ៏មហារុងរឿងថ្កើងថ្កានអស្ចារ្យ។ ប៉ុន្តែក្រោយពីព្រះមហាក្សត្រខ្មែរព្រះបាទ ជយវរ្ម័នទី៧សោយទិវង្គត នគរខ្មែរត្រូវទទួលរងនូវវិនាសកម្មគ្រប់បែបយ៉ាង។ ការវិភាគផ្នែកស្ថាបត្យកម្មបានឱ្យដឹងថា ភាពវិនាសនេះបណ្តាលមកពីមូលហេតុពីរ គឺការវាតទីនិយមរបស់ប្រទេសសៀមដែលទើបបានបង្កើតឡើង នៅលើអាណាខេត្តនានារបស់អតីតព្រះកម្ពុជទេស នឹងការផ្លាស់ប្តូរពីសំណាក់ព្រះមហាក្សត្រខ្មែរ គឺព្រះបាទជយវរ្ម័នទី៨។ ព្រះអង្គបានប្តូរសាសនាផ្លូវការ ពីព្រះពុទ្ធសាសនាមហាយានរបស់ព្រះបាទជយវរ្ម័នទី៧ ទៅព្រហ្មញ្ញសាសនាវិញ ដែលបានធ្វើឱ្យជនជាតិខ្មែរបែកបាក់សាមគ្គីរវាងគ្នា និងគ្នា។ ក្នុងករណីនេះហើយ ដែលគេសង្កេតឃើញប្រព័ន្ធសាសនា ដែលមានពីមុនត្រូវបានផ្លាស់ប្តូរស្ទើរតែទាំងអស់។ មួយភាគធំនៃចម្លាក់នៃបុរាណដ្ឋាននានា ដែលឧទ្ទិសចំពោះព្រះពុទ្ធសាសនាត្រូវគេបំផ្លាញ ឬផ្លាស់ប្តូរទម្រង់ ពីលក្ខណៈពុទ្ធនិយមទៅព្រាហ្មណ៍និយមវិញ។ ដូចជាការផ្លាស់រូបព្រះពុទ្ធអង្គទៅជារូបព្រះសិវលិង្គ លើកលែងតែ ចម្លាក់តំណាងព្រះពោធិសត្វ

អវលោកេស្វរះចេញ ដែលមានភាពស្រដៀងនឹងលទ្ធិព្រាហ្មណ៍សាសនាផ្នែកនិមិត្តរូប ឬអត្ថន័យ។ ការដែលយើងឃើញព្រះកេសនៃព្រះពុទ្ធអង្គប្រក់នាគជាច្រើនព្រះអង្គ ត្រូវបានបំផ្លាញ។ មូលហេតុនៃការបំផ្លាញនៃព្រះពុទ្ធរូបទាំងនោះបណ្ដាលមកពីកត្តាសាសនា។ ចម្លាក់ព្រះពុទ្ធអង្គ នៅតាមប្រាសាទនានាត្រូវគេដាប់ចោល ហើយត្រូវបានជំនួសដោយសំណាកសិវលិង្គ។ រីឯព្រះពុទ្ធអង្គមួយចំនួនទៀតត្រូវគេឈូសចោលតែម្ដង។

តាមការសង្កេតលើលក្ខណៈនៃការខូចខាតរបស់ប្រាសាទ ពិសេសចម្លាក់ប្រាសាទនាគព័ន្ធ និងប្រាសាទដទៃទៀត បានបង្ហាញឱ្យឃើញថា ប្រទេសកម្ពុជាបានទទួលនូវការផ្លាស់ប្ដូរសាសនាក្នុងរយៈពេលដ៏ខ្លី នាសតវត្សរ៍ទី១៣នៃគ្រឹស្តសករាជ។ ក៏ប៉ុន្តែទង្វើនេះ ពុំបានទទួលនៅជោគជ័យជាស្ថាពរឡើយ។ ព្រហ្មណ៍សាសនានៅសម័យក្រោយអង្គរ ឈប់ក្លាយជាសាសនារបស់រដ្ឋដូចសម័យមុនៗទៀត។

ព្រះបាទស្រីន្ទ្រវម៌្ម បានប្ដូរសាសនាផ្លូវការម្ដងទៀតទៅពុទ្ធសាសនាថេរវាទ ដូចឃើញក្នុងសិលាចារឹកK.៧៥៤ ឆ្នាំ១៣០៩ ហើយនាមព្រះអង្គ គេឃើញមាននៅក្នុងប្រាសាទបន្ទាយស្រីK.៥៦៧ និងK.៥៦៨, K.៥៦៩ និងក្នុងសិលាចារឹកមង្គលាថ៌ K.៤៨៨។ សិលាចារឹកមួយផ្សេងទៀត K.៩៣០ តាមរូបរាងអក្សរចារឹកក្នុងសម័យនោះ និយាយពីការធ្វើតង្វាយដល់ព្រះពុទ្ធរូបពីរអង្គគឺវ្រះ កម្រតេងអញ ស្រីស្រីន្ទ្រសុគត និង ស្រីន្ទ្រត្រៃលោក្យមហានាថ។ សិលាចារឹក K.៧៥៤ សិលាចារឹកនេះ ចាប់ផ្ដើមដោយកាលបរិច្ឆេទស.ក(មហាសករាជ)១២៣០ និងនាមព្រះមហាក្សត្រវ្រះកម្រតេងអញ ស្រី ស្រីន្ទ្រវម៌្មទេវ ។ យើងឃើញថា គោរម្យងារព្រះមហាក្សត្រពុំប្ដូរតាមការផ្លាស់ប្ដូរសាសនាទេ។ សិលាចារឹករបស់ព្រះបាទស្រីន្ទ្រវម៌្ម ដែលផ្ដើមជាភាសាបាលី១០គាថា ដោយបន្តភាសាខ្មែរចំនួន៣១ជួរ ផ្នែកភាសាបាលីផ្ដើមដោយសំដែងការគោរពចំពោះព្រះពុទ្ធ(ជីនៈ) ធម្ម និងសង្ឃ។ បន្ទាប់មកនិយាយថា នៅឆ្នាំ១២៩៦ មានព្រះមហាក្សត្រមួយអង្គព្រះនាម**សិរិសិរិន្ទវម៌្ម**(ឈ្មោះជាភាសាបាលីរបស់ព្រះបាទស្រីស្រីន្ទ្រវម៌្ម)សោយរាជ្យនៅយសោធរបុរៈ។ នៅឆ្នាំ១២៣០ ស្ដេចអង្គនេះបានប្រទានភូមិ សិរិសិរិន្ទរតនគាម ឱ្យដល់មហាថេរ សិរិសិរិន្ទមោលិ។ ក្រោយមកទៀតនៅ១២៣១ ព្រះពុទ្ធបដិមាមួយអង្គទៀត ត្រូវបានស្ថាបនាឡើង ដោយមានថ្វាយអ្នកថែទាំទាំងប្រុសទាំងស្រី។ ទាំងនេះ បង្ហាញឱ្យឃើញថា នៅសម័យក្រោយៗមកពុទ្ធសាសនាត្រូវបានមហាក្សត្ររាប់រកឡើងវិញ។

## 13. សង្គ្រាមវាតទឹកដី និងសង្គ្រាមជាមួយប្រទេសជិតខាង

គោលការណ៍របស់ព្រះរាជានៅសម័យអង្គរ ដែលជាអ្នកកាន់ និងគោរពព្រហ្មណ៍សាសនានោះត្រូវតែប្រកាន់តួនាទីជាមហាក្សត្រសឹក ដែលចាំបាច់ត្រូវតែធ្វើសង្គ្រាមវាតទីទឹកដី ជាជាងការរង់ចាំឱ្យសត្រូវឈ្លានពានហើយទើបនាំទ័ពទៅទប់ទល់ជាក្រោយ។ អញ្ចឹងហើយទើបនៅសម័យអង្គរ ព្រះមហាក្សត្រខ្មែរបានវាតទីទឹកដីបានយ៉ាងធំធេងលាតសន្ធឹងលើវិសាលភាពមួយភាគធំនៃតំបន់អាស៊ីអាគ្នេយ៍ ។

### 13.1. សង្គ្រាមជាមួយចាម្ប

តាមសិលាចារឹកខ្មែរ និង កំណត់ឯកសារប្រវត្តិសាស្ត្រចិនជំនាន់ដើម យើងកត់សំគាល់ឃើញថាប្រទេសខ្មែរតែងតែជួបប្រទះសង្គ្រាមតទល់ជាមួយចាម្ប៉ា ជាញឹកញាប់។ ពីព្រោះនៅអាស៊ីអាគ្នេយ៍ក្នុងសម័យនោះកម្លាំង ឬជាតិសាសន៍ដែលប្រឈមមុខគ្នា មានតែខ្មែរ និងចាមប៉ុណ្ណោះ។ សង្គ្រាមនោះជាសង្គ្រាមវាតទឹកដី វាតអំណាច វាតឥទ្ធិពល ដែលនាំមកនូវផលអាក្រក់មហន្តរាយយ៉ាងធ្ងន់ធ្ងរបំផុតដល់ជោគវាសនាចាម្ប។

ជនជាតិចាម មានដើមកំណើតចេញមកពីអំបូរម៉ាឡាយូ-ប៉ូលីនេស្យាន ឬអូស្រូនេស្យាន ដែលក្រុមភាសាធំក្នុងអំបូរនេះ ជាបន្ថែម រួមមានជនជាតិជ្វា, ម៉ាឡេ, ហ្វីលីពីន, កោះម៉ាដាហ្គាស្កា និងប៉ូឡេនេស៊ី ដែលរស់នៅក្នុងភូមិភាគប្រទេសម៉ាឡេស៊ី និងឥណ្ឌូនេស៊ីបច្ចុប្បន្ននេះ។

នៅដើមសតវត្សរ៍ទី១នៃគ្រិស្តសករាជ ជនជាតិចាម ដែលមានឈ្មោះល្បីល្បាញ ជាអ្នកប៉ិនប្រសប់ខាងធ្វើដំណើរតាមសមុទ្រ បាននាំគ្នាមកកាន់កាប់ទឹកដីចន្លោះជួរភ្នំអាណ្ណាម និងសមុទ្រ។ ព្រំប្រទល់ខាងជើង ជាប់នឹងទឹកដីខេត្តចិន តុងកឹង និងខាងត្បូងជាប់និងទឹកដីខ្មែរកម្ពុជាក្រោម។ គឺជាច្រកទឹកដីមួយចង្អៀត ដោយមានរបាំងធម្មជាតិ(ជួរភ្នំអាណ្ណាម)ឃាំងជាប់ទៅនិងទិសខាងលិច និងខាងកើតសមុទ្រចិន។

ក្នុងសតវត្សរ៍ទី២ នៃគ្រិស្តសករាជ ជនជាតិចាម្ប បានរៀបចំទឹកដីនេះឱ្យក្លាយជានគរមួយមានឈ្មោះ នគរចាម្ប។ នៅខាងជើងនោះ មាននគរមួយទៀត ដែលអ្នកដំណើរចិន ដាក់ឈ្មោះហៅថា លីន យី។ កាលមុនបណ្ដាអ្នកប្រាជ្ញល្បីៗជនជាតិបារាំងបានអះអាងខ្វែងគំនិតគ្នាជាពីរ ដោយម្ខាងថា លីនយីជាទឹកដីរបស់ចាម្បមួយក្រុម ហើយម្ខាងទៀតថា លីនយីជាទឹកដីរបស់ពួកមន-ខ្មែរមួយក្រុមទៅវិញ ដែលចិនធ្លាប់បានកត់ត្រានៅលើកដំបូងបំផុតក្នុងទសវត្សរ៍១៩០ ថា បានធ្វើសង្គ្រាមវាយប្រហារខ្លួន ដែលទំនងជាការវាយប្រហារទៅលើយួន-យ៉ាវជីរបស់ចិន។ ជាដំបូងនៅក្នុងប្រវត្តិសាស្ត្ររបស់ខ្លួន នគរចាម្ប បានទទួលឥទ្ធិពល អំពីប្រទេសឥណ្ឌា ហើយគោរពបូជាព្រាហ្មណ៍សាសនា។ ព្រះមហាក្សត្រចាម្បទាំងប៉ុន្មានតែងតែប្រកាសតាំងខ្លួនថា ចុះមកពីព្រះសិវៈ ឬព្រះឥសូរ។

ដោយលក្ខណៈភូមិសាស្ត្រ និងកំណើនប្រជាជន ប្រទេសចាម្បត្រូវតែវាតទឹកដី។ ពីសតវត្សរ៍ទី៣ និងសតវត្សរ៍ទី៤នៃគ្រិស្តសករាជ ចាម្បបានពង្រឹងកម្លាំងវាយលុកដណ្ដើមយកខេត្តតុងកឹង។ តែសង្គ្រាមនេះ ហាក់ដូចជាមិននាំមកនូវជោគជ័យដល់នគរចាម្បទេ។ ជនជាតិយួនបានវាយតបតចាម្បវិញ ធ្វើឱ្យចាម្បដកថយ រើរាជធានីពីឥន្ទ្របុរះ(វៀតណាមបច្ចុប្បន្ន ត្រង់ចំណុចចាគីវខាងលិចមីសឺន) ចុះមកតាំងទីនៅបាណ្ឌុរង្គ(បច្ចុប្បន្ន ទីក្រុងវៀតណាមផាន់រ៉ាង)។ ក្រោយមក ចាម្បត្រូវលើកមកនៅកៅថារៈ(ញ៉ាចាង)។ ដោយមានសង្គ្រាមជាមួយជ្វាផង ជាមួយចិនផងដែលត្រួតត្រានៅតុងកឹង ដែលបានធ្លាប់ដាក់នគរចាម្បជាចំណុះ ស្ថិតក្នុងកាលៈទេសៈនេះ នាំឱ្យនគរចាម្បរកផ្លូវធ្វើដំណើរចុះមកក្រោមវាតទីមកខាងត្បូងសំដៅមកកម្ពុជា។ ដំបូងការចុះតម្រង់ចូលមកទឹកដីខ្មែរ គ្មានលក្ខណៈជាការវាយប្រហារ ឬជាសង្គ្រាមទេ។ ចាប់តាំងពីនៅពាក់កណ្ដាលទី២នៃសតវត្សរ៍ទី៨ ចាម្បទំនងជាចាប់ផ្ដើមវាតអំណាចរបស់ខ្លួនមកលើផ្នែកខាងកើតនៃទឹកដីរបស់ខ្មែរ។ ចាប់ពីពេលនោះមក សង្គ្រាមខ្មែរចាម្បតែងតែកើតមានឡើងជារឿយៗ សង្គ្រាមនេះឯងកាន់តែរីកធំឡើងជាលំដាប់រហូតដល់ឆ្នាំ១១៧៧។

សង្គ្រាមរវាងខ្មែរ ចាម្ប មានកម្រិតយ៉ាងធ្ងន់ធ្ងរក្លាយជាសង្គ្រាម ទ័ពខ្មែរក្រោមការដឹកនាំរបស់មហាក្សត្រ ព្រះបាទឥន្ទ្រវរ្ម័ទី១ បានវាយរុញច្រានកំចាត់កងទ័ពចាម្ប រហូតចូលលុកដល់នគរចាម្ប ហើយដណ្ដើមយកបានរាជធានីកៅថារៈ។ សិលាចារឹកចាម្បបានចារឹករឿងនេះ ថាកងទ័ពខ្មែរបានលួចយករូបព្រះបដិមាព្រះនាងភគវតី ដែលធ្វើអំពីមាស។ នៅក្នុងរាជ្យរបស់ព្រះបាទហស៌វរ្ម័ទី៣ សិលាចារឹកចាមមួយអះអាងថា ពួកគេបានវាយលុកកម្ពុជា និងដណ្ដើមយកបានសម្ភុបុរៈ នៅឆ្នាំ១០៧៥។ នៅរជ្ជកាលព្រះបាទ សូរ្យវរ្ម័ទី២ ចាម្បបានបញ្ជូនកងទ័ពមករាតត្បាត លុកលុយ និងកាន់កាប់ត្រួតត្រាដែនដីខ្មែរ នៅដីសណ្ដទន្លេមេគង្គ។ ក្រោយពីព្រះបាទសូរ្យវរ្ម័ទី២ ពង្រឹងអំណាច និងរៀបចំទឹកដីឱ្យមានឯកភាពរួចស្រេចហើយ ព្រះអង្គក៏ចាប់ផ្ដើមបើកការវាយប្រហារដេញកំចាត់ទ័ពចាម្បចេញពីនគរ។ គ្រិស្តសករាជ ១១២៣ ព្រះអង្គដេញកងទ័ពចាម្បរហូតដល់ស្រុកយួន ដោយយួនគាំទ្រចាម្ប ព្រះអង្គបានលើកទ័ពទៅច្បាំងនឹងយួនទៀត។

នៅគ.ស.១១៣១ ដោយយល់ឃើញថា យួនជាសត្រូវមួយដ៏ធំ ដែលអាចនាំមកផលអាក្រក់គ្រប់បែបយ៉ាងដល់កម្ពុជា ព្រះអង្គក៏សម្រេចចិត្តលើកទ័ពវាយយួនម្តងទៀតឱ្យចប់។ ស្តេចចាម្បឈ្មោះ ជយឥន្ទ្រវម៌្មទី៣ បានធ្វើជាសម្ព័ន្ធមិត្ត នាំកងទ័ពរួមកម្លាំងនឹងទ័ពខ្មែរ ទៅវាយប្រយុទ្ធនឹងយួន។ ទ័ពខ្មែរ-ចាម្បពុំបានទទួលជ័យជំនះលើយួនទេ។ គ្រិស្តសករាជ១១៣៦ ទ័ពចាម្បដែលជួយវាយខ្មែរ ពុំបានស្មោះត្រង់ ក៏ទៅចុះចូលនឹងកងទ័ពយួន ពេលនោះ ព្រះបាទសូរ្យវម៌្មទី២ បានសម្រេចវាយនគរចាម្បឱ្យបាក់ស្បាត ហើយយកបញ្ចូលក្នុងខេត្តខ័ណ្ឌខ្មែរ។ ក្នុងគ្រិស្តសករាជ១១៤៥ ព្រះអង្គលើកទ័ពដ៏សម្បើមអស្ចារ្យទៅវាយនគរចាម្ប។ រាជធានីចាម្បវិជ័យ ក៏ត្រូវធ្លាក់ក្នុងកណ្តាប់ដៃខ្មែរ។ ទ័ពខ្មែរធ្វើការកាន់កាប់ត្រួតត្រានគរចាម្បទាំងមូល។ នគរចាម្បស្ថិតនៅជានគរចំណុះ ក្រោមការត្រួតត្រារបស់ខ្មែរអស់រយៈពេល៥ឆ្នាំ ក្រោយនោះចាម្បងើបប្រឆាំងនឹងអំណាចខ្មែរវិញ។

ការវាតទីលើផ្លូវសមុទ្ររបស់ព្រះបាទសូរ្យវម៌្មទី២ ស្របទៅនឹងទំនាក់ទំនងរវាងនយោបាយពាណិជ្ជកម្មចិន និងការរីកចម្រើន ការធ្លាក់ចុះខ្សោយ និងការប្រែប្រួលរដ្ឋនៅអាស៊ីអាគ្នេយ៍។ ប្រហែលព្រះអង្គពេលនោះ បានព្យាយាមទាញយកផលប្រយោជន៍ពីទំនាក់ទំនងពាណិជ្ជកម្មថ្មីជាមួយចិន តែភស្តុតាងបន្តិចបន្តួច ទើបយើងអាចឱ្យយើងស្នើឡើងថា ព្រះអង្គកំពុងប្រើវិធីសាស្ត្របែបរដ្ឋដែលពឹងផ្អែកលើដីកសិកម្ម គឺព្រះអង្គធ្វើការវាយឈ្លានពាន និងកាន់កាប់ដោយផ្ទាល់លើតំបន់ទាំងអស់ពីរាជធានីទៅដល់ឆ្នេរ និងប្រកចេញចូលផ្លូវសមុទ្រដែលព្រះអង្គត្រូវការ ជាងការប្រើវិធីសាស្ត្រជារដ្ឋពាណិជ្ជកម្មតែតាមសមុទ្រ ដែលក្រោយបំផុតបានទទួលជោគជ័យដោយការទិញដូរផលិតផលពីតំបន់ដាច់ស្រយាល, ដោយការធ្វើជំនួញ ឬដោយការប្រមូលពន្ធដារ រួចដឹកជញ្ជូនផលិតផលនោះតាមផ្លូវទន្លេស្ទឹង ដោយទុកចោលតំបន់ដាច់ស្រយាលជាច្រើន។ ដូច្នេះ នយោបាយវាតទីទឹកដីរបស់ព្រះបាទសូរ្យវម៌្មទី២ ឆ្ពោះទៅឆ្នេរសមុទ្រវៀតណាម–ចាម្ប ពុំទទួលបានជោគជ័យដោយសារមជ្ឈមណ្ឌលនយោបាយមួយនៅពេលនោះ ពុំអាចគ្រប់គ្រងតំបន់ធំធេងយ៉ាងនោះបានទេ។

នៅក្នុងរាជ្យព្រះបាទជយវម៌្មទី៧យោងតាមសិលាចារឹករបស់ព្រះអង្គ ដូចជាសិលាចារឹកនៅភិមានាកាស និយាយថាព្រះបាទ ជយវម៌្មទី៧ បានយាងទៅចាម្ប ប្រហែលក្នុងនាមជាអភិបាលលើចាម្ប ក្រោយពីការឈ្លានពានក្នុងរាជ្យបិតាទ្រង់ ឬក្នុងរាជ្យព្រះបាទយសោវម៌្មទី២ ប្រហែលនៅរវាងឆ្នាំ១១៦០។ ក្នុងពេលព្រះអង្គគង់នៅចាម្ប មានមនុស្សម្នាក់ដែលសិលាចារឹកហៅថា ជាអ្នកជ្រែករាជ្យនោះបានធ្វើគតព្រះបាទយសោវម៌្ម ហើយបានឡើងសោយរាជ្យដោយមានគោរម្យងារថា ត្រិភូវនាទិត្យវម៌្ម ។

ព្រះបាទ ជយវម៌្មទី៧ បានត្រឡប់មកជួយព្រះបាទ យសោវម៌្មទី២ តែយឺតពេលទៅហើយ។ បន្ទាប់ពីពេលនោះចាមបានវាយលុក និងដណ្តើមកាន់កាប់ក្រុងអង្គរក្នុងឆ្នាំ១១៧៧ និងធ្វើគត់ត្រីភូវនាទិត្យវម៌្ម។ គេពុំដឹងថាព្រះបាទជយវម៌្មទី៧ គង់នៅឯណាទេនៅពេលនោះ តែមិនយូរប៉ុន្មានព្រះបាទ ជយវម៌្មទី៧បានកំចាត់ចាមពីអង្គរ និងច្បាំងដើម្បីរួបរួមខ្មែរទាំងអស់ ពេលនោះព្រះអង្គមានជំនួយពីទ័ពចាមដែលព្រះអង្គនាំមកពីចាម្ប។ រឿងរ៉ាវនៃហេតុការណ៍នេះជាច្រើន ដឹងពីសិលាចារឹកចាម មិនមែនបានពីសិលាចារឹកកម្ពុជាដែលស្រពិចស្រពិលច្រើននៅរវាងឆ្នាំ ១១៤៥-១១៨១។ នៅកម្ពុជា គ្មានសិលាចារឹកបន្សល់ទុកទេ ពីអំឡុងឆ្នាំ១១៤៥-១១៨៦ លើកលែងK.៨៥០ ដែលប្រហែលជារបស់ព្រះបាទ ធរណីន្ទ្រវម៌្មទី២នៅភ្នំបាយ៉ង់។

ការវាតទឹកដីអង្គរទាំងទៅទិសខាងកើតនិងខាងលិចនៅតែបន្ត និងកាន់តែរីកធំឡើង ដែលជាលក្ខណៈពិសេសនៃសម័យកាលដ៏រុងរឿងនៃរាជ្យព្រះបាទ ជយវម៌្មទី៧ ។ ព្រះអង្គបានទទួលជោគជ័យទាំងស្រុងក្នុងយុទ្ធនាការត្រួតត្រាចាម្បជាថ្មី ។ នៅរាជ្យព្រះបាទជយវម៌្មទី៧ ព្រះអង្គពុំត្រឹមតែធ្វើសង្គ្រាមជាមួយចាម្បទេ ព្រះអង្គនៅបាន

ធ្វើសង្គ្រាមវាយលុកវៀតណាមទៀត។ ទាំងនេះ គឺបានរៀបរាប់ក្នុងរបាយការណ៍ចិន និងវៀតណាមថា កម្ពុជាបានវាយលុកវៀតណាម(សិលាចារឹក ហៅ យវន,យួន)ក្នុងខេត្តងេអាន (Nghe An) គឺនៅឆ្នាំ១២១៦, ១២១៨ និងក្នុងឆ្នាំ១២២០។ ក្រោយឆ្នាំ១២២០ កម្ពុជាបានដកខ្លួនពីចាម្ប(វិជ័យ) ហើយព្រះអង្គម្ចាស់ចាម ដែលចម្រើនវ័យនៅកម្ពុជាក្នុងរាជ្យព្រះបាទជយវរ្ម័នទី៧ បានឡើងជាស្តេចនៅវិជ័យ។ គួរចាប់អារម្មណ៍ថា រឿងរ៉ាវទាំងអស់ស្តីពីបញ្ហាសង្គ្រាមជាច្រើន ចារឹកទុកក្នុងសិលាចារឹកចាម្ប ប៉ុន្តែគ្មានក្នុងសិលាចារឹកនៅកម្ពុជាទេ។ ស្តេចចាម្បនៅវិជ័យនោះ ទំនងជាបានក្លាយជាស្តេចឯករាជ្យ។

### 13.2. សង្គ្រាមក្នុងស្រុករវាងខ្មែរនឹងខ្មែរ

បើតាមសិលាចារឹកទួលតាពេជ ទំនងជាមានសង្គ្រាមធំរវាងព្រះបាទឥសានវរ្ម័នទី២ និងព្រះបាទជយវរ្ម័នទី៤ ដែលសោយរាជ្យនៅឆោកគរគីរ-កោះកេរ្តិ៍។ សិលាចារឹកនៅតំបន់កោះកេរ្តិ៍ បង្ហាញថា គេបានធ្វើការស្ថាបនាប្រាសាទនៅទីក្រុងនេះចាប់តាំងពីឆ្នាំ៩២១មកម្ល៉េះ។ ប្រហែលចាប់ពីពេលនោះហើយ ដែលព្រះបាទជយវរ្ម័នទី៤ចាប់ផ្តើមពង្រឹងអំណាចរបស់ខ្លួនឡើងបន្តិចម្តងៗ។ ដូច្នេះសេចទាំងពីរ ត្រូវមានបកពួកនិងដែនដីក្រោមការគ្រប់គ្រងរៀងខ្លួន ដែលអាចម្ខាងមានដែនដីនៅភាគខាងជើងភ្នំដងរែក ម្ខាងទៀតនៅភាគខាងត្បូងអង្គរ។

ជាបន្ទាប់មកចាប់ពីរាជ្យព្រះបាទឧទយាទិត្យវរ្ម័នទី១ សង្គ្រាមក្នុងស្រុកកើតមានឡើងជារឿយៗ ជាពិសេសព្រះអង្គពិតជាបានប្រយុទ្ធដណ្តើមអំណាចពីរាជបុត្រព្រះបាទជយវរ្ម័នទី៥។ ជាបន្តប្រទេសកម្ពុជាត្រូវបែងចែកជាពីរផ្នែកដែលនៅតំបន់អង្គរគ្រប់គ្រងដោយព្រះបាទជយវីរវរ្ម័ ទំនងជាព្រះរៀមព្រះបាទឧទយាទិត្យវរ្ម័នទី១ និងនៅសម្ពុបុរៈ-ឥសានបុរៈគ្រប់គ្រងដោយព្រះបាទសូរ្យវរ្ម័នទី១។ សិលាចារឹកទួលតាពេជថា ក្រោយពីប្រយុទ្ធគ្នាអស់៩ឆ្នាំពីឆ្នាំ១០០២ដល់១០១០ ទើបព្រះបាទសូរ្យវរ្ម័នទី១សម្រេចការបង្រួមបង្រួមប្រទេសតែមួយឯកភាពឡើងវិញរហូតដល់យ៉ាងហោចលពបុរី និងពាក់កណ្តាលជ្រោយម៉ាឡេស៊ីដែរ។ សិលាចារឹកមួយផ្សេងទៀតនៅជើងព្រៃ K.92 រៀបរាប់អំពីមេទ័ពរបស់ព្រះបាទសូរ្យវរ្ម័នទី១បង្ក្រាបជនបះបោរឈ្មោះ អជុំន(អរជុន)នៅខាងត្បូង។ គួរចាប់អារម្មណ៍ព្រោះគោរម្យងារ" អរជុន" នៅសម័យកាលយូរក្រោយមកទៀត គឺជាស្តេចត្រាញ់នៅត្បូងឃ្មុំ។ សិលាចារឹកព្រះងោក K. 289 នាគ.ស. ១០៦៦ នៅជិតប្រាសាទបាពួនក្នុងរាជ្យព្រះបាទឧទយាទិត្យវរ្ម័នទី២ បង្ហាញពីការបះបោរធំៗបីដងប្រឆាំងព្រះមហាក្សត្រអង្គនេះ។ សិលាចារឹកនេះ ចារដោយមន្ត្រីល្បីឈ្មោះម្នាក់ឈ្មោះ សង្គ្រាម ដែលបានបង្ក្រាបជនបះបោរប្រឆាំងព្រះមហាក្សត្រទាំងបីលើកនោះ។

មិនយូរប៉ុន្មាន ស្តេចត្រាញ់នៅមហីធរបុរៈភាគខាងជើងភ្នំដងរែកបានផ្តាច់ខ្លួនពីអង្គរ ប្រកាសឯករាជ្យតាំងខ្លួនជាព្រះបាទជយវរ្ម័នទី៦ នៅឆ្នាំ១០៧៦ ហើយធ្វើសង្គ្រាមប្រឆាំងស្តេចនៅអង្គរអស់ប្រមាណ៣០ឆ្នាំ ចាប់ពីរាជ្យព្រះបាទហស៌វរ្ម័នទី៣ ដល់នរបតីន្ទ្រវរ្ម័ ទើបអាចបង្កើតឯកភាពទឹកដីខ្មែរឡើងវិញបាន នៅមុនពេលព្រះបាទជយវរ្ម័នទី៦ សោយទិវង្គតប្រហែល១ឆ្នាំ។

ចំណែកព្រះបាទសូរ្យវរ្ម័នទី២ បានចារសិលាចារឹកបញ្ជាក់ថា ព្រះអង្គបានបង្រួបបង្រួមអាណាចក្រ(ខ្មែរ)ពីរដែលមួយព្រះអង្គដណ្តើមពីព្រះបាទធរណីន្ទ្រវរ្ម័នទី១ និងមួយទៀត ទំនងជាមានមូលដ្ឋានរាជធានីនៅល្វោ-លពបុរីដូចដែលគេឃើញរូបមេទ័ពខេត្តក្រៅនៅល្វោ នៅក្នុងរូបចម្លាក់ត្រួតពលរបស់ព្រះបាទសូរ្យវរ្ម័នទី២ នៅភ្នំសិវបាទ មានទ្រង់គ្រឿងឥស្សរិយយសធំជាងព្រះមហាក្សត្រទៅទៀត(បាំងក្លស់ចំនួន១៧ នៅពេលព្រះបាទសូរ្យវរ្ម័នទី២បាំងក្លស់១៥ប៉ុណ្ណោះ)។

ក្នុងរាជ្យព្រះបាទសូរ្យវម៌្មទី២ បានបង្ហាញតឹកតាងច្បាស់លាស់មួយចំនួនពីចំណាប់អារម្មណ៍ទៅលើពាណិជ្ជកម្ម និងការវាតទីលើវិស័យនេះ។ ក្រោយពីកាត់ផ្តាច់អស់ប៉ុន្មានរាជវង្សមក ព្រះអង្គបានចាប់ផ្តើមទំនាក់ទំនងពាណិជ្ជកម្មនេះឡើងវិញ ដោយបានបញ្ជូនទូតពីអង្គរឱ្យទៅកាន់ប្រទេសចិននៅឆ្នាំ១១១៦ និង១១២០។ ព្រះអង្គក៏បានព្យាយាមធ្វើសង្គ្រាមឈ្លានពានយួនជាច្រើនដង និងបានជោគជ័យ ដោយបានយកទឹកដីចាម្បដាក់ឱ្យនៅក្រោមអំណាច។ សម័យនោះចាម្បស្ថិតនៅតំបន់ដែលបច្ចុប្បន្នជាប្រទេសវៀតណាមកណ្តាល និងខាងត្បូង។ ជាការពិតតំបន់ទាំងពីរនេះ គឺជាច្រកចេញចូលផ្លូវសមុទ្រយ៉ាងសំខាន់។ គួរឱ្យស្តាយដែលកំណត់ហេតុសិលាចារឹកអង្គរ ពុំបានចារឹកឱ្យយើងបានដឹងអំពីព្រឹត្តិការណ៍សំខាន់ៗនេះទេ។

មកដល់រាជ្យព្រះបាទជយវម៌្មទី៨ ដែលមានស្រុកកំណើតនៅខេត្តល្វៅ ភាគខាងកើតទន្លេមេគង្គ នៅលវោទ័យបានផ្តាច់ខ្លួន។ ទំនងមកពីព្រះអង្គមិនជាប់ញាតិជាមួយព្រះបាទជយវម៌្មទី៧ ដែលមានអ្នកជំនាន់ក្រោយគឺព្រះអង្គម្ចាស់នរបតីន្ទ្រវម៌្ម គ្រប់គ្រងនៅទីនោះតាំងពីចុងសតវត្សរ៍ទី១២មកបើតាមសិលាចារឹកកិមានាកាស K. 485។ ដោយសារការរីកចម្រើនសេដ្ឋកិច្ចនៅតំបន់នេះផ្សេងពីអង្គរ នៅរវាងឆ្នាំ១២៩៥ ពួកនេះត្រូវគេស្គាល់ថាជា សៀន ឬ សៀម បើតាមកំណត់ត្រារបស់លោកជីវតាក្វាន់ ថាពួកនេះបានព្យាយាមវាយយកអង្គរនៅមុនពេលគាត់មកដល់។ នេះគឺជាការវាយប្រហារ ដើម្បីធ្វើការបង្រួបបង្រួមអាណាចក្រខ្មែរតែមួយឡើងវិញ។

### 13.3. សង្គ្រាមជាមួយសៀម ឬអយុធ្យា

បើតាមជីវតាក្វាន់ ដែលបានមកដល់អង្គរនៅឆ្នាំ១២៩៦ បានឱ្យដឹងថា ពួកសៀន-សៀមទើបតែបានវាយប្រហារលើរាជធានីអង្គរកន្លងទៅថ្មីៗ ទើបធ្វើឱ្យព្រះមហាក្សត្រខ្មែរពេលនោះ មានការប្រយ័ត្នប្រយែងដូចនៅលើសមរភូមិដែរ នៅពេលណាព្រះអង្គយាងព្រះរាជដំណើរចេញក្រៅទីក្រុង។

បើតាមប្រភពពង្សាតារខ្មែរ ជាច្រើនច្បាប់ ដែលសិក្សាដោយសាស្ត្រាចារ្យបណ្ឌិត ឃឹន សុខ និងម៉ាក់ ភឹន ព្រឹត្តិការណ៍នៃការលុកលុយទីក្រុងអង្គរដោយពួកអយុធ្យា មានយ៉ាងហោចណាស់២លើកដែរ នៅរវាងចាប់ពីពាក់កណ្តាលសតវត្សរ៍ទី១៤ដល់ពាក់កណ្តាលទី១នៃសតវត្សរ៍ទី១៥។ នៅអំឡុងឆ្នាំ១៣៥៣-៥៧ អង្គរត្រូវធ្លាក់ក្នុងដៃអយុធ្យា ក្រោមរជ្ជកាលស្តេចលំពង់រាជា ហើយក្រោយមកទើបត្រូវរំដោះបានវិញដោយស្តេចស្រីសុរិយោវង្ស។ បន្ទាប់មកទៀត នៅក្នុងរជ្ជកាលស្តេចស្រីធម្មាសោក ទីក្រុងអង្គរត្រូវអយុធ្យាវាយដណ្តើមយកកាន់កាប់ម្តងទៀត ក្នុងរយៈពេលខ្លីប្រមាណមួយ ឬពីរឆ្នាំប៉ុណ្ណោះ។ ដោយសត្រាខ្លះថា នៅអំឡុងទសវត្សរ៍ឆ្នាំ១៣៨០ និងខ្លះទៀតថា នៅអំឡុងទសវត្សរ៍ឆ្នាំ១៣២០។ ហើយលើកនេះ អ្នកដែលមានស្នាដៃក្នុងការរំដោះចេញពីការត្រួតត្រារបស់អយុធ្យា គឺព្រះបាទពញាយ៉ាត។ បើតាមលោកវ៉លធ័រ យល់ថា នៅសតវត្សរ៍ទី១៤សៀម បានវាយអង្គរតែម្តងគត់ ប្រហែលនៅឆ្នាំ១៣៨៩ នៅពេលស្តេចខ្មែរតាំងរាជធានីនៅបាសាន។ ក្រោយពីស្តេចខ្មែរឈ្នះសង្គ្រាមហើយនោះ ទើបព្រះអង្គតាំងរាជធានីនៅអង្គរឡើងវិញ ដូចដែលរាជទូតចិនមកគាល់ស្តេចខ្មែរនៅអង្គរ នាឆ្នាំ១៤០៥ក្នុងរាជ្យស្តេចថ្មីព្រះនាម សម្តេចព្រះចៅពិងយ៉ា។[44]

ប៉ុន្តែលោក ម៉ៃឃើល វិកឃើរី បានអះអាងថា រឿងរ៉ាវទាំងអស់អំពីសង្គ្រាមជាមួយសៀមនៅសតវត្សរ៍ទី១៤-១៥សុទ្ធសឹងមានកាលបរិច្ឆេទខុស។ រឿងរ៉ាអំពីសង្គ្រាមទាំងនោះ បានវិវត្តន៍ពីរឿងចាស់មួយ អំពីសង្គ្រាមពិតមួយ នៅ

[44] Cf., Oliver Wolters, 1966. "The Khmer King at Basan (1371-3) and the Restoration of the Cambodian Chronology during the Fourteenth and Fifteenth Centuries." in *Asia Major*, ed. by W. Simon, volumer XII, Lund Humphries, London, pp. 46-52. (pp. 44-89).

ពេលដែលអយុធ្យាដណ្តើមបានអង្គរក្នុងឆ្នាំ១៤៣១ និងកាន់កាប់អស់រយៈកាល១៥ឆ្នាំ រហូតដល់ឆ្នាំ១៤៤៥។ ក្រោយមកពីព្រះបាទពញាយ៉ាត បានវាយបណ្តេញកងទ័ពអាយុធ្យាពីអង្គរ និងបានកសាងអាណាចក្រកម្ពុជាជាថ្មីឡើងវិញ ដោយផ្លាស់រាជធានីមកភ្នំពេញ។

ហេតុអ្វីបានជាពង្សាវតារដែលមានការបរិច្ឆេទ និងរឿងរ៉ាវមិនពិតទាំងនោះកើតមានឡើង? លោកវិកឃើរី បានសន្និដ្ឋានចំពោះរឿងនេះថា គឺក្រោយពីរាជធានីបានប្តូរពីអង្គរមកភ្នំពេញ នៅក្រោយរជ្ជកាលស្តេចពញាយ៉ាត កម្ពុជាមិនបានសរសេរពង្សាវតាររបស់ខ្លួនទេ រហូតដល់ពាក់កណ្តាលសតវត្សរ៍ទី១៨។ ក្រោយមក ពួកគេបានសរសេរពង្សាវតារមួយ ដោយចាប់ផ្តើមពីស្តេចដែលដឹកនាំនៅលង្វែក គឺផ្តើមពីស្តេចអង្គចន្ទ។ នៅសម័យមុនព្រះអង្គ គេគ្មានកំណត់ហេតុចាស់ៗណាមួយទេ។ ពង្សាវតារនោះ ពុំមាននៅសល់ដល់សព្វថ្ងៃដែរ។ ប៉ុន្តែផ្នែកខ្លះនៃរឿងរ៉ាវទាំងនោះ ឃើញមានក្នុងពង្សាវតារផ្សេងៗទៀតនៅសតវត្សរ៍ទី១៩។

សម័យកាលក្រោយមក ដោយសារកម្ពុជានៅសតវត្សរ៍ទី១៨ និងទី១៩ស្ថិតក្រោមឥទ្ធិពលថៃយ៉ាងខ្លាំងនោះ កម្ពុជាបានសម្រេចថា ពួកគេគួរតែមានពង្សាវតាររបស់ខ្លួន ដែលចាប់ផ្តើមក្នុងពេលប្រហាក់ប្រហែលនឹងពង្សាវតារនៅអយុធ្យា។ ពង្សាវតារអយុធ្យា បានចាប់ផ្តើមរឿងរ៉ាវរបស់គេពីការស្ថាបនាទីក្រុងអយុធ្យានៅឆ្នាំ១៣៥០-៥១ ទើបធ្វើឱ្យកម្ពុជា មានបំណងចាប់ផ្តើមពង្សាវតារថ្មីរបស់ខ្លួនពីពេលនោះ។ ប៉ុន្តែនៅពេលនោះ គ្មានកំណត់ហេតុចាស់ៗណាមួយ ដែលអាចយកមកធ្វើជាបង្អែកបាន ទើបត្រូវពួកគេកែច្នៃជារឿងឡើង។ រឿងមួយចំនួនដូចជារឿងរបស់ព្រះបាទនិព្វានបទ គេបានដាក់បំពេញដោយយករឿងពីប្រវត្តិសាស្ត្រកម្ពុជាសម័យក្រោយ ឯរឿងរ៉ាវមួយចំនួនផ្សេងទៀតខ្ចីពីកន្លែងផ្សេង។

ចំពោះកាលបរិច្ឆេទពិតនៃព្រឹត្តិការណ៍នៅសតវត្សរ៍ទី១៥ បើតាមការសន្និដ្ឋានរបស់លោក វិកឃើរី ថា ដំបូងគេយោងលើមូលដ្ឋានឯកសារដែលនៅសេសសល់បន្តិចបន្តួច និងដែលពុំអាចឱ្យដឹងបានអ្វីទាល់តែសោះអំពីព្រឹត្តិការណ៍ក្នុងប្រទេសកម្ពុជាមុនសង្គ្រាមឆ្នាំ១៤៣២។ ក្រោយព្រឹត្តិការណ៍នៃការវាយលុករាជធានីអង្គរដោយអយុធ្យានោះ ទើបមានកាលបរិច្ឆេទពិតមួយចំនួន ដូចខាងក្រោម ៖

សង្គ្រាមរវាងអយុធ្យា និងអង្គរនៅរវាងឆ្នាំ១៣៥១-១៣៥៧ ដែលអះអាងដោយពង្សាវតារខ្មែរ គឺមិនអាចជាការពិតទេ។ ព្រោះនៅអំឡុងពេលនោះ ព្រះបាទជយវរ្ម័នទី៩ កំពុងសោយរាជ្យនៅអង្គរធំយ៉ាងសុខសាន្ត ហើយថែមទាំងបានជួយជ្រោមជ្រែងបុត្រសុណិសាព្រះអង្គ ព្រះនាម ហ្វាង៉ុមឱ្យបង្រួបបង្រួមទឹកដីឡាវបានសម្រេច ហើយដាក់ឈ្មោះជា ឡានសាង ដែលភាសាខ្មែរសម័យកណ្តាលហៅថា លានជាង (គឺដំរីរាប់លាន)ទៀតផង នៅរវាងឆ្នាំ១៣៥៣។ បន្ទាប់មក ព្រះបាទជយវរ្ម័នទី៩ បានបញ្ជូនគណៈប្រតិភូផ្សាយពុទ្ធសាសនាទៅផ្សព្វផ្សាយធម៌ព្រះពុទ្ធនៅប្រទេសឡាវ ព្រមជាមួយជំនួនគម្ពីរព្រះត្រៃបិដក និងព្រះពុទ្ធរូបមាសហៅ[2]ព្រះបង ឬព្រះបាង[3] ចំពោះព្រះរាជបុត្រី ព្រះអង្គនាម កែវកន្យា ដែលជាអគ្គមហេសី ព្រះចៅ ហ្វាង៉ុម តាមការស្នើរបស់ក្សត្រទាំងពីរអង្គនេះ។ តាមការអះអាងរបស់ពង្សាវតារឡាវបែបនេះ ឃើញថានៅអំឡុងពេលនោះគ្មានចម្បាំងឈ្លានពានរបស់អយុធ្យានៅអង្គរនោះទេ។ ជាងនេះទៀត ពង្សាវតារអយុធ្យាវិញ បានអះអាងថា ស្តេចរបស់ខ្លួនបានរើរាជធានីពីលវោទ័យមកកសាងនៅអយុធ្យា នាអំឡុងឆ្នាំ១៣៥១ដែរ។ ដូច្នេះ កាន់តែច្បាស់ថា ស្តេចសៀម-អយុធ្យា មិនអាចលើកទ័ពមកច្បាំងជាមួយអង្គរក្នុងពេលខ្លួនកំពុងកសាងរាជធានីនោះទេ។

ការឈ្លានពានពីសំណាក់អយុធ្យា និងការកាន់កាប់អង្គរ ១៤៣១-១៤៤៥ ហើយអយុធ្យាពេលនោះ គឺជារាជវង្សខ្មែរមួយក្រុមទៀត ដែលគ្រប់គ្រងទឹកដីភាគជើងភ្នំដងរែក ដោយបោះមូលដ្ឋាននៅលវោទ័យ ឬល្វោ ដែល

ត្រូវនឹងតំបន់លពបុរីរបស់ថៃសព្វថ្ងៃ។ ដូច្នេះ សង្គ្រាមពេលនោះអាចនិយាយបានថា ជាសង្គ្រាមបង្រួបបង្រួមប្រទេសកម្ពុជាឡើងវិញ ដូចកាលពីចុងសតវត្សរ៍ទី១១ដើមទី១២ដែរ។

ពញាយ៉ាតដណ្តើមយកបានក្រុងអង្គរ ប៉ុន្តែបានផ្លាស់រាជធានីមកភ្នំពេញវិញចាប់ពីឆ្នាំ១៤៤៥....? (ទីបញ្ចប់សម័យព្រះបាទពញាយ៉ាត ពុំច្បាស់)។

សង្គ្រាមរវាងខ្មែរ-ថៃពិតប្រាកដ គឺនៅចុងសម័យលង្វែក១៥៨៧-៩៤ ព្រោះរាជវង្សខ្មែរចាស់នៅអយុធ្យាត្រូវបំផ្លាញដោយស្តេចរាជវង្សហង្សាវតីរបស់ភូមានៅឆ្នាំ១៥៦៩ ហើយតុរង្វាន់ចំពោះអ្នកជួយជ្រោមជ្រែងក្នុងចម្បាំងនេះ ព្រះមហាក្សត្រភូមា បានលើកព្រះអង្គម្ចាស់ធម្មរាជា ដែលជារាជវង្សថៃមកពីសុខោទ័យ ឱ្យឡើងសោយរាជ្យនៅអយុធ្យាជាជំនួសរាជវង្សខ្មែរចាស់នោះវិញ។ ដូច្នេះអយុធ្យាខ្មែរ បានក្លាយទៅជាអយុធ្យាថៃ ចាប់ពីពេលនោះមក។

## សេចក្តីសន្និដ្ឋាន

ចុងសម័យអង្គរដែលចាប់រាប់ពីរាជព្រះបាទជយវរ្ម័ទី៩មក គ្មានពត៌មានសហសម័យណាមួយបង្ហាញពីការធ្លាក់ចុះឡើយ។ ការគោរពពុទ្ធសាសនាថេរវាទ មិនចាំបាច់តម្រូវឱ្យមានការកសាងប្រាសាទធំៗ ទំនប់ទឹកធំៗទៀតតែប៉ុណ្ណោះ។ កត្តាគ្មានសំណង់ធំៗ, កត្តាសង្គ្រាមជាច្រើនលើកច្រើនគ្រាជាមួយចាម្ប និងរវាងខ្មែរគ្នាឯង ហើយចុងក្រោយគឺជាមួយខ្មែរអយុធ្យា មិនមែនជាសូចនាករបង្ហាញពីការធ្លាក់ចុះនៃសម័យអង្គរនោះទេ។ ការធ្វើសង្គ្រាមជាមួយចាម្បយ៉ាងយូរអង្វែង បានធ្វើឱ្យកម្ពុជាលែងរវងការគំរាមកំហែងខាងសន្តិសុខនយោបាយពីប្រទេសនេះចាប់ពីក្រោយឆ្នាំ១២២០មក។ ប្រទេសនេះយកចិត្តទុកដាក់តែការពង្រឹងពង្រីកអំណាចទៅលើប្រទេសវៀតណាមប៉ុណ្ណោះនៅសតវត្សរ៍ទី១៤-១៥។ ការបែកជាពីរនៃរាជាអាណាចក្រខ្មែរសម័យអង្គរ ហើយបន្តវាយប្រយុទ្ធបង្រួបបង្រួមគ្នាដូចពេលមុនៗនោះ ជាកត្តាអាចធ្វើឱ្យខ្មែរបាត់កម្លាំងឯកភាពដ៏រឹងមាំមួយមែន ប៉ុន្តែមិនពិតថា ខ្មែរអយុធ្យាបានធ្វើឱ្យអង្គរធ្លាក់ចុះដោយផ្ទាល់នោះទេ។ ព្រោះការរីកចម្រើនរបស់រាជធានីនីមួយៗតែងមានចំណងទាក់ទងជាមួយមូលដ្ឋានបង្អែកសេដ្ឋកិច្ចច្បាស់លាស់។ ដូច្នេះ ការធ្លាក់ចុះនៃទីក្រុងអង្គរបណ្តាលមកពីបុព្វហេតុការប្រែប្រួលនៃសក្តានុពលសេដ្ឋកិច្ចជាចម្បង ហើយការផ្លាស់ប្តូររាជធានី ក៏ដោយសារការរត់ទៅរកទីតាំងមានសក្តានុពលសេដ្ឋកិច្ចដែរ៕

# មេរៀនទី 5   ការលើករាជធានីមកតាំងនៅចតុមុខ

## 1. ទីបញ្ចប់សម័យអង្គរ

តើទីបញ្ចប់សម័យអង្គរមានន័យយ៉ាងដូចម្តេច? មានមនុស្សមួយចំនួនគិតថា ចុងបញ្ចប់នៃសម័យកាលនេះ គឺនៅពាក់កណ្តាលសតវត្សរ៍ទី១៤ ព្រោះក្រោយនោះគ្មានប្រាសាទអស្ចារ្យណាមួយ ឬក៏សិលាចារឹកណាមួយត្រូវបានស្ថាបនា ឬចារឹកឡើងទេ រហូតដល់ពាក់កណ្តាលសតវត្សរ៍ទី១៦។ តើមានរឿងអ្វីកើតឡើងក្នុងរយៈកាលប្រមាណ ២០០ឆ្នាំនោះ? គំនិតផ្សេងទៀតយល់ថា ចុងបញ្ចប់សម័យអង្គរ គឺនៅសតវត្សរ៍ទី១៥ ព្រោះថាអង្គរនៅជាមជ្ឈមណ្ឌលនយោបាយកណ្តាល រហូតដល់ឆ្នាំ១៤៣២។

អស់រយៈកាល២០០ឆ្នាំនោះ មានប្រភពឯកសារក្នុងស្រុកតែមួយគត់គឺពង្សាវតារ ដែលសុទ្ធសឹងសរសេរឡើងនៅសតវត្សរ៍ទី១៩។ បើតាម លោកម៉ៃឃើល វិកឃើរី ថាបញ្ហាស្មុគស្មាញមាននៅក្នុងពង្សាវតារ។ តើពង្សាវតារទាំងនោះពិតដែរឬទេ? ពង្សាវតារដែលល្អ ចាស់ជាងគេសរសេរនៅឆ្នាំ១៨១៨ ដោយលោក នង ជាមន្ត្រីម្នាក់ ប៉ុន្តែយើងមិនស្គាល់តំណែងរបស់គាត់ច្បាស់ទេ ព្រោះងាររបស់គាត់ត្រូវគេលែងប្រើទៀត ហើយអ្នកនិពន្ធក្រោយៗច្រឡំគាត់ជាមួយមនុស្សម្នាក់ ឬពីរនាក់ផ្សេងទៀត ដែលមានឈ្មោះ នងដូចគ្នា។ នៅមានបំណែក ពង្សាវតារចាស់ៗពីរទៀតដែរ មួយគេហៅថា "បំណែករបស់អង្គអេង" ដែលត្រូវបានផ្ញើទៅបាងកក ក្នុងឆ្នាំ១៧៩៦ ហើយបច្ចុប្បន្ននៅមានតែអត្ថបទដែលប្រែជាភាសាថៃប៉ុណ្ណោះ គឺពង្សាវតារខ្លី ក្នុងនោះមានត្រឹមតែ ពីររជ្ជកាលស្តេច និព្វានបទ ដល់ពញាយ៉ាតប៉ុណ្ណោះ។ បំណែកពង្សាវតារមួយទៀត ដែលចាស់ជាងពង្សាវតាររបស់នង គឺ «ពង្សាវតារ១១៧០» សរសេរក្នុងទសវត្សរ៍ឆ្នាំ១៨០០ ដោយពណ៌នាលំអិតពីរាជ្យព្រះបាទ សត្ថា និងសុរិយោពម៌ នៅចុងសតវត្សរ៍ទី១៦ និងដើមសតវត្សរ៍ទី១៧។ ពង្សាវតារនេះក៏ត្រូវបានផ្ញើទៅកាន់បាងកកដែរក្នុងឆ្នាំ១៨០៨ បច្ចុប្បន្ននៅតែមានអត្ថបទដែលប្រែជាភាសាថៃប៉ុណ្ណោះ។

ពង្សាវតារដែលនៅល្អមួយទៀតសរសេរក្នុងទសវត្សរ៍ឆ្នាំ១៨៧៨ ដោយព្រះអង្គម្ចាស់នុប្បរតណ៍ ដែលប្រហែលជាបុត្រារបស់ព្រះបាទនរោត្តម។ ជាទូទៅ ព្រះអង្គបានចម្លងចេញពីពង្សាវតាររបស់ «នង» ប៉ុន្តែមានបន្ថែមពត៌មានប្លែកមួយចំនួន និងប្តូរកាលបរិច្ឆេទខ្លះ។ ពង្សាវតារមួយទៀតសរសេរក្នុងឆ្នាំ១៨៦៩ ដោយរាជបញ្ជារបស់ព្រះបាទនរោត្តម បច្ចុប្បន្នគេដឹងថា ជាពង្សាវតារវត្តកោកកាក។ កាលបរិច្ឆេទពង្សាវតារនេះ ខុសគ្នាខ្លាំងពី នង។ ពង្សាវតារដែលប្រវត្តិវិទូជាច្រើន បានចាត់ទុកជាផ្លូវការ គឺរបស់លោក ឧកញ៉ាវាំង ជួន ជាមន្ត្រីធំម្នាក់នៃរដ្ឋាភិបាល។ ពង្សាវតារនេះ សរសេរឡើងនៅវាំងឆ្នាំ១៩០៣ និង១៩៣០។ មានពង្សាវតារផ្សេងៗច្រើនទៀតផងដែរ។ ក្នុងនោះមួយសំខាន់ គេហៅជាភាសាខ្មែរថា អម្បាលក្សត្រ ដែលគ្រាន់តែបញ្ជីព្រះនាមព្រះមហាក្សត្រ និងកាលបរិច្ឆេទនៃរាជ្យស្តេចទាំងនោះប៉ុណ្ណោះ។ ប្រវត្តិវិទូបស្ចិមប្រទេសបានឱ្យឈ្មោះថា"Liste /List"។ ព្រោះអ្នកដំបូង ដែលពណ៌នាអំពីរឿងរ៉ាវពង្សាវតារនោះនៅសតវត្សរ៍ទី១៩ គឺជាជនជាតិបារាំង។

ដូច្នេះ អំពីព្រឹត្តិការណ៍នៃការបញ្ចប់សម័យអង្គរ មានលក្ខណៈស្មុគស្មាញ។ កន្លងមកធ្លាប់មានការអះអាងថាសម័យអង្គរបញ្ចប់នៅពេលព្រះបាទពញាយ៉ាត ផ្លាស់ប្តូររាជធានីចេញពីរាជធានីអង្គរធំ មកតាំងនៅតាមដងទន្លេមេគង្គវិញ។ ការពិតប្រវត្តិសាស្ត្រ គំនិតនៃបច្ចេកពាក្យ"សម័យអង្គរ" មិនមែនមានតែប៉ុណ្ណោះទេ។ ការផ្លាស់ប្តូរ

ចេញពីយុគសម័យអង្គរ ត្រូវបានគេមើលឃើញថា មានការពាក់ព័ន្ធយ៉ាងសំខាន់ជាមួយនឹងការប្រែប្រួលនៃជំនឿរបស់អ្នកដឹកនាំ និងប្រជារាស្ត្រភាគច្រើន ពីហិណ្ឌូសាសនាមកពុទ្ធសាសនាថេរវាទ។ គេមិនត្រូវបំភ្លេចរឿងដើមសំខាន់មួយ ដែលថា រាល់ប្រាសាទឥដ្ឋ និងថ្មទាំងឡាយកើតឡើងព្រោងព្រាតដោយសារ"ជំនឿសាសនារបស់មេដឹកនាំ និងប្រជាជន" ហើយវាបានក្លាយទៅជាការប្រកួតប្រជែងគ្នាខាងសំណង់ស្ថាបត្យកម្មពីរាជ្យមួយទៅរាជ្យមួយ ពីជំនាន់មួយទៅជំនាន់មួយ ដែលបង្កើតជាការអភិវឌ្ឍន៍ស្នាដៃសិល្បៈ និងនិម្មាបនកម្មដ៏ច្រើនអនេក។ នៅពេលមានការផ្លាស់មកកាន់ពុទ្ធសាសនាថេរវាទស៊ប់ ចាប់ពីរជ្ជកាលព្រះបាទស្រីន្ទ្រវរ្ម័ ទាំងអ្នកដឹកនាំ និងទាំងប្រជារាស្ត្រ ហាក់ដូចជានៅស្ងប់ស្ងៀម ស្ងប់ស្ងល់នឹងភាពគ្មានការប្រកួតប្រជែងសាងកេរ្តិ៍តទៅទៀត។ មិនត្រឹមតែប៉ុណ្ណោះ ការចារសិលាចារឹកក៏កាន់តែហោចទៅៗ រហូតដល់លែងមាននៅសតវត្សរ៍ទី១៥ និងដើមសតវត្សរ៍ទី១៦ ដែលជាហេតុធ្វើឱ្យអ្នកប្រវត្តិសាស្ត្រ មិនអាចដឹងច្បាស់អំពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រពិតប្រាកដកើតឡើងនៅអំឡុងពេលនេះ។ រឿងរ៉ាវដែលគេបានបំពេញប្រង្គប់នៅចន្លោះពេលនេះ និងបន្តរហូតដល់រជ្ជកាលមុនព្រះបាទចន្ទរាជា បើតាមលោក ម៉ៃឃើល វិកឃើរី ថា សុទ្ធសឹងត្រូវគេសរសេរឡើងនៅចុងសតវត្សរ៍ទី១៨ និងសតវត្សរ៍ទី១៩ប៉ុណ្ណោះ ហើយអំណះអំណាងទាំងនោះភាគច្រើន មានលក្ខណៈមិនពិត គ្រាន់តែជារឿងព្រេងនិទាន។ បើនិយាយដោយពឹងផ្អែកលើគោលការណ៍នយោបាយដើមនៃខ្លឹមសារសម័យអង្គរ ដែលបង្កើតឡើងដោយព្រះបាទជយវរ្ម័ទី២ សម័យអង្គរគួរតែបញ្ចប់តាំងពីរជ្ជកាលព្រះបាទជយវរ្ម័ទី៨ ចុងសតវត្សរ៍ទី១៣មកម្ល៉េះ។ ត្បិតចាប់ពីរាជ្យស្តេចអង្គនេះបានបំផ្លិចបំផ្លាញសំណង់របស់បុព្វបុរសអស់ជាច្រើន ហើយអ្នកបន្ទាប់មកទៀតមិនបានបន្តប្រើប្រាស់មនោគមវិជ្ជានយោបាយវាតទីនិយម និងស្ថាបនានិយមរបស់ស្ថាបនិកទាំងឡាយពីខាងដើមឡើយ។

## 2. ការធ្លាក់ចុះ និងការបោះបង់ចោលទីក្រុងអង្គរ

មានឯកសារតិចតួចបំផុត ដែលបាននិយាយអំពីសម័យកាលនេះ។ ការចារអក្សរលើថ្ម នៅចន្លោះសតវត្សរ៍ទី១៤ ដល់ដើមសតវត្សរ៍ទី១៦ ស្ទើរតែពុំមានឡើយ។ នៅមុនឆ្នាំ១៣០០ គេបានកត់ចំនួនសិលាចារឹកជាង១០០០ផ្ទាំង។ ឯនៅសម័យក្រោយៗមកនេះ សិលាចារឹកដែលគេប្រទះឃើញមានចំនួនមិនដល់១០០ផ្ទាំងផង។ ប្រភពឯកសារផ្សេងៗទៀត មានសិលាចារឹកចាម១ផ្ទាំង និងសិលាចារឹកខ្លះទៀតនៅប្រទេសសៀម។ នៅមានពង្សាវតារសៀមចំនួន២ច្បាប់ ដែលគេបានតែងនៅសតវត្សរ៍ទី១៧ ក្នុងនោះមាន១ច្បាប់ដែលមានតែជាផ្នែកៗ។[45]

សៀវភៅពង្សាវតារខ្មែរជាប្រពៃណីបានពន្យល់ហេតុផលថា អង្គរបានរងការវាយប្រហារពីសៀម-អយុធ្យាជាច្រើនលើក ដូចជានៅវាងឆ្នាំ១៣៥១-៧, ១៣៨០ ឬ១៣៩០ និង១៤១៩-២០ជាដើម។ ដូចយើងបានពិភាក្សាពីខាងដើម ប្រភពព័ត៌មានដែលគួរឱ្យជឿជាងគេនោះ គឺចេញពីពង្សាវតារអយុធ្យា ដែលបានអះអាងថា ការវាយប្រហារកាន់កាប់រាជធានីអង្គរដោយអយុធ្យា គឺនៅអំឡុងឆ្នាំ១៤៣១-៥៥។ គឺការវាយប្រហារនេះហើយដែលបានបង្កឱ្យរាជធានីអង្គរ មានសភាពខ្ទេចខ្ទាំខ្លាំង ដោយសារការខូចខាងហេដ្ឋារចនាសម្ព័ន្ធទីក្រុង និងប្រព័ន្ធធារាសាស្ត្រ។ មានការធ្លាក់ចុះយ៉ាងគំហុក ខាងបរិមាណគ្រឿងឧបភោគបរិភោគសម្រាប់ផ្គត់ផ្គង់ដល់ជីវភាពរាជវង្សានុវង្សខ្មែរនៅក្នុងរាជវាំង ឬក្នុងរាជធានី ដែលអាស្រ័យទៅលើការប្រមូលយកពន្ធដារ និងសួយសារអាករពីប្រជារាស្ត្រជាកសិករនៅក្នុងតំបន់ជុំវិញទីក្រុង។ ទន្ទឹមនោះដែរ ធ្វើឱ្យតំបន់រាជធានីនេះ ក្លាយជាវាលរហោឋាន ដោយសារមនុស្សភាគ

[45] ប្រហែលជាពង្សាវតារនេះអាចផ្តល់ព័ត៌មានពិតខ្លះអំពីហេតុការណ៍ដែលកើតឡើងក្នុងរយៈពេល២០០ឆ្នាំនោះ។ចំណែកឯពង្សាវតារខ្មែរដែលចែងអំពីសម័យនោះវិញ ភាគច្រើនទំនងជាគេបានចម្លងចេញពីរឿងព្រេង និងពីពង្សាវតារបុរាណរបស់សៀម ហើយខុសគ្នាពីពង្សាវតារទាំងឡាយដែលចែងអំពីព្រឹត្តិការណ៍ក្រោយឆ្នាំ១៥៥០នោះ មានការពិបាកក្នុងការប្រៀបធៀបជាមួយប្រភពដទៃទៀតណាស់។

ច្រើនស្លាប់នៅពេលមានសង្គ្រាម, អ្នកសល់ពីស្លាប់ជាពិសេសប្រជារាស្ត្រខ្មែរនៅអាណាខេត្តខាងលិច ក៏ត្រូវសៀមកៀរយកទៅអស់ជាច្រើន (នេះបើតាមសៀវភៅលោក ត្រឹង ងា១៩៧៣) និងគ្មានប្រជាជនពីតំបន់ដទៃចូលទៅរស់នៅបំពេញទីវាលនោះវិញ។

ក្រៅពីការកំទេចដោយមនុស្ស គឺភស្តុតាងនៃមហន្តរាយបង្កដោយធម្មជាតិ ដែលបានពីការស្រាវជ្រាវវិភាគតាមរូបថតពីលើអាកាស, បុរាណវិទ្យា និងជាពិសេសរុក្ខវិទ្យាបានឱ្យដឹងថា នៅសតវត្សរ៍ទី១៤ពីឆ្នាំ១៣៦០-១៣៩០ និងដើមសតវត្សរ៍ទី១៥ពីឆ្នាំ១៤០០-១៤២០ បារាយណ៍យសោធរតដាក ឬបារាយណ៍ខាងកើតដ៏ធំធេង ត្រូវរីងស្ងួតដោយសារបញ្ហាប្រែប្រួលនៃផ្លូវទឹក និងការកកស្ទះនៅតាមច្រកបណ្តាញបង្ហូរទឹកចូល។ ដូចគ្នានេះដែរ បារាយណ៍ទឹកថ្លា ឬបារាយណ៍ខាងលិច ក៏លែងមានទឹកច្រើនពេញប្រៀបដូចពេលមុនទៀតហើយ។ អ្នកស្រុកបាននាំគ្នាចូលទៅរស់នៅក្នុងពោះបារាយណ៍ទាំងពីរ ដែលមិនលិចទឹក។ ដូច្នោះ នយោបាយកសិកម្មអតិផល និងបង្កើនដង់ដាំដុះដូចលោកជីវតាក្វាន់បានបញ្ជាក់ក្នុងសតវត្សរ៍មុនៗត្រូវបរាជ័យ។ នៅដូរប្រាំង មុខជាមានការខ្វះខាតទឹកសម្រាប់ប្រើប្រាស់ក្នុងជីវភាព និងរបរកសិកម្ម។ បញ្ហាបរិស្ថាន ជាពិសេស ដីដែលគ្មានទឹកស្រោចស្រពគ្រាប់គ្រាន់ និងដីដែលធ្លាប់ប្រើប្រាស់រាប់រយឆ្នាំមកហើយនោះ អាចជួបប្រទះនឹងវិបាកនៃភាពខ្សោះជីវជាតិ។

ដូចដែលលោក ម៉ៃឃើល វិកឃើរី បានបំភ្លឺគួរឱ្យយើងជឿជាក់បាន ថាការផ្លាស់ប្តូរទីតាំងនៃមជ្ឈមណ្ឌលកណ្តាលរបស់ប្រទេសកម្ពុជានៅសតវត្សរ៍ទី១៤នោះ ប្រហែលមានជាប់ពាក់ព័ន្ធនឹងការរីកធំឡើងយ៉ាងឆាប់រហ័សនៃពាណិជ្ជកម្មតាមសមុទ្ររបស់ចិន ជាមួយអាស៊ីអាគ្នេយ៍ ជាពិសេសជាមួយប្រទេសជីគោក នៅក្នុងសម័យដែលពួកម៉ុងហ្គោលបានគ្រប់គ្រងប្រទេសចិន និងនៅដើមសម័យរាជវង្សមិង។ ខ្មែរបានបញ្ជូនបេសកទូតនាំសួយសារអាករចំនួន២១លើក ទៅកាន់រាជវាំងមិងរបស់ចិននៅចន្លោះឆ្នាំ១៣៧១ និង១៤១៩។ កំណត់ហេតុចិនបាននិយាយពីទំនាក់ទំនងជាមួយកម្ពុជា ច្រើនជាងកាលពី៥០០ឆ្នាំមុន ក្នុងសម័យអង្គរ។ បើមើលកម្ពុជានៅសម័យនោះ មានស្ថានភាពដូចសម័យហ្វូណាន។ ទោះជាយ៉ាងណាក៏ដោយ របាយការណ៍ចិនទាំងនោះ ពុំបានឱ្យយើងដឹងអ្វីទាំងអស់អំពីស្ថានការណ៍ក្នុងប្រទេសនោះទេ។ ព្រោះគេបានរៀបរាប់តែសកម្មភាពជំនួញតាមដងទន្លេមេគង្គ និងឈ្មោះព្រះរាជាមួយចំនួនដែលមិនអាចឱ្យគេរកឃើញអត្តសញ្ញាណជាភាសាខ្មែរបាន។ ហើយទោះបីជាបេសកទូតដែលបញ្ជូនទៅក្នុងទម្រង់ជាពិធីសារខ្លះតែប៉ុណ្ណោះក៏ដោយ ក៏ទំនងជាបេសកកម្មភាគច្រើន គឺដើម្បីធ្វើពាណិជ្ជកម្ម ឬដើម្បីរៀបចំទំនាក់ទំនងខាងពាណិជ្ជកម្ម ហើយក៏ប្រហែលជាក្នុងបំណងស្នើសុំជំនួយគាំទ្រពីចិន ដើម្បីប្រឆាំងនឹងការប្លន់កំទេចជារឿយៗពីសំណាក់ពួកសៀមផងដែរ។ ចំនួននៃបេសកកម្ម ព្រមទាំងការទទួលស្គាល់ពីចិនសឱ្យឃើញថា នៅគ្រានោះ ប្រទេសខ្មែរនៅតែសកម្ម និងពោរពេញដោយអំណាច ហើយប្រហែលជាសឱ្យឃើញផងដែរថា ដោយសារពួកវរជនខ្មែរបានបន្ថយការផ្តោតទៅលើសំណង់ព្រហ្មញ្ញសាសនា និងពិធីរបស់ក្រុមព្រាហ្មណ៍បុរោហិត ក៏បែរជាមានបំណងចង់ទាញយកផលប្រយោជន៍ពីជំនួញជាមួយចិនវិញ។ តែការផ្លាស់ប្តូរក្នុងគំនិត និងការអនុវត្តរបស់ពួកគេបានកើតឡើងយ៉ាងដូចម្តេច និងដោយហេតុអ្វីនោះក៏ជាការដែលពុំអាចឱ្យគេបញ្ជាក់បានឡើយ។ ប៉ុន្តែលោក ម៉ាយឃើល វិកឃើរី (Michael Vickery), លោក ក្លូត ហ្សាក់(Claude Jacques) និងលោក អូលីវ៉េ វ៉ុលធ័រ្ស (Oliver Wolters) បានគូសបញ្ជាក់ថា ការផ្លាស់ប្តូរនេះមិនគប្បីគេបកស្រាយថា ជាសញ្ញាណនៃ"ការធ្លាក់ចុះដុនដាប"ទេ។ ពីព្រោះលោក អូលីវ៉េ វ៉ុលធ័រ្ស បានកត់សម្គាល់ "ក្នុងការចាត់ទុកការដុនដាបនៃអង្គរនាសតវត្សរ៍ទី១៤ និង១៥ ថា ជាគ្រោះមហន្តរាយដ៏មហិមានោះ ជាការសន្និដ្ឋដ៏លឿនពេកហើយ"។តាមពិតពេលនោះ អ្នកគ្រប់គ្រងទឹកដីក្នុងព្រំដែនប្រទេសខ្មែរបច្ចុប្បន្ន អាចធ្វើការប្រកួតប្រជែងដណ្តើមធនធាន និងពាណិជ្ជកម្មជាមួយនឹងប្រជាជនជិតខាងដែលទើបមកដល់ថ្មីៗ ហើយដែលមានការរីកចម្រើននៅខាងលិចមហានគរ គឺក្រុងស្រីអយុធ្យាបាននៅឡើយ។ ការសិក្សាថ្មីៗ បានបង្ហាញថា តំបន់អង្គរនេះមានប្រជាជនរស់នៅយ៉ាងច្រើនកុះករ ហើយសំណង់មួយចំនួននៅអង្គរ គេក៏បានជួសជុល

នៅក្នុងគ្រានោះផងដែរ។ ខ្មែរក៏អាចញាំងចិនឱ្យជឿថា ខ្លួននៅតែមានសារៈសំខាន់ ហើយរហូតមកដល់សតវត្សរ៍ទី ១៧ ខ្មែរនៅតែអាចធ្វើសង្គ្រាមបង្ក្រាបពួកសៀមបានដដែល។

លោក វិកឃើរី (២០០១-២)បានអះអាងថា ព្រះបាទពញាយ៉ាត ប្រហែលមានស្រុកកំណើតនៅភាគខាងត្បូងជាប់មាត់ទន្លេមេគង្គ ទើបព្រះអង្គគ្មានទម្លាប់រស់នៅតំបន់អង្គរដ៏សោះកក្រោះនៅពេលនោះ។ តែពង្សាវតារ បានអះអាងថា ដោយចេះតែអែងខ្លាចសៀមចូលមកលុកលុយប្រទេសខ្មែរទៀត ម្យ៉ាងទៀតទីក្រុងនេះស្ថិតនៅប្រមាណតែ៤០០គ.ម.ពីទីក្រុងអយុធ្យាតែប៉ុណ្ណោះ ទើបព្រះបាទពញាយ៉ាតក៏បានសម្រេចព្រះទ័យ លើករាជធានីចេញឱ្យឆ្ងាយពីអង្គរ។

គឺដោយសារការផ្លាស់ប្តូរនេះកើតមានឡើង នៅក្នុងសម័យកាលមួយ ដែលសកម្មភាពរបៀបសម័យអង្គរ ដូចជាការសង់ប្រាសាទថ្ម, ការចារសិលាចារឹក ឬការជីកបារាយណ៍, ព្រៃក និងប្រឡាយបានចប់ទៅហើយ បានជាអ្នកនិពន្ធជាច្រើនតែងនិយាយអំពីការធ្លាក់ចុះដុនដាប ជាជាងនិយាយថា មានការផ្លាស់ប្តូរ។ បើនិយាយពីការចុះដុនដាបនេះ យើងពុំអាចពន្យល់អំពីអានុភាពនៃប្រទេសកម្ពុជា ដែលមានជាយូរអង្វែងទៅទៀតបានឡើយ ។

ម្យ៉ាងទៀតជាឧទាហរណ៍ ពាក្យនេះអាចធ្វើឱ្យយើងគិតថា ព្រះបាទជយវម៌្មទី៧ គឺជាព្រះមហាក្សត្រខ្មែរពិតប្រាកដជាងព្រះមហាក្សត្រខ្មែរដែលកាន់ពុទ្ធសាសនាថេរវាទ ដែលលោក ជីវ តាក្វាន់បានសង្កេតមើលក្នុងឆ្នាំ១២៩៦ នោះទៅទៀត។ អ្នកនិពន្ធខ្លះបានភ្ជាប់ការចាកចោលអង្គរទៅនឹងបរាជ័យនៃកម្លាំងជាតិ និងការបាត់បង់ចំនួនប្រជាជនដ៏ច្រើន។ ម្យ៉ាងទៀត ប្រហែលជាមុនទសវត្សរ៍ឆ្នាំ១៥៦០ ការចាកចោលអង្គរនេះ ពុំទាន់បានចាប់ផ្តើមនៅឡើយទេ។ ទឡ្ហីករណ៍នោះក៏បន្តទៀតថា ការបាត់បង់ទាំងនេះធ្វើឱ្យគេមិនអាចគ្រប់គ្រងប្រព័ន្ធជារាសាស្ត្រ(ប្រព័ន្ធបង្ហូរទឹក) នៅអង្គរបានតទៅទៀត។ ដូច្នេះទឹកក៏បានស្ទះស្អុយ ហើយក្លាយជាកន្លែងកកើតមូសដែកគោលដែលចម្លងជំងឺគ្រុនចាញ់ ម្ល៉ោះហើយក្រោយមក ធ្វើឱ្យចំនួនប្រជាជនថយចុះ។

មានអ្នកស្រាវជ្រាវផ្សេងទៀត បានលើកឡើងថា ពុទ្ធសាសនាថេរវាទ ជាដើមហេតុធ្វើឱ្យការរួបរួមគ្នា ដែលធ្លាប់មានក្នុងសម័យអង្គរបានចុះខ្សោយ ហើយនៅគ្រាដដែលនោះ សាសនាថេរវាទនេះផ្តល់កម្លាំងដល់នយោបាយនៅក្រុងស្រីអយុធ្យាក្នុងប្រទេសសៀម និងក្រុងបាហ្គានក្នុងប្រទេសភូមា ។ គេបានលើកចរិត"សុខស្ងប់"នៃសាសនាថេរវាទនេះ សម្រាប់ពន្យល់ពីបរាជ័យរបស់ប្រទេសកម្ពុជា ប៉ុន្តែគេពុំបានលើកមកសម្រាប់ពន្យល់ពីជោគជ័យរបស់សៀមដែលមានជំនឿដូចគ្នានោះឡើយ។

ទោះជាយ៉ាងណាក៏ដោយ ក៏ការជាក់ស្តែងមួយដែលប្រទេសកម្ពុជាបានចូលទៅក្នុង«សម័យកណ្តាល» ដូចដែលអ្នកស្រី អាស្លី ថមសុន(Ashley Thompson)បាននិយាយ គឺមុនការបោះបង់ចោលអង្គរមកម្ល៉េះ។ ស្ថាប័នសម័យអង្គរ ដូចជាសិលាចារឹក, ប្រាសាទថ្ម, ព្រះរាជវង្សានុវង្សដែលគោរពបូជាសាសនាព្រាហ្មណ៍ និងប្រព័ន្ធជារាសាស្ត្រជាដើម ហាក់ដូចជាជាប់គាំង......។ ជាការគិតខ្លីពេក បើយល់ថា ការផ្លាស់ប្តូរនេះ កើតចេញមកតែពីមនោគមវិជ្ជា ឬពីសាសនាថ្មីនេះ។ ទំនងជាការផ្លាស់ប្តូរនេះ អាចពាក់ព័ន្ធទៅនឹងការរីកចម្រើននៃរាជាណាចក្រកាន់សាសនាថេរវាទនៅអយុធ្យា ដែលនៅខាងលិចអង្គរ និងពាក់ព័ន្ធទៅនឹងទំនាក់ទំនងដ៏ពិបាក និងស្មុគ្រស្មាញ ដែលមានរហូតដល់ទសវត្សឆ្នាំ១៨៦០ រវាងព្រះរាជវង្សានុវង្សនៅប្រទេសកម្ពុជា និងព្រះរាជវង្សានុវង្សនៅប្រទេសសៀម។ ប្រជាជន ចិត្តគំនិត អត្ថបទ និងស្ថាប័នផ្សេងៗ បានផ្លាស់កន្លែងទៅខាងលិច ពីមហានគរ(អង្គរ)ទៅក្រុងស្រីអយុធ្យា ដែលនៅទីនោះបានកែប្រែ ហើយក្រោយមកក៏ត្រូវបាននាំត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ដើម្បីជួយប្រទេសនេះឱ្យរួចផុតពីការធ្លាក់ចុះដុនដាប ដែលចាប់ផ្តើមមានមែនទែនចាប់ពីសតវត្សរ៍ទី១៨មក។ ការផ្លាស់ស្រុករបស់ប្រជាជនទាំងនោះ

ភាគច្រើនជាឈ្លើយសង្គ្រាម និងក្រុមគ្រួសារដែលត្រូវសៀមកៀរយកទៅ ពេលគេចូលឈ្លានពានអង្គរជាបន្តបន្ទាប់ ជាពិសេសនៅឆ្នាំ១៤៣១។ ដោយសារការឈ្លានពានរបស់សៀមនៅតែមានតទៅទៀត ប្រជាជនព្រមទាំងស្ថាប័នផ្សេងៗ បានផ្លាស់ទៅភូមិភាគដែលនៅខាងត្បូងក្រុងអង្គរ គឺទៅតំបន់ភ្នំពេញ ដែលរាជធានីខ្មែរតាំងនៅរហូតដល់រយៈពេលប្រមាណ ៦០០ឆ្នាំក្រោយមក។

ទោះជាយ៉ាងណាក៏ដោយ ការធ្លាក់ចុះនៃអំណាចរបស់ខ្មែរ ដោយសារតែមានអ្នកចេះដឹងកាន់តែតិចទៅៗ។ ព្រោះពលរដ្ឋខ្មែរតាំងពីបុរាណ តែងតែផ្ដេកផ្ដួលជោគវាសនារបស់ខ្លួនទៅលើក្រុមគ្រួសារវរជន ដែលជាអ្នកកាន់អំណាច។ នៅពេលក្រុមគ្រួសារទាំងនោះជាប់រវីរវល់នឹងរឿងពាលាជាច្រើនបែប មិនបានសិក្សារៀនសូត្រឱ្យបានចេះដឹងជ្រៅជ្រះ រួមផ្សំនឹងភាពមានះរឹងត្អឹង អកិរក្សជ្រុលពេក នាំឱ្យភាពឈ្លាសវៃ និងសមត្ថភាពធ្វើរបស់ពួកគេកាន់តែខ្សោយ ជាពិសេសសម្រាប់ព្រះមហាក្សត្រភាគច្រើនដែលបានឡើងសោយរាជ្យ ក្នុងពេលមានព្រះជន្មក្មេងពេក។

## 3. ការតាំងទីក្រុងនៅទួលបាសាន-ការផ្លាស់រាជធានីទៅចតុមុខ

គួររំលឹកឡើងវិញនូវព្រឹត្តិការណ៍សំខាន់ ដែលទាក់ទងនឹងព្រះបរមរាជា ចៅពញាយ៉ាត ដោយព្រះអង្គបានទទួលរាជាភិសេកជាព្រះមហាក្សត្រនៅអង្គរក្នុងគ.ស.១៤២១ ជាមហាក្សត្រពេញលក្ខណៈ នៅគ.ស.១៤៣១។ នៅឆ្នាំ១៤៣២ ព្រះអង្គតាំងរាជធានីស្រីសន្ធរ នៅទួលបាសាន ក្រោយមកព្រះអង្គសម្រេចផ្លាស់រាជធានីទៅចតុមុខវិញ ក្នុងឆ្នាំ១៤៣៤ គឺត្រង់រាជធានីភ្នំពេញសព្វថ្ងៃនេះ ។

ទីក្រុងស្រីសន្ធរ នៅត្រង់ទួលបាសាន ជាទីក្រុងមួយថ្មីទៀតនៅចុងសម័យអង្គរ បើតាមកំណត់ត្រារបស់ចិនចាប់ពីឆ្នាំ១៣៧១ ហើយដែលសិក្សាដោយលោក វ៉ូលធ័រ។[46] តែក្នុងពង្សាវតារ យើងចាត់ទុកថា ជារាជធានីនៅសម័យក្រោយអង្គរ ដែលព្រះបាទពញាយ៉ាត បានប្រឹក្សាសម្រេចជាមួយនាម៉ឺនសព្វមុខមន្ត្រី ហើយបញ្ជាឱ្យតាំងជារាជធានីសម្រាប់ប្រទេសទាំងមូល។ រាជធានីតាំងនៅទួលបាសាន ដោយមានបូជនីយដ្ឋានស្នូលនៃរាជធានីស្ថិតនៅត្រង់ប្រាសាទព្រះធាតុបារាយណ៍សព្វថ្ងៃ។ តាមពិតទីស្ថាននេះ មានសំណង់ប្រាសាទថ្មតាំងពីសម័យអង្គរ ប្រហែលសតវត្សទី១១-១២មកម្ល៉េះ។ ដោយសារឈ្មោះរាជធានីអង្គរជាប្រពៃណី មានមនុស្សស្គាល់ទូលំទូលាយ និងល្បីសុសសាយដោយកិត្តិយស ព្រះបាទពញាយ៉ាត នៅតែប្រើនាមនេះ ដាក់ឱ្យរាជធានីថ្មីរបស់ព្រះអង្គដែរ។ ដោយសារភាសាខ្មែរពាក្យវែងបំផុត មានត្រឹមតែពីរព្យាង្គ អ្នកស្រុកមិនអាចហៅថា ស្រីយសោធរបុរី ដ៏វែងនេះបានទេ។ ដូច្នោះហើយ គាត់ហៅត្រឹមតែពាក្យមួយព្យាង្គខាងដើម និងព្យាង្គខាងចុង ទើបចេញជា ស្រីសធរ ឬ ស្រីសន្ធរ ។ ជាក់ស្ដែងនៅទីនោះមានវត្តមួយឈ្មោះវត្តស៊ីធរ រហូតដល់សព្វថ្ងៃ ហើយឈ្មោះខេត្តពីរជាប់នឹងស្រីសន្ធរនេះ គឺស៊ីធរពារាំង និងស៊ីធរកណ្ដាល។[47] ព្រះមហាក្សត្រគង់នៅទីនោះបានពីរឆ្នាំ ដោយសារមានទឹកជំនន់ធំជន់លិចរាជធានីថ្មីខុសធម្មតា ទើបព្រះអង្គបញ្ជាឱ្យលើករាជធានីពីទួលបាសានទៅតាំងនៅចតុមុខ(ភ្នំពេញសព្វថ្ងៃ)វិញ។

---

[46] Cf., O. W. Wolters, 1966. The Khmer King at Basan (1371-3) and the Restoration of the Cambodian Chronology during the Fourteenth and Fifteenth Centuries. in *Asia Major*, XII, 1 (1966), pp. 44-89.

[47]ពង្សាវតារសតវត្សទី១៩ បានអះអាងថា ឈ្មោះ ស្រីសន្ធរ បានក្លាយមកពីឈ្មោះនារីស្អាតម្នាក់ឈ្មោះ'ស" ដែល'ឈរ"នៅមុខវត្តព្រៃបាំង និងដែលបានទាក់ទាញព្រះទ័យស្ដេចស្រីសុគន្ធបទឱ្យស្រឡាញ់ និងលើកជាស្នំឯក។ ប្រយោគ'ស្រីសឈរ" នោះត្រូវស្ដេចយកទៅដាក់ជាឈ្មោះខេត្ត ទើបអ្នកស្រុកហៅក្លាយជា ស្រីសន្ធរ។ ប៉ុន្តែ ការបញ្ជាក់នេះ ពិតជាមិនត្រឹមត្រូវព្រោះ ឈ្មោះស្រីសន្ធរកើតមានមុននាងស្រីសឈរមួយសតវត្ស។

អំណះអំណាងបែបនេះ មិនសូវសមស្របទាល់តែសោះ ព្រោះនៅចតុមុខក៏ជាប់មាត់ទន្លេ ដែលតែងរងទឹកជំនន់នៅរដូវវស្សាដូចគ្នានៅស្រីសន្ធរដែរ។ លើសនេះទៀតស្ថានភាពភូមិសាស្ត្រចតុមុខ គឺពោរពេញដោយបឹង ហើយអាចមានតែតំបន់វត្តភ្នំ និងម៉ុំជាប់មាត់ទន្លេចាប់ពីវត្តឧណ្ណាលោមដល់វត្តបទុមវតីប៉ុណ្ណោះដែលជាដីទួលធ្នូតៗ។ តាមការពិតជាក់ស្តែង ការលើករាជធានីពីតំបន់មួយទៅកាន់តំបន់មួយទៀត សុទ្ធសឹងជាព្រះរាជតម្រិះ ស្វែងរកទីតាំងអំណោយផលខាងសេដ្ឋកិច្ច និងសម្រាប់ជាយុទ្ធសាស្ត្រការពារសត្រូវ។ ផ្ទុយទៅវិញក៏មានអ្នកខ្លះនិយាយថា ការលើករាជធានីនេះ បង្ហាញអំពីអំណាចធ្លាក់ចុះរបស់ខ្មែរ និងដែលស្ទើរពុំមានលទ្ធភាពការពារខ្លួនឯងបាន។ ប៉ុន្តែគំនិតទាំងនេះហាក់ដូចផ្ទុយនឹងភស្តុតាងបញ្ជាក់ថា ខ្មែរមានសមត្ថភាពទប់ទល់វាយបកទៅលើសត្រូវវិញ ហើយបន្តរស់នៅដោយសុខសាន្ត។ការរកទីតាំងថ្មីប្រហែលមកពីបញ្ហាសេដ្ឋកិច្ចច្រើនជាងការដកខ្លួនរត់គេចពីសត្រូវ ភស្តុតាងរបស់ចិនជាប្រភពភស្តុតាងយ៉ាងសំខាន់ជាងគេសម្រាប់ហេតុផលនេះ។ ដូច្នេះ ការលើករាជធានីមកចតុមុខ គឺដើម្បីផលប្រយោជន៍ខាងសេដ្ឋកិច្ចសុទ្ធសាធ ព្រោះព្រះរាជាត្រូវការមានទំនាក់ទំនងរកស៊ីជាមួយឈ្មួញបរទេសឱ្យបានកាន់តែច្រើន, ត្រូវការត្រួតត្រាសកម្មភាពជំនួញ និងដកហូតពន្ធដារពីអ្នកជំនួញនៅតាមដងទន្លេទាំងបួនឱ្យមានប្រសិទ្ធភាព ទើបមានតែទីតាំងចតុមុខទេ ដែលល្អជាងគេ។ ម្យ៉ាងទៀតបើតាមទ្រឹស្តីសាសនារបស់ឥណ្ឌាដែលខ្មែរប្រកាន់យកតាំងពីសម័យហ្វូណានមកនោះ កន្លែងណាមានទន្លេប្រសព្វគ្នា គេចាត់ទុកជាព្រះតីថ៌ៈ ឬអ្នកតាផ្លូវទឹកដ៏សំខាន់ ហើយចតុមុខ មានទន្លេដល់ទៅ៤ជួបគ្នា នាំឱ្យមានកាន់តែពិសិដ្ឋឡើងថែមទៀតតាមផ្លូវជំនឿសាសនា។ សរុបមក ទីនេះ គឺជាទីជ័យភូមិដ៏ប្រសើរជាងគេ បើតាមជំនឿសាសនា។

ទីតាំងដ៏ល្អនៃភ្នំពេញ ដែលស្ថិតនៅត្រង់ទីប្រសព្វនៃទន្លេធំ និងទន្លេសាប គឺនៅត្រង់ទន្លេចតុមុខអនុញ្ញាតឱ្យទីក្រុងមួយដែលមានកំពង់ផែព័ទ្ធជុំវិញ អាចត្រួតពិនិត្យជំនួញដែលមកពីប្រទេសលាវតាមដងទន្លេ ក៏ដូចជាជំនួញក្ងួមផ្ទាំង ត្រីងៀត និងទឹកត្រី មកពីទន្លេសាប ព្រមទាំងទំនិញនាំចូល ជាពិសេសទំនិញមកពីស្រុកចិន តាមដែនដីសណ្តទន្លេមេគង្គ ដែលមានប្រជាជនខ្មែររស់នៅយ៉ាងច្រើននៅពេលនោះ។ ក្រោយពីពេលដែលប្រទេសខ្មែរបានសម្រេចចិត្តក្លាយជាប្រទេសធ្វើជំនួញមក(ប៉ុន្តែគេពុំអាចនិយាយបានថា ចាប់ពីពេលណាមក កើតឡើងដូចម្តេច ដោយសារមូលហេតុអ្វី?) ការតាំងរាជធានីនៅតំបន់អង្គរ លែងមានន័យអ្វីតទៅទៀតហើយ ក្នុងវិស័យសេដ្ឋកិច្ចនោះ។ ក្នុងគ្រានោះដែរ ក្រុងអង្គរហាក់ដូចជា នៅតែជាទីប្រជុំជនសំខាន់ដដែលពេញសតវត្សរ៍ទី១៥ ដូចការស្រាវជ្រាវរបស់លោក ក្លូដ ហ្សាក់ បានលើកមកបង្ហាញ។

ការលើករាជធានីភាគខាងត្បូងនេះ ហាក់ដូចជាជោគជ័យមួយរយៈខ្លីនៃផលប្រយោជន៍ថ្នាក់តំបន់ដែលក្រោយមកគេបានរៀបចំឱ្យមានលក្ខណៈស្របច្បាប់ និងយូរអង្វែង ហើយប្រហែលជាដើម្បីប្រយោជន៍របស់ស្តេចត្រាញ់។ បញ្ហានេះធ្វើឱ្យខូចប្រយោជន៍ដល់ប្រជាជនដែលរស់នៅជិតតំបន់អង្គរ ឬដែលរស់នៅផ្តុំគ្នាតាមអាងទន្លេចៅផ្រះយ៉ា (ទន្លេមេណាម) នៅភាគខាងលិច ។ សមាជិកនៃពួកវរជនខ្មែរដែលនៅភូមិភាគអាគ្នេយ៍ទាំងនោះ(ដោយអត្ថប្រយោជន៍ទាំងនេះ ជាអត្ថប្រយោជន៍របស់មេដឹកនាំ និងស្ម័គ្របក្សពួករបស់ពួកគេ ជាជាងរបស់អ្នកស្រែ)ប្រហែលជាបានឆ្លៀតឱកាសពីការស្ថិតនៅឆ្ងាយពីទីក្រុងអយុធ្យា ដើម្បីធ្វើជំនួញជាមួយចិន។ ប្រហែលពួកអ្នកទាំងនោះ អាចពឹងផ្អែកលើជំនួយពី ហ្វូណាន ជាភូមិភាគមួយដែលប្រហែលជាមិនសូវស្តាប់បទបញ្ជារបស់ក្រុងអង្គរ។ ជាការច្បាស់ជាងបើយើងនិយាយថា រឿងបរមបុរាណអំពីការស្ថាបនាក្រុងភ្នំពេញ ដែលតំណាលពីស្ត្រីម្នាក់ ឈ្មោះដូនពេញ ដែលបានប្រទះឃើញព្រះពុទ្ធរូបក្នុងរន្ធដើមគគីរ ដែលអណ្តែតចុះតាមខ្សែទឹក គឺជារឿងប្រឌិតឡើងក្រោយពីទីក្រុងបានបង្កើតហើយ ដោយមានឈ្មោះបញ្ជាក់អំពីទីតាំងស្ថិតនៅទីប្រសព្វនៃទន្លេពីរ ហើយជាឈ្មោះដែលគេបានរក្សារហូតមកដល់សព្វថ្ងៃនេះថា «ទន្លេចតុមុខ» ឬ«ទន្លេបួនមុខ» ដែលធ្វើឱ្យនឹកឃើញដល់រូបចម្លាក់នៅប្រាសាទបាយ័ន។

តួនាទីរបស់ពួកបរទេស ដែលបានមកធ្វើជំនួញក្នុងទីក្រុងថ្មីនេះ ពិបាកននឹងប៉ាន់ស្មានណាស់ ប៉ុន្តែទំនង មានពួកដែលនិយាយភាសាមាឡាយូមកពីប្រទេសចម្ប៉ា ឬក៏មកពីកោះនៃប្រទេសឥណ្ឌូនេស៊ីបច្ចុប្បន្ន ពីព្រោះនៅសល់ពាក្យរបស់គេមួយចំនួនក្នុងភាសាខ្មែរ ដូចជាថា«កំពង់» ក្នុងភាសាម៉ាឡាយូ មានន័យថា«ភូមិ» និង ផ្សារ ក៏ដូចជាគោរម្យងារមួយចំនួននៅក្នុងមុខងាររាជការ និងរដ្ឋបាល ។ មរតករបស់ម៉ាឡាយូនេះ តាមពិតប្រហែលជាជ្រៅជាងនេះទៅទៀត ហើយការពិពណ៌នារបស់ពួកអឺរ៉ុបអំពីតំបន់ខ្មែរតាមដងទន្លេនៅសតវត្សរ៍ទី១៧នោះ និងអំពីការរៀបចំផ្នែកនយោបាយ មានលក្ខណៈដូចគ្នាខ្លាំងណាស់នឹងការពណ៌នានៅសម័យនោះ និងក្រោយមកទៀត ទៅនឹងអ្នករស់នៅតាមមាត់ស្ទឹង នៅប្រទេសម៉ាឡាយូដែរ។ ពួកបរទេសផ្សេងទៀត ដែលមានសកម្មភាពនៅភ្នំពេញ គឺពួកចិនដែលធ្លាប់ប្រឡូកយ៉ាងសកម្មក្នុងពាណិជ្ជកម្មនៅអង្គរនាសតវត្សរ៍ទី១៣ ហើយពួកនេះមានប្រមាណ៣០០០នាក់នៅភ្នំពេញ ក្នុងទសវត្សឆ្នាំ១៥៤០។ ទំនងជាឈ្មួញចិន និងម៉ាឡាយូ ព្រមទាំងកូនចៅរបស់ពួកគេ បានរៀបការជាមួយកូនស្រីរបស់ពួកវរជនខ្មែរ(ដូចដែលពួកចិននៅតែធ្វើជាបន្តក្រោយមកទៀត) ដើម្បីរឹតចំណងទាក់ទងជាមួយព្រះមហាក្សត្រ, អ្នកហែហមព្រះអង្គ និងដើម្បីផលចំណេញក្នុងផ្នែកជំនួញ។ ឈ្មោះទីក្រុងចតុមុខមង្គល បើតាមពង្សាវតារថា មកពីនៅទីក្រុងនេះ មានអត្ថិភាពព្រះបដិមាមុខបួនពីរអង្គ ដែលរឿងព្រេងថា ដូនពេញរើសបានពីរន្ធគរគីរអណ្តែតទឹក។ តែបើតាមឯកសាររបស់ពួកអឺរ៉ុប ដែលកត់ត្រាដោយផ្អែកលើលក្ខខណ្ឌភូមិសាស្ត្រ បានអះអាងថា មកពីទីនេះមានទន្លេជួបគ្នាហើយបែកជាបួនមុខ។ នៅកណ្តាលទីក្រុងនេះ គេបានលើកដីពូនជាកូនភ្នំសិប្បនិមិត្តមួយ ដាក់តំកល់ព្រះបដិមាពិសិដ្ឋៗ ដើម្បីធ្វើជាស្នូលនៃរាជធានី។ បូជនីយដ្ឋានដ៏ពិសិដ្ឋនេះ មានឈ្មោះភ្នំពេញ ដែលក្លាយមកពីឈ្មោះ ដូនពេញ ដែលជាអ្នកកសាងភ្នំនេះ។ នេះបើពឹងផ្អែកលើរឿងព្រេងនិទានអំពីប្រវត្តិភ្នំដូនពេញ ដែលគេទើបនឹងចងក្រងឡើងនៅសតវត្សរ៍ទី១៩ប៉ុណ្ណោះ។

ប៉ុន្តែបើតាមការស្រាវជ្រាវតាមទ្រឹស្តីប្រវត្តិវិទ្យា និងភាសាវិទ្យាវិញ ឈ្មោះ "ភ្នំពេញ" មិនគួរក្លាយមកពីពាក្យថា "ភ្នំដូនពេញ" នោះទេ។ ព្រោះតាំងពីសតវត្សរ៍ទី១៦មក កំណត់ត្រាសហសម័យរបស់ព័រទុយហ្គាល់ និងហូឡង់មិនបានហៅទីនេះ ដូចពង្សាវតារខ្មែរបានអះអាងនោះទេ។ ដូច្នេះឈ្មោះ "ភ្នំពេញ"នេះ គួរតែមកពីពាក្យថា "ភ្នំបឹង" គឺភ្នំដែលមានបឹងព័ទ្ធជុំវិញ។ ឯកសារនៅសម័យសតវត្សរ៍ទី១៦របស់ព័រទុយហ្គាល់ គេបានឃើញសរសេរថា ពុំបិង *Ponom Beng* និងនៅឆ្នាំ១៦៤៤ ពួកហូឡង់សរសេរថា ពុំពិង *Ponum Pingh* ឬពុំពិញ។[48] ដោយសារអក្សរ "ប" នៅសម័យបុរាណ គេបញ្ចេញសំលេងជា "ប៉" ឬ "ព" ចំណែកព្យញ្ជនៈ "ង" និង "ញ" តែងតែត្រូវគេប្រើជាតួប្រកបជំនួសគ្នាបានទៅវិញទៅមក។ បញ្ហានេះហើយ ដែលអាចនាំឱ្យអ្នកស្រុកហៅច្រឡំ និងភ្លេចគំនិតរបស់អ្នកដាក់ឈ្មោះពីខាងដើម។ ព្រោះ "បឹង"ត្រូវគោកដោយសារទឹកជំនន់នាំដីល្បាប់មកចាក់បង្គរ ឬត្រូវគេលុបចោលជាបន្តបន្ទាប់ដើម្បីយកដីសង់លំនៅស្ថានទីក្រុង។

នៅចុងសតវត្សរ៍ទី១៥ ការរៀបចំសង្គមការិយាធិបតេយ្យ និងអាទិភាពសេដ្ឋកិច្ចដែលធ្លាប់មាននៅសម័យអង្គរ (ហើយដែលពឹងផ្អែកលើចំនួនកម្លាំងពលកម្មដោយបង្ខំ និងលើឧត្តមភាពរបស់វណ្ណៈបព្វជិត) ទំនងជាលែងមានភាពខ្លាំងក្លាតទៅទៀតទៅហើយ។ ម្យ៉ាងទៀតការរៀបចំរចនាសម្ព័ន្ធថ្មី ទីតាំងថ្មី និងអាទិភាពថ្មី ដែលពឹងផ្អែកមួយផ្នែកទៅលើការធ្វើជំនួញក្រៅប្រទេស អាចដំណើរការទៅបាន និងមានការទាក់ទាញផង ។

[48] បើស្ថាននាមនេះជា ពុំបិង ឬ ពុំពិញ ពិតជាសក្តិសមនឹងភូមិសាស្ត្រនៅជុំវិញវត្តភ្នំសព្វថ្ងៃមែន។ ព្រោះនៅភ្នំពេញពិតជាគ្របដណ្តប់ដោយបឹងជាច្រើនមែនដូចជា បឹងកក់, បឹងតេជោ(តំបន់ផ្សារថ្មី), បឹងរាំង(ខាងលិចសាលាព្រះស៊ីសុវត្ថិ), បឹងព្រលិត(អូរឫស្សី), បឹងកេងកង, បឹងត្របែក, បឹងទំពុន, បឹងសាឡាង, បឹងប្រយ៉ាប, បឹងពោងពាយ និងបឹងក្បៀន ជាដើម។

យើងបានធ្វើការសន្និដ្ឋានរួចមកហើយ ចំពោះមូលហេតុនៃការផ្លាស់ប្តូរមួយចំនួន ដែលប្រទេសកម្ពុជាឆ្លងកាត់នៅសម័យកាលនោះ។ កត្តាផ្សេងទៀត ដែលធ្វើឱ្យមានការផ្លាស់ប្តូរ ប្រហែលជាអាចហៅថាកត្តានៃការប្រកួតប្រជែង ទាំងនៅភ្នំពេញ និងរាជធានីផ្សេងៗទៀតនៅក្បែរនោះ និងនៅក្រុងស្រីអយុធ្យា។ តំបន់ទាំងអស់នោះ គេបានរៀបចំជាអាណាចក្រពាណិជ្ជកម្មថ្មីៗ ដោយគោរពអនុស្សាវរីយ៍នៃក្រុងអង្គរ។ ក្នុងទសវត្សរ៍ឆ្នាំ១៤០០ ក្រុងស្រីអយុធ្យា និងក្រុងពាណិជ្ជកម្មនៅកម្ពុជទេសបានពឹងគ្នាទៅវិញទៅមក ជាងការអាស្រ័យទៅលើការប្រព្រឹត្តិនៅអតីតកាល។ លើសពីនោះទៅទៀត រហូតមកដល់ចុងសតវត្សរ៍ទី១៦ "ភ្នំពេញ" ឬ"លង្វែក" ឬ"ឧដុង្គ" និង"អយុធ្យា" បានចាត់ទុកខ្លួនឯងថា ពុំមាននយោបាយដោយឡែកពីគ្នាទេ តែរួមចំណែកក្នុងល្បាយវប្បធម៌មួយ។ ការលាយឡំគ្នានេះ មានជាតួរួម ដូចជារាជាធិបតេយ្យដែលគោរពព្រហ្មញ្ញសាសនាតពីអង្គរផង កាន់ពុទ្ធសាសនាថេរវាទផង ដែលប្រហែលបានយកមកពីប្រទេសទ្វារវតីរបស់ជនជាតិមន ជារដ្ឋបានកាន់ពុទ្ធសាសនាថេរវាទអស់រយៈពេលជិតមួយពាន់ឆ្នាំ ព្រមទាំងសំណល់នៃរបៀបដឹកនាំថ្នាក់ភូមិតាមបែបបិតុនិយម ដែលប្រហែលតមកពីបុព្វជននៃកុលសម្ព័ន្ធជនជាតិថៃទាំងឡាយដែលរស់នៅតាមព្រៃភ្នំនៅភូមិភាគខាងត្បូងនៃប្រទេសចិន។ ពេញមួយសតវត្សរ៍ទី១៤ និងមួយភាគធំនៃសតវត្សរ៍ទី១៥ ប្រហែលជាប្រទេសទាំងពីរ(ខ្មែរ និងសៀម) មានភាសារួមមួយ គឺភាសាខ្មែរ។ ក្នុងសង្គមនៃប្រទេសទាំងពីរ មនុស្សសាមញ្ញអាចបួសជាព្រះសង្ឃ។ ដោយសារមានការសេតគប់គ្នាតាមរយៈសង្គ្រាម ចលនាប្រជាជន និងសាសនាដូចគ្នា សៀម និងខ្មែរមានវប្បធម៌លាយឡំជាមួយគ្នា ហើយមានការរីកលូតលាស់ខុសគ្នាពីបុព្វជននៃជនជាតិទាំងពីរនេះ។

ការលាយឡំជាមួយគ្នានេះកម្រឱ្យមានភាពក្សេមក្សាន្តណាស់។ អាណាចក្រទាំងពីរ បានវាយតម្លៃទៅលើកម្លាំងនយោបាយ ដោយអាងលើការគ្រប់គ្រងកម្លាំងប្រជាករច្រើនជាងគ្រប់គ្រងទឹកដី ហើយគិតថាអានុភាពនេះ និងសួយសារអាករ ជាកស្តុតាងនៃព្រះរាជសម្ភារ និងកិត្យានុភាពរបស់ព្រះរាជា។ សៀមបានរៀនពីខ្មែរ ហើយខ្មែរក៏បានរៀនពីសៀមវិញ តាមរយៈអ្នកកៀសខ្លួន និងឈ្លើយសឹក។ នៅចន្លោះសតវត្សរ៍ទី១៤ និងទី១៩ សឹកសង្គ្រាមកើតឡើងជារឿយៗរវាងខ្មែរ និងសៀម។ តាមធម្មតាការច្បាំងគ្នា មាននៅភាគខាងលិចទន្លេមេគង្គ។ សង្គ្រាមទាំងនេះ ធ្វើឱ្យតំបន់មួយចំនួនធំ ជាទីលានឆ្លងកាត់ដោយកងទ័ព ពេលចូលឈ្លានពាន និងពេលដកថយទៅវិញ។ ជាទូទៅការឈ្លានពាន កើតឡើងជួនពេលជាមួយនឹងសម័យកាលកំពុងចុះខ្សោយនៃតំបន់ដែលត្រូវគេចូលឈ្លានពាននោះ។ ជាឧទាហរណ៍ នៅទសវត្សរ៍ឆ្នាំ១៥៧០ ក្រោយពីទីក្រុងស្រីអយុធ្យា ត្រូវទទួលរងគ្រោះការវាយបំផ្លាញពីសំណាក់ភូមា ខ្មែរបានឆ្លៀតឱកាសប្រមូលកម្លាំងចេញទៅវាយសៀម។

ការរ៉ាយរ៉ាប់អំពីប្រវត្តិសាស្ត្រនៅសតវត្សរ៍ទី១៥ និងទី១៦ មានការសរសេរគ្រួសៗ ដោយសង្ខេបដែលជាពត៌មានតិចតួចបំផុត។ ការគ្រប់គ្រងដោយសៀមនៅតំបន់អង្គរ ប្រហែលជាត្រូវផ្តួលរំលំដោយកម្លាំង ដែលមានភក្តីភាពចំពោះមហាក្សត្រភ្នំពេញ នៅពាក់កណ្តាលសតវត្សរ៍ទី១៥ គឺប្រមាណ២០ឆ្នាំក្រោយការវាយលុកចុងក្រោយរបស់សៀមលើរាជធានីអង្គរ។ ក្រោយពេលដែលសៀមត្រូវបានគេដេញកំចាត់ពីអង្គរ សៀមក្តី ខ្មែរក្តី គ្មានភាគីណាមួយបានខិតខំគ្រប់គ្រងរាជធានីអង្គរទេ។ អស់រយៈពេលជាង១០០ឆ្នាំ ក្នុងកំឡុងពេលនោះ ព្រះរាជាក្រោយៗបានកាន់អំណាចនៅភ្នំពេញ ហើយព្រះបរមនាមនៃព្រះរាជាទាំងនោះ និងកាលបរិច្ឆេទដែលគេបានកត់ត្រាក្នុងព្រះរាជពង្សាវតារ ប្រហែលជាការប្រឌិត។

## 4. ជម្លោះផ្ទៃក្នុង ដើម្បីរាជសម្បត្តិ(២លើក)

គួរគប្បីជ្រាបថា មហាក្សត្រ បរមរាជាពញាយ៉ាត មានបុត្របីព្រះអង្គ(ពុំសូវស្របគ្នាចំពោះនាមមហេសីរបស់ព្រះអង្គ)។

១-នារាយណ៍រាជា រាជបុត្រ អ្នកម្នាងទេវី(ខ្លះថា ជាបុត្ររបស់អ្នកម្នាងសៀមស្រងៀម ឬស៊ីសាងាម)
២-ស្រីរាជា រាជបុត្រ អ្នកម្នាងបទុមកេសរ(ខ្លះថា បុត្រអ្នកម្នាងចន្ទ ឬចាន់)
៣-ធម្មរាជា រាជបុត្រអ្នកម្នាងស្រីសៀមស្រងៀម ឬស៊ីសាងាម

ព្រះបរមរាជា ចៅពញាយ៉ាត ផ្ទេររាជ្យសម្បត្តិនៅគ.ស១៤៦៣ ទៅឱ្យបុត្រច្បង គឺនរាយណ៍រាជា ដែលមាននាមសម្រាប់រាជ្យថា ព្រះបាទសម្តេចព្រះរាជឱង្ការព្រះនរាយណ៍រាជារាមាធិបតី ព្រះស្រីសុរិយោពម៌ធម្មិកមហារាជបរមបពិត្របណ្ឌិតជាឥសូរ ។

ក្នុងគ.ស.១៤៦៦ ព្រះបិតា គឺបរមរាជាពញាយ៉ាត សោយទិវង្គតដោយជរាពេគក្នុងជន្មាយុ៧០វស្សា។ ព្រះបាទនារាយណ៍សោយរាជ្យបន្តពីបិតាព្រះអង្គ បានតែ៥-៦វស្សា(១៤៦៣-១៤៦៩)ទ្រង់ប្រឈួនក៏សោយទិវង្គតទៅ។ ព្រះអង្គមានរាជបុត្រមួយអង្គ ទំនងជាមានព្រះជន្មក្មេងពេក មិនទាន់មានតំណែងសំខាន់ធំដុំនិងមានបក្សពួកច្រើនក្នុងរាជការជាន់ខ្ពស់ ទើបព្រះរាជាវង្សានុវង្ស និងនាម៉ឺនសព្វមុខមន្ត្រី សូមយាងព្រះស្រីរាជាដែលជាព្រះរាជអនុជបន្ទាប់ និងជាអ្នកមានបក្សពួកច្រើនស្រាប់ក្នុងរាជការ ឱ្យឡើងសោយរាជ្យស្នងព្រះជេដ្ឋា ដោយមានព្រះនាមសម្រាប់រាជ្យថា ព្រះរាជឱង្ការព្រះស្រីរាជារាមាធិបតីធម្មិករាជោត្តបរមមហាចក្រពត្រាធិរាជព្រះបរមនាថមហាបពិត្រ។ ស្តេចអង្គនេះ មានចំណាប់អារម្មណ៍ចំពោះការការពារទឹកដីដែលអយុធ្យាសញ្ជ័យយកពីមុនមក ឬប្រហែលជាព្រះអង្គមានព្រះរាជបំណងបង្រួបបង្រួមប្រទេសកម្ពុជាឡើងវិញ ទើបជាហេតុនាំឱ្យមនុស្សលោកក្នុងរាជវង្សធក់ឱកាសដណ្តើមអំណាចផ្ទៃក្នុង។ ចាប់ពីរជ្ជកាលព្រះអង្គនេះហើយ ដែលប្រទេសខ្មែរត្រូវពើបប្រទះនូវទុក្ខវេទនាយ៉ាងខ្លាំង បណ្តាលមកពីវិបត្តិក្នុងរាជវង្សានុវង្សខ្មែរ ។

### +ដំណាក់កាលទី១ ៖ ការបែងចែកប្រទេសកម្ពុជា (១៤៥៧-១៥០៤)

នៅឆ្នាំ១៤៧៥ ព្រះបាទស្រីរាជា បានបញ្ជាក្បួនទ័ពដោយផ្ទាល់ សំដៅទៅខេត្តខាងលិច។ កងទ័ពខ្មែរបានវាយកំចាត់ទ័ពសៀម និងយកខេត្តខ្មែរដែលសៀមកាត់យកលើកមុនបានមកវិញ ។

ពេលដែលព្រះស្រីរាជា កំពុងជាប់ដៃធ្វើសង្គ្រាមជាមួយសៀម ព្រះស្រីសុរិយោទ័យ ជាបុត្រព្រះនរាយណ៍រាជា ដែលមានភារកិច្ចប្រមូលស្បៀងឧបត្ថម្ភសមរភូមិមុខ បានឆ្លៀតឱកាសបញ្ចុះបញ្ចូលចៅហ្វាយខេត្តមួយចំនួននៅខាងកើត មានស្រីសន្ធរ ត្បូងឃ្មុំ បាភ្នំ ដូងណាយ ឱ្យគាំទ្រខ្លួនធ្វើជាស្តេច និងបានទន្ទ្រានយកខេត្តប៉ែកខាងកើតខ្លះទៀត ដូចជាកំពង់សៀម ស្ទឹងត្រង់ ជើងព្រៃ ហើយតាំងខ្លួនជាព្រះមហាក្សត្រ បង្កើតរាជាណាចក្រខាងកើត មានរាជធានីនៅស្រីសន្ធរ។ មិនតែប៉ុណ្ណោះទ្រង់បានរៀបចំកងទ័ពចេញទៅស្កាត់ផ្លូវសម្តេចមា គឺព្រះស្រីរាជា។ ចំណែក ព្រះធម្មរាជា ដែលជារាជបុត្រពៅរបស់ស្តេចពញាយ៉ាតដែរនោះ ហើយដែលមានភារកិច្ចថែរក្សារាជធានីចតុមុខ ក៏បានក្បត់ ដោយយកលំពែងនិងព្រះខ័នរាជ្យរក្សាទុកនៅព្រះបរមរាជវាំង ហើយប្រកាសបង្កើតរាជាណាចក្រមួយថ្មី ឈ្មោះរាជាណាចក្រខាងលិច ។

ក្រោយពីបានជ័យជំនះលើកងទ័ពសៀម ព្រះស្រីរាជានាំទ័ពត្រឡប់វិញ ហើយទៅតាំងរាជធានីនៅកំពង់សៀម (កំពង់ចាម) ហៅថារាជាណាចក្រខាងជើង។ បន្ទាប់ពីបើកការប្រយុទ្ធវាយបណ្តេញទ័ពបះបោរ ស្រីសុរិយោទ័យ ឱ្យបាក់តេចេញពីខេត្តខាងជើងថយមកនៅត្រើយខាងកើតទន្លេមេគង្គ។ ស្ថិតក្នុងការបែងចែកប្រទេសដូចនេះ ប្រជារាស្ត្ររស់ពុំបានសុខទេ ដោយភាពទុរ្ភិក្ស ចោរកម្ម និងជម្ងឺរាតត្បាត។ ហើយចុងក្រោយព្រះបាទធម្មរាជា បានលួចទាក់ទងសម្ងាត់ជាមួយស្តេចអយុធ្យា ឱ្យគាំទ្របេក្ខភាពខ្លួនជាព្រះមហាក្សត្រនៅកម្ពុជា ទើបធ្វើពើជាអញ្ជើញស្តេចអយុធ្យាឱ្យធ្វើអាជ្ញាកណ្តាល ក្នុងការចរចាបញ្ចប់សង្គ្រាមនៅឆ្នាំ១៤៨៥។ ដោយមិនដឹងពីល្បិចកលរបស់ព្រះធម្មរាជា ព្រះបាទស្រីរាជា និងស្រីសុរិយោទ័យ បានចូលទៅចរចាតាមការណាត់ និងកម្រិតចំនួនកងទ័ពយកតាមខ្លួន ទើបត្រូវស្តេចអយុធ្យាក្រសោបចាប់យកទៅអយុធ្យាបាត់អស់។ ចុងក្រោយ ព្រះបាទធម្មរាជា បានឡើងសោយរាជ្យនៅចតុមុខតែមួយអង្គឯង ហើយខិតខំធ្វើបុណ្យសព្វបែបយ៉ាង ដើម្បីយកចិត្តរាស្ត្រ និងមន្ត្រីមួយចំនួនធំ។ ប៉ុន្តែទឹកដីដែលព្រះបាទស្រីរាជា ខិតខំវាយយកបានពីអយុធ្យា បានក្លាយជាតុរង្វាន់សម្រាប់ស្តេចអយុធ្យា ដែលបានជួយអន្តរាគមន៍នៅគ្រានោះវិញ។

### +ដំណាក់កាលទី២ ៖ សង្គ្រាមផ្ទៃក្នុងរវាងស្តេចស្រីសុគន្ធបទ និងចន្ទរាជា ជាមួយស្តេចកន

ពេលដែលព្រះធម្មរាជា សោយទិវង្គតទៅ ព្រះស្រីសុគន្ធបទ ដែលជាព្រះរាជបុត្រាច្បងបានឡើងគ្រងរាជ្យបន្តនៅគ.ស១៥០៤។ នៅក្នុងរាជ្យរបស់ព្រះអង្គ រាជធានីតាំងនៅស្រីសន្ធរ ឯព្រះអនុជ នាមអង្គច័ន្ទ ដែលជាមហាឧបរាជ គង់នៅភ្នំពេញ។ ដោយសារព្រះស្រីសុគន្ធបទ សព្វព្រះរាជហឫទ័យលើនាងពៅ(ឯកសារខ្លះថា "ឈ្មោះនាងស(ឈរ)"នេះហើយជាដើមកំណើតឈ្មោះស្រុកស្រីសន្ធរ ឬស្រីសឈរនាពេលបច្ចុប្បន្ន) ព្រះអង្គតែងតាំងនាងនោះជាស្នំឯក។ រីឯនាយកន ដែលត្រូវជាប្អូនថ្លៃព្រះអង្គ និងជាយុវជនដែលមានចំណេះដឹង និងជំនាញយុទ្ធសាស្ត្រ ត្រូវព្រះអង្គតែងតាំងជាមេទ័ព និងបានឡើងឋានន្តរស័ក្តិហូតជា យុនហ្លួងព្រះស្តេច។ ក្រោយមកដោយខ្លាចហ្លួងព្រះស្តេចនេះ ក្បត់ដណ្តើមរាជ្យ ទ្រង់ក៏រិះរកវិធីសម្លាប់ចោល តែការធ្វើឃាតនោះមិនបានសម្រេច។ ដើម្បីការពារជីវិតរបស់ខ្លួន ស្តេចកនត្រូវបង្ខំចិត្តក្បត់នឹងបងថ្លៃជាព្រះរាជា ដោយទៅបញ្ឆោតចៅហ្វាយខេត្ត និងស្រុកចំណុះខេត្តបាភ្នំឱ្យប្រមូលកងទ័ពឱ្យខ្លួនក្រោមរាជបញ្ជារបស់ស្តេចផែនដី។ ដូច្នោះហើយ គាត់បានប្រើល្បិចបំបែកកម្លាំងរាជវង្សដោយប្រើវិធីញុះញង់បំបែកបំបាក់បន្លាចអង្គចន្ទ ឱ្យគេចចេញពីព្រះបាទស្រីសុគន្ធបទ។ ឧបរាជអង្គចន្ទ ក៏ប្រញាប់ភៀសព្រះកាយទៅស្រុកសៀមបាត់ទៅ។ នាយកន ក៏ចាប់ផ្តើមធ្វើសង្គ្រាមជាមួយព្រះបាទស្រីសុគន្ធបទ តាំងពីឆ្នាំ១៥០៨ រហូតធ្វើគតព្រះអង្គបាននៅឆ្នាំ១៥១២ នៅបន្ទាយស្ទឹងសែន ក្នុងខេត្តកំពង់ធំសព្វថ្ងៃ ហើយប្រកាសខ្លួនជាស្តេចគ្រប់គ្រងរាជធានីនៅស្រីសន្ធរ និងក្រោយមកផ្លាស់ទៅតាំងនៅបន្ទាយស្រឡប់ពិជ័យ។

ក្រោយពីដឹងថា ព្រះរៀមសុគតដោយស្នាដៃស្តេចកនហើយ ព្រះអង្គចន្ទរាជា បានរកឧបាយកលបញ្ឆោតស្តេចអយុធ្យា ដើម្បីបានត្រឡប់មកទឹកដីខ្មែរវិញ។ សង្គ្រាមរវាងព្រះអង្គចន្ទរាជា និងហ្លួងព្រះស្តេច ប្រព្រឹត្តទៅអស់រយៈពេលដប់ឆ្នាំ លុះដល់ឆ្នាំ១៥២៥ ទើបកងទ័ពព្រះអង្គចន្ទរាជា យកជ័យជំនះបានជាស្ថាពរ ហើយបានឡើងសោយរាជ្យតែមួយអង្គឯងរហូតដល់ឆ្នាំ១៥៦៦។ ការយកជ័យជម្នះបាននេះ បើតាមលក្ខខណ្ឌទីតាំងភូមិសាស្ត្ររាជធានីរបស់គូបដិបក្សទាំងពីរ គេអាចយល់បានដោយងាយថា ព្រះអង្គម្ចាស់ចន្ទរាជា បោះទីតាំងនៅកន្លែងដែលមានសក្តានុពលសេដ្ឋកិច្ចជាស្តេចកន ព្រោះទ្រង់តាំងនៅក្បែរមាត់បឹងទន្លេសាប ដែលសំបូរដោយប្រភពអាហារ និងមានសកម្មភាពពាណិជ្ជកម្ម។ លើសនេះព្រះអង្គយកព្រះទ័យទុកដាក់លើការងារជំនួញជាមួយបរទេស ព្រមទាំងដាក់កំហិតលើការប្រមូលពន្ធដារសព្វសារពើ។ ចំណែកស្តេចកន វិញតាំងរាជធានីនៅបន្ទាយព្រៃនគរ ដែលមានសក្តានុពលខាងកសិកម្មស្រូវវស្សាតែមួយមុខ ហើយគ្មានការយកព្រះទ័យទុកដាក់លើកិច្ចការជំនួញ ថ្វីបើព្រះអង្គ

ចេះផ្តួចផ្តើមគំនិតបោះប្រាក់ស្លឹងសម្រាប់ចាយ ធ្វើជាមធ្យោបាយកណ្តាលសម្រាប់ការជួញដូរក្តី។ ទន្ទឹមនោះ ដើម្បីទាក់ទាញទឹកចិត្តប្រជារាស្ត្រ ព្រះអង្គបានបន្ធូរបន្ថយការប្រមូលពន្ធដារ ទើបទំនងជាធ្វើឱ្យមានវិបត្តិសេដ្ឋកិច្ច។

## 5. អន្តរាគមន៍របស់សៀមលើកដំបូង

គេបានដឹងថា នៅក្នុងដំណាក់កាលទី១ នៃទំនាស់រាជវង្សខ្មែរនាពាក់កណ្តាលទី២សតវត្សទី១៥ បណ្តាលមកពីបញ្ហារាជ្យសម្បត្តិ ដែលនាំឱ្យមានវិបត្តិរីករាលឡើង។ នៅសម័យមហានគរ ពុំឃើញមានទេ នូវការពឹងពាក់បរទេស (ចាម, យួន, ចិន) ដើម្បីដោះស្រាយវិវាទក្នុងទំនាស់រាជវង្សានុវង្សខ្មែរ។ ប៉ុន្តែបើតាមការអះអាងជាថ្មីរបស់អ្នកស្រាវជ្រាវ គឺអយុធ្យាពីឆ្នាំ១៣៥១-ដល់១៥៦៩ គឺជាខ្មែរនៅឡើយ។ ដូចនេះ វាជាការពឹងពាក់ខ្មែរគ្នាឯងនោះទេ។ នៅពេលក្រោយមក មេដឹកនាំអយុធ្យាក្លាយទៅជាថៃក៏ដោយ ក៏ទម្លាប់ពឹងពាក់អយុធ្យានេះ នៅតែបន្តកើតមានកាន់តែញឹកញាប់ទៀត ជាពិសេសនៅសតវត្សទី១៨ និង១៩។ វប្បធម៌ពឹងបរទេសក្នុងជម្លោះរវាងបងប្អូនឯង របស់មេដឹកនាំខ្មែរ ពុំបានធ្វើឱ្យសភាពការណ៍នយោបាយផ្ទៃក្នុងប្រទេស មានលទ្ធផលល្អទេ។

អន្តរាគមន៍នេះ បានកើតឡើងនៅឆ្នាំ១៤៨៥ ដោយសារសំណើរបស់ព្រះបាទធម្មរាជា។ ស្តេចសៀមបាននាំកងទ័ពត្រឹមតែ៣០.០០០នាក់ប៉ុណ្ណោះ ចូលមកស្រុកខ្មែរ ក្នុងលេសថា មកជួយសម្រុះសម្រួលបញ្ចប់សង្គ្រាមនៅកម្ពុជា។ ដោយពុំបានដឹងពីការឃុបឃិតប្រើល្បិចកលរបស់ព្រះអនុជ ឬ ឪពុកមាជាមួយនឹងសៀម ព្រះស្រីរាជា និងព្រះស្រីសុរិយោទ័យ បានយល់ព្រមធ្វើការចរចា។ ស្តេចអយុធ្យា ឆ្លៀតឱកាសនោះ ក្រសោបចាប់យកស្តេចទាំងពីរអង្គ នាំទៅស្រុកបាត់ទៅ។ ក្រោយមកព្រះរាជាទាំងពីរអង្គ ក៏សោយទិវង្គតនៅអយុធ្យានោះទៅ។

ព្រះបាទធម្មរាជា បានឡើងជាស្តេចនៅកម្ពុជាតែមួយអង្គឯងពីឆ្នាំ១៤៨៥-១៥០៤ ដោយតាំងរាជធានីនៅភ្នំពេញដដែល។ ដើម្បីសងគុណស្តេចអយុធ្យា ព្រះអង្គបានប្រគល់ខេត្ត និងគ្រួសារសៀមដែលព្រះបាទស្រីរាជា វាយយកបានមកពីសៀម ទៅឱ្យសៀមវិញ ព្រមជាមួយបណ្ណាការជាច្រើនទៀតផង។

## 6. ប្រភពឯកសារសហសម័យ

បើតាមសិលាចារឹកវត្តព្រះធាតុខ្ទាវ K. 177 នៅស្រុកជីក្រែង ដែលប្រហែលជាចារឹកនៅរវាងឆ្នាំ១៤៨៥ បានអះអាងថា ទឹកដីខ្មែរនៅភាគខាងជើងភ្នំដងរែករួមបញ្ចូលតាំងពីដែនដីព្រៃស្វាយ ឬស្រី(ស)ជ្ជនាល័យបុរី ដែលនៅខាងលិចសុខោទ័យចម្ងាយ ៣០គម ចុះមកទិសខាងត្បូងរហូតដល់ធនបុរី ទល់មុខទីក្រុងបាងកក និងដល់ខេត្តចន្ទបុរីមាត់សមុទ្រប្រទេសថៃសព្វថ្ងៃ។[49]

ទាក់ទងនឹងការបះបោររបស់ស្តេចកន មិនបានបញ្ជាក់ថា ព្រះមហាក្សត្រស្រីសុគន្ធបទ ត្រូវមេបះបោរសម្លាប់នោះចោលនៅឆ្នាំ១៥១២នោះទេ។ ពីព្រោះព្រះអង្គ នៅមានព្រះជន្មនៅឡើយក្នុងឋានៈជាចៅហ្វាយខេត្តជាន់ខ្ពស់ដូចឧបរាជ រហូតមកដល់ឆ្នាំ១៥៦៦ ជាពេលដែលព្រះបាទចន្ទរាជាចូលទិវង្គត។ មានប្រភពភស្តុតាងឯកសារសហសម័យពីរ ដែលបញ្ជាក់អំពីរឿងនេះ។

**ទី១**-គឺលោក ហ្គាស្ប៉ាដាគ្រុស ដែលបានទស្សនា និងស្នាក់នៅទីក្រុងលង្វែក ពីឆ្នាំ១៥៥៥-៥៧បានឱ្យដឹងថា ព្រះមហាក្សត្រពេលនោះ(ចន្ទរាជា)អាចឡើងសោយរាជ្យបាន ដោយសារមានការបះបោរដ៏ធំមួយរបស់ប្រជា

[49] ស.ម., វង់ សុធារ៉ា (២០១២) *សិលាចារឹកនៃប្រទេសកម្ពុជាសម័យកណ្តាល,* នគរវត្ត, ទំព័រ ???

ជន ប្រឆាំងនឹងព្រះមហាក្សត្រដែលជាព្រះរៀមរបស់ព្រះអង្គ។ ក្រោយមកព្រះអង្គបានបង្ក្រាបការបះបោរនោះប្រកបដោយជោគជ័យ ទើបព្រះរៀមរបស់ព្រះអង្គប្រគល់ព្រះរាជាណាចក្រនោះ មកឱ្យព្រះអង្គគ្រប់គ្រងវិញ។ ពត៌មាននេះបង្ហាញយ៉ាងប្រាកដថា ស្រីសុគន្ធបទ មិនបានសុគតក្រោមការបះបោរនោះឡើយ។[50]

**ទី២**-តាមរយៈសិលាចារឹកវត្តនគរបាជ័យខេត្តកំពង់ចាម ឆ្នាំ១៥៦៦ ផ្នែកភាសាបាលីបានឱ្យដឹងថា បុរសដែលមានព្រះនាមដ៏ខ្ពង់ខ្ពស់ថា ²សិរិសោគន្ធបទ គឺជាអតីតព្រះមហាក្សត្រ³។ ចំណែកនៅក្នុងអត្ថបទជាភាសាខ្មែរថា សំតេចឱកញាយស្សស្រីសៅគន្ធបទ បានធ្វើបុណ្យសាងព្រះចេតីយបញ្ចុះព្រះសរីរិកធាតុ នៅត្រង់តួប៉មកណ្តាលនៃប្រាសាទនោះ និងធ្វើព្រះវិហារមួយនៅចន្លោះតួប៉មកណ្តាលនោះជាមួយកំពែងជ្រុងខាងកើត ដើម្បីឧទ្ទិសចំពោះព្រះវិញ្ញាណក្ខន្ធព្រះអនុជចន្ទរាជា ដែលមានមរណនាមថា មហាបរមនិព្វានបទ និងប្រគេនចំពោះព្រះអរិយសង្ឃមួយព្រះអង្គនាម ព្រះកម្រតេងអញមហានាគសេនបពិត្រ។ ដូច្នេះ មន្ត្រីនាមស្រីសុគន្ធបទ កំពុងមានជីវិតនៅឡើយទើបគាត់អាចប្រារព្ធធ្វើពិធីវេរប្រគេនទេយ្យទានចំពោះព្រះអរិយសង្ឃអង្គនេះបាន[51] ហើយរូបគាត់នេះឯងគឺពិតជាអតីតព្រះបាទស្រីសុគន្ធបទ ហើយព្រះអង្គនៅមានព្រះជន្មនៅឡើយរហូតមកដល់ឆ្នាំ១៥៦៦ នៅពេលដែលព្រះបាទចន្ទរាជា ចូលទិវង្គតរួចហើយ៕

---

[50] Cf. Michael T. Vickery, 1977. *Cambodia After Angkor, the Chronicular Evidence of the Fourteenth to Sixteenth Centuries,* Volume 1, Ann Arbor, University Microfilms International, pp. 229, 332.

[51] Cf. Jean Filliozat, Une inscription cambodgienne en Pali et en Khmer de 1566 (K. 82 Vatt Nagar). *Académie des Inscriptions et Belles-Lettres,* Comptes-Rendus des séances de l'année 1969 Janvier-mars, Paris, Éditions Klineksierk, 11, rue de Lille 1969, pp. 93-106.

# មេរៀនទី 6 សម័យលង្វែក និងការពង្រឹងអានុភាពជាតិឡើងវិញ

## 1. ការកសាងបន្ទាយលង្វែក

ជម្លោះរវាងស្ដេចកន និងចន្ទរាជា ជាជម្លោះផ្ទៃក្នុងមួយដែលផ្ដើមពីការមិនទុកចិត្តគ្នា រវាងស្ដេចស្រីសុគន្ធបទ[52] និងស្ដេចកន ហើយបន្តបង្កជាទំនាស់រវាងស្ដេចកន និងចន្ទរាជា ក្រោយពីព្រះស្រីសុគន្ធបទត្រូវធ្វើគត់នៅក្នុងសង្គ្រាម។ សង្គ្រាមគ្នាឯងនេះ មានរយៈពេល៩ឆ្នាំ(១៥១៦-១៥២៥) នៅទីបញ្ចប់ស្ដេចកន និងក្រុមបក្សពួក ត្រូវបានក្រុមរបស់ព្រះចន្ទរាជា សម្លាប់ចោលអស់។

ដោយរាជ្យសម្បត្តិពុំមានអ្នកស្នង ព្រោះពញាយសរាជា ដែលជារាជ្យបុត្ររបស់ស្រីសុគន្ធបទក៏ត្រូវធ្វើគតទៅហើយដែរនោះ ព្រះចន្ទរាជា ក៏ព្រមឡើងសោយរាជ្យតាមសំណូមពររបស់រាជវង្សានុវង្ស និងនាម៉ឺនសព្វមុខមន្ត្រីរបស់ព្រះអង្គ។ ព្រះចន្ទរាជា មានរាជធានីតាំងបណ្ដោះអាសន្ននៅក្នុងខេត្តពោធិ៍សាត់ក្រោយមកព្រះអង្គសព្វព្រះរាជហឫទ័យ លើករាជធានីមកតាំងនៅលង្វែកវិញ។ លង្វែក ជារាជធានីទី២នៅសម័យក្រោយអង្គរ បន្ទាប់ពីរាជធានីចតុមុខ-ភ្នំពេញ។ រាជធានីថ្មីនេះត្រូវបានកសាងឡើង អស់រយៈពេលប្រមាណជា៣ឆ្នាំ គឺនៅគ្រិស្តសករាជ១៥២៧ ដល់១៥២៩ ទើបរួចជាស្ថាពរ ហើយព្រះអង្គក៏យាងមកគង់នៅរាជវាំងលង្វែកនៅឆ្នាំកសាងរួចនោះ។

មូលហេតុឱ្យជ្រើសរើសយករាជធានីលង្វែក ដោយព្រះអង្គទ្រង់ឈ្វេងយល់ថា កន្លែងនោះជាកន្លែងជ័យភូមិល្អ ព្រោះព្រះអង្គបានប្រទះឃើញបាតុភូតដ៏អស្ចារ្យមួយនៅទីនោះ គឺថ្មមួយដុំធំនៅលើប្រគាបឈើគរគីរមួយដើមដ៏ធំដែរ។ ដែលតាមពិត ថ្មនោះអាចទើលើមែកគរគីរបានដោយសារអព្ភូតហេតុខ្យល់កួចខ្លាំងប៉ុណ្ណោះ។ តែពីសម័យបុរាណគេមិនដឹងរឿងនេះ ទើបចាត់ទុកជាអច្ឆរិយភាព។ ហេតុនោះហើយទើបព្រះអង្គបញ្ជាឱ្យគេកាប់ដើមគរគីរដ៏ធំនោះធ្វើជាព្រះពុទ្ធរូបបួនអង្គឈរទល់ខ្នងគ្នាកម្ពស់១៨ហត្ថ និងឱ្យគេកាត់ថ្មមួយដុំធំនោះធ្វើជាពុទ្ធបាទបួនគូទ្រព្រះពុទ្ធរូបឈើ។ ដើម្បីតម្កល់ព្រះនោះ ព្រះអង្គបានឱ្យគេលើកដីពូនជាកូនភ្នំតូចមួយ រួចដាក់តំកល់ព្រះពុទ្ធរូបដ៏មានឫទ្ធិអំណាចនោះ ហើយធ្វើព្រះវិហារមុខបួនគ្របពីលើ តាមមុខព្រះពុទ្ធរូបទាំងបួនអង្គ ដែលគេហៅថា ព្រះវិហារត្រឡែងកែង ប្រតិស្ឋានជាទីសក្ការបូជាស្នួលនៃរាជធានីថ្មី។ នៅជុំវិញបន្ទាយ ព្រះអង្គឱ្យគេដាំដើមឫស្សីយ៉ាងក្រាស់កម្រាស់១៥០(១៦០ម៉ែត្រ)[53] នៅតាមជ្រុងទាំងបី លើកលែងជ្រុងខាងកើតដែលជាបឹង ដើម្បីធ្វើបន្ទាយយុទ្ធសាស្ត្រមួយស្រួលការពារខ្លួន ក្នុងករណីមានសត្រូវមកឈ្លានពាន។ ក្រៅពីភាពមាំមួនដោយកំពែងឫស្សី នៅក្នុងបន្ទាយមានបឹង និងទន្លេសាបនៅទិសខាងកើត ដែលផ្ដល់ប្រយោជន៍ខាងស្បៀងអាហារជាពិសេសត្រីសាច់សម្រាប់ធ្វើម្ហូប និងផ្លូវគមនាគមន៍តាមជើងទឹក។ ក្នុងសម័យកាលដែលមហាក្សត្រជ្រើសរាជធានី ដូចជា ចតុមុខ, រាជធានីលង្វែក, រាជធានីទួលបាសាន(ស្រីសន្ធរ) ឃើញថាទីតាំងនៃរាជធានីទាំងនោះសុទ្ធតែជាចំណុចយុទ្ធសាស្ត្រ ស្ថិតនៅជិតទន្លេបឹងនិងព្រៃធ្វើជារបាំងឧបសគ្គសម្រាប់បង្អាក់លក្ខណៈងាយស្រួលការពារខ្លួនបាន។ ម្យ៉ាងទៀត រាជធានីនីមួយៗសុទ្ធតែមានកំពែង និងគូទឹក ឬអូរព័ទ្ធជុំវិញ ហើយមានបន្ទាយ មានសើនឬប៉មគយជាច្រើនកន្លែងសម្រាប់បង្ការសត្រូវ។

---

[52] គួរកត់សម្គាល់ថា ឈ្មោះបែបនេះ គឺជាបច្ឆាមរណនាម ទំនងមិនមែនជានាមពេលព្រះអង្គនៅគង់ព្រះជន្មនោះទេ ប្រសិនបើយើងពិចារណាដោយពឹងផ្អែកលើបទដ្ឋាននាមព្រះមហាក្សត្រនៅសម័យអង្គរជាមូលដ្ឋាន។

[53] ស.ម ត្រឹង ងា(១៩៧៣), *ប្រវត្តិសាស្ត្រខ្មែរ*, ភាគ១និង២, ការផ្សាយរបស់គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ, ទំព័រ១៤៤។

រាជធានីលង្វែក ជាបន្ទាយមួយមាំមួនជាងបន្ទាយឯទៀត នេះគឺដោយសារតែមានព្រៃឫស្សីយ៉ាងក្រាស់ដែលព័ទ្ធពីក្រៅគូទឹកទៀត។

## 2. ការកសាងឯកសារ ក្បួនខ្នាត ច្បាប់រដ្ឋ

ទស្សនៈហិណ្ឌូ"គោ"ជាតំណាងឱ្យច្បាប់ ដូចដែលបានលើកយកមកពិភាក្សារួចមកហើយនៅមេរៀនមុន។ គេកសាងរូបព្រះគោធ្វើអំពីថ្ម ដើម្បីជានិមិត្តរូបនៃការរៀបចំច្បាប់សម្រាប់អនុវត្តន៍លើព្រះរាជាណាចក្រ។ ព្រះគោក៏ជានិមិត្តរូបតំណាងឱ្យ «ធម៌» ផងដែរ។ ជំនឿលើគោជានិម្មិតរូប មានជាយូរមកហើយ តាំងពីសម័យដំបូងនៃប្រវត្តិសាស្ត្រ និងបន្តដល់គំនិតមហាក្សត្រនាសម័យអង្គរ។ ជំនឿនេះបានបន្តមកក្នុងគំនិតខ្មែរ នាសម័យក្រោយៗមកទៀត។

ក្នុងរាជពង្សាវតារ បានអះអាងថា នៅពេលតាំងរាជធានីនៅលង្វែកស៊ប់ហើយ ព្រះបាទចន្ទរាជា បានអំពាវនាវក្នុងផ្ទៃប្រទេសរកអ្នកប្រាជ្ញរាជបណ្ឌិត ដែលនៅសេសសល់ទាំងអស់មកជុំគ្នា ដើម្បីរៀបចំតាក់តែងក្បួនខ្នាតច្បាប់ទុកសម្រាប់ព្រះនគរឡើងវិញ។ តែគួរឱ្យស្តាយច្បាប់ទាំងនោះមិនបាននៅគង់វង្សទេ ដោយគេយល់ថា ត្រូវរលំរលាយនៅពេលសៀមវាយកំទេចទីក្រុងលង្វែកនៅចុងសតវត្សរ៍ទី១៦នោះ។ ចំពោះច្បាប់ចាស់ដែលនៅសេសសល់មួយចំនួនរហូតដល់សព្វថ្ងៃ ភាគច្រើនបានចងក្រងឡើងវិញ ឬធ្វើវិសោធនកម្មឡើងវិញ នៅក្នុងរជ្ជកាលព្រះបាទជយជេដ្ឋាទី៣ ចុងសតវត្សរ៍ទី១៧។ តែមានច្បាប់ខ្លះ បានបញ្ចូលរឿងរ៉ាវបទពិសោធន៍របស់ស្តេចនៅស្រុកសៀមទៅក្នុងនោះដែរ។

នៅពេលបន្ទាយលង្វែកត្រូវបែកបាក់ ដោយការឈ្លានពានរបស់សៀម នៅឆ្នាំ១៥៩៣-១៥៩៤ មានការលើកឡើងថា ពេលសៀមព័ទ្ធទីក្រុងលង្វែកជាប់ហើយ គេបានប្រមូលគម្ពីរ ក្បួនខ្នាតយកមកលាក់ទុកនៅក្នុងពោះរបស់ព្រះគោ។ នៅសម័យលង្វែក ដែលជាសម័យកាលចុងក្រោយដែលគេជឿថាគម្ពីរ ក្បួនខ្នាតរបស់ខ្មែរ ត្រូវអស់ចាប់ពីត្រឹមនេះ។ ពេលសៀមវាយលុកលង្វែក សៀមបានចាប់ព្រះគោព្រះកែវដែលជាបងប្អូនបង្កើតនឹងគ្នាយកទៅស្រុកសៀម។ គម្ពីរ ក្បួនខ្នាតទាំងឡាយត្រូវជាប់នៅនឹងពោះព្រះគោ ដែលគេបានលាក់ទុកនៅក្នុងនោះ ត្រូវសៀមប្រមូលយកទៅអស់ផងដែរ។ យើងគិតថា ដោយជំនឿខ្មែរមានយូរលង់មកហើយលើសត្វគោ ដែលតំណាងឱ្យច្បាប់ដូចបានអធិប្បាយមកនោះហើយដែលជាមូលហេតុ យើងជឿថាសម័យលង្វែកនេះហើយ ដែលខ្មែរបានរក្សាឃ្លាំងវប្បធម៌មួយរបស់ជាតិបន្ទាប់ពីរាជធានីអង្គរមក។ ហេតុផលមួយទៀត គឺនៅសម័យកាលក្រោយលង្វែកនេះឯងដែលប្រវត្តិសាស្ត្របង្ហាញថា ខ្មែរទទួលឥទ្ធិពលសាសនា,នយោបាយ និងវប្បធម៌ រហូតដល់មហាក្សត្រដែលត្រូវសោយរាជ្យសម្បត្តិ ក៏ត្រូវមានការអនុញ្ញាតពីសៀមដែរ។ ការធ្វើឱ្យខ្មែរបាត់នូវឥស្សរភាព មិនមែនបាត់នូវឯកសារដែលលាក់ទុកនៅក្នុងពោះព្រះគោទេ តែយើងជឿលើព្រះគោដូចបានអធិប្បាយហើយមកនេះ។ ក្បួនខ្នាតទាំងអស់ បង្កប់នូវតម្លៃខាងវប្បធម៌ដ៏ជ្រាលជ្រៅ ដែលដូនតាបុព្វបុរសខ្មែរបានស្ថាបនាឡើងក្នុងបំណងអប់រំកូនចៅ។ ព្រោះ លោកដឹងថា ដើម្បីនិរន្តរភាពនៃជាតិសាសន៍ខ្មែរ គឺការអប់រំជាគន្លឹះមូលដ្ឋាន ដែលមិនអាចខ្វះបានសម្រាប់កុលបុត្រធីតានាថ្ងៃអនាគត។ ហេតុនេះហើយបុព្វបុរសខ្មែរខិតខំចងក្រងគម្ពីរ ដីកា ក្រឹត្យក្រមដ៏មានតំលៃឥតគណនា។ ឯកសារទាំងនោះមានលក្ខណៈពិសិដ្ឋដែលខ្មែរបុរាណឱ្យឈ្មោះថា ព្រះគម្ពីរ ឬព្រះសាស្ត្រានោះ ត្រូវគេចាត់ទុកជាវត្ថុសិរីមង្គល ដែលអាចធ្វើឱ្យជនជាតិខ្មែរក្លាយខ្លួនពីអ្នកមានអធិបតេយ្យភាពទៅជាអ្នកមានឫទ្ធានុភាពខ្លាំងពូកែ។ នៅក្នុងសម័យសង្គ្រាម សៀមដឹងយ៉ាងច្បាស់ណាស់ ដូច្នេះគម្ពីរ និងក្បួនខ្នាតត្រូវគេដុតបំផ្លាញចោល ឬលួចចម្លងទុកជាសម្បត្តិគេផ្ទាល់។ សៀមយល់ច្បាស់ អ្នកកាន់កាប់បាននូវរាល់ការចេះដឹង ខាងសិល្បសាស្ត្រ ក៏ដូចជាបច្ចេកទេសដែលកត់ត្រាក្នុងគម្ពីរ គឺអ្នកនោះជាអ្នកខ្លាំងពូកែ អ្នកឈ្នះមានប្រៀបលើអ្នកចាញ់។

មានក្បួនខ្នាតដែលជាបច្ចេកពាក្យសម្រាប់ស្ដេចត្រូវបង្គាប់ឱ្យហៅដូចក្នុងករណីរបស់ព្រះបរមរាជាពញាយ៉ាត កាលដែលទ្រង់បានធ្វើការរំដោះរាជធានីអង្គរពីកណ្ដាប់ដៃអយុធ្យា ហើយនិងព្រះបាទចន្ទរាជាកាលដែលមិនទាន់ច្បាំងឈ្នះស្ដេចកន ក្នុងករណីនេះត្រូវហៅថា គ្រងរាជ្យសម្បត្តិ។ ម្យ៉ាងទៀត ប្រសិនបើអភិសេកក្នុងពេលធ្វើសង្គ្រាមលោកឱ្យហៅថា សង្គ្រាមាភិសេក ហើយបើសិនអភិសេកក្នុងពេលបង្ក្រាបខ្មាំងសត្រូវឱ្យរាបទាបលោកឱ្យហៅថា ប្រាប្តាភិសេកទៅវិញ។

**ការអភិសេកក្សត្រឡើងសោយរាជ្យពេលញជាលក្ខណៈក្សត្រ លុះត្រាណាមានគ្រឿងសម្រាប់រាជ្យ គឺ៖**

មានព្រះខ័នរាជ្យ១
ព្រះលំពែងជ័យ១
និងគ្រឿងបញ្ចក្សេត្រ ដែលសុទ្ធសឹងជាទេវរូបសំខាន់ៗសម្រាប់រាជ្យ
មានឯកសារខ្លះ គេបានបញ្ចូលព្រះខ័នរាជ្យ ឬព្រះខ័នជ័យនេះទៅក្នុងចំណោមគ្រឿងបញ្ចក្សេត្រវិញ និងគ្រឿងដែលគេហៅថា រាជបញ្ចកុកុធភ័ណ្ឌ គឺ ៖

១-ព្រះម្កុដ
២-ព្រះវាលវីជនី(ផ្លិតធ្វើដោយរោមសត្វព័ណស)
៣-ព្រះខ័ន(មាស)
៤-ស្វេតច្ឆត្រ
៥-ព្រះសុវណ្ណបាទុកា (ឬ ព្រះសុពណ៌បាទ=ស្បែកជើងមាស)

ការបន្តរាជសម្បត្តិជាទូទៅ គេសង្កេតឃើញថា ត្រូវបន្តពីបិតាជាក្សត្រទ្រង់រាជ្យទៅបុត្រាច្បង។ បានសេចក្ដីថា នៅពេលដែលព្រះបិតាសោយទិវង្គតទៅ ឬក៏ដាក់រាជ្យ គឺបុត្រច្បងត្រូវមានសិទ្ធិឡើងសោយរាជ្យស្នង ហើយប្រសិនបើបុត្រច្បងត្រូវសុគតមុនរាជ្យបិតា គឺបុត្របន្ទាប់ក្លាយជាបេក្ខភាពមានសិទ្ធិសោយរាជ្យស្នងព្រះបិតា។ យើងឃើញ នារាយណ៍រាជា ឡើងសោយរាជ្យស្នងព្រះបរមរាជាទី២ ចៅពញាយ៉ាត ព្រះសត្ថាទី១ សោយរាជ្យស្នងព្រះបរមិន្ទរាជា។ ឯព្រះបរមិន្ទរាជា បានសោយរាជ្យស្នងពីព្រះចន្ទរាជា។ ព្រោះបុត្រច្បងនាមរាមាធិបតី បានសុគតមុនសោយរាជ្យ។

ក្នុងករណីដែលក្សត្រទ្រង់រាជ្យពុំមានបុត្រសោយរាជ្យស្នងទេ សិទ្ធិនេះត្រូវបានទៅព្រះអនុជជាបន្តបន្ទាប់គ្នា។ ព្រះចន្ទរាជា បានឡើងសោយរាជ្យជាតំណវង្សពីព្រះបាទស្រីសុគន្ធបទ។ ព្រោះរាជបុត្រក្សត្រអង្គនេះ គឺពញាយសរាជា បានសុគតមុនសោយរាជ្យ។ ប្រសិនបើមិនគោរពតាមទម្លាប់នេះទេ នោះវិបត្តិច្បាស់ជាកើតឡើងចៀសមិនបាន ដូចករណីរបស់ស្រីសុរិយោទ័យ ដែលត្រូវបានឡើងសោយរាជ្យស្នងព្រះបិតា គឺព្រះនារាយណ៍រាជា តែបែរជាបានទៅព្រះស្រីរាជាជាអនុជទៅវិញ។នោះហើយដែលជាហេតុនាំឱ្យមានចម្បាំងរវាងគ្នាឯងអស់រយៈពេលដប់ឆ្នាំ(១៤៧៥-១៤៨៥)។ ក្នុងករណីដែលបុគ្គលណាមួយ ទោះជាមន្ត្រីជាន់ខ្ពស់ក្ដី ទោះជាប់ព្រះញាតិនឹងក្សត្រទ្រង់រាជ្យក្ដី តែបើពុំមានសិទ្ធិទទួលរាជសម្បត្តិទេ ហើយបែរជាប្រើកម្លាំងអាវុធ ដើម្បីបានឡើងសោយរាជ្យនោះ គេឱ្យឈ្មោះហៅថាស្ដេចជ្រែករាជ្យ ករណីដូចជា ស្ដេចរាមាជើងព្រៃ។

ទាំងនេះ គឺទុកជាច្បាប់មួយរបស់ប្រទេស សម្រាប់មហាក្សត្រនៅពេលក្រោយៗមកទៀត។ ទោះបីជាយ៉ាងណា យើងឯកភាពជាមួយការអះអាងរបស់ប្រវត្តិវិទូ ម៉ៃឃើល វិកឃើរី ដែលថា នៅកម្ពុជាតាំងពីដើមរៀងមក មិន

បានកំណត់ច្បាប់រជ្ជទាយាទ ឱ្យបានច្បាស់លាស់នោះទេ។ ហើយបើយើងក្រឡេកត្រឡប់ក្រោយវិញ តាំងពីសម័យមុនអង្គរមករហូតដល់សតវត្សរ៍ទី១៦-១៧នេះ ឃើញថា រាជបល្ល័ង្កខ្មែរត្រូវបានផ្ទេរតាមរូបមន្តជាច្រើនបែបគឺ ៖

ពីឪពុកទៅកូន
ពីបង ឬប្អូនប្រុស ទៅប្អូន ឬបងប្រុស
ពីឪពុកមា ទៅក្មួយ ដែលជាបុត្រារបស់បង ឬប្អូនស្រីខ្លួន
ពីបង ឬប្អូនជីដូនមួយ ទៅប្អូន ឬបងជីដូនមួយ (ខ្សែខាងម្តាយ)
ពីជីតាមីង ទៅចៅមីង ដែលត្រូវជាកូនប្រុសនៃក្មួយស្រីដែលជាកូនស្រីរបស់បង ឬប្អូនស្រីខ្លួន
ពីឪពុកក្មេក ទៅកូនប្រសារប្រុស

ទំនងជា ដោយសារវិបាកបែបនេះហើយទើបក្នុងផ្ទៃរាជវាំង ឬរាជវង្សានុវង្សខ្មែរ តែងតែប្រណាំងប្រជែងដណ្តើមអំណាចគ្នាមិនចេះចប់។ ព្រោះ មានបេក្ខភាពប្រកបដោយនីតិសម្បទាធ្វើជាព្រះមហាក្សត្រច្រើនអង្គពេក។

## 3. ការកសាង និងការពង្រស់ទេវស្ថានបន្ទាយសត្រូវ និងវត្តអារាម

ព្រះបាទ ចន្ទរាជា យាងមកគង់នៅរាជវាំងលង្វែក ដែលជារាជវាំងថ្មី នៅរវាងឆ្នាំ១៥២៧។ ព្រះអង្គ ជាមហាក្សត្រដែលមានជំនឿលើព្រះពុទ្ធសាសនាយ៉ាងមុតមាំ។ ក្រៅពីវត្តអារាមជាច្រើនដែលទ្រង់បញ្ជាឱ្យសាងនៅពោធិ៍សាត់ និងបរិបូណ៌ ព្រះអង្គបានឱ្យសាង និងជួសជុលនៅឧដុង្គមានវត្តនៅលើភ្នំព្រះរាជទ្រព្យជាដើម(ព្រះពុទ្ធរូបចូលនិព្វាន) ព្រះអង្គបានឱ្យសាងវត្តត្រឡែងកែង នៅក្នុងបន្ទាយលង្វែកទៀត។ ក្នុងព្រះវិហារ មានតម្កល់ព្រះពុទ្ធរូបត្រឡែងកែង គឺព្រះពុទ្ធរូប៤អង្គគង់ឈរទល់ព្រះប្រឹស្ឋ (ខ្នង)នឹងគ្នា ហើយបែរព្រះភ័ក្រទៅទិសទាំងបួន។ ក្នុងសម័យនោះខ្មែរយើងចាត់ទុកជាព្រះពុទ្ធរូបត្រឡែងកែងនេះជាវត្ថុសក្តិសិទ្ធមួយដែរ។

មានលក្ខណៈពិសេសមួយ នៅរាល់ការវាយប្រហាររបស់សត្រូវ តែងជួបប្រទះឧបសគ្គជាច្រើន ដែលគេជឿថា បណ្តាលមកពីទេពរ័ក្ស រក្សាព្រះនគរដែលព្រះរាជាខ្មែរពីអតីតកាល ប្រតិស្ឋានទុក។ ហើយប្រការនេះ សូម្បីតែព្រះរាជាខ្មែរនៅពេលក្រោយៗមកទៀត ដែលមិនបានដឹង និងគោរពបូជា ក៏តែងតែទទួលការរំខាន ដោយបង្កើតជាឧបសគ្គផ្លូវងងឹតផងដែរ។ ទេពរ័ក្សទាំងអស់នោះ ត្រូវបានព្រះបាទចន្ទរាជា ពង្រស់នូវការគោរពបូជាឡើងវិញ ដើម្បីទុកជាសរណៈវត្ថុស័ក្តិសិទ្ធិក្នុងព្រះនគរ។

1- អ្នកតាភ្នំត្រៀល, (វត្តភ្នំត្រៀល) ដែលព្រះបាទចន្ទរាជាដូរឈ្មោះជា "ភ្នំចំពិត"វិញ
2- អ្នកតាភ្នំស្រង់ (វត្តភ្នំស្រង់) សម្រាប់ការពារសឹកសត្រូវវាយពីទិសខាងលិច និងខាងជើង
3- អ្នកតាវត្តព្រែកអំបិល នៅស្រុកស្អាង
4- អ្នកតាវត្តស្លាកែត នៅកៀនស្វាយ
5- អ្នកតាវត្តព្រះវិហារសួគ៌ នៅស្រុកខ្សាច់កណ្តាល សម្រាប់ការពារសឹកសត្រូវវាយពីទិសខាងត្បូង និងខាងកើត។

នៅកន្លែងទាំង៥នេះ ព្រះបាទពញាយ៉ាត ធ្លាប់ប្រសិទ្ធីបញ្ចុះព្រះអាទិទេពសំខាន់ៗមាន ព្រះទសមុខ៤អង្គ ព្រះឥសូរ, ព្រះនារាយណ៍ និងលោកយាយទេព ជាច្រើនអង្គ។ មកដល់រាជ្យព្រះបាទចន្ទរាជា ព្រះអង្គ បញ្ជាឱ្យគេធ្វើកឋិនហែរចូលវត្តទាំងនេះ ជារៀងរាល់ឆ្នាំ។

6- អ្នកតាឃ្លាំងមឿង នៅខេត្តពោធិ៍សាត់ (ដំបូកអ្នកមេនាងខៀវ, ដំបូកឃ្លាំងមឿង, ដំបូកក្រវាញ, និងកន្លែងដូនពេញ ឬ កោះដូនពេញ ដែលសុទ្ធសឹងជាដំបូកផ្ទុកប្រផ្នូលនៃប្រទេស)។
7- ព្រះត្រឡែងកែង នៅក្នុងវត្តវិហារហ្លួង កណ្ដាលបន្ទាយលង្វែក ដែលព្រះអង្គបានយកដុំថ្មធំស័ក្តិសិទ្ធិមួយដំធំនៅលើដើមឈើទាលធំមួយ មកឆ្លាក់ធ្វើព្រះបាទ និងដើមឈើទាលនោះមកឆ្លាក់ធ្វើព្រះពុទ្ធរូបឈរកម្ពស់៦ម៉ែត្រ។ សរណៈវត្តពីរកន្លែងនេះ ជាទេពរក្ស ដែលប្រតិស្ឋានដោយព្រះបាទចន្ទរាជា។ តាំងទីកន្លែងសំខាន់ដទៃទៀត មានដូចជា ៖
8- វត្តពោធិមានបុណ្យ នៅខេត្តពោធិ៍សាត់
9- បូជនីយដ្ឋានភ្នំព្រះធាតុ នៅខាងលិចលង្វែកចម្ងាយប្រមាណជិត៤០គីឡូម៉ែត្រ
10- ព្រះជ្រៃ នៅខេត្តកំពង់ឆ្នាំង
11- ប្រាសាទព្រះធាតុខ្វាវ ក្នុងអតីតខេត្តព្រំទេព ឬស្រុកសូទ្រនិគមភាគខាងជើងសព្វថ្ងៃ
12- ភ្នំសន្ទុក ខេត្តកំពង់ធំ
13- វត្តសរសៃមួយរយ ស្រុកសំបូរណ៍ ខេត្តក្រចេះ
14- អ្នកតាមេសរ នៅបាភ្នំ
15- ភ្នំក្បោកមាសនៅស្ទឹងត្រែង ត្រើយខាងលិចនាទន្លេមេគង្គ

លើសពីនេះទៀត អតីតបន្ទាយកងទ័ពជាច្រើនកន្លែងរបស់ព្រះអង្គ ដែលមានទីតាំងនៅតាមរយៈផ្លូវភាគខាងលិចបឹងទន្លេសាប នៅពេលព្រះអង្គចល័តកងទ័ពវាយប្រហារដណ្ដើមយកទឹកដីពីស្ដេចកន ឬព្រះស្រីជេដ្ឋាវិញ ព្រះបាទចន្ទរាជា បានបញ្ជាឱ្យគេកសាងជាវត្តអារាម ដែលមានវិហារប្រក់ស្បូវ និងនិមន្តព្រះសង្ឃមកគង់នៅចាំវស្សាតជាប់មករហូតដល់សព្វថ្ងៃ។

ស្ដេចទី២ នៃគ្រួសាររាជវង្សថៃ ក្នុងទីក្រុងអយុធ្យាមានឈ្មោះថា នរេសួន/នរេស ខ្លះថា នរេសូរ។ព្រះអង្គជាស្ដេចល្មោភសង្គ្រាម។ ដំបូងព្រះអង្គច្បាំងជាមួយភូមា ដើម្បីរំដោះអយុធ្យាឱ្យមានឯករាជ្យឡើងវិញ។ បន្ទាប់មកព្រះអង្គវាយលុកមួយផ្នែកផ្សេងទៀតនៃប្រទេសថៃ ហើយនៅឆ្នាំ១៥៩៣-៩៤ ព្រះអង្គបានវាយបំផ្លាញរាជធានីលង្វែករបស់ខ្មែរ។ គួរកត់សម្គាល់ថា ស្ដេចនរេសួន មិនចាប់អារម្មណ៍លើក្រុងអង្គរទេ។ សង្គ្រាមដំបូងៗរវាងអយុធ្យាជាមួយកម្ពុជា គឺអយុធ្យាចង់ដណ្ដើមកាន់កាប់រាជធានីបុរាណ ព្រោះគេគិតថា អង្គរជារាជធានីដើមរបស់គេដែរ។ ផ្ទុយទៅវិញទ្រង់ នរេសួន ជាស្ដេចសុខោទ័យពុំមានពាក់ព័ន្ធប្រពៃណីអង្គរទេ ដោយចាប់អារម្មណ៍ត្រឹមតែការត្រួតត្រានយោបាយ នៅភាគខាងត្បូងកម្ពុជាដែលជាប់នឹងសមុទ្រ។ ពេលស្ដេចនរេសួន វាយលង្វែកនៅក្នុងឆ្នាំ១៥៨៧ គឺជាការប៉ុនប៉ងដណ្ដើមកាន់កាប់លើកដំបូង មិនអាចយកលង្វែកបានទេ។ ដោយហេតុថា បន្ទាយលង្វែកមានរបងឫស្សីយ៉ាងក្រាស់ការពារ ហើយនរេសួន ក៏ថយទៅរាជវាំងវិញ ហើយបានចាត់ឱ្យស៊ើបសួរអំពីបញ្ហាខាងក្នុងរាជវាំងលង្វែកនោះ ដឹងថា ក្រៅអំពីរបងឫស្សីដែលព័ទ្ធខាងក្រៅដ៏មាំនេះ នៅក្នុងប្រទេសមានទេវរក្ស១៣អង្គ ជួយថែរក្សាការពារប្រទេសតាមក្បួនអបិយជំនឿ ដែលគេជឿថា អ្នកតាទាំងនោះអាចកាច់ព្រលឹងទ័ពបរទេសឈ្លានពានឱ្យមានការភ័យខ្លាច និងមានជំងឺតម្កាត់ផ្សេងៗមិនអាចមានឆន្ទៈ និងស្មារតីពេញលេញនៅក្នុងបេសកកម្មរបស់ខ្លួន។ ហេតុនោះហើយ ទើបមុននឹងដកថយទៅ សេៈចសៀមប្រើឧបាយកលបាញ់ប្រាក់ដួងជាច្រើនចូលក្នុងគុម្ពឫស្សី ដែលជារបងមាំមួនជាទីបំផុតរបស់បន្ទាយ។ ក្រោយមកក៏ចាត់ឱ្យមានចារបុរសសៀមពីររូបក្លែងខ្លួនធ្វើព្រះសង្ឃ ប្រើល្បិចឱ្យមេដឹកនាំខ្មែរទុកចិត្ត ហើយឱ្យចូលបំពេញការងារខាងមន្តអាគមនៅក្នុងបន្ទាយបំផ្លាញទេវរូប និងទេវស្ថាន ហើយស្លង់កាណុងកាំភ្លើងធំសម្រាប់ការពារបន្ទាយ។ ពេលស្ដេចនរេសួន លើកទ័ពឈ្លានពានជាលើកទី២ក៏អាចដណ្ដើមជោគជ័យលើខ្មែរបាននៅឆ្នាំ១៥៩៣។

## 4. ទំនាក់ទំនងជាមួយជនជាតិអឺរ៉ុប

លោក ហ្គាស្ប៉ាដាក្រុស គឺជាបេសកបុព្វជិតផ្សាយគ្រិស្តសាសនានិកាយដូមីនីកាំងជនជាតិព័រទុយហ្គាល់ដំបូងគេ ដែលបានមកដល់លង្វែកនាចន្លោះឆ្នាំ១៥៥៥-៧ ក្នុងរាជ្យព្រះបាទចន្ទរាជា និងបានបន្សល់ទុកកំណត់ត្រាមួយចំនួនស្តីពីកម្ពុជា។ បន្ទាប់មកទើបមានកំណត់ហេតុរបស់បព្វជិត Gabriel de San Antonio ឱ្យដឹងថាព្រះបាទបរមរាជាទី៤ ទ្រង់ឈ្វេងយល់ថា សកម្មភាពខាងជំនួញនឹងកើតមានឡើង បន្ទាប់ពីមានការមកដល់របស់ពួកបព្វជិត។ ព្រះអង្គទ្រង់បានអំពាវនាវ សុំឱ្យអង្គការពាណិជ្ជកម្មកណ្តាលនៅ Malacca បញ្ជូនអ្នកផ្សាយសាសនាមកកាន់ប្រទេសខ្មែរ។ ដោយហេតុនេះហើយ ទើបមានបព្វជិតពីរអង្គ បាននិមន្តមកកាន់ប្រទេសខ្មែរ គឺបព្វជិតឈ្មោះលោក Lapo Cardoso និង Joao Madeira គេពុំដឹងថា បព្វជិតទាំងពីរអង្គនេះ និមន្តមកតាំងពីឆ្នាំណាទេ បើតាមហេតុការណ៍នៅពេលតមកទៀតនោះ ប្រហែលបព្វជិតទាំងពីរអង្គ មកដល់លង្វែកមុនគ្រិស្តសករាជ១៥៧០។

មានអ្នកនិពន្ធជាតិអឺរ៉ុបជាច្រើនបានអះអាងថា នៅគ.ស១៥៧០ អ្នកផ្សព្វផ្សាយសាសនាព័រទុយហ្គាល់ម្នាក់បានរកឃើញប្រាសាទអង្គរ ហើយបានកត់ទុកកំណត់ហេតុរបស់លោក។ គេមិនបានបញ្ជាក់ពីឈ្មោះអ្នកផ្សាយសាសនារូបនោះទេ តាមស្មានប្រហែលមានតែបព្វជិត Cardoso និង Madeira ប៉ុណ្ណោះ។

ដោយហេតុថា វត្តមានរបស់អ្នកផ្សាយសាសនាពុំបានញុំាងជំនួញឱ្យមានសកម្មភាពដូចបំណងរបស់ព្រះអង្គនោះ ព្រះរាជាក៏ទ្រង់ចាប់ផ្តើមធ្វើទុកបុកម្នេញលើរូបពួកបព្វជិត។ មានបព្វជិតមួយរូបទៀតឈ្មោះ Sylvestre d'Acevedo បានមកជំនួស Madeira ឯបព្វជិត Cardoso ក៏ត្រូវត្រឡប់ទៅវិញ។ បន្ទាប់មកមានបព្វជិតពីរអង្គទៀតបាននិមន្តមកដល់ តែគង់មិនយូរប៉ុន្មានក៏វិលត្រឡប់ទៅវិញទៀត។ ក្នុងរយៈពេលយ៉ាងយូរបព្វជិត Sylvestre d'Acevedoដែលបានស្ថិតនៅប្រទេសខ្មែរ ពុំបានផ្សាយសាសនាគ្រិស្តឱ្យជ្រួតជ្រាបក្នុងសង្គមខ្មែរបានឡើយ ។

ប្រភពពីអឺរ៉ុបថា ព្រះសត្ថាទី១ ជាក្សត្រទន់ខ្សោយ ជានិច្ចកាលទ្រង់ប្រណែននឹងព្រះអនុជរបស់ខ្លួនគឺព្រះស្រីសុរិយោពម៌។ ហេតុនេះព្រះអង្គត្រូវការប្រឆាំងនឹងសត្រូវទាំងខាងក្នុង និងខាងក្រៅ ព្រះអង្គទ្រង់យកចិត្តទុកដាក់លើពួកផ្សព្វផ្សាយគ្រិស្តសាសនាយ៉ាងខ្លាំង។ ព្រះសត្ថា បើកសិទ្ធិឱ្យអ្នកផ្សាយគ្រិស្តសាសនាទាំងនេះ សង់ព្រះវិហារនៅគ្រប់ទីកន្លែងក្នុងព្រះរាជាអាណាចក្រ។ បន្ថែមលើនេះព្រះអង្គជួយឧបត្ថម្ភពួកនេះនូវអង្គ និងវត្ថុផ្សេងៗទៀតឱ្យទៅអង្គការសាសនានៅម៉ាឡាកា។ នៅគ.ស១៥៨៥ គេបានបញ្ជូនមកបន្ថែមបព្វជិតសាសនាពីរអង្គទៀត គឺ Antonio Dorta និងបព្វជិត Antonio Caldeira ។ នៅពេលតំណាលគ្នានោះដែរ មានបព្វជិតខាងគណៈហ្វ្រង់ស៊ីស្កាំង (Françiscain)ក៏បានមកដល់ប្រទេសខ្មែរដែរ ក្នុងចំណោមនោះមានបុព្វជិតនាម Gregorio Ruiz តែដោយមានការធ្វើទុកបុកម្នេញកើតឡើងជាថ្មីទៀតនោះ បព្វជិតទាំងពីរអង្គខាងក្រោយនោះក៏និមន្តត្រឡប់ទៅវិញអស់ ។ ពេលនោះបព្វជិត Sylvestre បានប្រើឥទ្ធិពលរបស់លោក ហើយព្រះសត្ថា ក៏ទ្រង់អនុញ្ញាតនៅគ.ស១៥៨៩ ថា បព្វជិតអង្គណាក៏ដោយ អាចផ្សព្វផ្សាយសាសនាបាននៅគ្រប់ទីកន្លែងក្នុងប្រទេសខ្មែរ ហើយជនជាតិខ្មែរណាក៏ដោយក៏អាចកាន់សាសនាថ្មីនេះបានដោយគ្មានខ្លាចពីការសងសឹកឡើយ ។ ដោយហេតុនេះបព្វជិតSylvestre ក៏បានសុំឱ្យអង្គការកណ្តាលបញ្ជូនបព្វជិតមកជាបន្ថែម ។ ឆ្លើយតបសេចក្តីអំពាវនាវនេះបព្វជិតមានបុព្វជិតពីរអង្គទៀតត្រូវបានបញ្ជូនមក ។ គួរជ្រាបថា នៅគ្រានោះមិនគ្រាន់តែមានបព្វជិតទេមានអ្នកផ្សងព្រេងខ្លះក៏បានមកដល់ប្រទេសខ្មែរក្នុងពេលជាមួយគ្នាដែរ ។

នៅគស១៥៨៥ ព័រទុយហ្គាល់ដែលមានវ័យក្មេងឈ្មោះ Diogo Velosoបានមកដល់ប្រទេសខ្មែរជាមួយបក្សពួកមួយក្រុម។ នៅដើមឆ្នាំ១៥៩៣ អ្នកផ្សងព្រេងជាតិអេស្ប៉ាញក៏បានមកដល់ គឺលោក Ruiz de ernan

Gonzalès និង Vargas Machuca ។ ពួកអ្នកផ្សងព្រេងទាំងនេះត្រូវបានព្រះសត្ថាទី១ ស្រឡាញ់រាប់អានយ៉ាងខ្លាំង ហើយពួកនេះក៏ជាប់ជំពាក់ចិត្តយ៉ាងខ្លាំងជាមួយព្រះអង្គវិញផងដែរ។ គួរគប្បីជ្រាបថា ជនជាតិអេស្ប៉ាញ ជាជនជាតិអឺរ៉ុបដែលបានមកកាន់អាស៊ីអាគ្នេយ៍បន្ទាប់ពីពួកព័រទុយហ្គាល់។ ពួកនេះបានបញ្ចុះបញ្ចូលឱ្យព្រះមហាក្សត្រខ្មែរទាក់ទងសុំជំនួយពីមេដឹកនាំយោធារបស់គេនៅម៉ានីល។ នៅពេលលង្វែកទទួលការគំរាមកំហែងខ្លាំងស្តេចខ្មែរ បានប្រើប្រាស់ Veloso និង Ruiz ឱ្យទៅសុំជំនួយពីចៅហ្វាយក្រុងម៉ានីល ជាថ្នូរនឹងការការសន្យាកាន់សាសនាគ្រិស្តរបស់ព្រះអង្គ និងស្បៀងអាហារជាច្រើន។ តែបេសកជនពីរនាក់នេះត្រូវកងទ័ពជើងទឹកសៀមចាប់បានដោយចៃដន្យ ទើបមិនអាចជួយស្រោចស្រង់ព្រះសត្ថាទី១បានទាន់សភាពការណ៍។ ទម្រាំតែសៀមដោះលែងពួកគេវិញ បន្ទាយលង្វែកត្រូវបែកបាក់អស់ ហើយចៅហ្វាយក្រុងម៉ានីលក៏មិនបានផ្តល់ជំនួយដែរ នៅពេលត្រឡប់មកដល់ស្រុកខ្មែរវិញ ស្តេចខ្មែរបាននិរទេសខ្លួនទៅដល់ស្រុកឡាវបាត់ទៅហើយ។ ដោយភក្តីភាព ពួកគេបាននាំស្ន័គ្របក្សពួក ធ្វើដំណើរទៅតាម និងនាំយកបុត្រាដែលនៅគង់ព្រះជន្មនៅឡើយត្រឡប់មកពីស្រុកឡាវវិញ។ ប៉ុន្តែ មុននឹងពួកគេទៅដល់ទីនោះបានវាយប្រហារមួយឈុតសម្លាប់ស្តេចរាមជើងព្រៃ ដែលជាអ្នកវាយរំដោះក្រុងលង្វែកពីដៃសៀម និងដែលបានឡើងសោយរាជ្យខ្លួនឯង ដោយតាំងរាជវាំងនៅស្រីសន្ធរ។

ចាប់ពីសតវត្សរ៍ទី១៧តទៅ ខ្មែរបានទាក់ទងជាមួយជនជាតិអឺរ៉ុបថ្មីៗទៀត ជាពិសេសជនជាតិហុល្លង់ដ៍។ ផ្ទុយពីពួកព័រទុយហ្គាល់ និងអេស្ប៉ាញដែលមានបំណងធំនៅក្នុងការផ្សាយសាសនានៅអាស៊ី ពួកហុល្លង់ដ៍ធ្វើសកម្មភាពតែក្នុងវិស័យជំនួញ។ ចាប់ពីគ.ស.១៥៩៥ ពួកនេះបានផ្តើមធ្វើប្រតិបត្តិការសឹកឆ្ពោះទៅកោះជ្វា ហើយបន្ទាប់មកបានដណ្តើមយកពីពួកព័រទុយហ្គាល់ និងអេស្ប៉ាញនូវអាណានិគមទាំងអស់លើកលែងតែ Macao ចេញ ហើយបានបង្កើតគ្រឹះស្ថានជំនួញនៅប្រទេសឥណ្ឌា នៅកោះសេរីលង្កា នៅ Malacca នៅប្រទេសសៀម និងនៅប្រទេសជប៉ុន។

នៅក្រោយពេលព្រះបាទជយជេដ្ឋាទី២ ចូលទិវង្គត ព្រះអនុជរបស់ព្រះអង្គនាម ឧទយរាជា បានក្លាយទៅជាអ្នកមានអំណាចធំនៅកម្ពុជា។ ស្តេចអង្គនេះ ប្រើប្រាស់កម្លាំងប្រដាប់អាវុធជនជាតិប៉័រទុយហ្គេ ធ្វើជាអង្គរក្សផ្ទាល់ព្រះអង្គ។ ក្រុមអង្គរក្សនោះហើយ ដែលបានតាមប្រមាញ់ព្រះបាទធម្មរាជាព្រះរាជសម្ភារ ដោយបាញ់ព្រះអង្គទម្លាក់ពីចុងត្នោតនៅម្តុំក្បែរវត្តសសរមួយរយ ក្នុងស្រុកសំបូរណ៍ខេត្តក្រចេះ។ ពីព្រោះតែស្តេចអង្គនេះ បានសាហាយស្មន់ជាមួយ មហេសីស្តេចមា-ឧទយរាជា ព្រះនាម ព្រះម៉េយួរ បុប្ផាវតី ដែលជាអតីតគូរដណ្តឹង។

## 5. **សង្គ្រាមជាមួយសៀម និងឡាវ**

ក្រោយពីព្រះចន្ទរាជា សម្ពោធរាជធានីថ្មីនៅលង្វែករួចរាល់ហើយ ស្តេចក្រុងអយុធ្យា បានចាប់ផ្តើមធ្វើសង្គ្រាមឈ្លានពាន ដើម្បីបង្ក្រាបការរឹងទទឹងរបស់ព្រះអង្គ ដែលមិនចំណុះក្រុងអយុធ្យា ជាអ្នកធ្លាប់មានអ្វីដែលគេហៅថា សារគុណចំពោះព្រះអង្គ។ នៅឆ្នាំ១៥៣០ បើតាមពង្សាវតារឧកញ្ញាវាំង ជួន ស្តេចអយុធ្យាបានបញ្ជាឱ្យកងទ័ពខ្លួន លុកលុយកម្ពុជានៅខេត្តមហានគរ ឬសៀមរាបសព្វថ្ងៃ ដើម្បីជាការបង្ក្រាបចំពោះភាពមិនចុះញ៉មរបស់ព្រះបាទចន្ទរាជា។ ទ័ពសៀមបាន ដណ្តើមកាន់កាប់តំបន់ប្រាសាទអង្គរមួយរយៈពេល ហើយមេដឹកនាំបានទស្សនាប្រាសាទទាំងនោះប្រកបដោយការកោតស្ញប់ស្ញែង។ បន្ទាប់មក ទ័ពស្តេចសៀមនេះ បានពើបប្រយុទ្ធគ្នាជាមួយកងទ័ពព្រះបាទចន្ទរាជា។ ទ័ពសៀមត្រូវផ្ចាញ់ឱ្យបរាជ័យយ៉ាងធ្ងន់ធ្ងរ នៅតំបន់អង្គរ។ មានសត្រាខ្លះថា ដោយហេតុនោះហើយទើបស្តេចខ្មែរអង្គនេះ បានបញ្ញត្តិឱ្យផ្លូវឈ្មោះខេត្តមហានគរនេះ ដាក់ឈ្មោះជា"ខេត្តសៀមរាប"វិញ ដែលមានន័យថា "ទ័ពសៀមត្រូវបង្ក្រាបឱ្យរាប"នៅទីនោះ។ នៅឆ្នាំ១៥៣៦ ដែលត្រូវនឹងឆ្នាំរកអដ្ឋស័ក បើតាមព្រះរាជ

ពង្សាវតារភាគ៣គ៥៣-៣ បានឱ្យដឹងថា ស្តេចអយុធ្យាបានប្រើបុត្រារបស់ព្រះបាទស្រីរាជា នាមពញាអុងរាជា ដែលត្រូវជាបុត្រាធម៌ ឱ្យលើកទ័ពមកកំចាត់ព្រះបាទចន្ទរាជា ដែលជាព្រះអនុជដ៏ដូនមួយរបស់ខ្លួន។ ក្នុងសង្គ្រាមនោះ ពញាអុងត្រូវព្រះអង្គចន្ទរាជាចាក់សម្លាប់ចោលនៅលើខ្នងដំរី នាពេលប្រយុទ្ធគ្នានៅវាលព្រះម្លូ ខេត្តពោធិសាត់។ រីឯកងទ័ពជើងទឹក បានមកពើបប្រយុទ្ធគ្នានៅក្នុងខេត្តកំពត កងទ័ពខ្មែរដែលដឹកនាំដោយចៅពញាពិស្ណុលោក និងចៅពញាអធិកវង្សា បានយកជ័យជម្នះលើកងទ័ពអយុធ្យា ដែលដឹកនាំដោយពញាយោមរាជ។

ក្រោយពីព្រះចន្ទរាជាសោយទិវង្គតទៅនៅឆ្នាំ១៥៦៦ រាជបុត្រទី២ដែលជាព្រះមហាឧបរាជ គឺព្រះបរមិន្ទរាជា ឡើងស្នងរាជជំនួសព្រះបិតា ដោយមាននាមសម្រាប់រាជ្យថា ព្រះសម្តេចព្រះបរមិន្ទរាជាធិរាជរាមាធិបតី (១៥៦៦-១៥៧៩)។ នៅក្នុងរាជ្យព្រះអង្គ កម្ពុជាជាប្រទេសមានឫទ្ធិអំណាចខ្លាំង កងទ័ពខ្មែរវាយដណ្តើមយកបានអាណាខេត្តខាងលិច និងខេត្តភាគខាងជើងជួរភ្នំដងរែកបានមកវិញ។ ព្រះបាទបរមិន្ទរាជា បានលើកទ័ពប្រមាណ២០ ០០០នាក់ ចូលវាយក្រុងស្រីអយុធ្យាលើកចូលបានមកដល់ជាយក្រុង ដោយសេនាវេហ៍ពល មេទ័ពស្លាប់ច្រើននោះ ទ័ពខ្មែរក៏ត្រឡប់មកកៀរមនុស្សនៅខេត្តតាមផ្លូវជាឈ្លើយអស់ជាច្រើន។ ឆ្លៀតឱកាសដែលភូមាទើបនឹងវាយយកទីក្រុងអយុធ្យា ខ្មែរបានលើកទ័ពចូលវាយលុកយកបានខេត្តនគររាជសីមា ហើយដាក់មន្ត្រីខ្មែរឱ្យនៅឈរត្រួតត្រាទីនោះ។

ស្តេចបរមិន្ទរាជា ព្រះអង្គជាស្តេចដែលពូកែខាងជល់ដំរីផងដែរ។ រាជពង្សាវតារខ្មែរ បានលើកឡើងថា នៅឆ្នាំ១៥៧២ ស្តេចលាវនគរ-លានជាង ទ្រង់ត្រាស់បញ្ជាឱ្យនាម៉ឺន២នាក់ និងពល១០០០នាក់ មកបបួលខ្មែរប្រជល់ដំរីដាក់នគរ គឺថាបើដំរីនៃនគរណាចាញ់ នគរនោះត្រូវចំណុះនគរម្ខាងទៀតដែលមានដំរីឈ្នះ។ កាលនោះ ព្រះបរមិន្ទរាជាក៏យល់ព្រមតាមសំណើររបស់លាវ។ ទោះដំរីលាវមានទំហំ និងកំពស់ខ្ពស់ជាងដំរីខ្មែរយ៉ាងណា ក៏នៅតែមិនអាចឈ្នះដំរីខ្មែរបានឡើយ។ រឿងនេះបានធ្វើឱ្យស្តេចលាវខ្ញាល់ ក៏បញ្ជាឱ្យលើកទ័ពចូលវាយខ្មែរទាំងផ្លូវគោក និងទាំងផ្លូវទឹកតាមដងទន្លេមេគង្គ។ ទ័ពលាវចូលវាយ និងចាប់ខ្មែរជាឈ្លើយបានជាច្រើនសមរភូមិភាគខាងជើង។ តែទីបញ្ចប់ស្តេចលាវត្រូវចាញ់ដៃខ្មែរវិញ។ ខ្មែរចាប់ទ័ពលាវធ្វើជាឈ្លើយ ហើយចាត់ចែងឱ្យលាវ១០០០នាក់រស់នៅក្នុងខេត្តបារាយណ៍ សល់ពីនេះឱ្យទៅនៅខេត្តខាងត្បូង និងខាងលិច។ ខាងជើងទឹក ខ្មែរមានជ័យជំនះលើទ័ពលាវនៅសមរភូមិលើដងទន្លេមេគង្គក្នុងខេត្តកំពង់ចាមសព្វថ្ងៃ។ ព្រះបរមិន្ទរាជា ទ្រង់យាងមកលង្វែកវិញ ទ្រង់ចាត់ឱ្យធ្វើបុណ្យឆ្លងជោគជ័យ ហើយបែងចែកឱ្យលាវ៨០០នាក់ទៅនៅស្រុកបាភ្នំ, ឱ្យ៥០០នាក់ទៅនៅសម្រាប់ថែរក្សាវត្តភ្នំពេញ ដែលតម្រូវឱ្យតាំងលំនៅដ្ឋានម្តុំសាលាបាក់ទូកសព្វថ្ងៃ។ ពួកលាវនេះខ្មែរហៅថាលាវបាក់ទូក។ ទំនងដោយសារវត្តមានពួកនេះហើយ ទើបស្ថាននាមបាក់ទូកនៅរក្សារហូតដល់សព្វថ្ងៃ នៅពេលគេយកទៅដាក់ឈ្មោះឱ្យសាលារៀនមួយនៅក្បែរនោះ។

លាវបម្រុងសងសឹកខ្មែរវិញ ប៉ុន្តែគាប់ជួនភូមានាំសៀមចូលវាយលុករៀងចន្ទ នៅគ.ស១៥៧៤ ដោយមានភ្លៀងធ្លាក់ខ្លាំងផង ទ័ពលាវដកថយទៅវិញអស់។ ត្រង់នេះមានពង្សាវតារខ្លះ ថាលាវចាញ់ខ្មែរទៀត ឯឧបរាជបានរត់រួចចូលទៅស្រុកវិញ។ព្រះបរមិន្ទរាជា សុគតនៅគស១៥៧៦ ឯកសារខ្លះទៀតថាឆ្នាំ១៥៧៩ រីឯឯកសារសៀមថានៅគ.ស១៥៧៤ គឺតាំងពីកាលដែលព្រះអង្គលើកទ័ពទៅវាយអយុធ្យាម្ល៉េះ។ ព្រះអង្គមានរាជបុត្រទាំងអស់៤ព្រះអង្គ គឺ ៖ ១-ព្រះសត្ថា, ២-ព្រះស្រីសុរិយោពម៌, ៣-ពញានូ និង ៤-ចៅពញាអន ។

នៅរាជ្យរបស់ព្រះសត្ថាទី១ បន្ទាយលង្វែកត្រូវទទួលនូវការលុកលុយពីសំណាក់ប្រទេសសៀមពីរលើក។ នៅពេលសៀមវាយលង្វែកទាំងពីរលើកនោះ ព្រះស្រីសុរិយោពម៌ បានខិតខំទប់ទល់អស់ពីសមត្ថភាព។ នៅឆ្នាំ១៥៨៧

សៀមបានលើកទ័ពចូលមកវាយខ្មែរ យកបានស្រុកបាត់ដំបង និងពោធិ៍សាត់ វាយយកបានបន្ទាយមានជ័យ និងបន្ទាយបរិបូណ៌ទៀត។ ព្រះមហាឧបរាជ ស្រីសុរិយោពម៌ នាំទ័ពចូលក្នុងបន្ទាយលង្វែកវិញ។ ទោះបីទ័ពសៀមមានចំនួនច្រើនសន្ធឹកសន្ធាប់យ៉ាងណាក៏ដោយ ក៏សៀមមិនអាចវាយបន្ទាយលង្វែកឱ្យបាននៅលើកទី១ដែរ។ នៅពេលសៀមវាយលង្វែក លើកទី២ នៅគស១៥៩៣ ព្រះនរេសួន បានលើកទ័ពមកបីផ្លូវ។ ខ្មែរលើកទ័ពចេញទៅតទល់ តែលើកនេះក៏ដូចជាលើកមុន សៀមវាយយកបានជាបន្តបន្ទាប់គ្នានូវ បន្ទាយពោធិ៍សាត់ និងបន្ទាយបរិបូណ៌។ ទ័ពខ្មែរបរាជ័យគ្រប់ផ្នែក ទាំងជើងទឹកក៏មិនអាចយកជ័យបាន ព្រះស្រីសុរិយោពម៌ ក៏ថយមកបន្ទាយរលាប្អៀរ ហើយសុំជំនួយពីលង្វែក។ ព្រះមហាឧបរាជ ស្រីសុរិយោពម៌បានប្រមូលស្បៀងចូលក្នុងបន្ទាយលង្វែក ដើម្បីការពារខ្លួនសិនរង់ចាំទ័ពជំនួយពីតាមខេត្ត។ ទ័ពសៀមក៏លើកមកតាមព័ទ្ធបន្ទាយនេះទៀត។ លុះទ័ពសៀមជិតមកដល់ ព្រះសត្ថាទី១ នាំរាជបុត្រនាម ជយជេដ្ឋា? និងចៅពញាតន់ភៀសទៅគង់នៅស្រីសន្ធរ។ ក្រោយមកភៀសទៅគង់នៅស្ទឹងត្រែង ហើយនៅទីបំផុតទៅដល់វៀងចន្ទ ដែលជារាជធានីរបស់ប្រទេសលាវ ជាមួយរាជបុត្រច្បង?។

ចំណែកព្រះស្រីសុរិយោពម៌ បានស្ថិតនៅក្នុងបន្ទាយលង្វែកដើម្បីប្រយុទ្ធនឹងសត្រូវ។ តែទោះជាព្រះអង្គខិតខំការពារបន្ទាយយ៉ាងស្វិតស្វាញយ៉ាងណាក៏ដោយ ក៏បន្ទាយត្រូវធ្លាក់នៅក្នុងកណ្ដាប់ដៃសត្រូវ ក្រោយពីត្រូវឡោមព័ទ្ធអស់រយៈពេល៣ខែ។ ម្យ៉ាងទៀត ក៏មកពីដើមឫស្សីដ៏សែនក្រាស់ដែលបានដាំធ្វើជាកំពែងនោះ ត្រូវគេកាប់ឆ្ការអស់ ដើម្បីរើសប្រាក់ដួង។ សៀមចាប់ព្រះមហាឧបរាជ ស្រីសុរិយោពម៌ និងបុត្រទាំងពីរ គឺព្រះជយជេដ្ឋាទី២(ព្រះជន្ម១៥វស្សា) និងព្រះឧទ័យ(ព្រះជន្ម៥វស្សា)នាំយកទៅឃុំទុកនៅប្រទេសសៀម។

## 6. សន្ធិសញ្ញាមិត្តភាពជាមួយសៀម លើកដំបូង

តាមប្រភពប្រវត្តិសាស្ត្រប្រទេសថៃ មិនដែលមានបញ្ជាក់អំពីសន្ធិសញ្ញាមិត្តភាពរវាងសៀម និងខ្មែរឡើយ។ ប៉ុន្តែ ប្រភពរាជពង្សាវតារខ្មែរវិញ មានបញ្ជាក់អំពីព្រឹត្តិការណ៍ដ៏សំខាន់នេះស្ទើរតែគ្រប់ច្បាប់។ នៅពេលកំពុងស្តារប្រទេសឡើងវិញ បន្ទាប់ពីការលើកបន្ទុបរបស់ស្តេចភូមានៃរាជវង្សហង្សាវតី, រាជវង្សសុខោទ័យនៅអយុធ្យា មិនអាចប្រឈមមុខនឹងការវាយលុកន្លើនរបស់ព្រះបាទបរមិន្ទរាជាបាន ទើបសុំចរចាចងមិត្តភាពជាមួយលង្វែក ហើយយល់ព្រមទទួលស្គាល់ទឹកដីរបស់កម្ពុជាជាប្រពៃណីពីមុនមក ដោយមានទាំងរៀបចំគណៈកម្មការចម្រុះបោះបង្គោលខ័ណ្ឌសីមាកំណត់ដែនដីនៃប្រទេសទាំងពីរទៀតផង ក្រោមអធិបតីភាពព្រះសង្ឃជាន់ខ្ពស់នៃប្រទេសទាំងពីរ។ តាមឯកសារខ្លះ ថា ត្រង់ខ្សែបន្ទាត់ព្រំដែននោះ គ្មានដើមឈើដុះឡើយ ហើយញែកព្រៃនៃប្រទេសទាំងពីរឱ្យបែកចេញពីគ្នា។ ព្រៃខាងដីខ្មែរ ទោរមកខាងខ្មែរ ព្រៃខាងសៀមទ្រេតទៅខាងអយុធ្យា។ ត្រង់នោះគេហៅថា ព្រៃញែក ដែលគេជឿថា មានទីតាំងស្ថិតនៅក្បែរខាងកើតក្រុងបាងកកសព្វថ្ងៃ។

**ទាក់ទងនឹងសន្ធិសញ្ញានេះ បើតាមច្បាប់ពង្សាវតាររបស់លោក វាំង ជួន សរសេរថា ៖**

"ថ្ងៃ៥កើត ខែបឋមាសាឍ ឆ្នាំជូតអដ្ឋស័ក ម៉ោង៧ព្រឹក[54] ទ្រង់ឱ្យសេនាបតីមន្ត្រីធំតូចតែងខ្លួនពេញយសស័ក្តិចូលគាល់ ឱ្យលួងទិព្វសេនាតូចនាំរាជទូតនិងឧបទូតសៀមចូលគាល់ និងសេនាបតីរាជទូតសៀម ក៏ថ្វាយព្រះរាជសារ និងគ្រឿងបណ្ណាការទ្រង់ទទួលហើយឱ្យទិព្វចិន្តា"សោម" សូត្រព្រះរាជសារថ្វាយសេចក្តីថា ព្រះរាជសារព្រះបាទសម្តេចព្រះមហាធម្មរាជា។ ព្រះចៅក្រុងជាពវត្តិស្រីអយុធ្យាជាព្រះជេដ្ឋាធិរាជ សូមចម្រើនផ្លូវព្រះរាជមេត្រី មក

[54] កាលបរិច្ឆេទនេះត្រូវនឹងឆ្នាំ១៥៧៥ ដែលត្រូវគ្នានឹងសៀវភៅលោក ត្រឹង ងា តែមានឯកសារផ្សេងៗទៀត បានដាក់កាលបរិច្ឆេទនៃសន្ធិសញ្ញានេះខុសៗពីគ្នាដែរ គឺឆ្នាំ១៥៧៦(អ៊ិន ឱមសាម៉េង) និងឆ្នាំ១៥៧៧ (ឃីន សុខ)។

សម្តេចព្រះបរមិន្ទរាជាធិរាជរាមធិបតីបានជ្រាប ត្បិតក្រុងកម្ពុជាធិបតី និងក្រុងធារាវត្តីស្រីអយុធ្យា តាំងពីបូរាណរាជរៀងមក ធ្លាប់សម្ព័ន្ធមិត្តជាប់ជិតដែនដីជាមួយគ្នា ក៏យើងទាំងពីរបានសោយរាជ្យសម្បត្តិ ជាមហាក្សត្រដ៏ប្រសើរ ជាមោលីទីពឹងនៃសមណជីព្រាហ្មណ៍ បណ្តារាស្ត្រទាំងពួង។ ឥឡូវមកកើតបដិបក្ខយ៉ាងនេះ ខុសនឹងបុរាណរាជប្រវេណីសមណជីព្រាហ្មណ៍ បណ្តារាស្ត្រកើតក្តីក្តៅក្រហាយព្រាត់ប្រាស់កូនប្រពន្ធ ទីលំនៅ គួរយើងទាំងពីរតាំងព្រះរាជប្រកបដោយមេត្តាករុណា ខន្តីញ៉ាំងព្រះពុទ្ធសាសនាឱ្យថ្កើងរុងរឿង សមណជីព្រាហ្មណ៍និងអាណាប្រជានុរាស្ត្របានសេចក្តីសុខរឿងនេះសូមសម្តេចព្រះអនុជាធិរាជកាត់បង់មានះចេញ ខ្ញុំសុំចងផ្លូវតាមរាជមេត្រី តាមផ្លូវបូរាណរាជប្រវេណី ព្រះនគរទាំងពីរនឹងបានជា។" (២៩)-សម្ព័ន្ធមិត្តនឹងគ្នាតទៅ លុះទ្រង់ព្រះសណ្តាប់សេចក្តីក្នុងរាជសារចប់ហើយ ទ្រង់មានព្រះទ័យទន់ចុះ ដោយព្រះករុណាទ្រង់ព្រះរាជតម្រាស់នឹងរាជទូតសៀមថា "យើងគាប់ព្រះទ័យនឹងព្រះចៅក្រុងស្រីអយុធ្យា សុំចងផ្លូវព្រះរាជមេត្រីហើយ" ទ្រង់សួរពីសុខទុក្ខក្នុងព្រះនគរ ស្តេចឱ្យព្រះរាជតេជះនាំរាជទូតសៀមទៅសំណាក់នៅថៃវខាងមុខព្រះបរមរាជវាំង ចាត់ភោជនាហារឱ្យបរិភោគតាមគួរ ហើយស្តេចយាងចូលក្នុងវិញ។

លុះដល់វេលារសៀលថ្ងៃនោះ ស្តេចឱ្យប្រជុំរាជវង្សានុវង្ស មុខមន្ត្រីទាំងពួងមកគាល់ត្រៀបត្រាទ្រង់ប្រឹក្សាថា ស្តេចសៀមជាសត្រូវនឹងយើង ឥឡូវនេះទ្រង់ប្រើព្រះរាជទូតឱ្យមកសុំចងផ្លូវព្រះរាជមេត្រីនេះ ដោយរអាថ្វីដៃយើង១ ដោយកើតសឹកនឹងមន១ បើយើងមិនព្រមទទួលដោយផ្លូវព្រះរាជមេត្រីផងមិនល្អ គួរទទួលចុះនឹងបានសេចក្តីសុខដល់សមណជីព្រាហ្មណ៍ បណ្តារាស្ត្រតទៅខាងមុខ កុំឱ្យចងវេរានឹងគ្នា។ នោះព្រះរាជវង្សានុវង្ស សេនាបតី មុខមន្ត្រីទាំងពួង ក៏យល់ព្រមតាមព្រះរាជតំរិះ។ (៣១)-ទើបទ្រង់ព្រះរាជបញ្ញាឧកញាប្រាជ្ញាធិបតី(វង) ឱ្យតែងព្រះរាជសារឧកញាប្រាជ្ញាធិបតីតែងជាសេចក្តីថា "ព្រះរាជសារព្រះបាទសម្តេចព្រះបរមិន្ទរាជាធិរាជរាមាធិបតីសិរីសុរិយោវង្សព្រះចៅក្រុងកម្ពុជាធិបតីក្នុងខេមរប្រទេស ចម្រើនផ្លូវព្រះរាជមេត្រីមកព្រះបាទសម្តេចព្រះមហាធម្មរាជាព្រះចៅក្រុងស្រីអយុធ្យា ដ៏ប្រកបដោយបញ្ញត្តិសម្ភារជាទីសរណៈនៃជនក្នុងស្យាមប្រទេសរាជធានីជាជេដ្ឋាធិរាជបានជ្រាប។ ត្បិតមានព្រះរាជសារទៅសុំចងផ្លូវព្រះរាជមេត្រីតាមបូរាណរាជប្រវេណីនោះ ខ្ញុំព្រះចៅក្រុងកម្ពុជាទទួលផ្លូវព្រះរាជមេត្រី ឯខេត្តដែនខ្មែរដែលខ្ញុំអនុជបានធ្វើសង្គ្រាមឈ្នះ បានខេត្តដែនត្រឹមណាឱ្យនៅនឹងត្រឹមនោះ។ បើព្រមត្រូវចាត់ព្រះរាជបម្រើទាំងពីរនគរឱ្យមកបោះគោល ជ្រួចទឹកស្នោទកជាចារឹកឱ្យអស់កប្បាវសានទៅខាងមុខ កុំឱ្យក្សត្រខាងណារំលោភដោយអំណាចរុករានទន្ទ្រានចូលឱ្យហួសដែនដែលមានគោលជាកំណត់ ប្រយោជន៍នឹងឱ្យសាមណជីព្រាហ្មណ៍ បណ្តារាស្ត្របានសេចក្តីសុខ ដោយបូរាណរាជប្រវេណីព្រះនគរទាំងពីរ។ បើមានសឹកសត្រូវនឹងលើកចតុរង្គមកជួយទៅវិញទៅមកតាមព្រះរាជមេត្រី ហើយស្តេចឱ្យរាជទូតសៀមចូលគាល់ ទ្រង់ប្រោសព្រះរាជទានរបស់តាមសមគួរទ្រង់ចាត់ ភ្លុកដំរី៥ក្បាល សំពត់ហូលជរ៣ជាន់៥៦សំពត់ ផាមួង១០០ ក្រវាញ២ហាប ត្រកោះ៥ហាប ក្រមួនឃ្មុំ៥ហាប ស្បែង១០ហាប ជាគ្រឿងរាជបណ្ណាការតបថ្វាយទៅឱ្យល្មមនឹងរាជបណ្ណាការដែលស្តេចសៀមថ្វាយមករួចទ្រង់ចាត់ព្រះអញ្ចេទស(រស់)១ ព្រះឥន្ទ្រាតេជោ(ដៃ)១ ព្រះទ្រង់គុជ្ជេន(សោម)១ លួងស្រីនគរបាល(ម៉ា)១ លួងឫទ្ធីគុជ្ជេន(កុយ)១ លួងនរេនឫទ្ធី(មាស)១ ជារាជទូតឱ្យអញ្ជើញព្រះរាជសរ និងរាជបណ្ណាការទៅជាមួយនឹងរាជទូតសៀម (៣២)-លុះរាជទូតទៅដល់នោះ ព្រះចៅក្រុងស្រីអយុធ្យា ទ្រង់ចាត់ព្រះរាជតេជោឱ្យចេញមកទទួលនៅប៉ាណាម នាំរាជទូតចូលដល់ក្រុង ស្តេចឱ្យនាំរាជទូតខ្មែរចូលគាល់ រាជទូតក៏ថ្វាយរាជសារ និងរាជបណ្ណាការទាំងពួង ទ្រង់ទតជ្រាបសព្វសេចក្តី ទ្រង់មានព្រះអំណររណាស់ថា យើងតាមព្រះអនុជទាំងអស់ស្តេចចាត់មន្ត្រីឱ្យនាំរាជទូតទៅនៅថៃវមុខព្រះបរមរាជវាំងឱ្យលាងភោជនាហារមិនឱ្យខ្វះខាត។

វេលានោះមានសំបុត្រចៅហ្វាយស្រុកពិស្ណុលោកប្តឹងមកថា ខ្លួនចង់មកប្រមូលសេនាទាហាននឹងលើកមកវាយកម្ពុជា?, ស្តេចសៀមក៏ប្រញាប់ធ្វើព្រះរាជសារតបមក ចាត់ព្រះស៊ីសៅរាជ១ យុនលួងធម្មាទិស១ យុនចន្ទ្រាទិព្វ

១ យុនធៀនយរាជ១ ឱ្យអញ្ជើញព្រះរាជសារ និងបណ្ណាការ ស្ដេចឱ្យមើលថ្វាយសេចក្ដីថា ដែលព្រះអនុជ្ជាធិរាជព្រម ទទួលផ្លូវព្រះរាជមេត្រី ឱ្យជ្រួចទឹកស្នោទក បោះគោលជាចារឹកដែនព្រះនគរនោះ ខ្ញុំជាជេដ្ឋាមានអំណរណាស់ហាក់ ដូចបានវិមានទិព្វ វេលានេះសូមព្រះអនុជ្ជាធិរាជចាត់ព្រះរាជបម្រើ និងសមណជីព្រាហ្មណ៍ សេនាបតីមកប្រជុំបោះ គោលជាចារឹក នៅតំបន់ខេត្តស្រះកែវ ដោយបូរាណរាជប្រវេណី។

ព្រះបាទសម្ដេចព្រះបរមិន្ទរាជា ទ្រង់ចាត់សម្ដេចចៅហ្វាទឡ្ហៈ១ ឧកញ្ញាធម្មាតេជោ១ ឧកញ្ញាចក្ររតនៈ ១ ព្រះស្រីភូវប្រីជា១ ព្រះរាជវរានុកូល១ លួងរាជា៣១ ម៉ឺនស្នេហាភិរម្យ១ និងខុនម៉ឺនច្រើនឈ្មោះ ចំណែកខាង សមណៈ សម្ដេចព្រះមហាព្រហ្មមុនី១អង្គ ព្រះធម្មមុនី១អង្គ ព្រះធម្មឧត្តម១អង្គ ព្រះអរិយព្រឹទ្ធាចារ្យ១អង្គ ព្រះវិន័យ ធរ១អង្គ និងព្រះសង្ឃ៨អង្គទៀត មន្ត្រីខាងរាជបណ្ឌិត៤ ខាងហោរា៤ខាងព្រាហ្មណ៍បុរោហិត៤ សេនាទាហាន ៥០០ ចេញទៅបោះគោលជាមួយរាជទូតសៀម។

ចំណែកព្រះចៅក្រុងស្រីអយុធ្យាចាត់ពញាចក្រី១ ពញាភិមុខមន្ត្រី១ ពញាទេព្វរុណ្ណរុងព្រៃជ១ ព្រះ ពហុល្លទេព្វ១ និង ខុនម៉ឺនច្រើននាក់ ខាងព្រះសង្ឃនោះសម្ដេចព្រះសង្ឃរាជគាមវាសី១ អរញ្ញវាសី១ ព្រះគ្រូធ្វេង១ និងព្រះភិក្ខុសង្ឃ២០អង្គ ខាងព្រាហ្មណ៍ព្រះមហិន្ទរាជាសូភាវត្តី ព្រះបរមោចារ្យ១ ព្រះទេព្វាចារ្យ១ ព្រះហោរាធិបតី១ និងពួកបុរោហិត១០នាក់ សេនាបតីព្រាហ្មណ៍គណាចារ្យទាំងពីរ ចំណែកមកជួយជំនុំព្រមនៅស្រះកែវចាត់ចែងពិធី និងជ្រួចទឹកស្នោទកបោះគោលចារឹកនៅទីនោះ។

ព្រះពុទ្ធសករាជ២១២១ មហាសករាជ១៤៩៩ ចុលសករាជ ៩៣៩ គ.ស.១៥៧៧ ឆ្នាំឆ្លូវនព្វស័ក ថ្ងៃ ព្រហស្បត្តិ ៨កើត ខែកត្តិក ជាថ្ងៃបានឫក្សប្រជុំបោះគោលចារឹកសត្យាទីស្ថានក្នុងសិលាបាទ ហើយព្រះភិក្ខុសង្ឃ ទាំងសងខាងជ្រួចទឹកស្នោទក លើគោលសីមាជាបន្ទាល់សាក្សី ដើម្បីនឹងព្រះរាជមេត្រីសីមាមណ្ឌលទាំងពីរព្រះនគរ ស្ថិតស្ថេរចីរកាលដរាបដល់កប្បាវសាន ហើយឱ្យឧបសម្បទកម្មភិក្ខុ៦អង្គនៅទីនោះ ខាងលិចបានជាដែនសៀម ខាងកើតបានជាដែនខ្មែរ។ តាំងចៅហ្វាយស្រុកឱ្យឈររក្សាខែត្រ ទើបទីនោះជាប់ហៅថាអាងសិលាបាទរហូតដល់ បច្ចុប្បន្ននេះ។ តាំងពីនោះមក ក្រុងកម្ពុជាធិបតី និងក្រុងស្រីអយុធ្យា ជាមេត្រីនឹងគ្នា។

បើតាមពិនិត្យស្ថានភាពនយោបាយនៅអយុធ្យា អំឡុងទសវត្សរ៍ឆ្នាំ១៥៦០ និង១៥៧០ មានសភាពដុន ដាបខ្លាំង ដោយសារាជវង្សចាស់របស់អយុធ្យាត្រូវបំផ្លាញដោយកងទ័ពភូមាមកពីក្រុងហង្សាវតី និងទ័ពរបស់ពួក រាជវង្សសុខោទ័យរបស់ថៃ។ បើតាមលោក វិកឃើរីថា ចាប់ពីឆ្នាំ១៥៦៩មក រាជវង្សសុខោទ័យទើបតែត្រូវភូមាបន្តុប ឡើងនៅអយុធ្យា។ ម្ល៉ោះហើយ អយុធ្យាបានក្លាយជារដ្ឋចំណុះមួយរបស់ភូមា។ នៅពេលរាជវាំងលង្វែកធ្វើការវាយ ប្រហារសង្កត់ជាបន្តបន្ទាប់ទៀតនោះ ធ្វើឱ្យអយុធ្យាត្រូវតែបន្ទន់ឥរិយាបថ ដើម្បីបញ្ចប់ភាពជាសត្រូវជាមួយខ្មែរ និង ជៀសវាងកង្វល់ចំពោះសមរភូមិពីរក្នុងពេលតែមួយ។ ចំណែកភាគីខ្មែរវិញ តែងតែធាប់ជឿទុកចិត្តសត្រូវ ដោយគ្មាន បង្ការ និងការប្រយ័ត្នប្រយែងឡើយ។ ទើបធ្វើឱ្យអយុធ្យាឆ្លៀតឱកាសប្រើប្រាស់កម្លាំងរបស់ខ្មែរ ក្រោមផ្លាកជួយមិត្ត ដើម្បីវាយភូមារំដោះអនិស្សរភាពរបស់ខ្លួនបាន។ នៅពេលសមរភូមិខាងជើង និងខាងលិចលែងគំរាមកំហែងគេ ហើយ ស្ដេចអយុធ្យាឈ្មោះ នរេសួន បានថ្លែងអំណរគុណខ្មែរ ដោយលើកទ័ពមកវាយប្រហារយកលង្វែក ក្រោម លេសមួយចំនួន និងសងសឹកខ្មែរដែលបានវាយខ្លួននៅអំឡុងពេលក្រោយសង្គ្រាមជាមួយភូមាភ្លាម។ នេះគ្រាន់តែ ជា មេរៀនប្រវត្តិសាស្ត្រមួយសម្រាប់ខ្មែរ កាលពីសតវត្សរ៍ទី១៦។

## 7. ការបែកបាក់សាមគ្គីភាព ជាហេតុនៃការដួលរលំ

### + ស្តេចក្មេង ៖

ពេលព្រះបាទសត្ថាទី១ ឬព្រះបរមរាជាទី៥ឡើងសោយរាជ្យ, ព្រះអនុជនាមព្រះស្រីសុរិយោពម៌ឡើងជាមហាឧបរាជ។ ដោយភ័យខ្លាចរាជ្យសម្បត្តិបានទៅព្រះអនុជ ព្រោះថា ព្រះអនុជអង្គនេះ មានប្រជារាស្ត្រស្រឡាញ់ជាច្រើន នៅឆ្នាំ១៥៨៦ ព្រះសត្ថាទ្រង់សព្វព្រះរាជហឫទ័យដាក់រាជ្យ ថ្វាយទៅព្រះរាជបុត្រដែលទ្រង់មានព្រះជន្មក្មេងៗ ដោយរាជបុត្រច្បងព្រះនាម ជយជេដ្ឋា ដែលមានព្រះជន្ម១១វស្សា ឱ្យឡើងសោយរាជ្យ ហើយតាំងរាជបុត្របន្ទាប់ដែលទើបមានព្រះជន្ម៦វស្សាជាមហាឧបរាជ។ ឯព្រះស្រីសុរិយោពម៌ ត្រូវបានឡើងជាឧភយោរាជ។ ដោយព្រះរាជបុត្រសុទ្ធតែនៅក្មេងៗពេក កិច្ចការគ្រប់គ្រងរដ្ឋស្ថិតនៅក្នុងព្រះហស្តរបស់ព្រះអង្គទាំងអស់។ អ្នកប្រវត្តិសាស្ត្រ បានគិតថាការដាក់រាជ្យថ្វាយទៅរាជបុត្រទាំងនៅក្មេងៗ ដូចនេះ ព្រោះព្រះបាទសត្ថា គិតខ្លាចក្រែង ព្រះស្រីសុរិយោពម៌ដណ្តើមយកប្រជាប្រិយភាព ថ្ងៃណាមួយរាជ្យសម្បត្តិមុខតែធ្លាក់ក្នុងកណ្តាប់ដៃព្រះស្រីសុរិយោពម៌មិនខាន ដោយសារព្រះសមត្ថភាព និងប្រជាប្រិយភាពរបស់ព្រះអង្គ។ អំពើរបស់ព្រះសត្ថា ធ្វើឲ្យមានការអាក់អន់ស្រពន់ចិត្តពីសំណាក់ក្រុមរាជវង្សានុវង្ស នាម៉ឺនសព្វមុខមន្ត្រី និងអាណាប្រជារាស្ត្រ។ ពួកគេអស់សង្ឃឹមចំពោះបញ្ហានយោបាយដោយសារតែព្រះចិន្តាអាត្មានិយមជ្រុលរបស់ព្រះមហាក្សត្រ។

### + មន្ត្រីបែកសាមគ្គី ៖

ទន្ទឹមនោះ មានឯកសារខ្លះថា ព្រះមហាក្សត្រកុមារភាពទាំងពីរ តែងនឹកឃើញល្បែងលេងពេលប្រជុំរដ្ឋមន្ត្រី ហើយប្រើរដ្ឋមន្ត្រីចាស់ៗឱ្យវារធ្វើគោឱ្យពួកគេជិះលេងជាល្បែងក្មេងនៅក្នុងរោងជំនុំ។ រដ្ឋមន្ត្រីចាស់ៗទាំងនោះអាក់អន់ចិត្ត ចំពោះការបណ្តោយឱ្យកូនក្មេងប្រមាថមន្ត្រីចាស់ៗរបស់ព្រះបាទសត្ថាទី១។

### + ល្បិចកលបាចប្រាក់បានសម្រេច ៖

ដោយការមិនបានយកចិត្តទុកដាក់បំពេញរាជកិច្ចរាជការឲ្យបានល្អ បណ្តាលឱ្យមានចោរលួច ចោរប្លន់ កកើតឡើងព្រោងព្រាត ជាពិសេសមានការបណ្តែបណ្តោយឱ្យអ្នកស្រុកកាប់ឆ្ការព្រៃឫស្សីកំពែងរាជធានីរើសយកប្រាក់ដួង ដែលស្តេចសៀមឱ្យទាហានខ្លួនបាញ់ចូល មុនពេលពួកគេដកថយនៅពេលវាយប្រហារលង្វែកនៅលើកទី១។ ដោយមិនសប្បាយចិត្តជាមួយនឹងព្រះសត្ថាស្រាប់ និងដោយរាស្ត្រខ្វះខាត, ប្រឈមមុខនឹងគ្រោះទុរ្ភិក្សផងនោះ ពួកមន្ត្រីធំតូចបានធ្វើគធ្វើថ្លង់ចំពោះប្រជារាស្ត្រដែលនាំគ្នាកាប់ឆ្ការ ឬត្រាយព្រៃឫស្សីនោះ ដើម្បីរើសយកប្រាក់ដួង។ ក្រោយមកទោះបីរាជការមានការហាមឃាត់យ៉ាងណា ក៏ជាការឥតប្រយោជន៍ ពីព្រោះមន្ត្រីធំតូចទាំងនោះមិនសូវយកចិត្តទុកដាក់ស្តាប់។ នៅពេលកំពែងឫស្សីដ៏ក្រាស់រឹងមាំនេះ ត្រូវបានបំផ្លាញអស់ជាច្រើនអន្លើបែបនោះ វាជាការបង្កលទ្ធភាពងាយស្រួលដល់សឹកសត្រូវឈ្លានពានក្នុងការដណ្តើមកាន់កាប់យកបន្ទាយនេះ។

ទោះបីជាយ៉ាងណា ឈ្មោះថា ប្រាក់ដួង ទើបនឹងកើតឡើងនៅក្នុងរាជ្យព្រះបាទអង្គដួង ក្នុងទសវត្សរ៍ឆ្នាំ១៨៥០ប៉ុណ្ណោះ។ ការដែលថា សៀមមានប្រាក់ដួងបាញ់បំផ្លោងចូលព្រៃឫស្សីកំពែងបន្ទាយលង្វែកកាលពីឆ្នាំ១៥៨៧នោះ អាចជារឿងបំប៉ោងរបស់លោកអ្នកចារពង្សាវតារនៅក្រោយរជ្ជកាលព្រះបាទអង្គដួង ប៉ុណ្ណោះ៕

# មេរៀនទី 7 សម័យឧដុង្គ និងឥទ្ធិពលរបស់សៀម-យួនមកលើកម្ពុជា

ព្រះស្រីសុរិយោពណ៌ ជាមហាឧបរាជនៃព្រះសត្ថាទី១ ក្រោយមកឡើងជាព្រះឧភយោរាជ នៅសម័យដែលបន្ទាយលង្វែកមិនទាន់បែកបាក់។ ពេលសៀមវាយបន្ទាយលង្វែកលើកទី២នៅឆ្នាំ១៥៩៣ ព្រះស្រីសុរិ-យោពណ៌ ទ្រង់បានការពារបន្ទាយលង្វែកលុះដំណាក់កាលចុងក្រោយ ដែលសៀមវាយដណ្តើមកាន់កាប់បន្ទាយបាន។ ពេលនោះបានចាប់យកព្រះអង្គ និងរាជបុត្រទាំងពីរអង្គ គឺព្រះជយចេស្តា(ជយជេដ្ឋា) និង ព្រះឧទ័យនាំយកទៅឃុំទុកនៅអយុធ្យា។ នៅឆ្នាំ១៥៩៤ ព្រះរាមាជើងព្រៃ បានប្រមូលទ័ពរួចវាយដណ្តើមបានបន្ទាយលង្វែកវិញ។ បន្ទាប់ពីរាមាជើងព្រៃត្រូវធ្វើគតទៅ ស្តេចដែលទទួលរាជសម្បត្តិបន្តពីព្រះអង្គ សុទ្ធសឹងជាក្សត្រពាល គ្មានទសពិធរាជធម៌ក្នុងខ្លួន ជាហេតុឱ្យស្រុកទេសកើតកលយុគឥតឈប់ឈរ ក្រោយមកដោយមានសំណូមពរពីរាស្ត្រ និងពីសំណាក់រាជវង្សានុវង្សផងនោះ ស្តេចសៀមបានដោះលែងព្រះស្រីសុរិយោពណ៌ ឱ្យយាងត្រឡប់មកប្រទេសវិញ ដើម្បីទទួលរាជសម្បត្តិ។ ក្នុងរាជ្យព្រះអង្គ ៗបាននាំយកនូវឥទ្ធិពលពីសៀមយ៉ាងច្រើន ជាហេតុធ្វើឱ្យមានការមិនសប្បាយចិត្តពីសំណាក់មន្ត្រី និងរាស្ត្រ។ ព្រះអង្គបានសំណូមពរសៀមសុំយាងរាជបុត្រទាំងពីររបស់ព្រះអង្គ ឱ្យវិលត្រឡប់មកស្រុកខ្មែរវិញ។ ដោយឈ្វេងយល់ឃើញអំពីអនាគតមិនសូវល្អរបស់ជាតិ ព្រះអង្គបានសម្រេចព្រះទ័យចងស្ពានមេត្រីជាមួយប្រទេសអាណ្ណាម ដើម្បីទប់ទល់និងអំណាចសៀម។ តាមពង្សាវតារសរសេរនៅសតវត្សរ៍ទី១៩ បានអះអាងថាទ្រង់បានស្តីដណ្តឹងបុត្រីព្រះចៅ ង្វៀងសៃវឿង ត្រៀមទុកអភិសេកជាមួយព្រះរាជបុត្រច្បងរបស់ព្រះអង្គទៀតផង។ តែនៅក្នុងឯកសារប្រវត្តិសាស្ត្រ មិនបានកត់ត្រាអំពីទំនាក់ទំនងបែបនេះទាល់តែសោះ។ ហើយបើតាមបំណែកពង្សាវតារខ្មែរចាស់ជាងគេ ដែលត្រូវព្រះអង្គអេង ថ្វាយទៅឱ្យស្តេចសៀមនៅឆ្នាំ១៧៩៦ និងដែលត្រូវគេបកប្រែជាភាសាថៃបានអះអាងថា "ស្តេចយួននៅភាគខាងត្បូងពេលនោះ មានបំណងវាយប្រហារពួករាជវង្សនៅភាគខាងជើងទើបលើករាជបុត្រីមួយព្រះអង្គ ឱ្យព្រះបាទជយជេដ្ឋាទី២ ដើម្បីជាថ្នូរសុំដំរីសឹកពីព្រះអង្គ" ដោយទ្រង់សព្វព្រះរាជហឫទ័យ ស្តេចខ្មែរលើកព្រះនាងធ្វើជារាជអគ្គមហេសី។ទំនាក់ទំនងនេះហើយ ដែលនាំភាពរឹករវរ កាន់តែខ្លាំងឡើងនៅក្នុងរាជវាំងខ្មែរ នាពេលក្រោយៗមកទៀតនៃសម័យឧដុង្គ។

ព្រះបាទ ជយជេដ្ឋា (អ្នកប្រវត្តិសាស្ត្រនិយមហៅថា ព្រះជ័យជេដ្ឋាទី២) បានទទួលរាជ្យសម្បត្តិពេលដែលបិតារបស់ទ្រង់ដាក់រាជ្យថ្វាយនៅឆ្នាំ១៦១៨។ ព្រះជយជេដ្ឋាទី២ បានឡើងសោយរាជ្យក្នុងព្រះជន្ម២៦ព្រះវស្សា រីឯព្រះឧទ័យជាអនុជធ្វើជាមហាឧបរាជ។ ដំបូងរាជធានីរបស់ព្រះអង្គរួមនិងបិតា តាំងនៅ"ល្វាឯម"ក្រោយមក គឺនៅឆ្នាំ១៦២០ ព្រះអង្គបានលើករាជធានីមកឧដុង្គមានជ័យវិញ។

សករាជ ឧដុង្គ ត្រូវបានគេរាប់ចាប់ពីរាជ្យរបស់ព្រះអង្គនៅឆ្នាំ១៦២០នេះមក។ សម័យឧដុង្គត្រូវបានកត់សម្គាល់ដោយព្រឹត្តិការណ៍សំខាន់ពីរ ៖ គឺការទន្ទ្រានយកទឹកដីពីសំណាក់យួន និងការតាំងអំណាចសៀម-យួននៅលើទឹកដីខ្មែរ។

## 1. វិបត្តិរាជវង្សានុវង្ស

ក្រោយពីព្រះបាទ ជយជេដ្ឋាទី២ សោយទិវង្គតទៅ ស្តេចដែលត្រូវទទួលរាជ្យសម្បត្តិ គឺព្រះពញាតូ(ដែលគេនិយមហៅថា ព្រះរាជសម្ភារ)តាំងរាជធានីនៅ "កោះឃ្លោក"។ ព្រះឧទ័យ ដែលត្រូវជាព្រះបិតុលា ជាមហាឧបរាជរាជធានីនៅរាជវាំងឧដុង្គមានជ័យ។ ក្នុងរាជ្យរបស់ព្រះអង្គ មានទំនាស់កើតឡើងរវាងមា និងក្មួយដែលជាបញ្ហា

សំខាន់នៅក្រោយការសោយទិវង្គតនៃព្រះជ័យជេដ្ឋាទី២។ ទំនាស់នេះឈានទៅរកការសម្លាប់ព្រះពញាតូ ក្នុងរឿងដណ្តើមយកព្រះម៉ែឃ្លរ បុប្ផាវតី (បុត្រីម្ចាស់ក្សត្រីអង្គចូវ)អតីតគូដណ្តឹង និងព្រះឧទ័យកំពុងជាស្វាមីព្រះនាងបុប្ផាវតី ហើយបង្កើតជាទំនាស់មា និងក្មួយឡើង។ ចាប់ពីឆ្នាំ១៦២០ដល់១៧៧៥វិបត្តិធ្ងន់ធ្ងរធំមួយកើតឡើង ដែលបណ្តាលឱ្យប្រទេសជាតិមានការចុះទន់ខ្សោយ និងជំរុញឱ្យប្រទេសធ្លាក់ទៅក្នុងកណ្តាប់ដៃបរទេស គឺវិបត្តិដណ្តើមរាជសម្បត្តិ។ វិបត្តិនេះពុំមែនមានតែម្តងទេ គឺជាវិបត្តិបន្តរហូតសឹងតែមិនឈប់ឈរឡើយ។ ក្នុងចំណោមព្រះញាតិវង្សានុវង្ស លែងស្គាល់បងប្អូន លែងស្គាល់មា លែងស្គាល់ក្មួយលែងស្គាល់ញាតិ គឺខ្វល់ខ្វាយតែពីរឿងកាមរាគៈ និងរាជបល័ង្កតែមួយមុខតែប៉ុណ្ណោះ។

នៅឆ្នាំ១៦៣៥ ព្រះអង្គទង(ពញានូ) ដែលជាបុត្រាទី២របស់ព្រះបាទជយជេដ្ឋាទី២ចូលទិវង្គត។ តាមទម្លាប់ រាជសម្បត្តិត្រូវថ្វាយទៅព្រះពញាចន្ទ(អង្គចន្ទទី២) ដែលត្រូវជាអនុជពៅរបស់ព្រះអង្គ។ ប៉ុន្តែពេលនោះឪពុកមារបស់ព្រះអង្គ គឺព្រះឧទ័យរាជា បានបង្វែររាជ្យទៅថ្វាយរាជបុត្រព្រះអង្គ ព្រះនាមបទុមរាជាអង្គនន់វិញ។ ក្សត្រក្រោយនេះ ជាស្វាមីរបស់ក្សត្រីដែលជាបុត្រីមួយអង្គរបស់ព្រះបាទជយជេដ្ឋាទី២ និងព្រះនាងអង្គចូវ។ នៅឆ្នាំ១៦៣៨ ព្រះពញាចន្ទ ក៏វាយលុកចូលធ្វើគត់ព្រះបទុមរាជាអង្គនន់ និងព្រះឧទ័យរាជាជាឪពុកមា។ ព្រះពញាចន្ទ ក៏ឡើងសោយរាជ្យសម្បត្តិដោយយកនាមជា រាមាធិបតី អង្គចន្ទ រហូតមកទល់នឹងឆ្នាំ១៦៥៦។

ក្នុងរជ្ជកាលបទុមរាជា អង្គសូរ (១៦៥៦-១៦៧០)ដែលជាអ្នកសោយរាជ្យបន្ទាប់ ត្រូវរាជបុត្រប្រសារព្រះអង្គនាមបទុមរាជាស្រីជយជេដ្ឋ ដែលត្រូវជាក្មួយបង្កើតព្រះអង្គផងនោះ នាំបក្សពួកចូលលុកធ្វើគតបិតាក្មេក រួចឡើងគ្រងរាជសម្បត្តិ។ មកដល់ឆ្នាំ១៦៧២ បក្សម្ខាងទៀតបាននាំគ្នាចូលលុកធ្វើគតស្តេចអង្គនេះដណ្តើមរាជសម្បត្តិវិញ។ នៅពេលឡើងគ្រងរាជ្យ ព្រះអង្គនន់ពុំសូវមានទសពិធរាជធម៌ទេ បណ្តាលឱ្យកើតចលាចលហើយត្រូវមន្ត្រីមួយក្រុមធ្វើគត់ ព្រមជាមួយរាជបុត្របង្កើតទាំងបួនអង្គផង។ សម័យនោះមហាក្សត្រទាំងអស់ សឹងមានគំនិតតែមួយដូចគ្នា គឺខ្លាចបាត់បង់រាជបល្លង្ក។ ម្ល៉ោះហើយ រាជសម្បត្តិក៏ត្រូវផ្ទេរពីឪពុកទៅកូនពីកូនទៅឪពុកវិញ គឺពុំមានសំអាងលើសមត្ថភាព ឬលើអ្វីឡើយ។ ការឡើងឋានៈជាព្រះមហាក្សត្រ ជួនកាលមានក្សត្រខ្លះ ឡើងសោយរាជ្យ៤ដង ក្សត្រខ្លះសោយរាជ្យ៣ដង ខ្លះទៀត២ដង។ ដូចជាព្រះបាទជ័យចេស្តាអង្គសូរ ឬជយជេដ្ឋាទី៣ ឡើងសោយរាជ្យ៤លើក, ព្រះបាទធម្មរាជាទី២ ឬជយជេដ្ឋាទី៤ ជាបុត្រាសោយរាជ្យ៣លើក ចាប់ពីមានព្រះជន្ម១៣វស្សា, ព្រះបាទកែវហ្វាអង្គឥម ជាបុត្រសុណិសាឡើងសោយរាជ្យ៣លើក និងព្រះបាទសត្ថាអង្គជី ជាព្រះរាជនត្តា សោយរាជ្យ២លើក។

## 2. វប្បធម៌ពឹងប្រទេសជិតខាង ដើម្បីអំណាច

ប្រវត្តិសាស្ត្រខ្មែរនៅសម័យក្រោយអង្គរ ក្នុងរវាងបីសតវត្សរ៍ មុនពេលដែលបារាំងមកដល់ លេចឡើងនូវព្រឹត្តិការណ៍ ដែលគួរឱ្យសោកស្តាយមួយ ដោយសារគេសង្កេតឃើញថា សមាជិករាជវង្សានុវង្សដែលមានទំនាស់និងគ្នាតែងតែនាំគ្នាភៀសខ្លួនទៅជ្រកកោន ពឹងពាក់សុំអន្តរាគមន៍ពីស្តេចសៀម ឬស្តេចយួន ដើម្បីច្បាំងដណ្តើមរាជ្យបល្ល័ង្កគ្នាទៅវិញទៅមក។ ដោយសារទង្វើច្រំដែលៗបែបនេះ កើតឡើងក្នុងរយៈពេលយូរអង្វែងមួយ ដែលក្លាយជាទម្លាប់ ឬជាវប្បធម៌យ៉ាងសាមញ្ញមួយរបស់សមាជិករាជវង្សានុវង្សខ្មែរ។

ចាប់ផ្តើមពីរាជ្យរបស់ព្រះបាទស្រីរាជា ដែលជាបុត្រាទី២ របស់ស្តេចពញាយ៉ាត ត្រូវព្រះអនុជរបស់ព្រះអង្គព្រះនាមធម្មរាជា ក្បត់ដណ្តើមរាជ្យសម្បត្តិ ដោយបង្កើតការឃុបឃិតជាមួយប្រទេសជិតខាង(អយុធ្យា)នៅ១៤៧៥-១៤៨៥″។ ដោយសារព្រះស្រីរាជា និងស្រីសុរិយោទ័យ ដែលជាគូបដិបក្ខនិងគ្នា មិនបានដឹងអំពីកលល្បិច

របស់ព្រះអនុជ និងព្រះបិតុលា ទើបត្រូវស្តេចអយុធ្យាចាប់ខ្លួននៅពេលដែលស្តេចទាំងពីរចូលមកចរចាសម្រុះសម្រួលគ្នា ដើម្បីបញ្ចប់សង្គ្រាមនោះ។ ចំណែកស្រីធម្មរាជា ក៏បានឧកាសឡើងសោយរាជ្យជាស្តេចតែមួយអង្គឯង។ មកដល់ពាក់កណ្តាលនៃសតវត្សរ៍ទី១៧ នៅក្នុងជម្លោះពញាតូ និងព្រះឧទ័យ (ឪពុកមា និងក្មួយ ជម្លោះដណ្តើមព្រះនាងបុប្ផាវតី) បន្តឈានទៅរកការកាប់សម្លាប់គ្នា។ ថ្វីត្បិតតែនេះ ពុំមែនជារឿងដើម្បីដណ្តើមរាជ្យសម្បត្តិគ្នាក៏ដោយ តែចំណុចពិសេសត្រង់ថា ដើម្បីសម្លាប់ពញាតូ ដែលដណ្តើមព្រះនាងបុប្ផាវតីនោះ ព្រះឧទ័យបានពឹងពាក់បរទេសខ្មាន់កាំភ្លើងជាតិព័រទុយហ្គេ។ ក្នុងរឿងជម្លោះរាជវង្ស ឱ្យអ្នកដទៃក្រៅអំពីរង្វង់គ្រួសារខ្លួនឯងចូលមកឡូកឡំដោះស្រាយវិវាទ ទោះបីថាទំនាក់ទំនងនៅពេលនោះ ពួកព័រទុយហ្គាល់គ្មានឥទ្ធិពលលើខ្មែរដូចសៀម,យួនក៏ដោយ ក៏នេះជាទំលាប់មួយមិនល្អផងដែរ។ លុះមកដល់រាជ្យព្រះរាមាធិបតីស្រីសុរិយោពម៌អង្គចន្ទ(អង្គចន្ទទី២ ឬអង្គចន្ទអ៊ីប្រាហ៊ីម) ដែលជាអនុជពៅរបស់ព្រះរាជសំភារ ប៉ុន្តែមាតាជាតិលាវ។ ក្នុងជម្លោះដណ្តើមរាជ្យសម្បត្តិ ពេលដែលព្រះបិតុលា គឺព្រះឧទ័យបានបង្វែររាជ្យទៅឱ្យរាជបុត្រព្រះអង្គគឺព្រះអង្គនន់ នោះក៏កើតមានការមិនសប្បាយចិត្តពីសំណាក់ពញាចន្ទ។ ដោយមានកម្លាំងពួកចាម-ជ្វា ដែលស្តេចពញាចន្ទ បានពឹងពាក់នោះ គឺពួកចាម-ជ្វាបះបោរនោះឯង ដែលជួយឱ្យពញាចន្ទ ចូលធ្វើគតព្រះឧទ័យ ដែលជាព្រះបិតុលា និងស្តេចអង្គនន់ ដែលត្រូវជាបងប្អូនជីដូនមួយរបស់ព្រះអង្គនោះបានសម្រេចទៅ។

សូមរំលឹកថា ក្រោយពេលដែលព្រះពញាចន្ទ ចូលធ្វើគតព្រះឧទ័យ និងស្តេចអង្គនន់ ពេលនោះបុត្រព្រះឧទ័យ ពីរព្រះអង្គទៀត គឺព្រះអង្គសូរ និងព្រះអង្គតន់បានសន្យាចំពោះព្រះអង្គច័ន្ទថា ទ្រង់ទាំងពីរអង្គនឹងមិនសងសឹកចំពោះព្រះអង្គចន្ទឡើយ ហេតុនេះហើយទើបព្រះអង្គចន្ទមិនបានសម្លាប់ផ្តាច់ពូជ។ តែក្រោយមក ដោយមានការអុជអាលពី អង្គចូវ ស្តេចទាំងពីរអង្គលែងលះបង់គំនិតមិនសងសឹកចំពោះព្រះរាមាធិបតីនោះទៅវិញ។ ជម្លោះរវាងព្រះពញាចន្ទ និងព្រះអនុជជីដូនមួយទាំងពីរក៏កើតឡើងដោយពញាចន្ទ ពឹងពួកចាម-ជ្វា ដែលព្រះអង្គធ្លាប់មានទំនាក់ទំនងរួចមកហើយជាមេកម្លាំងក្នុងជម្លោះនេះ។ ឯខាងអនុជទាំងពីរ ក្រោយពីប្រមូលបានពលរេហ៍ខ្មែរដែលព្រះអង្គចលនាបានពីបណ្តាខេត្ត មានខេត្តទ្រាំង បាទី បន្ទាយមាស កំពត កំពង់សោម ព្រះត្រពាំង និងរាស្ត្រត្រើយខាងកើតហើយនោះ នៅឆ្នាំ១៦៥៧ព្រះអង្គ ក៏លើកទ័ពទៅបោះនៅខេត្តសំរោងទងមួយកង និងមួយកងទៀតនៅព្រៃកញ្ជៅមួយកង។ ចម្បាំងរវាងបងប្អូនទាំងពីរ មិនចាញ់មិនឈ្នះ ព្រោះកម្លាំងទាំងសងខាងប្រហាក់ប្រហែលគ្នា។ ព្រះអង្គសូរ ទ្រង់បានយកសេចក្តីក្នុងការប្រយុទ្ធគ្នា ទៅរៀបរាប់ថ្វាយព្រះអង្គចូវជ្រាប ទើបទ្រង់ស្នើសុំអង្គចូវ ផ្ញើសារមួយទៅព្រះចៅក្រុងវ៉េ។ ក្រុងវ៉េចាត់មេទ័ពឈ្មោះ អុងកូបៀង ដឹកនាំទ័ព ៧០០០០នាក់ សំដៅមកក្រុងភ្នំពេញ។

ទ័ពរបស់ព្រះរាមាធិបតីអង្គចន្ទ ចាញ់ទ័ពព្រះអង្គសូរ និងព្រះអង្គតន់នៅសមរភូមិ អូផ្អ សំរោងទងព្រៃកញ្ជៅ និងភ្នំពេញហើយក៏ដកថយមកបន្ទាយឧដុង្គមានជ័យ ដើម្បីបង្គំទូលព្រះរាជាសុំកេណ្ឌទ័ពបន្ថែមទៀត។ ពេលដែលព្រះរាជាទ្រង់ជ្រាបថាទ័ព អុងកូបៀងបានមកដល់ភ្នំពេញ ព្រះអង្គទ្រង់ប្រឹក្សាជាមួយសម្តេចបរទេសរាជថៃ ស៊ុន និងមន្ត្រីចាមដទៃទៀត។ ពេលនោះមន្ត្រីចាម បាននាំទ័ពចាម-ជ្វាមាន ១០០០០នាក់ សុទ្ធតែអ្នកខ្លាំងពូកែ។ ទ័ពព្រះរាជា និងទ័ពរបស់ យួនអុងកុបៀង ជួបតតាំងគ្នានៅម្តុំភូមិព្រៃកតាទែន។ ដោយមានការសប្បាយមិនចិត្តចំពោះព្រះរាជា ដែលទ្រង់រាប់អានជាតិចាម ខុសនិងគន្លងបំភ្លេចព្រះពុទ្ធសាសនា នៅពេលចម្បាំងមកដល់ មេទ័ពរួមនិងកូនចៅចេះតែទទួលយកអាសារព្រះរាជាទាំងមិនសប្បាយចិត្ត។ ម្ល៉ោះហើយនាំគ្នាដោះដៃរត់យករួចខ្លួន នៅសល់តែទ័ពចាមតទល់។ ទ័ពយួន ព័ទ្ធចាប់បានព្រះរាមាធិបតី ហើយដាក់ទ្រុងដែកបញ្ជូនទៅស្រុកយួនមុនបាត់ទៅ។ ចំណែកមេទ័ពយួន អុង កូបៀងមិនបានត្រឡប់ទៅភ្លាមទេ ព្រោះមានគម្រោងការសំងាត់វាយបំបាក់ទ័ពខ្មែរព័ទ្ធចាប់ព្រះរាជាទាំងពីរអង្គ គឺព្រះអង្គសូរ និងអង្គតន់ ដើម្បីដាក់ខ្មែរជាដែនដីនៃប្រទេសអាណ្ណាម។ លើកនេះយួនឆ្លៀតឱកាស ក្តោបយកស្រុកខ្មែរភ្លាមៗតែម្តង។

នៅក្នុងរាជ្យព្រះសត្ថាទី២ អង្គជី(រជ្ជកាលទី៣៖ ១៧៤៩) ក្នុងជម្លោះរវាងព្រះអង្គទង នៅពេលចាញ់ដៃគូបដិបក្ខ ព្រះអង្គទងបានភៀសព្រះកាយទៅស្រុកសៀម។ ចំណែកព្រះអង្គជី ក៏លើកទ័ពចូលក្នុងក្រុងឧដុង្គ។ បន្ទាប់មកព្រះអង្គចាត់ឱ្យទ័ពយួនធ្វើបន្ទាយនៅខេត្តលង្វែក និងខេត្តលោវៀរ បង្ការក្រែងកងទ័ពសៀមគាំទ្រព្រះអង្គទងលើកមកវាយប្រហារ។ ក្នុងរាជ្យព្រះអង្គនេះហើយ ដែលកងទ័ពយួនជាអ្នកកាន់អំណាចស្ទើរតែទាំងអស់ អំណាចហូតពន្ធដារ អំណាចផ្លាស់ប្តូរចៅហ្វាយស្រុកខ្មែរ និងយកច្បាប់ក្រុងវេមកអនុវត្តន៍ក្នុងផ្ទៃរាជការខ្មែរថែមទៀត។ យួនបង្ខំឱ្យព្រះសត្ថា ប្រគល់ខេត្តពីរទៅយួនតាមកិច្ចសន្យាគឺខេត្តមេសរ និងខេត្តលង់ហោ។ ពេលនោះហើយដែលកងទ័ពយួនចូលមកដីខ្មែរកាន់តែច្រើនឡើង។ ការក្តាប់អំណាចដោយយួនលើដីខ្មែរនេះ បានធ្វើឱ្យមន្ត្រីរាជការខ្មែរមិនសប្បាយចិត្ត រាស្ត្រក្តៅក្រហាយ បើកឱកាសឱ្យលោកឧកញ៉ាក្រឡាហោមឧិក និងឧកញ៉ាសួគ៌ា បញ្ចុះបញ្ចូលចៅហ្វាយស្រុកនៅខេត្តមហានគរ កំពង់ស្វាយ សៀមរាប កេណ្ឌទ័ព និងលើកទ័ពចូលមកតាមទិសពីខាងជើង។ ចំណែកលោកឧកញ៉ាទាំងពីរ និងលោកចៅហ្វាយស្រុកខេត្តបាត់ដំបង ខេត្តពោធិ៍សាត់នាំទ័ពចូលពីខាងលិច។

ទ័ពយួនរបស់ព្រះសត្ថា និងទ័ពខ្មែរ ជួបប្រយុទ្ធគ្នានៅខេត្តលោវៀរ ប៉ុន្តែការប្រយុទ្ធមិនឈ្នះមិនចាញ់ក៏ដកទ័ពថយរៀងខ្លួន។ ទ័ពយួនស្នើសុំជំនួយទ័ពពីព្រះសត្ថា។ ព្រះអង្គទ្រង់ចាត់ឱ្យព្រះអង្គអ៊ីងនាំទ័ពជំនួយ។ ពេលនាំទ័ពជំនួយមកដល់កំពង់ឆ្នាំង ព្រះអង្គអ៊ីងទ្រង់ប្រឈួនហើយសុគតទៅ។ លោកឧកញ៉ាមេទ័ពខ្មែរទាំងពីរលុះដឹងថា ព្រះអង្គអ៊ីង ដែលនាំជំនួយនោះទ្រង់សុគតហើយ ក៏ប្រមូលកម្លាំងវាយលុកទ័ពយួននៅវាលសាបអង្កាម(ខេត្តកំពង់ឆ្នាំងសព្វថ្ងៃ)។ មេទ័ពយួនត្រូវស្លាប់ក្នុងសមរភូមិសាបអង្កាម។ ទ័ពយួននៅសល់ត្រូវដកថយរត់ ហើយទ័ពខ្មែរដេញតាម។ លុះទ្រង់ជ្រាបថា ព្រះអង្គអ៊ីងទ្រង់សុគតមេទ័ពជើងគោករបស់យួនក៏ស្លាប់ទៀត ហើយទ័ពខ្មែរក៏ដេញទ័ពយួនកាន់តែកិតដល់ក្រុងឧដុង្គមានជ័យទៀត ព្រះសត្ថា ទ្រង់ភៀសទៅស្រុកយួន។ ព្រះអង្គទ្រង់ទោមនស្សតូចព្រះទ័យយ៉ាងខ្លាំង ក៏ទ្រង់ប្រឈួនហើយសុគតនៅកណ្តាលផ្លូវក្នុងព្រះជន្ម៤៦វស្សា។

លុះសភាពការណ៍ក្នុងប្រទេសបានស្ងប់ស្ងាត់ហើយ លោកឧកពញ៉ាមេទ័ពទាំងពីរធ្វើចុតហ្មាយទូលព្រះចៅសៀមសុំអនុញ្ញាតឱ្យស្តេចខ្មែរយាងត្រឡប់មកវិញ។ ព្រះអង្គស្ងួន(រាជបុត្ររបស់ព្រះធម្មរាជាទី៣)បានទទួលការអនុញ្ញាតឱ្យយាងត្រឡប់មកស្រុកខ្មែរមុន ប៉ុន្តែស្តេចសៀមបានឃាត់ព្រះអង្គទង និងព្រះឧទ័យរាជាទុកនៅឯស្រុកសៀមសិន។ ត្រង់នេះ គ្រាន់តែពួកក្សត្រខ្មែរសុំជីសៀមជ្រកកោនមួយរយៈ ក៏ត្រូវខាតប្រយោជន៍ដែរ។ ព្រោះសៀមចេះឆ្លៀតកេងយកឱកាសនេះ ដើម្បីបង្កើតឥទ្ធិពលលើរាជវាំងខ្មែរ និងស្រុកខ្មែរដូចជាចំណុះគេ។ ចំពោះស្តេចខ្មែរវិញ នៅជំនាន់នោះ តើធ្លាប់ឆ្លៀតឱកាសបង្កើតឥទ្ធិពលខ្លួនលើនយោបាយប្រទេសដែលមានអ្នកដឹកនាំធ្លាប់រត់មកជ្រកកោនដូច្នេះដែរឬទេ?

នៅរាជ្យព្រះបាទស្រីជយជេដ្ឋអង្គស្ងួន(១៧៤៩-១៧៥៥) ឯកសារខ្លះថាព្រះបាទជយជេដ្ឋាទី៥ ព្រះស្រីជ័យជេដ្ឋ សព្វព្រះទ័យតែងតាំងលោកឧកញ៉ា(អតីតចៅហ្វាយស្រុក ខេត្តពោធិសាត់) ជាសម្តេចចៅហ្វ៊ាទឡ្ហៈ ដើម្បីតបស្នងស្នាដៃរបស់លោកក្នុងការកំចាត់ទ័ពយួន។ ការតែងតាំងនេះបាននាំឱ្យមានការច្រណែន។ ពួកមន្ត្រីទាំងនោះគិតថា ឧកញ៉ាសួគ៌ា ជាមន្ត្រីថ្នាក់ខេត្តមិនគួរឡើយត្រូវដំឡើងឋានៈដើម្បីត្រួតត្រាលើពួកគេឡើយ។ លុះបានមួយឆ្នាំ ពួកមន្ត្រីទាំងនោះបានចូលទៅបង្គំគាល់ព្រះរាជាទូលថ្វាយនូវពាក្យមួលបង្កាច់ថា «សម្តេចចៅហ្វ៊ាទឡ្ហៈ មានគម្រោងការក្បត់ដណ្តើមយករាជ្យសម្បត្តិ»។ ព្រះរាជាទ្រង់ពុំបានត្រិះរិះម៉ត់ចត់ ក៏បញ្ជាចាមម្នាក់ឈ្មោះ បាទីន ឱ្យនាំចាមផ្វាមួយក្រុមទៅលបវាយលុកចៅហ្វ៊ាទឡ្ហៈ ទាំងយប់។ ប៉ុន្តែសម្តេចចៅហ្វ៊ាទឡ្ហៈ បានដឹងខ្លួនទាន់ក៏ដោះខ្លួនចេញ ហើយគេចទៅស្រុកសៀម។

នៅអំឡុងទសវត្សរ៍១៧៧០ ស្តេចខ្មែរនាម នារាយរាជាអង្គតន់ ឡើងសោយរាជ្យបានដោយសារកងទ័ពយួនការពារទំនុកបម្រុង។ ចំណែកជីដូនមួយរបស់ព្រះអង្គនាម អង្គនន់ ចង់សោយរាជ្យដែរ ក៏រត់ទៅពឹងសៀម។ ពេលស្តេចខ្មែរថ្វាយសួយសារអាករឱ្យ សៀមសំងំឈឹង ឃាត់អង្គនន់ទុកនៅស្រុកខ្លួន លែងអើពើរឿងដណ្តើមអំណាចឱ្យវិញ។ ពេលអង្គនន់រំអុកខ្លាំង និងការចង់បានឥទ្ធិពលលើខ្មែរផ្តាច់មុខ ទើបសៀមធ្វើជាគាំទ្រលើកទ័ពមកស្រុកខ្មែរប្រយុទ្ធគ្នាជាមួយយួន។

នៅឆ្នាំ១៨០៧ ព្រះអង្គចន្ទ ទ្រង់ចាត់ព្រះកែវ អង្គជួង និងឧញ៉ាចក្រីកែប នាំគ្រឿងបណ្ណាការទៅថ្វាយព្រះចៅសៀម និងសុំឱ្យរាជ្យវង្សខ្លះបានយាងត្រឡប់មកកម្ពុជាវិញ។ ស្តេចសៀមទ្រង់អនុញ្ញាតឱ្យតែព្រះមាតា និងព្រះអង្គពៅ យាងត្រឡប់មកវិញ។ ស្តេចសៀមទ្រង់តែងតាំង ព្រះអង្គស្ងួន ជាឧកយោរាជ និងតាំងព្រះអង្គអិម ជាឧបរាជដោយឥតមានប្រឹក្សា និងព្រះរាជាខ្មែរឡើយ ហើយថែមទាំងបញ្ជាឱ្យកេណ្ឌរាស្រ្តខ្មែរ យកទៅរក្សាក្រុងបាងកកផង។

ព្រះអង្គចន្ទ(ទី៣) ទ្រង់ជិតស្និទ្ធជាមួយយួន ហើយលើកសួយសារអាករទៅថ្វាយស្តេចយ៉ាឡុង៣ឆ្នាំម្តង។ ប៉ុន្តែជាមួយគ្នានោះ ព្រះអង្គក៏នាំបណ្ណាការទៅថ្វាយស្តេចសៀមតាមទំនៀមដែរ។

ស្តេចសៀមទ្រង់មិនសព្វព្រះទ័យទេ ចំពោះការដែលព្រះអង្គចន្ទបានទាក់ទងនឹងស្តេចយួន ហើយទ្រង់បានបញ្ជាទ័ពចំនួន ៥០០០នាក់ ឱ្យចូលមកកម្ពុជា ដោយយកលេសថា មកជួយធ្វើបុណ្យសពព្រះអង្គកែវជួង។ ប៉ុន្តែតាមការពិត សៀមលើកទ័ពតាមផ្លូវគោក(តាមខេត្តបាត់ដំបង និងតាមខេត្តស្ទឹងត្រែង)និងតាមជើងទឹក គឺដើម្បីជួយសម្រេចកិច្ចការផែនដីថ្វាយព្រះអង្គស្ងួន។ ទ័ពចំរុះខ្មែរសៀមមានប្រៀបជាងវាយបំបាក់ទ័ព"ខ្មែរយួន"ឱ្យដកថយជាបន្តបន្ទាប់។ លុះទ្រង់ជ្រាបសភាពការណ៍សឹកយ៉ាងដូច្នេះហើយព្រះអង្គចន្ទ ទ្រង់ប្រឹក្សាជាមួយមន្ត្រីសេនាបតីដកថយពីឧដុង្គមានជ័យ ទៅប្រថាប់នៅកំពង់ពោធិតូច ដើម្បីរៀបចំដំណើរទៅកម្ពុជាក្រោម។ នាពេលនោះ នៅយប់មួយនៅស្រុក តឹងចូវ ព្រះអង្គអិម និងព្រះអង្គដួង[55] បានប្រឹក្សាជាមួយព្រះមាតាសម្រេចគេចចេញពីព្រះអង្គចន្ទ ជាព្រះរៀមដោយទ្រង់មិនព្រមចងស្ពានមេត្រីជាមួយសៀម ហើយទ្រង់ចងស្ពានមេត្រីជាមួយយួន ដែលមានសាសនាខុសគ្នាទៅវិញ។

ព្រះអង្គអិម ព្រះអង្គដួង និងព្រះវរមាតា ទ្រង់យាងមកជួបជុំនឹងព្រះអង្គស្ងួន នៅឧដុង្គមានជ័យរួចហើយទ្រង់នាំមន្ត្រីរាជការខ្ញុំបំរើទៅប្រទេសសៀម ដោយទុកមន្ត្រីសេនាបតីខ្មែរ សៀមខ្លះឱ្យចាំថែរក្សារាជវាំងនៅគ.ស ១៨១២។

នៅគ.ស.១៨១៣ ស្តេចយ៉ាឡុងទ្រង់បានបញ្ជាឱ្យ ឡេ វ៉ាន់យៀត ដែលមានឋានៈជា អុងតាគុននាំក្បួនទ័ពចំនួន១០.០០០នាក់ ដង្ហែព្រះអង្គចន្ទ ត្រឡប់មកកម្ពុជាវិញ។ ពេលកងទ័ពយួនមកដល់កំពង់ហ្លួង មន្ត្រីសេនាបតីខ្មែរដែលមិនបានទៅតាមព្រះអង្គស្ងួន បានក្រាបថ្វាយបង្គំព្រះអង្គចន្ទ និងអបអរសាទរ។ ចំណែកឯមន្ត្រី និងមេទ័ពសៀមខ្លះភ័យស្រឡាំងកាំង ខ្លះទៀតថ្វាយព្រះពរចំពោះព្រះអង្គចន្ទ រួចហើយដកថយទៅស្រុកសៀមវិញ។

ជាការកត់សម្គាល់នៅក្នុងប្រវត្តិសាស្ត្រ ការពឹងពាក់បរទេសដើម្បីដោះស្រាយវិវាទគ្នាឯង ពុំដែលបានហុចផលល្អពីរឿងទាំងនេះឡើយ។ ព្រោះថា អ្នកផ្តល់ជំនួយ តែងគិតពីផលប្រយោជន៍គេជាមុនសិន នៅពេលរឿងទាំង

---

[55] តាមពង្សាវតារ វត្តសិត្បូរ និងពង្សាវតារព្រះអង្គម្ចាស់នប្បុរត្ន័ ជាអត្ថបទសំណៅដើម សរសេរព្រះនាមព្រះអង្គថា 'ដួង" ដែលខុសគ្នាពីឯកសារទាំងឡាយដែលធ្លាប់សរសេរថា 'ឌួង"ដូច្នេះ។ អញ្ចឹងហើយ ទើបយើងយល់ថា គួរតែនាំគ្នាសរសេរព្រះនាមព្រះអង្គតាមឯកសារដើមវិញទើបប្រសើរ។

ឡាយត្រូវបានដោះស្រាយរួច អ្នកដែលសុំជំនួយគេតែងមានការអត់ឱនចំពោះមហិច្ឆតារបស់ម្ចាស់ជំនួយ ព្រោះខ្លួនជាអ្នកជំពាក់សារគុណរបស់គេ។ លើសនេះទៀត អ្នកដឹកនាំខ្មែរទាំងអស់នោះ ពិតជាគ្មានបានដឹង ឬចេះប្រវត្តិសាស្ត្រអ្វីទាំងអស់ ទើបគិតតែពីរត់ទៅជ្រកកោននៅបរទេស និងសុំឱ្យគេជួយអន្តរាគមន៍ដោយគ្មានអៀនខ្មាស។ បើសិនជាអ្នកដឹកនាំអស់ទាំងនោះ ដឹងអំពីព្រះកេរ្តិ៍ព្រះយស និងទង្វើរបស់បុព្វបុរសខ្លួន ដែលធ្លាប់ជាអ្នកអនុវត្តន៍នយោបាយមហាអំណាច តែងប្រើឱកាសជួយអ្នកដឹកនាំប្រទេសដទៃ ដើម្បីដាក់តាំងអំណាច ឬឥទ្ធិពលរបស់ខ្លួនលើប្រទេសនោះប្រហែលជាពួកគេមិនធ្វើដូច្នោះឡើយ។ ហើយរាល់គ្រាដែលពួកគេមានឱកាសជួយមេដឹកនាំប្រទេសជិតខាងដែលរត់មកពឹងខ្លួន ពិតជាពួកគេចេះឆ្លៀតឱកាសនោះ ចម្រាញ់យកប្រយោជន៍ដូច អ្នកជិតខាងចម្រាញ់យកពីខ្លួនជាខ្មែរដូច្នោះដែរ។

## 3. ការញុះញង់បំបែកបំបាក់ពីប្រទេសជិតខាង

ក្នុងជម្លោះព្រះអង្គសូរ និងព្រះអង្គតន់ ដែលសងសឹកនឹងព្រះរៀមជីដូនមួយ គឺព្រះរាមាធិបតីអង្គចន្ទដែលបានធ្វើគតព្រះបិតាទ្រង់ គឺព្រះឧទ័យរាជា ពេលនោះ ព្រះអង្គទាំងពីរក៏រៀបចំគម្រោងការសងសឹកវិញ។ បងប្អូនទាំងពីរ ក៏ចាត់ឱ្យមន្ត្រីទៅចលនារាស្ត្រនៅភាគខាងកើត ចាប់ពីខេត្តស្រីសន្ធរទៅត្បូង។ ចំណែកឯព្រះអង្គចូវ(បុត្រីព្រះចៅង៉ៀន អតីតអគ្គមហេសីរបស់ព្រះជយជេដ្ឋាទី២) ទ្រង់ជួយដល់ព្រះអង្គម្ចាស់ទាំងពីរ ដោយចាត់មន្ត្រីសម្ងាត់ទៅបញ្ចុះបញ្ចូលរាស្ត្រនៅខេត្តបាទី ខេត្តទ្រាំង បន្ទាយមាស កំពតកំពង់សោម បាសាក់ ព្រះត្រពាំង និងត្រើយខាងកើងខ្លះ។ នៅក្នុងការប្រយុទ្ធគ្នាមិនឈ្នះមិនចាញ់ ដោយកម្លាំងទាំងសងខាងស្មើគ្នានោះ ព្រះអង្គសូរ ក៏យកសេចក្ដីក្នុងការប្រយុទ្ធគ្នាទៅរៀបរាប់ថ្វាយព្រះអង្គចូវជ្រាប និងទ្រង់ស្នើសុំព្រះអង្គចូវ ផ្ញើសារមួយទៅព្រះចៅក្រុងវ៉េ។ ព្រះអង្គចូវទ្រង់ពិភាក្សាជាមួយនឹង "អ្នកស្ដេចខ្លួនធំ"(ជាស្វាមីទី២ របស់ព្រះនាងអង្គចូវ បន្ទាប់ពីព្រះបាទជយជេដ្ឋាទី២ សោយទិវង្គតទៅ។ សេចក្ដីក្នុងសារផ្ញើទៅស្ដេចក្រុងវ៉េ មានដូចតទៅ៖

ព្រះបាទរាមាធិបតី ព្រះចៅកម្ពុជា ស្ដេចទ្រង់ប្រព្រឹត្តិនូវអំពើមិនគប្បី ៥ប្រការ ៖

- ទ្រង់លបលួចធ្វើគតសម្ដេចព្រះឧទ័យមហាឧបរាជ ដែលមានព្រះគុណធ្ងន់លើព្រះអង្គ
- ទ្រង់ធ្វើគតព្រះបទុមរាជា ដណ្ដើមយករាជសម្បត្តិពុំគិតដល់ព្រះគុណដែលទ្រង់ព្យាយាមធ្វើឱ្យបានសេចក្ដីរុងរឿងនោះឡើយ។
- ទ្រង់បោះបង់ចោលព្រះពុទ្ធសាសនា និងជាតិសាសន៍ខ្មែរ ហើយចូលសាសន៍ចាម ជ្វា រួចត្មះតិះដៀលជាតិយួនទៀត។
- ទ្រង់លើកតែមន្ត្រីចាម ជ្វា ឱ្យមានអំណាចកំហែងគំរាមមន្ត្រីខ្មែរ-យួន ពុំគិតដល់ការចងមេត្រីភាព ដើម្បីសេចក្ដីសុខសាន្ត។
- ក្នុងព្រះនគរកើតមានចោរលួចប្លន់ ចលាចល ពុំបានប្រាបប្រាមបានរៀបរយ។ គង់ប្រកិតប្រកើយតែអ្នកម្នាងវ៉ាស ប៉ុណ្ណោះ ធ្វើឱ្យរាស្ត្រក្ដៅក្រហាយពន់ពេកណាស់។

ខ្ញុំព្រះរាជការ មន្ត្រីតូចធំ សូមព្រះតេជានុភាពព្រះចៅក្រុងវ៉េ មហានគរចាត់កងទ័ពទៅកំចាត់ចេញ ដើម្បីមន្ត្រីរាស្ត្របានសេចក្ដីសុខតទៅ។

យួនបានឱកាស ក៏លើកទ័ពលុកលុយស្រុកខ្មែរភ្លាម ដើម្បីជួយព្រះអង្គម្ចាស់ទាំងពីរអង្គ ដែលប្រទុស្តរាយនឹងព្រះមហាក្សត្រ។ មិនត្រឹមប៉ុណ្ណោះ មេទ័ពយួនឈ្មោះ អុងកូបៀង ចង់ឆ្លៀតលេបយកស្រុកខ្មែរតែម្ដង។ អ្នកសុំជំនួយ ត្រូវ

ប្រឈមមុខប្រយុទ្ធជាមួយមហាមិត្តមិនស្មោះត្រង់នេះវិញ នៅម្តុំវត្តស្បែង (ចន្លោះឧដុង្គ និងកំពង់ហ្លួង)។ សំណាងល្អហើយ ដែលពួកគេអាចវាយឈ្នះកងទ័ពរបស់អុង ភូបៀង។

ទៅដល់ស្រុកវិញ អុង ភូបៀង បានទូលថ្វាយព្រះចៅក្រុងវេ នូវពាក្យប្រឌិតញ៉ុះញង់ថា ព្រះអង្គសូរ និងព្រះអង្គតន់ បានប្រែក្រឡាសតាំងខ្លួនជាសត្រូវវិញ ដោយលើកទ័ពមកសម្លាប់ទាហានយួនស្លាប់អស់ជាច្រើនធ្វើឱ្យព្រះចៅអាណ្ណាម ខ្ញាល់ពន់ប្រមាណ ហើយលើកគោលការណ៍ផ្តាច់ស្ពានមេត្រីភាពជាមួយកម្ពុជា ដោយប៉ុនប៉ងប្រើប្រាស់កូនអុកមួយ ដែលមានក្នុងដៃស្រាប់មកសោយរាជ្យនៅកម្ពុជាវិញ។ នោះគឺការបញ្ជូនព្រះរាមាធិបតីចន្ទមកវិញ។ ប៉ុន្តែនៅក្នុងដំណើរបញ្ជូនត្រឡប់មកកម្ពុជា ដោយនឹកតូចព្រះទ័យពេក ព្រះរាមាធិបតី ធ្លាក់ខ្លួនឈឺជាទម្ងន់ ហើយក៏សុគតនៅតាមផ្លូវនៅត្រង់ម្តុំស្រុកបាក់ចិញៀន ក្នុងដែនដីកម្ពុជាក្រោម (ឯកសារខ្លះថា យួនឃុំព្រះអង្គរហូតដល់សុគតតែម្តង) ដែលជាហេតុធ្វើឱ្យស្តេចវេ ខកបំណង។

នៅរវាងឆ្នាំ ១៦៧០ ព្រះអង្គសូរ ទ្រង់រៀបក្បួនដង្ហែសពព្រះរាមាធិបតីចន្ទ ពីស្រុកបាក់ចិញៀនមកធ្វើបុណ្យហើយទ្រង់បញ្ជាឱ្យបញ្ចុះអដ្ឋិធាតុព្រះអង្គក្នុងចេតិយ៍លើភ្នំព្រះរាជទ្រព្យ។

ទោះជាយ៉ាង ព្រះអង្គម្ចាស់មួយអង្គ ក្នុងចំណោមពីរអង្គនោះ ជាក្សត្រមានប្រាជ្ញាឆ្លៀសវៃគ្រាន់បើនៅពេលបានឡើងសោយរាជ្យនៅអំឡុងដើមទសវត្សរ៍ឆ្នាំ១៦៩០ ក្រោមព្រះនាម ព្រះជយជេដ្ឋាទី៣ អង្គស៊ូ ចាប់ផ្តើមនយោបាយបង្រួបបង្រួមរាជវង្សានុវង្សឡើងវិញ ដើម្បីកុំឱ្យប្រទេសជិតខាងឆ្លៀតប្រើប្រាស់ពួកគេធ្វើជាលេសលុកលុយស្រុកខ្មែរ និងដាក់គំនាបលើរាជវាំងខ្មែរតទៅទៀត។ ទ្រង់បាននឹកគិតទៅដល់ព្រះអង្គអិម(បុត្រាព្រះអង្គនន់ ដែលជាអតីតគូបដិបក្ខរបស់ទ្រង់) ដែលបានខ្ចាត់ព្រាត់ទៅស្រុកយួនតាំងពីយូរមកហើយ។ ព្រះអង្គ បានបញ្ជាឱ្យរាជទូតនាំព្រះរាជសារទៅថ្វាយព្រះចៅអាណ្ណាម ដើម្បីសុំព្រះអង្គអិម ត្រឡប់មកវិញ។ ព្រះចៅអាណ្ណាមទ្រង់អញ្ជើញព្រះអង្គអិមមកសួរនាំដោយមានបន្ទូលថា៖ "ឥឡូវនេះព្រះចៅក្រុងកម្ពុជា សុំក្មួយត្រឡប់ទៅវិញ មាមិនចង់ឱ្យក្មួយត្រឡប់ទៅទេ។ ព្រោះ មាមានគម្រោងយករាជសម្បត្តិ និងនគរកម្ពុជាមកថ្វាយក្មួយឱ្យបាន។ ម្យ៉ាងទៀត ព្រះចៅកម្ពុជាសព្វថ្ងៃនេះខ្លាំងពូកែ និងវាងវៃណាស់។ មាភ័យក្រែង នេះជាឧបាយកលយកក្មួយទៅធ្វើទោសទេក៏មិនដឹង? រឿងនេះ គឺស្រេចតែក្មួយគិតគូរចុះ"។ ដោយមិនអាចបញ្ចុះបញ្ចូលព្រះអង្គអិមបាន ព្រោះទ្រង់ក៏មានបំណងរកសន្តិភាពជាមួយព្រះអង្គស៊ូជាមាជីដូនមួយ ដើម្បីបានត្រឡប់មកកម្ពុជាវិញដែរ។ ព្រះចៅអាណ្ណាមក៏ទ្រង់ត្រាស់ចាក់បណ្តោយថា "បើក្មួយចង់ត្រឡប់មកកម្ពុជាវិញ មាក៏ជួយត្រេកអរដែរ"។ ព្រះអង្គចាត់ឱ្យរៀបទ័ព ៥០០នាក់ជាចំណងដៃ និងគ្រឿងបណ្ណាការ ហើយទ្រង់ផ្តាំផ្ញើតាមរាជទូតខ្មែរឱ្យនាំសារថ្វាយព្រះចៅកម្ពុជាថា ៖ "ប្រទេសអាណ្ណាមមានបំណងចងស្ពានមេត្រីជាមួយនគរកម្ពុជាយូរអង្វែង"។

ក្រោយមកមានមន្ត្រីក្បត់ គឺ នរិន្ទអិម ដែលជាអតីតមន្ត្រីជាន់ខ្ពស់ម្នាក់ ក្រោយពីត្រូវព្រះរាជាបកស័ក្តិទម្លាក់បុណ្យ ក៏ស្កាត់ជួបមេទ័ពយួន ថ្លែងប្រឌិតអំពីកិច្ចការផែនដីថា "ព្រះចៅក្រុងកម្ពុជា សព្វថ្ងៃពុំប្រកបដោយទសពិធរាជធម៌ទេ។ ប្រជារាស្ត្រជួបតែនឹងសេចក្តីក្តៅក្រហាយ។ មិនតែប៉ុណ្ណោះ ទ្រង់ចាត់ហ្វឹកហាត់សេនាទាហាន ហើយប្រឹក្សាជាមួយមន្ត្រីរាជការបម្រុងនាំរាជសារទៅស្រុកសៀម ពឹងសៀមឱ្យជួយកម្លាំងត្រៀមលើកទ័ពមកវាយប្រទេសអាណ្ណាមដាក់ជាចំណុះ។ ការដែលសុំព្រះអង្គអិម ទៅវិញនោះ គឺគ្រាន់តែជាឧបាយកល ដើម្បីកាត់ផ្តាច់កម្លាំងខាងយួនតែប៉ុណ្ណោះ។ ក្នុងការប្រជុំ ខ្ញុំបានទូលជំទាស់ចំពោះព្រះតំរិះ ប៉ុន្តែព្រះអង្គទ្រង់មិនស្តាប់ខ្ញុំ ហើយត្រឡប់ជាខ្ញាល់នឹងខ្ញុំ ចាត់ឱ្យគេយកខ្ញុំទៅដាក់គុកហូតងារថែមទៀត។ ខ្ញុំខ្មាស់គេណាស់ ទើបលួចរត់ចេញមកពឹងពាក់បារមីព្រះចៅអាណ្ណាម ដើម្បីធ្វើការបម្រើលុះអស់ជីវិត។ ដូចនេះសូមលោកជួយយកសេចក្តីនេះ ទូលថ្វាយព្រះចៅអាណ្ណាម ហើយសូមទូលថ្វាយ

ឱ្យចាត់កងទ័ពលើកទៅវាយព្រះចៅកម្ពុជា ដែលកំពុងងាកទៅរកចងស្ពានមេត្រីនឹងសៀម។ ព្រោះឥឡូវនេះ ព្រះអង្គទ្រង់ពុំទាន់ចាត់រាជទូតទៅពឹងសៀមនៅឡើយទេ។˝ នេះជាការញ៉ុះញង់ពីសំណាក់អតីតមន្ត្រីខ្មែរ ដើម្បីបង្កការមិនទុកចិត្តគ្នារបស់ប្រទេសទាំងពីរ និងឈានទៅរកជម្លោះយួន និងខ្មែរម្តងទៀត។

នៅឆ្នាំ ១៦៩៩ កងទ័ពព្រះកែវហ្វ៊ាអង្គអិម និងទ័ពព្រះស្រីធម្មរាជា(រាជបុត្រព្រះអង្គសូ៊) ប្រយុទ្ធតទល់នឹងកងទ័ពយួន ទីបំផុតទ័ពព្រះកែវហ្វ៊ាអង្គអិមចាប់បាន នរិន្ទអិម ដែលជាមន្ត្រីក្បត់ប្រហារជីវិតដោយកាត់ក្បាល និងពលយួន២០០ នាក់បញ្ជូនទៅធ្វើការកសិ ុនៅតាមមាត់ទន្លេសាប។ ពួកយួនក្រាញនៅលើដីខ្មែរត្រង់ ព្រៃនគរ កំពង់ស្រកាត្រី និងបារា ដែលនរិន្ទអិមសន្យាថា ទុកជាថ្នូរនឹងជំនួយទ័ពយួនសម្រាប់ខ្លួនពឹងយួនឱ្យវាយជាតិឯង។ ចាប់ពីឆ្នាំ១៦៩៩ ខេត្តទីមួយនៅភាគខាងត្បូងដែលយើងបាត់ គឺខេត្តបារៀ។

រហូតដល់ឆ្នាំ១៧៥៨ យួនបានមកតាំងនៅគ្រប់ខេត្តនៃដែនដីកម្ពុជាក្រោម។ ក្រោយពីព្រះអង្គអេងសោយទិវង្គតទៅ បល្ល័ង្កក្រុងឧដុង្គនៅទំនេរ អស់រយៈពេល ១០ឆ្នាំ ដោយព្រះអង្គម្ចាស់កម្ពុជាខ្លះជាប់នៅប្រទេសសៀម ខ្លះជាប់នៅប្រទេសយួន។ ម្ល៉ោះហើយនៅស្ថានភាពទូទៅនៅប្រទេសកម្ពុជា ពុំមានស្ថេរភាពឡើយ។ រហូតដល់ឆ្នាំ ១៨០៦ ទើបស្តេចសៀមដែលជាអាណាព្យាបាលប្រទេសកម្ពុជា បានលើកព្រះអង្គចន្ទដែលមានព្រះជន្ម១៥ឆ្នាំជារាជបុត្រព្រះអង្គអេង ឱ្យឡើងសោយរាជ្យជាមហាក្សត្រកម្ពុជា(១៨០៦-១៨៣៤)។ ជាមួយគ្នានេះស្តេចក្រុងវ៉េ បានបញ្ជាឱ្យអ្នកនាំសារម្នាក់នាំវត្ថុអនុស្សាវរីយ៍ជាត្រាមាសមួយ យកមកថ្វាយព្រះអង្គចន្ទ។ ត្រាមាសនោះ ជានិមិត្តរូបនៃសាមន្តរាជភាពកម្ពុជាចំពោះស្តេចក្រុងវ៉េ។ ដើម្បីឱ្យមានប្រៀបជាងក្រុងវ៉េ ស្តេចសៀមបានប្រគល់គោរម្យងារជាន់ខ្ពស់ដល់ពួកអភិជនកម្ពុជា ដែលជាបរិពារក្រុងឧដុង្គ។ ស្តេចសៀម បានអូសទាញចៅហ្វាយខេត្តបាត់ដំបងឱ្យប្រឆាំងនឹងស្តេចកម្ពុជា។ ដើម្បីទប់ទល់នឹងស្ថានភាពបែបនេះ ព្រះអង្គចន្ទបានចេញបញ្ជាឱ្យចាប់ខ្លួនមន្ត្រីណា ដែលមាននិន្នាការខាងសៀម។ ម្ល៉ោះហើយស្តេចសៀម ក៏បញ្ជូនកងទ័ពជាបន្ទាន់ចូលមកខេត្តបាត់ដំបង។

ព្រះអង្គចន្ទ បានរៀបចំផែនការទប់ទល់ដោយបញ្ជូនអ្នកនាំសារពីរនាក់ទៅក្រុងវ៉េ ដើម្បីសុំជំនួយដែរ។ ចាប់ពីពេលនោះមក ព្រឹត្តិការណ៍ច្របូកច្របល់កើតមានជាបន្តបន្ទាប់ទូទាំងប្រទេស រហូតដល់ព្រះអង្គចន្ទចូលទិវង្គត។

គួរកត់សម្គាល់ថា នៅពេលដែលព្រះអង្គចន្ទ ឡើងសោយរាជ្យសម្បត្តិនោះ ព្រះអនុជរបស់ព្រះអង្គនាម អង្គអិម និងអង្គដួង បានយាងទៅគង់នៅឯប្រទេសសៀម ជាហេតុធ្វើឱ្យព្រះអង្គចន្ទងាករេកាន់តែស៊ប់ទៅរកក្រុងវ៉េ។ នៅពេលដែលព្រះអង្គចន្ទចូលទិវង្គតនៅឆ្នាំ១៨៣៤ នៅក្នុងប្រទេសកម្ពុជាពុំមានក្សត្រាសម្រាប់សោយរាជ្យទេ។ ហេតុនេះហើយ បានជាក្រុងវ៉េកំពុងតែមានឥទ្ធិពលខ្លាំងលើកិច្ចការកម្ពុជានោះ ក៏បានលើកក្សត្រីអង្គម៉ី ជាបុត្រីព្រះអង្គចន្ទ ឱ្យឡើងសោយរាជ្យ។ ឆ្លៀតឱកាសល្អប្រសើរនេះ នាហ្មឺនមន្ត្រីវៀតណាមជាច្រើននាក់ បានជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងព្រះរាជាណាចក្រកម្ពុជាកាន់តែខ្លាំងឡើងៗ។

## 4. អនិស្សរភាពរបស់ព្រះមហាក្សត្រ

សម័យឧដុង្គ គេឃើញថា ខ្មែរបាត់នៅឥស្សរភាពរបស់ខ្លួន ដោយសារតែវិបត្តិដែលមានក្នុងរាជវង្សានុវង្សធ្វើឱ្យប្រទេសជិតខាងលូកដៃចូលមកធ្វើអន្តរាគមន៍ ទីបំផុត ដើម្បីបានអំណាចត្រួតត្រាលើបយួន និងសៀម។ ព្រះមហាក្សត្រខ្មែរត្រូវទៅទទួលការអភិសេកនៅបរទេស និងមានភ្នាក់ងារបរទេសនៅក្នុងរាជវាំងខ្មែរ។សៀមលែងយ៉ាងណាឱ្យក្សត្រស្នងរាជ្យខ្មែររស់នៅក្នុងអំណាចរបស់គេ បើចង់តាំងក្សត្រអង្គណាមួយជាមហាឧបរាជ ឬព្រះកែវហ្វ៊ា ក៏ត្រូវសុំការអនុញ្ញាតពីសៀមដែរ។ ឧបាយកលរបស់គេ សុទ្ធតែបានទទួលលទ្ធផលដូចបំណងរបស់គេមែន។ ព្រះរាមាធិបតីអង្គ

នន់ បានឡើងសោយរាជ្យនៅឧដុង្គដោយសារតែសៀមជួយជ្រោមជ្រែង។ ដូចនេះហើយ បានជានៅក្នុងឱកាសសៀមច្បាំង នឹងលាវក្នុងឆ្នាំ១៧៧៨ ព្រះរាមាធិបតីអង្គនន់ ខំកេណ្ឌប្រុសខ្មែរឱ្យទៅជួយសៀម និងស្រីខ្មែរឱ្យបុកអង្ករ រៀបចំស្បៀងសម្រាប់ជួយឧបត្ថម្ភកងទ័ពខ្មែរផង ទ័ពសៀមផង។ អ្នកណាប្រព្រឹត្តប្រឆាំងនឹងព្រះរាជអាជ្ញានេះ នឹងត្រូវប្រហារជីវិត។ ក្រៅពីអង្គនន់ សៀមបានចាត់មន្ត្រីខ្មែរ ជំនិតម្នាក់ឱ្យទៅជួយមើលការខុសត្រូវ គឺឧកញ៉ាអភ័យធិបេស បែន ឱ្យត្រួតត្រាលើប្រទេសខ្មែរ (នៅពេលក្រោយមកត្រួតត្រាភាគពាយព្យ និងខាងជើង)។ នៅឆ្នាំ១៧៩១ ក្នុងការគ្រប់គ្រងរបស់បែន បានកេណ្ឌខ្មែរយកទៅធ្វើការឱ្យសៀម គឺជួយជីកព្រែកជីកស្រះ ជុតឥដ្ឋនៅវត្តស្រះកែវ។ លុះដឹងថារាស្ត្រខ្មែរក្តៅក្រហាយនឹងបែនខ្លាំង ទើបសៀមអនុញ្ញាតឱ្យស្តេចអង្គអេង យាងមកសោយរាជ្យនៅឧដុង្គវិញ។

នៅគ.ស.១៧៩៤ ព្រះអង្គអេង ត្រូវបានព្រះចៅសៀមរៀបអភិសេកនៅបាងកក ជាព្រះចៅនគរកម្ពុជាក្នុងព្រះជន្ម២២វស្សា ដោយមានព្រះនាមថា សម្តេចព្រះរាជឱង្ការព្រះនារាយណ៍រាមាធិបតីព្រះស្រីសុរិយោពម៌បរមសុរិន្ទ្រា។ ព្រះចៅសៀមទ្រង់តាំងឧកញ៉ាក្រឡាហោម ប៉ុក ជាចៅហ្វាទឡ្ហ ជាចៅហ្វាទឡ្ហៈជាចៅហ្វាទឡ្ហៈ បែន ហើយទ្រង់រៀបចំឱ្យដង្ហែព្រះអង្គអេង មកសោយរាជ្យ។ ព្រះចៅសៀមទ្រង់ស្នើតាំងចៅហ្វាទឡ្ហៈ មកសោយរាជ្យ។ ព្រះចៅសៀមទ្រង់ស្នើតាំងចៅហ្វាទឡ្ហៈបែន ជាស្តេចត្រាញ់ត្រួតត្រាខេត្តបាត់ដំបង និងសៀមរាប ដោយគាត់មានជម្លោះជាមួយចៅហ្វាប៉ុក ទើបគាត់គ្រប់គ្រងដែនដីភាគពាយព្យ និងខាងជើងភ្ជាប់ទៅខាងស្តេចសៀមផ្ទាល់(ឯកសារខ្លះថា បានជាស្តេចសៀមទ្រង់តាំងជាចៅហ្វាទឡ្ហៈ ជាស្តេចត្រាញ់ត្រួតត្រាខេត្តបាត់ដំបង និងសៀមរាប ដោយគាត់មានជម្លោះជាមួយចៅហ្វា ប៉ុក ទើបគាត់គ្រប់គ្រងដែនដីភាគពាយ័ព្យ និងខាងជើង ភ្ជាប់ទៅខាងស្តេចសៀមផ្ទាល់)។

សូមបញ្ជាក់ថា ចៅហ្វាទឡ្ហៈបែន ជាអតីតមន្ត្រីរបស់ព្រះអង្គនន់ ដោយសារគាត់មិនបានការពារស្តេចទាន់ពេល ធ្វើឱ្យមន្ត្រីបីនាក់បងប្អូននៅកំពង់ធំបះបោរកាប់សម្លាប់ព្រះអង្គចោល គាត់ត្រូវស្តេចសៀមកោះហៅពីស្រុកខ្មែរ រួចធ្វើទោសទណ្ឌកម្មដោយចៀរស្លឹកត្រចៀក។ ក្រោយមកស្តេចសៀម រកមន្ត្រីខ្មែរមានថ្វីដៃ ល្បិចកល និងស្មោះភក្តីដូចចៅហ្វាបែនមិនបាន ក៏ធ្វើជាអភ័យទោសឱ្យបែន ដើម្បីប្រើគាត់ឱ្យសាងគុណលាងទោស។ បែន បានទទួលងារថ្មីជា ឧកញាអភ័យធិបេស បែន មានន័យថា មន្ត្រីដែលបានទទួលរាជប្រទានលើកលែងទោស។ គាត់ត្រូវស្តេចសៀមបញ្ជូនចូលមកស្រុកខ្មែរដើម្បីកំចាត់មន្ត្រីក្បត់នឹងព្រះអង្គនន់ ទាំងអស់ ក្លាយជាអ្នកមានគុណបំណាច់ម្នាក់ដដែលចំពោះរាជការ។ ដោយគាត់ស្វាមីភ័ក្តិជាមួយខ្លួន និងខ្លាចក្រែងព្រះអង្គអេង កើតមានបញ្ហាជាមួយសៀមទៅថ្ងៃមុខ ស្តេចសៀមគាំទ្រភ្លាមចំពោះសំណើដែល បែន ចង់នាំខេត្តទាំងនោះឡើងទៅស្តេចសៀមដោយផ្ទាល់។ ម្យ៉ាងទៀតនេះ ក៏ជាលេសដើម្បីយកទឹកដីខ្មែរតាមសន្តិវិធី។

មុនពេលព្រះអង្គអេងទ្រង់សោយទិវង្គតនៅគ.ស.១៧៩៦ ក្នុងព្រះជន្ម២៥វស្សា ព្រះអង្គមានព្រះរាជបុត្រ៥អង្គគឺ **ព្រះអង្គចន្ទ ព្រះអង្គស្ងួន ព្រះអង្គអិម ព្រះអង្គភិម** និង**ព្រះអង្គដួង** ដែលគ្រប់អង្គសុទ្ធសឹងមានមហិច្ឆតាចង់ធ្វើស្តេចដូចៗគ្នា លើកលែងព្រះអង្គដួង ដែលជានិច្ចកាលស្ងប់ស្ងាត់មិនប្រជែងជាមួយព្រះរៀមទាំងបួនរបស់ខ្លួន។

ខែសីហា គ.ស.១៨០៦ ព្រះអង្គចន្ទ ក្នុងពេលមានព្រះជន្មត្រឹម១៦វស្សា ព្រះអង្គ បានទទួលរាជាភិសេកជាស្តេចខ្មែរ នៅឯក្រុងបាងកក ដោយមានព្រះនាមថា ព្រះបាទសម្តេចព្រះឧទ័យរាជារាមាធិបតីព្រះស្រីសុរិយោពម៌ ហើយទ្រង់យាងមកសោយរាជ្យនៅឧដុង្គមានជ័យវិញ។ សមាជិករាជវង្សានុវង្សភាគច្រើន រស់នៅស្រុកសៀម ទើបនៅឆ្នាំ១៨០៧ ព្រះអង្គទ្រង់ចាត់ព្រះកែវ អង្គដួង និងឧញ៉ាចក្រី កែប នាំគ្រឿងបណ្ណាការទៅថ្វាយព្រះចៅសៀម និងសុំឱ្យរាជ្យវង្សខ្លះបានយាងត្រឡប់មកកម្ពុជាវិញ។ តែស្តេចសៀមទ្រង់អនុញ្ញាតឱ្យតែព្រះមាតា និងព្រះអង្គពៅ យាងត្រឡប់មកវិញ។ ចៅ កម្ពុជៈ ដែលជារាជបុត្ររបស់ព្រះអង្គពៅ និងព្រះចៅវង្សតណា ក៏ស្តេចសៀមបានឃាត់ទុកដែរ។ ស្តេច

សៀម ធ្វើការតែងតាំងមន្ត្រី ជាពិសេសរាជវង្សានុវង្ស ដូចជា តែងតាំងព្រះអង្គស្ងួន ជាឧភយោរាជ និងតាំងព្រះអង្គអិម ជាឧបរាជ ដោយឥតមានប្រឹក្សានឹងព្រះរាជាខ្មែរឡើយ ហើយថែមទាំងបញ្ជាឱ្យកេណ្ឌរាស្ត្រខ្មែរយកទៅរក្សាក្រុងបាងកកទៀតផង។ដោយការមិនទុកចិត្តសៀម ព្រះអង្គចន្ទទ្រង់បានងាកទៅជិតជិតជាមួយយួន ហើយលើកសួយសារអាករទៅថ្វាយស្តេច យ៉ាឡុង រាល់៣ឆ្នាំម្តង ។ ប៉ុន្តែជាមួយគ្នានោះ ព្រះអង្គក៏ទ្រង់នាំបណ្ណាការទៅថ្វាយស្តេចសៀមតាមទំនៀមដែរ។ ស្តេចសៀមនៅតែមិនសព្វព្រះទ័យទេ ចំពោះការដែលព្រះអង្គចន្ទទាក់ទងជាមួយនឹងយួន ទ្រង់បានបញ្ជាទ័ពចំនួន៥០០០នាក់ ឱ្យចូលមកកម្ពុជា ដោយយកលេសថា មកជួយធ្វើបុណ្យសពព្រះអង្គកែវដួង។ ប៉ុន្តែតាមការពិត សៀមលើកទ័ពតាមផ្លូវគោក(តាមខេត្តបាត់ដំបង និងតាមខេត្តស្ទឹងត្រែង) និងតាមជើងទឹក គឺដើម្បីជួយសម្រេចកិច្ចការផែនដីថ្វាយព្រះអង្គស្ងួន។ ទ័ពចំរុះ"ខ្មែរ-សៀម" ប្រយុទ្ធគ្នានឹងទ័ពចំរុះ "ខ្មែរ-យួន" តាមជើងគោក និងតាមជើងទឹក។ ទ័ពចំរុះខ្មែរសៀមមានប្រៀបជាងវាយបំបាក់ទ័ព"ខ្មែរយួន"ឱ្យដកថយជាបន្តបន្ទាប់។ លុះទ្រង់ជ្រាបសភាពការណ៍សឹកយ៉ាងនេះហើយ ព្រះអង្គចន្ទទ្រង់ប្រឹក្សាជាមួយមន្ត្រីសេនាបតីដកថយពីឧដុង្គមានជ័យ ទៅប្រថាប់នៅកំពង់ពោធិតូច ដើម្បីរៀបចំបន្តដំណើរទៅកម្ពុជាក្រោម។ នាពេលនោះ នៅយប់មួយនៅស្រុកតឹងចូវ ព្រះអង្គអិម និងព្រះអង្គឌួង បានប្រឹក្សាជាមួយព្រះមាតាសម្រេចគេចចេញពីព្រះអង្គចន្ទ ជាព្រះរៀម ដែលទ្រង់មិនព្រមចងស្ពានមេត្រីជាមួយសៀម ហើយទ្រង់ចងស្ពានមេត្រីជាមួយយួនដែលមានសាសនាខុសគ្នាទៅវិញ។

ព្រះអង្គអិម ព្រះអង្គដួង និងព្រះវរមាតា ទ្រង់យាងមកជួបជុំនឹងព្រះអង្គស្ងួន នៅឧដុង្គមានជ័យរួចហើយ ទ្រង់នាំមន្ត្រីរាជការខ្ញុំបំរើទៅប្រទេសសៀម ដោយទុកមន្ត្រីសេនាបតីខ្មែរ សៀមខ្លះ ឱ្យចាំថែរក្សារាជវាំងនៅគ.ស. ១៨១២។

នៅគ.ស១៨១៤ ឡេ វ៉ាន់យៀក បានការអនុញ្ញាតពីស្តេចយួនឱ្យសង់បន្ទាយនៅភ្នំពេញ និងនៅល្វាឯម ហើយដាក់ទ័ព ១០០០នាក់ ប្រចាំការធ្វើអាណាព្យាបាលលើកម្ពុជា។ ឡេ វ៉ាន់យៀក បានចាត់ឱ្យលើកដីសង់ «ដំណាក់ព្រះបារមី» មួយនៅជ្រោយចង្វារសំរាប់មន្ត្រីយួនខ្មែរទៅសំពះរំលឹកគុណស្តេចយួន។ ពេលនោះទាំងព្រះរាជា ទាំងនាម៉ឺនសព្វមុខមន្ត្រីស្លៀកពាក់តាមរបៀបយួន។

ព្រះបាទឧទ័យរាជាអង្គចន្ទ ទ្រង់មានបុត្រីបួនអង្គគឺ អង្គប៉ែន អង្គម៉ី អង្គពៅ និងអង្គស្ងួន។ នៅពេលដែលព្រះអង្គចន្ទសោយទិវង្គតទៅ ព្រះចៅ មិញ ម៉ាង ដែលជារាជបុត្រស្តេចយ៉ាឡុង ទ្រង់ចាត់អុង ខាំម៉ាង ជារាជទូតឱ្យនាំគ្រឿងបណ្ណាការមកជួយបុណ្យព្រះបរមសព និងដើម្បីចូលរួមជ្រើសរើសក្សត្រគ្រងរាជ្យបន្ត ។ បន្ទាប់មកមន្ត្រីសេនាបតី និង អុង ខាំម៉ាង ជំនុំព្រមអញ្ជើញព្រះអង្គម៉ី ជាព្រះរាជបុត្រីទី២ ឱ្យឡើងសោយរាជ្យ នៅកោះស្លាកែតក្នុងព្រះជន្ម២០វស្សា។ ព្រះអង្គប៉ែន ជាបុត្រីច្បងមិនត្រូវបានគេជ្រើសរើសទេ ពីព្រោះអ្នកម្ទាងទេព ជាព្រះមាតាកំពុងគង់ឯស្រុកសៀម។ ក្សត្រីអង្គពៅ ត្រូវបានតាំងជាឧបរាជិនី និងក្សត្រីអង្គស្ងួនជា កែវហ្វា។ ការយាងក្សត្រីឱ្យគ្រងរាជ្យមិនបានធ្វើឱ្យរាស្ត្រងឿងឆ្ងល់ខ្លាំងពេកទេ ពីព្រោះគេធ្លាប់ដឹងថា មានព្រះរាជាខ្លះដែរ ដែលដក់ព្រះទ័យក្នុងការកសាងព្រះផ្នួស ហើយទ្រង់ផ្ទេរអំណាចផែនដីឱ្យទៅព្រះអគ្គមហេសី ឬព្រះមាតាដែរ។

ក្សត្រីអង្គម៉ី ពុំមានអំណាចអ្វីធំដុំទេ។ យួនបានបន្ទាបឋានៈរបស់ព្រះនាង មកត្រឹមតែចៅហ្វាយខេត្តតែប៉ុណ្ណោះ។ មេទ័ពនឹងមន្ត្រីយួនគ្រប់ជាន់ថ្នាក់ សរុប១០៧ នាក់ បានចាត់ការគ្រប់យ៉ាងជំនួសខ្មែរ និងផ្លាស់ឈ្មោះប្រទេស ខេត្ត ស្រុករបស់ខ្មែរទៅជាភាសាយួន។ យួនបង្រួញចំនួនខេត្តខ្មែរពី៥៥មកនៅត្រឹមចំនួន៣៣វិញ។

## 4.1. ការលូកដៃរបស់ព័រទុយហ្គេក្នុងទំនាស់រាជវង្សខ្មែរ

ជននៅអឺរ៉ុប បានមកដល់ប្រទេសយើងនៅកំឡុងសតវត្សរ៍ទី១៦ ដែលមានសង្ឃជាតិព័រទុយហ្គាល់នាម ហ្គាស់ស្ប៉ាដាគ្រុយស៍ (Gaspar da Cruz)ក្នុងបំណងផ្សាយសាសនាគ្រិស្តនៅឆ្នាំ១៥៥៥។ បន្ទាប់មកមានអ្នកផ្សងព្រេងជាតិអេស្ប៉ាញ ឈ្មោះ រ៊ីស៍ ដឺ ហែរណង់ហ្គុងសាឡិស(Ruiz de Hernan Gonzales)និងវ៉ាហ្គាស់ ម៉ាស៊ូកា(Vargas Machuca) ដែលបានមកដល់នៅដើមគ.ស១៥៩៣។ ខ្មែរ ក៏បានទាក់ទងជាមួយជនជាតិអង់គ្លេសនៅគ.ស១៦១២ ផងដែរ។បន្ទាប់មកទៀតយើងមានទំនាក់ទំនងជាមួយជនជាតិហុល្លង់ឈ្មោះហ្សាកុបហ្គែម៉ាន់(Jacob Garman)ដែលបានមកដល់ភ្នំពេញនៅគ.ស១៦២០ ហើយនៅគ.ស១៦២៣ ជនជាតិហុល្លង់បានបង្កើតគ្រឹះស្ថានជំនួញជាលើកដំបូងនៅកំពង់ហ្លួង។ នៅអំឡុងពេលប្រហែលជាគ.ស ១៨៥៥ ទើបយើងមានទំនាក់ទំនងជាមួយ និងជាតិបារាំងដែលជាគណៈបេសកទូតកាតូលិកឈ្មោះ មីស។ គេសង្កេតឃើញថា ចាប់ពីសតវត្សរ៍ទី១៦ ដល់១៩ ទំនាក់ទំនងជាមួយនឹងពួកបរទេសមានបន្តគ្នាជាលំដាប់ មុនពេលឈានមករករបបអាណាព្យាបាលបារាំង។

តើទំនាក់ទំនង ជាមួយនឹងបរទេសទាំងនេះក្នុងបំណងអ្វី? ជនព័រទុយហ្គាល់ និងអេស្ប៉ាញធ្លាប់មានការទាក់ទងនឹងកម្ពុជា តាំងពីចុងរជ្ជកាលព្រះបាទអង្គចន្ទទី១ ដូចយើងបានដឹងហើយថា គោលបំណងសំខាន់របស់ពួកនេះ គឺ ផ្សាយគ្រឹស្តសាសនា និងធ្វើជំនួញ។ ព្រះសត្ថា ព្រះអង្គសព្វព្រះរាជហឫទ័យណាស់និងជនជាតិព័រទុយហ្គាល់ម្នាក់ឈ្មោះវេឡូសូ(Veloso) និងជនជាតិអេស្ប៉ាញម្នាក់ទៀតឈ្មោះថា រ៊ីស(Ruiz)។ ព្រះអង្គបានលើកព្រះអង្គក្សត្រីមួយអង្គ ឱ្យធ្វើជាភរិយាដល់វេឡូសូ និងលើក រ៊ីសឱ្យធ្វើជាព្រះរាជអង្គរ័ក្ស។ ក្នុងសម័យដែលសៀមវាយលង្វែកជនទាំងនេះ ជនពីរនាក់នេះ បានជួយយកអាសារព្រះរាជាខ្មែរ ក្នុងការទប់ទល់នឹងសៀម រហូតដល់សៀមចាប់បានធ្វើជាឈ្លើយនាំយកទៅក្រុងអយុធ្យា។ ក្នុងរជ្ជកាលព្រះរាមាជើងព្រៃ, វេឡូសូ និងរ៊ីស ត្រូវសៀមដោះលែង ហើយបានចូលមកកម្ពុជាទៀត។ មានថ្ងៃមួយដោយមានការវិវាទរវាងពួកខ្លួន និងពួកចិន វេឡូសូបានទទូចសុំចូលគាល់ព្រះរាជាដើម្បីធ្វើយុត្តិកម្ម។ ទោមនស្សនឹងព្រះអង្គដែលមិនបើកឱ្យចូលគាល់តាមចិត្តខ្លួន វេឡូសូ និងរ៊ីស នាំទាហានទៅវាយប្រហារព្រះរាជវាំងនៅស្រីសន្ធរ។ ក្នុងពេលនោះព្រះបាទរាមាជើងព្រៃ ក៏បានសោយទិវង្គតទៅ។ នៅពេលក្រោយមក រ៊ីស និងវេឡូសូ បានទៅដល់ប្រទេសលាវជួបនឹងព្រះពញាតន់ ដែលជារាជបុត្រទី២នៃព្រះសត្ថា បានថ្លែងការណ៍សព្វគ្រប់ពីរាជវាំងលង្វែក និងការដែលខ្លួនទាំងពីរបានធ្វើឃាត ព្រះរាមាជើងព្រៃ ហើយក៏ដង្ហែព្រះពញាតន់ មកក្រុងស្រីសន្ធរដើម្បីគ្រងរាជ្យ។

ពួកបរទេស ពិសេសពួកព័រទុយហ្គេ នៅសម័យក្រោយមក ពួកនេះក៏មានតួនាទីសំខាន់ផងដែរ នៅក្នុងដំណោះស្រាយជម្លោះក្នុងរាជ្យវង្សានុវង្សខ្មែរ។ នៅរាជ្យព្រះពញាតូ(ព្រះរាជសំភារ)នៅពេលដែលជម្លោះដណ្តើមព្រះនាងបុប្ផាវតី ពីមានិងក្មួយ គឺព្រះពញាតូ និងព្រះឧទ័យដែលចុងក្រោយឈានទៅដល់ការសម្លាប់ព្រះពញាតូនោះ ក៏គេសង្កេតឃើញថា ក្នុងបញ្ហាជម្លោះនេះពួកព័រទុយហ្គេបានជួយយកអាសារព្រះឧទ័យ រហូតធ្វើគតព្រះពញាតូ បានសម្រេច។

រួមមកគេសង្កេតឃើញថា ក្រៅពីបំពេញមុខងារជាគណៈបេសកទូតបព្វជិត និងជាអ្នកជំនួញ ពួកព័រទុយហ្គាល់ ក៏បានទាក់ទងយ៉ាងជ្រៅក្នុងកិច្ចការរាជវង្សដែលធ្វើឱ្យមហាក្សត្រទុកព្រះទ័យលើពួកនេះ និងរាប់អានពួកនេះដោយស្មោះស្ម័គ្រ។

### 4.2. ការគាបសង្កត់ និងបាត់បង់ទឹកដីដោយសន្សឹមៗ

ជារៀងដរាបមកបុព្វបុរសខ្មែរជាច្រើន តែងតែតស៊ូការពារជាតិសាសន៍ និងទឹកដី ប៉ុន្តែដោយខ្វះការដឹកនាំឯកភាពពីសំណាក់ថ្នាក់លើ ដែលរវល់តែបែកបាក់គ្នា ទឹកដីត្រូវបាត់បង់ជាបណ្ដើរៗ។ ចាប់ពីការបែកបាក់បន្ទាយលង្វែកដោយសៀមវាយលុកនៅឆ្នាំ១៥៩៣មក ទឹកដីខ្មែរមួយចំណែកធំនៅឯនាយភ្នំដងរែកត្រូវបាត់បង់ជាស្ថាពរ។

ក្រោយមកទៀតជម្លោះដណ្ដើមអំណាចគ្នារវាងអ្នកដឹកនាំខ្មែរ មានកាន់តែញឹកញាប់ឡើងៗ។ ក្នុងការធ្វើឱ្យសម្រេចបំណងរៀងៗខ្លួន អ្នកដឹកនាំយើង បានបញ្ចុះបញ្ចូលកេណ្ឌរាស្ត្រឱ្យបង្ហូរឈាមគ្នា ហើយអ្នកខ្លះទៀតរត់ទៅពឹងពាក់ពួកបរទេស ឱ្យជួយគាំទ្រ ឱ្យចូលមកជួយសម្លាប់ជាតិឯង។ ទីបំផុតខ្មែរចុះខ្សោយ ជាហេតុនាំឱ្យប្រទេសជិតខាងលូកដៃចូលជ្រៀតជ្រែកផ្ទៃក្នុងរបស់ខ្មែរ តាមការប៉ុនប៉ងរបស់គេ ។

នៅមុន និងក្រោយឆ្នាំ១៦២៣ ខ្មែរមិនទាន់មានខេត្តណាមួយ នៅភាគខាងត្បូងត្រូវបាត់បង់ទៅយួននៅឡើយ។ ខេត្តទីមួយនៅភាគខាងត្បូងដែលបាត់មុនគេ នៅគ.ស.១៦៩៩ គឺខេត្តបារៀ។ បន្តមកទៀតប្រទេសអាណ្ណាមបានទន្ទ្រានយកខេត្តខាងត្បូងរបស់ខ្មែរបន្តបន្ទាប់។ រហូតមកដល់គ.ស.១៧៥៨ យួនបានមកតាំងនៅគ្រប់ខេត្តនៃដែនដីកម្ពុជាក្រោម ។

ក្នុងការទន្ទ្រានយកខេត្តរបស់ខ្មែរ គេកត់សម្គាល់ឃើញថា ស្ដេចអាណ្ណាមបានប្រើយុទ្ធវិធីមួយចំនួនដូចតទៅ ៖

-នៅពេលដំបូង គឺការបង្កើតចំណងមេត្រីភាពផ្លូវការរវាងប្រទេសទាំងពីរ។ ដោយដាក់ភ្នាក់ងារ ដោយស្ងប់ស្ងៀម តែជាមនុស្សថ្នាក់ដ៏មានពិសពុល ដើម្បីប្រើវិធីញុះញង់សមាជិករាជវង្ស តាមបែបសមហេតុផល និងណែនាំពួកគេ ឱ្យទាក់ទងតែជាមួយយួន។

-ក្នុងពេលបន្ទាប់មក បង្កើតគុណបំណាច់លើមេដឹកនាំ ជាពិសេស នៅពេលពួកគេជួបនឹងវិបត្តិនៃការដណ្ដើមរាជសម្បត្តិគ្នា។

-ការចិញ្ចឹមបីបាច់សមាជិករាជវង្សានុវង្សខ្មែរ នៅស្រុករបស់ខ្លួន ដើម្បីកំហែងគំរាមដោយប្រយោលដល់អ្នកកាន់កាប់អំណាចនៅស្រុកខ្មែរ។

-ការសាកល្បងដណ្ដើមកាន់កាប់ស្រុកខ្មែរដោយផ្ទាល់ដៃតែងជួបប្រទះការលំបាក និងបរាជ័យយ៉ាងធាប់ហើស។ ម្ល៉ោះហើយ គេប្រើវិធីគ្រប់គ្រងដោយប្រយោលវិញ ដោយទំនុកបម្រុងមេដឹកនាំណា ដែលស្មោះស្ម័គ្រភក្ដីបម្រើប្រយោជន៍គេ។

#### ក-ចំណងការទូតផ្លូវការ

រជ្ជកាលរបស់ព្រះជ័យជេដ្ឋាទី២ ដែលមានអគ្គមហេសីជាក្សត្រីជាតិយួននោះ យួនបានសុំការអនុញ្ញាតពីមហាក្សត្រខ្មែរឱ្យជនជាតិគេមករស់នៅប្រកបរបររកស៊ីនៅក្នុងខេត្តកំពង់ក្របី និងកំពង់ស្រកាត្រីដែលជាខេត្តត្រូវឡើងសួយមកអគ្គមហេសី។ ក្រោយមកសុំសិទ្ធិដាក់ប៉ុស្តិ៍គយ ទារពន្ធពីជំនួញតាមទូកសំពៅនៅព្រៃនគរនៅឆ្នាំ១៦២៣។ ព្រះជ័យជេដ្ឋាទី២ ក៏យល់ស្របតាមសេចក្ដីសុំ។ មហាក្សត្រវៀ សុំសម្បទានដីនៅព្រៃនគរ ដើម្បីធ្វើបន្ទាយបង្វឹកកងទ័ព សម្រាប់ត្រៀមវាយប្រហារស្ដេចក្រុងហាណូយ។ ពេលចប់កិច្ចសន្យាស្ដេចវៀធ្វើមិនដឹង មិនព្រមប្រគល់អំណាចកាន់កាប់មកខ្មែរវិញ។ ស្ដេចខ្មែរ សោយរាជ្យបន្តបន្ទាប់មកពុំមានឆន្ទៈក្លៀវក្លាទារទឹកដីនេះមកវិញ។ ក្រោយមក មានរាមាធិបតីអង្គចន្ទ ដែលជាអ្នកសុំទារយកពីក្សត្រីអង្គចូវ ដែលមានឋានៈជា «សម្ដេចព្រះទាវ»។

ដោយមានការទាមទារកាន់តែសម្ញើញ អង្គចូវ ធុញនឹងការរិះរកល្បិចពន្យារពេល ក៏ជួយអុចឈ្នួនភ្លើងសង្គ្រាមស៊ីវិល នៅស្រុកខ្មែរ ធ្វើឱ្យអ្នកបះបោរលង់ខ្លួន។ បានឱកាសធ្លាក់អង្គចូវបានណែនាំ ក្សត្រចង់ឈ្នះរត់ទៅស្តេចក្រុងវ៉េ។

### ខ-ច្បាំងយកអំណាចឱ្យក្សត្រខ្មែរ

ព្រះអង្គនន់ មិនសប្បាយចិត្តនឹងព្រះបាទជ័យជេដ្ឋាអង្គសូ នៅទសវត្សរ៍១៦៨០-៩០ បានរត់ទៅសុំជំនួយពីស្តេចក្រុងវ៉េ ដើម្បីដណ្តើមអំណាច។ ទ័ពយួនលុកចូលក្រុងឧដុង្គ ចាប់បានព្រះមាតាស្តេចមកទុកនៅក្នុងបន្ទាយជ្រោយចង្វារ។ ព្រះសត្ថាអង្គជី បុត្រអង្គអិម ចៅអង្គនន់កាន់អំណាចនៅកម្ពុជាបាន ដោយសារអន្តរាគមន៍របស់កងទ័ពវ៉េ ដើម្បីទប់ទល់ជាមួយធម្មរាជា ដែលជាឱពុកមា។ ព្រះបាទនារាយរាជាអង្គតន់ព្រះបិតាស្តេចអង្គអេង ពឹងកងទ័ពយួន ដើម្បីប្រយុទ្ធជាមួយរាមាធិបតីអង្គនន់ ដែលពឹងទ័ពសៀមនៅអំឡុងទសវត្សរ៍ទី១៧៦០-៧០។ ចំណែកព្រះអង្គចន្ទទី៣ ដែលជាបុត្រច្បងព្រះអង្គអេង កាន់អំណាចបានជាង៣០ឆ្នាំបាន ដោយសារកងទ័ពយួនការពារទំនុកបម្រុង រហូតដល់ឆ្នាំ១៨៣៤។ ចំណែកបុត្រីស្តេចអង្គនេះ នាមអង្គម៉ី សោយរាជ្យដោយការលើកបន្តុបរបស់យួន និងមានមន្ត្រីយួនជាង១០០នាក់ធ្វើការរាជការ។

### គ-ចិញ្ចឹមសមាជិកក្សត្រខ្មែរទុក

ព្រះអង្គអិម ដែលជាបុត្រាព្រះអង្គនន់ ត្រូវយួននាំទៅទុកនៅក្រុងវ៉េ ពេលព្រះបិតាប្រឈួនស្លាប់ នៅពេលយួនប៉ុនប៉ងនាំមកសោយរាជ្យនៅកម្ពុជា។ បងប្អូន និងក្មួយៗរបស់ព្រះអង្គដួង ត្រូវវៀតណាមចាប់ទុកជាពិសេស ព្រះមាតារបស់ព្រះអង្គ ដែលជាហេតុបង្កឧបសគ្គ និងបង្កើតសង្គ្រាមយូរអង្វែងជាមួយយួនមុនពេលព្រះអង្គត្រូវយួនយល់ព្រមឱ្យឡើងសោយរាជ្យនៅឆ្នាំ១៨៤៥។

### ឃ-ការត្រួតត្រាខ្មែរដោយផ្ទាល់ និងប្រយោល

ការវាយប្រហារប្រុងប្រៀបវាយប្រហារលើព្រះអង្គម្ចាស់ខ្មែរពីរអង្គ ដែលបានពឹងខ្លួនឱ្យមកជួយបណ្តេញព្រះរាមាធិបតីអង្គចន្ទ នៅឆ្នាំ១៥៥៧ ត្រូវក្សត្រខ្មែរវាយបកវិញយ៉ាងទន់ហាន់។ នៅក្នុងរាជ្យស្តេចអង្គចន្ទទី៣ យួនជួយទំនុកបម្រុងព្រះអង្គ យកព្រះអង្គធ្វើជាខែល ដើម្បីប្រើប្រាស់ជនជាតិខ្មែរ និងកាន់កាប់ស្រុកខ្មែរ។ តែដោយសារចង់ឆាប់សម្រេចគោលដៅលេបខ្មែរក្នុងរយៈពេលខ្លី គេប្រើធម៌ក្តៅខ្លាំងពេក ជាពិសេសនៅក្នុងរាជ្យក្សត្រីអង្គម៉ី ត្រូវប្រជាជនខ្មែរបះបោរប្រឆាំងវិញយ៉ាងខ្លាំងក្លា។ ម្ល៉ោះហើយទើប ចុងក្រោយយល់ព្រមលែងស្រុកខ្មែរពីក្រញាំដៃវិញ ហើយទទួលយកការណបរបស់សម្តេចអង្គដួង និងសួយសារអាករដែលព្រះអង្គសន្យាថ្វាយវិញ។

## 4.3. ខេត្តខ្មែរដែលបាត់ទៅយួន និងសៀម

### *៤-គ-១-ទឹកដីបាត់ទៅយួន*

ចំពោះខេត្តពាម–ហាទៀង ដែលស្តេចខ្មែរអនុញ្ញាតឱ្យបក្សពួកមេទ័ពចិនភៀសខ្លួនមួយគ្រួសារធំ រស់នៅដោយការវាតទី និងពង្រីកឥទ្ធិពលមិនឈប់ឈរ វាបានក្លាយទៅទឹកដីស្ថិតក្រោមការត្រួតត្រារបស់គ្រួសារចិននោះឯង។ ប្រមុខគ្រួសារជាតិចិន ដែលបានតម្កើងខ្លួនជាស្តេចត្រាញ់នោះឈ្មោះម៉ាក់គីវ ហើយត្រូវស្តេចខ្មែរឱ្យងារជា ព្រះសុទ័ត។ ព្រះបាទនារាយរាជាអង្គតន់ ធ្លាប់រត់ទៅពឹងពាក់ ជ្រកកោនបារមីនៃគ្រួសារនេះមួយរយៈ និងបានលើកម៉ាក់ជាបិតាធម៌របស់ព្រះអង្គ។ ដោយសារ ព្រះសុទ័តមើលឃើញពួកយួននៅព្រៃនគរមានអំណាចខ្លាំងជាងរាជការខ្មែរ គាត់បាននាំយកខេត្តពាមឡើងទៅអុងយួននៅព្រៃនគររហូតមក។

ទឹកដីខ្មែរ ដែលបាត់បង់ទៅប្រទេសយួន ដោយការទន្ទ្រានកាន់កាប់បន្តិចម្តងៗនោះ មានទំហំជាង ៦៤.០០០គម² ក្នុងនោះមានខេត្ត ៖

| | | | |
|---|---|---|---|
| ១-ព្រះត្រពាំង | ២-សុកទ្រាំង-ឃ្លាំង | ៣-មាត់ជ្រូក | ៤-ក្រមួនស |
| ៥-ពលលាវ | ៦-ទឹកខ្មៅ | ៧-ពាម | ៨-ព្រៃកប្បស្សី |
| ៩-លង់ហោ | ១០-ពាមបារ៉ាជ | ១១-រោងដំរី | ១២-ព្រៃនគរ |
| ១៣-ទួលតាមោក | ១៤-ផ្សារដែក | ១៥-ចង្វាត្រពាំង | ១៦-មេសរ |
| ១៧-ព្រះសួគ៌ា | ១៨-កោះគង(គោះគង) | ១៩-កំពង់ឫស្សី | ២០-អូរកាប់ |
| ២១-កំពង់ក្របី | | | |

មានឯកសារខ្លះទៀតថា ខេត្តដែលបាត់បង់ដោយយួនមានចំនួន ២១ ខេត្តដូចគ្នា ប៉ុន្តែឃើញមានឈ្មោះមិនដូចគ្នាទេ ដែលយើងពុំដឹងថាឈ្មោះទាំងនោះ វាដូចគ្នាទៅឈ្មោះខេត្តណាមួយ ។

ខេត្តទាំងនោះមានដូចជា៖ កំពង់ស្រកាត្រី, ផ្សំអំបិល, ឈ្មោះថ្មី...។

បណ្តាឈ្មោះខេត្តខាងលើនេះ ត្រូវបានរាជការយួនប្តូរឈ្មោះជាភាសាយួន។ ខេត្តខ្លះ ត្រូវបានប្តូរជាច្រើនលើក។ ខេត្តខ្លះបញ្ចូលគ្នាទៅជាខេត្តមួយថ្មី ខេត្តខ្លះទៀតបំបែកជាខេត្តថ្មី។

| **ឈ្មោះខ្មែរ** | **ជំនាន់បារាំង** | **មុនឆ្នាំ ១៩៧៥** | **សព្វថ្ងៃ** |
|---|---|---|---|
| រោងដំរី | តៃនិញ | តៃនិញ | តៃនិញ,ឡុងនិញ,ថាញ់អាញ់ |
| អូរកាប់ | កាប់សាំងហ្សាក់ | វ៉ង់តាវ | វ៉ង់តាវ |
| ព្រៃនគរ | សាយហ្គន | សាយហ្គន | ហូជីមិញ |
| ទួលតាមោក | ធូយ៉ូវម៉ូក | ប៊ីញឡុង | សុងប៊ែរ |
| មាត់ជ្រូក | ចូវដុក | ឡុងស្វៀង | អានយ៉ាង |
| ព្រះត្រពាំង | ត្រាយិញ | វិញប៊ីញ | គីវឡុង |
| ទឹកខ្មៅ | កាម៉ៅ | អានស្វៀង | មិញហាយ |
| ពលលាវ | បាក់លីវ | បាស្វៀង | |
| ស្រុកឃ្លាំង | សុកទ្រាំង | សុកទ្រាំង | ហូវយ៉ាង |
| ព្រៃកប្បស្សី | កាន់ថឺ | ផុងឌិញ | កាន់ថឺ |
| លង់ហោ | វិញឡុង | វិញឡុង | វិញឡុង |

រយៈពេលប្រមាណជា១២២ឆ្នាំ គឺចាប់ពីឆ្នាំ ១៦៩៩ ដល់ឆ្នាំ១៨២១ គឺ៦ឆ្នាំបន្ទាប់ពីយួនបានបញ្ជាឱ្យជីកព្រែកវិញតេ កំណត់ព្រំដែនថ្មីរវាងខ្មែរ-យួន, ខ្មែរត្រូវបាត់បង់ទឹកដីកម្ពុជាក្រោមទាំងមូលទំហំប្រមាណជាង ៦៤.០០០គ.ម²។

<u>ការបរិច្ឆេទនៃការបាត់បង់ទឹកដីកម្ពុជាក្រោម</u>

| | | | |
|---|---|---|---|
| ១ | ព្រៃនគរ (១៦៩៩) | ៧ | មេសរ (១៧៣២) |
| ២ | កំពង់ស្រកាត្រី (១៦៩៩) | ៨ | លង់ហោ (១៧៣២) |
| ៣ | បារៀ (បារាជ) ឬ សួគ៌ា | ៩ | មាត់ជ្រូក "ចូវដុក" (១៧៥៧) |
| ៤ | ពាម "ហាទៀង" (១៧០៧) | ១០ | ផ្សារដែក (១៧៥៧) |
| ៥ | ក្រមួនស "រ៉ាចយ៉ា" (១៧០៧) | ១១ | ព្រះត្រពាំង (១៧៥៨) |
| ៦ | ទឹកខ្មៅ "កាម៉ៅ" (១៧០៧) | ១២ | ស្រុកឃ្លាំង "ស្រុកត្រាង" (១៧៥៨) |

មានខេត្តចំនួន ១០ ទៀតបាត់នៅក្នុងរាជ្យស្តេច ពីរអង្គ គឺ ៖

-ក្នុងរជ្ជកាលព្រះអង្គទង ព្រះអង្គបានលះបង់ឱ្យយួនថែមស្រុកពីរ នៃខេត្តលង់ហោ, ដោយសារមូលហេតុយួនបានបង្កើតចលាចលក្នុងស្រុកខ្មែរ គឺនៅខេត្តទ្រាំង, បន្ទាយមាស និងខេត្តព្រែកប្បាស នៅពេលដែលខ្មែរមានវិបត្តិជាទម្ងន់ក្នុងផ្ទៃរាជវង្សានុវង្ស។

-នៅរជ្ជកាលព្រះឧទ័យរាជា ឬនារាយរាជាអង្គតន់ ព្រះអង្គបានជូនជាសារគុណដល់យួននូវខេត្តផ្សារដែក, កោះតែង និងបណ្តាខេត្តដទៃទៀត ដែលយួនបានរំលោភយកបន្ថែមមាន ៖

| | | | |
|---|---|---|---|
| ១-ព្រែកឫស្សី | ២-រោងដំរី | ៣-ពាមបារាជ | ៤-ទួលតាមោក |
| ៥-ពលលាវ | ៦-ឈ្មោះថ្មី | ៧-កំពង់ឫស្សី ឬផ្សំអំបិល | ៨-អូរកាប់ |
| ៩-កោះគង | | | |

ក្រៅអំពីទឹកដីដែលយួនប្រវ័ញ្ចយកនៅឆ្នាំ១៨១៥ ស្តេចយួនបានបញ្ជាទ័ពឱ្យកេណ្ឌខ្មែរជីកព្រែកពីរ គឺ៖ព្រែកវិញតេប្រវែង ៥៣គីឡូម៉ែត្រ និងព្រែកវិញអានប្រវែង ១៤គីឡូម៉ែត្រ។ ក្នុងការពលីកម្មជីកព្រែកទាំងពីរនេះ យួនបានធ្វើបាបខ្មែរឥតត្រាប្រណី។ រឿង"កំពប់តែអុង"បានកើតឡើងនៅពេលនោះ និងការបង្ក្រាបខ្មែរស៊ីវិលនៅខេត្តបារាយណ៍ បន្ទាប់ពីមានការបះបោរមួយប្រឆាំងកងទ័ពយួនឈរជើងត្រួតត្រានៅទីនោះ។

### *៤-គ-២-ទឹកដីបាត់ទៅសៀម*

ការទន្ទ្រានទឹកដីពីសំណាក់សៀមវិញ ក្នុងដំណាក់កាលទី១នៃសម័យឧដុង្គ សៀមគ្រាន់តែជួយច្បាំងក្សត្រខ្មែរឱ្យបានសោយរាជ្យ ឬច្បាំងដើម្បីយកស្រុកខ្មែរជាចំណុះប៉ុណ្ណោះ។ នៅដំណាក់ទី២សៀមបានឈានមួយកម្រិតទៀត ដោយលៃយ៉ាងណាឱ្យមានមន្ត្រីខ្មែរ ឬក្សត្រខ្មែរដែលនិយមសៀមនៅកាន់អំណាចក្នុងប្រទេសខ្មែរតែម្តង។ ពីព្រោះសៀមបារម្ភខ្លាចប្រទេសខ្មែរបានទៅយួន ។

នៅរជ្ជកាលរបស់អង្គអេង(១៧៩៤-១៧៩៦) នៅពេលនោះមន្ត្រីបែន ក្បត់ដែលបានទូលស្តេចសៀមនាមពុទ្ធយ៉តហ្វាចូឡាលោក ថា "ខ្ញុំព្រះករុណាប្រាថ្នាចង់ឱ្យខេត្តបាត់ដំបង និងសៀមរាប ភ្ជាប់ទៅនឹងទឹកដីសៀម។បើព្រះអង្គមិនទាស់ហឫទ័យទេ សូមធ្វើរាជសារព្រមទាំងឡាយព្រះហស្តផងថ្វាយស្តេចអង្គអេង។ ព្រោះដោយអានុភាពរបស់ព្រះអង្គ ស្តេចក្រុងកម្ពុជា នឹងខ្លបខ្លាច ហើយព្រមប្រគល់ខេត្តទាំងពីរមកសៀមជាពុំខានឡើយ"។ ខេត្តទាំងពីរនេះ ធ្លាក់ទៅក្នុងកណ្តាប់ដៃសៀមក្នុងឆ្នាំ១៧៩៥ នៅឆ្នាំដដែលនេះព្រះអង្គអេងទ្រង់យាងទៅទាមទារយកខេត្តទាំងពីរវិញមកដែរ។ ដោយយល់ព្រមជាមួយគ្នាថា សៀមនឹងបន្តកាន់កាប់ទឹកដីនោះ ដរាបដល់ស្តេចចូឡាលោកចូលទិវង្គត។ ប៉ុន្តែនៅឆ្នាំ១៧៩៦ ព្រះអង្គ សុគតមុនស្តេចសៀមបាត់ទៅ។ ចាប់ពីពេលនោះមក បាត់ដំបង, មហានគរ (សៀមរាប) និងកំពង់ធំខាងជើង ត្រូវសៀមប្រវ័ញ្ចយករហូត។ ចាប់ពីឆ្នាំ១៧៩៦ រាជវង្សានុវង្សខ្មែរត្រូវជាប់នៅឯស្រុកសៀមទាំងអស់ បើចង់ត្រឡប់មកមាតុប្រទេសវិញ ត្រូវសុំអនុញ្ញាតពីសៀមសិន។ នៅដើមសតវត្សរ៍ទី១៩ យួននិងសៀមចេះតែលួចល្បិចគ្នាទៅវិញទៅមក ដោយខ្លាចក្រែងប្រទេសខ្មែរធ្លាក់ក្នុងកណ្តាប់ដៃជនជាតិម្ខាងទៀតតែរៀងខ្លួន។

នៅគ.ស.១៨១៤សៀមបានរំលោភយកខេត្ត ម្លូព្រៃ ទន្លេរពៅ និងស្ទឹងត្រែង ហើយម្តងនេះសៀមដណ្តើមយកដីខ្មែរដោយត្រង់ៗតែម្តង។

ទឹកដីខ្មែរដែលបាត់បង់ទៅលើប្រទេសថៃមានទំហំជាង៦០.០០០ គ.ម$^{២}$ ដែលមានចំនួន១២ខេត្ត៖

| | | | |
|---|---|---|---|
| ១- នគររាជសីមា | ២- បុរីរម្យ | ៣- សុរិន្ទ | ៤- ធនបុរី |
| ៥- សិរីសោកេត | ៦- ស្ទឹងជ្រៅ | ៧- ចន្ទបុរី | ៨- គោកខណ្ឌ |
| ៩- បស្ចិមបុរី | ១០-ក្រាត | ១១- សង្គិត | ១២- អ៊ូប៊ុន |

# មេរៀនទី 8 អារ្យធម៌ខ្មែរសម័យកណ្តាល

ដូចបានបង្ហាញនៅមេរៀនមុន, ប្រវត្តិសាស្ត្រកម្ពុជាបន្ទាប់ពីការចាកចោលទីក្រុងអង្គរដ៏ស្កុកស្តម្ភ គេហាក់ដូចជាមើលឃើញថា អំណាចនៃប្រទេសកម្ពុជា បានចុះខ្សោយជាលំដាប់ ដោយសារព្រឹត្តិការណ៍ឈ្លោះទាស់ទែងគ្នាដើម្បីដណ្តើមអំណាចគ្នារបស់រាជវង្សានុវង្ស, ការពឹងពាក់ប្រទេសជិតខាងឱ្យជួយធ្វើអន្តរាគមន៍ដោយកងទ័ព, អំពើពាលាអាវ៉ាសែរបស់ព្រះរាជាមួយចំនួន, និងសមត្ថភាពទន់ខ្សោយរបស់ពពួកក្សត្រតែម្តង។ តែទោះជាយ៉ាងណាក្តី មានប្រវត្តិវិទូជាច្រើនបានអះអាងថា ខ្មែរនៅតែមានមានសមត្ថភាពរឹងមាំរហូតមកដល់ដំណាច់សតវត្សរ៍ទី១៧ គ្រាន់តែអំឡុងពេលនេះ យើងមិនបានបន្តការកសាងប្រាសាទថ្ម ដូចកាលពីចន្លោះសតវត្សរ៍ទី៩-១២ទៀតមែន។

ភាពរឹងមាំ និងរុងរឿងនេះ អាចអះអាងបានតាមរយៈសមត្ថភាពទប់ទល់ និងលើកទ័ពវាយបកទ័ពសៀម និងទ័ពយួន បានប្រកបដោយជោគជ័យជាច្រើនលើកច្រើនសារ រហូតមកដល់ពាក់កណ្តាលសតវត្សរ៍ទី១៧។ ចំណែកនៅចុងសតវត្សរ៍ទី១៧ និងដើមសតវត្សរ៍ទី១៨ ក្នុងរជ្ជកាលព្រះរាជា ជយជេដ្ឋាទី៣ ឬជយចេស្តាអង្គសូរ ខ្មែរនៅតែមានសមត្ថភាពដដែល។ ទោះបីនៅអំឡុងចុងសតវត្សរ៍នោះ មានការប្រជែងគ្នាពីអ្នកអង្គម្ចាស់អង្គនន់ ដែលជាបងប្អូន ជីដូនមួយ និងបានពឹងពាក់អន្តរាគមន៍របស់យួនក្តី ក៏ស្តេចអង្គនេះ មានសមត្ថភាពបញ្ចប់សង្គ្រាម និងបង្រួបបង្រួមជាតិប្រកបដោយជោគជ័យ។ ខាងវិស័យសេដ្ឋកិច្ច ក៏ខ្មែរមានការរីកចម្រើនដែរ ដោយសារសកម្មភាពពាណិជ្ជកម្មនៅតាមដងទន្លេមេគង្គ។ លើសនេះទៀត ស្តេចអង្គនេះ បានរៀបចំក្បួនខ្នាតសម្រាប់ប្រទេសឡើងវិញ ដោយបន្សល់ទុកជាស្នាព្រះហស្តនូវច្បាប់វិសោធនកម្មរួចជាច្រើនក្រម សម្រាប់ព្រះរាជាក្រោយៗមកទៀត រហូតដល់រាជ្យព្រះបាទអង្គដួង។ នេះជាការសក្ខីភាពនៃការខិតខំប្រឹងប្រែង គ្រប់គ្រងប្រទេសជាតិ ដោយប្រើប្រាស់ច្បាប់ជាគោល។ លើសនេះទៀតនៅមានស្នាដៃអក្សរសិល្ប៍ជាច្រើន ដែលកវីអ្នកប្រាជ្ញខ្មែរបានតាក់តែងឡើង ទាំងច្បាប់ទូន្មាន និងសាស្ត្រាល្បែងផ្សេងៗ ដើម្បីអប់រំទូន្មានយុវជន និងជនជាតិខ្មែរទាំងមូល។ ទោះបីជាយ៉ាងណា កិច្ចការអប់រំបញ្ញវន្តខ្មែរ នៅអំឡុងពេលចាប់ពីសតវត្សរ៍ទី១២-១៣មក ជាភារកិច្ចរបស់ព្រះសង្ឃពុទ្ធសាសនា ហើយចាប់ពីសតវត្សរ៍ទី១៤វិញ គឺព្រះសង្ឃពុទ្ធសាសនាថេរវាទ ដែលពឹងផ្អែកលើគម្ពីរព្រះត្រៃបិតក និងទ្រឹស្តីអាចរិយវាទ ដែលបានប្រៀនប្រដៅ និងបង្ហាញផ្លូវសម្រាប់ប្រតិបត្តិ និងគោរពតៗគ្នា បែបជាទំនៀមទម្លាប់។

## 1. កម្រងច្បាប់សម្រាប់គ្រប់គ្រងរដ្ឋដ៏ល្អ

ជាការពិតកម្រងច្បាប់ខ្មែរ មានលក្ខណៈទូទៅ គ្មានកាលបរិច្ឆេទ និងប្រភពថាមកពីទីណានោះទេ។ បើតាមការពិនិត្យផ្នែកសេចក្តីផ្តើម និងក្នុងអត្ថន័យ គេអាចឃើញដានថា ជាប់ជាព្រះកេរ្តិ៍ចាប់ពីព្រះរាជាជយជេដ្ឋាទី២, ព្រះរាជាជយជេដ្ឋាទី៣ អង្គសូរឆ្នាំ១៦៧៥ ព្រះបាទហរិរក្សរាមា អង្គដួង និងព្រះបាទនរោត្តម។ ច្បាប់ខ្មែរសម័យកណ្តាលទាំងអស់នោះ អាចបែងចែកបានជា ៥៤នីតិក្រម ដែលក្នុងចំនួននេះមាន៣៩នីតិក្រម បានបោះពុម្ពផ្សាយនៅក្នុងរាជ្យព្រះបាទនរោត្តម ជាច្បាប់សរសេរដោយដៃ បោះពុម្ពផ្សាយដោយរោងពុម្ពប្រូតិចតូរ៉ា(Protectorat)។ សព្វថ្ងៃក្រមដែលបានបោះពុម្ពផ្សាយនៅឆ្នាំ១៨៩១ទាំងនេះ មានប្រមាណ២០ក្រម តម្កល់នៅបណ្ណសារដ្ឋានជាតិ, បណ្ណាល័យវិជ្ជាស្ថានបារាំងចុងបូព៌ាប្រទេសរួមជាមួយឯកសារច្បាប់ចារចម្លងលើសត្រាស្លឹករឹត, បណ្ណាល័យនៅទីក្រុងអាឡង់សុង, បណ្ណាល័យឯកជនរបស់លោកស្រីប៉ូរ៉េតិ៍ ម៉ាស្ប៉េរ៉ូ និងបណ្ណាល័យជាតិក្រុងប៉ារីស មានលក្ខណៈដូចគ្នា។

តាមពង្សាវតារ នៅក្នុងរជ្ជកាលព្រះបាទជយជេស្ដាអង្គសួរ ទ្រង់បានពិនិត្យ និងធ្វើវិសោធនកម្មកែសម្រួលច្បាប់ចំនួន២៤ក្រម ដើម្បីដាក់ឱ្យមន្ត្រីរាជការយកទៅអនុវត្តនៅតាមដែនដីរបស់ខ្លួន។ ច្បាប់ទាំងនោះមានដូចជា ក្រមសុភាធិបតី១, ក្រមចែកមុខងារទុកនៅដៃ ឧកញាមន្ត្រីអនុជិត១, ក្រមទាសករិយា១,ក្រមចែកពល១, ក្រមឧទេន១, ក្រមរុងសង្ឃ១, ក្រមពហុលទេព១, ក្រមគោ១, ក្រមសេះ១, ក្រមទូក១, ក្រមស្នួស្ដី១ ជាដើម។ ក៏ប៉ុន្តែ នីតិក្រមដែលយើងឃើញមាននៅបណ្ណសារដ្ឋានជាតិ និងនៅបណ្ណាល័យទាំងពីរនៅស្រុកបារាំង មានច្រើនលើសពីនេះ ដូចជា ៖

1- ក្រមព្រះធម្មសាត្រ(ក្រមព្រះធម៌សាស្ត្រ) ដែលនិយាយអំពីដំបូន្មានសម្រាប់ចៅក្រម
2- ក្រមព្រះធម្មនុញ្ញ
3- ក្រមត្រលាការ (តុលាការ)
4- ក្រមព្រះរាជក្រិត្យសំឃីរីដែលចែងអំពីច្បាប់ទម្លាប់ភ្ជាប់សម្ព័ន្ធរៀបការ និងព្រះសង្ឃ
5- ក្រមព្រះមន្ទីរបាល ដែលចែងអំពីទោសនៅក្នុងព្រះរាជវាំង
6- ក្រមលំនៅ
7- ក្រមទាសករិយា
8- ក្រមវិវាទ-ចែងអំពីការឈ្លោះទាស់ទែងវាយដំគ្នា ជេរប្រទេចផ្ដាសាដាក់គ្នា
9- លក្ខណៈទាសកម្មករណ៍
10- ក្រមពហុលទេព-ចែងអំពីច្បាប់សម្រាប់ជនបទ និងការងារស្រែចម្ការ
11- ក្រមបៀរ ដែលចែងអំពីរបៀបដកហូតពន្ធ ឬតុងល្បែងបៀរ
12- ក្រមសាក្សីពិសោទ្ធ(ពិសោធន៍)ដែលអំពីប្រភេទនៃសាក្សី និងលក្ខណៈនៃប្រប្រាស់សាក្សី
13- ក្រមទទួលពាក្យបណ្ដឹង និងការប្ដឹង
14- ក្រមឧទ្ធរណ៍
15- ក្រមទំរង់ស័ក្តិ ដែលចែងអំពីច្បាប់ទម្លាប់ក្នុងការប្រើពាក្យពេជន៍ពេលសរសេរសំបុត្រសម្រាប់មន្ត្រីរាជការទូទាំងប្រទេស។
16- ក្រមមរតក ដែលចែងអំពីច្បាប់នៃការបែងចែកកេរ្តិ៍មរតកនៅក្នុងគ្រួសារខ្មែរ
17- ក្រមអញ្ញាមញ្ញបដិភាស ដែលនិយាយអំពីអ្នកតំណាងនៅក្នុងតុលាការ
18- ក្រមក្បត់សឹក ដែលនិទានអំពីទណ្ឌកម្មសម្រាប់ទាហានរត់ចោលជួរ, ក្បត់ជួរ និងចុះចូលខ្មាំង
19- ក្រមអាជ្ញាហ្លួង ដែលចែងពីភារកិច្ចដើរហូតពន្ធពីប្រជារាស្ត្រ និងទទួលសួយពីមន្ត្រីដែនដី
20- ក្រមចក្រី ឬក្រមដំរី ដែលនិយាយអំពីការទាក់ដំរី, ថែរក្សា, កំណែន និងការពាក់ព័ន្ធល្មើស
21- ក្រមសេះ
22- ក្រមគោ
23- ច្បាប់ទំនឹមពីបូរាណ-និយាយអំពីរឿងខ្លីៗស្ដីពីបទពិសោធន៍ក្នុងការវិនិច្ឆ័យរឿងក្ដី
24- ក្រមព្រហ្មទណ្ឌ
25- ក្រមចោរ
26- ក្រមព្រះរាជប្រដាប់អភិសេក
27- ក្រមស្រុក ជាដើម

នៅក្នុងច្បាប់នីមួយៗនេះ គេបានបែងចែកជាផ្នែកលម្អិតជាច្រើនទៀត។ ចំពោះច្បាប់ដែលបានបោះពុម្ពរួចទាំងនេះ អ្នកអាណាព្យាបាលបារាំងបានបញ្ជូនទៅឱ្យចៅហ្វាយខេត្ត និងមេស្រុកដែលជាអាជ្ញាធរដែនដីនៅទូទាំងប្រទេសសម្រាប់ធ្វើជាក្បួនក្នុងការគ្រប់គ្រងដែនដីរបស់ខ្លួន។ លើកលែងតែក្រមក្បត់សឹក ដែលមិនបានអនុញ្ញាតឱ្យយកមកប្រើ ដើម្បីដាក់ទោសទណ្ឌិត ព្រោះវាមានលក្ខណៈព្រៃផ្សៃពេក ធ្វើឱ្យអ្នកត្រូវបានផ្តន្ទាទោសរងទារុណកម្មស្លាប់ដោយឃោឃៅបំផុត។

ក្នុងចំណោមច្បាប់ទាំងនេះ យើងអាចលើកឧទាហរណ៍ជាច្រើនអំពីការកាត់ក្តីប្រកបដោយយុត្តិធម៌ ដែលមានកាត់ត្រានៅក្នុងក្បួនទំនឹមពីបូរាណ ដែលព្រះរាជាជ័យចេស្តាអង្គសូរបានរៀបរៀងឡើង ដោយមានការផ្តល់យោបល់ និងផ្ទៀងផ្ទាត់ពីសម្តេចព្រះទាវ ជាព្រះរាជមាតារបស់ទ្រង់។ ច្បាប់នេះ បានកំណត់អំពីបរិមាណពិន័យចំពោះអ្នកប្រព្រឹត្តិខុសក្នុងកម្រិតរដ្ឋប្បវេណី និងព្រហ្មទណ្ឌ ដោយកាត់កងយកសំណងជាទ្រព្យសម្បត្តិ តាមបរិមាណជាភាគ និងមេគុណ។ ទោះបីអ្នកមានទោសនោះ ជារាជវង្សានុវង្ស,នាហ្មឺន,មន្ត្រី, អ្នកមាន និងទាសកម្មករ។

ជាឧទាហរណ៍ ៖ **ទំនឹម១០** ដែលនិយាយពីការដាក់ទោសដល់មហាតដែលអាងអំណាចចៅហ្វាយជាស្តេចទៅបំផ្លាញដំណាំអ្នកស្រុក ដោយកាប់ក្បាល៥រណ្តៅម្នាក់ និងដាក់ពិន័យអ្នកស្រុកម្ចាស់ដំណាំ មិនប្តឹងស្តេចជាអម្ចាស់មហាត បែរជាបំផ្លើងពាក្យនាំឱ្យប៉ះពាល់ដល់កិត្តិយសស្តេច។[56]

**មានទំនឹម២៣** និយាយពីរជ្ជកាលព្រះបាទសម្តេចព្រះរាជឱង្ការព្រះស្រីធម្មរាជា ដែលមានអក័ម៉ឺនមហាស្និទ្ធជាមហាតឡឹកម្នាក់ប្រព្រឹត្តិខុសលើអ្នកដទៃដោយក្តីធ្វេសប្រហែស។ មហាតឡឹករូបនេះបរសេះលេងទៅពានលើកូនចៅជ្ជេតប៉ាញាថ្លោះត្រគាក។ក្រោយពីចៅនេះទៅប្តឹងនៅសាឡាបាញ្ញាន់សឹង មហាតឡឹកក៏សុំប្រាក់ពីប្រពន្ធចំនួន៣ជញ្ជីង១៧តម្លឹង យកទៅប្រគល់ឱ្យដើមចោទ។ តែដើមចោទនៅតែច្រឡោតខឹងនឹងគាត់ មិនយកប្រាក់សំណងដែលគាត់បង់ក្នុងតម្លៃយ៉ាងខ្ពស់ ស្មើកម្រិតប្រាក់ពិន័យសម្រាប់ពួករដ្ឋមន្ត្រីដែលប្រព្រឹត្តខុសនោះឡើយ។

នៅពេលចៅក្រម យករឿងនោះទៅព្រះរាជា ព្រះអង្គបានប្រគល់សំណងឱ្យដើមចោទត្រឹមតែ១៣តម្លឹង៣បាត្រប៉ុណ្ណោះ។ សល់ក្រៅពីនោះ ស្តេចដកទុកក្នុងរាជឃ្លាំង។ នេះកាយវិការព្រមានដល់មន្ត្រីរូបនោះផង និងអ្នកដទៃទៀតផង កុំឱ្យអាងតែខ្លួនជាមនុស្សមានអំណាច ឬជាជំនិតរបស់ស្តេច ចេះតែប្រព្រឹត្តិផ្តេសផ្តាស បំពារបំពានលើអ្នកដទៃ និងជាការបង្ហាញកស្តុតាងពីការមិនសមគំនិតជាមួយមន្ត្រីរបស់ខ្លួន។[57]

**មានទំនឹម២៤** ពួកមន្ត្រីកាត់ក្តី និងព្រះរាជាដាក់ទោសពិន័យដល់ភ្នាក់ងាររាជការជាអង្គរក្ស ដែលធ្វើការអាងអំណាចនាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់អ្នកស្រុក ដោយសារពួកគេទៅចាប់មនុស្សដែលរត់ចូលក្នុងស្រូវស្រែ

---

[56] *(១១)ទំនឹម១០(២០) កាលរាជព្រះអង្គអំពីមុននោះ មានមហាតសម្តេចព្រះឯកឧត្រ្តី ព្រះនាមង(១២) ក្រោយហៅអ្នកមានបុន់ពីសែស មហាតព្រះអង្គនោះ វាទៅរែកត្បាតបែះបោចសារពើ(១៣)ដំណាំគេ ទើបអសអ្នកស្រុកហៅថាអ្នកមានបុណ្យពីសែស អួតថាពីសេសម្តេច ហើយ ឱ្យតែ(១៤)មហាតមក រែកត្បាតគេ ទើបអសមហាតនោះ វា ពួ ហើយវាទៅទូលព្រះអង្គ ឮជ្រាបហើយ (១៥)ព្រះអង្គខ្ញាល់ ហើយឱ្យទៅប្រកោះអ្នកស្រុកដែលថានោះមកឱ្យជុំនុំ ទើបអស់ជុំនុំពី(១៦)ចារណា ទើបអសអ្នកស្រុកឆ្លើយថា ដ្បីតយលអសមហាតនោះទៅរែកតបេះបោចអស់(១៧)ដំណាំនោះឯងខ្លួននេះស្រដីមែន ទើបព្រះអង្គឱ្យពិន័យអ្នកស្រុកដែលថានោះ ជីង៣ជុំឡើង(១៨)១៧ ឯមហាតដែលទៅរែកនោះ ព្រះអង្គឱ្យកាប់ក្បាល៥រណ្តៅសម្រាប់មួយទូរ(ម្នាក់)ហើយអស់(១៩)ជុំនុំចុះទៅសាឡា ហើយឱ្យភ្នាក់ងារទាហានកាប់ក្បាលអសមហាតទាំង៥នាក្ខ ហើយនាំ(២០)ក្រយ៉ាពិន័យថ្វាយ ។*

[57] ទំនឹម២៣(៣៣) ក្នុង ច្បាប់ទំនឹមព្បីបូរាណ, ទំព័រ២៨-២៩។

កំពុងចេញផ្លែ ហើយម្ចាស់ស្រូវទៅអង្វរសុំកុំឱ្យធ្វើទារុណកម្មមនុស្សនៅក្នុងស្រែនោះ តែពួកគេអាងអំណាចថា ជាអ្នកធ្វើតាមបង្គាប់បញ្ជាតុលាការ ទើបត្រូវម្ចាស់ស្រែប្តឹងទាសំណង។ នេះជាការព្រមានដល់អ្នកអនុវត្តន៍ច្បាប់ទាំងឡាយ មិនត្រូវធ្វើការឱ្យប៉ះពាល់ដល់ផលប្រយោជន៍ប្រជារាស្ត្រឡើយ។[58]

**មានទុំនីម២៧** កាលរាជ្យព្រះបាទសម្តេចព្រះរាជឱង្ការព្រះដៃជេស្ឋាបរម្មនាដ្ឋបរំម្មបពិត្រ មានមន្ត្រីជាន់ខ្ពស់ខាងតុលាការមួយរូបប្រព្រឹត្តិល្មើសក្នុងបទសាហាយស្មន់អន្ទករជាមួយស្ត្រីបម្រើរបស់អ្នកដទៃ។ ព្រះអង្គបានដាក់ទោសពិន័យមន្ត្រីនាមប្បញ្ញត្តិសុភាអនុជិតនោះ ដោយការទម្លាក់ស័ក្តិ២ហ៊ូពាន់ និងតម្រូវឱ្យតាមលោះនាងនោះយកធ្វើភរិយា តាមការសន្យារបស់ខ្លួនពេលចែចង់នាងនោះ។ នេះជាការមិនសមគំនិតរបស់ព្រះរាជាជាមួយមន្ត្រីរបស់ខ្លួន ដែលប្រព្រឹត្តិប្រាសចាកសីលធម៌ប្រពៃណីខ្មែរ។[59]

---

[58] *(១០) មានទុំនីម២៤ (៣៤) ឈ្មោះថៅសោមប្រយូង មានខ្ញុំ ស្រី១ ឈ្មោះម្បេសុក ទៅជន្ទាត់ហើយ (១១)បានត្រឹមកស្លរពុំ ថែទាំ(ឱ្យល្អ ស្ល)ដោយទាំងកូនក្អាត់ទៅក្នុងសំឡរ លើកទៅឱ្យថៅសោមហូប (១២)បាយ ថៅសោមយល់កូនក្អាត់នៅថ្វានសម្លរ ហើយ ទើបថៅសោមហៅមេសុកមកវាយលុះទុំ(១៣) ម្វន់ ធ្វន់ឈាមដាប មេសុករត់ទៅនៅផងមហាតអង្រាក់ ឈ្មោះអក័ហ្លួង កូវ ថៅសោមទៅ(១៤)យកដើង៣ មេសុកពុំមកឡើយ នៅលើផ្ទះអក័ហ្លួងកូវ ទើបថៅសោមរកជង្វាយឡើងទៅ(១៥)ក្រាប ទូល អំពីដំណើរតួមេសុករត់ទៅផ្ទះអក័ហ្លួងកូវ ទើបទ្រង់ព្រះចិន្តាថានឹងថៅហ្វាយ ឱ្យបំរើ(១៦)ទៅយកតួមេសុក ទើបថៅហ្វាយប្រើអក័ហ្លួងកុំចសើល និងកូនងារ៣នាក់ឈ្មោះចាន្ទ១(១៧)នៀ១ឆាន់១ ទៅយកមេសុកអំពីផ្ទះអក័ហ្លួងកូវ បើកឱ្យដំណើរមកដល់កណ្តាលផ្លូវ(១៨)មេសុករត់ទៅចូលក្នុងស្រូវថៅថ្វាន់ព្រៃងារ ទើបអក័ហ្លួងកុំចសើល នៅអស់កូនងារដេញ(១៩)តាមទៅច្វាប់មេ សុកចងថងវាយល្អិតល្អន់នៅក្នុងស្រូវថៅចន្ទ ទើបថៅចាន្ទស្រដីអង្វរឃាត់(២០)កុំឱ្យច្វាប់ក្នុងស្រូវជ្បឹតស្រូវកុំពង់ផ្លែ អក័ហ្លួងកុំចសើលនៅអសកូនងារថា ខ្លួនជាមហាតពុំ(២១)កោតញញើតឡើយ ហើយនាំតួម្បេសុកយកមកដល់ថៅហ្វាយ ទើបថៅហ្វាយឱ្យ តួមេសុក(៣០-(១))ទៅថៅសោម ហើយថៅសោមបង់ប្រាក់ដំម្លឹង១ឱ្យទៅអក័ហ្លួងកុំចសើល នៅអស់កូនងារជាឈ្នួល(២)ទើប ថៅចាន្ទអំម្ចាស់ស្រូវឡើងក្រាបទូល ទ្រង់ព្រះកូរណោពិសេសដោយដំណើរជ្រាបសព្វគ្រប់ហើយ (៣) ដាក់សេចក្តីឱ្យទៅថៅហ្វាយ ជុំនុំពិចារណា យលអក័ហ្លួងកុំចសើលនៅកូនងារធ្វើអំពើព្យាង្វាយ(៤)ពុំគួរជ្បិតព្រះព្បៃស្រពនេះ ជាព្រះដីន្បីដីនុកចិញ្ចឹមមនុស្សផង ទើបថៅហ្វាយនៅអស់ ជុំនុំម (៥)កាត់សេចក្តីនេះ ឱ្យថៅចាន្ទអូសខ្ញុំអំពីថៅសោមយក ទើបឱ្យអក័ហ្លួងកុំចសើល នៅកូនងារ (៦)យកប្រាក់ជុំម្លឹង៣០ទៅលោះមេសុកអំពីថៅចាន្ទនោះ ត្រូវអក័ហ្លួងកុំចសើលជឹង១ ត្រូវអស់កូន(៧)ងារជុំម្លឹង១០ ឱ្យទៅថៅ ចាន្ទអំម្ចាស់ស្រូវ ទើបថៅចាន្ទទ៏ទួលយកប្រាក់បើកតួមេសុកឱ្យទៅអកហ្លួង(៨)កុំចសើល ហើយអក័ហ្លួងប្រគល់តួម្បេសុកឱ្យទៅ ថ្វៅសោម ទើបថៅចាន្ទយកប្រាក់ជឹង១ឱ្យថៅហ្វាយនាំ(៩)ឡើងក្រាបទូលថ្វាយទ្រង់ព្រះកូណាពីសែស ហើយត្រាស់ឱ្យថៅហ្វាយ ទុកប្រាក់ជឹង១ ឱ្យជាប្រាក់ង្វារឱ្យលោះ(១០)មហាតនៅអស់ពល កុំឱ្យកុំជឹងទ្រព្យអសអាណាប្រជានុរាស្ត្រផងទាំងពួង ក្រែងខ្វាត់ ភ្លាត់(១១)អស់មហាតនៅពលអស់ទាំងនេះ សឹងជាខ្ញុំសំរ៉ាបព្រះបាទអ្នកជា អំម្ចាស់សព្វរាជរៀងមកហោង។:*

[59] *(១៤)មានទុំនីម២៧(៣៨) កាលរាជ្យព្រះបាទសម្តេចព្រះរាជឱង្ការព្រះដៃជេស្ឋាបរម្មនាដ្ឋបរំម្មបពិត្រ(១៥)កាល្មោះមានចិន១ ឈ្មោះថៅឡាក់ ជាក្តីនឹងព្រះស្រែនជ្បែជានាយអង្គរក្សព្រះស្រែនជ្បែបានទៅប្តឹងថ្វៅ(១៦)ហ្វាយ ៗឱ្យទៅហៅថៅឡាក់៣ដើងពុំ មកឡើយ ថាវេរវេរល់ ទើបថៅហ្វាយឱ្យទៅថានឹងឱកញ្ញា(១៧)រាជនុរេស ឱ្យទៅអូសខ្ញុំថៅឡាក់បាន៥នាក់ប្រុស៣ស្រី២ ខ្ញុំ១ ឈ្មោះអានង១,ពៅ១, សិត១ ឯខ្ញុំស្រីមេម៉ារ១, ពៅ១។ (១៨)លុះបានទាំង៥នាក់មកហើយ ឱ្យឱកញ្ញារាជនុរេស់ យកទៅទុកនៅ ដៃព្រះសូភាអន្ទីត ៗមាន(១៩)ចិត្រចង់មេពៅ (ក៏)ស្រដីប្រលោមយកចិត្តវាថានឹងយកជាប្រពន្ធទើបម្បេពៅព្រមដោយព្រះសូ (២០)ភាអន្ទីត់ ៗឱ្យសំពត់១ស្បៃ១ លុះហើយសេចក្តីព្រះស្រែនជ្បែ នឹងថៅឡាក់ ទើបអស់ជុំនុំ (២១)បង្គាប់ឱ្យព្រះសូភាអន្ទីត យកខ្ញុំទាំង៥នាក់ មកឱ្យថៅឡាក់ ៗមើលយល់មេពៅបានស្បៃ (៣៤_(១))កាស្បា១សំពត់១ យល់អង្កើរក្តីដូច្នោះ ថៅឡាក់លោមជន្តឹង(សួរ)មេពៅ ៗប្រាប់ដោយនូវពាក្យពុំនឹកថា (២)ព្រះសូភាអន្ទីតមកជាស្មន់អន្ទករ ហើយឱ្យស្បៃនៅសំពត់នេះឯង ទើបថៅឡាក់ពុំអត់ឡើយក្រាប(៣)ទូលព្រះបាទអ្នកជាអំម្ចាស់បានជ្រាបសព្វគ្រប់ហើយ មានព្រះបន្ទូលត្រាស់ឱ្យថៅហ្វាយជុំនុំម ពិចារណា(៤)រកសេចក្តីព្រះសូភាអន្ទីត និងមេពៅ ទើបអ្នកថៅហ្វាយឱ្យ*

**មានទំនឹម៣៣** មានអធិករណ៍មួយរវាងអ្នកស្រុកធម្មតាឈ្មោះចៅកូវបែកផ្សេង និងព្រះនន្ទធូបែសចំបងកុំឡោះអង្គរក្សរបស់មន្ត្រីធំម្នាក់ ដោយសារប្រធានក្រុមអង្គរក្សរូបនោះ យកពំនូតសំពត់ទទឹកទៅពាក់លើចុងដងវែកចៅកូវដែលកំពុងវែកអង្ករឡើងពីកំពង់ផែ។ ព្រះរាជាបានដាក់សេចក្តីឱ្យទៅចៅហ្វាយ និងឧកញ្ញារាជនុរេសទទួលបន្ទុកជុំនុំនៅសាលាព្រះបញ្ញ៉ាន់សិង្ហ។ ក្រោយមកដោយសារតែកំហុសពាយងាយនោះ ព្រះនន្ទធូបែសត្រូវពិន័យឱ្យបង់ប្រាក់៣០តម្លឹងសងជំងឺចិត្តចៅកូវ តែចំនួននេះត្រូវបែងជាភាគ៣ ភាគ១ប្រណីឲ្យ ភាគ២យកជាក្រយាពិន័យសម្រាប់ឱ្យចៅកូវបែកផ្សេង។ នេះជាការពិន័យដល់មន្ត្រីរាយមាយ ដែលខ្លួនជាអ្នកមានបុណ្យស័ក្តិ និងមានចៅហ្វាយនាយជាអ្នកធំ ធ្វើអំពើប្រមាថដល់អ្នកក្រីក្រ។[60]

ហេតុដូច្នេះហើយ បានជាលោក ឡឺក្លែរ ថ្លែងកោតសរសើរចំពោះឧត្តមគតិរបស់ប្រជាជាតិខ្មែរពីអតីតកាលដែលធ្លាប់ជាប្រជាជាតិដ៏ធំ ជាមនុស្សចេះប្រើគតិបណ្ឌិត និងច្បាប់សម្រាប់ដឹកនាំស្រុកឱ្យបានរីកចម្រើន និងមានសណ្តាប់ធ្នាប់សង្គម។ គាត់បានសង្ឃឹមថា បារាំងនឹងរកឃើញនូវអ្វីដែលខ្មែរត្រូវការ និងរបៀបដែលខ្មែរគិត ដើម្បីធ្វើនវូបនីយកម្មជនជាតិនេះឱ្យបានជោគជ័យ និងធ្វើឱ្យប្រជាជាតិដែលធ្លាក់ខ្លួនចុះទន់ខ្សោយនេះ ចាប់ផ្តើមសាងសមត្ថភាពខ្លួន ចេះគិត និងចេះធ្វើអ្វីៗដោយខ្លួនឯងឡើងវិញ។

## 2. ចំណេះដឹងខាងទ្រឹស្តីគ្រប់គ្រងរដ្ឋបែបឥណ្ឌា

គេធ្លាប់ឃើញតែសង្គមខ្មែរនៅសម័យអង្គរ ដែលក្រេបជញ្ជក់យកចំណេះដឹងវប្បធម៌ឥណ្ឌាយ៉ាងជោគជាំ តែតាមការពិត អ្វីៗដែលខ្មែរចេះពីសម័យអង្គរតាមរយៈវប្បធម៌សំស្ក្រឹតនោះ នៅតែរស់ជាបន្តទៀតនៅក្នុងសង្គមខ្មែរសម័យកណ្តាល ដែលជាពិសេសក្នុងវប្បធម៌ប្រើភាសាបាលីវិញម្តង។ ជាក់ស្តែងទ្រឹស្តីនៃជាតុទាំង៧របស់រដ្ឋបែបឥណ្ឌា គេនៅតែមានគេចេះចាំ និងចងក្រងទុកជាបន្តទៀតសម្រាប់អប់រំវណ្ណៈអ្នកដឹកនាំ និងសម្រាប់យកមកអនុវត្តន៍ក្នុងការគ្រប់គ្រងរដ្ឋ ជាពិសេសគេបានបញ្ចេញបច្ចេកពាក្យនេះឱ្យឃើញនៅក្នុងសិលាចារឹកនគរវត្តលេខ៣ខ (ប.២៩)ឆ្នាំ១៥៧៩ ក្រោមពាក្យថា «សប្តប្រក្រឹតិ» និងអំពីកេតនភ័ណ្ឌនៃភាពជាស្តេចចក្រពត្តិ នៅក្នុងសិលាចារឹកវត្តនគរ

*ហៅព្រះសូភាអន្ទីត់ទៅសាឡាព្រះបញ្ញ៉ាន់(៦)សីង្ឃ ជុំនុំម ជួបជុំមនឹងអស់ចៅក្រមនៅព្រះសាល៉ា ទើបពីចារណាព្រះសូភាអន្ទីតៗឆ្លើជុំរាប(៧) អ្នកចៅហ្វាយ និងអសជុំនុំថា ខ្ញុំប្របាទជា អន្ទករនឹងមេពៅមែន មេពៅក៏ឆ្លើយត្រូវដូចពាក្យ(៨)ព្រះសូភាអន្ទីត ដូច្នោះទើបឱ្យពិន័យព្រះសូភាអន្ទីតដៀរនៅសក្ខ័ពីរចុះ ហើយឱ្យ ព្រះសូភាអន្ទីត(៩)តាមទៅសូមលោះមេពៅអំពីចៅឡាក់ដឹង៣ដំម្លឹង១០ ជាសូរេចហោង ។:*

[60] *(៥)មានទុំនីម៣៣(៤៤)ឈ្មោះចៅកូវបែកផ្សេងទៅទិញអង្ករឯកំពុង ទិញបានហើយយកកញ្ជៀរមក(៦)ផ្តងនៅដង្រែក ហើយ គាព្ទព្រះនន់ធូបែសចំបងកុំឡោះទៅង្វូតទឹកនៅកំពុង់ លុះឡើងមកពួតសំពត់(៧)ង្វូតរួចហើយ ចៅកូវបែកផ្សេងលើកអំម្រេកដើរទ្នៅ ឯព្រះនន់ធូបែសនោះដើរតាមក្រោ្យទ្នៅនោះ(៨)ព្រះនន់ធូបែសយកសំពត់ង្វូតនោះពាកនៅចង់ដងរ៉ែកឯចៅកូវនោះពុំដឹង ឡើយ លុះបង្ហិល(៩)ដង្រែកនោះទៅមុក់យល់សំពត់ង្វូតនោះ ចៅកូវដន្តឹងថានែះសំពត់ង្វូតន៏ណា ទើបព្រះនន់ធូបែស(១០) ឆ្លើថាសំពត់អាញ់ ចៅកូវពុំអត់ឡើយទៅដល់ផ្ទះចៅកូវបានដង្ហ្យឡើងក្រាព្វទូលថ្វាយ ហើយទូលដោ្យជុំណើ(១១)បានជ្រាព្វ សព្វគ្រប់ហើយ ទ្រង់ព្រះកូរណាដាក់សេចក្តីឱ្យទៅចៅហ្វាយ នៅឱកញ្ញារាជនុរេសជុំនុំនៅសាល៉ា(១២)ព្រះបញ្ញ៉ាន់សីង្គ ហើយ ឱ្យហៅព្រះនន់ធូបែសមកពីចារណា ឯព្រះនន់ធូបែសឆ្លើយថា ពាក់លេងទេរ(១៣)ទើបអស់ជុំនុំយលថាព្រះនន់ធូបែសពាយ ងាយយកសំពតង្វូតឯងទៅពាក់លើដង្រែកគេ ដូច្នែះទើបឱ្យកាត់(១៤)ក្រយ៉ាពិន័យដំម្លឹង៣០ បែងជាភាគ៣ ភាគ១ប្រណីឲ្យភាគ២យកជាក្រយ៉ាពិន័យឱ្យទៅចៅកូវបែកផ្សេង(១៥)ហោង។: ទំនឹមទាំងពីរបន្តបន្ទាប់គ្នានេះ បង្ហាញឱ្យឃើញថា ស្តេចមិនសម គំនិតការពារមន្ត្រីមានកំហុស និងការដែលអ្នកក្រីក្រ ជាសាមញ្ញជន អាចហ៊ានប្តឹងតទល់ជាមួយអ្នកមានអំណាច ដើម្បីយុត្តិធម៌ ។*

បាជ័យ (K. 82A, l.8)ឆ្នាំ១៥៦៦ក្រោមបច្ចេកពាក្យថា"សត្តរតនៈ"[61] និងនៅក្នុងសៀវភៅសំណៅឯកសារដើមរបស់នាយ ឈឺន ដែលគេតម្កល់នៅបណ្ណាល័យសាលាបារាំងចុងបូព៌ាប្រទេស(No. P. Camb. 53)។[62] ឯកសារអប់រំអ្នកដឹកនាំប្រទេសមួយច្បាប់នេះ បានឆ្លុះបញ្ចាំងពីចំណេះដឹងវប្បធម៌គ្រប់គ្រងរដ្ឋ របស់ខ្មែរតាំងពីបុរាណមកដល់សម័យទំនើប ដោយសារយើងឃើញទម្រង់ជាច្រើននៅតែត្រូវគេយកមកប្រើរហូតដល់សព្វថ្ងៃ។ ជាពិសេស នយោបាយបង្កើតសម្ព័ន្ធមិត្តដើម្បីគ្រប់គ្រងប្រទេស ទាំងការចងមិត្តជាមួយមេដឹកនាំបរទេស និងការចងមិត្តនៅក្នុងចំណោមមេដឹកនាំធំៗក្នុងប្រទេស តាមរយៈអាពាហ៍ពិពាហ៍នយោបាយ។

## 3. ភារកិច្ចរបស់ព្រះរាជា

ជាម្ចាស់ផែនដីត្រូវមានវត្ត៧ គឺភាពជាម្ចាស់១, មានអាមាត្យ១, មាននូវ(ជនបទ)ដែនដីខេត្តទាំងឡាយ១, មានរាជធានីប្រកបដោយគូទឹកជុំវិញ និងកំពែងឆ្លងក្រុង១, មាននូវឃ្លាំង១២សម្រាប់ដាក់ទ្រព្យសម្បត្តិ១, មាននូវ(កងទ័ព)ពលពាហណៈដ៏ក្លៀវក្លា១, និងមានព្រះរាជសម្ព័ន្ធមិត្តដែលយល់ចិត្តគ្នាកាលណាមានភ័យ១។

ព្រះរាជាគប្បីជាអ្នកប្រាថ្នាសេពគប់ត្រូវ ដោយរាប់អានអ្នកមានធម៌សប្បុរស, អ្នកមានប្រាជ្ញា, អ្នកមានគុណវិជ្ជា ហើយព្រះអង្គឯង មុនអ្វីៗទាំងអស់ត្រូវតែហាត់ហ្វឹកហ្វឺន, ព្យាយាមធ្វើឱ្យស្ទាត់ជំនាញក្នុងកិច្ចការផងទាំងពួង ជាពិសេស កិច្ចការជិះសេះ ជិះដំរីជាដើម។ រក្សាការសង្កេតពិចារណាជានិច្ចកាលលើពួកខ្ញុំបម្រើរាជការទាំង៦ពួក ចាប់ពីអាមាត្យ រៀងទៅតាមលំដាប់។

ជាព្រះរាជាដ៏ប្រសើរ គប្បីមានប្រាជ្ញា ដឹងអធ្យាស្រ័យដល់អ្នកដទៃឱ្យបានរហ័ស, រៀបចំនូវពាក្យទ្រគោះ ហើយឈ្លាសវៃក្នុងទីផ្សេងៗ។ មានព្រះហឫទ័យអំណត់ ទៀងត្រង់ ប្រកាន់ទសពិធរាជធម៌ និងមិនឫស្យាក្នុងទ្រព្យសម្បត្តិរបស់អ្នកដទៃ។

ជាព្រះរាជាដ៏ប្រសើរក្នុងគ្រប់សារពើការ គប្បីចេះពិចារណាជាមុនសឹមធ្វើ ហើយឱ្យប្រកបដោយអង្គទាំង៦ប្រការ គឺមានសម្ព័ន្ធមិត្តដែលអាចកំញើញបរបក្ស១, ធ្វើជាទីពឹងប្រជាជន១, ចេះធ្វើឱ្យបរបក្ស ជាសត្រូវបាក់បបខ្លបខ្លាចដោយយុត្តិធម្ម១, មានព្រះហទឫទ័យក្លៀវក្លាដោយការព្យាយាមច្រើន១, មានសតិខ្ជាប់ខ្ជួនជានិច្ច១ និងទ្រង់មានព្រះប្រាជ្ញាដឹងការវិនាស និងចម្រើន១។

ព្រះរាជាគប្បី ត្រូវចេះដឹងគុណគេ ហើយឱ្យក្លៀវក្លាសមាគមសេពគប់ជាមួយអ្នកធំទាំង៦ គឺអ្នកមានប្រាជ្ញាច្រើន និងមានអាយុវែង១ អ្នកមានត្រកូលខ្ពស់១ អ្នកមិនបានធ្វើអំពើឱ្យវិនាសខ្លួន មានការភ្ញាល់ និងការភ្ញាល់ជាដើម១ មុនធ្វើការងារទាំងពួងតោងពិចារណារួចទើបធ្វើ១ មិនបានតិះដៀលគេ ដែលពុំគួរនឹងតិះដៀល១ ប្ដេជ្ញាដូចម្ដេច ក៏ប្រកាន់ខ្ជាប់ខ្ជួនដូច្នោះ១។

ជាព្រះរាជាហើយ កុំឱ្យភ្លេចភ្លាំងស្មារតី ៖ កុំកាច់ចង្កូមព្រះនគរ កុំញីញក់ទង់ជ័យ, កុំបង្កវិបរិតព្រះនគរជាដើម។ ត្រូវមានព្រះឥរិយាបថល្អ ទ្រង់រាប់អានសប្បុរសជន ប្រកបដោយរាជវត្តប្រណិបត្តិទាំង៧ ជាហេតុឱ្យចម្រើនព្រះនគរ ជាបច្ចុប្បន្ន ដឹងនូវប្រទេសល្អអាក្រក់ ដឹងកាលដ៏គួរ និងមិនគួរ មិនហួងហែងព្រះរាជទ្រព្យ។

---

[61] សូមមើល, វង់ សុធារ៉ា, ២០០៩, សិលាចារឹកនៃប្រទេសកម្ពុជាសម័យកណ្ដាល១, សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

[62] សូមមើល, សៀវភោវ របស់នាយ ឈឺន។ ក្រុងភ្នំពេញ, No. P. Camb. 53, EFEO Library, Paris.

មានសេចក្តីអធិប្បាយប្រៀបធៀបថា ព្រះរាជបុត្រ និងព្រះជេដ្ឋា ឈ្មោះថា ចុងចង្កូមព្រះនគរ, អ្នកប្រាជ្ញ បុរោហិតដែលចេះដឹងគម្ពីរព្រះត្រៃបិដក និងត្រៃវេទ ឈ្មោះថា ភ្នែកព្រះនគរ, មហាឫសីមុនី ឈ្មោះថា ទង់ជ័យព្រះនគរ, សេដ្ឋី គហបតី ឈ្មោះថា ពោះព្រះនគរ, ពលទាហានក្លៀវក្លា ឈ្មោះថា ជើងព្រះនគរ, បិតាមាតា បីដូចចន្ទោលមុខ, កូនប្រុស-ស្រីមហាជនទាំងពួង ប្រៀបបីដូចជា កញ្ចក់ឆ្លុះ បើព្រះរាជាឯណា ទម្លាយញីញក់កូនប្រុសកូនស្រីរបស់គេ ចាប់យកដោយកម្លាំងពលទាហាន និងការកំហែងគំរាម ឈ្មោះថា ទម្លាយមុខព្រះនគរ។ ហេតុដូច្នោះ ចូរកុំទម្លាយធ្មុងចង្កូមព្រះនគរ, កុំធ្មៀលភ្នែកព្រះនគរ, កុំកាច់ទង់ជ័យព្រះនគរ, កុំញីញក់ក្បាលព្រះនគរ។

មួយទៀត ព្រះរាជា និងពួកអាមាត្យ ព្រមទាំងខ្ញុំព្រះរាជការឱ្យជំនុំគ្នា១ថ្ងៃ៣ពេល គិតប្រឹក្សានឹងគ្នា១ ញ៉ាំងកិច្ចការព្រះនគរឱ្យរាបទាបព្រមគ្នា១, កាន់យកខ្ទាត់សួយទៅដាក់បង្គាប់(អាយា=អាជ្ញា)ឱ្យត្រឹមត្រង់ដោយសមគួរ១ , រាប់អានចាស់ព្រឹទ្ធាចារ្យ១, មិនបានញីញក់បៀតបៀនបុត្រធីតាអ្នកនគរ១ ធ្លាប់រាប់អានបូជាទេវតាក្នុងព្រះនគរក្រៅព្រះនគរ ដោយធ្វើតាមទម្លាប់១, រក្សាសមណជីព្រាហ្មណ៍ដោយប្រពៃ១ ព្រះរាជាគប្បីឱ្យប្រកបដោយធម៌ទាំង៧ប្រការនេះកុំឱ្យដាច់។

ជាព្រះរាជាហើយ គប្បីឱ្យដឹងសម្រួលចិត្តប្រជារាស្ត្រ ឈ្លាសវៃក្នុងឧបាយក្នុងទីនឹងពិចារណា កាត់សន្ទេហរាស្ត្រ(កុំឱ្យរាស្ត្រឆ្ងល់) ឱ្យត្រេកអរក្នុងទានសីល ញញឹមជាមុន ទើបមានព្រះបន្ទូលជាក្រោយ។

ជាព្រះរាជាហើយ គួរប្រកបដោយគុណសម្បត្តិទាំងឡាយដូចសម្តែងមកនេះ ទើបនឹងប្រាបប្រាមប្រជានុរាស្ត្រ បានទូទាំងផែនដី ហើយនឹងបានបុញ្ញរាសី ជាសួស្តីពិកទ្ធមង្គលវិមលស្តម្ភ បរមសុខ ក្សេមក្សាន្តរៀងរួចលុះអវសានកាល។

ព្រះរាជាឯណាឧស្សាហ៍ក្នុងព្រះសណ្តាប់ធម៌ជានិច្ច ទ្រង់ព្រះប្រាជ្ញាឈ្វេងយល់អាថ៌ធម៌ជាលោកីលោកុត្តរៈច្រើន មានព្រះទ័យមិនឫស្យាទ្រាព្យសម្បត្តិអ្នកដទៃ ចូលទៅសមាគមសេពគប់ត្រូវ ដែលចេះដឹងរឿយៗ ព្រះរាជានោះនឹងបរិបូណ៌ដោយឥស្សរិយយស និងបរិវារដ៏ឱឡារិកសព្វកាល។

ព្រះរាជាណាប្រកបដោយអង្គទាំង៧(សត្តហិអង្គេហិ-សត្តរតនៈ) រាជវត្តប្រណិបត្តិទាំង៧ប្រការ ដូចពោលមកហើយនេះ ព្រះរាជានោះនឹងបានសេចក្តីចម្រើនក្នុងបច្ចុប្បន្ននេះប្រាកដ ហើយនិងអាចជម្នះបច្ចាមិត្តទាំងផែនដី។

លោកអ្នកដ៏មានគុណទាំងឡាយមាន៨ គឺព្រះឥន្ទ្រ១ ព្រះច័ន្ទ១ ព្រះអាទិត្យ១ ព្រះពាយុទេវតា១ ព្រះយមរាជ១ ព្រះមហាស្រមុទ្ទ១ ភូមិទេវតា១ ព្រះវេស្សវណហៈទេវតា១ ព្រះទាំង៨អង្គនេះ ជាទីប្រៀបនឹងព្រះមហាក្សត្រ ដែលទ្រង់ទសពិធរាជធម៌។

**ជាព្រះរាជា គប្បីប្រកាន់តួនាទីដូចព្រះទាំងអម្បាលនេះឯង ដូចជា ៖**

ព្រះឥន្ទ្រជាស្តេចលើទេវតាទាំងពួង អនុគ្រោះទេវតា បើមានការសង្កត់សង្កិន ត្រូវលើកលែងខ្ញុំបម្រើរាជការនូវទោស និងគុណដូចព្រះឥន្ទ្រនោះឯង។

ព្រះអាទិត្យរះឡើង ចែងចាំញ៉ាំងទឹកឱ្យស្ងួតអស់៨ខែ ដោយរស្មីនោះដូចម្តេចមិញ ព្រះមហាក្សត្រយកសួយខ្ទាត់ពីប្រជានុរាស្ត្រ តាមសមគួរ ដោយព្រះរស្មី គឺសង្គហវត្ថុឈ្មោះ បុរិសមេធំ ដូច្នោះ។

ព្រះយមរាជ សាកសួរពីបុណ្យបាប ជាមួយសត្វនរកមិនរើសមុខថា ជាស្អប់ស្រលាញ់នោះដូចម្តេច ព្រះមហាក្សត្រទ្រង់វិនិច្ឆ័យសេចក្តីឱ្យត្រង់ កុំរើសមុខថា ស្អប់ស្រលាញ់ដូច្នោះដែរ។

មហាសមុទ្ទមិនប្រាថ្នាគុណប្រយោជន៍ពីស្ទឹងតូចៗ ហើយហូរទៅបំពេញឱ្យស្ទឹងតូចៗពេញបរិបូណ៌ នេះដូចព្រះមហាក្សត្រមិនប្រាថ្នាទ្រព្យសម្បត្តិពីប្រជានុរាស្ត្រ ហើយសង្គ្រោះប្រជានុរាស្ត្រដោយសង្គហវត្ថុដូច្នោះដែរ។

មហាជនឃើញព្រះចន្ទពេញបូណ៌មី ហើយមានសេចក្ដីត្រេកអរដូចម្ដេច ប្រជានុរាស្ត្របានឃើញព្រះភ័ក្ត្រព្រះមហាក្សត្រ ត្រេកអរដូច្នោះ។

ផែនដីទ្រទ្រង់សត្វទាំងឡាយ ដែលល្អអាក្រក់មិនរើសមុខ ទុកឱ្យស្មើគ្នាដូចម្ដេចមិញ ព្រះមហាក្សត្រគ្រប់គ្រងប្រជាជន ទុកឱ្យស្មើមុខទាំងក្នុង និងក្រៅព្រះនគរដូច្នោះឯង។

ព្រះភិរុណបង្អុរភ្លៀង ក្នុងរដូវកាលអស់៤ខែនេះ ដូចព្រះមហាក្សត្រឱ្យពួកយោធាទាហានទាំងពួងត្រេកអរដោយគ្រឿងបរិភោគទាំងពួង។

ជាព្រះរាជាដ៏ប្រសើរគួរស្ថិតដោយទសពិធរាជធម៌ទាំង១០ប្រការ ទ្រង់បញ្ចសីលជាប្រក្រតី អដ្ឋសីល នូវឧបោសថសីល មេត្តាករុណាសត្វទាំងពួង ហើយទ្រង់ឧស្សាហ៍ក្នុងមនសិការៈ និងប្រកាន់តាមកម្ពីព្រះធម្មសាស្ត្រ និងរាជនិតីជានិច្ចជាកាល។ ទ្រង់ប្រព្រឹត្តិធម៌៤ប្រការ គឺពិចារណាសេចក្ដីភាពខុសនៃប្រជាជន ដ៏ធ្វើនូវប្រយោជន៍ និងមិនប្រយោជន៍ក្នុងព្រះអង្គ១ ទំនុកអំម្រុងមនុស្សដែលមានសីលសត្វ១ ប្រមូលព្រះរាជទ្រព្យទុកដោយយុត្តិធម៌១ រក្សាព្រះនគរ រាជសីមាឱ្យក្សេមសុខដោយយុត្តិធម៌១ ស្ថិតក្នុងរាជកិច្ចប្រវេណីមិនដាច់ គឺវេលាសន្ធិយា(ព្រះអាទិត្យលិចបាត់)ទ្រង់ស្ដាប់សទ្ទះសង្កិតកុរិយង្គៈកន្ត្រិន? ហើយទើបទ្រង់ព្រះសណ្ដាប់នីតិនិយាយពីបុរាណរាជប្រពៃណី ក្នុងបឋមយាម ទ្រង់ព្រះសណ្ដាប់យុត្តិធម៌ប្រពៃណី លុះបច្ឆឹមយាម ព្រះរាជាចូលទីក្រលាបន្ទំ បរម្មសុខ សែយ្យនិវេសដោយគួរនឹងវេលា។

លុះតើនឡើងទ្រង់ស្រប់ព្រះភ័ក្ត្រទៅទិសបូព៌–មិនបានត្រាស់ព្រះរាជបរិហារប្រការអ្វីឡើយ មួយទៀតឈើចាក់ព្រះទន្តនោះ ប្រវែង១២ធ្នាប់ លុះចម្រះរួច ឱ្យយកទៅទុកក្នុងភូមិស្ថានដ៏បរិសុទ្ធ។ ទើបទ្រង់គ្រឿងប្រដាប់ ទ្រង់ញញឹមព្រះឱស្ឋទតព្រះនេត្រចំពោះមនុស្ស៤ជុំពួក គឺពួកពេទ្យ, ហោរា, រាជសូរិយោវង្ស និងរាជបណ្ឌិតដ៏មានប្រាជ្ញាដោយនៅសមគួរ ទើបស្ដេចទៅសាលារាជវិនិច្ឆ័យ ព្រមដោយពួកមន្ត្រី កីរី រាជបុរោហិតាចារ្យ ដ៏ស្ថិតក្នុងសីល ផ្ទង់ព្រះរាជហឫទ័យស្ដាប់អាថ៌សេចក្ដី ដែលសុភាសាលាពិចារណាដោយយុត្តិធម៌។ ជាវៃក្វៃនយកគម្ពីរ*(មានន័យថាដែលឈ្លាសវៃ ឬដែលស្ទាត់ជំនាញ)*ព្រះធម្មសាស្ត្រជាព្រះនេត្រ ទតទេសកាលព្រះនគរដោយសមគួរ។ យកព្រះហស្តស្ដាំ គឺព្រះសតិសម្បជ្ជញ្ញៈទ្រង់ព្រះខ័ន្ធក្វៃន គឺពិចារណាបញ្ចវិនិច្ឆ័យកាត់សេចក្ដី អាណាប្រជានុរាស្ត្រដោយយុត្តិធម៌។

ជាព្រះរាជាហើយ គប្បីឱ្យដឹងប្រដៅមនុស្ស ឱ្យដឹងប្រយោជន៍ដែលមិនទាន់ដឹង គប្បីកាត់សង្ស័យឱ្យ ហើយតាក់តែងសម្ដែងវិសេសឱ្យ ដោយគំនិតខ្លួន។

ជាព្រះរាជាគួរលើកមនុស្សល្អ គួរសង្កត់មនុស្សអាក្រក់ចេញ ហើយគួរកន្លងហេតុ៦ប្រការ គឺកំហឹង១ សោយសោក១ ភ័យខ្លាច១ លោភ១ វិនាសត្រកូល១ វិនាសធនធាន១ ទើបធ្វើជាស្ដេចបាន។

ជាស្ដេចហើយ គប្បីទូន្មាន មានមនុស្សខ្លាំងពូកែខាងធ្វើដោយស្មើព្រមគ្នា, ទូន្មានមនុស្សខ្លាច ដោយចែកពួកមាក់(?) ទូន្មានមានមនុស្សលោភខាងឱ្យទ្រព្យ ទូន្មានមានមនុស្សមិនងាយប្រដៅ ទាល់តែដាក់ព្រះអាជ្ញា។

ព្រះរាជាប្រៀបដូចដើមឈើ ចៅហ្វាយខ្លាំងដូចឫសឈើ រាជវង្ស និងមិត្តអាមាត្យដូចមែកឈើ, ស្ដេចប្រាសចាកទ្រព្យសម្បត្តិដូចបក្សីគ្មានស្លាប ទ្រព្យសម្បត្តិដូចឥន្ទ្រីយ៍មានភ្នែកដែលឱ្យសម្រេចប្រយោជន៍បានជាដើម។ ហេតុដូច្នោះ ស្ដេចគួរព្យាយាមរកទ្រព្យដោយយុត្តិធម៌ ហើយរក្សាទុកឱ្យប្រពៃ ចាកផុតពីការអន្តរាយទាំងពួង។

ជាព្រះរាជាហើយ រក្សាខេត្តខ័ណ្ឌខ្លួនឱ្យរួចចាកបរបក្ស ឱ្យរួចពីមនុស្សស្និទ្ធស្នាល១ ឱ្យរួចពីមនុស្សដ៏មានទ្រព្យមាំមួន១ ឱ្យរួចពីមហារចោរ ហើយគប្បីរក្សាឃ្លាំងទាំង១២ ឱ្យប្រពៃបានឈ្មោះថា គ្រងរក្សាខេត្តដែនដីឱ្យប្រពៃ។

ជាព្រះរាជាហើយ គប្បីយកព្រះទ័យទុកដាក់ជាប្រចាំចំពោះគម្ពីររាជនីតិសាស្ត្រនេះ, ជ្រាបហេតុដែលនឹងអាចឈ្នះបរបក្ស ហើយក៏មិនមានអប្បុកព្រះទ័យ គប្បីជម្នះផ្ចាលផ្ចាញ់ និងញ៉ាំងរាជភ័យទាំងឡាយឱ្យរាបទាបពេញទាំងផែនដី លុះអវសានកាលក៏នឹងទៅសោយសុខក្នុងសួគ៌ាលោកនោះហោង។

## 4. ភារកិច្ចអាមាត្យ-មន្ត្រី

អាមាត្យទាំងឡាយ ដ៏មានវង្សត្រកូលធ្វើការស្អាតល្អិតក្លៀវក្លា បានស្តាប់មកច្រើន ហើយជាទីស្រលាញ់នៃមហាជនស្ទាញស្ទាត់ក្នុងនីតិសាស្ត្រ គួរឱ្យជិតជិតនឹងព្រះអង្គ។

ជាមន្ត្រីមានអង្គ៨ គឺបានសណ្តាប់មកច្រើន១ គឺមានសីលគុណ១ ក្លៀវក្លា១ មានសេចក្តីព្យាយាមច្រើន១ ធ្វើកិច្ចការរាជការរួចបានឆាប់១ មានកម្លាំងច្រើន១ លោភតិច១ មានលក្ខណៈជាទីស្រឡាញ់១ ប្រកបអង្គទាំង៨នេះទើបអាចធ្វើជាមន្ត្រីបាន។ ជាខ្ញុំបម្រើព្រះរាជការ គប្បីទូលជំទាស់ព្រះមហាក្សត្រដែលប្រព្រឹត្តិការអាក្រក់១ គប្បីឱ្យប្រកបដោយប្រយោជន៍ដ៏ចម្រើន១ ជួយបិតបាំងចំណុចអាក្រក់របស់អម្ចាស់ចេញ១ សម្តែងគុណម្ចាស់ឱ្យប្រាកដ១ វេលាអាប់ចុះមិនចោលអម្ចាស់១ វេលាអត្តខាត់មិនរាថយការសង្គ្រោះម្ចាស់តាមសតិកម្លាំង១ លក្ខណៈ៦ប្រការនេះគួរអាមាត្យគប្បីប្រកាន់យកឱ្យសព្វខ្លួន។[63]

## 5. វប្បធម៌ដែលផ្អែកលើព្រះពុទ្ធសាសនា

ព្រះសង្ឃពុទ្ធសាសនាថេរវាទ នៅសម័យកណ្តាល បានដើរតួនាទីយ៉ាងសំខាន់ក្នុងសង្គមខ្មែរ ជំនួសឱ្យពួកព្រាហ្មណ៍ដ៏ល្បីល្បាញនៅសម័យអង្គរ ដែលបានកន្លងផុតទៅនៅអំឡុងសតវត្សរ៍ទី១៤។ នៅក្នុងឯកសារពង្សាវតារទាំងអស់ បង្ហាញឱ្យឃើញថា ពុទ្ធសាសនាថេរវាទ ជាសាសនារដ្ឋ និងជាសាសនាផ្លូវការមួយ ដែលមានលក្ខណៈឯកភាពនៅទូទាំងប្រទេសតពីនោះមករហូតដល់សព្វថ្ងៃ។ រាល់សង្គ្រាមទាំងអស់ ទាំងសង្គ្រាមជាមួយបរទេស ជាពិសេសប្រទេសសៀម និងទាំងសង្គ្រាមក្នុងស្រុក ការកាប់ចាក់គ្នារវាងសមាជិកនៃរាជវង្សានុវង្ស ដែលអាងថាខ្លួនមានសិទ្ធិឡើងសោយរាជ្យដូចគ្នា គេតែងយកលេសមួយយកមកនិយាយ គឺ « ដើម្បីសេចក្តីសុខនៃសមណជីព្រាហ្មណ៍ និងប្រជានុរាស្ត្រផង ដែលជាអ្នកកាន់ពុទ្ធសាសនា"។ បន្ទាប់មក គេនឹងចាប់ផ្តើមធ្វើសង្គ្រាម ឬបញ្ឈប់សង្គ្រាម ដោយមានការចរចាបង្កើតយុទ្ធសន្តិភាព ដោយស្ម័គ្រចិត្តរៀងៗខ្លួន (Eng 1985)។ រហូតមកទល់ពេលនេះ មានអ្នកស្រាវជ្រាវខ្មែរ និងបរទេសមួយចំនួនតូច ដែលបានយកចិត្តទុកដាក់ធ្វើការសិក្សាអំពីប្រវត្តិសាស្ត្រសម័យកណ្តាលរបស់កម្ពុជា តាមរយៈសត្រាពង្សាវតារដែលគេបានតាក់តែងឡើងនៅសតវត្សរ៍ទី១៩។ ប៉ុន្តែការសិក្សាទាំងនោះផ្តោតទៅលើព្រឹត្តិការណ៍សង្គ្រាម និងរបាខ្សត្រ ច្រើនជាងផ្នែកសង្គម និងចរន្តនៃការផ្លាស់ប្តូររបស់វា ជាពិសេស មានព្រះរាជាជាច្រើនអង្គដែលគេបានប្រឌិតឈ្មោះឡើង ដើម្បីបំពេញការខ្វះខាតឯកសារ (Vickery 2002)។ ម្យ៉ាងទៀត

---

[63] (ឯកសារចារដោយ) អនន្តញាណព្រហ្ម១ សុក្ខព្រហ្ម១ ជាព្រះរាជគ្រូចែនាកម្ពីរាជនិតិកាលព្រះពុទ្ធសាស្នារកន្លង៥០០(ជាកាលបរិច្ឆេទបំផ្លើសរបស់ស្មេរ) ឆ្នាំរោងន័ក្សត្រ ថ្ងៃព្រះប្ញាអាកែ្សគារមិណិ ស្រុកសូន្ទះលោក្យ ខែត្រស្យាម។។ បើតាមចំណារនៅខាងចុងនៃឯកសារនេះ យើងយល់ថា អ្នកចារឹកជាខ្មែរនៅក្នុងខេត្តសង្ខះលោក ដែលសៀមអយុធ្យាវាតទីយកចាប់ពីចុងសតវត្សរ៍ទី១៨ និងដើមទី១៩។ ហើយប្រហែលស្មេរនេះឯងជាអ្នកបកប្រែបច្ចេកពាក្យទាំងនេះ ទៅជាភាសាបាលី។

ដោយសារកង្វះខាតឯកសារ ទាក់ទងនឹងបញ្ហាសាសនា ទើបការសិក្សាអំពីប្រធានបទនេះ មានការលំបាក ដែលធ្វើឱ្យអ្នកស្រាវជ្រាវជាច្រើននាំគ្នាចៀសវាង ហើយចូលចិត្តផ្តោតការស្រាវជ្រាវរបស់ខ្លួន ចាប់ពីសតវត្សរ៍ទី១៩ ឡើងមកដល់សម័យទំនើបតែម្តង។ ពីព្រោះ រយៈពេលនេះមានឯកសារ និងកំណត់ហេតុពត៌មានជាច្រើនស្តីអំពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ហើយបាតុភូតនេះ វាបានលេចឡើងបន្ទាប់ពីពួកបស្ចិមប្រទេស ទាំងអ្នកប្រាជ្ញ និងអ្នកនយោបាយ យោធាមកដល់កាន់តែច្រើនឡើង នៅក្នុងតំបន់អាស៊ីអាគ្នេយ៍។

ជាការពិតណាស់ថា មុនពេលទ្រឹស្តីវិទ្យាសាស្ត្របច្ចេកទេសរបស់ពួកបស្ចិមប្រទេសរីកចម្រើនឡើង និងផ្សព្វផ្សាយនៅទូទាំងពិភពលោក ជាពិសេសមកដល់តំបន់អាស៊ីអាគ្នេយ៍, ប្រភពចំណេះដឹងដ៏សំខាន់សព្វបែបយ៉ាងរបស់មនុស្សនៅក្នុងតំបន់នេះ ទាំងធម្មចក្រ និងអាណាចក្រ គឺមានការពឹងផ្អែកតែទៅលើទ្រឹស្តីសាសនានេះឯង។ ម្លោះហើយ សាសនា គឺជាមនោគមវិជ្ជាម្យ៉ាង ដែលអ្នកដឹកនាំរដ្ឋពីបុរាណត្រូវតែចេះដឹងអំពីខ្លឹមសាររបស់វាឱ្យបានច្បាស់លាស់ និងយកមកប្រើជាឧបករណ៍សម្រាប់ប្រមូលផ្តុំមនុស្ស, អ្នកជឿ និងកាន់គោរពទាំងអស់ ឱ្យមូលកម្លាំងគ្នា ដើម្បីធ្វើអ្វីៗសម្រេចតាមបំណងរបស់អ្នកមេគំនិតឬមេដឹកនាំកំពូលនៃប្រទេស។ នៅអំឡុងពេលនោះ សង្គ្រាមជាច្រើនបានកើតឡើង ដោយសារសាសនា ទាំងនៅអឺរ៉ុប និងជាពិសេសនៅកម្ពុជាចាប់ពីសតវត្សរ៍ទី១៤មក។ នៅសម័យចាស់វេលាខ្មែរកាន់ព្រហ្មញ្ញសាសនា, ព្រាហ្មណ៍ជាគ្រូបង្រៀនដល់ពួកក្សត្រ និងយុវអភិជនទាំងឡាយ ហើយនៅតាមអាស្រមនានា កូនចៅអ្នកស្រុកមានព្រាហ្មណ៍សាស្ត្រាចារ្យនៅកន្លែងផ្ទាល់(អធ្យាបកៈ)ជាអ្នកជួយបង្ហាត់បង្រៀន។ ប៉ុន្តែនៅពេលពុទ្ធសាសនាថេរវាទបានប្រតិស្ឋានខ្ជាប់ខ្ជួន ភារកិច្ចជាអ្នកបង្រៀន បានផ្ទេរមកឱ្យព្រះសង្ឃ ដែលបួសគង់នៅតាមវត្តអារាមទាំងឡាយក្នុងអាណាចក្រ (Pou 1984)។

តាមភស្តុតាងប្រវត្តិសាស្ត្រ ខ្មែរបានស្គាល់ទ្រឹស្តីពុទ្ធសាសនា យ៉ាងហោចណាស់តាំងពីសតវត្សរ៍ទី៧នៃគ.ស ដោយមានអ្នកខ្លះបានកាន់ និងគោរពទ្រឹស្តីនេះ(សឺដេស1954: 6)។ ក្នុងចំណោមអ្នកបួស និងបរិស័ទព្រហ្មញ្ញសាសនាដ៏មានចំនួនច្រើនលើសលប់នៅក្នុងសង្គមកម្ពុជា ចាប់តាំងពីសម័យនោះ រហូតមកដល់សតវត្សរ៍ទី១៤(បើតាមសិលាចារឹកគោកស្វាយចេក K. 754 ឆ្នាំ១៣០៩គ.ស.) ពុទ្ធសាសនាបានបង្ហាញនូវការខំប្រឹងរស់ និងប្រណាំងប្រជែងគ្នាយ៉ាងវេទនា ក្នុងការដណ្តើមយកតួនាទីផ្តាច់មុខខាងផ្នែកមនោ-គមវិជ្ជា និងទស្សនវិជ្ជាអប់រំផ្លូវចិត្តក្នុងសង្គមខ្មែរ។

គេបានដឹងច្រើនអំពីតួនាទីរបស់ព្រហ្មញ្ញសាសនា នៅក្នុងការរួមចំណែកញ៉ាំងវឌ្ឍនភាពនៃសង្គមខ្មែរ នៅសម័យអង្គរ ឱ្យរីកចម្រើនរុងរឿងបាន ដោយសារភស្តុតាងប្រវត្តិសាស្ត្រជាច្រើននៅសេសសល់គង់វង្សរហូតដល់សព្វថ្ងៃ ដូចជា ប្រាសាទនានា, ប្រព័ន្ធគូរទឹក និងបារាយណ៍ស្តុកទឹកដ៏មហិមាទាំងឡាយ ដែលសឹងមានកំណត់ត្រាបញ្ជាក់នៅលើផ្ទាំងសិលាថា សមិទ្ធិផលទាំងនោះកើតឡើងដោយសារស្នាដៃព្រះរាជា និងមន្ត្រីទាំងឡាយ ដែលកាន់គោរពព្រហ្មញ្ញសាសនា។ ក្នុងចំណោមព្រះរាជាកាន់ពុទ្ធសាសនាទាំងឡាយ មានតែព្រះបាទ ជយវ្ម័ទី៧ (១១៨១-១២២០គ.ស.) មួយអង្គគត់ ដែលបានសាងស្នាដៃដ៏មហិមាប្រណាំងនឹងព្រះរាជាកាន់ព្រហ្មញ្ញសាសនាទាំងឡាយ ដែលជាបុព្វបុរសរបស់ទ្រង់(សឺដេស 1935)។

បន្ទាប់ពីការប្រជែងគ្នាចុងក្រោយ ក្នុងអំឡុងពេលប្រមាណជាងមួយសតវត្សរ៍ ព្រះរាជាទាំងឡាយនៅចុងសម័យអង្គរ បានក្លាយទៅប្រមុខនៃអ្នកព្រះពុទ្ធសាសនានិកាយថេរវាទ (ស្រដៀងនឹងហីនយាន)តជាប់រហូតមកដល់សព្វថ្ងៃ។ នៅសម័យនៃការកាន់សាសនានេះ នៅកម្ពុជាគេសង្កេតឃើញថា លែងមានការសាងសង់សំណង់ធំៗមហិមា ដូចពេលមុនទៀតហើយ ជាពិសេស ប្រាសាទសម្រាប់ឧទ្ទិសចំពោះទេពតាដូចពេលមុន។ ចំណែកពុទ្ធសាសនាថេរវាទក៏មិនតម្រូវឱ្យគេសាងសង់វត្តអារាមល្អស្កឹមស្កៃ និងបារាយណ៍ទឹកធំតមកទៀតដែរ។ លើសពីនេះ

ទៀត មេដឹកនាំប្រទេសនៅសម័យកាលនេះ ហាក់ដូចជាមិនសូវចាប់អារម្មណ៍ ដល់ការធ្វើសង្គ្រាមពង្រីកទឹកដី និងការពារទឹកដីជាអចិន្ត្រៃយ៍ប្រឆាំងការឈ្លានពានពីបរទេសដែរ។ អ្នកដឹកនាំធ្វើការផ្លាស់ប្តូរ រាជធានីនៃប្រទេសជាញឹកញាប់ ដើម្បីស្វែងរកទីតាំងល្អ ជាពិសេសងាយស្រួលទប់ទល់ និងងាយគេចចេញពីការក្រសោបចាប់យករបស់ប្រទេសជិតខាង (Khin 1988)។ យុទ្ធសាស្ត្ររបស់អ្នកដឹកនាំខ្មែរពុទ្ធសាសនាថេរវាទ ហាក់ដូចជាប្រុងប្រៀបខ្លួនរត់ និងពឹងពាក់ជំនួយពីប្រទេសជិតខាងជាជាងខំប្រឹងពង្រឹងកម្លាំងរបស់ខ្លួន ដោយខ្លួនឯង។

ភស្តុតាងខ្លះៗ ដែលគេបានដឹងអំពីព្រះសង្ឃពុទ្ធសាសនាខ្មែរ តាំងពីសតវត្សរ៍ទី១៦ គឺថា អ្នកស្រុកមានភក្តីភាពស្មោះត្រង់ជាខ្លាំងចំពោះព្រះសង្ឃ។ អ្នកផ្សាយសាសនាគ្រីស្តលោក ហ្គាស្ប៉ារដាគ្រុស(Gaspar da Cruz) បានបរាជ័យក្នុងការព្យាយាមអូសទាញជនជាតិខ្មែរ ឱ្យជឿលើព្រះគ្រីស្ត ដោយសារអ្នកស្រុកជឿ និងគោរពយ៉ាងរឹមុត្តិចំពោះបុគ្គលពីរប្រភេទ គឺ"ព្រះរាជា" និង"ព្រះសង្ឃ"ដែលលោក ឆាណ្ឌល័រ(១៩៩៣:៨២) ហៅថា "អបិយជំនឿរបស់អ្នកស្រុក"(the superstition of people)។ តាមទស្សនវិស័យបេសកទុតផ្សាយគ្រិស្តសាសនាជនជាតិអឺរ៉ុបម្នាក់ឈ្មោះលោក ហ្គាស្ប៉ា ដាគ្រុស បានកត់សម្គាល់តុល្ហិភាពរបស់ព្រះសង្ឃខ្មែរនាពេលនោះ បែបច្រណែនថា ៖

*«ភិក្ខុទាំងនេះក្រអឺតក្រទម និងមានអំណួតខ្លាំង... ពេលនៅរស់រានមានជីវិត អ្នកស្រុកគោរពពួកភិក្ខុដូចទេវតា ដោយហេតុថា មនុស្សមានឋានៈទាប តែងគោរពប្រណិប័តន៍លោកជំ ដោយក្រាបថ្វាយបង្គំនៅចំពោះមុខ។ ហេតុនេះហើយ បានជារាស្ត្រសាមញ្ញមានការទុកចិត្តខ្លាំងចំពោះព្រះសង្ឃ ដោយសេចក្តីប្រណិប័តន៍ និងគោរពបូជា។ ដូច្នេះហើយគ្មានអ្នកណាហ៊ានធ្វើអ្វីផ្ទុយនឹងព្រះសង្ឃទាំងនោះឡើយ... មានពេលខ្លះ ខណៈដែលខ្ញុំកំពុងទេសនា មានមនុស្សជាច្រើននៅជុំវិញមកស្តាប់យ៉ាងល្អ ហើយពេញចិត្តនឹងអ្វីដែលខ្ញុំបាននិយាយទៅកាន់ពួកគេ។ តែបើសិនជាពេលនោះ មានភិក្ខុមួយអង្គណានិមន្តមកដល់ ហើយមានថេរដីកាថា "អ្វីដែលលោកនេះនិយាយនោះក៏ល្អម្យ៉ាង តែធម៌របស់យើងល្អជាង" ក៏ពួកគេបានដើរចេញពីខ្ញុំអស់រលីង» (Gaspar da Cruz cited in Chandler 2005: 87 )*។

លើសនេះទៀត បេសកជនផ្សព្វផ្សាយគ្រីស្តសាសនាដដែលនេះ ដែលបានទស្សនាក្រុងលង្វែក នៅអំឡុងឆ្នាំ១៥៥៦ បានកត់សម្គាល់ថា "ព្រះសង្ឃមានចំនួនច្រើនជាងមួយភាគបីនៃចំនួនបុរសពេញវ័យនៅប្រទេសកម្ពុជា ឬតាមស្មានមានចំនួនរាប់សែននាក់"( Chandler 1993: 82 )។

លោក ឆាណ្ឌល័រ( ១៩៩៦: ៦១-៧៥) បានបង្ហាញឱ្យដឹងពីពត៌មានសំខាន់មួយទៀតទាក់ទងនឹងមេបះបោរមួយរូប នាមភិក្ខុ"កែវ" ដែលជាព្រះសង្ឃចេះសិល្ប៍មន្តអាគមធុតធាប់ បានប្រមូលស្ម័គ្របក្សពួកកទ័ពនៅតំបន់បាភ្នំនាអំឡុងឆ្នាំ១៩២០-១៩២១ ដើម្បីប្រឆាំងនឹងពួកយួនឈ្លានពានកម្ពុជានៅពេលនោះ។ ព្រោះស្ថានភាពនយោបាយរបស់ខ្មែរនៅពេលនោះ ទទួលរងការធ្វើទុក្ខបុកម្នេញ និងការលំបាកវេទនាខ្លាំងពេក ដោយសារអំពើដ៏ឃោរឃៅយង់ឃ្នងរបស់កងទ័ពយួន។ បន្ទាប់មកកងកម្លាំងបះបោរនេះ មានការចូលរួមដៃរបស់មន្ត្រីខេត្តក្រៅផងដែរ។ សមរភូមិដំបូង ក្រុមបះបោរបានយកជ័យជំនះលើគូបដិបក្សជានិច្ច។ ប៉ុន្តែមិនយូរប៉ុន្មាន ព្រះសង្ឃមេបះបោរលែងមានសិល្ប៍ពូកែដូចមុន ត្រូវកងទ័ពយួនជំនួយមកពីទីក្រុងព្រៃនគរ បង្ក្រាបឱ្យបរាជ័យយ៉ាងជូរចត់។ អ្នកស្រុក និងព្រះសង្ឃទាំងឡាយ ទាំងអ្នកទើបនឹងចាកសិក្ខាបទ ទាំងអ្នកនៅគ្រងចីវរនៅឡើយ ត្រូវកងទ័ពយួនកាប់សម្លាប់ដោយគ្មានត្រាប្រណី។ គេបានចោទថា មកពីព្រះសង្ឃទាំងនោះមិនបានតាំងខ្លួនឯងក្នុងធម៌ស្ងប់ស្ងាត់ ចូលរួមក្នុងការកាប់សម្លាប់មនុស្សល្មើសនឹងសិក្ខាបទ ទើបធ្វើឱ្យសាបសីលសាស្ត្រសៃយនោះទៅ។ នៅចុងបញ្ចប់ ព្រះសង្ឃកែវត្រូវបរាជ័យរហូតដល់ស្លាប់ខ្លួន និងនាំទុក្ខដល់ស្ម័គ្របក្សពួកឱ្យរងគ្រោះ ដោយការសម្លាប់រង្គាលសងសឹកពីសំណាក់មេទ័ពយួនទាំងនោះដែរ។

កន្លងមកនេះ មានការសិក្សាមួយស្តីអំពីពុទ្ធសាសនាថេរវាទ នៅចន្លោះចុងសតវត្សរ៍ទី១៨ ដល់ពាក់កណ្តាលសតវត្សរ៍ទី២០នេះ ក្នុងក្របខ័ណ្ឌនិក្ខេបបទ ដើម្បីបំពេញលក្ខខណ្ឌសញ្ញាប័ត្រអនុបណ្ឌិតប្រវត្តិសាស្ត្រ។ ក្នុងប្រធានបទនេះ លោក សំ យ៉ាង(១៩៩០) បានសិក្សាផ្តោតទៅលើស្រទាប់មេដឹកនាំសាសនា, អង្គការចាត់តាំងរបស់ព្រះសង្ឃ ឬការបែងចែករចនាសម្ព័ន្ធ និងឋានានុក្រមព្រះសង្ឃ, និងការសិក្សាអប់រំរបស់ព្រះសង្ឃនៅកម្ពុជាចាប់ពីឆ្នាំ១៧៩៥ ដល់១៩៥៤។ ដោយគ្របដណ្តប់ រយៈពេល១៦០ឆ្នាំ លើវិសាលភាពចាប់តាំងពីខេត្តបាត់ដំបង, កំពង់ធំ, និងស្ទឹងត្រែង ដែលត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់សៀម។ អំពីតួនាទីរបស់ព្រះសង្ឃពុទ្ធសាសនា នៅក្នុងសង្គមខ្មែរសម័យកណ្តាលវិញ គឺបានសម្តែងនៅក្នុងជីវភាពនយោបាយ នៅពេលស្ថានភាពស្រុកទេសពោរពេញដោយវិបត្តិផ្ទៃក្នុង រវាងសាច់សារលោហិតរាជវង្សានុវង្សខ្មែរ ដើម្បីដណ្តើមរាជបល្លង្គគ្នា, ការអប់រំផ្លូវចិត្តដល់មហាជនជាពុទ្ធសាសនិក, ជីវភាពរស់នៅរបស់ព្រះសង្ឃ និងកិច្ចការជាប្រយោជន៍ខាងសង្គមកិច្ចនៅតាមមូលដ្ឋាននានា។

លោក ឆាណ្ឌល័រ (២០០៥) បានទទួលស្គាល់ថា ព្រះពុទ្ធសាសនានៅប្រទេសខ្មែរសម័យកណ្តាលបានដើរតួនាទីយ៉ាងសំខាន់ ដោយសារមានមន្ត្រីជាន់ខ្ពស់ជាច្រើន ក្នុងរាជ្យស្តេចនីមួយៗ សុទ្ធសឹងជាអ្នកបានបួសរៀនក្នុងសំណាក់ពុទ្ធសាសនាអស់រយៈពេលយ៉ាងយូរ។ តែគួរឱ្យស្តាយ ដោយសារគេមិនសូវឃើញមានឯកសារច្រើនផ្តល់ព័ត៌មានទាក់ទងនឹងតួនាទីរបស់ព្រះសង្ឃនៅសម័យនេះ។ ម្ល៉ោះហើយចំណោទបញ្ហាមួយ ដែលបានលើកឡើងជាទូទៅដោយប្រជារាស្ត្រខ្មែរខ្លួនឯង នៅពេលណាគេបានដឹងអំពីប្រវត្តិសាស្ត្ររុងរឿង និងអាប់អោនរបស់ជាតិ តែងតែចោទទម្លាក់កំហុសថា មកពីកម្ពុជាកាន់ពុទ្ធសាសនា(ថេរវាទ)ទើបនាំឱ្យចុះទន់ខ្សោយ។ បន្ទាប់មក គេបានទាញការពន្យល់ហេតុផលជាច្រើន តាមពីក្រោយដើម្បីគាំទ្រអំណះអំណាងរបស់ខ្លួន។ ក៏ប៉ុន្តែ ចំណោទនេះតែងតែពិបាករកទឡ្ហីករណ៍មកពន្យល់ នៅពេលមានការផ្តល់គំនិតប្រៀបធៀបថា ប្រទេសសៀម ឬថៃ កាន់ពុទ្ធសាសនាថេរវាទ តាំងពីដើមកំណើតរៀងមកដែរ (Chandler 1993: 78)។ ព្រះសង្ឃដែលជាសាវ័កផ្សព្វផ្សាយពុទ្ធសាសនា ក្រៅពីបានសម្តែងតួនាទីយ៉ាងសំខាន់នៅក្នុងការរួមចំណែក ការពារ និងកសាងសង្គមខ្មែរ ចាប់ពីសតវត្សរ៍ទី១៦ រហូតដល់ទី១៩ ដូចជាលើការអប់រំធនធានមនុស្ស, ការតែងនិពន្ធ និងកត់ចម្លងឯកសារ, ការងារសង្គមកិច្ច, និងកិច្ចការនយោបាយ។

អត្ថបទនេះនឹងសិក្សាអំពីការសម្តែងតួនាទីរបស់ព្រះសង្ឃពុទ្ធសាសនា នៅក្នុងផ្នែកនយោបាយ, សង្គមកិច្ច, ជំនឿ, និងការអប់រំសង្គម នៅចន្លោះសតវត្សរ៍ទី១៦ ដល់ទី១៩។ ការកំណត់រយៈពេលដ៏វែងបែបនេះ ដោយសារបាទ្រី សាន អាន្តូនិយ៉ូ និងពួកអឺរ៉ុបជាច្រើន ដែលធ្លាប់ស្គាល់សង្គមខ្មែរសម័យកណ្តាលនៅចន្លោះពេលខាងលើនេះថា "រូបភាពនៃរចនាសម្ព័ន្ធរបស់សង្គមខ្មែរ ស្ទើរតែពុំមានការប្រែប្រួល"(Chandler 2005: 93)។ លើសនេះទៀត នៅភាគខាងដើមនៃសៀវភៅរបស់លោក ឆាណ្ឌល័រ(១៩៩៣៖ ១០)ហាក់ដូចជាបានឯកភាពថា ក្នុងរយៈពេលរាប់ពាន់ឆ្នាំ មុនការមកដល់នៃរបបអាណាព្យាបាលបារាំង ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជាមាន"លក្ខណៈមិនប្រែប្រួល" ហើយដោយសារបារាំង ទើបសង្គមខ្មែរចាប់ផ្តើមប្រែប្រួលឆ្ពោះមករកអភិក្រមទំនើបកម្ម និងអារ្យធម៌បែបដូចសព្វថ្ងៃនេះ។ ទោះបីជាយ៉ាងណា ការសិក្សាលើផ្នែកនេះ នៅតែមានឧបសគ្គច្រើនអន្លើ ដោយសារបញ្ហាកង្វះខាតប្រភពឯកសារ ដែលផ្តល់ព័ត៌មានទាក់ទងនឹងពុទ្ធសាសនា ជាពិសេសព្រះសង្ឃ ដែលជាភ្នាក់ងារដ៏សំខាន់។

ព្រះសង្ឃពុទ្ធសាសនានៅកម្ពុជា ជាបុគ្គលពិសិដ្ឋ, គួរជាទីគោរព ព្រោះប្រកបដោយគុណសម្បត្តិខាងសីលធម៌, ភាពម្ចាស់ការ, គុរុភារៈ, ចំណេះដឹង ដែលជាទីប្រាថ្នាចង់បាន របស់អាណាព្យាបាលនៃក្រុមគ្រួសារខ្មែរទាំងអស់ និងជាភ្នាក់ងារសង្គមដ៏មានសីលធម៌ខ្ពស់ ជាស្នូលសំខាន់ទី២បន្ទាប់ពីព្រះរាជា ក្នុងការបង្កើតកម្លាំងសាមគ្គី និងឯកភាពជាតិ។ ចំពោះតួនាទីដែលទាក់ទង នឹងបញ្ហានយោបាយ ព្រះសង្ឃក៏អាចចូលរួមបានដែរ តែស្ថិតនៅក្នុង

លក្ខខណ្ឌមួយ ត្រង់ថា ″សម្តែងបានតែក្នុងសកម្មភាពវិហឹសា ដោះស្រាយទំនាស់ដោយសន្តិវិធី និងមិនអាចបង្កើតចលនាឬចូលរួមក្នុងសកម្មភាពនយោបាយប្រទុស្តរាយតាមផ្លូវយោធាបានឡើយ″។

## 6. តើពុទ្ធសាសនាចូលមកកម្ពុជាតាមរបៀបណា?

តាមចារឹកប្រាសាទព្រះខ័ន នៅលើផ្ទាំកគម្ពីរធំមួយ ដែលអង្គុយពែនភ្នែនទូលដោយសំណាកបដិមាស្រ្តីម្នាក់ ឬព្រះសង្ឃមួយអង្គ(K. 888)និងក្នុងស្ថិតក្នុងស្ថានភាពគោរពបូជាចំពោះព្រះរតនត្រៃ គេបានចាត់ទុកព្រះពុទ្ធជាគ្រូ, ព្រះធម៌ជាជម្រកស្នាក់អាស្រ័យ និងព្រះសង្ឃជាភ្នាក់ងារអាជ្ញាខាងសាសនា(Pou 1989: 14)។ តាមគម្ពីរជិនកាលមាលីបករណ៍(ទំ.៩៨) បានឱ្យដឹងថា ពុទ្ធសាសនាហីនយាន ឬតាមគំនិតរបស់បរិស័ទស្រីលង្កាហៅថា ″ថេរវាទ″ បានប្រតិស្ឋាននៅប្រទេសកម្ពុជាតាំងពីឆ្នាំ១៤២៦នៃគ.ស. ដោយប្រកាន់យកតាមក្បួនព្រះត្រៃបិដកភាសាបាលីជាគោល(ង៉ែត សោភ័ណ ២០០៤)។

ទោះជាយ៉ាងណា ការប្រតិស្ឋាននៃពុទ្ធសាសនាថេរវាទនៅកម្ពុជា ស្ថិតនៅក្នុងសំណួរមិនទាន់ដាច់ស្រេចមួយ ថាតើកម្ពុជាទទួលផ្ទាល់មកពីស្រីលង្កា ឬកម្ពុជាទទួលពីស្រីលង្កាតាមរយៈសុខោទ័យរបស់សៀមឬថៃ(សឺដេស 1936)? លោក ហ្វ្រង់ស្វ័រ ប៊ីហ្សោត៍(១៩៩២)វិញ ក្រោយពីគូសបញ្ជាក់អំពីទឡ្ហីករណ៍ជាច្រើនស្តីពីវត្តមានពុទ្ធសាសនាថេរវាទរបស់ស្រីលង្កានៅភូមា, ថៃ-មន, ឡាវ និងកម្ពុជារួចមក បានពន្យល់ថា ″ជនជាតិសៀមទើបតែបង្ហាញវត្តមាននៅអង្គរចាប់ពីសតវត្សរ៍ទី១២ និងបង្កើនឥទ្ធិពលរបស់ខ្លួនមកលើប្រទេសកម្ពុជាជាបន្តបន្ទាប់គ្នាមិនឈប់ឈរ។ ស្លាកស្នាមដ៏ច្រើននោះ មានជាប់នៅក្នុងស្នាដៃអក្សរសិល្ប៍ពុទ្ធសាសនាខ្មែរ។ម្យ៉ាងទៀត ទាក់ទងនឹងបច្ចេកពាក្យនៃពិធីបូជា-សែនព្រេន និងពិធីបុណ្យធម្មតាជាច្រើន គឺមានប្រភពជាភាសាសៀម។ ក៏ប៉ុន្តែ ជាតុពិតនៃបច្ចេកពាក្យទាំងឡាយ ដែលខ្មែរបានថែរក្សាទុកនោះ បង្ហាញឱ្យឃើញនូវភាពដូចគ្នារបស់ពួកសៀមដែលបានធ្វើត្រាប់តាមជនជាតិមន ដោយមិនចាំបាច់ពិចារណាយ៉ាងនោះដែរ″។ ក៏ប៉ុន្តែជាសន្និដ្ឋាន អ្នកនិពន្ធនេះ បានគិតថា ″ខ្មែរបានទទួលពុទ្ធសាសនាថេរវាទពីជនជាតិមន តាមរយៈជនជាតិសៀម ដែលជាអន្តរការី″(Bizot 1992: 27)។ ការអះអាងនេះ គួរឱ្យអស់សំណើច ពីព្រោះថា បើពុទ្ធសាសនាថេរវាទភាសាបាលី ត្រូវសៀមទទួលបានពីមន ហេតុអ្វីបានជារាល់គម្ពីរសាសនាទាំងអស់ដែលសៀមប្រើរហូតដល់ឆ្នាំ១៩១២ នៅតែសរសេរជាអក្សរខ្មែរ ដែលសៀមខំបំភ្លៃថា ជាអក្សរខមទៅវិញ? ហើយគម្ពីរព្រះត្រៃបិដកជាអក្សរសៀម ទើបតែមកដល់រាជ្យស្តេចចុឡាឡុងកនប៉ុណ្ណោះ ទើបចាប់ផ្តើមសរសេរព្រះត្រៃបិដកជាអក្សរសៀមឡើង ដើម្បីជំនួសសត្រាដែលសៀមប្រើជាអក្សរខ្មែរជាប្រពៃណីតាំងពីដើមមក (Cornelius Beach Bradley, ១៩០៧, ១៩១២, ១៩១៧)។[64]

ចំណែកភស្តុតាងធម្មតាមួយទៀត គឺទាក់ទងនឹងនាមរបស់តួអង្គមួយចំនួនក្នុងរឿងមហាវេស្សន្តរជាតកដែលជារឿងដ៏សំខាន់មួយ ក្នុងពុទ្ធសាសនាហីនយាន។ ព្រោះ រឿងជាតកមួយនេះ បង្ហាញពីកំណើតរបស់ព្រះពុទ្ធមួយជាតិមុនពេលបានត្រាស់ដឹងធម៌។ តួអង្គសំខាន់ៗនៃរឿងនេះ ខ្មែរបានស្គាល់ និងបានចងចាំ តែឈ្មោះជាភាសាសំស្ក្រឹត ដូចជា នាង«មេទ្រី» ដែលពួកអ្នកប្រើភាសាបាលីហៅថា «មេទី» និងនាង«ក្រឹស្ណា» ជាភាសាបាលីហៅថា «កណ្ហា»។ ឈ្មោះទាំងនេះខ្មែរ មិនដែលហៅតាម ភាសាបាលីម្តងណាឡើយ។ ដូច្នេះ រឿងរបស់ពុទ្ធសាសនាហីនយានភាសាសំស្ក្រឹត អាចត្រូវគេនាំចូលមកផ្សាយនៅកម្ពុជាតាំងពីយូរយារណាស់មកហើយ មុនពេលពុទ្ធ

---

[64] Cornelius Beach Bradley, Indications of a Consonant-Shift in Siamese since the Introduction of Alphabetical Writing. in *Transactions and Proceedings of the American Philological Association*, Vol. 38. (1907), pp.19-29; The Proximate Source of the Siamese Alphabet. in *Transactions and Proceedings of the American Philological Association*, Vol. 43. (1912), pp.23-33; and The History of the Sukhothai Letters. in *Transactions and Proceedings of the American Philological Association*, Vol. 48. (1917), pp.63-72.

សាសនាថេរវាទប្រើភាសាបាលី[65] របស់ស្រីលង្កា ចូលមកដល់ទៅទៀត។ ដោយសារខ្មែរស្គាល់រឿងជាតកនៃពុទ្ធសាសនាថេរវាទតាំងពីយូរយារមកហើយនោះ បានន័យថា ពុទ្ធសាសនានេះ ក៏អាចត្រូវគេនាំចូលមកផ្សាយក្នុងពេលជាមួយគ្នានោះដែរ នៅលើទឹកដីកម្ពុជា ដែលរួមមានទាំងភូមិភាគកណ្ដាល, ឥសាន និងខាងត្បូងនៃប្រទេសថៃសព្វថ្ងៃនេះដែរ ដែលពេលនោះជនជាតិថៃអាចគ្រាន់តែជាអន្តោប្រវេសន្តធម្មតាប៉ុណ្ណោះ។ ប្រជាជនសំខាន់ គឺពួកមន និងខ្មែរដែលជាអ្នកក្ដាប់អំណាចរដ្ឋាភិបាល។ ម្យ៉ាងទៀត ដោយសារពេលនោះ វប្បធម៌ប្រើភាសាសំស្ក្រឹតមានការនិយមខ្លាំងជាង នាំឱ្យគេហៅឈ្មោះតួអង្គក្នុងរឿងជាតកភាសាបាលីទាំងនោះ ទៅជាភាសាសំស្ក្រឹតដែរ។ ចំណុចនេះមានភស្តុតាងច្រើនណាស់តាមរយៈសិលាចារឹកនៅសម័យក្រោយអង្គរ ពេលដែលខ្មែរនាំគ្នារៀនតែធម៌អាចំតាមគម្ពីរព្រះត្រៃបិដកភាសាបាលីរាប់រយឆ្នាំទៅហើយ ក៏អ្នកស្រុកនៅតែប្រើវាក្យស័ព្ទសំស្ក្រឹតធម្មតាក្នុងការសរសេរអត្ថបទទាំងឡាយដែរ (ក្រសេម ១៩៨៤)។ ម្ល៉ោះហើយ ភស្តុតាងខាងលើនេះមិនអាចឆ្លុះបញ្ចាំងថា ជនជាតិថៃបានស្គាល់ និងប្រកាន់យកទ្រឹស្ដីថេរវាទមុនជនជាតិខ្មែរដែរ។

តាមរយៈសិលាចារឹកភាសា និងអក្សរខ្មែរមួយផ្ទាំងធំមានកាលបរិច្ឆេទនៅឆ្នាំ១៣៦១នៃគ.ស., រកឃើញនៅក្នុងតំបន់ព្រៃស្វាយ នៃអតីតទីក្រុងសុខោទ័យរបស់ប្រទេសថៃសព្វថ្ងៃ ជាសិលាចារឹករបស់ព្រះរាជាសុខោទ័យមួយអង្គនាម ស្រីសូរ្យពង្ស រាមមហាធម្មរាជាធិរាជ។ ខ្លឹមសារនៃចារឹកនេះ បានឱ្យដឹងថា ស្ដេចអង្គនេះបានប្រើរាជបណ្ឌិតរបស់ខ្លួនឱ្យ "ទៅអញ្ជើញមហាសាមីសង្ឃរាជដ៏មានសីល រៀនចប់ព្រះត្រៃបិដកដែលសឹងនៅលង្កាទ្វីប និងជាអ្នកមានសីលាចារ្យដូចជាក្សីណាស្រពផង កាលពីព្រេងនាយ"។ សម្ដេចព្រះមហាថេរ និងភិក្ខុសង្ឃជាច្រើនអង្គ ដែលគេអញ្ជើញបានមកពីស្រីលង្កាពេលនោះ បានក្លាយជាកម្លាំងដ៏សំខាន់ក្នុងការផ្សព្វផ្សាយធម៌ពុទ្ធសាសនាថេរវាទនៅសុខោទ័យ ហើយដែលសូម្បីព្រះរាជាអង្គនោះ ក៏បានស្ម័គ្រចិត្តជ្រះថ្លាបួសមួយរយៈក្រោមការបំបួសរបស់ព្រះមហាស្វាមីសង្ឃរាជអង្គនោះដែរ (សឺដេស 1924; Pou 1978)។ ដូច្នេះបានន័យថា មកដល់សតវត្សរ៍ទី១៤ ពុទ្ធសាសនាថេរវាទរបស់ស្រីលង្កាបានប្រតិស្ឋានយ៉ាងមាំទៅហើយ នៅប្រទេសសៀម–សុខោទ័យ។

ក៏ប៉ុន្តែ បើយោងតាមភស្តុតាងសិលាចារឹកភាសាបាលីនៅកម្ពុជា នាមតួអង្គមួយចំនួនក្នុងរឿងទសជាតក និងគម្ពីរពង្សាវតារនៃប្រទេសលាវ ពុទ្ធសាសនាហីនយាន ឬថេរវាទ គួរតែចូលមកដល់ប្រទេសកម្ពុជា តាំងពីយូរយារណាស់មកហើយ ដែលយ៉ាងហោចណាស់ ក៏ចាប់តាំងពីសតវត្សរ៍ទី៦ដែរ។ សិលាចារឹកតាព្រហ្មK. 40 របស់ព្រះបាទរុទ្រវម៌្ម នៅសតវត្សរ៍ទី៦ បង្ហាញពីវត្តមានពុទ្ធសាសនាហីនយាន ដោយអត្ថបទជាភាសាសំស្ក្រឹតនោះចាប់ផ្ដើមឡើងដោយបទនមស្សការ ចំពោះព្រះជិនស្រី ព្រះធម៌ និងព្រះសង្ឃ។ នៅសតវត្សរ៍ទី៧ សិលាចារឹកវត្តព្រៃវៀរ K. 49 បានបង្ហាញពីវត្តមានព្រះសង្ឃពុទ្ធសាសនាពីព្រះអង្គដែលជាប់ខ្សែរាជវង្សព្រះបាទជយវម៌្មទី១ បានកសាងមូលនិធិសម្រាប់ព្រះមួយកន្លែង។ ចំណែកចារឹកភាសាបាលីយ៉ាងខ្លីមួយ K. 820 នៅសតវត្សរ៍ទី៧ ចារឹកលើខ្នងព្រះពុទ្ធរូបមួយសម័យមុនអង្គរ ដែលគេរកឃើញនៅលើទួលព្រះធាតុ នៅវលាំងចក ខេត្តកំពង់ស្ពឺ បង្ហាញពីការរំឭកដល់ទ្រឹស្ដីរបស់ព្រះតថាគត(ព្រះពុទ្ធ)ដែលជាមហាបុព្វបុរស បានសម្ដែងអំពីលក្ខខណ្ឌធម៌ ដែលផ្ដល់ឱ្យនូវ "ហេតុ" និងដូចគ្នានេះដែរ ចំពោះ "និរោធ" (សឺដេស 1964: 108)។ នេះជាសញ្ញានៃចំណេះដឹងខាងទ្រឹស្ដីនៅក្នុងគម្ពីរដើមរបស់ព្រះពុទ្ធរបស់អ្នកស្រុកនៅទីនោះ។ បន្ទាប់មកទៀត មានសិលាចារឹកភាសាបាលីថ្មីមួយផ្ទាំងទៀត ដែលមានវាក្យស័ព្ទចាប់ផ្ដើមដូចគ្នានឹងចារឹកទួលព្រះធាតុដែរ ត្រូវបានគេរកឃើញនៅតំបន់អង្គបុរី នៃខេត្តតាកែវ (ត្រាណេ ២០០៣)។ តែបើពិនិត្យលើលក្ខណៈរូបរាងនៃតួអក្សរសិលាចារឹករកឃើញថ្មីនេះ គួរតែមានអាយុកាលនៅសតវត្សរ៍ទី៨នៃគ.ស។

[65] គម្ពីរពុទ្ធសាសនាថេរវាទ ជាភាសាបាលី ទើបតែបកប្រែដោយ អដ្ឋកថាចារ្យដ៏ល្បីល្បាញមួយរូបនាម ព្រះពុទ្ធឃោសាចារ្យ នៅអំឡុងសតវត្សរ៍ទី៥ប៉ុណ្ណោះ នៅស្រីលង្កា។ ចំណែកគម្ពីរព្រះត្រៃបិដកដើម ជាភាសាសីហឡ: ត្រូវគេដុតបំផ្លាញចោល។

នៅគោកស្វាយចេក ឯខេត្តសៀមរាបវិញ មានសិលាចារឹកភាសាបាលី និងភាសាខ្មែរមួយទៀត កាលបរិច្ឆេទឆ្នាំ ១៣០៩ ដែលចាប់ផ្ដើមដោយបទនមស្ការចំពោះព្រះជិន(ស្រី),ព្រះធម៌ និងព្រះអរិយសង្ឃ បានឱ្យដឹងថា នៅពេលព្រះបាទស្រីស្រីន្ទ្រវរ្ម័ទេព ដាក់រាជ្យឱ្យទៅយុវរាជ រួចទ្រង់បានយាងទៅបួសនៅក្នុងព្រៃ។ នៅឆ្នាំ១៣០៩ ដដែលនេះ[66] ព្រះអង្គបញ្ជាឱ្យក្សត្រីមួយអង្គ នាមកម្រតេងអញស្រីមាលិនិរតនលក្ស្មី សាងវិហារមួយ ដាក់តម្កល់ព្រះពុទ្ធរូបមួយអង្គ នាម កម្រតេងអញស្រីស្រីន្ទ្រមហាទេវ ដើម្បីប្រគេនចំពោះ មហាស្វាមីថេរ នាមស្រីស្រីន្ទ្រមៅលីទេវៈធ្វើជាទីសំណាក់អាស្រ័យបម្រើដល់ព្រះភិក្ខុសង្ឃទាំងឡាយជាព្រះគម្ដែងនៃយើង(សឺដេស 1989: 286-287)។ បើតាមលោកស្រីបណ្ឌិត ពៅ សាវស(១៩៨៩, ទំព័រ១២១)ថា "សិលាចារឹកភាសាបាលីមួយនេះបានបញ្ជាក់អំពីទ្រឹស្ដីនៃពុទ្ធសាសនាថេរវាទ"។

កាន់តែច្បាស់ជាងនេះ នៅមានសិលាចារឹកប្រាសាទកំបុត(K. 144)មួយទៀត ដែលជារបស់ព្រះរាជគ្រូនៃព្រះបាទ ស្រីន្ទ្រជយវរ្ម័ សោយរាជ្យនៅរាជធានីយសោធរបុរៈ នាដើមសតវត្សរ៍ទី១៤ បានឱ្យដឹងមិនមែនត្រឹមតែវត្តមានទេ តែអំពីខ្លឹមសារនៃធម៌ពុទ្ធសាសនាថេរវាទផងដែរ។ ដោយបង្ហាញអំពីវាលវដ្ដសង្សារនៃជីវិតសត្វលោក ដែលត្រូវប្រឈមមុខនឹងរូបំ, ទុក្ខំ, អនិច្ចំ និងអនត្តានៃធម៌ត្រៃលក្ខណ៍មានជាតិ, ជរា-ព្យាធិ និងមរណៈ, និងត្រៃសរណគមន៍នៃពុទ្ធសាសនា មានព្រះពុទ្ធ, ព្រះធម៌ និងព្រះសង្ឃ សម្រាប់ជាទីពឹង និងជាទីរឭក (Pou 1981)។

រីឯប្រភពឯកសារចេញពីប្រទេសឡាវពីរ, ទី១ តាមរយៈពង្សាវតារនិយាយអំពីព្រះពុទ្ធរូបទ្រង់ឈរធ្វើអំពីមាសហៅថា "ព្រះបង" ដែលជាប់ជាឈ្មោះទីក្រុង"ហ្លួងព្រះបាង"សព្វថ្ងៃ។ ព្រះបង ត្រូវបានស្មិតដោយលោកសង្ឃស្រីលង្កាមួយអង្គនាម ចុល្លនាគ នៅឆ្នាំ៨៧៤គ.ស.។ ស្ដេចនៃប្រទេសស្រីលង្កាបានថ្វាយព្រះពុទ្ធរូបដ៏មានតម្លៃនេះមកស្ដេចខ្មែរតាំងពីឆ្នាំ១០៥៦។ ព្រះពុទ្ធរូបព្រះបង ជាវត្ថុពិសិដ្ឋមួយ ដែលគេដឹងថា បានបញ្ចុះព្រះសរីរិកធាតុប្រាំដុំនៅក្នុងនោះ។ នេះជាភស្ដុតាងនៃទំនាក់ទំនងរវាងប្រទេសខ្មែរ-ស្រីលង្កាលើកដំបូងបំផុត នៅសតវត្សរ៍ទី១១។ ចំណែក ភស្ដុតាងនៃទំនាក់ទំនងនៅលើកទី២ មានដំណាលពីប្រតិភូខ្មែរមួយក្រុមទៅកាន់ប្រទេសស្រីលង្កា ដែលដឹកនាំដោយព្រះសង្ឃនាមតាមលិន្ទ ដែលគេសន្និដ្ឋានថា ប្រហែលជាបុត្រាមួយអង្គរបស់ព្រះបាទជ័យវរ្ម័ទី៧។ ក្រោយពីបានសិក្សាព្រះត្រៃបិតកនៅលង្កាទ្វីបបានសម្រេច គណៈប្រតិភូនេះបាននាំទាំងគម្ពីរនោះត្រឡប់មកស្រុកវិញ ដោយធ្វើដំណើរកាត់តាមភូមា ហើយពេលនោះ បានជួយបង្កើតគណៈសង្ឃពុទ្ធសាសនាមួយក្រុមនៅប្រទេសនេះទៀតផង។

សៀវភៅប្រវត្តិសាស្ត្រឡាវ របស់លោក វីរវង្ស មហាសីល(១៩៥៩)បានបញ្ជាក់ដែរថា រដ្ឋបុរសដែលជាស្ថាបនិករដ្ឋឡាវរួបរួមដំបូងគេ នាមព្រះចៅហ្វាងុម ជាកូនប្រសាររបស់ស្ដេចខ្មែរនៅទីក្រុងអង្គរ។ នៅឆ្នាំ១៣៥៦ បន្ទាប់ពីព្រះអង្គដណ្ដើមយកមួងវៀងច័ន្ទ និងដាក់អធិរាជភាពលើសុខោទ័យ ទ្រង់បានប្រារព្ធពិធីជប់លៀងកងទ័ពយ៉ាងអធិកអធម អស់រយៈពេល៧យប់៧ថ្ងៃ។ ចំណែក ព្រះអគ្គមហេសីរបស់ទ្រង់ព្រះនាមកែវកន្យា(ឬកែវកេងយា) ដោយមើលឃើញថា ពួកកងទ័ពលារជឿលើព្រលឹងខ្មោចអារក្សអ្នកតា សែនព្រេនព្រលឹងខ្មោច។ ការកាប់សម្លាប់សត្វសម្រាប់ជប់លៀង និងយកទៅបូជា មានលក្ខណៈឃោរឃៅគួរឱ្យរន្ធត់ ទើបសម្រេច សុំយោបល់ឯកភាពពីព្រះចៅ ហ្វាងុម ជាព្រះស្វាមី ដើម្បីផ្ញើលិខិតទូលសុំព្រះរាជាខ្មែរជាព្រះបិតា និងជាបិតាក្មេកនៅរាជធានីអង្គរ ឱ្យចាត់បញ្ជូនព្រះសង្ឃជាបេសកទូតផ្សាយពុទ្ធសាសនាថេរវាទចូលទៅក្នុងស្រុកលាវ។ ព្រះរាជាខ្មែរបានយល់ព្រមបញ្ជូនគណៈប្រតិភូបេសកទូតមួយក្រុមធំឱ្យទៅកាន់រាជាណាចក្រឡាវ តាមសេចក្ដីស្នើ (LeClère 2005: 255) ដោយមាន

[66] កាលបរិច្ឆេទនៅក្នុងសិលាចារឹកប្រាប់ថា នៅឆ្នាំ១២៣១សកៈ តែបើគិតជាឆ្នាំសុរិយគតិនៃគ.ស. គឺនៅឆ្នាំ១៣០៩ដដែល។

ព្រះមហាបស្ន័ន ជាជនជាតិខ្មែរ និងអតីតគ្រូរបស់ព្រះចៅហ៊្វាងុមនៅស្រុកខ្មែរតាំងពីវ័យកុមារភាព, មានមហាថេរជនជាតិស្រីលង្កាបីអង្គទៀត ដែលកំពុងបំពេញកិច្ចការជាអ្នកផ្សាយសាសនានៅប្រទេសខ្មែរស្រាប់ គឺព្រះសង្ឃពីរអង្គជាបងប្អូនបង្កើតនឹងគ្នាមហាទេពលង្កាថៅ និងព្រះមហាទេពលង្កា, និងមហានន្ទិបញ្ញាថៅ(តាមសិលាចារឹកវត្តកែវនៅឆ្នាំ១៦០២) និងថែមព្រះសង្ឃខ្មែរ២០អង្គ រួមជាមួយអ្នកជំនាញឯកទេសបីរូបផ្សេងទៀត មាននាមនរសិង្ហ, នរាយ និងនរទេស។ ក្រៅពីប្រតិភូ នៅមានជំនូនវត្ថុសំខាន់ពីរមុខទៀត គឺគម្ពីរព្រះត្រៃបិតក និងព្រះពុទ្ធរូបធ្វើពីមាសឈ្មោះ ”ព្រះបង”(Goonatilake 1996)ដែលគេជឿថា ដោយសារវត្ថុមានរបស់ព្រះបងនេះឯង ទើបអតីតរាជធានី”មួងស្វា” របស់ឡាវត្រូវដូរមកជា”ហ្លួងព្រះបង ឬហ្លួងព្រះបាង”វិញ។ នេះជាសក្ខីភាពសំខាន់ទី២បញ្ជាក់អំពីវត្តមានយ៉ាងចំណាស់នៃពុទ្ធសាសនាថេរវាទនៅកម្ពុជានាស.វ.ទី១៤។

ម្ល៉ោះហើយ បើតាមភស្តុតាង ដូចបានបង្ហាញជាបន្តបន្ទាប់មកនេះ ពុទ្ធសាសនា ថេរវាទគួរតែចូលមកកម្ពុជាមុនប្រទេសសុខោទ័យ[67] យ៉ាងហោចណាស់ ក្នុងរយៈពេលមួយសតវត្សរ៍មុន។ គ្រាន់តែថាកម្ពុជាមិនមែនជាកន្លែងសំណាក់នៃមជ្ឈមណ្ឌលធំខាងវិជ្ជាពហុសូតផ្នែកពុទ្ធសាសនាភាសាបាលីឡើយ។ ផ្ទុយទៅវិញ តួនាទីនេះ គេឃើញភស្តុតាងថា ស្ថិតនៅស្រុកភូមា, សុខោទ័យ និងលានជាង[68]ឯណោះទេដែលជាកន្លែងពុទ្ធសាសនាថេរវាទរបស់ស្រីលង្កា មានការរីកចម្រើនថ្កុំថ្កើងរុងរឿងជាងគេ(Pou., *op. cit.*) ចាប់ពីសតវត្សរ៍ទី១៥រហូតមក លើកលែងតែប្រទេសលាវចេញ។

## 7. រចនាសម្ព័ន្ធ និងច្បាប់ព្រះសង្ឃ

នៅក្នុងប្រទេសកម្ពុជា មុនរាជ្យព្រះបាទអង្គដួង ព្រះសង្ឃទាំងអស់ស្ថិតនៅក្រោមអធិបតីនៃកំពូលមហាសង្ឃថេរមួយអង្គដែលមានបរមនាមបញ្ញត្តិថា "សម្តេចព្រះសុគន្ធាធិបតីសិរីសង្ឃនាយក ឬជាសម្តេចព្រះមហាសង្ឃរាជ"តែមួយអង្គគត់។ បន្ទាប់មក មានសម្តេចព្រះមហាសង្ឃរាជជាច្រើនអង្គជារាជាគណៈ ដែលគ្រងឋានន្តរនាមដូចៗគ្នាតែនាមបញ្ញត្តិផ្សេងៗគ្នា និងព្រះសង្ឃរាជ[69]ដែលជាចៅអធិការវត្តនីមួយៗ( Pou 1989: 41 )។

នៅមុនរជ្ជកាលរបស់ព្រះបាទ នរោត្តម ព្រះពុទ្ធសាសនាគ្មានបែងចែកជានិកាយទេ តែការនិយមប្រតិបត្តិព្រះបរិយត្តធម៌ គឺប្រព្រឹត្តិតាមមាគ៌ាពីរយ៉ាងសំខាន់គឺ ព្រះសង្ឃដែលគង់នៅក្នុងព្រៃឆ្ងាយដាច់ស្រយាលពីភូមិស្រុក (អារញ្ញវាសី)បែបជាលោកធុតុង្គ ឬតាបសឥសី ដើម្បីធ្វើសមាធិកម្មដ្ឋានចម្រើនប្រាជ្ញា តាមមាគ៌ា"វិបស្សនាធុរៈ" និងព្រះសង្ឃទាំងគង់នៅតាមវត្តក្នុងស្រុក ឬសហគមន៍មនុស្សជម្មតា(គាមវាសី) ដើម្បីសិក្សាព្រះធម៌នៃពុទ្ធសាសនា តាមមាគ៌ា"គន្ថធុរៈ" ( Eng 1991; Sam 1990 )។

រចនាសម្ព័ន្ធសង្ឃជាន់ខ្ពស់នៅចន្លោះសម័យនេះ មានលក្ខណៈស្មុគស្មាញ ពិបាកយល់ ដោយសារព្រះសង្ឃដែលមានឋានន្តរៈ"សម្តេចព្រះមហាសង្ឃរាជ" ឬ"សម្តេចព្រះសង្ឃរាជ"មានចំនួនច្រើនដូចជា ៖

---

[67] សុខោទ័យ ជាឈ្មោះទីក្រុង ឬ ប្រទេស ដែលជាមូលដ្ឋានដើមនៃប្រទេសថៃសព្វថ្ងៃ។

[68] ក្នុងឯកសារខ្មែរសម័យក្រោយអង្គរ ហៅប្រទេសឡាវថា 'លានជាង ឬ លានដ្ឋាង" បែបនេះ។

[69] ពាក្យ'សង្ឃរាជ"នេះ ពីបុរាណមិនមែនសំដៅចំពោះព្រះសង្ឃជាអធិបតីនៃសង្ឃទាំងឡាយនៅក្នុងប្រទេសនោះទេ តែជាអធិបតីនៃព្រះសង្ឃមួយក្រុម។ ពាក្យនេះហើយ ក្លាយមកជា'សង្ក្រាជ-សង្ក្រាជ"វត្ត ដែលអ្នកស្រុកនិយមប្រើសម្រាប់ហៅព្រះសង្ឃមួយអង្គជា'មេវត្ត"( Sam 1990 )នីមួយៗរហូតមកដល់សព្វថ្ងៃនេះ។

សម្តេចព្រះសុគន្ធាធិបតី មហាសង្ឃរាជា សង្ឃនាយក (១៥៣៩គ.ស.ដល់[70] សតវត្សរ៍ទី២១)
សម្តេចព្រះនាគ្គរាម្មាគុន្ធាធីប្តី មហាសង្ឃរាជ (១៥៣៧គ.ស. ទំនឹមពីបូរាណ)
សម្តេចព្រះធម្មលិខិត មហាសង្ឃរាជ (១៥៣៧គ.ស.ទំនឹមពីបូរាណ, ១៥៨៧គ.ស.,K.27)
សម្តេចព្រះពោធិវាំង មហាសង្ឃរាជ (១៥៣៧គ.ស. ទំនឹមពីបូរាណ)
សម្តេចព្រះវ័នរត្ន មហាសង្ឃរាជ (១៥៣៧គ.ស. ទំនឹមពីបូរាណ)
សម្តេចព្រះមហាព្រហ្ម មហាសង្ឃរាជ (១៥៣៧គ.ស. ទំនឹមពីបូរាណ)
សម្តេចព្រះពោធិញាណ មហាសង្ឃរាជ (១៦២៧គ.ស. K. 75)
សម្តេចព្រះរាជសុមង្គល មហាសង្ឃរាជបពិត្រ (១៦៨៣គ.ស. សនវ លេខ២៨)
សម្តេចព្រះរាជសីលាចារ្យ មហាសង្ឃរាជបពិត្រ (១៦៨៣គ.ស. សនវ លេខ២៨)
សម្តេចព្រះមហាបទុម មហាសង្ឃរាជបពិត្រ (១៦៨៣គ.ស. សនវ លេខ២៨)
សម្តេចព្រះជោត្តិទេវា មហាសង្ឃរាជបពិត្រ (សនវ លេខ៣៦)
សម្តេចព្រះវរជេដ្ឋ មហាសង្ឃរាជបពិត្រ (១៧០១គ.ស. សនវ លេខ៣៧)
សម្តេចព្រះជេដ្ឋសត្ថា មហាសង្ឃរាជបពិត្រ (១៧០១គ.ស. សនវ លេខ៣៧)
សម្តេចព្រះរាជសត្ថា មហាសង្ឃរាជបពិត្រ (១៧០១គ.ស. សនវ លេខ៣៧)
សម្តេចព្រះឥន្ទទិព្វចក្ខុ មហាសង្ឃរាជបពិត្រ (១៧០១គ.ស. សនវ លេខ៣៧)
សម្តេចព្រះបញ្ញាពិទូរ មហាសង្ឃរាជបពិត្រ (១៧០១គ.ស. សនវ លេខ៣៧)
សម្តេចព្រះធម្មសីលាបារមី មហាសង្ឃរាជបពិត្រ (១៧០១គ.ស. សនវ លេខ៣៧)
សម្តេចព្រះសត្តវង្ស មហាសង្ឃរាជបពិត្រ (១៧០១គ.ស. សនវ លេខ៣៧)
សម្តេចព្រះពុទ្ធវង្សា មហាសង្ឃរាជបពិត្រ (១៧០១គ.ស. សនវ លេខ៣៧)

នៅក្នុងចំណោមសម្តេចសង្ឃរាជទាំងអស់នេះ មិនឃើញមាននាម"ព្រះមង្គលទេព្វាចារ្យ"ដែលព្រះអង្គដួង លើកជាដើមក្រសួងព្រះសង្ឃនៅអំឡុងទសវត្សរ៍១៩៤០នោះឡើយ(Eng 1990: 1069)។

បើតាមសិលាចារឹកនគរវត្តលេខ៣៤លោក ជ័យនន្ទ កាលនៅគ្រងតំណែងជាឧកញ៉ាយមរាជ ក្នុងរជ្ជកាលព្រះបាទជ័យជេដ្ឋាទី៣ នាឆ្នាំ១៦៩៧[71] បានឱ្យដឹងថា "សម្តេចព្រះ...មហាសង្ឃរាជ(បពិត្រ) "ទាំងអស់នៅពេលនោះមានចំនួន១៦អង្គ ហើយលោកបាននិមន្តទាំង១៦អង្គនោះទៅធ្វើបុណ្យនៅប្រាសាទអង្គរវត្ត តាមព្រះរាជបញ្ជារបស់ព្រះរាជា ឱ្យមកសាងត្រីសូល៍ និងគាងឃ្វាយថ្វាយព្រះស្រីរតនត្រៃ។ លោកឧកញ៉ាបានរៀបចំរណ្តាប់ដង្វាយក្នុងមួយមុខចំនួន១៦ដែរ សម្រាប់ថ្វាយដល់ព្រះមហាសង្ឃរាជទាំង១៦អង្គនោះ (Krassem 1984: 84)។

---

[70] នៅខាងដើមរជ្ជកាលព្រះបាទអង្គឌួង គោរម្យងារនេះ ជាអធិបតីគណៈសង្ឃក្នុងកម្ពុជា ទ្រទ្រង់សង្ឃព្រះរាជាគណៈទាំង៤ សម្រាប់ ជាធំខាងវិបស្សនាធុរៈ ។

[71] តាមសិលាចារឹកនគរវត្ត លេខ៣៤ ថា កាលលោកឧកញ៉ាយមរាជ ប្តីជំទាវទេពសុពណ៌ មកលើកត្រីសូល៍ គាងឃ្វាយនោះ នៅអង្គរវត្ត ស្ថិតនៅក្នុងឆ្នាំ១៦១៨ សកៈ ខែផល្គុណ ត្រូវនឹងឆ្នាំជូត។

បន្ទាប់ពីសម្តេចមហាសង្ឃរាជដ៏ច្រើនអង្គនោះ នៅមានព្រះសង្ឃ ដែលគ្រងឋានៈជា"សម្តេច...បពិត្រ"ជាច្រើនអង្គទៀត។ ព្រះសង្ឃដែលគ្រងឋានន្តរនាម"សម្តេច" ឬ "អ្នកសម្តេច"ទាំងអស់នេះ ទំនងភាគច្រើន មានមុខនាទីត្រឹមជា"ចៅអធិការវត្ត" និងជា"ព្រះមហាថេរ"[72]ប៉ុណ្ណោះ។

ថ្វីបើព្រះសង្ឃពុទ្ធសាសនានៅកម្ពុជា ជាស្រទាប់ជនជាទីគោរពសក្ការបូជាស្មើព្រះមហាក្សត្រ និងរាជវង្សានុវង្ស តែព្រះសង្ឃទាំងអស់ ស្ថិតនៅក្រោមច្បាប់ពិសេសដោយឡែកមួយសម្រាប់ព្រះសង្ឃ។ តាមក្បួនទំនឹមពីបុរាណ ដែលរៀបរៀងឡើងវិញដោយព្រះបាទជ័យជេដ្ឋាទី៣អង្គសូ នាឆ្នាំ១៦៩២[73] មានការនិមន្តចូលរួមពិភាក្សាផ្ទៀងផ្ទាត់ពីសម្តេចព្រះសុគន្ធាធិបតី ជាសង្ឃនាយក និងព្រះរាជាគណៈសង្ឃជាច្រើនអង្គផងនោះ ហាក់ដូចបញ្ជាក់ឱ្យដឹងថា ច្បាប់សម្រាប់គ្រប់គ្រងព្រះសង្ឃពុទ្ធសាសនានៃប្រទេសកម្ពុជា ត្រូវគេរៀបចំឡើងតាំងពីយូរយារណាស់មកហើយ។ តាមប្រភពពត៌មានពង្សាវតារ បានឱ្យដឹងថា ក្នុងចំណោមច្បាប់ចំនួន២៤ក្រម ដែលព្រះអង្គប្រកាសឱ្យប្រើ មានច្បាប់មួយសម្រាប់ព្រះសង្ឃគឺ"ក្រមរុងសង្ឃ"[74](Eng 1991: 805-6)។ នៅក្នុងរជ្ជកាលរបស់ព្រះអង្គដដែល មានច្បាប់មួយហៅក្បួន"ទំនឹមពីបូរាណ" ដែលជាឯកសារទាក់ទងនឹងកំណត់ត្រាបទពិសោធន៍នៃការជម្រះក្តីរបស់តុលាការបុរាណ។ តាមរយៈក្បួននេះ គេបានរំឭកដល់"ច្បាប់១សម្រាប់ព្រះសង្ឃ" ដែលគេបានយកមកប្រើក្នុងការកាត់ក្តីពេលនោះ ថាត្រូវបានរៀបរៀងឡើងតាំងតែពីថ្ងៃ ១៣រោជ ខែបុស្ស ឆ្នាំ១៥៣៩គ.ស. ក្នុងរជ្ជកាលព្រះបាទសម្តេចព្រះបរមរាជាធិរាជ នារាយនបូបតី[75]។ ក្នុងកំណត់ហេតុនៃការជំនុំជម្រះ លើឧប្បត្តិហេតុទំនាស់ករណីព្រហ្មទណ្ឌមួយ ដោយសារញោមព្រះសង្ឃពុទ្ធសាសនា[76]នៅក្នុងវត្តមួយ បង្កឱ្យខ្ញុំបម្រើហ្លួងម្នាក់ស្លាប់។ ព្រះរាជា ក៏បញ្ជាឱ្យមន្ត្រីជាន់ខ្ពស់មួយចំនួនដែលធ្លាប់បួសរៀន មានចំណេះដឹងធម៌អាថ៌ជ្រៅជ្រះ រួបរួមគ្នាជាមួយសម្តេចព្រះសង្ឃរាជពីរអង្គ និងសង្ឃរាជមួយចំនួនទៀត ពិចារណាករណីជម្លោះនោះ។ ក៏ប៉ុន្តែ បន្ទាប់ពីសម្រេចសេចក្តីហើយនោះ គេបានកែសម្រួលច្បាប់សម្រាប់ព្រះសង្ឃនេះឡើងវិញជាច្រើនអន្លើ ដោយការបន្ថែមបន្ទុក, ទម្ងន់ទោស និងការចាត់ចែងលើករណីពលព្រះរតនត្រ័យ និងញោមព្រះសង្ឃ។

អត្ថបទច្បាប់ក្រមរុងសង្ឃ យើងមិនទាន់រកឃើញនៅឡើយ តែមាត្រាមួយចំនួននៃច្បាប់ព្រះសង្ឃ ដែលវរជនខាងលើបានលើកយកមកពិភាក្សាផ្ទួរផ្តងរកការដាក់បន្ទុក និងកាត់ទោស ថ្វីបើមិនអាចបង្ហាញឱ្យដឹងអំពីខ្លឹមសារទាំងស្រុងនៃក្រមនោះ ក៏ប៉ុន្តែ ច្បាប់បញ្ញតិនេះ មានការសង្កត់ធ្ងន់ទៅលើវិន័យសង្ឃដែលព្រះពុទ្ធបានសម្តែងទុកក្នុងព្រះវិន័យបិដក និងការគ្រប់គ្រងសម្បត្តិរបស់ព្រះសង្ឃ និងវត្តអារាម។ ដូចជា លើមូលហេតុនាំឱ្យព្រះសង្ឃបរាជិកដែលមានចំនួន ៥ប្រការធំៗ គឺ ទី១-ការសេពសន្ទវៈ ទោះបីជាមួយស្រី ឬបុរសដែលមានភេទដូចគ្នា ក្នុងរូបភាពបី គឺតាមមាត់, ទ្វារមាស និងទ្វារជុះ។ ទី២-ការលួចទ្រព្យសម្បត្តិរបស់អ្នកដទៃ,រាជការ, វត្ត, ឬព្រះ។ ទី៣-គៃបន្លំយកទ្រព្យ

[72] សម្គាល់ព្រះសង្ឃដែលបាននៅក្នុងភាពជាអ្នកបួស កាន់សីលសិក្ខាបទក្នុងរយៈកាលមួយយូរអង្វែងលើសពី១០ឆ្នាំ និងជាអ្នកបួសដែលមានចំណេះដឹងខ្ពង់ខ្ពស់ ឬ ពហុសូត្រ ខាងផ្លូវធម៌ព្រះពុទ្ធសាសនា។

[73] បើតាមឯកសារមហាបុរសខ្មែរ រៀបរៀងដោយលោក អេង សុត, ព្រះរាជាអង្គនេះ បានប្រកាសឱ្យប្រើច្បាប់ទាំងអស់ដែលព្រះអង្គបានធ្វើវិសោធនកម្មរួច ឱ្យចូលជាធរមានចាប់ពីថ្ងៃចន្ទ បីរោចខែកត្តិក ឆ្នាំច ឆស័ក ម.ស.១៥៩៧, ព.ស.២២១៩ ដែលត្រូវនឹងគ.ស.១៦៧៦(តែលោក អេង សុត ដាក់ថាត្រូវនឹង គ.ស.១៦៧៥ ទៅវិញ)។

[74] តាមន័យអក្សរសាស្ត្រ 'ក្រមរុងសង្ឃ" មានន័យថា ច្បាប់+ឧត្តម+សង្ឃ គឺ ច្បាប់សម្រាប់ព្រះសង្ឃដ៏ឧត្តុង្គឧត្តម។

[75] ព្រះបរមនាមនេះ ដូច នារាយរាជា ដែលជាព្រះរាជាសោយរាជ្យនៅទីក្រុងចតុមុខ បន្ទាប់ពីព្រះបាទ ពញាយ៉ាត តែបើតាមកាលបរិច្ឆេទ ឆ្នាំ១៥៣៩វិញ ព្រះនាមនេះទំនងជាត្រូវនឹងព្រះបាទ'ចន្ទរាជា" ដែលជាស្ថាបនិកទីក្រុងបន្ទាយលង្វែក។

[76] ញោមព្រះសង្ឃ មានន័យសំដៅលើ ²ខ្ញុំបម្រើរបស់ព្រះសង្ឃ ដែលគង់នៅក្នុងវត្តអារាម ³

អ្នកដទៃណាក៏ដោយ,ទី៤-ការកេងយកចំណេញពីអ្នកខ្ចីប្រាក់ និងបញ្ចាំមនុស្សជាមួយខ្លួន, និងទី៥-ការរួមគំនិតពន្លូតគភ៌ដោយប្រើថ្នាំ។

ក្រោយមកនៅក្នុងរជ្ជកាលព្រះបាទហរិរក្សរាមាឥស្សរាធិបតី ព្រះអង្គដួង ឆ្នាំ១៨៥៣បានរៀបរៀងច្បាប់មួយមានចំណងជើងថា "ក្រមព្រះរាជក្រិតសំឃរី"[77] ដែលបន្ទាប់មក ព្រះបាទនរោត្តម បានប្រើឱ្យស្មៀនរាជការសរសេរចម្លងឡើងវិញ និងបោះពុម្ពផ្សាយដោយរោងពុម្ពប្រូតិចតូរ៉ានៅឆ្នាំ១៨៩១។ ច្បាប់នេះ បញ្ជាក់ពីគោលបំណងថា ចង់តម្រង់ផ្លូវអេស់គម្លែងសង្ឃ កុំធ្វើឱ្យសាបសូន្យសាសនាព្រះតថាគត ដើម្បីឱ្យសាសនានេះបានរុងរឿងថ្កើងថ្កល់ដល់៥ពាន់ព្រះវស្សា។ ត្បិតមនុស្សបុថុជ្ជន និងអាណាប្រជានុរាស្ត្រក្នុងពេលនោះ កាន់ពាក្យពិតសុច្ចរិតកាន់តែតិចទៅ, មានប្រព្រឹត្តិកន្លងនឹងច្បាប់ព្រះរាជសាសន៍, អ្នកខ្លះជេរប្រមាថឪពុកម្តាយឯង, ខ្លះរំលាយព្រះ រំលើងព្រះចេតិយ ព្រះវិហារ សីមា និងកុដិ, កាត់ដុតដកដើមព្រះស្រីរតនពោធិព្រឹក្ស, និងមានខ្លះរៀបការចងសម្ព័ន្ធនឹងគ្នា ព្រមទាំងទំនាក់ទំនងរួមរ័ក្សស្នេហាល្មើសនឹងក្រមព្រះរាជក្រឹត្យសំឃរីដែលបានហាមប្រាម។ កិច្ចការអនុវត្តច្បាប់នេះ ត្រូវប្រគល់បន្ទុកឱ្យទៅភ្នាក់ងារសំឃរី ជាអ្នកស្រង់ជីរាជការ, កាត់ទោស និងដាក់ពិន័យយកទ្រព្យសម្បត្តិជនល្មើសទុកជាដង្វាយថ្វាយដល់ព្រះមហាក្សត្រ។ ហេតុនេះហើយ ទើបច្បាប់ដែល៥១មាត្រានេះ បានដាក់បន្ទុកហាមប្រាមចំពោះអ្នករៀបមង្គលការ កុំឱ្យយកគ្នាជាប្តីប្រពន្ធបំពានលើត្រណមច្បាប់ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់វត្តអារាម។

## 8. ការកសាងវប្បធម៌សន្តិភាព ៖ ការខិតខំបង្កើតឯកភាពជាតិឡើងវិញ

ដូចបានបង្ហាញខាងលើហើយថា ប្រទេសខ្មែរនៅតែមានសមត្ថភាពរឹងមាំនៅឡើយ មកដល់ចុងសតវត្សរ៍ទី១៧ ថ្វីបើកំពុងប្រឈមមុខនឹងការគម្រាមកំហែងពីសំណាក់ក្រុងអយុធ្យា និងវ៉េ ក៏ដោយ។

ក្រោយពីព្រះបាទស្រីសុរិយោពម៌ ត្រូវស្តេចអយុធ្យាដោះលែងឱ្យមកស្រុកខ្មែរវិញតាមសំណូមពររបស់ព្រះមហាក្សត្រិយានី រាជវង្សានុវង្ស និងមន្ត្រីជាន់ខ្ពស់ខ្មែរនៅដើមសតវត្សរ៍ទី១៧ ខ្មែរបានទទួលឥទ្ធិពលវប្បធម៌សៀមយ៉ាងខ្លាំងក្លា។ មកដល់រជ្ជកាលព្រះបាទជ័យជេដ្ឋាទី២ សៀមបានលើកទ័ពជើងទឹកយ៉ាងច្រើនសន្ធាប់ ដើម្បីឈ្លានពានខ្មែរ តែត្រូវកងទ័ពខ្មែរវាយប្រហារឱ្យបាក់ទ័ពយ៉ាងអាម៉ាស។

បុត្រាពីរអង្គរបស់ព្រះមហាឧកយោរាជ ឧទយរាជា ដែលពឹងពាក់កងទ័ពយួនជួយធ្វើអន្តរាគមន៍ផ្តួលរំលំព្រះបាទរាមាធិបតីអង្គច័ន្ទ ឬព្រះរាមាចោលសាសន៍ ទោះបីទើបនឹងដណ្តើមរាជ្យអំណាចបានថ្មីៗ តែព្រះអង្គអាចវាយបកបណ្តេញកងទ័ពយួន ដែលមានបំណងរឹបយកស្រុកខ្មែរតែម្តងទាំងនោះឱ្យបរាជ័យបានដែរ។ ព្រោះបន្ទាប់ពីជួយផ្តួលរំលំស្តេចចាស់បានហើយ មេទ័ពយួនយល់ថា ស្តេចថ្មីមិនទាន់មានកម្លាំងរឹងមាំអាចតដៃ ឬទប់ទល់ជាមួយខ្លួនបាន។ ប៉ុន្តែការពិតផ្ទុយស្រឡះ ព្រះអង្គម្ចាស់ទាំងពីរអង្គបានបង្ក្រាបកងទ័ពយួនឱ្យបរាជ័យយ៉ាងទន់ហន់។

នៅចុងសតវត្សរ៍ទី១៧ ជម្លោះរាជវង្សានុវង្ស បានបន្តកើតឡើងទៀត ដោយការសងសឹកគ្នា និងយល់ច្រឡំគ្នារវាងរាជវង្សានុវង្ស។

---

[77] ក្រមនេះបកប្រែជាភាសាបារាំងថា Loi sur les outrages aux moeurs at aux coutumes ។ ចំណែកនៅក្នុងសេចក្តីផ្តើមបានបញ្ជាក់ឱ្យដឹងថា ច្បាប់«សំឃរី» មានខ្លឹមសារទាក់ទងនឹង ព្រះសង្ឃពុទ្ធសាសនា និងមានភ្នាក់ងាររាជការទទួលខុសត្រូវអនុវត្តន៍ច្បាប់ ក្នុងករណីមានការទាក់ទងនឹងព្រះសង្ឃ។

ព្រះបាទជ័យជេដ្ឋាអង្គសូរ បានគ្រប់គ្រងរាជកិច្ចតស៊ូប្រឆាំងបក្សម្ខាងទៀត ដែលគាំទ្រដោយកងទ័ពយួន។ ក្រោយពីពួកនោះបរាជ័យ ព្រះបាទជ័យជេដ្ឋា បានដាក់រាជ្យប្រគល់ឱ្យក្មួយនាមរាមាធិបតីអង្គយ៉ង ដែលជារាជបុត្រ របស់ស្ដេចមុនព្រះកែវហ្វាអង្គជី(១៦៧២-១៦៧៦គ.ស.)។ បន្ទាប់ពីព្រះរាជាអង្គនេះចូលទិវង្គតដោយរោគាព្យាធិ ព្រះជ័យជេដ្ឋាអង្គសូរ បានលើកគ្រឿងបណ្ណាការជាច្រើន ទៅថ្វាយស្ដេចយួនដើម្បីសុំក្មួយជីដូនមួយ អង្គអិមជាកូន របស់ឧភយោរាជអង្គនន់ នាមអង្គអិម ដែលបាននិរទេសខ្លួនទៅជ្រកកោននៅស្រុកយួន បន្ទាប់ពីមេទ័ពយួន ព្យាយាមដណ្ដើមអំណាចថ្វាយមិនបានសម្រេចនោះ ត្រឡប់មកខ្មែរវិញ ប្រយោជន៍កុំឱ្យស្ដេចយួនទុកប្រើប្រាស់ក្នុង ការគម្រាមកំហែងរាជវាំងឧត្ដុង្គតទៅថ្ងៃមុខទៀត។ ស្ដេចយួនបានបញ្ចុះបញ្ចូលទ្រង់កុំឱ្យយាងត្រឡប់ដែរ តែអង្គអិម ដោយបានជ្រាបពីគុណសម្បត្តិរបស់ជ័យជេដ្ឋាអង្គសូរ ក៏បានយល់ព្រមយាងត្រឡប់វិញជាមួយរាជទូតខ្មែរ និងពល ទាហានយួនជាច្រើនរយនាក់។

ការបង្រួបបង្រួមជាតិនេះបានសម្រេច ស្ដេចបានលើកអង្គអិមឱ្យធ្វើជាព្រះកែវហ្វា ងារជាឧបរាជព្រមទាំង ប្រទានរាជបុត្រីធ្វើជាមហេសី ដើម្បីភ្ជាប់សាច់ឈាមគ្នា និងលួងចិត្តផង។ ក្រោយមកព្រះអង្គថែមទាំងបានលើកឱ្យ ឡើងសោយរាជ្យអស់មួយរយៈពេលទៀតផង។

## 9. ស្នាដៃអក្សរសិល្ប៍ សាស្ត្រាល្បែង

នៅសម័យក្រោយអង្គរ ក្រៅពីច្បាប់នីតិក្រមសម្រាប់រដ្ឋាភិបាល នៅមានច្បាប់សុភាវធម៌ជាច្រើនទៀត ដែល អ្នកប្រាជ្ញពុទ្ធសាសនានៅចន្លោះសតវត្សរ៍ទី១៤-១៩ បានតាក់តែង និពន្ធសម្រាប់អប់រំសីលធម៌ និងវឌ្ឍនធម៌នៅក្នុង សង្គមខ្មែរ។ ច្បាប់ទាំងអស់នោះ ភាគច្រើននៅមានតម្លៃអប់រំរហូតដល់សព្វថ្ងៃ។ ក្រៅពីកម្រងស្នាដៃកំណាព្យអប់រំ ទាំងនោះ នៅមានស្នាដៃអក្សរសិល្ប៍ ដែលគេហៅថា សាស្ត្រាល្បែងជាច្រើនរឿងទៀត។

ដូចជា កំណាព្យល្បើកអង្គរវត្ត តែងដោយរាជវង្សានុវង្សមួយរូបនាមអ្នកប៉ង ដែលរៀបរាប់អំពីក្បាច់រចនានៃ ប្រាសាទអង្គរវត្ត និងរូបចម្លាក់នៅលើជញ្ជាំងថែវ ដែលនិទានអំពីរឿងរាមកេរ្តិ៍។

កំណាព្យរបស់ព្រះរាជសម្ភារ ពញាតូ ដែលពោរពេញដោយពាក្យទូន្មានប្រៀនប្រដៅមនុស្ស កុំឱ្យឆ្កួតនឹង ស្រី, ស្រា និងល្បែងពាលា។ នៅឱកាសចុងក្រោយ ទ្រង់តែងកំណាព្យដេរ"អាបារាំងអប្បលក្ខណ៍ វាតាមបាញ់អ្នក ព្រះរាជសម្ភារ ឡើងលើចុងត្នោត ពុំកោតចេស្ដា អ្នកលើកហត្ថា រារាំងឃាត់ទុក"។

កំណាព្យច្បាប់រាជនេតិ៍ ឬ ត្រីនេត្រ សម្រាប់ប្រៀនប្រដៅអ្នកដឹកនាំឱ្យចេះគិតគូរ ពិចារណាឱ្យបានវែងឆ្ងាយ មុននឹងសម្រេចចិត្តធ្វើអ្វីមួយ ត្រូវគិតប្រមាណអំពីផលប្រយោជន៍រាស្ត្រទូទៅសិន។

កំណាព្យច្បាប់ស្រី ច្បាប់ប្រុស សម្រាប់ប្រដៅមនុស្សទាំងប្រុសស្រី ឱ្យស្គាល់ភារកិច្ច កាតព្វកិច្ចរបស់ខ្លួន និង ចេះស្គាល់ទុក្ខធុរៈគ្នា ដើម្បីធ្វើជាបុរស-ស្ត្រីល្អ, ប្ដី-ប្រពន្ធល្អ, ម្ដាយ-ឪពុកល្អ និងជីដូន-ជីតាល្អ ជាគំរូដល់បច្ឆាជន របស់ខ្លួន។

កំណាព្យរបស់ជ័យនន្ទនៅឆ្នាំ១៧០១គ.ស.នៅប្រាសាទអង្គរវត្ត ដែលបង្ហាញអំពីទុក្ខលោកនៃការព្រាត់ ប្រាសប្រពន្ធកូន និងការបួងសួងអធិដ្ឋានសម្រាប់អនាគតជាតិ កុំឱ្យជួបកម្មព្រាត់ប្រាសនិរាសគ្នាទៀត។ លើសនេះ កំណាព្យបង្ហាញឱ្យដឹងថា ជ័យនន្ទគឺជាអតីតចៅហ្វាយខេត្ត និងជារដ្ឋមន្ត្រី(សេនាបតី)ម្នាក់ នៅក្នុងរាជការ បានធ្វើ បុណ្យសាងចេតិយថ្មបាយក្រៀមមួយនៅទៀបជ្រុងខាងកើតនៃប្រាសាទអង្គរវត្ត ដើម្បីដាក់ធាតុប្រពន្ធកូនលោក និង

សាងព្រះពុទ្ធរូបបាក់បែកនៅព្រះពិស្ណុលោកឱ្យបានល្អឡើងវិញ ដើម្បីកុសលបុណ្យទៅជាតិមុខ។ តែអត្ថន័យកំណាព្យរបស់គាត់ បង្ហាញនូវមហិច្ឆតា លោភលន់ដោយស្រមើស្រមៃគ្មានព្រំដែន របស់គាត់ក្នុងអនាគតជាតិ ព្រមជាមួយជំនឿមិនសមហេតុផលមួយ គឺការជឿលើមន្តអាគម ដោយចង់ឱ្យខ្លួនមានឫទ្ធិអំណាចគ្មានព្រំដែន។

ច្បាប់ផ្សេងៗសម្រាប់ទូន្មានខ្លួន ដូចជា ច្បាប់ក្រម, កេរ្តិ៍កាល, សួស្តី, ត្រីនេតិ៍, កឹងកន្រ្តៃ ឬច្បាប់ពាក្យចាស់ជាដើម។

កំណាព្យច្បាប់កឹងកន្រ្តៃ ដែលទូន្មានអំពីរបៀបរស់នៅជាមនុស្ស ដែលត្រូវរៀនសូត្រតាមចំណុចល្អ និងចំណុចខ្លាំងរបស់សត្វនៅក្នុងធម្មជាតិជុំវិញខ្លួន។ ហើយនៅចំណុចខ្លះ ហាក់មានលក្ខណៈការព្យាករណ៍ព្រឹត្តិការណ៍សង្គម ដែលប្រែប្រួល ដូចជា ៖

«ហ៊ីងកំប៉ោងកុំអាលអើត គីងគុកចំទើតកុំអាលថា យលគេដើរកុំអាលថាគ្នា ក្រែងគេជាសត្រូវផង។ ខ្លាឈ្មោលស្វែងរកស៊ី ខ្លាញីដើរទេងទោង ខ្លាពពាលខ្នងកងកន្ទុយ រមាសមានកុយកុំពឹងព្រៃស្លុកដំរីមានភ្លុកកុំពឹងព្រៃនោម ក្រែងថ្មើរព្រៃវាតាម វាទាន់វាបាញ់ដួលច្រងៃៗ។

«ប្រើត្រាប់កុកសាប់ កុំត្រាប់កុកស ប្រើត្រាប់ឬស្សីល កុំត្រាប់ពុតស្នាយ ប្រើត្រាប់ពុតក្ងោក កុំត្រាប់ពុតទន្សាយ ប្រើត្រាប់អ្នកប្រាជ កុំត្រាប់អ្នកខ្លៅ ទោះបីដើរទៅ មានដៃនុះចាប់។

«ងើយត្រង់កើតស្លក ឱនជជ្រកកើ(ត)គ្រាប់ ចង់ចេះប្រើស្តាប់ ចង់ភ័ព្វប្រើឧស្សាហ៍

«ប្រើប្រក់ស្បូវភ្លាំង ប្រើរាំងព្រះសូភារ ប្រើរាប់ញាតិកា មានកុំម្រផ្សឹងៗ

«បាស្រូវជាភាព្វផ្ទា ប្រពុនមារជាភាព្វក្ស ដំម្រើស្លាប់ជាភាព្វគួយ ប្រពុនឱ្យជាភាព្វមារ។

«ស្រាក៏ផិក សឹកឱ្យច្បាំង ចិតក៏ឱ្យខ្លាំង រាំង(ក៏)ឱ្យខ្ជាប់ បុណ្យក៏ធ្វើឈើក៏កាប់ សត្វក៏សំម្លាប់ច្បាប់ក៏កាន់។

«ស្រម៉មិនដែលទុំ ក្រមុំមិនដែលស្លូត ពពៃមិនដែលងូត ចង្កូតមិនដែលនឹង។ ខ្មែរមិនដែលសុទ្ធ ព្រះពុទ្ធមិនដែលខឹង ត្រាវស្មោរមិនដែលរឹង ស្ទឹងបឹងមិនដែលត្រង់។

«សៀមមិនបង់ក្បួន យួនមិនបង់ពុត ខ្មែរសុទ្ធទ្រុតមិនលែងចៃចូវ។

«អស្ចារ្យធំចោរ កង្កែបអាច់គោ ដេញខាំពស់វែក អស្ចារ្យចម្លែក មៀមដេញខាំក្អែក ៗរត់ចេញឆ្ងាយ អស្ចារ្យ១ទូលាយ ម្តេចឡើយទន្សាយ មកដេញខាំឆ្កែ ពងមាន់ដាក់នៅរៀវរៃ ម្តេចឡើយមកប្រែ ពាំក្អែកហើរទៅ ឆ្កែស្អុយអូសទៅ ចោលកណ្តាលត្រាញ់ ម្តេចឡើយមកប្រែ ដេញខាំឯត្មាតវិញ ។

«អស្ចារ្យ១ត្រពាំង រត់រួសនូវកំលាំង ដេញតាមអណ្តើកទៅ អស្ចារ្យ១ត្រឡាំង ម្តេចធ្វើស្រែប្រាំង លើចុងរកា អស្ចារ្យ១ណា ម្តេចសំណាញ់បង់ប្រា ក្នុងគុម្ពឬស្សី អស្ចារ្យមហិមា ម្តេចឥតពិចារណា យកខុសជាគាប់ រីអ្នកដ៏មានចុនភ័ព្វ រស់នៅក៏គាប់ ស្លាប់ទៅក៏គួរ ធ្វើស្រែមិនបាច់ព្រួយភ្លួរ រក្សាតែម្ជុរបានស្រូវសល់ខ្នាត រករបស់ពុំព្រួយសង្វាត បានប្រាក់ពេញពាសបំពេញអាត្មា ។

«អនាគតទៅ កង្កែបនឹងដេញខាំពស់ ៗនឹងដេញខាំស្ការ ដំរីសារនឹងរត់នឹងកន្ទួរបង្កងហោង។ អ្វីធ្វើឱ្យសាន្ត អ្វីធ្វើឱ្យបាន ធ្វើអ្វីឱ្យផ្ទង់ ធ្វើអ្វីឱ្យត្រូវ ធ្វើអ្វីឱ្យត្រង់ ធ្វើអ្វីឱ្យគង់ ធ្វើអ្វីឱ្យគាប់ រីធ្វើឱ្យសាន្ត ប្រើអត់ក្រោធបាន រំសាស ទោសធាប់ រីធ្វើឱ្យបាន ប្រើឱ្យទានទ្រព្យ ប្រើផ្ទង់ចិត្តស្តាប់ ច្បាស់ច្បាប់មាត្រា។

«ធម្មតាអ្នកជា អ្នកមានប្រាជ្ញា មានផៅសន្តាន មិនចេះអាងអួត ប្រកួតរៀនកាន បំពាក់បំពាន បង្កអួតអង្គ។ ទោះនឹងយាត្រា ទៅទិសឋានណា តើដោយកុជង្គ សិរសាទន់ទាប សុភាពផ្គត់ផ្គង់ លំឱតឱនអង្គ ការកេរ្តិ៍អ្នកជា ។ រី អ្នកសាមាន្យ ខ្សត់ខ្សោយសន្តាន អាប់ឥតប្រាជ្ញា ដំណើរឯងឱង កែងកោងហត្ថា តូចខ្ជួយសោះសារ មែនមានពិស តិច។»

នៅមានរឿងជាច្រើនទៀតគេបានតាក់តែងឡើង ក្នុងន័យអប់រំ និងបង្ហាញពីតថភាពសង្គម និងផ្ទត់គំនិត សង្គមដែរ ដូចជា រឿងរាមកេរ្តិ៍, រឿងក្រុងសុភមិត្រ, ភោគកុលកមារ, ទេវន្ទ, ល្បើកចចក, ទុំទាវ, ព្រះជិនវង្ស, ទស្សជាតក និងបញ្ញាសជាតកជាដើម។ ក្រៅពីនោះនៅមានព្រះសង្ឃជាន់ខ្ពស់ បានសរសេរសត្រាពង្សាវតារ ដែល ជីវិតលោកបានឆ្លងកាត់ មើលឃើញ និងដឹងឮទុកឱ្យជនានុជនជាន់ក្រោយបានដឹងអំពីជោគវាសនា ដ៏សែនអាក្រក់ របស់ប្រជាជាតិខ្មែរក្នុងភ្លើងសង្គ្រាម សៀម–យួននៅសតវត្សរ៍ទី១៩។

## 10. ការបាត់បង់ធនធានមនុស្ស(ពលរដ្ឋ និងអ្នកចេះដឹង)

បើតាមរយៈព្រឹត្តិការណ៍សង្គ្រាមជាប់គ្នារដឹកចាប់ពីសតវត្សរ៍ទី១៨ មកដល់ពាក់កណ្តាលទី១សតវត្សរ៍ទី១៩ គេអាចប៉ាន់ប្រមាណបានថាមនុស្សខ្មែរ មិនអាចមានកំណើនទាន់ការស្លាប់ក្នុងចម្បាំង និងការកៀរយកធ្វើជាទាសក របស់សៀមបានឡើយ។

ក្នុងពង្សាវតារនៅសតវត្សរ៍ទី១៤-១៦ តួលេខយុទ្ធជនពេលច្បាំងគ្នាម្តងៗ មានរហូតដល់រាប់សិបម៉ឺននាក់ តែ ចំនួននេះបានថយជាលំដាប់មកដល់សតវត្សរ៍ទី១៧ ជាពិសេសនៅសតវត្សរ៍ទី១៨-១៩ ដែលក្នុងសឹកសង្គ្រាម នីមួយៗ គេមិនអាចកែនមនុស្សបានដល់១០ម៉ឺននាក់ម្តងណាឡើយ។ ហើយរហូតដល់ក្រោយពេលស្តេច នរោត្តម ចុះសន្ធិសញ្ញាដាក់កម្ពុជាក្រោមការការពាររបស់បារាំងនៅឆ្នាំ១៨៦៣ បារាំងបានធ្វើជំរឿនឃើញថា ខ្មែរមិន មានចំនួនដល់១លាននាក់ផង ដោយរាប់ទាំងជំពូកមនុស្សខ្ញុំបម្រើនៅតាមគ្រួសារខ្មែរនីមួយៗផង។

លោក ដេវីដ ឆាណ្ឌល័រ បានឱ្យតម្លៃថា ប្រទេសសៀម និងយួន បានតម្លើងខ្លួនជាមហាអំណាចបានដោយ សារអំនួតខាងបរិមាណនៃប្រជាពលរដ្ឋរបស់គេ ហេតុនេះហើយបានជារាល់លើកនៃការលុកលុយស្រុកខ្មែរ ទ័ព សៀមតែងតែកៀរគ្រួសារខ្មែរយកទៅធ្វើជាពលកំណែនរបស់ខ្លួន។ ចំណែកយួនវិញ គិតតែពីការកាប់សម្លាប់ជាង និងដុតបំផ្លាញទ្រព្យសម្បត្តិអលនវត្ថុរបស់ជនជាតិខ្មែរនៅតំបន់ដែលគេឆ្លងកាត់ ជាជាងការកៀរយកធ្វើជាឈ្លើយ ឬ ទាសករដូចពួកសៀម។

បើតាមលោក ឆាណ្ឌល័រ (២០០៣) បានឲ្យដឹងថា ប្រជាជនខ្មែរនៅសតវត្សរ៍ទី១៦ មិនហ៊ានចេញទៅធ្វើការ រកស៊ីនៅក្រៅភូមិរបស់ខ្លួន ឲ្យហួសពីសំលេងផ្គៃព្រួសឮដល់ឡើយ។[78] ប្រការនេះមកពីពួកគាត់បាក់ស្បាតដោយ សង្គ្រាមឈ្លានពាន ការកៀរយកជាឈ្លើយ ដែលធ្វើឲ្យបែកព្រាត់ប្រាសគ្រួសារ។ និងចាប់ធ្វើទារុណកម្ម កាប់សម្លាប់

---

[78] Cf., Chandler David, 2003, *A History of Cambodia*, 3rd Edition, p. ???

ចោលគ្មានត្រាប្រណីពីសំណាក់សៀម និងយួន និងដែលធ្វើឱ្យខ្មែរស្ទើរតែផុតពូជនោះ គឺនៅពាក់កណ្តាលទី១សតវត្សរ៍ទី១៩ មុនការមកដល់របស់បារាំងនេះឯង៕ [79]

[79] សូមមើល ឃីន សុខ, ២០០២, *រឿងកំពប់តែអុង*។

# មេរៀនទី ៩ សម័យអាណានិគមបារាំង៖ នយោបាយបញ្ចៀសគ្រោះថ្នាក់បាត់បង់ទឹកដី

*កម្ពុជា មុនទំនាក់ទំនងជាមួយបារាំង

យើងបានដឹងខ្លះៗហើយថា នៅរាជ្យស្តេចអង្គអេង មានមន្ត្រីមួយរូបដែលបានភ្ជាប់ខេត្តខ្មែរគឺខេត្តបាត់ដំបង និងសៀមរាបឱ្យទៅសៀម មន្ត្រីនោះគឺចៅហ្វា បែន ជាស្តេចត្រាញ់ (ចៅហ្វាទឡ្ហៈចុឡាលោក សម្តេចព្រះពុទ្ធយ៉តហ្វាចុឡាលោក)។ ទឹកដីនៅភាគពាយ័ព្យ ដែលមានខេត្តទាំងពីរនេះបានធ្លាក់ទៅក្នុងការគ្រប់គ្រងរបស់សៀមនៅឆ្នាំ ១៧៩៥ (ប៉ុន្តែ ប្រទេសខ្មែរនៅក្រោមចំណុះសៀមទាំងស្រុងនៅមុនការឡើងសោយរាជ្យរបស់ស្តេច អង្គអេង នៅបាងកកឆ្នាំ ១៧៩៤ទៅទៀត)។ នៅឆ្នាំនោះដដែលព្រះអង្គអេង យាងទៅប្រទេសសៀមសុំយកខេត្តទាំងពីរនេះមកវិញ ក្រោយមកព្រះអង្គក៏សោយទីវង្គតទៅនៅឆ្នាំ១៧៩៦ ដោយបន្សល់ទុករាជ្យបុត្ររបស់ព្រះអង្គទាំងនៅក្មេងៗប្រាំព្រះអង្គ មាន៖ អង្គចន្ទ,អង្គស្ងួន, អង្គអិម, អង្គភិម, អង្គដួង ។

នៅក្នុងរជ្ជកាលព្រះបាទអង្គចន្ទ«១៨០៦-១៨៣៤» យួនចូលមកជ្រៀតជ្រែកប្រទេសខ្មែរកាន់តែខ្លាំងឡើងៗ។ នៅពេលដែលសុំយាងអង្គស្ងួន ឱ្យត្រឡប់មកវិញមិនបាន ព្រះអង្គចន្ទ ក៏ប្រុងប្រៀបខ្លួននឹងធ្វើសង្គ្រាម ដោយសុំយួនឱ្យចូលមកជួយ ។ សៀមដឹងដូចនោះក៏សុំយាងអង្គស្ងួនចូលទៅក្រុងអាយុធ្យា ហើយលើកទ័ពមកច្បាំងនឹងយួន។ ព្រះអង្គចន្ទ ក៏ចូលនឹងយួនស៊ប់មែនទែន ដើម្បីឱ្យបានសោយរាជ្យនៅឧដុង្គតទៅទៀត ។ សៀមនិងយួនមកច្បាំងគ្នានៅក្នុងប្រទេសខ្មែរ ដើម្បីឱ្យស្តេចខ្មែរដែលពឹងគេនោះ បានសោយរាជ្យតែរៀងៗខ្លួន។ ដោយមានជំនួយពីទ័ពយួន ព្រះអង្គចន្ទក៏បានសោយរាជ្យឡើងវិញនៅកម្ពុជារហូតដល់ឆ្នាំ១៨៣៤។

កាលនៅឆ្នាំ១៨១៥ រាស្ត្រខ្មែរយ៉ាងច្រើនត្រូវបានបង្ខំឱ្យទៅជីកព្រែកវិញតេ/ហាទៀន(ហាទៀង) នៅវៀតណាម ដែលបច្ចុប្បន្នព្រែកនេះកាត់តាមបណ្តោយព្រំដែនប្រទេសកម្ពុជានិងវៀតណាម។ ព្រែកវិញតេ ដែលមានប្រវែង៥៣គ.ម និងព្រែកមួយទៀតភ្ជាប់ពីទន្លេមាត់ជ្រូកទៅទន្លេខាងកើតប្រវែង១៣,៧០៤គ.ម។ នៅក្នុងការជីកព្រែកនេះ រាស្ត្រខ្មែរដែលជាប់កំណែននោះមានទុក្ខលំបាកយ៉ាងខ្លាំង ធ្វើការមួយថ្ងៃទល់ព្រលប់ប្រៀបបាននឹងអ្នកទោស ក្រៅពីបាយទឹកមិនគ្រប់គ្រាន់យួនវាយសំពងថែមទៀត ដោយចោទប្រកាន់ថាខ្មែរខ្ជិល ធ្វើពុត ខ្មែរយឺត។ យួនបើកទឹកព្រែកបង្ហូរ មិនប្រាប់បណ្តាលឱ្យកម្មករកំណែនខ្មែរ ដែលរត់មិនទាន់លិចលង់ក្នុងព្រែកស្លាប់យ៉ាងច្រើន ។ រឿងនេះបានបង្កឱ្យមានទំនាក់ទំនងមិនល្អរវាងខ្មែរ និងយួន។ ប្រាំឆ្នាំក្រោយមក មានការបះបោរប្រឆាំងនឹងយួននៅបាភ្នំ ។ ការបះបោរនេះដឹកនាំដោយព្រះសង្ឃមួយអង្គ។ ព្រះបាទអង្គច័ន្ទ ចាប់បានមេបះបោរនោះរួចសម្លាប់។ ក្នុងរជ្ជកាលស្តេចអង្គចន្ទនេះ យួនចូលមកយាយី ក្សត្រខ្មែរឥតមានកំរើកតវ៉ាអ្វីឡើយ ។

ភាពវឹកវរក្នុងប្រទេសចេះតែខ្លាំងឡើងៗ។រាស្ត្រស្ថិតនៅក្នុងភាពជ្រួលច្របល់។ នៅពាក់កណ្តាលទី១ នៃសតវត្សរ៍ទី១៩ ពិសេសក្រោយការចូលទីវង្គតរបស់ស្តេចក្រុងបាងកក គឺព្រះអង្គរាមាទី១ (គឺជាគោរម្យងារស្តេចសៀមព្រះពុទ្ធយ៉តហ្វា"១៧៨២-១៨០៩") និងព្រះចៅយ៉ា ឡុងនៃប្រទេសវៀតណាម។ ក្នុងឆ្នាំ ១៨២០ កម្ពុជា គឺជាទីលានប្រយុទ្ធគ្នាស្ទើរតែជាប្រចាំរវាងសៀម និងយួន ពួកគេទាំងសងខាងអះអាងរៀងខ្លួន នូវសិទ្ធិគ្រប់យ៉ាងរបស់គេ ដោយឈរលើមូលដ្ឋាននៃការសុខចិត្តធ្វើសម្បទានរបស់ព្រះអង្គម្ចាស់កម្ពុជាពីអតីតកាល។

សង្គ្រាមទាំងនោះនៅកម្ពុជា ជារឿយៗកើតឡើងតំណាលគ្នា និងជម្លោះស្រដៀងគ្នារវាងថៃ និងវៀតណាម នៅក្នុងប្រទេសលាវ ហើយខាងភាគីថៃមានមន្ត្រី និងឧត្តមសេនីយ៍ដដែលមួយចំនួនពាក់ព័ន្ធជាមួយលាវផង និងជាមួយនិងកម្ពុជាផង។ ក្រោយមកបារាំងចាប់ផ្តើមឈានជើងចូលកម្ពុជា និងលាវក្នុងពេលប្រហាក់ប្រហែលគ្នា ហើយពួកគេអះអាងថាពួកគេបន្តសិទ្ធិគ្រប់គ្រងពីវៀតណាម។ ដោយសារភាពច្របូកច្របល់ ទីបំផុតក៏សម្រេចយាងព្រះអង្គឌួងឱ្យចូលមកសោយរាជ្យនៅឧដុង្គ។ តែ សៀមនិងយួនពុំទាន់ឈប់ធ្វើចម្បាំងនិងគ្នាទេ។ ផ្នែកខាងត្បូងភ្នំពេញនៅក្រោមអំណាចយួន ផ្នែកខាងក្រុងឧដុង្គនៅក្រោមអំណាចសៀម។

លុះមកដល់ឆ្នាំ ១៨៤៦ យួន និងសៀម សម្រេចបញ្ឈប់សង្គ្រាមនៅក្នុងប្រទេសខ្មែរ។ គេប្តូរឈ្លើយសង្គ្រាមគ្នា។ សៀមរុះរើបន្ទាយយួន យួនរុះរើបន្ទាយសៀម។ ស្តេចខ្មែរដែលសោយរាជ្យនៅពេលនោះ គឺព្រះបាទអង្គដួង និងព្រះបាទនរោត្តម(ផ្នែកខាងដើមនៃរជ្ជកាល)គ្រាន់តែជានិមិត្តរូបប៉ុណ្ណោះ ពុំបានចេញមុខមាត់ចាត់ចែងកិច្ចការអ្វីឡើយ។ ទឹកដីកម្ពុជាក្រោម ក៏ចេះតែបាត់បន្តិចម្តងៗដោយសារការទន្ទ្រានរបស់យួនកាលពីមុន ។

នៅប្រទេសវៀតណាម ស្តេច មិញ ម៉ាង ឡើងជាស្តេចនៅក្នុងឆ្នាំ ១៨២០។ ឆ្នាំ១៨៣២ មានការឈ្លានពានពីសំណាក់ថៃ ព្រះអង្គចន្ទ បានភៀសព្រះកាយទៅវៀតណាម។ មេទ័ពសៀមឈ្មោះ បឱនតេជោដែលធ្លាប់ច្បាំងនៅលាវដែរ បាននាំបងប្អូនរបស់ព្រះអង្គចន្ទ គឺព្រះអង្គអិម និង អង្គដួងទៅភ្នំពេញ។ ឯកងទ័ពសៀមបានបន្តវាយវៀតណាមក្នុងតំបន់មាត់ជ្រូក(ចូវដុក)។ ប៉ុន្តែពេលមេទ័ពបឱន ព្យាយាមវាយចូលឱ្យជ្រៅក្នុងដែនដីវៀតណាម គាត់ក៏បានទទួលបរាជ័យ។ ពេលនោះទ័ពសៀមបានត្រឡប់ទៅបាងកកវិញ ឯព្រះអង្គអិម និងអង្គដួង ស្នាក់នៅបាត់ដំបង។ ក្នុងពេលនោះដែរ យួនបាននាំព្រះអង្គចន្ទត្រឡប់មកភ្នំពេញវិញ។

ក្នុងឆ្នាំ១៨៣៤ ទើបតែឡើងសោយរាជ្យម្តងទៀតបានតែបន្តិច ព្រះបាទអង្គចន្ទសោយទីវង្គត។ បងប្អូនប្រុសរបស់ទ្រង់មិនត្រូវបានស្តេច មិញម៉ាងជ្រើសរើសទេ ដោយសារពួកព្រះអង្គមានទំនាក់ទំនងជិតស្និតជាមួយសៀម។ ដូច្នេះស្តេចមិញ ម៉ាង បានតែងតាំងបុត្រីព្រះអង្គចន្ទនាម អង្គម៉ី ឱ្យឡើងគ្រងរាជ្យ។ ប៉ុន្តែព្រះនាងត្រូវនៅក្រោមការគ្រប់គ្រងរបស់មន្ត្រីយួន និងគ្មានអំណាចពិតប្រាកដ។ ក្រោយនេះស្តេចមិញ ម៉ាង ព្យាយាមអនុវត្តន៍នយោបាយយួនូបនីយកម្មពិតប្រាកដក្នុងប្រទេសកម្ពុជា។

មេទ័ពយួនបានបំផ្លោងពាក្យអន្ទងហៅព្រះអនុជទាំងពីររបស់អង្គច័ន្ទ ឱ្យមកទទួលរាជ្យសម្បត្តិបន្ត។ ព្រោះព្រះអង្គគ្មានរាជបុត្រស្នង។ ទ្រង់អង្គអិម ជឿជាក់លើយួនក៏បានវិលត្រឡប់មកស្រុកវិញ ចូលមករកពួកយួនដោយចង់ឡើងសោយរាជ្យ។ ទើបព្រះអង្គត្រូវយួនចាប់យកទៅប្រទេសយួន ហើយក៏សុគតនៅទីនោះ។ ឯពួកសៀមដោយខឹងសម្បារយ៉ាងខ្លាំង បាននាំព្រះអង្គដួង ត្រឡប់ទៅឃុំឃាំងទុកនៅបាងកកវិញ ។

ពេលនោះ មន្ត្រីកម្ពុជាបានស្នើសុំឱ្យសៀមបញ្ជូនព្រះអង្គដួងត្រឡប់មកសោយរាជ្យវិញ ព្រះអង្គដួង ក៏យាងត្រឡប់មកជាមួយមេទ័ពបឱន។ ពេលស្តេចមិញ ម៉ាង ចូលទីវង្គតនៅក្នុងឆ្នាំ១៨៤១ រាជបល្ល័ង្កត្រូវស្នងដោយបុត្រារបស់ទ្រង់ព្រះនាម ធៀវទ្រី។ ពេលនោះ នយោបាយយួនចាប់ផ្តើមផ្លាស់ប្តូរ។ ស្តេចធៀវ ទ្រីពុំមាននយោបាយដណ្តើមទឹកដីកម្ពុជាដូចព្រះបិតាទ្រង់នាម មិញ ម៉ាង ទេ។ ព្រះអង្គចេញបញ្ជាឱ្យកងទ័ពយួន ត្រឡប់មកប្រទេសខ្លួនវិញ ហើយការចរចាបានចាប់ផ្តើមរវាងយួន និងសៀម ។

ជាលទ្ធផល ក្នុងឆ្នាំ១៨៤៧ សៀម និងយួនបានព្រមព្រៀងឱ្យព្រះអង្គដួង បានគ្រងរាជ្យ និងយល់ព្រមដកកងទ័ពបរទេសទាំងអស់ចេញពីកម្ពុជា។ នេះមិនមែនមានន័យថា កម្ពុជាមានឯករាជ្យទាំងស្រុងទេ។ យោងតាមច្បាប់

អន្តរជាតិសម័យនោះ កម្ពុជាស្ថិតនៅក្រោមអាណាព្យាបាលរបស់សៀម និងយួន។ ព្រះអង្គដួង ត្រូវបញ្ជូនសួយសារអាករទៅប្រទេសយួន រៀងរាល់បីឆ្នាំម្តង និងទៅប្រទេសសៀម ជារៀងរាល់ឆ្នាំ ហើយព្រះអង្គពុំមានលទ្ធភាពដណ្តើមយកមកវិញនៅខេត្តណាមួយរបស់កម្ពុជាដែលបាត់បង់ទៅទាំងលើសៀម និងយួនឡើយ។ ដោយព្រួយបារម្ភចំពោះជោគវាសនារបស់ប្រទេសដូច្នេះ ទើបព្រះអង្គមានចេតនាទាក់ទងជាសម្ងាត់ជាមួយមហាអំណាចថ្មីមួយទៀត ដែលទំនងជាព្រះអង្គទ្រង់ឆ្វេងយល់យ៉ាងល្អិតល្អន់រួចជាស្រេចហើយថា គេអាចនឹងក្លាយជាអ្នកមានអំណាចថ្មីនៅក្នុងតំបន់នេះផង។

## 1. គំនិតផ្តួចផ្តើមទាក់ទងជាមួយបារាំង ដោយព្រះអង្គដួង

តាំងពីពាក់កណ្តាលទី១ នៃសតវត្សរ៍ទី១៩មក មហាអំណាចចក្រពត្តិជាច្រើនដូចជាប្រទេសព័រទុយហ្គាល់ អេស្ប៉ាញ អង់គ្លេស បារាំង ជាដើម បានបង្កសង្គ្រាមឈ្លានពាន នៅពាសពេញពិភពលោកដែលនៅក្នុងនោះ ក៏រួមមានប្រទេសជាច្រើន នៅអាស៊ីផងដែរ ។

នៅអាស៊ី បារាំងបានតម្រង់ទិសដៅមករកប្រទេសចិនភាគខាងត្បូង និងបណ្តាប្រទេសនៅឧបទ្វីប មានកម្ពុជា វៀតណាម លាវ សៀម។ នៅក្នុងប្រទេសទាំងនេះ បេសកបព្វជិតកាតូលិកបានចូលមកផ្សព្វផ្សាយសាសនាជាយូរមកហើយ។ បេសកបព្វជិតទាំងនេះ បានបំពេញបេសកកម្មរបស់ខ្លួនយ៉ាងម៉ឺងម៉ាត់បំផុត និងយ៉ាងស្វាត់កំបាំង តាមរយៈប្រជាជនដែលកាន់សាសនាគ្រឹស្ត ។

បន្ទាប់ពីមានព្រឹត្តិការណ៍ចម្បាំងអាភៀន នៅប្រទេសចិន (១៨៤០-១៨៤២)មក សកម្មភាពបេសកបព្វជិតបារាំងត្រូវបានបង្កើនយ៉ាងរហ័សមកក្នុងប្រទេសកម្ពុជា ។ បេសកបព្វជិតបារាំង ដែលធ្វើការហ្មត់ចត់ជាងគេក្នុងការរៀបចំដណ្តើមការគាំទ្រពីកម្ពុជា គឺបព្វជិតបារាំងឈ្មោះ ហ្សង់ក្លូដ មីស្ហ(*Jean-Claude Miche*)។ បេសកបព្វជិតរូបនេះ ត្រូវបានទទួលការសព្វព្រះទ័យពីព្រះបាទអង្គដួង ទើបតែងតាំងជាគ្រូពេទ្យសម្រាប់ព្រះអង្គ និងជាគ្រូបាអាចារ្យបង្ហាត់បង្រៀនរជ្ជទាយាទ។ គាត់តែងតែពោលសរសើរអំពីគុណសម្បត្តិដ៏ល្អប្រពៃរបស់ព្រះចៅណាប៉ូឡេអុងរបស់គាត់ ក្នុងការរាប់អានជាមួយប្រទេសឯនាយសមុទ្ទ ដោយឆន្ទៈដ៏បរិសុទ្ធ។ ប្រហែលដោយសារភាពប៉ិនប្រសព្វខាងការទូតរបស់លោក មីស្ហ ផង ទើបធ្វើឱ្យព្រះបាទអង្គដួង ចាប់អារម្មណ៍ និងជឿថាប្រហែលជាមានស្តេចបរទេសប្រកបដោយសប្បុរស និងគុណធម៌បែបនោះមែន។ ឆ្លៀតឱកាសល្អបែបនោះ បព្វជិតនេះបានថ្វាយយោបល់ដល់មហាក្សត្រខ្មែរឱ្យធ្វើសារលិខិត និងផ្ញើដង្វាយទៅព្រះចៅអធិរាជណាប៉ូឡេអុងទី៣ ដើម្បីសុំឱ្យប្រទេសបារាំងជួយការពារប្រទេសកម្ពុជា។ គួរបញ្ជាក់ដែរថា នៅអំឡុងនៅសតវត្សរ៍ទី១៩នោះហើយ ដែលការចាប់ផ្តើមមានទំនាក់ទំនងរបស់បារាំងនៅប្រទេសខ្មែរបានកើតឡើង។ នៅពេលដែលពួកផ្សាយសាសនាកាតូលិកបានមកតាំងលំនៅ នៅក្នុងបរិវេណក្រុងឧដុង្គមានជ័យ។ ប៉ុន្តែនៅមុនទសវត្ស១៨៥០ ការជាប់ទាក់ទងជាមួយពួកនេះ ពុំមែនក្នុងន័យនយោបាយទេ។ ហើយព្រឹត្តិការណ៍នោះ កើតឡើងស្របពេលជាមួយនឹងការជាប់ទាក់ទងរបស់បារាំងនៅប្រទេសអាណ្ណាម(យួន)។ ដើម្បីឱ្យខ្មែរបានឆ្លៀតឱកាសទាញយកផលប្រយោជន៍ពីនោះ ព្រះបាទសម្តេចព្រះហរិរក្សរាមាឥស្សរាធិបតី(ព្រះអង្គដួង) បានទ្រង់បានយល់ស្របជាមួយគំនិតរបស់លោក មីស្ហ ក្នុងការស្វែងរកជំនួយពីបារាំងក្នុងបំណងធ្វើឱ្យសៀម និងយួនប្រឆាំងគ្នា ឬយ៉ាងហោចណាស់ ក៏អាចទប់ស្កាត់ឥទ្ធិពលរបស់ពួកគេបានដែរ។

រាជសារដំបូងរបស់ព្រះអង្គដួងផ្ញើថ្វាយស្តេចបារាំង គេមិនដឹងថាធ្វើនៅឆ្នាំណា និងមានអត្ថន័យថាដូចម្តេចដែរ។ តែរាជសារបន្ទាប់ដែលធ្វើនៅខែវិច្ឆិកាឆ្នាំ១៨៥៣ បានទៅដល់ប៉ារីនៅ១៨៥៤។ នៅក្នុងឆ្នាំបន្ទាប់ គឺ១៨៥៥ សាលដឺម៉ុងទីញី(Charles de Montigny) ដែលជាបេសកជនបារាំងប្រចាំស្រុកសៀម-ចិន បានទទួលបញ្ជាឱ្យមក

ជួបព្រះបាទអង្គដួង ដើម្បីចុះសន្ធិសញ្ញាមិត្តភាព និងពាណិជ្ជកម្មជាមួយកម្ពុជា។ បេសកទូតរូបនេះ ទើបតែចុះសន្ធិសញ្ញាជាមួយស្តេចសៀមនាមព្រះមហាមង្គុត។ អំឡុងពេលស្នាក់នៅលើកដំបូងនៅបាងកក ដើម្បីចុះហត្ថលេខាលើសន្ធិសញ្ញាមួយជាមួយព្រះចៅសៀម និងឱកាសទទួលគួរសមផ្លូវទូតដោយស្តេចសៀម លោក Montigny បានធ្វើឱ្យផ្លោយសម្តីស្តីអំពីដំណឹងបេសកកម្មរបស់គាត់ ដែលត្រូវធៀងចូលក្រុងឧដុង្គ ជួបជាមួយព្រះបាទអង្គដួង។ ទើបស្តេចសៀម រិះរកវិធីបង្អាក់ដំណើរគាត់ កុំឱ្យមានពេលគ្រប់គ្រាន់មកកាន់ទីក្រុងឧដុង្គបាន។ ព្រោះសៀមមិនយល់ព្រមឱ្យកម្ពុជា ដែលគេចាត់ទុកជានគរសាមន្តរាជ មានសិទ្ធិចុះសន្ធិសញ្ញាដោយគ្មានការឯកភាពពីគេឡើយ។ ស្តេចសៀមចាត់មន្ត្រី១ម្នាក់ ឱ្យចុះជិះកប៉ាល់ជាមួយលោក De Montignyជាសម្ងាត់ ដើម្បីពិនិត្យសកម្មភាពរបស់រាជទូតបារាំងនេះផង និងនាំសារមកថ្វាយព្រះរាជាខ្មែរផង (នោះគឺជាសារហាមឃាត់ ព្រោះរាជសារនោះ ពោរពេញដោយពាក្យគំរាមកំហែងព្រះអង្គដួង)។

ដោយផែនការនៃការធ្វើដំណើរទៅអាណ្ណាម និងចិន ត្រូវយឺតយ៉ាវ ទើបនៅពេលមកដល់កំពត លោក ម៉ុងទីញី ស្នាក់នៅទីនោះ ដើម្បីរង់ចាំចុះសន្ធិសញ្ញាមួយជាមួយព្រះអង្គ។ ព្រះអង្គដួង មិនបានទៅជួបបេកសកជនរូបនេះទេ។ ដឹងដូច្នោះ ម៉ុងទីញី បានចាត់ព្រះសង្ឃកាតូលិកឈ្មោះ (អាបេ)ហ្សេ ស្រ្តិស ដែលមីស្ទទើបតែងតាំងឱ្យឈរជើងនៅខេត្តកំពត ឱ្យនាំយកសន្ធិសញ្ញាពាណិជ្ជកម្ម ដែលចម្លងខ្លឹមសារតាមសន្ធិសញ្ញាដែលបារាំងទើបបានចុះជាមួយសៀម មកថ្វាយព្រះអង្គដួងឡាយព្រះហស្តលេខា។ ហើយដើម្បីកុំឱ្យខកដំណើរទៅកាន់ប្រទេសចិន ដែលជាគោលដៅធំជាង លោក ម៉ុងទីញី គ្រាន់តែបញ្ជូនរាជសារនោះ មកឧដុង្គ ដើម្បីឱ្យព្រះអង្គចុះហត្ថលេខា ហើយរង់ចាំទទួលយកវិញនៅកំពត។ តែដោយចាំបាត់ៗ យូរពេក មិនឃើញរាជសារនោះវិលវិញសោះ ចំណែកកម្មវិធីធ្វើដំណើរកាន់តែខើចខ្លីពេកហើយ គាត់ក៏ប្រញាប់ចាកចេញទៅប្រទេសអាណ្ណាម និងចិនបាត់ទៅ។ ចំណែករាជសារសេចក្តីព្រាងសន្ធិសញ្ញាស្តីពីកិច្ចសហប្រតិបត្តិការនោះ ទំនងជាមិនបានទៅដល់ព្រះអង្គដួងឡើយ តែបែរជាធ្លាក់ទៅដល់ដៃស្តេចសៀមទៅវិញ។ ព្រោះមន្ត្រីមួយចំនួនរបស់ព្រះអង្គនៅពេលនោះ មានភក្តីភាពជាមួយសៀមជាង ដោយត្រូវនាម៉ឺនសៀមនៅរាជវាំងខ្មែរ បំភ័យទាំងព្រះរាជា និងទាំងនាម៉ឺនខ្មែរទាំងនោះ។

ដូច្នេះការបរាជ័យនេះ គឺដោយសារតែភាពមិនប៉ិនប្រសព្វ និងការធ្វេសប្រហែសនៃបេសកទូតបារាំងទើបធ្វើឱ្យបាត់ឱកាសក្នុងការដាក់អាណាព្យាបាលមកលើកម្ពុជាតាំងពីឆ្នាំ១៨៥៦ មុនសង្គ្រាមនៅកូសាំងស៊ីនជាច្រើនឆ្នាំ។ ចំណែកព្រះអង្គដួង ហាក់ដូចជាបាក់ស្បាតក្នុងការព្យាយាមចុះកិច្ចសន្យាបែបនេះ ជាមួយបស្ចិមប្រទេស។

រាជសារព្រះបាទអង្គដួង លើកទី១ (បើមើលអត្ថន័យនៃសារនេះ វាគួរតែមិនមែនជាសារលើកដំបូងនោះទេ) ផ្ញើចេញនៅ ខែវិច្ឆិកាឆ្នាំ១៨៥៣ ថ្វាយទៅព្រះចៅណាប៉ូឡេអុងទី៣។ បើតាមសៀវភៅលោក *Adhémard Leclère* ព្រះអង្គដួងផ្ញើនោះ "ដើម្បីសំដែងមិត្តភាព និងគារវកិច្ចរបស់ព្រះអង្គ ស្នើសុំការការពារដ៏ជ្រាលជ្រៅពីអធិរាជណាប៉ូឡេអុងទី៣"។[80]

---

[80] *យើង, ព្រះហរិរក្សរាមា មហាឥស្សរាធិបតី ព្រះបាទអង្គដួង ព្រះមហាក្សត្រនៃប្រទេសកម្ពុជា សូមសំដែងនូវមិត្តភាពដ៏ស្មោះស្ម័គ្រចំពោះព្រះករុណា អធិរាជណាប៉ូឡេអុងទី៣ អធិរាជនៃប្រទេសបារាំង។ ដោយមានបំណងបង្ហាញនូវសេចក្តីស្មោះត្រង់របស់ទូលព្រះបង្គំចំពោះព្រះករុណា, ទូលព្រះបង្គំមានកិត្តិយសសូមថ្វាយព្រះករុណាទ្រង់ជ្រាបថា 'ទូលព្រះបង្គំមានហឫទ័យរីករាយ ចំពោះដំណើរទេស្សនកិច្ចដែលបានធ្វើឡើងចំពោះទូលព្រះបង្គំដោយបេសកជនរបស់ករុណាលោក Charles de Montigny។ ទូលព្រះបង្គំបានបញ្ជាឱ្យមន្ត្រីថ្នាក់ខ្ពស់របស់ព្រះរាជាណាចក្រកម្ពុជា៣នាក់ និងមន្ត្រីថ្នាក់បន្ទាប់បន្សំ១៥នាក់ទៀតទៅទទួលស្វាគមន៍លោក Charles de Montigny នៅខេត្តកំពត[80]។ ពីព្រោះថា ចាប់តាំងជាច្រើនឆ្នាំមកហើយ*

ក្រោយពីទាក់ទងចុះកិច្ចសន្យាជាមួយបារាំងពុំបានសម្រេច ព្រះករុណាព្រះបាទអង្គដួង បានផ្ញើរាជសារមួយទៀតទៅព្រះចៅណាប៉ូឡេអុងទី៣ នៅឆ្នាំ១៨៥៦ ទៀត។ រាជសារទី២(តាមពិតគួរតែជាទី៣)នេះ ត្រូវបានករុណាព្រះបាទអង្គដួងផ្ញើទៅព្រះចៅណាប៉ូឡេអុងទី៣នៅឆ្នាំ១៨៥៦។ ព្រះអង្គដួង រាយការណ៍អំពីសាវតារនៃប្រទេសកម្ពុជាដែលជាអតីតប្រទេសដ៏ធំមួយដោយសង្ខេបប្រាប់អធិរាជបារាំង និងការប្រើល្បិចវាតទីយកទឹកដីនៃប្រទេសកម្ពុជាកាន់កាប់ ដោយព្រះចៅយ៉ាឡុង និងមិញម៉ាងនៃប្រទេសយួន បន្ទាប់ពីដណ្តើមអំណាចបានពីពួកបះបោរតៃសឺន។[81]

---

*សាសនទូតបារាំងដែលរស់នៅក្នុងប្រទេសកម្ពុជា បានឱ្យទូលព្រះបង្គំដឹង ជាមួយនឹងពាក្យសរសើរជាច្រើនថា អធិរាជបារាំងទ្រង់មានព្រះរាជហឫទ័យអាណិតករុណាចំពោះប្រជាជាតិទាំងអស់, មិនគ្រាន់តែគិតគូរដល់ផលប្រយោជន៍របស់រដ្ឋរាសីប៉ុណ្ណោះទេ ព្រះអង្គថែមទាំងការពារ ដើម្បីធានានូវភាពសុខសាន្ត និងសុខុមាលភាពរបស់ពួកគេថែមទៀតផង។ ទើបពេលក្រោយមក ព្រះចៅអធិរាជបារាំង គឺជាមហាក្សត្រដ៏ល្អ និងមិនមានបំណងដូចមហាក្សត្រផ្សេងៗទៀតនៅអឺរ៉ុប ដែលតែងស្វែងរកការធ្វើអាជីវកម្មលើប្រទេសដទៃទៀតនោះទេ។ ដោយហេតុនេះ ទូលព្រះបង្គំមានហឫទ័យរីករាយខ្លាំងណាស់ ដើម្បីសម្រេចជាមួយព្រះចៅអធិរាជបារាំងនូវសម្ព័ន្ធភាពដ៏ស្ថិតស្ថេរមួយទៅនឹងប្រទេសដ៏ធំ និងអ្នកមានមួយនេះនូវគុណប្រយោជន៍សម្រាប់ប្រជាជន។ ដោយហេតុនេះ បានជាទូលបង្គំបានឱ្យបព្វជិត Ridré Avirémadâktâ Miche Posdansera ទទួលបន្ទុកសរសេរនូវលិខិតមួយនេះ ដើម្បីបង្ហាញនូវមិត្តភាពរបស់យើង និងថ្វាយដល់ព្រះករុណាព្រះចៅអធិរាជបារាំង នូវដំរីសឹក៤ក្បាល ស្នែងរមាស២ ថ្នាំគូរគំនូរពណ៌លឿងចំនួន៥០ Piculs, ស្ករ៥ Piculs, ម្រេច៤ Piculs។*

[81] *...ឥឡូវនេះ ទូលព្រះបង្គំបានថ្វាយដល់ព្រះអង្គនូវសំពត់ និងដំរីការពារ(ដំរីសឹក)ចំនួន៤ក្បាលដែលជាជង្វាយដ៏ស្តួចស្តើងដែលមានគោលបំណងតែមួយគត់ ដើម្បីឱ្យព្រះអង្គបានដឹងអំពីហឫទ័យទូលព្រះបង្គំ។ តាមការពិតនៅក្នុងពេលនេះ លោក M. de Montignyដែលត្រូវអញ្ជើញទៅពិភាក្សាជាមួយអាណ្ណាម បន្ទាប់មកលោកបានធ្វើដំណើររហូតទៅដល់ប្រទេសចិនទៀតនោះ គឺមិនអាចចូលមកប្រទេសកម្ពុជាបានឡើយ។ ដោយហេតុនេះហើយ ទូលព្រះបង្គំផ្ញើថ្វាយព្រះអង្គនូវជង្វាយបន្តិចបន្តួចនេះ គឺគ្រាន់តែដើម្បីបង្ហាញនូវមិត្តភាពរបស់ទូលព្រះបង្គំ ហើយព្រមជាមួយនេះទូលព្រះបង្គំ ក៏សូមថ្វាយដល់ព្រះករុណា ព្រះចៅអធិរាជបារាំងទ្រង់ជ្រាបដូចតទៅនេះ៖*

*«កាលពីមុនប្រទេសកម្ពុជា គឺជាប្រទេសដ៏ធំទូលាយមួយដែលមានខេត្តធំៗ។ ក្រោយមកពួកអាណ្ណាមដែលជាមនុស្សអសុទ្ធចិត្តដែលធ្វើជាសម្ព័ន្ធមិត្តជាមួយកម្ពុជានោះ បានស្វែងរកការផ្តាច់ចេញពីប្រទេសកម្ពុជាជួនកាលស្រុកមួយជួនកាលស្រុកពីរ។ នៅក្នុងអំឡុងនៃការបះបោររបស់ពួកតៃសឺន(Tay Son) ស្តេចយ៉ាឡុងទ្រង់យាងគេចចេញពីព្រះរាជាណាចក្ររបស់ព្រះអង្គមកសុំការជួយសង្គ្រោះពីរាជាណាចក្រក្រុងទេព(សៀម) , ពេលនោះស្តេចអាណ្ណាមបានជួបព្រះវរបិតារបស់ទូលព្រះបង្គំ ដែលពេលនោះព្រះអង្គជាព្រះមហាក្សត្ររបស់ប្រទេសកម្ពុជា ដែលព្រះអង្គទទួលបាននូវសម្ព័ន្ធភាព។ ក្រោយពីភៀសព្រះកាយមកនៅក្រុងទេព និងបន្ទាប់មកបានមកគង់នៅក្នុងស្រុកព្រះត្រពាំង(ត្រាវិញ)ដែលជាទឹកដីរបស់កម្ពុជា, ទីកន្លែងដែលព្រះអង្គបានរៀបចំកងទ័ព ដើម្បីប្រយុទ្ធប្រឆាំងពួកតៃសឺន ព្រះករុណាព្រះវរបិតារបស់ទូលព្រះបង្គំបានបញ្ជូនកងទ័ពទៅជួយព្រះអង្គរហូតដល់ព្រះអង្គទទួលបានជ័យជម្នះលើពួកតៃសឺន ហើយបានឡើងសោយរាជ្យនៅអាណ្ណាម។ ដោយទ្រង់វាយតម្លៃថា ស្រុកព្រះត្រពាំង គឺជាអ្នកធ្វើគុណចំពោះព្រះអង្គ ស្តេចយ៉ាឡុងបានស្នើសុំដល់ព្រះវរបិតារបស់ទូលព្រះបង្គំឱ្យស្រុកនេះរួចខ្លួនពីការនាំសួយសារអាករ(មកប្រទេសកម្ពុជា) និងកុំប្រើអ្នកស្រុកនេះធ្វើការ។...»*

*ព្រះករុណាព្រះបិតារបស់ទូលបង្គំបានចាត់ទុកថា នេះគឺជាអំពើអាណិតអាសូរមួយចំពោះព្រះអង្គស្តេចយ៉ាឡុងក្នុងន័យអនុគ្រោះមួយចំពោះសម្ព័ន្ធមិត្តនោះ ក៏ទ្រង់យល់ព្រមចំពោះការស្នើសុំនេះ និងមិនបានដាក់អ្នកស្រុកនេះឱ្យស្ថិតនៅក្រោមកំណែនណាមួយឡើយ។ យូរក្រោយមកស្តេចយ៉ាឡុង បានធ្វើឱ្យអ្នកស្រុកនោះក្លាយទៅជាអាណានិគមមួយរបស់អាណ្ណាមមកដល់ជេដ្ឋកាលព្រះវរជេដ្ឋារបស់ទូលបង្គំ ដែលព្រះអង្គបានបែរទៅរកអធិរាជ យ៉ា ឡុង ដើម្បីស្នើសុំឱ្យអធិរាជនោះ គាំទ្រព្រះអង្គ។ ចំណែកទូលព្រះបង្គំ ក៏បានយាងទៅគង់នៅព្រះរាជាណាចក្រក្រុងទេព។ ព្រះរាជបុត្ររបស់ព្រះចៅយ៉ាឡុង ព្រះនាមមិញម៉ាង*

ព្រះរាជសារ ត្រូវផ្ញើទៅឱ្យអធិរាជបារាំង «ណាប៉ូឡេអុងទី៣» ជាង៧ឆ្នាំនៅមុនការចុះហត្ថលេខាលើសន្ធិសញ្ញាថ្ងៃទី៥ មិថុនា ឆ្នាំ១៨៦២ ពេលនោះអធិរាជ"ធូឌឹក" បានប្រគល់ទៅឱ្យប្រទេសបារាំងនូវខេត្តបៀនហ្វា, ឌិនទឿង និងពូឡូកុងឌ័រ(កោះត្រឡាច)។ កាលនោះបុត្រារបស់ព្រះអង្គដួងគង់នៅបាងកកនៅឡើយ ប្រហែលដើម្បីជាការបញ្ជាក់ថា ព្រះបាទអង្គដួងនៅមានភក្តីចំពោះសៀម។[82]

ជាចុងក្រោយ ដូចមានចក្ខុវិស័យដឹងជាមុននូវគោលដៅយុទ្ធសាស្ត្រចាប់យកទឹកដីអាណានិគមរបស់បារាំងនៅឥណ្ឌូចិន ព្រះបាទអង្គដួង បានប្រកាសអំពីការរក្សាសិទ្ធិកាន់កាប់ទឹកដីរបស់«ប្រទេសកម្ពុជា»ទៅលើកម្ពុជាក្រោម«អនាគតកូសាំងស៊ីន»ដែលមានឈ្មោះខេត្តមួយចំនួន ចាប់ពីត្រើយខាងលិចនៃទន្លេសៃហ្គន ឲ្យអធិរាជបារាំងដឹង។ បើទោះបីជា ទឹកដីនោះកំពុងស្ថិតក្រោមការកាន់កាប់របស់យួនក្តី។ ព្រះអង្គបានស្នើដល់អធិរាជបារាំង កុំឱ្យទទួលពីស្តេចអាណ្ណាមនូវ «ទឹកដីកម្ពុជាក្រោមដែលយួនកំពុងកាន់កាប់ដោយអយុត្តិធម៌នៅពេលនោះ»។ ពីព្រោះវានឹងក្លាយជាទង្វើអគុណធម៌របស់បារាំង ប្រសិនបើព្រមទទួលយកទឹកដីនោះពីយួន។[83]

---

*បានឡើងសោយរាជ្យ និងបានបញ្ជាឱ្យគេជីកព្រែកមួយកាត់ព្រះរាជាណាចក្រកម្ពុជា ចាប់តាំងពីពាមហូតដល់ចូវដុក(ខេត្តមាត់ជ្រូក)ដើម្បីរៀបចំដាក់មន្ត្រី និងប្រជាជនអាណ្ណាម។*
*នៅពេលសោយទីវង្គត ព្រះបិតាជាទីគោរពរបស់ទូលព្រះបង្គំ បានបន្សល់ទុកព្រះម្ចាស់ក្សត្រីមួយព្រះអង្គ។ អធិរាជ មិញម៉ាង ក្នុងការចាត់វិធានការណ៍បង្ក្រាប បានបញ្ជាឱ្យនាំខ្លួនព្រះរាជបុត្រីរបស់ព្រះវរជេដ្ឋា ព្រះមាតា ព្រះរាជបុត្រផ្ទាល់របស់ទូលព្រះបង្គំ និងបានឱ្យគេធ្វើគតព្រះរាជបុត្រីមួយអង្គរបស់ព្រះវរជេដ្ឋាទូលព្រះបង្គំ ព្រមទាំងបញ្ជាឲ្យមន្ត្រីធំៗ និងអ្នកស្រុកនៃប្រទេសកម្ពុជាឱ្យទៅរស់នៅទីឆ្ងាយ អ្នកខ្លះនៅលើកោះ និងអ្នកខ្លះទៀតទៅជាយដែនតុងកឹងនៅជិតប្រទេសចិន។ ប្រជាជនកម្ពុជា បានដឹងអំពីបំណងអាក្រក់របស់អធិរាជអាណ្ណាម បានងើបបះបោរ និងបានសម្លាប់វង្គាលកងទ័ពអាណ្ណាម។ ពួកគេបានស្នើសុំឱ្យទូលព្រះបង្គំយាងចេញពីព្រះរាជាណាចក្រក្រុងទេព ដើម្បីសោយរាជ្យ(នៅកម្ពុជា)។*

[82] *ព្រះមហាក្សត្រព្រះបាទសាងក្លៃ ព្រះចៅយូហ្វរ បានបញ្ជាឱ្យ «ចៅពញា បឌិនតេជោ» ដែលជាមេទ័ពធំម្នាក់ ដើម្បីដឹកនាំកងទ័ព ដែលមានទាហាន ជាង៥ពាន់នាក់ ជាមួយកាំភ្លើងធំ កាំភ្លើងតូចអាវុធ គ្រាប់រំសេវ ក្រណាត់ របស់របរ ប្រាក់កាស មាស គឺជាទ្រព្យដ៏ច្រើនសម្បើម ដែលយកមកពីឃ្លាំងរបស់ព្រះអង្គ ដើម្បីជួយទូលព្រះបង្គំក្នុងការប្រយុទ្ធប្រឆាំងជាមួយពួកអាណ្ណាម។ សង្គ្រាមបានប្រព្រឹត្តិទៅអស់ ប្រហែល១៨ឆ្នាំនៅប្រទេសកម្ពុជា។ អធិរាជអាណ្ណាម បានស្នើចងសម្ព័ន្ធភាពជាមួយទូលព្រះបង្គំ ដោយយល់ព្រមធ្វើមាតុភូមិនិវត្តន៍នៃព្រះមាតាជាទីគោរពរបស់ទូលព្រះបង្គំព្រះរាជបុត្ររបស់ទូលព្រះបង្គំ ព្រះរាជបុត្ររបស់ព្រះរៀមជាទីគោរពរបស់ទូលព្រះបង្គំ និងនាហ្មឺន មន្ត្រីទាំងអស់ក៏ដូចជាប្រជាជនកម្ពុជា ដែលត្រូវបានគេនិរទេសឱ្យទៅរស់នៅលើកោះ និងស្រុកផ្សេងៗ។*

[83] *ស្តេចអាណ្ណាមបានទទួលស្គាល់ព្រះមហាក្សត្រនៃប្រទេសកម្ពុជា និងបានផ្ញើអំណោយនូវត្រាអាណ្ណាមពីរ មួយធំ មួយតូចដល់ទូលព្រះបង្គំ និងបានសន្យាប្រគល់មកឱ្យស្រុកខ្មែរវិញនូវទឹកដីកម្ពុជាទាំងអស់ដែលពួកអាណ្ណាមបានដណ្តើមយក។ សេនាបតី «ចៅពញាបឌិនតេជោ»បានទូលប្រាប់ទូលបង្គំថា ព្រះចៅសៀមបានព្រមព្រៀងទទួលយក(យុទ្ធ)សន្តិភាព។ ពីព្រោះថា ទូលព្រះបង្គំបានទទួលមកវិញនូវព្រះមាតាជាទីគោរពរបស់ទូលព្រះបង្គំនៅចុល្លសករាជ១២០៩ ឆ្នាំមមែ នព្វស័ក។ បន្ទាប់មក មិនគ្រាន់តែទឹកដីដែលអាណ្ណាមបានសន្យាប្រគល់មកឱ្យ(ប្រទេសកម្ពុជា)វិញ ហើយបែរជាមិនបានប្រគល់ឱ្យប៉ុណ្ណោះទេ, ប៉ុន្តែយើងបែរជាបានទទួលនូវការហាមឃាត់មិនឱ្យទទួលនូវស្នួយសារអាករពីរដ្ឋនៅក្នុងចំណុះ ហើយប្រជារាស្ត្រកម្ពុជា ដែលបានកសាងនាវាធ្វើពាណិជ្ជកម្មជាមួយបរទេសនោះ មិនត្រូវបានអនុញ្ញាតឱ្យធ្វើឡើយ។*

*បញ្ហាដែលកើតមាននៅប្រទេសកម្ពុជានេះ ព្រះករុណាអធិរាជបារាំងត្រូវព្រះតម្រិះអំពីការបង្កើតការត្រួតត្រារបស់អាណ្ណាម ដោយគ្រាន់តែជាការកាន់កាប់របៀបយ៉ាងស្ងប់ស្ងាត់ ២០០ឆ្នាំមកហើយ។ ស្រុកដែលពួកអាណ្ណាមយកធ្វើជារបស់ខ្លួននៅពេលក្រោយមកគឺ សេកុង លុងហោរ សាដែក ស្នឹជ័រ ចូវដុក ក្រមួនសរ អូម៉ុន ទឹកខ្មៅ ស្រុកពាម និងកោះត្រល់ កោះត្រឡាច។ អំណោះតទៅ ប្រសិនបើពួកអាណ្ណាមប្រគល់ឱ្យអធិរាជបារាំងនូវទឹកដីទាំងនេះ និងទឹកដីផ្សេងៗទៀតនោះ ទូលព្រះបង្គំសូមអង្វរ*

នៅឆ្នាំ១៨៥៦ ព្រះអង្គដួងបានស្នើសុំការអនុញ្ញាតពីស្តេចសៀម(មកុដ) ដើម្បីតែងតាំងព្រះអង្គម្ចាស់អង្គវតី (នរោត្តម ឬព្រះអង្គប្រឡឹង) ជាមហាឧបរាជ និងសុំឱ្យបុត្រាទី២របស់ទ្រង់ដែលជាអនាគតស្តេចស៊ីសុវត្ថិ ឡើងជាព្រះកែវហ្វា និងសុំឱ្យពួកព្រះអង្គទាំងនោះយាងត្រឡប់មកកម្ពុជាវិញ។ ស្តេចមកុដ ក៏យល់ព្រម។ គួរកត់សម្គាល់ថា ព្រះអង្គមិនបានបង្កើតតំណែង ឧភយោរាជ ឡើយ។ ប្រហែលព្រះបាទអង្គដួងចង់បំបាត់តំណែងនោះ ដែលពីពេលមុននោះ បានបង្កឱ្យមានបញ្ហាច្រើនកើតឡើង។

នៅឆ្នាំ១៨៥៨ ព្រះបាទអង្គដួងបានព្យាយាមទាក់ទងជាមួយបារាំងម្តងទៀត ពេលដែលពួកបារាំងកំពុងចាប់ធ្វើអន្តរាគមន៍នៅវៀតណាម ដើម្បីជួយអ្នកកាន់សាសនាគ្រីស្ត ។ ក្នុងឆ្នាំនោះដែរ មានចលនាបះបោរធំមួយរបស់ពួកចាម្ប និងជ្វានៅក្នុងស្រុកត្បូងឃ្មុំ។ មេដឹកនាំនោះមានឈ្មោះ ទួនហ៊ីម, ទួនស៊ី និងទួនអ៊ិត។ ព្រះអង្គដួង បានបង្ក្រាបពួកគេ និងបានសម្លាប់មេដឹកនាំម្នាក់ រីឯអ្នកផ្សេងទៀតក៏បានភៀសខ្លួនទៅវៀតណាមបាត់អស់ទៅ។ កងទ័ពខ្មែរ បានចូលលុកលុយដល់ដីកម្ពុជាក្រោម ដើម្បីដេញតាមចាប់ពួកឧទ្ទាមចាម្ប ហើយជនជាតិចាម្បស្ទើរតែទាំងអស់បានចាកចេញពីកម្ពុជានៅពេលនោះ។ ប្រហែលនៅពេលនោះទ័ពវៀតណាមនៅកម្ពុជាក្រោមនៅទន់ខ្សោយ ព្រោះបារាំងបានចាប់ផ្តើមវាយលុក ដាណាំង/Tourane នៅភាគខាងជើង។[84] ចំណែកពួកចាមនៅភាគខាងលិចទន្លេសាប ដែលមានភក្តីភាពចំពោះប្រមុខសាសនានាម អ៊ីមុំា សាន់ មិនបានចូលរួមក្នុងការបះបោរនោះទេ។ ដើម្បីសំដែងស្វាមីភ័ក្តិចំពោះព្រះបាទអង្គដួង អ៊ីមុំា សាន់បានថ្វាយខ្លួនជាចំណាប់ខ្មាំងរបស់ព្រះរាជា ទើបព្រះបាទអង្គដួង ប្រទានឲ្យគាត់ធ្វើវិហារនៅលើកំពូលភ្នំបរិនិព្វាននៃភ្នំព្រះរាជទ្រព្យ និងស្នាក់នៅទីនោះរហូតអស់ជីវិត។[85]

---

*ព្រះករុណាអធិរាជបារាំងសូមមេត្តាកុំព្រមទទួលឱ្យសោះ ពីព្រោះថា ទេសភូមិនេះ គឺពិតជាទឹកដីរបស់កម្ពុជា។ ផ្នែកដែលចេញពីត្រើយខាងលិចនៃទន្លេសេកុងរហូតដល់ពាម(ហាទៀន)ដោយរួមទាំងកោះពីផងនោះ ត្រូវតែស្ថិតនៅជារបស់កម្ពុជាដូចពេលមុន។ ចំណែកតំបន់ដែលស្ថិតនៅលើត្រើយខាងកើតទន្លេសេកុង ដែលពួកអាណ្ណាមបានកាន់កាប់ចាប់តាំងពីយូរមកហើយ ទូលព្រះបង្គំមិនតវ៉ាទាមទារទេ។*

*មូលហេតុដែលទូលព្រះបង្គំយកបញ្ហាទាំងនោះ ទូលថ្វាយព្រះករុណាអធិរាជបារាំងដើម្បីទ្រង់ជ្រាបដ៏ខ្ពង់ខ្ពស់នោះ គឺព្រោះតែទូលព្រះបង្គំមិនចង់ដោយសារតែទ្រព្យសម្បត្តិរបស់យើង ហើយត្រូវឱ្យយើងទទួលឈឺចាប់ថែមទៀតនោះទេ។ ដូច្នេះព្រះករុណាអធិរាជបារាំង និងទទួលបាននូវព្រះកិត្តិនាមល្បីល្បាញដ៏ពិតប្រាកដថា ជាមហាក្សត្រដែលមានទឹកព្រះទ័យទូលាយ និងដែលបានធ្វើការដើម្បីផលប្រយោជន៍របស់ប្រទេសផ្សេងៗទៀត ហើយប្រជាជនកម្ពុជានិងប្រជាជនបារាំងនឹងស្រឡាញ់គ្នា ហើយនឹងរក្សាឱ្យបានស្ថិតស្ថេរនូវទំនាក់ទំនងដ៏ល្អរបស់ប្រទេសយើងទាំងពីរ។*

*ធ្វើនៅព្រះបរមរាជវាំងឧដុង្គ និងប្រថាប់ត្រានៅថ្ងៃអង្គារ ខែកត្តិក ថ្ងៃ១៣រោជ ចុល្លសករាជ១២១៥ ឆ្នាំរោង អដ្ឋស័ក។*

*ផ្ញើទៅសាំងកាប៉ូ (សឹង្ហបុរី)*

*ព្រះករុណាទ្រង់ឡាយព្រះហស្តលេខា អង្គដួង*

<u>សេចក្តីបញ្ជាក់</u>៖ កាលបរិច្ឆេទខាងលើនៅខាងចុងនៃរាជសាររបស់ព្រះអង្គដួង មិនគួរជាឆ្នាំរោងទេ គួរតែជាឆ្នាំឆ្លូវ ត្រីស័ក ទើបត្រឹមត្រូវទៅតាមការគណនា។ ប៉ុន្តែយើងមិនដឹងថាយ៉ាងណាទេ ដោយសារយើងក៏មិនបានឃើញដោយផ្ទាល់នូវរាជសារព្រះបាទអង្គដួង ដែរ ដូច្នេះបានត្រឹមតែគណនាតាមខ្លឹមសារនេះ គឺត្រូវនឹងគ.ស.១៨៥៣ ប៉ុណ្ណោះ។

[84] សូមមើល, ម៉ៃឃើល វិកឃើរី, ២០០១-២, *ប្រវត្តិសាស្ត្រខ្មែរ,* សម្រាប់បង្រៀននៅមហាវិទ្យាល័យបុរាណវិទ្យា នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ។

[85] សូមមើល,អ៊ាន ហារីស,២០០៥, *ប្រវត្តិពុទ្ធសាសនាថេរវាទនៅកម្ពុជា,* ភាគទី១,គ្រឹះស្ថានបោះពុម្ពផ្សាយនគរវត្ត,ជំពូកទី២-ទី៣។

អ្វីដែលមានសារៈសំខាន់ក្នុងរជ្ជកាលព្រះបាទអង្គដួង គឺការកើតមានសន្តិភាពក្នុងប្រទេសជាលើកដំបូង ក្រោមរដ្ឋាភិបាលរួបរួមមួយ។ ប៉ុន្តែ ព្រះអង្គដួងនៅតែត្រូវគេបង្ខំឱ្យទទួលយកនូវក្រិត្យនយោបាយមួយចំនួន ក្រោមការគ្រប់គ្រងរបស់ប្រទេសយួន និងសៀម។ ទោះបីព្រះអង្គធ្វើសកម្មភាពដោយឯករាជ្យក្នុងប្រទេសក៏ដោយ ។

ព្រះអង្គដួង បានប្រឹងប្រែងពង្រីកពាណិជ្ជកម្មក្រៅប្រទេសឡើងវិញ ដែលមានកំពង់ផែសំខាន់នៅកំពត និងមានការកសាងផ្លូវមួយពីឧដុង្គទៅកំពត។ រូបិយប័ណ្ណកម្ពុជា ទម្រង់ជាកាក់បានបោះចេញឱ្យប្រើប្រាស់។ គេឃើញមានវិមជ្ឈការខ្លះ ក្នុងការដឹកនាំ។ ចំនួនខេត្តត្រូវបានកាត់បន្ថយ ហើយចៅហ្វាយខេត្តត្រូវបានដាក់ឱ្យនៅក្រោមរដ្ឋបាលរបស់ព្រះមហាក្សត្រច្រើនជាងមុន។

ការដែលព្រះបាទអង្គដួង បានទទួលលោក មូហូត៍ និងអ្នកដំណើរអឺរ៉ុបផ្សេងៗទៀតយ៉ាងរាក់ទាក់នៅពេលនោះ មកពីមិត្តភាពរបស់ព្រះអង្គជាមួយសាសនទូតបារាំងសែសជាសង្ឃរាជសាសនាកាតូលិក គឺ លោកម្ចាស់ (Mon Seigneur)ហ្សង់ក្លូដ មីស្ហ(*Jean-Claude Miche*)ដែលបានទ្រទ្រង់យ៉ាងសកម្មដល់បេសកកម្មការទូតនៅឆ្នាំ១៨៥៦។ ព្រោះ គាត់បានទូលព្រះបាទអង្គថា ការដកខ្លួនចេញពីអំណាចរបស់សៀម និងពីការគំរាមកំហែងរបស់យួន អាចមានផលប្រយោជន៍ច្រើន។ ថ្វីបើ ការទាក់ទងលើកទី១នោះបរាជ័យ និងត្រូវសៀមប្រមាថក៏ដោយ ក៏ព្រះអង្គនៅតែបន្តការទាក់ទងជាសម្ងាត់ជាមួយបារាំងតមកទៀតដែរ។ ក្នុងពីរឆ្នាំចុងក្រោយនៃរាជ្យរបស់ព្រះអង្គ ៗបានទ្រង់ព្រះតំរិះយល់ឃើញថា ការវាតទីរបស់បារាំងសែសចូលក្នុងទឹកដីយួន ជាឱកាសល្អមួយសម្រាប់ព្រះអង្គ ក្នុងការទាមទារទឹកដីខ្មែរដែលយួនដណ្តើមយកក្នុងរយៈពេលជាង២០០ឆ្នាំនោះ មកវិញបាន។

ដោយជាប់ផុងក្នុងសង្គ្រាមទ័ពព្រៃនៅប្រទេសអាណ្ណាម និងដោយភាពមិនច្បាស់លាស់ចំពោះការគាំទ្រពីទីក្រុងប៉ារីស រដ្ឋបាលបារាំងនៅព្រៃនគរមានការយឺតយ៉ាវក្នុងការឆ្លើយតបនឹងសំណើសុំចងស្ពានមេត្រីរបស់ខ្មែរ។ រឿងនេះបានថ្លោះធ្លោយម្តងទៀត នៅពេលដែលព្រះបាទអង្គឌួង សោយទីវង្គតនៅឆ្នាំ១៨៦០ និងនៅក្នុងពេលដែលប្រទេសកម្ពុជាធ្លាក់ចូលទៅក្នុងសង្គ្រាមរវាងគ្នាឯងជាបន្តបន្ទាប់។ បន្ទាប់ពីព្រះអង្គដួងទ្រង់សុគតទៅ សេនាបតីសព្វនាម៉ឺនមន្ត្រី និងព្រាហ្មណ៍បុរោហិតរួមទាំងរាជវង្សានុវង្ស បានយាងរាជបុត្រច្បង ព្រះនាមព្រះបាទ នរោត្តម ឱ្យសោយរាជ្យបន្តពីព្រះអង្គ ។

## 2. សន្ធិសញ្ញាអាណាព្យាបាល (១១សីហា១៨៦៣)

នៅមុនការចាកចេញពីកំពតទៅវិញរបស់ Montigny គាត់បានទុកគម្រោងសន្ធិសញ្ញាឱ្យបេសកបព្វជិតបារាំងពីររូប គឺលោក Hestrest និងម្នាក់ទៀត P-Aussoleil សេចក្តីព្រាងសន្ធិសញ្ញានេះមានចែងពីខផ្សេងៗ ក្នុងនោះមាននិយាយពីកិច្ចប្រតិបត្តិការ ដែលគេបានសម្រេចក្រោយមកនៅឆ្នាំ១៨៦៣។ ជាឧទាហរណ៍ បារាំងចង់បានឈើម៉ៃសាក់ ដើម្បីសង់កប៉ាល់ព្រមទាំងសេរីភាពក្នុងការធ្វើដំណើរក្នុងប្រទេស និងសេរីភាពក្នុងការផ្សព្វផ្សាយសាសនាកាតូលិក។ ហើយក្រោយការបរាជ័យខាងផ្លូវយោធា ក្នុងការប៉ុនប៉ងកាន់កាប់តំបន់យូណាន់ និងតំបន់ដីសណ្តទន្លេក្រហមរបស់តុងកឹងដ៏មានភោគទ្រព្យធម្មជាតិសំបូរហូរហៀរ បារាំងបានងាកមកផ្តោតការយកចិត្តទុកដាក់លើដងទន្លេមេគង្គ ដែលគេសង្ឃឹមថា អាចធ្វើដំណើរតាមជើងទឹកឡើងដល់យូណាន់ ឬចិនភាគខាងត្បូង និងនិរតីបានដោយងាយ។ ហេតុនោះហើយ ទើបបារាំងជំរុលការកាន់កាប់ស្រុកខ្មែរ ដើម្បីបម្រើគោលដៅនោះ។

សន្ធិសញ្ញាបារាំងខ្មែរចុះថ្ងៃទី១១ខែសីហាឆ្នាំ១៨៦៣ មានខ្លឹមសារជាសន្ធិសញ្ញាមិត្តភាព និងពាណិជ្ជកម្មរវាងភាគីទាំងពីរ និងបានបើកទ្វារឱ្យបារាំងចូលមកកម្ពុជាដោយស្របច្បាប់ជាលើកដំបូង។ សន្ធិសញ្ញានេះធ្វើឡើង

រវាងព្រះបាទ នរោត្តម និងឧត្តមនាវី ដឺឡាហ្គ្រង់ដឺយែរ(De La Grandière) ជាអគ្គទេសាភិបាលបារាំងនៅកូសាំងស៊ីន សន្ធិសញ្ញាធ្វើនៅរាជវាំងឧដុង្គមានជ័យដោយបារាំងសន្យាថា នឹងមានរ៉េស៊ីដង់(អធិបតី)បារាំងម្នាក់ នឹងផ្ដល់ការការពារដល់ព្រះអង្គ លុះត្រាតែព្រះអង្គទ្រង់អនុញ្ញាត និងផ្ដល់សិទ្ធិឱ្យបារាំងធ្វើអាជីវកម្មព្រៃឈើ និងយករ៉ែបាន។ សម្ដេចនរោត្តមបានចាត់ចែងលាក់ទុកសន្ធិសញ្ញានេះ មិនឱ្យអាមាត្យសៀមដឹងរឿងនេះអស់រយៈពេលជាច្រើនខែ។ នៅពេល ដែលពួកអាមាត្យសៀមបានដឹងរឿងនេះ ពួកគេបានរាយការណ៍ទៅក្រុងបាងកក។ ពេលនោះព្រះអង្គបានថ្លែងអះអាងឡើងវិញភ្លាមៗថា ព្រះអង្គស្ថិតនៅចំណុះព្រះចៅសៀម ដោយបញ្ជាក់ទៅអាមាត្យសៀមថា "សព្វព្រះទ័យនៅជាព្រះរាជបម្រើព្រះចៅសៀមរហូតអស់ជីវិត។ វាគ្មានអ្វីប្រែប្រួលទេ ក្នុងព្រះទ័យរបស់យើង"។ ចំណែក ពួកសៀមក៏បានលាក់ទុកការប្រែព្រះចិន្ដាបែបនេះជាការអាថ៌កំបាំង ជាពិសេសមិនឱ្យបារាំងដឹង។ ហើយបារាំងក៏បានដឹងពីរឿងនេះ បន្ទាប់ពីការប្រកាសអំពីភក្ដីភាពរបស់ព្រះអង្គចំពោះបារាំងបានចូលជាធរមាន នៅទីក្រុងប៉ារីស នាដើមឆ្នាំ១៨៦៤។

ទំនាក់ទំនងជាផ្លូវការរវាងបារាំង និងខ្មែរដែលនឹងឈានទៅរកអាណាព្យាបាល គឺចាប់ផ្ដើមឡើងតាមរយៈសន្ធិសញ្ញាថ្ងៃទី១១ សីហា ឆ្នាំ១៨៦៣ នេះហើយ។ តាមសន្ធិសញ្ញានេះ ប្រទេសបារាំងបានយល់ព្រមផ្ដល់នូវការការពារចំពោះប្រទេសកម្ពុជា ដើម្បីកុំឱ្យប្រទេសជិតខាងមកឈ្លានពានបាន។ បារាំងមានសមត្ថកិច្ចតែនយោបាយក្រៅប្រទេសទេ។ រីឯព្រះមហាក្សត្រខ្មែរ រក្សាអំណាចទាំងអស់ក្នុងផ្ទៃប្រទេស។ ត្បិតខ្លឹមសារនៃសន្ធិសញ្ញានេះ គឺជា" សន្ធិសញ្ញាមិត្តភាព និងពាណិជ្ជកម្ម" រវាងអធិរាជបារាំង និងស្ដេចកម្ពុជា ដែលតាមពិតពេលនោះ ព្រះអង្គ នៅមានឋានៈជាផ្លូវការត្រឹមតែជាព្រះមហាឧបរាជខ្មែរប៉ុណ្ណោះ។ សន្ធិសញ្ញានិយាយថា បារាំងបានយល់ព្រមប្ដូរសិទ្ធិគ្រប់គ្រងអធិបតេយ្យភាពរបស់គេលើប្រទេសកម្ពុជា ទៅជាអាណាព្យាបាលវិញ។ ខ្លឹមសារសន្ធិសញ្ញានេះភាគច្រើន និយាយអំពីសេរីភាពនៃការធ្វើពាណិជ្ជកម្ម ក៏ប៉ុន្តែក្នុងមាត្រាទី១ និយាយថា ប្រទេសបារាំងបានដាក់អាណាព្យាបាលលើកម្ពុជា។ ភាគីកម្ពុជា បានយល់ព្រមចំពោះការតែងតាំងទេសាភិបាលបារាំងម្នាក់ដោយទេសាភិបាលជាន់ខ្ពស់នៅកូសាំងស៊ីន ហើយទាំងអស់គ្នាសន្យាថា មិនអនុញ្ញាតឱ្យប្រទេសផ្សេងទៀតបញ្ជូនកុងស៊ុលមកកម្ពុជាទេ។

ក្នុងពេលនោះ បារាំងចាប់អារម្មណ៍លើកម្ពុជា ដែលជាប្រភពចំណីអាហារសម្រាប់អាណានិគមរបស់គេនៅកូសាំងស៊ីន ហើយគេក៏សង្ឃឹមដែរថា ទន្លេមេគង្គអាចជាផ្លូវពាណិជ្ជកម្មល្អមួយសម្រាប់នាវាឆ្ពោះទៅប្រទេសចិន (Vickery, 2001-02, 247-248) ដែលគេធ្លាប់បរាជ័យក្នុងការប្រើកម្លាំងយោធា ដើម្បីដណ្ដើមយកទីនោះ និងប្រកចូលតាមដងទន្លេក្រហមរបស់យួនតុងកឹងម្ដងរួចមកហើយ។

ក្រោយពីលាក់ព្រឹត្តិការណ៍ដ៏សំខាន់នេះលែងជិត សម្ដេចនរោត្តម មានការភិតភ័យកោលាហលជាខ្លាំងដោយសារការគំរាមកំហែង និងគំនាបពីស្ដេចសៀម។ ព្រះអង្គបានសន្យាជាមួយស្ដេចសៀម ថានៅតែមានភក្ដីភាពចំពោះគេ និងដាក់ប្រទេសកម្ពុជាជាសាមន្តរដ្ឋរបស់សៀម ព្រមទាំងចុះសន្ធិសញ្ញាជាសម្ងាត់នៅថ្ងៃទី០១ធ្នូ១៨៦៣ ទទួលស្គាល់ទឹកដីខេត្តបាត់ដំបង, មង្គលបុរី, ស៊ីសុផុន, អង្គរ, កំពង់ស្វាយ និងពោធិ៍សាត់ ថាជាទឹកដីរបស់សៀមដោយស្របច្បាប់។

អ្វីដែលសម្ដេច នរោត្តម ទ្រង់មានព្រះបំណងចង់បានពីបារាំង ដើម្បីទប់ទល់នឹងសៀមនោះ គឺមិនច្បាស់លាស់ទេ។ ប្រហែលជាព្រះអង្គទ្រង់មានព្រះបំណងចង់ឱ្យគេធ្វើរាជាភិសេកផ្លូវការថ្វាយទ្រង់។ ទើបគេឃើញនៅពាក់កណ្ដាលឆ្នាំ១៨៦៤ សៀម និងបារាំងសែស ក្រោយពីចរចាគ្នាយ៉ាងតឹងតែង ក៏បាននាំគ្នាយល់ព្រមជានាអភិសេកទ្រង់ឱ្យឡើងសោយរាជ្យជាផ្លូវការ។ ទើបសៀមប្រញាប់ប្រញាល់បញ្ជូនកេតនភ័ណ្ឌទាំងអស់សម្រាប់ព្រះអង្គសោយ

រាជ្យមកឧដុង្គវិញ។ នៅពេលធ្វើរាជាភិសេកនេះ នៅថ្ងៃទី០៣មិថុនា១៨៦៤ កើតរឿងកំប្លែងដោយអចេតនាមួយ ដូចមានរៀបរាប់នៅក្នុងឯកសារបារាំងសេសជាច្រើន ដូចតទៅនេះ៖ មន្ត្រីសៀម និងមន្ត្រីបារាំង បានឈ្លោះទាស់ទែងគ្នាអំពីរាជបវេណី ពិធីការ និងគ្រឿងរាជាភិសេក។ រីឯព្រះបាទនរោត្តម នៅពេលជាមួយគ្នានោះ ទ្រង់បានប្រកាសចុះចូលរាជវាំងទាំងសងខាងនោះ ដោយមានព្រះរាជបន្ទូលថា "ទុកព្រះអង្គដូចជាកូនរបស់សៀម និងបារាំងសែសទៅចុះ"។ ពេលនោះ គឺជាលើកចុងក្រោយបំផុត ដែលមានព្រះចៅសៀមបានប្រោសព្រះរាជទានរាជទិន្នន៍នាមដល់ព្រះរាជាខ្មែរ ហើយក៏ជាលើកចុងក្រោយបំផុត ដែលព្រះរាជាខ្មែរទទួលបានភាពស្របច្បាប់ពីរាជវាំងបរទេសទាំងពីរ។ ទន្ទឹមនឹងនេះ វាក៏ជាលើកទី១ដែរ ដែលព្រះរាជាខ្មែរបានទទួលរាជាភិសេកពីជនជាតិអឺរ៉ុប។ ព្រះរាជាខ្មែរបីព្រះអង្គបន្ទាប់មកទៀត ក៏ធ្វើដូចគ្នានេះដែរ។ ពីពេលនោះមកឥទ្ធិពលរបស់សៀមលើប្រទេសកម្ពុជាបានចាប់ផ្តើមចុះអន់ថយ សាបរលាប និងកាន់តែខ្សោយទៅៗ ជាពិសេស បន្ទាប់ពីព្រះចៅសៀម ព្រះចមក្លាវ(ព្រះមកុដ) សោយទិវង្គតក្នុងឆ្នាំ១៨៦៧នោះមក។

### 3. ដំណើរពីអាណាព្យាបាល ទៅជាអាណានិគម និងការបាត់បង់អំណាចរបស់ព្រះរាជាខ្មែរ

តាមការកត់សម្គាល់របស់បារាំងមួយចំនួន អំពីប្រទេស និងជនជាតិខ្មែរ ថា ៖ ជាប្រទេសមួយដ៏ចាស់គំរឹល, ហិនហោច ទ្រុឌទ្រោម ដោយសារសង្គ្រាម និងអំពើបង្ខិនបង្ខោចជិះជាន់ពីប្រទេសជិតខាងរងនូវភាពទ្រុឌទ្រោមរាប់សតវត្សរ៍មកហើយ, ខ្មែរជាពូជដែលចាញ់គេ-ចាញ់ធម្មជាតិ-ចាញ់មនុស្ស-ចាញ់ខ្លួនឯង, ជាសង្គមនៃមនុស្សដែលរស់នៅដោយការខ្លាចភិតភ័យនៅក្នុងអន្លង់អវិជ្ជា, មានជំនឿផ្តេសផ្តាសអកុសលឥតហេតុផល។ បើតាមសៀវភៅ "ឥណ្ឌូចិនបារាំង" បោះពុម្ពផ្សាយពីឆ្នាំ១៩០០ អ្នកនិពន្ធបានកត់សម្គាល់ថា ៖

- ប្រជាជនកម្ពុជាទំនងជាខ្លាំងជាងប្រជាជនវៀតណាមខាងកម្លាំងកាយមែន
- តែខ្វះសមត្ថភាព, គ្មានគំនិតខ្លួនឯង, ពឹងផ្អែកតែលើអ្នកដទៃ
- ជាជនជាតិល្ងង់ខ្លៅ-ឥតតម្រិះវិជ្ជា-ឥតប្រាជ្ញា ធ្វើអ្វីៗតាមគេទាំងស្រុង ឥតមានការត្រិះរិះពិចារណាសោះឡើយ។ ដោយផ្ទុយទៅវិញ នៅវៀតណាម ជនជាតិវៀតណាម ទោះជាក្រីក្រយ៉ាងណាក្តី ទោះជាគ្រួសារធំតូចក្តី ក៏នៅតែមានការអប់រំស្ទើរទាំងអស់គ្នា។
- ខាងផ្លូវចិត្តវិញ ខ្មែរខ្វះសាមគ្គី ឥតមានមនសិកាជាតិសោះ ឥតទាំងយល់ថា មាតុភូមិជាអ្វីផង?
- ជាសរុបជនជាតិខ្មែរអន់ជាងជនជាតិវៀតណាមយ៉ាងឆ្ងាយគ្រប់វិស័យ សូម្បីប្រាក់ចំណូលមែនទែនរបស់ស្តេចខ្មែរ ក៏សុទ្ធតែបានពីការយកគុងលើល្បែងស៊ីសង ដែលជនជាតិឯទៀតជាអ្នកកាន់កាប់ ហើយពាណិជ្ជកម្មប្រទេសទាំងមូល ក៏នៅក្នុងកណ្តាប់ដៃជនបរទេស គឺ៖ ចិន-ចាម-ជ្វា,យួន...)។

មានការរិះគន់អំពីចរិតខ្មែរ នៅក្នុងសៀវភៅ "ទំនៀមទម្លាប់ខ្មែរ" ដែលបោះពុម្ពផ្សាយពីឆ្នាំ១៩៣៨ អ្នកនិពន្ធបានកត់ត្រាទុកថា៖

- ជនជាតិខ្មែរទាំងឡាយដែលអួតថាខ្លួនជាអ្នកចេះដឹងនោះ ច្រើនតែមិនសូវមានប្រាជ្ញាឈ្លាសវៃ មិនសូវមានចំណេះអ្វីប្រាកដទេ
- ឥតរវល់យល់យកចិត្តទុកដាក់អ្វីទាំងអស់ក្នុងកិច្ចការសង្គម
- ពូកែខាងវាយឫកថា ខ្លួនជាពូជខ្មែរអង្គរនៅចំពោះមុខជនជាតិអឺរ៉ុប
- ធ្វើតាមជនជាតិអឺរ៉ុបតាំងពីឫកពាររហូតការរស់នៅប្រចាំថ្ងៃ ដើម្បីឱ្យអ្នកនៅក្រោមបង្គាប់ខ្លបខ្លាច។

- ពួកនេះសុទ្ធសឹងជាអ្នកសុខចិត្តរស់នៅក្រោមម្លប់បារមីនៃអ្នកមានអំណាចដូចជាអាទិទេពដែលគ្រប់គ្រងសង្គមខ្មែរ។
- រីឯនៅបាតសង្គមវិញ សុទ្ធតែជារាស្ត្រល្ងង់ខ្លៅ ក្រីក្រតោកយ៉ាក មានមុខរបរជាអ្នកស្រែចម្ការតូចតាច រស់នៅក្នុងពិភពមួយ ពោរពេញទៅដោយជំនឿផ្តេសផ្តាសអកុសល ប្រាសចាកហេតុផលគ្មានការពិត ចូលចិត្តជឿទៅលើអច្ឆរិយវត្ថុ, អារក្ស, អ្នកតា, មន្តគាថា អាគមឱមអាម។ល។
- ដូចនេះជនជាតិខ្មែរ ជាមនុស្សដែលគេស្រណុកបញ្ឆោត ហើយគ្មានប្រតិកម្មអ្វីឡើយ ។

នៅក្នុងសៀវភៅមួយទៀត ឈ្មោះ "ឥណ្ឌូចិនបារាំងសែស" ដែលបោះពុម្ពផ្សាយនៅឆ្នាំ ១៩០៥និពន្ធដោយលោកប៉ូល ឌូមែរ*(Paul Doumer)* អ្នកនិពន្ធបានសរសេររិះគន់ត្មះតិះដៀលប្រជាជនខ្មែរដោយត្រង់ៗថា៖

- តើសាសន៍ខ្មែរនៅមានសេសសល់ទេ ?
- តើសាសន៍នេះបានដឹងពីភាពចុះអាប់ឱនរបស់ខ្លួនទេ ?
- តើជនានុជននៅកម្ពុជាសព្វថ្ងៃ ជាជនជាតិសៀមដែលជាកូនចៅរបស់ខ្លួនឬអ្វី?
- ឆ្លើយថា មិនមែនទេ ព្រោះថាសាសន៍ឈ្នះ គេមិនត្រឹមដឹកជញ្ជូនទ្រព្យសម្បត្តិរបស់សាសន៍ចាញ់តែប៉ុណ្ណោះទេ គឺគេថែមទាំងកំទេចសាសន៍ចាញ់ចេញពីបញ្ជីមនុស្សរស់ទៀតផង។
- មានភស្តុតាងយ៉ាងច្បាស់ ត្បិតនៅក្នុងបណ្តាជនកម្ពុជា ឥតមានសល់ប្រពៃណី ឬអនុស្សាវរីយ៍អ្វី១ជារបស់សាសន៍ខ្មែរឡើយ។
- យើងជាបារាំង បានឃើញសាសន៍នេះ ឈរមើលជាទស្សនិកជនព្រងើយកន្តើយ មុខអច្ឆរិយភាពនៃស្ថាបត្យកម្មដ៏អស្ចារ្យ ឥតដឹង ឥតយល់នូវអក្សរចារឹកលើផ្ទាំងសិលានៃប្រាសាទដ៏ធ្មើមទាំងឡាយដែលនៅក្នុងប្រទេសកម្ពុជា។ ពួកគេ ក៏ជាជនបរទេសដូចពួកយើងដែរ នៅចំពោះមុខមនុស្សដែលរស់នៅទីនោះពីមុខខ្លួន ក្នុងជីវភាពមួយដ៏រុងរឿងខ្ពង់ខ្ពស់បំផុត ដែលឥតមានប្រជាជាតិណាមួយ ឬស្ទើរតែគ្មានបុគ្គលណាម្នាក់ហ៊ានអួតអាងថាខ្លួនជាពូជសាសន៍ខ្មែរនោះឡើយ។
- ករណីសាសន៍ខ្មែរនៅអាស៊ី មិនខុសពីករណីនៃសាសន៍ក្រិចរ៉ូម៉ាំងនៅអឺរ៉ុបសោះឡើយ
- <u>Paul Doumer</u>កត់ត្រាទៀតថា "សេចក្តីស្លាប់បានផ្តាច់ជីវិតមនុស្សទាំងឡាយ ក្នុងពេលដែលខ្លួនបានផ្តាច់ជីវិតប្រជាជាតិទាំងឡាយក៏ពិតមែនហើយ តែមានអព្ភូតហេតុទី៣កើតឡើង នៅទីឆ្ងាយដាច់ស្រយ៉ាលក្នុងកម្ពុជាដែលកប់បាត់ក្នុងព្រៃស្រោងដ៏ជ្រៅធំធេងចូលមិនចុះ ដែលមានបណ្តាជនរស់នៅជាសាសន៍មួយ ខុសប្លែកពីសាសន៍មនុស្សម្នាដែលរស់នៅកម្ពុជា ហើយនិយាយភាសាប្រាសាទបុរាណលែងពិរោះអស់ហើយ រយីករយាកអស់ហើយ ប៉ុន្តែគេអាចសម្គាល់បានភ្លាមថា តើក្នុងចំណោមមនុស្សមួយក្រុមតូចនេះ មានខ្មែរដ៏ឧត្តមជាបុព្វការីឬទេ? ទំនងជាមាន១ ឬ២គ្រួសារក៏មិនដឹង ដែលបានគេចផុតពីអំពើសម្លាប់រង្គាល និងការបំផ្លិចបំផ្លាញ ដែលបានកើតឡើងកាលពី ៥ ឬ៦សតវត្សរ៍កន្លងទៅនោះ ហើយមានជីវិតរស់នៅ បន្ទាប់ពីគេចខ្លួនទៅរស់នៅក្នុងតំបន់ព្រៃភ្នំដាច់ស្រយ៉ាល បន្តពូជរៀងរហូតមក ក្នុងភាពក្រីក្រលំបាកតោកយ៉ាក ក្នុងភាពអាប់ឱន និងភ័យខ្លាចជានិរន្តរ៍រហូតមក។ តើមនុស្សរហេមរហាមក្រុ◌ុមនោះ ជាកូនចៅអ្នកចម្បាំងដ៏ធ្មើមឬ ? ជាកូនចៅអ្នកសិល្បៈដ៏ឧត្តម ឬក៏ជាកូនចៅវិស្វករដ៏មហិមានៃរាជាណាចក្រដែលរលត់រលាយបាត់ទៅនោះឬ ? ការសន្និដ្ឋាននេះ អាចជាសេចក្តីពិតដែរ ហើយបើដូច្នេះមែន។
- ព្រលឹងឱពុកម្តាយជីដូនជីតាខ្លួនដែលប្រមើលមើលកូនចៅពីស្ថានសួគ៌នៃព្រះពុទ្ធនោះ មិនដឹងជាឈឺចាប់ក្នុងខ្លួនគាត់យ៉ាងណាទេ! ច្បាស់ជាគាត់ចង់ឱ្យអំពើសម្លាប់រង្គាលដែលបានផ្តាច់ជីវិតគាត់ក្នុងសម័យនោះកុំទុកកូនចៅគាត់ឱ្យសល់ម្នាក់ ជាជាងទុកឱ្យសល់លើទឹកដីនេះ នូវអនុស្សាវរីយ៍ដ៏ខ្លោចផ្សារបស់គាត់ និងដំបូន្មានរបៀបនេះ ដល់ប្រជាជនទាំងឡាយដែលបានបោះបង់ខ្លួនចោល"។

ក្នុងតួនាទីជាអ្នកការពារ ឬអាណាព្យាបាលលើកម្ពុជាអស់២១ឆ្នាំយ៉ាងអន្ទះសារ និងគិតថាខាតពេលទើប ទេសាភិបាលបារាំងនៅកូសាំងស៊ីន ឈ្មោះ Charles Thompson ចាត់ការបង្ខំឱ្យព្រះបាទនរោត្តមឱ្យឡាយព្រះហស្ត លេខាទាំងយប់ លើអនុសញ្ញា ថ្ងៃទី១៧ មិថុនា ១៨៨៤ ដែលជាអនុសញ្ញាមិនស្មើភាពគ្នាព្រោះខ្លឹមសាររបស់វាបាន ដករាជអំណាច និងសិទ្ធិគ្រប់គ្រងរាជការខ្មែរទាំងអស់។ នៅក្នុងរាជវាំងព្រះបាទនរោត្តម ទ្រង់គ្រប់គ្រងប្រទេសទៅ តាមរបៀបម្យ៉ាង ដែលតាមយោបល់របស់បារាំងសែសថា ជារបៀបគ្រប់គ្រងតាមអំពើចិត្ត និងអំណាចផ្តាច់ការ។ ទោះជាបារាំងបានរិះគន់របបគ្រប់គ្រងនេះក៏ដោយ ក៏ពួកគេមិនបានថ្វាយរបៀបគ្រប់គ្រងផ្សេងទៀតដល់ព្រះអង្គ ឡើយ ហើយពេញមួយរាជ្យរបស់ព្រះបាទនរោត្តម អាទិភាពនៃព្រះអង្គពុំមែនជាគំនិតបង្កើតរដ្ឋបាលយ៉ាងត្រឹមត្រូវ ទេ។

នៅក្នុងដំណាក់កាលដំបូងនៃភាពជាអាណាព្យាបាលលើប្រទេសកម្ពុជា បារាំងបានទាញយក ផលប្រយោជន៍សេដ្ឋកិច្ចពីធនធានធម្មជាតិរបស់ខ្មែរ និងផលប្រយោជន៍ខាងពាណិជ្ជកម្មតែប៉ុណ្ណោះ។ ប៉ុន្តែ បើតាម លោកដេវីឌ ឆាណ្ឌល័រថា នៅពេលក្រោយមក រូបភាពអាណាព្យាបាលនេះបានប្រែក្លាយបន្តិចម្តងៗមកជាទម្រង់នៃ របបអាណានិគមទៅវិញ។ លោកថា ចាប់ពីរាជ្យព្រះបាទ ស៊ីសុវត្ថិ ដែលសោយរាជ្យឆ្នាំ១៩០៤-១៩២៧ រួមបញ្ចូល ទាំងរជ្ជកាលនៃព្រះរាជបុត្រច្បងរបស់ព្រះអង្គ គឺព្រះបាទស៊ីសុវត្ថិ មុនីវង្ស ពីឆ្នាំ១៩២៧-១៩៤១ គេអាចចាត់ទុក បានជាសម័យអាណានិគមយ៉ាងពេញទីនៅក្នុងប្រវត្តិសាស្ត្រខ្មែរ។ ព្រោះបារាំងសែស បានក្តោបក្តាប់ការត្រួតត្រា កម្ពុជាយ៉ាងណែនក្នុងកណ្តាប់ដៃ និងសម្រេចធ្វើអ្វីៗស្រេចតែនឹងអំពើចិត្ត ដើម្បីផលប្រយោជន៍របស់ខ្លួន។ ចំណែក ពេលវេលាដែលនៅសល់ មុនបរាជ័យឆ្នាំ១៩៤៥ និងការត្រឡប់មកវិញភ្លាមនៅចុងឆ្នាំដដែល គឺចាប់ពីឆ្នាំ១៩៤១ ហូតដល់១៩៥៣ បារាំងបានព្រួយបារម្ភតែចំពោះការក្តាប់អំណាចជាជាងការរៀបចំរចនាសម្ព័ន្ធអាណានិគម។

នៅមុនបារាំងមកដល់ មហាក្សត្រមានអំណាចយ៉ាងច្រើន ទាំងអំណាចក្នុងការតាក់តែងច្បាប់ និងសណ្តាប់ ធ្នាប់របៀបរៀបរយសង្គម ជាដើម។ ដីធ្លីទាំងអស់ជារបស់ព្រះរាជា រាស្ត្រដែលធ្វើកសិកម្មលើដីធ្លីទាំងនោះ ត្រូវបង់ពន្ធ ជារជូនរាជការ។ តែឆ្លងតាមបទពិសោធន៍មួយរយៈពេលក្នុងរាជវាំងជាមួយស្តេចខ្មែរ អ្នកតំណាងអាណានិគម ហាក់ កាន់តែមានគំនិតលោភលន់ខ្លាំង ដោយឃើញភាពមិនសូវឈ្លាសវៃរបស់ខ្មែរជាពិសេស ការមិនអើពើរបស់អ្នកដឹកនាំ ក្នុងការប្រើប្រាស់ឱកាសសំខាន់ៗ ដើម្បីឱ្យបារាំងជួយគិតគូរ លើកផែនការអភិវឌ្ឍន៍ស្រុករបស់ខ្លួន។ ហេតុនេះហើយ ទើបបារាំងកើតគំនិតច្បាមយកអំណាចពីស្តេចខ្មែរឱ្យអស់ ដើម្បីគេងាយនឹងចម្រាញ់យកផលប្រយោជន៍ពីប្រទេស កម្ពុជា ឱ្យបានកាន់តែច្រើនឡើង។ ទើបប្រមាណ២០ឆ្នាំក្រោយពីភាពស្ងប់ស្ងាត់នៃទំនាក់ទំនងបារាំង-ខ្មែរ ទេសាភិបាលបារាំងនៅកូសាំងស៊ីន បានរៀបចំផែនការបង្ខំព្រះបាទនរោត្តម ឱ្យចុះហត្ថលេខា លើអនុសញ្ញាបន្ថែម មួយ ដើម្បីឱ្យដកអំណាចជាច្រើនផ្នែកទៀតពីស្តេចផ្ទាល់តែម្តង។

ដោយសារអនុសញ្ញានៅថ្ងៃ១៧ មិថុនា ឆ្នាំ១៨៨៤ នោះ ព្រះបាទ នរោត្តម យល់ព្រមបង្វែរពន្ធដារផ្សេងៗ ពិសេសលើការនាំចេញ ដើម្បីសងថ្លៃបំពេញកិច្ចការងាររបស់ភ្នាក់ងារបារាំង។ អនុសញ្ញានេះបានដកសិទ្ធិរបស់ស្តេច ទើបត្រូវប្រវត្តិវិទូ ចាត់ទុកថាជាដំណាក់កាលបត់ប្រវត្តិសាស្ត្រមួយដែលកែប្រែតួនាទីរបស់បារាំងពីភាពជា"អាណា ព្យាបាល" មកជា"អាណានិគម"វិញ។ ព្រះបាទនរោត្តម បានផ្ញើសារទូរលេខមួយទៅកាន់ប្រធានាធិបតីបារាំង ដើម្បី ប្រកែកនឹងការគាបសង្កត់របស់បារាំង តែព្រះអង្គត្រូវ Gouverneur de Conchin-Chine ទេសាភិបាលដែនដីកូសាំង ស៊ីន គឺលោក សាល ថមសុន ស្តីបន្ទោសអំពីរឿងនេះ។ គាត់ប្រហែលជាបានចរចាស្ទាត់ជាមួយនឹងសម្តេចព្រះមហា ឧបរាជស៊ីសុវត្ថិ ដើម្បីរៀបចំការផ្ទេរអំណាច បើសិនព្រះបាទនរោត្តម បដិសេធមិនធ្វើកំណែទម្រង់អំណាច។

ក្នុងអនុសញ្ញានេះ ព្រះអង្គបានសន្យាទទួលនូវរាល់កំណែទម្រង់ទាំងអស់ដែលបារាំងស្នើឡើង។ ព្រះអង្គបានសន្យាបញ្ចប់"ទាសភាព និងកែទម្រង់ដីធ្លី ពីដីទាំងអស់ជារបស់ស្តេច ទៅជារបបកម្មសិទ្ធិឯកជន"ផងដែរ។ ចំនួនមន្ត្រីបារាំងបានកើនឡើង ដោយមានរេស៊ីដង់ជាន់ខ្ពស់នៅក្រុងភ្នំពេញ និងមានរេស៊ីដង់នៅគ្រប់ខេត្ត។ ហេតុផលមួយដែលនាំឱ្យព្រះបាទនរោត្តមយល់ព្រមចុះហត្ថលេខានោះ គឺព្រះអង្គភ័យខ្លាចក្រែងបារាំងដកទ្រង់ពីបល្ល័ង្ក ហើយដាក់ព្រះអនុជទ្រង់ គឺព្រះអង្គម្ចាស់ស៊ីសុវត្ថិឱ្យគ្រងរាជ្យជំនួសវិញ។ ព្រោះថាជារឿយៗព្រះអង្គម្ចាស់ស៊ីសុវត្ថិតែងគាំទ្របារាំង និងធ្វើតាមសំណូមពរបារាំង។

តាមរយៈរាជប្បញ្ញត្តិ ចុះថ្ងៃទី១១ កក្កដា ១៨៩៧ ព្រះរាជាខ្មែរលែងមានអំណាចនយោបាយ នៅសល់តែអំណាចជានិមិត្តរូបប៉ុណ្ណោះ។ ហើយនេះគឺជាការចាប់ផ្តើមនូវរបបអាណានិគមពិតប្រាកដរបស់បារាំងមកលើប្រទេសកម្ពុជា។ ចាប់ពីពេលនោះមកព្រះរាជាខ្មែរ បាត់អំណាចនីតិប្បញ្ញត្តិ ដែលពីមុនធ្លាប់មាន ហើយរ៉េស៊ីដង់ជាន់ខ្ពស់(Résident Supérieur)បារាំង ជាអ្នកកាន់អំណាចពិតប្រាកដ។

## 4. ការបះបោរ និងចលនាប្រឆាំងបារាំង

កាលពីឆ្នាំ១៨៦១ព្រះអនុជពៅរបស់នរោត្តមព្រះនាមស៊ីវត្ថា និងម្ចាស់មារបស់ទ្រង់ស៊ីវត្ថា នាមសិរីវ៉ស បានឱ្យឈ្មោះស្នងសូរ និងមនោកែវ ជាមន្ត្រីជំនិតដែលមានថ្វីដៃល្អ បំបះបំបោរសាស្ត្រ និងកាន់កាប់ភាគខាងជើងកម្ពុជាស្ទើរតែទាំងអស់។ ការបះបោរនេះបន្តរហូតដល់ស្តេចស៊ីវត្ថាសោយទិវង្គតក្នុងឆ្នាំ១៨៩១។ មូលហេតុនៃការបះបោរនេះ គេពុំដឹងច្បាស់ទេថា ជាហេតុផលនយោបាយ ឬក៏បញ្ហាបុគ្គលផ្ទាល់ខ្លួន។ មានឯកសារមួយ បានអះអាងថា ព្រះអង្គម្ចាស់ស៊ីវត្ថាប្រកាន់យកបុគ្គលភាពរបស់ខ្លួន ដែលជាអ្នកចេះដឹងភាសាខ្មែរ និងប្រពៃណីខ្មែរបានជ្រៅជ្រះជាងព្រះអង្គច្រឡឹង ដែលនិយមនិយាយភាសាសៀមជាជាងខ្មែរ។ ព្រះអង្គគិតថា រាជសម្បត្តិគួរតែបានមកអ្នកណាមានសមត្ថភាពជាង និងចេះស្គាល់ខ្មែរបានល្អច្បាស់ជាងគេដូចរូបព្រះអង្គ។ ជាការពិតនៅពេលមនុស្សដែលចូលគាល់ព្រះអង្គ ព្រះបាទនរោត្តម តែងតែនិយាយសៀមជាមុន ទើបនិយាយខ្មែរជាក្រោយប្រសិនបើដឹងថា អ្នកនោះឯងមិនចេះនិយាយសៀម។ ខុសពីស៊ីវត្ថាដែលជានិច្ចកាល មានវោហារថ្វីមាត់ជាភាសាខ្មែរបានក្បោះក្បាយជាង។ ពេលដែលការបះបោរចាប់ផ្តើមព្រះបាទ នរោត្តមបានភៀសព្រះកាយទៅបាងកក តែបានត្រឡប់មកវិញជាមួយកងការពារជាតិសៀមក្នុងឆ្នាំ១៨៦២ ដោយមិនបានទទួលការអនុញ្ញាតឱ្យយកគ្រឿងប្រដាប់សម្រាប់សោយរាជ្យ ដែលព្រះអង្គបាននាំទៅជាមួយនោះ មកវិញឡើយ។ ការបះបោររបស់អ្នកអង្គម្ចាស់ស៊ីវត្ថា បានអូសបន្លាយពេលយ៉ាងយូរ។

ការបះបោរផ្សេងទៀតក្នុងឆ្នាំ១៨៦៤ នៅខាងត្បូងក្បែរបាភ្នំ ទ្រាំង និងព្រំប្រទល់វៀតណាម បានចាត់ចែងឡើងដោយបុរសម្នាក់ឈ្មោះ អាចារ្យសួរ ដែលគេហៅដោយទ្រគោះថា អាចារ្យស្វា ឬអាស្វា។គាត់បានអះអាងថា គាត់ជាក្មួយរបស់ព្រះបាទអង្គដួង បុត្រាព្រះអង្គភិម។ តែមានឯកសារខ្លះ ថាគាត់បានបញ្ឆោតគេថា ជាព្រះអង្គភិម បងប្រុសរបស់អង្គឌួងទៅវិញ។ គាត់បានត្រួតត្រាតំបន់ភាគច្រើននៅខាងត្បូងអស់ប៉ុន្មានឆ្នាំ រហូតដល់គាត់ត្រូវបារាំងចាប់នៅឆ្នាំ១៨៦៦។ ទោះជាយ៉ាងណា ជោគវាសនាចុងក្រោយរបស់មេបះបោររូបនេះ មានប្រភពជាច្រើន ដែលបានអះអាងខុសៗពីគ្នា ដែលយើងមិនអាចជឿបានថា មួយណាជាការពិតបាន។

មានការបះបោរសំខាន់មួយទៀតនៅភាគខាងកើត ដែលដឹកនាំដោយលោកពោធិកំបោរ គាត់ក៏បានអះអាងថា មានដើមកំណើតចេញពីគ្រួសាររាជវង្សដែរ ដោយត្រូវជាចៅរបស់ព្រះអង្គចន្ទ។ គាត់លេចមុខដំបូង និងជួបបារាំងនៅសៃហ្គនក្នុងឆ្នាំ១៨៦៥ រួចត្រឡប់មកកម្ពុជា និងបានចាប់ផ្តើមសកម្មភាពប្រឆាំងនឹងបារាំង និងប្រឆាំងនឹងអាជ្ញាធរកម្ពុជា។ ចលនាបះបោររបស់គាត់ចាប់ផ្តើមចេញដំណើរពីខេត្តរោងដំរី ឬខេត្តតៃនិញរបស់វៀតណាមសព្វថ្ងៃ។

ដោយសារមានថ្វីដៃយ៉ាងល្អខាងគុណដាវ កាប់ចាក់ គាត់បានជោគជ័យជាហូរហែ វាយសំរុកដល់ក្រុងឧដុង្គ។ ក្រោយពីរាជការ និងទ័ពបារាំងវាយរុញច្រានរហូតដល់ខេត្តកំពង់ស្វាយ-កំពង់ធំ គាត់ត្រូវអ្នកស្រុកចាប់ខ្លួនបានក្នុងឆ្នាំ១៨៦៧ ហើយក៏សម្លាប់គាត់ចោលទៅ។ ចំពោះជោគវាសនារបស់មេបះបោររូបនេះម្នាក់ទៀត ក៏យើងមិនអាចដឹងបានដែរថា តើប្រភពណាមួយត្រឹមត្រូវពិតប្រាកដ។

ក្រោយសន្ធិសញ្ញា១៨៨៤ មានចលនាបដិវត្តន៍ខ្លាំងក្លាកើតឡើងនៅទូទាំងប្រទេសកម្ពុជាចាប់ពីខែវិច្ឆិកាមក ដើម្បីឆ្លើយតបនឹងការដកអំណាចអស់ពីព្រះរាជា។ មកដល់ខែមករា១៨៨៧ គឺអស់រយៈពេលជាងពីរឆ្នាំ ប្រជាជនកម្ពុជាដឹកនាំដោយចៅហ្វាយខេត្ត និងចៅហ្វាយស្រុកបានវាយប្រឆាំងនឹងបារាំងតែមិនបានជោគជ័យ។ ទាហានបារាំងរាប់ពាន់នាក់ស្លាប់ក្នុងការប្រយុទ្ធប្រឆាំងនេះ ទីបញ្ចប់បារាំងដឹងថា ព្រះបាទនរោត្តមបានជំរុញឱ្យមានការបះបោរនោះ ដូចនេះពួកគេបានចរចាជាមួយទ្រង់ ដើម្បីបញ្ចប់ការបះបោរ។ ព្រះបាទនរោត្តម និងបុត្រាបានយាងទៅតាមខេត្តនានា ហើយស្នើសុំឱ្យប្រជារាស្ត្របញ្ឈប់ការវាយប្រយុទ្ធ ដោយមានបន្ទូលថា បារាំងយល់ព្រមមិនបង្ខំឱ្យអនុវត្តន៍នូវរាល់លក្ខខណ្ឌនៃអនុសញ្ញាឆ្នាំ១៨៨៤ នោះទេហើយអនុញ្ញាតឱ្យកម្ពុជាដឹកនាំរដ្ឋតាមប្រពៃណី។ ក្នុងអំឡុងពេលជម្លោះនោះ ព្រះអនុជប្រុសនាមព្រះស៊ីសុវត្ថិ បានបង្ហាញនូវភក្តីភាពយ៉ាងស្មោះត្រង់ចំពោះបារាំង ហើយបារាំងបានសម្រេចថា រាល់កំណែទម្រង់របស់គេគួរតែរង់ចាំដល់ពេលព្រះបាទនរោត្តមសោយទិវង្គតនិងក្រោយពេលឱ្យទ្រង់ស៊ីសុវត្ថិ ឡើងស្នងរាជ្យជាស្តេចហើយ។ ទោះជាយ៉ាងណា ព្រះបាទនរោត្តម ត្រូវលះបង់យ៉ាងហោចណាស់មេបះបោរម្នាក់ ដើម្បីឱ្យបារាំងចាប់ខ្លួនយកទៅផ្តន្ទាទោស។ មេបះបោររូបនោះ គឺឧកញ៉ាក្រឡាហោម គង់ ដែលជាវីរបុរសដ៏ល្បីល្បាញម្នាក់, ឧកញ៉ាពិស្ណុលោកឈូក, ឧកញ៉ាឧទយាធិរាជ ចៅហ្វាយស្រុកសំរោងទង, ឧកញ៉ាវង្សាឧទយាទិត្យ ចៅហ្វាយស្រុកភ្នំស្រួច, ឧកញ៉ាវិបុលរាជ កែប ចៅហ្វាយស្រុកគងពិសី, ឧកញ៉ាវង្សាអគ្គរាជញ៉ឹក ចៅហ្វាយស្រុកកណ្តាលស្ទឹង, ឧកញ៉ាវិបុសសង្គ្រាមស ចៅហ្វាយស្រុកស្អាង, និងឧកញ៉ាចក្រីម៉ា ចៅហ្វាយស្រុកបាទី។ មានឯកសារអះអាងថា ព្រះរាជាបានកោះហៅគាត់ឱ្យចូលគាល់នៅព្រះបរមរាជវាំង ហើយពេលចេញពីវាំងវិញ ត្រូវបារាំងចាប់ចងផ្អោបនឹងបំពង់ផ្សែងកប៉ាល់។ ម្ល៉ោះលោក ក៏ត្រូវស្លាប់មួយរំពេចនោះ ដោយសារកំដៅក្តៅពេក។ តែសៀវភៅប្រវត្តិសាស្ត្រខ្មែរភាគទី២ របស់លោក ត្រឹង ងាថា មេដឹកនាំបះបោរដែលត្រូវគេសម្លាប់បន្ទាប់ពីនោះ មានពីរនាក់ គឺឧកញ៉ាពិស្ណុលោក ឈូក ត្រូវគេលួចធ្វើឃាតចំណែកឧកញ៉ាក្រឡាហោមគង់ ត្រូវបារាំងឱ្យនាហ្មឺនខ្មែរបញ្ឆោតឱ្យឡើងមើលកប៉ាល់ ទើបត្រូវគេចាប់ចងផ្អោបនឹងបំពង់ភ្លើងកប៉ាល់រហូតដល់ក្ស័យជីវិតទៅ។ ឯកសារខ្លះ ថាគាត់ចេះមន្តអាគម សិល្ប៍សាស្ត្រ ខាងបែងភាគ ធ្វើឱ្យបារាំងយល់ច្រឡំរូបគាត់ជាមួយដើមចេក ហើយការពិតបារាំងចងដើមចេកទៅវិញទេ នៅនឹងបំពង់ផ្សែងកប៉ាល់នោះ។ ឯកសារខ្លះទៀត ថា ព្រះរាជាធ្វើកិច្ចបង្វែងដានបារាំងដើម្បីជួយសង្គ្រោះលោកឧកញ៉ាក្រឡាហោមគង់ ហើយចុងក្រោយគាត់បានទៅរស់នៅក្នុងស្រុកបាកានខេត្តពោធិ៍សាត់ លាក់អត្តសញ្ញាណ លាក់ប្រវត្តិរបស់ខ្លួន កសាងជីវិតគ្រួសារថ្មី។ រហូតមកដល់ឥឡូវនេះ នៅមានមនុស្សដែលអះអាងថា ជាចៅរបស់គាត់នៅរស់នៅក្នុងស្រុកនោះឡើយ។

អំឡុងដើមសតវត្សរ៍ទី២០ គ្មាននយោបាយបះបោរណាមួយច្បាស់លាស់ទេ ប៉ុន្តែមានការបះបោរតូចៗជាច្រើន ដែលបារាំងចាត់ថា ជាពួកចោរព្រៃ។ នេះបង្ហាញថា ប្រជាជនមិនពេញចិត្តនឹងការដឹកនាំ ប៉ុន្តែគ្មានការរៀបចំចលនាប្រឆាំងបារាំងជាទ្រង់ទ្រាយធំណាមួយទេ។

សង្គ្រាមលោកលើកទី១ (១៩១៤ - ១៩១៨) ពុំសូវជះឥទ្ធិពលលើអាស៊ីអគ្នេយ៍ប៉ុន្មានទេ។ ក៏ប៉ុន្តែ នៅវៀតណាមបារាំងបានកេនមនុស្សប្រមាណជប់ម៉ឺននាក់ ទៅធ្វើទាហាននៅស្រុកបារាំង។ នៅកម្ពុជាបារាំងបានស្នើអ្នកស្ម័គ្រចិត្ត

ហើយមានខ្មែរខ្លះស្ម័គ្រចិត្តទៅច្បាំងនៅបារាំង ដោយរួមមានក្សត្រខ្មែរ៦អង្គផងដែរ ក្នុងចំណោមនោះ មានពីរអង្គសុគតនៅទីនោះ។

ភ្លាមនោះក្នុងខែមករា ឆ្នាំ១៩១៦ ប្រជាកសិកររាប់ពាន់នាក់ ដំបូងមកពីខ្សាច់កណ្តាល និងកំពង់ចាម ហើយក្រោយមក ក៏មានមកពីខេត្តផ្សេងៗទៀតដែរ បានមកធ្វើបាតុកម្មនាក្រុងភ្នំពេញនៅមុខព្រះបរមរាជវាំង។ នៅចុងបញ្ចប់មានមនុស្សកើនឡើងដល់ទៅមួយសែននាក់។ ពួកគេទាមទារចូលគាល់ព្រះមហាក្សត្រ ជាបាតុកម្មអហឹង្សាដោយពុំបានវាយបារាំង ឬបង្កចលាចលទេ។ ពួកគេប្តឹងតវ៉ាពីអំពើពុករលួយរបស់មន្ត្រីកម្ពុជានៅតាមខេត្ត និងមូលដ្ឋានដែលកៀបសង្កត់ខ្លាំងលើកំណែនពលកម្ម ដោយការបំផ្លើសចំនួនលើសផែនការ និងការជំរិតទារថ្លៃមិនចូលរួមកំណែនលើសលប់ថ្លៃឈ្នួលពលករធម្មតា។

ព្រោះនៅពេលនោះ បារាំងបានចាប់ផ្តើមកម្មវិធីកសាងផ្លូវ ហើយគេបានអនុវត្តន៍កំណែនកម្លាំងពលកម្មតាម និងយកថ្លៃជាប្រាក់ជំនួសសម្រាប់ពលករណាជាប់កំណែនតែមិនចង់ទៅការដ្ឋាន ដែលនេះជាពន្ធពលកម្មចាស់ជាប្រពៃណីមានតាំងពីយូរយារណាស់មកហើយ។ តាមច្បាប់ក្នុងឆ្នាំ១៩១៦ មនុស្សម្នាក់អាចគេចពីពន្ធការងារបានបើគាត់បង់ពន្ធពិសេសចំនួន៣ព្យាស(រូបិយប័ណ្ណឥណ្ឌូចិន)។ ប៉ុន្តែ មន្ត្រីខេត្តបានទារលើសចំនួនដល់ទៅ ១០ ឬ១៥ ព្យាស។ ពួកគេបានយកប្រាក់នោះមួយចំនួន ជួលកម្មករសេរីជនជាតិចិន(ប្រទេសមិនត្រូវធ្វើពន្ធការងារទេ)ហើយគេទុកប្រាក់ដែលនៅសល់ទាំងនោះសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន។ នេះជាមូលហេតុនៃការធ្វើបាតុកម្មក្នុងឆ្នាំ១៩១៦។ ព្រះបាទស៊ីសុវត្ថិបានមានព្រះឱង្ការទៅកាន់ពួកបាតុករ ដោយសន្យាថានឹងដោះស្រាយបញ្ហានេះ។ ពួកគេបានត្រឡប់ទៅភូមិស្រុកវិញ។ ក្រោយមក ពួកមន្ត្រីនៅខេត្តមួយចំនួនបានទទួលទណ្ឌកម្ម ប៉ុន្តែពួកបាតុករប្រមាណជាង៤០០នាក់ត្រូវបារាំងចាប់ខ្លួន ដាក់គុក។

បាតុកម្មនេះ មានលក្ខណៈសំខាន់ខុសពីការបះបោរនាឆ្នាំ ១៨៨៤-១៨៨៦។ បដិវត្តន៍មុននេះដឹកនាំដោយមន្ត្រីចាស់ៗ ប៉ុន្តែនៅឆ្នាំ១៩១៦ ប្រជាកសិករ ដឹកនាំប្រឆាំងនឹងពួកមន្ត្រីដែលកាន់ប្រពៃណីចាស់។មានការបែកបាក់រវាងមេដឹកនាំនឹងប្រជាជន។

គោលនយោបាយបារាំងទូទៅក្នុងសតវត្សរ៍ទី២០ មិនសូវមានសារៈប្រយោជន៍ចំពោះប្រជានុរាស្ត្រកម្ពុជាសាមញ្ញទេ។ ពន្ធឡើងខ្ពស់ មន្ត្រីតែងពុករលួយ ហើយថវិកាចំណាយលើការអភិវឌ្ឍន៍វិស័យអប់រំនិងសុខាភិបាលមានចំនួនតិចតួច។ ពន្ធការងារជួនកាលគាបសង្កត់ខ្លាំង ដូចករណីកសាងបូរីបូកគោ ដែលមានកម្មករស្លាប់ដោយសារជំងឺគ្រុនចាញ់ចំនួន៩០០នាក់នៅទីនោះក្នុងរយៈពេល៩ខែ។ កត្តានេះមិនខុសប៉ុន្មានពីអត្រាស្លាប់ក្នុងការដ្ឋានខ្មែរក្រហម។

ហេតុការណ៍បះបោរប្រឆាំងនឹងបារាំងយ៉ាងឃោរឃៅបន្ទាប់មកទៀត គឺឃាតកម្មលើរូបរេស៊ីដង់បារាំងម្នាក់ឈ្មោះ បារដេស នៅខេត្តកំពង់ឆ្នាំង ។ បារដេស ព្យាយាមប្រើកម្លាំងប្រមូលពន្ធក្នុងភូមិក្រាំងលាវ ហើយត្រូវបានអ្នកភូមិសម្លាប់រួមទាំងអ្នកបកប្រែ និងទាហានម្នាក់ជាអង្គរក្សរបស់គាត់ផង ។ ពេលនោះព្រះរាជាបានប្តូរឈ្មោះទៅជាភូមិតិរិច្ឆាន នេះបង្ហាញថាព្រះរាជាគាំទ្របារាំង។

## 5. ការកាត់ទោសបាតុករខ្មែរ

រឿងអាស្រូវដ៏អយុត្តិធម៌របស់បារាំង គឺការឆ្លើយតបនឹងបាតុកម្មទាមទារយុត្តិធម៌ដោយអហឹង្សារបស់កសិករខ្មែរនៅឆ្នាំ១៩១៦ ដោយការចាប់អតីតបាតុករកាត់ទោសប្រហារជីវិត, ដាក់គុកយ៉ាងយូរសម្រាប់ម្នាក់ៗ និងការកាត់

ទោសអនីតិជនម្នាក់(១៦ឆ្នាំ)ឈ្មោះរៀល នៅខេត្តព្រៃវែង ឱ្យជាប់គុកជាង២០ឆ្នាំ។ នេះជាទង្វើរបស់អាប្បជនបារាំង ដែលជាអាណាព្យាបាលខ្មែរ និងជាអ្នកនាំអារ្យធម៌ដ៏ខ្ពង់ខ្ពស់ថ្លៃថ្លាមកឱ្យខ្មែរ។

នៅចុងឆ្នាំ១៩២៣ រេស៊ីដង់បារាំងប្រចាំខេត្តព្រៃវែង ដែលជាមនុស្សម្នាក់មានភាពស្វាហាប់ និងមហិច្ឆតាខ្លាំង ឈ្មោះ ហ្វេលិច លួីស៍ បារដេស បានរាយការណ៍ពីយោបល់របស់គាត់ថា មានបុព្វហេតុបីដែលធ្វើប្រាក់ពន្ធមានកម្រិតទាបខ្លាំងនោះគឺ "ភាពអសកម្មពេញទីនៃមន្ត្រីខ្មែរ ការខ្វះការត្រួតពិនិត្យលើមន្ត្រីប្រមូលពន្ធ និងគុណវិបត្តិក្នុងរបៀបប្រមូលពន្ធ"។ ដោយខឹងនឹងសេចក្តីរាយការណ៍ថាភូមិក្រាំងលាវនៅជំពាក់ពន្ធ លោកបាដេសបានចុះពិនិត្យមើលភូមិនោះដោយផ្ទាល់ខ្លួនឯង ជាមួយនិងចឹបកប្រែមួយរូប និងកងរក្សាស្រុកជាតិខ្មែរម្នាក់ផងដែរ។ ចុងក្រោយបំផុត បារដេស សម្រេចដាក់ខ្នោះអ្នកមិនព្រមបង់ពន្ធ ហើយដាក់គុកថែមទៀត ដោយកំហឹងនឹងលោក បារដេស រាស្ត្រត្រូវវេងទុក្ខដោយភាពអត់ឃ្លានផង ហើយត្រូវទារុណកម្មទៀត នៅក្នុងចំណោមមនុស្សរាប់រយនាក់ មានមនុស្សពី២០ទៅ៣០នាក់បានចោមរោមវាយដំច្រំជាក់ដោយក្តីក្តៅក្រហាយ។ បារដេស រួមជាមួយចឹបកប្រែ និងកងរក្សាស្រុកទាំងបីនាក់ត្រូវបានប្រជាជនខឹងសម្បារ សម្លាប់នៅឆ្នាំ១៩២៥។ ឃាតកម្មលើរូប បារដេសបារាំងបានទូលព្រះស៊ីសុវត្ថិ ឱ្យបញ្ជូនព្រះរាជបុត្រច្បងរបស់ព្រះអង្គ គឺព្រះអង្គម្ចាស់មុនីវង្ស ឱ្យយាងទៅកាន់តំបន់នោះជាមួយនឹងទីប្រឹក្សាបារាំងម្នាក់ទៀតទៅកាន់តំបន់នោះ ដើម្បីបញ្ជាក់ពីការមិនសពព្រះទ័យរបស់ព្រះរាជា។

រឿងនេះបានឈានទៅដល់ការប្រកាសមួយឱ្យប្តូរឈ្មោះភូមិក្រាំងលាវទៅជាភូមិតិរច្ឆាន និងមនុស្សចំនួន១៨នាក់ទៀតត្រូវបានចោទប្រកាន់ថា បានរួមគំនិតនេះ។ តែឈ្មោះនេះត្រូវដាក់បានតែមួយឆ្នាំ ក៏ត្រូវគេលុបចោលវិញ។

នៅថ្ងៃ៥ឧសភា១៩៣៦ ជាលើកដំបូងបំផុត ដែលសិស្សវិទ្យាល័យព្រះស៊ីសុវត្ថិ ធ្វើកូដកម្មប្រឆាំងនឹងបារាំងដែលចេញច្បាប់មួយ តម្រូវឱ្យសិស្សខ្មែរអាយុលើសពី២០ឆ្នាំត្រូវតែបង់ពន្ធ ក្នុងពេលដែលសិស្សយួនដែលរៀននៅក្នុងថ្នាក់ជាមួយគ្នានោះ មិនបានជាប់ពន្ធអ្វីទាំងអស់(កែវ ប៊ុនធឿន,១៩៩៥,ក្រុងភ្នំពេញមុនឆ្នាំ១៩៥៤,ទំព័រ៥៦-៧)។ នេះហើយ ជាទង្វើបង្កការឈឺចាប់របស់បារាំងមកលើខ្មែរម្ចាស់ស្រុក និងការលើកតម្កើងពួកយួននៅកម្ពុជា។

នៅឆ្នាំ១៩៤២ មានបាតុកម្មរបស់ព្រះសង្ឃទាមទារឱ្យបារាំងនៅសាលាក្រុងដោះលែងអាចារ្យ ហែម ចៀវ និងនួន ឌួង ដែលត្រូវបារាំងចាប់ផ្សឹក និងឃុំឃាំង ដោយសារបានទេសនា និងផ្សព្វផ្សាយដាស់តឿនទាហាន និងនិស្សិតឱ្យភ្ញាក់ឭកគិតដល់បញ្ហាជាតិ ជាពិសេសឯករាជ្យរបស់ជាតិ។ សង្គ្រាមឆ័ត្រនោះ បានធ្វើឱ្យបារាំងបង្កប់ភ្នាក់ងារ ដើម្បីចាប់ទាំងលោកប៉ាច ឈឺនថែមទៀត។ លើសពីនោះ ក្រោយបាតុកម្ម បារាំងបានតាមចាប់អ្នកពាក់ព័ន្ធជាច្រើនដាក់គុក និងនិរទេស។ នេះជាការបង្ក្រាបពួកបញ្ញវន្តប្រពៃណី ដែលជាអ្នកភ្ញាក់កំណើតស្នេហាជាតិ។

## 6. ការជ្រើសរើសស្តេចឡើងសោយរាជ្យ

ព្រះបាទអង្គដួងសុគតក្នុងឆ្នាំ១៨៥៩។កាលពីព្រះអង្គនៅមានព្រះជន្មនៅឡើយព្រះអង្គមានព្រះទ័យចង់ឱ្យបុត្រារបស់ព្រះអង្គព្រះនាម អង្គវឌ្ឍី(ឯកសារខ្លះ អង្គវតី) ឬអង្គច្រឡឹង ក្រោយមកហៅនរោត្តមស្នងរាជ្យ ។ តែពិធីគ្រងរាជ្យកាន់ដោយសៀម ព្រោះគ្រឿងចាំបាច់ពិសេសទាំងប្រាំ ដូចជាព្រះខ័ន ជាដើម ត្រូវគេរក្សាទុកនៅឯក្រុងបាងកក ហើយសៀមជឿថា គេមានអំណាចលើកម្ពុជា។ ពួកគេមិនច្បាស់ថាតើគួរអភិសេកទ្រង់នរោត្តម ឬក៏ព្រះអនុជរបស់ទ្រង់មួយអង្គផ្សេងទៀត ។ព្រះអង្គដួងសុគតទៅ សេនាបតីសព្វមុខមន្ត្រី និងព្រាហ្មណ៍បុរោហិត រួមទាំងរាជវង្ស បាន

អញ្ជើញ ព្រះអង្គវតី ឱ្យគ្រងរាជ្យ នៅឧដុង្គមានជ័យតាមបណ្តាំរបស់ព្រះអង្គដួង ដោយមាននាមថា ៖ ព្រះបាទសម្តេចព្រះនរោត្តមព្រហ្មបរិក្ស ។

មានការលើកឡើងរបស់លោក វិកឃីរី ថា បារាំងបញ្ចុះបញ្ចូលសៀមឱ្យយល់ព្រមអភិសេកទ្រង់នរោត្តម ជាព្រះមហាក្សត្រ ហើយនៅក្នុងខែមិថុនា ឆ្នាំ១៨៦៤ មន្ត្រីសៀមបាននាំយកគ្រឿងអភិសេករាជ្យមកឧដុង្គ ហើយទ្រង់នរោត្តមក៏បានអភិសេកជាមហាក្សត្រ ដោយមានការចូលរួមពីតំណាងប្រទេសសៀមនិងបារាំង ។

តំណែងរាជវង្សកម្ពុជាបានធ្លាក់ចុះក្នុងពេលដែលវណ្ណៈមន្ត្រីថ្មីបានរីកដុះដាលក្រោមការដឹកនាំរបស់បារាំង។ មន្ត្រីថ្មីទាំងនោះភាគច្រើនចេញពីគ្រួសារក្រីក្រ ប៉ុន្តែបានរៀនភាសាបារាំង ហើយត្រូវបានតម្លើងឋានៈតួនាទីយ៉ាងឆាប់។ ឧទាហរណ៍ ដ៏ល្អមួយគឺលោក រាំង ជួនដែលនៅឆ្នាំ១៨៩៨ បានឡើងជាអគ្គលេខាក្រុមប្រឹក្សារដ្ឋមន្ត្រី ហើយពេលនោះជារដ្ឋមន្ត្រីប្រឆាំងនឹងព្រះបាទ នរោត្តម ត្រូវបានតែងតាំងឡើង។

ក្នុងឆ្នាំ១៩០០ បុត្រាច្បងបង្អស់របស់ព្រះ នរោត្តម គឺព្រះអង្គយុគន្ធរ ដែលទ្រង់នរោត្តមសង្ឃឹមថានឹងអាចស្នងរាជ្យពីទ្រង់នោះ បានយាងទៅក្រុងប៉ារីស ហើយធ្វើការតវ៉ាប្រឆាំងនឹងនយោបាយបារាំងនៅកម្ពុជាលើទំព័រកាសែត និងកិច្ចប្រជុំ។ ចំណុចសំខាន់ពិសេសនៃការតវ៉ារបស់ព្រះអង្គគឺថា ព្រះអង្គមិនប្រឆាំងនឹងអាណាព្យាបាលទេ ប៉ុន្តែជំទាស់នឹងស្ថានការណ៍ដែលបារាំងមិនរក្សាសង្គមប្រពៃណី និងរាជវង្ស តែបានអនុញ្ញាតឱ្យមនុស្សថ្មីដូចលោកជួន ឡើងមានអំណាចលើសព្រះអង្គម្ចាស់។

ព្រះបាទនរោត្តម សោយទីវង្គតនៅថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩០៤ ក្នុងព្រះជន្ម៧០វស្សា ដោយរោគាពាធ។ ព្រះអនុជទ្រង់ គឺព្រះបាទស៊ីសុវត្ថិ បានឡើងសោយរាជ្យតាមដែលបារាំងពេញចិត្ត។

ក្រោយព្រះអង្គម្ចាស់ ស៊ីសុវត្ថិ គ្រងរាជ្យភ្លាម បារាំងមានលទ្ធភាពបញ្ចុះបញ្ចូលសៀមឱ្យប្រគល់មកវិញនូវខេត្តដែលគេបានយកពីកម្ពុជាមុននោះ។ ក្នុងឆ្នាំ១៩០៤ តំបន់មួយចំនួននៅភាគខាងជើងតាមជួរភ្នំដងរែកក្នុងស្រុកម្លូព្រៃ ទន្លេរពៅ និងខេត្តស្ទឹងត្រែង ត្រូវបានប្រគល់មកឱ្យកម្ពុជាវិញ ហើយនៅឆ្នាំ១៩០៧ខេត្តដ៏ធំនៅភាគពាយ័ព្យ គឺបាត់ដំបង, សៀមរាប និងបន្ទាយមានជ័យ ក៏ត្រូវបានប្រគល់ឱ្យកម្ពុជាវិញដែរ។ ព្រះអង្គ ស៊ីសុវត្ថិ សុគតនៅថ្ងៃទី០៩ ខែសីហា ឆ្នាំ១៩២៧ ក្នុងព្រះជន្ម ៨៨វស្សា។

ក្រោយរាជ្យព្រះបាទនរោត្តម មានបញ្ហាយ៉ាងច្រើនក្នុងការជ្រើសរើសព្រះមហាក្សត្រថ្មី ។ បារាំងបានប្រឆាំងនឹងប្រពៃណីកម្ពុជាពីមុននោះ ដោយសម្រេចថា មានតែខ្សែស្រឡាយរាជ្យវង្សពីរ គឺនរោត្តម និងស៊ីសុវត្ថិ។ កម្ពុជា មិនដែលមើលរាជវង្សក្នុងខ្សែបែបនេះទេ ហើយជាការពិតនៅមុនឆ្នាំ១៩០៧ ក្នុងប្រទេសកម្ពុជា រាជវង្សគ្មាននាមត្រកូលគ្រួសាររបស់ខ្លួនទេ។ ប្រសិនបើយើងសង្កេតមើលពង្សាវតាររាជវង្សក្នុងសតវត្សរ៍ទី១៦-១៩ យើងឃើញថា ពួករាជវង្សរៀបអភិសេករវាងគ្នា ហើយយើងមិនអាចរកខ្សែស្រឡាយរាជវង្សផ្សេងគ្នាឃើញទេ។

នៅមុនពេលព្រះបាទ នរោត្តមសោយទិវង្គតទៅ ព្រះអង្គសង្ឃឹមថា បារាំងនឹងជ្រើសរើសបុត្រាទ្រង់មួយអង្គ។ ក៏ប៉ុន្តែបារាំងបារម្ភខ្លាចបុត្រារបស់ព្រះបាទនរោត្តមប្រឆាំងនឹងបារាំង ហើយពួកគេដឹងថាទ្រង់ស៊ីសុវត្ថិ គាំទ្របារាំង។ ក្នុងអំឡុងរជ្ជកាលព្រះស៊ីសុវត្ថិ ព្រះអង្គចង់បញ្ចុះបញ្ចូលបារាំងឱ្យជ្រើសរើសបុត្រាទ្រង់មួយអង្គ តែពេលនោះព្រះអង្គម្ចាស់ខ្សែនរោត្តម មានបន្ទូលថា ពួកទ្រង់គួរតែបានឡើងសោយរាជ្យវិញ ពីព្រោះពួកទ្រង់បានជាប់ខ្សែស្រឡាយច្បងក្នុងរាជវង្ស។ នេះបញ្ជាក់ថា ព្រះអង្គម្ចាស់កំពុងប្រើគំនិតបារាំងអំពីរាជវង្ស ដែលមិនមែនជាគំនិតប្រពៃ

ណីរបស់កម្ពុជាទេ។ នៅចុងបញ្ចប់រាជ្យព្រះបាទស៊ីសុវត្ថិ បារាំងនៅតែបារម្ភពីព្រះអង្គម្ចាស់ខ្សែនរោត្តម ហើយពួកគេក៏បានសម្រេចជ្រើសរើសបុត្រារបស់ព្រះបាទសីសុវត្ថិ ព្រះនាមមុនីវង្ស ឱ្យឡើងគ្រងរាជ្យ។

នៅពេលដែលព្រះរាជាស៊ីសុវត្ថិ សោយទីវង្គតនៅឆ្នាំ១៩២៧ ដើម្បីជ្រើសរើសក្សត្រមួយអង្គទៀតសោយរាជ្យបន្ត អគ្គទេសាភិបាលឥណ្ឌូចិន សំលឹងមើលខ្សែក្សត្រទាំងពីរ គឺនរោត្តម និង ស៊ីសុវត្ថិដោយជ្រើសរើសបេក្ខភាពម្ខាង៥រូប ដែលរដ្ឋាភិបាលឥណ្ឌូចិន ថ្ងៃទី០៣-សីហា-១៩២៧ ផ្ញើទៅរដ្ឋមន្ត្រីក្រសួងអាណានិគម នូវបញ្ជីរាយនាមរាជបុត្រដូចខាងក្រោមនេះ

| | ខាងព្រះនរោត្តម (មានរាជបុត្រ) | | ខាងព្រះស៊ីសុវត្ថិ (មានរាជបុត្រ) |
|---|---|---|---|
| ១ | យុគន្ធរ(Yukanthor) មានព្រះជន្ម ៦៧ឆ្នាំ | ១ | *មុនីវង្ស មានព្រះជន្ម ៥១វស្សា* |
| ២ | ផានុវង្ស មានព្រះជន្ម ៥៦ឆ្នាំ | ២ | ឌួងលក្ខិណា មានព្រះជន្ម ៤១ឆ្នាំ |
| ៣ | សាលវន្ត មានព្រះជន្ម ៥៥ឆ្នាំ | ៣ | ខណ្ឌារក្ស មានព្រះជន្ម ៤៩ឆ្នាំ |
| ៤ | សត្ថារតន៍ មានព្រះជន្ម ៥៥ឆ្នាំ | ៤ | សុផានុវង្ស មានព្រះជន្ម ៣៩ឆ្នាំ |
| ៥ | ចន្ទលក្ខិណា មានព្រះជន្ម ៥៤ឆ្នាំ | ៥ | វង្គត មានព្រះជន្ម ៣៥ឆ្នាំ |

រីឯសមាសភាពឧត្តមក្រុមប្រឹក្សារាជសម្បត្តិ នៅពេលដែលព្រះសុិសុវត្ថិសុគត ៖

១-រ៉េស៊ីដង់ជាន់ខ្ពស់ (Resident Superieur)

២-ឧកញ៉ាវាំងជួន(ជាមនុស្សដែលមានឥទ្ធិពលខ្លាំងនៅសម័យបារាំង ជាមនុស្សខ្លាំងនៅក្នុងរដ្ឋាភិបាល) ជារដ្ឋមន្ត្រីទទួលបន្ទុករាជវាំង ហិរញ្ញវត្ថុ និងវិចិត្រសិល្បៈ ។

៣-ឧកញ៉ាចក្រីប៉ុន រដ្ឋមន្ត្រីខាងចម្បាំង, សាធារណសិក្សា និងសាធារណការ

៤-ឧកញ៉ាយមរាជ សុន ឌៀប រដ្ឋមន្ត្រីយុត្តិធម៌

៥-ព្រះធម្មលិខិត អ៊ុក ជា ប្រធានគណៈមហានិកាយ

៦-ព្រះមង្គលទេព្វាចារ្យ ស៊ុក ប្រធានគណៈធម្មយុត្តិ

៧-សម្តេចខាងបាគូ សម្តេចព្រះឥសីភទ្ទ[86] រស់ ប្រធានខាងបាគូ(ប្រធានក្នុងវាំង?)សម្តេចនេះឈឺត្រូវជំនួសដោយ ព្រះធម្មឫទ្ធិ ម៉ាង (ជាកូន)

៨-ព្រះរាមាធិបតី ជុំ ប្រធានក្រុមគ្រួសារមហាក្សត្រខ្មែរ

៩-ឧកញ៉ាមហាមន្ត្រី ល្អុត (ប្រធានពិធីការ)

១០-លោក ឡារុនេត ជាតំណាងរបបអាណាព្យាបាល នៅអមរដ្ឋាភិបាលខ្មែរ មានវត្តមានក្នុងឱកាសនោះក្នុងឋានៈជាលេខាធិការ ។

ក្នុងការជ្រើសរើសបេក្ខភាពមហាក្សត្រ ពីបេក្ខជននីមួយៗ គណកម្មការចម្រុះបារាំង-ខ្មែរលើកយកមកវាយតំលៃលើបេក្ខភាពបុគ្គលភាពមួយអង្គៗយកមកពិភាក្សា ខាងបេក្ខជនដែលមានខ្សែខាងនរោត្តម ដែលមានសមាស

---

[86] ក្នុងសៀវភៅនិក្ខេបបទថ្នាក់បណ្ឌិតប្រវត្តិវិទ្យារបស់លោក ស៊ន សំណាង ដាក់ឈ្មោះ អធិបតីបាគូរូបនេះថា សម្តេចព្រះឥសីផុត រស់ ជាឈ្មោះដែលមាននាមត្រកូល 'ផុត'។ តែគួរឱ្យឆ្ងល់ត្រង់កូនប្រុសរបស់តា'រស់' គឺព្រះធម្មឫទ្ធិ ម៉ាង បែរជាគ្មានភ្ជាប់នាមត្រកូល ដូចឪពុកខ្លួនសោះ។ ហេតុនេះហើយ ទើបយើងគិតថា លោកតានោះគួរតែមានឋានន្តរនាមដូចអធិបតីបាគូរ ឬអ្នកកាន់កាប់ក្សាប្រដាប់សម្រាប់ស្តេចសោយរាជ្យនៅសម័យបុរាណដែរ គឺ 'សម្តេចព្រះឥសីភទ្ទ' ដែលមានឈ្មោះ 'រស់' តែមួយម៉ាត់ប៉ុណ្ណោះ។

ភាពទាំងប្រាំព្រះអង្គ គណៈកម្មការបានយក ព្រះអង្គម្ចាស់យុគន្ធរមកពិភាក្សាថា ដោយគេបានលើកនូវអនុស្សរណៈរបស់ព្រះអង្គកាលពីដើមទសវត្សរ៍១៩០០មកពិភាក្សា ។ ព្រះអង្គបានសរសេរថា របបអាណាព្យាបាលដ៏សាមញ្ញទង្វើរបស់បារាំង ឥឡូវនេះបានក្លាយទៅជាការត្រួតត្រាទាំងស្រុង ផ្តាច់ការនិងតឹងរ៉ឹងជាងនៅក្នុងប្រទេស ដែលគេច្បាំងដណ្តើមបាននោះទៅទៀត។ ជនជាតិខ្មែរមានសេរីភាពក្រោមអំណាចផ្តាច់ការរបស់ព្រះរាជា ឥឡូវនេះបានក្លាយជាទាសករនៅក្នុងសេរីភាព នៃអ្នកគ្រប់គ្រងបារាំង សំណុំរឿងរបស់ព្រះអង្គម្ចាស់យុគន្ធរត្រូវបានគេលើកយកមកពិភាក្សា ហើយក៏សម្រេចដកបេក្ខភាពនេះចេញពីការជ្រើសរើសព្រះមហាក្សត្រ ដោយសារទ្រង់មិនបានគាំទ្រ ឬមានភាពក្រអឺតក្រទមចំពោះបារាំងដែលជាអ្នកអាណាព្យាបាល ពុំសក្តិសមនឹងទទួលតំណែងមហាក្សត្រឡើយ។ ជាលទ្ធផលព្រះអង្គភៀសខ្លួនទៅបាងកកមិនអាចត្រឡប់មកវិញទេ។ សូមបញ្ជាក់ថា នៅខែ តុលា ឆ្នាំ១៩០០ ព្រះអង្គម្ចាស់យុគន្ធរបានភៀសខ្លួនទៅប្រទេសប៊ែលស៊ិក មកដល់ខែធ្នូ ឆ្នាំ១៩០០ បានមកដល់សិង្ហបុរី ចាប់ពីពេលផ្តើមសង្គ្រាមលោកលើកទី១ យុគន្ធរបានទៅនៅប្រទេសសៀម ហើយក៏សុគតនៅទីក្រុងបាងកកក្នុងឆ្នាំ១៩៣៤។ ចំពោះបេក្ខភាពទី២ គឺព្រះអង្គម្ចាស់ ផានុវង្ស តាមការវាយតំលៃរបស់បារាំងថា មានគុណសម្បត្តិគ្រប់គ្រាន់ហើយ។ បេក្ខជនទី៣ គឺព្រះអង្គម្ចាស់សាលវន្ត គ្មានមុខងារជាផ្លូវការក្នុងរដ្ឋាភិបាលទេ ជក់អាភៀនផង។ បេក្ខជនទី៤ គឺ ព្រះអង្គម្ចាស់សត្ថារតន៍ មានគុណសម្បត្តិគ្រប់គ្រាន់ ស្លៀកពាក់ស្អាតបាត មានលំនឹងក្នុងស្មារតី ជាជាវីខាងពុទ្ធសាសនា(បានដកខ្លួនចេញពីរាជ្យសម្បត្តិមិនប្រជែងនឹងរាជសម្បត្តិទេ)ភៀសខ្លួនទៅនៅជាយក្រុង ។ បេក្ខជនទី៥ គឺព្រះអង្គម្ចាស់ចន្ទ លក្ខិណាសមាជិកនៃគណកម្មាធិការក្រុងភ្នំពេញ មិននិយាយពីគុណសម្បត្តិទេ។

រីឯសមាសភាព ខ្សែខាងស៊ីសុវត្ថិ ដែលមានបេក្ខភាពប្រាំព្រះអង្គដែរ ត្រូវបានគណកម្មការលើកយកមកពិភាក្សាដែរថា ព្រះអង្គម្ចាស់មុនីវង្ស ជាបេក្ខជនដែលបិតា ចង់ឱ្យឡើងសោយរាជ្យ ប៉ុន្តែមិនសូវមានប្រាជ្ញា ដូចរាជបុត្រខាងនរោត្តមទេ។ ប៉ុន្តែចិត្តល្អ មានប្រជាប្រិយភាពក្នុងមជ្ឈដ្ឋានប្រជាពលរដ្ឋខ្មែរ ជាបេក្ខជនក្នុងគណៈមហានិកាយ ដែលជាគណៈសង្ឃមានប្រជាប្រិយភាព ដោយមានប្រជាជនកាន់គោរតពច្រើនជាងគេ។ ទី២គឺ ព្រះអង្គម្ចាស់ឌួងលក្ខិណា ជានាយកខាងភ្នាក់ងារដឹកជញ្ជូនរបស់ព្រះរាជវាំង។ ប៉ុន្តែតាមរបាយការណ៍ថា គ្មានគុណសម្បត្តិទេ(មិនអាចសោយរាជ្យបាន)។ បេក្ខជនទី៣ គឺព្រះម្ចាស់ខណ្ណារក្ស នាយកភ្នាក់ងារខាងជើងទឹក របស់ព្រះមហាក្សត្រ(មិនមានគុណសម្បត្តិ)។ បេក្ខជនទី៤ ព្រះអង្គម្ចាស់សុផានុវង្ស រដ្ឋមន្ត្រីក្រសួងកងទ័ពជើងទឹក(ម៉ារីន) ស្លៀកពាក់ស្អាតបាត ចិត្តគំនិតល្អមិនសូវសកម្មជាប្អូនព្រះអង្គម្ចាស់មុនីវង្ស។ បេក្ខជនទី៥ គឺព្រះអង្គម្ចាស់វង្គត បានស្នាក់នៅស្រុកបារាំង ប៉ុន្តែមិនបានទាញយកផលប្រយោជន៍ពីការនៅស្រុកបារាំងទេ។

នៅក្នុងការពិភាក្សា ឧត្តមក្រុមប្រឹក្សារាជបល្ល័ង្កលើកយកបេក្ខភាពរបស់ព្រះអង្គម្ចាស់មុនីវង្ស មកពិចារណាដោយយើងសុំលើកបណ្តាំផ្ញើរបស់ព្រះបាទស៊ីសុវត្ថិ ដែលសរសេរនៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩២៤ ឱ្យទុករាជបុត្រច្បងរបស់ព្រះអង្គ គឺព្រះអង្គម្ចាស់មុនីវង្ស ជាស្តេចដែលត្រូវទទួលរាជ្យសម្បត្តិ។ បានឃើញរាជលិខិត ចុះថ្ងៃទី២៥ ខែកុម្ភៈឆ្នាំ១៩០៩ ផ្ញើជូនលោក ប៉ូល លុស(Paul Luce) ជារេស៊ីដង់ជាន់ខ្ពស់នៃសាធារណរដ្ឋបារាំងប្រចាំនៅកម្ពុជា ដោយស្នើសុំឱ្យបញ្ជូនទៅឱ្យលោកក្លូបូកូវស្គី (Klobukowski) ជាអគ្គទេសាភិបាលឥណ្ឌូចិន នូវសាររបស់យើងលេខ៧ ចុះកាលបរិច្ឆេទដដែល ដែលបានតែងតាំងរាជបុត្រច្បង គឺព្រះអង្គម្ចាស់ ស៊ីសុវត្ថិមុនីវង្ស ដោយសារទ្រង់មានប្រាជ្ញា មានការអប់រំ មានចំណេះដឹង មានសម្បទាគ្រប់គ្រាន់ និងភក្តីភាពចំពោះប្រទេសបារាំង ដែលទ្រង់បានទទួលការសិក្សាវិជ្ជាយោធានៅទីនោះ គុណសម្បត្តិទាំងនេះហើយ ដែលអាចនឹងដឹកនាំរាជាណាចក្រកម្ពុជាឱ្យបានរុងរឿងក្រោមអាណាព្យាបាលបារាំងបាន។ បើឧត្តមក្រុមប្រឹក្សារាជបល្ល័ង្ក មិនអនុញ្ញាតឱ្យបុត្ររបស់ព្រះស៊ីសុវត្ថិ សោយរាជ្យទេ បានសេចក្តីថាក្បត់នឹងបណ្តាំរបស់ព្រះរាជា។ ដោយមានការលើកឡើងរបស់លោក ឡៅប ដែលជារដ្ឋមន្ត្រីយុត្តិធម៌ ហើយ

ក៏ជាសមាជិកគណកម្មការដែរនោះ បានលើកពីគុណសម្បត្តិរបស់ព្រះមុនីវង្ស ថាបានជួយបារាំង ពួកគេក៏លើករាជសម្បត្តិឱ្យព្រះអង្គម្ចាស់មុនីវង្សទៅ។

ក្នុងរាជ្យព្រះអង្គ(១៩២៧-១៩៤១) ព្រះអង្គក៏សាងសមិទ្ធិផល សំខាន់ៗមានដូចជា ស្ពានបេតុងមួយដែលកាត់តាមទន្លេបាសាក់ប្រវែង២៩២ម ត្រូវបានសម្ពោធនៅថ្ងៃទី១៨វិច្ឆិកា ១៩២៨ ដែលមានឈ្មោះថា ស្ពានព្រះមុនីវង្ស (អ្នកខ្លះស្ពានក្បាលថ្នល់ ឬស្ពានជ្រោយអាអោក), នៅឆ្នាំ១៩៣០ ក៏បង្កើតវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ និងសាលាអនុវត្តន៍សម្រាប់ព្រះសង្ឃ"សង្ឃ-គ្រូ"ឡើង។

ការជ្រើសរើសមហាក្សត្រ ដើម្បីឡើងសោយរាជ្យដែលគិតគូរដោយបារាំង ក៏ត្រូវបានបន្តនៅក្រោយការសោយទីវង្គតរបស់ព្រះបាទមុនីវង្ស (ព្រះអង្គសុគត នៅ១៩៤១)។ រេស៊ីដង់ជាន់ខ្ពស់បារាំង*Thibaudeau*សម្លឹងឃើញបេក្ខភាពស្តេចពីរព្រះអង្គ ដែលសក្តិសមនឹងទទួលរាជ្យសម្បត្តិ គឺ ទ្រង់មុនីរ៉េត និង ទ្រង់សុរាម្រិត។ បារាំងបានយកបេក្ខភាពក្សត្រទាំងពីរព្រះអង្គនេះ យកមកពិភាក្សាថា ទ្រង់មុនីរ៉េត(បញ្ចប់ការសិក្សាមធ្យមសិក្សានៅស្រុកបារាំង) គេយល់ថា ទ្រង់មានការប្រឆាំងនឹងបារាំង។ ប៉ុន្តែ ក៏មានអ្នកការពារបេក្ខភាពទ្រង់មុនីរ៉េត គឺលោក *Marineth* (១៩៣៦)លោកជាអ្នកតំណាងប្រទេសខ្មែរ នៃក្រុមប្រឹក្សាជាន់ខ្ពស់នៃប្រទេសបារាំងឯនាយសមុទ្រ។ គាត់អះអាងថា មុនីរ៉េតទទួលការអប់រំពីស្រុកបារាំងដូចនេះធ្លាប់បានទទួលស្មារតីពីបារាំង ដូចនេះមុនីរ៉េត មានឫកពារមិនខ្លាចបារាំង គឺជាលក្ខណៈសម្បត្តិនាំពីប្រទេសបារាំង ដែលតែងផ្តល់នូវសេរីភាពក្នុងការនិយាយស្តី សេរីភាពក្នុងគំនិតដែលជាមូលដ្ឋាននៃអរិយធម៌មួយ។ មានការលើកឡើងថា ទ្រង់មុនីរ៉េត និយមសៀម (ជិតដិតសៀម) ព្រោះទ្រង់បានរៀបអាពាហ៍ពិពាហ៍ជាមួយនាង Rosette Pok ជាកូនស្រីរបស់ចៅក្រមម្នាក់ឈ្មោះ ប៉ុក ហែល ដែលមានទំនាក់ទំនងក្រុមគ្រួសារនៅក្នុងប្រទេសសៀម។

ទ្រង់ សុរាម្រិត ដែលជារាជបុត្ររបស់សុជារស(បារាំងហៅ សុថារ័ត ឬសត្ថារតន៍-ខ្សែនរោត្តម)លក្ខណៈទន់ខ្សោយ(ស្លូតបូតពេក) ព្រះអង្គម្ចាស់ធ្លាប់បានទៅសិក្សានៅវិទ្យាល័យ *Chasseloup Laubat* (ជាឈ្មោះរដ្ឋមន្ត្រីក្រសួងទ័ពជើងទឹកឆ្នាំ១៩២៩)នៅក្រុងព្រៃនគរ)។ រីឯ នរោត្តម សុធាពិន នរិន្ទតេជ(កើត១៩០៦)មានមធ្យមសិក្សាប័ត្រនៅប្រទេសបារាំង និងវិញ្ញាបនប័ត្រថ្នាក់បរិញ្ញាប័ត្រ ខាងអក្សរសាស្ត្រ ផ្នែកចិត្តវិទ្យា នៅឆ្នាំ១៩៣៤ ដែលត្រូវបានតែងតាំងជាក្រមការថ្នាក់លេខ២។

នៅទីបំផុតឆ្នាំ១៩៤១ ឧត្តមនាវីអគ្គទេសាភិបាលឥណ្ឌូចិន *Decoux* បានសម្រេចជ្រើសរើសព្រះអង្គម្ចាស់ នរោត្តម សីហនុ ដោយគេអះអាងថា ព្រះអង្គម្ចាស់សុរាម្រិត ដែលជាព្រះរាជបិតា មានសាច់សារលោហិតខាងនរោត្តម និងព្រះមាតាជាបុត្រីព្រះបាទស៊ីសុវត្ថិ មុនីវង្ស ជាប់ខ្សែស្រឡាយក្សត្រទាំងពីរខ្សែទាំងស្រុង។

ព្រះបាទ នរោត្តម សីហនុ ប្រសូត្រនៅឆ្នាំ១៩២២ រៀបអភិសេកជាស្តេចនៅឆ្នាំ១៩៤១។ ព្រះអង្គបានដាក់រាជ្យសម្បត្តិថ្វាយទៅព្រះរាជបិតា គឺព្រះសុរាម្រិត នៅឆ្នាំ១៩៥៥។

## 7. ការលុកលុយរបស់ជប៉ុន និងឯករាជ្យខ្មែរឆ្នាំ១៩៤៥

នៅក្រោយសង្គ្រាមលោកលើកទី២ ពិភពលោកមានការផ្លាស់ប្តូរយ៉ាងច្រើន ជាពិសេសចំពោះបណ្តាប្រទេសដែលស្ថិតនៅក្រោមអាណានិគម។ នៅមុនសង្គ្រាមលោកលើកទី២ កើតឡើង ឥទ្ធិពលរបស់បារាំង មានការចុះខ្សោយបន្ទាប់ពីអាល្លឺម៉ង់វាយកាន់កាប់ប្រទេសខ្លួននៅចុងឆ្នាំ១៩៤០។ ដោយដឹងថា បារាំងកំពុងតែខ្សោយដែរនៅឥណ្ឌូចិន ប្រទេសថៃបានធ្វើសង្គ្រាមប្រឆាំងនឹងបារាំងនៅក្នុងទឹកដីខ្មែរ នៅខែ ធ្នូ ឆ្នាំ១៩៤០ដដែល។ ចំណែក

ប្រទេសជប៉ុនដែលមានបំណងត្រួតត្រាទ្វីបអាស៊ីនោះ បានខិតខំពង្រីងឥទ្ធិពលរបស់ខ្លួននៅឥណ្ឌូចិនដែរ ហើយតាមរយៈកិច្ចព្រមព្រៀងដាឡង់-កាតូ (Darland kato) រវាងបារាំង និងជប៉ុននៅថ្ងៃទី២៩ កក្កដា ១៩៤១ ដែលបានចុះហត្ថលេខានៅទីក្រុងវីស៊ី(Vichy)នោះ បានអនុញ្ញាតឱ្យជប៉ុនមានសិទ្ធិដាក់កងទ័ពលើទឹកដី ឥណ្ឌូចិនទាំងមូល បន្ទាប់មកនៅខែសីហា ១៩៤១ ទាហានជប៉ុន ៨០០០នាក់ បានដាក់ទ័ពនៅកម្ពុជា។

បន្ទាប់ពីពេលនោះ កម្លាំងចលនាជាតិនិយម ដែលបានកើតឡើងនៅកម្ពុជាតាំងពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៣០ បានចេញមុខប្រឆាំងបារាំងយ៉ាងខ្លាំង តាមរយៈការសម្តែងបាតុកម្មព្រះសង្ឃនៅថ្ងៃទី២០ខែ កក្កដា ឆ្នាំ ១៩៤២ ដឹកនាំដោយលោក ស៊ឹង ង៉ុកថាញ់ និងលោក ប៉ាច ឈឺន ដោយសង្ឃឹមថា កងទ័ពជប៉ុននឹងជួយធ្វើអន្តរាគមន៍។

ចាប់តាំងពីត្រួតត្រាឥណ្ឌូចិនពីឆ្នាំ១៩៤០ មកទល់នឹងដើមឆ្នាំ១៩៤៥ ជប៉ុនបានចាប់ផ្តើមធ្វើសកម្មភាពប្រឆាំងបារាំងកាន់តែខ្លាំងក្លាឡើង ហើយទីបំផុតក៏សម្រេចប្រើកងកម្លាំងយោធារបស់ខ្លួនវាយប្រហារបារាំងមួយរាត្រីនៅទូទាំងឥណ្ឌូចិន នៅថ្ងៃទី០៩ មីនា ១៩៤៥ ដែលគេហៅថា ពលប្រហាររបស់ជប៉ុន និងបានរុញច្រានមហាអំណាចបារាំងឱ្យទៅម្ខាង។ ដោយកងទ័ពបារាំងទាំងអស់ត្រូវចាប់ឃុំឃាំង

ជាលទ្ធផលក្នុងបរិការណ៍នៃការលុកលុយរបស់កងទ័ពជប៉ុន ឬចក្រភពព្រះអាទិត្យរះ និងដោយសារបានជំនួយពីពួកនេះ បីថ្ងៃក្រោយ បន្ទាប់ពីជប៉ុនកាន់កាប់ឥណ្ឌូចិននៅក្នុងដៃ ព្រះបាទ នរោត្តម សីហនុព្រះមហាក្សត្រខ្មែរ បានចេញព្រះរាជក្រមមួយចុះថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៤៥ ថាព្រះអង្គកាន់តំណែងរស៊ីដង់ជាន់ខ្ពស់ និងព្រះរាជក្រមមួយទៀតចុះថ្ងៃដដែល ស្តីពីការប្រកាសឯករាជ្យនៃប្រទេសកម្ពុជា ហើយប្រកាសលុបចោលសន្ធិសញ្ញាឆ្នាំ ១៨៦៣ និងនិងអនុសញ្ញាឆ្នាំ១៨៨៤ ដែលធ្វើឱ្យប្រទេសកម្ពុជាក្លាយជារដ្ឋក្រោមអាណាព្យាបាលបារាំងនោះ ជាពិសេសលុបចោលតំណែងរស៊ីដង់ជាន់ខ្ពស់លែងឱ្យមានទៀត។ ចាប់ពីពេលនោះមក ព្រះមហាក្សត្របានយកអំណាចទាំងអស់មកកាន់កាប់វិញ ដូចក្នុងរបបរាជាធិបតេយ្យផ្តាច់ការ ពីសម័យដើមតាមព្រះរាជក្រម លេខ៩ន.ស ចុះថ្ងៃទី១៧ខែមីនាឆ្នាំ១៩៤៥។ នេះជាការប្រឹងប្រែងលើកទី១ របស់ព្រះមហាក្សត្រ ដើម្បីឯករាជ្យជាតិ។ ប៉ុន្តែ ឯករាជ្យនេះមិនបានទទួលស្គាល់ ដោយរដ្ឋាភិបាលជប៉ុនជាផ្លូវការនៅឡើយទេ។

បន្ទាប់ពីជប៉ុនចាញ់សង្គ្រាមលោកលើកទី២ សភាពការណ៍បានប្រែប្រួលយ៉ាងឆាប់រហ័សនៅក្នុងឥណ្ឌូចិន។ នៅថ្ងៃទី២៣ខែកញ្ញា អង្គភាពនៃកងទ័ពបារាំង ក្រោមការដឹកនាំរបស់ឧត្តមសេនីយ ដឺហ្គោលនិងកងទ័ពអង់គ្លេសបានវាយចូលកាន់កាប់ទីក្រុងព្រៃនគរ។ អន្តរាគមន៍បែបនេះ បានរីកសាយដល់ប្រទេសកម្ពុជា។ នៅថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៤៥ អង្គភាពនៃកងឆ័ត្រយោងបារាំង បានចូលមកដល់ទីក្រុងភ្នំពេញតាមផ្លូវអាកាស។ តាមបញ្ជារបស់ឧត្តមសេនីយ៍បារាំង ឡឺក្លែក, សឹង ង៉ុកថាញ់ និងសមាជិកនៃរដ្ឋាភិបាលរបស់ខ្លួនបានត្រូវចាប់ឃុំឃាំង ។

ចាប់ពីពេលនោះមកចលនាតស៊ូរំដោះជាតិរបស់ពួកឥស្សរៈ កាន់តែមានភាពខ្លាំងក្លាឡើង ដោយមានការគាំទ្រពីកម្លាំងទ័ពវៀតមិញថែមទៀតផង។ ដើម្បីជៀសវាងពីសង្គ្រាមបង្ហូរឈាមគ្នាមួយ ដែលមានស្ថានភាពមិនស្មើគ្នារវាងប្រជាជនកម្ពុជា ជាមួយនឹងកងទ័ពមហាអំណាចបារាំងប្រកបដោយសព្វាវុធទំនើបៗសម្តេច នរោត្តមសីហនុ បានជ្រើសរើសយកមាគ៌ា កិច្ចព្រមព្រៀងសម្របសម្រួលជាមួយនឹងពួកអាណានិគមបារាំង ដើម្បីឯករាជ្យជាតិ។ ក្នុងការតស៊ូ ដើម្បីឯករាជ្យរបស់ព្រះមហាក្សត្រត្រូវបានចាប់ផ្តើមឡើងពីលេខសូន្យឡើងទៅវិញ ។

ព្រះមហាក្សត្រព្រះរាជាណាចក្រកម្ពុជា ពុំទទួលស្គាល់សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមនៅក្នុងស្ថានភាពសហព័ន្ធឥណ្ឌូចិនបែបនេះឡើយ ព្រះអង្គបានបន្តនយោបាយជាមួយបារាំងតទៅទៀត។ ទន្ទឹមនឹងនេះ ការបង្កើតសម្ព័ន្ធភាពប្រជាជនឥណ្ឌូចិន បានធ្វើឱ្យការវាយលុករបស់កងទ័ពវៀតណាម និងកងទ័ព"ខ្មែរឥស្សរៈ"កាន់តែមានសន្ទុះខ្លាំងឡើងៗ មួយកម្រិតថែមទៀត។

## 8. ម៉ូឌុសវីវ៉ង់ឌី និងឯករាជ្យខ្មែរ១៩៤៩

ម៉ូឌុសវីវ៉ង់ឌី(Modus Vivendi) ជាសន្ធិសញ្ញា ដែលឈានទៅដល់កិច្ចព្រមព្រៀងបណ្តោះអាសន្នមួយរវាងប្រទេសបារាំងតំណាងដោយឧត្តមសេនីយ៍ អាឡិចសង់ឌ្រ៍ និងប្រទេសកម្ពុជាតំណាងដោយ ស្តេចក្រុមហ្លួង ស៊ីសុវត្ថិ មុនីរ៉េត ដោយចែងអំពីការប្រគល់ឱ្យប្រទេសកម្ពុជា នៅជារដ្ឋគ្រប់គ្រងដោយខ្លួនឯង(រដ្ឋស្វ័យត) តែស្ថិតនៅក្រោមការត្រួតពិនិត្យរបស់សហភាពបារាំង។ សន្ធិសញ្ញានេះធ្វើឡើង នៅពេលបន្ទាប់ពីបារាំងវិលត្រឡប់មកជាន់ដីកម្ពុជាជាលើកទី២ចាប់ពីខែកញ្ញា១៩៤៥ នៅក្រោយពេលដែលជប៉ុនចុះចាញ់សង្គ្រាមលោកលើកទី២។ បារាំង ចូលកម្ពុជានៅលើកទីពីរ បារាំងបានធ្វើការផ្លាស់ប្តូរនយោបាយជាច្រើនផ្នែករបស់ខ្លួន។

ពេលដែលបារាំងវិលត្រឡប់ចូលមកកម្ពុជាវិញភ្លាម បានចាប់ខ្លួនលោកស៊ឹង ង៉ុកថាញ់ ដែលពេលនោះ ជានាយករដ្ឋមន្ត្រីខ្មែរ នៅថ្ងៃទី១៥តុលាឆ្នាំ១៩៤៥ ហើយដាក់សម្តេច ស៊ីសុវត្ថិ មុនីរ៉េត ដែលត្រូវជាព្រះបិតុលារបស់ព្រះបាទនរោត្តម សីហនុ ឱ្យឡើងជំនួស នៅថ្ងៃទី១៧ តុលា ១៩៤៥ ដើម្បីឡាយព្រះហស្តលេខាលើកិច្ចព្រមព្រៀងបណ្តោះអាសន្នមួយជាមួយឧត្តមសេនីយ អាឡិចសង់ដ្រ៍(Alexandre) ស្នងការនៃសាធារណរដ្ឋបារាំងប្រចាំប្រទេសកម្ពុជា។ សន្ធិសញ្ញានោះ ធ្វើនៅថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៤៦។

ក្រោយពីចុះសន្ធិសញ្ញា ម៉ូឌុសវីវ៉ង់ឌី ដែលមានខ្លឹមសារសន្យាផ្តល់ស្វ័យភាពដល់កម្ពុជានោះហើយបារាំងមិនបានអើពើធ្វើអ្វីទាំងអស់។ ពេលវេលាបានអូសបន្លាយទៅអស់ប្រមាណបីឆ្នាំ បារាំងផ្តោតការយកចិត្តទុកដាក់តែទៅលើសង្គ្រាមជាមួយពួកវៀតមិញ ដែលមានចិនធ្វើខ្នងបង្អែក។ សភាពការណ៍នៅវៀតណាមខាងជើងកាន់តែធ្ងន់ធ្ងរ ធ្វើឱ្យបារាំងបែកគំនិតចង់ចាប់យួនបៅដាយឱ្យខាំគ្នាជាមួយយួនខាងជើងដែលជាកុម្មុយនិស្ត។ តែបៅដាយ ក៏ជាស្តេចដ៏ឆ្លៀតឆ្លាតគិតតែពីផលប្រយោជន៍ជាតិគេយ៉ាងខ្ពស់ដែរ ថ្វីបើមានពត៌មានខ្លះថាចូលចិត្តប៉ោឡែ អាវាសែផ្តេសផ្តាសក៏ដោយ។ ព្រោះគាត់បានទាមទារឱ្យបារាំងកាត់ដីកូសាំងស៊ីន ដែលស្ទើរតែទាំងមូលជាទឹកដីកម្ពុជាក្រោម ឱ្យទៅគាត់ជាមុនសិន ទើបគាត់អាចរៀបចំកងទ័ពប្រយុទ្ធប្រឆាំងនឹងពួកវៀតមិញបាន។ហេតុនេះហើយទើបនៅថ្ងៃទី២៥ខែមេសាឆ្នាំ១៩៤៩ បារាំងបានសន្យាថា នឹងប្រគល់ទឹកដីកូសាំងស៊ីននោះទៅឱ្យគាត់ ដែលជាហេតុធ្វើឱ្យពួកអេលីតខ្មែរនៅភ្នំពេញ មានការជ្រួលច្របល់យ៉ាងខ្លាំងចំពោះដំណឹងនេះ។

បើតាមខ្លឹមសារសៀវភៅ ក្រុងភ្នំពេញមុនឆ្នាំ១៩៥៤ (ទំព័រ១១០-៣)របស់អ្នកនិពន្ធ កែវ ប៊ុនធឿន បានឱ្យដឹងថា មកដល់ឆ្នាំ១៩៤៩ បារាំងបានយល់ព្រមឱ្យខ្មែរបង្កើតគណៈកម្មការមួយ ដើម្បីចូលចរចាជាមួយបារាំងនៅភ្នំពេញ ក្នុងគោលបំណងបញ្ចប់អាណត្តិសន្ធិសញ្ញាម៉ូឌុសវីវ៉ង់ឌី និងប្រែក្លាយមកជាកិច្ចព្រមព្រៀងរៀបចំទំនាក់ទំនងបារាំង-ខ្មែរ ឱ្យបានច្បាស់លាស់ឡើងជាងពេលមុន។ ស្របពេលក្រុមអ្នកចរចាសមភាគីជាមួយបារាំងនៅភ្នំពេញកំពុងប្រព្រឹត្តទៅ ក្រោមការដឹកនាំរបស់លោក ឈាន វ៉ម, ធន់ អ៊ុក និងសុន វ៉ុនសៃ ការសន្យាកាត់ដីកូសាំងស៊ីនឱ្យបៅដាយបានលេចឡើង ទើបរដ្ឋាភិបាលសម្រេចចិត្តបញ្ជូនប្រតិភូទៅចរចារឿងដីកម្ពុជាក្រោមនេះជាមួយរដ្ឋាភិបាលបារាំងនៅទីក្រុងប៉ារីសតែម្តង។ គណៈកម្មការនោះប្រុងប្រៀបទាមទារជាឱឡារិកនៅចំពោះមុខប្រធានាធិបតីបារាំង ហ្វ្រង់ស្វ័រ អូរីយ៉ូល ដែលគាំទ្រយួន និងមេដឹកនាំបក្សប្រឆាំងនាម សាល ដឺហ្គោល (Charles De Gaulle) ដែលមាន

ទំនោរគាំទ្រការទាមទាររបស់ខ្មែរ។ ពេលនោះការសម្រេចកាត់ដីកូសាំងស៊ីនឱ្យយួនបៅដាយ មិនទាន់សម្រេចនៅឡើយ ដោយសារ ព្រឹទ្ធសភាបារាំងដែលដឹកនាំដោយសាល ដឺហ្គោល មិនទាន់ប្រជុំអនុម័តនៅឡើយ។ ម្ល៉ោះហើយព្រះមហាក្សត្រខ្មែរ ព្រះបាទនរោត្តម សីហនុ និងលោក យ៉ែម សំបូរ ជានាយករដ្ឋមន្ត្រី បានបញ្ជូនប្រតិភូ ដែលដឹកនាំដោយលោក ឈាន វ៉ម ទៅចរចាជាមួយបារាំងនៅប៉ារីស ដោយទាមទារឱ្យបារាំងធានាបញ្ហាបីចំណុច ៖

**ខទី១**-សុំឱ្យខ្មែរកម្ពុជាក្រោម ដែលរស់នៅលើទឹកដីកូសាំងស៊ីន មានសិទ្ធិរក្សាសញ្ជាតិរបស់ខ្លួនជាខ្មែរជនជាតិភាគតិច មានសិទ្ធិរក្សាភាសាខ្មែរជាភាសារបស់ខ្លួន និងរក្សាវប្បធម៌ប្រពៃណីរបស់ខ្លួនជាខ្មែរ។

**ខទី២**-សុំឱ្យពន្យារការប្រគល់ទឹកដីកូសាំងស៊ីនទាំងមូលសិន។ សុំធ្វើការកែប្រែព្រំដែនខ្មែរ ឱ្យសមស្របតាមភូមិសាស្ត្រធម្មជាតិ គឺយកព្រែកជីកវិញតេជាព្រំដែនដើម ដោយពុំមែនគូសព្រំដែនខ្មែរនៅចម្ងាយ៣គីឡូម៉ែត្រពីព្រែកជីក ដោយមិនឱ្យខ្មែរចុះដងទឹកបានក្នុងព្រែកដែលខ្លួនបានជីកនោះទេ។ល។ និង។ល។

**ខទី៣**-សុំឱ្យទុកទន្លេមេគង្គជាផ្លូវទឹកអន្តរជាតិសម្រាប់ចុះទៅសមុទ្រ។

ពេលគណៈប្រតិភូកំពុងពិភាក្សាគ្នាយ៉ាងផុលផុស នៅក្នុងវិមានព្រឹទ្ធសភា ក្រោមការរង់ចាំជួយគាំទ្ររបស់ដឺហ្គោល ដែលជាមេបក្សប្រឆាំង អាចបោះឆ្នោតទម្លាក់រដ្ឋាភិបាលបារាំងនៅពេលនោះបាន។ ប៉ុន្តែ ជាអកុសលមានសារទូរលេខមួយពី ដឺរ៉េម៉ុង រ៉េស៊ីដង់ស៊ុប៉េរីយ័រនៅភ្នំពេញបានទៅដល់។ លោក ប៉ូល កូស្តហ្វ្ល័រេ (Paul Coste Floret) ដែលជារដ្ឋមន្ត្រីកិច្ចការឯនាយសមុទ្ទ សុំផ្អាកសម័យប្រជុំ ដើម្បីផ្តល់សារទូរលេខនោះ។ លោករ៉េស៊ីដង់ស៊ុប៉េរីយ័រ បានផ្តល់ដំណឹងថា "គណៈប្រតិភូខ្មែរដែលនៅក្នុងសាលព្រឹទ្ធសភានេះ ពុំមែនជាតំណាងខ្មែរទេ អ្នកដែលមកនេះតំណាងឱ្យតែខ្លួនឯងតែប៉ុណ្ណោះ។... នៅភ្នំពេញមានការព្រមព្រៀងគ្នារួចអស់ហើយ លើខ្លឹមសារនៃកិច្ចព្រមព្រៀងខ្មែរ-បារាំង អំពីគម្រោងដាក់ជំនួសម៉ូឌុសវីវ៉ង់ឌីនោះ"។

ក្រុមបារាំងដែលចង់ជួយប្រតិភូខ្មែរ ប្រែជាស្រឡាំងកាំង ងើបឡើងពីតុមើលមុខគណៈប្រតិភូខ្មែរ ដោយក្តីងឿងឆ្ងល់ ដំណាលគ្នានឹងសេចក្តីកាន់តែងឿងឆ្ងល់ មិនយល់ការវិវត្តន៍សភាពការណ៍របស់គណៈប្រតិភូខ្មែរដែរ។ ពួករដ្ឋាភិបាលបារាំង ដែលចង់ជំរុញល្បឿននៃការផ្ទេរសមត្ថកិច្ចគ្រប់គ្រងកូសាំងស៊ីន ឱ្យទៅបៅដាយឱ្យបានឆាប់ បានប្រញាប់ពន្យល់សមាជិកបក្សប្រឆាំងរបស់ខ្លួនថា ផលប្រយោជន៍របស់គេនៅវៀតណាមមានទំហំធំជាង និងបន្ទាន់ជាង ត្បិតចិនកុម្មុយនិស្តកាន់តែរំកិលមកកៀកកិតជិតព្រំដែនយួនមែនទែនហើយ ដើម្បីគាំទ្រពួកវៀតមិញនៅវៀតណាមខាងជើង។ ដូច្នេះ បារាំងត្រូវការយកយួនខាងត្បូងរបស់បៅដាយ ទៅទប់យួនខាងជើងរបស់ហូជីមិញ។ អញ្ចឹងហើយ ទើបត្រូវកាតផ្តាច់កូសាំងស៊ីនឱ្យបៅដាយជាប្រញាប់ ដើម្បីស្តារសភាពការណ៍ឱ្យទាន់ពេលវេលា។

ពេលគណៈប្រតិភូខ្មែរ ដែលរួមមានលោក សឺន សាន ផងដែរនោះ មកដល់សណ្ឋាគារវិញ ក៏បានឃើញសារទូរលេខយ៉ាងខ្លីរបស់លោក យ៉ែម សំបូរ បញ្ជាក់ថា "បេសកកម្មរបស់គណៈប្រតិភូ ត្រូវចប់តែត្រឹមនេះ"។ នេះជាការបាត់បង់ឱកាសល្អដ៏ធំមួយរបស់ខ្មែរ ក្នុងការទាមទារយកសិទ្ធិមួយចំនួនសម្រាប់ដែនដីកម្ពុជាក្រោម។ ពេលគណៈប្រតិភូត្រឡប់មកដល់មាតុប្រទេសវិញ ទើបបានដឹងថា នៅអំឡុងពេលពួកគេកំពុងចរចា នៅភ្នំពេញរដ្ឋាភិបាលបារាំងបានប្រញាប់ប្រញាល់ធ្វើកិច្ចព្រមព្រៀងមួយជាមួយរាជរដ្ឋាភិបាលខ្មែរ ស្តីពីកម្មវិធីសន្យាប្រគល់ស្វ័យភាពកម្ពុជា ដើម្បីជាថ្នូរនឹងការដែលខ្មែរទាមទារសិទ្ធិលើដីកូសាំងស៊ីន។ បើតាមសៀវភៅ កម្ពុជា និងសហព័ន្ធឥណ្ឌូចិន របស់លោក ចាន់ ដារ៉ា ថានៅពេលនោះ លោកអគ្គទេសាភិបាលបារាំងប្រចាំនៅឥណ្ឌូចិន បានធ្វើទស្សនកិច្ចនៅភ្នំពេញ ហើយបានលើបញ្ហាពីរឱ្យព្រះមហាក្សត្រនរោត្តម សីហនុ ជ្រើសរើសយកតែមួយប៉ុណ្ណោះ នោះគឺ

ជម្រើសរវាងទឹកដីកូសាំងស៊ីន និងឯករាជ្យរបស់កម្ពុជា។ បើចង់បានទឹកដីកូសាំងស៊ីន បារាំងនឹងមិនទាន់ប្រគល់ឯករាជ្យឱ្យខ្មែរទេ។ ផ្ទុយទៅវិញ បើចង់បានឯករាជ្យ នោះត្រូវតែបាត់ទឹកដីកូសាំងស៊ីន។[87] ហើយចម្លើយរបស់ព្រះរាជាគឺព្រះអង្គចង់បាន"ឯករាជភាព"ទើបបារាំងអស់កង្វល់ក្នុងការដោះស្រាយបញ្ហានេះ។ ក្រោយពីព្រះមហាក្សត្ររំលាយរដ្ឋសភាចោល ព្រោះពួកសភាដែលភាគច្រើនជាសមាជិកគណបក្សប្រជាធិបតេយ្យ អាចជាអ្នកជំទាស់ដំណើរការទទួលឯករាជ្យរបស់ព្រះអង្គ ៗបានប្រគល់នាទីឱ្យស្ដេចក្រុមហ្លួង ស៊ីសុវត្ថិ មុនីពង្ស ចុះហត្ថលេខាលើគម្រោងឯករាជ្យពីបារាំងរបស់កម្ពុជានៅ ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៤៩ នោះដោយជោគជ័យ។ ឯករាជ្យនេះត្រូវបានប្រកាសផ្សព្វផ្សាយ និងទទួលបានការអបអរសាទរពីបណ្ដាប្រទេសជាច្រើន ប្រមាណជាង៤០ប្រទេសក្នុងអំឡុងពេលប្រមាណបីខែបន្ដបន្ទាប់មក។ តែទោះជាយ៉ាងណា ព្រះបាទនរោត្ដម សីហនុ នៅតែចាត់ទុកឯករាជ្យនោះថាជាឯករាជ្យក្លែងក្លាយ មិនពេញលេញឡើយ រហូតធ្វើឱ្យព្រះអង្គ សម្រេចព្រះទ័យចាប់ធ្វើរាជបូជនីយកិច្ចទាមទារឯករាជ្យពិតប្រាកដមួយចាប់ពីដើមឆ្នាំ១៩៥២ ចេញពីខេត្តសៀមរាប៕

[87] នៅថ្ងៃទី០៤ខែមិថុនាឆ្នាំ១៩៤៩ បារាំងបានសម្រេចជាផ្លូវការប្រគល់ទឹកដីកម្ពុជាក្រោមឱ្យទៅស្ដេចបៅដាយរបស់វៀតណាម។

# មេរៀនទី 10 អាណិក្រមទំនើបកម្មរបស់បារាំងនៅកម្ពុជា និងផលវិបាក

អភិក្រមទំនើបកម្ម គឺជាសកម្មភាព ឬគោលនយោបាយដែលបារាំងសាបព្រោះ ដើម្បីធ្វើឱ្យជីវភាពរស់នៅរបស់អ្នកស្រុកមានការប្រែប្រួលបែរឆ្ពោះទៅរកភាពទំនើប តាមគំរូនៃមហាប្រទេសនៅទ្វីបអឺរ៉ុប។ ក្នុងករណីកម្ពុជាដែលស្ថិតនៅក្រោមរបបអាណាព្យាបាល និងអាណានិគមបារាំង គេបានដឹងថា បានទទួលឥទ្ធិពលនៃចរន្តទំនើបភាវូបនីយកម្មពីបារាំង ស្ទើរគ្រប់វិស័យ។ ជាការពិត មានអ្នកនិពន្ធអឺរ៉ុបម្នាក់ បានថ្លែងកោតសរសើរ ថា ប្រសិនបើកម្ពុជាគ្មានបារាំងទេ ម្ល៉ោះកម្ពុជា គ្មានកំណែទម្រង់ស្ថាប័នជាតិតាមបែបបស្ចិមប្រទេស និងញ៉ាំងឱ្យប្រទេសរបស់ខ្លួនមានភាពជឿនលឿនបានដែរ។ យ៉ាងហោចណាស់ បារាំងបានចាប់ផ្តើមគិតគូរពីទំនើបភាវូបនីយកម្មនៅកម្ពុជា ចាប់ពីទសវត្សរ៍ឆ្នាំ១៨៨០មកដែរ បើយើងក្រឡេកមើលទៅព្រឹត្តិការណ៍បង្ខំស្តេចនរោត្តម ឱ្យចុះអនុសញ្ញាថ្ងៃទី១៧ មិថុនា ១៨៨៤ ដោយទេសាភិបាលកូសាំងស៊ីន នាម Charles Thompson។

ទាក់ទងនឹងចំនួនប្រជាជនកម្ពុជា ចាប់តាំងពីស្ថិតក្រោមការការពាររបស់បារាំងរហូតដល់បានទទួលឯករាជ្យ ដែលមានអំឡុងពេលជិតមួយសតវត្សរ៍ ក្នុងសុខសន្តិភាព ឃើញថា មានកំណើនប្រមាណ៤ដង៖

- ឯកសារខ្លះថា មានខ្មែរជិតមួយលាននាក់នៅពេលបារាំងចូលមកដល់ដំបូង
- ឯកសារខ្លះទៀត ថាមានជាងមួយលាននាក់ (អេត្យេន អៃម៉ូនីញេ =១,២លាននាក់)
- បន្ទាប់ពីការគ្រប់គ្រងអស់ជិតមួយសតវត្សរ៍ គេឃើញប្រជាជនខ្មែរកើនឡើងប្រមាណ៤ដង គឺជាង៤លាននាក់នៅឆ្នាំ១៩៥៧

## 1. អភិក្រមទំនើបកម្ម

### 1.1. កំណែទម្រង់រចនាសម្ព័ន្ធរដ្ឋបាល

បើតាមស្នាដៃនិក្ខេបបទ ថ្នាក់បណ្ឌិតប្រវត្តិសាស្ត្ររបស់លោកបណ្ឌិត ស៊ន សំណាង បានគូសបញ្ជាក់អំពីការវិវឌ្ឍន៍នៃអង្គការរដ្ឋបាល នៅកម្ពុជាក្រោមរបបអាណានិគមបារាំង ដូចតទៅនេះ៖

*** រដ្ឋបាលកណ្តាល**

**១- រដ្ឋបាលអាណាព្យាបាល**

អ្នកតំណាងប្រទេសបារាំងមានឈ្មោះជាបន្តបន្ទាប់ថា

អ្នកតំណាងរបបអាណាព្យាបាល (១៨៦៣-១៨៨៥)

អគ្គរេស៊ីដង់ (១៨៨៥-១៨៨៩)

រេស៊ីដង់ជាន់ខ្ពស់ (១៨៨៩ រហូតដល់ចប់របបអាណានិគម)

ក្រឹត្យចុះថ្ងៃទី ២០ តុលា ១៩១១ បញ្ជាក់ច្បាស់អំពីអំណាចរបស់រេស៊ីដង់ជាន់ខ្ពស់ដែលប្រគល់ឱ្យដោយអគ្គទេសាភិបាលឥណ្ឌូចិន ។

**១-១-ក្រុមប្រឹក្សាអាណាព្យាបាល**

ក្រិត្យចុះថ្ងៃទី២០ តុលា ១៩១១ បង្កើតក្រុមប្រឹក្សាមួយហៅថា ក្រុមប្រឹក្សាអាណាព្យាបាលនៅអមរេស៊ីដង់ជាន់ខ្ពស់នៅកម្ពុជាដើម្បីដាក់ស្នើគម្រោងផ្សេងៗ និងពិគ្រោះយោបល់ក្នុងគ្រប់ករណីដែលចាំបាច់ ។

ពោលឱ្យខ្លីក្រុមប្រឹក្សាអាណាព្យាបាល នៅអមរេស៊ីដង់ជាន់ខ្ពស់ ដើម្បីជួយសម្រួលភារកិច្ចរដ្ឋបាល ប៉ុន្តែមិនអាចជំទាស់យោបល់ និងសកម្មភាពការងាររបស់រេស៊ីដង់ជាន់ខ្ពស់ទេ ។

**១-២-ការិយាល័យនៃទីស្តីការរេស៊ីដង់ជាន់ខ្ពស់**

ខុទ្ទកាល័យ, ទីចាត់ការការិយាល័យ, ការិយាល័យទី១, ការិយាល័យទី២, ការិយាល័យទី៣ និងការិយាល័យទី៤

**១-៣-អធិការកិច្ចនៃកិច្ចការនយោបាយ និង រដ្ឋបាល**

ដើម្បីជួយរំលែកកិច្ចការរបស់រេស៊ីដង់ជាន់ខ្ពស់ តាមអនុក្រិត្យចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩១២ អគ្គទេសាភិបាលឥណ្ឌូចិន បង្កើតនៅកម្ពុជា នូវអធិការកិច្ចនៃកិច្ចការនយោបាយ និងរដ្ឋបាល ។

**១-៤-សាលាក្រុងភ្នំពេញ** (មើលមាត្រាទី១០ នៃអនុសញ្ញាថ្ងៃទី១៧ មិថុនា ១៨៨៤)។

**២-រដ្ឋាភិបាលកម្ពុជា**

គឺរាជប្រកាសចុះថ្ងៃទី០៣ និងទី១១កក្កដា ១៨៩៧ ដែលបានកំណត់នូវរបត់ដ៏សំខាន់មួយក្នុងនយោបាយរដ្ឋបាលនៃរាជាណាចក្រកម្ពុជា ។

*ក្រុមប្រឹក្សារដ្ឋមន្ត្រី

រាជប្រកាសចុះថ្ងៃទី ៣កក្កដា១៩០៥, ៣១ធ្នូ១៩២៦ និង១៩មីនា១៩២៩ កំណត់នូវសមត្ថកិច្ចរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី។ ក្រុមប្រឹក្សានេះ ដែលរួមប្រជុំក្រោមអធិបតីភាពរបស់រេស៊ីដង់ជាន់ខ្ពស់ មានសមាសភាពដូចតទៅ ៖

អគ្គមហាសេនា ៖ រដ្ឋមន្ត្រីទី១, រដ្ឋមន្ត្រីមហាផ្ទៃ និងធម្មការ

វាំង ៖ រដ្ឋមន្ត្រីរាជវាំង, ហិរញ្ញវត្ថុ និងវិចិត្រសិល្បៈ

យមរាជ ៖ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ចក្រី ៖ រដ្ឋមន្ត្រីសង្គ្រាម, សាធារណសិក្សា និងសាធារណការ

ក្រឡាហោម ៖ រដ្ឋមន្ត្រីទ័ពជើងទឹក, កសិកម្ម, ឧស្សាហកម្ម និងពាណិជ្ជកម្ម ។

* រដ្ឋបាលខេត្ត

តាមក្រមថៅហ្វាយស្រុកនៅឆ្នាំ១៨០៨ ដែលសល់កេរ្តិ៍ពីព្រះបាទជយជេដ្ឋាទី៣ឆ្នាំ១៦៩៣បានរៀបរាប់ឈ្មោះស្រុក(គឺខេត្ត)សរុបឱ្យដឹងថា មានចំនួន៣១។ បើតាមប្រកាសអារ៉ែតេរបស់លោករ៉េស៊ីដង់ស៊ុប៉េរ្យើរ ចុះថ្ងៃទី៣ខែធ្នូ ឆ្នាំ១៩១៧ បានកំណត់ឱ្យមានខេត្ត៥១ ដែលត្រូវចាត់ថ្នាក់ជា៥ក្រុម គឺខេត្តផុតលេខចំនួន៣ខេត្ត, ខេត្តលេខមួយចំនួន៦, ខេត្តលេខពីរ ៧ខេត្ត, ខេត្តលេខបី ១០ខេត្ត, ខេត្តលេខបួន ១២ខេត្ត, និងខេត្តលេខប្រាំ ១៣ខេត្ត។

**១-ការអនុវត្តកំណែទម្រង់រដ្ឋបាលនៅប្រទេសកម្ពុជាក្រោយសង្គ្រាមលោកលើកទី១(១៩១៨)**

**១-១ ការប្រមូលផ្តុំអំណាចរដ្ឋបាល**

រាជប្រកាសថ្ងៃទី១១ខែធ្នូឆ្នាំ១៩២១ បង្កើតតំបន់រដ្ឋបាលមួយហៅថា ខ័ណ្ឌនៅចន្លោះស្រុក និងឃុំ។

**១-២ ការផ្តាច់ខ្លួនចេញនៃអំណាចតុលាការ**

តុលាការសម្រាប់ជនម្ចាស់ស្រុកត្រូវបានកែទម្រង់ដោយរាជប្រកាសចុះថ្ងៃទី១៤ កញ្ញា ១៩២២។ អត្ថបទនៃរាជប្រកាសនេះ បានលុបចោលសាលាឧក្រិដ្ឋចំនួន៥២ នៅតាមខេត្ត ហើយជំនួសដោយសាលាឧក្រិដ្ឋតែមួយដែលបើកសវនាការមួយ ហើយជំនួសទៅដោយសាលាឧក្រិដ្ឋតែមួយដែលបើកសវនាការមួយត្រីមាសម្តងនៅភ្នំពេញ ។

**២-ការវិវត្តចាប់ពីឆ្នាំ ១៩២១**

**២-១ អំណាចរដ្ឋបាល**

**តារាងខាងក្រោមនេះបង្ហាញនូវការវិវឌ្ឍន៍នៃរចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ខេត្តៈ**

| មុនកំណែទម្រង់ | ក្រោយកំណែទម្រង់ (រ.ប ១១ ធ្នូ ១៩២១) |
|---|---|
| <u>រេស៊ីដង់ខេត្ត</u><br>ខេត្ត<br>ស្រុក<br>ឃុំ | <u>រេស៊ីដង់ខេត្ត = ខេត្ត</u><br>ស្រុក<br>ខ័ណ្ឌ<br>ឃុំ |

**២-២ ការវិវត្តនៅក្នុងរេស៊ីដង់ព្រៃវែង**

| របបរដ្ឋបាលចាស់ | របបរដ្ឋបាលថ្មី |
|---|---|
| ១៩២១ មករា ១៩២២<br>ខេត្ត៥ ៖ ខេត្ត៤ ៖<br>ព្រៃវែង - ព្រៃវែង<br>បាភ្នំ - បាភ្នំ<br>ស៊ីធរកណ្តាល - ស៊ីធរកណ្តាល<br>ស៊ីធរពារាំង - ពារាំង<br>ល្វាឯម<br>ខ័ណ្ឌ ៤ ៖ ខ័ណ្ឌ ៣ ៖<br>កំចាយមារ -កំចាយមារ<br>កញ្ជៀច -កញ្ជៀច<br>អានបិញ -អានបិញ<br>បាណាម | <u>១០ កញ្ញា ១៩២២</u><br>ខេត្ត១ ៖<br>ព្រៃវែង<br>ស្រុក២ ៖<br>ព្រៃវែង<br>បាភ្នំ<br>ខ័ណ្ឌ ៨ ៖<br>កំចាយមារ<br>កញ្ជៀច<br>អានបិញ<br>ព្រៃវែង, ពារាំង, ស៊ីធរកណ្តាល,<br>កំពង់ត្របែក, ឈើកាច់ |

ក្នុងរយៈពេលដប់ឆ្នាំក្រោយកំណែទម្រង់ អង្គការរដ្ឋបាលមានស្ថេរភាព។ ការប្រែប្រួលកើតមានឡើងជាថ្មីនៅឆ្នាំ ១៩៣៤ ដោយការលុបបំបាត់ខ័ណ្ឌទៅវិញ ។

**តារាងខាងក្រោមនេះសង្ខេបនូវការវិវឌ្ឍន៍ ៖**

| មុន ១៩២១ | ចាប់ពី១៩២១ | កក្កដា ១៩៣៤ |
|---|---|---|

| | | |
|---|---|---|
| ទីរស៊ីដង់<br>ខេត្ត<br>ស្រុក<br>ឃុំ | រេស៊ីដង់ខេត្ត = ខេត្ត<br>ស្រុក<br>ខ័ណ្ឌ<br>ឃុំ | រេស៊ីដង់ខេត្ត = ខេត្ត<br>ស្រុក<br>..... (លុបចោល)<br>ឃុំ |

*ចាប់ពីថ្ងៃទី ១ សីហា ១៩៣៧ មានការបង្កើតនិគម ជាការពិសោធន៍នៅខេត្តព្រៃវែង ។*

ដូច្នេះ បារាំងបានរៀបចំកែទម្រង់ដែនដីរដ្ឋបាលទូទាំងប្រទេស ដែលមានលក្ខណៈសាំញ៉ាំស្មុគស្មាញឱ្យមានទម្រង់រចនាសម្ព័ន្ធ និងឋានានុក្រមបែបបារាំង។ ដោយដំបូងឡើងបារាំងរួបរួមអតីតខេត្តបុរាណមួយចំនួនបញ្ចូលគ្នា បង្កើតជា"តំបន់" Circonscription/Division ។ ក្រោយមក "តំបន់"នេះឯងត្រូវបន្ថយមកជា "ខេត្ត" Province វិញ។ ចំណែកអតីតខេត្ត ខ្លះត្រូវបន្ថយមកជា "ស្រុក" District , ខ្លះទៀតធ្លាក់ទៅជា "ឃុំ"Commune និងខ្លះទៀត ត្រូវធ្លាក់ទៅនៅត្រឹមជាឈ្មោះ "ភូមិ" Village និងខ្លះទៀត ត្រូវបាត់ឈ្មោះសូន្យឈឹងតែម្តង ដូចជា ខេត្តអន្លង់រាជ, កុញ្ជរ, ព្រំទេព, ព្រៃក្ដី ជាដើម។

ជាង៣០ឆ្នាំដំបូង បារាំងមិនបានតាំងរេស៊ីដង់របស់ខ្លួននៅតាមខេត្តទេ តែនៅចុងសតវត្សរ៍ទី១៩និងដើមសតវត្សរ៍ទី២០ បារាំងបានតាំងមន្ត្រីរបស់ខ្លួនឱ្យឈរត្រួតមើល មន្ត្រីរាជការខ្មែរនៅតាមតំបន់ និងខេត្ត(ពេលក្រោយមក) យ៉ាងសកម្ម ហើយដែលមានរបៀបរបបធ្វើការខុសគ្នាស្រឡះពីអ្នករាជការខ្មែរ។

### 1.2. នយោបាយសារពើពន្ធ

នយោបាយទារពន្ធដារពីប្រជារាស្ត្រខ្មែរ ដោយរដ្ឋបាលបារាំង ចាប់ផ្តើមឡើងក្រោយមានការលុបបំបាត់ចោលនូវរបបទាសភាព និងរបបដែលចាត់ទុកថា ដីធ្លីទាំងអស់របស់ប្រទេសគឺ ដីរបស់ស្ដេច។ ហើយគេបានអនុញ្ញាតឱ្យមាន និងទទួលស្គាល់របបកម្មសិទ្ធិឯកជនរបស់ប្រជាពលរដ្ឋ។

បារាំងបានចាប់ផ្តើមលុបបំបាត់ចោលនូវបទបញ្ញត្តិពន្ធដារបែបប្រពៃណីរបស់កម្ពុជា នៅអំឡុងចុងសតវត្សរ៍ទី១៩ បន្ទាប់ពីពេលដែលគេអាចដកអំណាចទាំងអស់ពីព្រះបាទនរោត្តមបាន ប្រកបដោយជោគជ័យ។ ជាពិសេសរបៀបទារពន្ធដារដោយអាជ្ញាហ្លួង ដែលជាភ្នាក់ងារទារពន្ធដាររបស់ព្រះរាជា ត្រូវជំនួសដោយភ្នាក់ងារជាមេឃុំ ដែលធ្វើការក្រោមកិច្ចត្រួតពិនិត្យ និងណែនាំដោយបារាំង។ ហើយសារពើពន្ធបានចាប់ផ្តើមពង្រឹងនៅពេលបារាំងតាំងរ៉េស៊ីដង់នៅតាមទីរ៉េស៊ីដង់នីមួយៗ ដែលគេបានប្រមូលខេត្តខ្មែរបុរាណមួយចំនួនចូលគ្នា ហើយដែលទីរ៉េស៊ីដង់ទាំងនោះ យើងអាចចំណាំបានដោយងាយ ដោយសព្វថ្ងៃវាក្លាយជាទីរួមខេត្តទាំងអស់នៃប្រទេសកម្ពុជា។ លើកលែងតែពន្ធលើកម្លាំងពលកម្មមួយប៉ុណ្ណោះ ដែលបារាំងមិនបានលុបបំបាត់ចោល ព្រោះពន្ធបែបនេះ វាបានចម្រើនដល់រាជការបារាំង។

ទាក់ទងនឹងនយោបាយសារពើពន្ធនេះ យើងបានលើកយកស្នាដៃសង្ខេបមួយរបស់លោកបណ្ឌិតរដ្ឋ ឃឹន សុខ ដែលសរសេរសម្រាប់ការបង្រៀនស្តីអំពី"ប្រទេសកម្ពុជាក្នុងរជ្ជកាល ព្រះបាទស៊ីសុវត្ថិពី គ.ស.១៩០៤ ដល់១៩២៧ ព្រះបាទស៊ីសុវត្ថិមុនីវង្ស ពីគ.ស.១៩២៧ ដល់១៩៤១ និងព្រះបាទ សីហនុ ពីគ.ស.១៩៤១....." មកសម្រួលដូចតទៅនេះ ៖

#### ក-ពន្ធខ្លួន

ការបង់ពន្ធខ្លួនបានចាប់ផ្តើមឡើង សម្រាប់ប្រជាជនខ្មែរភេទប្រុសទាំងអស់ដែលមានអាយុចាប់ពី១៨ឆ្នាំ គត់រហូតដល់៦០ឆ្នាំគត់ លើកលែងតែព្រះរាជបុត្រា បុត្រី ព្រះរាជនត្តា អ្នកដែលជាប់ជាព្រះវង្សនៃស្តេចកំពុងសោយរាជ្យ និងបុព្វក្សត្រ ពួកបារគូ ព្រះវង្ស ព្រះសង្ឃ ដែលមានសញ្ញាប័ត្រ (ដូចមានចែងនៅក្នុងព្រះរាជប្រកាស ចុះថ្ងៃទី១៨មីនា១៩១៦) ជនពិការ ទាហានខ្មែរ ពួកឃាមល្បាតដែលបំពេញបំពេញមុខការ ទាហានបម្រុង និងទាហានឃាមល្បាតចូលនិវត្ត និងជនពិការទទួលប្រាក់បំណាច់។ ក្រៅពីនោះមានជនជាតិសៀម និងលាវ ដែលបារាំងចាត់ទុកដូចជាជនជាតិខ្មែរដែរ។ ចំណែកជនជាតិយួន-អាណ្ណាម នៅអំឡុងទសវត្សរ៍១៨៨០-១៩០០ ត្រូវបារាំងលើកលែង ដើម្បីទាក់ទាញពួកនេះឱ្យចូលមករស់នៅកម្ពុជាកាន់តែច្រើនឡើង។ ហើយចាប់ពីទសវត្សរ៍ ១៩១០ មក ទើបត្រូវជាប់កាតព្វកិច្ចបង់ពន្ធដូចគ្នានឹងខ្មែរ។ តែបារាំងបានចាត់ចែងប្រធានឃុំយួនសម្រាប់គ្រប់គ្រងទទួលខុសត្រូវលើពួកយួនដោយឡែកពីខ្មែរ។ ទោះបីជាពួកគេរស់នៅលាយឡំជាមួយសង្កាត់ខ្មែរក៏ដោយ។ ប្រធានថ្នាក់ឃុំពួកយួនទាំងនោះ តែងតាំងដោយរ៉េស៊ីដង់ជាន់ខ្ពស់របស់បារាំង។ សម្រាប់ពួកយួន ត្រូវបង់ពន្ធខ្លួនម្នាក់ៗ ចំនួន ៣,១ប្យ៉ាស ឬបីរៀលមួយកាក់ក្នុងមួយឆ្នាំ។ អ្នកទារពន្ធគឺជាមេឃុំខ្មែរ និងប្រធានយួន(ថ្នាក់ឃុំ)។ រីឯជនជាតិក្លិង្គ(ឥណ្ឌា) និងចិនកាត់យួន គេចាត់ទុកដូចជាជនជាតិមិញហួងនៃដែនដីកូសាំងស៊ីន ឬដូចគ្នានឹងជនជាតិយួន-អាណ្ណាមដែរ។

## ខ-ពន្ធកំណែន

### *ខ-១-ជនជាតិខ្មែរ និងជនជាតិអាស៊ី*

ក្នុងចំណោមមុខពន្ធទាំងអស់ដែលបារាំងបានកែប្រែ មានតែពន្ធកំណែននេះឯង ដែលបារាំងនៅមានចេតនារក្សាទុក។ ព្រោះ វាធ្វើឱ្យបារាំងចំណេញថវិកា និងកម្លាំងពលករដែលធ្វើការងារពលកម្មសព្វបែបយ៉ាងដោយមិនបាច់ចំណាយលុយជួល។ ពន្ធកំណែន គឺជាពន្ធសម្រាប់យកទៅចំណាយលើការងារសាធារណការ។ ប្រជាជនខ្មែរត្រូវជាប់ពន្ធធ្វើការងារកំណែនចំនួន១០ថ្ងៃ ហើយវាជាកាតព្វកិច្ចសម្រាប់តែប្រជាជនណាដែលជាប់ពន្ធខ្លួនប៉ុណ្ណោះ។ ជនជាតិខ្មែរ, សៀម, លាវ, យួន-អាណ្ណាម ត្រូវបង់ពន្ធនេះចំនួន៤ប្យ៉ាស ឬ៤រៀលក្នុងមួយឆ្នាំ ដោយគិតកម្រៃ០,៤ប្យ៉ាស ឬ៤កាក់ក្នុងមួយថ្ងៃ។ លើកលែងតែពួកបរទេសអាស៊ី (គឺចិន) ត្រូវបង់តម្លៃទ្វេគុណ គឺ៨ប្យ៉ាស ឬ ៨រៀលក្នុងមួយឆ្នាំ។

លោកអគ្គទេសាភិបាល សម្រេចឱ្យយកប្រាក់ចំនួន៣%នៃពន្ធកំណែន ឱ្យទៅប្រធានជនជាតិយួន និងប្រធានសហគមន៍នៅក្រុងភ្នំពេញ ដែលជាអ្នកទទួលខុសត្រូវក្នុងការទារពន្ធនេះ ដោយពុំចាំបាច់មានជំនួយពីចៅសង្កាត់ខ្មែរឡើយ។ នៅឆ្នាំ១៩១៤ ពន្ធកំណែននៅកម្ពុជាប្រមូលបានចំនួន ១០៩២០០០ប្យ៉ាស។

**សម្រាប់ការលោះពន្ធកំណែន សម្រាប់មនុស្សម្នាក់ៗ គឺៈ**

| ជនជាតិ និងក្រុមដែលនៅជាមួយ | អាយុមនុស្សជាប់កំណែន | ឆ្នាំ១៩២០ | ឆ្នាំ១៩៣០ |
|---|---|---|---|
| ខ្មែរ | ២១-៦០ឆ្នាំ | ១០ថ្ងៃ=៤ប្យ៉ាស | ៤ថ្ងៃ=១,៦ប្យ៉ាស |
| យួន-អាណ្ណាម | ១៨-៦០ឆ្នាំ | ១០ថ្ងៃ=៤ប្យ៉ាស | ៥ថ្ងៃ=២ប្យ៉ាស |
| បរទេសអាស៊ី | ១៨-៦០ឆ្នាំ | ១០ថ្ងៃ=៨ប្យ៉ាស | ៦ថ្ងៃ=៤,៨ប្យ៉ាស |

### *ខ-២-ជនជាតិអឺរ៉ុប*

ជនបរទេសអឺរ៉ុប ក៏ដូចជាជនជាតិបារាំងដែរ ត្រូវជាប់ពន្ធអាករ ជំនួសឱ្យពន្ធខ្លួន និងពន្ធកំណែនដែលក្នុងមួយឆ្នាំៗ ពួកគេត្រូវបង់មានចាប់ពី១០ប្យ៉ាស ទៅ៥០ប្យ៉ាស អនុលោមទៅតាមចំនួនប្រាក់ចំណូល ដែលបាននៅចន្លោះ ២៣៩៩ប្យ៉ាសដល់៣២០០ប្យ៉ាស។ កម្រិតពន្ធនេះ នៅមានការបន្ធូរបន្ថយថែមទៀតអាស្រ័យតាមចំនួនមនុស្សនៅក្នុងបន្ទុក ដូចជា ៖

គេបន្ថយ១ភាគ៥ បើអ្នកជាប់ពន្ធនោះមានមនុស្សម្នាក់ នៅក្នុងបន្ទុក
គេបន្ថយ១ភាគ៣ បើអ្នកជាប់ពន្ធនោះមានមនុស្សពីរនាក់ នៅក្នុងបន្ទុក
គេបន្ថយ១ភាគ២ បើអ្នកជាប់ពន្ធនោះមានមនុស្សបីនាក់ នៅក្នុងបន្ទុក
គេបន្ថយ៣ភាគ៤ បើអ្នកជាប់ពន្ធនោះមានមនុស្ស៤នាក់ឡើង នៅក្នុងបន្ទុក

### គ-ពន្ធដារ និងពន្ធអាករ

#### *គ-១-ពន្ធលើដីដាំដំណាំ*

ចាប់ពីថ្ងៃទី១៧ខែតុលាឆ្នាំ១៩២១មក ដីដែលអាចធ្វើដំណាំបាន ត្រូវតែជាប់ពន្ធ គឺលើ"ដីដាំដុះ"ឬ"ពន្ធដីដំណាំ"។ ពោលគឺ ដីណាដែលកាប់ឆ្ការរួចហើយ ៗអាចធ្វើដំណាំបាន ទោះជាមានដំណាំក្ដី មិនមានដំណាំក្ដី លើកលែងតែដីស្រែដែលគេប្រើច្បាប់មួយដោយឡែកទៀត។ គេបែងចែកដីដំណាំទាំងនោះជាប្រភេទ យោងតាមដីនោះមានជីរជាតិ ឬអត់ និងតាមទំហំផ្ទៃរបស់វា។ ចំពោះដីដំណាំណា ដែលម្ចាស់មិនទាន់ធ្វើដំណាំនៅលើវានៅឡើយ បារាំងមិនទាន់គិតពន្ធទេ។ តែចំពោះដីណា គេធ្លាប់ដាំដំណាំហើយ ធ្លាប់ទទួលបានផលហើយ បើទុកជាឆ្នាំបន្តបន្ទាប់ ម្ចាស់មិនបានធ្វើក៏ដោយ ក៏រដ្ឋការបារាំងត្រូវគិតពន្ធដារដែរ ដោយម្ចាស់មិនអាចយកលេសផ្សេងៗមានដោះសារ ដើម្បីសុំឱ្យលើកលែងពន្ធបានដែរ។ អាណានិគមបារាំងធ្វើយ៉ាងនេះ ដើម្បីបង្ខំម្ចាស់ដីកុំឱ្យទុកដីចោលទំនេរ។ ព្រោះ គេត្រូវការធ្វើឱ្យខ្មែរក្លាយជាកសិករសកម្ម មានសេដ្ឋកិច្ចរីកចម្រើន។ ព្រោះគេមិនឱ្យកសិករធ្វើឱ្យខូចដល់ប្រយោជន៍រួម ដោយសារប្រទេសត្រូវបាត់បង់ផលិតផលដំណាំនៅលើដីទាំងនោះ។

តាមពិតទៅ ការកំណត់ច្បាប់បែបនេះ មិនបានធ្វើឱ្យប្រជាកសិករខ្មែរសប្បាយចិត្តឡើយ។ ពួកគាត់ពេលខ្លះទប់កំហឹងមិនបាន។ ព្រោះថា ការងារដាំដុះ ដំណាំចំការ អាចធ្វើទៅកើត អាស្រ័យលើអំណោយផលរបស់ធម្មជាតិជាច្រើនផ្នែក និងលទ្ធភាពរបស់មនុស្ស។ បើទោះបីជា គ្រឿងចក្រ ក៏នៅគ្មានភាពទៀងទាត់ក្នុងការប្រើប្រាស់បានដែរ ចុះទម្រាំកម្លាំងមនុស្ស រឹតតែមិនអាចបញ្ចេញប្រកបដោយនិយតភាពបានឡើយ។

**ដីបួនប្រភេទដែលបារាំងបានបែងចែក គឺ ៖**

ប្រភេទទី១ គឺដីពិសេសសម្រាប់ដាំថ្នាំ និងអំពៅ ថ្លៃពន្ធដី១ហិចតា ១២ប្យ៉ាស
ប្រភេទទី២ គឺដីដែលអាចដាំកាហ្វេ កប្បាស ដូង ស្លា និងកៅស៊ូ ថ្លៃពន្ធដី១ហិចតា ៨ប្យ៉ាស
ប្រភេទទី៣ គឺដីដែលអាចដាំត្រុំ ចេក សណ្ដែក ល្ង បន្លែ និងមន ថ្លៃពន្ធដី១ហិចតា ៥ប្យ៉ាស
ប្រភេទទី៤ គឺសម្រាប់ដាំដំឡូងជ្វា សណ្ដែកបាយ សណ្ដែកសៀង ត្រាវ ពោត ល្ពៅ ឪឡឹក ត្រសក់ ត្រប់ ប៉េងប៉ោះ ល្ហុងខ្វៃ ដើមឈើស៊ីផ្លែ ថ្លៃពន្ធដី១ហិចតា ៣ប្យ៉ាស។

#### *គ-២-ពន្ធចម្ការ និងពន្ធដីពន្ធាស*

*គ-២-១-ដីចម្ការ*

តាមសេចក្តីប្រកាសចុះថ្ងៃទី៣១ធ្នូ១៩១៧ ដាក់ឱ្យអនុវត្តន៍ព្រមគ្នានូវបទបញ្ញត្តិ៨ ដែលតម្រូវឱ្យទារពន្ធផ្សេងៗ ដូចជាពន្ធលើការការទាក់ និងលក់ដំរី, លើដីចម្ការ និងដីពន្ទាស, លើដំណាំម្រេច, លើប្រដាប់ប្រដារនេសាទ, លើទូក, ពន្ធខ្លួន និងកំណែន។ ក្នុងនោះ បារាំងកំណត់ពន្ធដីចម្ការតាមប្រភេទដី និងមុខដំណាំដែលត្រូវដាំដុះលើដីនោះ តាមចំនួនឯកតាហិចតា។

| **ប្រភេទដំណាំ** | **ប្រភេទទី១** | **ប្រភេទទី២** | **ប្រភេទទី៣** |
|---|---|---|---|
| អំពៅ | ២០ប្យ៉ាស | ១៧ប្យ៉ាស | ១៥ប្យ៉ាស |
| ថ្នាំជក់ | ១៦ប្យ៉ាស | ១៤ប្យ៉ាស | ១២ប្យ៉ាស |
| កប្បាស មន ចេក | ១០ប្យ៉ាស | ៨ប្យ៉ាស | ៥ប្យ៉ាស |
| សណ្តែកបាយ, សណ្តែកដី, សណ្តែកសៀង, ត្រាវ, ល្ង, ពោត, ដំឡូង | ៨ប្យ៉ាស | ៦ប្យ៉ាស | ៤ប្យ៉ាស |
| ឪឡឹក, ម្ទេស, ប៉េងប៉ោះ, ត្រសក់,ត្រប់ ៤ប្យ៉ាស | ៣ប្យ៉ាស | ២ប្យ៉ាស | |
| ដីចោលទំនេរ មិនដាំដំណាំ | ៣ប្យ៉ាស | ២ប្យ៉ាស | ១ប្យ៉ាស |

*គ-២-២-ដីពន្ទាស*

ជាប្រភេទដីចម្ការដែលមិននៅតាមមាត់ទន្លេ ហើយមិនលិចទឹក ត្រូវជាប់ពន្ធអាករ តាមប្រភេទដំណាំ ក្នុង១ហិចតា។

| **មុខដំណាំ** | | **ទំហំដី១ហិចតា** |
|---|---|---|
| ថ្នាំជក់ | | ១២ប្យ៉ាស |
| កប្បាស,សណ្តែកបាយ,ល្ង,គ,ចេក,អំពៅ,ត្រុំ | | ៤ប្យ៉ាស |
| ឪឡឹក,ត្រាវ,ដំឡូងបារាំង,ដំឡូង | | ២,៥ប្យ៉ាស |
| ត្រសក់,ម្ទេស,ត្រប់,ប៉េងប៉ោះ,ល្ហុងប្រេង,មន | | ១,៥ប្យ៉ាស |
| ដើមឈើស៊ីផ្លែ | | ១ប្យ៉ាស |
| ម្លូមួយជន្លង់ | ជាប់ពន្ធថ្លៃ | ០,២ប្យ៉ាស |
| ត្នោតមួយដើម | ជាប់ពន្ធថ្លៃ | ០,១ប្យ៉ាស |

*គ-៣-ពន្ធលើផលដំណាំ, សត្វ, ប្រដាប់ប្រដារធ្វើស្រែ*

*គ-៣-១-ស្រូវ*

តាមព្រះរាជប្រកាសចុះថ្ងៃទី២៦ខែកញ្ញាឆ្នាំ១៩២៤ បានចែងថា ៖ ជនជាតិខ្មែរ ឬអ្នកដែលគេចាត់ទុកដូចជាជនជាតិខ្មែរ ចាប់ពីខែមករាឆ្នាំ១៩២៥តរៀងទៅ ត្រូវបង់ពន្ធសម្រាប់ដីកម្មសិទ្ធិរបស់ខ្លួន និងដីដែលគេគ្រាន់តែកាន់កាប់ ទោះបីមិនបានដាំដុះក្តី។ ពន្ធបែបនេះ គេឱ្យឈ្មោះថា "ពន្ធស្រូវ"។ ថ្លៃពន្ធត្រូវគេគិតតាមផលប្រចាំឆ្នាំ គិតតាមផ្ទៃដីដកស្ទូង និងមើលទៅតាមផលជាមធ្យមតាមតំបន់នីមួយៗ។

ថ្លៃពន្ធស្រូវ គឺ ០,០៥ប្យ៉ាស ឬ៥សេន ក្នុងមួយថាំង (=៤០ដម$^{៣}$)

តាមច្បាប់ថ្មីរាជការយកពន្ធស្រូវប្រចាំឆ្នាំ ដោយគិតតាមទំហំដីស្រែ គឺទារថ្លៃ ០,២ប្យ៉ាស ឬ២កាក់សម្រាប់ដីស្រែ១ហិចតា ដែលមិនបានធ្វើដាំដុះ ដោយមូលហេតុអ្វីក៏ដោយ។ ចំពោះប្រភេទស្រែរបស់ជនជាតិអឺរ៉ុប និងមនុស្សដែលគេចាត់ទុកជាពួកអឺរ៉ុប ត្រូវកំណត់ពន្ធតម្លៃដូចគ្នា ឬស្រដៀងគ្នានឹងខ្មែរដែរ។

### *គ-៣-២-ពន្ធម្រេច*

ចម្ការម្រេចមានច្រើននៅក្នុងខេត្តកំពត គេតម្រូវឱ្យបង់ពន្ធអាករក្នុងបរិមាណដែលកម្រិតតាមកម្ពស់នៃដើមជន្លង់មួយដើមៗរបស់វា ដូចតទៅនេះ៖

ម្រេចកម្ពស់ពី១,៥ម៉ែត្រទៅ២,៥ម៉ែត្រ ត្រូវបង់ពន្ធជាម្រេចចំនួន ១តម្លឹង (=០,០៣៧៥គ.ក.)
ម្រេចកម្ពស់ពី២,៥១ម៉ែត្រទៅ៣ម៉ែត្រ ត្រូវបង់ពន្ធជាម្រេចចំនួន ២តម្លឹង
ម្រេចកម្ពស់ពី៣,០១ម៉ែត្រទៅ៣,៥ម៉ែត្រត្រូវបង់ពន្ធជាម្រេចចំនួន ៣តម្លឹង
ម្រេចកម្ពស់ពី៣,៥១ម៉ែត្រឡើងទៅ ត្រូវបង់ពន្ធជាម្រេចចំនួន ៤តម្លឹង

ចាប់ពីឆ្នាំ១៩៣៦មក ទោះបីម្រេចមានដើមកម្ពស់ណាក៏ដោយ ក៏ត្រូវបង់ពន្ធជាប្រាក់ចំនួន០,៥ប្យ៉ាស ឬ ៥ កាក់ ទាំងអស់។

### *គ-៣-៣-ពន្ធសត្វ*

បារាំងបានកំណត់ពន្ធលើក្បាលសត្វពាហនៈ ដែលខ្មែរប្រើប្រាស់សម្រាប់កម្លាំងអូសទាញ ជួយកសិករក្នុងការងារស្រែចម្ការ និងជីវភាពប្រចាំថ្ងៃ។

ក្របី១ក្បាល ក្នុង១ឆ្នាំ ត្រូវបង់ពន្ធ ០,២ប្យ៉ាស (=២កាក់)
គោ១ក្បាល ក្នុង១ឆ្នាំ ត្រូវបង់ពន្ធ ០,១ប្យ៉ាស (=១កាក់)
សេះ១ក្បាល ក្នុង១ឆ្នាំ ត្រូវបង់ពន្ធ ០,២ប្យ៉ាស (=២កាក់)
ដំរី១ក្បាល ក្នុង១ឆ្នាំ ត្រូវបង់ពន្ធ ១,៥ប្យ៉ាស (=១រៀល៥កាក់)
ឆ្កែឈ្មោល១ក្បាល ក្នុង១ឆ្នាំ ត្រូវបង់ពន្ធ ០,៣ប្យ៉ាស (=៣កាក់)
ឆ្កែញី១ក្បាល ក្នុង១ឆ្នាំ ត្រូវបង់ពន្ធ ០,៥ប្យ៉ាស (=៥កាក់)

### *គ-៣-៤-ពន្ធយានជំនិះ*

| | | |
|---|---|---|
| រទេះសេះ១ | ក្នុង១ឆ្នាំត្រូវបង់ពន្ធ | ០,៥ប្យ៉ាស (=៥កាក់) |
| ស៊ីក្លូ១ | ក្នុង១ឆ្នាំត្រូវបង់ពន្ធ | ០,៣ប្យ៉ាស (=៣កាក់) |
| កង់មួយ | ក្នុង១ឆ្នាំត្រូវបង់ពន្ធ | ០,៥ប្យ៉ាស (=៥កាក់) |
| រ៉ឺម៉ក១ | ក្នុង១ឆ្នាំត្រូវបង់ពន្ធ | ០,២ប្យ៉ាស (=២កាក់) |

នៅខែកក្កដាឆ្នាំ១៩២០ លោករ៉េស៊ីដង់ខេត្តកំពង់ចាម បានស្នើឱ្យរាជការបារាំងយកពន្ធរទេះគោថែមមួយមុខទៀត។ គាត់ដឹងថា តែកាលណាបង្កើតមុខពន្ធដារថ្មី មុខជាប្រជារាស្ត្រមិនសប្បាយចិត្ត ឬអបអរសាទរឡើយ។

ម្ល៉ោះហើយ ដើម្បីកុំឱ្យពួកគេមានប្រតិកម្មប្រឆាំងរាជការគួរតែកំណត់ថ្លៃពន្ធទាប គឺត្រឹមតែ០,១ប្យ៉ាសសម្រាប់រទេះទឹមគោមួយក្បាល ហើយបើប្រើគោ២ក្បាល ត្រូវហូតថ្លៃ ០,២កាក់។ ហើយចំនួនពន្ធនេះ នឹងត្រូវឡើងទ្វេគុណ ពី១ទៅ៥ដង នៅពេលអនាគត។

សរុបសេចក្តីមក បើតាមរបាយការណ៍របស់រ៉េស៊ីដង់ជាន់ខ្ពស់ សរសេរនៅឆ្នាំ១៩៣២ បានឱ្យដឹងថា៉"គណៈកម្មការធ្វើអធិការកិច្ចលើដែនដីអាណានិគម ក្រោយពីបានពិនិត្យ និងប្រៀបធៀបបរិមាណប្រាក់បង់ពន្ធរបស់ប្រជាពលរដ្ឋនៅគ្រប់ស្រុកនៃសហភាពឥណ្ឌូចិន បានមើលឃើញថា ប្រជាជនខ្មែរបង់ពន្ធច្រើនក្រៃពេកណាស់។ គណៈកម្មការបានស្នើសុំឱ្យបន្ថយប្រាក់ពន្ធខ្លួនពីខ្មែរ ចំនួន២ប្យ៉ាស(២រៀល)។" នៅក្នុងកាសែតឡេកូឌុយកាំបូដ (L'Echo du Cambodge) ចុះថ្ងៃទី៥ធ្នូ១៩២៥ លោក ឡេអូប៉ែរតាំង បានសរ-សេរឱ្យដឹងថា "រៀងរាល់ឆ្នាំ ប្រទេសកម្ពុជាបញ្ជូនឱ្យទៅឃ្លាំងប្រាក់ឥណ្ឌូចិន គិតតាំងពីប្រាក់ចំណូលផ្សេងៗក្នុងស្រុក និងពន្ធដារផ្ទាល់ និងប្រយោលមានចំនួនពី១៤ទៅ១៥លានប្យ៉ាស ហើយកម្ពុជាបានទទួលមកវិញ ស្ទើរតែមិនដល់៦លានប្យ៉ាសផង"។ ដូច្នេះប្រទេសកម្ពុជា ប្រៀបបានទៅនឹងមេគាផ្តល់ទឹកដោះ ឬជាអណ្តូងនៃពន្ធដារសម្រាប់ផ្តល់ទៅឱ្យប្រទេសឯទៀតៗនៃសហភាពឥណ្ឌូចិនបារាំង។

### 1.3. ការអប់រំ

បើតាមសៀវភៅនិក្ខេបបទថ្នាក់បណ្ឌិតប្រវត្តិសាស្ត្ររបស់លោក ស៊ន សំណាង បានឱ្យដឹងថា ការសិក្សានៅសម័យអាណានិគម មានបីប្រភេទ គឺការសិក្សានៅសាលាវត្តកែទម្រង់, ការសិក្សានៅសាលារៀនផ្លូវការរបស់បារាំង និងការសិក្សាខាងផ្លូវធម៌ពុទ្ធសាសនា ជាពិសេសភាសាបាលី។

*ក-សាលាវត្តកែទម្រង់*

ការសាកល្បងបង្កើតសាលាវត្តបណ្តុះបណ្តាលកុលបុត្រខ្មែរដំបូង បានធ្វើនៅវត្តជីជុះ ខេត្តកំពង់ចាម តែត្រូវបរាជ័យទៅវិញនាឆ្នាំ១៩១៦ ដោយសារមូលហេតុមួយចំនួន ដូចជា ការបញ្ចូលកម្មវិធីសិក្សាភាសាបារាំង, ព្រះសង្ឃជាគ្រូបង្រៀន តែគ្រហស្ថជាអធិការត្រួតមើលការបង្រៀនរបស់ព្រះសង្ឃ នាំឱ្យព្រះសង្ឃគ្រូមិនសូវសប្បាយចិត្ត។ ក្រោយមកបារាំងបានសាកល្បងម្តងទៀត នៅវត្តជុំក្រៀល ឬជើងក្រៀលនៅក្នុងខេត្តកំពត ជិតមាត់សមុទ្រ ម្តងទៀតនៅឆ្នាំ១៩២៤។ ដោយកម្មវិធីសិក្សាម្តងនេះ មានការកែសម្រួលខុសពីមុន, ព្រះសង្ឃជាគ្រូបានទទួលការបណ្តុះបណ្តាលជំនាញគរុកោសល្យរួចស្រេច, តាំងអធិការជាព្រះសង្ឃដូចគ្នាដែលបានទទួលការបណ្តុះបណ្តាលគរុវិជ្ជាដែរ ការសិក្សាគ្មានបញ្ចូលកម្មវិធីភាសាបារាំង។ ម្ល៉ោះហើយ សាលាវត្តនៅទីនេះបានជោគជ័យ បារាំងបានបើកអនុវត្តអប់រំតាមបែបសាលាវត្តនៅទូទាំងប្រទេស នាឆ្នាំ១៩៣១។ តែសាលានេះ ក្រោយពីបញ្ចប់ការសិក្សារយៈពេលបីឆ្នាំ សិស្សមិនអាចទៅបន្តការសិក្សានៅថ្នាក់បឋមសិក្សាបានឡើយ។ ពួកគេចេះបានត្រឹមតែអាន និងគិតលេខតិចតួចប៉ុណ្ណោះ។

*ខ-សាលារៀនផ្លូវការបារាំង-ខ្មែរ*

នៅក្នុងវេលាដ៏យឺតយ៉ាវបំផុត ដែលបារាំងបានបង្កើតឱ្យមានសាលារៀនសម័យទំនើបថ្នាក់បឋមសិក្សា និងអនុវិទ្យាល័យ សាលាបណ្តុះបណ្តាលវិជ្ជាពេទ្យបឋម និងមន្ទីរពេទ្យដ៏តិចតួចសម្រាប់សេវាកម្មសុខភាពប្រជាជនខ្មែរ ដែលជាអ្នកមានជីវភាពធូរធារគួរសម។

ដំបូងឡើយសាលារដ្ឋផ្លូវការបានចេញដំណើរពីកម្មវិធីបង្រៀនភាសាមួយ ដែលហៅថា "ការបង្រៀនអ្នកធ្វើការក្នុងស្រុក"នៃប្រទេសកម្ពុជា ("Service local d'Enseignement' du Cambodge) ដែលគេបានបង្កើតឡើងនៅឆ្នាំ ១៩១១ និងគ្រប់គ្រងផ្ទាល់ដោយអធិការអប់រំបឋមសិក្សា ដែលត្រូវបានជ្រើសរើសដោយរ៉េស៊ីដង់ខេត្ត ដែលជាអ្នកកាន់កាប់ថវិកា។[88] បន្ទាប់ពីនេះ មានសាលាបឋមសិក្សាបីប្រភេទ ដែលគេបានបង្កើតជាបន្តបន្ទាប់គ្នា ដូចជា សាលារៀនសហគមន៍ ដែលទ្រទ្រង់ដោយថវិកាឃុំ-សង្កាត់។ នៅទសវត្សរ៍១៩២០ នៅតាមខេត្តភាគច្រើនមានសាលានេះត្រឹមតែមួយក្នុងមួយខេត្តប៉ុណ្ណោះ។ ហើយតួលេខបានកើនឡើងខ្ពស់តែនៅឆ្នាំ១៩៣០ សម្រាប់ឆ្នាំបន្តបន្ទាប់មកទៀត, បរិមាណនេះបានថមថយចុះជាលំដាប់គឺ

| | | |
|---|---|---|
| **១៩៣០** | **២០៣សាលា** | **សិស្ស ៧២៥៩នាក់** |
| ១៩៣១ | ១៣៦ | |
| ១៩៣២ | ១១៣ | |
| ១៩៣៥ | ៨៥ | សិស្ស ៣៧១៣នាក់ |
| ១៩៣៦ | ៨២ | -- ៣៦២៣នាក់ជាមួយនឹងអ្នកត្រួតពិនិត្យ ៧៧រូប[89] |

បន្ទាប់មក គឺសាលាបឋមសិក្សា (Ecoles élémentaires) ដែលជាសាលាបង្រៀនផ្លូវការដ៏មានប្រជាប្រិយភាពនៅកម្ពុជា។ មកដល់ថ្ងៃទី១៨កញ្ញាឆ្នាំ១៩២៤ ទើបគេឃើញមានក្រឹត្យមួយចេញដោយអគ្គទេសាភិបាលឥណ្ឌូចិន ដើម្បីប្រកាសបញ្ជាក់ពីសញ្ញាបត្រការសិក្សារយៈពេល៣ឆ្នាំនេះ ដោយដាក់ឈ្មោះថា "បដិញ្ញាណបឋមសិក្សាវិជ្ជា ស្រុកអាយ" (Certificat d'études élémentaires indigènes) ។ ទោះជាយ៉ាងណា តួលេខនៃបរិមាណសាលាប្រភេទនេះ និងចំនួនកូនសិស្ស មានការកើនឡើងគួឱ្យកត់សម្គាល់ ចាប់តាំងពីឆ្នាំបើកដំបូងមក។

| | | |
|---|---|---|
| ១៩២១ ៦១ សាលា | សិស្ស ៣១២៥ នាក់ | ពីឆ្នាំ១៩២១ ដល់១៩៣១ |
| ១៩២២ ៦៦ សាលា | សិស្ស ២៩៥៦ នាក់ | ឃើញថាតួលេខសិស្សកើន |
| ១៩៣១ ៧៤ សាលា | សិស្ស ៣៥០៧ នាក់ | ឡើងតិចតួចយឺតជាងសាលា |
| ១៩៣៦ ៩៦ សាលា | សិស្ស ៦៧៧០ នាក់ | |
| ១៩៤៤ --- | សិស្ស ២២៧១៣ នាក់ ឃើញសិស្សកើនលើស៦ដង | |

ក្រៅពីនេះនៅមានសាលាបឋមសិក្សាមួយប្រភេទទៀត ហៅថា"សាលាបឋមសិក្សាបំពេញវិជ្ជា ឬសាលាអនុវត្តន៍ពេញលេញ (Ecoles primaire complémentaires ou Ecoles de plain exercise)។ សាលានេះផ្តល់នូវការសិក្សាបានទូលាយ និងយូរឆ្នាំជាងសាលាមុនៗ ដោយសារវាតម្រូវឱ្យបំពេញមុខងារពីរវគ្គសិក្សា គឺវគ្គបឋមសិក្សា និងវគ្គបំពេញបន្ថែម។ ដូច្នេះនៅក្នុងរង្វង់សាលានេះ អាចត្រូវរួមបញ្ចូលជាមួយសាលាបឋមសិក្សាផ្លូវការ។ ចំណែកមុខវិជ្ជាសិក្សាឃើញថា មានលក្ខណៈស៊ីជម្រៅ និងទូលាយជាងមុន។

### *គ-ការសិក្សាខាងផ្លូវធម៌ព្រះពុទ្ធសាសនា*

[88] Voir, Sorn Samnang. 1995, Octobre. *L'Evolution de la soiété cambodgienne entre les deux guèrres mondiales (1919-1939).* Thèse pour doctorat d'histoire, tome II, Université Paris VII, Paris, p. 238.
[89] Voir, *Ibid,* p. 239.

តាមលោក ឃឹន សុខ បានដឹងថា គោលបំណងដំបូងនៃការសិក្សាខាងផ្លូវធម៌ពុទ្ធសាសនាកើតឡើងនៅឆ្នាំ ១៩០៩ តាមព្រះគំនិតផ្តួចផ្តើមរបស់សម្តេចព្រះមហាសង្ឃរាជ និល ទៀង សង្ឃនាយកគណៈមហានិកាយ។ ក្រោយពីព្រះអង្គឆ្លងយោបល់ និងទទួលការឯកភាពពីរដ្ឋការបារាំង និងខ្មែររួចហើយ គេបានសម្រេចបង្កើតសាលាបាលីមួយនៅអង្គរវត្ត តែអាយុកាលសាលានេះបានតែបីឆ្នាំប៉ុណ្ណោះ។ ព្រោះត្រូវគេលុបចោលនៅឆ្នាំ១៩១១ ពេលគឺគេបង្កើតជាលើកដំបូងនូវគ្រឹះស្ថានសិក្សាបារាំង-ខ្មែរខាងពុទ្ធិកសិក្សា ដែលត្រូវក្លាយជាគម្រោងការសិក្សាផ្លូវការ។ ដើម្បីរារាំងការនិយមនិមន្តទៅរៀនភាសាបាលី និងសំស្ក្រឹតនៅបាងកកទៀត នៅចុងឆ្នាំ១៩១៤រដ្ឋការបារាំងបានសម្រេចបង្កើតសាលាបាលីមួយទៀតជាជំនួសនៅភ្នំពេញ ហើយសាលានោះបានក្លាយជាវិមានរដ្ឋសភាចាប់ពីឆ្នាំ ១៩៤៦មក។ សាលាបាលីនេះ ក្រោយមកនៅឆ្នាំ១៩២២-៥ បានឡើងជាសាលាបាលីជាន់ខ្ពស់ ហើយនៅឆ្នាំ ១៩៣៣ គេបានបង្កើតសាលាបាលីរងនៅទូទាំងប្រទេសខ្មែរ។ ចុងក្រោយនៅទសវត្សរ៍១៩៤០ គេអាចបង្កើតពុទ្ធិកវិទ្យាល័យព្រះសុរាម្រិតឡើង នៅក្នុងមណ្ឌលជាមួយគ្នានោះ។

### *ឃ-ថ្នាក់មធ្យមសិក្សា*

សាលាមធ្យមសិក្សាមានតែមួយគត់ នៅកម្ពុជា ក្នុងអំឡុងពេលពេញមួយសម័យអាណានិគមបារាំងគឺ វិទ្យាល័យព្រះស៊ីសុវត្ថិ ដែលត្រូវគេតម្លើងឋានៈចាប់ពីឆ្នាំសិក្សា១៩៣៥-៦។ តាមពិតទៅសាលានេះមានសាវតារដំបូងជាអនុវិទ្យាល័យនៃអាណាព្យាបាលបារាំង ដែលកើតឡើងនៅភ្នំពេញនាឆ្នាំ១៨៩៣ ហើយបន្ទាប់មកនៅឆ្នាំ១៩០៥ គេហៅថា សាលាបឋមសិក្សាជាន់ខ្ពស់ភ្នំពេញ។ មកដល់ឆ្នាំ១៩១១ ក្លាយជាអនុវិទ្យាល័យស៊ីសុវត្ថិ ។

សារៈសំខាន់របស់សាលានេះ គឺជាកន្លែងបណ្តុះបណ្តាលមន្ត្រីរាជការនៅតាមក្រសួងនានា នៅក្នុងប្រទេស។ នៅឆ្នាំ១៩២០សិស្សនៅអនុវិទ្យាល័យនេះ មានចំនួន១៥០នាក់។ ពេលបន្ទាប់មកគេចែកសាលានេះចេញជាពីរផ្នែក គឺសាលាបឋមសិក្សាជាន់ខ្ពស់ និងសាលាមធ្យមសិក្សា។ មកដល់ខែវិច្ឆិកាឆ្នាំ១៩២២ គេបានបង្កើតផ្នែកមួយទៀត ហៅថា ផ្នែកគរុវិជ្ជា សម្រាប់បណ្តុះបណ្តាលសិស្សបញ្ចប់ការសិក្សាចំណេះទូទៅឱ្យទៅជាគ្រូបង្រៀន។

ផ្នែកគរុវិជ្ជា ដែលបានបើកការបណ្តុះបណ្តាលតាំងពីឆ្នាំ១៩២៣ មកដល់ឆ្នាំ១៩៣៩ ផលិតបានគ្រូត្រឹមតែ ៧៥នាក់ប៉ុណ្ណោះ នៅទូទាំងប្រទេស ដែលក្នុងនោះ មានអ្នកគ្រូ១១នាក់។

### *ង-ថ្នាក់ឧត្តមសិក្សា*

នៅពេលដែលនៅហាយណូយ បារាំងបានបង្កើតសាកលវិទ្យាល័យតាំងពីថ្ងៃទី២៨ខែមេសាឆ្នាំ១៩១៨ នៅកម្ពុជារហូតមកដល់ឆ្នាំ១៩៤៨ ទើបមានគ្រឹះស្ថានឧត្តមសិក្សាខ្លះកើតឡើង ដូចជា វិជ្ជាស្ថានជាតិខាងច្បាប់នយោបាយ និងសេដ្ឋកិច្ច និងសាលាភូមិន្ទវិជ្ជាពេទ្យ។ ៦ឆ្នាំបន្ទាប់មក ទើបកើតវិជ្ជាស្ថានគរុកោ-សល្ល, នៅឆ្នាំ ១៩៥៦ ទើបកើតសាលាភូមិន្ទរដ្ឋបាល, នៅឆ្នាំ១៩៥៩ កើតសាលជាតិពាណិជ្ជកម្ម, នៅឆ្នាំ១៩៦០គេបង្កើតមហាវិទ្យាល័យពីរ គឺមហាវិទ្យាល័យអក្សរសាស្ត្រ និងមនុស្សសាស្ត្រ និងមហាវិទ្យាល័យវិទ្យាសាស្ត្រ។ ដូច្នេះនៅមុនឆ្នាំ១៩៤៨ កូនសិស្សខ្មែរ ដែលរៀនចប់មធ្យមសិក្សាទុតិយភូមិ បើចង់បន្តការសិក្សាទៀត ត្រូវតែទៅរៀននៅហាណូយ ឬប្រទេសបារាំងតែម្តង។

តួលេខនិស្សិតខ្មែរ ដែលបានរៀនថ្នាក់ឧត្តមសិក្សានៅឥណ្ឌូចិន ឃើញថាមានចំនួនតិចតួចណាស់ បើប្រៀបធៀបទៅនឹងពួកយួនទាំងបីដែនដីរដ្ឋបាល។ ហេតុនេះហើយ បានជាយួនសំបូរធនធានមនុស្សជាបញ្ញវន្តច្រើនជាងគេក្នុងចំណោមប្រទេសទាំងបី ដែលនៅក្រោមការត្រួតត្រារបស់បារាំង។ បរិមាណនិស្សិតខ្មែរតិចបែបនេះ

ត្រូវប្រវត្តិវិទូគិតថា មកពីនៅកម្ពុជាមានសាលាមធ្យមសិក្សានៅភ្នំពេញតែមួយកន្លែងប៉ុណ្ណោះ ដែលជាហេតុបង្កការលំបាកដល់សិស្សដែលមានធនធានមធ្យមនៅតាមខេត្ត មិនអាចឱ្យពួកគេបន្តការសិក្សាថ្នាក់វិទ្យាល័យនៅភ្នំពេញបាន។

***ស្ថិតិនិស្សិតឧត្តមសិក្សានៅឥណ្ឌូចិនពីឆ្នាំ១៩៣៩ដល់១៩៤៤***

| | | | | | | |
|---|---|---|---|---|---|---|
| សញ្ជាតិ | ១៩៣៩ | ១៩៤០ | ១៩៤១ | ១៩៤២ | ១៩៤៣ | ១៩៤៤ |
| បារាំង | ៨៨ | ៨៩ | ១៣៨ | ២០៦ | ៣១៣ | ៣៧១ |
| យួនតុងកឹង | ៣៩៤ | ៤២៨ | ៤១៩ | ៤៧៦ | ៥៥៦ | ៦៨១ |
| យួនកូសាំងស៊ីន | ១៣២ | ១៣៧ | ១៣៦ | ១៩៧ | ២២៣ | ២១២ |
| យួនអាណ្ណាម | ៩២ | ១១៧ | ១៤៩ | ១៧២ | ២០២ | ២១៨ |
| ខ្មែរ | ៨ | ៨ | ១១ | ៨ | ១៥ | ២៣ |
| ឡាវ | ៧ | ៦ | ៨ | ៦ | ៥ | ១២ |
| ចិន និងជាតិដទៃ | ១១ | ២០ | ១៤ | ២០ | ១១ | ១១ |

ថ្វីបើក្រឡេកមើលមួយភ្លែត គេឃើញថារដ្ឋការបារាំងហាក់ដូចជាខំប្រឹងប្រែងដោយយកចិត្តទុកដាក់ក្នុងការពង្រីកការសិក្សានៅកម្ពុជា តែទូទៅគេមិនបានផ្តល់សារៈសំខាន់ដល់ការសិក្សាអប់រំនៅកម្ពុជា ដូចនៅបណ្តាប្រទេសផ្សេងទៀតនៃសហភាពឥណ្ឌូចិនរបស់បារាំងនោះទេ។ បើតាមអត្ថបទមួយនៅក្នុងព្រឹត្តិបត្រនៃសាលបឋមសិក្សានៅប្រទេសកម្ពុជា ឆ្នាំ១៩៤០ លេខ៣ ទំព័រ១១ ដែលលោក យឹន សុខ បានលើកយកមកធ្វើការវិភាគនោះ បានពន្យល់ថា នៅដើមខែមករាឆ្នាំ១៩៤០ បារាំងមិនព្រមបន្ថែមថវិកាជាង១លានប្យ៉ាសឱ្យខ្មែរ សម្រាប់វិស័យអប់រំនៅកម្ពុជាឡើយ។ ដូច្នោះហើយបានជាខ្មែរមិនអាចសង់សាលារៀនល្អៗបាន ហើយខ្មែរនៅតែខ្វះគ្រូបង្រៀនសម្រាប់បង្រៀនកូនខ្មែរឱ្យបានត្រឹមត្រូវ។

ចំណែកជនជាតិបារាំងម្នាក់ឈ្មោះ ឡេអូ ប៉ែរតាំង បានសរសេរអត្ថបទមួយក្រោមចំណងជើងថា "ប្រទេសកម្ពុជាត្រូវគេបោះបង់ចោល" នៅក្នុងកាសែត ឡេកូឌុយកាំបូជ ចុះថ្ងៃទី៥ខែធ្នូឆ្នាំ១៩២៥ ដោយមានសេចក្តីថា "ដើម្បីបង្ហាញឱ្យឃើញថា ខ្ញុំនិយាយមិនបំផ្លើសទេ នៅពេលខ្ញុំសរសេរនៅខាងដើមអត្ថបទនេះថា ប្រជាជនខ្មែរ ត្រូវគេចាត់ទុកដូចវណ្ណៈថោកទាប បើប្រៀបធៀបទៅនឹងប្រជាជននៃរដ្ឋផ្សេងទៀតនៅក្នុងសហភាពឥណ្ឌូចិនបារាំងដូចគ្នា។ ជាតឹកតាងនៃការអះអាងនេះ ខ្ញុំសូមលើកយកចំនួនតិចតួចនៃគ្រឹះស្ថានសិក្សាខ្មែរ និងភាពមិនយូរអង្វែងនៃជំនួយរបស់អាណាព្យាបាលបារាំង។ ឧទាហរណ៍ នៅឆ្នាំ១៩២០ ប្រទេសកម្ពុជាបានទទួលប្រាក់ពីសហភាពឥណ្ឌូចិនទាំងអស់ សម្រាប់ចំណាយគ្រប់ប្រភេទក្នុងប្រទេសទាំងមូល តែក្នុងចំនួនទឹកប្រាក់ ៣០០ ០០០ប្យ៉ាសប៉ុណ្ណោះ។ នៅពេលដំណាលគ្នានេះ យួនអាណ្ណាមទទួលបាន១លានប្យ៉ាស ហើយសម្រាប់យួនតុងកឹងឯណោះទទួលបានដល់ទៅ ១២០០០០០ប្យ៉ាស។ ទឹកប្រាក់៣០០០០០ប្យ៉ាសសម្រាប់ខ្មែរនេះ ត្រូវរដ្ឋការបារាំងកំណត់ឱ្យចាយវាយសម្រាប់ការងារបន្ទាន់ផង និងសម្រាប់ចំណាយទៅលើការសិក្សា និងចំណាយផ្សេងៗទៀតផង។..... គេសង្កេតឃើញថា ក្នុងរយៈពេលដូចគ្នា ចំពោះការសិក្សា បារាំងតែងឱ្យមកខ្មែរស្តួចស្តើងជាងគេ ក្នុងចំណោមប្រទេសទាំងឡាយនៃសហភាពឥណ្ឌូចិន។ ជាឧទាហរណ៍ នៅពេលដែលក្នុង១ឆ្នាំ យួនអាណ្ណាមបើកបាន ៥១៥ ០០០ប្យ៉ាស, យួនតុងកឹងបាន៥៦០ ០៨០ប្យ៉ាស ហើយលាវបាន២០០ ០០០ប្យ៉ាស ខ្មែរបានត្រឹមតែ ១៦៥ ០០០ប្យ៉ាសប៉ុណ្ណោះ។"

***តារាងប្រៀបធៀបការចំណាយសម្រាប់វិស័យសិក្សាធិការនៃប្រទេសឥណ្ឌូចិនបារាំង+ភាគរយតាមរដ្ឋនីមួយៗ***

| ឈ្មោះប្រទេស | ឆ្នាំ១៩៣០ | % | ឆ្នាំ១៩៣៨ | % | ឆ្នាំ១៩៤៤ | % |
|---|---|---|---|---|---|---|
| កូសាំងស៊ីន | ២៥៦៣៤១៦ | ១២,៤៧% | ៤៨៧៤១៥៥ | ១៣,៤០% | ៩៤៧៧៦០៣ | ១១,៨២% |
| តុងកឹង | ២៨៩៨៦៥០ | ១៤,២៣% | ២៩៥៤៦០៣ | ១៤,២២% | ៧៦៣៧៣៨១ | ១៣,៣៦% |
| អាណ្ណាម | ១៥៩៦២៦៩ | ១៤,៤៥% | ១៧០៨៧២១ | ១១,២៧% | ៣៧៧៦៣២៦ | ១០,៥៩% |
| ខ្មែរ | ៨២៤ ៥៥៨ | ៦,១៦% | ៨៧០ ១៦៥ | ៧,៤០% | ២៤៦២ ៦០០ | ១០,៥៧% |
| ឡាវ | ៣៦៧ ២០១ | ៨,៧៦% | ២៧២ ៣៦៣ | ៨,៥១% | ៩៤៤ ៣៧០ | ១០,៥២% |

### 1.4. គមនាគមន៍

បារាំងយកចិត្តទុកដាក់អភិវឌ្ឍន៍វិស័យគមនាគមន៍ផ្លូវគោក និងផ្លូវដែក គឺជាយុទ្ធសាស្ត្រនយោបាយដ៏សំខាន់មួយ ដើម្បីពង្រឹងការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខ និងដើម្បីបង្កើនការបូមប្រមូលយកប្រយោជន៍សេដ្ឋកិច្ចពីផ្នែកផ្សេងៗគ្នានៃប្រទេសកម្ពុជាតែប៉ុណ្ណោះ។ សមិទ្ធិផលជាផ្លូវថ្នល់ដែលបារាំងធ្វើបានសម្រេច គឺដោយសារការប្រើប្រាស់ពន្ធកំណែនជាប្រាក់ និងកម្លាំងពលកម្មរបស់ប្រជារាស្ត្រខ្មែររៀងរាល់ឆ្នាំ ដែលម្នាក់ៗត្រូវមានកាតព្វកិច្ចបរិច្ចាគចំនួន ១០ថ្ងៃនោះឯង។ បើតាមតថភាពនៃរឿងនិពន្ធក្រោមចំណងជើងថា"គូលីកំណែន" ប្រជាជនខ្មែរសាមញ្ញមិនសូវសប្បាយចិត្តឡើយ ដោយសារពួកគេមិនអាចប្រើប្រាស់ផ្លូវថ្នល់ទាំងនោះ ដើម្បីផលប្រយោជន៍របស់ខ្លួនបាន នៅលើផ្លូវគមនាគមន៍ដែលពួកគេបានចំណាយញើសឈាមកសាងឡើងនោះ។ ព្រោះ ក្នុងករណី ដែលពួកគេបររទេះគោលើផ្លូវនោះត្រូវភ្នាក់ងាររាជការហាមឃាត់ ដោយព្រមានថាខ្លាចខូចផ្លូវ។

ផ្លូវថ្នល់ជាតិក្រាលកៅស៊ូ ដែលបារាំងបានចាប់ផ្តើមគូសវាសឡើង និងបន្សល់ទុកជាកេរ្តិ៍មានដូចជា ផ្លូវជាតិលេខ១ ពីភ្នំពេញទៅស្វាយរៀងដល់ច្រកព្រំដែនបាវិត, ផ្លូវជាតិលេខ២ ពីភ្នំពេញទៅតាកែវ ដល់ច្រកព្រំដែនភ្នំដិន, ផ្លូវជាតិលេខ៣ពីភ្នំពេញទៅកំពត, ផ្លូវជាតិលេខ៥ ពីភ្នំពេញទៅបាត់ដំបងដល់ព្រំដែនប៉ោយប៉ែត, ផ្លូវជាតិលេខ៦ពីភ្នំពេញទៅកំពង់ធំ-សៀមរាបដល់សិរីសោភ័ណ, ផ្លូវជាតិលេខ៧ ពីស្គន់ទៅមេមត់ដល់ស្នួល, ផ្លូវជាតិលេខ១៣ ពីស្នួលទៅក្រចេះ-ស្ទឹងត្រែងដល់ច្រកដុំក្រឡ, ផ្លូវលេខ១៥ ភ្ជាប់ពីផ្លូវជាតិលេខ១ទៅផ្លូវជាតិលេខ៧ ដោយកាត់ទីរួមខេត្តព្រៃវែង-អូរាំងឪ និងផ្លូវលេខ១០ភ្ជាប់ខេត្តបាត់ដំបងជាមួយក្រុងបរប៉ៃលិន។ ក្រៅពីនេះ នៅមានផ្លូវតភ្ជាប់ពីទីរួមខេត្ត ទៅកាន់ទីប្រជុំជនស្រុក និងជនបទសំខាន់ៗ នៅទូទាំងប្រទេស។ ផ្លូវទាំងនោះ គឺជាមូលដ្ឋានដ៏មានសក្តានុពលសម្រាប់ការអភិវឌ្ឍន៍បណ្តាញផ្លូវថ្នល់នៅកម្ពុជាសព្វថ្ងៃ។

នៅមានផ្លូវដែកដ៏សំខាន់មួយខ្សែ ពីភ្នំពេញទៅអូរជ្រៅ ព្រំដែនខ្មែរថៃ ដែលត្រូវស្ថាបនារួចនៅឆ្នាំ ១៩៣២ ដើម្បីដឹកនាំផលិតផលពីខេត្តបាត់ដំបងមកភ្នំពេញ។ ផ្លូវនេះនៅតែជាកេរ្តិ៍ដំណែលយ៉ាងសំខាន់ខាងគមនាគមន៍ផ្លូវដែកនៅកម្ពុជាសព្វថ្ងៃ។ ព្រោះរដ្ឋាភិបាលខ្មែរ នៅតែគ្មានសមត្ថភាពសាងផ្លូវថ្មី ឬក៏កែលម្អផ្លូវចាស់នេះបាននៅឡើយ។

### 1.5. សង្គមកិច្ច និងសុខាភិបាល

បារាំងបានរៀបចំកែទម្រង់របៀបរៀបចំភូមិស្រុកនៅតាមជនបទរបស់ខ្មែរ ឱ្យមានលក្ខណៈប្រសើរឡើង។ ដោយតម្រូវឱ្យនាំគ្នាតាំងលំនៅតាមដងផ្លូវ មិនឱ្យនៅបែបប្រមូលផ្តុំផ្ទះស្អេកស្កះ នៅតំបន់ដាច់ស្រយាល ឆ្ងាយពីផ្លូវគមនាគមន៍, គ្មានច្រកចូលផ្ទះត្រឹមត្រូវ និងងាយស្រួល។ ទម្លាប់ឱ្យមានការប្រើប្រាស់ទឹកអណ្តូងជីក ជៀសវាងប្រើប្រាស់ទឹកត្រពាំងរួមគ្នា មនុស្ស សត្វ ដែលនាំឱ្យងាយឆ្លងជំងឺ។ ទន្ទឹមនោះ បារាំងបានកេណ្ឌអ្នកស្រុកលើកបណ្តាញ

ផ្លូវគមនាគមន៍ឡើង ខ្វាត់ខ្វែងពេញផ្ទៃប្រទេស។ ការរៀបចំដ៏ប្រសើរនេះ ក៏ស្ថិតនៅក្នុងផែនការយុទ្ធសាស្ត្ររបស់បារាំង ដើម្បីត្រៀមទុកក្នុងការបង្ក្រាបពួកបះបោរ និងបង្កលក្ខណៈសម្បត្តិឱ្យងាយស្រួលគ្រប់គ្រងប្រជាជន។

នាឆ្នាំ១៨៨៧ បារាំងបានបង្ខំឱ្យស្ដេចនរោត្តម លុបបំបាត់ចោលបែបផែនទាសភាពដែលមាននៅកម្ពុជាតាំងពីយូរយារណាស់មកហើយ។ ពួកអ្នកបម្រើនៅតាមផ្ទះសាមញ្ញជន, អភិជន, មន្ត្រី, និងវត្តអារាមព្រមទាំងព្រះសង្ឃ។ ស្ដេចលែងជាសក្តិភូមិដែលជាម្ចាស់ដីធ្លីនៅទូទាំងប្រទេសទៀតហើយ ៗអ្នកស្រុកក៏ចាប់ផ្តើមមានកម្មសិទ្ធិដីធ្លីឯកជន សម្រាប់ប្រកបរបរកសិកម្មដោយសេរីភាព។

សេវាកម្មព្យាបាលជំងឺ និងចំណេះដឹងអនាម័យបែបវិទ្យាសាស្ត្រទំនើប មានការរីកចម្រើនសន្សឹមៗនៅតាមទីក្រុងធំៗ ដូចជា ភ្នំពេញ នឹងទីរួមខេត្តធំៗ ដោយសារបារាំងមិនសូវអើពើដល់វិស័យនេះដែរ ដូចដែលលោក ឡេអូ ប៉ែរតាំង បានសរសេរអត្ថបទមួយក្រោមចំណងជើងថា "ប្រទេសកម្ពុជាត្រូវគេបោះបង់ចោល" នៅក្នុងកាសែត ឡេកូឌុយកាំបូដ ចុះថ្ងៃទី៥ខែធ្នូឆ្នាំ១៩២៥ ថា "ពីឆ្នាំ១៩២២មក១៩២៥ ប្រទេសកម្ពុជាបានទទួលថវិកាប្រចាំឆ្នាំ សម្រាប់កិច្ចការសុខាភិបាល នូវទឹកប្រាក់ត្រឹមតែ២៨០ ០០០ប្យ៉ាសប៉ុណ្ណោះ ខណៈដែលយួនតុងកឹងទទួលបាន ៤៣៥០០០ប្យ៉ាស។"

### 1.6. គណបក្សនយោបាយ

ការអនុញ្ញាតឱ្យមានគណបក្សនយោបាយច្រើន គឺជាការបង្កើតឱ្យមានទម្រង់លទ្ធិប្រជាធិបតេយ្យដែលជាលទ្ធិដឹកនាំមួយ មានកំណើតតាំងពីសម័យក្រិកបុរាណ ដែលមេដឹកនាំប្រទេសភាគច្រើននៅអឺរ៉ុបចាប់អារម្មណ៍យកមកកែច្នៃ និងអនុវត្តន៍ចាប់ពីសតវត្សរ៍ទី១៨មក។

ពាក្យប្រជាធិបតេយ្យ មាននិយមន័យថា ការគ្រប់គ្រងរដ្ឋរបស់ប្រជារាស្ត្រ ដោយប្រជារាស្ត្រ និងសម្រាប់ប្រជារាស្ត្រ។ តាមប្រវត្តិសាស្ត្រសម្រាប់ប្រទេសកម្ពុជា យើងមានប្រពៃណីអនុវត្តន៍លទ្ធិប្រជាធិបតេយ្យដោយសារបារាំងជាអ្នកនាំមក។ ព្រោះ ក្រោយសង្គ្រាមលោកលើកទី២ផុតទៅ ពិភពលោកមានការផ្លាស់ប្តូរ ប្រទេសកម្ពុជាមិននៅក្រៅរង្វង់នេះដែរ។ ឥទ្ធិពលបារាំងចុះខ្សោយបន្ទាប់ពីអាល្លឺម៉ង់វាយកាន់កាប់ប្រទេសខ្លួននៅចុងឆ្នាំ១៩៤០។ ឆ្នាំ ១៩៤១បារាំងចេញពីកម្ពុជា ជំនួសដោយរដ្ឋការជប៉ុនម្តងបន្តរហូតដល់ ១៩៤៥ ពេលជប៉ុនចាញ់សង្គ្រាមលោកលើកទី២ ជប៉ុនចេញពីកម្ពុជា។

នៅពេលដែលបារាំងឈានជើងចូលដឹកកម្ពុជាជាលើកទី២ បារាំងបានធ្វើការផ្លាស់ប្តូរយ៉ាងច្រើននូវឥរិយាបថទាំងឡាយដែលធ្លាប់មានកាលពីមុន។ នៅក្នុងរយៈកាលលើកទីមួយដែលបារាំងត្រួតត្រាកម្ពុជា បាននាំឱ្យមានការមិនសប្បាយចិត្តយ៉ាងច្រើនពីសំណាក់ប្រជារាស្ត្រខ្មែរ ចំពោះអ្នកអាណាព្យាបាល និងអាណានិគម ទើបបង្កបង្កើតឱ្យមាននូវចលនាជាច្រើនដែលប្រឆាំងនឹងបារាំង។ ដើម្បីជាការលួងចិត្តខ្មែរឱ្យងាកចេញពីការតស៊ូប្រឆាំងនឹងខ្លួន បារាំងបានដាក់លំហាត់ប្រជាធិបតេយ្យបែបបារាំងមកឱ្យខ្មែរអនុវត្តន៍។ ការអនុវត្តន៍ជាបឋម គឺព្រះរាជក្រមលេខ ១៦៦ន.ស. និងព្រះរាជក្រមលេខ ១៦៧ ន.ស. ចុះថ្ងៃទី១៥ ខែ មេសាឆ្នាំ១៩៤៦ ដែលចែងអំពីសេរីភាពនៃការប្រជុំ និងសេរីភាពនៃការបង្កើតសមាគម។ ព្រះរាជក្រមទាំងពីរនេះបានផ្តល់ឱ្យប្រជារាស្ត្រខ្មែរនូវសេរីភាពនៃការរួមប្រជុំ និងការបង្កើតសមាគមដោយរួមទាំងគណបក្សនយោបាយផង។ ទោះបីជាព្រះរាជក្រមទាំងពីរនេះ ដាក់ឱ្យប្រើប្រាស់ជាបណ្តោះអាសន្នក៏ដោយ។ ក្រោយពីការប្រកាសឱ្យប្រើព្រះរាជក្រមនេះ សមាគមនយោបាយនៅ

ប្រទេសកម្ពុជាក៏ចាប់បដិសន្ធិឡើងដែរ ដែលសុទ្ធសឹងតែស្ថិតនៅក្រោមការដឹកនាំរបស់ក្រុមព្រះញាតិវង្ស មានជាអាទិ៍គឺ ៖

គណបក្សប្រជាធិបតេយ្យ(មានរូបក្បាលដំរីកាន់ផ្កាឈូកបីជាសញ្ញាលក្ខណ៍) ដឹកនាំដោយព្រះអង្គម្ចាស់ ស៊ីសុវត្ថិ យុត្តិវង្ស ។

គណបក្សសេរីភាព (រូបប្រាសាទកំពូលបីជាសញ្ញាលក្ខណ៍)ដឹកនាំដោយព្រះអង្គម្ចាស់ នរោត្តមសុទ្ធាវង្ស នរិន្ទតេជ ដែលនិយមបារាំង ព្រោះបានទទួលជំនួយថវិកាពីបារាំង ដើម្បីបន្ថយល្បឿនយុត្តិវង្ស។

គណបក្សចម្រើនជាតិ (រូបព្រួញទម្លុះកងបួន ជាសញ្ញាលក្ខណ៍) ដឹកនាំដោយព្រះអង្គម្ចាស់ ន.ម៉ុងតាណា ដែលមានគំនិតអភិរក្សដូចបក្សសេរីភាពដែរ ទើបរះឡើងមិនយូរ (ធាណ្ឌាល័រ,២០០៥ : ១៩០-១)។

នៅឆ្នាំ ១៩៤៦ កម្ពុជា មានគណបក្សនយោបាយតែបីប៉ុណ្ណោះ ដែលយើងចាត់ទុកនៅក្នុងដំណាក់កាលដំបូងក្នុងប្រវត្តិសាស្ត្រនៃការចាប់ផ្តើមរបបនយោបាយពហុបក្ស ។ ចំណោមគណបក្សទាំងបីខាងលើនេះ មានតែគណបក្សប្រជាធិបតេយ្យទេដែលទាញការគាំទ្រពីសំណាក់រាស្ត្របានយ៉ាងច្រើន ។

នៅឆ្នាំ ១៩៥១ បន្ថែមលើគណបក្សនយោបាយដែលមានបីពីលើកមុន មានគណបក្សផ្សេងទៀតជាច្រើនដែលគណបក្សទាំងនោះបានបែកចេញពីគណបក្សប្រជាធិបតេយ្យ ដោយសារតែការខ្វែងទស្សនៈគ្នាក្នុងបក្សចាស់។ ក្នុងនោះមាន ៖

គណបក្សតម្កើងប្រជាជាតិ (រូបហនុមានទ្រផែនទីស្រុកខ្មែរ ជាសញ្ញាលក្ខណ៍) បក្សនេះដឹកនាំដោយលោក **យ៉ែម សំបូរ** អតីតអ្នកតំណាងរាស្ត្រមកពីគណបក្សប្រជាធិបតេយ្យដែរ។

គណបក្សខេមរប៉ុណ្ណាការ (រូបនាងគង្គីងព្រះធរណី, ដឹកនាំដោយលោក **លន់ នល់**)

គណបក្សវៀសានមានជ័យ(រូបទង់ជាតិពីរខ្វែងគ្នាទ្រម្កុដ ជាសញ្ញាលក្ខណ៍) បក្សនេះដឹកនាំដោយលោក**ម៉ៅ ចយ** អតីតសមាជិករបស់គណបក្សប្រជាធិបតេយ្យ

គណបក្សរាស្ត្រ(រូបកណ្តាប់ស្រូវជាសញ្ញាលក្ខណ៍)ដឹកនាំដោយលោក **សំ ញាណ** អតីតសមាជិកគណបក្សប្រជាធិបតេយ្យ ។

នៅឆ្នាំ ១៩៥៥ គណបក្សនយោបាយនៅកម្ពុជា មានការថយចុះ ដោយសារគណបក្សខ្លះបានចូលរួមជាមួយចលនាសង្គមរាស្ត្រនិយមតែម្តង នេះប្រហែលមានការទុកចិត្តលើគណបក្សសង្គម ឬក៏មកពីការបែកបាក់នៅក្នុងគណបក្សខ្លួនពីមុនផង ។

គណបក្សរាស្ត្រនិយមដែលមានធាយាលក្ខណ៍**សម្តេច នរោត្តម សីហនុ** ជារូបសញ្ញា

គណបក្សប្រជាធិបតេយ្យ

គណបក្សសេរីភាព (**នរោត្តម សុទ្ធាវង្ស នរិន្ទតេជ**)

គណបក្សតម្កើងជាតិ

គណបក្សខ្មែរឯករាជ្យ ដែលមានរូបកងចក្រ និងផ្កាឈូកប្រាំ ជាសញ្ញាលក្ខណ៍

គណបក្សប្រជាជន ដែលមានរូបនង្គ័លជាសញ្ញា

គណបក្សកម្មករខ្មែរ ដែលមានរូបភ្ញីផ្កា និងស្លឹកឈើជាសញ្ញា និង
គណបក្សឯកច្ឆ័ន្ទ មានសញ្ញាបី គឺ ជើងពានទ្រូវរដ្ឋធម្មនុញ្ញ បន្ទាត់ និងកូនសោ

ដូចនេះនៅក្នុងដំណើររបបសេរីពហុបក្ស ចាប់ពីឆ្នាំ១៩៤៦មកដល់ឆ្នាំ១៩៥៥ មានគណបក្សនយោបាយជាច្រើនប្រកួតប្រជែងគ្នា។ នេះជាជានប្រវត្តិសាស្ត្រកម្ពុជាលើកដំបូងនៅលើមាគ៌ារបបអនុវត្តន៍លទ្ធិប្រជាធិបតេយ្យ។ ប៉ុន្តែនយោបាយប្រកាន់លទ្ធិប្រជាធិបតេយ្យនោះ មិនបានដើរលើផ្លូវរលូននោះទេ។

## 1.7. រដ្ឋធម្មនុញ្ញដំបូងរបស់កម្ពុជា

និយមន័យរបស់ "រដ្ឋធម្មនុញ្ញ" គឺជាគោលការណ៍គ្រឹះ ជាច្បាប់កំពូល របស់រដ្ឋដែលមានអាទិភាពជាងគេ។ លើកទីមួយនៅក្នុងប្រវត្តិសាស្ត្រសម្រាប់ប្រទេសយើង មានរដ្ឋធម្មនុញ្ញជាលើកដំបូងនៅឆ្នាំ១៩៤៧។ នៅក្នុងសេចក្តីព្រាងរដ្ឋធម្មនុញ្ញ ដែលបានធ្វើឡើងកាលពីឆ្នាំ១៩៤៦ គឺជាការរៀបចំឡើងដោយគណៈកម្មការបារាំង-ខ្មែរ ។ ដោយសារគណបក្សប្រជាធិបតេយ្យ ជាបក្សដែលមានសម្លេងភាគច្រើននៅក្នុងសភា ដូចនេះគណបក្សប្រជាធិបតេយ្យបានទាមទារសិទ្ធិ តាមរយៈសភាជាប់ឆ្នោតដើម្បីរៀបចំរដ្ឋធម្មនុញ្ញមួយឡើង ដោយគ្មានការជ្រៀតជ្រែកពីសំណាក់បារាំង និងពីរដ្ឋាភិបាល ។

រដ្ឋធម្មនុញ្ញខ្មែរឆ្នាំ ១៩៤៧ ជារដ្ឋធម្មនុញ្ញដែលបានចម្លងចេញពីរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋទី៤របស់បារាំងឆ្នាំ ១៩៤៦ ។ ដោយហេតុដូចនេះហើយ ទើបរដ្ឋធម្មនុញ្ញនៅឆ្នាំនោះបង្កើតឱ្យមានសភាពីរដូចបារាំងដែរ គឺ រដ្ឋសភា ឬសភាជាតិក្រុមប្រឹក្សាព្រះរាជាណាចក្រ ដែលមានសមាជិកជ្រើសតាំងដោយវិធីចាត់តាំងខ្លះ នឹងសមាជិកចាត់តាំងដោយព្រះមហាក្សត្រ មានសមាជិកជ្រើសតាំងដោយរដ្ឋសភា តែយកក្រៅពីអ្នកតំណាងរាស្ត្រ មានសមាជិកជ្រើសតាំងដោយការបោះឆ្នោតអសកលមិនចំពោះ ដែលជាអ្នកតំណាងភូមិភាគនីមួយៗឬក្រុងភ្នំពេញ ហើយនិងមានសមាជិកតំណាងវិជ្ជាជីវៈផ្សេងៗ និងតំណាងអ្នករាជការ ដែលត្រូវបានបោះឆ្នោតដោយចំពោះនិងតាមសំបុត្រ។ ក្នុងចំណោមសភាទាំងពីរនេះមានតែរដ្ឋសភាទេដែលមានសិទ្ធិបញ្ចេញមតិតាំងច្បាប់ សិទ្ធិនេះរដ្ឋសភាមិនអាចប្រគល់ឱ្យទៅនរណាបានឡើយ ។ ចំណែកឯក្រុមប្រឹក្សាព្រះរាជាណាចក្រ ដែលមានអាណត្តិស្មើនឹងអាណត្តិរបស់រដ្ឋសភាដែរនោះ មានតួនាទីត្រឹមតែជាអ្នកពិនិត្យ ហើយឱ្យយោបល់អំពីសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់ដែលរដ្ឋសភាដាក់ឱ្យពិនិត្យ ។

ដូចបារាំងដែរ រដ្ឋធម្មនុញ្ញឆ្នាំ ១៩៤៧ ក៏មានបង្កើតក្រុមប្រឹក្សាជាន់ខ្ពស់នៃតុលាការ ដែលបច្ចុប្បន្នហៅថាឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ សមាជិកក្រុមប្រឹក្សាជាន់ខ្ពស់នៃតុលាការមាន រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជាអធិបតី សមាជិកពីររូបដែលព្រះមហាក្សត្រទ្រង់ចាត់តាំង សមាជិកពីររូបដែលរដ្ឋសភាជ្រើសតាំង និង សមាជិកពីររូបដែលតុលាការទាំងឡាយជ្រើសតាំង ។ ក្រុមប្រឹក្សាជាន់ខ្ពស់នៃតុលាការត្រូវប្រព្រឹត្តិតាមបញ្ញត្តិច្បាប់ ដើម្បីឱ្យចៅក្រមទាំងឡាយរក្សាវិន័យ និងប្រតិបត្តិជាឯកច្ឆ័ន្ទបាន។

តាមរដ្ឋធម្មនុញ្ញនេះរបបនយោបាយខ្មែរ ជារបបសភានិយម គឺរដ្ឋាភិបាលត្រូវតែមានសេចក្តីទុកចិត្តរបស់សភា ដូច្នេះរដ្ឋាភិបាលត្រូវទទួលខុសត្រូវខាងនយោបាយចំពោះមុខសភា ។

ទន្ទឹមនឹងនេះដែរ ដោយរដ្ឋធម្មនុញ្ញឆ្នាំ ១៩៤៧ ជាស្នាដៃរបស់បញ្ញវន្តជាតិនិយម ដែលមិនសូវយល់ដឹងផ្នែកច្បាប់បានល្អិតល្អន់ និងចូលចិត្តចម្លងតាមរដ្ឋធម្មនុញ្ញបារាំងឆ្នាំ១៩៤៦ ដោយមិនបានដឹងថាទ្រឹស្តីអធិបតេយ្យជាតិបណ្តាលឱ្យមានវិបត្តិរវាងព្រះមហាក្សត្រ និងរដ្ឋសភាទៅថ្ងៃមុខ។ សូម្បីសមាជិករដ្ឋសភា និងសមាជិកក្រុម

ប្រឹក្សាព្រះរាជាណាចក្រខ្លះយល់ថា មានតែរដ្ឋសភាទេដែលត្រូវមានអធិបតេយ្យ ពោលគឺអំណាចស្ថិតនៅលើរដ្ឋសភា ឯអ្នកខ្លះទៀតយល់ថា ព្រះមហាក្សត្រទេដែលត្រូវមានអធិបតេយ្យខាងផ្លូវច្បាប់ ដូចជាមាត្រាទី២១ នៃរដ្ឋធម្មនុញ្ញចែងថា ៖ អំណាចគ្រប់យ៉ាងមកពីព្រះមហាក្សត្រ(នេះជាទ្រឹស្តីរាជាធិបតេយ្យ) តែប្រយោគបន្ទាប់មកសរសេរថា អំណាចទាំងនេះត្រូវប្រើទៅតាមបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញ នេះបានន័យថា ព្រះមហាក្សត្រមិនកាន់អំណាចទាំងឡាយដាច់ខាតទេ។ ក្នុងមាត្រាទី២២ទៀតក៏ចែងថា ៖ រដ្ឋសភាជាអង្គការតែមួយគត់ ដែលមានអំណាចនីតិប្បញ្ញត្តិ ដើម្បីញែកឱ្យដាច់រវាងអំណាចព្រះមហាក្សត្រនិងរដ្ឋសភា។ តែទោះជាយ៉ាងណាក៏ដោយ ក៏រដ្ឋធម្មនុញ្ញនេះបានផ្តល់អំណាចយ៉ាងច្រើនទៅឱ្យរដ្ឋសភាដែរ។

សម្តេចព្រះនរោត្តមសីហនុ ព្រះចៅក្រុងកម្ពុជា ទ្រង់បានយល់ព្រមឡាយព្រះហស្តលេខាលើរដ្ឋធម្មនុញ្ញនេះនៅថ្ងៃទី០៦ ឧសភា ១៩៤៧ ក្នុងឋានៈប្រទេសកម្ពុជា ជាសមាគតរដ្ឋ (Etat Associé)នៅក្នុងសហភាពឥណ្ឌូចិនបារាំង។

## 2. វិបាកនៃទំនើបនីយកម្ម

### 2.1. ការនាំយួនចូលស្រុកខ្មែរ

បើតាមស្នាដៃប្រវត្តិសាស្ត្រសង្ខេបនៃប្រទេសកម្ពុជា និពន្ធដោយ សាស្ត្រាចារ្យបណ្ឌិតរដ្ឋ ឃឹន សុខ សម្រាប់បង្រៀននៅសាលាភូមិន្ទរដ្ឋបាល បានឱ្យដឹងថា ″បារាំងបានអនុវត្តន៍នយោបាយបដិបក្សជាតិសាសន៍ ដើម្បីគ្រប់គ្រងកម្ពុជា″។ អ្នកតំណាងដំបូងបំផុតរបស់រាជការអាណាព្យាបាលបារាំងនៅកម្ពុជា(ពីខែមេសាឆ្នាំ១៨៦៣ ដល់ខែកក្កដាឆ្នាំ១៨៦៦ គឺឌូដាដឺឡាគ្រេ(Doudard de Lagrée) ក៏ដូចជាជនជាតិបារាំងដទៃទៀត ដែលបានមកដល់ស្រុកខ្មែរ បានសម្តែងនូវក្តីអស់សង្ឃឹមរបស់គេចំពោះចរិតធ្វើហឹ មិនអើពើរបស់ខ្មែរ។ ទើបធ្វើឱ្យគាត់ អនុញ្ញាតឱ្យពួកយួនច្រៀតចូលស្រុកខ្មែរ ដោយសន្សឹមៗ ល្មមៗ ដោយមិនឱ្យខ្មែរដឹងខ្លួន ដែលអាចនាំឱ្យខឹងនឹងគាត់។

ដោយដឹងច្បាស់ថា ពេលនោះ″ខ្មែរស្អប់យួនខ្លាំងពេក″ ជាការមួយជួយឱ្យកើតប្រយោជន៍ដល់បារាំងក្នុងការទន្ទ្រានកាន់កាប់ប្រទេសយួននោះ លោក ឡាហ្គ្រង់ឌីយែរ (La Grandière) ដែលជាទេសា-ភិបាលបារាំងនៅកូសាំងស៊ីន បានធ្វើឱ្យពួកមន្ត្រីខ្មែរមើលឃើញថា ប្រសិនបើពួកគេចង់ឱ្យបារាំងជួយការពារទល់នឹងពួកយួន ពួកគេត្រូវតែមានកក្តីស្មោះស្ម័គ្រទាំងកាយ ទាំងចិត្តចំពោះ″លោកបារាំង″។ អនុព័ន្ធបារាំងម្នាក់ប្រចាំនៅស៊ូល ឈ្មោះ លួីស៍ដឺការណេ(Louis de Carnet)បានទស្សន៍ទាយថា យួនជាពូជសាយកូននៅពេលបន្តិចទៀត តែកាលណានៅកូសាំងស៊ីនពួកគេរស់នៅកាន់តែចង្អៀតទៅ ពួកគេមុខជារាលដាលមកនៅតាមតំបន់វាលទំនាបរបស់ខ្មែរជាមិនខាន។ ផលប្រយោជន៍បារាំង គឺត្រូវបង្កលក្ខណៈសម្បត្តិងាយស្រួលឱ្យដល់ចលនាពង្រីកទឹកដីរបស់កូនចៅយួន។ ហើយយោបល់បែបនេះ គឺត្រូវមេដឹកនាំសំខាន់ៗរបស់បារាំងដែលបានឡើងកាន់អំណាចនៅកម្ពុជា និងអ្នកស្រាវជ្រាវរបស់ពួកគេ យល់ស្របគ្នារៀងមក ដូចជាលោក ហ្សង់ ម៉ូរ៉ា, លោក អេត្យេន អែម៉ូនីញេ, លោក លុយរ៉ូ ជាដើម។

បើតាមគំនិតដ៏ចង្អៀមួយទៀតរបស់លោក ឡឺមៀរ ដឺវីលែរ ដែលជាទេសាភិបាលកូសាំងស៊ីនពីឆ្នាំ១៨៧៩-១៨៨៣ និងធ្លាប់ជាអ្នកធ្វើការរដ្ឋបាលនៅប្រទេសបារាំង និងនៅអាល់ហ្សេរី និងដែលបានចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះនយោបាយបារាំងនៅកម្ពុជាពេលនោះ ម្ល៉េះសមស្រុកខ្មែរត្រូវក្លាយជារបស់យួនយ៉ាងស្ងៀមស្ងាត់តាំងពីចុងសតវត្សរ៍ទី១៩មក។ ក្នុងពេលស្នាក់នៅភ្នំពេញ រយៈពេល២០ថ្ងៃ នាដើមឆ្នាំ១៨៨២ គាត់បានធ្វើការវិភាគអំពីស្ថានភាពនៃប្រទេសនេះថា៖ ចំពោះរូបលោក ជនជាតិខ្មែរដែលពុំមានចំណង់ខាងការសិក្សានោះ ″មិនងាយនឹងវិវឌ្ឍន៍ឡើងទេ″។

ប្រទេសបារាំងមុខជាខាតពេលវេលាក្នុងការជំរុញជាតិសាសន៍នេះ ដែលត្រូវទំនាយថា នឹងត្រូវលុបរលាយសាបសូន្យ។ ......

"ផលប្រយោជន៍បារាំង គឺជួយយួនឱ្យចូលមកស្រុកខ្មែរដោយសន្តិវិធី ហើយត្រូវធ្វើយ៉ាងប្រញាប់ យកយួនមកជំនួសខ្មែរ ដូចរឿងដែលបានកើតឡើងរួចហើយនៅលើដែនដីកូសាំងស៊ីន នៅរវាងប៉ុន្មានឆ្នាំចុងក្រោយនេះ"។ នៅក្នុងទស្សនៈវិស័យបែបនេះហើយ ដែលបារាំងបានប្រើវិធានការណ៍សមស្របជាច្រើន ដើម្បីឱ្យយួនចូលមករស់នៅក្នុងស្រុកខ្មែរ។ ក្រិត្យមួយចុះថ្ងៃទី២៣កុម្ភៈ១៨៨១ បើកផ្លូវឱ្យប្រមែប្រមូលពួកជនជាតិយួន ដែលជាមនុស្សរបស់បារាំង (protegés) ឱ្យចុះឈ្មោះនៅក្រោមរាជការអាណាព្យាបាលបារាំង ដាក់ក្រោមអំណាចរបស់តុលាការបារាំង ឬតុលាការចម្រុះ ហើយបន្ទាប់មក មានបទបញ្ញត្តិមួយទៀតចុះថ្ងៃទី១២ មេសា១៨៨២ សម្រេចឱ្យពួកយួនដែលកំពុងរស់នៅក្នុងប្រទេសកម្ពុជាទាំងអស់នោះ រួចពន្ធខ្លួន។ ដូច្នេះ នយោបាយរបស់របស់ ឡឺមៀរដឺវីលែរ គឺពង្រឹងការត្រួតត្រារបស់បារាំងនៅប្រទេសកម្ពុជា ដោយបញ្ចូលយួនឱ្យមកនៅស្រុកខ្មែរ ដើម្បីឱ្យខ្មែរ ដែលជាប្រជាជនស្ទក់ មិនអើពើចំពោះការអប់រំ និងទំនើបកម្ម ភ្ញាក់ខ្លួនឡើង នៅពេលរស់នៅប្រឈមមុខចំពោះការប្រណាំងប្រជែងជាមួយយួន។ តាមរយៈការដាក់បញ្ចូលយួននៅក្រោមអំណាចតុលាការបារាំង និងការលើកលែងពន្ធខ្លួនសម្រាប់ជនជាតិយួននៅកម្ពុជា ក្នុងអនាគតដ៏ខ្លីពួកយួនមុខជាសំដៅមករស់នៅក្នុងប្រទេសកម្ពុជាបានកាន់តែច្រើនឡើងលើសពី ១០០ ០០០នាក់ភ្លាមៗ។

ស្របគ្នានឹងគំនិតនេះ គឺគំនិតរបស់លោក អាមីរ៉ាល់ ចូរ៉េគីបេរី ជារដ្ឋមន្ត្រីក្រសួងអាណានិគមរបស់បារាំងនៅពេលនោះ។ គាត់មានជំនឿយ៉ាងមុតមាំថា ភារកិច្ចរបស់បារាំងដែលចាត់ចែងទៅយ៉ាងនេះ នឹងទៅជារឿងសាមញ្ញ ហើយអាចកាត់បន្ថយពេលវេលាបានយ៉ាងខ្លីបំផុត ប្រសិនបើក្នុងពេលជាមួយនេះ ប្រទេសបារាំងបង្កភាពងាយស្រួលឱ្យយួន ធ្វើការទន្ទ្រានយកប្រទេសកម្ពុជាដោយសន្តិភាព។ ក្នុងទស្សនៈនេះហើយ ដែលមន្ត្រីអាណាព្យាបាលបារាំងលើកទឹកចិត្តអ្នកនៅក្រោមបង្គាប់របស់ខ្លួន ឱ្យខិតខំប្រឹងប្រែងជួយយួន យកឱ្យបានជាបណ្តើរៗនូវសិទ្ធិកាន់កាប់ដីធ្លី និងការធ្វើជំនួញដោយសេរី រួមទាំងការការពារយួនទល់នឹងការលោភលន់របស់មន្ត្រីខ្មែរ។ ការយកជនជាតិយួនមកដាក់ជំនួសខ្មែរ មុខតែប្រព្រឹត្តិទៅដោយឯកឯង បើសិនជាការធ្វើខ្មែរឱ្យទៅជាយួនមិនអាចធ្វើបាននៅឡើយ។ ចំណែកលោករដ្ឋមន្ត្រីក្រសួងការបរទេសបារាំង ពេលនោះក៏យល់ស្របនឹងនយោបាយស្ងៀមស្ងាត់របស់បារាំង ដូចគ្នានឹងសហសេវិកនៃក្រសួងអាណានិគមដែរ។ គាត់យល់ស្របនឹងវិធានការណ៍ផ្សេងៗដែលលោកទេសាភិបាលកូសាំងស៊ីនទើបនឹងចាត់ចែងឡើងនោះ គឺការធ្វើអន្តរគមន៍បន្តិចម្តងៗនៅក្នុងរដ្ឋការខ្មែរ និងការពារជនជាតិយួន ដែលជាមនុស្សរបស់បារាំងប្រកបដោយប្រសិទ្ធភាព ជួយយួនឱ្យមកកាន់ប្រទេសកម្ពុជា ដើម្បីពង្រឹងរដ្ឋអំណាចរាជការអាណាព្យាបាលឱ្យបានប្រាកដ ដោយកុំឱ្យមានវិបត្តិអ្វីកើតឡើង។

ជាភ័ព្វល្អបន្តិច លោក ក្លូបូកូវស្គី ដែលជានាយកខុទ្ទកាល័យរបស់លោកទេសាភិបាល សាល ថមសុន នៅខែកក្កដាឆ្នាំ១៨៨៥ បានធ្វើរបាយការណ៍មួយ ដែលមានខ្លឹមសារបដិសេធនយោបាយប្រកាន់ពូជសាសន៍ របស់អតីតទេសាភិបាល ឡឺមៀរដឺវីលែរ។ ប៉ុន្តែ គាត់បានបញ្ជាក់បន្ថែមថា "ជនជាតិខ្មែរស្លឹកមិនអើពើ បានជួយបារាំងត្រឹមតែធ្វើស្រុកខ្មែរឱ្យបានឡើងជាបង្គួរប៉ុណ្ណោះ"។

ដំណាលគ្នានោះលោកឧត្តមសេនីយ បេសាំង ជាទេសាភិបាលថ្មីនៃដែនដីកូសាំងស៊ីន(ពីខែកក្កដា១៨៨៥ ដល់១៨៨៦) បានធ្វើការប្រៀបធៀបការបះបោររបស់អ្នកប្រាជ្ញយួនតុងកឹង និងយួនអាណ្ណាម ទៅនឹងចលនាបះបោររបស់ប្រជាជនខ្មែរ(វិច្ឆិកា១៨៨៤-មករា១៨៨៧) ដែលគាំទ្រដោយព្រះបាទនរោត្តម។ គាត់បានខិតខំប្រើគ្រប់

មធ្យោបាយ ដើម្បីធ្វើឱ្យមានការស្ងប់ស្ងាត់ទៅវិញនៅស្រុកខ្មែរ។ គាត់បានសរសេរថា៖បើធ្វើឱ្យខ្មែរទុកចិត្ត ខ្មែរស្រឡាញ់រាប់អាន ហើយបារាំងខំការពារប្រយោជន៍របស់ខ្មែរ នោះបារាំងមុខជាទទួលការគាំទ្រយ៉ាងមុតមាំពីខ្មែរដែលស្អប់យួន។ ខ្មែរមានចិត្តអង់អាចក្លាហាន ជាទាហានយ៉ាងល្អវិសេស។ ជាមួយនឹងខ្មែរ បើគេប្រើការអត់ធ្មត់ និងការប្រុងប្រយ័ត្ន នោះជនជាតិខ្មែរមុខជាជួយយើង ដើម្បីនឹងពង្រឹងការត្រួតត្រានៅប៉ែកខាងត្បូងនៃដែនដីឥណ្ឌូចិនបានមុតមាំ។ មុននឹងស្វែងរកការកាន់កាប់ទូទាំងដែនដីជ្រោយឥណ្ឌូចិន ដោយឱ្យជនជាតិយួនជាអ្នករាតត្បាត មុនដំបូងយើងត្រូវពង្រីកអត្តភាពរបស់ខ្លួនឱ្យបានខ្លាំងពូកែសិន ដោយធ្វើឱ្យមានការគាំទ្រពីខ្មែរដែលស្អប់ពួកយួន ដែលពេលនេះមានពួកអ្នកប្រាជ្ញកំពុងធ្វើការបះបោរពេញមុខ។ វិធានការណ៍ដែលត្រូវធ្វើជាដំបូង គឺរាជការអាណាព្យាបាលត្រូវបណ្តេញឱ្យអស់ពីរដ្ឋការខ្មែរនូវពួកយួន ដែលកំពុងតែសម្តែងការប្រមាថមាក់ងាយដោយឥតលាក់លៀម។ បារាំងត្រូវបណ្តុះបណ្តាលខ្មែរ ឱ្យទៅជាអ្នកបកប្រែភាសា ជាអ្នកធ្វើការខាងប្រៃសណីយ៍។ នៅពេលនោះ គេបង្កើតកងអាសារស្ម័គ្រខ្មែរ ដើម្បីជំនួសពួកទាហាន និងកងអាសារស្ម័គ្រយួន ដើម្បីឱ្យខ្មែរដើរតួនាទីជាអ្នករក្សាសន្តិសុខនៅប្រទេសកម្ពុជាវិញ។

នយោបាយជាតិសាសន៍ប្រើតុល្យភាពរវាងយួន និងខ្មែរបែបនេះ លោកប្លង់គូបេ ដែលជាតំណាងរាស្ត្រនៅកូសាំងស៊ីន ក៏បានសម្តែងការយល់ស្របដែរ។ គាត់បានថ្លែងថា ចលនាបះបោររបស់ជនជាតិខ្មែរ បណ្តាលឡើងជាពិសេសមកពីការភ័ន្តច្រឡំនៃអនុសញ្ញាចុះថ្ងៃទី១៧មិថុនាឆ្នាំ១៨៨៤ ដែលបារាំងបានប្រើនយោបាយ"ចូលលុកលុយ" និងការ"លេបត្របាក់ខ្មែរ"បញ្ចូលទៅក្នុងទឹកដីកូសាំងស៊ីន ពោលគឺឱ្យទៅយួន។ នោះគឺជានយោបាយភាន់ច្រឡំ និងចង្រៃ ផ្ទុយពីផលប្រយោជន៍នៃការត្រួតត្រាកាន់កាប់របស់បារាំងតទៅអនាគត។ ការរក្សាទុកកម្ពុជា ឱ្យនៅជារដ្ឋស្វយ័ត អាចឱ្យផលល្អពីរយ៉ាង៖ ប្រទេសបារាំងរាតទីនៅដែនដីកូសាំងស៊ីនដោយប្រើអំណាចតិច បើគេប្រើតុល្យភាពរវាងខ្មែរ និងយួន ព្រោះគេស្អប់គ្នាខ្លាំងណាស់។ ដោយហេតុថា ខ្មែរមានអត្តសញ្ញាណខាងសាសនា និងអរិយធម៌ ខ្មែរជាសារធាតុយ៉ាងសំខាន់ និងចាំបាច់ចំពោះបារាំង សម្រាប់បង្កើតជាការទាក់ទងខាងនយោបាយ និងពាណិជ្ជកម្មជាមួយនឹងប្រទេសលាវ និងអាណាខេត្តនានានៅជិតជាប់នឹងប្រទេសសៀម។ ការកែទម្រង់ ដែលទើបតែនឹងអនុវត្តន៍តាមអនុសញ្ញាខែមិថុនាឆ្នាំ១៨៨៤ មិនត្រឹមតែធ្វើឱ្យមានការប៉ះពាល់ដល់មនោសញ្ចេតនាស្នេហាជាតិរបស់ប្រជាជនខ្មែរទេ ថែមទាំងធ្វើឱ្យជាតិសាសន៍ខ្មែរខ្សោយ ធ្វើឱ្យខ្មែរបាត់បង់នូវលក្ខណៈពិសេសរបស់ខ្លួនទៀត ធ្វើឱ្យខ្មែរឆោប់រលាយជាមួយនឹងជាតិសាសន៍យួន គឺបញ្ចូលសារធាតុដែលមានលក្ខណៈប្លែកៗគ្នា ឱ្យទៅជាអ្វីមួយ ថាអាចប្រើសម្រាប់ធានារ៉ាប់រងការត្រួតត្រារបស់បារាំងបាន។

យ៉ាងណាក៏ដោយ គំនិតបារាំងប្រឆាំងនឹងនយោបាយឱ្យយួនចូលមកនៅក្នុងស្រុកខ្មែរ ដើម្បីឱ្យបារាំងត្រួតត្រានៅឥណ្ឌូចិនបានស្រួលនោះ បានកើតឡើងតែមួយពេលដែលបារាំងកំពុងប្រឈមមុខតទល់នឹងចលនាបះបោររបស់យួនតែប៉ុណ្ណោះ។ បានន័យថា បារាំងប្រើនយោបាយតុល្យភាពកម្លាំងសត្រូវនេះ តែនៅពេលបារាំងមានការលំបាក។ លុះសន្តិភាពកើតមានឡើងវិញ ដោយសារពួកយួនសុខចិត្តដាក់កាយធ្វើកញ្ជះបារាំងដោយអស់ចិត្តហើយនោះ ទាំងលោកទេសាភិបាលបារាំងនៅកូសាំងស៊ីន និងលោករ៉េស៊ីដង់បារាំងទាំងប៉ុន្មាននៅស្រុកខ្មែរ ក៏ចាប់ផ្តើមប្រកាន់យកគោលគំនិតដើម ដែលចាត់ទុកជនជាតិយួនរស់នៅស្រុកខ្មែរថា មានតួនាទីសំខាន់ខ្លាំង តមកទៀត។

ក្រោយពីបារាំងបានសម្រេចបង្កើតសហភាពឥណ្ឌូចិនបារាំងនៅឆ្នាំ១៨៨៧ តាមគំនិតរបស់លោក ជូល អារម៉ង់ (Jule Armand) ដែលបានគូសវាសឡើងតាំងពីឆ្នាំ១៨៨៦ មេដឹកនាំរដ្ឋបាលបារាំងដំបូងគេ ឈ្មោះ ប៉ូល ឌូម៉ែ ជាអគ្គទេសាភិបាលឥណ្ឌូចិន បានសុំឱ្យព្រះបាទនរោត្តម យល់ព្រមតាមនៅឆ្នាំ១៨៨៧ ទើបព្រះរាជាត្រូវបង្ខំព្រះទ័យចេញរាជប្រកាសដកអំណាចរបស់ខ្លួនមួយ នៅថ្ងៃទី១១ កក្កដា ឆ្នាំដដែល។ ចាប់ពីពេលនោះមក រ៉េស៊ីដង់ជាន់ខ្ពស់

បានក្លាយជាអ្នកមានអំណាចពិតប្រាកដនៅកម្ពុជា ដោយគាត់ជាអ្នកគ្រប់គ្រងគណៈរដ្ឋមន្ត្រីរបស់ស្តេចខ្មែរដោយផ្ទាល់ ដោយមិនចាំបាច់មានការចូលរួមជាអធិបតីភាពពីព្រះមហាក្សត្រដូចពេលមុន និងសុំការសម្រេច ឬថ្វាយដំណឹងនៃការសម្រេចចិត្តរបស់អង្គប្រជុំដល់ព្រះរាជាឡើយ។ ព្រះមហាក្សត្រក្លាយជាស្តេចនៅក្នុងតែរាជវាំង ដែលចាមតែទទួលប្រាក់បៀវត្សរ៍ពីបារាំងប៉ុណ្ណោះ។ ប្រទេសខ្មែរ លាវ យួនទាំងបីដែនដីរដ្ឋបាលគឺ កូសាំងស៊ីន, អាណ្ណាម និងតុងកឹង ត្រូវស្ថិតក្រោមដែនដីរដ្ឋបាលធំរួមមួយ ដែលធ្វើឱ្យព្រំដែននៃប្រទេសនីមួយៗលែងក្លាយជាបញ្ហាសំខាន់។ ប្រជាជនសរុបនៃដែនដីរដ្ឋបាលថ្មីនេះ ប្រមាណ៤ភាគ៥ គឺជាពួកយួន។ បារាំងបន្តនយោបាយលើកតម្កើងផលប្រយោជន៍ពួកយួនឱ្យមានប្រៀបលើជនជាតិខ្មែរ និងលាវបន្ថែមទៀត។ ព្រោះពួកយួនស្ទើរគ្រប់ជំនាញវិជ្ជាជីវៈ អាចដើរចេញពីស្រុកកំណើតរបស់ខ្លួន មកតាំងទីលំនៅថ្មីបាននៅគ្រប់ទីកន្លែងទាំងអស់។ នៅក្នុងរបាយការណ៍ផ្លូវការខ្លះ គេគ្រាន់តែនិយាយអំពីការធ្វើអន្តោប្រវេសន៍ទៅនៅក្នុងស្រុកឯទៀតកាន់តែច្រើនឡើង។ តែនៅក្នុងឯកសារភាគច្រើន បារាំងបានប្រើពាក្យថា "ការលុកលុយ" ឬ "ការរាតត្បាត" ឬ "ការទន្ទ្រានកាន់កាប់ដោយសន្តិវិធី"របស់ពួកយួន។ អណិកជននៃរដ្ឋឥណ្ឌូចិននានា បានក្លាយទៅជាមានឈ្មោះថា "ជនស្រុកងាយនៃសហភាពឥណ្ឌូចិន"។ ព្រោះជនជាតិណាក៏ដោយ អាចធ្វើដំណើរពីស្រុកមួយទៅមួយទៀតបាន ក្នុងដែនដីឥណ្ឌូចិនបារាំង ដោយគ្រាន់តែមានកាតសម្គាល់ខ្លួនសម្រាប់បង្ហាញអាជ្ញាធរមូលដ្ឋានប៉ុណ្ណោះ។

បទប្បញ្ញត្តិទាក់ទងនឹងកិច្ចសម្រួលផលប្រយោជន៍ជនជាតិយួននៅកម្ពុជា ដែលអន្តរាគមន៍ដោយបារាំងមានតាំងពីនៅក្នុងសន្ធិសញ្ញាបារាំង-ខ្មែរ ថ្ងៃទី១១សីហា១៨៦៣មកម្ល៉េះ គឺនៅក្នុងមាត្រាទី៥ ដែលមានខ្លឹមសារបែបបង្វែងថា "មនុស្សរបស់បារាំង មានសិទ្ធិសេរីភាពពេញលេញនៅក្នុងប្រទេសកម្ពុជា"។ ដោយពាក្យខាងដើមនេះ មានន័យសំដៅដល់ពួកយួន នេះឯង។ នៅឆ្នាំ១៨៦៥ លោក ឡាហ្គ្រង់ឌីយែរ បានទទួលរាជានុញ្ញាតពីព្រះបាទនរោត្តមលុបចោលនូវការបង់ពន្ធគយដោយពួកមនុស្សរបស់បារាំង ឬយួនកូសាំងស៊ីន ដែលទៅរកស៊ីនៅបឹងទន្លេសាប។ នៅថ្ងៃទី១១កុម្ភៈ១៨៩៣ អគ្គទេសាភិបាលបានចេញប្រកាសចេញលិខិតធ្វើដំណើរ និងស្នាក់នៅមួយរយៈពេល១ឆ្នាំម្តងដល់ពួកយួនកូសាំងស៊ីនណាដែលមានបំណងចង់រស់នៅរកស៊ីក្នុងស្រុកខ្មែរ។ បើសំបុត្រនោះអស់សុពលភាព គេអាចទៅប្រកាសសុំពន្យារពេលតមកទៀត។

នៅឆ្នាំ១៩២០ ពេលបង្កើតដំណាំកៅស៊ូនៅភាគខាងកើតខេត្តកំពង់ចាម បារាំងបាននាំយួនតុងកឹង និងអាណ្ណាម ចំនួនរាប់ម៉ឺននាក់ មកឱ្យធ្វើកម្មករចៀរជ័រនៅទីនោះ។ បន្ទាប់ពីនោះ គឺពួកផ្សាយសាសនាកៅដាយ ដែលចេញពីខេត្តតៃនិញ មានចលនាផ្សព្វផ្សាយរកតែពួកយួននៅក្នុងក្នុងស្រុកខ្មែរ ដែលមកដល់ឆ្នាំ១៩២៨ ធ្វើឱ្យផែនទីយួននៅស្រុកខ្មែរ មានស្នាមអុជស្នេកស្កះដែលតំណាងឱ្យភូមិដ្ឋានរបស់យួន។ ហើយនៅទីក្រុងភ្នំពេញ ជនជាតិខ្មែរមានប្រមូលផ្តុំគ្នាតែនៅតំបន់ជាយក្រុង ខាងលិចផ្លូវព្រះមុនីវង្ស ដែលជាសង្កាត់ក្រីក្រប៉ុណ្ណោះ។ ចំណែកតំបន់ទីក្រុងសំខាន់នៅចាប់ពីផ្លូវព្រះមុនីវង្សទៅមាត់ទន្លេ ភាគខាងជើងព្រែកផ្សារចាស់ គឺជាលំនៅរបស់ពួកបារាំង ចាប់ពីផ្សារចាស់ដល់អនាគតសួនច្បារវិមានឯករាជ្យជាសង្កាត់ចិន និងចាប់នោះទៅត្បូងដល់ក្បាលថ្នល់ជាសង្កាត់របស់ពួកយួនអាណ្ណាម។

គឺកម្លាំងពួកយួនដែលចូលមកស្រុកខ្មែរតាំងយូរយារមក និងទើបនឹងចូលមកអស់ទាំងនេះហើយ ដែលបានក្លាយជាមូលដ្ឋានបង្អែកនៃការតស៊ូកុម្មុយនិស្តរបស់វៀតណាមនៅកម្ពុជា នាទសវត្សរ៍ឆ្នាំ១៩៤០ និង១៩៥០។[90]

---

[90] Cf., Ben Kiernan, *Pol Pot Regime,* and *How Pol Pot Came to Power?*

## 2.2. ការចូលស្រុកខ្មែររបស់ពួកចិន

ចិនចូលមកស្រុកខ្មែរមានរបៀបខុសពីយួន។ បារាំងចាត់បញ្ចូលជនជាតិចិនទៅក្នុងប្រភេទ«ជនជាតិបរទេសនៃទ្វីបអាស៊ី»។ ពេលចូលកាន់កាប់នៅកូសាំងស៊ីនបានភ្លាម បារាំងចាប់អារម្មណ៍ជាខ្លាំងចំពោះសមត្ថភាពក្តោបក្តាប់ពាណិជ្ជកម្មរបស់ពួកចិន ដែលអាចជាការកាត់បន្ថយផលប្រយោជន៍ពាណិជ្ជកម្មរបស់ពួកបារាំង។ ទើបបារាំងត្រូវរកវិធីគ្រប់គ្រងពួកនេះ ដោយការបង្កើតច្បាប់សហគមន៍ ដោយបង្ខំឱ្យជាតិពន្ធចិននីមួយៗបង្កើតជាសមាគម។ ក្រោមការគ្រប់គ្រងរបស់បារាំង គេហៅសហគមន៍ស្របច្បាប់ទាំងអស់នោះថា ”ហួយគួន”(Hui Guan) តាមភាសាចិន និងដែលកំណត់ដោយភាសាបារាំងថា Congrégation។ នេះជាសហគមន៍ជាតិពន្ធដូចគ្នា ហើយកេណ្ឌានីមួយៗប្រមូលផ្តុំពួកអ្នកនិយាយភាសាដើមតែមួយដូចគ្នា។[91] ច្បាប់នេះត្រូវបារាំងយកមកអនុវត្តន៍នៅប្រទេសកម្ពុជាដូចគ្នានោះដែរ។ ប្រសិនបើជនជាតិចិនណា ចង់មករស់នៅក្នុងប្រទេសកម្ពុជា ត្រូវតែមានការទទួលអនុញ្ញាតពីប្រធានសមាគមចិន ដែលនិយាយភាសាដូចគ្នានោះសិន។ ប្រធានសមាគមនោះឯង គេហៅថា ”អុងប៉ាង”គឺជាអ្នកទទួលធានារ៉ាប់រងពួកនោះ ចំពោះរដ្ឋការបារាំង។ ទោះជាយ៉ាងណា ដោយរាប់បញ្ចូលទាំងពួកចិនដែលមានជាច្រើនជនជាតិផ្សេងគ្នានៅស្រុកខ្មែរ សង្គមខ្មែរពេលនោះ គេអាចហៅបានថា ជា”សង្គមចម្រុះ”ជាតិសាសន៍។ ដោយសារពួកឥណ្ឌា និងជ្វា ធ្វើពាណិជ្ជកម្មមានចំនួនតិចតួច យើងមិនចាំបាច់យកមកនិយាយក្នុងទីនេះឡើយ។ ប៉ុន្តែ ការប្រមូលផ្តុំជនជាតិចិនតាមមាគមបែបនេះ បានបង្កើតទៅជារចនាសម្ព័ន្ធនយោបាយសម្រាប់អង្គការសង្គមចិន នៅតាមមជ្ឈមណ្ឌលសេដ្ឋកិច្ចសំខាន់ៗនៅកម្ពុជា។ រហូតមកដល់ទសវត្សរ៍១៩៦០, សហគមន៍ចិននៅកម្ពុជា ក៏ដូចនៅតាមប្រទេសទីបីដទៃទៀត បានបង្កើតជាសមាគមស្ម័គ្រចិត្ត ដើម្បីផ្តល់នូវគ្រោងឆ្អឹងនយោបាយផង និងនូវអត្តសញ្ញាណវប្បធម៌មួយចំណែកធំផងដែរ។

មកដល់ឆ្នាំ១៩១២ គេបានបង្កើតមន្ទីរអន្តោប្រវេសន៍ និងមន្ទីរធ្វើកាតមួយ ក្នុងគោលបំណងត្រួតពិនិត្យជនបរទេសអាស៊ី ដែលជាចិន។ ជាពិសេស ដើម្បីត្រួតពិនិត្យលើការស្នាក់នៅ និងការចេញចូលនៃពួកបរទេសអស់ទាំងនោះ។ ទោះបីជាយ៉ាងណា នៅដើមដំបូងនៃកិច្ចការនេះ គេបានកំណត់សកម្មភាពរបស់អាជ្ញាធរនេះ ឱ្យនៅត្រឹមតែពិនិត្យមើលសារពើពន្ធនៃជនបរទេសអាស៊ីក្នុងក្រុងភ្នំពេញ។ ពីមួយថ្ងៃទៅមួយថ្ងៃ បារាំងពិនិត្យពិច័យយ៉ាងខ្លាំង ចំពោះដំណើរសេដ្ឋកិច្ចរវាងសហគមន៍ចិននៃរាជធានីភ្នំពេញ និងសហគមន៍ចិនធំៗតាំងនៅព្រៃនគរ និងទីក្រុងច្រឹឡឹង។ នេះជាការចាំបាច់ ក្នុងការដាក់ពួកចិនអន្តោប្រវេសន៍ស្រុកខ្មែរជាមួយនឹងអន្តោប្រវេសន៍កូសាំងស៊ីន។ ត្រង់នេះបញ្ជាក់ឱ្យឃើញថា បារាំងធ្វើតែច្បាប់ស្តីអំពីអន្តោប្រវេសន៍ចិន។ ប៉ុន្តែបារាំងពុំបានធ្វើច្បាប់ណាមួយស្តីអំពីអន្តោប្រវេសន៍យួននៅស្រុកខ្មែរទេ។

តាមសៀវភៅរបស់លោក H. J. H. Alers បានស្នើថា ពួកជនជាតិចិនចូលមកកាន់អាស៊ីអាគ្នេយ៍តាមរបៀបពីរប្រភេទខុសពីគ្នា ៖ ១)-នៅក្នុងតំបន់កសិកម្មដែលមានប្រជាជនរស់នៅ (ជាពិសេសកោះជ្វា) ជនជាតិចិនបានចូលទៅកាន់តំបន់នេះក្នុងឋានៈជាអ្នកជំនួញ។ ពីព្រោះតែពួកគេគ្មានដីធ្លីសម្រាប់ធ្វើកសិកម្ម។ ២)-ប៉ុន្តែនៅក្នុងតំបន់ដែលមិនសូវមានប្រជាជនច្រើន (កោះប័រណេអូ, ម៉ាឡាយ៉ា), ជនជាតិចិនតាំងលំនៅនៅលើកោះទាំងនោះ ក្នុងឋានៈជាអ្នកស្រែចម្ការ និងជីករ៉ែ។ របៀបតាំងលំនៅទាំងពីរបែបនេះ គេឃើញកើតមាននៅក្នុងប្រទេសកម្ពុជា។[92] នៅក្នុងតំបន់

---

[91] Cf., William E. Willmott, (1967). *The Chinese in Cambodia*, University of Brittish Columbia.

[92] ច្បាស់ណាស់ថា ការតាំងទីលំនៅទាំងពីរប្រភេទនេះ គេឃើញមាននៅក្នុងផ្នែកជាច្រើនទៀតនៃតំបន់អាស៊ីអាគ្នេយ៍ ជាពិសេសម៉ាឡាយ៉ា និងប្រទេសថៃ។ កត្តាដែលមានដីធ្លីគ្រប់គ្រាន់សម្រាប់ការតាំងទីលំនៅក្នុងតំបន់ឧបទ្វីបឥណ្ឌូចិន យ៉ាងយឺតពីរសតវត្សរ៍កន្លងទៅនេះ បានដាក់ប្រស្នាចំពោះអ្នកជំនាញភូមិសាស្ត្រមួយចំនួន។ លោក Zelinski និយាយអំពីតំបន់នេះថាជា

វាលស្រែទំនាបដ៏សំបូរជីរជាតិនៃអាងទន្លេសាប និងទន្លេមេគង្គ ជនជាតិចិនបោះទីតាំងរស់នៅក្នុងឋានៈជាអ្នកលក់ដូរ និងចងការប្រាក់ ដោយប្រមូលផ្តុំគ្នាជាពិសេសនៅភ្នំពេញ។ នៅតំបន់មិនសូវសំបូរមនុស្សដូចកំពត កន្លែងដែលផ្ទៃដីខ្ពស់ផុតពីទឹកជំនន់ ជនជាតិចិនតាំងទីលំនៅក្នុងតំបន់ជនបទនេះ ដើម្បីដាំដំណាំម្រេច។

លក្ខណៈសម្បត្តិសេដ្ឋកិច្ចសំខាន់បំផុតរបស់ដែលគេហៅថា "កសិករ"ចិននៅកម្ពុជា គឺការរស់នៅក្នុងការដាំដុះគ្រាប់ពូជក្រដាសប្រាក់ ជាពិសេសសម្រាប់ទីផ្សារ ដែលជារូបិយប័ណ្ណដែលគេត្រូវប្រើសម្រាប់ទិញអាហារបរិភោគ។[93] ក្នុងន័យម្យ៉ាងទៀត សូម្បីតែចិននៅស្រុកស្រែចម្ការ ក៏ត្រូវភ្ជាប់ខ្លួននឹងរបរជួញដូរដែរ ដែលជាការខុសគ្នាឆ្ងាយពីកសិករជនជាតិដើម ឬកសិករចិននៅក្នុងប្រទេសចិន។ ដោយសារពួកគេដាំដំណាំ ដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ និងយ៉ាងច្រើនគោលដៅទីពីរ គឺដើម្បីតែទិញរបស់ចាំបាច់នានាសម្រាប់ជីវភាពប៉ុណ្ណោះ។ (មានតែជនជាតិចិន ដែលក្លាយជាអ្នកធ្វើស្រែនៅកម្ពុជា ក្នុងខេត្តបាត់ដំបងប៉ុណ្ណោះ ដែលបង្ហាញនូវការដាក់ចិត្តកាយជាប្រជាជាតិខ្មែរ ស្របតាមបរិយាកាសនៅជុំវិញលំនៅដ្ឋានរបស់ពួកគេ)។ នៅក្នុងន័យធម្មតារបស់ពាក្យនេះ វាគ្មានកសិករចិនទេ នៅក្នុងប្រទេសកម្ពុជា។

កង្វះកម្មករជាតិចិននាំឱ្យកើតមាននូវកត្តា ដែលថានៅកម្ពុជាមិនទាន់មានការនាំចូលនូវកម្លាំងកម្មករកិច្ចសន្យា ក្នុងបរិមាណគួរឱ្យចាប់អារម្មណ៍នៅឡើយ លើកលែងតែពួកកម្មករភាគច្រើនជាជនជាតិចិនហៃណាន់នៅក្នុងចំការដំណាំម្រេចខេត្តកំពត ដែលក្រោយពីបញ្ចប់កិច្ចសន្យា ពួកគេមានទាំងត្រឡប់ទៅប្រទេសចិនវិញផង និងមានទាំងអ្នកបន្តរស់នៅកម្ពុជាផង ដើម្បីចាប់ផ្តើមដាំដំណាំម្រេចដោយខ្លួនឯងនៅលើផ្ទៃដីដែលអាចអនុគ្រោះដល់ពួកគេ។ កម្មករចិននៅឯនាយសមុទ្ទ ដូចគ្នានឹង"កសិករ"ចិន គឺថាប្រភេទតែមួយដូចគ្នានៃទស្សនវិស័យ និងមហិច្ឆតារបស់ពួកគេក្នុងការរួបរួមគ្នាយ៉ាងជិតស្និទ្ធជាមួយនឹងពួកពាណិជ្ជករចិននៅក្រៅប្រទេសភាគច្រើន នៅក្នុងសង្គមចម្រុះរបស់កម្ពុជា។[94]

គំនិតនាំមកនូវសន្តិភាព ក្នុងសង្គមចម្រុះរបស់កម្ពុជា ពឹងផ្អែកលើវត្តមានរបស់មហាអំណាចអាណានិគមបារាំង ត្រូវបានគេស្នើឡើងតាំងពីយូរ ដោយលោកបណ្ឌិត ម៉ូរីស ហេប្ប (Maurice Hepp) មុនលោក ហ្វឺនីវ៉ល (Furnivall) ទៅទៀត។ ក្នុងស្នាដៃរបស់គាត់នៅឆ្នាំ១៩២៨, លោក ហេប្បបានស្នើថា បើទុកជាពួកគេមានអរិយធម៌

---

'ប្រជាជនមិនប្រក្រតី" សម្រាប់ការបង្ហាញនូវដង់ស៊ីតេប្រជាជនគួរឱ្យចាប់អារម្មណ៍ ក្រោមលក្ខខណ្ឌតំបន់ជិតខាង និងមានទិដ្ឋភាពដូចគ្នា។ គាត់បានស្នើហេតុផលបីឡើងថា តើមូលហេតុអ្វីក៏រឿងនេះទៅជាដូច្នេះ ៖ ១)-ដីទំនាបចន្លោះជួរភ្នំជាច្រើនដែលដូចគ្នានឹង'ភាពជាច្រកផ្លូវ" ដែលអាចឱ្យគេធ្វើចំណាកស្រុកជាប្រចាំពីផ្ទៃខាងក្នុង ដោយគ្មានឧបសគ្គដល់ការតាំងទីលំនៅ។ ២)-'ការតាំងលំនៅជាស្ទួល"មានទំហំតូចតាច។ ៣)-ពុទ្ធសាសនាប្រតិស្ថានដោយគ្មានតម្លៃទៅលើបច្ចាជន ហើយធម្មភាពបូជារបស់បុព្វបុរសក៏ត្រូវបាត់បង់។ បើក្រឡេកមើលប្រទេសកម្ពុជាវិញ បរិមាណមួយភាគបួន និងប្រហែលជាហេតុផលសំខាន់បំផុតដែលគប្បីបន្ថែមថា សង្គ្រាមប្រឆាំងនឹងពួកអាណ្ណាម និងថៃ បានដឹកនាំឱ្យមានការកាប់សម្លាប់អ្នកលក់ដូរបោះដុំជាច្រើននាក់ និងការចាប់ជម្រត់ខ្មែរអស់រយៈពេលបួនសតវត្សរ៍ ចន្លោះការធ្លាក់ចុះនៃមហាអំណាចអង្គរ និងការបង្កើតសន្ធិសញ្ញាសន្តិភាពព្រមរួមរស់នៅក្រោមមហាអំណាចមួយ បីដូចនឹង *the pax gallica* ជាឈ្មោះ សន្ធិសញ្ញាសន្តិភាព ដែលពួកហ្គោល ឬ បារាំង បុរាណត្រូវទទួលស្គាល់អំណាចរបស់រ៉ូមលើប្រទេសបារាំង។ កាលពីសតវត្សរ៍ទី១មុនគ.ស.)។

[93] នេះគឺពិតជាដូចគ្នានឹងជនជាតិចិនខិ ដែលជាអ្នកដាំចំការកៅស៊ូនៅកោះសារ៉ាវ៉ាក់ (តៀន) និងពួកចិនទាជីវ ដែលជាអ្នកដាំបន្លែនៅម៉ាឡាយ៉ា (ញូវែល)។

[94] កត្តាដែលកម្មករជាតិចិននៅបរទេស តែងតែមានមហិច្ចតាដូចៗគ្នា នៅខណៈពេលដែលពួកបញ្ញវន្តធ្វើការវិភាគលើមនោគមវិជ្ជាម៉ាក្សនិយមទៅលើការលំបាក និងការដឹកនាំខុសខាងសង្គមរបស់ពួកជនជាតិចិននៅឯនាយសមុទ្ទ។ Simoniya បានព្យាយាមធ្វើការវិភាគបែបនេះ ប៉ុន្តែមិនសូវបានបានជោគជ័យល្អទេ (cf. W. Willnott 1963).

ខ្ពង់ខ្ពស់ក៏ដោយ ក៏ពួកជនជាតិចិនមានសារៈប្រយោជន៍ណាស់នៅក្នុងរបបអាណានិគម ដរាបណារដ្ឋបាលអាណានិគមដាក់ការត្រួតពិនិត្យលើពួកគេដោយគត់មត់ (Hepp, 251) ។ ប៉ុន្តែថា ទាំងលោក ហេប្ប និងទាំងលោក ហ្វឺនីវ៉ល បានពន្យល់ចំណុចនេះមិនបានច្បាស់គ្រប់គ្រាន់ដូចគ្នា ដោយសារកត្តាដែលថា សង្គមចម្រុះនៅកម្ពុជា បានកើតមានយ៉ាងហោចណាស់ពីរសតវត្សរ៍មុនការមកដល់របស់បារាំង ជាក់ស្តែងវាគ្មានទាំងអំពើហិង្សា ឬទាំងព្រឹត្តិការណ៍មិនល្អ។[95] ច្បាស់ណាស់ គេត្រូវតែរកឱ្យឃើញ នូវការពន្យល់កាន់តែល្អពីសារជាតិនៃសាមគ្គីភាពក្នុងសង្គមចម្រុះ។

លោក វីលៀម វីលមុត(William E. Willmott)ធ្វើការពន្យល់ ដោយផ្អែកលើរចនាសម្ព័ន្ធសង្គមនៃបំណែកជាតិពន្ធនីមួយៗក្នុងសង្គមចម្រុះ។ កត្តាសំខាន់មួយទៀត គឺទំនាក់ទំនងសេដ្ឋកិច្ច ដែលពួកគេផ្ទាល់ជាប់ជំពាក់ជាមួយសហគមន៍ជាតិពន្ធខុសៗពីគ្នា។ ទោះបី ការពិតថា សង្គមចម្រុះអាចខ្វះនូវការរួមចំណែកខាង”ឆន្ទៈសង្គម” ដូចដែលលោក ហ្វឺនីវ៉លបានលើកឡើង ក៏សារជាតិនៃចំណងសេដ្ឋកិច្ចរវាងពួកពាណិជ្ជករជាតិចិន និងកសិករជនជាតិដើម ទាមទារឱ្យមាននិរន្តរភាព និងការពន្យល់បន្ថែម ក្នុងន័យដើម្បីផលប្រយោជន៍ទាំងសងខាង។ បើគ្មានពាណិជ្ជករទេ កសិករក៏គ្មានប្រភពធនធានជាផលិតផលផ្សេងៗពីរោងចក្រ ដែលជាតម្រូវការចាំបាច់ដែរ ហើយបើគ្មានកសិករទេ អ្នកជំនួញក៏គ្មានអតិថិជនសម្រាប់ទំនិញរបស់គាត់ដែរ ថែមទាំងគ្មានអ្នកផ្គត់ផ្គង់ផលកសិកម្មសម្រាប់គាត់យកទៅលក់នៅទីក្រុងដែរ។ ជាងនេះទៀត ការចាត់ចែងឱ្យខ្ចីបុលប្រាក់ ដោយផ្អែកលើមូលដ្ឋានទុកចិត្តគ្នាជាពិសេស ដែលភាគីទាំងពីរមិនដែលក្បត់គ្នា បានចងពួកគេមិនឱ្យបែកចេញពីគ្នាបាន (cf. Ward 150f.) ។ និយាយម្យ៉ាងទៀត ទំនាក់ទំនងសេដ្ឋកិច្ចរវាងក្រុមអ្នកមានមុខងារជាក់លាក់ទាំងឡាយ បង្កើតនូវប្រយោជន៍រួមគ្នាដែលចងក្រងសង្គមជាច្រើនជាមួយគ្នា ថាតើ មានឬគ្មានសម្ពាធពីខាងក្រៅរបស់មហាអំណាចអាណានិគម បង្ខំឱ្យពួកគេរស់នៅដោយស្ងប់ស្ងៀមដែរឬទេ។

គំនិតនេះ ទើបតែចម្រើនជឿនលឿនឡើងដោយសារអត្ថបទមួយរបស់លោកសាស្ត្រាចារ្យ វើធីម (Prof. Wertheim) ដែលថា ភាពខុសគ្នាខាងវប្បធម៌ មិនបានទាំងពន្យល់ពីពួកគេផ្ទាល់ខ្លួន នូវភាពតានតឹងក្នុងសង្គមចម្រុះផង និងទាំងការកេងប្រវ័ញ្ចសេដ្ឋកិច្ចនៃក្រុមជាតិពន្ធមួយ ដោយក្រុមមួយទៀតដែលចាំបាច់នាំឱ្យកើតជម្លោះ។ ជាការពិត ការសិក្សាអំពីប្រវត្តិសាស្ត្ររបស់អាស៊ីអាគ្នេយ៍លេចចេញនូវសំណើថា ជម្លោះឆ្លងព្រំដែនជាតិពន្ធបានកើតឡើង នៅពេលណាមានវណ្ណៈសេដ្ឋកិច្ចស្រដៀងគ្នាច្រើន នៅក្នុងក្រុមជាតិពន្ធទាំងពីរ ក្នុងការប្រកួតប្រជែងដោយផ្ទាល់រវាងពួកគេទាំងសងខាង (Wertheim 1964, 76ff.) ។ នៅកោះជ្វា សំនួនវោហារនៃមនោសញ្ចេតនា និងព្រឹត្តិការណ៍ហិង្សាប្រឆាំងពួកចិនកើតឡើងនៅពេលវណ្ណៈជ្វាថ្នាក់កណ្តាលបានចាប់កំណើតឡើង នៅពេលឯកទេសនីយកម្មជាប្រពៃណីរបស់ជាតិពន្ធកំពុងរងការវិនាស, ភ្លាមនោះ នៅពេលរចនាសម្ព័ន្ធបានចាប់ផ្តើមផ្លាស់ប្តូរពីប្រភេទឧត្តមគតិនៃសង្គមចម្រុះ ដែលបានពិពណ៌នាដោយហ្វឺនីវ៉ល (*ibid.*) ។[96] ស្ថិតក្នុងស្ថានភាពបែបនោះ វត្តមាននៃកង

[95] គំនិតសង្គមចម្រុះកើតមាននៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ផ្តល់អាទិភាពដល់ការវាតទីរបស់ពួកអឺរ៉ុប ដែលហាក់ដូចជាគេចចេញពីគំនិតរបស់ហ្វឺនីវ៉ល ដែលមិនមែនជាអ្នកប្រវត្តិសាស្ត្រ សម្រាប់អ្វីដែលគាត់ចង្អុលបង្ហាញថា សង្គមចម្រុះ គឺជាការបង្កើតឡើងពីគោលនយោបាយរបស់ពួកអាណានិគម (Furnivall 1942, 198-9)។ វាពិតណាស់ថា អ្នកកាន់អំណាចអាណានិគមបានជួយជំរុញលក្ខខណ្ឌសេដ្ឋកិច្ចសម្រាប់សង្គមចម្រុះ និងថា របបអាណានិគមខ្លះជាពិសេសហូឡង់ និងបារាំងបានផ្តល់នូវនិយមន័យស្របច្បាប់បង្កើតទម្រង់សារជាតិចម្រុះនៃសង្គមអាណានិគម។ ប៉ុន្តែ បើតាមយោបល់ខ្ញុំ វាគ្មានហេតុផលអ្វីត្រូវទាត់ចោលនូវលទ្ធិគោលការណ៍ និងចក្រពត្តិនិយមរបស់អាស៊ីអាគ្នេយ៍មុនរបបអាណានិគមពីគំនិតនេះដែរ។

[96] វិកបើក បាននិយាយបន្ថែមនូវរឿងដូចគ្នានេះនៅប្រទេសហ្វីលីពីន (Wickberg 1962, 276-7)។ នៅទំព័រ២៨៥ គាត់ធ្វើការអះអាងយ៉ាងច្បាស់លាស់អំពីនិក្ខេបបទរបស់លោក វើធីម ៖ ក្រោយឆ្នាំ១៨៥០ កំណើនបរិមាណ, របាយ និងអំណាចសេដ្ឋកិច្ចរបស់ជនជាតិចិន បាននាំមកនូវសភាពការប្រកួតប្រជែងគ្នាជាមួយអាជីវកម្មរបស់ពួក *mestizo* និងពួកហ្វីលីពីន ដែលបានអភិវឌ្ឍន៍

ទ័ពអាណានិគមអាចរារាំងអំពើហិង្សា ក៏ប៉ុន្តែជាញឹកញាប់ ចលនាប្រឆាំងនឹងជនជាតិចិនមួយ អាចជាផលប្រយោជន៍របស់មហាអំណាចអាណានិគម។ ដោយហេតុដូច្នេះហើយ ទើបគេបានលើកទឹកចិត្តឱ្យវាកាន់តែរីកដុះដាលឡើង។ ជាឧទាហរណ៍ នៅក្នុងប្រទេសហ្វីលីពីន អំឡុងសតវត្សរ៍ទី១៩ ពួកអេស្ប៉ាញពិតជាសប្បាយចិត្តពេលឃើញមនោសញ្ចេតនាប្រឆាំងពួកជនជាតិចិន សម្តែងចេញឡើងដោយពួកហ្វីលីពីន (Wickberg 1962, 276f) ។ បាតុកម្មប្រឆាំងជនជាតិចិននៅសៃហ្គនក្នុងឆ្នាំ១៩១៩ និងនៅកំពង់ផែហៃហ្វុង ក្នុងឆ្នាំ១៩២៧ យ៉ាងហោចណាស់ មានការគាំទ្រជាកម្លាំងចិត្តដោយដោយពួកបារាំង ដែលបានអនុគ្រោះឱ្យពួកពាណិជ្ជករយួនបំបាក់សេដ្ឋកិច្ចពួកចិន ដែលបានក្តាប់នៅទូទាំងឥណ្ឌូចិន និងកាត់បន្ថយខ្លះ នៅតុងកឹង។[97] ជាការពិតណាស់ថា ការប្រៀបធៀបជាមួយប្រទេសវៀតណាម នាំឱ្យគេកត់សម្គាល់នូវហេតុផលសេដ្ឋកិច្ចថា ហេតុអ្វីក៏ជម្លោះបែបនេះ មិនបានអភិវឌ្ឍន៍ផងនៅកម្ពុជារវាងពួកខ្មែរ និងចិន។ សម្រាប់បញ្ហានេះ វាចង្អុលបង្ហាញឱ្យឃើញច្បាស់ថា មកពីនៅកម្ពុជាគ្មានវត្តមានយ៉ាងហោចណាស់នូវវណ្ណៈខ្មែរថ្នាក់កណ្តាលមួយ។

ទ្រព្យសម្បត្តិភាគច្រើនរបស់ពួកយួននៅឥណ្ឌូចិន បានមកពីការធ្វើម្ចាស់ដីធ្លី សម្រាប់៨០%នៃដីស្រែចម្ការស្ថិតនៅក្នុងដៃពួកកុម្ម៉ីក៍ នៅខណៈដែលមានតែកសិករម្នាក់ក្នុងចំណោមម្ចាស់ដីតូចតាចបួននាក់ ដែលគាត់បានធ្វើការដាំដុះ (Jacoby, 160f.) ។ ផ្ទុយទៅវិញ នៅកម្ពុជា កសិករ៩៥%គឺជាអ្នកដាំដុះដំណាំលើដីធ្លីរបស់ខ្លួន (*ibid.*, 157) ហើយមានប្រជារាស្ត្រតិចតួចណាស់ ដែលមានដីកម្មសិទ្ធិធំជាងទំហំដែលគេអាចដាំដុះបានដោយខ្លួនឯង។[98] កង្វះវណ្ណៈកុម្ម៉ីក៍នៅកម្ពុជា អាចបណ្តាលមកពីមូលហេតុមួយចំនួន រួមទាំងកត្តាដែលថា វាលស្រែភាគច្រើនជាវាលទំនាបលិចទឹកច្រើនជាងវាលស្រែដីគោកត្រូវប្រើប្រព័ន្ធធារាសាស្ត្រ ដីទាំងអស់នោះជារបស់ម្ចាស់តែម្នាក់ គឺស្តេចរហូតដល់ឆ្នាំ១៩០៤ ហើយដែលតែងតែមានដីកសិកម្មមិនបានដាំដុះគ្រប់គ្រាន់នៅក្នុងតំបន់មានជីវជាតិ រារាំងដល់

---

តាំងពីអំឡុងមួយសតវត្សរ៍១៧៥០-១៨៥០មកហើយ។ គម្លាតគ្នាខាងវប្បធម៌បានកើតឡើងយ៉ាងច្បាស់ក្រឡែត នៅក្នុងជម្លោះប្រឆាំងពួកចិននៅរវាងទសវត្សរ៍១៨៨០ និង១៨៩០។ ប៉ុន្តែកត្តាសេដ្ឋកិច្ចបានធ្វើឱ្យមានឥទ្ធិពលដល់ការសម្រេចចិត្ត។ កត្តាអាទិភាពចំពោះអារម្មណ៍ប្រឆាំងជាជាតិចិននៅក្នុងសតវត្សរ៍ទី១៦ និង១៧បានជុំរុញឡើង និងប្រើប្រាស់ដោយពួកអេស្ប៉ាញ។ ប៉ុន្តែវាខ្វះនូវមូលដ្ឋានបង្អែកសេដ្ឋកិច្ចក្នុងចំណោមពួកហ្វីលីពីន។

[97] នៅឆ្នាំ១៩១៩ បាតុកម្មនៅសៃហ្គន ប្រកាន់យកទម្រង់នៃការបដិសេធចោលនូវពាណិជ្ជកម្មចិន និងការប្រឹងប្រែងរបស់ពួកយួន ដើម្បីបង្កើតក្រុមហ៊ុនពាណិជ្ជកម្មរបស់ខ្លួនឯង ជំនួសតួនាទីរបស់ចិន។ បំណងនោះត្រូវបរាជ័យ នៅពេលពួកចិនទារយកប្រាក់ចងការដ៏ច្រើនៗទាំងអស់នោះមកវិញ។ កុប្បកម្មនៅទីក្រុងហៃហ្វុង ត្រូវគេផ្តើមធ្វើនៅខែសីហាឆ្នាំ១៩២៦ ហើយដឹកនាំឱ្យមានការដុតបំផ្លាញសង្កាត់ចិននៅទីក្រុងនេះ ដោយពួកកម្មករកំពង់ផែយួន (Dennery 1931, 156)។ លោករ៉ូបេក្វេន(ទំព័រ៤០) និងយូឡេត ផ្តល់កាលបរិច្ឆេទនៃកុប្បកម្មនៅហៃហ្វុងថានៅឆ្នាំ១៩២៧។ អនុលោមតាមលោក យូឡេត លទ្ធផលនៃកុប្បកម្មនោះធ្វើឱ្យមនុស្សស្លាប់៦នាក់, របួស១០០នាក់, បំផ្លាញផ្ទះអស់៣០, ដុតបំផ្លាញអគារ៨, មនុស្ស ១៥០នាក់ត្រូវចាប់ខ្លួន ហើយ៥៧នាក់ក្នុងចំណោមនោះត្រូវផ្តន្ទា ដោយកាត់ក្តីព្យួរទោសពី៣ខែទៅ៦ខែ (Coulet, 464) >

[98] See Delvert, 488-501, ជាពិសេសទំព័រ៤៩៥ ដែលគាត់ផ្តល់ជាបន្តបន្ទាប់នូវរបាយនៃផ្ទាស់ដី (ម្ចាស់កម្មសិទ្ធិអចលនាទ្រព្យ)ចំនួន ៧២៧០០០នាក់ នៅក្នុងការសិក្សាអង្កេតរបស់គាត់ ដែលបានរួមបញ្ចូលនូវដីវាលស្រែទំនាបភាគច្រើនបំផុតនៃប្រទេសកម្ពុជា ៖ ៤០២ ០០០ (៥៥%) មានដីស្រែ តិចជាង ១ហិចតា

| | | | |
|---|---|---|---|
| ១៨៣ ០០០ | (២៥%) | មានដីស្រែពី | ១ហិចតាទៅ ២ហិចតា |
| ៩០ ០០០ | (១២%) | មានដីស្រែពី | ២ហិចតាទៅ ៤ហិចតា |
| ៤៨ ០០០ | (៧%) | មានដីស្រែពី | ៥ហិចតាទៅ ១០ហិចតា |
| ៩ ៣០០ | (១%) | មានដីស្រែពី | ១០ហិចតាទៅ ២០ហិចតា |
| ១ ១៩១ | | មាន ដីស្រែ | លើស ពី ២០ ហិចតា |

ការអភិវឌ្ឍន៍ទីផ្សារដីដាំដំណាំសកម្មមួយ។ ហេតុផលអ្វីក៏ដោយ មានខ្មែរតែប៉ុន្មាននាក់ប៉ុណ្ណោះ ឡើងជាអ្នកមានទ្រព្យសម្បត្តិហូរហៀរដោយភាពជាម្ចាស់ដី។ ដូចដែលលោក ដែលវើរ បានសរសេរថា “អ្នកមាននៅកម្ពុជាគឺជាពាណិជ្ជករ មិនមែនម្ចាស់ដីធ្លីនោះទេ” (Delvert, 498) ។ ជាផលវិបាក ដោយលើកលែងសម្រាប់ពួកអភិជនមួយក្តាប់តូច មានតែពួកចិនប៉ុណ្ណោះ ដែលមានដើមទុនដើម្បីចូលប្រឡូកក្នុងអាជីវកម្មជំនួញ ហើយចំពោះពួកអភិជនបានសប្បាយចិត្តតែបង្កើនចំណូលទ្រព្យសម្បត្តិតាមរយៈពួកឈ្មួញចិន ជាជាងដើរតួនាទីជំនួសពួកគេ។

ហេតុផលទីពីរ សម្រាប់កង្វះវណ្ណៈខ្មែរថ្នាក់កណ្តាលកប់នៅក្នុងសារជាតិនៃអ្នកគ្រប់គ្រងអាណានិគមអំឡុងពេលបារាំងដាក់អាណាព្យាបាលលើកម្ពុជា។ ដោយសាររដ្ឋការបារាំងនិយមប្រើបុគ្គលិកយួនជាជាងខ្មែរកម្ពុជាមិនអាចអភិវឌ្ឍន៍វណ្ណៈនៃអ្នកបម្រើរាជការជាជនជាតិដើមបានទេ, អ្នកមានកម្រិតវប្បធម៌ខ្ពស់គ្រាន់បើជាងកសិករទេ និងដោយផ្នែកពួកគេត្រូវបានអប់រំការឱ្យតម្លៃចំពោះបស្ចិមប្រទេសរួចជាស្រេច យ៉ាងណាក៏ដោយពួកគេត្រូវបដិសេធដោយរបបអាណានិគម។ ខុសពីឥណ្ឌូនេស៊ី និងវៀតណាម នៅកម្ពុជាគ្មានគ្រោះថ្នាក់អ្វីទាំងអស់ នៅពេលមានការតស៊ូ ដើម្បីឯករាជ្យពីអ្នកដឹកនាំអាណានិគម គឺពួកវណ្ណៈថ្នាក់កណ្តាលដែលមិនសប្បាយចិត្តទាំងអស់នេះឯងដែលបាននាំមុខគេ (Wertheim 1962, 5-8; Lancaster, 66) ដណ្តើមយកឯករាជ្យរបស់ខ្លួន តាមរយៈរាជបូជនីយកិច្ចផ្ទាល់ខ្លួន ដែលដឹកនាំដោយព្រះបាទ នរោត្តម សីហនុ។ ដូច្នោះហើយ ខ្មែរអ្នកជាតិនិយមរួមមានអ្នកគ្មានសញ្ចេតនាប្រឆាំងជនជាតិចិន មានសម្តែង និងបញ្ជាក់យ៉ាងច្បាស់នៅក្នុងសេចក្តីថ្លែងការអ្នកជាតិនិយមនៅក្នុងប្រទេសជាច្រើននៅអាស៊ីអាគ្នេយ៍ឡើយ។[99]

បន្ទាប់មក ដោយសារប្រវត្តសាស្ត្រដាក់លាក់របស់ខ្លួន កម្ពុជាបានបង្កើតនូវសង្គមមួយដែលគ្មានវណ្ណៈខ្មែរមួយប្រកួតប្រជែងនឹងវណ្ណៈពាណិជ្ជកម្មចិន។ ខ្ញុំបានពិភាក្សាតាមក្រោយលោក វើធីម ថា ទំនាក់ទំនងយ៉ាងជិតស្និទ្ធជាសាច់ញាតិ ដែលបានទទួលរវាងពួកខ្មែរ និងចិន មានការពាក់ព័ន្ធនឹងកង្វះនៃការប្រកួតប្រជែងគ្នានោះឯង។ សារៈសំខាន់ចម្បងនៃកង្វះជម្លោះរវាងខ្មែរ និងក្រុមជាតិពន្ធចិនជាច្រើនក្រាបនៅក្នុងពន្លកនៃវរជនចិនកាត់ខ្មែរ។[100]

---

[99] ខ្មែរឥស្សរៈ ឬ 'រណសិរ្សខ្មែរសេរី" ដែលបានធ្វើការប្រយុទ្ធជាសង្គ្រាមឧទ្ទាមទ័ពព្រៃប្រឆាំងនឹងបារាំងតាំងពីឆ្នាំ១៩៤៥ គេត្រូវសម្រួលឱ្យនៅក្រោមក្រសែភ្នែករបស់ខ្មែរ ដោយទំនាក់ទំនងជាមួយចលនាជាតិនិយមវៀតណាម។ ពិតណាស់ វាច្បាស់ជាត្រឹមត្រូវថា រាជបូជនីយកិច្ចរបស់ព្រះមហាក្សត្រមិនអាចដំណើរការទៅមុខដោយជោគជ័យទេ បើបារាំងមិនបានប្តេជ្ញាចិត្តខ្ពស់ប្រើប្រាស់យោធា ដើម្បីប្រឆាំងនឹងពួកវៀតមិញ ក្នុងន័យការពារតំបន់មានសារៈសំខាន់ខាងសេដ្ឋកិច្ចនៃដីសណ្តទន្លេក្រហម និងមេគង្គ។ ពួកគេមិនអាចប្រឹងប្រែងធ្វើសកម្មភាពពីក្រោយខ្នងប្រឆាំងខ្មែរឥស្សរៈនៅក្នុងតំបន់តែមួយបានទេ គឺកម្ពុជា។ សម្រាប់គំនិតពួកគេ គឺវាមានតែនៅតំបន់ឆ្ងាយពីទីក្រុងប៉ុណ្ណោះ។ យ៉ាងណាក៏ដោយ ចលនានីមួយៗរំកិលទៅមុខដោយសារបារាំងបែរឆ្ពោះទៅរកការប្រគល់ឱ្យនូវឯករាជ្យ ដែលត្រូវបង្ខិតបង្ខំដោយសកម្មភាពជាក់លាក់មួយចំនួនរបស់ស្តេច និងវរជនទាំងអស់ដែលកំពុងធ្វើការជាមួយព្រះអង្គ។ កម្ពុជាដណ្តើមបានឯករាជ្យរបស់ខ្លួន ចំនួន៨ខែមុនសន្និសីទហ្សឺណែវ ដែលត្រូវបើកឡើងបន្ទាប់ពីការបរាជ័យរបស់បារាំងនៅឌៀនបៀនហ្វូ និងដែលបានពុះចែកប្រទេសវៀតណាម។ សម្រាប់រឿងរ៉ាវផ្លូវការនៃការតស៊ូដើម្បីឯករាជ្យជាតិរបស់កម្ពុជា, សូមមើល ញ៉ឹក ជូឡុង, Livre Jaune សម សារី, ១_១២០។ បទសង្ខេបដ៏សំខាន់មួយស្តីពី «រាជបូជនីយកិច្ចដើម្បីឯករាជ្យ»មានផ្តល់ឱ្យនៅ ក្នុងជំពូក ទី៣ របស់អាមស្ត្រុង ទំព័រ ៥៣_៧៥ ។

[100] William E. Willmott. 1968. *The Chinese in Cambodia*, pp. 44-102.

### 2.3. សេដ្ឋកិច្ច

បង្កើតច្បាប់ទារពន្ធដារ ជំនួសមន្ត្រីអាជ្ញាហ្លួង តែការនេះបារាំងបានអនុវត្តន៍ជ្រុលជ្រួសធ្ងន់ធ្ងរ ក្លាយជាការគាបសង្កត់ បង្ខិតបង្ខំ នាំឱ្យកសិករខ្មែរមានកំហឹង និងប្រឆាំងតបតវិញ ដូចមានបាតុកម្មកសិករនៅឆ្នាំ១៩១៥ និង ១៩១៦ ជាឧទាហរណ៍។

របរពាណិជ្ជកម្មបារាំងប្រគល់អាទិភាពឱ្យចិនក្តោបក្តាប់ ធ្វើឱ្យពួកចិនក្លាយជាអ្នកមានធនធានច្រើន និងមានឥទ្ធិពលសង្កត់សង្កិនទីផ្សារផលិតផលរបស់ខ្មែរស្រេចទំនើងចិត្ត។ កសិករក្រីក្រមានកាន់តែច្រើនឡើងដោយសារខ្ចីបុលប្រាក់ពីចិន ដោយសន្យាកាត់សងវិញជាផលិតផល និងគ្មានផលិតផលគ្រប់គ្រាន់សម្រាប់សង ឬលក់ឱ្យចិន។ ម្ល៉ោះហើយ ជាបន្តបន្ទាប់ គេក្លាយជាកសិករគ្មានដីធ្លី សម្រាប់ធ្វើកសិកម្ម ដោយសារការកាត់សងបំណុល និងលក់យកលុយបំពេញតម្រូវការចាំបាច់ក្នុងកាលៈទេសៈអាសន្នអន់ក្រផ្សេងៗ។ ជនជាតិចិន ក្លាយជាក្រុមមនុស្សមានឥទ្ធិពលលើខ្មែរដែលជាម្ចាស់ស្រុក បន្ទាប់ពីបារាំង និងរួចផុតពីការគ្រប់គ្រងរបស់ខ្មែរ។

មកដល់ឆ្នាំ១៩៥០ ខ្មែរអ្នកចេះដឹង១ក្រុមបានបង្កើតភាសិតថា ״ប្របាច់កចិនលៀនអណ្តាតខ្មែរ״។ ព្រោះចិនតែងរួចខ្លួនពីការបំពេញកាតព្វកិច្ចជាពលរដ្ឋខ្មែរ ដោយសារនយោបាយគ្រប់គ្រងរបស់បារាំង ជាពិសេស ទាក់ទងនឹងកំណែនបំពេញការងារពលកម្មសាធារណៈ និងពន្ធអាករ។ ក្នុងពេលដែលបារាំងតម្លើងថ្លៃពន្ធអាជីកម្មលើពួកគេម្តងៗ និងនៅរដូវបុណ្យទានជាប្រពៃណីម្តងៗ ចិនដែលសុទ្ធសឹងជាអ្នកលក់ទំនិញសព្វសារពើ បានតម្លើងថ្លៃទំនិញយកចំណេញស្រេចតែអំពើចិត្ត ដែលនាំឱ្យកសិករ និងកម្មករខ្មែររងការចម្រាញ់ និងកេងប្រវ័ញ្ចកាន់តែធ្ងន់ឡើងៗ។

ចំណែកខាងសាធារណៈសុខាភិបាល មានសកម្មភាពបន្តិចបន្តួច ឬស្ទើរតែគ្មាន នៅទីក្រុងភ្នំពេញ លើកលែងមន្ទីរពេទ្យចិនរបស់សមាគមចិន សម្រាប់ទទួលអ្នកជំងឺជាជាតិចិន ដែលបើកទ្វារឡើងតាំងពីឆ្នាំ១៩១៦។ នៅអំឡុងចុងសម័យអាណានិគម ដោយសារអត្ថិភាពអំពើពុករលួយខាងតុលាការនៅតែបន្ត នាំឱ្យភ្នាក់ងាររាជការមានការប្រណែនគ្នា ចំពោះតួនាទីដែលអាចរកលុយបានដោយងាយ និងដោយលំបាកតាមរយៈអំពើពុករលួយ។ ក្នុងចំណោមនោះគេសង្កេតឃើញ សម្តីផ្ទឹមផ្ទង់គ្នាក្នុងសង្គមបានកើតឡើង រវាងពួកគ្រូពេទ្យ និងចាងហ្វាងសាលាដំបូង( តុលាការខេត្ត )ថា៖״ចំណីណាឆ្ងាញ់យកទៅឱ្យសាលាដំបូង ដំបៅណាខ្ទុងៗយកមកឱ្យគ្រូពេទ្យ״ បានន័យថា តុលាការអាចប្រព្រឹត្តិអំពើពុករលួយ កេងប្រវ័ញ្ចបានលុយដោយស្រួល ពីភាគីអធិករណ៍ណាដែលនាំក្តីទៅប្តឹងពួកគាត់ ប៉ុន្តែគ្រូពេទ្យវិញ បើទុកជាចង់ប្រព្រឹត្តិអំពើពុករលួយ ក៏ការងារពួកគាត់ត្រូវតែប្រឈមមុខនិងការលំបាកជាងពួកតុលាការដែរ។ ព្រោះគាត់ជួបប្រទះតែអ្នកឈឺថ្កាត់ ដោយជំងឺសព្វបែបយ៉ាង មនុស្សរងរបួស និងមានដំបៅដែលឃើញគួរឱ្យព្រឺព្រួចខ្ពើមរអើម និងមានវិការភាពប្រកបដោយភាពសង្វេគ ជាពិសេស គឺសុទ្ធសឹងជាអ្នកមានទុក្ខ។ ជារួមគុណសម្បត្តិរបស់ភ្នាក់ងារពីរជំពូកនេះ គឺសុទ្ធសឹងបំពេញការងារសង្គហកិច្ចដូចគ្នា ដែលមួយត្រូវរកភាពយុត្តិធម៌ឱ្យប្រជាជន និងមួយទៀតត្រូវសង្គ្រោះជីវិតមនុស្ស ដោយផ្ទាល់តែម្តង។

ខឿនសេដ្ឋកិច្ចបែបទំនើបកម្មដំណើរការទៅមិនបានល្អ បានបន្តជះឥទ្ធិពលអាក្រក់រហូតដល់សព្វថ្ងៃ។ ប៉ុន្តែចំណុចជាច្រើននេះ បារាំងបានទម្លាក់កំហុសលើព្រះរាជាខ្មែរ តាំងពីរជ្ជកាលនរោត្តម ដែលជានិច្ចកាល តែងតែរាំងដល់ដំណើរការកំណែទម្រង់ស្ថាប័នគ្រប់គ្រង និងនវូបនីយកម្មសេដ្ឋកិច្ចនៅកម្ពុជា។

ជាវិបាកធំខាងសេដ្ឋកិច្ច បន្តិចម្តងៗបញ្ហាសេដ្ឋកិច្ច ធ្វើឱ្យសង្គមខ្មែរមានការបែងចែកគម្លាតគ្នាកាន់តែឆ្ងាយរវាងស្រទាប់ប្រជាពលរដ្ឋ ជា״អ្នកមាន និងអ្នកក្រ״ដែលមានចំនួនកាន់តែកើនឡើងជាលំដាប់នៅតាមជនបទ ជាពិសេស។ ត្រង់ចំណុចនេះហើយ ដែលធ្វើឱ្យពួកខ្មែរមាននិន្នាការកុម្មុយនិស្តនៅចុងសម័យអាណាព្យាបាលបារាំងបានលេស និងឱកាស ខិតខំពន្យល់អ្នកស្រុកអំពីមូលហេតុ និងឫសគល់នៃបញ្ហានេះ ហើយចុងក្រោយធ្វើឱ្យកើតជា״បដិវត្តន៍វណ្ណៈអធន״ឡើងនៅកម្ពុជា។

### 2.4. វប្បធម៌

អភិក្រមទំនើបកម្មដែលបារាំងនាំមកឱ្យខ្មែរមាន ៖ ការលុបបំបាត់អំពើពុករលួយជាប្រពៃណីក្នុងជួរមន្ត្រីរាជការខ្មែរ ដោយការលុបបំបាត់របៀបទារពន្ធដារបែបបុរាណ ដែលអនុវត្តន៍ដោយក្រុមអាជ្ញាហ្លួងរបស់ព្រះរាជា ម្តងក្នុងមួយឆ្នាំ នៅរដូវបន្ទាប់ពីកសិករប្រមូលកសិផលរួច។ មន្ត្រីរាជការត្រូវតែងតាំងឱ្យកាន់មុខតំណែងតាមសមត្ថភាពចំណេះដឹង និងបទពិសោធន៍ការងារ។ គ្មានការស៊ីសំណូកសម្រាប់ឡើងបុណ្យស័ក្តិ ក្នុងជួរក្រមការ និងអភិបាលស្រុកខេត្ត។ មានការកែទម្រង់ក្នុងការជ្រើសរើស និងតែងតាំងមេឃុំ ដោយមានការបោះឆ្នោត។ របៀបរបបនៃការធ្វើការងាររដ្ឋបាល ដែលមានបទដ្ឋានពេលធ្វើការ,ច្បាប់ការងារ និងឋានានុក្រមការងារបែបបស្ចិមប្រទេសជាដើម។

ដោយសារបារាំងបង្ហាញឱ្យឃើញពីការស្រឡាញ់ជាតិបារាំងរបស់ពួកគេ និងមានបារាំងខ្លះមានសណ្តានចិត្តស្រឡាញ់ខ្មែរពិតប្រាកដ បានលួចពន្យល់យុវបញ្ញវន្តខ្មែរ ធ្វើឱ្យខ្មែរចេះដឹងមួយចំនួននោះ បើកគំនិត ដុះធន្ទះជាតិនិយមឡើង ជាពិសេស បញ្ញវន្តប្រពៃណីខ្មែរនៅពុទ្ធសាសនបណ្ឌិត្យ។ បន្តិចម្តងៗ គេបានបង្កើតទម្រង់ចលនាជាតិនិយមខ្មែរ ដោយការដាស់តឿន គ្រើនរំឭកប្រជាជាតិខ្មែរ ឱ្យចេះរៀនគិត និងធ្វើអ្វីៗដោយខ្លួនឯង ដើម្បីសមត្ថភាពម្ចាស់ការដោយខ្លួនឯង ទៅអនាគត។ គេចាប់ផ្តើមបង្កើតអត្តសញ្ញាណខ្មែរទំនើបឡើង តាមបែបផែនថ្មីពីឥទ្ធិពលបរទេស ដូចជា បញ្ហាជីវភាពរស់នៅប្រចាំថ្ងៃ, សិល្បៈ, ចម្រៀង, តន្ត្រី, និងគំនូរ។

ចំណែកវប្បធម៌ដែលបារាំងបញ្ចូលមកសាបព្រោះនៅកម្ពុជា មិនសូវមានលក្ខណៈស៊ីសង្វាក់គ្នាជាមួយវប្បធម៌របស់អ្នកស្រុកដើម–ខ្មែរ, វាមានលក្ខណៈទំនាស់គ្នាច្រើន ដូចជា ទម្លាប់រស់នៅ, ស្លៀកពាក់, វេជ្ជសាស្ត្រ, ភាសា, និងការសាកល្បងធ្វើកំណែទម្រង់អក្សរខ្មែរ ដោយប្រើអក្សរឡាតាំងនៅពីឆ្នាំ១៩៤១។

របៀបរបបរស់នៅរបស់ខ្មែរមានការជឿនលឿនជាងមុន បើទោះបីជាមិនអាចយល់បាន និងធ្វើតាមបានទាំងស្រុងនូវកម្រិតជីវភាពរបស់បារាំង។

ការនាំមកនូវក្បួនច្បាប់បែបបស្ចិមប្រទេស ដែលភាគច្រើនមិនស៊ីគ្នានឹងប្រពៃណីក្នុងស្រុក ត្រង់នេះធ្វើឱ្យខ្មែរ ដែលមានទម្លាប់ចូលចិត្តប្រើមនោសញ្ចេតនា ធំជាងការអនុវត្តន៍ច្បាប់ បង្កើតពាក្យស្លោកថា "យល់ញាតិ ឃ្លាតច្បាប់" ដើម្បីគ្រើនរំឭកអ្នកកាន់ច្បាប់ និងអនុវត្តន៍វិធានការច្បាប់។

ការផ្ទេរសមត្ថកិច្ច ឬកេតនភ័ណ្ឌឯករាជ្យសម្រាប់កម្ពុជា ធ្វើឡើងគ្មានលក្ខណៈរលូន និងស្ថេរភាពល្អ។ បារាំងមិនបានរៀបចំដំណើរការនវូបនីយកម្មស្ថាប័នរដ្ឋបាល និងសេដ្ឋកិច្ច ព្រមទាំងបង្រៀនខ្មែរឱ្យយល់ពីសារៈសំខាន់នៃបទប្បញ្ញត្តិដ៏សំខាន់មួយ ដែលគេហៅថា "រដ្ឋប្រជាជាតិសម័យទំនើប" (Modern Nation-State)។ ហេតុដូច្នេះហើយនាំឱ្យអ្នកដឹកនាំខ្មែរ មិនសូវបានយល់ច្បាស់អំពីតម្លៃ និងសារៈសំខាន់របស់វា នៅក្នុងការដឹកនាំរដ្ឋនាសម័យទំនើបនេះ រហូតដល់សព្វថ្ងៃ។

### សេចក្តីសន្និដ្ឋាន

ទោះជាបារាំងបានយកចិត្តទុកដាក់តែលើផលប្រយោជន៍សេដ្ឋកិច្ច និងវប្បធម៌របស់ខ្លួន ចាត់ទុកកម្ពុជាដូចមេគោចិញ្ចឹមយកតែទឹកដោះ ហើយយកលុយជាច្រើនទៅបំពេញតែសេចក្តីត្រូវការរបស់ខ្លួននៅឋាណ្ឌយ និងដែនដីរដ្ឋបាលយួនពីរទៀតដែលជាកូនសំលាញ់ ឬសំណព្វជាងគេយ៉ាងណាក្តី ក៏យើងទទួលស្គាល់ថា ក្នុងចំណោមគុណវិបត្តិដ៏ច្រើនរបស់បារាំងដែលយើងមើលឃើញ បារាំងមានគុណសម្បត្តិដ៏ធំមួយ គឺបានទាមទារពីសៀមមកវិញបាននូវទឹកដីខេត្តបាត់ដំបង សៀមរាប ម្លូព្រៃ កំពង់ធំភាគខាងជើង និងស្ទឹងត្រែង ដែលប្រទេសសៀមបានរឹបអូសយកតាំងពីយូរមកហើយ។ គុណសម្បត្តិដ៏ធំមួយទៀត ដែលយើងមិនអាចកែក្រឡែបាន គឺបានថែរក្សាស្រុកខ្មែរនៅគង់វង្ស ចាកផុតពីការហែកចែកគ្នារបស់សៀម និងយួននៅសតវត្សរ៍ទី១៩។

បារាំងបានខិតខំស្រាវជ្រាវសរសេរប្រវត្តិសាស្ត្រពិតប្រាកដមួយឱ្យខ្មែរ និងបានខិតខំចាប់ផ្តើមសង្គ្រោះ ជួសជុល ថែរក្សា ការពារ អភិរក្សប្រាង្គប្រាសាទដ៏ច្រើនអនេកជាបេតិកភ័ណ្ឌមិនអាចកាត់ថ្លៃបានរបស់ខ្មែរ ទុកឱ្យខ្មែរសព្វថ្ងៃ បានធ្វើអាជីវកម្មទាញយកប្រយោជន៍យ៉ាងគគ្រឹកគគ្រេង។ បារាំងជាអ្នកបើកបង្ហាញភាពល្បីល្បាញ និងគំនិតដ៏អស្ចារ្យរបស់ខ្មែរពីអតីតកាលឱ្យពិភពលោកបានដឹង និងកោតសរសើរ។

ហើយទោះបី នៅមានការសន្យាជាច្រើនចំណុចរបស់បារាំង ដែលបារាំងមិនបានធ្វើសម្រាប់កម្ពុជា ក៏នៅមានចំណុចគុណសម្បត្តិមួយទៀតដែលយើងមិនអាចបំបាត់ចោលបានដែរនោះ គឺបារាំងពិតជាបាននាំទំនើបភាវូបនីយកម្មទាំងសម្ភារៈនិយម និងមនោគមវិជ្ជាដឹកនាំប្រទេសមកឱ្យកម្ពុជា ដែលខ្មែរខ្លួនឯងភាគច្រើននៅតែមិនព្រមយល់អំពីគំនិតទាំងអស់នោះ រហូតមកដល់សព្វថ្ងៃ៕

# មេរៀនទី 11 បញ្ហានយោបាយ និងសេដ្ឋកិច្ចសម័យសង្គមរាស្ត្រនិយម

## 1. ការតស៊ូដើម្បីឯករាជ្យ

បារាំងបានធ្វើអាណាព្យាបាលលើប្រទេសកម្ពុជា អស់រយៈពេល៩០ឆ្នាំ (១៨៦៣-១៩៥៣) នៅពេលដែលបារាំងត្រួតត្រាកម្ពុជា បារាំងធ្វើទុក្ខបុកម្នេញខ្មែរយ៉ាងខ្លាំង ហេតុធ្វើឱ្យមានការតស៊ូប្រឆាំងនឹងបារាំងយ៉ាងខ្លាំងក្លា ដូចមានចលនាជាតិនិយមយ៉ាងច្រើន បានរីករាលដាលក្នុងប្រទេសកម្ពុជាដើម្បីប្រឆាំងនឹងបារាំងទាមទារនូវឯករាជ្យ។ ការទាមទារនូវឯករាជ្យ យើងឃើញមានជាច្រើនតំណាក់កាល។ ប៉ុន្តែ ឯករាជ្យ ដែលខ្មែរមាននៅពេលនោះ ពុំមែនជាឯករាជ្យពិតប្រាកដទេ។

ក្រុមដែលតស៊ូដើម្បីឯករាជ្យមានច្រើន ដូចជា សមាជិកសភាគណបក្សប្រជាធិបតេយ្យ ពួកខ្មែរឥស្សរៈសេរីនៅបាត់ដំបង ដែលក្រោយមកបែកសំបុក និងបំបែកជាច្រើនក្រុម, ពួកគណៈជាតិមុត្តគាហារដែលគេហៅថា ក្រុមឥស្សរខ្មែរវៀតមិញ និងក្រុមឥស្សរៈបែកខ្ញែកដទៃទៀត។ ប៉ុន្តែ អ្នកដែលដណ្តើមបានឯករាជ្យពិតប្រាកដ ដោយសន្តិវិធី ជូនកម្ពុជាបានមុនគេ គឺព្រះបាទ នរោត្តម សីហនុ ដែលធ្វើរាជបូជនីយកិច្ចទាមទារឯករាជ្យក្រោយគេនៅឆ្នាំ១៩៥២ តែបានជោគជ័យជាស្ថាពរ នៅថ្ងៃទី៩វិច្ឆិកា១៩៥៣។ ដូច្នេះហើយ ទើបក្រុមខ្មែរឥស្សរក្រៅពីនេះ ទាំងពួកឥស្សរចោរព្រៃ និងអ្នកតស៊ូពិតប្រាកដ បានចុះចូលរួបរួមជារាជរដ្ឋាភិបាល និងសង្គមជាតិទាំងអស់។ លើកលែងតែក្រុមខ្មែរឥស្សរ-វៀតមិញ និងកងទ័ពវៀតមិញរបស់វៀតណាមខាងជើង ដែលនៅតែធ្វើសកម្មភាពយោធារំខានអាជ្ញាធរកម្ពុជានៅឡើយជាពិសេស នៅតាមជនបទនៃប្រទេសកម្ពុជា។

## 2. សន្និសីទហ្សឺណែវ ឆ្នាំ១៩៥៤

សន្និសីទអន្តរជាតិក្រុងហ្សឺណែវ បានចាប់ផ្តើមបើកនៅថ្ងៃទី២៦ ខែមេសា ១៩៥៤ ដើម្បីពិភាក្សាអំពីបញ្ហាកូរ៉េខាងជើង និងខាងត្បូង ចំណែកការពិភាក្សាស្តីអំពីបញ្ហាបញ្ចប់សង្គ្រាមនៅឥណ្ឌូចិន ធ្វើឡើងចាប់ពីថ្ងៃទី៧ឧសភា១៩៥៤ ដោយមានការចូលរួមពីរដ្ឋមន្ត្រីការបរទេសនៃមហាប្រទេស ដែលអ្នកចូលរួមផ្ទាល់ និងចូលរួមក្នុងឋានៈជាអ្នកសង្កេតការណ៍ ដែលសរុបមកពីប្រទេសចំនួន១៩ប្រទេស ដូចជា ៖

ចក្រភពអង់គ្លេស សហភាពសូវៀត សហរដ្ឋអាមេរិក បារាំង សាធារណរដ្ឋប្រជាមានិតចិន និងប្រទេសពាក់ព័ន្ធមួយចំនួនទៀត។ នៅក្នុងឱកាសពិភាក្សាឥណ្ឌូចិនបានចូលរួមដោយរដ្ឋមន្ត្រីការបរទេសអង់គ្លេស បារាំង សហភាពសូវៀត សហរដ្ឋអាមេរិច ចិនប្រជាមានិត សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម រាជាណាចក្រឡាវ រាជាណាចក្រកម្ពុជា និងអំណាចបាវដាយវៀតណាម។ គណៈប្រតិភូនៃរដ្ឋាភិបាលកម្ពុជាដឹកនាំដោយរដ្ឋមន្ត្រីការបទេសទេពផន, នង គឹមនី, សម សារី, សឺន សាន, ញឹក ជូឡុងជារដ្ឋមន្ត្រីក្រសួងការពារជាតិ, ប៉ុក ធឿនស្រីសាម៉ន និងស៊ុត សាខន ដែលទាំងពីនាក់ចុងក្រោយ ជាវរសេនីយត្រី ។ ក្រៅពីសមាជិកប្រតិភូនេះ នៅមានអ្នកតំណាងខ្មែរឥស្សរៈសំខាន់ៗបួននាក់ទៀត គឺដាប ឈួន, ចន្ទរង្សី,ពុត ឆាយ និងសាវ៉ាងវង្ស ដែលត្រូវនាំទៅបង្ហាញអន្តរជាតិ ក្នុងឋានៈជាអ្នកតស៊ូប្រដាប់អាវុធ ដើម្បីឯករាជ្យជាតិពីបារាំង និងដែលបានចុះចូលរួបរួមជាមួយរាជរដ្ឋាភិបាលស្របច្បាប់រួចហើយ។ ចំណែក ប្រតិភូវៀតមិញ ឬវៀតណាមខាងជើង បាននាំអ្នកតំណាងចលនាតស៊ូ

រំដោះជាតិខ្មែរឥស្សរៈវៀតមិញ ទៅហ្សឺណែវដែរ ដើម្បីឱ្យសហភាពសូវៀត និងសាធារណរដ្ឋប្រជាមានិតចិន និងសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ជួយទាមទារឱ្យមានចំណែកនៅក្នុងការប្រជុំនោះដែរ។ តែទោះបីជាមានជួយជ្រោមជ្រែងពីសូវៀត និងយួនខាងជើងយ៉ាងណាក៏ដោយ ក៏តំណាងចលនាតស៊ូនោះពុំបានទទួលការអនុញ្ញាតឱ្យចូលរួមក្នុងសន្និសីទដែរ។

ក្រោយពីដំណើរការចរចាយ៉ាងស្វិតស្វាញអស់ប្រមាណ៧៥ថ្ងៃ គេបានចុះហត្ថលេខាលើឯកសារមួយចំនួនដែលក្នុងនោះទាក់ទងជាមួយកម្ពុជាដូចតទៅ ៖

- កិច្ចព្រមព្រៀង ស្ដីពីការបញ្ឈប់បទបាញ់គ្នានៅក្នុងប្រទេសកម្ពុជា
- សេចក្ដីប្រកាសរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងសម្ព័ន្ធភាពយោធា ទាក់ទងទៅនឹងមូលដ្ឋានទ័ពបរទេស និងការជួយឧបត្ថម្ភកម្លាំងយោធាពីបរទេស
- សេចក្ដីប្រកាសពីរបស់រដ្ឋាភិបាលបារាំង ស្ដីអំពីការដកកងទ័ពបារាំងចេញពីទឹកដីឥណ្ឌូចិន និងការប្រកាសផ្ដល់ឯករាជ្យ អធិបតេយ្យភាពដល់ប្រទេសនៅក្នុងឥណ្ឌូចិន
- សេចក្ដីថ្លែងការណ៍របស់តំណាងសហរដ្ឋអាមេរិក ស្ដីអំពីឥរិយាបថរបស់ខ្លួនទាក់ទងនឹងកិច្ចព្រមព្រៀងហ្សឺណែវ
- សេចក្ដីថ្លែងការបិទសន្និសីទ

នៅលើកិច្ចព្រមព្រៀងទាក់ទងទៅនឹងការបញ្ឈប់សកម្មភាពយោធានៅក្នុងប្រទេសកម្ពុជា បានចុះហត្ថលេខាដោយថ្នាក់អនុរដ្ឋមន្ត្រីការពារជាតិសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ដែលតំណាងឱ្យអគ្គមេបញ្ជាការកងទ័ពជាតិវៀតណាម និងកងទ័ពខ្មែរឥស្សរៈ និងរដ្ឋមន្ត្រីការពារជាតិរដ្ឋាភិបាលកម្ពុជា លោកញឹក ជូឡុង ក្នុងនាមតំណាងឱ្យអគ្គមេបញ្ជាការជាន់ខ្ពស់កងទ័ពជាតិខ្មែរ (កងទ័ពខេមរភូមិន្ទ) ។ ដោយអាស្រ័យទៅនឹងកិច្ចព្រមព្រៀងនេះ សកម្មភាពការប៉ះទង្គិចគ្នា ដោយយោធាត្រូវបញ្ឈប់នៅលើទឹកដីកម្ពុជាទាំងស្រុងចាប់ពីថ្ងៃទី៧ ខែ សីហា ឆ្នាំ១៩៥៤ ។ កិច្ចព្រមព្រៀងបាននិយាយអំពីការដកកងទ័ពបរទេសចេញពីទឹកដីកម្ពុជាឱ្យអស់នៅក្នុងកំឡុង៩០ថ្ងៃ បន្ទាប់ពីចាប់ផ្ដើមសុពលភាពកិច្ចព្រមព្រៀងហ្សឺណែវ។

ចំពោះកម្លាំងទ័ពខ្មែរឥស្សរៈត្រូវរំសាយក្នុងកំឡុង៣០ថ្ងៃ។ ទន្ទឹមនឹងនេះដែរ រាជរដ្ឋាភិបាលកម្ពុជាបានធ្វើសេចក្ដីប្រកាស ស្ដីពីការធានាដល់អតីតអ្នកចូលរួមចលនាតស៊ូ ធានាដល់សិទ្ធិពលរដ្ឋ ការពារជីវិតនិងទ្រព្យសម្បត្តិ និងធានាដល់សិទ្ធិនៃការអនុវត្តសេរីភាពប្រជាធិបតេយ្យ ។ រាជរដ្ឋាភិបាលបានធ្វើការអះអាងចំពោះសេចក្ដីសម្រេចចិត្តរបស់ខ្លួនថា ប្រជាពលរដ្ឋកម្ពុជាទាំងអស់រួមរស់នៅក្នុងសហគមន៍តែមួយដោយគ្មានការប្រកាន់ពូជសាសន៍ និងធានាដល់ប្រជាពលរដ្ឋកម្ពុជាទាំងអស់ក្នុងការប្រើសិទ្ធិ និងសេរីភាពរបស់ខ្លួន ដូចមានចែងក្នុងការប្រើសិទ្ធិ និងសេរីភាពរបស់ខ្លួនដែលមានចែងក្នុងច្បាប់រដ្ឋធម្មនុញ្ញ ។ ដោយយោងទៅតាមមាត៌ាអភិវឌ្ឍន៍សន្តិភាវូបនីយកម្មនៅក្នុងប្រទេសកម្ពុជា ដែលមានចែងក្នុងសេចក្ដីសម្រេចចិត្តសន្និសីទនាទីក្រុងហ្សឺណែវនៅក្នុងប្រទេសកម្ពុជាបានប្រព្រឹត្តិទៅនូវការបោះឆ្នោតជាសកលនាឆ្នាំ១៩៥៥។

នៅក្នុងសេចក្ដីប្រកាសបិទសន្និសីទទីក្រុងហ្សឺ ែណាវ សមាជិកទាំងអស់បានប្រកាសស្ដីអំពីកាតព្វកិច្ចរបស់ខ្លួន គោរពដល់អធិបតេយ្យភាព ឯករាជ្យភាព ឯករាជ្យជាតិ និងអធិបេតយ្យភាពរបស់ប្រទេសនៅក្នុងឥណ្ឌូចិន។

សន្និសីទទីក្រុងហ្សឺណែវ បានកំណត់នូវដំណើរវីកចំរើននយោបាយជាប្រវត្តិសាស្ត្រថ្មីរបស់ប្រទេសកម្ពុជា ដោយការពង្រឹងគោលជំហររបស់ខ្លួននៅលើឆាកអន្តរជាតិ អធិបតេយ្យភាព និងកិត្យានុភាពស្នេហាជាតិមាតុភូមិរបស់ខ្លួន។ នៅក្នុងសេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលសហភាពសូវៀត ដែលធ្វើឡើងនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៥៤ បានគូសបញ្ជាក់ថា "កិច្ចព្រមព្រៀងហ្សឺណែវបានឱ្យអត្ថន័យទៅលើការតស៊ូរំដោះជាតិ និងវីរភាពដ៏អស្ចារ្យរបស់ប្រជាជនឥណ្ឌូចិន ដែលបានធ្វើពលិកម្មនៅក្នុងការតស៊ូនេះ "។

ទោះបីតំណាងរបស់ចលនាខ្មែរឥស្សរៈ ពុំត្រូវបានអនុញ្ញាតឱ្យចូលរួមនៅក្នុងសន្និសីទយ៉ាងណាក្តីពួកគេក៏បានវាយតំលៃខ្ពស់ចំពោះលទ្ធផលនៃសន្និសីទនេះផងដែរ។

នៅក្នុងខែសីហា គណៈកម្មការបានចាប់ផ្តើមបំពេញការងាររបស់ខ្លួន នៅថ្ងៃ១៨តុលា១៩៥៤ កងទ័ពវៀតណាមបានដកចេញទាំងស្រុងពីទឹកដីកម្ពុជា។ ក្នុងកំឡុងខែ សីហា-កញ្ញា កងទ័ពខ្មែរឥស្សរៈបានរំសាយ។ ថ្ងៃទី១២ ខែតុលា ១៩៥៤ ព្រះមហាក្សត្របានធ្វើសេចក្តីប្រកាសលើកលែងទោស ដល់អ្នកចូលរួមចលនាតស៊ូប្រឆាំងនឹងរាជរដ្ឋាភិបាល។

លោក Vickery ថា រាល់ចម្បាំងទាំងអស់ក្នុងឥណ្ឌូចិនបានបញ្ចប់ក្នុងឆ្នាំ១៩៥៤។ កងទ័ពបារាំងចាញ់វៀតណាម ហើយត្រូវបង្ខំឱ្យប្រគល់ឯករាជ្យរួចហើយនៅកម្ពុជា។ បារាំងបានយល់ព្រមប្រគល់ឯករាជ្យឱ្យប្រទេសទាំងបីនៅឥណ្ឌូចិន ហើយកិច្ចប្រជុំនៅហ្សឺណែវ រៀបចំឡើងក្នុងគោលបំណងនេះ។ ប្រទេសអន្តរជាតិសំខាន់ៗ ដែលបានចូលរួមមាន អង់គ្លេស, បារាំង, សហរដ្ឋអាមេរិក, ចិន និងគណៈប្រតិភូឯករាជ្យមកពីប្រទេសកម្ពុជា និងរដ្ឋាភិបាលកុំម្មុយនីស្តវៀតណាមខាងជើង មានគណៈប្រតិភូមកពី លាវ និងវៀតណាមខាងត្បូងដែលមិនមែនកុំម្មុយនីស្ត។ ក៏ប៉ុន្តែ ពួកគេស្ថិតនៅក្រោមការមើលខុសត្រូវរបស់បារាំងព្រោះគេមិនទាន់បានឯករាជ្យ។

កិច្ចប្រជុំហ្សឺណែវ បានផ្តល់ឯករាជ្យឱ្យឥណ្ឌូចិន បានកំណត់ឱ្យមានការដកកងទ័ពបារាំង និងមានការបោះឆ្នោតក្នុងប្រទេសនីមួយៗក្រោមរដ្ឋធម្មនុញ្ញចាស់។ ការបោះឆ្នោតក្នុងប្រទេសវៀតណាមបានកំណត់ធ្វើឡើងក្នុងឆ្នាំ១៩៥៦ ដើម្បីរួបរួមវៀតណាមក្រោមពួកកុំម្មុនីស្ត ហូជីមិញ ឬក្រោមមេដឹកនាំវៀតណាមខាងត្បូងតាមជម្រើសអ្នកបោះឆ្នោត។ នៅកម្ពុជា ការបោះឆ្នោតបានធ្វើឡើងនៅក្នុងឆ្នាំ១៩៥៥ ក្រោមរដ្ឋ-ធម្មនុញ្ញចាស់ គឺមានចំនួនគណបក្សដដែលដូចមុន ។

ក្នុងប្រទេសលាវ គេប្រគល់ខេត្តពីរនៅភាគខាងជើងឱ្យទៅទ័ពពួកកុម្មុយនិស្តកាន់កាប់ផ្ទាល់ ក៏ប៉ុន្តែពួកកុំម្មុនីស្ត និងពួកឥស្សរៈនៅកម្ពុជា គេពុំបានប្រគល់តំបន់ដោយឡែកណាមួយឱ្យទេ។ ពួកគេត្រូវបញ្ឈប់រាល់ការប្រយុទ្ធ និងរស់នៅជាពលរដ្ឋសាមញ្ញ។ យោងលើកិច្ចព្រមព្រៀងហ្សឺណែវ ពួកនេះមិនត្រូវធ្វើគេធ្វើទុក្ខទោសទេ ហើយអាចកើតគណៈបក្សនយោបាយដើម្បីការបោះឆ្នោតអាណត្តិក្រោយ។

អតីតពួកឥស្សរៈ និងពួកកុំម្មុយនីស្តមិនសប្បាយចិត្តនឹងកិច្ចប្រជុំហ្សឺណែវទេ ព្រោះពួកគេមិនបានទទួលតំបន់ពិសេសណាមួយ។ ក៏ប៉ុន្តែសម្តេចសីហនុ និងអ្នកគាំទ្រពិតជាសប្បាយចិត្ត ព្រោះពួកគេអាចបន្តកាន់អំណាច។ ចំណែក រដ្ឋសភាត្រូវសម្តេចសីហនុរំលាយចោលតាំងពីឆ្នាំ១៩៥២។ តែភាគីកម្ពុជា បានយល់ព្រមនៅហ្សឺណែវថានឹងមានការបោះឆ្នោតសេរី នៅក្នុងឆ្នាំ១៩៥៥។

## 3. នយោបាយក្នុង និងក្រៅប្រទេស

ដូចបានបង្ហាញពីខាងដើមខ្លះ មកហើយថា "ភាពជាអព្យាក្រឹត្យរបស់កម្ពុជា" គឺជាក្ដីប្រាថ្នា និងជាលក្ខខណ្ឌរបស់មហាអំណាចកុម្មុយនិស្តនៅក្នុងសន្និសីទហ្សឺណែវឆ្នាំ១៩៥៤ តម្រូវឱ្យកម្ពុជាទទួលយក។ មិនត្រឹមប៉ុណ្ណោះ ភាគីវៀតណាម ដែលមានផាម វ៉ាន់ដុងជាប្រធាន បានទាមទារកុំឱ្យកម្ពុជា មានគ្រឿងសព្វាវុធ និងមានកងទ័ពប្រកបដោយសមត្ថភាពប្រយុទ្ធខ្ពស់ សម្រាប់ការពារខ្លួនជាអចិន្ត្រៃយ៍ផងដែរ។ បន្ទាប់មក សម្ដេចសីហនុ សព្វព្រះទ័យចូលរួមនៅក្នុងចលនាមិនចូលបក្សសម្ព័ន្ធនេះតាំងពីឆ្នាំ១៩៥៥ នៅក្នុងការប្រជុំនៅទីក្រុងបានឌុងប្រទេសឥណ្ឌូនេស៊ី។ នៅទីនោះហើយ ដែលព្រះអង្គបានជួបប្រាស្រ័យទាក់ទងយ៉ាងជិតស្និទ្ធជាមួយលោកជូ អេនឡាយ នាយករដ្ឋមន្ត្រីចិន និងផាម វ៉ាន់ដុង នាយករដ្ឋមន្ត្រីវៀតណាម និងសព្វព្រះទ័យខ្លាំងចំពោះការផ្ដល់នូវកិត្តិយសដ៏ឧត្តុង្គឧត្តមមួយរបស់មហាអំណាចក្នុងតំបន់ទាំងពីរនេះ ដោយសារតែពិធីការដ៏ទន់ភ្លន់ និងបដិសណ្ឋារកិច្ចដ៏គួរសមគ្មានខ្ចោះរបស់ពួកគេ និងបានក្លាយជាមហាមិត្តរបស់ប្រទេសកុម្មុយនិស្តទាំងនេះបន្តិចម្ដងៗរហូតដល់ដើមទសវត្សរ៍១៩៧០។

ទោះបីមានការចោទប្រកាន់ពីអាមេរិកថា ព្រះអង្គជាព្រះអង្គម្ចាស់ក្រហមក៏ដោយ ក៏ព្រះអង្គចាត់ទុកការដឹកនាំនយោបាយរបស់ព្រះអង្គ ថាត្រឹមតែ"នយោបាយពណ៌ស៊ីជម្ពូ"ដែរ ដែលជារួមគេមើលឃើញថា ជាអព្យាក្រឹត្យស្និទ្ធនឹងកុម្មុយនិស្ត។ ហេតុនោះហើយ ទើបចំណងនយោបាយការបរទេសជាមួយលោកសេរី ជាពិសេស ជាមួយសហរដ្ឋអាមេរិក កាន់តែរង្គោះរង្គើឡើងពីមួយថ្ងៃទៅមួយថ្ងៃ រហូតដល់ប្រកាសឈប់ទទួលជំនួយពីអាមេរិកនៅខែវិច្ឆិកាឆ្នាំ១៩៦៣ និងផ្ដាច់ទំនាក់ទំនងទូតជាមួយគ្នានៅឆ្នាំ១៩៦៤។ បន្ទាប់ពីភាពតានតឹងខាងព្រំដែន ជាមួយថៃ និងវៀតណាមខាងត្បូង ដែលជាមហាសម្ព័ន្ធមិត្តរបស់អាមេរិក។ កត្តានេះ បានជំរុញឱ្យកម្ពុជា កាន់តែខិតទៅកៀកកិតជិតពិភពលោកកុម្មុយនិស្ត ជាពិសេស វៀតណាមខាងជើង និងចិន ដែលប្រកាសថារង់ចាំតែជួយខ្មែរប៉ុណ្ណោះ។

ចំពោះនយោបាយក្នុងប្រទេសវិញ សម្ដេច ស៊ីហនុ បានព្យាយាមបង្កើតចលនាសង្គមរាស្ត្រនិយម ដើម្បីប្រមូលកម្លាំងបាក់បែកនៅក្នុងបណ្ដាបក្សនយោបាយនានា ឱ្យមកចូលរួមជាមួយព្រះអង្គ។ ដោយសារភាពជារាជវង្សរបស់ព្រះអង្គ ជាមួយនឹងព្រះគុណបំណាច់ក្នុងការទាមទារឯករាជ្យជាតិ គណបក្សរបស់ព្រះអង្គបានឈ្នះឆ្នោតដាច់ខាត ដែលអាចបង្កើតរដ្ឋាភិបាលបានដោយខ្លួនឯង។ រាជរដ្ឋាភិបាលសម័យនេះ គេហៅថា រដ្ឋាភិបាលសង្គមរាស្ត្រនិយម ឬ សម័យសង្គមរាស្ត្រនិយម ដែលក្ដាប់ដោគវាសនារបស់ប្រទេសជាតិអស់១៦ឆ្នាំ។

ចន្លោះពីឆ្នាំ១៩៥៥ដល់១៩៦០ ព្រះនរោត្តមសីហនុកាន់តំណែងជានាយករដ្ឋមន្ត្រី តែចាប់ពីឆ្នាំ១៩៦០ បន្ទាប់ពីព្រះបិតានាមនរោត្តម សុរាម្រិត ជាព្រះមហាក្សត្របានសោយទិវង្គត ព្រះអង្គបានឱ្យសភាបង្កើតតំណែង"ព្រះប្រមុខរដ្ឋ"មួយទៀតសម្រាប់ព្រះអង្គ។ ម្ល៉ោះហើយ ចាប់ពីពេលនោះមក ព្រះអង្គកាន់តំណែងជានាយករដ្ឋមន្ត្រីផង និងព្រះប្រមុខរដ្ឋផង តែជួនកាលក៏កាន់តែតំណែងចុងក្រោយនេះតែមួយដែរ។ អ្វីដែលគួរឱ្យកត់សម្គាល់នោះ គឺនោះក្នុងរវាង១៦ឆ្នាំនេះ ព្រះអង្គបានបង្កើតឱ្យមាន ដល់ទៅ ២៥គណៈរដ្ឋមន្ត្រី ឬរដ្ឋាភិបាល។ ដោយរដ្ឋាភិបាលខ្លះមានអាយុត្រឹមតែ១សប្ដាហ៍ លើកលែងតែគណៈរដ្ឋមន្ត្ររបស់ព្រះអង្គទើបអាចមានអាយុវែងជាងគេ។

## 4. រឿងក្ដីប្រាសាទព្រះវិហារ

*ក-ដើមហេតុនៃរឿងក្ដី*

ជម្លោះខ្មែរ-ថៃ លើការទាមទារប្រាសាទព្រះវិហារ ចេញពីការចូលលុកលុយកាន់កាប់ប្រាសាទនេះ ដោយកងទ័ពថៃ នៅឆ្នាំ១៩៥៥ ដែលជាទង្វើដ៏ព្រហើន គគ្រើន និងមើលងាយដល់បូរណភាពទឹកដីរបស់ព្រះរាជាណាចក្រ

កម្ពុជា។ ទំនងជាដោយសារ ថៃយល់ថា កម្ពុជាទើបនឹងទទួលបានឯករាជ្យបរិបូណ៌ នៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ ១៩៥៣ និងមិនទាន់បានចូលជាសមាជិកនៃអង្គការសហប្រជាជាតិនៅឡើយទេ រហូតមកដល់ចុងឆ្នាំ១៩៥៥ទើបបានចូលជាសមាជិក។ បន្ទាប់ពីអស់លទ្ធភាពក្នុងការប្រកាសទាមទារឱ្យថៃដកកងទ័ពចេញតាមផ្លូវសន្តិវិធី ក្រោមការដឹកនាំរបស់សម្ដេច នរោត្តម សីហនុ បានសម្រេចធ្វើការការពារបូរណភាពទឹកដី ដោយប្ដឹងចំពោះប្រទេសថៃ ពីករណីរំលោភកាន់កាប់ នឹងឈ្លានពានលើទឹកដីកម្ពុជាយើង រឿងដីប្រាសាទព្រះវិហារនេះទៅកាន់តុលាការអន្តរជាតិ (International Court of Justice in Hague)នៅទីក្រុងឡាអេ នៃប្រទេសហូឡង់នៅថ្ងៃទី៣០ខែកញ្ញា ឆ្នាំ១៩៥៩ ។

*ខ-សវនាការសំខាន់ៗនៃរឿងក្ដី*

សវនាការសំខាន់នៃការដោះស្រាយរឿងក្ដីសំខាន់ៗនៅទីក្រុងឡាអេ មានដូចតទៅ ៖

សវនាការថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៦១

នៅក្នុងការប្ដឹងតវ៉ាគ្នានេះ គេបានកត់សម្គាល់ថា គូភាគីនីមួយៗបានយកនូវសេចក្ដីសម្រេចរបស់តុលាការមកធ្វើការបកស្រាយ គឺ ៖

**១-ការបកស្រាយរបស់ព្រះរាជាណាចក្រកម្ពុជា**

ប្រទេសកម្ពុជាយើង បានលើកឡើងពីគោលការណ៍ចំបងស្ដីពីការរួមផ្សំគ្នារវាងផលប៉ះពាល់នៃការទទួលយកនូវការបង្គាប់បញ្ជា សេចក្ដីសម្រេចរបស់តុលាការ និងការប្រកាសជាសាធារណៈដែលធ្វើឡើងដោយប្រទេសថៃ នៅថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៥០ ហើយបានចេញសេចក្ដីថ្លែងការដូចតទៅ ៖

"ខ្ញុំ មានកិត្តិយសសូមជម្រាបជាព័ត៌មានថា តាមរយៈសេចក្ដីប្រកាសធ្វើនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ ១៩២៩ ព្រះករុណាជាម្ចាស់ជីវិតលើត្បូង បានទទួលយកនូវការបង្គាប់នៃយុត្តាធិការរបស់តុលាការអន្តរជាតិអចិន្ត្រៃយ៍(Permanent CIJ)ទៅលើលក្ខ័ន្តិកៈសម្រាប់រយះពេល១០ឆ្នាំ និងលក្ខខណ្ឌទៅវិញទៅមកឬបដិការដែលបានអនុលោមទៅតាមមាត្រា៣៦ កថាខ័ណ្ឌទី២។ ការប្រកាសនេះបានត្រូវធ្វើឡើងវិញនៅថ្ងៃទី០៣ ខែឧសភា ឆ្នាំ១៩៤០សម្រាប់កំឡុងពេល១០ឆ្នាំផ្សេងទៀត"។

"កិច្ចព្រមព្រៀងជាមួយ ខដែលបានចែងលើមាត្រា៣៦ កថាខ័ណ្ឌទី៤ ស្ដីពីលក្ខន្តិកៈនៃតុលាការអន្តរជាតិ ។ នៅពេលនេះខ្ញុំបាទសូមជម្រាបថា ព្រះករុណាជាម្ចាស់ជីវិតតំកល់លើត្បូងបានធ្វើឡើងវិញនូវសេចក្ដីប្រកាសថ្មីមួយតាមរយៈការធ្វើនិទ្ទេសវែកញែកសេចក្ដីដូចបានជម្រាបជូនខាងលើសម្រាប់រយៈពេល១០ឆ្នាំតទៅទៀត ដោយរាប់ចេញពីថ្ងៃទី០៣ ខែឧសភា ឆ្នាំ១៩៥០ ដោយមានពេលកំណត់ និងប្រធានបទដែលមានលក្ខខណ្ឌ និងការបម្រុងទុកដូចគ្នានៅក្នុងសេចក្ដីប្រកាសលើកទី៤នេះ ដែលលើកទី១គឺនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩២៩ " ។

២-ការបកស្រាយរបស់ព្រះរាជាណាចក្រថៃ

ឯកភាគីនៃប្រទេស គឺបានលើកឡើងពីប្រធានបទផ្ដើមទី១ថា សេចក្ដីប្រកាសនេះមិនបានចែងពីការទទួលយកជាបានការនៅលើផ្នែកខ្លះនៃការបង្គាប់របស់យុធិការតុលាការអន្តរជាតិឡើយ។ ថៃគ្មានផ្លូវអាចប្រកែកថា ខ្លួនមិនមានឆន្ទៈពេញលេញចំពោះការទទួលយកនូវការបង្គាប់បញ្ជានៃយុត្តាធិការរបស់តុលាការអន្តរជាតិទេ ប៉ុន្តែមានការព្រមព្រៀងទៅនឹងការឈ្លោះប្រកែកឬជជែកគ្នា ។ ថៃបានធ្វើពង្រៀងសេចក្ដីប្រកាសរបស់ខ្លួន ដោយបញ្ចេញឱ្យ

គេឃើញច្បាស់ពីសេចក្តីសម្រេចរបស់តុលាការអន្តរជាតិនៅថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ១៩៥៩ នៅក្នុងករណីរឿងក្តីមួយ រវាងអ៊ីស្រាអែល និងប៊ុលហ្គារី ក្នុងករណីឧប្បតិហេតុលើផ្លូវអាកាស នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៥៥ ដែលមិនមានប្រសិទ្ធភាព ។

នៅមាត្រា៣៦ កថាខ័ណ្ឌទី៥ នៃលក្ខន្តិកៈតុលាការអន្តរជាតិបានចែងថា "សេចក្តីប្រកាសធ្វើក្រោមមាត្រាទី៣៦នៃល័ក្ខន្តិកៈរបស់តុលាការអន្តរជាតិអចិន្ត្រៃយ៍ និងដែលយល់ថា នៅតែស្ថិតក្នុងការគ្រប់គ្រងនៃតុលាការនៅឡើយ។ ក្នុងពេលបច្ចុប្បន្នរវាងគូភាគីទាំងពីរនោះ ភាគីណាមួយបានទទួលយកនូវការបង្គាប់របស់តុលាការ ក្នុងអំឡុងពេលដែលពួកគេនៅតែអនុវត្តចាត់ទុកជាបានការ និងដោយអនុលោមទៅតាមការព្រមព្រៀងរបស់គូភាគី "។

### ៣-ការបកស្រាយរបស់ចៅក្រមនៃតុលាការអន្តរជាតិ

ឯការសម្រេចរបស់តុលាការលើ ខ ដែលបានចែងនោះគឺមានឥទ្ធិពលតែនៅលើគូភាគីដំបូងបំផុតដែលទាក់ទងនឹងល័ក្ខន្តិកៈនោះ ហើយគេក៏បានកំណត់ថា ប៊ុលហ្គារីមិនបានក្លាយជាគូភាគីនៃល័ក្ខន្តិកៈនេះរហូតដល់ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៥៥ ហើយថាសេចក្តីប្រកាសទទួលយកការសម្រេចរបស់តុលាការរបស់គេនោះត្រូវអស់សុពលភាពត្រឹមថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៤៦មកម្ល៉េះ ។ ពេលនោះតុលាការបានបញ្ឈប់នូវការប្តឹងបន្តនូវរឿងក្តីនោះ ។

ឯចំណែករឿងក្តីព្រះវិហារវិញ ប្រទេសសៀមបានបន្តប្តឹងដោយឈរលើគោលជំហរថា ស្ថានភាពនេះខ្លួនមានលក្ខណៈដូចគ្នានឹងករណីរបស់ប្រទេសប៊ុលហ្គារីដែរ។ តាំងតែពេលដែលគេបានក្លាយជាភាគីតែមួយគត់នៃល័ក្ខន្តិកៈ នាថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ១៩៤៦ ដែល៨ខែបន្ទាប់ពីការរំសាយនៃតុលាការអចិន្ត្រៃយ៍អន្តរជាតិ (១៩-៤-១៩៤៦)។

សេចក្តីប្រកាសរបស់សៀម គឺចង់ទទួលបាននូវសេចក្តីសម្រេចរបស់តុលាការ ដែលគួរតែមិនត្រូវបានផ្លាស់ប្តូរចំពោះការទទួលយកនូវសេចក្តីសម្រេចនោះ ដោយទាក់ទងទៅនឹងតុលាការនៅពេលបច្ចុប្បន្ននេះ។ ថែមលើនេះទៀត ថៃនឹងសម្រេចនូវគោលបំណងពិតប្រាកដរបស់ខ្លួនទាំងអស់ គឺត្រូវការចាំបាច់នូវការបិទមិនឱ្យដំណើរការថ្មីក្នុងការទទួលយកនូវការបង្គាប់លើសេចក្តីសម្រេចរបស់សាលាក្តី ដែលមិនមានពេលច្រើនក្នុងការប្តឹងតវ៉ា ឬជំទាស់ឡើយ។ ពោលគឺគេមិនចង់ឱ្យខ្មែរលើកយកហេតុផលផ្សេងដើម្បីប្តឹងជំទាស់ឡើយ ហើយគេចង់បញ្ឈប់រឿងក្តីនេះ ។

តុលាការមិនបានពិចារណាថា ការវិនិច្ឆ័យរបស់ខ្លួននៅឆ្នាំ ១៩៥៩ មានផលវិបាកដល់ការទាមទាររបស់សៀមឡើយ។ ក្រៅពីនេះដំណើរហេតុនៃការវិនិច្ឆ័យបានចាត់ទុកជាមោឃៈ នូវការមិនបានរាប់បញ្ចូលកងកម្លាំងរវាងគូភាគីទាំងសងខាង។ តុលាការបានធ្វើការពិនិត្យមើលទៅលើប្រទេសថៃតាមរយៈសេចក្តីប្រកាសរបស់ថៃនៅថ្ងៃទី២០ ខែ ឧសភា ឆ្នាំ១៩៥០ ដែលបានកំណត់ថាប្រទេសថៃមានលក្ខណៈខុសពីប្រទេសប៊ុលហ្គារី ។

តែនៅឆ្នាំ ១៩៤០ មិនមែនមានតែសេចក្តីប្រកាសរបស់ប្រទេសថៃតែម្នាក់ឯងទេ ដែលមិនទាន់ត្រូវបានគេផ្លាស់ប្តូរនូវការទទួលយកនូវយុត្តាធិការរបស់តុលាការបច្ចុប្បន្ននោះ ប៉ុន្តែវាហួសពេលកំណត់ទៅហើយ។ មិនតែប៉ុណ្ណោះ យើងតាមសេចក្តីប្រកាសរបស់ថៃ គឺធ្វើឡើងដោយមុនពេលកំណត់២សប្តាហ៍ នៅថ្ងៃទី០៦ ខែឧសភា ឆ្នាំ១៩៥០។ សេចក្តីប្រកាសថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៥០ មិនមែនជាសេចក្តីប្រកាសថ្មីមួយ និងមានការប្រព្រឹត្តិទៅ ដោយឯករាជ្យឡើយ ។ ដូច្នេះគេបានធ្វើតាមមាត្រា៣៦ កថាខ័ណ្ឌទី ០៥ នៃល័ក្ខន្តិកៈនេះ ជាកិច្ចប្រតិបត្តិការណ៍លើការពិនិត្យមើលមួយដើម្បីទាត់ចោលនូវការទាមទាររបស់ថៃ ។

នៅក្នុងគោលបំណងនៃការបន្តនូវរឿងក្តីនេះ មានការវែកញែកខ្លះយល់ថា ទោះជាការប្រព្រឹត្តិទៅនោះអស់សុពលភាពក៏ដោយតែគេអាចធ្វើសាជាថ្មីឡើងវិញបាន ។ ក៏ប៉ុន្តែតុលាការបានពិចារណាថានេះគឺជាបញ្ហាពិតដែលបានធ្វើឱ្យប៉ះពាល់ទៅលើសេចក្តីប្រកាសឆ្នាំ ១៩៥០។ ការសម្រេចរបស់តុលាការក៏បានបញ្ជាក់ឱ្យបានច្បាស់លាស់ផងដែរថា ថៃមានសេចក្តីប្រកាសនេះនៅឆ្នាំ ១៩៥៩ ដែលមានការខ្វះខាតក្នុងការត្រួតពិនិត្យ និងសេចក្តីសំអាង ដោយគេបានប្រើប្រាស់សេចក្តីប្រកាសដែលមានលាយល័ក្ខអក្សរជាភាសារបស់ខ្លួន(ភាសាថៃ)ប៉ុណ្ណោះ។ ការសម្រេចចិត្តនៅឆ្នាំ១៩៥៩នេះ បានបង្ហាញឱ្យឃើញពីការមិនមានប្រសិទ្ធភាពគ្រប់គ្រាន់ក្នុងការសម្រេចគោលបំណងរបស់ថៃ។ តែតុលាការមិនបានធ្វើការសម្រេចថា បញ្ហានោះជាការខុសឆ្គងមួយយ៉ាងពិតប្រាកដនៅក្នុងករណីរឿងក្តីបច្ចុប្បន្ននេះទេ ។ បញ្ហានេះក៏ត្រូវបានគេជជែកគ្នាថា គោលបំណងវាគ្មានភាពគ្រប់គ្រាន់សម្រាប់ជាការគួបផ្សំគ្នាដើម្បីក្លាយជាសេចក្តីសម្រេចមួយមានតម្លៃខាងផ្លូវច្បាប់នោះទេ។ វាគ្រាន់តែជាការបង្គ្រប់កិច្ច ទៅតាមការទាមទារសម្រាប់ការបំពេញករណីកិច្ចក្នុងមហាសន្និបាតអង្គការសហប្រជាជាតិប៉ុណ្ណោះ។ ហើយការបង្គ្រប់កិច្ចនេះបានត្រូវបំពេញជាស្រេចដោយភាគីថៃនៅក្នុងកិច្ចព្រមព្រៀងដោយយោងតាមមាត្រា៣៦ កថាខ័ណ្ឌទី៤នៃល័ក្ខន្តិកៈនេះ ។

ដូច្នេះបញ្ហាដែលទាក់ទងតែមួយគត់ គឺបើទោះជាមានការប្រើប្រាស់នូវភាសារបស់ថៃក្នុងសេចក្តីប្រកាសរបស់គេនៅឆ្នាំ១៩៥០ ដែលមានការទាក់ទងទៅនឹងចេតនាយ៉ាងច្បាស់ក្នុងការទទួលស្គាល់នូវការបង្គាប់របស់តុលាការ ដែលមាននៅក្នុងមាត្រាទី៣៦ ទី២នៃល័ក្ខន្តិកៈ។ បើសិនជាតុលាការអនុវត្តន៍នូវគោលការណ៍ធម្មតាទូទៅរបស់ខ្លួនក្នុងការបកប្រែលើសេចក្តីប្រកាសនេះ វាមិនអាចមានន័យផ្សេងដ៏ទៃទៀតជាជាងការទទួលយកនូវការបង្គាប់យុត្តាធិការរបស់តុលាការបច្ចុប្បន្ននោះទេ។ ប្រទេសថៃ មិនត្រឹមតែមានគោលបំណងនៅក្នុងការថ្លែងសន្ទរកថាក្នុងមហាសន្និបាតអង្គការសហប្រជាជាតិក្រោមកថាខ័ណ្ឌទី៤ នៃមាត្រា៣៦ របស់ល័ក្ខន្តិកៈនេះជាជាងទទួលស្គាល់នូវការបង្គាប់យុត្តាធិការរបស់តុលាការនៃកថាខ័ណ្ឌទី២របស់មាត្រានេះប៉ុណ្ណោះ និងថែមទាំងធ្វើតាមបែបផ្សេងទៀត ទោះជាប្រទេសថៃបានយល់ដឹងយ៉ាងច្បាស់ថាតុលាការអចិន្ត្រៃយ៍អន្តរជាតិនោះមិនអាចបន្តអាយុកាលក៏ដោយពោលគឺវាដឹងច្បាស់តែយកលេសនេះមកធ្វើការបកស្រាយទៅវិញ ។ ឯផ្នែកនៅសល់នៃសេចក្តីប្រកាសនេះ បានបកស្រាយជាចំហរក្នុងទីក្លី និងច្បាស់លាស់ពីហេតុការណ៍សំខាន់ និងការបកស្រាយពីបរិបទទូទៅនៃសេចក្តីប្រកាសដោយមានឯកសារយោងលើសេចក្តីថ្លែងការឆ្នាំ១៩២៩ និង១៩៤០ ត្រូវតែមើលដោយភាពសាមញ្ញ និងមានរបៀបងាយស្រួលគ្មានការថ្លែងការណ៍លើសេចក្តីប្រកាសនេះក្នុងការព្រមព្រៀងគ្នាទេ ហើយវាជាលក្ខខណ្ឌមួយដែលយោងដោយការទទួលយកមកធ្វើ ។

### ៤-ការប្រកាសនូវសេចក្តីសម្រេច និងបង្គាប់ឱ្យមានការគោរព

ក្រោយពីទទួលនូវពាក្យបណ្តឹងរួចរាល់ហើយនោះ តុលាការអន្តរជាតិបានលើកយករឿងនេះមកពិចារណា។ ក្រោយមកមានការសម្រេចជាឯកច្ឆ័ន្ទ ថារឿងក្តីនេះបានត្រូវជំនុំជំរះរួចរាល់ហើយ។ នៅក្នុងចំណោមចៅក្រមទាំងអស់នោះ យើងឃើញថាអនុប្រធានAlfaro នៅចៅក្រម Wellington Koo, Sir Gerald Fitzmaurice និង Tanaka បានរក្សាការប្រកាសនៃការវិនិច្ឆ័យ ឯលោកចៅក្រម Sir Perey Spender និង លោក Morelli បានរក្សាអំពីការបែងចែកនៃសេចក្តីសម្រេចនោះផងដែរ ។

តុលាការបានពិចារណាថា សេចក្តីប្រកាសទាំងនោះមិនអាចរក្សាទុកជាការមន្ទិលសង្ស័យណាមួយដែលមានបង្កប់អត្ថន័យ និងផលប៉ះពាល់នោះទេ។ ដូច្នេះវាគួរតែបានគេសន្មត់ថាជាសេចក្តី ប្រកាសឆ្នាំ១៩៥០ ហើយតុលាការបានធ្វើការច្រានចោលនូវប្រធានបទទីមួយរបស់ថៃ ដែលបានទាមទារយកប្រាសាទព្រះវិហារនោះ ។

តុលាការបានរកឃើញថា ការសន្និដ្ឋាននោះសមល្មមក្នុងការរកពីយុត្តាធិការនៃតុលាការអន្តរជាតិនិងថា វាក្លាយជាភាពមិនចាំបាច់ក្នុងការបន្តទៅការពិចារណាអំពីការយកមកប្រើប្រាស់របស់កម្ពុជា នូវមូលដ្ឋានទី២នៃយុត្តាធិការ(វាជាសន្ធិសញ្ញាពិតប្រាកដសម្រាប់ការព្រមព្រៀងគ្នានៃតុលាការទៅលើការជជែកគ្នាអំពីការទាក់ទងទៅនឹងករណីយរឿងក្តីបច្ចុប្បន្ន) និងអំពីប្រធានបទរបស់ថៃសម្រាប់មូលដ្ឋាននៃយុត្តាធិការនេះ ។

### *គ-ការសម្រេចក្នុងសវនាការថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៦២*

ចៅក្រមបានរកឃើញថា ប្រធានបទនៃជម្លោះ គឺជាអធិបតេយ្យភាពនៃតំបន់ប្រាសាទព្រះវិហារ នៅក្នុងសវនាការរបស់គេ។ បដិសណ្ឋានបុរាណ និងភាគខ្លះរបស់វា នេះបានឈរយ៉ាងត្រដែតលើជ្រោយដ៏ខ្ពស់នៃជួរភ្នំដងរែក ដែលបានកសាងឡើងនៅចន្លោះព្រំប្រទល់ខ្មែរ-សៀម ។ ជម្លោះនេះមាន Fon និងOrigoរបស់វានៅតាមព្រំប្រទល់ព្រមព្រៀងគ្នាធ្វើឡើងនៅកំឡុងឆ្នាំ ១៩០៤-១៩០៨ រវាងបារាំង(ពេលនោះជាអ្នកធ្វើតំណាងនៃទំនាក់ទំនងអន្តរជាតិរបស់ឥណ្ឌូចិន)ជាមួយសៀម។ ការស្នើសុំនៃសន្ធិសញ្ញាថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩០៤ គឺទាក់ទងទៅនឹងលក្ខណៈពិសេសរបស់វា។ សន្ធិសញ្ញានេះធ្វើឱ្យមានឡើងនូវលក្ខណៈទូទៅនៃខ្សែបន្ទាត់ត្រង់ព្រំដែនពិតនៃអ្វីដែលគ្មានព្រំដែនតាមរយៈ"គណៈកម្មការចំរុះ Franco-Siam"។[101]

[101] ប្រាសាទព្រះវិហារ មានលក្ខណៈគួរឱ្យចាប់អារម្មណ៍លើខ្សែព្រំដែនកម្ពុជា-ថៃ ពោល គឺនៅលើជួរភ្នំដងរែក ដែលមានកម្ពស់៦២៥ ម៉ែត្រធៀបនឹងកំពស់ទឹកសមុទ្រ។ ប្រាសាទនេះមានលក្ខណៈជាច្រាំងបាក់ចុះទៅខាងដីខេត្តព្រះវិហារទៀតផង។ វាមានទីតាំងស្ថិតនៅខាងជើងនៃប្រទេសកម្ពុជា មានចំងាយ ៦២៥គីឡូម៉ែត្រពីរាជធានីភ្នំពេញ និងជាកន្លែងជួបប្រសព្វគ្នានៃព្រំប្រទល់កម្ពុជា-ថៃផងដែរ ។

**ខ-លក្ខណៈសំខាន់នៃប្រាសាទព្រះវិហារ**

ប្រាសាទនេះ មានលក្ខណៈខុសពីប្រាសាទដទៃទៀត ដោយបែរមុខទៅទិសខាងជើង ។ ប្រាសាទនេះបែរមុខទៅទិសខាងជើង ដោយសណ្ឋកលើភ្នំដងរែក ។

ប្រាសាទព្រះវិហារមានលក្ខណៈជាភ្នំ បើយើងសង្កេតលើភាពស្ថាបត្យកម្មខ្មែរពីមុន ដែលគោរពលើព្រះសុមេរុនោះ។ ពោល គឺវាមានលក្ខណៈជំរេលចុះទៅខាងទឹកដីសៀម ។

បើគិតពីលក្ខណៈស្ថាបត្យកម្មវិញនោះ យើងឃើញថាមូលហេតុដែលកសាងប្រាសាទនេះបែរទៅទិសខាងជើង គឺដោយសារសម័យនោះ មានការគោរពព្រហ្មណ៍សាសនា ដូចនេះគេសង់ប្រាសាទនេះឡើង គឺឧទ្ទិសដល់ព្រះវិស្ណុ ។ ដោយយើងមើលរូបភាពពុះនោះ យើងនឹងឃើញហាក់បីដូចជាព្រះវិស្ណុកំពុងផ្ទំ ដោយយកជើងបែរទៅទិសខាងជើង ។រួមសេចក្តីមកប្រាសាទព្រះវិហារ ជាប្រាសាទដែលបុព្វបុរសខ្មែរបានបន្សល់ទុកឱ្យ ។

ឯចំណែកបញ្ហាដែលថា ប្រាសាទព្រះវិហារបែរមុខទៅប្រទេសថៃ(ទិសខាងជើង)មិនមានអ្វីដែលគួរឱ្យងឿងឆ្ងល់ទេ ព្រោះទឹកដីរបស់ខ្មែរយើងនាសម័យនោះមានទំហំធំធេងណាស់ គឺខាងជើងទល់នឹងប្រទេសចិន។ នៅពេលនោះថៃមិនទាន់មានទឹកដីនៅឡើយទេ(ថៃមានដើមកំណើតពីជនជាតិចិនភាគតិចដែលបានរត់គៀសខ្លួនពីការវាយប្រហាររបស់ប្រទេសម៉ុងហ្គោលី) ។

**គ-លក្ខណៈព្រំដែនគោកកម្ពុជា-ថៃ**

ព្រំដែនកម្ពុជា-ថៃ មានប្រវែង៨០៣គីឡូម៉ែត្រ ចាប់ពីឈូងសមុទ្រសៀម ឆ្ពោះទៅទិសខាងជើងរួចបត់ទៅទិសខាងកើតតាមជួរភ្នំដងរែករហូតដល់ព្រំប្រទល់ទាំង៣ គឺកម្ពុជា ថៃ និងឡាវ នៅត្រង់ច្រកភ្នំព្រះចោមបុត្រ។ ព្រំដែនកម្ពុជា–ថៃ ត្រូវកំណត់ឡើងដោយសន្ធិសញ្ញាអន្តរជាតិ ហើយព្រមទាំងបោះបង្គោលខណ្ឌសីមានៅនឹងកន្លែងទៀតផង ។ ព្រំដែននេះបានត្រូវគេទទួលស្គាល់ជាថ្មីថា ជាព្រំដែនអន្តរជាតិនៅក្នុងរឿងក្តីក្តាំ ប្រាសាទព្រះវិហារឆ្នាំ ១៩៦២នៅក្នុងតុលាការអន្តរជាតិក្រុងឡាអេ ។

***លក្ខណៈច្បាប់**

ព្រំដែនកម្ពុជា-ថៃ ជាព្រំដែនបានកំណត់ឡើងដោយកិច្ចព្រមព្រៀងអន្តរជាតិ រវាងអាណានិគមបារាំង និងប្រទេសថៃ។ ព្រំដែននេះបានត្រូវគណៈកម្មការចំរុះ បារាំង-សៀម បានកំណត់ឡើង និងបោះបង្គោលខ័ណ្ឌសីមា ចំនួន៧៣ បង្គោលក្នុងអំឡុងឆ្នាំ ១៩១៨-១៩១៩ ។ ប៉ុន្តែ ដោយបង្គោលខ្លះធ្វើអំពីឈើ ឬយកដើមឈើធ្វើបង្គោលនោះ គណៈកម្មការចំរុះបារាំង-សៀម បានសម្រេចបោះបង្គោលសារជាថ្មី និងមានឯកសារស្តីពីការដាំបង្គោល ព្រមទាំងមានការបញ្ជាក់អះអាងថាបង្គោលទាំងនោះសាងសង់ដោយ បេតុងអាមេ ក៏ដោយ ក៏យើងមានសង្ឃឹមតិចតួចណាស់ថា នឹងមានលទ្ធភាពរកបង្គោលដែលបានធ្វើឡើង ជិតមួយសតវត្សហើយនោះ ឱ្យឃើញទាំងអស់បានដែរ។

ឯកសារដែលមានដូចខាងក្រោមនោះ គឺជាឯកសារផ្លូវច្បាប់ដ៏ចម្បងសម្រាប់កំណត់ព្រំដែនកម្ពុជា-ថៃ ៖

សន្ធិសញ្ញាបារាំង-ខ្មែរ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣ និងប្តូរសច្ចាប័ននៅថ្ងៃទី១៩ ខែមេសាឆ្នាំ១៨៦៤។

តាមរយៈសន្ធិសញ្ញាដែលមាន២០ មាត្រា ចុះហត្ថលេខាដោយព្រះរាជាខ្មែរព្រះបាទនរោត្តម ជាមួយលោកអគ្គទេសាភិបាលបារាំងប្រចាំកូសាំងស៊ីន De La Grandière បានចែងក្នុងមាត្រា១ថា «ព្រះចៅអធិរាជនៃប្រទេសបារាំង មានសិទ្ធិផ្តល់នូវការការពារដល់ប្រទេសកម្ពុជា »។ តាមរយៈមាត្រានេះ មានន័យថា បារាំងដាក់ប្រទេសខ្មែរក្រោមអាណាព្យាបាលរបស់គេ ។

***សន្ធិសញ្ញាខ្មែរ-សៀម ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ១៨៦៣**

នេះជាសន្ធិសញ្ញាសំងាត់មួយដែលធ្វើឡើងដោយព្រះបាទនរោត្តម ជាមួយព្រះចៅសៀម ក្នុងកំឡុងពេលដែលសន្ធិសញ្ញាបារាំង-ខ្មែរ ថ្ងៃទី ១១ សីហា ឆ្នាំ១៨៦៣ បានបញ្ជូនទៅឱ្យព្រះចៅណាប៉ូឡេអុង ដើម្បីផ្តល់សច្ចាប័ន។ តាមរយៈសន្ធិសញ្ញានេះ ប្រទេសខ្មែរគឺជាសម្ព័ន្ធរដ្ឋរបស់សៀម នូវខេត្តបាត់ដំបង អង្គរ មង្គលបុរី ស៊ីសុផុន កំពង់ស្វាយ និងពោធិសាត់។

សន្ធិសញ្ញាបារាំង-សៀម ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៨៦៧

តាមរយៈមាត្រា១ នៃសន្ធិសញ្ញានេះ ព្រះចៅសៀមទ្រង់ទទួលស្គាល់ជាឧឡារិកនូវអាណាព្យាបាលភាពរបស់បារាំងមកលើប្រទេសកម្ពុជា ហើយបារាំងបានសន្យាថា មិនវាយយកប្រទេសកម្ពុជាទៅបញ្ចូលជាមួយអាណានិគមកូសាំងស៊ីនរបស់ខ្លួនឡើយ ។ រីឯមាត្រា៤ នៃសន្ធិសញ្ញានេះដដែលបានទទួលស្គាល់ថា ខេត្តបាត់ដំបង អង្គរ មង្គលបុរី ស៊ីសុផុន កំពង់ស្វាយ និងពោធិសាត់ជាកម្មសិទ្ធិរបស់សៀម ។

សន្ធិសញ្ញាសន្តិភាព និង អនុសញ្ញារវាងបារាំង-សៀម ចុះហត្ថលេខានៅថ្ងៃទី ០៣ ខែតុលា ឆ្នាំ១៨៩៣ នៅទីក្រុងបាងកក ហើយឱ្យសច្ចាប័ននៅថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ១៨៩៩។

សៀមបានប្រគល់ទឹកដីទាំងអស់ នៅភាគខាងកើតទន្លេមេគង្គទៅឱ្យបារាំង ។ ដោយរាប់បញ្ចូលទាំងខេត្តស្ទឹងត្រែង ដែលបារាំងបានដាក់ឱ្យនៅក្រោមការគ្រប់គ្រងរដ្ឋបាលបណ្តោះអាសន្នរបស់ឡាវផង។ក្រោយមក ខេត្តនេះបានត្រូវគេបែងចែកក្នុងចំណោមប្រទេសឡាវ-កម្ពុជា និងអណ្ណាម ។

***អនុសញ្ញា បារាំង-សៀម ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ១៩០២**

សន្ធិសញ្ញានេះ សៀមបានប្រគល់នូវខេត្តម្លូព្រៃ ទន្លេរពៅ និងអាណាចក្របាសាក់ តែអនុសញ្ញានេះ មិនប្តូរសច្ចាប័នទេ ដោយសារមានការទិតៀន ហើយបានត្រូវគេជំនួសអនុសញ្ញាឆ្នាំ១៩០៤វិញ។

អនុសញ្ញាបារាំង-សៀម លើការសម្របសម្រួលបញ្ហាខ្លះ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩០៤ ។

តាមអនុសញ្ញានេះ ខេត្តម្លូព្រៃ ទន្លេរពៅ បណ្តោយត្រើយខាងលិចទន្លេមេគង្គ និងអាណាចក្របាសាក់បានត្រូវមកឥណ្ឌូចិន-បារាំងសេស។ អនុសញ្ញាដដែលនេះ ក៏បានកំណត់ព្រំដែនពីត្រើយខាងឆ្វេងបឹងទន្លេសាប ដោយយកខ្សែបែងចែកទឹកដីនៃភ្នំដងរែកធ្វើជាព្រំដែន ហើយបារាំងក៏បានបោះពុម្ពផែនទីមួយចំនួនដែរពេលក្រោយមក អនុសញ្ញានេះឱ្យយើងយកជាឯកសារក្នុងការកាត់ក្តីតវ៉ាយកប្រាសាទព្រះវិហារ ។

**សន្ធិសញ្ញាបារាំង-សៀម និង ប្រូតូកូលលើការកំណត់ព្រំដែនចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩០៧**

- តាមរយៈសន្ធិសញ្ញា និងប្រូតូកូលនេះ សៀមបានប្រគល់ខេត្តបាត់ដំបង សៀមរាប និងស៊ីសុផុនមកឱ្យបារាំង ។ ប៉ុន្តែ បារាំងបានឱ្យជាថ្នូរមកវិញនូវដែនដី ដាន់សៃ និងត្រាត ។ បន្ទាប់គណៈកម្មការបារាំង-សៀម បានកំណត់ព្រំដែនរវាងប្រទេសទាំងពីរ ដោយបានចែកព្រំដែនជា៥តំបន់នេះគឺ ជាផែនទីប្រើប្រាស់ខ្នាត ១ភាគ២០០.០០០ ដែលមានឈ្មោះថាផែនទីគណៈកម្មការកំណត់ព្រំដែនរវាងឥណ្ឌូចិន និងសៀម ។

**ទើបចៅក្រមធ្វើការសម្រេចចុងក្រោយ ដោយបោះឆ្នោត ៖**

១- សេចក្ដីសម្រេចពីចៅក្រមប្រាំបួនទល់និងបី បានរកឃើញថា ˝ប្រាសាទព្រះវិហារពិតជាស្ថិតនៅក្នុងអធិបតេយ្យភាពដែនដីខ្មែរយ៉ាងប្រាដក˝
២- សេចក្ដីសម្រេចពីចៅក្រមប្រាំបួនទល់និងបី បានប្រកាសថា *ប្រទេសថៃត្រូវគោរពក្នុងការដកកងទ័ពតម្រួតកងការពារឬកងរក្សាទាំងអស់របស់ខ្លួនចេញពីប្រាសាទព្រះវិហារ ឬដែនអធិបតេយ្យភាពរបស់កម្ពុជា * * *
៣- សេចក្ដីសម្រេចដោយចៅក្រមប្រាំពីរទល់និងប្រាំ បានប្រកាសថា ប្រទេសថៃត្រូវប្រគល់មកវិញនូវសម្បត្តិទាំងឡាយដែលថៃបានដឹញ្ជូនចេញពីប្រាសាទព្រះវិហារ និងក្នុងតំបន់ប្រាសាទព្រះវិហារក្នុងអំឡុងពេលប្រទេសថៃកាន់កាប់ខុសច្បាប់ពីឆ្នាំ១៩៥៤ ហើយសេចក្ដីសម្រេចនេះបានចុះហត្ថលេខា ដោយលោក **WINIAR SKI** ប្រធានតុលាការយុត្តិធម៌អន្តរជាតិ ( **I .C.J** )។

## 5. ជំនួយសហរដ្ឋអាមេរិក និងវិស័យសុខាភិបាល

ជំនួយសហរដ្ឋអាមេរិកដល់ប្រទេសកម្ពុជា ពីឆ្នាំ១៩៥៥ដល់១៩៦៣ គឺជាចំណងជើងសារណារបស់ខ្ញុំសម្រាប់បំពេញលក្ខខណ្ឌជាសាស្ត្រាចារ្យមធ្យមសិក្សាទុតិយភូមិ ដែលត្រូវបម្រើការនៅឧត្តមសិក្សានៅឆ្នាំ១៩៩៧ បានឱ្យដឹងថា ជំនួយនេះចាប់ផ្តើមបន្ទាប់ពីមានកិច្ចព្រមព្រៀងមួយរវាងស្ថានកូតអាមេរិកជាមួយក្រសួងការបរទេស

---

- តំបន់ទី១ ៖ បោះពុម្ពឡើងក្នុងឆ្នាំ១៩០៧-១៩០៨ ចាប់ពីឈូងសមុទ្រសៀមឆ្ពោះទៅភ្នំធំ ដោយមានបង្គោលព្រំដែនចំនួន៣គិតចាប់ពីលេខ ៧១ ដល់៧៣
- តំបន់ទី២ ៖ បោះពុម្ពឡើងក្នុងឆ្នាំ១៩០៨-១៩០៩ ដោយមានបង្គោលព្រំដែនចំនួន៥គិតចាប់ពីលេខ៦៦ដល់៧០
- តំបន់ទី៣ ៖ បោះពុម្ពឡើងក្នុងឆ្នាំ១៩០៧-១៩០៨ ដោយមានបង្គោលព្រំដែនចំនួន១៧ គិតចាប់ពីលេខ៤៩ដល់៦៥
- តំបន់ទី៤ ៖ បោះពុម្ពឡើងក្នុងឆ្នាំ១៩០៧-១៩០៩ ដោយមានបង្គោលព្រំដែនចំនួន២៥ គិតចាប់ពីលេខ២៣ដល់៤៨

តំបន់ទី៥ ៖ បោះពុម្ពឡើងក្នុងឆ្នាំ ១៩០៧-១៩០៨ ដោយមានបង្គោលព្រំដែនចំនួន២៤ គិតចាប់ពីលេខ០១ដល់លេខ ២២B ដោយគេបានបញ្ជាក់ថា២២A មិនទាន់បានសាងសង់ពីបេតុងនៅឡើយទេ ។

គួរកត់សំគាល់ដែរថា ផែនទីទាំង៥តំបន់នេះ មិនបានកំណត់ព្រំដែនទាំងអស់រវាងប្រទេសកម្ពុជានឹងថៃទេ ដោយនៅសល់មួយតំបន់ទៀត លើជួរភ្នំដងរែកដល់ច្រកភ្នំព្រះចោមបុត្រនៃព្រំប្រទល់ប្រទេសទាំងបី កម្ពុជា ថៃ និងឡាវ។ ដោយគណៈកម្មការចម្រុះ ស្នើសុំទុកផែនទីដែលបានកំណត់ឡើងដោយគណៈកម្មការចំរុះឆ្នាំ ១៩០៤ ជាឯកសារចម្បង ដែលអាចឱ្យកម្ពុជាឈ្នះក្ដីនៅតុលាការអន្តរជាតិនាឆ្នាំ១៩៦២។

**ប្រតូកូលបាងកក ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩២៥ និងអនុសញ្ញាចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ១៩២៦**

ពិធីសារ និងអនុសញ្ញានេះ បានធ្វើសាជាថ្មីនូវការកំណត់ព្រំដែនកម្ពុជា-សៀម ដោយគ្មានការប្រែប្រួល ។

**សន្ធិសញ្ញាបារាំង-សៀមចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ១៩៣៧**

ក្នុងសន្ធិសញ្ញានេះ គេបានធ្វើការបញ្ជាក់សារជាថ្មីនូវការកំណត់ព្រំដែនដែលបានបញ្ជាក់ម្តងរួចមកហើយតាមប្រូតូកូលបាងកក កាលពីឆ្នាំ១៩២៥។

**អនុសញ្ញាសន្តិភាពបារាំង-សៀម នៅទីក្រុងតូក្យូ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ១៩៤១**

ដោយមានការឃុបឃិត និងដោយការបង្ខិតបង្ខំពីជប៉ុន ទៅលើប្រទេសបារាំង ដែលពេលនោះបារាំងកំពុងតែចាញ់សង្គ្រាមជាមួយពួកហ្វាស៊ីសហ៊ីត្លែរផង ព្រំដែនបារាំង-សៀម ត្រូវត្រលប់ថយក្រោយទៅយកព្រំដែនមុនឆ្នាំ១៩០០ ដោយបារាំងប្រគល់ឱ្យថៃនូវទឹកដីប្រទេសកម្ពុជា និងឡាវ ដែលទទួលបានពីពេលមុនមក។

កិច្ចព្រមព្រៀងក្រុងវ៉ាស៊ីនតោន ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៤៦។ តាមរយៈកិច្ចព្រមព្រៀងនេះអនុសញ្ញាក្រុងតូក្យូឆ្នាំ១៩៤១ បានត្រូវលុបចោល ហើយបង្គាប់ឱ្យប្រទេសថៃ វិលទៅរកព្រំដែនដែលមុនសង្គ្រាមលោកទី២ ឡើងវិញ។

ខ្មែរ នៅថ្ងៃទី១៦ឧសភាឆ្នាំ១៩៥៥ ស្ដីអំពីការផ្ដល់ជំនួយខាងយោធា និងសេដ្ឋកិច្ចដល់ប្រទេសកម្ពុជា។ ជំនួយនេះគឺជាផ្នែកតូចមួយនៃផែនការជំនួយរបស់អាមេរិកដល់លោកសេរី ដើម្បីប្រកួតប្រជែងគ្នាដណ្ដើមពិភពលោកជាមួយសហភាពសូវៀត ក្រោយសង្គ្រាមលោកលើកទី២បានបញ្ចប់។ ជំនួយនេះក៏ជាការទាក់ទាញសមានចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាឱ្យចូលរួមជាមួយចលនាសេរីនិយម និងអង្គការសន្ធិសញ្ញាស៊ីតូ (SEATO) ឬអូតាស (OTASE)[102] ដែរ។ ជំនួយនេះ មិនបានកំណត់អណត្តិរបស់ខ្លួនឡើយ ក៏ប៉ុន្តែដោយសារមើលឃើញថា បរិមាណរបស់វាកាន់តែថយចុះពីមួយឆ្នាំមកមួយឆ្នាំ សម្ដេចព្រះនរោត្តម សីហនុទ្រង់ឆ្ងេងយល់ថា វាសូវមានផលប្រយោជន៍ និងកាន់តែបង្កបញ្ហាដល់កម្ពុជាទៅវិញ ព្រះអង្គបានសម្រេចព្រះទ័យបដិសេធឈប់ទទួលយកចាប់តាំងពីខែវិច្ឆិកាឆ្នាំ១៩៦៣មក។

ជំនួយនេះ មិនមានរូបភាពជាជំនួយប្រាក់ដុល្លាសុទ្ធសាធនោះទេ តែជាជំនួយកំណត់បរិមាណទឹកប្រាក់ជាសមាមាត្រជាមួយតម្លៃទំនិញជាសម្ភារៈផ្សេងៗដែលអាមេរិកទិញយកមកឱ្យកម្ពុជា។ រាជរដ្ឋាភិបាលត្រូវកំណត់តម្លៃទំនិញ ឬសម្ភារៈទាំងនោះ លក់ឱ្យឈ្មួញ ឬមន្ទីរក្រសួងរបស់រដ្ឋដែលត្រូវការទំនិញទាំងនោះ។ រួចហើយទើបបង្វែរសាច់ប្រាក់ដែលលក់ចេញទាំងនោះ ដាក់ទៅក្នុងគណនីលុយជំនួយអាមេរិកនៅក្នុងធនាគារជាតិ។ បន្ទាប់មកទើបក្រសួងនីមួយៗដែលត្រូវការប្រើប្រាស់ថវិកានោះ ធ្វើសំណើដកប្រាក់ទាំងនោះមកចាយ តាមចំណែករបស់សាមីក្រសួងដែលបានចែងនៅក្នុងផែនការអភិវឌ្ឍន៍ប្រចាំឆ្នាំ ដោយប្រើប្រាស់ថវិកាជំនួយ។ ចំណែក ជំនួយខាងផ្នែកកងទ័ព ក៏មានរបៀបដូចគ្នានេះដែរ គឺអាមេរិកជួយជាសម្ភារៈសឹកគ្រប់បែបយ៉ាងមកស្រេចតែម្ដង ទើបរដ្ឋាភិបាលចាត់ការបែងចែកទៅតាមអង្គភាព ដូចដែលបានគ្រោងទុក ដើម្បីបំពាក់ឱ្យយុទ្ធជន នាយទាហាន និងទីបញ្ជាការដ្ឋាន។

បរិមាណទឹកប្រាក់ជំនួយរបស់អាមេរិករយៈពេល៩ឆ្នាំនេះ ថ្វីបើឯកសារជាច្រើន បង្ហាញនូវតួលេខខុសៗពីគ្នាក្ដី តែបើសរុបទាំងជំនួយយោធា និងសេដ្ឋកិច្ចចូលគ្នា មានប្រមាណ៣៥០លានដុល្លា ហើយបើយកបរិមាណនេះទៅប្រៀបធៀបជាមួយជំនួយទាំងអស់ដែលផ្ដល់ឱ្យដោយពិភពលោកកុម្មុយនិស្ត វាពិតជាមានចំនួនច្រើនជាង១០ដង។ បំណែកភាគច្រើននៃជំនួយផ្ដោតទៅលើសម្ភារៈសឹក ដែលបានធ្វើឱ្យកងខេមរភូមិន្ទបានហ៊ឺហាអស់មួយរយៈពេល។ ប៉ុន្តែអាវុធយុទ្ធភ័ណ្ឌទាំងនោះត្រូវអាមេរិកដាក់លក្ខខណ្ឌព្រមានរាជរដ្ឋាភិបាលខ្មែរ កុំឱ្យប្រើប្រាស់ ដើម្បីប្រយុទ្ធប្រឆាំងនឹងកងទ័ពនៃប្រទេសជាសម្ព័ន្ធមិត្តរបស់អាមេរិក គឺប្រទេសថៃ និងវៀតណាមខាងត្បូង ដែលកំពុងតែបង្កហេតុរំលោភព្រំដែនខ្មែរនោះទៅវិញ។

បរិមាណជំនួយដែលអាមេរិកផ្ដល់ឱ្យខ្មែរតាមឆ្នាំ គិតជាដុល្លា

| ឆ្នាំ | ជំនួយសេដ្ឋកិច្ច | ជំនួយយោធា | ជំនួយសរុប |
|---|---|---|---|
| ១៩៥៥ | ១៦ ៨០០ ០០០ | ៦៨ ២០០ ០០០ | ៨៥ ០០០ ០០០ |
| ១៩៥៦ | ២០ ១០០ ០០០ | ៤២ ០០០ ០០០ | ៦៣ ១០០ ០០០ |
| ១៩៥៧ | ១៨ ៧០០ ០០០ | ២១ ៨០០ ០០០ | ៤០ ៥០០ ០០០ |
| ១៩៥៨ | ២០ ៤០០ ០០០ | ២០ ៥០០ ០០០ | ៤០ ៩០០ ០០០ |
| ១៩៥៩ | ៩ ៥០០ ០០០ | ១៨ ៥០០ ០០០ | ២៨ ០០០ ០០០ |
| ១៩៦០ | ៧ ៩០០ ០០០ | ១៤ ៧០០ ០០០ | ២២ ៦០០ ០០០ |
| ១៩៦១ | ៧ ៥៦៥ ០០០ | ១៩ ១០០ ០០០ | ២៦ ៦៦៥ ០០០ |

[102] SEATO: South-East Asian Treaty Organization (in English)
OTASE: Organisation de Traité de l'Asie Sud-Est (en Française)

| | | | | |
|---|---|---|---|---|
| ១៩៦២ | ១ ៤០០ ០០០ | ២២ ៥០០ ០០០ | ២៣ ៩០០ ០០០ | |
| ១៩៦៣ | ៩ ៣០០ ០០០ | ១០ ០០០ ០០០ | ១៩ ៣០០ ០០០ | [103] |
| ជំនួយសរុប | ១១១ ៦៦៥ ០០០ | ២៣៩ ៣០០ ០០០ | ៣៤៩ ៩៦៥ ០០០ | [104] |

ក្នុងចំណោមបរិមាណជំនួយខាងលើនេះ យើងឃើញមានការរំលែកនូវភាគដ៏តិចតួចមួយសម្រាប់ជួយដល់ផ្នែកសុខាភិបាល។ បំណែកសល់ក្រៅពីនោះ រដ្ឋាភិបាលប្រើប្រាស់កញ្ចប់ថវិកាជាតិមួយចំណែកសម្រាប់បំពេញ ការអភិវឌ្ឍន៍វិស័យនេះ។ មកដល់ឆ្នាំ១៩៦២ ជំនួយអាមេរិកលើវិស័យសុខភាពសាធារណៈដែលបានចាប់ផ្តើមពីឆ្នាំ ១៩៥៦ មានប្រមាណជាង២%ប៉ុណ្ណោះ ដែលស្មើនឹងទឹកប្រាក់ ៧.៨៣២.០០០ដុល្លាហើយបើសរុបជាមួយទឹកប្រាក់ជំនួយដដែល ប្រមាណ៣%នៅឆ្នាំ១៩៦៣ គឺឡើងដល់៨.៤២៣.០០០ដុល្លា។ ដើម្បីធ្វើការពិចារណាអំពីស្ថានភាពចំណាយលើសុខាភិបាលចន្លោះឆ្នាំដដែល សូមពិនិត្យមើលតួលេខថវិកាជំនួយបរទេស និងថវិកាជាតិសម្រាប់អភិវឌ្ឍន៍វិស័យសុខាភិបាល ខាងក្រោមនេះ គិតជារៀល ៖

| ឆ្នាំ | ទឹកប្រាក់ជំនួយបរទេស | ការចំណាយថវិកាជាតិ | ការចំណាយសរុបប្រចាំឆ្នាំ |
|---|---|---|---|
| ១៩៥៥ | ២.២២៥.០០០ | ៨៤.០០០.០០០ | ៨៦.២២៥.០០០ |
| ១៩៥៦ | ៤.៧៦១.០០០ | ៨៧.០០០.០០០ | ៨២.៧៦១.០០០ |
| ១៩៥៧ | ១៥.៤៩៦.០០០ | ១៨៣.០០០.០០០ | ១៩៨.៤៩៦.០០០ |
| ១៩៥៨ | ២៧.៤៣៨.០០០ | ២០៣.០០០.០០០ | ២៣០.៤៣៨.០០០ |
| ១៩៥៩ | ២២.៦៧០.០០០ | ២២៥.០០០.០០០ | ២៤៧.៦៧០.០០០ |
| ១៩៦០ | ១១.៩៦៤.០០០ | ២៨៧.០០០.០០០ | ២៩៨.៩៦៤.០០០ |
| ១៩៦១ | ៨.៦៣៣.០០០ | ៤០៥.០០០.០០០ | ៤១៣.៦៣៣.០០០ |
| ១៩៦២ | | ៤៦៣.០០០.០០០ | |
| ១៩៦៣[105] | ១៨.៩១២.០០០ | ៤១០.៧៤៨.៨៤២ | ៤២៩.៦៦០.៨៤២ |

ជំនួយបរទេសប៉ុន្មានឆ្នាំនេះ ផ្តោតសំខាន់ជាងគេលើការងារកំចាត់ និងបង្ការជំងឺគ្រុនចាញ់។ ចាប់ពីឆ្នាំ ១៩៥៥ ជំនួយចាប់ផ្តើមបើយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងជំងឺទាំងឡាយ ដោយអនុលោមតាមកិច្ចប្រតិបត្តិការជា

[103] សៀវភៅសម្តេច នរោត្តម សីហនុ នៅឆ្នាំ១៩៧៣ ក្រោមចំណងជើងថា សង្គ្រាមរបស់ខ្ញុំប្រឆាំងនឹង សេអ៊ីអា ទំព័រ ១០៩-១១០ បានអះអាងថាជំនួយនៅឆ្នាំ ១៩៦៣។ កម្ពុជាទទួលបានតែ ៨,៦០០,០០០ ដុល្លា ប៉ុណ្ណោះ។ ទំនងវាជាការពិត ព្រោះនៅខែវិច្ឆិកា ព្រះអង្គបានប្រកាសទាត់ចោលរាល់ជំនួយរបស់អាមេរិក។ ដូច្នេះវាអាចថាកម្ពុជា មិនទាន់ទទួលបានសម្ភារៈជំនួយប្រចាំឆ្នាំដែលបានគ្រោងទុក នោះអស់នៅឡើយ។

[104] ទោះជាយ៉ាងណា បរិមាណនេះ មិនមែនជាតួលេខត្រឹមត្រូវពិតប្រាកដដែរ ដោយសារឯកសារទាំងអស់ដែលបានចង្អុលបង្ហាញពីបរិមាណជំនួយនេះ តែងតែផ្តល់នូវតួលេខខុសៗពីគ្នា ដែលយើងពិបាកនឹងអារកាត់បានថា មួយណាជាប្រកតត្រឹមត្រូវនោះ។

[105] តួលេខទឹកប្រាក់នៅឆ្នាំនេះ គឺជាបរិមាណទឹកប្រាក់ដែលគេគ្រោងទុកប៉ុណ្ណោះ។ សម្រាប់ខ្ទង់ទឹកប្រាក់ជំនួយបរទេស គឺចង្អុលបង្ហាញពីជំនួយអាមេរិកនៅឆ្នាំ១៩៦៣តែមួយគត់ ហើយទឹកប្រាក់ឆ្នាំនេះជាឆ្នាំចុងក្រោយ ដែលបរិមាណជំនួយមានកម្រិតកាន់តែតិចបំផុត។ តើគួរឱ្យជឿបានដែរឬទេ ចំពោះតួលេខលុយជំនួយនៅក្នុងប៉ុន្មានឆ្នាំមុននេះ ដែលបរិមាណជំនួយអាមេរិកសរុបមានច្រើនជាងឆ្នាំ១៩៦៣ ពីម្តងទៅបីដង។ ដូច្នេះ យើងគិតថា បរិមាណទឹកប្រាក់ប៉ុន្មានឆ្នាំនេះ ទំនងជាមានតួលេខខ្លះមិនពិត។

សំខាន់របស់អង្គការសុខភាពពិភពលោក ព្រមជាមួយការផ្តល់នូវបុគ្គលិកពេទ្យខាងគ្រប់គ្រង និងចល័តចំនួនទ្វេមួយជាពីរលើសឆ្នាំមុនៗ។ គេបានធ្វើការចែកចាយឱសថ, ការពង្រីកកម្មវិធីប្រឆាំងជំងឺគ្រុនចាញ់ ដោយបាចថ្នាំដេដេតេសម្លាប់មូសមួយចំហៀងប្រទេសកម្ពុជា (មួយចំហៀងទៀតត្រូវបាចនៅឆ្នាំបន្ទាប់), ប្រឆាំងជំងឺភ្នែកក្រហម និងរោគស្ត្រី ជាដើម។ មានការរៀបចំអណ្តូងទឹក ដើម្បីធ្វើឱ្យតាមភូមិស្រុកនីមួយៗមានការប្រើប្រាស់ទឹកអនាម័យឱ្យបានប្រសើរឡើង។ ក្រៅពីនោះ មានការចាប់ផ្តើមគម្រោងការសាងសង់មន្ទីរព្យាបាលរោគ និងគិលានដ្ឋាននៅតាមភូមិមួយចំនួនឱ្យបានទំនើបឡើងដែរ។ ចំណែកគ្រូពេទ្យ គិលានុបដ្ឋាក និងគិលានុបដ្ឋាយិកាជំនាញ ខាងគាំពារ និងព្យាបាលទារក ត្រូវបានរៀបចំចាត់តាំងនៅតាមមន្ទីរព្យាបាល និងគិលានដ្ឋានទាំងនោះ ព្រមជាមួយគ្រូបង្រៀនទាំងឡាយ ដើម្បីបង្រៀននៅតាមសាលារៀននានា អំពីគោលការណ៍សំខាន់ៗនៃអនាម័យដើម្បីសុខភាព។

កម្មវិធីរបស់ UNICEF និងអាមេរិកាំងប្រតិបត្តិការរួមគ្នា បានប្រើថ្នាំ BCG ដើម្បីចាក់ឱ្យកូនក្មេងបង្ការជំងឺក្អក របេង។ ព្រមជាមួយគ្នានោះដែរ គេបានបើយុទ្ធនាការ ឃោសនាអំពីចំណេះដឹងអនាម័យនៅក្នុងគ្រប់ខេត្តទាំងអស់ ដោយប្រើប្រាស់បុគ្គលិកចំនួន៤៨នាក់ ដែលបានទទួលការហ្វឹកហ្វឺនដោយគ្រូពេទ្យខ្មែរអង្គការសុខភាពពិភពលោក និងអ្នកជំនួយការអាមេរិក។

មកដល់ឆ្នាំ១៩៥៨ ថវិកាជំនួយផ្តោតលើសកម្មភាពសំខាន់ពីរ គឺការបាចថ្នាំ DDT .ដើម្បីកម្ចាត់មូសដែលអាចបង្កជំងឺគ្រុនចាញ់ជាបន្តទៀត និងការស្តាបនាអ ណ្តូងស្នប់នៅតាមជនបទ ដើម្បីនយោបាយការផ្គត់ផ្គង់ទឹកស្អាត មានអនាម័យ។ សកម្មភាពអាទិភាព បានប្រព្រឹត្តិទៅនៅក្នុងខេត្តកំពង់ស្ពឺ និងកំពត។

មកដល់ឆ្នាំ១៩៥៩ ដោយសារតម្រូវការប្រើប្រាស់ឧបករណ៍ពេទ្យ នៅតាមមន្ទីរពេទ្យជាច្រើន ជំនួយអាមេរិក ចំនួន៨៨៥០០០ដុល្លា បានផ្តល់សម្រាប់ទិញភស្តុភារទាំងនេះ មានតាំងពីគ្រែដេក ឧបករណ៍វះកាត់ប្រដាប់ស្ទង់ស្តាប់សរីរៈ និងសីតុណ្ហមាត្រ។ ក្រៅពីនេះ ជំនួយត្រូវបន្ថែមលើការខួងអណ្តូង និងបរិក្ខារសម្រាប់បំពាក់ឱ្យអណ្តូង នៅតាមខេត្តចំនួន៥ ដែលមានចំនួនសរុប ៦០២អណ្តូងខួង ដើម្បីធានាផ្គត់ផ្គង់ទឹកស្អាត។ ក្នុងនោះ មានចំនួន ៤៨អណ្តូង នៅខេត្តកំពង់ចាម។ ដើម្បីកុំឱ្យអ្នកស្រុកបង្ការជំងឺតម្កាត់ ដោយការប្រើកំបោរគួសវាសលើផ្ទះសំបែង ជំនួយបានរួមជាមួយអង្គការសុខភាពពិភពលោក លៃហិរញ្ញប្បទានផ្តល់ដល់សេវាកម្មប្រឆាំងជំងឺគ្រុនចាញ់ នៃក្រសួងសាធារណៈសុខាភិបាល ដើម្បីចុះចែកចាយថ្នាំសង្កូវដល់អ្នកស្រុកនៅតាមជនបទ ធ្វើការស្រាវជ្រាវពិសោធន៍ និងការបណ្តុះបណ្តាលបុគ្គលិកពិសេស ដើម្បីជួយណែនាំអ្នកស្រុក ដោយផ្តល់សេវាកម្មជាអចិន្ត្រៃយ៍ ប្រយុទ្ធប្រឆាំងនឹងជំងឺគ្រុនចាញ់ ក្រោមកម្មវិធីបណ្តុះបណ្តាលរបស់អង្គការជំនួយ។

មកដល់ឆ្នាំ១៩៦២ ជំនួយក៏នៅតែផ្តោតសំខាន់លើកម្មវិធីកំចាត់ និងបង្ការជំងឺគ្រុនចាញ់ ព្រមជាមួយគោលនយោបាយប្រើប្រាស់ទឹកស្អាតនៅតំបន់ជនបទដដែល។

**ការកសាងសាលាពេទ្យ**

មុនឆ្នាំ១៩៤៦ នៅប្រទេសកម្ពុជា មិនទាន់មានសាលាពេទ្យនៅឡើយ។ ហេតុនោះហើយទើបមកដល់ឆ្នាំនេះ មានព្រះរាជក្រឹត្យមួយ ចុះថ្ងៃទី០៦មករា១៩៤៦ បង្កើតសាលាមន្ត្រីសុខាភិបាល ជាលើកដំបូង និងជាភ្នាក់ងារជួយសង្គម និងប្រជារាស្ត្រខ្មែរខាងវេជ្ជសាស្ត្រ។ រហូតមកដល់ឆ្នាំ១៩៤៨ ទើបសាលានេះបើកទ្វារដំណើរការបានទូលាយ។ មកដល់ឆ្នាំ១៩៥៣ សាលានេះមានបំពាក់បរិក្ខារសម្រាប់បម្រើការសិក្សា និងពិសោធន៍បានគ្រប់គ្រាន់

និងបណ្តុះបណ្តាលបានមន្ត្រីសុខាភិបាលចំនួន៧៨នាក់ ដែលបានក្លាយជាធនធានដ៏សំខាន់សម្រាប់ដំណើរការមន្ទីរពេទ្យនានា និងមជ្ឈមណ្ឌលសុខភាពសហគមន៍នៅទូទាំងប្រទេស ព្រមទាំងក្នុងអង្គភាពកងខេមរភូមិន្ទ។

តាមរយៈរាជក្រិត្យចុះថ្ងៃទី១២តុលា១៩៥៣ សាលាមន្ត្រីសុខាភិបាល ត្រូវប្តូរឈ្មោះជា សាលាភូមិន្ទវិជ្ជាពេទ្យ ។ ដោយសារការប្រែប្រួលយ៉ាងហ័សនេះ ការបង្រៀនបច្ចេកទេសសុទ្ធពីពេលមុន ត្រូវបានគេកែសម្រួលកម្មវិធីសិក្សាឡើងវិញ ដោយតម្រូវឱ្យនិស្សិតរៀនបំពេញបន្ថែមនូវចំណេះដឹងវប្បធម៌ទូទៅ,អក្សរសាស្ត្រ, ប្រវត្តិអរិយធម៌, ភូមិវិទ្យាមនុស្ស, ចិត្តវិទ្យា, តក្កវិទ្យា, សីលធម៌ និងសង្គមវិទ្យា។

សាលាភូមិន្ទវិជ្ជាពេទ្យ ក្រោយពីស្ថាបនារួចរាល់ភ្លាមក្រោមជំនួយបដិភាគរបស់អាមេរិក និងបារាំងបានចាប់ផ្តើមបើកទ្វារឡើងវិញ នៅថ្ងៃទី០៣វិច្ឆិកា១៩៥៥ និងធ្វើការសម្ពោធជាឱឡារិកនៅព្រឹកថ្ងៃទី០៧មករា១៩៥៦ ក្រោមព្រះរាជាធិបតីភាពព្រះបាទនរោត្តមសុរាម្រិត និងសម្តេចព្រះមហាក្សត្រិយានី ស៊ីសុវត្ថិនារីរ័ត្នសិរីវឌ្ឍនា ។ នៅក្នុងសំណង់អគារនោះ គេបានបំពាក់ឧបករណ៍សម្រាប់បម្រើការសិក្សា និងពិសោធន៍តាមតម្រូវការចាំបាច់។

ចំនួនសាស្ត្រាចារ្យ និងសាស្ត្រាចារ្យអាហ្គ្រេហ្សេ ដែលមកពីប៉ារីសប្រទេសបារាំង ផ្តល់ការបង្រៀននៅសាលានេះ។ មាននិស្សិតខ្មែរ កាន់តែច្រើនដែលបញ្ចប់ការសិក្សានៅសាលានេះ ហើយចេញទៅបន្តការសិក្សានៅប្រទេសបារាំង ដើម្បីពង្រឹងសមត្ថភាព និងបំពេញវិជ្ជាបន្ថែមទៀត។ អ្នកទាំងអស់នោះហើយ គឺជាអនាគតវរជនវេជ្ជសាស្ត្រនៅកម្ពុជា។

ទន្ទឹមនោះ អង្គការសុខភាពពិភពលោក, រាជរដ្ឋាភិបាលកម្ពុជា, រដ្ឋាភិបាលសហរដ្ឋអាមេរិក, និងរដ្ឋាភិបាលបារាំង បានសន្យាព្រមគ្នា ជួយស្ថាបនា និងបំពាក់បរិក្ខារចាំបាច់ទាំងឡាយឱ្យសាលានេះកាន់តែទំនើប និងមានប្រសិទ្ធភាពឡើង ដូចជា បង្កើតមន្ទីរពិសោធន៍ដ៏ល្អមួយ, បណ្ណាល័យយ៉ាងធំទូលាយមួយ, និងបន្ទប់ចក្ខុទស្សន៍យ៉ាងល្អមួយ។ មកដល់ឆ្នាំ១៩៥៨ មានសាស្ត្រាចារ្យ និងគ្រូពេទ្យជំនាញចំណានៗជាច្រើនមកពីប៉ារីស មកពីខាងកងទ័ពបារាំង មកពីអង្គការសុខភាពពិភពលោក បានបញ្ជូនមកជួយបង្រៀននៅសាលានេះជាបន្តបន្ទាប់។ ចំណែក នាយកសាលា គឺជាសាស្ត្រាចារ្យវេជ្ជបណ្ឌិត ជនជាតិបារាំង ឈ្មោះ ម៉ាក់ មេយណារដ៍ ដែលមកពីសាកលវិទ្យាល័យពេទ្យនៅក្រុងប៉ារីស។

មកដល់ពេលនេះ និស្សិតខ្មែររៀននៅសាលានេះមានចំនួន១៦០នាក់ បន្ទាប់ពីប្រឡងប្រជែងគ្នារួច។រដ្ឋាភិបាលបានផ្តល់អាហារូបករណ៍ដល់ពួកអ្នក ដែលបានប្រឡងជាប់ឈ្នះគេទាំងអស់នោះ។ មកឆ្នាំ១៩៥៨ នេះដែរ សាលាទើបតែបណ្តុះបណ្តាលបាននិស្សិតថ្នាក់ដំបូងគេបានត្រឹមឆ្នាំទី២ប៉ុណ្ណោះ។ និស្សិតភេទស្រីជាច្រើននាក់ក៏បានប្រឡងជាប់ និងឈ្នះគេ បានចូលរៀនដូចគ្នានឹងបុរសដែរ។ តាមរបាយការណ៍របស់នាយកសាលាជាជនជាតិបារាំងនោះ បានឱ្យដឹងថា និស្សិតថ្មីថ្នាក់ឆ្នាំទី១ទាំងអស់ សុទ្ធសឹងមានសក្តានុពលល្អ ដោយមានការឈ្លាសវៃ និងចូលចិត្តវិជ្ជានេះយ៉ាងមោះមុត។ វិជ្ជាជំនាញត្រូវបែងចែកជាពីរប្រភេទ គឺការសិក្សា៤ឆ្នាំ សម្រាប់ធ្វើពេទ្យខាងអនាម័យ និងសិក្សារយៈពេល៧ឆ្នាំ សម្រាប់ធ្វើជាគ្រូពេទ្យធំ ឬដុកទ័រវេជ្ជសាស្ត្រ។

ការសាងសង់សាលារៀនព្យាបាលថ្មីមួយកន្លែងនៅក្នុងបរិវេណមន្ទីរពេទ្យព្រះកេតុមាលា ដោយប្រើទឹកប្រាក់បដិភាគ ដើម្បីធ្វើជាសាលាបណ្តុះបណ្តាលវិជ្ជាព្យាបាល និងវិជ្ជាឆ្មបដល់គ្រូពេទ្យបឋម។

នៅក្នុងបរិវេណមន្ទីរសម្ភព ក្រុមបេសកកម្មជំនួយបានសាងសង់អាគារពីរខ្នងបន្ថែម ដើម្បីធ្វើជាបន្ទប់សិក្សា, បន្ទប់ពិសោធន៍, បន្ទប់ដាក់សម្ភារៈ និងបន្ទប់បណ្ណាល័យ ឬបន្ទប់ធ្វើសន្និសីទ។ អគារពីខ្នងនេះត្រូវបើកសម្ពោធនៅ

ខែធ្នូ១៩៥៤។ វាជាបន្ទប់សម្រាប់ប្រើការក្នុងការបណ្ដុះបណ្ដាលគិលានុបដ្ឋាក និងឆ្មបផងដែរ។ ក្រៅពីនោះអ្នកផ្ដល់ជំនួយ បានបន្ថែមថវិកាសម្រាប់ជួសជុល, ថែរក្សា, ទិញសម្ភារៈបរិក្ខារបំពាក់បន្ថែម និងជំនួសសម្ភារៈដែលខូចខាត និងថវិកាសម្រាប់ប្រាក់បៀវត្សរ៍របស់អ្នកធ្វើការនៅក្នុងនោះមួយចំនួន។

នៅមានគ្រឹះស្ថានមួយទៀត ដែលត្រូវសម្ពោធនៅខែឧសភាឆ្នាំ១៩៥៥ ត្រូវបានកសាងឡើងដោយថវិកាជំនួយរបស់អាមេរិកដែល។ សាលានេះអាចទទួលបានសិស្សពេទ្យកម្រិតបឋម មានគិលានុបដ្ឋាក និងឆ្មប យ៉ាងហោចណាស់៣៦នាក់ម្ដង ឱ្យចូលសិក្សាហ្វឹកហ្វឺន។ ជំនួយគ្របដណ្ដប់ទាំងការទិញបរិក្ខារប្រើប្រាស់ក្នុងការសិក្សា និងពិសោធន៍នៅនឹងកន្លែងរៀនតែម្ដង។

នៅមន្ទីរពេទ្យព្រះកេតុមាលា នាឆ្នាំ១៩៥៨ ដោយសារថវិកាជំនួយបានស្ថាបនាបន្ទប់សម្រាប់ព្យាលជំងឺកុមារ និងបង្កើតបន្ទប់វះកាត(សល្យាគារ)មួយ។

នៅឆ្នាំ១៩៥៩ មានជំនួយជាថវិកាបេជិភាគសម្រាប់ស្ថាបនាអគារពេទ្យកុមារ, មន្ទីរសម្ភពក្រុងភ្នំពេញ មជ្ឈមណ្ឌលសុខាភិបាលក្រុងមួយនៅទឹកល្អក់ និងមជ្ឈមណ្ឌលសុខាភិបាលនៅជនបទតាខ្មៅ ព្រមជាមួយការបំពាក់បរិក្ខារប្រើប្រាស់ ដោយរួមជាមួយជំនួយរបស់អង្គការសុខភាពពិភពលោក ដែលផ្ដល់ជាបុគ្គលិកពេទ្យ ថ្នាំបង្ការជំងឺយ៉ាងទំនើបៗ និងការបង្កើតមជ្ឈមណ្ឌលសម្រាប់បណ្ដុះបណ្ដាលបុគ្គលិកបម្រើការខាងសុខភាពនៅតាមមជ្ឈមណ្ឌលដូចខាងលើនោះ។

នៅឆ្នាំ១៩៦២ ជំនួយមួយចំណែកនៃថវិកាសរុប២៦,២លានរៀល បានដាក់ទៅលើសម្ភារៈបរិក្ខារសម្រាប់បំពាក់នៅមណ្ឌលសុខភាពកំពង់ត្រាច ខេត្តកំពត។

មានមណ្ឌលហ្វឹកហ្វឺនគ្រូអប់រំមូលដ្ឋានជាតិខាងសុខភាពធំមួយ នៅទន្លេបាទី ត្រូវបានកសាងឡើងក្រោមកម្មវិធីទឹកប្រាក់ជំនួយ។ នៅឆ្នាំ១៩៦២ មជ្ឈមណ្ឌលនេះ បានបើកកម្មវិធីហ្វឹកហ្វឺនរយៈពេលពីរសប្ដាហ៍ ដែលមានសិក្ខាកាមខ្មែរ ៧០នាក់ចូលរួមហ្វឹកហ្វឺន។ កម្មវិធីរយៈពេលខ្លីបែបនេះ គេផ្ដោតសំខាន់ទៅលើ វិធីរៀបចំចំណីអាហារសម្រាប់ស្ត្រីមានគភ៌, ការថែរក្សាទារក សុខភាពរបស់ទារក, វិធីថែរក្សារបស់ស្ត្រីទើបនឹងសម្រាលកូនរួច, វិធីចាត់ចែង និងរបៀបធ្វើការនៅក្នុងក្រុម, វិធីធ្វើការជាមួយនឹងអ្នកស្រុក ភូមិជាដើម បន្ទាប់មក គឺការសិក្សាអនុវត្តន៍ផ្ទាល់ សិក្ខាកាមត្រូវរៀនជីករណ្ដៅ, បង្គន់, រៀនធ្វើទរទឹកកខ្វក់ រៀនកសាងកន្លែងសម្រាប់ដាក់ជីរលាមកគោ។

សរុបសេចក្ដីមក ជំនួយសហរដ្ឋអាមេរិក បានជួយអភិវឌ្ឍន៍វិស័យសុខាភិបាលបានមួយចំណែក បើពិនិត្យលើជំនួយពីប្រទេសដទៃទៀត កម្ពុជាទទួលបានផលប្រយោជន៍ច្រើន ដើម្បីជាវិភាគទានសម្រាប់សុខមាលភាពរបស់ប្រជារាស្ត្រ។ ជាទូទៅ គេអាចធ្វើការប្រៀបធៀបបានថា ជំនួយបរទេសអាចជំរុញឱ្យមានវឌ្ឍនភាពសុខាភិបាល ប៉ុណ្ណោះ បើរួមទាំងផលទុនដែលរដ្ឋាភិបាលបានដាក់ថែមទៀតនោះ យើងអាចនឹងគិតបានថា នៅសម័យនេះវិស័យសុខាភិបាលមានការរីកចម្រើនយ៉ាងឆាប់រហ័ស ខុសពីសម័យអាណានិគមជាច្រើនដង ដែលអស់រយៈពេលជាងកន្លះសតវត្សរ៍ គេមិនបានយកចិត្តទុកដាក់ធ្វើទាល់តែសោះ។

## 6. ការបះបោររបស់កសិករ និងការជ្រៀតចូលរបស់វៀតកុង

*នៅសំឡូត*

ការបះបោររបស់កសិករនៅសំឡូតកើតឡើង ដោយសារការដណ្តើមដីធ្លីរបស់អ្នកស្រុកដើម ដើម្បីការអភិវឌ្ឍន៍រោងចក្រស្ករសមួយនៅក្នុងតំបន់នេះ ពីសំណាក់ពួកមន្ត្រីរាជការស្រុក និងខេត្តបាត់ដំបង ព្រមទាំងមានការឃុបឃិតគ្នាជាខ្សែសង្វាក់ដ៏វែងមួយរហូតដល់មន្ត្រីធំៗនៅក្រសួងមហាផ្ទៃ ហើយទំនងជាមានការពាក់ព័ន្ធជាមួយក្រុមរាជវង្សានុវង្សទៀតផង។ តាមលោកឪពុក ហ្វ្រង់ស្វ័រ ប៉ុងសូ បានគូសបញ្ជាក់ថា ″សំឡូតជាភូមិតូចមួយនៅក្នុងខេត្តបាត់ដំបងភាគខាងលិច។ ក្នុងតំបន់ដែលសំបូរទៅដោយព្រៃឈើ និងឆ្ងាយដាច់ស្រយ៉ាលនេះ មានជនជាតិ″ព័រ″ ជាសមាជិកនៃកុលសម្ព័ន្ធភាគតិចមួយ ដែលរស់នៅឆ្ងាយពីការរីកចម្រើនរបស់សង្គមជាតិស៊ីវិល័យ។ នៅក្នុងអំឡុងសង្គ្រាមឥណ្ឌូចិនលើកទី១ ពួកវៀតមិញបានមកជ្រកពួកនៅក្នុងតំបន់នេះយ៉ាងច្រើន ហើយមានកម្មាភិបាលជាច្រើនរបស់ពួកគេនៅតែស្ថិតនៅទីនេះទៀត បន្ទាប់ពីមានកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវតម្រូវឱ្យពួកគេដកចេញទៅវិញហើយក៏ដោយ ក៏ពួកនេះនៅតែរក្សាភាពប្រទុស្តរាយមួយដែលមិនបង្ហាញសញ្ញាណមកក្រៅ ជាការប្រឆាំងនឹងអាជ្ញាធរមូលដ្ឋានរបស់រាជរដ្ឋាភិបាល។ ពួកនេះនៅមានអាវុធប្រមាណ២០០ដើមទៀត ដែលគេបានលាក់ទុកក្នុងព្រៃបន្ទាប់ពីការរំសាយនៅឆ្នាំ១៩៥៤។ នៅឆ្នាំ១៩៦៦ អាជ្ញាធរប្រចាំខេត្តបាត់ដំបង បានសម្រេចកសាងរោងចក្រផលិតស្ករសមួយ នៅកំពុងកុល ដែលស្ថិតនៅក្បែរសំឡូត។ ដើម្បីកសាងរោងចក្រនេះ អាជ្ញាធរបានចាត់ចែងចាប់យកដីធ្លីជាច្រើនកន្លែងរបស់អ្នកស្រុកអាយ ដោយគ្មានផ្តល់សោហ៊ុយ ដែលមានតម្លៃស្មើគ្នានឹងដីធ្លីរបស់កសិករជាម្ចាស់ទាំងនោះបាត់បង់ឡើយ។ ពួកអតីតកម្មាភិបាលរបស់ខ្មែរវៀតមិញ បានឆ្លៀតយកឱកាសនេះ ដើម្បីជំរុញឱ្យប្រជាជនងើបឡើងធ្វើការបះបោរជាចំហ។

‶រាជរដ្ឋាភិបាលក្រុងភ្នំពេញបានធ្វើប្រតិកម្មតបតយ៉ាងឃោរឃៅ ដោយផ្តើមធ្វើប្រតិបត្តិការឃោឃាមួយក្រោមការបញ្ជារបស់វរៈសេនីយ៍ទោ ឆាយ ឡាយ។ អ៊ំ ម៉ាណូរិនដែលជាបងថ្លៃសម្តេច សីហនុ និងជារដ្ឋលេខាធិការក្រសួងមហាផ្ទៃ បានបញ្ជូនប៉ូលីសជាច្រើននាក់ទៅកាន់ទីនោះទៀត។ ពួកប៉ូលីស និងកងទ័ពបានលេងដៃធ្ងន់មែនទែន ដោយសម្លាប់អ្នកភូមិ និងដុតបំផ្លាញផ្ទះសម្បែងអស់យ៉ាងច្រើន។ ប្រជាជនបាននាំគ្នារត់ចូលព្រៃ ដោយពាំនាំទៅជាមួយនូវការស្អប់ គុំគួនកាន់តែខ្លាំងបំផុតចំពោះរាជរដ្ឋាភិបាលមួយ ដែលកំពុងប្រព្រឹត្តអំពើអយុត្តិធម៌ និងធ្វើឱ្យមានសេចក្តីវិនាសបែបនេះ″។[106]

## *នៅខ្ពង់រាបខេត្តរតនគិរី*

កំសួលនៃការមិនសប្បាយចិត្តរបស់អ្នកស្រុកសំឡូតមិនទាន់បានស្ងប់ផងនោះ នៅឆ្នាំបន្ទាប់ ការសម្រេចព្រះទ័យរបស់សម្តេចសីហនុ ដើម្បីពង្រីកការអភិវឌ្ឍន៍ដំណាំកៅស៊ូនៅខ្ពង់រាបដីក្រហមខេត្តរតនគិរី បានបង្កឱ្យមានជម្លោះដ៏ធំមួយទៀតរវាងអាជ្ញាធរខេត្ត និងអ្នកស្រុកដើមជនជាតិភាគតិចព្នង ដែលជាម្ចាស់ស្រុកនៅតំបន់នោះ។ ការអភិវឌ្ឍន៍នេះ ក្នុងគោលបំណងរិះរកប្រភពរូបិយប័ណ្ណបរទេសសម្រាប់ជំនួសជំនួយសហរដ្ឋអាមេរិក។ អ្នករាតត្បាតតំបន់ព្រៃភ្នំនេះ គឺជាអ្នករស់នៅភ្នំពេញដែលជាខ្មែរភូមិភាគកណ្តាល។ ការទន្ទ្រានកាន់កាប់ ដោយកាប់ឆ្ការព្រៃនៅតំបន់នេះ បានធ្វើឱ្យប៉ះពាល់ផលប្រយោជន៍របស់ជនជាតិភាគតិច ដែលរស់ដោយអាស្រ័យផលព្រៃឈើ និងដំណាំចំការព្រៃដុត ទើបធ្វើឱ្យពួកគាត់មិនសប្បាយចិត្តចំពោះអំពើឈ្លានពានទាំងកំរោលនេះ។ អភិបាលខេត្តម្នាក់ឈ្មោះ អ៊ុង ញ៉ូច បានប្រើកម្លាំងប្រដាប់អាវុធ រំលោភបំពានរាប់មិនអស់ ដើម្បីរឹបអូសយកដីធ្លីពីពួកអ្នកស្រុកភ្នំជាច្រើនគ្រួសារ ក្នុងបំណងដាំដើមកៅស៊ូនោះ។ គាត់បានបាញ់សម្លាប់ខ្មែរលើដោយអាវុធ ស្លាប់អស់ប្រមាណ២០នាក់។ ម្ល៉ោះហើយ អ្នកស្រុកព្រៃភ្នំទាំងនោះត្រូវបង្ខំចិត្តរត់ចូលព្រៃជាមួយនឹងអាវុធបុរាណ ធ្នូ ស្នា កាំបិតរបស់ពួកគេ។ ការធ្វើ

[106] Voir, François Ponchaud. 1976, Octobre. *Cambodge Année Zéro.* Document Kailash, Paris, (Kh., pp.183-4)

សង្គ្រាមរវាងអ្នកប្រើអាវុធប្រពៃណីនេះ ជាមួយកងទ័ពនិយ័តរបស់រាជរដ្ឋាភិបាល បានប្រព្រឹត្តិទៅយ៉ាងស៊ីសាច់ហុតឈាម។ ទីបំផុត អ្នកស្រុកភ្នំដែលស្គាល់ភូមិសាស្ត្រច្បាស់ និងមានទម្លាប់រស់នៅក្នុងតំបន់ព្រៃភ្នំ តាំងពីកំណើតតដូនតារាប់រយពាន់ឆ្នាំមកហើយនោះ បានវាយប្រហារកងទ័ពរដ្ឋាភិបាលឱ្យវិនាស និងលែងទុកចិត្តលើខ្លួនឯង។ អ្នកស្រុកលើទាំងនោះ បានរៀបចំខ្លួនឱ្យមានទម្រង់ជាកងទ័ពជាស្រេច ម្យ៉ាងទៀត ដោយពួកគេបានទទួលជំនួយអាវុធ និងគ្រាប់រំសេវខ្លះពីពួកអ្នកបដិវត្តន៍វៀតណាម ដែលនៅក្នុងព្រៃជិតគ្នានោះស្រាប់។

ចាប់ពីពេលនោះមក ពួកវៀតណាមបដិវត្តន៍ទាំងអស់នោះ បានក្លាយទៅជាគ្រោះថ្នាក់មួយយ៉ាងពិតប្រាកដសម្រាប់របបសង្គមរាស្ត្រនិយម។ តែទោះជាយ៉ាងណា នៅដំណាក់កាលដំបូងនេះ គេបានផ្តល់អាវុធឱ្យពួកខ្មែរលើអ្នកបដិវត្តន៍ទាំងនោះ តែបន្តិចបន្តួចប៉ុណ្ណោះ ដើម្បីរក្សាទំនាក់ទំនងល្អជាមួយអ្នកស្រុកភ្នំ និងផលប្រយោជន៍ធំដែលកំពុងដាក់នុយស្នូចពីរដ្ឋាភិបាលភ្នំពេញ។ ហេតុនេះហើយ បានជាព្រះប្រមុខរដ្ឋបានអនុញ្ញាតឱ្យក្បួនរថយន្តដឹកអាវុធ និងគ្រាប់រំសេវរបស់វៀតណាមខាងជើងពីកំពង់ផែកំពង់សោម ឆ្លងកាត់ជាតិលេខ៤ លេខ៦ និងលេខ៧ទៅកាន់តំបន់នៅតាមព្រំដែនក្នុងខេត្តក្រចេះ, មណ្ឌលគិរី និងរតនគិរី។[107]

## 7. វិបត្តិនយោបាយ និងសេដ្ឋកិច្ចជាតិចុងទសវត្សរ៍១៩៦០

ជាគូបនីយកម្មសេដ្ឋកិច្ចរបស់សង្គមរាស្ត្រនិយម ហាក់ដូចជាបរាជ័យ ចាប់ពីឆ្នាំ១៩៦៦-៧ នៅពេលដែលការរកស៊ីត្រូវខាតដើម ព្រោះតែការជំពាក់ និងកិបកេងលុយរដ្ឋរបស់មន្ត្រីទុច្ចរិត។ ចាប់ពីដើមទសវត្សរ៍១៩៦០ សេដ្ឋកិច្ចជាតិមានស្ថានភាពល្អប្រកបដោយសក្តានុពល។ មានរោងចក្រច្រើនប្រភេទ ចាប់ផ្តើមរីកដុះដាលនៅកម្ពុជា។ ប៉ុន្តែមិនយូរប៉ុន្មាន ប្រតិបត្តិការទាំងនោះ ចាប់ផ្តើមអតុល្យភាពរវាងចំណាយ និងចំណូល ធ្វើឱ្យឃ្លាំងជាតិរីងហួតយ៉ាងលឿន។ បន្ទាប់ ពីការបោះលុយថ្មីបន្ថែមនៅឆ្នាំ១៩៦៦ រដ្ឋាភិបាលបានសម្រេចដាក់ទុនវិនិយោគលើវិស័យភាពយន្តរដ្ឋម្តងដោយតួឯកគឺជាព្រះប្រមុខរដ្ឋ ព្រះជាយា និងរាជបុត្រ។ ដំបូងឡើយ ការរកស៊ីបានជោគជ័យ រដ្ឋទទួលបានចំណូលយ៉ាងច្រើន។ ពីព្រោះប្រជារាស្ត្រពេញចិត្តនឹងចង់ឃើញព្រះភ័ក្ត្រ និងព្រះសកម្មភាពកាយវិការរបស់ក្សត្រខ្លួន ទើបនាំគ្នាទៅទស្សនាយ៉ាងច្រើនកុះករ។ ប៉ុន្តែ ដល់ច្រើនរឿងបន្តិចទៅ គេចាប់ផ្តើមនឿយណាយ បរិមាណអ្នកទិញសំបុត្រទស្សនា កាន់តែហោចទៅៗ ធ្វើឱ្យបរិមាណចំណូលតិចជាងការចំណាយពេលផលិត។ ចុងបំផុត វិស័យភាពយន្តរដ្ឋត្រូវដួលរលំ។

ទន្ទឹមនឹងដំណើរទៅរកឱនភាពនោះ ដំណោះស្រាយសេដ្ឋកិច្ចមួយទៀត គឺការបើកកាស៊ីណូរដ្ឋ ដែលពេលមុនមានតែគ្រឹះស្ថានស្របច្បាប់ពិសេសមួយចំនួនតូច ដូចជា នៅលើកំពូលភ្នំបូកគោ និងទីក្រុងខ្លះទៀត ប៉ុន្តែចាប់ពីឆ្នាំ១៩៦៨មក រដ្ឋាភិបាលបានអនុញ្ញាតឱ្យបើកនៅទូទាំងប្រទេស ដើម្បីប្រមូលប្រាក់តុងប៉ៀរ។ ដូច្នោះ ហើយនៅតាមក្រុង និងជនបទទាំងអស់ ចាប់ពីទីស្នាក់ឃុំ ការិយាល័យស្រុក រហូតដល់មន្ទីរនៅតាមខេត្ត បានក្លាយជាកន្លែងបើកបនល្បែងភ្នាល់គ្នា ស៊ីសង ដើម្បីប្រមូលប្រាក់ចូលហោប៉ៅជាតិ។ ប៉ុន្តែទន្ទឹមនឹងនោះ អំពើពុករលួយកិបកេងរបស់មន្ត្រីរាជការកាន់តែកម្រើកកក្រើកខ្លាំងឡើង។ វិបត្តិសង្គម កើតមានកាន់តែច្រើន ដោយសារចាញ់ល្បែងភ្នាល់។ គ្រួសារខ្លះត្រូវធ្លាក់ខ្លួនក្រ លក់អស់នូវចលន និងអចលនៈទ្រព្យ ដែលខ្លួនមានបានតមរតកពីដូនតាមក ឬទើបនឹងរកស៊ីសន្សំបាន។ សមាជិកគ្រួសារ ដែលមានឪពុក, ម្តាយ ឬកូនជាអ្នកញៀនល្បែងស៊ីសង ចាប់ផ្តើមឈ្លោះទាស់ទែង

[107] Voir, *Ibid*, (Kh.) p. 185.

គ្នាហែកហួរគ្នា បង្កើតសោកនាដ្យកម្មក្នុងគ្រួសារ។ អ្នកខ្លះ ក្រោយពីលក់អស់ ចាប់ផ្ដើមលួច ក្រោយពីលួចលែងបានចាប់ផ្ដើមឆក់ប្លន់ កាប់សម្លាប់អ្នកដទៃយកទ្រព្យសម្បត្តិ។

ដោយឃើញផលវិបាកបែបនេះ រដ្ឋាភិបាលចាប់ផ្ដើមចេញច្បាប់បិទការបើកបនល្បែងភ្នាល់គ្នាវិញនៅដើមឆ្នាំ១៩៦៩។ សភាពការណ៍លេងល្បែងភ្នាល់ ហាក់ដូចជាមិនសូវហ៊ឹកហ៊ាក់ដូចពេលមុន ប៉ុន្តែការប្រព្រឹត្តិល្បែងលួចលាក់នៅតែបន្ត ជួនកាលអាជ្ញាធរមូលដ្ឋានជាអ្នកការពារ និងដកតុង។ វិបត្តិសង្គមនៅតែបន្ត ព្រោះអ្នកញៀនទាំងឡាយមិនអាចឈប់បាន អ្នកចាញ់ទាំងឡាយ មិនទាន់ដាច់ចិត្តឈប់តាមរកឱកាសស្រង់ដើមមកវិញ។ ម្ល៉ោះហើយ នៅលើទំព័រកាសែត រៀងរាល់សប្ដាហ៍ គេតែងឃើញផ្សាយលទ្ធផលនៃការបង្ក្រាបរបស់អាជ្ញាធរមានសមត្ថកិច្ច ទៅលើអ្នកលួចលេងខុសច្បាប់ ដែលជួនកាលចាប់បានទាំងប្ដី–ប្រពន្ធ និងកូន ព្រមទាំងអាជ្ញាធរមូលដ្ឋាន។

នាពេលចុងទសវត្សរ៍១៩៦០នោះដែរ ការជ្រៀតចូលរបស់ពួកវៀតកុង ដែលបង្កជាសង្គ្រាមឥណ្ឌូចិនលើកទី២ មកក្នុងទឹកដីជនបទចុងកាត់មាត់ញកនៃប្រទេសកម្ពុជា ក៏កាន់តែមានចំនួនច្រើនឡើង។ ការប្រមូលទិញស្បៀងសម្រាប់ហូបចុក យកទៅលក់នៅក្រៅប្រទេស កាន់តែថយចុះ ព្រោះពួកវៀតកុងបានប្រើវិធីប្រមូលទិញពីអ្នកស្រុកជនបទដោយខ្លួនឯង ដោយប្រើក្រដាសប្រាក់ក្លែងក្លាយ ទាំងផ្ទាំងៗ។ យុវជនខ្មែរ និងកសិករយៃកណ្ដាលយ៉ាងច្រើន ធ្វើសកម្មភាពរត់ពន្ធអង្ករ សាច់ងៀត និងថ្នាំពេទ្យយកទៅលក់ឱ្យពួកវៀតកុងនៅតាមភូមិស្រុកឆ្ងាយពីផ្លូវជាតិគមនាគមន៍ ដើម្បីដូរយកក្រដាសប្រាក់ទាំងផ្ទាំងៗ ដែលមិនទាន់កាត់នៅឡើយ។[108] សកម្មភាពពាណិជ្ជកម្មរដ្ឋត្រូវដួល បិទទ្វារ ទើបគេកែសម្រួលទៅធ្វើក្រោមរូបភាពពាណិជ្ជកម្មផ្សេងៗវិញ។

ទន្ទឹមនឹងនេះនៅកម្ពុជា មានពួកខ្មែរកុម្មុយនិស្តដើរឃោសនាអ្នកស្រុក ឱ្យស្រឡាញ់មនោគមវិជ្ជានេះតាមពួកខ្លួនដែរ បើទោះបីពួកគេមិនយល់ទ្រឹស្ដីនោះច្បាស់ក៏ដោយ។ ព្រោះពួកគេជក់ចិត្តនឹងរបបសង្គមដែលពួកកុំមុយនីស្តឃោសនាថា ជាសង្គម គ្មានវណ្ណៈអ្នកមានអ្នកក្រ, អ្នកដែលត្រូវគេជិះជាន់ និងវណ្ណៈជិះជាន់គេ អ្នកកេងប្រវ័ញ្ចគេ និងអ្នកត្រូវគេកេងប្រវ័ញ្ចន៍ចម្រាញ់ញើសឈាម។ ម្ល៉ោះហើយ ជំពូកមនុស្សមានវិបត្តិមួយចំនួន ក៏ចុះចូលធ្វើជាភ្នាក់ងារឱ្យពួកកុម្មុយនិស្តនោះទៅ។ ចំណែកអ្នកនៅតាមជាយដែន ទទួលរងគ្រោះដោយការទម្លាក់គ្រាប់បែកដោយកងទ័ពអាកសអាមេរិក។ ពួកគេរងនូវទុកសោកវេទនា ដែលគ្មានអ្នកណាអើពើជាមួយ។ ព្រោះតែវត្តមានរបស់វៀតកុង ធ្វើសកម្មភាពទិញស្បៀងនៅកម្ពុជា និងឆ្លងដែនទៅវាយប្រហារកងទ័ពអាមេរិកនៅវៀតណាមខាងត្បូង។ ពេលពួកនោះដកថយមកវិញ អាមេរិកដឹងថា ឆ្លងដែនមកជ្រកកោននៅតាមព្រៃ និងភូមិដ្ឋានប្រជាជនខ្មែរ ទើបពួកគេតាមដាញទម្លាក់។ មិនត្រឹមប៉ុណ្ណោះ ជួនកាលមានមន្ត្រីរដ្ឋាភិបាលខ្មែរ ដឹកអាវុធយុទ្ធភ័ណ្ឌ និងស្បៀងអាហារទាំងឡានៗ ទៅផ្គត់ផ្គង់ឱ្យពួកវៀតកុងតែម្ដង។ អញ្ចឹងហើយ ទើបឆ្នួនភ្លើងសង្គ្រាមឥណ្ឌូចិនលើកទី២ បានគម្រាមកំហែងកម្ពុជាចុងសម័យសង្គមរាស្ត្រនិយមយ៉ាងទំុដោរណាស់ទៅហើយ។

ទោះបីជាយ៉ាងណាក៏ដោយ អ្នកនិពន្ធសៀវភៅក្រោមចំណងជើងថា "ខ្មែរក្រោក"(Khmer Stand Up!) ឈ្មោះ ចាស្ទីន ខូហ្វៀល (Justine Coffield) បានឱ្យតម្លៃថា "យុគសម័យមាសនៃប្រវត្តិសាស្ត្រខ្មែរសម័យទំនើប គឺនៅសម័យសង្គមរាស្ត្រនិយម" ក្រោមព្រះរាជកិច្ចដឹកនាំរបស់សម្ដេច ព្រះនរោត្តម សីហនុ។ ព្រោះគាត់ផ្អែកលើការរីក

---

[108] បទសម្ភាសន៍របស់ខ្ញុំជាមួយ មនុស្ស១០នាក់អាយុចន្លោះ៥២-៦២ឆ្នាំ នៅខេត្តកំពង់ចាម–ព្រៃវែង កាលពីខែមេសាឆ្នាំ២០០៥។ ពួកគាត់ពេលចូលរួមព្រឹត្តិការណ៍នោះ ខ្លះជាសិស្សអនុវិទ្យាល័យ–វិទ្យាល័យ និងជាអ្នកស្រុកធម្មតា ដែលទើបការប្រពន្ធរួច។

ចម្រើននៃវិស័យសិក្សាធិការ, សុខាភិបាល, ឧស្សាហកម្ម និងយុត្តាធិការ ជាពិសេសកម្រិតជីវភាពយ៉ាងសមរម្យរបស់មន្ត្រីរាជការ ដោយសារបានទទួលប្រាក់បៀវត្សរ៍ខ្ពស់។ មនុស្សដែលរស់នៅក្នុងរបបនយោបាយបន្តបន្ទាប់មកទៀត ហូតដល់សព្វថ្ងៃ នៅតែលើកសរសើរ និងស្រមៃចង់បានសង្គមមួយដូចនោះឡើងវិញ៕

# មេរៀនទី 12 របបសាធារណរដ្ឋខ្មែរ

សាធារណរដ្ឋខ្មែរជាឈ្មោះរបបនយោបាយមួយ ដែលលេចឡើងនៅចន្លោះឆ្នាំ១៩៧០ដល់១៩៧៥បន្ទាប់ពីព្រឹត្តិការណ៍ជាតិធំមួយបានកើតឡើង គឺរដ្ឋសភា ដកសេចក្តីទុកចិត្តចំពោះសម្តេចព្រះនរោត្តម សីហនុ នៅថ្ងៃទី ១៨ មីនា ឆ្នាំ១៩៧០។

## 1. ការទម្លាក់សម្តេច នរោត្តម សីហនុ

របបសាធារណរដ្ឋខ្មែរ មានកំណើតក្រោយព្រឹត្តិការណ៍ ១៨ មីនា ១៩៧០។ មានមតិជាតិ និងអន្តរជាតិជាច្រើនយល់ថា មានមនុស្ស៣រូប គឺលោក លន់ នល់, សិរិមតៈ និងលោក អ៊ិន តាំ ជាមេគំនិតនាំឱ្យមានព្រឹត្តិការណ៍នេះ។ ប៉ុន្តែបើតាមលោក រស់ ចន្ត្រាបុត្រ ក្នុងសៀវភៅ"សាធារណរដ្ឋខ្មែរ"ហាក់ដូចជាចង់បង្ហាញថា នៅមានមនុស្សទី៤ម្នាក់ទៀត គឺលោក លន់ ណុន ត្រូវជាប្អូនរបស់លោក លន់ នល់ ដែលជាអ្នករៀបចំផែនការទាំងអស់ក្នុងការដកហូតតំណែងសម្តេច នរោត្តម សីហនុ។

រហូតមកដល់សព្វថ្ងៃ មជ្ឈដ្ឋានអ្នកសិក្សានៅតែអះអាងអំពីការទម្លាក់សម្តេច ព្រះនរោត្តម សីហនុ ពីព្រះប្រមុខរដ្ឋនៅខែមីនា១៩៧០ ក្នុងយោបល់ពីរផ្ទុយគ្នា គឺនោះជាព្រឹត្តិការរដ្ឋប្រហារខុសច្បាប់ និងទី២ថា ជាការទម្លាក់ពីអំណាចដោយស្របច្បាប់រដ្ឋធម្មនុញ្ញ។ ដូចគ្នានេះដែរ ព្រះមហាក្សត្រ នរោត្តម សីហនុ នៅតែចោទថា លោក លន់ នល់ ធ្វើរដ្ឋប្រហារខុសច្បាប់ប្រឆាំងនឹងព្រះអង្គ ចំណែកពួកមន្ត្រីជាន់ខ្ពស់ ដែលមានភក្តីភាពជាមួយរបបសាធារណរដ្ឋខ្មែរថា នោះជាការទម្លាក់ដោយសមាជិកសភារបស់សម្តេច សីហនុ។ ព្រោះសមាជិកសភារបស់ព្រះអង្គ ជាអ្នកបោះឆ្នោតដកសេចក្តីទុកចិត្តពីព្រះអង្គ ក្រោមមូលហេតុចោទថា ព្រះអង្គមានការទាក់ទងជាមួយវត្តមានវៀតកុងនៅលើដីខ្មែរនៅពេលនោះ។

ចំណែក មតិសាធារណៈ ដែលគេធ្លាប់មានបទពិសោធន៍ឆ្លងកាត់ព្រឹត្តិការណ៍នោះ យល់ផ្ទុយទៅវិញថា នោះជាដំណើរល្បិចកលនយោបាយដ៏ស្ទាត់កំបាំងមួយរបស់សម្តេច ន. សីហនុ និងលោក លន់ នល់ ក្នុងការដោះស្រាយបញ្ហាវៀតណាម និងវៀតកុងនៅកម្ពុជា អំឡុងពេលសង្គ្រាមឥណ្ឌូចិនលើកទី២។ ព្រោះ គេជឿថា ឥស្សរជនខ្មែរទាំងពីររូបនេះ បានព្រមព្រៀងគ្នាជាមុន ដើម្បីសម្តែងល្ខោននយោបាយ មួយឆាកដោយមួយដើរតួអាក្រក់ ហើយមួយទៀតដើរតួទេវតា។

ដោយគេមានជំនឿថា ៖

- លន់ នល់ ជាមនុស្សនិយមជឿលើបញ្ហាអបិយជំនឿយ៉ាងងប់ងល់ ដែលមិនអាចឱ្យគាត់ហ៊ានក្បត់សម្តេចជាអម្ចាស់ ដែលគាត់ជាប់ស្បថស្បែរថា ស្មោះស្ម័គ្រភក្តីជាមួយនោះទេ។
- សម្តេច សីហនុ ធ្លាប់មានបន្ទូល អំពីលទ្ធភាពនៃការដកថយពីអំណាចរបស់ព្រះអង្គ នៅក្នុងសន្និសីទកាសែតមួយនៅលើកំពូលភ្នំបូកគោ កាលពីឆ្នាំ១៩៦៧។ ទ្រង់មានបន្ទូលថាក្នុងករណីព្រះអង្គដកព្រះកាយចេញពីរដ្ឋាភិបាលទៅ ក្នុងចំណោមរជនទាំងអស់ ទំនងជាព្រះអង្គទុកព្រះទ័យប្រគល់ឱ្យតែលោក លន់ នល់ ទេ ធ្វើជាអ្នកស្នង។

- ព្រះអង្គ ហាក់មានការប្រញាប់ប្រញាល់ ដោយគ្មានហេតុផលសមស្រប ក្នុងការចាកចេញទៅព្យាបាលព្រះរោគនៅអឺរ៉ុប តាំងពីថ្ងៃទី៦មករា១៩៧០។ ដោយចេញពីមន្ទីរពេទ្យកាល់ម៉ែត្រហើយ ឆៀងចូលព្រះរាជវាំងតែប៉ុន្មានម៉ោងប៉ុណ្ណោះ ដើម្បីទទួលពិធីជយន្តោពីព្រះមហាសង្ឃរាជ រួចក៏ចាកចេញទៅក្រៅប្រទេស ដោយនាំទៅជាមួយនូវសមាជិកយ៉ាងច្រើន នៃគណៈរដ្ឋមន្ត្រីរបស់រដ្ឋាភិបាលស្រោចស្រង់ជាតិ របស់លន់ នល់។
- មុនពេលលោក លន់ នល់ វិលត្រឡប់មកកម្ពុជាវិញពីទីក្រុងប៉ារីស នៅថ្ងៃ១៨កុម្ភៈ១៩៧០ បានចូលជួបសវនាការជាមួយ សម្តេចសីហនុ នៅទីក្រុងប៉ារីស អស់រយៈពេលជាច្រើនម៉ោង។
- ក្រោយព្រឹត្តិការណ៍ ១៨មីនា គាត់ហាក់ដូចជា ខំប្រឹងក្តាប់អំណាចនៅក្នុងដៃជានិច្ច ទោះបីគាត់មានសុខភាពមិនល្អក្តី ប្រៀបដូចជាគាត់ខំរក្សាអំណាចឯកភាពគ្នា ដើម្បីអ្នកណាម្នាក់។

ប៉ុន្តែទោះជាមានហេតុផលបែបនេះក្តី យើងឃើញថា មេដឹកនាំនយោបាយទាំងពីរ មិនបានរួបរួមគ្នាវិញឡើយ នៅពេលវៀតកុងដកកងទ័ពរបស់ខ្លួនចេញពីកម្ពុជាអស់ ក្រោយសន្ធិសញ្ញាយុទ្ធសន្តិភាពនៅក្រុងប៉ារីសខែមករាឆ្នាំ១៩៧៣រវាងអាមេរិក និងវៀតណាមខាងជើង។ ផ្ទុយទៅវិញ មេដឹកនាំទាំងពីររូប បានប្រកាសដាច់អហំង្ការមិនចរចាគ្នា ដើម្បីបញ្ចប់សង្គ្រាមឡើយ។ ដូច្នេះ បើមេដឹកនាំទាំងពីរបោតរៀបចំឆាកល្ខោនដើម្បីដេញវៀតណាម និងវៀតកុងចេញពីកម្ពុជាមែន ពួកគេគួរតែរួបរួមគ្នាវិញនៅពេលនោះ។ ដើម្បីឧត្តមប្រយោជន៍ជាតិខ្មែរទាំងមូល ពួកគេមិនចាំបាច់ប្រកាសយកឈ្នះគ្នាដោយចុងកាណុងនោះទេ។

## 2. សង្គ្រាម និងការទម្លាក់គ្រាប់បែករបស់អាមេរិក

ក្រោយពីការប្រកាសទម្លាក់សម្តេច ន. សីហនុ សហរដ្ឋអាមេរិកបានប្រកាសទទួលស្គាល់របបថ្មី និងសន្យាផ្តល់ជំនួយឧបត្ថម្ភយ៉ាងច្រើន ទាំងខាងសេដ្ឋកិច្ច និងយោធា។ នោះដោយសារ មេដឹកនាំធ្លាប់ជាពួកស្និទ្ធនឹងអាមេរិកស្រាប់ ហើយកម្ពុជា នៅតែជាប្រទេសយុទ្ធសាស្ត្រមួយសម្រាប់អាមេរិក ក្នុងការធ្វើសង្គ្រាមទប់ការរីករាលដាលនៃមនោគមវិជ្ជាកុំមុយនីស។ សហរដ្ឋអាមេរិកបានបញ្ចុះបញ្ចូលកម្ពុជាតាំងពីឆ្នាំ១៩៥៤ ឱ្យចូលរួមក្នុងការធ្វើជាសមាជិកនៃអង្គការសន្ធិសញ្ញាអាស៊ីអាគ្នេយ៍ SEATO ។

ដោយសម្តេច សីហនុ រួមដៃជាមួយពួកខ្មែរក្រហម និងយល់ព្រមឱ្យវៀតណាមខាងជើងជួយជ្រោមជ្រែងក្នុងការវាយប្រហារដណ្តើមអំណាចពីពួកប្រតិកិរិយា លន់ នល់ ដែលជាបរិវាររបស់ចក្រពត្តិអាមេរិក ទើបពួកវៀតកុងមានលេសស្របច្បាប់ និងកាន់តែបើកចំហពង្រាយគ្នាពេញជនបទនៃប្រទេសកម្ពុជា ដើម្បីធ្វើសង្គ្រាមទ័ពព្រៃប្រឆាំងនឹងរបបលន់ នល់។

ការទម្លាក់គ្រាប់បែករបស់អាមេរិក ដែលកាលពីមុនធ្វើនៅតាមតំបន់ជាប់ព្រំដែនខ្មែរ–វៀតណាមខាងត្បូងបន្តិចម្តងៗ បានទម្លាក់នៅលើផ្ទៃដី២ភាគ៣នៃប្រទេសកម្ពុជា ដើម្បីប្រឆាំងនឹងពួកវៀតកុង ក្រោមការស្នើសុំអន្តរាគមន៍ ដោយស្របច្បាប់ពីរដ្ឋាភិបាលភ្នំពេញ។ ព្រោះកងកម្លាំងរបស់លន់ នល់ ក៏មិនអាចទប់ទល់ជាមួយពួកវៀតកុងដោយប្រើត្រឹមតែកងទ័ពថ្មើរជើងបាន។ គួរកត់សម្គាល់ថា វិនាសកម្មនៃការទម្លាក់គ្រាប់បែកលើកម្ពុជា មិនសូវប៉ះទៅលើមូលយោធាដូចក្តីប្រាថ្នារបស់អាមេរិកឡើយ។ ផ្ទុយទៅវិញ ប្រជារាស្ត្រ និងផ្ទះសម្បែងរបស់ពួកគាត់នៅតាមជនបទឯណោះទេ ដែលត្រូវរងគ្រោះ និងកាន់តែរស់ក្នុងជីវភាពតោកយ៉ាកខ្លោចផ្សារ ដោយការមិនហ៊ានចេញទៅប្រកបការងារ ស្រែចម្ការ និងនេសាទដូចសព្វដង។

ចំណែកពួកកុម្មុយនិស្ត កម្ពុជាដែលមានសម្តេច សីហនុ ជាប្រមុខចលនា បានឱកាសល្អ ក្នុងការកសាងកងកម្លាំងប្រយុទ្ធ និងកម្មាភិបាលបង្គោលរបស់ខ្លួន ក្រោមផ្លាករណសិរ្សរួបរួមជាតិកម្ពុជា និងការអំពាវនាវឱ្យចូលព្រៃធ្វើសង្គ្រាមរំដោះជាតិពីក្រញាំចក្រពត្តិអាមេរិករបស់សម្តេច សីហនុ។ ដូច្នេះ អំណាចពិតប្រាកដ មិនបាននៅក្នុងព្រះហស្តរបស់ព្រះអង្គ ដែលតែងតែគង់ប្រថាប់នៅក្នុងទីក្រុងប៉េកាំងនោះទេ។ ពួកខ្មែរក្រហម បានឱកាស ធ្វើអ្វីៗស្រេចនឹងចិត្ត ដែលពួកគេចង់បាន ដូចដែលលោក អ៊ិត សារិន ធ្លាប់បានផ្សព្វផ្សាយនៅក្នុងសៀវភៅ «**ស្រណោះព្រលឹងខ្មែរ**» របស់គាត់ឱ្យប្រជាជនខ្មែរដឹង កាលពីឆ្នាំ១៩៧៣ បន្ទាប់ពីគាត់បានក្លក្សរសជាតិ ដើរតាមពួកនេះ អស់៩ខែ។

ពួកនេះប្រើយុទ្ធសាស្ត្រ ″ជនបទឡោមព័ទ្ធទីក្រុង″ បែបបដិវត្តន៍កុម្មុយនិស្តរបស់ម៉ៅ សេទុង នៅប្រទេសចិន។ ហេតុនេះហើយ តាំងពីឆ្នាំ១៩៧០ ពួកវៀតកុងជាសម្ព័ន្ធមិត្តរបស់គេ បានវាយប្រហារផ្តាច់ផ្លូវសេដ្ឋកិច្ចរបស់សាធារណរដ្ឋខ្មែរ និងកាន់កាប់តំបន់ជនបទដាច់ស្រយាលទូទាំងប្រទេស។ មូលដ្ឋានបង្អែកបែបនេះបានបង្កការលំបាកយ៉ាងខ្លាំងដល់កងទ័ពសាធារណរដ្ឋខ្មែរ។ ជាបន្តបន្ទាប់ ផ្លូវសេដ្ឋកិច្ចសំខាន់ៗ ត្រូវកាត់ផ្តាច់ទាំងស្រុងនៅឆ្នាំ១៩៧៣។ ទីរួមខេត្តនៅឆ្ងាយពីភ្នំពេញទាំងអស់ ត្រូវឡោមព័ទ្ធជាប់ដោយពួករំដោះនៅឆ្នាំ១៩៧៣ដែរ។ ដូច្នេះពីភ្នំពេញទៅកាន់ទីក្រុងទាំងនោះ អាចទាក់ទងគ្នាបានតែតាមផ្លូវអាកាស។

ដោយសារសន្ធិសញ្ញាបញ្ចប់សង្គ្រាមនៅក្រុងបារីសឆ្នាំដដែលនេះ រវាងវៀតណាមខាងជើង និងអាមេរិក ពួកខ្មែរក្រហម បានទាមទារឱ្យវៀតកុង ដកកងទ័ពថយពីកម្ពុជាដែរ។ ដោយសារគេសង្ឃឹមថា កងកម្លាំងរបស់គេ អាចម្ចាស់ការវាយប្រហារផ្តាច់ព្រ័ត ដណ្តើមយកទីក្រុងទាំងឡាយរបស់សាធារណរដ្ឋខ្មែរបាន។ ព្រោះ កងកម្លាំងប្រយុទ្ធធំរបស់សាធារណរដ្ឋខ្មែរ ត្រូវបំបែកបំបាក់ខ្ទេចខ្ទាំ ចុះខ្សោយអស់ ដោយពួកវៀតកុង។ ពួកខ្មែរសង្ឃឹមថា នឹងច្បាមយកអំណាចបានទាំងស្រុង ដោយគ្មានអ្វីអាចរារាំងបាន។ មកដល់ឆ្នាំ១៩៧៤ ពួកគេ បានកំណត់ថ្ងៃចុងក្រោយរបស់សាធារណរដ្ឋខ្មែរជាស្រេច ដូចមានសេចក្តីក្នុងបទចំរៀងជាច្រើនបទ ដែលគេបានហាត់រៀនច្រៀង និងថតទុកចាក់ផ្សាយនៅថ្ងៃជ័យជម្នះ១៧មេសា១៩៧៥។ ជាការពិតណាស់ ក្តីសង្ឃឹមរបស់ពួកគេ ដោយសារការក្តាប់បានអំពីនយោបាយការបរទេសរបស់អាមេរិក ដែលសម្រេចដកចេញពីវៀតណាមខាងត្បូង និងបញ្ឈប់រាល់ជំនួយយោធាដល់ប្រទេសនៅឥណ្ឌូចិនរួមទាំងរដ្ឋាភិបាលភ្នំពេញផង នៅឆ្នាំ១៩៧៣។

យុទ្ធសាស្ត្រសង្គ្រាមបំភ្លៃ ត្រូវគេបង្កើតឡើង ដើម្បីគៀរគយ និងឃោសនាប្រមូលកម្លាំងទ័ពរៀងៗខ្លួន គឺខាងលន់ នល់ ព្យាយាមបង្ហាញត្រឹមតែថា សាធារណរដ្ឋខ្មែរ កំពុងតែធ្វើសង្គ្រាមប្រឆាំងពួកយួនឈ្លានពាន ហៅ វៀតកុង។ ចំណែកពួកវៀតកុង ឃោសនាប្រាប់ប្រជាជនខ្មែរដែលភាគច្រើនលើសលប់ នៅមានភក្តីភាពចំពោះសម្តេច ន. សីហនុ ថា ពួកគេប្រយុទ្ធប្រឆាំងកងកម្លាំងរបស់ជនក្បត់លន់ នល់ ដើម្បីយកអំណាចថ្វាយសម្តេច សីហនុវិញ។ ចំណែកភាគីរណសិរ្សរួបរួមជាតិកម្ពុជា ប្រកាសថា គេធ្វើសង្គ្រាម ដើម្បីរំដោះកម្ពុជាពីនឹមចក្រពត្តិអាមេរិក និងបរិវារ លន់ នល់ ដែលលក់ជាតិទឹកដី។ ដូច្នេះ ពួកគេប្រយុទ្ធប្រឆាំងនឹងកងទ័ពអាមេរិកឈ្លានពាន។ ជាលទ្ធផល ប្រជាជនខ្មែរជាអ្នកចាញ់ ពីព្រោះឈាមខ្មែរហូរគ្រប់នាទី ជីវិតប្រជាជនខ្មែររាប់ម៉ឺននាក់ត្រូវស្លាប់ដោយសង្គ្រាមអន្តរជាតូបនីយកម្មនេះ។

### 3. អំពើពុករលួយ

រដ្ឋាភិបាលសាធារណរដ្ឋខ្មែរ ពោរពេញទៅដោយមនុស្សហៃអើនិយម សីហនុនិយម បក្សពួកនិយម និងអញនិយម។

គេឃើញហេតុការណ៍នៃការដណ្តើមអាចគ្នា វាតឥទ្ធិពលលើគ្នា ដោយភ្លេចគិតផលប្រយោជន៍ជាតិជាធំ។ ជាពិសេសរវាងបក្សសម្ព័ន្ធដង្កោ-ដងរែកបស់លោក សឺង ង៉ុកថាន់ និងបក្សពួករបស់ លន់ ណុន ដែលមានអំណាចវាតទីនៅក្នុងទីក្រុងស្រាប់។ ពួកគេប្រជែងគ្នា ដើម្បីកាន់កាប់តំណែងក្នុងគណៈរដ្ឋមន្ត្រី។

ដោយសារឆ្នួននៃអំពើពុករលួយ ដែលលេចឡើងតាំងពីឆ្នាំ១៩៦៦ គេមិនអាចបង្ក្រាបបាន នៅសល់កាន់ច្រើនស្មុគស្មាញ និងខ្លាំងឡើង ក្រោយព្រឹត្តិការណ៍១៨មីនា បានបង្កការលំបាកដល់រដ្ឋាភិបាលនេះកាន់តែទ្វេឡើង។ មន្ត្រីរដ្ឋការកាន់តែច្រើន បានធ្លាក់ខ្លួនពុលនៅក្នុងអំពើពុករលួយ។ អ្នកនិពន្ធសៀវភៅប្រវត្តិសាស្ត្រសម័យនេះជាច្រើននាក់ បានឯកភាពចំពោះការឆក់ឱកាសពុករលួយរបស់នាយទាហាន និងមន្ត្រីស៊ីវិល។ អតីតនាយទាហាន និងភរិយានាយទាហានធ្លាប់បាននិយាយថា ដើម្បីបានលុយពីបេសកកម្ម និងទាហានខ្មោច(មានតែឈ្មោះ) នាយទាហានធ្វើជាស្ម័គ្រចិត្តឡើងសមរភូមិ។ លោកស្រីម្នាក់ឈ្មោះ ហ... ធ្លាប់បានអះអាងថា ធ្លាប់រស់នៅផ្ទះរបស់លន់ នល់ អាចចេញចូលផ្ទះលន់ នល់បានគ្រប់ពេល និងអាចរត់ការឡើងតំណែងផ្សេងៗឱ្យមន្ត្រីណាៗ ដែលហ៊ានសូកយកតំណែងសំខាន់ៗ។ គាត់មានប្តីជាវរសេនីយត្រីម្នាក់ ដែលតែងតែដោះស្រាយភាពអផ្សុករបស់គាត់ ដោយដឹកទៅដាក់ផ្ទះលោកស្រី ឬជំទាវដទៃទៀត ដើម្បីប្រជុំគ្នាលេងបៀរ។ ដោយសារគាត់លេងចាញ់អស់លុយច្រើន ហើយគ្មានលុយច្រើនសម្រាប់លេងដូចពេលមុន ក៏លួចស្ម័គ្រចិត្តទៅបំពេញបេសកកម្មសិកនៅខេត្តស្វាយរៀង។ គ្រាន់តែរថយន្តប្តីគាត់ទៅដល់គោលដៅភ្លាម ត្រូវកងទ័ពវៀតកុងវាយប្រហារសង្គ្រប់សម្លាប់ចោល។ គាត់និយាយប្រាប់ខ្ញុំនៅដើមឆ្នាំ១៩៩៤ ដោយបន្ទោសទាំងខ្មោចប្តីគាត់ថា សមមុខគាត់ហើយ ដែលចេញធ្វើបេសកកម្ម ដើម្បីបានលាភសក្ការៈយកមកឱ្យគាត់ ដោយមិនប្រាប់គាត់ជាប្រពន្ធមួយម៉ាត់។

មានសាច់រឿងជាច្រើនដែលនិយាយអំពីអំពើក្បត់លក់ពត៌មានកងទ័ព និងលួចរាយការណ៍សកម្មភាពសិករបស់សាធារណរដ្ឋខ្មែរ។ ទន្ទឹមនោះ មានមេទ័ពដែលមានចេតនាបំបាក់កងកម្លាំងទ័ពណា ដែលមានវីរភាពក្នុងការប្រយុទ្ធ ដូចជាពួកកន្សែងស, កន្សែងក្រហម ឬទព័កណ្តុររបស់សឺង ង៉ុកថាន់ជាដើម។ ព្រោះ ខ្លាចកងទ័ពនោះល្បីខ្លាំង ដោយសារតែថ្វីដៃ ភាពតស៊ូអត់ធ្មត់ និងជោគជ័យលើសមរភូមិរបស់ពួកគេ។

ដោយសារភាពស្រមើស្រមៃ និងក្តីជឿជាក់ថា សម្តេចសីហនុ ជាប្រមុខនៃកងទ័ពរំដោះស្រាប់ នៅពេលណាភាគីព្រះអង្គឈ្នះ ក៏ខ្លួននៅតែអាចធ្វើមន្ត្រីរាជការបានតទៅទៀត មុខជាគ្មានបញ្ហាកាប់សម្លាប់គ្នាកើតឡើងនោះ ពួកគេរាយមាយធ្វេសប្រហែសក្នុងការបំពេញភារកិច្ចបម្រើរដ្ឋាភិបាលលន់ នល់ តាមតួនាទី និងការទទួលខុសត្រូវរបស្វខ្លួនក្នុងតំណែង។ លើសនេះទៀត ពួកគេរវកម្ម និងចារកម្មរបស់វៀតកុង ក៏ដូចពួកខ្មែរក្រហម អាចលាក់ខ្លួនធ្វើសកម្មភាពបង្កវិច្ឆេទកម្មក្នុងរដ្ឋាភិបាលបានយ៉ាងងាយ។

លើសនេះទៀត នាយទាហានរបស់សាធារណរដ្ឋខ្មែរ លួចលក់អាវុធបរិក្ខាសឹករបេបរបស់កងទ័ពខ្លួនឱ្យពួកខ្មែរក្រហម យកមកបាញ់ប្រហារក្រុមរបស់ខ្លួនវិញ។ មនុស្សលាមកបែបនោះ គេអាចរាប់បានទាំង លន់ ណុន ប្អូនប្រុសរបស់លន់ នល់ផងដែរ។ ពួកមន្ត្រី នាយទាហានដែលមានគុណបំណាច់ចំពោះខ្មែរក្រហមទាំងនោះ និងពួកអ្នកជឿលង់ការឃោសនាដ៏ផ្អែមល្ហែមរបស់ខ្មែរក្រហម គេអាចសម្គាល់ឃើញថា នៅថ្ងៃ១៧មេសា មិនសូវចាប់អារម្មណ៍រកផ្លូវរត់គៀសខ្លួននោះទេ។ ប៉ុន្តែគេថែមទាំងនាំគ្នាទៅកាន់មុខក្រសួងឃោសនាការ តាមការអំពាវនាវតាមវិទ្យុជាតិដោយពួកខ្មែរក្រហម ដើម្បីពិភាក្សាគ្នារឿងផែនការរៀបចំកសាងរបបថ្មីជាមួយគ្នា។ ម្លោះហើយ ពួកគេត្រូវខ្មែរក្រហមនាំយកទៅបាញ់ចោលបានយ៉ាងងាយស្រួលបំផុត។

## 4. រដ្ឋាភិបាលសាធារណរដ្ឋខ្មែរ

ថ្វីបើស្រុកមានសង្គ្រាម តែរដ្ឋាភិបាលរបស់ លន់ នល់ បានខិតខំបង្ហាញឱ្យគេឃើញពីទម្រង់នៃលទ្ធិប្រជាធិបតេយ្យដែលមានការបោះឆ្នោត,មានស្ថាប័នសភាពីរថ្នាក់(ព្រឹទ្ធសភា និងសភា),រដ្ឋាភិបាល និងតុលាការ។ ដើម្បីដោះស្រាយសភាពការណ៍ដែលកាន់តែធ្ងន់ធ្ងរ លន់ នល់ ក្នុងនាមប្រធានាធិបតី ឬប្រមុខរដ្ឋ បានតែងតាំងឥស្សរជនជាច្រើនរូបបន្តបន្ទាប់គ្នា ឱ្យបង្កើតគណៈរដ្ឋមន្ត្រី។

ក្នុងអំឡុងពេល៥ឆ្នាំនោះ មានរដ្ឋាភិបាល១០ ត្រូវបានបង្កើតឡើង ដូចជា ៖

ទី១- រដ្ឋាភិបាលទី១ របស់លន់ នល់ ពីថ្ងៃទី២កក្កដា១៩៧០–៥ឧសភា១៩៧១[109]
ទី២- រដ្ឋាភិបាលទី២ របស់លន់ នល់ ពីថ្ងៃទី៥ឧសភា១៩៧១-១២មីនា១៩៧២[110]
ទី៣- រដ្ឋាភិបាលទី៣ របស់ សឺង ង៉ុកថាន់ ពីថ្ងៃទី២០មីនា១៩៧២-១៤តុលា១៩៧២[111]
ទី៤- រដ្ឋាភិបាលទី៤ របស់ ហង្ស ធុនហាក់ ពីថ្ងៃទី១៧តុលា១៩៧២-១៧មេសា១៩៧៣[112]
ទី៥- រដ្ឋាភិបាលទី៥ របស់ អ៊ិន តាំ ពីថ្ងៃទី១៥ឧសភា១៩៧៣-២២តុលា១៩៧៣[113]
ទី៦- រដ្ឋាភិបាលទី៦ របស់ អ៊ិន តាំ ពីថ្ងៃទី២២តុលា១៩៧៣-២៦ធ្នូ១៩៧៣[114]

---

[109] ឧត្តមសេនីយទោ លន់ នល់ ជានាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងការពារជាតិ (គណៈរដ្ឋមន្ត្រីទី៣), ឧត្តមសេនីយ ស៊ីសុវត្ថិ សិរិមតៈ ជាឧបនាយករដ្ឋមន្ត្រី, លោក យ៉ែម សំបូរ ជាទេសរដ្ឋមន្ត្រី ទទួលបន្ទុកយុត្តាធិការ។

[110] សេនាប្រមុខ លន់ នល់ ជាប្រធានាធិបតី (គណៈរដ្ឋមន្ត្រីទី៤), ឧត្តមសេនីយ៍ទោ ស៊ីសុវត្ថិ សិរិមតៈ ជាប្រតិភូប្រធានាធិបតី និងជារដ្ឋមន្ត្រីក្រសួងការពារប្រទេស, ឧត្តមសេនីយ អ៊ិន តាំ ជាអនុប្រធានាធិបតី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ....
លោក សុខ ឈង ជាអនុប្រធានាធិបតី ទី២ និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច ,លោក ហង្ស ធុនហាក់ ជាអនុប្រធានាធិបតី ទី៣ និង ជារដ្ឋមន្ត្រីទទួលបន្ទុកអភិវឌ្ឍន៍សហគមន៍ ។

[111] លោក សឺង ង៉ុកថាញ់ ជានាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការបរទេស , លោក យ៉ែម សំបូរ ជាទេសរដ្ឋមន្ត្រីទទួលបន្ទុកយុត្តាធិការ វេជ្ជ បណ្ឌិត ម៉ៅ សាយ ជាទេសរដ្ឋមន្ត្រី អនុព័ន្ធរបស់ប្រធានាធិបតីរបស់សាធារណរដ្ឋ , ឧត្តមសេនីយ សក់ ស៊ុត សាខន ជាទេសរដ្ឋមន្ត្រីទទួលបន្ទុកក្រសួងការពារជាតិ , លោក ផ្លែក ឆាត ជាទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការជំនួនបរទេស និងអភិវឌ្ឍន៍ , ឧត្តមសេនីយ៍ ឋបនា ឌិន ជាទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លោក ឡុង បូរ៉េត ជារដ្ឋមន្ត្រី ក្រសួង ពត៌មាន។

[112] លោក ហង្ស ធុនហាក់ ជា នាយក រដ្ឋមន្ត្រី , វេជ្ជ បណ្ឌិត ម៉ៅ សាយ ជា ទេសរដ្ឋមន្ត្រី អនុព័ន្ធ ជាមួយ ខុទ្ទកាល័យប្រធានាធិបតីសាធារណរដ្ឋ , លោក ឆន សុខុម ជាទេសរដ្ឋមន្ត្រី ទទួលបន្ទុកយុត្តាធិការ, ឧត្តមសេនីយ៍ ឋបនា ឌិន ជាទេសរដ្ឋមន្ត្រី ទទួលបន្ទុកក្រសួងការពារជាតិ, ឧត្តមសេនីយ៍ សរ ហោ ជាទេសរដ្ឋមន្ត្រី ទទួលបន្ទុកក្រសួងមហាផ្ទៃ និង សាសនា , លោក ហែម កេតសាណា ជារដ្ឋមន្ត្រីអនុព័ន្ធខុទ្ទកាល័យនាយក រដ្ឋមន្ត្រី , លោក ឡុង បូរ៉េត ជារដ្ឋមន្ត្រីក្រសួងការបរទេស។

[113] ឧត្តមសេនីយ៍ អ៊ិន តាំ ជានាយករដ្ឋមន្ត្រី (លើកទី១),វេជ្ជបណ្ឌិត ម៉ៅ សាយ ជាទេសរដ្ឋមន្ត្រី អនុព័ន្ធជាមួយខុទ្ទកាល័យប្រធានាធិបតីសាធារណរដ្ឋ, លោក ឆន សុខុម ជាទេសរដ្ឋមន្ត្រី ទទួលបន្ទុកនាយកដ្ឋានរបស់នាយករដ្ឋមន្ត្រី។

[114] ឧត្តមសេនីយ៍ អ៊ិន តាំ ជានាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីមហាផ្ទៃ ,សាសនា និងកំណែនទូទៅ, លោក ហង្ស ធុនហាក់ ជាឧបនាយករដ្ឋមន្ត្រីទី១ រដ្ឋមន្ត្រីទទួលបន្ទុកទំនាក់ទំនងរដ្ឋសភា ,សម្របសម្រួលនាយកដ្ឋានចរបា និងសន្តិភាព , វប្បធម៌ , សកម្មភាពសង្គម និងអ្នកភៀសខ្លួន , លោក ឱប គឹមអាង ជាឧបនាយករដ្ឋមន្ត្រី ទី២ រដ្ឋមន្ត្រីទទួលបន្ទុកការងារសាធារណៈ សម្របសម្រួលនាយកដ្ឋាន អភិវឌ្ឍន៍សហគមន៍, ការងារ, សុខមាលភាពសាធារណៈ, ការងារប្រៃសណីយ៍ទូរគមនាគមន៍ និងទេសចរណ៍ ឧត្តមសេនីយ៍ ឋបនា ឌិន ជាឧបនាយករដ្ឋមន្ត្រី ទី៣ រដ្ឋមន្ត្រីទទួលបន្ទុកការពារជាតិ, សម្របសម្រួល នាយកដ្ឋានពត៌មាន, សុខភាពសាធារណៈ, ព្រឹទ្ធបុរសចំពោះកិច្ច និងជនរងគ្រោះក្នុងសង្គ្រាម។

ទី៧- រដ្ឋាភិបាលទី៧ របស់ ឡុង បូរ៉េត ពីថ្ងៃទី២៦ធ្នូ១៩៧៣-១៦មិថុនា១៩៧៤[115]
ទី៨- រដ្ឋាភិបាលទី៨ របស់ ឡុង បូរ៉េត ពីថ្ងៃទី១៦មិថុនា១៩៧៤-២១មីនា១៩៧៥[116]
ទី៩- រដ្ឋាភិបាលទី៩ របស់ ឡុង បូរ៉េត ពីថ្ងៃទី២១មីនា១៩៧៥-១២មេសា១៩៧៥[117]
ទី១០-គណៈកម្មាធិការជាន់ខ្ពស់ ( the Supreme Committee )[118]

គណៈរដ្ឋមន្ត្រីនេះ បានបង្ហាញការខិតខំបិតភ្ជិតស្នាមប្រេះឆារបស់ពួកវរជននៃរបបសាធារណរដ្ឋខ្មែរ។ គេឃើញការព្យាយាមបោះបាល់អំណាចឱ្យគ្នាទៅវិញទៅមក រវាងវរជននៅក្នុងគណ្សនយោបាយបី គឺក្រុមលន់ នល់ ដែលមានឡុង បូរ៉េត នៅក្នុងបក្សសង្គមសាធារណរដ្ឋរបស់លន់ណុន, សឹងង៉ុកថាញ់ ដែលមានហ្សង ធុនហាក់ នៃបក្សសម្ព័ន្ធដងរែក-ដង្គោ និងអ៊ិនតាំ តំណាងឱ្យគណបក្សសាធារណរដ្ឋ។

## 5. ថ្ងៃចុងក្រោយ នៃរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ

ដើម្បីវាយដណ្តើមទីក្រុងភ្នំពេញ ពួកខ្មែរក្រហមបានផ្តើមការវាយលុកជាបន្តបន្ទាប់ចំនួន៣លើកនៅឆ្នាំ ១៩៧៣, នៅឆ្នាំ ១៩៧៤, និងនៅឆ្នាំ ១៩៧៥ ។

ការវាយលុកលើកទី១ បានប្រព្រឹត្តិទៅពីខែឧសភាដល់ខែកក្កដា ឆ្នាំ១៩៧៣ ។ នៅពេលនោះពួកខ្មែរក្រហមដែលមានចំនួនតិច, ដែលហ្វឹកហាត់ល្មមៗ និងដែលមានអាវុធតិចតួចមិនគ្រប់គ្រាន់ដើម្បីដណ្តើមយកការសម្រេចចិត្តឡើយ ។ ប៉ុន្តែសាឡុតស ដែលបញ្ជាប្រតិបត្តិការនេះប្រហែលជាមានបំណងឈានឱ្យបានមុនសម្ព័ន្ធមិត្តវៀតណាមខាងជើងរបស់គាត់ គឺវាយយកភ្នំពេញមុនពេលដែលពួកវៀតណាមខាងជើងដណ្តើមយកបានក្រុងបានក្រុងព្រៃនគរ។[119] ការវាយលុកនៅលើកទី១នេះ កងទ័ពរបស់ខ្មែរក្រហមមិនអាចវាយកងទ័ពលន់ នល់ បានទេ។ នៅពេលដែលពួកេគដកថយទៅវិញ ពួកគេបានជម្លៀសប្រជាជនទីក្រុងរាប់ពាន់នាក់ទៅជាមួយដែរ។

ការវាយលុកនៅលើកទី២ ធ្វើឡើងនៅដើមឆ្នាំ ១៩៧៤ ពួកខ្មែរក្រហមបានប្រមូលផ្តុំឡើងវិញដើម្បីឡោមព័ទ្ធទីក្រុងភ្នំពេញ។ ប៉ុន្តែពួកខ្មែរក្រហមបានបរាជ័យនៅលើកទី២ទៀត។ បរាជ័យរបស់ពួកខ្មែរក្រហម ធ្វើឱ្យពួកគេ

---

[115] លោក ឡុង បូរ៉េត ជានាយករដ្ឋមន្ត្រី(លើកទី១), លោក ឱប គីម អាង ជាឧបនាយករដ្ឋមន្ត្រីទី១ រដ្ឋមន្ត្រីការងារសាធារណៈ ឧត្តមសេនីយ៍ ឋបនា ងិន ជាឧបនាយករដ្ឋមន្ត្រី ទី២ រដ្ឋមន្ត្រីការពារជាតិ , ព្រឹទ្ធបុរសចំពោះកិច្ច និងអ្នករងគ្រោះក្នុងសង្គ្រាម, លោក ធន សុខុម ជារដ្ឋមន្ត្រីមហាផ្ទៃ , សាសនា , កំណែនទូទៅ, សន្តិភាវូបនីយកម្ម និងការស្រុះស្រួលគ្នា។
[116] លោក ឡុង បូរ៉េត ជានាយករដ្ឋមន្ត្រី(លើកទី ២), លោក ប៉ាន់ សុធី ជាឧបនាយករដ្ឋមន្ត្រី ទី១ រដ្ឋមន្ត្រីអប់រំជាតិ និងទំនាក់ទំនងរដ្ឋសភា , ឧត្តមសេនីយ៍ ឋបនា ងិន ជាឧបនាយករដ្ឋមន្ត្រី ទី២ រដ្ឋមន្ត្រីការពារជាតិ , ព្រឹទ្ធបុរសចំពោះកិច្ច , អសុពលភាព ស្ត្រីមេម៉ាយ និងក្មេងកំព្រាដោយសារសង្គ្រាម, ការងារសាធារណៈ, និងទូរគមនាគមន៍។
[117] លោក ឡុង បូរ៉េត ជានាយករដ្ឋមន្ត្រី (លើកទី៣), លោក ហង្ស ធុនហាក់ ជាឧបនាយករដ្ឋមន្ត្រីទី១ ទទួលបន្ទុកការងារនយោបាយ បេសកកម្មពិសេស, ឧត្តមសេនីយទោ សក់ ស៊ុតសាខន ជាឧបនាយករដ្ឋមន្ត្រីទី២ រដ្ឋមន្ត្រីការពារជាតិ, លោក ប៉ាន់ សុធី ជាឧបនាយករដ្ឋមន្ត្រីទី៣ រដ្ឋមន្ត្រីអប់រំជាតិ និងទំនាក់ទំនងរដ្ឋសភា។
[118] ឧត្តមសេនីយ៍ សក់ ស៊ុតសាខនជាប្រធាន,លោក ឡុងបូរ៉េតអនុប្រធាន,លោកហង្សធុនហាក់ សមាជិក,លោកអ៊ុងប៊ុនហោ មកពីរដ្ឋសភា, លោក ឱប គីមអាង មកពីគណបក្សសាធារណរដ្ឋ, ឧត្តមសេនីយ ថង វ៉ាន់ផាំម្លួង - មកពីទាហាន, ឧត្តមសេនីយ៍ ម៉ី ស៊ីចាន់ -មកពីបុគ្គលិកទូទៅ, ឧត្តមនាវី វង់ សារិនឌី -មកពីទ័ពជើងទឹក, ឧត្តមសេនីយ៍ ជា ឈួង -មកពីទ័ពអាកាស។
[119] ប៉ុល ពត មេពេជ្ឈឃាតនៅកម្ពុជា, ទំព័រ៩២, ៩៣។

កាត់ផ្តាច់ផ្លូវគមនាគមន៍សំខាន់ៗដែលតភ្ជាប់ពីជនបទទៅទីក្រុង។ ការផ្គត់ផ្គង់ស្បៀងអាហារអាចធ្វើបានតាមការដឹកជញ្ជូនដោយយន្តហោះ ឬដោយផ្លូវទឹកប៉ុណ្ណោះ។

នៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៥ វេលាម៉ោង១រំលងអាធ្រាត្រ កាំភ្លើងធំរបស់ខ្មែរក្រហមបានចាប់ផ្តើមផ្លោងដាក់រដ្ឋធានីពីទិសខាងជើង, ខាងត្បូង, ខាងកើត និងខាងលិច។ ដោយការឡោមព័ទ្ធទីក្រុង នៅថ្ងៃបន្ទាប់ កងទ័ពរដ្ឋាភិបាលដែលដាក់ពង្រាយនៅត្រើយខាងឆ្វេងទន្លេមេគង្គបានរត់ចោលទីតាំងរបស់ពួកគេ ដើម្បីដកថយមកកាន់រាជធានី ។ នៅពេលយប់ កងទ័ពខ្មែរក្រហមដាក់ពង្រាយមីនអណ្តែតទឹកនៅតាមទន្លេ ជាហេតុធ្វើឱ្យនាវារបស់រដ្ឋាភិបាល លន់ នល់ មិនអាចធ្វើសកម្មភាពអ្វីបាន។ដូច្នេះ រដ្ឋាភិបាលមានផ្លូវជើងអាកាសតែមួយមុខប៉ុណ្ណោះសម្រាប់ការដឹកជញ្ជូនអ្វីៗដែលចាំបាច់ ។ យន្តហោះធំៗរបស់អាមេរិកាំង បានចុះចតនៅពោធិចិនតុងដោយមានផ្ទុកអង្ករ និងគ្រាប់រំសេវផង។ មិនយូរប៉ុន្មានស្ថានការណ៍មានសភាពតានតឹងរឹតតែធ្ងន់ធ្ងរឡើង អាកាសយានដ្ឋានបានស្ថិតនៅក្រោមគ្រាប់រ៉ុក្កែតរបស់ពួកខ្មែរក្រហម មិនអាចយន្តហោះធ្វើការហោះហើរនិងធ្វើការចុះចតបាន ។

នៅដើមខែមេសា ឆ្នាំ១៩៧៥ ឧត្តមសេនីយ៍ លន់ នល់ បានចេញទៅជាដំណាក់ៗ ដំបូងកោះបាលី ប្រទេសឥណ្ឌូនេស៊ី រួចហូណូលូលូ(Honolulu)"កោះហាវ៉ៃ" ជាទីដែលគាត់សុំបានសិទ្ធិជ្រកកោនពីរដ្ឋាភិបាលអាមេរិក។ បើតាមលោក ឆាង សុង បានអះអាងថា ការចាកចេញនោះ គឺជារដ្ឋប្រហារសម្ងាត់មួយ ដែលបានបង្ខំគាត់ឱ្យត្រូវតែចាកចេញ ដើម្បីរកមធ្យោបាយចរចាជាមួយពួក GRUNK (រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា)របស់សម្តេច សីហនុ។

នៅថ្ងៃទី១២ ខែមេសា គឺវេនរបស់ឯកអគ្គរដ្ឋទូតអាមេរិកាំង ហ្សុនហ្គាន់ធ័រ ឌៀន(John Gunther Dean)ម្តង។

ថ្ងៃទី១៧មេសា គឺជាថ្ងៃផ្តាច់ព្រ័ត ដែលពួកខ្មែរក្រហមបានកំណត់ទុក ពួកគេបានប្រើកងកម្លាំង៣ភូមិភាគ ដើម្បីវាយកាន់កាប់ទីក្រុង គឺ ពួកមកពីភូមិភាគបូព៌ាទទួលខុសត្រូវភាគខាងកើតទីក្រុងភ្នំពេញ មកទល់ផ្លូវនរោត្តម ចាប់ពីផ្លូវនេះទៅលិចជាការទទួលខុសត្រូវរបស់ក្រុមភូមិភាគនិរតីរបស់តាម៉ុក និងពួកភូមិភាគពិសេស ទំនងនៅភាគខាងជើងត្រឹមផ្លូវសហព័ន្ធរុស្ស៊ី។

ក្រោយពីកងទ័ពចូលដល់ក្នុងទីក្រុង មនុស្សម្នាលើកទង់ជ័យសឈរអមផ្លូវអបអរសាទរ ដែតមិនបានប៉ុន្មាននាទីផង អ្នកក្រុងណាមមានផ្ទះនៅតាមដងផ្លូវធំ ត្រូវកងទ័ពក្រុមផ្សេងមួយទៀត ដើរគម្រាមបណ្តេញចេញពីគេហដ្ឋានយ៉ាងប្រញាប់ ដើម្បីគេចពីមហន្តរាយទម្លាក់គ្រាប់បែករបស់ទាហានអាមេរិក គប្បីពួកគេជម្លៀសខ្លួនចេញពីទីក្រុងចំនួន៣ថ្ងៃសិន ដោយមិនចាំបាច់យកសម្ភារៈអ្វីច្រើនតាមខ្លួនឡើយ។ ចំណែកអ្នកមានគេហដ្ឋាននៅតាមផ្លូវតូច អាចសំងំដេកក្នុងផ្ទះបានមួយរាត្រីទៀត៕

# មេរៀនទី 13 លទ្ធិកុំម្មុយនីស្ត៖ របបកម្ពុជាប្រជាធិបតេយ្យ

បដិវត្តន៍សន្ធោសន្ធៅ ឈាមក្រហមឆ្អៅ គឺជាទំនុកនៃបទចម្រៀងពួកខ្មែរក្រហមនិយមក្នុងពេលដែលពួកគេកាន់អំណាច។ ពាក្យបដិវត្តន៍, ការពារមាតុភូមិ, ដើម្បីប្រជាជន...ជាពាក្យដែលពួកខ្មែរក្រហមតែងលើកយកមកពោលជារឿយៗ សម្រាប់របបមួយដែលគេប្រសិទ្ធនាមថា "របបកម្ពុជាប្រជាធិបតេយ្យ"។ របបកុំម្មុយនីស្ត ដែលធ្វើការគ្រប់គ្រងទូទាំងប្រទេសកម្ពុជា ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ខែ មករា ឆ្នាំ ១៩៧៩ ត្រូវបានគេស្គាល់នៅក្នុងប្រវត្តិសាស្ត្រថា ជា«**របបកម្ពុជាប្រជាធិបតេយ្យ**»។ ត្រឹមតែរយៈពេលបីឆ្នាំប្រាំបីខែ និងម្ភៃថ្ងៃ របបនេះបណ្តាលជីវិតមនុស្សស្លាប់ជិត២លាននាក់។ ដោយការលាបពណ៌ឱ្យគ្នាទៅវិញទៅមក ការប្រព្រឹត្តដ៏ឃោរឃៅរបស់ពួកអ្នកដឹកនាំដែលបង្កទុក្ខវេទនាដល់ប្រជាជនទូទាំងប្រទេស។ នេះជាអត្តសញ្ញាណដ៏សំខាន់របស់របបកម្ពុជាប្រជាធិបតេយ្យ។ គឺរបបមួយដែលប្រកាន់យកលទ្ធិ«កុម្មុយនិស្ត»ដ៏ក្រហមសន្ធោសន្ធៅ ដោយការប្រមូលផ្តុំគ្នាឱ្យរស់នៅ, ដាក់មធ្យោបាយផលិតកម្ម, ធ្វើការងារពលកម្មផលិត, ដាក់ទ្រព្យសម្បត្តិ, ដាក់ផលិតផល និងអនុញ្ញាតឱ្យតែហូបចុក"រួមគ្នា"។ នៅក្នុងទ្រឹស្តីរបស់កុម្មុយនិស្ត ហៅរបបបែបនេះថា ជារបបកុម្មុយនិស្តកម្រិតខ្ពស់។ តែបើគ្រាន់តែ ធ្វើការរួម ហើយបែងចែកផលឱ្យឯកជនទុកដាក់សម្រាប់ហូបចុកតាមគ្រួសារផ្ទាល់ខ្លួន ហើយដីធ្លីផលិតកម្មទាំងអស់ជាទ្រព្យសម្បត្តិរបស់រដ្ឋ, របបបែបនោះគេហៅថា "របបសង្គមនិយម"ដោយសារវាគ្រាន់តែមានរូបភាពសមូហភាពក្នុងកម្រិតទាបប៉ុណ្ណោះ។

តើរបបនេះកើតឡើងបានតាមរបៀបណា? ដំបូងបំផុតក្រុមនិស្សិតមាននិន្នាការកុម្មុយនិស្តមកពីស្រុកបារាំងដែលរួមមាន ប៉ុលពត, អៀងសារី, រដ្ឋសាមឿន នាំគ្នាចុះចូលក្នុងចលនាខ្មែរឥស្សរកុម្មុយនិស្ត អតីតគណៈជាតិមុត្តគាហា ដែលប្រែឈ្មោះជា បក្សប្រជាជនបដិវត្តន៍ខ្មែរ ចាប់ពីចុងខែ មិថុនា ឆ្នាំ១៩៥១។ ក្រោយសន្និសីទហ្សឺណែវឆ្នាំ១៩៥៤ ចលនានេះត្រូវរំសាយ ដោយមានអ្នកខ្លះនៅខិតខំបង្កើតបក្សប្រជាជនកម្ពុជា ចូលរួមការបោះឆ្នោតជាតិឆ្នាំ១៩៥៥ ហើយអ្នកខ្លះទៀតរត់ទៅជ្រកកោននៅហាណូយ។ នួន ជា ចូលរួមវគ្គសិក្សារបស់បក្សនៅហាណូយកាលពីឆ្នាំ១៩៥៤ និងត្រឡប់មកវិញនៅឆ្នាំ១៩៥៥ ហើយក្លាយជាអនុលេខាបក្សនៅឆ្នាំ១៩៦០។ នៅឆ្នាំ១៩៦១ បុលពតឡើងជាអនុលេខាទី២របស់បក្សពលករកម្ពុជា ដែលទើបតែបានប្តូរឈ្មោះមកពីបក្សប្រជាជនបដិវត្តន៍ខ្មែរ តាមរយៈមហាសន្និបាតពីថ្ងៃទី២៨-៣០កញ្ញា១៩៦០ នៅក្នុងស្ថានីយរថភ្លើងក្រុងភ្នំពេញ។ ដោយសារទូ សាមុត ដែលជាលេខាបក្ស បានបាត់ខ្លួនកាលពីឆ្នាំ១៩៦២ ប៉ុល ពត ត្រូវគេជ្រើសតាំងជាលេខាបក្សជំនួស តាមរយៈមហាសន្និបាតបន្ទាន់នាខែកុម្ភៈឆ្នាំ១៩៦៣។ នៅឆ្នាំ១៩៦៥ ប៉ុល ពតបានធ្វើដំណើរថ្មើជើងតាមផ្លូវលំហូជីមិញទៅហាណូយ ជួបជាមួយមេដឹកនាំវៀតណាម និងបន្តទៅប្រទេសចិន និងកូរ៉េខាងជើង។ នៅប្រទេសពីរចុងក្រោយនេះ គាត់បានទទួលបដិសណ្ឋារកិច្ចយ៉ាងរាក់ទាក់យកចិត្តទុកដាក់ជាងនៅវៀតណាម។ ដូច្នេះហើយពេលគាត់វិលត្រឡប់មកប្រទេសវិញនៅឆ្នាំ១៩៦៦ ក៏បានរៀបចំសន្និបាតប្តូរឈ្មោះបក្សទៅជាបក្សកុម្មុយនិស្តកម្ពុជាវិញ ដើម្បីគោលដៅកាត់បន្ថយពីឥទ្ធិពលរបស់វៀតណាម ដែលបានស្នើគាត់ថា បក្សពលករកម្ពុជា គប្បីបន្តស្ថិតនៅក្រោមការមើលខុសត្រូវរបស់វៀតណាមតទៅទៀត និងដើម្បីរឹតបន្តឹងចំណងមិត្តភាពជាមួយចិនវិញ។ ការតស៊ូយ៉ាងសោះកក្រោះរបស់ក្រុមនេះ ដែលដំបូងមានជាអាទិ៍ ប៉ុលពត, នួនជា, អៀងសារី, វ៉ន់វ៉េត និងសុន សេន និងចាប់ពីឆ្នាំ១៩៦៧មកមាន ហ៊ូនឹម, ហ៊ូយន់ និងខៀវសំផន ចូលរួមថែមទៀតនោះ គ្មានសង្ឃឹមបានជោគជ័យឡើយ។ ចៃដន្យលន់នល់ បានធ្វើរដ្ឋប្រហារទម្លាក់សម្តេច នរោត្តម សីហនុ ទើបនាំឱ្យព្រះអង្គសម្រេចធ្វើការតស៊ូយោធា ដើម្បីប្រឆាំង

នឹងរបបដែលគាំទ្រដោយអាមេរិកមួយនេះ។[120] ដោយមានជំនួយសេដ្ឋកិច្ចពីចិន និងយោធាពីវៀតណាម-វៀតកុង និងពឹងផ្អែកលើប្រជាប្រិយភាពរបស់សម្ដេច ន.សីហនុ ពួកខ្មែរក្រហមបានឆ្លៀតកសាងកងកម្លាំងប្រដាប់អាវុធរបស់ខ្លួនបានយ៉ាងឆាប់រហ័ស។ នៅក្រោមការទម្លាក់គ្រាប់បែកដ៏មហន្តរាយរបស់កងទ័ពអាកាសអាមេរិក ប្រជាជនកម្ពុជានៅជនបទកាន់តែមានកំហឹងពុះពោរជាមួយអាមេរិក និងរបបលន់នល់។ ហេតុនេះហើយ ទើបធ្វើឱ្យប្រជាជនកាន់តែច្រើនឡើង នាំគ្នាចុះចូលជាមួយរណសិរ្សរួបរួមជាតិកម្ពុជា ដែលគ្រប់គ្រងដោយពួកខ្មែរក្រហមទាំងស្រុង។ នៅដើមឆ្នាំ ១៩៧៣ អាមេរិកបានសន្យាបញ្ឈប់ការទម្លាក់គ្រាប់បែក និងបញ្ឈប់ជំនួយយោធា និងសេដ្ឋកិច្ចដល់ប្រទេសកម្ពុជា។ ចំណែកកងទ័ពវៀតកុង ដែលជួយច្បាំងជំនួសរណសិរ្សរួបរួមជាតិកម្ពុជា ក៏ត្រូវអំពាវនាវឱ្យដកចេញ ពេលដែលកងកម្លាំងយោធាពួកតស៊ូសន្យាថា អាចម្ចាស់ការប្រយុទ្ធលើសមរភូមិដោយខ្លួនឯងបាន ទើបធ្វើឱ្យរបបសាធារណរដ្ឋខ្មែរ ក្លាយជាចង្កៀងដែលរង់ចាំពេលរលត់ដោយអស់ប្រេងជាស្ថាពរ។ មកដល់ឆ្នាំ១៩៧៤ ទីក្រុងទាំងអស់នៅកម្ពុជាត្រូវកងទ័ពរណសិរ្សរួបរួមជាតិកម្ពុជា ឡោមព័ទ្ធជាប់ ដោយទុករង់ចាំតែថ្ងៃវាយកំទេចផ្ដាច់ព្រ័ត្រនាថ្ងៃទី១៧មេសា ១៩៧៥តែប៉ុណ្ណោះ។

## 1. ការជម្លៀសប្រជាជន[121]

តាមពិតគោលការណ៍របស់ពួកខ្មែរក្រហមដែលសម្រេចដោយប៉ុលពត បានកំណត់គោលនយោបាយ៨ចំណុច ដើម្បីដឹកនាំរបបថ្មីរបស់ខ្លួន គឺ ៖

1- ជម្លៀសប្រជាជនចេញពីទីក្រុងទាំងអស់ ជាពិសេសទីក្រុងភ្នំពេញ
2- លុបបំបាត់ទីផ្សារ
3- លុបបំបាត់រូបិយវត្ថុសម្រាប់ទូទាត់ការទិញលក់
4- ផ្សឹកព្រះសង្ឃឱ្យបំពេញការងារជាកសិករ
5- ប្រហារជីវិតមេដឹកនាំរបបលន់នល់
6- បង្កើតសហករណ៍កម្រិតខ្ពស់ ដាក់មជ្ឈោបាយផលិតកម្មរួម
7- បណ្ដេញអាណិកជនវៀតណាមចេញពីកម្ពុជាឱ្យអស់
8- បញ្ជូនកងទ័ពទៅកាន់ព្រំដែន ជាពិសេសព្រំប្រទល់ដែនជាមួយវៀតណាម

ការរីករាយនឹងជោគជ័យលើកងទ័ពលន់ នល់ និងចក្រពត្តិអាមេរិកធ្វើឱ្យប្រជាជនកម្ពុជាមានការត្រេកអរយ៉ាងខ្លាំង ដោយសង្ឃឹមថា ស្រុកទេសបានសន្តិភាពហើយ។ មិនទាន់ទាំងបានប៉ុន្មានម៉ោងផង ភាពរីករាយប្រែក្លាយទៅជាផេះផង់ ដោយពួកខ្មែរក្រហមបញ្ជាឱ្យជម្លៀសប្រជាជនពីទីក្រុងជាបន្ទាន់។ ការជម្លៀសប្រជាជនពីទីក្រុង តែរយៈពេលបីថ្ងៃប៉ុណ្ណោះ ដើម្បីងាយស្រួលក្នុងបោសសម្អាតពួកចក្រពត្តិអាមេរិក និងពួកបរិវារប្រតិកិរិយា។ បក្សកុម្មុយនិស្តកម្ពុជា បានកំណត់យកផ្សារថ្មីធ្វើជាគោលក្នុងការជម្លៀសប្រជាជនទៅកាន់ខេត្តផ្សេងៗ។ ខ្មែរក្រហមបានបែងចែកប្រជាជននៅទីក្រុងភ្នំពេញជាប្រាំផ្នែក និងចាត់ទុកជាជ័យភណ្ឌរបស់កងទ័ពភូមិភាគនីមួយៗ។ ប្រជាជនរាប់លាននាក់ត្រូវបង្ខំចិត្តចាកចេញពីទីក្រុងភ្នំពេញទៅកាន់ជនបទ តាមបញ្ជារបស់មេបញ្ជាការកងទ័ពខ្មែរក្រហម

[120] ឌីខាំបូលី, ២០០៧, ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩), មជ្ឈមណ្ឌលឯកសារកម្ពុជា។
[121] ហ៊ុយ វណ្ណៈ, ២០០៣, *កងទ័ពខ្មែរក្រហមលេខ ៧០៣ ពីជ័យជំនះឆ្ពោះទៅការបំផ្លាញខ្លួនឯង,* ទំព័រទី៣៤-៣៥។

និងគណៈភូមិភាគនីមួយៗ។ នៅលើទ្រូងផ្លូវទាំងឡាយនៅទីក្រុងភ្នំពេញណែនណាន់តាន់តាប់ទៅដោយហ្វូងប្រជាជន និងកងទ័ពដែលកំពុងតែជ្រួលច្របល់។

ខ្មែរក្រហមបានបែងចែកប្រជាជននៅប៉ែកខាងកើតដងទន្លេមេគង្គជាពីរផ្នែកគឺ ប៉ែកខាងត្បូងទន្លេបួនមុខនិងប៉ែកខាងជើងទន្លេបួនមុខ។ ប្រជាជនទាំងនេះ ត្រូវបានចាត់ទុកជាជ័យភ័ណ្ឌរបស់កងទ័ពភូមិភាគបូព៌ា។ កងទ័ពភូមិភាគបូព៌ាបានជម្លៀសប្រជាជនទាំងនេះចេញពីទីក្រុងភ្នំពេញឆ្ពោះទៅកាន់ខេត្តកំពង់ចាម ខេត្តព្រៃវែង និងស្វាយរៀង។ ប្រជាជនរស់នៅប៉ែកខាងកើត ចាប់ពីស្ថានីយ៍រថភ្លើងរហូតដល់តំបន់ទួលគោកប៉ែកខាងកើតត្រូវបានចាត់ទុកជាជ័យភ័ណ្ឌរបស់កងទ័ពភូមិភាគឧត្តរ។ កងទ័ពភូមិភាគឧត្តរបានជម្លៀសប្រជាជនទាំងនេះទៅតាមផ្លូវជាតិលេខ៥ រួចហើយឆ្លងទន្លេសាបទៅតាមផ្លូវជាតិលេខ៦ ឆ្ពោះទៅកាន់ខេត្តកំពង់ធំ និងសៀមរាប។ ប្រជាជនរស់នៅភាគខាងជើងប៉ែកខាងលិច ចាប់ពីស្ថានីយ៍រថភ្លើងរហូតដល់តំបន់ទួលគោកប៉ែកខាងកើតត្រូវបានចាត់ទុកជាជ័យភ័ណ្ឌរបស់កងទ័ពភូមិភាគពាយព្យ។ កងទ័ពភូមិភាគពាយ័ព្យបានជម្លៀសប្រជាជនទាំងអស់ចាកចេញពីទីក្រុងភ្នំពេញទៅតាមផ្លូវជាតិលេខ៥ ឆ្ពោះទៅកាន់ខេត្តពោធិ៍សាត់និងខេត្តបាត់ដំបង។ ប្រជាជនរស់នៅប៉ែកខាងជើង ចាប់ពីផ្លូវសាលជីហ្គោលរហូតដល់តំបន់ទួលគោកប៉ែកខាងលិច ត្រូវបានចាត់ទុកជាជ័យភ័ណ្ឌរបស់កងទ័ពភូមិភាគបស្ចិម។ កងទ័ពភូមិភាគបស្ចិមបានជម្លៀសប្រជាជនទាំងនេះទៅកាន់ខេត្តកំពង់ឆ្នាំង និងខេត្តកំពង់ស្ពឺ។ ប្រជាជនរស់នៅប៉ែកខាងត្បូងផ្លូវសាលជីហ្គោលរហូតដល់សាលារៀន១៨មីនាក៏ត្រូវបានចាត់ទុកជាជ័យភ័ណ្ឌរបស់កងទ័ពភូមិភាគបស្ចិមដែរ។ កងទ័ពភូមិភាគបស្ចិម បានជម្លៀសប្រជាជនទាំងនេះចេញពីទីក្រុងភ្នំពេញតាមផ្លូវស្ទឹងមានជ័យកាត់តាមស្ទឹងស្លាគូឆ្ពោះទៅកាន់ខេត្តតាកែវ និងខេត្តកំពត។ ប្រជាជនរស់នៅភាគខាងត្បូង ចាប់តាំងពីប៉ែកខាងកើតផ្លូវមុនីវង្សរហូតដល់មាត់ទន្លេ ត្រូវបានចាត់ទុកជាជ័យភ័ណ្ឌរបស់កងទ័ពភូមិភាគពិសេស។ កងទ័ពភូមិភាគពិសេស បានជម្លៀសប្រជាជនទាំងនេះចេញពីក្រុងភ្នំពេញ តាមក្បាលថ្នល់កាត់តាមក្រុងតាខ្មៅទៅកាន់ខេត្តកណ្តាល និងខេត្តតាកែវ។

នៅមុនពេលចូលមកដល់ទីក្រុងភ្នំពេញ កងទ័ពខ្មែរក្រហមបានប្រយុទ្ធយ៉ាងខ្លាំងក្លាជាមួយទាហានរបបសាធារណរដ្ឋខ្មែរ នៅស្រុកអរិយក្សត្រស្ថិតនាត្រើយខាងកើតទន្លេបួនមុខនៃទីក្រុងភ្នំពេញ ។

ពួកកម្មាភិបាលកុម្មុយនិស្តបានជម្លៀសប្រជាជនទាំងអស់ចេញពីទីក្រុង និងទីប្រជុំជនដើម្បីកែប្រែប្រទេសឱ្យបានហ្មត់ចត់ និងដោយប្រើពេលដ៏ខ្លីនោះ ។ នៅក្នុងរយៈពេល១សប្តាហ៍ក្រោយថ្ងៃ១៧ មេសា ១៩៧៥ ប្រជាជនខ្មែរជាង២លាននាក់ត្រូវគេបង្ខំឱ្យចេញពីទីក្រុងទៅកាន់តំបន់ជនបទ ដោយពុំបានដឹងថា តើវាសនារបស់ខ្លួននឹងទៅជាយ៉ាងណាឡើយ ហើយមានតែក្រុមគ្រួសាររបស់មន្ត្រីបក្សកុម្មុយនិស្តជាន់ខ្ពស់ និងកម្មកររោងចក្រពីរបីរយនាក់ប៉ុណ្ណោះ ដែលគេអនុញ្ញាតឱ្យរស់នៅក្នុងទីក្រុងតទៅទៀត ។ បញ្ហាដ៏ព្រៃផ្សៃនេះ ដែលពួកគេមិនពន្យល់ឱ្យបានច្បាស់នោះ បានផ្តាច់ជីវិតមនុស្សរាប់ពាន់នាក់ទៀត បន្ថែមលើចំនួនមនុស្សប្រមាណប្រាំសែននាក់ ដែលស្លាប់នៅក្នុងសង្គ្រាមរវាងគ្នាឯង ។ របាយការណ៍នានា ដែលបានលេចឮដល់បស្ចិមប្រទេសនោះ បានឱ្យដឹងថា មានអ្នកជម្ងឺនៅតាមមន្ទីរពេទ្យត្រូវគេចាប់បង្ខំឱ្យចេញពីគ្រែដេក និងមានមនុស្សដែលត្រូវបានគេបាញ់សម្លាប់ដោយមិនរើសមុខ។របាយការណ៍នោះបានបញ្ជាក់ផងដែរថា មនុស្សឈឺ និងមនុស្សចាស់ជរា ព្រមទាំងកូនក្មេងតូចៗជាច្រើននាក់បានស្លាប់ ឬត្រូវបានគេបោះបង់ចោលនៅតាមដងផ្លូវ ។ ការជម្លៀសប្រជាជនបានធ្វើឱ្យជនរងគ្រោះ និងអ្នកសង្កេតការណ៍នៅក្នុងប្រទេសក្រៅតក់ស្លុត ទោះបីជាអ្នកសង្កេតការណ៍ទាំងនោះបានសង្ឃឹមថា របបថ្មីនេះនឹងព្យាយាមគ្រប់គ្រងប្រទេសតាមរបៀបការបង្រួបបង្រួមជាតិ ដោយបំភ្លេចចោលនូវអំពើព្រៃផ្សៃ ដែលភាគីទាំងសងខាងបានធ្វើនៅក្នុងសង្គ្រាម ។ អ្នកសង្កេតការណ៍មួយចំនួនទៀត ដែលមានសន្តានចិត្តចំពោះទស្សនៈបដិវត្តន៍ បានយល់ការជម្លៀសនោះថា ជា

មធ្យោបាយតែមួយគត់ដែលធ្វើឱ្យប្រទេសអាចផលិតស្បៀងអាហារបានគ្រាន់ដើម្បីចិញ្ចឹមជីវិត ដើម្បីបំបែកឋានានុក្រមសង្គមដែលបានចាក់ឫសយ៉ាងជ្រៅ ហើយចាប់ដំណើរការយុទ្ធសាស្ត្រមហាលោតផ្លោះ មហាអស្ចារ្យរបស់ខ្លួន។[122]

**មានហេតុផលពីរយ៉ាងក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ**

១- ទាក់ទងនឹងបញ្ហាស្បៀង ដែលជាបញ្ហាធ្ងន់ធ្ងរដោះស្រាយមិនរួច។ ឧទា. ដូចជានៅភ្នំពេញពេលនោះ មានប្រជាជនដល់ទៅជិត៣លាននាក់។ រដ្ឋអំណាចថ្មីមិនមានលទ្ធភាពផ្គត់ផ្គង់បានទេ។ ផ្លូវនិង ស្ពាន ខូចខ្ទេចខ្ទី ចំនួនឡានក៏ខ្វះ។

២- ទាក់ទងនឹងបញ្ហាសន្តិសុខ និងការពារជាតិ។ នៅពេលដែលវៀតណាមបានបង្រួបបង្រួមឡើងវិញ ហើយក្លាយទៅជាគ្រោះថ្នាក់មួយយ៉ាងធំជាងពេលណាៗទាំងអស់។ ភ្នំពេញ និងទីរួមខេត្តផ្សេងៗដែលមានប្រជាជនណែនណាន់តាន់តាប់ ហើយធ្លាប់ជាជម្រកនៃបនអ្នកលេងគ្រប់ធុនយូរមកហើយ អាចក្លាយទៅជាកន្លែងមួយសម្រាប់សេអ៊ីអា-CIA សំណល់នៃកងទ័ពលន់នល់ និងពួកសេរីបង្កប់ខ្លួនធ្វើវិច្ឆេទកម្ម។

ប៉ុល ពត បានឆ្លើយចំពោះមុខអ្នកកាសែតយូហ្គោស្លាវី កាលពីឆ្នាំ ១៩៧៨ ថា ការដេកប្រជាជនពីទីក្រុងភ្នំពេញនេះដោយសារមានមូលហេតុច្រើនយ៉ាងទី១- គឺបញ្ហាសេដ្ឋកិច្ច បញ្ហាផ្គត់ផ្គង់ស្បៀងដល់ប្រជាជនរាប់លាននាក់ រាប់សែនតាមក្រុមនីមួយៗ។ យើងខ្ញុំពិនិត្យឃើញថា យើងខ្ញុំដោះស្រាយមិនរួចទេ បើប្រជាជនច្រើនលានអញ្ចឹង។ បើយកប្រជាជននេះទៅជនបទនៅក្នុងសហករណ៍ សហករណ៍ឧបត្ថម្ភបាន ព្រោះសហករណ៍មានស្រែ មានមធ្យោបាយផលិតកម្មអីស្រេច។ យើងខ្ញុំមានសហករណ៍ដែលទទួលប្រជាជនពីក្រុងទៅធ្វើស្រែជាមួយគេ។ សហករណ៍មានគោមានក្របី មានមធ្យោបាយផលិតកម្មទាំងអស់។ នៅជនបទយើងខ្ញុំមានចំណុចខ្លាំង។នៅទីក្រុងយើងខ្ញុំមានចំណុចខ្សោយ។ ដូច្នេះឱ្យប្រជាជនទៅជនបទទើបដោះស្រាយស្បៀងបាន។ ដោះស្រាយស្បៀងបាន បានប្រជាជនមានជំនឿ។ បើនៅទីក្រុងប្រជាជនអត់បាយ ប្រជាជនមិនមានជំនឿលើបដិវត្តន៍ទេ។ នេះជាមូលហេតុសេដ្ឋកិច្ច ។

ទន្ទឹមនឹងមូលហេតុសេដ្ឋកិច្ចនេះ ក៏មានបញ្ហាការពារប្រទេស ការពារសន្តិសុខរបស់ប្រទេស។ មុនរំដោះយើងខ្ញុំដឹងមុននូវផែនការណ៍របស់ចក្រពត្តិអាមេរិក និងបរិវារ។ វាមានផែនការណ៍រៀបចំចាញ់របស់វា។ តាមផែនការបើកាលណាយើងខ្ញុំឈ្នះចូលមកភ្នំពេញ វាក្រឡុកយើងខ្ញុំនៅភ្នំពេញទាំងសេដ្ឋកិច្ច ទាំងយោធា ទាំងនយោបាយគ្រប់ផ្នែក ដើម្បីវាយរំលំបដិវត្តន៍យើង។ ដូច្នេះឈរលើសភាពការណ៍នេះ យើងខ្ញុំដកប្រជាជនទៅនៅជនបទ នៅក្នុងសហករណ៍ដោះស្រាយស្បៀងផង ហើយវាយកំចាយជាមុននូវផែនការណ៍របស់ចក្រពត្តិអាមេរិក កុំឱ្យវាយយើងខ្ញុំបាន ពេលដែលយើងខ្ញុំចូលទីក្រុងភ្នំពេញ។ដូច្នេះបញ្ហានេះ មិនមែនជាគម្រោងរៀបចំមុនរបស់យើងខ្ញុំទេ។ គឺសភាពការណ៍ជាក់ស្តែងដែលខ្វះស្បៀងត្រូវដោះស្រាយស្បៀងឱ្យប្រជាជន សភាពការណ៍ជាក់ស្តែង ដែលចក្រពត្តិអាមេរិកនិងបរិវារវាចង់វាយយើងខ្ញុំ សភាពការណ៍នឹងនាំឱ្យយើងខ្ញុំមានវិធានការណ៍ដកប្រជាជន។

ការជម្លៀសប្រជាជនចេញពីទីក្រុងនេះ ធ្វើឡើងតាមសេចក្តីសម្រេចរបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដែលសម្រេចក្នុងរយៈពេលដ៏ខ្លីមុនពេលរំដោះបានទីក្រុងភ្នំពេញ។ ប៉ុន្តែ នេះគឺជាការសម្ងាត់បំផុតមួយ ហើយថែមទាំងបានធ្វើឱ្យមេបញ្ជាការកុម្មុយនិស្តមួយចំនួន មានការភ្ញាក់ផ្អើលយ៉ាងខ្លាំងទៀតផង។ មូលហេតុដែលនាំឱ្យមានការសម្រេចបែបនោះ គឺមកពីរដ្ឋជានីនេះខ្វះស្បៀងអាហារយ៉ាងខ្លាំង។ មូលហេតុមួយទៀត គឺមកពីការលំបាកក្នុងការគ្រប់គ្រងប្រជាជនរាប់លាននាក់ ដែលបានប្រឆាំងនឹងបដិវត្តន៍។ មូលហេតុទីបី គឺមកពីអ្នកដឹកនាំបក្សកុម្មុយនីស្ត

---

[122] ដេវិឌ ឆេណ្ឌលរ័, ២០០៣, *ប្រវត្តិសាស្ត្រខ្មែរ,* ទំព័រ២៣០។

កម្ពុជា មានការភ័យក្លាចចំពោះសន្តិសុខផ្ទាល់ខ្លួន។ លើសពីនេះទៀត ហេតុផលសំខាន់បំផុតនោះ គឺប្រហែលជាបំណងប្រាថ្នាក្នុងការបញ្ជាក់ពីជ័យជំនះរបស់បក្សកុម្មុយនីស្ត ពីឥទ្ធិពលរបស់អ្នកជនបទមកលើអ្នកទីក្រុង និងបុព្វសិទ្ធិរបស់អ្នកក្រីក្រ។ សាឡុត ស និងសហសេវិកពុំបានចំណាយអស់រយៈពេល៧ឆ្នាំនៅក្នុងព្រៃ និង៥ឆ្នាំទៀតក្នុងការធ្វើសង្គ្រាមក្នុងស្រុក ដើម្បីគ្រាន់តែបានតំណែងជាទីប្រឹក្សាក្រុងប៉ុណ្ណោះឡើយ។ ពួកគេបានចាត់ទុកទីក្រុងថាជាកន្លែងប្រមូលផ្តុំកម្លាំងសម្រាប់ការប្រឆាំងបដិវត្តន៍ ហើយអាទិភាពខាងសេដ្ឋកិច្ចរបស់ពួកគេ គឺផ្អែកលើការកែប្រែកសិកម្មកម្ពុជា ជាពិសេសផ្អែកលើការបង្កើនផលិតផលស្រូវ។ គេបានសង្ឃឹមថា រដ្ឋាភិបាលនឹងទទួលបានប្រាក់ចំណូលដោយសារការនាំចេញនូវផលិតផលដែលលើសពីសេចក្តីត្រូវការ សម្រាប់ចំណាយលើទំនិញនាំចូល និងចុងក្រោយបំផុត ដើម្បីផ្តល់ធនដល់ឧស្សាហូបនីយកម្ម។ បក្សកុម្មុយនិស្តត្រូវការកសិករទាំងអស់ ដែលខ្លួនអាចរកបាន ដើម្បីទទួលបានផលិតផលលើសពីសេចក្តីត្រូវការ ។

ប្រាំមួយខែក្រោយមក ប្រជាជនដែលគេបង្ខំឱ្យចាកចេញពីទីក្រុង ហើយដែលគេហៅថា"ប្រជាជនថ្មី" ឬ"ប្រជាជន១៧មេសា"នោះ ត្រូវគេបង្ខំឱ្យធ្វើស្រែ និងដាំដំណាំផ្សេងៗទៀតក្រោមការត្រួតពិនិត្យរបស់ទាហាន និងកម្មាភិបាលកុម្មុយនិស្ត។ ស្ថានភាពនេះប្រកបដោយការលំបាកយ៉ាប់យ៉ឺនខ្លាំង សម្រាប់អ្នកដែលមិនធ្លាប់បញ្ចេញកម្លាំងពលកម្ម។ ប៉ុន្តែដោយសារនៅក្នុងស្រុកមួយចំនួននាពេលនោះ មានអាហារបរិភោគគ្រប់គ្រាន់ នាំឱ្យអ្នកគេចផុតពីស្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យជាច្រើនបានយល់ឃើញអំពីរយៈពេលប៉ុន្មានខែនោះថា ជាសម័យសម្បូណ៌គ្រាន់បើទៅវិញ។ ជាលើកដំបូងក្នុងរយៈពេលប៉ុន្មានឆ្នាំនោះ ដែលប្រទេសកម្ពុជាពុំកើតសង្គ្រាម ហើយ"ប្រជាជនថ្មី"ជាច្រើននាក់មានទឹកចិត្តចង់កសាងប្រទេសជាតិដែលហិនហោចដោយសារសង្គ្រាមឡើងវិញ។ [123] ប្រហែលជាបញ្ហារបស់ប្រទេសកម្ពុជាធ្ងន់ធ្ងរពេក បានជាត្រូវមានដំណោះស្រាយបែបបដិវត្តន៍ទេដឹង?

## 2. រចនាសម្ព័ន្ធរដ្ឋាភិបាល ឬ អង្គការ

របបកម្ពុជាប្រជាធិបតេយ្យ បានចាប់ផ្តើមឡើងពីថ្ងៃទី ១៧ មេសា ឆ្នាំ ១៩៧៥ រហូតដល់ខែមករា ឆ្នាំ ១៩៧៩ ទើបត្រូវបញ្ចប់។ ប៉ុន្តែរចនាសម្ព័ន្ធចាត់តាំងរបស់ខ្មែរក្រហមមិនត្រូវបានរលាយទៅតាមការដួលរលំនៃរបបនេះឡើយ ។ ពោលគឺពួកគេមានការដឹកនាំ ចាត់តាំងនៅក្នុងព្រៃធ្វើការតស៊ូបន្តទៅទៀត ។ ពិបាកនឹងនិយាយថាគ្មានក្រុមគ្រួសារ សាច់ញាតិណាម្នាក់ដែលមិនត្រូវបានស្លាប់នៅក្នុងរបបនេះឡើយ ។

មេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលជាសមាជិកនៃបក្សកុំម្មុយនីស្តកម្ពុជា បានចាត់ទុកខ្លួនឯងថាជា "អង្គការបដិវត្តន៍" និងបង្ហាញពីអំណាចរបស់ខ្លួនតាមរយៈកងទ័ព, កងឈ្លប និងគុក ដែលគេបានបង្កើតឡើងតាំងពីឆ្នាំ១៩៦៧មក។ [124] ពួកគេបានព្យាយាមផ្លាស់ប្តូរប្រទេសកម្ពុជា ដោយលុបបំបាត់នូវអ្វីៗដែលពួកគេបានយល់ឃើញថា ជាឧបសគ្គចំពោះស្វយ័តជាតិ និងយុត្តិធម៌ក្នុងសង្គម ដោយយកមនោគមន៍វិជ្ជាបដិវត្តន៍មកជំនួសជាថាមពលវិញ។ ជីវិតគ្រួសារ បុគ្គលនិយម និងអ្វីៗដែលគេចូលចិត្តហៅថា ស្ថាប័ន "សក្តិភូមិ " នោះសុទ្ធតែជាការរារាំងដល់បដិវត្តន៍។ គេបានលើកយកមកនិយាយថា ជនក្រីក្រនៅប្រទេសកម្ពុជា តែងតែត្រូវបានគេជិះជាន់ និងយកធ្វើជា

---

[123] ដេវិឌ ឆេណ្ឌ លឹរ, ២០០៥, ប្រវត្តិសាស្ត្រកម្ពុជា, ទំព័រ ២៣០_២៣១

[124] ការ អះអាង ឡើង វិញ របស់ កាំង ហ្គិកអ៊ាវ ហៅ ឌុច នៅ តុលាការ ខ្មែរ ក្រហម ព្រឹក ថ្ងៃ ទី ១៩ ខែ មីនា ឆ្នាំ ២០១២

។ប្រវត្តិសាស្ត្រខ្មែរ ,ដេ វីឌ ឆាណ្ឌលឹរ ទំ ១២

ទាសករជានិច្ច។ ដោយត្រូវបានរំដោះដោយបដិវត្តន៍ និងបានអំណាចដោយជ័យជំនះផ្នែកយោធា ជនក្រីក្រទាំងនេះបានក្លាយជាម្ចាស់វាសនារបស់ខ្លួន ព្រមទាំងជាម្ចាស់រួមនៃប្រទេសជាតិ។[125]

កម្ពុជាប្រជាធិបតេយ្យរបស់ពួកខ្មែរក្រហម បានបែងចែកប្រទេសកម្ពុជាជា៧ភូមិភាគ ដោយដាក់ឈ្មោះទៅតាមទិស គឺ ៖ ទិសឧត្តរ, ទិសឦសាន, ទិសបូព៌ា, ទិសនិរតី, ទិសបស្ចិម, ទិសពាយ័ព្យ, និងភូមិភាគពិសេស ព្រមទាំងតំបន់ពិសេសនៅខេត្តក្រចេះ គឺតំបន់៥០៥ និងតំបន់ពិសេស លេខ១០៦នៅខេត្តសៀមរាប(មុនពាក់កណ្តាលឆ្នាំ១៩៧៧)។ ក៏ដូចជាការបែងចែករដ្ឋបាលថ្នាក់ក្រោមៗដែរ ភូមិភាគក៏មានលេខសម្គាល់ដែរ ប៉ុន្តែក្រោយមកគេមិនសូវប្រើលេខសម្រាប់ហៅភូមិភាគឡើយ គឺគេហៅភូមិភាគទៅតាមឈ្មោះទិសទៅវិញ។ ម្យ៉ាងទៀត ការបែងចែករដ្ឋបាលនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមិនស្ថិតស្ថេរ ដោយមិនផ្លាស់ប្តូរនោះឡើយ។ នៅមុនឆ្នាំ១៩៧៥ ភូមិភាគបស្ចិម និងភូមិភាគនិរតី គឺស្ថិតនៅជាភូមិភាគតែមួយទេ ដែលគេហៅថាភូមិភាគនិរតី។ ហើយក៏មានភូមិភាគពិសេសដែរ ដែលរួមមានតំបន់១៥, តំបន់២១, តំបន់២៥, និងតំបន់៣៣។ បន្ទាប់ពីមានការបោសសម្អាតកម្មាភិបាលនៅភូមិភាគឧត្តរនៅក្នុងឆ្នាំ១៩៧៧ រចនាសម្ព័ន្ធរដ្ឋបាលរបស់ភូមិភាគឧត្តរ និងភូមិភាគកណ្តាល ត្រូវបានប្រែប្រួលដោយខេត្តសៀមរាប ក្លាយជាតំបន់៤៤ នៅក្នុងភូមិភាគឧត្តរ"ថ្មី"។

ភូមិភាគទាំងឡាយរបស់របប ប៉ុល ពត មិនមានលក្ខណៈដូចគ្នា ទៅនឹងការបែងចែកភូមិសាស្ត្ររដ្ឋបាលមុនសម័យបដិវត្តន៍ឡើយ។ ភូមិភាគខ្លះកើតឡើងពីខេត្តចាស់ច្រើនជាងមួយ ហើយជួនកាលខេត្តចាស់ កាលពីសម័យមុនបដិវត្តន៍ ត្រូវបានពុះជាពីររវាងភូមិភាគពីរ។ ភូមិភាគពាយ័ព្យកើតឡើងពីខេត្តចំនួនពីរ គឺពោធិសាត់និងបាត់ដំបង ពោលគឺស្ទើរតែដូចខេត្តបាត់ដំបង និងពោធិសាត់ចាស់។ រីឯភូមិភាគឧត្តរ រួមមានខេត្តឧត្តរមានជ័យ, ព្រះវិហារ, សៀមរាប, កំពង់ធំ, និងមួយភាគនៃខេត្តស្ទឹងត្រែង។ ចំណែកឯតំបន់ពិសេសនៃខេត្តក្រចេះ គឺតាំងនៅស្ទើរតែលើខេត្តក្រចេះចាស់ លើកលែងតែផ្នែកពីរកន្លែង គឺខាងជើងនឹងខាងត្បូង ត្រង់កន្លែងដែលទន្លេមេគង្គបត់ទៅលិច–កើត។ ចំណែកឯភូមិភាគបូព៌ាវិញ រួមមានផ្នែកនៃខេត្តក្រចេះ, ខេត្តកំពង់ចាម, ព្រៃវែង, ស្វាយរៀង និងមួយផ្នែកនៃខេត្តកណ្តាល។ ភូមិភាគនិរតី រួមមានផ្នែកខាងត្បូងនៃខេត្តកណ្តាល ដែលនៅសល់ខេត្តតាកែវ, កំពតនិងមួយផ្នែកនៃខេត្តកំពង់ស្ពឺ។ ចំណែកឯភូមិភាគបស្ចិមផ្សំឡើងពីខេត្តកំពង់ឆ្នាំង, កោះកុង នឹងមួយផ្នែកនៃខេត្តកំពង់ស្ពឺ។ ព្រំប្រទល់ភូមិភាគកណ្តាល មិនមានលក្ខណៈច្បាស់លាស់ឡើយ នៅពេលដែលភូមិភាគនោះត្រូវបានញែកចេញពីភូមិភាគឧត្តរ ប៉ុន្តែគេគ្រាន់តែដឹងថា ភូមិភាគកណ្តាលក៏រួមមានទាំងផ្នែកដែលនៅសល់នៃខេត្តកំពង់ចាម ត្រង់ខាងជើងទន្លេមេគង្គដែរ។

ភូមិភាគនីមួយៗត្រូវគេបែងចែកជាតំបន់តទៅទៀត ហើយតំបន់ទាំងអស់ ឬស្ទើរតែទាំងអស់ត្រូវគេយកតាមព្រំប្រទល់ រដ្ឋបាលចាស់។ ជាទូទៅ តំបន់ត្រូវគេសម្គាល់ដោយលេខ។ ការដាក់លេខសំរាប់តំបន់ភាគច្រើន បានចង្អុលតាមប្រព័ន្ធលំដាប់របស់លេខ ប៉ុន្តែហេតុផលនៃការកំណត់បែបនេះ គ្មានអ្នកណាមួយដឹងច្បាស់ឡើយ។ នៅភូមិភាគពាយ័ព្យគេបានកំណត់លេខតំបន់ចាប់ពី១ ដល់៧។ លេខ១ (តំបន់១)ដែលគេបានដាក់ឈ្មោះនៅតំបន់នៃភូមិភាគពាយ័ព្យ ប្រហែលជាមកពីតំបន់នោះរួមមានសំឡូតដែលជាទីកន្លែងកសិករបះបោរមុនគេ នៅឆ្នាំ១៩៦៧-១៩៦៨។ សម្រាប់ជនបដិវត្តន៍ខ្មែរ ការបះបោរនោះជាការចាប់ផ្តើម ជាការងើបឡើងដោយអាវុធប្រឆាំងនឹងរដ្ឋាភិបាល។ ក៏ប៉ុន្តែការដាក់លេខតំបន់នៅភូមិភាគពាយ័ព្យ មិនអាចស្របទៅនឹងលំដាប់ដោយងាយស្រួលនោះឡើយ។

ក្រៅពីភូមិភាគពាយ័ព្យ តំបន់ទាំងឡាយមិនត្រូវបានគេដាក់លេខតាមលំដាប់លំដោយទូទាំងប្រទេសឡើយ ប៉ុន្តែជាទូទៅតំបន់ទាំងនោះត្រូវបានដាក់លេខទៅតាមលេខកូដរបស់ភូមិភាគ។ នៅក្នុងភូមិភាគបូព៌ាដែលជាកន្លែងប្រមូលផ្តុំនៃសកម្មភាពបដិវត្តន៍ ហើយដែលជាភូមិភាគមួយដែលមានពួកក្រុមកុំម្មុយនីស្តខ្មែរមួយក្រុម ដែលមានលក្ខណៈប្លែកខុសគេ (ស្និទ្ធិនឹងយួន) តំបន់ទាំងប្រាំនៃភូមិភាគនោះ កាលពីដំបូងត្រូវបានគេដាក់លេខពី១០ដល់១៤។ ការនេះដូចជាគ្មានហេតុផលទាក់ទងទៅនឹងលេខនោះឡើយ លើកលែងតែតំបន់២០ ដែលមានទីតាំងភូមិសាស្ត្រស្ថិតនៅចំកណ្តាលភូមិភាគបូព៌ា ហើយមានមូលដ្ឋានតស៊ូចាស់របស់ពួកកុំម្មុយនីស្តនៅទីនោះ គឺកំចាយមារ ។

ភូមិភាគនិរតី និងភូមិភាគបស្ចិមក៏មានតំបន់តស៊ូដែរ ប៉ុន្តែលេខកូដភូមិភាគទាំងពីរនេះមិនសូវជាប្លែកប៉ុន្មានឡើយ គឺប្រហែលជាការឆ្លុះបញ្ចាំងពីការឯកភាពរវាងតំបន់ទាំងពីរមុនឆ្នាំ១៩៧៥ និងដំណាក់កាលដំបូងនៃការកកើត។ ជាទូទៅលេខកូដភូមិភាគ សម្រាប់ភូមិភាគនិរតីចាស់ គឺគេប្រើតែលេខខ្ទង់៣០។ ឯលេខតំបន់ទាំងអស់នៅក្នុងតំបន់ភូមិភាគនិរតីចាស់គឺ ៣១, ៣២, ៣៣, ៣៥ និង៣៧។ ក្រោយមកបន្ទាប់ពីគេ បង្កើតភូមិភាគបស្ចិមឡើង តំបន់៣១, ៣២, និង៣៧ត្រូវគេកាត់ទៅឱ្យភូមិភាគបស្ចិម។ ប៉ុន្តែភូមិភាគនិរតី ក៏មានតំបន់១៣នៅភូមិភាគខាងត្បូងខេត្តតាកែវក្បែរព្រំដែនយួន តំបន់១១នៅភាគខាងជើងខេត្តកោះកុង និងតំបន់១៥ជាប់ខាងលិចក្រុងភ្នំពេញ។ តំបន់១១ និង១៥ក្រោយមកក៏ត្រូវគេកាត់ទៅឱ្យភូមិភាគបស្ចិម បន្ទាប់ពីគេបង្កើតភូមិភាគនេះនៅឆ្នាំ១៩៧៥។

ទន្ទឹមនឹងនេះដែរភូមិភាគនិរតី ក៏បានកាន់កាប់យកតំបន់២៥ដែរ ដែលកាលពីដំបូងឡើយគឺជាផ្នែកមួយនៃភូមិភាគបូព៌ា និងចាប់ពីឆ្នាំ១៩៧១ គឺជាផ្នែកនៃភូមិភាគពិសេស។

នៅភូមិភាគឧត្តរ នឹងភូមិភាគកណ្តាល លេខកូដជាទូទៅស្ថិតនៅក្នុងខ្ទង់៤០។ តំបន់៤១ គឺចាប់ផ្តើមពីទឹកដីផ្នែកឦសានជាប់ក្រុងភ្នំពេញ ហើយបន្ទាប់មកគឺតំបន់៤២, ៤៣, និងតំបន់៤៤ នៅក្នុងខេត្តសៀមរាប និងតំបន់១០៣ដែលស្ថិតនៅខាងជើងគេបំផុត ហើយដែលស្ថិតនៅលើទឹកដីខេត្តព្រះវិហារ។ការនេះអាចឆ្លុះបញ្ចាំងពីការព្រមព្រៀងគ្នាកាលពីដំបូងដែលខេត្តព្រះវិហារត្រូវបានគេបញ្ចូលទៅក្នុងភូមិភាគឧត្តរ និងភូមិភាគឦសាន នៅពេលដែលភូមិភាគឦសានត្រូវបានគេបង្កើតឡើងក្រោយឆ្នាំ១៩៧៥។តំបន់ទាំងឡាយ នៃភូមិភាគឦសានត្រូវគេដាក់លេខ១០០, ១០២, ១០៤, ១០៥, និងតំបន់១០៧។

នៅខាងក្រោមតំបន់ គឺគេបានបែងចែកជាស្រុក ឃុំ និងភូមិ បន្ទាប់មកគឺក្រុម។នៅតាមតំបន់ខ្លះ ពួកកម្ពុជាប្រជាធិបតេយ្យបានប្រើលេខដើម្បីសម្គាល់ឈ្មោះស្រុកដែរ ដូចជានៅតំបន់២៥នៃភូមិភាគនិរតីជាដើម គេបានហៅឈ្មោះស្រុកទៅតាមលេខ ដូចជាស្រុកលើកដែក មានឈ្មោះជាស្រុក១៤,ស្រុកកៀនស្វាយ គឺស្រុក១៦, ស្រុកស្អាង គឺស្រុក២០, ស្រុកកោះធំ គឺស្រុក១៨ និងស្រុកកណ្តាលស្ទឹង គឺស្រុក១៥៤ ។

ជាទូទៅភូមិនីមួយៗមានប្រជាជនពី២០០ទៅ៤០០នាក់ ហើយក្រោយមក គេបានបង្កើតនូវរចនាសម្ព័ន្ធសហករណ៍ឡើងដោយសហករណ៍នីមួយៗជាទូទៅ គឺមានទំហំស្មើមួយឃុំតែម្តង ហើយក្នុងសហករណ៍នីមួយៗមានភូមិជាច្រើននៅក្នុងនោះ។

នៅក្នុងការគ្រប់គ្រង រដ្ឋបាលនៅតាមលំដាប់ថ្នាក់នីមួយៗ ត្រូវបានដឹកនាំដោយកម្មាភិបាល មានគ្នាបីនាក់ដែលគេហៅថា"គណៈ"ឬ"គណៈកម្មាធិការ"ដែលលំដាប់ក្រោមបំផុត (ថ្នាក់ឃុំ និងភូមិ,ក្រុម)ជាទូទៅត្រូវដឹកនាំដោយប្រជាជនមូលដ្ឋាន។ សម្រាប់ការដឹកនាំនៅលំដាប់ខាងក្រោមនេះ បើសិនជាគ្មានមនុស្ស របស់បក្សកុម្មុយនិស្ត

កម្ពុជា ដែលគេហៅថាជនបដិវត្តន៍នោះទេ គេយកមនុស្សក្រីក្របំផុត នៅក្នុងវណ្ណៈកសិករដើម្បីទៅដឹកនាំ។ នៅកន្លែងខ្លះ ដែលគេទើបតែបង្កើតភូមិថ្មី ហើយដែលនៅក្នុងភូមិទាំងមូល មានសុទ្ធតែប្រជាជនដែលគេបណ្តេញចេញពីទីក្រុង ឬគេហៅថាអ្នក១៧ មេសានោះអង្គការបានចាត់តាំងប្រជាជនថ្មីឱ្យធ្វើជាមេភូមិ ឬប្រធានភូមិ តែការតែងតាំងនោះជារឿយៗលេចចេញនូវការមិនសម្បាយចិត្តក្នុងចំណោមប្រជាជនថ្មីដូចគ្នា និងមិនសម្បាយចិត្តសម្រាប់រដ្ឋអំណាចបដិវត្តន៍ផងដែរ។

នៅក្នុងលំដាប់ថ្នាក់ភូមិភាគ និងតំបន់ កម្មាភិបាលដែលគេធ្វើការកត់សម្គាល់នៅក្នុងឆ្នាំ១៩៧៥ គឺជារឿយៗជាបញ្ញវន្ត ដែលបានចូលរួមជាមួយចលនាតស៊ូក្នុងព្រៃម៉ាគី តាំងពីក្នុងទសវត្សឆ្នាំ១៩៦០។ ឯកម្មាភិបាលខ្លះទៀតគឺជាអតីតខ្មែរវៀតមិញ ឬក៏"ក្រុមប្រជាជន" ឬក៏ជាមនុស្សដែលមានអតីតកាលផ្នែកនយោបាយ ឬយោធា ដែលគេស្គាល់ថា ជាពួក"ឥស្សរៈ"។

មកទល់ពេលនេះគ្មានអ្នកណាមួយ អាចមានលទ្ធភាពចងក្រងនូវបញ្ជីពួកកម្មាភិបាលថ្នាក់លើបានចប់សព្វគ្រប់នៅឡើយទេ។ ហើយសូម្បីតែប្រជាជនចាស់ និងថ្មី ក៏មិនបានដឹងពីអត្តសញ្ញាណរបស់មនុស្សដែលពួកគេនៅក្រោមបង្គាប់ឡើយ។[126]

ដោយសារបានគ្រប់គ្រងលើផ្ទៃដីមួយផ្នែកធំនៃប្រទេស ពួកខ្មែរក្រហមបានចាប់ផ្តើមអនុវត្តន៍ទៅតាមគម្រោងរបស់ខ្លួន ធ្វើកំណែទម្រង់នៅលើរចនាសម្ព័ន្ធសេដ្ឋកិច្ច ទំនាក់ទំនងរដ្ឋបាល និងប្រព័ន្ធនយោបាយនៅក្នុងប្រទេស។ នៅពាក់កណ្តាលឆ្នាំ១៩៧៣ គេបានធ្វើការបែងចែករចនាសម្ព័ន្ធរដ្ឋបាលនៅក្នុងប្រទេសសារជាថ្មី ដោយពុំមានលក្ខណៈទៅតាមប្រវត្តិសាស្ត្រជាតិទេ។ ប្រព័ន្ធរដ្ឋបាលដែលកើតឡើងនៅលើទឹកដីកម្ពុជា ជាប្រវត្តិសាស្ត្រប្រពៃណីទំនៀមទម្លាប់ បានត្រូវលុបចោល ហើយបង្កើតជាប្រព័ន្ធរដ្ឋបាលភូមិភាគធំៗ ដូចជា ៖

-ភូមិភាគបូព៌ាមាន ខេត្តស្វាយរៀង ព្រៃវែង កំពង់ចាម និងក្រចេះដែលជាខេត្តមានព្រំប្រទល់ជាប់នឹងប្រទេសវៀតណាម ។

-ភូមិភាគឧត្តរលាតសន្ធឹងនៅលើទឹកដីខេត្តកំពង់ធំ-សៀមរាប(មួយផ្នែក) ឧត្តរមានជ័យ និងបន្ទាយឆ្មារ។

-តំបន់ដែលក្នុងនោះមានខេត្តពោធិសាត់ សៀមរាប ប៉ៃលិន និងបាត់ដំបងត្រូវគេរាប់បញ្ចូលទៅក្នុងភូមិភាគពាយ័ព្យ។

-ភូមិភាគពិសេស គេរាប់បញ្ចូលតំបន់ទាំងឡាយណាដែលនៅជាប់នឹងរដ្ឋធានីភ្នំពេញ។

-ភូមិភាគឦសានបង្គុំទៅដោយខេត្តទាំងឡាយ ដែលស្ថិតនៅភូមិភាគឧត្តរ និងឦសាននៃប្រទេសមានខេត្តមណ្ឌលគិរី រតនគិរី ស្ទឹងត្រែង និងព្រះវិហារ ។

នៅក្នុងភូមិភាគនីមួយៗបានត្រូវបែងចែកជាតំបន់ ហើយដែលត្រូវបែងចែកជាស្រុកទៀត ស្រុកបង្គុំទៅដោយឃុំ រីឯឃុំ បង្គុំទៅដោយភូមិ ។

នៅក្នុងភូមិនីមួយៗដឹកនាំទៅដោយគណៈកម្មាធិការភូមិ ដែលក្នុងនោះមានប្រធានភូមិ អនុប្រធានភូមិ និងសមាជិក។ សមាជិកគណៈកម្មាធិការភូមិទទួលខុសត្រូវលើវិស័យសេដ្ឋកិច្ច នយោបាយសង្គម កងទ័ព និងវប្បធម៌ ។

---

យល់ដឹង ពី របប ខ្មែរ ក្រហម ,ទំព័រ ១៩២_១៩៧ ។

សមាជិកនៅក្នុងគណៈកម្មាធិការតំបន់ ត្រូវមានឋានៈជាសមាជិកបក្សកុំម្មុយនីស្តកម្ពុជា។ នៅក្នុងគណៈកម្មាធិការស្រុក ជាពិសេសឃុំ និងភូមិជាដំបូងត្រូវបានជ្រើសរើសមនុស្សដែលមិនមែនជាសមាជិកបក្ស ប៉ុន្តែគេបានចូលរួមនៅក្នុងចលនាតស៊ូរំដោះជាតិ។ នៅពេលដែលកម្មាភិបាលកាន់តែមានឋានៈទាបទៅៗ នោះការគ្រប់គ្រងពីសំណាក់គណៈកម្មាធិការមជ្ឈិមបក្ស ក៏កាន់តែខ្សោយទៅដែរ។

ដំណាក់កាលបែបនេះ បានបន្តនៅក្នុងប្រទេសកម្ពុជាមិនយូរប៉ុន្មានទេ ។ នៅក្នុងឆ្នាំ១៩៧៣ពេលដែលពួកខ្មែរក្រហមបានពង្រឹងកំលាំងរបស់ខ្លួនបានហើយរចនាសម្ព័ន្ធរដ្ឋបាលថ្នាក់មូលដ្ឋានក៏បានពង្រឹងដូចគ្នានេះដែរ។ នៅក្នុងជួរកម្មាភិបាលស្រុក ឃុំ ភូមិ ពួកខ្មែរក្រហមបានបង្កើតសាខាបក្សរបស់ខ្លួន។ ក្រុមតូចៗនេះ គេបានឱ្យឈ្មោះថា "អនុសាខាបក្ស" ដែលមានចំនួនមិនតិចជាងពីរនាក់។ "អនុសាខាបក្ស" បានកើនចំនួនយ៉ាងឆាប់រហ័ស នៅឆ្នាំ១៩៧៤បានរីករាលដាលពាសពេញផ្ទៃតំបន់រំដោះ។ ដូច្នេះពួកខ្មែរក្រហមកាន់តែពង្រឹងគោលជំហរនយោបាយរបស់ខ្លួន នៅក្នុងកម្រិតមូលដ្ឋាន។ "អនុសាខាបក្ស"ត្រូវតែគោរពប្រតិបត្តិតាមស្ថាប័នបក្សជាន់លើ ហើយបានក្លាយជាអំណាចទីពីរ និងសំខាន់នៅក្នុងមូលដ្ឋាន ដែលបានបង្កើតឡើងនៅក្នុងជួរមហាជន ហើយដែលជាអំណាចមួយយ៉ាងកាចសាហាវជាទីបំផុតទៅថ្ងៃអនាគត។ "អនុសាខាបក្ស" មួយចំនួនអាចផ្តុំគ្នាទៅកម្រិតឃុំ បង្កើតបានជាសាខាបក្ស។ សាខាបក្សអាចមានចំនួនលើសពី១០ នាក់។ បីបួន ឬលើសពីនេះនៃសាខាបក្ស អាចបង្កើតបានជាគណៈកម្មាធិការស្រុក ឬហៅថា "គណៈស្រុក" ។

មេដឹកនាំគណៈភូមិភាគ គណៈតំបន់ ឬគណៈស្រុក ក្នុងពេលជាមួយគ្នាក៏ជាមេដឹកនាំរដ្ឋបាលទាំងអស់ដែរ។ អំណាចរបស់គេ បើមានកម្រិតភូមិភាគ ជាអំណាចមួយធំណាស់ ប៉ុន្តែមិនដាច់ខាតទេ ពីព្រោះនៅទីនោះ អាចមានឥទ្ធិពលពីមេបញ្ជាការកងទ័ពទទួលបន្ទុកជានាយស្នងការនយោបាយបក្ស។ នៅក្រោមការគ្រប់គ្រងរបស់នាយស្នងការនយោបាយ មិនត្រឹមតែនៅលើមេដឹកនាំគណៈភូមិភាគទេ ហើយគេក៏ជាមេដឹកនាំមួយនៅក្នុងគណៈមជ្ឈិមបក្សដែរ។ ប៉ុន្តែនាយកស្នងការនយោបាយបក្ស និងគណៈភូមិភាគអាចជាមនុស្សតែម្នាក់។ ប្រព័ន្ធអង្គការអំណាចបែបនេះ គេបង្កើតឱ្យមានបណ្តាញទាក់ទងរបស់មេដឹកនាំគ្រប់ជាន់ថ្នាក់ ផ្សារភ្ជាប់ទៅនឹងគណៈមជ្ឈិមបក្សកុម្មុយនិស្តខ្មែរ ហើយគ្មានមេដឹកនាំរដ្ឋបាលណាមួយអាចមានអារម្មណ៍ថាខ្លួនមានអំណាចពេញលេញឡើយ នៅក្នុងប្រព័ន្ធរដ្ឋបាលរបស់ខ្លួន។ ក្នុងស្ថានភាពបែបនេះ អាចធ្វើឱ្យគណៈមជ្ឈិមមានការងាយស្រួលក្នុងការបង្រ្កាបដល់រាល់រូបភាពប្រឆាំងណាមួយ ដែលលេចឡើងនៅក្នុងថ្នាក់មូលដ្ឋានជាពិសេសថ្នាក់ភូមិភាគ ដែលមានបំណងចង់ដឹកនាំដោយឯករាជ្យពីនយោបាយគណៈមជ្ឈិមបក្សកុម្មុយនិស្តកម្ពុជា ។

យើងមានការចាប់អារម្មណ៍ទៅលើប្រព័ន្ធរដ្ឋបាលថ្មី ដែលមានលក្ខណៈពិសេសមួយទៀតជាប្រព័ន្ធដែលមានតាំងពីយូរមកហើយ នៅក្នុងរបបសក្តិភូមិកម្ពុជាគឺ "ប្រព័ន្ធឧបត្ថម្ភ" គឺស្ថាប័នថ្នាក់ក្រោមត្រូវតែឧបត្ថម្ភស្ថាប័នថ្នាក់លើ តាមការពិត ជានិច្ចកាលគេមិនបានប្រើមធ្យោបាយនៃ"ប្រព័ន្ធឧបត្ថម្ភ"ទេ ទៃគេដកហូតតែម្តង(កសិផលនៅពេលនោះ គឺស្រូវ ដំឡូង និងគ្រាប់ធញ្ញជាតិផ្សេងៗទៀត) ដែលគេតែងតែប្រើពាក្យថា "អង្គការឱ្យស្មើ"។ ហើយប្រយោគនេះ គេតែងប្រើជាទូទៅសម្រាប់ដកហូតអ្វីពីប្រជាជនទូទៅផងដែរ។

### 3. សហករណ៍ប្រមូលផ្តុំ

នៅគ្រប់មូលដ្ឋានតាំងពីជនបទ រហូតដល់ទីក្រុងពួកខ្មែរក្រហម រៀបចំប្រទេសទាំងមូលឱ្យមានសហករណ៍មួយ ដែលគេហៅថា "សហករណ៍ប្រមូលផ្តុំ "។ នៅក្នុងសហករណ៍ប្រមូលផ្តុំនេះ ទាំងអស់គ្នាធ្វើការរួមគ្នា ហូបចុករួមគ្នា និងមានអ្នកគ្រប់គ្រងម្នាក់ហៅថា ប្រធានសហករណ៍។

ក្រុមនីមួយៗដែលរួមមានច្រើនគ្រួសារ ឬភូមិនីមួយៗបង្កើតបានជា"សហករណ៍"មួយ។ សហករណ៍ ជាច្រើនបានជួយជ្រោមជ្រែងបដិវត្តន៍យ៉ាងខ្លាំង ដែលនាំឱ្យខ្មែរក្រហមបានឈ្នះសង្គ្រាម...។ តាំងពីទទួលជ័យជំនះ សហករណ៍ទាំងនេះបានមានតួនាទីសំខាន់មួយ ដើម្បីកសាងសេដ្ឋកិច្ចជាតិ និងដោយសារសហករណ៍ទាំងនេះហើយដែល យើងមានអង្ករល្អបរិភោគនៅក្នុងរដូវភ្លៀងចុងក្រោយនេះ។ បន្ទាប់ពីការច្រូតកាត់ បន្ទុករបស់សហករណ៍នៅក្នុងរដូវប្រាំង គឺដឹកនាំវែរសម្រុកដើម្បីលើកភ្លឺស្រែថ្មីៗទៀត" ។ សហករណ៍ទាំងនេះ បានទទួលការវិវត្តន៍មួយយ៉ាងធំនៅក្នុងបណ្ដាឆ្នាំចុងក្រោយ ត្រាតែគេពុំដឹងពីពាក្យនេះដែលលេចចេញឡើងវិញ ដោយពិតប្រាកដណាស់ទោះជានៅពេលបច្ចុប្បន្នក៏ដោយ ។លោក ហ៊ូ យន់ និងលោកខៀវ សំផន បាននិយាយណែនាំពីការបង្កើត "ក្រុមប្រវ៉ាស់ដៃ" បន្ទាប់មក "សហករណ៍កម្រិតខ្ពស់" គឺ "គំរូពាក់កណ្ដាលសង្គមនិយម" និង "សហករណ៍ផ្គត់ផ្គង់ស្បៀង និងលក់ដូរតាំងពីយូរមកហើយ" ។

រហូតមកដល់ឆ្នាំ ១៩៧៣ «នៅក្នុងតំបន់រំដោះនានា» មានរៀបចំបង្កើត «ក្រុមប្រវាស់ដៃ» ជាច្រើនក្រុម គោលដៅរបស់គេគឺរៀបចំសម្រួលការជួយគ្នាទៅវិញទៅមក ដែលផ្ដោតទៅលើប្រជាកសិករសម្រាប់ការចុះធ្វើស្រែជាពិសេសនៅពេលភ្ជួររាស់ និងពេលច្រូតកាត់។ គ្មានអ្វីមួយត្រូវដាក់ជារួមទេមានត្រឹមតែការងារប៉ុណ្ណោះ។ នៅពេលនោះ អង្គការបានសម្រេចថា ការងារនឹងត្រូវធ្វើជារួមតាមបែបបទជាប់ជាប្រចាំមួយ ហើយលែងធ្វើទៅតាមកាលៈទេសៈទៀតហើយ ។

ប្រហែលនៅឆ្នាំ១៩៧៣ "សហករណ៍កម្រិតទាប"បានលេចរូបរាងឡើង នៅពេលនោះប្រជាកសិករបាន ដាក់ជារួមនៅមធ្យោបាយផលិតកម្មរបស់ពួកគេទាំងអស់ទាំងពី ដីធ្លី,គោ–ក្របី,និងប្រដាប់ប្រើប្រាស់ផ្សេងៗ។"ប្រជាកសិករ បានផ្ដល់ចំណែកដីរបស់គេ រៀបចំការងារលើមូលដ្ឋាននៃការចាត់ចែងដឹកនាំរួមគ្នា...។ ដីធ្លី និងមធ្យោបាយផលិតកម្មនៅតែជាកម្មសិទ្ធិរបស់ប្រជាកសិករដដែលប៉ុន្តែត្រូវដាក់ទៅក្នុងការចាត់ចែងរួមក្នុងការប្រឹងប្រែងធ្វើសង្គ្រាម ឬការស្ដារប្រទេសឡើងវិញ ក្រោមការដឹកនាំរបស់អង្គការ ទៅតាមគម្រោងការមួយស្ដីពីតម្រូវការផ្សេងៗ។

ប្រហែលនៅឆ្នាំ ១៩៧៤ នៅក្នុងមួយចំណែកនៃ "តំបន់រំដោះ"ទាំងឡាយ ហើយប្រហែលនៅខែតុលាឆ្នាំ ១៩៧៥ នៅក្នុងភូមិជាច្រើនរបស់ "ប្រជាជនថ្មី"សហករណ៍ទាំងនេះបានប្រែក្លាយទៅជា "សហករណ៍កម្រិតខ្ពស់" ដែលមធ្យោបាយផលិតកម្មទាំងអស់ត្រូវដាក់ជារួម ការច្រូតស្រូវត្រូវបានជាកម្មសិទ្ធិរបស់សហករណ៍ដែលបែងចែកទៅឱ្យប្រជាជនម្នាក់ៗវិញទៅតាមភាពគួរនឹងត្រូវបានរង្វាន់ និងសេចក្ដីត្រូវការផ្សេងៗរបស់គាត់។ ពុំមានកម្មសិទ្ធិឯកជនទៀតទេ ប៉ុន្តែគ្រួសារនីមួយៗនៅមានស្វ័យភាពខ្លះក្នុងការដាំបាយខ្លួនឯងហូបដែរ។ ស្វ័យភាពដែលមិនទៀងនេះនឹងត្រូវលុបបំបាត់ចោលដូចគ្នានៅខែមករាឆ្នាំ១៩៧៦ ពេលដែលគេបង្កើត "សហគមន៍"ជាជំនួសវិញ។ តាំងពីនោះមក ការបែងចែកម្ហូបអាហារបានរលាយបាត់ ការហូបបាយត្រូវប្រព្រឹត្តទៅជារួម។ ម្នាក់នៅមានតែកម្លាំងកាយផ្ទាល់របស់ខ្លួនប៉ុណ្ណោះដែលត្រូវផ្ដល់ទៅឱ្យសហករណ៍។

រហូតដល់ខែមករា ឆ្នាំ១៩៧៦ សហករណ៍ទាំងអស់បានត្រូវដាក់ឈ្មោះជា "ក្រុមសាមគ្គីបង្កបង្កើនផល" ឬ "ក្រុមសាមគ្គីលើកទំនប់ និងជីកប្រឡាយ"។ អំណឹះតទៅ ឈ្មោះផ្លូវការត្រូវគេហៅ "សហករណ៍ផលិតកម្ម"វិញ។ ប៉ុន្តែគេពិបាកនឹងដឹងពីសារសំខាន់នៃចំនួនគ្រួសាររបស់សហករណ៍នីមួយៗណាស់ "សហករណ៍"ទាំងនោះ គ្មានអ្វីផ្សេងក្រៅពី "ក្រុមដែលមាន១០គ្រួសារ" ហើយដែលយើងបាននិយាយពីខាងដើមថា ជាកោសិការបស់ភូមិឡើយ។ ភូមិនឹងក្លាយទៅជា "ក្រុមរួមផ្ដុំដោយសហករណ៍ច្រើន" ដូចដែលវិទ្យុបាននិយាយ។ សហករណ៍ចំនួនបី នឹងបង្កើតបានជា "ក្រុមតូច"មួយ, "ក្រុមតូច"ចំនួនបួន នឹងបង្កើតបានជា"ក្រុមធំ"មួយ ដែលមាន១២០គ្រួសារ។

តាមពួកអ្នកកៀសខ្លួនខ្លះទៀតថា "សហករណ៍"មួយត្រូវគេរៀបចំឱ្យមាន១០០គ្រួសារ ដែលត្រូវបរិភោគបាយជារួម។ ជាឧទាហរណ៍ "នៅឃុំរំាំរិនមាន២២សហករណ៍"។ តាមអ្នកកៀសខ្លួន ខ្លះទៀតថាសហករណ៍មួយបានក្រសោបទៅដល់១០០០គ្រួសារឯណោះ។ តាមអ្នកកៀសខ្លួនខ្លះទៀតថា សហករណ៍មួយមានសមាជិកតិចឬច្រើនយ៉ាងណាក៏ដោយ ក៏សហករណ៍ទាំងនោះនៅតែត្រូវដឹកនាំដោយមនុស្ស៣នាក់ជានិច្ច ប្រធានម្នាក់, អនុប្រធានម្នាក់ និងសមាជិកម្នាក់។

តាំងពីការលេចចេញ"សហករណ៍កម្រិតខ្ពស់" គេសង្កេតឃើញរបៀបចាត់ចែងធ្វើការងារឱ្យចម្រើន និងធ្វើជាច់ដោយឡែកៗពីគ្នាក្នុងការធ្វើស្រែបានចាប់ផ្តើមលេចឡើងដែរ ក្រុមខ្លះបានទទួលបន្ទុកផ្តាច់មុខខាងការភ្ជួរដីក្រុមខ្លះទៀតខាងការរាស់ ខ្លះទៀតខាងការស្ទូងស្លាបនាបេងនិងធ្វើឧបករណ៍ផ្សេងៗខ្លះទៀតទទួលខាងការដកស្ទូង។ល។ សហករណ៍នីមួយៗ សុទ្ធតែមាន"ឃ្លាំង" "ជង្រុក" មួយដូចៗគ្នាសម្រាប់ទុកដាក់ស្រូវ, សាច់ក្រណាត់, ប្រដាប់ប្រដាធ្វើការងារ និងអ្វីៗដែលប្រជាជនត្រូវការ ។

ជាញឹកញយ ប្រធានសហករណ៍នេះត្រូវបានជ្រើសរើសពីក្នុងចំណោមមនុស្សនៃវណ្ណៈក្រីក្របំផុត។ ជួនកាលគេជ្រើសរើសខ្មែរក្រហមម្នាក់។ ជួនកាលគេជ្រើសរើសខ្មែរក្រហមម្នាក់ឱ្យធ្វើជាប្រធានដែរ ក្នុងករណីដែលសហករណ៍នោះសំខាន់។ គាត់មានភារៈមើលខុសត្រូវលើបណ្តាសមាជិករបស់សហករណ៍ ដើម្បីឱ្យយុត្តិធម៌ត្រូវគេប្រតិបត្តិតាមដោយម៉ឺងម៉ាត់ និងធ្វើអង្កេតស្តីពីសកម្មភាពរបស់សមាជិកសហករណ៍។ នៅក្នុងបន្ទុកនេះ គាត់ត្រូវជួយពី "ពួកឈ្លប" ជាច្រើននាក់ ដែលគាត់ជ្រើសរើសដោយខ្លួនឯងផ្ទាល់ ក្នុងលក្ខណៈសម្ងាត់បំផុត។ គាត់ គឺជាអ្នករៀបចំធ្វើគម្រោងទុកជាមុនអំពីបញ្ហាស្រូវ, ម្ហូបអាហារ, គ្រាប់ពូជនិងរុក្ខជាតិផ្សេងៗដែលអង្គការបញ្ជាឱ្យដាំ ជំរុញឱ្យសមាជិកទាំងឡាយរបស់សហករណ៍ចិញ្ចឹមជ្រូក មាន់ ទា គោញី និងគោឈ្មោល ដែលជាកម្មសិទ្ធិរបស់សមាជិកសហករណ៍ទាំងអស់គ្នា។ គឺក្រោមការដឹកនាំរបស់ប្រធានសហករណ៍នេះដែរ ដែលជាអ្នកធ្វើជំរឿនស្តីពីចំនួនសត្វជ្រូក, គោក្របី, សត្វមាន់ទា, ក្ងាន និងដំណាំផ្សេងៗនៅតាមតំបន់នានា ហើយដែលវិទ្យុរដ្ឋចូលចិត្តយករបាយការណ៍មកផ្សាយជារឿយៗ។

តាំងពីចុងឆ្នាំ១៩៧៥ ប្រភេទសហគ្រាសកសិកម្មមួយទៀតបានចាប់ផ្តើមបង្ហាញរូបរាងឡើងគឺ "កសិដ្ឋានរដ្ឋ"។ នេះគឺជាកសិដ្ឋានដែលមានលក្ខណៈរួម និងដែលស្ថិតនៅក្រោមអំណាចបញ្ជាផ្ទាល់របស់គណៈកម្មាធិការតំបន់ ហើយផលិតផលដែលធ្វើបាន គឺត្រូវទុកទាំងស្រុងជូនរដ្ឋ។ កសិដ្ឋានទាំងនោះបានប្រើប្រាស់ត្រាក់ទ័រជាច្រើនគ្រឿងសម្រាប់ភ្ជួររាស់។ ក៏ប៉ុន្តែនៅពេលដែលគ្រឿងយន្តមានពុំគ្រប់គ្រាន់ គឺគេយកមនុស្សទៅអូសជំនួសម្តងដូចដែលអ្នកកៀសខ្លួនម្នាក់ ក្នុងចំណោមអ្នកកៀសខ្លួនជាច្រើននាក់ទៀត បានរៀបរាប់ពីបទពិសោធន៍នេះ ដែលគាត់បានជួបអនុវត្តន៍ផ្ទាល់។[127]

### 4. ការបែងចែកប្រភេទប្រជាពលរដ្ឋ

បើប្រវត្តិវិទូបរទេសថា អង្គការខ្មែរក្រហម ធ្វើការបែងចែកប្រជាជនកម្ពុជាជាពីរក្រុម គឺ ៖

ក្រុមទី១ ៖ ហៅថាប្រជាជនចាស់ ឬហៅថាប្រជាជនមូលដ្ឋាន ជាក្រុមប្រជាជនដែលនៅនឹងមូលដ្ឋាននោះផ្ទាល់ ហើយដែលអ្នកទាំងនោះរស់នៅក្នុងតំបន់រំដោះមុនពួកខ្មែរក្រហម បើកប្រតិបត្តិការណ៍វាយយកទីក្រុងភ្នំពេញ។ ជា

[127] កម្ពុជា ឆ្នាំ សូន្យ ,ទំ ១០៦_១១០

ទូទៅប្រជាជនចាស់ ឬប្រជាជនមូលដ្ឋានទាំងនោះមានសិទ្ធិច្រើន ដោយសារបដិវត្តន៍ខ្មែរក្រហមបានពឹងផ្អែកជាសំអាងលើ"ប្រជាជនមូលដ្ឋាន" ឬហៅថា "ប្រជាជនចាស់" ឬ "ប្រជាជនពេញសិទ្ធិ"។

ក្រុមទី២ ៖ ហៅថាប្រជាជនថ្មី ឬប្រជាជន១៧មេសា ជាប្រជាជនដែលបានវិលត្រឡប់ទៅរស់នៅស្រុកកំណើតខ្លួនវិញ និងប្រជាជនដែលរស់នៅទីក្រុងភ្នំពេញ។ "ប្រជាជនថ្មី" គឺប្រជាជនរស់នៅតាមទីក្រុងនានា ដែលត្រូវរំដោះក្រោយគេ។ "ថ្មី"មានអត្ថន័យមួយធ្ងន់ទៅខាងរឿងមិនល្អ គឺប្រជាជនដែលមានទម្លាប់អាក្រក់ទទួលពីពួកបរទេស ។ "ប្រជាជនត្រៀម "គឺប្រជាជននៅតាមជនបទនានាដែលគេ "រំដោះ "នៅថ្ងៃទី ១៧ មេសា ឆ្នាំ១៩៧៥ ហើយដែលឆ្លងមេរោគពីឥទ្ធិពលចង្រៃតិចតួច ដោយប្រើការអប់រំមួយ ដែលប្រៀបផ្ទឹមទៅនឹងការលត់ដំមួយ គេអាចប្រមូលបានមកវិញ (នូវអ្វីៗដែលបម្រុងនឹងខូចខាត)។ "ប្រជាជនបញ្ញើ"គឺប្រជាជនក្រុងភ្នំពេញ ដែលធ្វើឱ្យមានទម្លាប់ផ្តេសផ្តាសខ្លាំងបំផុត ដោយសារឥទ្ធិពលចង្រៃនៃអារ្យធម៌បរទេស ជាអ្នកដែលប្រហែលជាគេមិន "ស្រង់"មកវិញទេ ។

"ចាស់" និង"ថ្មី" គឺក្នុងការត្រឡប់ទៅរកអតីតកាលដ៏យូរលង់ ជានិមិត្តរូបនៃភាពស្អាតបរិសុទ្ធនេះហើយ ដែលអាចឱ្យគេយល់ពីការប្រព្រឹត្តរបស់ពួកអ្នកបដិវត្តន៍។ ដោយផ្ទុយនឹងអ្នកបដិវត្តន៍ម៉ាកស៊ីសនិយមដទៃទៀតដែលរៀបចំខ្លួនឆ្ពោះទៅរកនវភាព(ភាពថ្មី) និងការរីកលូតលាស់ការបដិវត្តន៍របស់ខ្មែរបានប្រែក្រឡាប់ទៅរកអតីតកាលវិញយ៉ាងអង់អាច។

គួរកត់សម្គាល់ថា ជាការអនុវត្តន៍ទូទៅ របប ប៉ុល ពត មានការបែងចែកប្រភេទមនុស្សលើសពីពីរនេះទៅទៀត។ ដូចជា លោក នៃ ប៉េណា (១៩៩១០:៩៦-៩៧)បានអះអាងថា កម្ពុជាប្រជាធិបតេយ្យ បានបែងចែកប្រជាជនជាបីប្រភេទ គឺ ៖

- ប្រភេទទី១ "ប្រជាជនពេញសិទ្ធិ" ដែលរួមមានប្រជាជនរស់នៅក្នុងតំបន់រំដោះ មុនឆ្នាំ១៩៧៥ ហើយដែលជាអ្នកក្រីក្រ គឺជាប្រភេទ"ស្អាតស្អំ"។ អ្នកទាំងនោះ មានកម្មករពលករជនបទ, កសិករក្រីក្រ, កសិករកណ្តាលថ្នាក់ក្រោម, កសិករកណ្តាលថ្នាក់កណ្តាល។ ប្រជាជនពេញសិទ្ធិមានសិទ្ធិអនុម័ត មានសិត្ថិដឹកនាំគ្រប់គ្រង, មានសិទ្ធិបោះឆ្នោត និងឈរឈ្មោះឱ្យគេបោះឆ្នោត។

- ប្រភេទទី២ "ប្រជាជនត្រៀម" ដែលរួមមានអ្នករស់នៅក្នុងតំបន់រំដោះមុនឆ្នាំ១៩៧៥ដែរ តែជាអ្នកមានទ្រព្យធនគួរសម អ្នកទាំងនោះច្រើនមានចិត្តគំនិតប្រឆាំងនឹងចលនាតស៊ូរបស់ប៉ុលពត។ ប្រជាជនត្រៀម ជាអនុធនថ្នាក់ក្រោម, អនុធនថ្នាក់កណ្តាល, អនុធនថ្នាក់លើ ដែលរួមមានសិស្ស, និស្សិត, អ្នកលក់ដូរ, កសិករមាន, អ្នករដ្ឋការសង្គមចាស់, ព្រះសង្ឃ... ពួកទាំងនេះមានសិទ្ធិផ្តល់យោបល់ តែពុំមានសិទ្ធិសម្រេចនិងពុំមានសិទ្ធិដឹកនាំគ្រប់គ្រងទេ។

- ប្រភេទទី៣ "ប្រជាជនបញ្ញើ"ដែលរួមមានអ្នកត្រូវបានរំដោះកាលពីថ្ងៃ១៧មេសា១៩៧៥ ចាប់ពីពលករ, កម្មករឯកជន ឡើងដល់មន្ត្រី, អភិជន, ស្តេច និងគិតទាំងព្រះសង្ឃផងដែរ។ អ្នកទាំងនោះកាន់តែធ្ងន់ធ្ងរ ជាងប្រភេទប្រជាជនត្រៀមទៅទៀត គឺពុំមានសិទ្ធិអ្វីទាំងអស់ រស់គ្រាន់តែជាបញ្ញើប៉ុណ្ណោះ។ ប្រជាជនបញ្ញើ ក៏ដូចជាប្រជាជនត្រៀមដែរ គឺក្នុងទំនាក់ទំនងសង្គម គេពុំមានសិទ្ធិយកប្រពន្ធ ឬប្តី ជាមួយប្រជាជនពេញសិទ្ធិបានទេ។ អង្គការសុទ្ធតែមានផែនការរួចទៅហើយ ចំពោះអ្នកទាំងនោះ។ ដូច្នេះ រង់ចាំតែថ្ងៃត្រូវគេយកទៅសម្លាប់ប៉ុណ្ណោះ។

ឯក្នុងចំណោមពួកកម្មាភិបាលខ្មែរក្រហម ប្រសិនបើមាននរណាម្នាក់ត្រូវចាប់ខ្លួន ក្រុមគ្រួសារទាំងអស់របស់អ្នកមានទោសនោះ ត្រឡប់ទៅជាប្រភេទអ្នកបញ្ញើទាំងអស់ដោយស្វ័យប្រវត្តិ។ អង្គការចាក់ទុកកម្មករនៃរបបចាស់, បញ្ញាជន, គ្រូបង្រៀន, អ្នកបច្ចេកទេស, អ្នកនិពន្ធ និងសិល្បករ។ល។ ជា"បរិវារខ្មាំង" និងស្ថិតក្នុង"វណ្ណៈខ្មាំង"។ អង្គការបាននិយាយថា អ្នកប្រភេទទី៣នេះ គឺជាមនុស្សបញ្ញើក្អែកដែលត្រូវតែកំទេចចោល។[128]

វណ្ណៈសង្គមដែល "ល្អឥតខ្ចោះ"គឺវណ្ណៈ "កសិករក្រកណ្តាលថ្នាក់ក្រោម" គឺថាកសិករទាំងឡាយដែលអាចហូបគ្រប់គ្រាន់តែក្នុងរយៈពេលពី៣ទៅ៤ខែប៉ុណ្ណោះក្នុងមួយឆ្នាំ ។ តាមភូមិសាស្ត្រ "វណ្ណៈ"នេះមានមួយភាគធំបំផុតរស់នៅតាមតំបន់នានា ដែលក្រីក្រជាងគេនៃប្រទេសកម្ពុជា មានព្រំប្រទល់ជាប់ព្រៃភ្នំ គឺថានៅចេនឡា។

វាពុំមែនឥតផលប្រយោជន៍ទេ ដែលត្រូវកត់សម្គាល់ថា ៖ភាគច្រើននៃពួកអ្នកទីក្រុង បានត្រូវគេបញ្ជូនទៅកាន់ព្រៃភ្នំមុនគេ បន្ទាប់មកទើបឱ្យធ្វើស្រែវិញនោះ ដើម្បីដាក់បង្ខឱ្យធ្វើការងារបង្កបង្កើនផលមួយ។ នេះប្រហែលជាដើម្បីជ្រមុជពួកនេះទៅក្នុង"អាងទឹក"មួយ ដែលពួកអ្នកខ្លាំងជាងគេនឹងងើបចេញមកវិញជាមនុស្សដែលត្រូវផ្លាស់ទឹកចិត្តថ្មី។[129]

បើសិនជាគេលើកលែងក្មេងៗអាយុតិចជាង១៤ឆ្នាំ ដែលនៅទទួលការអប់រំនៅឡើយនោះ ប្រជាជនខ្មែរទាំងអស់ត្រូវគេបែងចែកទៅជា "កម្លាំង" មាន៣ប្រភេទ ៖

"កម្លាំងទី១"រួមមានយុវជននៅលីវ ដែលមានអាយុលើ១៤ឆ្នាំ។ យុវជនទាំងនេះគឺជា "កងការងារឆ្នើមជាងគេ"។ ក្នុងភូមិនីមួយៗពួកគេបានរួមបង្កជា "ក្រុមយុវជន "មួយកង ឬ"ក្រុមយុវនារី"មួយកងជាមួយប្រធានម្នាក់ ឬប្រធានស្រីម្នាក់ អនុប្រធានម្នាក់និងសមាជិកម្នាក់។ ក្រុមទាំងនេះធ្វើការជាគុណប្រយោជន៍សម្រាប់ភូមិ ជួនកាលធ្វើការបែកពីគ្នាផង ។ ពួកគេច្រើនទៅធ្វើការជាញឹកញយនៅតាមការដ្ឋាននានា ឬតាមកសិដ្ឋានផ្សេងៗរបស់រដ្ឋ ។ ក្នុងករណីនេះ ពួកគេត្រូវតែចាកចេញទៅធ្វើការឆ្ងាយពីក្រុមគ្រួសារនិងភូមិរបស់ពួកគេ ដើម្បីហាត់លត់ដំខ្លួន ដែលជួនកាលហួតដល់រាប់ខែ។ គេហៅក្រុមយុវជនទាំងនេះថា "កងចល័ត" ពីព្រោះពួកគេស្ថិតនៅក្រោមការចាត់ចែងរបស់អង្គការទាំងស្រុង ដែលប្រើប្រាស់កម្លាំងនេះទៅតាមសេចក្តីត្រូវការផ្សេងៗរបស់ខ្លួន ។

«កម្លាំងទី២»គឺរួមមានអ្នកដែលរៀបការរួចជាមួយនឹងកូនៗ ឬ«មនុស្សអាយុមជ្ឈិម»នេះជាពាក្យពេជន៍ដែលគេផ្សាយចេញតាមវិទ្យុ។ "ពួកគេធ្វើការយ៉ាងសកម្មនូវអ្វីដែលអង្គការបានស្នើ ពួកគេធ្វើការដោយស្មើភាពគ្នាសម្រាប់បុរសនិងស្ត្រី អ្វីដែលបុរសធ្វើបាន, ស្ត្រីក៏អាចធ្វើបានដូចគ្នា"។ ស្ត្រីដែលមានផ្ទៃពោះលើសពី៧ខែ និងស្ត្រីដែលមានកូនវ័យក្មេងម្នាក់ សុទ្ធតែមានរបបការងារពិសេសមួយ។ នៅតំបន់ជាច្រើនគេបានរាយការណ៍ឱ្យដឹងថា បុរសៗនៃ"កម្លាំងទី២"នេះក៏ចាកចេញពីក្រុមគ្រួសារនិងភូមិរបស់គេសម្រាប់រយៈពេលបីខែ ដើម្បីបំពេញការងារពិបាកៗដូចជាការភ្ជួររាស់ ឬច្រូតស្រូវជាដើម ។ ត្រឡប់មកផ្ទះវិញ សម្រាប់រយៈពេលមួយឬពីរថ្ងៃពួកគេត្រូវចាកចេញជាថ្មី ដើម្បីទៅបំពេញការងារផ្សេងទៀត ។

"កម្លាំងទី៣" រួមមាន "បុរសនិងស្ត្រីអាយុច្រើន" ដែលគេហៅយ៉ាងគួរឱ្យធ្ងល់ថា"យុវចាស់"។ មនុស្សទាំងនេះ បានប្រមូលផ្តុំទៅជាក្រុមបុរស និងក្រុមស្ត្រីមានមេដឹកនាំបីនាក់ដូចក្រុមឯទៀតៗដែរ។ នៅពេលដែលយុវជន

[128] នៃ ប៉េណា, ១៩៩១, *ការផ្តួលរលំនៃរបបប្រល័យពូជសាសន៍ប៉ុលពត,* ការបោះពុម្ពផ្សាយរបស់កាសែតប្រជាជន, ភ្នំពេញ, ទំព័រ ៩៦-៩៨។

[129] *កម្ពុជា ឆ្នាំសូន្យ ,*។ទំព័រ ។២៤៧

និងពួកពេញវ័យធ្វើការនៅក្នុងស្រែ ជីកប្រឡាយ ឬលើកទំនប់ "យុវចាស់ទាំងនេះ នៅអង្គុយក្រោមម្លប់ឈើ ឬក្បែរខ្ទម ដើម្បីវេញខ្សែ, ត្បាញកញ្ច្រែង, ល្អី, កញ្ជេ, ចង្អេរ...ដោយសប្បាយរីករាយ និងប៉ិនប្រសប់ក្នុងកម្រិតភ្ញាក់លើកខ្ពស់មួយ"។

ចំណែកពួកស្ត្រីវ័យចំណាស់ បាន"ខិតខំយកចិត្តទុកដាក់មើលថែទាំក្មេងតូចៗដោយដាំបាយ,មុជទឹកនិងនាំវាឱ្យដេកដោយត្រឹមត្រូវ"។ ដើម្បីអប់រំក្មេងៗទាំងនោះ ពួកគាត់បាន "និទានរឿងប្រវត្តិខ្លីៗនៃវីរជនមួយចំនួន ដើម្បីឱ្យក្មេងទាំងនោះពង្រឹងស្មារតីបដិវត្តន៍របស់គេ"។

មនុស្សចាស់ជរាទាំងឡាយចូលចិត្តនិយាយឡើងវិញថា"គឺកិត្តិយសមួយធំណាស់ ដែលបានមករស់នៅក្នុងកម្ពុជាបដិវត្តន៍" ។

## 5. ការសម្លាប់មនុស្ស

ក្នុងរយៈពេលនៃការកាន់កាប់អំណាចផ្ដាច់ការរបស់ខ្មែរក្រហមចំនួន៤៤ខែ ឬ ៣ឆ្នាំ៨ខែ ២០ថ្ងៃ តើមានប្រជាជនកម្ពុជាស្លាប់ប៉ុន្មាននាក់? សព្វថ្ងៃនេះទៀត គេពុំបានដឹងរឿងនេះដោយជាក់លាក់ឡើយ។ ហើយប្រហែលជាគេពុំដឹងចំនួនពិតប្រាកដជារៀងរហូត។

### តើគេអាចសម្រេចធ្វើបញ្ជីបូកសរុបដោយរបៀបណា?

នៅឆ្នាំ១៩៧០ គេបានវាយតម្លៃជាទូទៅថា នៅប្រទេសកម្ពុជាមានប្រជាជន៨លាននាក់ ដែលមានជនជាតិវៀតណាម៤០០.០០០នាក់ និងជនជាតិចិនច្រើនជាងនេះបន្តិច កំពុងរស់នៅក្នុងប្រទេសនេះតាំងពីច្រើនឆ្នាំមកហើយ។ នៅឆ្នាំ១៩៧៥ សម្ដេច សីហនុ បានមានព្រះតម្រិះដូចគ្នានឹងពួកអាមេរិកាំងដែរ ដែលគិតថាមានអ្នកស្លាប់ដោយសារសង្គ្រាមចំនួន៦០០.០០០នាក់ និងអ្នករបួស៦០០.០០០នាក់ដែរ។ នៅក្នុងឱកាសនៃការប្រារព្ធខួបកំណើតលើកទី១ ក្នុងការរំដោះប្រទេសជាតិ គឺថ្ងៃទី១៧ មេសា១៩៧៥ ពួករដ្ឋអំណាចកម្ពុជាប្រជាធិបតេយ្យបានប្រកាសថាប្រជាជនខ្មែរ៨០០.០០០នាក់ បានត្រូវស្លាប់ដោយសារសង្គ្រាមនិងអ្នករបួសពិការ២៤០.០០០នាក់។[130]

ពួកអ្នកស្លាប់ដោយសារសង្គ្រាម។ សង្គ្រាម៤លើកក្នុងរវាង២៥ឆ្នាំ ៖ សង្គ្រាមរបស់កងទ័ពខេមរភូមិន្ទបន្ទាប់មកកងទ័ពលន់ នល់ ប្រឆាំងនឹងពួកខ្មែរក្រហម, សង្គ្រាមរបស់អាមេរិកាំងប្រឆាំងនឹងប្រទេសកម្ពុជា, សង្គ្រាមរបស់ប្រទេសវៀតណាម និងពួកខ្មែរក្រហម, សង្គ្រាមផ្ទៃក្នុងបន្ទាប់ពីការដណ្ដើមបានទីក្រុងភ្នំពេញវិញនៅឆ្នាំ១៩៧៩។

ពួកអ្នកស្លាប់ដោយការហេវហត់ ដោយការអស់កម្លាំងនៅតាមផ្លូវនានាក្នុងឱកាសនៃការជម្លៀសចេញពីទីក្រុងភ្នំពេញនៅឆ្នាំ១៩៧៥។ តួលេខចំនួនអ្នកស្លាប់នេះ គេនៅមិនដឹងរហូត ។

ពួកអ្នកស្លាប់ដោយការអត់ឃ្លាន, របបអាហារដែលមានចំនួនកាន់តែខ្សត់ទៅៗយ៉ាងខ្លាំង។ គេនិយាយថា មានអ្នករងគ្រោះ៨០០.០០០នាក់។

ពួកអ្នកដែលស្លាប់ដោយសារជម្ងឺ។ គេអាចព្យាបាលអ្នកទាំងនោះឱ្យជាបាន បើសិនជាគេមានថ្នាំពេទ្យសម្រាប់ព្យាបាលនៅពេលដែលគេត្រូវការ ប៉ុន្តែវាគ្មានអ្វីទាំងអស់ ។

---

130 កម្ពុជា ឆ្នាំ សូន្យ ,ទំ ៨៨

ពួកអ្នកដែលស្លាប់ដោយការបាញ់សម្លាប់ចោល ពីព្រោះពួកគេសុទ្ធតែជានាយទាហាន ឬនាយទាហានរងក្នុងកងទ័ពរបស់សម្តេចសីហនុ ឬលន់ នល់ ហើយដែលពួកខ្មែរក្រហមបានសម្រេចសម្លាប់អ្នកទាំងនោះដាច់អហង្ការ។

ពួកអ្នកស្លាប់ដោយបន្ថប់ដង្ហើម ដោយពួកអ្នកពេជ្ឈឃាតរបស់អង្គារ, អ្នកសម្លាប់ទាំងនេះសុទ្ធតែទទួលបញ្ជាឱ្យសន្សំសំចៃគ្រាប់កាំភ្លើងជាដាច់ខាត។ នៅពេលនោះ ពួកគេបានបន្ថប់ដង្ហើមពួកអ្នករងគ្រោះ ដោយច្រកក្បាលចូលទៅក្នុងថង់ប្លាស្ទិកមួយ។

ពួកអ្នកស្លាប់ដោយចម្ការមីនទាំងឡាយ នៅពេលកំពុងសាកល្បងឆ្លងកាត់ព្រំដែនទៅប្រទេសថៃ។

ពួកអ្នកស្លាប់ដោយនៅក្នុងគុក និងជំរំនានា ជាកន្លែងដែលពួកគេត្រូវឃុំឃាំងដោយអំណាចផ្តាច់ការ។ អ្នកខ្លះស្លាប់ ពីព្រោះពួកគេពាក់វ៉ែនតា ហើយដែលគេចោទថា ជា "បញ្ញវន្ត"...។

ពួកអ្នកស្លាប់នៅក្រុងភ្នំពេញ ក្នុងគុកទួលស្លែង ដោយស្នាដៃប្រធានសន្តិសុខដ៏គួរឱ្យព្រឺខ្លាចឈ្មោះ ឌុច ដែលបានបញ្ចេញគំនិតឱ្យដឹងតាំងពីពេលនោះថា "យើងគ្មានបានទទួលពីការណែនាំណាមួយពីបក្ស ស្តីពីរបៀបសម្លាប់អ្នកទោសឡើយ ប៉ុន្តែយើងមិនប្រើគ្រាប់កាំភ្លើងទេ។ ជាធម្មតាយើងសម្លាប់អ្នកទាំងនោះដោយអារកតែម្តង (សម្ភាសន៍របស់ឌុច ជាមួយទស្សនាវដ្តី Far Eastern Economic Review ដែលចេញផ្សាយនៅទីក្រុងហុងកុង )។ គាត់ភ្លេចបន្ថែមថា ៖ បន្ទាប់ពីការធ្វើទារុណកម្មដ៏ខ្លាំងហួសហេតុ...ក្នុងចំនួនអ្នកជាប់គុកប្រហែល ២០.០០០នាក់ មានតែ៧នាក់ប៉ុណ្ណោះដែលរស់រានមានជីវិតចេញពីឋាននរកនេះ...។

ពួកអ្នកស្លាប់ដោយដុត និងកប់ទាំងរស់ ឬជ្រមុជទឹកសម្លាប់ក្នុងទន្លេមេគង្គ ។

ពួកអ្នកស្លាប់ទាំងក្មេងខ្ចីក្នុងដៃម្តាយរបស់គេ ពីព្រោះពួកគេសុទ្ធតែមានមាត់ចាំតែស៊ី ឥតប្រយោជន៍។

បន្ទាប់ពីនេះគេបានសម្លាប់ម្តាយរបស់វាថែមទៀត ។

ពួកអ្នកដែលស្លាប់ដោយមានអាយុច្រើនពេក ពីព្រោះពួកនេះលែងមានប្រយោជន៍អ្វីទៀតហើយ។ ប៉ុល ពត ហ៊ានអះអាងថា៖ "ដើម្បីរៀបចំកម្ពុជាថ្មី យើងត្រូវការយុវជនតែមួយលាននាក់ ឬពីរលាននាក់គ្រប់គ្រាន់ហើយ"។

នៅឆ្នាំ១៩៧០ មុនពេលដែលមហន្តរាយសង្គ្រប់មកលើប្រទេសកម្ពុជាបន្តិច អ្នកឯកទេសខាងប្រជាសាស្ត្រម្នាក់បានវាយតម្លៃថា ក្នុងប្រទេសមានប្រជាជនចំនួន៧៦៣.០០០នាក់ (សៀវភៅ Cambodge : faits et problèmes de population របស់លោក Jacques Migozzi, Paris, CNRS ,1973 )។

នៅទីបំផុតនៅពេល ដែលសង្គ្រាមរលត់ហើយដែលគេអាចចាប់ផ្តើមរាប់ចំនួនមនុស្សឡើងវិញ គេដឹងថា អ្នកបាត់បង់ជីវិត ឬអ្នកបាត់ខ្លួនមានចំនួនច្រើនសម្បើមណាស់។ នៅឆ្នាំ១៩៩០ តួលេខអ្នកស្លាប់ជាផ្លូវការដែលចេញផ្សាយដោយរដ្ឋាភិបាលរបស់កម្ពុជា គឺ ៣.៣១៤.៧៦៨ នាក់។ ប៉ុន្តែភាពជាក់លាក់នៃតួលេខនេះបានជំរុញឱ្យគេចោទសួរខ្លួនឯងអំពីភាពត្រឹមត្រូវរបស់វា។ ក្នុងប្រទេសមួយ ដែលគ្មានវិទ្យាស្ថានណាមួយអាចប្រៀបធៀបបាននឹងវិទ្យាស្ថានជាតិនៃស្ថិតិ និងការស្រាវជ្រាវផ្នែកសេដ្ឋកិច្ចរបស់យើង តើគេអាចរៀបចំធ្វើស្ថិតិអ្នករងគ្រោះបានដោយរបៀបណា ? ឧបមាថា គេទទួលស្គាល់ចំនួនអ្នកស្លាប់សរុបដ៏សម្បើមនេះ តែគ្មានអ្នកណាផ្តល់នូវការចង្អុលបង្ហាញដ៏ប្រាកដប្រជាស្តីពី ចំណែកដែលជាអំពើប្រល័យពូជសាសន៍ផ្ទាល់ឡើយ។

ដើម្បីល្បងចង់ដឹងរឿងនេះច្រើនថែមទៀត ការងារជាច្រើនបានត្រូវចាប់ផ្តើមធ្វើដោយកម្មវិធីប្រល័យពូជសាសន៍របស់កម្ពុជា(Cambodian Genocide Program)នៃសាកលវិទ្យាល័យយែលរបស់អាមេរិកាំង ដោយសហការណ៍គ្នាជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា, ជាវិទ្យាស្ថានមិនមែនរដ្ឋាភិបាលមួយនៅក្រុងភ្នំពេញ។ ពីឆ្នាំ១៩៩៥ ដល់ឆ្នាំ១៩៩៧ ដោយមានជំនួយរបស់រដ្ឋាភិបាលអាមេរិកាំង,អូស្ត្រាលី និងហុល្លង់ផង អ្នកគូរផែនទីជាច្រើនក្រុម

បានស្រាវជ្រាវ និងកំណត់យ៉ាងច្បាស់ទីតាំងគរឆ្អឹងខ្មោចចំនួន២២០កន្លែង នៅ៨១ស្រុក ក្នុងចំណោម១៧០ស្រុក នៃប្រទេសកម្ពុជា។ ទីតាំងគរឆ្អឹងខ្មោចទាំងនោះរួមមាន៩.១៣៨រណ្តៅ មានផ្ទុកសាកសពប្រហែលកន្លះលាននាក់។ ដូច្នេះសាកសពដែលកប់នៅក្នុងរណ្តៅទាំងនោះ តាមប្រហាក់ប្រហែលនឹងមានចំនួនមួយលាននាក់ ។

ការវាយតម្លៃដែលធ្វើឡើងដោយពួកអ្នកស្រាវជ្រាវអាមេរិកាំង ជាពិសេសលោក បិន ឃៀនិន បានធ្វើឱ្យដឹងថា ចំនួនជនរងគ្រោះសរុបពីអំពើប្រល័យពូជសាសន៍កម្ពុជា គឺក្បែរ១លាន៧សែននាក់ទៅ១លាន៨សែននាក់(បិន ឃៀនិន, ទាញហេតុសំអាងនៅក្នុងសៀវភៅរបស់គាត់,ទំព័រ៥៣៤, នូវតួលេខអ្នករងគ្រោះចំនួន ១.៦៧១.០០០នាក់។ តួលេខនេះ គឺដូចតួលេខដែលត្រាទុកក្នុងសៀវភៅរបស់គាត់ ដែលមានចំណងជើងថា Le Génocide Khmer rouge = une analyse démographique, Paris, L´Harmattan, 1995 ។ គេអាចមើលដោយការយកចិត្តទុកដាក់នូវសៀវភៅរបស់លោក ហង់រី ឡូការដ៍ ក្រោមចំណងជើងថា Prisonnier de l'Angkor, Paris, Fayard, 1993 ដែលវាយតម្លៃថា មួយភាគបីនៃអ្នករងគ្រោះ បានត្រូវសម្លាប់នៅក្នុងគុកទាំងឡាយរបស់ខ្មែរក្រហម។ ត្រូវជម្រាបឱ្យដឹងពីការធ្វើជាសាក្សីដ៏គួរឱ្យចាប់អារម្មណ៍ខ្លាំងរបស់លោក François bizot ផងដែរដែលជាអ្នកនិពន្ធសៀវភៅ Le Portail , La Table ronde, 2000។ ជាសមាជិកសាលាបារាំងចុងបូព៌ាប្រទេស គាត់បានត្រូវចាប់ដាក់គុកដោយពួកខ្មែរក្រហមនៅឆ្នាំ១៩៧១ គឺ៤ឆ្នាំមុនការដណ្តើមបានទីក្រុងភ្នំពេញ។ ក្នុងសៀវភៅនោះ គាត់បានរៀបរាប់ពីការធ្វើបដិវត្តន៍នៅផ្នែកខាងក្នុង...។[131]

បញ្ញវន្ត ឬអ្នកមានឈ្មោះល្បីល្បាញទាំងអស់ សុទ្ធតែត្រូវតាមស្វែងរក, បង្ខំឱ្យធ្វើកិច្ចការធ្ងន់ៗឬសម្លាប់ចោលដោយគ្មានធ្វើការកាត់ទោសឡើយ។ ចំពោះអ្នកណាចេះដាក់ខ្លួន ទោះបីពួកកម្មាភិបាលខ្មែរក្រហមហៅថា " លោកបញ្ញាសុញ"ក៏ដោយ ក៏នៅតែញញឹម ធ្វើមិនឈឺ មិនយល់សេចក្តី ទើបអាចគង់ជីវិតបាន។ ពេញរយៈពេលនៃការកាន់កាប់របស់របបពួកខ្មែរក្រហម ដែលជាម្ចាស់លើប្រទេសជាតិ ពួកគេបានបំផ្លាញ៥.៨៥៧សាលារៀន, ១.៩៨៧ វត្ត (ដែលនៅសល់ស្ទើរតែមិនដល់៥០០វត្តផងនៅឆ្នាំ១៩៧៩)។[132]

ពេលវេលាដែលនៅតាមភូមិភាគមានការកាប់សម្លាប់រង្គាលខ្លាំង គឺនៅបន្ទាប់ពីការបង្ក្រាបក្រុម សោ ភឹម បានជោគជ័យ។ ពេលនោះ កម្មាភិបាលស្រុកអាយ ឬក្នុងស្រុកដ៏ឆ្មើមៗក្នុងការកាប់សម្លាប់ជនស្លូតត្រង់មិនរើសមុខ ត្រូវកម្មាភិបាលស្រុកនាយ ដែលទំនងចេញពីភូមិភាគបស្ចិម[133] ដែលធ្លាប់ត្រូវប៉ុល ពតបណ្តុះបណ្តាលផ្ទាល់ដៃប្រើវិធីក្តៅ និងត្រជាក់ ចាប់យកទៅកំទេចចោលទាំងអស់។

លេសដើម្បីធ្វើការសម្លាប់មនុស្ស របស់ពួកខ្មែរក្រហម

ជាទូទៅអ្នកទោសត្រូវបានពួកគេចោទប្រកាន់ថាជាភ្នាក់ងារ គិញសម្ងាត់ "សេអ៊ីអា"អាមេរិក ឬ កាហ្សេបេ" សូវៀត" ឬយួន។ ក្នុងចម្លើយទាំងបីនេះ មួយណាក៏អ្នកទោសមិនអាចគេចផុតពីសេចក្តីស្លាប់បានឡើយ។ គ្រូពេទ្យម្នាក់ត្រូវចាប់នៅពេលភ្លើងអគ្គិសនីដាច់ដែលធ្វើឱ្យខូចថ្នាំដែលរក្សាទុកក្នុងទូរទឹកកក ហើយរូបគេត្រូវបញ្ជូនទៅស.២១ ដែលជាគុកមជ្ឈិមមួយក្នុងចំណោម១៩៦គុកនៅទូទាំងប្រទេសពេលនោះ។ ពួកខ្មែរក្រហម

[131] ប៉ុល ពត ទំព័រ ២៧២_២៧៦

[132] ដដែល ទំព័រ ២៧៦

[133] ពួកនេះនិយាយរដឺន ហើយប្រាប់អ្នកស្រុកថា ខ្លួនចេញពីភូមិភាគនិរតី។ ប៉ុន្តែ នៅភូមិភាគនិរតី គ្មានស្រុកណាមួយដែលអ្នកស្រុកនិយាយរដឺនបែបនោះឡើយ។ ក្រោយពីខ្ញុំស្គាល់ទឹកដីកំពង់ស្ពឺ ខាងថ្ពង, ឱរ៉ាល់, រលាក់កងជើង និងភ្នំស្រួច ទើបខ្ញុំហ៊ានសន្និដ្ឋានថា មនុស្សនោះ ច្បាស់ជាចេញពីតំបន់នេះឯង។

សម្លាប់មនុស្សនៅក្នុងជួរបក្ស ជាទូទៅគេធ្វើការចោទប្រកាន់ថាបានរំលោភលើមាគ៌ា ""វណ្ណៈអធនជាច់ខាត" គេចោទជាជនក្បត់ អង្គការបក្សនៅឆ្នាំ១៩៧៨ ចំនួនជាង១ភាគ៤នៃសមាជិកគណៈមជ្ឈឹមបក្សដែលមានគ្នាទាំងអស់ ២២នាក់ត្រូវបានសម្លាប់។

នៅភូមិភាគបូព៌ាដែលនៅជាប់ព្រំដែនយួនបានស្ថិតក្រោមការសង្ស័យ ហើយប្រជាជនត្រូវចាប់។ពួកគេត្រូវសង្ស័យថាក្បត់ដែលមាន"ក្បាលយួនខ្លួនខ្មែរ"ហើយភូមិភាគទាំងមូលត្រូវបាន"បោសសំអាត"ខ្លាំង។

បន្ទាប់ពីការដួលរលំរបស់ខ្មែរក្រហមនៅក្នុងឆ្នាំ១៩៧៩ ប្រជាជនមួយភាគបីត្រូវសម្លាប់។ ក្នុងចំណោមវេជ្ជបណ្ឌិត៥៥០នាក់នៅរស់តែ៤៨នាក់ ក្នុងចំណោមនិស្សិត ១១ ០០០នាក់នៅសល់តែ៤៥០នាក់ដែលរកឃើញ ហើយក្នុងចំណោមសិស្សមធ្យមសិក្សា ១០៦០០០នាក់ នៅរស់តែ ៥៣០០នាក់ប៉ុណ្ណោះ។

ជាទូទៅមានការទទួលស្គាល់ថា ក្នុងរយៈពេល១៣៦៤ថ្ងៃក្រោមរបបខ្មែរក្រហម ប្រជាជនចំនួនជាង២លាននាក់បានស្លាប់ ជាលទ្ធផលនៃនយោបាយរបស់ខ្មែរក្រហម ពោលគឺស្លាប់ប្រមាណ១៤៦៦នាក់ក្នុងមួយថ្ងៃ។ បើគិតជាភាគរយនៃប្រជាជនវិញ ការសម្លាប់រង្គាលនៅកម្ពុជាមានកម្រិតអាក្រក់ជាងអ្វីដែលបានកើតមាននៅកន្លែងដទៃទៀតនៃសកលលោក។ ពោលគឺច្រើនជាងចំនួនមនុស្សដែលត្រូវបានសម្លាប់នៅក្នុងទ្វីបអឺរ៉ុបដែលទន្ទ្រានកាន់កាប់ដោយពួកណាហ្ស៊ី និងការប្រល័យពូជសាសន៍នៅរ្វ៉ាន់ដាទៅទៀត។ ក្នុងន័យនេះ ខ្មែរក្រហមបានសម្រេចប្រកបដោយប្រសិទ្ធភាពជាងគេ ក្នុងការសម្លាប់រង្គាលនៅក្នុងប្រវត្តិសាស្ត្រកម្ពុជាសម័យសហសម័យ។[134]

អ្នកណាដែលមានការទាក់ទងនឹងសង្គមចាស់ដោយបែបណាក៏ដោយ ត្រូវបានកៀងបញ្ចូលដាក់ឡាន និងនាំយកទៅសម្លាប់ចោល។[135]

នៅក្នុងសហករណ៍ទូទាំងប្រទេស ប្រជាជនមូលដ្ឋានបានស៊ើបការណ៍ពី "ប្រជាជនថ្មី" ហើយអ្នកនៅជិតខាងគ្នាយកការណ៍ពីគ្នាទៅវិញទៅមក។ ទាំងអស់គ្នាមិនទុកចិត្តគ្នាទៅវិញទៅមកទេ។ ការសង្ស័យតែបន្តិចបន្តួចតាមពាក្យចចាមអារ៉ាម ឬពាក្យសំដីបញ្ចិតបញ្ចៀងដាក់គ្នា គឺជាការគ្រប់គ្រាន់សម្រាប់យកអ្នកណាម្នាក់ចេញ។ ដោយការត្រួតត្រាប្រជាជនដ៏តឹងរ៉ឹងរបស់ខ្មែរក្រហម និងការប្រែប្រួលជាប្រចាំនៃច្បាប់នេះហើយ ទើបប្រជាជនខិតខំរកវិធីផ្សេង ដើម្បីការពារខ្លួនរបស់គេ។ ភាគច្រើនបានប្រកួតប្រជែងគ្នាដើម្បីមុខតំណែង និងឥទ្ធិពលអ្វីមួយ។ ការសងសឹកត្រូវបានសម្តែងចេញតាមរូបភាពផ្សេង ដូចជាការច្រណែន និងការចាក់ចុចអុចអាលពីរឿងកំប៉ិកកំប៉ុកធ្វើជាលេសដែលសុទ្ធតែជាលក្ខណៈពិសេសនៃជីវិតនៅតាមភូមិនោះ ហើយការនោះមានកម្លាំងគ្រោះថ្នាក់រហូតដល់ជីវិត។ វាហាក់ដូចជាប្រទេសទាំងមូលមានទំហំស្មើឃុំមួយប៉ុណ្ណោះ។ មានពេលខ្លះការសម្លាប់ត្រូវបានធ្វើនៅទីកន្លែងសាធារណៈ ដើម្បីជាគំរូសម្រាប់អ្នកដទៃទៀត។[136]

បើតាមលោកឱពុក ហ្វ្រង់ស្វ័រ ប៉ុងសូដ៍ (១៩៧៧) បានអះអាងថា "ប្រជាជនកម្ពុជាស្លូតបូត ស៊ូអត់ទ្រាំនឹងកំហឹងគ្រប់បែបយ៉ាង ប៉ុន្តែជួនកាលកំហឹងដែលលាក់ទុកក្នុងជម្រៅចិត្តនោះមិនអាចទប់បាន វាក៏ផ្ទុះឡើងយ៉ាងខ្លាំងក្លាបំផុត។ ខ្មែរក្រហមខឹងក្តៅក្រហាយនឹងកងទ័ពជើងអាកាសអាមេរិក ដែលទម្លាក់គ្រាប់បែកពាសពេញប្រទេស ក៏

[134]. នីក ដង ឡុប , ពេជ្ឈឃាដ បាត់ ខ្លួន , ទំព័រ ១៥២_១៥៣

[135]. *សៀវភៅ ដដែល , ទំ ៨៨*

[136]. *សៀវភៅ ដដែល , ទំ ៩៧*

ផ្ទុះកំហឹងទៅលើអ្នកក្រុង ហើយចោទថា បានរួមគំនិតជាមួយអាមេរិក រួចក៏សងសឹកយ៉ាងឃោរឃៅ។ អ្នករស់នៅជនបទគុំគួនអ្នកក្រុងរហូត។"[137]

ការសម្លាប់មនុស្សដែលគេប្រើពាក្យថា "កំទេច" ឬ "បោសសំអាត" ពួកខ្មែរក្រហមបានចាប់ផ្តើមធ្វើឡើងលើមនុស្សដែលស្ថិតនៅក្នុងជួរបក្ស, កងទ័ព ដែលអ្នកទាំងនោះ ជាមនុស្សដែលមានតួនាទីនៅក្នុងបក្សកុំម្មុយនិស្ត ជាលេខាភូមិភាគ មានភូមិភាគពាយ័ព្យ, ភូមិភាគឧត្តរ, ភូមិភាគឦសានរហូតដល់ជាសមាជិកបក្សរបស់ពួកគេទៀតផង។ ក្រៅពីនេះ អ្នកដែលជាប់និន្នាការពីរបបចាស់ ទាំងមន្ត្រីរាជការស៊ីវិល ចាប់ពីអ្នកដែលមានឋានៈរហូតដល់អ្នកដែលធម្មតា ត្រូវបានគេចាត់ទុកជាសត្រូវនឹងបដិវត្តន៍ត្រូវតែយកចេញ។

នៅពេលមនុស្សម្នាក់ត្រូវគេសង្ស័យថា ធ្លាប់ធ្វើកងទ័ពក្នុងរបបចាស់ ធ្លាប់ធ្វើជាអ្នករដ្ឋការឬកងកុម្ម៉ង់ដូរ ឬជាមេ១០ខ្នង, ៥០ខ្នង, ១០០ខ្នង ត្រូវគេយកទៅសម្លាប់ចោលគ្មានបង្អង់ ឬបាត់ខ្លួនតែម្តង។[138] រៀងរាល់យប់មនុស្សយ៉ាងច្រើនត្រូវគេហៅទៅ "អង្គការលើ" មនុស្សត្រូវបាត់ខ្លួនជាបន្តបន្ទាប់។ គ្រួសាររបស់អ្នកបាត់ខ្លួនត្រូវតែចៀសវាងកុំស្វះស្វែងចង់ដឹងពីជោគវាសនារបស់អ្នកនោះ ដោយខ្លាចមានវាសនាដូចគ្នាដែរ។ ចំពោះស្ត្រីម្នាក់ដែលយំសោកពីការសម្លាប់ប្តីរបស់គាត់ បានត្រូវកម្មាភិបាលខ្មែរក្រហមតបមកវិញថា៖ "ហេតុអ្វី បានជាអ្នកឯងយំសោកពីការស្លាប់របស់សត្រូវម្នាក់ របៀបនេះបង្ហាញឱ្យឃើញថា អ្នកឯងមិនស្រឡាញ់បដិវត្តន៍ទេ"។ ជួនកាលពួកកម្មាភិបាលបដិវត្តន៍ផ្ទាល់បានទទួលស្គាល់ថា បានសម្លាប់បុរសម្នាក់ដោយគ្មានហេតុផលគ្រប់គ្រាន់ឡើយ។ "សម្លាប់អ្នកស្លូតត្រង់ម្នាក់ ប្រសើរជាងទុកសត្រូវម្នាក់នៅមានជីវិត" នេះជាពាក្យដែលពួកគេនិយាយសម្រាប់ដោះសារពីអំពើឧក្រិដ្ឋរបស់ខ្លួន។ ទុកជាយ៉ាងណាក៏ដោយ ក៏ពួកអ្នកបដិវត្តន៍ខ្មែរយកចិត្តទុកដាក់តិចតួចណាស់អំពីតម្លៃជីវិតរបស់បងប្អូនជនរួមជាតិឯងដែលមិនចូលរួមក្នុងបុព្វហេតុរបស់គេ "ទុកមិនចំណេញ ដកចេញក៏មិនខាត"។

ពួកខ្មែរក្រហមកម្រធ្វើឱ្យផ្អើលឈូឆរណាស់ នៅពេលដែលពួកគេចាត់ការសម្លាប់មនុស្សម្តងៗ។ ជាទូទៅអ្នកភូមិទទួលក្រដាសមួយសន្លឹក ដែលមានដាក់បញ្ជាឱ្យទៅជួបអង្គការលើ។ អ្នកភូមិត្រូវពួកយោធាខ្មែរក្រហមនាំយកទៅនៅពេលយប់។ ដោយការសន្សំសំចៃ នៅពេលទៅដល់កន្លែងធ្វើទារុណកម្ម ជាទូទៅពួកអ្នកទោសត្រូវគេវាយកញ្ចឹងកនឹងដងចប ឬព្រនង់ធ្ងន់ដែលធ្វើពីជាតុផ្សេងៗគ្នា។ ពួកកម្មាភិបាលខ្មែរក្រហមនិយាយថា "គេមិនត្រូវខ្ជះខ្ជាយគ្រាប់កាំភ្លើង សូម្បីមួយគ្រាប់សម្រាប់មនុស្សទាំងនេះទេ។

ពួកយុទ្ធជនក្មេងៗបានត្រូវគេឱ្យឈ្មោះបន្ថែមថា "អាខ្សែនីឡុង" ឬ "អាខ្សែតេអូ" ពីព្រោះជាមួយឧបករណ៍នេះហើយដែលពួកគេត្រូវចងពួកអ្នកទោសមុននឹងយកទៅសម្លាប់ចោល។ ម្យ៉ាងទៀតយុវជនក្មេងៗទាំងនេះបានបញ្ចេញឱ្យឃើញឆន្ទៈសប្បាយរីករាយនឹងការសម្លាប់ណាស់។ មនុស្សដែលគេធ្លាប់ជាអ្នកស្លូតត្រង់, អឹមអៀន តែជាបានគេឃើញនៅពេលនេះជាមនុស្សម្នាក់ ដែលមានចិត្តសាហាវឃោរឃៅ។

អ្នកភៀសខ្លួនមួយចំនួនសុទ្ធ តែជាអ្នកដែលស្ថិតក្នុងក្រុមមនុស្សត្រូវទទួលទោសឬប្រហាក់ប្រហែលត្រូវមានទោស។ ការដើរហើរគ្មានការអនុញ្ញាត ក៏ត្រូវបានគេយកទៅសម្លាប់ដែរ។[139]

---

[137] François Ponchaud, (1977). *កម្ពុជាឆ្នាំសូន្យ, គ្រឹះស្ថានបោះពុម្ពផ្សាយ* SIPAR, ភ្នំពេញ, ទំព័រ១៩៦។

[138] កម្ពុជាឆ្នាំសូន្យ ,ទំ ៨១

[139] កម្ពុជាឆ្នាំសូន្យ, ទំ ៨២-៨៣

ការងារគ្មានពេលសម្រាក ម្ហូបអាហារមិនគ្រប់គ្រាន់ ស្ថានភាពសុខភាពអាក្រក់ ការភ័យរន្ធត់ និងការកាប់សម្លាប់គ្មានចាំបាច់កាត់ទោស អាចធ្វើឱ្យគេស្រមៃឃើញពីតម្លៃមនុស្សដ៏ចម្លែករបស់ការបដិវត្តន៍ខ្មែរ។

កសិករមូលដ្ឋានស្អប់អ្នកក្រុង ដោយសារពួកអ្នកក្រុងជាខ្មាំងវណ្ណៈ និងដោយសារតែអ្នកទីក្រុងត្រូវគេចោទប្រកាន់ពីបទធ្វើឱ្យខូចខាតដល់ជនបទ ក្នុងពេលសង្គ្រាម។[140]

(សម្លាប់)ស្ត្រីដែលជាប្រពន្ធៗនាយទាហាន ដែលយំសោកពីការបាត់ខ្លួនរបស់ប្ដី "ហេតុអ្វីបានជាអ្នកឯងយំ? វា គឺជាសត្រូវម្នាក់"

ក៏ប៉ុន្តែ នៅតំបន់ជាច្រើនពួកអ្នកបដិវត្តន៍ពុំញញើតនឹងសម្លាប់ប្រពន្ធ និងកូនរបស់អ្នកជាប់ទោសឡើយ បន្ទាប់មកសម្លាប់ទាំងពួកកម្មាភិបាលខ្មែរក្រហមទៀត កាលបើគេដឹងពីចំណងគ្រួសាររបស់ពួកនេះ។ តាមការពិតនេះ គឺជាការដាក់ទណ្ឌកម្មជាប្រពៃណីមួយ "ការអនុវត្តន៍ សម្រាលមួយនូវក្រមព្រហ្មទណ្ឌរបស់កម្ពុជាឆ្នាំ១៩៧៧ ដែលគ្រោងទុកជាមុនថា ការសម្លាប់ហ៊េសអាចរាលដាលទៅដល់គ្រួសារអ្នកមានទោសទាំងមូល"។

តាំងពីឆ្នាំ១៩៧៥ និងជាពិសេសតាំងពីឆ្នាំ១៩៧៧ ការដកកម្មាភិបាលខ្មែរក្រហមមួយចំនួនធំចេញពីអំណាច ហើយជួនកាលការសម្លាប់របស់គេ(ខ្មែរក្រហម)បានបង្ហាញឱ្យឃើញដើមហេតុដោយសារចំណងគ្រួសារ ដែលពួកគេមានពាក់ព័ន្ធជាមួយពួកកងទ័ពខាងសាធារណរដ្ឋខ្មែរគឺ "ជាប់និន្នាការនយោបាយ"។[141]

បើតាមការសង្កេតតាំងពីដើម រហូតដល់ចុងសាច់រឿង មូលហេតុនៃការសម្លាប់មនុស្សរបស់ពួកខ្មែរក្រហម ដឹកនាំដោយប៉ុល ពត បណ្ដាលមកពីរឿងចម្បងមួយ គឺ"សងសឹក"។ គំនុំសងសឹករបស់ពួកនេះ មានចាប់តាំងពីមេដឹកនាំកំពូលចុះតាមលំដាប់រហូតដល់កម្រិតមូលដ្ឋាន។ ដោយសារ«ចង់សងសឹក» ពួកខ្មែរក្រហមបង្កើតលេសផ្សេងៗទៀត យកបិទបាំងអំពើលាមករបស់ខ្លួន ដូចជា ៖

១-ការធ្វើបដិវត្តកុំមុយនីសនៅលើលោកនេះ តែងតែបានកាប់សម្លាប់ប្រជាជនខ្លួនឯង។ ពីព្រោះទ្រឹស្ដីរបស់ពួកគេ គឺត្រូវតែ"កំទេច"អ្វីៗទាំងអស់ ទាំងមនុស្ស និងសម្ភារៈដែលជាប់និន្នាការរបបចាស់ និងជាកេរដំណែលរបស់ពួកប្រតិកិរិយា បន្ទាប់មកទើបគេត្រូវកសាងអ្វីៗឡើងវិញសារជាថ្មី ទាំងមនុស្ស និងសម្ភារៈ។ ហេតុនេះហើយទើបពួកគេត្រូវសម្លាប់មនុស្សដែលគេបានគិតទុកថា អាចប្រឆាំងនឹងគំនិតរបស់ពួកគេ ដូចជាបដិវត្តខែតុលា១៩១៧នៅរុស្ស៊ី មនុស្សស្លាប់អស់ប្រមាណ៥លាននាក់, នៅប្រទេសចិនអស់ប្រមាណជាង៧០លាននាក់, នៅកូរ៉េខាងជើង អស់ប្រមាណ២លាននាក់(និងបន្តស្លាប់ដោយសារគ្រោះអត់ឃ្លាន អស់ជាច្រើនលាននាក់ទៀតដរាបដល់សព្វថ្ងៃ), នៅវៀតណាមអស់ប្រមាណ២លាននាក់, នៅឥណ្ឌូនេស៊ីការបង្ក្រាបពួកកុម្មុយនិស្ត និងពួកជនសង្ស័យដែលមានស្នាមសាក់នៅលើដងខ្លួន បានសម្លាប់អស់មនុស្សស្ទើរតែ២លាននាក់ដែរ។ អញ្ចឹងហើយបានជាខ្មែរក្រហម ដែលមានមហិច្ឆតាចង់ធ្វើអ្វីៗឱ្យល្បីជាងគេនោះ (មហាលោតផ្លោះ មហាអស្ចារ្យ) សម្លាប់ជាតិសាសន៍ខ្លួនឯងក្បែរ២លាននាក់ដែរ ក្នុងចំណោមប្រជាជនសរុបប្រមាណ៨លាននាក់។

[140] យល់ដឹងពីរបបខ្មែរក្រហម , ទំ២៣៦

[141] កម្ពុជាឆ្នាំសូន្យ,ទំ២៥២-២៥៣

២-ពួកគេប្រើវិធីបំផុសកំហឹងវណ្ណៈ(Social class anger)និងបង្កគំនិតរើសអើង (Discrimination) ប្រឆាំងប្រជាជាតិឯង ដោយការលាតត្រដាងបំភ្លៃការពិត ធ្វើឱ្យអ្នកស្រែស្អប់ ចងកំហឹងពុះពោរចំពោះអ្នកក្រុង និងបណ្ដុះបណ្ដាលគំនិតសងសឹកនេះ ដល់យុវជន ឬអ្នកជនបទដែលគ្មានចំណេះដឹងទូទៅ ត្រៀមធ្វើកម្មាភិបាល បម្រើមុខងារតួម៉ាស៊ីនអង្គការបដិវត្តន៍របស់ខ្លួននៅតាមមូលដ្ឋាន តាំងពីមុនពេលបានកាន់អំណាច។ ពេលឱកាសគ្រប់គ្រងពេញលេញបានមកដល់ដៃ ក៏តាំងបែងចែកស្រទាប់មនុស្ស រួច"ចែកអំណាចសម្រេចចិត្តសម្លាប់មនុស្ស"ឱ្យពួកកម្មាភិបាលវ័យក្មេងនៅក្នុងស្រុក និងកម្មាភិបាលដែលខ្លួនបានអប់រំមនោគមវិជ្ជា ដោយគ្មានសតិសម្បជញ្ញៈ និងខួរក្បាលសម្រាប់គិតពិចារណាទាំងនោះ។ ម្ល៉ោះហើយ សូម្បីជារឿងទំនាស់ផ្ទាល់ខ្លួនបន្តិចបន្តួច ក៏កម្មា-ភិបាលទាំងនោះ អាចចោទប្រកាន់ ចាប់បញ្ជូនអ្នកគ្មានអំណាចទាំងឡាយទៅសម្លាប់ ឬកាត់ទោសសម្លាប់ដោយដៃខ្លួនឯងបានតែម្ដង។ ជាញឹកញយ គ្រាន់តែកូនឈ្លបម្នាក់ ក៏អាចបាញ់សម្លាប់ប្រជាជនបានដែរបើពួកគេចង់ធ្វើ។

៣-ការដែលពួកគេបង្ហាញពីគំនិតជាតិនិយមដ៏ជ្រុលហួសហេតុរបស់ខ្លួន ដើម្បីប្រើផែនការសម្រិតសម្រាំង (purge) ដើម្បីសម្លាប់មនុស្សណា ដែល

-ជាមន្ត្រីរាជការ, រដ្ឋការចាស់ ទាំងស៊ីវិល និងកងទ័ព ដែលគេចោទថា ខួរក្បាលជាប់កំអែលសក្តិភូមិ និងមូលធននិយម មានគំនិតពុយរលួយ ជិះជាន់មនុស្សដូចគ្នា ឬមិនបានស្រឡាញ់ជាតិជាដើម។

-ជាប្រជាជនថ្មី គឺពួកអ្នកទីក្រុងដែលទើបត្រូវរំដោះនៅថ្ងៃ១៧មេសា ដែលជាពួកមូលធន អនុធន សុទ្ធសឹងជាពួកឱកាសនិយម រង់ចាំទទួល ឬបេះផលស្រាប់ពីបដិវត្តន៍ ដោយមិនបានចុះចូលជួយបដិវត្តន៍ទាន់ពេល។

-អ្នកចេះដឹងទាំងឡាយ ដែលចេះគិតពិចារណា

-អ្នកទាក់ទងនឹងភ្នាក់ងារសម្ងាត់ស៊ីអាយអេ (CIA) របស់អាមេរិក និងកាហ្សេបេ (KGB) របស់រុស៊ី

-អ្នកទាក់ទងជាមួយវៀតណាម ជាពិសេស កម្មាភិបាលស៊ីវិល និងយោធា ដែលអប់រំដោយហាណូយ

៤-គេមានការភ័យអោរចំពោះអំពើក្បត់នៅជុំវិញខ្លួន (Paranoia) តែស្រមោលដ៏ឃោរឃៅ និងគំនិតឆ្វេងនិយមជ្រុលរបស់ខ្លួនឯង ទើបចេះតែគិតថា អ្នកដទៃនៅជុំវិញខ្លួនកំពុងគិតផែនការក្បត់ចំពោះខ្លួន ហើយចេះតែបាត់ការសម្លាប់មនុស្សពាសវាលពាសកាល។ ដោយសារទារុណកម្មសួរចម្លើយ ឬបង្ខំឱ្យឆ្លើយចោទដាក់គ្នា ឬបក្សពួកខ្សែរយៈក្បត់ នាំឱ្យជនរងគ្រោះបង្ខំចិត្តឆ្លើយផ្ដេសផ្ដាស់ ដែលនាំឱ្យកើត ការតាមចាប់ជនស្លូតត្រង់យកទៅកាប់សម្លាប់កាន់តែរង្គាល និងបន្តជាប់គ្នារយោងដូចសម្លកំពិស។

៥-ពួកមេដឹកនាំខ្មែរក្រហម ជាពិសេសប៉ុលពត ប្រកាន់យកគំនិតថា ខ្មែរដែលល្អស្អាតស្អំ គឺ"ខ្មែរដើម"កាលពីសម័យកុម្មុយនិស្តបុព្វកាល មុនប្រប្រវត្តិសាស្ត្រ មុនពេលកើតមានរបបរាជានិយមសក្តិភូមិ និងនាយទុននិយមដែលពោរពេញដោយការជិះជាន់សង្កត់សង្កិតគ្នា កេងប្រវ័ញ្ចបម្រាញ់យកផលប្រយោជន៍គ្នា ជញ្ជក់ឈាមគ្នាមិនសមហេតុផល ទើបមានក្ដីប្រាថ្នា ធ្វើបដិវត្តន៍ផ្តួលរំលំ រំលើងឫសគល់នៃសង្គមប្រតិកិរិយាទាំងអស់នោះចោល ហើយកសាងសង្គមឱ្យល្អបរិសុទ្ធ គ្មានអ្នកមានអ្នកក្រ គ្មានម្ចាស់គ្មានចៅហ្វាយនាយ និងគ្មានអំពើមនុស្សជិះជាន់មនុស្សដូចសម័យបរប្រវត្តិសាស្ត្រវិញ។ ប៉ុន្តែតាមការពិត គឺជាអំពើបោកប្រាសសុទ្ធសាធ ព្រោះអង្គការ និងកម្មាភិបាលជាភ្នាក់ងាររបស់ខ្លួន បានក្លាយជាវណ្ណៈជិះជាន់ដ៏មានអំណាចគ្មានព្រំដែនក្នុងការកំណត់ជោគវាសនារបស់ប្រជាជននៅគ្រប់ទិសទី។ ពួកអង្គការលើរស់នៅយ៉ាងសុខស្រួល មានអ្វីៗសព្វបែបយ៉ាងសម្រាប់បម្រើសេចក្ដីត្រូវការរបស់ខ្លួន តាំងពីគ្រូពេទ្យជំនាញត្រឹមត្រូវ, ថ្នាំព្យាបាលវិទ្យាសាស្ត្រ, អ្នកឯកទេស, គ្រូបង្រៀនសម្រាប់អប់រំកូនៗរបស់ពួកគេ ហូតដល់ការហូបចុកគ្រប់គ្រាន់ នៅពេលដែលប្រជាពលរដ្ឋនៅទូទាំងប្រទេសជាពិសេស អ្នកជំនាញឯកទេសផ្សេងៗគ្នាត្រូវ

តែលាក់ខ្លួនលាក់ប្រវត្តិនៅសម្ងំធ្វើស្រែចម្ការ ហើយអ្នកបំពេញមុខការឯកទេសជាច្រើនជំនួសអ្នកទាំងអស់នោះ គឺជាមនុស្សអវិជ្ជា ដែលអង្គការបង្ហាត់បង្រៀនជំនាញអនុវត្តន៍ក្នុងរយៈពេលយ៉ាងខ្លីបំផុត។ នេះហើយ គឺជាគំនិតសងសឹកមនុស្សរបស់ពួកខ្មែរក្រហម។

## 6. វិស័យសុខាភិបាល

ទិដ្ឋភាពដ៏សម្បើមមួយនៃការប្រល័យពូជសាសន៍នេះ គឺការស្រាវជ្រើសអ្នករងគ្រោះ។ ពួកខ្មែរក្រហមបានសម្លាប់គ្រូពេទ្យ៩១ភាគរយ, ឱសថការី៨៣ភាគរយ, ទន្តពេទ្យ៥៨ភាគរយ, មន្ត្រីសុខាភិបាល៥២ភាគរយ, គិលានុបដ្ឋាក៤៥ភាគរយ, ឆ្មប៣២ភាគរយ។

ដូច្នេះ នេះជាផ្នែកមួយយ៉ាងធំទាក់ទងនឹងវិស័យពេទ្យ ហើយជាទូទៅប្រព័ន្ធសុខាភិបាលទាំងមូលបានត្រូវកម្ទាត់ចោលយ៉ាងឃោរឃៅ។ ប៉ុន្តែអ្នកមានវិជ្ជាជីវៈផ្សេងៗទៀត បានទទួលរងជោគវាសនាដូចគ្នាៈ សាស្ត្រាចារ្យ, វិស្វករ, មេធាវី, ចៅក្រម ចៅក្រមនេះមានតែ៦នាក់ប៉ុណ្ណោះក្នុងទូទាំងប្រទេសនៅពេលដែលរបបខ្មែរក្រហមត្រូវផ្ដួលរំលំ។ ក្នុងចំនួននេះគេតោងតែបន្ថែមមន្ត្រីបុគ្គលិកផ្នែកសេដ្ឋកិច្ចស្ទើរតែទាំងអស់ទៀត។ ហើយគេមិនត្រូវភ្លេចព្រះសង្ឃដែលមានចំនួន៥៤.០០០អង្គនៅឆ្នាំ១៩៧៥ជាមួយអ្នកបួសថ្មី១៤០.០០០អង្គឡើយ។ ពួកកាតូលិក ដែលមាន ៦៥.០០០នាក់ ហើយដែលមួយភាគធំជាវៀតណាម បានត្រូវសម្លាប់អស់យ៉ាងហោចណាស់៥.០០០នាក់។ អ្នកកាន់សាសនាប្រូតេស្តង់៣.០០០នាក់ ហើយដែលមានប៉ាស្ទ័រ(អាចារ្យ)ប្រមាណ១៥នាក់បានត្រូវសម្លាប់ ។

បើតាមឯកសារនៅសេសសល់ ដែលគេបានចងក្រងអំពីមន្ទីរពេទ្យមួយនៅអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ អាចនិយាយបានថា ជាគំរូមួយនៃមន្ទីរពេទ្យទូទាំងប្រទេសបាន។ ក្រៅពីមន្ទីរពេទ្យ ដែលមានរាយនៅស្ទើរគ្រប់ស្រុក របបកម្ពុជាប្រជាធិបតេយ្យបានយកចិត្តទុកដាក់បាចថ្នាំ DDT ដើម្បីកំចាត់មូសដែលអាចបង្កជំងឺគ្រុនចាញ់ផងដែរ។ តែមន្ទីរពេទ្យ ការចែកថ្នាំសង្កូវ និងការយកចិត្តទុកដាក់បង្ការជំងឺតម្កាត់ដែលញាំញីអ្នកស្រុក ស្ទើរតែគ្មានប្រសិទ្ធភាពអ្វីទាំងអស់។ ពីព្រោះថា វាមានតែរូបភាពប៉ុណ្ណោះ ហើយប្រជាជនត្រូវអង្គការពង្រាយនៅគ្រប់តំបន់ចុងកាត់មាត់ញក ដែលគម្រាមកំហែងដល់សុខភាពជាពិសេសតំបន់ចាញ់ ព្រមជាមួយភាពគ្មានហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់តម្រូវការក្នុងជីវភាពប្រចាំថ្ងៃ។

ដែលហៅថាបុគ្គលិកពេទ្យ គឺអ្នករៀនវិជ្ជាចាក់ថ្នាំ ដោយអនុវត្តន៍លើគ្នាទៅវិញទៅមកដោយផ្ទាល់។ ការហ្វឹកហាត់មានរយៈពេលខ្លី និងមិនធ្វើតាមក្បួនពេទ្យត្រឹមត្រូវ។ ចំណែកថ្នាំពេទ្យ គេនាំគ្នាផលិតតែថ្នាំបែបដូចអាចម៍ទន្សាយ ដើម្បីចែកឱ្យអ្នកជំងឺព្យាបាលជំងឺគ្រប់បែបយ៉ាង។ ចំពោះថ្នាំពេទ្យទំនើប ដែលគេប្រមូលជ័យភ័ណ្ឌបាន គេរក្សាទុកសម្រាប់បម្រើការព្យាបាលឱ្យតែពួកកម្មាភិបាលសំខាន់ៗតែប៉ុណ្ណោះ។ កុមារឈឺ ឬគ្រោះថ្នាក់ផ្សេងៗ ដែលត្រូវដេកព្យាបាលនៅមន្ទីរពេទ្យ គេមិនអនុញ្ញាតឱ្យឪពុកម្ដាយនៅកំដរឡើយ។ ព្រោះខ្លាចបាត់កម្លាំងពលកម្មផលិតកម្មម្នាក់ទៀត។ ប្រហែលជាអាចរាប់ថា ចំណុចល្អតែមួយគត់ គឺរបបអាហារនៅមន្ទីរពេទ្យ មានស្ថានភាពគ្រាន់បើជាង នៅតាមរោងបាយសហករណ៍បន្តិច។ ដោយសារនៅពេល រោងបាយសហករណ៍ចម្អិនតែបបរដឹកវែកក្លូកឱ្យកសិករហូប អាហារនៅមន្ទីរពេទ្យ គឺបបរខាប់លាយពោតមួយគ្រាប់ៗ៕

# មេរៀនទី 14 លទ្ធិសង្គមនិយម ៖ របបសាធារណរដ្ឋប្រជាមានិតកម្ពុជា

## 1. រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា

មកដល់ឆ្នាំ១៩៧៧ សន្ទុះនៃការបោសសម្អាតផ្ទៃក្នុងអង្គការបដិវត្តន៍របស់កម្ពុជាប្រជាធិបតេយ្យ កាន់តែខ្លាំងក្លាឡើង ធ្វើឱ្យកងទ័ពមានការជ្រួលច្របល់ជាខ្លាំង ជាពិសេស អ្នកធ្លាប់មានទំនាក់ទំនងជាមួយវៀតណាម។ ហេតុនេះហើយ ទើបនាំឱ្យមានមេបញ្ជាការកងទ័ពជាច្រើនក្រុម នាំកងទ័ព និងប្រជាជននៅភូមិភាគបូព៌ា រត់ទៅប្រទេសវៀតណាម។ ចំណែកវៀតណាម ទើបតែត្រូវវាយលុកក្នុងទ្រង់ទ្រាយធំដោយកងទ័ពខ្មែរក្រហមរួចថ្មីៗ ទំនងកំពុងចិញ្ចឹមចិត្តផ្តួលរំលំកម្ពុជាប្រជាធិបតេយ្យដ៏រមិលគុណនេះស្រាប់ ក៏មកពើបនឹងក្រុមខ្មែរ ដែលចង់ផ្តួលរំលំរបបនេះដែរ។ ហេតុដូច្នេះហើយ បានជាវៀតណាមបង្រួបបង្រួមក្រុមភៀសខ្លួនទាំងនោះ រួចបញ្ជូនចូលមកក្នុងទឹកដីខ្មែរភាគខាងកើត ដើម្បីរៀបចំបង្កើតជា «**រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា**»ឡើង។ ជាការពិតណាស់ការ បង្កើតរណសិរ្សនេះជាតម្រូវការចាំបាច់ និងផ្តល់ប្រយោជន៍ដ៏ធំសម្រាប់សង្គ្រោះប្រជាជនកម្ពុជាពីមាត់រណ្តៅពិឃាតដោយផ្ទាល់ និងប្រយោលរបស់មេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យ។

រណសិរ្សត្រូវបានបង្កើតឡើង នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨ នៅស្រុកស្នួល ខេត្តក្រចេះ។ ទន្ទឹមនឹងនោះ រណសិរ្សបានអំពាវនាវឱ្យប្រជាជនខ្មែរ ជាកសិករ, កម្មករ, បញ្ញវន្ត, ព្រះសង្ឃ, ជនជាតិភាគតិច និងកងទ័ពចូលរួមក្នុងជួររណសិរ្ស ក្រោកឈរឡើង ដើម្បីផ្តួលរំលំរបបប្រល័យពូជសាសន៍។ បេសកកម្មរបស់រណសិរ្ស មានជំនួយពីកងទ័ព(ស្ម័គ្រចិត្ត) និងសម្ភារៈសឹកវៀតណាម ក្នុងទ្រង់ទ្រាយធំ វាយប្រហារផ្តួលរំលំរបបខ្មែរក្រហមបានជោគជ័យនៅទូទាំងប្រទេស ក្នុងរយៈពេលប្រមាណជាងពីរខែ។ ក្រោយពីបង្កើតរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជារួចនៅប្រមាណមួយសប្តាហ៍ ក្រោយថ្ងៃរំដោះក្រុងភ្នំពេញថ្ងៃទី៧មករា១៩៧៩ រណសិរ្សនេះបានកែប្រែឈ្មោះ ទៅជា «**រណសិរ្សសាមគ្គីកសាងការពារមាតុភូមិកម្ពុជា**» វិញ។

## 2. រដ្ឋាភិបាល និងរចនាសម្ព័ន្ធ

ប្រទេសជាតិនេះមានស្ថាប័នបី ដែលគ្រប់គ្រងដោយបក្សតែមួយ ដូចនៅតាមបណ្តាប្រទេសសង្គមនិយមដទៃទៀតដែរ គឺ អង្គការនីតិបញ្ញត្តិ–សភា, នីតិប្រតិបត្តិ–រដ្ឋាភិបាល, និងអង្គការតុលាការប្រជាជនបដិវត្តន៍នៅតាមខេត្ត–ក្រុងនានា ទូទាំងប្រទេស។ មេដឹកនាំសំខាន់ៗដំបូងនៃរដ្ឋាភិបាលដែលវៀតណាមអះអាងថា ជា"រដ្ឋាភិបាលឯករាជ្យ" នេះ មាន សមមិត្ត ហេង សំរិន, សមមិត្ត ប៉ែន សុវណ្ណ, សមមិត្ត ចាន់ ស៊ី, សមមិត្ត ជា ស៊ីម, សមមិត្ត ហ៊ុន សែន, សមមិត្ត ជា សុទ្ធ, សមមិត្ត សាយ ភូថង, សមមិត្ត រស់ សម័យ ជាដើម។ ក្នុងចំណោមឥស្សរជនទាំងនេះ មានតែសមមិត្ត ហ៊ុន សែន ប៉ុណ្ណោះដែលមានថាមពល និងឈ្លាសវៃជាងគេ រហូតបានឡើងជានាយករដ្ឋមន្ត្រី និងក្លាយជាអ្នកប្រយុទ្ធជួរមុខដ៏ឆ្នើមជាងគេរបស់បក្សប្រជាជនបដិវត្តន៍កម្ពុជារហូតដល់សព្វថ្ងៃ។

អង្គការនីតិប្រតិបត្តិ ជារដ្ឋាភិបាល និងជាអ្នកមានអំណាចធំជាងគេនៅក្នុងរបបនេះ។ អាជ្ញាធរ ដែលគេហៅថា រដ្ឋអំណាច គ្រប់លំដាប់ថ្នាក់ចាប់ពីរដ្ឋាភិបាលមជ្ឈឹម ដល់ខេត្ត, ស្រុក និងឃុំ មានឋានៈប្រធានពីររូប គឺ "លេខាបក្ស" និង"ប្រធានគណៈកម្មាធិការប្រជាជនបដិវត្តន៍"។ តែលេខាបក្សមានឋានៈខ្ពស់ជាង ប្រធានគណៈកម្មាធិការ។

ដូច្នោះហើយ ទើបគេឃើញមានគ្រឹះស្ថានសម្រាប់មន្ត្រីកាន់តំណែងទាំងពីរនេះនៅដាច់ពីគ្នា ហើយភាគច្រើននៃមន្ទីរ, ការិយាល័យ ឬទីស្នាក់ការលេខាបក្ស បានក្លាយជាមន្ទីរ, ការិយាល័យ ឬទីស្នាក់ការគណបក្សប្រជាជនកម្ពុជា នៅពេលសព្វថ្ងៃ។ រហូតដល់ឆ្នាំ១៩៨១ មានការបោះឆ្នោតនៅទូទាំងប្រទេសមួយ ដើម្បីជ្រើសរើសមេឃុំដែលមានសមាសភាពមកពីបក្សតែមួយ។

ចំពោះសកម្មភាពរបស់រដ្ឋសភាប្រជាជនបដិវត្តន៍កម្ពុជា គេស្ទើរតែមិនបានឮសម្លេង និងសកម្មភាពការងារផ្សេងៗទាក់ទងនឹងការតាក់តែងច្បាប់របស់ពួកគេឡើយ។ ពីព្រោះ សមាជិកសភាកើតឡើងពីការតែងតាំង ឬការបោះឆ្នោតអសកល។ ប្រៀបដូចជា សមាជិកអង្គការព្រឹទ្ធសភាសព្វថ្ងៃ កើតឡើងពីសម្លេងរបស់សមាជិកក្រុមប្រឹក្សាឃុំដូច្នោះដែរ។

## 3. ជំនាញការវៀតណាម

ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ កងទ័ព(ស្ម័គ្រចិត្ត)វៀតណាម ឈរជើងនៅពាសពេញផ្ទៃប្រទេសកម្ពុជា ព្រមទាំងមានភ្នាក់ងារស៊ីវិល ធ្វើការអមរដ្ឋអំណាចខ្មែរ ក្នុងតួនាទីមួយដែលគេឱ្យឈ្មោះថា "ជំនាញការវៀតណាម" (Vietnamese Advisor)។ បើគេក្រឡេកមើល ន័យ និងតួនាទីរបស់បុគ្គលកាន់មុខនាទីនេះ អាចជាមនុស្សគ្មានអំណាច និងឥទ្ធិពលអ្វីទាំងអស់លើការសម្រេចចិត្តធ្វើអ្វីៗរបស់ភ្នាក់ងាររដ្ឋអំណាចខ្មែរ។ ប៉ុន្តែ តាមពិតជំនាញការវៀតណាមគ្រប់ក្រសួង, មន្ទីរ, ការិយាល័យ និងទីស្នាក់ការឃុំនៅតាមមូលដ្ឋាន គឺជាអ្នកបញ្ជាពីក្រោយខ្នងកម្មាភិបាលខ្មែរ។ អ្នកជំនាញការវៀតណាម សុទ្ធសឹងជាមនុស្សពូកែខាងគ្រប់គ្រងចិត្តសាស្ត្រ និងយុទ្ធសាស្ត្រ ទាំងផ្នែកស៊ីវិល និងកងទ័ព។ ពួកគេមានខ្សែបណ្តាញយ៉ាងស្អិត និងពិបាកយល់។ ភាគច្រើននៃបញ្ហារបស់ពួកគេជាបញ្ហាផ្ទាល់មាត់ ម្ល៉ោះហើយការស្រាវជ្រាវពឹងលើឯកសារសរសេររបស់អ្នកនិពន្ធបរទេស មិនអាចរកភស្តុតាងនៃការដឹកនាំប្រទេសខ្មែរក្រោមខ្សែញាក់របស់វៀតណាមបានឡើយ។ សូម្បីឥស្សរជននយោបាយគណបក្សប្រជាជនកម្ពុជា ក៏ធ្លាប់មានប្រសាសន៍នៅខែមករា១៩៩៨ដែរថា រហូតមកដល់ឆ្នាំ១៩៨៩ បើគាត់គ្មានសិទ្ធិស្វ័យសម្រេចចិត្តបានដោយខ្លួនឯងខាងផ្នែកនយោបាយការបរទេស គាត់មិនអាចអារកាត់ក្នុងការចរចាជាមួយភាគីជម្លោះផ្សេងទៀតបានទេ។

## 4. សេដ្ឋកិច្ចសង្គមនិយម

បន្ទាប់ពីប្រជាជនកម្ពុជា រួចផុតពីក្រញាំពិឃាតរបស់យុទ្ធមិត្តបដិវត្តន៍ ដែលបណ្តុះបណ្តាលដោយប៉ុល ពត ពួកគេនាំគ្នាធ្វើដំណើរវិលត្រឡប់រកស្រុកកំណើត ជួបជុំបងប្អូន ញាតិមិត្តវិញយ៉ាងមមាញឹក អស់រយៈពេលជាងមួយឆ្នាំ គឺតាំងពីខែមករា១៩៧៩ រហូតដល់ប៉ុន្មានខែដើមឆ្នាំ១៩៨០។ ស្ថានភាពពេលនោះ គេហាក់ដូចជាមិនសូវបានឱ្យតម្លៃខ្លាំងលើការងារដាំដុះ ដើម្បីជីវភាពជាបន្ទាន់របស់ខ្លួននោះទេ។ ស្បៀងអាហារ សម្រាប់ឆ្នាំ១៩៧៩ របស់ប្រជាជនបានពីការច្រូតស្រូវក្នុងស្រែយក, បោកបែកកណ្តាប់ស្រូវក្នុងស្រែស្រាប់, និងនាំគ្នាទម្លាយជង្រុកស្រូវធំៗរបស់សហករណ៍ក្នុងតំបន់។ ចំពោះអ្នកមិនបានប្រមូលស្បៀងទុក ត្រូវរដ្ឋអំណាចទើបតែតាំងថ្មីដោះស្រាយឱ្យដោយដើរទារយកចំណែកស្រូវពីផ្ទះណាដែលប្រមូលបានខ្លះ ឬប្រមូលបានច្រើន យកចែករំលែកឱ្យអ្នកគ្មានឱ្យបានទុកហូបដែរ។ ជាការពិតណាស់ នៅឆ្នាំដំបូងនោះ គ្រោះទុរ្ភិក្សដោយសារខ្វះស្បៀងកើតមានទូទាំងប្រទេស តែធនធានធម្មជាតិជាច្រើនទៀត កម្ពុជាមានសំបូរហូរហៀរ លើកលែងតែមនុស្សខ្ជិលគ្មានគំនិតទើបអាចស្លាប់ដោយអត់ឃ្លានបាន។ នៅក្នុងទឹកសំបូរត្រី នៅក្នុងព្រៃសំបូរសត្វព្រៃដែលអាចចាប់ ឬបាញ់សម្លាប់ធ្វើម្ហូបបាន ក្រៅពីនេះ ដំឡូងជាច្រើនប្រភេទ រួមទាំងមើមក្តួចផង ដែលគេអាចគាស់យកមកស្ងោរហូបជំនួសបាយបាន។

សាធារណរដ្ឋប្រជាមានិតកម្ពុជា មានគោលដៅក្នុងការកសាងប្រទេសជាជំហានៗ ឆ្លងកាត់អន្តរកាលឆ្ពោះទៅរកលទ្ធិសង្គមនិយម។ របបនេះមានគោលដៅកសាងប្រទេសជាតិ ដោយគេចង់សម្រេចបាន ត្រឹមតែជា"ប្រទេសសង្គមនិយម"ប៉ុណ្ណោះ មិនមានគោលនយោបាយកសាងតាមរបៀប"មហាលោតផ្លោះ មហាអស្ចារ្យ" ដូចរបបកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវតែសម្រេចឱ្យបាននូវរបប"កុម្មុយនីស្តនិយម"នោះទេ។ ខឿនសេដ្ឋកិច្ចរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា ជាសេដ្ឋកិច្ចសង្គមនិយម។ ទឹក ដី ព្រៃ ភ្នំ ស្ទឹងបឹង ព្រែក ទន្លេ សមុទ្រ រ៉ែក្រោមដី អាកាស និងរោងចក្រផលិតកម្មទាំងអស់ ជារបស់រដ្ឋ។ នៅដើមរបបនេះ ដើម្បីដោះស្រាយបញ្ហាខ្វះខាតកម្លាំងមនុស្សប្រុស(ស្រីមេម៉ាយ) សត្វពាហណៈសម្រាប់អូសទាញ និងមធ្យោបាយផលិតកម្មកសិកម្ម រដ្ឋាភិបាល បានរៀបចំឱ្យមាន"ក្រុមសាមគ្គីបង្កបង្កើនផល"។ តែក្រុមសាមគ្គីនេះ មិនមែនបែបសហករណ៍ប្រមូលផ្តុំ"ដាក់កម្មសិទ្ធិរួម ហូបរួម" ដូចរបបខ្មែរក្រហមឡើយ។ ម្ល៉ោះហើយ គ្រួសារណាក៏ដោយ ក៏អាចរស់បានតាមរបៀបប្រវាស់ដៃ និងទទួលចំណែកភោគផលតាមកម្លាំងពលកម្មនោះបានដែរ។ ប៉ុន្តែផលស្រូវទាំងនោះ មិនមានបរិមាណច្រើនអាចឱ្យគេរំលែកលក់ដូរ ដើម្បីយកប្រាក់ទិញម្ហូបអាហារប្រចាំថ្ងៃបានទេ។ កសិករត្រូវតែប្រកបរបររួមផ្សំបន្ថែមទៀត ទើបអាចមានជីវភាពគ្រប់គ្រាន់សមរម្យបាន។ ក្រុមសាមគ្គីបង្កបង្កើនផល ត្រូវរំសាយនៅឆ្នាំ១៩៨៣ បន្ទាប់ពីប្រមូលផលស្រូវដើមឆ្នាំរួច។ ដីស្រែរបស់ក្រុមសាមគ្គីនីមួយៗ ត្រូវពុះចែកតាមគ្រួសារនីមួយៗជាសមាជិកក្រុម ទៅតាមចំនួនសមាជិកពេញវ័យនៃគ្រួសារនីមួយៗ។ ថ្វីបើរដ្ឋាភិបាល មិនទាន់បានប្រកាសទទួលស្គាល់កម្មសិទ្ធិឯកជនលើដីស្រែទាំងនោះក៏ដោយ ក៏គ្រួសារនីមួយធ្វើអាជីវកម្មលើដីស្រែ-ចម្ការ ជារបបផ្ទាល់ខ្លួននោះរហូតដល់មានការប្រកាសទទួលស្គាល់កម្មសិទ្ធិដីឯកជនដោយសមមិត្តហ៊ុន សែននៅឆ្នាំ១៩៨៨។

ការលើកទិសដៅនយោបាយសេដ្ឋកិច្ច គឺស្របទៅតាមការសម្រេចចិត្តរបស់មហាសន្និបាតបក្សប្រជាជនបដិវត្តន៍កម្ពុជា។ ក្រោយពីបក្សសម្រេចចិត្តហើយ ទើបរដ្ឋាភិបាលយកមកអនុវត្តន៍ ដោយចាត់វិធានការណ៍ទៅតាមនោះ។ ជាក់ស្តែងមហាសន្និបាតបក្សលើកទី៤ នៅឆ្នាំ១៩៨១ និងមហាសន្និបាតបក្សទូទាំងប្រទេសនៅឆ្នាំ១៩៨៥ បានកំណត់គោលដៅសេដ្ឋកិច្ច ដោយពឹងផ្អែកលើមុខព្រួញសេដ្ឋកិច្ច៤ផ្នែកដូចគ្នា គឺ ៖

ជំរុញអាជីវកម្មដំណាំស្បៀង ក្នុងវិស័យកសិកម្ម
ជំរុញការធ្វើអាជីវកម្មចាក់ជ័រកៅស៊ូ
ជំរុញអាជីវកម្មព្រៃឈើ និងរក្សាប្រមាញ់
ជំរុញការបង្កើនទិន្នផលនេសាទត្រី ទាំងទឹកសាប និងសមុទ្ទ

តាមពិត ការកំណត់ទិសដៅនេះ គេមិនបានឃើញមានវិធានការណ៍ សម្រាប់ការអភិវឌ្ឍន៍យូរអង្វែងឡើយ ដូចជា ការជំរុញឱ្យមានការចិញ្ចឹមត្រីប្រពលវប្បកម្ម, ការដាំដុះព្រៃឈើឡើងវិញ ឬការយកចិត្តទុកដាក់ ស្តារ និងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់ និងបង្កើតថ្មីៗទៀតឡើយ។ ប៉ុន្តែ ទោះជាយ៉ាងណា លោកឆាណ្ឌល័រ ហាក់មានការឯកភាពជាមួយគំនិតរបស់លោក វិកឃើរី( ១៩៨៣៖២២៥ cited in Chandler, 2000: 230) ដែលបានវាយតម្លៃថា "គោលគោលនយោបាយរបស់របបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងវៀតណាមដែលជាខ្នងបង្អែករបស់គេ មានលក្ខណៈព្រហ្មវិហារធម៌, សំអាងលើការប្រតិបត្តិ និងមិនបង្ខិតបង្ខំ"។ បើគេប្រៀបធៀបទៅនឹងរបបកុម្មុយនិស្តខ្មែរក្រហមពីអតីតកាល ដែលទើបវិនាសផុតទៅ។

**5. ក-៥**

**ក-៥** ជាអក្សរកាត់ ចេញពីប្រយោគថា "កែន កងកម្លាំង កាប់ឆ្ការព្រៃ ការពារព្រំដែន កម្ពុជា"។ ផែនការនេះបានលេចឡើងតាំងពីឆ្នាំ១៩៨២ ប៉ុន្តែចាប់ពីឆ្នាំ១៩៨៥ ទើបកម្មវិធីក៥បានចាប់ផ្តើមអនុវត្តន៍ ស្របពេលគ្នានឹងការប្តេជ្ញាចិត្តរបស់កងកម្លាំងទ័ពព្រៃ ប្រកាសថា ពួកគេនឹងបើកការវាយប្រហារទ្រង់ទ្រាយធំ ផ្តួរផ្តាច់ជីវិតជាមួយរដ្ឋាភិបាលភ្នំពេញ និងកងទ័ពវៀតណាម។ តែការពិត នៅរដូវប្រាំងឆ្នាំ១៩៨៤-៥នោះហើយ ដែលកងកម្លាំងតស៊ូ និងជុំរុំជនភៀសខ្លួននៅជាយដែនខ្មែរ-ថៃ ត្រូវកងទ័ពវៀតណាមវាយកំទេចចោលអស់ រួមទាំងកងកម្លាំងតស៊ូផង ក៏ត្រូវរងការខូចខាតយ៉ាងដំណំ។ ហើយជំរំជនភៀសខ្លួន ត្រូវរុះរើទីតាំងដកថយទៅបោះនៅកន្លែងថ្មី ដែលភាគច្រើននៅលើទឹកដីថៃ។

នៅថ្ងៃទី៣តុលា១៩៨៥ រដ្ឋាភិបាលបានកំណត់កាតព្វកិច្ចយោធារយៈពេល៥ឆ្នាំសម្រាប់ពលរដ្ឋខ្មែរប្រុសស្រីម្នាក់ៗចាប់ពីអាយុ១៨ឆ្នាំឡើង។ ក្នុងនោះដែរ ក៏កំណត់កាតព្វកិច្ចយោធាសម្រាប់យុវជនយុវនារីដែលមានអាយុចាប់ពី១៦ឆ្នាំឡើងដែរ ដើម្បីជុំរុញការអនុវត្តផែនការ«ក-៥» ដែលជាផែនការកាប់ឆ្ការព្រៃក្នុងទ្រង់ទ្រាយធំរបស់រដ្ឋាភិបាល នៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ដើម្បីផលប្រយោជន៍ដែលគេហៅថា "បំផ្លាញជម្រកខ្មាំង" នៅតាមព្រំដែន។ សូមបញ្ជាក់ថា យុទ្ធនាការកាប់បំផ្លាញព្រៃឈើនេះ មិនមែនមានតែនៅតាមព្រំដែនប៉ុណ្ណោះទេ តែនៅតាមតំបន់ជនបទ ក៏មានការបញ្ជាឱ្យកាប់ព្រៃក្បែរភូមិ ដើម្បីបំផ្លាញជម្រកលាក់ខ្លួនរបស់ខ្មាំងសត្រូវដែរ។ ចំណែកដើមឫស្សីនៅទូទាំងប្រទេស ទាំងឫស្សីចាស់ និងខ្ចី សុទ្ធតែចេញផ្កាគ្រប់គុម្ព ហើយងាប់អស់ទៅ។ កន្លែងខ្លះ ត្រូវគេកាប់យកទៅធ្វើជារបងយុទ្ធសាស្ត្រការពារភូមិឃុំ តែខ្លះទៀតត្រូវភ្លើងព្រៃអុជឆេះវិនាសអស់ដែរ។ ដូច្នេះ ព្រៃឈើ និងដើមឫស្សី ត្រូវរងការបំផ្លាញយ៉ាងដំណំ។

មានរឿងរ៉ាវសោកនាដ្យកម្មច្រើន ទាក់ទងនឹងការបំពេញកាតព្វកិច្ចក-៥របស់ប្រជាជនខ្មែរ។[142] ដោយសារការប្រឈមមុខនឹងសេចក្តីស្លាប់ ដោយគ្រាប់ផ្លោងរបស់ភាគីចលនាតស៊ូ, ការវាយប្រហារត្រង់ៗ, ការដើរជាន់មីន និងជំងឺផ្សេងៗ ជាពិសេស គ្រុនចាញ់ ទើបប្រជាជនខ្មែរភាគច្រើន តែងតែប៉ុនប៉ងគេចវេសពីការបំពេញកាតព្វកិច្ចនេះ។ អ្នកខ្លះមានលុយកាក់ច្រើន ក៏ជួលអ្នកដទៃឱ្យទៅជំនួស អ្នកខ្លះទៀត ក៏សូកមន្ត្រីមូលដ្ឋាន ដើម្បីឱ្យបានរួចខ្លួន ពីការចុចឈ្មោះឱ្យទៅ។ ហេតុនេះហើយ បានជាតារាកំប្លែង ព្រំ ម៉ាញ ធ្លាប់និយាយកំប្លែងលេងទាក់ទងនឹងបញ្ហានេះថា "ពលករស្ម័គ្រចិត្ត រុញក្តិតឡើងឡាន ទៅអាចជិះឡាន ម៉ោវិញជិះចាន ទទូរសំពត់ស"។ នៅតាមស្រុកនីមួយៗតែងតែមានកន្លែងសម្រាប់តំកល់សពពលករក-៥ ជាភស្តុតាង អគារមួយនៃសាលាស្រុកអង្គរបុរី ខេត្តតាកែវសព្វថ្ងៃ គឺជាអតីតសាលសម្រាប់តម្កល់ខ្មោចពលករ ដែលបានស្លាប់ពេលទៅបំពេញកាតព្វកិច្ចក-៥។[143]

បើតាមលោក ហង់រី ឡូការដ៍ ថា នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៨០ របបសាធារណរដ្ឋប្រជាមានិតកម្ពុជា បានជាប់គាំងនៅក្នុងបញ្ហាសង្គ្រាមស៊ីវិល ដែលមិនអាចដោះស្រាយរួច ក្នុងស្ថានភាពគ្មានភាគីខាងណាមួយអាចឈ្នះផ្តាច់បានឡើយ។ ពេលនោះប្រទេសចិន អាស៊ាន និងលោកខាងលិចបានធ្វើការគាំទ្រភាគីរណសិរ្សតស៊ូ(ត្រីភាគី)នៅតាមបណ្តោយព្រំដែនខ្មែរ-ថៃ ហើយសង្គ្រាមឥណ្ឌូចិនលើកទី៣ ហាក់ដូចជារកថ្ងៃរលត់គ្មាន។ មានពួកបស្ចិមប្រទេសតិចតួចកំពុងស្នាក់នៅប្រទេសកម្ពុជា ហើយពេលនោះមានការផ្សាយពត៌មានថា វៀតណាមមានបំណងស្ថាបនាជញ្ជាំងបែងចែកកម្ពុជាឱ្យដាច់ចេញពីថៃ។ ផែនការនោះគេហៅថា ក៥ ហើយដែលជាបន្ទាប់មកបានប្រែក្លាយជាគោល

[142] Cf., JENNAR, Raoul M., 1995. *Les clés du Cambodge,* Maisonneuve & Larose, Paris, p.92.

[143] បទ សម្ភាសន៍ ជាមួយ អភិបាល រង ម្នាក់ ។ នៃ ស្រុក អង្គរបុរី ។ ថ្ងៃ ទី ១២ មេសា ២០០២ ៕

នយោបាយមួយ កាន់តែគ្មានប្រជាប្រិយភាពរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា បើតាមការធ្វើកំណែនក្នុងឆ្នាំ ១៩៨៥-៨៦។ បញ្ហានេះលោក ប៉ែន សុវណ្ណ ដែលជាអតីតនាយករដ្ឋមន្ត្រីទី១នៃរបបនេះ ក៏ធ្លាប់បានអះអាងជារឿយថា **ក-៥** គឺជាផែនការកំណត់ដោយវៀតណាមដែរ។ ពោលគឺមិនមែនជាគំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាលភ្នំពេញឡើយ។ លោក អ៊ីវិន ហ្គោតេសមេន (២០០២ : ២៣១)បានប៉ាន់ប្រមាណថា មានប្រជាពលរដ្ឋស៊ីវិលប្រមាណកន្លះលាននាក់ ត្រូវគេកេណ្ឌឱ្យទៅកាប់ព្រៃ....និងជីកលើកទំនប់ដីប្រវែងរាប់រយគីឡូម៉ែត្រ, ដោយជីកជាលេណដ្ឋានជម្រៅពីរម៉ែត្រកន្លះ, ជីកកប់ខ្សែទូរស័ព្ទ និងដាក់មីន។ គំនិតបែបនេះ គឺគ្មានអ្វីក្រៅពីចង់សង់"កំពែងទីក្រុងប៉ែរឡាំង"មួយបែបទៀត ដែលពុះកាត់តាមបណ្តោយព្រំដែនខ្មែរ-ថៃ និងបង្ការកុំឱ្យកងទ័ពតស៊ូអាចជ្រៀតចូលមកផ្ទៃក្នុងប្រទេសបាន។ ទង្វើបែបនេះ បានជំរុញបង្កើននយោបាយភាពជាម្ចាស់ (patronage politics) និងអ្នកបម្រើ, និងអំពើពុករលួយ។ វាជាគ្រោះមហន្តរាយមួយចំពោះពួកពលករ។ មានប្រជាជនមួយចំនួនបានស្លាប់ដោយសារអត់បាយ។ បើតាមការស្មាន គ្រាន់តែស្លាប់ដោយជំងឺគ្រុនចាញ់ អាចចូលដល់ចំនួនរាប់ម៉ឺននាក់ប្លាយ(ទំ.២៣៦)។ នៅចុងដំណាច់ឆ្នាំ១៩៨៤-៨៥ នារដូវប្រាំង គេបានដាក់បង្កប់មីនប្រឆាំងមនុស្សបានចំនួនប្រមាណ ៤៦៤០០០គ្រាប់ ហើយលើកផែនការបង្កប់មីនទៅក្នុងដីចំនួន ១៦១៨៤០០គ្រាប់ទៀត នៅឆ្នាំបន្ទាប់។

## 6. ការអប់រំ

គោលនយោបាយសំខាន់ខាងអប់រំក្នុងដំណាក់កាលនោះ គឺ"អ្នកចេះច្រើន បង្រៀនអ្នកចេះតិច, អ្នកចេះតិចបង្រៀនអ្នកមិនចេះ"។ ព្រោះតែធនធានមនុស្ស ដែលជាអ្នកចេះដឹង សល់ពីស្លាប់ដោយរបបវាលពិឃាតមានសេសសល់តិចតួចណាស់។ ប៉ុន្តែដោយសារ ពេលនោះ សង្គមកម្ពុជាមិនទាន់មានការរត់ប្រណាំងគ្នាខាងសម្ភារនិយម ដូចរបបសេដ្ឋកិច្ចទីផ្សារសេរីនៅឡើយ ក្រោយថ្ងៃរំដោះជីវភាពប្រជាពលរដ្ឋ ស្ថិតក្នុងស្ថានភាពប្រហាក់ប្រហែលគ្នា មន្ត្រីរដ្ឋការ ជាពិសេស គ្រូបង្រៀន មានឆន្ទៈតស៊ូធ្វើការខ្លាំងក្លា ទោះបីរស់ក្នុងភាពអត់ឃ្លានក៏ដោយ ក៏នៅតែពុះពារកសាងធនធានមនុស្សដោយយកចិត្តទុកដាក់។ វិស័យអប់រំ មានការរីកចម្រើន ទោះបីកាលៈទេសៈប្រទេសស្ថិតក្នុងស្ថានភាពអសន្តិសុខក៏ដោយ។ ជាងនេះទៀត មានការខិតខំប្រឹងប្រែងចាត់វិធានការណ៍ជាច្រើនបែប ក្នុងការប្រយុទ្ធប្រឆាំងនឹងអនក្ខកម្មនៅទូទាំងប្រទេស ពេញមួយទសវត្សរ៍ឆ្នាំ១៩៨០ ដែលធ្វើឱ្យអត្រាអ្នកមិនចេះអក្សរនៅមានចំនួនតិចបំផុត។ ចំណែក អំពើពុករលួយក្នុងវិស័យនេះ ក៏មានបរិមាណតិចតួចដែរ ដោយសារមានការចោទប្រកាន់ពីបទពុករលួយ និងអំពើបក្សពួកនិយមពីមហាជនទូទៅ និងពីក្រុមសិស្សដែលប្រឡងធ្លាក់ជាច្រើន។ ដូចមានពាក្យស្លោកថា "កូនអ្នកក្រធ្វើទាហាន កូនអ្នកមានធ្វើនគរបាល កូនកម្មាភិបាលទៅរៀននៅបរទេស" ។ ព្រោះគេឃើញអ្នកដែលពេញវ័យហើយ មិនរៀននៅតាមសាលា មុខជាអាចត្រូវគេចុចឈ្មោះឱ្យធ្វើជាកងទ័ព។ យុវជនកូនកាត់ចិន ដែលឪពុកម្តាយមានជីវភាពធូរធារគ្រាន់បើ អាចសូកប៉ាន់ឱ្យកូនបានចូលធ្វើនគរបាលមូលដ្ឋាន ដែលមិនមានភារកិច្ចច្បាំងប្រឈមមុខជាមួយកងទ័ពសត្រូវដូចកងទ័ពនោះទេ។ ចំណែក អ្នកដែលបានទៅសិក្សានៅបរទេស ភាគច្រើនបំផុតជាកូនចៅកម្មាភិបាលជាន់ខ្ពស់ ចាប់ពីនាយកសាលាបឋមសិក្សាឡើង។

## 7. ជំនួយបរទេស

ទាក់ទងនឹងជំនួយបរទេស លោក ឆាណ្ឌាល័រ (២០០០: ២២៩-៣០)ធ្លាប់សរសេរថា "មានប្រជាជនខ្មែរតិចណាស់ ដែលទ្រាំរស់នៅកន្លែងដដែល ធ្វើស្រែយកស្រូវ និងដាំដំណាំយកផលនៅអំឡុងឆ្នាំ១៩៧៩-៨០ និងនៅពេលដែលស្រូវសំណល់ពីរបបមុន ត្រូវវៀតណាមប្រមូលទុក និងចែករំលែកទុកសម្រាប់កងកម្លាំងរបស់ខ្លួន ធ្វើឱ្យប្រជាជនខ្មែររាប់សែននាក់ នៅសល់ស្បៀងតិចតួចសម្រាប់ទុកហូប ឬក៏គ្មានអ្វីស៊ីតែម្តង។ គ្រោះទុរ្ភិក្សមានសភាពកាន់តែ

ធ្ងន់ធ្ងរឡើងដោយសារគ្រោះរាំងស្ងួតផងដែរ។ នៅពេលនោះហើយ ដែលប្រទេសខ្មែរ បានទាក់ទាញការយកចិត្តទុកដាក់ពីប្រទេសលោកខាងលិច ដែលមានអ្នកទស្សនាតាមកញ្ចក់ទូរទស្សន៍ ធ្លាប់បានដឹងព្រាលៗអំពីរឿងរ៉ាវឆ្គួតញាប់ញ័រ ដែលប្រព្រឹត្តដោយរបបកម្ពុជាប្រជាធិបតេយ្យ។ ពួកគេមានការខ្លោចចិត្តពេលឃើញខ្មែរស្គាំងស្គមកំព្រឹងដោយស្បែកដណ្ដប់ឆ្អឹង ដែលប្រឹងទាំងត្រដររត់ចូលដីថៃ ឬស្ទើរស្លាប់ដោយអត់អាហារនៅតាមដងផ្លូវក្នុងប្រទេស។ ទុក្ខវេទនានោះ បានអំពាវនាវឱ្យមានការឆ្លើយតបយ៉ាងគគ្រឹកគគ្រេងពីសប្បុរសជន ប៉ុន្តែការផ្ដល់អំណោយស្បៀង និងថ្នាំពេទ្យពីប្រទេសក្រៅនានា តែងតែមានការយឺតយ៉ាវដោយបញ្ហាប្រទាញប្រទង់គ្នាខាងការិយាធិបតេយ្យ, ដោយឧបសគ្គបង្កបង្កើតឡើងដោយប្រទេសថៃ និងសម្ព័ន្ធមិត្តរបស់គេ, និងមួយចំណែកតូចទៀត ដោយសារវៀតណាម។ ព្រោះគេអាចយល់បានថា វៀតណាមបានប្រើប្រាស់ស្បៀង និងថ្នាំពេទ្យមួយចំណែក ដើម្បីផ្គត់ផ្គង់ឱ្យទៅកងទ័ពដ៏តានតឹង និងបុគ្គលិករដ្ឋបាលផ្ទាល់ខ្លួនរបស់ពួកគេ”។

ក្រៅពីនេះ រដ្ឋាភិបាលខ្មែរទទួលបានជំនួយតែពីសហភាពសូវៀត និងសម្ព័ន្ធមិត្តនៅក្នុងប្លុកកុម្មុយនិស្តជាមួយគ្នា។ ចំណែកវៀតណាមវិញ ក្រៅពីប្រើកងកម្លាំងបណ្ដេញពួកមេដឹកនាំកម្ពុជាប្រជាធិបតេយ្យដ៏យង់ឃ្នងចេញពីអំណាច គេមិនបានឃើញធ្វើជំនួយជាស្បៀងអាហារធំដុំដល់កម្ពុជាឡើយ។ អស់រយៈពេលជាច្រើនខែ ដែលគេមិនឱ្យអ្នកសង្កេតការណ៍បរទេសចូលស្រុកខ្មែរ និងព្យាយាមបដិសេធថា គ្មានវត្តមានកងទ័ពរបស់ខ្លួននៅកម្ពុជាទៀតផង។ ទោះជាយ៉ាងណា ប្រជាជននៅផ្ទៃក្នុងប្រទេសកម្ពុជាពេលនោះ មិនទទួលបានការជួយសង្គ្រោះជាស្បៀងអាហារ ឬថ្នាំពេទ្យ ដោយភ្នាក់ងារអង្គការសហប្រជាជាតិឡើយ។ ពីព្រោះ សហគមន៍អន្តរជាតិ មិនបានទទួលស្គាល់រដ្ឋាភិបាលក្រុងភ្នំពេញ។ នេះជាការផ្ទុយស្រឡះពីជនភៀសខ្លួនខ្មែរ រាប់ម៉ឺននាក់ នៅតាមព្រំដែនកម្ពុជា-ថៃ។

## 8. ចលនាតស៊ូនៅតាមព្រំដែនខ្មែរ-ថៃ

ទោះបីត្រូវកងទ័ពវៀតណាម វាយប្រហារឱ្យបរាជ័យគ្រប់សមរភូមិក៏ដោយ កងកម្លាំងរបស់កម្ពុជាប្រជាធិបតេយ្យ នៅតែពុះពាររត់គេច និងដកថយរកទីបង្អែកប្រកបដោយក្បួនយុទ្ធសាស្ត្រ នៅតាមបណ្ដោយព្រំដែនខ្មែរ-ថៃដែរ។ មូលដ្ឋានបង្អែកសំខាន់របស់ពួកគេ នៅតាមតំបន់ព្រៃក្រាស់ស្មុគស្មាញ ក្នុងទ្រង់ទ្រាយចល័តផង និងអចល័តផង ដូចជា នៅសំឡូត, ប៉ៃលិន, ម៉ាឡៃ, អន្លង់វែង–ត្រពាំងប្រាសាទ, ភ្នំព្រះវិហារ, ក្រចេះ, កំពង់ស្ពឺ និងកំពត។ កងទ័ពនេះ នៅតែបន្តសកម្មភាពក្នុងទ្រង់ទ្រាយសង្គ្រាមឈ្លបតាមក្រុមតូចតូចអុកឡុក បង្កអសន្តិសុខដល់រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា ជារៀងរាល់ថ្ងៃ។ សកម្មភាពយោធារបស់ពួកគេ អាចធ្វើទៅបានដោយសារមានជំនួយពីប្រទេសចិន និងការលក់សម្បត្តិធម្មជាតិនៅតំបន់ដែលពួកគេកាន់កាប់។

ថ្ងៃទី១១មករា១៩៧៩ សម្ដេចសីហនុ យាងទៅកាន់ក្រុមប្រឹក្សាសន្តិសុខ អង្គការសហប្រជាជាតិនៅញូយ៉កថ្កោលទោសការឈ្លានពាននៅកម្ពុជាដោយវៀតណាម ក្នុងនាមអ្នកនាំពាក្យរបបកម្ពុជាប្រជាធិបតេយ្យ ហើយអៀងសារីទៅប៉េកាំង បានទទួលជំនួន៥លានដុល្លារពីចិនដើម្បីធ្វើការតស៊ូតទៅទៀត។ ដោយដឹងការពិតថាវៀតណាមកំពុងលុកលុយកម្ពុជាមែន ខុសពីគោលការណ៍ច្បាប់អន្តរជាតិ ថ្ងៃទី១៣ មករា១៩៧៩ ក្រុមប្រឹក្សាសន្តិសុខសហប្រជាជាតិទាមទារឱ្យ”កងទ័ពបរទេស”(គឺសំដៅវៀតណាម)ដកកងទ័ពខ្លួនជាបន្ទាន់ចេញពីកម្ពុជា ហើយប្រកាសនៅទទួលស្គាល់”កម្ពុជាប្រជាធិបតេយ្យ”ជារដ្ឋាភិបាលស្របច្បាប់តែមួយគត់នៅកម្ពុជា។ បន្ទាប់មក នៅថ្ងៃទី១៤ខែមករានោះសម្ដេចសីហនុ បានព្យាយាមគេចចេញពីការគ្រប់គ្រងរបស់ប្រតិភូខ្មែរក្រហមនៅញូយ៉ក ហើយក្រោយមកនៅចុងខែកុម្ភៈបានទទួលការអញ្ជើញឱ្យគង់នៅប៉េកាំងដោយប្រធានធិបតីចិននាម តេងស៊ាវភីង។ ដើម្បីឱ្យវត្តមានកងទ័ព និងកម្មាភិបាលស៊ីវិលវៀតណាមនៅកម្ពុជាដោយស្របច្បាប់ នៅថ្ងៃទី១៧កុម្ភៈ១៩៧៩ សាធារណរដ្ឋប្រជាមានិតកម្ពុជា

និងសាធារណរដ្ឋសង្គមនិយមវៀតណាមបានចុះសន្ធិសញ្ញាមិត្តភាព*សហប្រតិបត្តិការនៃប្រទេសទាំងពីរ និងបក្សទាំងពីរ។

បន្ទាប់មកនៅថ្ងៃទី៩ តុលា ឆ្នាំ១៩៧៩ លោកសឺន សាន បានបង្កើតរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ (រជរបខ-FNLPK)នៅជំរំសុខសាន្ត ក្នុងខេត្តត្រាត ប្រទេសថៃ ដោយធ្វើការប្រកាសថាជាចលនាតស៊ូប្រឆាំងរដ្ឋាភិបាលភ្នំពេញ និងវត្តមានកងទ័ពវៀតណាមនៅកម្ពុជា។ ចលនាតស៊ូទ័ពព្រៃមួយនេះ មានឈ្មោះមួយទៀតថា ចលនា"សេរីកា"។ លោក សឺន សាន ជាអតីតនាយករដ្ឋមន្ត្រីមួយរយៈខ្លីរបស់សម្តេច ន. សីហនុ។ ក្រោយមក សម្តេចសឺនសាន មានបំណងថ្វាយតំណែងប្រមុខនៃចលនានេះ ដល់សម្តេចនរោត្តម សីហនុ ប៉ុន្តែនៅថ្ងៃទី២៥ វិច្ឆិកា១៩៧៩ នៅទីក្រុងប៉ារីស ពេលជួបសន្ទនាជាមួយប្រធានាធិបតីបារាំងនាម ហ្សីស្កាដេស្តាំង, សម្តេចសីហនុ បានបដិសេធសំណើលោកសឺនសាន។ ប៉ុន្មានឆ្នាំក្រោយពីមានសន្តិភាពនៅកម្ពុជាមក សម្តេចហ៊ុន សែន ធ្លាប់បញ្ជាក់មូលហេតុនៃការបដិសេធរបស់សម្តេចមិនទទួលធ្វើប្រមុខរណសិរ្សរបស់សម្តេច សឺនសានពេលនោះថា មកពីថ្ងៃកំណើតរបស់រណសិរ្សនេះ"ចំថ្ងៃខួបកំណើតរបបសាធារណរដ្ឋខ្មែររបស់លន់ នល់"។ ចលនានេះតាំងមូលដ្ឋានចល័តនៅតាមជាយដែនខ្មែរ-ថៃ ក្នុងទឹកដីខេត្តបន្ទាយមានជ័យ និងឧត្តរមានជ័យ។ ចលនាតស៊ូនេះ ត្រូវគេអះអាងថា នឹងប្រើកម្លាំងយោធាបណ្តេញកងទ័ពវៀតណាមឈ្លានពាន ចេញពីប្រទេសកម្ពុជា។ បើតាមការសម្ភាសន៍ផ្ទាល់ជាមួយអតីតយុទ្ធជនរបស់ចលនានេះនៅថ្ងៃពួកនាខែមេសាឆ្នាំ២០០៦ និងការសរសេររបស់លោកឪពុក ហ្វ្រង់ស្វ័រ ប៉ុងសូដ៍ថា៖ ដោយសារមានជនភៀសខ្លួនច្រើន អ្នកទាំងនោះបានក្លាយជាប្រភពធនធានមនុស្សសម្រាប់តស៊ូប្រដាប់អាវុធ ព្រោះពួកមេដឹកនាំតស៊ូ ប្រើវិធីបង្អត់ជំនួយសម្រាប់អ្នកភៀសខ្លួនជាបុរស ដើម្បីឱ្យពួកគេចុះចូលក្នុងចលនាតស៊ូ។ ក្រុមចលនាតស៊ូនេះ មិនមានឥទ្ធិពលគំរាមកំហែងខ្លាំងដល់ក្រុងភ្នំពេញនោះទេ។ ព្រោះ ចលនានេះ មានបញ្ហាបាក់បែកផ្ទៃក្នុង និងប្រណាំងប្រជែងគ្នាមិនចេះចប់ រហូតបែកជាពីរក្រុមផ្សេងគ្នានៅពេល មុនមានកិច្ចព្រមព្រៀងនៅប៉ារីសឆ្នាំ១៩៩១។

ចំណែកចលនាតស៊ូមួយទៀត មានឈ្មោះថា ម៉ូលីណាកា ជាចលនាអ្នកតស៊ូសីហនុនិយម ដែលត្រូវបានគេបង្កើតឡើងតាំងពីឆ្នាំ១៩៧៩។ មកដល់ថ្ងៃទី៥មីនា១៩៨០ សម្តេចសីហនុបានស្នើខៀវសំផនឱ្យបង្កើតរណសិរ្សរួបរួមជាតិមួយប្រឆាំងវៀតណាម, តែខ្មែរក្រហមបដិសេធ ហើយនៅថ្ងៃទី៨ កុម្ភៈ ឆ្នាំ១៩៨១ សម្តេចសីហនុ បានប្រកាសទិសដៅរួបរួមគ្នារវាងគ្រប់កងកម្លាំងដែលប្រឆាំងរបបគ្រប់គ្រងនៅភ្នំពេញ ក៏នៅតែគ្មានលទ្ធផលអ្វីដដែល។ ទើបមកដល់ថ្ងៃទី២៦មីនា១៩៨១ ព្រះអង្គបានបង្កើតចលនា"ហ្វុនស៊ិនប៉ិច"ឡើងនៅប៉ារីស លើមូលដ្ឋានកងទ័ពតស៊ូម៉ូលីណាកា។ ដោយព្រះអង្គធ្វើព្រះប្រធាន ហើយនៅថ្ងៃទី១មករា១៩៨២ ព្រះអង្គប្រកាសបោះបង់ការព្យាយាមចរចាជាមួយហាណូយ មកការកសាងកងទ័ព១០០០០០នាក់ភ្លាមៗនៅក្នុងកម្ពុជា ដើម្បីប្រឆាំងយួននៅកម្ពុជា។

ក្រោយមក គេស្គាល់ថាហ្វ៊ុនស៊ិនប៉ិច មានមូលដ្ឋាននៅបន្ទាយមានឫទ្ធិ, បឹងត្រកួន ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ។ ថ្វីបើដឹកនាំដោយអតីតព្រះប្រមុខរដ្ឋដ៏មានប្រជាប្រិយភាព ក៏ចលនានេះ នៅតែមានកម្លាំងទន់ខ្សោយ បើប្រៀបធៀបជាមួយចលនារបស់ពួកខ្មែរក្រហម។ ក្រុមនេះ ក៏ដូចក្រុមលោកសឺន សានដែរ ចាប់ផ្តើមធ្វើសកម្មភាពវាយឆ្មក់ នៅរវាងឆ្នាំ១៩៨១-២ តែពួកគេមិនសូវមានកម្លាំងច្រើនសម្រាប់លុកលុយអុកឡុករដ្ឋាភិបាលភ្នំពេញ ឬភូមិដ្ឋានអ្នកស្រុកបានច្រើនកន្លែង នៅពាសពេញផ្ទៃក្នុងប្រទេសដូចខ្មែរក្រហមឡើយ។

កងកម្លាំងតស៊ូក្រោមលេសប្រឆាំងវត្តមានវៀតណាម និងរបបក្រុងភំពេញ តែងតែប៉ះទង្គិចគ្នាជារឿយៗដោយសារមិនបានតស៊ូរួមគ្នា និងចុះសម្រុងគ្នា។ ប៉ុន្តែនៅថ្ងៃទី២២មិថុនា១៩៨២ ក្រោមសម្ពាធរបស់ប្រទេសអាស៊ានបក្សតស៊ូទាំងបីភាគីបានចុះហត្ថលេខាព្រមព្រៀងគ្នាបង្កើតរដ្ឋាភិបាលត្រីភាគីនៅកូឡាឡាំពួរ ដោយម៉ូលីណាកា

មានកងទ័ពប្រមាណ៣០០០០នាក់ រេរបខមានប្រមាណ៨០០០នាក់ និងខ្មែរក្រហមប្រមាណ៣៥០០០នាក់។ ឈ្មោះ "រដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ"(Gouvernement de Coalition du Kampuchea Démocratique-GCKD)។ ដូច្នេះ ការចងសម្ព័ន្ធមិត្តគ្នារបស់បក្សទាំងបីនេះ ត្រូវធ្វើឡើងទាំងទើសទាល់ ស្របតាមការចង់បានរបស់ប្រទេសផ្តល់ជំនួយប៉ុណ្ណោះ។ ក្រោយមក រដ្ឋាភិបាលចម្រុះត្រីភាគីនិរទេសខ្លួនមួយនេះ មានការទទួលស្គាល់ពីសហគមន៍អន្តរជាតិ។ រដ្ឋាភិបាលនិរទេសនេះ ទទួលបានភាពស្របច្បាប់ក្នុងការកាន់កាប់អាសនៈកម្ពុជានៅអង្គការសហប្រជាជាតិ រហូតមកដល់ចុងទសវត្សរ៍ឆ្នាំ១៩៨០។

- ក្រុមទាំងនេះធ្វើសកម្មភាពយោធាទាំងតាមព្រំដែនខ្មែរ-ថៃ និងផ្ទៃក្នុងប្រទេស
- ក្នុងការវាយប្រហារកងទ័ពប្រជាជនបដិវត្តន៍កម្ពុជា និងកងទ័ពវៀតណាម បង្កើតស្ថានភាពអសន្តិសុខ និងការបំផ្លាញសំណង់សាធារណៈ ឱ្យលាតសន្ធឹងនៅទូទាំងផ្ទៃប្រទេស។
- តាមភូមិស្រុកកងកម្លាំងទាំងបីនេះ មិនបានធ្វើឱ្យប្រជាជនសាមញ្ញ មានការភ័យខ្លាចនោះទេ តែអ្នកស្រុកខ្លាចពេលពួកគេប៉ះទង្គិចជាមួយកងទ័ពរដ្ឋាភិបាលភ្នំពេញ ឬវៀតណាម។ ទោះជាយ៉ាងណា ជាញឹកញយដោយសារកងកម្លាំងប្រឆាំងគ្នា៤ក្រុម និងថែមបរទេសមួយក្រុមបែបនេះទៀត ពួកគេពិតជាបង្កអស្ថិរភាពសង្គមមែន ដោយអំពើឃោរឃៅប្លន់ប្រដាប់អាវុធ ហើយទម្លាក់កំហុសដាក់គ្នា។
- រដ្ឋាភិបាលត្រីភាគីនេះ ទទួលការជេរប្រមាទ ចំអកឡកឡឺយ ដោយរដ្ឋាភិបាលភ្នំពេញ តាមប្រព័ន្ធឃោសនាយ៉ាងចាស់ដៃ។ មានទាំងបទចម្រៀងជេរសម្តេចសីហនុ, សឺនសាន និងប៉ុលពត ផងដែរ។

សាធារណមតិខ្មែរជាទូទៅយល់ថា វៀតណាមក៏ពេញចិត្តណាស់ដែរ ចំពោះវត្តមានរបស់កម្លាំងតស៊ូខ្មែរនៅតាមជាយដែន។ ព្រោះ វៀតណាមមានលេសក្នុងការបញ្ជូនកងទ័ពខ្លួននៅប្រទេសកម្ពុជា។ ចំណែកក្រុមតស៊ូក៏នៅតែមិនទុកចិត្តចំពោះវៀតណាម ដែលតែងតែចង់លុកលុយកាន់កាប់កម្ពុជាតាំងពីដើមរៀងមក ថា បើពួកគេមិនតស៊ូ វៀតណាមអាចដកចេញពីកម្ពុជាដោយស្វ័យប្រវត្តិ។

## 9. ការដកថយរបស់កងទ័ពវៀតណាម

កងទ័ពវៀតណាមនៅកម្ពុជា ចាប់ពីឆ្នាំ១៩៧៩ ត្រូវគេប៉ាន់ស្មានថា មានបរិមាណសរុបប្រមាណចំនួន ១៥០០០០នាក់។ នៅថ្ងៃទី១៣មករា១៩៧៩ ក្រុមប្រឹក្សាសន្តិសុខសហប្រជាជាតិ បានប្រកាសឱ្យវៀតណាមដកកងទ័ពខ្លួនថយចេញពីកម្ពុជា បន្ទាប់ពីសម្តេចសីហនុ ក្នុងនាមអ្នកនាំពាក្យរបស់ពួកខ្មែរក្រហម-កម្ពុជាប្រជាធិបតេយ្យ ដែលបានថ្លែងប្រកាសថ្កោលទោសថា វៀតណាមឈ្លានពានកម្ពុជានៅវិមានក្រុមប្រឹក្សាសន្តិសុខសហប្រជាជាតិ កាលពីថ្ងៃទី១១ មករា១៩៧៩។ ចាប់ពីថ្ងៃទី១៥កក្កដាឆ្នាំ១៩៨២ គេឃើញកងទ័ពវៀតណាមមួយចំនួនតូច ដកចេញពីកម្ពុជាជាលើកទី១។ នៅថ្ងៃទី៣មីនាឆ្នាំ១៩៨៣ កងទ័ពវៀតណាមចំនួន១០០០០នាក់ទៀត បានដកថយចេញពីកម្ពុជាជាលើកទី២។ មកដល់ថ្ងៃទី២០មិថុនា១៩៨៤កងទ័ពវៀតណាមប្រមាណ១០០០០នាក់ទៀត បានដកចេញពីកម្ពុជា ជាលើកទី៣។ ហើយនៅថ្ងៃទី៣មេសាឆ្នាំ១៩៨៥ កងទ័ពវៀតណាមចំនួន១៥០០០នាក់ទៀត ត្រូវបានចេញពីកម្ពុជាជាលើកទី៤ បន្ទាប់ពីយុទ្ធនាការសឹកដ៏ខ្លាំងក្លារបស់វៀតណាម នៅតាមព្រំដែនខ្មែរ-ថៃ ដោយបានកំទេចជុំរុំជនភៀសខ្លួនជាច្រើនកន្លែងរបស់ភាគីអ្នកតស៊ូ ដែលមានមូលដ្ឋាននៅតាមព្រំដែន និងក្នុងទឹកដីថៃ។ ក្រោយពីផ្អាកអស់ពីរឆ្នាំ នៅឆ្នាំ១៩៨៨ កងទ័ពវៀតណាមបានបន្តដកចេញពីកម្ពុជាចំនួនពីរលើកទៀត គឺនៅថ្ងៃទី៣០ ខែ មិថុនា ដែលមិនមានប្រកាសពីបរិមាណ និងនៅថ្ងៃទី១៥ធ្នូ មានការប្រកាសចំនួនកងទ័ព១៨០០០នាក់។

មកដល់ថ្ងៃទី៥មេសា១៩៨៩ សមមិត្ត ហ៊ុន សែន បានប្រកាសថា ដើម្បីផ្តល់ជាសម្បទានដ៏ចម្បង វៀតណាមនឹងដកកងទ័ព, អ្នកជំនាញការ និងសាស្ត្រាចារ្យវៀតណាមទាំងអស់របស់ខ្លួនចេញពីកម្ពុជា នៅចុងខែកញ្ញា។[144] ថ្ងៃទី២១ខែកញ្ញាឆ្នាំ១៩៨៩ ជានៅថ្ងៃកំណត់ដកចេញនោះបានមកដល់។ នៅទូទាំងប្រទេស ដែលមានផ្លូវជាតិតភ្ជាប់ជាមួយវៀតណាម បានរៀបចំពិធីលាដំណើរចាកចេញយ៉ាងគគ្រឹកគគ្រេង ក្រោមកិច្ចសង្កេតការរបស់អ្នកកាសែតបរទេស។[145] ពាក្យពេចន៍លាដំណើរដ៏ពិរោះដែលខ្មែរសម្តែងប្រកបដោយការដឹងគុណនោះ គេឃើញនៅតែចារជាប់លើស្លាកខ្លោងទ្វារព្រំដែនខ្មែរ-វៀតណាម ដូចជា នៅច្រកភ្នំដិនខេត្តតាកែវ ស្លាកនេះនៅមិនទាន់រលុបនៅឡើយ ″មិត្តដកទៅមែនពិត តែចិត្តនៅចងចាំជានិច្ច″(ទស្សនកិច្ចសិក្សាថ្ងៃទី៩ឧសភា២០០៥)។ ការដកកងទ័ពចេញរបស់វៀតណាមនៅថ្ងៃនោះ ត្រូវបានប្រព្រឹត្តទៅតាមច្រកព្រំដែនអន្តរជាតិបី គឺនិងច្រកផ្លូវជាតិលេខ២ ស្រុកគិរីវង់ ខេត្តតាកែវច្រកភ្នំដិន-ក្របៅ, ច្រកផ្លូវជាតិលេខ៧ស្រុកមេមត់, [146] និងច្រកផ្លូវជាតិលេខ១ខេត្តស្វាយរៀងបាវិត-ម៉ុកបាយ។ រៀងរាល់លើក ការដកថយជាផ្លូវការនោះ សុទ្ធសឹងមានអ្នកកាសែត និងអ្នកសង្កេតកាណ៍បរទេសចុះទៅយកការណ៍ផ្ទាល់ ក្រោមការចាត់ចែងដឹកជញ្ជូនដោយរដ្ឋាភិបាល តាមឧទ្ធម្ភាគចក្រ។ ការដកថយរបស់កងទ័ពវៀតណាម ធ្វើឱ្យប្រជាជនខ្មែរ នៅតាមដងផ្លូវជាតិលេខ៧ មិនអស់ចិត្តទាល់តែសោះ។ ដោយសារ គេមើលឃើញថា នៅរៀងរាល់លើកនៃការដកថយ ពេលព្រឹកមានរថយន្តរាប់រយ ដោយរថយន្តនីមួយៗផ្ទុកពោរពេញដោយវត្ថុ ឬឧបករណ៍ប្រើប្រាស់ប្រចាំថ្ងៃ និងមានកងទ័ពជិះប្រមាណ៥ទៅ១០នាក់ប៉ុណ្ណោះ។ ប៉ុន្តែ ក្រោយពីអ្នកសង្កេតការណ៍វិលត្រឡប់មកភ្នំពេញអស់ នៅរាត្រីថ្ងៃដដែលនេះ គេបានឃើញរថយន្តដឹកកងទ័ពដែលស្លៀកពាក់ដូចកងទ័ពវៀតណាមដែរប្រមាណពី៥០ទៅ៧០ឡាន ដែលឡាននីមួយៗផ្ទុកមនុស្សណែនណាន់តាន់តាប់ បើកបរត្រឡប់មកស្រុកខ្មែរវិញតាមផ្លូវជាតិលេខ៧។ រថយន្តទាំងនោះ ពេលខ្លះឈប់សំចតនៅក្រោមដើមស្វាយជ្រុំ ក្នុងបរិវេណបន្ទាយសឹកស្រុកកំពង់សៀមទៀបជើងភ្នំប្រុស នៅពេលថ្ងៃ មុននឹងពួកគេបន្តដំណើរទៅមុខទៀត នៅពេលព្រលប់មកដល់។ តើនោះជាកងទ័ពអ្វី? តើមានអ្នកណាដឹងច្បាស់ទេអំពីរឿងនេះ? ទាក់ទងនឹងបញ្ហានេះ លោក សឺន សាន ធ្លាប់បានបញ្ចេញប្រតិកម្មប្រឆាំងដោយចោទប្រកាន់ថា រដ្ឋាភិបាលភ្នំពេញបានលាក់កងទ័ពវៀតណាមជាច្រើននាក់ក្រោមរូបភាពជាជនស៊ីវិល។ យោងតាមឯកសារផ្លូវការ រដ្ឋាភិបាលក្រុងភ្នំពេញ បានធ្វើការអះអាងបំភ្លឺចំពោះការចោទប្រកាន់នោះ រហូតអំឡុងខែឧសភាឆ្នាំ១៩៩១ នៅពេលគេធ្វើការផ្តត់ផ្តង់ដើម្បីការសម្រេចចិត្ត និងប្រាក់ខែរបស់″កងទ័ពវៀតណាម និងជំនាញការវៀតណាមខាងសន្តិសុខដែលកំពុងដឹកនាំសកម្មភាពយោធា″។[147]

---

[144] Jennar, Raoul M., 1995. *Les clés du Cambodge*, Maisonneuve & Larose, pp. 87-99.

[145] Gottesman, Evan, 2002. Cambodia After the Khmer Rouge: inside the Politics of Nation Building, Yale University Press, p. 309.

[146] ពេលនោះខ្ញុំជាសិស្សថ្នាក់ទី១១(ឆ្នាំចុងក្រោយ)នៃវិទ្យាល័យកំពង់ចាម ត្រូវអាជ្ញាធរឱ្យចូលរួមពិធីជូនដំណើរបងៗកងទ័ពវៀតណាមយ៉ាងមហោឡារិកដូចលើកមុនៗដែរ។ តែពិធីម្តងនេះ គេធ្វើនៅលើដងផ្លូវឯនាយមុខមន្ទីរខេត្ត ដែលបែរមុខទៅរកមាត់ទន្លេមេគង្គ និងខាងលិចវិមានរំឭកគុណអ្នកស្នេហាជាតិខេត្ត ដែលសង់តាមរចនាបថវិមានឯករាជ្យ។ រោងពិធីនោះ គេធ្វើនៅចំពីមុខសណ្ឋាគារបង់ហ្គាឡូខេត្ត បែរមុខទៅខាងជើង ដែលមានទីវាលធំមួយនៅខាងកើតសាលាទក្សិណ។ ព្រឹកនោះដោយមានអ្នកឡើងថ្លែងសុន្ទរកថាវែងៗជាច្រើននាក់ រួមទាំងមេបញ្ជាការកងទ័ពវៀតណាមផងនោះ នាំឱ្យមានយុទ្ធជនវៀតណាមម្នាក់ដែលឈរយាមនៅក្បែរជើងសសរខាងកើតនៃវេទិកា កើតជំងឺខ្យល់គរដួលបោកខ្លួនទៅលើដីមួយរំពេច នាំឱ្យអ្នកចូលរួមទាំងអស់ស្លុតចិត្តអាណិតគ្រប់គ្នា។

[147] Cf., *Ibid.*, p. 309.

បើតាមកស្តុតាងផ្សេងៗ ការដកថយរបស់កងទ័ពវៀតណាម គឺជាការពិត។ ព្រោះមកដល់ខែសីហា ឆ្នាំ ១៩៩០ នៅឆេងទូ ប្រទេសចិន មន្ត្រីជាន់ខ្ពស់ចិន និងវៀតណាមបានប្រារព្ធធ្វើការប្រជុំកំពូលជាសម្ងាត់ និងដ៏មានសារៈសំខាន់បំផុតមួយ ដែលភាគីទាំងពីរបានសន្យាធ្វើសម្បទានដល់គ្នាទៅវិញទៅមកអំពីបញ្ហាកម្ពុជា។ ភាគីវៀតណាមបានទទួលយល់ព្រមថា កងទ័ពរបស់ខ្លួនដែលបានដកថយចេញនោះ គួរតែអនុញ្ញាតឱ្យសហប្រជាជាតិធ្វើការត្រួតពិនិត្យសារឡើងវិញ ហើយថាដូចគ្នានេះដែរ សម្រាប់ដំណោះស្រាយបញ្ហានយោបាយគួរតែធ្វើឡើងនៅក្រោមការគាំពាររបស់សហប្រជាជាតិដែរ។ ចំណែកភាគីចិនបានទទួលយល់ព្រមថា ត្រូវតែបង្ខំឱ្យភាគីខ្មែរក្រហម ដែលតំណាងដោយខៀវ សំផននោះ ធ្វើការយល់ព្រមឱ្យ៉ភាគីរដ្ឋកម្ពុជា៉ មានសមាជិកភាព៦រូបក្នុងចំណោម១២រូប ក្នុងការបង្កើតក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ដែលនឹងត្រូវធ្វើជាអ្នកថែរក្សាអធិបតេយ្យភាពរបស់កម្ពុជា នៅអំឡុងពេលអន្តរកាលនៃវត្តមានរបស់សហប្រជាជាតិនៅកម្ពុជា៕[148]



*ប្រកទ្វារភ្នំដិន ព្រំដែនកម្ពុជា-វៀតណាម*
*ទស្សនកិច្ចសិក្សារបស់និស្សិតប្រវត្តិវិទ្យា ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០៥*

[148] Cf., *Ibid.*, p. 343.

# មេរៀនទី 15 កិច្ចដំណើរការសន្តិភាព

## 1. បរិការណ៍ពិភពលោកនៅចុងទសវត្សរ៍ឆ្នាំ១៩៨0

នយោបាយសេដ្ឋកិច្ចរបស់មហាប្រទេសកុម្មុយនិស្តសហភាពសាធារណរដ្ឋសង្គមនិយម បានចាប់ផ្តើមចុះអន់ថយ និងរង្គោះរង្គើនៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៨០។ ពេលនោះ សហភាពសូវៀត ចាប់ផ្តើមបង្កើតគោលនយោបាយ″កែទម្រង់″(ឬ ប៉េរ៉េស្រ្តូយកា)សេដ្ឋកិច្ច ដើម្បីដោះស្រាយវិបត្តិនោះ។ ប៉ុន្តែជាការអត់ប្រយោជន៍ ព្រោះដំណាំកសិផលនៅតែខូចខាតមិនបានផល ចំណែកផលិតផលឧស្សាហកម្ម កាន់តែគ្មានតុល្យភាព។ សេដ្ឋកិច្ចផែនការរបស់កុម្មុយនិស្ត ដែលគ្មានការប្រកួតប្រជែង បានធ្វើឱ្យប្រទេសនេះឈានទៅរកការបរាជ័យសេដ្ឋកិច្ចខាងឧស្សាហកម្មទាំងធុនធ្ងន់ និងទាំងធុនស្រាល។ នៅប្រទេសអាល្លឺម៉ង់ ជញ្ជាំងទីក្រុងប៊ែរឡាំង ត្រូវបានគេកំទេចចោលនៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៨៩ អាល្លឺម៉ង់កុម្មុយនិស្ត និងសេរីចាប់ផ្តើមរួបរួមគ្នាឡើងវិញ ដែលបង្កើតជានិមិត្តរូបនៃការបញ្ចប់″សង្គ្រាមត្រជាក់″។ ដោយហេតុថា មេខ្លោងពិភពកុំមុយនីសត្រូវអស់ឫទ្ធានុភាព គ្មានអ្វីដែលអាចជួយដល់សាធារណរដ្ឋសង្គមនិយមវៀតណាមតទៅទៀត ទើបវៀតណាមសុខចិត្តដកដៃចេញពីកម្ពុជាបន្តិចម្តងៗ និងផ្តល់សិទ្ធិស្វ័យសម្រេចដល់ប្រមុខរដ្ឋាភិបាលរដ្ឋកម្ពុជានៅភ្នំពេញ។

## 2. រដ្ឋកម្ពុជា និងដំណើរការចរចាសន្តិភាព

នៅថ្ងៃទី២៩-៣០មេសាឆ្នាំ១៩៨៩ ជាថ្ងៃសង្ឃឹមដែលបានកំណត់កាលបរិច្ឆេទនៃការដកកងទ័ពវៀតណាមចុងក្រោយ ជាមួយនឹងអ្នកជំនាញការ និងសាស្ត្រាចារ្យវៀតណាមនៅសាកលវិទ្យាល័យចេញពីកម្ពុជា។ ជាមួយគ្នានោះដែរ សភាជាតិដែលជាប់ឆ្នោតតាំងពីឆ្នាំ១៩៨១មកនោះ បានអនុម័តការធ្វើវិសោធនកម្មច្បាប់ជាច្រើនក្រមអមរដ្ឋធម្មនុញ្ញ។ ក្រមច្បាប់ទាំងនោះមានចំនួនច្រើនគ្រប់គ្រាន់សម្រាប់រដ្ឋធម្មនុញ្ញថ្មីមួយ និងព្រមទាំងការផ្លាស់ប្តូររបបថ្មីមួយផង។ វាហាក់ដូចជារបបកុំមុយនីសមួយត្រូវគេបោះបង់ចោលជាផ្លូវការ ដោយប្រទេសកម្ពុជា លែងជា″សាធារណរដ្ឋប្រជាមានិត″តទៅទៀតហើយ, ដូចគ្នានឹងប្រទេសកុំមុយនីសទាំងអស់ដែរ។ ប៉ុន្តែ គេគ្រាន់តែផ្លាស់ប្តូរឈ្មោះជា″រដ្ឋកម្ពុជា″ ឬ **SOC** ប៉ុណ្ណោះ។

ការផ្លាស់ប្តូរឈ្មោះនេះ ត្រូវត្រូវគេធ្វើឡើងក្នុងបរិបទនៃការជំរុលដំណើរការទៅមុខនៃការចរចានៅលើវេទិកាអន្តរជាតិ។ ចាប់ពីឆ្នាំ១៩៨៧មក ដោយសារមានលោកស្រី ពុង ឈីវហ្គេក ធ្វើអន្តរការីរវាងសម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងសម្តេចព្រះ ន. សីហនុ បានជួបចរចាគ្នាជាលើកដំបូងនៅហ្វែរអង់តាជឺណ័រ ប្រទេសបារាំងនៅថ្ងៃទី៤-៥ ខែធ្នូ ឆ្នាំ១៩៨៧ និងខែមករាឆ្នាំ១៩៨៨។ ថ្វីត្បិតតែជំនួបនោះ មិនមានលទ្ធផលអ្វីជាធំដុំ តែបានបើកផ្លូវឱ្យភាគីខ្មែរ ដែលច្បាំងគ្នាស៊ីសាច់ហុតឈាម រកដំណោះស្រាយជាបន្តបន្ទាប់គ្នា ដើម្បីបញ្ចប់ការបង្ហូរឈាមគ្នានោះ។ នៅឆ្នាំបន្តបន្ទាប់ គេបានបន្តការចរចា ″ជំនួបក្រៅផ្លូវការ″នៅទីក្រុងហ្សាការតា នៅប្រទេសឥណ្ឌូ ដល់ទៅ២លើក(ហ្សីម១-២) នៅខែកក្កដាឆ្នាំ១៩៨៨ និងខែកុម្ភៈឆ្នាំ១៩៨៩ ដោយមានរដ្ឋមន្ត្រីការបរទេសឥណ្ឌូនេស៊ីនាម អាលីអាឡាតាស ធ្វើជាអាជ្ញាកណ្តាល រវាងភាគីជម្លោះទាំង៤ភាគី គឺសាធារណរដ្ឋប្រជាមានិតកម្ពុជា និងភាគីដែលហៅថា រដ្ឋាភិបាលនៃកម្ពុជាប្រជាធិបតេយ្យ (CGDK) ដែលរួមមានកម្ពុជាប្រជាធិបតេយ្យ (DK)ដែលដឹកនាំដោយ ប៉ុលពត, រណសិរ្សរួបរួមជាតិដើម្បីកម្ពុជាឯករាជ្យ អព្យាក្រឹត្យ សន្តិភាព និងសហ

ប្រតិបត្តិការ (FUNCINPEC) ដែលដឹកនាំដោយសម្តេច ន.សីហនុ, និងរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ (KPNLF) ដែលដឹកនាំដោយលោក សឺនសាន។ បញ្ហានេះក៏បាននាំដល់ជំនួបចរចាចតុភាគីនៅប៉ារីសជាលើកទី១ ពីថ្ងៃទី៣០ ខែកក្កដាដល់ថ្ងៃទី៣០សីហាឆ្នាំ១៩៨៩ ដោយមានប្រទេសជាមិត្តចំនួន១៩ប្រទេសចូលរួម តែចុងបញ្ចប់នៅតែគ្មានដំណោះស្រាយ។

សញ្ញាសម្គាល់ចាស់របស់ប្រទេស មានឈ្មោះ និងទង់ជាតិ ត្រូវបានគេផ្លាស់ប្តូរ ប៉ុន្តែមានបញ្ហាមូលដ្ឋានមួយចំនួនថែមទៀតនោះ គឺព្រះពុទ្ធសាសនា ដែលត្រូវបានបង្កើតឡើងវិញស្របតាមប្រពៃណីកាលពីមុនឆ្នាំ១៩៧៥នោះ បានឡើងជាសាសនាផ្លូវការ គ្រាន់តែមានការត្រួតពិនិត្យព្រះសង្ឃយ៉ាងតឹងតែងពីក្រសួងធម្មការ និងកិច្ចការសាសនា ជាមួយនឹងសម្តេចសង្ឃរាជ។ ទោសប្រហារជីវិត ត្រូវលុបចោល តែទោះបីជាយ៉ាងណានៅមានការសម្លាប់ចោរប្លន់ម៉ូតូនៅតាមផ្លូវ ក្រៅប្រព័ន្ធច្បាប់ដោយហ្វូងមហាជន និងព្រមជាមួយការសម្លាប់ខាងនយោបាយ។ សេរីភាពមួយចំនួនក្នុងការបង្កើតសមាគមត្រូវបានបើកឱ្យមានឡើងវិញ។ តែកត្តាសំខាន់ពីរ គឺរបបកម្មសិទ្ធិឯកជន ត្រូវគេអនុញ្ញាតឱ្យមានឡើងវិញ ស្របជាមួយគ្នានឹងទ្រព្យសម្បត្តិគ្រួសារ, សាជីវកម្ម, សហគមន៍ឬជាតិ។ នៅពេលដែលប្រព័ន្ធពហុបក្សនយោបាយ ត្រូវបានគេហាមឃាត់ដាច់អហង្ការ ហើយគេបានបញ្ជាក់យ៉ាងច្បាស់ពីបក្សតែមួយរបស់រដ្ឋ ដោយបក្សប្រជាជនបដិវត្តន៍កម្ពុជា នៅតែជាបក្សគ្រប់គ្រងតែមួយគត់លើប្រទេសកម្ពុជា ដូចដែលលោក វ៉ាអ៊ីលដេនណារ បានសរសេរថា បក្សគឺជា"កម្លាំងដឹកនាំរបស់សង្គមខ្មែរ និងរដ្ឋ, និងជាកម្លាំងស្នូលនៃមហាសាមគ្គីជាតិ និងរាល់កម្លាំងនយោបាយ"។ ឈ្មោះរបស់បក្សនេះ ត្រូវគេផ្លាស់ប្តូរ ហើយជាផ្លូវការបានប្រកាសបោះបង់ចោលលទ្ធិកុម្មុយនិស្តនៅឆ្នាំបន្ទាប់ប៉ុណ្ណោះ ដោយប្រែកាយឈ្មោះជា"**បក្សប្រជាជនកម្ពុជា**"នៅអំឡុងពេលសមាជថ្ងៃទី១៧-១៨ ខែតុលា ឆ្នាំ១៩៩០ ប៉ុន្តែវាត្រឡប់ទៅដូចឈ្មោះកាលពីឆ្នាំ១៩៥១ នៅពេលគេបង្កើតឡើងដំបូង និងជាពិសេសដូចនៅពេលគេចូលរួមបោះឆ្នោតជាតិឆ្នាំ១៩៥៥។ គេបានប្រារព្ធធ្វើបុណ្យអនុស្សាវរីយ៍លើកទី៥០ឆ្នាំនៅឆ្នាំ២០០១។ បក្សប្រជាជនកម្ពុជាបានបោះបង់ចោលមនោគមវិជ្ជាកុម្មុយនិស្ត តែគេនៅតែរក្សាបែបបទការិយាធិបតេយ្យ និងប្រមូលផ្តុំអំណាចអង្គការពីថ្នាក់កំពូលរហូតដល់មូលដ្ឋាន។

តាមការពិតជាក់ស្តែង គ្រប់មាត្រានៃច្បាប់រដ្ឋធម្មនុញ្ញ ហាក់ចង់បង្ហាញពីទិដ្ឋភាពថ្មីដ៏ទូលំទូលាយមួយចំពោះអភិបាលកិច្ច ដែលលោក ហង់រី ឡូការដ៍ រិះគន់ថា នោះគ្រាន់តែបង្ហាញពីការតុបតែងលម្អមាត់បង្អួចប៉ុណ្ណោះ។ បើសរុបមកវិញ មានបញ្ហាជាច្រើនត្រូវបានកែប្រែ និងបើកទូលាយ ដូចជា ការដូរឈ្មោះប្រទេស, ដូរសញ្ញាទង់ជាតិ, លុបចោលទោសប្រហារជីវិត, កែសម្រួលច្បាប់សម្រាប់ពុទ្ធសាសនា និងចាត់ទុកជាសាសនារបស់រដ្ឋ បង្កើតរបបកម្មសិទ្ធិឯកជនភាវូបនីយកម្មលើដីធ្លី និងអចលនទ្រព្យផ្សេងៗ និងប្រកាសបើកគោលនយោបាយសេដ្ឋកិច្ចទីផ្សារសេរី។ តែអ្វីគួរឱ្យកត់សម្គាល់តាមរយៈការបើកផ្លូវនៃច្បាប់កម្មសិទ្ធិឯកជននេះ ដោយរំពឹងគិតថា ពួកបក្សប្រឆាំងមុខជានឹងអាចចែករំលែកអំណាចជាមួយរដ្ឋាភិបាលភ្នំពេញ "គេបានសម្រេចចិត្តបង្វែររាល់គ្រឹះស្ថានឧស្សាហកម្មទាំងឯស់របស់រដ្ឋទៅជារបស់បក្ស"។[149] ក្នុងខែធ្នូឆ្នាំ១៩៩១ រោងចក្រសហគ្រាសទាំងអស់របស់ក្រសួងឧស្សាហកម្មត្រូវគេលក់ឱ្យឈ្មួញឯកជន លើកលែងតែរោងចក្របីប៉ុណ្ណោះ។ អតីតរោងភាពយន្តរបស់រដ្ឋមួយចំនួនធំក៏ត្រូវលក់ឱ្យឯកជនជាបន្តបន្ទាប់គ្នា។ នោះជាពេល ដែលដីធ្លី និងផ្ទះសំបែងត្រូវគេប្រែក្លាយជាទ្រព្យសម្បត្តិឯកជនយ៉ាងឆាប់រហ័សដូចគ្នា។ ហេតុនេះហើយ ទើបគេឃើញមានតែសមាជិកនៃគណបក្សប្រជាជនប៉ុណ្ណោះ ដែលក្លាយ

[149] Evan Gottesman, 2002, op. cit., p. 309.

ជាម្ចាស់ផ្ទះវីឡា និងភូមិគ្រឹះធំៗ សម្រាប់ជួលឱ្យភ្នាក់ងារអ៊ុនតាក់ធ្វើការិយាល័យ និងទីស្នាក់អាស្រ័យ និងលក់ឱ្យអ្នកមកពីបរទេស។

បើតាមលោក ហង់រី ឡូការដ៍ បានធ្វើសេចក្តីសន្និដ្ឋានថា រដ្ឋធម្មនុញ្ញថ្មីរបស់រដ្ឋកម្ពុជា មិនមែនដើម្បីគោលបំណងដ៏ខ្ពង់ខ្ពស់នោះទេ តែដើម្បីលុយ ទ្រព្យសម្បត្តិ និងការចាប់ផ្តើមធ្វើជាវរជនខាងមុខជំនួញ ដើម្បីក្តាប់មធ្យោបាយផលិតកម្ម និងសេដ្ឋកិច្ចក្នុងសករាជសេដ្ឋកិច្ចទីផ្សារសេរី ដែលជាប្រភពនៃអំណាចដ៏សំខាន់ អាចឱ្យគេគ្រប់គ្រងប្រទេសបានរហូតដល់សព្វថ្ងៃ។ នេះជាគោលនយោបាយថ្មីរបស់បក្សប្រជាជនកម្ពុជា ក្នុងការឈានជើងចូលក្នុងសម័យកាលអនុវត្តន៍លទ្ធិប្រជាធិបតេយ្យសេរី ដែលរដ្ឋាភិបាលត្រូវតែកើតឡើងពីការបោះឆ្នោត ទើបការគេត្រូវគិតគូរឡើងវិញចំពោះទ្រឹស្តីគ្រប់គ្រងរដ្ឋបែបប្រពៃណីបុរាណ ដែលអភិបាលខេត្តចូលកាន់តំណែង គេប្រើពាក្យថា "ធីខេត្ត" ហើយ"របបនយោបាយមួយមានស្ថេរភាពបាន ទាល់តែធ្វើឱ្យពួកមន្ត្រីក្លាយជាអ្នកមានទ្រព្យស្តុកស្តម្ភ"។ ហើយសេចក្តីប្រកាសមួយ ជាសាធារណៈរបស់រាជរដ្ឋាភិបាលចម្រុះអាណត្តិទី១ ចាប់ពីឆ្នាំ១៩៩៣មកគឺ គោលនយោបាយ "រាស្ត្រមានមុនរដ្ឋ" ដែលអាចឱ្យគេយល់បានអំពីគំនិតខាងលើរបស់មេដឹកនាំខ្មែរ ក្នុងសម័យសេដ្ឋកិច្ចទីផ្សារសេរី និងយុគសម័យនៃព្យុះសម្ភារៈនិយម។

មកដល់ចុងឆ្នាំ១៩៨៩-១៩៩០ ការចរចាបានផ្តោតទៅលើការបង្កើត"ឧត្តមក្រុមប្រឹក្សាជាតិ"មួយ (SNC-Supreme National Council)។ តែដំណោះស្រាយនេះ ត្រូវជាប់គាំងអស់ជាច្រើនខែ ដោយសាររូបមន្តសមាសភាពនៃគណៈកម្មាធិការនេះ និងឥស្សរជនដែលត្រូវធ្វើប្រធាន ដែលមិនមានការព្រមព្រៀងនៅឡើយ។ ព្រោះភាគីរដ្ឋកម្ពុជា ដែលគ្រប់គ្រងទឹកដីធំធេងជាគេ ស្នើឱ្យមានវរជន៦រូបពីរដ្ឋកម្ពុជា ដែលដឹកនាំដោយសម្តេច ហ៊ុន សែន និង៦រូបពីភាគីចលនាតស៊ូត្រីភាគីដែលដឹកនាំដោយសម្តេច ន.សីហនុ។ ប៉ុន្តែ ដោយសារមានជំនួបកំពូលជាសម្ងាត់នៅឆេងទូ (Chengdu)ប្រទេសចិន រវាងមន្ត្រីជាន់ខ្ពស់ចិន និងវៀតណាម នៅចុងខែសីហាឆ្នាំ១៩៨៩ ភាគីចិនស្នើសុំឱ្យវៀតណាមដកកងទ័ព និងមន្ត្រីស៊ីវិលចេញពីកម្ពុជាដោយមានភ្នាក់ងារសហប្រជាជាតិត្រួតពិនិត្យ ហើយចិនធានាចំពោះវៀតណាមវិញថា ត្រូវបង្ខំឱ្យខ្មែរក្រហមយល់ព្រមតាមរូបមន្តឧត្តមក្រុមប្រឹក្សាជាតិ ដែលស្នើដោយរដ្ឋកម្ពុជាវិញ។

មានចំណុចប្រទាញប្រទង់គ្នាដ៏ធំមួយគឺការប្រើពាក្យ"ប្រល័យពូជសាសន៍"។ ភាគីរដ្ឋកម្ពុជាបានទទូចប្រើពាក្យនេះ នៅពេលដែលភាគីរដ្ឋាភិបាលចម្រុះតស៊ូត្រីភាគីបានបដិសេធគំនិតនេះ និងចង់បានថា កិច្ចព្រមព្រៀងត្រូវកំហិតនៅក្នុងភាពជាអព្យាក្រិត្យ និងស្មើភាពគ្នា ៖ "គោលនយោបាយទាំងឡាយ និងការអនុវត្ត ពីអតីតកាល មិនគប្បីអនុញ្ញាតឱ្យវិលត្រឡប់វិញជាដាច់ខាត"។ នៅចុងបំផុត កិច្ចព្រមព្រៀងគ្នាលើបញ្ហានេះបានកើតឡើងនៅកិច្ចប្រជុំនាទីក្រុងប៉ាតាយ៉ា ប្រទេសថៃ ពីថ្ងៃទី២៤-២៦មិថុនា១៩៩០ ដែលនៅពេលនោះ ប៉ុលពត ស្ថិតនៅពីក្រោយឆាកចរចា ព្រោះគាត់ក៏បានធ្វើដំណើរទៅទីនោះដែរ។ ពេលនោះហើយ ដែលតំណាងប្រទេសចិនបានបង្ខំឱ្យប្រតិភូខ្មែរក្រហម ចុះហត្ថលេខាលើកិច្ចព្រមព្រៀង(បើតាមសារណាមិនទាន់បោះពុម្ពផ្សាយរបស់ សួង ស៊ីគឿន)។ ពួកមេដឹកនាំខ្មែរក្រហម បាននាំគ្នាពិចារណា និងសម្រេចចិត្តចុះហត្ថលេខា ៖ ព្រោះពួកគេត្រូវអស់ជម្រើសនៅពេលប្រទេសចិនបង្ខំឱ្យធ្វើដូច្នោះ។ ប៉ុន្តែ ពួកគេយ៉ាងហោចណាស់មានប៉ុលពត និងអ្នកជំនិតនៅជុំវិញខ្លួន បានសម្រេចចិត្តធ្វើតាមខព្រមព្រៀងដែរ។

មកដល់ចុងឆ្នាំ១៩៩០ ប្រទេសសមាជិកអចិន្ត្រៃយ៍ទាំងប្រាំនៃអង្គការសហប្រជាជាតិ (អង់គ្លេស, សហរដ្ឋអាមេរិក, បារាំង, សហភាពសូវៀត, និងចិន) បានសម្រេចថា ត្រូវដកក្រសួងគន្លឹះ៥នៅក្នុងរដ្ឋាភិបាលរដ្ឋកម្ពុជា គឺ

ក្រសួងការបរទេស, ការពារជាតិ, សេដ្ឋកិច្ច, មហាផ្ទៃ និងក្រសួងពត៌មាន ″ដាក់នៅក្រោមការគ្រប់គ្រងដោយផ្ទាល់របស់អ៊ុនតាក់″។[150] គេបានសម្រេចផងដែរថា កងកម្លាំងប្រដាប់អាវុធរបស់ភាគីទាំង៤ គប្បីត្រូវគេដកអាវុធ និងប្រមូលផ្តុំនៅក្នុងទីតាំងកំណត់ ព្រមទាំងត្រូវកាត់បន្ថយ៧០%។

ទីបំផុត ការចរចានៅប៉ារីស ថ្ងៃទី២៣ខែតុលាឆ្នាំ១៩៩១ ដែលគ្រប់សមាសភាពជម្លោះនៅកម្ពុជា, ប្រទេសមហាអំណាចក្នុងតំបន់ និងក្នុងពិភពលោក បានចុះហត្ថលេខាលើ កិច្ចព្រមព្រៀងដំណោះស្រាយនយោបាយនៃបញ្ហាជម្លោះនៅកម្ពុជា (the Accord on a Comprehensive Political Settlement of the Cambodian Conflict)។[151] សាក្សីនៃកិច្ចព្រមព្រៀងនេះ មាន២០ប្រទេស ក្នុងនោះមានប្រទេសអូស្ត្រាលី , ប្រ៊ុយណេដារូសាឡឹម, កម្ពុជា, កាណាដា, សាធារណរដ្ឋប្រជាមានិតចិន, សាធារណរដ្ឋបារាំង, សាធារណរដ្ឋឥណ្ឌា, សាធារណរដ្ឋឥណ្ឌូនេស៊ី, ជប៉ុន, សាធារណរដ្ឋប្រជាមានិតឡាវ, ម៉ាឡេស៊ី, សាធារណរដ្ឋហ្វីលីពីន, សាធារណរដ្ឋសឹង្ហបុរី, រាជាណាចក្រថៃឡង់, សហភាពសាធារណរដ្ឋសង្គមនិយមសូវៀត, រាជាណាចក្រអង់គ្លេស និងអៀរឡង់ខាងជើង, សហរដ្ឋអាមេរិក, សាធារណរដ្ឋសង្គមនិយមវៀតណាម និងសាធារណរដ្ឋសហព័ន្ធសង្គមនិយមយូហ្គោស្លាវី។ ដើម្បីជាសក្ខីកម្ម បណ្តាតំណាងបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះបញ្ចប់ទៅ គេបានទុកជាប្រាំច្បាប់ជា ភាសាចិន, អង់គ្លេស, បារាំង ខ្មែរ និងរុស្ស៊ី ដោយច្បាប់ជាភាសានីមួយៗមានតំលៃដូចគ្នា។ ច្បាប់ដើមនៃកិច្ចព្រមព្រៀងបញ្ចប់នេះត្រូវតម្កល់ទុកនៅរដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង និងសាធារណរដ្ឋឥណ្ឌូនេស៊ី។[152]

### 3. ការអនុវត្តន៍កិច្ចព្រមព្រៀងសន្តិភាព

នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ១៩៩១ ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ បានបង្កើតគណៈកម្មការមួយដែលហៅថា គណៈបេសកកម្មនាំមុខសហប្រជាជាតិនៅកម្ពុជា(យូណាមិច- UNAMIC) ហើយជាងពីរសប្តាហ៍ក្រោយថ្ងៃកិច្ចព្រមព្រៀងប៉ារីស បុគ្គលិកដំបូងនៃអង្គការ UNAMIC បានមកដល់ភ្នំពេញនៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៩១។ ចំណែកសភាជាតិរដ្ឋកម្ពុជា នៅចុងខែធ្នូឆ្នាំនោះ បានលុបចោលមាត្រាដែលចែងអំពីបក្សតែមួយប៉ុណ្ណោះដែលត្រូវគ្រប់គ្រងអំណាចរដ្ឋ។ ចំណែក ឧត្តមក្រុមប្រឹក្សាជាតិ (SNC) បានដាក់តាំងសេនាធិការដ្ឋានរបស់ខ្លួនជាលើកដំបូងនៅភ្នំពេញ ក្នុងវិមានរដ្ឋាភិបាល ជាប់មាត់ទន្លេបាសាក់ ក្បែរវត្តភ្នំ កាលពីថ្ងៃទី១៦ មករា១៩៩២។ បណ្តាសមាគម និងអង្គការក្រៅរដ្ឋាភិបាលទាំងអស់ ដែលចង់ដំណើរការសកម្មភាពរបស់ខ្លួន គេត្រូវតែទៅចុះឈ្មោះ សុំការអនុញ្ញាតពី SNCនេះឯង។

ប៉ុន្មានថ្ងៃក្រោយមកលោក ធន់ សារ៉ាយ និងលោកខៃ មធុរី បែរជាចង់ស្ថិតនៅឆ្ងាយពីនយោបាយគណបក្សជាង ដើម្បីកុំឱ្យជួបកំហុសច្រំដែល ដែលនាំឱ្យជាប់គុកនយោបាយទាំងឈឺចាប់ក្នុងចិត្តអស់ជាច្រើនខែដូចពេលមុន។ ពួកគាត់បានរៀបចំបង្កើតអង្គការសិទ្ធិមនុស្សដំបូងគេ នៅកម្ពុជា ដែលមានឈ្មោះថា សមាគមសិទ្ធិមនុស្សកម្ពុជា ហៅកាត់ថា អង្គការ″អាដហុក″(ADHOC-L'Association des Droits de l'Homme Cambodgienne) ។

ជាងមួយសប្តាហ៍ក្រោយមក នៅថ្ងៃទី២៧មករា១៩៩២ លោក អ៊ឹង ផន និងលោក នូ សាំងខន បានស្នើសុំក្រុមប្រឹក្សារដ្ឋមន្ត្រីចុះឈ្មោះគណបក្សសង្គមប្រជាធិបតេយ្យសេរី (Social Democratic Liberal Party) របស់ពួកគេ។ នៅ

---

[150] *Ibid.*, p. 343.

[151] *Ibid.*, p. 344.

[152] កិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយរួមនៃជម្លោះកម្ពុជា ២៣ តុលា ១៩៩១ , អ៊ុន តាក់ ,ទំ ព័រ ៣

ថ្ងៃបន្ទាប់ អ៊ួង ផន បានទទួលលិខិតអនុញ្ញាតជាផ្លូវការ។ ប៉ុន្តែនៅវេលារសៀលថ្ងៃនោះ គាត់ត្រូវក្រុមជនប្រដាប់អាវុធ ៦-៧នាក់ជិះម៉ូតូតាមបាញ់ នៅតាមផ្លូវម៉ុកុក្បាលថ្នល់ក្រុងភ្នំពេញ។ ក្បាលគ្រាប់កាំភ្លើងមួយគ្រាប់បានបុកទម្លុះខ្នង ហើយមួយគ្រាប់ទៀតបៀមនៅក្នុងករបស់គាត់ ប៉ុន្តែគាត់នៅតែមានសេចក្តីក្លាហានគ្រប់គ្រាន់ បើកឡានមកដល់ពេទ្យកាល់ម៉ែតដោយខ្លួនឯងបាន។ បន្តិចក្រោយមកសម្តេច ហ៊ុន សែន ដែលជាអតីតយុទ្ធមិត្តរួមលេណដ្ឋាន និងសមរភូមិរបស់គាត់ បានទៅដល់ពេទ្យដែរ ដើម្បីមើលសភាពគ្រោះថ្នាក់របស់គាត់ ទាំងស្រក់ទឹកភ្នែក។ បើតាមលោក អ៊ីវេន ហ្គោតេស្មេន បានអះអាងថា "គ្មានជញ្ជាំងក្រុងប៉ែរឡាំងត្រូវដួលរលំទេនៅកម្ពុជា។ វាគ្មានវ៉ាក្លាវហាវេល (Vaclav Havel) របស់ប្រទេសឆេកូ ឬ ឡិចវ៉ាឡេសា (Lech Walesa) របស់ប៉ូឡូញដែលធ្លាប់បានឡើងកាន់អំណាចឡើយ។ របបនយោបាយចាស់នៅកម្ពុជា មិនបានដួលរលំឡើយ របបនេះបានធ្វើការចចាហូតដល់នៅអាចមានជីវិតរស់នៅដដែល"។[153] នេះជាប្រវត្តិសាស្ត្រ ដែលបង្ហាញពីភាពឈ្លាសវៃរបស់មេដឹកនាំរដ្ឋកម្ពុជា ក្នុងការការពារ និងថែរក្សាសមិទ្ធិផលបដិវត្តន៍របស់ខ្លួន។

**ប្រសិនបើក្រឡេកមើលសមាសភាពផ្សេងៗគ្នារបស់បុគ្គលិកអ៊ុនតាក់-UNTAC មានជាចម្បងលើ ៖**

**១-ផ្នែកភាពយោធា ៖** ចំនួន១៥៩០០នាក់ ក្រោមកាទទួលខុសត្រូវត្រួតពិនិត្យជំរុំប្រមូលផ្តុំកងទ័ព និងរំសាយ៧០%នៃកងទ័ពទាំងអស់នៅកម្ពុជា។ កងកម្លាំងនេះត្រូវធ្វើសមាហរណកម្មកងកម្លាំងប្រដាប់អាវុធដែលនៅសល់៣០%ទៅក្នុងកងទ័ពជាតិរៀបរយ និងឯកភាពតែមួយ។ គេបានប្រមាណមើលឃើញថា ភាគីទាំង៤ មានយុទ្ធជនសរុបចំនួនប្រហែល២០០០០០នាក់ ដែលបានបង្ហាញទីតាំងរបស់ខ្លួននៅ៦៥០បន្ទាយ ដែលរួមជាមួយកងកម្លាំងឈ្លបភូមិទាំងអស់ចំនួន ២៥០០០០នាក់ទៀត។ រួមទាំងអស់អាចមានដល់ទៅប្រមាណ៥០០០កន្លែងនៅទូទាំងប្រទេស។ ការដាក់បង្ហាញបុគ្គលិកយោធាទាំងអស់នេះ បានចាប់ផ្តើមនៅក្នុងខែមីនាឆ្នាំ១៩៩២ ដោយកងកម្លាំងយោធាឥណ្ឌូនេស៊ីចំនួន២០០នាក់ ហើយគួរតែចំនួននេះកើនឡើងច្រើនបំផុតនៅខែឧសភាឆ្នាំ១៩៩២ ជាមួយនឹងការចាប់ផ្តើមរំសាយកងទ័ព និងប្រមូលផ្តុំតាមបន្ទាយ។ ដំណើរការការងារបែបនេះ ពិតជាមិនបានអនុវត្តទាល់តែសោះជាមួយកងកម្លាំងកម្ពុជាប្រជាធិបតេយ្យ ដោយសារពួកគេបានបដិសេធមិនសហការ ហើយវាបានធ្វើឱ្យភាគីផ្សេងទៀត បដិសេធមិនសហការដែរ។ ដំណើរការនោះ គប្បីត្រូវគេធ្វើបញ្ចប់នៅអំឡុងខែកញ្ញាឆ្នាំ១៩៩២។ ជាការពិត ដំណើរការនេះ មិនបានកើតក្រោមការចាត់ចែងរបស់យុទ្ធជនអ៊ុនតាក់ឡើយ។ ភាគីរដ្ឋកម្ពុជា បានធ្វើការរំសាយដោយខ្លួនឯង នូវកងកម្លាំងស្ម័គ្រចិត្ត និងកងទ័ពប្រយុទ្ធមួយភាគតូច។

**២-ផ្នែករៀបចំការបោះឆ្នោត ៖** ប្រជាជនកម្ពុជាប្រមាណ៤,៧លាននាក់អាចមានសិទ្ធិបោះឆ្នោតបាន។ មានអ្នកស្ម័គ្រចិត្តសហប្រជាជាតិចំនួន៤០០នាក់ ត្រូវបានដាក់ពង្រាយនៅតាមមណ្ឌលរៀបចំការបោះឆ្នោតថ្នាក់ស្រុកជាង២០០ស្រុក។ ពួកគេបានត្រួតមើលការចុះឈ្មោះរបស់គណបក្សនយោបាយ និងអ្នកបោះឆ្នោត, អប់រំអ្នកបោះឆ្នោត, ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយដោយសមធម៌, ចុះឈ្មោះអ្នកសង្កេតការណ៍បរទេស, ដំណើរការបោះឆ្នោត និងរាប់សន្លឹកឆ្នោត... មានបុគ្គលិកខ្មែរ៦២០០០នាក់បានចូលរួមជួយធ្វើការនេះផងដែរ។ មានការខ្វះខាតធនធានអ្នកបកប្រែ និងបុគ្គលិកដែលមានការបណ្តុះបណ្តាលត្រឹមត្រូវយ៉ាងច្រើន។ ប៉ុន្តែពួកគេបានបំពេញភារកិច្ចយ៉ាងល្អឆើត ហើយដែលនេះជាការងារបានជោគជ័យជាងគេមួយ ក្នុងចំណោមសមាសភាពបានជោគជ័យបំផុតពីរបស់អ៊ុនតាក់។

**៣-ផ្នែករដ្ឋបាលស៊ីវិល ៖** ចំណុចនេះអ៊ុនតាក់បានធ្វើឱ្យមានភាពលំអៀង នៅខណៈពួកគេកំពុងដោះស្រាយបញ្ហាមជ្ឈមណ្ឌលនៃអំណាចនយោបាយ និងការសម្រេចចិត្តខាងនយោបាយនៅក្នុងប្រទេសកម្ពុជា។ "រដ្ឋាភិបាល

---

[153] Evan Gottesman, *op. cit.*, p.348.

ភ្នំពេញបានបដិសេធយ៉ាងស្វិតស្វាញរាល់ការទាមទារដកអំណាចក្នុងស្រុករបស់ខ្លួនចេញ"។[154] នៅពេល ហ្គារ៉េត អេវ៉ាន្ស, រដ្ឋមន្ត្រីការបរទេសអូស្ត្រាលី បានបញ្ចេញឱ្យដឹងជាលើកដំបូងនូវគំនិតដាក់រដ្ឋកម្ពុជា នៅក្រោមអាជ្ញាធរសហប្រជាជាតិជាបណ្ដោះអាសន្ន ដែលគំនិតនេះឆ្លើយតបចំពោះក្ដីប្រាថ្នារបស់ប្រជាជនកម្ពុជាភាគច្រើនលើសលុប។ នេះគ្រាន់តែជាគំនិតស្រមើស្រមៃមួយ និងស័ក្ដិសមតែជាមួយកម្ពុជាដ៏ចម្លែក ដែលធ្លាប់ជាប្រទេសក្រោយកុម្មុយនិស្ត និងក្រោយអាណានិគម ច្រើន ឬតិច។ គំនិតនោះគឺត្រូវតែដាក់ជំនួសមន្ត្រីស៊ីវិលជាន់ខ្ពស់កម្ពុជា ប្រមាណ២០០នាក់ នៅថ្នាក់ក្រសួង និងប្រមាណ៣០០នាក់ថ្នាក់អភិបាលខេត្ត និងប្រធានមន្ទីរនៅក្នុងខេត្ត។ លក្ខខណ្ឌនេះគ្មានអ្នកណាម្នាក់បានប៉ុនប៉ងអនុវត្តឡើយ។ រដ្ឋការក្រុងភ្នំពេញបានព្យាយាមយ៉ាងសាមញ្ញ ក្នុងការបង្កើតបរិយាកាសនយោបាយអព្យាក្រឹត្យយ៉ាងគត់មត់ នៅមុនការបោះឆ្នោត។

ការត្រួតពិនិត្យបែបនោះ មិនដែលទាំងបានចាប់ផ្ដើមទៀតផង។ មានអ្នកត្រួតពិនិត្យអន្តរជាតិប្រមាណ ២០០នាក់ប៉ុណ្ណោះ នៅតាមខេត្តនានា, អ្នកបកប្រែភាសាមួយចំនួនតូច ទាំងអ្នកបកប្រែឯកសារ និងអ្នកបកប្រែសម្ដី ដែលមិនអាចមានមធ្យោបាយត្រួតមើលមន្ត្រីរដ្ឋការ ១៤០០០០នាក់ របស់រដ្ឋកម្ពុជាបានឡើយ។ សមាសភាពរដ្ឋបាលស៊ីវិល បានសម្រេចស្នាដៃមួយចំនួនតូច ដូចជាការកែលម្អស្ថានភាពគុក, ការរក្សាលិខិតចំណាយទូទៅ...។ ប៉ុន្តែវានៅតែមិនបានន័យថា មិនបរាជ័យនោះទេ។

**៤-ផ្នែកប៉ូលីសស៊ីវិល ៖** នគរបាលស៊ីវិលកម្ពុជាទាំងអស់ ត្រូវគេសន្មតឱ្យធ្វើការនៅក្រោមអាជ្ញាធរអ៊ុនតាក់។ មានប៉ុស្ដិ៍នគរបាលប្រមាណ១៥០០នៅក្នុងប្រទេស ត្រូវដាក់ឱ្យមានបុគ្គលិកប៉ូលីសសហប្រជាជាតិចំនួន២នាក់ សម្រាប់ប៉ុស្ដិ៍នីមួយៗ។ នេះមានន័យថា អ្នកត្រួតពិនិត្យជាប៉ូលីសប្រហែល៣០០០នាក់ត្រូវគេដាក់ឱ្យប្រតិបត្តិការ។ តាមពិតទៅ "ការដើរតួនាទីរបស់ប៉ូលីសស៊ីវិល ប្រហែលជាការបរាជ័យខ្លាំងជាងគេ នៃប្រតិបត្តិការរបស់អ៊ុនតាក់"។[155] មានបុគ្គលិកអ៊ុនតាក់ខ្លះ មានគោលការណ៍សីលធម៌ខ្សោយ និងប្រព្រឹត្តិអំពើពុករលួយដោយខ្លួនឯង។ ច្បាប់ និងសណ្ដាប់ធ្នាប់ បានធ្លាក់ចុះនៅក្រោមសម័យអ៊ុនតាក់ ហើយពួកចោរប្លន់កើតមានកាន់តែច្រើន។ ទោះបីជាយ៉ាងណាក៏ដោយ ក៏នៅអំឡុងពេលធ្វើយុទ្ធនាការឃោសនា និងបោះឆ្នោត ស្ថានភាពទូទៅមានលក្ខណៈកាន់តែស្ងប់ស្ងាត់ល្អឡើង។

**៥-ផ្នែកសិទ្ធិមនុស្ស ៖** ផ្នែកនេះស្ថិតនៅក្រោមការទទួលខុសត្រូវរបស់លោក ដេនីស ម៉ាក់ណាមារ៉ា(Dennis MacNamara)ដែលជាមេធាវីជនជាតិនូវែលហ្សេឡង់។ វាក្លាយជាកិច្ចប្រតិបត្តិការដោយគ្មានអ្នកហៅឱ្យជួយនៅក្នុងប្រវត្តិសាស្ត្ររបស់សហប្រជាជាតិ។ ផ្នែកនេះគេធ្វើបានជោគជ័យដ៏ត្រចះត្រចង់ ដោយបង្កើតបានស្នាដៃជាច្រើន និងបានទុកដាក់ឱ្យមានអ្នកតំណាងជាអចិន្ត្រៃយ៍ និងមានការិយាល័យរបស់គេមួយនៅភ្នំពេញ។ បន្ទាប់ពីអ្នកទី១មក គឺលោកចៅក្រម Michael Kirby នៃប្រទេសអូស្ត្រាលី ត្រូវបានតែងតាំងនៅខែវិច្ឆិកាឆ្នាំ១៩៩៣។ មុនពេលអ៊ុនតាក់អវត្តមានទាំងស្រុងពីកម្ពុជា មានតែទីស្នាក់ការអង្គការសិទ្ធិមនុស្សថ្មីមួយ ឈ្មោះអាដហុក ដែលដំណើរការនៅឯវត្តមានរចនាសម្ព័ន្ធរបស់ស្ថាប័ន។

កិច្ចការផ្នែកនេះមានការអប់រំសិទ្ធិមនុស្ស, លើកទឹកចិត្តផ្នែកវិជ្ជាជីវៈស្របច្បាប់ឱ្យកើតមានឡើងវិញ, ដោះលែងអ្នកទោសនយោបាយទាំងអស់ ប្រសិនបើនៅមានសល់, បញ្ចប់ការប្រើប្រាស់ច្រវ៉ាក់ខ្នោះឃ្នាងនៅក្នុងពន្ធនាគារ

---

[154] MacAlister Brown and Joseph J. Zasloff, 1998, *Cambodia Confounds the Peacemakers, 1979-1998,* Cornell University Press, Ithaca & London, p. 101.

[155] Ibid, p. 110.

របស់រដ្ឋកម្ពុជា, ការអនុម័តច្បាប់ព្រហ្មទណ្ឌអន្តរកាលថ្មីមួយ។ នៅក្នុងខែសីហា១៩៩២, មានអ្នកទោសនយោបាយ ២៥៨នាក់ត្រូវបានដោះលែងឱ្យមានសេរីភាពវិញ។ គណៈកម្មការនេះបានទទួលពាក្យបណ្ដឹងស្ដីពីអំពើរំលោភសិទ្ធិមនុស្សនៅភ្នំពេញ និងនៅតាមខេត្តនានា។ សំខាន់ជាងគេគណៈកម្មការនេះដោះបានដោះស្រាយបញ្ហាឃាតកម្មនយោបាយ ដែលបានវាយប្រហារលើក្រុមអ្នកនយោបាយបដិបក្សជាមួយគណបក្សប្រជាជនដែលកំពុងមានអំណាចគ្រប់គ្រង។ ក្រុមនេះបានព្យាយាមចាប់ផ្ដើមអំពាវនាវឱ្យមានតុលាការយុត្តិធម៌កម្ពុជាថ្នាក់ជាតិឡើង។ គេបានធ្វើអ្វីៗជាច្រើន ដើម្បីកំណត់អត្តសញ្ញាណ និងលើកសំណើទាក់ទងនឹងបញ្ហាជាច្រើនដែលកើតពីសង្គមមិនប្រើច្បាប់ជាមូលដ្ឋាន ដែលអ្នកមានអំណាចទើបមានសិទ្ធិសព្វបែបយ៉ាង ហើយអ្នកទន់ខ្សោយវិញជាអ្នកនៅក្រោមគេ គ្មានសិទ្ធិអ្វីទាំងអស់។

៦-គណៈកម្មការធ្វើមាតុភូមិនិវត្តន៍ ៖ កិច្ចការនេះធ្វើឱ្យសម្រេចដោយការិយាល័យនៃឧត្តមស្នងការដើម្បីអ្នកភៀសខ្លួនរបស់អង្គការសហប្រជាជាតិ ( UNHCR- the United Nations High Commisioner for Refuges ) ។ មានប្រជាជនកម្ពុជា៣៥០០០០នាក់ ត្រូវបានធ្វើមាតុភូមិនិវត្តន៍យ៉ាងសុខសាន្ត ហើយពួកគេភាគច្រើនត្រូវប្រឈមមុខនឹងការលំបាកមួយចំនួន រួមទាំងការត្រឡប់ទៅរកដីធ្លីរបស់ខ្លួនវិញ ប្រសិនបើគេធ្លាប់ជាកសិករ។ បន្ទាប់មកជាទ្រឹស្ដីពួកគេត្រូវទទួលដីធ្លីចំនួន២ហិចតា ដែលជាគោលការណ៍មិនអាចធ្វើទៅបានឡើយ។ ពួកគេភាគច្រើនច្រើនបានទៅនៅក្នុងតំបន់ទីក្រុង ហើយបន្តិចម្ដងៗបានព្យាយាមកសាងជីវភាពរស់នៅរបស់ខ្លួនទាំងត្រដាបត្រដួស បើទុកជាពួកគេបានទទួលប្រាក់ឧបត្ថម្ភតិចតួចពីអាជ្ញាធរអ៊ុនតាក់( ៥០ដុល្លាម្នាក់សម្រាប់មនុស្សពេញវ័យ និង២៥ដុល្លាម្នាក់សម្រាប់កុមារ) ដែលគេអាចចាយបានតែមួយភ្លែតប៉ុណ្ណោះ។ ជាធម្មតាពួកគេមិនបានទទួលការស្វាគមន៍ពីសង្គមក្នុងស្រុក ដោយសារពួកគេបានចាកចោលស្រុក ហើយការសិក្សា និងសញ្ញាបត្រទាបៗរបស់ខ្លួននៅក្នុងជុំរុំប្រទេសថៃ ត្រូវបានគេទទួលស្គាល់ដោយរបបក្រោយសម័យកាលអ៊ុនតាក់។

**៧-ផ្នែកស្តារនីតិសម្បទា និងការកសាងឡើងវិញ ៖** ការប្រជុំប្រទេសសន្យាផ្ដល់ជំនួយដល់កម្ពុជាជាលើកដំបូង បានធ្វើឡើងនៅទីក្រុងតូក្យូប្រទេសជប៉ុន នៅថ្ងៃទី២២ខែមិថុនាឆ្នាំ១៩៩២។ ប្រជាជាតិចំនួន៣៣ប្រទេសបានសន្យាធ្វើជំនួយនូវទឹកប្រាក់សរុបចំនួន ៨៨០លានដុល្លា ដោយទីដៅត្រូវដាក់ទុនលើមានលោកអគ្គលេខាធិការអង្គការសហប្រជាជាតិជាអ្នកសម្រេច។ នោះគឺសម្រាប់ការអភិវឌ្ឍន៍ជនបទ, ជំនួយដល់ការតាំងទីលំនៅថ្មីរបស់ជនភៀសខ្លួន និងចំពោះថវិកាប្រទេសកម្ពុជាដោយផ្ទាល់តែម្ដង។ ការចំណាយមែនទែនមានលក្ខណៈយឺតយ៉ាវមិនទាន់សភាពការណ៍។ នៅអំឡុងពេល១០ខែមុនពេលបោះឆ្នោត គេបានចំណាយអស់១០០លានដុល្លា សម្រាប់ការធ្វើមាតុភូមិនិវត្តន៍ជនភៀសខ្លួន, ការជួសជុលផ្លូវ និងស្ពាននានា, ការបោសសម្អាតមីន, ការជីកអណ្ដូងទឹក...។ វត្តមាននៃការចំណាយយ៉ាងខ្ពស់របស់បុគ្គលិកអាជ្ញាធរអ៊ុនតាក់ បានត្របាញ់សេដ្ឋកិច្ចឆ្ពោះទៅរកភាពអភិវឌ្ឍន៍លើសលប់លើវិស័យឧស្សាហកម្មសេវាកម្ម ដូចជា សណ្ឋាគារ និងភោជនីយដ្ឋាន, ដោយមិននិយាយអំពីពេស្យាចារ។ ការនាំចេញឈើមូល និងត្បូងពេជ្របានក្លាយជាប្រភពចំណូលចម្បងរបស់ពួកខ្មែរក្រហម។

**៨-ផ្នែកពត៌មាន និងអប់រំ ៖** "ការបំពេញភារកិច្ចដ៏គួរឱ្យភ្ញាក់ផ្អើលបំផុតរបស់អាជ្ញាធរអ៊ុនតាក់គឺការតម្រូវឱ្យចុះឈ្មោះដោយផ្នែកពត៌មាន និងអប់រំ"។[156] ពួកគេបានផ្ដល់នូវការអប់រំជនស៊ីវិលយ៉ាងច្រើន អំពីការបោះឆ្នោត និងសិទ្ធិមនុស្សក្រោមការដឹកនាំរបស់លោក ទីម៉ូធី ខារនី (Timothy Carney) ដែលជាយុទ្ធជនជើងចាស់ម្នាក់នៃទីភ្នាក់ងារសេវាកម្មបរទេសរបស់អាមេរិក។ ជនជាតិអាមេរិកម្នាក់ឈ្មោះ ស្ទីវហិដ័រ(Steve Heder) ជាអ្នកនិយាយ

[156] MacAlister Brown and Joseph J. Zasloff, *op. cit.*, p. 127.

ភាសាខ្មែរម្នាក់ទៀត ដែលពីដំបូងឡើយធ្វើការជាមួយទីភ្នាក់ងារលើកលែងទោសអន្តរជាតិ។ គាត់បានបង្កើតវិទ្យុអ៊ុនតាក់នៅក្នុងខែមេសាឆ្នាំ១៩៩៣ ដែលអាចផ្សាយដំណឹងទៅដល់ប្រជាជនខ្មែរទាំងអស់។ កិច្ចការផ្នែកនេះ ច្បាស់ជាត្រូវគេធ្វើជាមួយភ្នាក់ងាររៀបចំការបោះឆ្នោត ហើយវាជាកិច្ចការ ដែលគ្មានគុណសម្បត្តិថា បានទទួលជោគជ័យខ្លាំងជាងគេរបស់អ៊ុនតាក់នោះដែរ។ វាបានរីកចម្រើនរហូតដល់ផ្សាយបាន១៥ម៉ោងក្នុងមួយថ្ងៃនៅក្នុងខែមេសាឆ្នាំ១៩៩៣។ វាជាកិច្ចការស្នូល ដែលបានក្រាលផ្លូវសម្រាប់ការបោះឆ្នោតតាមឆន្ទៈរបស់ខ្លួន និងធានាចំពោះអ្នកបោះឆ្នោតថា ជម្រើសរបស់ពួកគេគឺជាកិច្ចការសម្ងាត់ ដែលគ្មានអ្នកណាដឹងក្រៅពីខ្លួនឯង។ លោក ហិដ័រ អាចត្រួតពិនិត្យលើមតិសាធារណស្តីពីការបោះឆ្នោត ដើម្បីដឹងអំពីអ្វីដែលអ្នកស្រុកកំពុងគិតចំពោះការណែនាំតាមរយៈវិទ្យុអ៊ុនតាក់ផងដែរ។

ការខិតខំប្រឹងប្រែងដ៏អស្ចារ្យនោះ មានសារៈសំខាន់ណាស់ដែរ ក្នុងដំណាក់កាលដើមដំបូងនៃការអភិវឌ្ឍន៍ទស្សនីយភាពសម្រាប់គ្រប់មធ្យោបាយនៃប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជាសម័យក្រោយអ៊ុនតាក់ និងបានបណ្តុះបណ្តាលអ្នកយកពត៌មានអាជីពបានជាច្រើននាក់ ដោយពិភពទាំងពីរ គឺទាំងពិភពនិយាយភាសាបារាំង និងទាំងពិភពនិយាយភាសាអង់គ្លេស។ ជាងនេះទៅទៀត វប្បធម៌ផ្ញើបទចម្រៀងតាមវិទ្យុ និងទូរទស្សន៍ ឬតាមប្រភេទការផ្សាយផ្សេងទៀត ទៅកាន់ញាតិមិត្ត និងមិត្តភ័ក្តិខ្លួន បានចាប់កំណើតនៅកម្ពុជាពេលមានវិទ្យុអ៊ុនតាក់នោះឯង។

ការបោះឆ្នោតជាសកលនៅកម្ពុជា ជាលើកដំបូងក្រោមការរៀបចំរបស់បុគ្គលិកសហប្រជាជាតិហៅកាត់ អ៊ុនតាក់ UNTAC បានប្រព្រឹត្តិទៅនៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៩៣ ក្រោមបរិយាកាសស្ងប់ស្ងាត់ និងរីករាយអបអរសាទរ។ ប្រជាពលរដ្ឋខ្មែរ ប្រមាណ៩០%នៃអ្នកបានចុះឈ្មោះបោះឆ្នោត បានចេញទៅបោះឆ្នោតជ្រើសរើសគណបក្ស ដែលខ្លួនពេញចិត្តតាមឆន្ទៈរបស់ខ្លួនដោយសេរី និងសម្ងាត់។ ជាលទ្ធផល គណបក្សដៃគូប្រឆាំងជាមួយរបបរដ្ឋកម្ពុជាបានឈ្នះ៦២%នៃសំលេងឆ្នោតសរុប ប៉ុន្តែពួកគេមិនអាចប្រមូលចូលគ្នាបានឡើយ។ ចំណែកគណបក្សប្រជាជនកម្ពុជា បានឈ្នះក្នុងសំលេង៣៨%។ លទ្ធផលឆ្នោតនេះ នាំឱ្យហ្វុនស៊ិនប៉ិចទទួលបាន៥៨អាសនៈ, គណបក្សប្រជាជនកម្ពុជាទទួលបាន៥១អាសនៈ, គណបក្សប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនា ទទួលបាន១០ អាសនៈ និងគណបក្សម៉ូលីណាកា និងអ្នកតស៊ូខ្មែរ ទទួលបាន១អាសនៈ នៅក្នុងសភាជាតិ ដោយរូបមន្តនៃការចែកអាសនៈពេលនោះធ្វើតាមចំនួនសមាមាត្រច្រើន-តិចនៃសំលេងឆ្នោតក្នុងមណ្ឌលខេត្តនីមួយៗ ខុសគ្នាពីរូបមន្តនៅអាណត្តិទី២។

ការបរាជ័យលើការអនុវត្តត្រង់ចំណុចខ្លះនៃកិច្ចព្រមព្រៀង ដោយសារភាគីកាន់អំណាចរដ្ឋកម្ពុជាមិនបានផ្ទេរឱ្យអ៊ុនតាក់តាមការចង្អុលក្នុងកិច្ចព្រមព្រៀងនោះ គ្មានអ្វីជាបញ្ហាធ្ងន់ធ្ងរឡើយ។ ហើយអ៊ុនតាក់ អាចបរាជ័យទាំងស្រុង មិនបានចូលមកកម្ពុជាផង ប្រសិនបើភាគីរដ្ឋកម្ពុជាគ្មានសុច្ឆន្ទៈចង់បានសន្តិភាព ការបង្រួបបង្រួមជាតិ ការស្រុះស្រួលជាតិជានាជាមួយគ្នានោះទេ។ ផ្ទុយទៅវិញ រដ្ឋកម្ពុជាបានយល់ព្រមសហការជាមួយអ៊ុនតាក់យ៉ាងអត់ធ្មត់ ខុសគ្នាស្រឡះពីឥរិយាបថរបស់ភាគីខ្មែរក្រហម។

## 4. ការបង្កើតរដ្ឋាភិបាលចម្រុះក្រោយការបោះឆ្នោតឆ្នាំ១៩៩៣

លទ្ធផលឆ្នោតខាងលើនេះ ត្រូវបដិសេធចោលដោយគណបក្សប្រជាជនកម្ពុជា ដែលកំពុងកាន់អំណាច។ លោក ស៊ិន សុង ដែលជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងព្រះអង្គម្ចាស់ នរោត្តម ចក្រពង្ស ដែលជាឧបនាយករដ្ឋមន្ត្រីរបស់រដ្ឋកម្ពុជា បានធ្វើអប្បគមន៍ផ្តាច់ខេត្តភាគខាងកើតទន្លេមេគង្គ។ ទតឃើញសភាពការណ៍បែបនេះ សម្តេច នរោត្តម សីហនុ បានប្រញាប់ប្រញាល់បើកការចរចា ដើម្បីបែងចែកអំណាចក្នុងចំណោមគណបក្សដែលទទួលបានអាសនៈក្នុងសភាជាតិ។ ក្រោយពីដោះស្រាយបញ្ហាបានភ្លាមសម្តេច ន. សីហនុបានប្រញាប់ប្រកាសបញ្ចប់ភារកិច្ចនៃ

បេសកកម្មរបស់អ៊ុនតាក់នៅកម្ពុជា និងធ្វើស័ង្កកថាផ្សាយតាមវិទ្យុជាតិ ក្នុងអត្ថន័យដ៏គួរឱ្យជនរួមជាតិទាំងអស់ភ្ញាក់ផ្អើលជាខ្លាំងថា ដរាបណាព្រះអង្គនៅមានព្រះជន្ម ព្រះអង្គមិនអនុញ្ញាតឱ្យបរទេសណាមួយ មានអំណាចគ្រប់គ្រងលើមាតុភូមិកម្ពុជាជាទីស្នេហាបំផុតនៃយើង បានឡើយ។

គណបក្សហ៊្វុនស៊ិនប៉ិចដែលឈ្នះឆ្នោតដោយសារប្រជាប្រិយភាពរបស់សម្តេចឪ ន.សីហនុ បានយល់ព្រមបែងចែកអំណាចរដ្ឋាភិបាលពាក់កណ្តាលជាមួយគណបក្សប្រជាជនកម្ពុជា។ ហេតុនេះហើយ បានជាគេឃើញនៅអាណត្តិទី១នោះ រដ្ឋាភិបាលមាន សហនាយករដ្ឋមន្ត្រី គឺសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិជានាយករដ្ឋមន្ត្រីទី១ និងសម្តេច ហ៊ុន សែន ជានាយករដ្ឋមន្ត្រីទី២ ដែលទាំងពីររូបមានបុព្វសិទ្ធិអំណាចស្មើគ្នា។ ចំណែកក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃ ក៏មានសហរដ្ឋមន្ត្រីដែរ លើកលែងក្រសួងក្រៅពីនេះ ដែលមានតែរដ្ឋមន្ត្រីមួយប៉ុណ្ណោះ ចម្រុះគ្នាជាមួយរដ្ឋលេខាធិការមកពីគណបក្សដៃគូ។ ប៉ុន្តែ ទោះបីជាយ៉ាងណា ក៏ការប្រកួតប្រជែងគ្នាដើម្បីសាងស្នាដៃនៅតាមក្រសួងនីមួយៗ បានបង្កការលំបាកជាច្រើនដល់រដ្ឋបាលទូទៅ ហើយគ្រប់ក្រសួងទាំងអស់មានតែសមាសភាពចេញពីគណបក្សប្រជាជនប៉ុណ្ណោះ ដែលមានប្រៀបខ្លាំង និងអាចធ្វើអ្វីៗឱ្យដំណើរការបាន។

រដ្ឋសភាអាណត្តិទី១ ដំណាក់កាលដំបូងជាសភាធម្មនុញ្ញ បានរួបរួមគ្នាបោះឆ្នោតទុកជាមោឃភាពនៃការសម្រេចដកសម្តេច នរោត្តម សីហនុពីព្រះប្រមុខរដ្ឋសង្គមរាស្ត្រនិយម និងសាលក្រមកាត់ទោសប្រហារជីវិតព្រះអង្គដោយសភាជាតិឆ្នាំ១៩៧០ និងតុលាការ របស់លន់ នល់។ បន្ទាប់មក គេបានតាក់តែងរដ្ឋធម្មនុញ្ញឡើង, ទន្ទឹមនោះប្រមុខដឹកនាំគណបក្សប្រជាជនកម្ពុជា បានសំណូមពរឱ្យសម្តេច នរោត្តម សីហនុ ឡើងគ្រងរាជ្យជាព្រះមហាក្សត្រឡើងវិញ។ ដូច្នេះហើយទើប នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ពេលប្រកាសឱ្យមានបញ្ញត្តិនៃរដ្ឋធម្មនុញ្ញ, ប្រទេសកម្ពុជាបានក្លាយជា"ព្រះរាជាណាចក្រ"ឡើងវិញ ដោយព្រះរាជាជាព្រះប្រមុខរដ្ឋ មិនកាន់អំណាច។

ក្រោយការបង្កើតរដ្ឋាភិបាលហើយ តាមការសង្កេតរបស់លោក ហង់រី ឡូការដ៍ថា គ្មានមេដឹកនាំបក្សកំពុងកាន់អំណាចរូបណាមួយ យកចិត្តទុកដាក់ចម្បងលើការជំរុញឱ្យមានច្បាប់ប្រឆាំងអំពើពុករលួយ, ការបង្កើតតុលាការសភាធម្មនុញ្ញ, និងវេទិកាសមាជជាតិ ដូចដែលតម្រូវដោយរដ្ឋធម្មនុញ្ញដំបូងឡើយហើយអំណាចតាក់តែងច្បាប់ និងអំណាចយុត្តាធិការ នៅតែស្ថិតក្រោមការគ្រប់គ្រងរបស់សាខាអំណាចប្រតិបត្តិរបស់រដ្ឋាភិបាលដដែល។ ជាឧទាហរណ៍ សមាជិកសភាជាតិមិនអាចផ្តួចផ្តើមគំនិតតាក់តែងច្បាប់បានឡើយ ពួកគេបានត្រឹមតែនាំគ្នាពិភាក្សាយ៉ាងតឹងតែង ឬបដិសេធចោលពង្រាងច្បាប់ទាំងឡាយដែលស្នើឡើងដោយរដ្ឋាភិបាលតែប៉ុណ្ណោះ។ ក្នុងរដ្ឋាភិបាលទី១ គេឃើញមនុស្សលេចធ្លោជាងគេម្នាក់[157] ដែលបានចាប់ផ្តើមប្រយុទ្ធយ៉ាងតឹងតែង និងប្រថុយប្រថានគ្រោះថ្នាក់ប្រឆាំងនឹងនិទណ្ឌភាព, អំពើពុកពុករលួយរត់គេចពន្ធ, ការអនុម័តច្បាប់ដាក់ឱ្យនៅក្រៅច្បាប់នូវភាគីខ្មែរក្រហមដែលមិនបានចូលរួមក្នុងដំណើរសន្តិភាពរបស់អ៊ុនតាក់ និងមានបំណងបញ្ចូលសៅកម្មស៊ីវិលអាជីព ទៅក្នុងមន្ត្រីថ្នាក់ខ្ពស់របស់រាជការ។ តែមិនយូរប៉ុន្មាន គាត់ត្រូវគេដកចេញពីតំណែងក្នុងរាជរដ្ឋាភិបាល និងបណ្តេញចេញពីបក្សហ៊្វុនស៊ិនប៉ិច។

កត្តាទាំងអស់នេះហើយ ដែលនាំឱ្យមានផលវិបាកដល់សង្គម និងរាជរដ្ឋាភិបាលជាប់ឆ្នោតចាប់ពីឆ្នាំ១៩៩៣មក ដូចដែលលោក អេវិន ហ្គោតេសមេន ( ទំ.៣៣៥ ) សរសេរថា "មន្ត្រីរាជការស៊ីវិល នៅតែទទួលបានប្រាក់ខែទាបមិនអាចយកទៅផ្គត់ផ្គង់ជីវភាពខ្លួនឯង និងក្រុមគ្រួសារបាន ទើបត្រូវបង្ខំចិត្តលួចដកទុកក្នុងហោប៉ៅផ្ទាល់ខ្លួននូវទឹក

[157] ក្រោយមកបានបង្កើតគណបក្សជាតិខ្មែរ និងក្រោយពីគណបក្សនេះត្រូវបានទៅក្រុមបំបែកផ្តាច់ខ្លួន ទើបបង្កើតគណបក្សថ្មីមួយទៀតដាក់ឈ្មោះខ្លួនឯងផ្ទាល់តែម្តង ឈ្មោះ គណបក្សសមរង្ស៊ី ដោយលើកគោលការណ៍នយោបាយប្រឆាំងនឹងរដ្ឋាភិបាលហូតដល់សព្វថ្ងៃ។

ប្រាក់បានពី ការផាកពិន័យ, ពន្ធដារ, កម្រៃឈ្នួលការងារ និងជំនូនផ្សេងៗ ដែលពួកគេបង្ខំឱ្យប្រជាពលរដ្ឋបង់។ ទឹកប្រាក់នៅសល់ ជួនកាលត្រូវគេយកទៅជូនរដ្ឋ ឬជូនបក្ស ប៉ុន្តែជាទូទៅគេយកទៅជូនចៅហ្វាយនាយរបស់ខ្លួន។ មន្ត្រីកំពូលៗមានការជាប់ពាក់ព័ន្ធជាមួយអំពើពុករលួយដោយផ្ទាល់ នៅពេលពួកគេចូលរួមធ្វើការដោះស្រាយបញ្ហាជាមួយវិនិយោគិនបរទេស។ ប៉ុន្តែអ្នកដឹកនាំទាំងឡាយជួយជំរុញអំពើពុករលួយនៅថ្នាក់ក្រោមផងដែរ ដោយសារការបន្តឱ្យប្រព័ន្ធប្រាក់ខែនៅយ៉ាងទាប និងដោយសារការបង្កើតបក្សពួកនិយម។ មេដឹកនាំដ៏មានអំណាចមានសុច្ឆន្ទៈតិចតួចក្នុងការដាក់ទោសទណ្ឌដល់អ្នកស្មោះត្រង់របស់ខ្លួន។ ដរាបណាមានការយកលុយទៅជះឱ្យ ពួកមន្ត្រីទាំងឡាយត្រូវធ្វើឱ្យនិទណ្ឌភាព ដោយយកចិត្តទុកដាក់ខ្លាំងចំពោះតែការលួច,ការកំហែងបោកយកប្រាក់ ឬកាន់តែអាក្រក់ជាងនេះទៀត"។

ទោះបីជាយ៉ាងណា ការអះអាងរបស់លោក ហ្គោតេសមេន គ្រាន់តែជាវិបត្តិមួយ ដែលរដ្ឋាភិបាលកំពុងចាត់វិធានការណ៍លុបបំបាត់ចោលដោយសន្សឹមប៉ុណ្ណោះ។ ព្រោះសង្គមខ្មែរ ទើបតែរួចផុតពីការបែកបាក់ ហែកហួរគ្នាកាប់សម្លាប់គ្នា បែរជាមកប្រឈមមុខនឹងទំនើបភាវូបនីយកម្ម និងសម្ភារៈនិយម ធ្វើឱ្យមនុស្សកើតគំនិតលោភលន់ប្រណាំងប្រជែងគ្នាកើតមានឡើង ជាពិសេសរឿងនេះកើតឡើងក្រោមការជួយជំរុញពីបរទេសចាប់ពីសម័យកាលអ៊ុនតាក់ដែរ។ ហើយរដ្ឋាភិបាលកំពុងចាត់វិធានការណ៍ក្តៅគគុក ដើម្បីដោះស្រាយបញ្ហានេះ ដោយថ្នមៗ ជៀសវាងភាពចលាចល ដែលនឹងអាចកើតមានសារជាថ្មី ហើយប្រទេសជាតិនៅតែបន្តបាត់បង់ឱកាសកសាងសេដ្ឋកិច្ចជាបន្តទៅទៀត។ ព្រោះមេរៀនប្រវត្តិសាស្ត្រថ្មីៗកន្លងមកនេះបានបង្រៀនយើងរួចហើយថា របបខ្មែរក្រហមគ្មានការអត់អោនឱ្យកម្មាភិបាល និងប្រជាជនរបស់ខ្លួន ដោយធ្វើទុកបុកម្នេញ និងកាប់សម្លាប់ខ្មែរគ្នាឯង ហេតុនេះហើយទើបនាំឱ្យមានខ្មែររត់ភៀសខ្លួនទៅវៀតណាម ដើម្បីរស់ និងប្រឆាំងរបបឃោរឃៅព្រៃផ្សៃនេះ ដោយសុំជំនួយកងទ័ពវៀតណាមទៀតផង។ ដូច្នេះ បញ្ហានេះ ជារឿងរ៉ាវប្រកបដោយគ្រោះថ្នាក់ចំពោះសន្តិសុខប្រទេស ប្រសិនបើរដ្ឋាភិបាលដោះស្រាយមិនបានល្អ។ ហើយកម្ពុជានៅត្រូវការពេលវេលាដ៏យូរអង្វែង ដើម្បីពង្រឹងការអប់រំ និងពង្រីកការយល់ដឹងរបស់ប្រជាពលរដ្ឋឱ្យបានកាន់តែច្រើន និងទូលំទូលាយថែមទៀត ទើបអាចរួមគ្នាកំចាត់អំពើពុករលួយដ៏រាលដាលនេះបាន។[158]

ម្យ៉ាងទៀត បើគេសង្កេតមើលស្ថានភាពលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្សនៅកម្ពុជា មានលក្ខណៈល្អប្រសើរជាងមុនច្រើន និងគ្រាន់បើជាងនៅប្រទេសដទៃនៅអាស៊ីអាគ្នេយ៍ទៀតផង ដោយសារកេរមរតករបស់អ៊ុនតាក់ ទាំងការបញ្ចេញមតិ, ការសម្តែងឆន្ទៈតាមរយៈបាតុកម្ម, គណបក្សនយោបាយច្រើន, ការបោះឆ្នោតជ្រើសរើសមេដឹកនាំខ្លួនតាមឆន្ទៈ និងការអនុញ្ញាតឱ្យមានប្រព័ន្ធផ្សព្វផ្សាយប្រឆាំងរដ្ឋាភិបាលជារៀងរាល់ថ្ងៃ។ ដោយសារមានប្រាក់ជំនួយបរទេស និងជំនួយឥណទានពីធនាគារអន្តរជាតិ និងសហគមន៍ប្រទេសសន្យាផ្តល់ជំនួយដល់កម្ពុជាផង កម្ពុជាមានការរីកចម្រើនយ៉ាងឆាប់រហ័សក្នុងយុគសម័យសន្តិភាព៕

[158] ក្រៅពីវិធានការណ៍ច្បាប់, ចំណេះដឹងខាងពុទ្ធចក្រ ក៏អាចចូលរួមចំណែកដោះស្រាយបញ្ហានេះបានដែរ ជាពិសេស ពុទ្ធភាសិតថា ហិរិឱត្តប្បៈ ដែលមានន័យថា 'សេចក្តីខ្មើមបាប និងខ្លាសបាប" គប្បីត្រូវគេនាំយកមកពន្យល់ប្រជាពលរដ្ឋខ្មែរឱ្យបានយល់ដឹងទូលំទូលាយផងដែរ។

# ផ្នែកឧបសម្ព័ន្ធ

# កំណត់សម្គាល់ និងការប្រើប្រាស់នាមព្រះមហាក្សត្រខ្មែរ នាសម័យបុរាណ តាមរយៈសិលាចារឹក[159]

ក្នុងគោលបំណងធ្វើឱ្យឯកភាព ក្នុងការសរសេរនាមទាំងអស់នោះហើយ ទើបយើងលើកបញ្ហានេះ មកនិយាយ ក្រោយពីបានពិនិត្យពិចារណា និងផ្ទៀងផ្ទាត់ជាមួយឯកសារដើមជាច្រើន ដែលទាក់ទិនរួចមក។ ត្បិតនរនាម នីមួយៗ ជាបញ្ហាសំខាន់ វាមិនត្រូវបាននរណាម្នាក់យកមកសរសេរ ម្តងតាមអក្ខរាវិរុទ្ធ ម្តងដូច្នេះ ម្តងដូច្នោះបានទេ កាន់តែ សំខាន់ទៅទៀតនោះ នាមរបស់ព្រះរាជា ដែលជាមេដឹកនាំកំពូលរបស់ជាតិ និងជាអ្នកទទួលខុសត្រូវធំបង្អស់ ចំពោះជោគវាសនាប្រទេស ក៏ដូចជា បណ្តាមន្ត្រីសំខាន់ៗនៃរជ្ជកាលរបស់ទ្រង់ ។

ជាបន្តបន្ទាប់ គឺជាបញ្ជីឈ្មោះព្រះរាជាខ្មែរសម័យមុនអង្គរ និងអង្គរ ដែលត្រូវបានស្រង់ចេញពីសិលាចារឹក សាស្ត្រាភាសាសំស្ក្រឹត និងភាសាខ្មែរ ព្រមទាំងឯកសារស្នាដៃនិពន្ធមួយចំនួនទៀត ។

## 1. អំពីពាក្យ "វម៌្ម" varmma និង "វម៌្ម ទេវ" varmmadeva

នៅពេល ណានរនាមមួយបញ្ចប់ដោយពាក្យ"--វម៌្ម" សម្គាល់ថា "ជានាមព្រះមហាក្សត្រនៅសម័យមុនអង្គរ"។ ចំណែកនរនាមណាបញ្ចប់ ដោយពាក្យ "---វម៌្មទេវ ឬ ---វម៌្មទេព" សម្គាល់ថា "ជានាម ព្រះមហាក្សត្រ នៅសម័យអង្គរ" ។

### 1.1. ពាក្យ "វម៌្ម" varmma

បើនៅលើសិលាចារឹក បុព្វបុរសខ្មែរបុរាណសរសេរថា "--វម៌្ម" ហេតុអ្វី-បានជា ជនជាតិខ្មែរសព្វថ្ងៃ ស្គាល់ និងប្រើជា "--វរ្ម័ន varman" ទៅវិញ ?

តាមសម្តេចសង្ឃរាជ ជួន ណាត "វរ្ម័ន" ជាភាសាសំស្ក្រឹត(វម៌្មន) មានន័យថា ក្រោះ ឬ អាវក្រោះ[160] (សម្រាប់ពាក់ការពារដើមទ្រូង ឬ ខ្លួន) ឬ ជាអ្នកការពារ។ វាជានាម ដែលមិនទាន់បំបែក ឬ ជាពាក្យដើម (infinitive)។

---

[159] នេះជាអត្ថបទមួយ ដែលខ្ញុំ (វ៉ង់ សុធារ៉ា) បានសម្តែងជូនសន្និសីទមួយដែលរៀបចំធ្វើដោយវិទ្យាស្ថានភាសាជាតិ នៃ រាជបណ្ឌិតសភា កម្ពុជា កាលពីខែកញ្ញាឆ្នាំ២០០០។ ក្រោយមក ដោយសារមិនឃើញអ្នករៀបចំ សន្និសីទនេះ បោះពុម្ពផ្សាយប្រជុំអត្ថបទនៃសន្និសីទ( the Proceedings of the Conference ) ខ្ញុំបាន សម្រេចចិត្ត យកអត្ថបទនេះទៅចុះផ្សាយនៅក្នុងទស្សនាវដ្តីកម្ពុជសុរិយា, ឆ្នាំ២០០១ លេខ ៣-៤។

[160] វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, ១៩៦៧, វចនានុក្រមខ្មែរ, ភ្នំពេញ បោះពុម្ពលើកទី៥ ទំព័រ១១៩៤។

លោក ឈឹម ក្រសេម ក៏បានបញ្ចេញមតិលើពាក្យ វរ្ម័ន នេះដែរ។ ដោយ លោកបានពន្យល់ថា ពាក្យ"វរម័ន" (វរ្ម័ន) ដែលគេប្រើនាពេលសព្វថ្ងៃ (នៅសម័យ អាណាព្យាបាលបារាំង) ពីដើមខ្មែរយើង សរសេរជា"វម៌្ម" ឬ "ពម៌្ម" បន្ទាប់មកតាម ពង្សាវតារជាន់ក្រោយ(អង្គរ) សរសេរជា "ព៌ា" ឬ "ពាណ៌" ដូចយ៉ាងព្រះនាមស្តេច មួយអង្គថា សុរិយោពាណ៌ ដែលនេះគឺ សុរិយោវម៌្ម ឬ សុរិយោពម៌្ម ។[161]

បើតាមអ្នកស្រីបណ្ឌិត ពៅ សាវរស ថាពាក្យ "វម៌្ម"នេះ អ្នកប្រាជ្ញបារាំងបុរាណ (មាន Louis Finot, G. Cœdès... etc.)[162] ចាប់អារម្មណ៍ ក៏ភ្ជាប់ភ្លាមទៅនឹងអក្សរតាមិល(Tamil) គឺ varman ដាច់ខាត។ ដោយសារ ពួកគាត់គ្មានពេលពិចារណាលើឯកសារដ៏ច្រើនអនេកនោះទេ។ រីឯពាក្យ ដែលខ្មែរបុរាណបានខ្ចី (វម៌្មន)មកប្រើត្រឹមតែ"វម៌្ម" ប៉ុណ្ណោះ ដែលពាក្យ នេះ អាចអានថា ៖ វរ័ ឬ ពរ័ bar, bəər ដូចគ្នានឹងពាក្យ ធម៌ ពណ៌ គភ៌ និង ព្រះនាម សុរិយោពម៌ (មហាក្សត្រខ្មែរនៅដើមសតវត្សរ៍ទី១៧) បើតាមភាសាខ្មែរមានតែប៉ុណ្ណឹង[163]។

ចំណែក ឯក្នុងវចនានុក្រមភាសាសំស្ក្រឹត varman មានន័យថា ស្រោមសំបុត្រ (envelope) ឬ អាវក្រោះការពារ (defensive armour)។ បើតាមឫគ្វេទ ថា varman ជា ក្រោះ(shelter) ការពារ (defense) និង ការថែរក្សាការពារ (protection) ដែលជាញឹកញាប់គេប្រើនៅខាងចុងនាមក្សត្រិយ៍ ឬជាឈ្មោះនៃ រូបមន្តគាំពារ និងអ្នកបួងសួងពិសេស ហើយ varma ជាពាក្យនៅក្នុងសមាសធាតុពាក្យ (in compound for) varman បើជា varmā វិញ សម្គាល់ភេទស្រី ។[164]

តាមការពិត អ្នកប្រាជ្ញខ្មែរបុរាណមានចំណេះដឹងជ្រៅជ្រះ សុខុម លើបញ្ហាភាសាសំស្ក្រឹត ទើបលោកទាំងនោះ អាចនិពន្ធជាអត្ថបទកំណាព្យសំស្ក្រឹតបានយ៉ាងល្អ រហូតធ្វើឱ្យអ្នកប្រាជ្ញសំស្ក្រឹតជនជាតិឥណ្ឌាសព្វថ្ងៃ កមលេស្វរ ភត្តាចារ្យ (K. Bhattacharya) អះអាងថា អត្ថបទទាំងនោះមានអត្ថន័យអត្ថរូប និងអត្ថរស ល្អវិសេស មិនចាញ់ស្នាដៃរបស់អ្នកប្រាជ្ញនៅស្រុក ឥណ្ឌា ដែលជាម្ចាស់ភាសាផ្ទាល់ នាសម័យជាមួយគ្នានោះឡើយ។ ដូចជា អត្ថបទកំណាព្យសំស្ក្រឹតមួយផ្ទាំងដ៏ធំ-វែង ចារឹកនាឆ្នាំ៩៦១ នៅ ប្រាសាទប្រែរូប ជា បទមនោហរៈ ដែលគេ មិនដែលឃើញមានសោះ នៅស្រុកឥណ្ឌា[165] ។

ហេតុនេះ ការខ្ចីពាក្យឥណ្ឌា"វម៌្មន" មកសរសេរជា "វម៌្ម" ដោយមានការ ផ្លាស់ប្តូរវិភត្តិបែបនេះ មិនមែនជាការ"ខុស"នោះទេ ត្បិតសំស្ក្រឹតតែងមានការផ្លាស់ប្តូរវិភត្តិទៅតាមបុរិសៈ និងកាលស្របតាម ក្បួនវេយ្យាករណ៍ជាក់លាក់ ដែលការនេះមិនខុសគ្នាពីក្បួនវេយ្យាករណ៍ភាសាឥណ្ឌូ-អឺរ៉ុបនោះឡើយ ។

បើតាម លោក ព្រហ្មចារីយ៍ សាស្ត្រាចារ្យភាសាសំស្ក្រឹត នៅពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ថា varman ជានាមដើមក្នុងភាសាសំស្ក្រឹត ។ ប្រសិន បើគេយកពាក្យនេះមកប្រើសម្រាប់ហៅឈ្មោះមនុស្ស វាត្រូវតែ មានការ

---

[161] មហាទេពពិទូរ ក្រសេម, ១៩៥៨, សិលាចារឹកនគរវត្ត ពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពលើកទី២ ភ្នំពេញ ទំព័រ ១៣៣-៤ ។

[162] គឺអ្នកស្រាវជ្រាវជាតិបរទេសទាំងអស់ ។

[163] Cf, *Journal Asiatique,* Année 1971, Recherche sur le vocabulaire cambodgien, par POU Saveros, pp. 123-4. លើសពីនេះ គាត់បានពន្យល់ខ្ញុំ តាមរយៈសំបុត្រមួយ ចុះថ្ងៃទី ៣០ កក្កដា ឆ្នាំ ២០០០ ។

[164] See, M. Monier Williams, *A SANSKRIT-ENGLISH DICTIONARY,* New Delhi, 1995, p. 926.

[165] Hema Goonatilake, The discourse stated in the occasion of opening the first Socio-Cultural Research Training Seminar, 13-18 January 1997 at RUPP II (Professor meeting hall).

ផ្លាស់ប្តូរវិភត្តិជាចាំបាច់ ដើម្បីតម្រូវតាមក្បួនវេយ្យាករណ៍ varman ត្រូវក្លាយជា varmma វម៌្ម (ទម្រង់ បុរាណ) ឬ varma វម៌្ម (ទម្រង់ថ្មី) ឬ varmā វម៌្មា (សម្រាប់ហៅ ភេទស្រី)[166] ។

ដូច្នេះ ប្រការដែលខ្មែរសព្វថ្ងៃសរសេរ និងហៅពាក្យ វរ្ម័ន តាមគេ (បារាំង)យ៉ាងនេះ មិនត្រឹមត្រូវទេ ព្រោះ បុព្វបុរសធ្លាប់បានប្រើប្រាស់ពាក្យនេះជាយូរមកហើយថា វម៌្ម ឬ ពម៌ (នៅចុង និងក្រោយសម័យអង្គរ)។ ហេតុនេះ គប្បីអ្នកស្រាវជ្រាវខ្មែរទាំងអស់គ្នា ជួយពិចារណាឡើងវិញ ។

### 1.2. ពាក្យ "វម៌្មទេវ" varmmadeva

ដូចបានបង្ហាញពីខាងលើហើយ ថានាមរបស់ព្រះមហាក្សត្រសម័យអង្គរ តែងតែបញ្ចប់ដោយពាក្យ "ទេវ deva"ទាំងអស់ ។ ប៉ុន្តែ បុព្វអ្នកប្រាជ្ញបារាំងបាន កាត់ពាក្យ "ទេវៈ" នេះចោល ហើយដាក់ត្រឹមតែ ពាក្យ "វរ្ម័ន" នៅខាងចុង ដូចដែលលោកអ្នកឃើញនាពេលបច្ចុប្បន្ន។ ប្រការនេះធ្វើឱ្យអ្នកអាន ឬ អ្នកសិក្សា មួយចំនួនមានការងឿងឆ្ងល់ ឬភ័ន្តច្រឡំ នៅពេលអានផ្ទាំងសិលាចារឹកដើម គេក៏មិនអាចបែងចែកបាន ចំពោះនាមរបស់មន្ត្រីទាំងឡាយ និងរបស់ព្រះរាជា។ ពីព្រោះ តែនៅសម័យអង្គរ រហស្សនាម "វម៌្ម" ត្រូវបានគេបំពាក់ឱ្យដល់មន្ត្រីទាំងឡាយ ឋានៈ ចាប់ពីមេតម្រួតពលថ្នាក់ស្រុកឡើងទៅ ហើយម្យ៉ាងទៀតដោយសារ គេមិនបានយល់ច្បាស់អំពីទ្រឹស្តី និងខ្លឹមសារនៃពីធី "ទេវរាជា" ឬ "កម្រតេងជគត តរាជ" (=ទេពធំជាងគេ ឬទេពរបស់ស្តេច) ដែលបានផ្តើមសម្ភោធ ឡើង ចាប់ពីរាជ្យព្រះបាទជយវម៌្មទី២ ឆ្នាំ៨០២ គ.ស.។

តាមចារឹកស្តុកកក់ធំ បានឱ្យដឹងថា ក្រោយពីផ្លាស់រាជធានីអស់ជាច្រើនដង ប្រយោជន៍បង្កលក្ខណៈងាយស្រួលដល់កិច្ចបង្រួបបង្រួមជាតិ ធ្វើសន្តិភាព និងឯកភាពបូរនីយកម្មនយោបាយ ចុងក្រោយបង្អស់ ព្រះអង្គបានលើករាជធានីទៅតាំងនៅលើមហេន្ទ្របវ៌ត ឬភ្នំគូលេន។ នៅទីនោះព្រះអង្គបាន អញ្ជើញព្រាហ្មណ៍ម្នាក់ ឈ្មោះហិរណ្យទាម ដែលជាអ្នកប្រាជ្ញមានចំណេះវិជ្ជាខ្ពង់ខ្ពស់ខាងមន្តអាគម មកធ្វើពិធីបន្ថែម[167] ហើយបើតាមលោកស្រីបណ្ឌិត ពៅ សាវរស ថា ជា "ពិធីសាសនាដ៏ធំសំបើមមួយ" (ម្ល៉េះ)(ប្រឡេះ?) លើកប្រទេសកម្ពុជា (Kambujadeśa) កុំឱ្យទៅនៅក្រោមអំណាចរបស់ជ្វា និងធ្វើឱ្យមានតែព្រះមហាក្សត្រ(ជយវម៌្មទី២)មួយអង្គប៉ុណ្ណោះ ជា"ស្តេចចក្រពត្តិ" ឬចក្រវតិ៌ន (Cakravartin = Sovereign ruler) ដោយ ព្រាហ្មណ៍នោះ សែកមន្តអាគម គាថាខាងសាសនា (magic-religious) តាម គម្ពីរ វិនាសិខ (Vināśikha) ប្រតិស្ឋាន កម្រតេង ជគត តរាជ (Kamrateṅ jagat ta rāja = the Master of the Universe who is the King[168] or Dieu-Roi[169]) គឺ ទេវរាជា ។ ពីព្រោះ បើតាមភាសាខ្មែរបុរាណ កម្រតេងជគត = អាទិទេព ឬ ទេវ, តរាជ = ដែលជាព្រះមហាក្សត្រ ឬ ព្រះរាជា។ ព្រះរាជាខ្មែរ ចាប់ពីពេលនោះមក ត្រូវមានព្រះនាមបញ្ចប់ដោយពាក្យ"--ទេវ"។ បន្ទាប់មក ព្រាហ្មណ៍ ហិរណ្យទាម និង ព្រះរាជា បានបញ្ញត្តិឱ្យ បច្ឆាជននៃវង្សរបស់ ព្រាហ្មណ៍ សិវកៃវល្យ តែមួយគត់ ជាអ្នកគ្រប់គ្រងថែរក្សា កម្រតេង ជគត តរាជ និងមាននាទី ប្រតិបត្តិពិធីសាសនា តាមធម្មភាព ដែលខ្លួនបាន រៀនចេះពីព្រាហ្មណ៍ ហិរណ្យទាម។ មិនតែប៉ុណ្ណោះ អ្នកនេះឯង ត្រូវបានទទួល ឋានៈជាអគ្គរាជបុរោហិត(អាចារ្យ៍ ប្រធាន ឬ ហោតរតេអគ្រ) របស់ព្រះរាជា ផងដែរ។

---

[166] បទសន្ទនារបស់ខ្ញុំជាមួយលោក ព្រហ្មចារីយ៍ នៅ UNESCO Phnom Penh ព្រឹកថ្ងៃទី ៣១ កក្កដា ២០០០ ។

[167] Adhir Chakravarti បកប្រែច្នៃកពាក្យលើសិលាចារឹក "វិធិលេហ" ជា Supplementary Ceremony ។

[168] Cf, Sdok Kak Thom II: 95-8.

[169] Cf, *APK II:* 198,220.

ចំណែកព្រះរាជា ដែលសោយរាជ្យជាបន្តបន្ទាប់មកក៏យកតម្រាប់តាម មាគ៌ារបស់ព្រះអង្គ រហូតដល់រាជ្យព្រះបាទហស៌វម៌្មទី៣ និង ជយវម៌្មទី៦ ទើប យើងលែងឃើញមាននិយាយដល់ កម្រតេង ជគត តរាជ ហើយរាជ្យបុរោហិត ដែលមាននាទីជា ហោតរតអគ្រ ក៏មិនមែនជាបច្ឆាជនរបស់សិវកៃវល្យដែរ តែជាគ្រួសារមួយនៃ វណ្ណ[170]កម្មាន្តរៈថ្នាក់ទី៣ ដែលមានដើមកំណើតនៅភូមិវ្រះទ្នង(ស្រុកវ្រះទ្នង = ទួលធ្នង់?) ស្រុកសទ្យា(វិសយ សទ្យា)។ បុព្វបុរសនៃសន្តាននោះឈ្មោះ វ្រះកម្រតេងអញវិន្ទុទេវ ជាបុរោហិតនៅ ឯប្រាសាទស្រី ជលាង្គេស្វរៈ (ប្រាសាទ ព្រះធាតុទឹកឆា ស្រុកព្រៃឈរ ខេត្តកំពង់ចាម) និងបងប្អូនប្រុសជាច្រើននាក់ទៀត ជាបុរោហិតនៅ ទីសក្ការ បូជាដទៃ ទៀត តាំងអំពីរាជ្យព្រះបាទជយវម៌្មទី៣។ នៅក្នុងត្រកូលនោះ គ្រប់ជំនាន់មានអ្នកល្បីល្បាញ ជារាជបុរោហិត សំខាន់ៗ សម្រាប់ព្រះរាជា ដែលរហូតដល់ដំណាច់សតវត្សរ៍ទី១១ មាន វាគីស្វរបណ្ឌិត[171] និងទិវាករបណ្ឌិត ដែលជាអ្នកបានដឹកនាំធ្វើពិធីបូជាសំខាន់ៗ នៅក្នុងរាជ្យព្រះបាទ ឧទយាទិត្យវម៌្មទី២, ហស៌វម៌្មទី៣ និងជាពិសេស ជាអ្នកធ្វើពិធីរាជាភិសេកព្រះបាទជយវម៌្មទី៦, ធរណីន្ទ្រវម៌្មទី១ និងសូរ្យវម៌្មទី២ ឱ្យឡើងសោយរាជ្យ។[172]

ទោះជាមានការប្រែប្រួលខ្លះ នៅចុងសតវត្សរ៍ទី១១ យ៉ាងនេះក្តី ក៏នាម របស់ព្រះរាជា ដែលបញ្ចប់ដោយពាក្យ -វម៌្មទេវ មិនបានប្រែប្រួល ឬ ត្រូវគេបោះបង់ចោលដែរ។

នេះជាទឡ្ហីករណ៍មួយ បង្ហាញអំពីមូលហេតុនៃការប្រើពាក្យ "ទេវៈ" របស់ព្រះរាជាខ្មែរនៅសម័យអង្គរ។ ចំណែកបញ្ហាមួយទៀត ដែលគួរលើកយកមកពិចារណាដែរនោះ គឺពាក្យ -វម៌្មទេវ នេះ យើងឃើញមានប្រើតាំង ពីសម័យមុនអង្គរមកម្ល៉េះ គឺប្រហែលជាក្នុងរាជ្យព្រះបាទ ជយវម៌្មទី១ស្ទួន នៅអំឡុងពាក់កណ្តាលទី២ នៃសតវត្សរ៍ទី៨ ដែលសិលាចារឹកពីរជាភាសាសំស្ក្រឹត ស្តីអំពីពត៌មានរបស់ព្រះអង្គ ត្រូវបាន គេបានរកឃើញនៅប្រាសាទព្រះធាតុបាស្រី ក្នុងស្រុកអូរាំងឪ ខេត្តកំពង់ចាម ដែលមានកាលបរិច្ឆេទឆ្នាំ៧៧០គ.ស.[173]។ មួយទៀតនៅល្បើកស្រុត នៅទិសឥសាននៃខេត្តក្រចេះ ចម្ងាយប្រមាណ៤០គីឡូម៉ែត្រ ដែលមានកាលបរិច្ឆេទឆ្នាំ ៧៨១គ.ស. ។

បើតាមចារឹកទាំងពីរនេះ យើងមិនអាចអះអាងថា នាមព្រះអង្គមាន ភ្ជាប់ដោយពាក្យ "ទេវ" នៅខាងចុងនោះទេ។ ប៉ុន្តែដោយ ផ្អែកលើភស្តុតាងនៃសិលាចារឹកពីរទៀត នៅក្នុងអំឡុងសតវត្សរ៍ទី៨នោះដែរ មួយនៅ ព្រៃចារែក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ដែលមានអក្សរតែពីរបន្ទាត់ប៉ុណ្ណោះ ជាភាសាខ្មែរ និង អក្សរខ្មែរសម័យ មុនអង្គរ បានចារឹកនាមព្រះរាជាមួយព្រះអង្គនាម វ្រះកម្រតេងអញគ្រី*ជយវម៌្មទេវ ដែលលោក សឺដេស សន្និដ្ឋានថា ប្រហែលជាព្រះបាទ ជយវម៌្មទី១ស្ទួន ។*[174]

ចារឹកមួយទៀតនោះ Ka 63 ដែលខ្ញុំទើបនឹងរកឃើញកាលពីចុងឆ្នាំ១៩៩៧ នៅលើកំពូលភ្នំពោធិញាន (ភ្នំ ដែលនៅខាងកើត ជាប់នឹងភ្នំបាយ៉ង់កោ) ស្រុកគិរីវង់ ខេត្តតាកែវ ជាភាសាសំស្ក្រឹតលាយខ្មែរ។ អត្ថបទផ្នែកភាសា ខ្មែរមាននាមព្រះរាជាមួយអង្គ គឺ វ្រះកម្រតាងអញ ស្រីជយវម៌្មទេវ ដែលយើងសន្និដ្ឋានថា នោះជានាមរបស់ ព្រះបាទ

---

[170] លោក សឺដេស បកប្រែពាក្យ "វណ៌្ណ-varnánáa" នៅក្នុងសិលាចារឹកថា ជា"ក្រុមសាជីវកម្ម= la corporation".

[171] Cf, Kuk Trapeang Sruk inscrip. K 91d:1-2, *C II:* 130.ទំនងព្រាហ្មណ៍នេះហើយ ដែលជាម្ចាស់សិលាចារឹកប្រាសាទតាកែវ និងជាស្ថាបនិកប្រាសាទឯកភ្នំខេត្តបាត់ដំបង ហើយគាត់ក៏ជាកូនប្រសាររបស់ព្រះបាទសូរ្យវម៌្មទី១ និងអគ្រទេវី វីរលក្ស្មី។

[172] Cf, *Ibid* and Phnom Sandak and Phnom Preah Vihear inscrips. K 194 and K 383 in *APK II:* 245-65.

[173] Cf, K 103N: 2, in *C V:* 33-4.

[174] Cf, K 48 in *C VI:* 27.

ជយវម៌្មទី១ស្ពួន ត្បិតចារឹកនេះមានកាលបរិច្ឆេទ នៅអំឡុងសតវត្សរ៍ទី៨ដែរ[175] តែគួរស្តាយនោះ គឺយើងមិនអាចដឹងឆ្នាំពិតប្រាកដ ព្រោះតែអក្សរខាងដើមដាច់បាត់នៅសល់តែផ្នែកពាក់កណ្តាល។[176]

នេះសឱ្យឃើញថាធម្មភាព"ទេវរាជា"មិនមែនជាលទ្ធិមួយថ្មីស្រឡាងដែលទើបបង្កើតឡើងនៅឆ្នាំ៨០២ គ.ស.ដោយព្រះបាទជយវម៌្មទី២ ឬ ក៏ត្រូវព្រះអង្គនាំយកមកពីស្រុកជ្វា ដូចលោក Boschបាននិយាយថា នៅស្រុក ជ្វា មាន ទេវរាជ ស្រដៀងគ្នានេះដែរ[177] ឬមួយក៏យកតម្រាប់តាមចាម្បនោះទេ។ អាចនិយាយបានថា ព្រលឹងនៃ ទេវរាជ មានការជាប់ទាក់ទងនឹងប្រពៃណី នៃការគោរពបូជាចំពោះអាទិទេព នៅលើកំពូលភ្នំធម្មជាតិ ឬភ្នំសិប្ប និម្មិត ដែលមានតាំងពីយូរយារមកហើយ (អាចដើមគ.ស.សម្រាប់ខ្មែរ=នគរភ្នំ!) សម្រាប់បណ្តារដ្ឋ ដែលទទួល ឥទ្ធិពលសាសនាព្រាហ្មណ៍ លោកសាស្ត្រាចារ្យ R.C. Majumdar ក៏យល់ឃើញយ៉ាងនេះដែរ។[178] ចំណែក ព្រះបាទ ជយវម៌្មទី២ គ្រាន់តែ បានធ្វើឱ្យលទ្ធិ នេះមានលក្ខណៈ កាន់តែច្បាស់ឡើង (Realization)តែប៉ុណ្ណោះ ។[179]

ហេតុដូច្នេះ ការបន្ថែមពាក្យ "ទេវ" បន្ទាប់ពាក្យ "វម៌្ម" បែបនេះ គឺ ជានយោបាយចាំបាច់មួយរបស់ព្រះរាជាក្នុងកំណែទម្រង់របបគ្រប់គ្រង ប្រយោជន៍ ប្រមូលផ្តុំទឹកដី ប្រជារាស្ត្រ ការជឿទុកចិត្ត មហាកម្លាំងសាមគ្គី[180] និងអំណាចរបស់ព្រះអង្គក្នុងកាលៈទេសៈប្រទេសជាតិមានវិបត្តិផ្ទៃក្នុង ដោយការបាក់បែក និងតាំងខ្លួនជាឥស្សរៈរៀងៗខ្លួន នៅសតវត្សរ៍ទី៨។

### 1.3. នាមព្រះមហាក្សត្រហ្វូណាន

ហ៊ុន ទៀន - លីវយី (លោក សឺដេស យល់ថា កៅណ្ឌិន្យ ជាមួយព្រះនាង សោមា ជាបឋមក្សត្រខ្មែរ) Kauṇḍiṇya I (Queen Somā) = Kaundinya I (Queen Somā) (គ.ស. ៥២ ?) មានឯកសារខ្លះសរសេរថា កៅឌិញ្ញ[181] ។

ស្រីមារៈ Śri Māra (គ.ស. ២២០-២២៨)[182]

កៅណ្ឌិន្យទី២ Kauṇḍiṇya II = Kaundinya II (គ.ស. ៤២០) មានឯកសាខ្លះថា កៅឌិញ្ញវរ្ម័ន ។[183]

ស្រីន្ទ្រវម៌្ម [184] Śrīndravarman (គ.ស. ៤៣០-៤៤០)

---

[175] កាលបរិច្ឆេទនោះ យើងអាចអានបានត្រឹមតែ –ឡុត្តសេឈ្លូតសកៈ។ បើតាមរូបរាងអក្សរចារឹក តួលេខនេះ ខ្ញុំគិតថា វាអាចជា – *នវឡុត្តសេឈ្លូតសកៈ គឺ ឆ្នាំ ៦៩០ប្លាយ--ទសវត្សរ៍ឆ្នាំ៦៩០សកៈ ឬ ទសវត្សរ៍ឆ្នាំ៧៧០គ.ស.។*

[176] Ka 63 in the new inventory organized by Dr. Michel Tranet.

[177] *BEFEO*, XXV, p. 391.

[178] Cf, Majumdar, KAMBUJA-DEÇA or An Ancient Hindu Colony in CAMBODIA, Madras 1944, p.77.

[179] សូមមើល, ត្រឹង ងា, ១៩៧៣, *ប្រវត្តិសាស្ត្រខ្មែរ,* ភាគ១ ភ្នំពេញ, ទំព័រ ១៣៧-៨ ។

[180] សូមមើល, លី គឹមឡុង "អ្វីជាកំលាំងនៃសាមគ្គីខ្មែរសម័យអង្គរ?" ក្នុង ទស្សនាវដ្តីមហាវិទ្យាល័យអក្សរសាស្ត្រ-មនុស្សសាស្ត្រ, ឆ្នាំទី២ លេខ៣ ឆ្នាំ១៩៧២ ភ្នំពេញ ទំព័រ ៥០ ។

[181] សូមមើល,របប ប្រវត្តិសាស្ត្រខ្មែរ ទំព័រ ១៧៤។ តាមយោបល់ខ្ញុំ រឿងរ៉ាវសន្មតថា ថា ហ៊ុនទៀន-លីវយី ត្រូវនឹងកៅណ្ឌិន្យ-សោមានេះ ជារឿងមិនពិតឡើយ។ ព្រោះកៅណ្ឌិន្យ-សោមានេះ គួរតែត្រូវនឹងដើមរាជវង្សរបស់ព្រះបាទរុទ្រវម៌្ម គឺជីតាទួតរបស់ព្រះអង្គ នៅហ្វូណន នាសតវត្សរ៍ទី៥ប៉ុណ្ណោះ។

[182] ត្រូវគ្នានឹងឈ្មោះស្តេច *Fan Shih Man*, voir, *SSIAC:* 28 និង សូមមើល ត្រឹង ងា ឯកសារដដែល ទំព័រ ៨៦ ។

[183] សូមមើល, របប ឯកសារដដែល ទំព័រ ១៧៩ ។

[184] មិនមែន ស្រីឥន្ទ្រវម៌្ម នោះទេ។

(កៅណ្ឌិន្យ)ជយវម៌្ម [185] (Kauṇḍiṇya) Jayavarman (គ.ស.៤៧០-៥១៤) ឯកសារសិលាចារឹក មានត្រឹមតែ ពាក្យ ជយវម៌្ម ប៉ុណ្ណោះ ។
គុណវម៌្ម (រជ្ជទាយាទ) Guṇavarman[186] (គ.ស. ៥១៤?)
រុទ្រវម៌្ម Rudravarman (គ.ស. ៥១៤-៥៥០)[187]
តាមឯកសារបណ្ឌិត រស់ ចន្ទ្រាបុត្រ ប្រវត្តិសាស្ត្រខ្មែរ ទំព័រ ១៨១ ថា រុទ្រវរ្ម័ន ។

### 1.4. នាមព្រះមហាក្សត្រចេនឡា សម័យហ្វូណាន[188]

ស្រុតវម៌្ម Srutavarman (គ.ស. ៥០០) (បុត្រាព្រហ្មឫសី កម្ពុ)[189]
ស្រេស្ឋវម៌្ម Śreṣṭhavarmman = Sreshthavarman (គ.ស. ៥៤៥-៥៦០)
ប្ឫថិវិន្ទ្រវម៌្ម Pṛthivindravarman = Prathivindravarman (បិតារបស់ភវវម៌្ម)
វីរវម៌្ម Vīravarman (គ.ស. ៥??--៥៨?)(បិតារបស់ មហេន្ទ្រវម៌្ម)

### 1.5. នាមព្រះមហាក្សត្រសម័យចេនឡា

ភវវម៌្មទី១ Bhavavarman I (គ.ស. ៥៨០-៥៩៨)
មហេន្ទ្រវម៌្ម (ចិត្រសេន) Mahendravarman (Citrasena) (គ.ស.៥៩៨-៦១០)
ឯកសារខ្លះដាក់ថា មហិន្ទ្រវម៌្ម ឯនាមមុនពេលសោយរាជ្យថា ចិត្រសេនា ទៅវិញ ។[190]
ឥសានវម៌្មទី១ Içānavarman I (គ.ស. ៦១០-៦៣៥)
ភវវម៌្មទី២ Bhavavarman II(គ.ស. ៦៣៥-៦៥២)

---

[185] Mahesh Kumar Sharan សរសេរត្រឹមតែ ជយវរ្ម័ន *Jayavarman* ប៉ុណ្ណោះដូចគ្នានឹងសិលាចារឹកប្រាសាទប្រាំល្វែង នៅថាប់ម៉ឺយ ប្រទេសវៀតណាមភាគខាងត្បូង។ បើគាត់អះអាង បែបនេះ ព្រះមហាក្សត្រ ដែលមាននាម ជយវម៌្ម នៅសម័យមុនអង្គរ មានចំនួនដល់ទៅបីអង្គ។ ក៏ប៉ុន្តែ ការដែលដាក់ថែមនាម កៅណ្ឌិន្យ ខាងមុខបែបនេះ ដោយសារផ្អែកលើឯកសារចិនថា ចោយេប៉ា ម៉ោ (=ជយវម៌្ម) មានត្រកូល គាវ ឆេន យូ (=កៅណ្ឌិន្យ)។
[186] តាមសិលាចារឹកប្រាសាទប្រាំល្វែង នៅថាប់ម៉ឺយ ថា ព្រះអង្គជាអនាគតព្រះរាជា ។ បើតាមន័យ ដាច់ៗក្នុងចារឹកត្រង់កន្លែងរលុប ព្រះបិតាព្រះអង្គ(កៅណ្ឌិន្យជយវម៌្ម)ទំនងជាធ្វើសង្គ្រាមជាមួយ ស្តេច វីរវម៌្ម(បិតាមហេន្ទ្រវម៌្មទី១?)(*APK I:* 208-9).
[187] Mahesh Kumar Sharan ជឿថា ព្រះបាទរុទ្រវម៌្ម ដែលប្រាកដនាមលើសិលាចារឹកក្តីអង្គ ដោយសារការនិទានរបស់គ្រូពេទ្យហ្លួង ជយវម៌្មទី១ ឈ្មោះ សីហទត្ត មិនមែនជាព្រះរាជានៃនគរភ្នំ ហេតុនេះហើយ ទើបគាត់ស្រង់នាមស្តេចអង្គនេះដាក់ទៅក្នុងរបាក្សត្រខាង ចេនឡាវិញ (*SSIAC:* 33) ។ បញ្ហានេះ លោក Michael Vickery និយាយបញ្ជាក់ជាច្រើនលើកសារ នៅក្នុងសម្មតិកម្មនៃការរួបរួម គ្នារវាង នគរភ្នំ និង ចេនឡា ដែលជាសាមន្តរដ្ឋមួយ ដោយទាញយកភស្តុតាងនៃ គ្រួសាររបស់ សីហទត្ត ដែលមានបុព្វបុរសជាអ្នកបម្រើស្តេច៥អង្គបន្តបន្ទាប់គ្នា ក្នុងនោះទី១ គឺព្រះបាទរុទ្រវម៌្ម ដែលជាមហាក្សត្រនគរភ្នំទី២ ព្រះបាទភវវម៌្មទី១, ទី៣ ព្រះបាទមហេន្ទ្រវម៌្ម ទី៤ ព្រះបាទឥសានវម៌្មទី១, និងទី៥ព្រះបាទជយវម៌្មទី១ ដែលព្រះមហាក្សត្រ៤អង្គ ចុងក្រោយនេះ ជាស្តេចរដ្ឋចេនឡា ដែលគេថា ជាអ្នក វាយយកអាណាចក្រភ្នំតាំងតែពីពាក់កណ្តាលសតវត្សរ៍ទី៦ គ.ស.។ ដូច្នេះតាមលោក វិកឃើរី, ព្រះបាទ រុទ្រវម៌្ម គឺជាព្រះរាជាសម័យហ្វូណាន។
[188] ដើមសន្តតិវង្សចេនឡា គឺព្រះឥសីកម្ពុ និង មេរា តំណាងសូរ្យវង្ស តាមសិលាចារឹកបក្សីចាំក្រុង សតវត្សរ៍ទី១០។ ក៏ប៉ុន្តែ នាមព្រះរាជា ដែលគេចាត់ទុកជាអ្នកបង្កបង្កើតរដ្ឋចេនឡាដំបូងគេ គឺ ព្រះបាទ ស្រុតវម៌្ម និងបុត្ររបស់ព្រះអង្គ ស្រេស្ឋវម៌្ម ដែល បានបង្កើតរាជធានី ស្រេស្ឋបុរៈ រហូតមកដល់សម័យអង្គរ ឈ្មោះនេះនៅតែឃើញមាន សម្គាល់ជាខេត្តមួយ "ប្រមានឬវិសយ"ស្រេស្ឋបុរៈ។
[189] cf., Prasat Kok Châk inscription K. 958, stanza II. G. Coedès, 1964. *Inscriptions du Cambodge,* vol. VII, EFEO, Paris, p. 144.
[190] សូមមើល, រថប ឯកសារដដែល ទំព័រ ១៨៥ ។

ជយវម៌្មទី១ Jayavarmman I (គ.ស. ៦៥២[191]-៦៨១)
ជយទេវី (មហាក្សត្រិយានី) Jayadevī (Queen) (គ.ស. ៦៨១-៧១៦)[192]

### 1.6. នាមព្រះមហាក្សត្រចេនឡាទឹកលិច

បុស្ករាក្ស[193] Puşkarākşa = Pushkaraksha (គ.ស. ៧១៦-៧៣០)
ឯកសារខ្លះសរសេរថា បុស្សករក្ស៍ បែបនេះ ។
សំភុវម៌្ម Śambhuvarman (គ.ស. ៧៥០)
រាជេន្ទ្រវម៌្មទី១ [194] Rājendravarman (គ.ស. ៧៦០)
ឯកសារខ្លះសរសេរថា រាជឥន្ទ្រវម៌្ម ដោយញែកការន្តសន្ធិនៃពាក្យ សមាស រាជេន្ទ្រ ។
មហីបតិន្ទ្រវម៌្ម (បុត្រារាជេន្ទ្រវម៌្មទី១) Mahīpativarman (គ.ស. ៧៨០?)
ជយវម៌្មទី១ស្ទួន Jajavarman I[bis] (គ.ស. ៧៧០-៧៨១)[195]

### 1.7. នាមព្រះមហាក្សត្រចេនឡាដីគោក

ជយសិង្ហវម៌្ម Jayasińghavarman [K 404, C VII: 73] (គ.ស. ៧--)

# បញ្ជីព្រះនាម និងមរណនាមស្តេចសម័យមុនអង្គរ និងអង្គរ

3

| ល.រ | ព្រះនាម ព្រះបាទ | រជ្ជកាល | ញាតិ ឬ មរណនាម |
|---|---|---|---|
| សម័យហ្វូណាន | | | |
| ១ | ហ៊ុនទៀន-លីវយី | (?៥២----) (អង្គរបុរី?) | (ម្ចាស់ស្រុក+បរទេស) |
| ២ | ហ៊ុនប៉ាន់ហួង | (----១០-) | (កូន) |
| ៣ | (ហ៊ុន)ប៉ាន់ប៉ាន់ | (១------) | (កូនទី២) |
| ៤ | ហ្វាន់ចេម៉ាន់ | (១៩០?----) | (មេទ័ពឡើងជាស្តេច) |
| ៥ | (ហ្វាន់)គីនចេង | (២--?----) | (កូន) |
| ៦ | ហ្វាន់ចាន់(ឆាន/ឆាង?) | (២៣០-៤៥?)ទាក់ទងឥណ្ឌាដំបូង | (ក្មួយ, កូននៃបងប្អូនស្រី) |
| ៧ | ហ្វាន់ឆាង | (២៤៥?) | (ធ្វើគត់ចាន់,សងសឹកឱ្យបង) |
| ៨ | ហ្វាន់ស៊ីយ៉ុន | (២៤៥?-២៨៩--)(រ្យាធបុរៈ?) | (មេទ័ព, ធ្វើគតឆាង) |
| ៩ | ជៀនឈូ ឆានតាន(ចន្ទ័ន) | (--៣៥៧?--) | (ថ្វាយដំរីស្វយដល់ស្តេចចិន) |

[191] សូមជមើល សិលាចារឹកថ្មីមួយ នៅវត្តពោធិវង្សលើ K. 62

[192] Voir, *supra.* p. 3.

[193] អានថា បុស ស្កៈ រ៉ាក់

[194] អានថា រៀច ជេន ទ្រាក់ វ រ្មាក់ គេមិនអាចកែនាមព្រះអង្គ ដោយសរសេរជា រាជឥន្ទ្រវម៌្ម បានទេ

[195] Voir, *supra.* p 9.

| | | | |
|---|---|---|---|
| ១០ | កៅណ្ឌិន្យ | (៤២០----) | (ចិនថាមកពីឥណ្ឌា?) |
| ១១ | ស្រីន្រ្ទវម៌្ម | (--៤៣១-៤-៥-៤៣៨--) | |
| ១២ | (កៅណ្ឌិន្យ)ជយវម៌្ម | (៤៧០-៥១៤) | (បច្ឆាជនរបស់កៅណ្ឌិន្យ) |
| ១៣ | គុណវម៌្ម | (៥១៤?) | (រជ្ជទាយាទ) |
| ១៤ | រុទ្រវម៌្ម | (៥១៤-៥៥០)(វ្យាធបុរៈ-អង្គរបុរី) | (បុត្រាស្នំ) |
| **សម័យចេនឡា** | | | |
| ១៥ | ស្រុតវម៌្ម Srutavarman | (500s?) K.958, 977AD, St. II | (បុត្រាព្រហ្មឫសី កម្ពុ) |
| ១៦ | ស្រេស្ឋវម៌្ម Śreṣṭhavarmman | (៥៤៥-៥៦០?) ស្តេចទី២ នៃវង្សកម្ពុ | (បុត្រាស្រុតវម៌្ម) |
| ១៧ | ប្រថិវីន្រ្ទវម៌្ម | K.978 (Si Tep) បុត្រាស្តេចចក្រពត្តិ | (បិតាភវវម៌្មទី១) |
| ១៨ | វីរវម៌្ម | (K.359, 363, 496)បុត្រាស្តេចសារ៌ភៅម | (បិតាចិត្រសេន) |
| ១៩ | ភវវម៌្មទី១ | (៥៥០-៦០០) | (ចៅមីង) |
| ២០ | មហេន្ទ្រវម៌្ម(ចិត្រសេន) | (៦០០-៦១៦) | (ប្អូនប្រុស, អនុជ) |
| ២១ | ឥសានវម៌្មទី១ | (៦១៦-៦៣៧)(ឥសានបុរៈ) | (បុត្រា) |
| ២២ | ភវវម៌្មទី២ | (៦៣៧-៦៥២)(ភវបុរៈ) | ភវបុរៈ |
| ២៣ | ជយវម៌្មទី១ | (៦៥២-៦៨១)(បុរន្ទរបុរៈ) | សិវបុរៈ |
| ២៤ | ជយទេវី | (៦៨១?-៧១៧) | (បុត្រី) |
| ២៥ | បុស្ករាក្ស | (៧១៦-៧៣០?) (សម្ភុបុរៈ) | ឥន្រ្ទលោក? |
| ២៦ | សំភុវម៌្ម | (--៧៥០--) | |
| ២៧ | រាជេន្រ្ទវម៌្មទី១ | (--៧៦០--) | |
| ២៨ | មហីបតិវម៌្ម | (--៧៧០--) | |
| ២៩ | នឫបេន្ទ្រទេវី | (៧---) (សម្ភុបុរៈ) | (បុត្រីឥន្រ្ទលោក) |
| ៣០ | ជយេន្រ្ទ-ភា(ទេវី) | (៧៨--) (សម្ភុបុរៈ) | (ចៅឥន្រ្ទលោក) |
| ៣១ | ជ្យេស្ឋារ្យា(ទេវី) | (--៨០៣----)(សម្ភុបុរៈ) | (ចៅទួតឥន្រ្ទលោក) |
| ៣២ | ទេវាទិត្យ | (៧១--)(ភវបុរៈ-សំបូរព្រៃគុហ៍) | |
| ៣៣ | ឥន្រ្ទាទិត្យ | (៧---)(ភវបុរៈ-សំបូរព្រៃគុហ៍) | |
| ៣៤ | ធម៌ាទិត្យ | (៧---)(ភវបុរៈ-សំបូរព្រៃគុហ៍) | |
| ៣៥ | ពាលាទិត្យ | (៧---)(អនិន្ទិតបុរៈ) | |
| ៣៦ | នឫបាទិត្យ | (៧---)(អនិន្ទិតបុរៈ) | |
| ៣៧ | ជយវម៌្ម(ទេវ)ទី១ស្ងួន[196] | (៧៦៣-៧៧០) វ្យាធបុរៈ-ធាន្យបុរៈ?បាយ៉ង់ | |
| ៣៨ | ជយវម៌្ម(ទេវ)ទី១ស្ងួន? | (៧៧០-៧៨១) ឥន្រ្ទបុរៈ-សម្ភុបុរៈ | |
| **សម័យអង្គរ** | | | |
| ៣៩ | ជយវម៌្ម(ទេវ)ទី២ | (៧៨១-៨០២-៣៤)(ហរិហរាល័យ) | បរមេស្វរៈ(ប្រា.ព្រះគោ) |
| ៤០ | ជយវម៌្ម(ទេវ)ទី៣ | (៨៣៤-៨៧៧)(---រលួស) | វិស្ណុលោក |

[196] Cf., K. 109, 770 AD; K. 135, 781 AD; K. 1236, 685çaka = 763 AD; Jayavarma(deva) inscriptions

| | | | |
|---|---|---|---|
| ៤១ | ឥន្ទ្រវម៌្ម(ទេវ)ទី១ | (៨៧៧-៨៨៩) | ឦស្វរលោក |
| ៤២ | យសោវម៌្ម(ទេវ)ទី១ | (៨៨៩-៨៩៩)(យសោធរបុរៈ-អង្គរ១) | បរមសិវលោក |
| ៤៣ | ហស៌វម៌្ម(ទេវ)ទី១ | (៨៩៩-៩២៥) | រុទ្រលោក |
| ៤៤ | ឥសានវម៌្ម(ទេវ)ទី២ | (៩២៣-៩២៨) | បរមរុទ្រលោក |
| ៤៥ | ជយវម៌្ម(ទេវ)ទី៤[197] | (៩២៥-៩៤១)(ឆោកគរគីរ) | បរមសិវបទ |
| ៤៦ | ហស៌វម៌្ម(ទេវ)ទី២ | (៩៤១-៩៤៤) | ព្រហ្មលោក |
| ៤៧ | រាជេន្ទ្រវម៌្ម(ទេវ)[198] | (៩៤៤-៩៦៨)(យសោធរបុរៈ) | សិវលោក |
| ៤៨ | ជយវម៌្ម(ទេវ)ទី៥ | (៩៦៨-១០០១) | បរមវីរលោក |
| ៤៩ | ឧទយាទិត្យវម៌្មទី១ | (១០០១-១០០២) | (គ្មានមរណនាម) |
| ៥០ | ជ័យវីរវម៌្ម(ទេវ) | (១០០២-១០១០)(ជយេន្ទ្រនគរី) | (គ្មានមរណនាម) |
| ៥១ | សូរ្យវម៌្ម(ទេវ)ទី១ | (១០០២-១០៥០) | បរមនិវ៌ានបទ |
| ៥២ | ឧទយាទិត្យវម៌្ម(ទេវ)ទី២ | (១០៥០-១០៦៨)(អង្គរទី២) | (គ្មានមរណនាម) |
| ៥៣ | ហស៌វម៌្ម(ទេវ)ទី៣ | (១០៦៦-១០៨៥) | សទាសិវបទ |
| ៥៤ | នឫបតិន្ទ្រវម៌្ម | (១០៨៥-១១--) | (មិនច្បាស់) |
| ៥៥ | ជយវម៌្ម(ទេវ)ទី៦ | (១០៧៦-១១០៧)(មហីធរបុរៈ) | បរមកៃវល្យបទ |
| ៥៦ | ធរណីន្ទ្រវម៌្ម(ទេវ)ទី១ | (១១០៧-១១១៣)(យសោធរបុរៈ) | បរមនិស្កលបទ |
| ៥៧ | សូរ្យវម៌្ម(ទេវ)ទី២ | (១១១៣–១១៥០) | បរមវិស្ណុលោក |
| ៥៨ | ធរណីន្ទ្រវម៌្ម(ទេវ)ទី២ | (១១៥១-១១៦០) | មហាបរមនិវ៌ានបទ |
| ៥៩ | យសោវម៌្ម(ទេវ)ទី២ | (១១៦០-១១៦៥?) | (គ្មានមរណនាម) |
| ៦០ | ត្រីភូវនាទិត្យវម៌្ម(ទេវ) | (?១១៦៥-១១៧៧) | (គ្មានមរណនាម) |
| ៦១ | ជយវម៌្ម(ទេវ)ទី៧ | (១១៨១-១២២០) (អង្គរ៣) | មហាបរមសៅគតបទ |
| ៦២ | ឥន្ទ្រវម៌្ម(ទេវ)ទី២ | (១២២០-១២៤៣) | (គ្មានមរណនាម) |
| ៦៣ | ជយវម៌្ម(ទេវ)ទី៨ | (១២៤៣-១២៩៥) | បរមេស្វរបទ |
| ៦៤ | ស្រីន្ទ្រវម៌្ម(ទេវ) | (១២៩៥-១៣០៧) | (ស្រីន្ទ្រសុគត) |
| ៦៥ | ស្រីន្ទ្រជយវម៌្ម(ទេវ) | (១៣០៧-១៣២៧) | (គ្មានមរណនាម) |
| ៦៦ | ជយវម៌្ម(ទេវ)ទី៩ | (១៣២៧-១៣៥៨?)[199] | ជយវម៌្មបរមេស្វរៈ |

[197] តាមសិលាចារឹកប្រាសាទនាងខ្មៅ K.35 ព្រះអង្គសោយរាជ្យនៅឆ្នាំ៩២៨។ Cf.,CII, 33.

[198] តាមសិលាចារឹកប្រាសាទប្រាំ ដែលចារនៅលើស៊ុមទ្វារនៃតួប៉មខាងជើង ក្នុងតំបន់កោះកេរ្តិ៍ អតីតខេត្តព្រំទេព ថា ព្រះអង្គជាបងប្រុសរបស់ព្រះបាទ ហស៌វម៌្មទេវទី២ និងជារាជបុត្រាព្រះបាទ ជយវម៌្មទេវទី៤។ Cf., *BEFEO,* XIII (6): 16-26; K.70A:7, CII, 60.

[199] Cf., Mahasil Viravong, (1964), *History of Laos,* USA. ថាស្ថាបនិករដ្ឋឡាវឡានសាង នាមហ្វាងុម អះអាងថា បានទទួលការគាំទ្រពីព្រះបាទជយវម៌្មទី៩ ជាបិតាក្មេក ដោយព្រះអង្គបានឱ្យខ្ចីកងទ័ពខ្មែរ ទៅវាយបង្រួបបង្រួមឡាវបានជាស្ថាពរនៅវាងឆ្នាំ១៣៥៣។ នៅឆ្នាំបន្តបន្ទាប់ ព្រះអង្គបានចាត់បញ្ជូនបេសកជនផ្សាយពុទ្ធសាសនា និងព្រះពុទ្ធរូបធ្វើពីមាសហៅព្រះបង ទៅឡានសាងតាមសំណូមរបស់ហ្វាងុម និងបុត្រីព្រះអង្គ ដែលជាអគ្គមហេសីរបស់ហ្វាងុម។ ដូច្នេះ រឿងរ៉ាវសៀម-អយុធ្យាវាយកាន់កាប់ទីក្រុងអង្គរនៅអំឡុង១៣៥៣-១៣៥៧ មិនមែនជាការពិតនោះទេ។ ព្រោះ ខ្មែរពេលនោះកំពុងមានសន្តិភាព និងស្ថេរភាពនយោបាយ ដែលអាចជួយប្រទេសឡាវបានទៀតផង។

ចំពោះព្រះមហាក្សត្រ ដែលគ្មានមរណៈនាមទាំងនោះ ប្រហែលព្រោះតែម្យ៉ាង គឺខ្វះសិលាចារឹកដែលនិយាយពីព្រះអង្គ។ ករណីដូចជា ព្រះបាទ ឧទយាទិត្យវម៌្មទី១, ជ័យវីរវម៌្ម, យសោវម៌្មទី២,ត្រិភុវនាទិត្យវម៌្ម និងស្តេចបន្ទាប់ពីព្រះបាទជយវម៌្មទី៧។ យ៉ាងណាមិញ ព្រះបាទឧទយាទិត្យវម៌្មទី២ សោយរាជ្យអស់រយៈពេល១៦ឆ្នាំ កសាងប្រាសាទសំខាន់ៗជាច្រើន និងមានសិលាចារឹកជាច្រើនក្នុងរាជ្យព្រះអង្គតែពុំឃើញមានមរណនាម។ ដូច្នេះ ពុំមានហេតុផលច្បាស់លាស់ទេ ចំពោះកង្វះមរណនាមព្រះមហាក្សត្របែបនេះ។

## សេចក្តីសន្និដ្ឋាន

ការស្គាល់បែបនោះ វាក៏នឹងនាំទៅឃើញឈ្មោះពិតប្រាកដរបស់បុគ្គលម្នាក់ៗ។ និយាយដោយឡែក វានាំឱ្យស្គាល់ព្រះរាជាថា តើនាមរបស់ព្រះអង្គត្រូវបានគេសរសេរ ដោយអក្ខរាវិរុទ្ធបែបណា ។

ការស្រាវជ្រាវវិទ្យាសាស្ត្រផ្នែកអ្វីក៏ដោយ រមែងទាមទារសុក្រឹតភាព ជាក់លាក់ ត្រឹមត្រូវ ហេតុនេះ នាមរបស់ព្រះមហាក្សត្រមិនគប្បីអ្នកស្រាវជ្រាវសរសេរ ផ្លាស់ប្តូរតម្រូវតាមសំនៀងអាន ឬមួយ សរសេរព្រាវៗតាម transliteration ឬ ឯកសារបរទេសនោះទេ។ បើយើងត្រួតពិនិត្យលើឯកសារដើម ឃើញថា ខ្មែរបុរាណ ក៏មិនបានចារឹកនាមរបស់ ព្រះរាជា ដោយអក្ខរាវិរុទ្ធខុសៗពីគ្នាដែរ។ ក្នុងករណីស្មេរបារម្ភ ឬ ខ្លាចអ្នកអាន ៗមិនត្រូវ នោះគួរតែធ្វើសញ្ញាសម្គាល់ ដើម្បីបញ្ជូនអ្នកអានឱ្យទៅមើលរបៀបអាននៅកន្លែងបន្ទាប់ ឬ នៅជើងទំព័រ ឬ កន្លែងណាមួយផ្សេងទៀត តាមតែ លទ្ធភាពស្មេរ។ ម្យ៉ាងទៀត បើនាមដើមសរសេរជាភាសាសំស្ក្រឹត ទោះបីស្មេរយកពាក្យ ភាសាបាលី ដែលមានន័យដូចគ្នា មកជំនួស ក៏មិនត្រឹមត្រូវដែរ។

ចំពោះពាក្យ "--វម៌្ម "នេះ គប្បីជនជាតិខ្មែរទម្លាប់ប្រើឡើងវិញ ដើម្បីជំនួសពាក្យ "--វរ្ម័ន" ប្រសិនបើខ្មែរចង់លើកតម្កើងខ្លួន ជាអ្នកគោរព និងឱ្យតម្លៃលើកេរ្តិ៍ស្នាដៃនៃបុព្វបុរស។ រីឯពាក្យ "ទេវ" ដែលមានប្រើនៅសម័យអង្គរមិនគួរយកមកដាក់នោះទេ។ ប្រសិនបើដាក់ វានឹងនាំឱ្យមានការរុះរើរបាក្សត្រទាំងអស់ ដែលគេបានដាក់លេខរៀងរួច ហើយនោះ និងធ្វើឱ្យប្រវត្តិសាស្ត្រជាតិខ្មែរកាន់តែស្មុគស្មាញថែមទៀត។ ការនេះលោកអ្នកប្រាជ្ញបារាំងធំៗ ធ្លាប់ជួបប្រទះ ម្តងហើយ នៅពេលគេរកឃើញ នាមព្រះរាជាជយវម៌្ម ដែលសោយរាជ្យនៅពាក់កណ្តាលទី២សតវត្សរ៍ទី៨នៃគ.ស.។

ដូច្នេះ នាមព្រះមហាក្សត្រទាំងឡាយ និងរជ្ជកាលរបស់ព្រះអង្គ ដែលបានរាយជូនខាងលើ អាចចាត់ទុកជាឯកសារ គោលសម្រាប់វិសោធនកម្មរបស់ក្រុមការងារជំនាញ នៃរាជបណ្ឌិតសភាកម្ពុជា ក្នុងការសម្រេចធ្វើឯកភាវូបនីយកម្មខាងបច្ចេកពាក្យ និងស័ព្ទប្រវត្តិវិទ្យានៅថ្ងៃអនាគត។

# អក្សរកាត់ដែលប្រើក្នុងអត្ថបទ

| | | |
|---|---|---|
| **APK I** | : | Articles sur le pays Khmer, tome I (I-II) |
| **C I** | : | Inscriptions du Cambodge, volume I (I-VIII) |
| **Sdok Kak Thom** | : | Sdok Kak Thom Inscription, part I-II |
| **SSIAC** | : | Studies in Sanskrit Inscriptions of Ancient Cambodia, by Mahesh Kumar Sharan |
| **រចប ប្រវត្តិសាស្ត្រខ្មែរ** | : | **រស់ ចន្ទ្រាបុត្រ** ប្រវត្តិសាស្ត្រខ្មែរ ភាគទី១ (ភាគរឿងព្រេងនិទាន និង តាមរយៈសិលាចារឹក) |

# នាមព្រះមហាក្សត្រសម័យអង្គរ និងស្នាព្រះហស្ថ

១- ជយវម៌្មទី២ (៧៨១-៧៩០-៨០២-៨៣៤) ជាក្សត្រមួយអង្គ ដែលចុះមកបង្កើតរាជាណាចក្រគ្រាដំបូង

ចំណោមសាច់រឿងផ្ទុយគ្នា តាមការស្រាវជ្រាវរបស់លោក សឺដេស និងក្លូដ (Jacques) យើងអាចទទួលយកបានថា ៖

**(១)**- ព្រះអង្គជាអ្នកដឹកនាំ យ៉ាងហោចណាស់ចាប់ពីទសវត្សរ៍ឆ្នាំ៧៨០ ព្រះអង្គគ្រងរាជ្យនៅសម្ភុបុរៈ (ក្រចេះ ) តំបន់ ដែលមានរាជបុត្រីដឹកនាំផ្ទាល់នៅ ទីនោះ ដែល លោក ម៉ៃឃើល វីកឃើរី យល់ថា ព្រះអង្គបានរៀបអភិសេកជាមួយ ក្សត្រីមួយអង្គនៅសម្ភុបុរៈ ។[200]

**(២)**- ឆ្នាំ ៧៩០ ព្រះអង្គ និង បុត្រាព្រះអង្គនាម **ឥន្ទ្រាយុធ** បានច្បាំងប្រឆាំងចាម្ប ដោយទទួលបានជោគជ័យ (ពេលនោះ មជ្ឈមណ្ឌលកណ្ដាលរបស់ចាម្ប នៅបាណ្ឌុរង្គ ឬជិតកម្ពុជាភាគខាងត្បូង។

**(៣)**- ក្នុងអំឡុងឆ្នាំ៧៨០-៨០២ ទ្រង់កាន់កាប់តំបន់ជាច្រើននៅភាគខាងជើងកម្ពុជា រួមទាំងខេត្តនៅបាត់ដំបង និងសៀមរាបផង។

**(៤)**-ព្រះអង្គធ្វើសកម្មភាពពីត្បូងទៅជើង ហើយព្រះអង្គតាំងមណ្ឌលសំខាន់នៅ **ហរិហរាល័យ** (រលួស) គ្រប់គ្រងទីក្រុង៤ គឺ៖

១-**ឥន្ទ្របុរៈ** " ប្រហែលបន្ទាយព្រៃនគរ " ខាងកើតកំពង់ចាម

២-**ហរិហរាល័យ**«ដែលសព្វថ្ងៃនៅរលួស មានចម្ងាយ១៨ គ.ម ភាគអាគ្នេយ៍អង្គរ សៀមរាប»

៣-**អមរេន្ទ្របុរៈ** ដែលលោក Cœdès គិតថា ស្ថិតនៅភាគពាយ័ព្យ (បាត់ដំបង ) ជាតំបន់ទីតាំងមិនច្បាស់ ប៉ុន្តែព្រះអង្គក៏បានទទួលបរាជ័យ ហើយរយៈពេលដ៏ខ្លី ទ្រង់ក៏បោះបង់ទីនោះទៅ ។

៤-**មហេន្ទ្របវ៌ត** « ភ្នំគូលែន » ជាទីកន្លែងដែលព្រះអង្គអភិសេកខ្លួនទ្រង់ជា ចក្រវរតិន, ចក្រវត្តិន ឬ ចក្រពត្តិន

គោរព ៖ ព្រហ្មញ្ញសាសនា

កសាង ៖ ប្រាសាទនៅលើភ្នំមហេន្ទ្រ « ភ្នំគូលែន » ព្រះរាជវាំងមួយនៅបឹងមាលា«៣ គីឡូម៉ែត្រពីភ្នំគូលែន»

២- ជយវម៌្មទី៣ ( ៨៣៤-៨៧៧) Jayavarman III (r.834- d 877 )

- បុត្ររបស់ ជយវម៌្ម ទី២
- រាជធានីហរិហរាល័យ "រលួស" តំបន់ប្រាសាទលលៃ
- មានថ្វីដៃខាងប្រមាញ់ ជាពិសេស ទាក់ដំរី
- កសាងប្រាសាទខ្លះទៀតនៅក្នុងតំបន់អង្គរ
- គោរព ៖ព្រហ្មញ្ញសាសនា

៣- ឥន្ទ្រវម៌្មទី១ ( ៨៧៧-៨៨៩ ) Indravarman (r.877- d.889)

[200] ការអះអាងនេះទំនងលែងមានសុពលភាពទៀតហើយ ព្រោះសិលាចារឹកកំពូលតានន្ទ-បាយ៉ង់ នៅឆ្នាំ៧៦៣ បង្ហាញស្ដេចមួយអង្គនាម គឺជយវម៌្មទេវ ដដែល។ វានាំឱ្យការស្មានរបស់លោក សឺដេស ថាមាន "ជយវម៌្មទី១ស្ទួន" នៅតែមានសុពលភាព។

- ជីដូនមួយ (មាតានិងមាតាបងប្អូនបង្កើត)របស់ ៖ ជយវម៌្ម ទី៣
- កសាង ៖ បារាយណ៍ឥន្រ្ទតដាក "៨៧៧ " បណ្តោយ ៨គ.ម, ទទឹង ២២០០.ម, ប្រាសាទព្រះគោ (Preah Ko) ឆ្នាំ៨៧៩ , ប្រាសាទបាគង (Bakong temple) នៅឆ្នាំ ៨៨១។

៤- យសោវម៌្មទី១ (៨៨៩-៨៩៩) Yaśovarman I (r.889/890- d.910/912)
- បុត្ររបស់ ៖ ឥន្រ្ទវម៌្ម ទី១
- ទ្រង់ផ្លាស់រាជធានី ពីរលួស (Rolous)ទៅកាន់តំបន់អង្គរ ហើយកសាងប្រាសាទបាខែង(Bakheng) និង បារាយណ៍យសោធរតដាក ដែលបារាំងហៅថា បារាយណ៍ខាងកើត (Eastern Baray )
- គោរព ៖ ព្រហ្មញ្ញសាសនា
- រាជធានី ៖ យសោធរបុរៈ មាន ទេវស្ថាន ភ្នំបាខែង[201] ធ្វើជាផ្ចិតនៃ ទីក្រុងអង្គរទី១
- ពង្រីកទឹកដី ៖ ខាងជើងដល់ចិន ខាងកើតដល់តុងកឹង ខាងលិច ដល់ទន្លេ ឥរ៉ាវតី « ភូមា »
- កសាង ៖ ប្រាសាទលលៃ (the temple Lolei ) ឆ្នាំ៨៩៣, ប្រាសាទនៅលើភ្នំបាខែង នៅមុនឆ្នាំ ៩០០, ប្រាសាទភ្នំក្រោម, ភ្នំបូក, ព្រះវិហារ បារាយណ៍ខាងកើត

៥- ហស៌វម៌្មទី១[202] (៨៩៩-៩២៥) Harshavarman I (r.899/- d.925 ) មានឯកសារខ្លះសរសេរថា ហរស្សវរ្ម័ន (មិនត្រឹមត្រូវទេ)។
- បុត្ររបស់ ៖ យសោវម៌្មទី១
- រាជធានី ៖ យសោធរបុរៈ (Yasodharapura )
- គោរព ៖ ព្រហ្មញ្ញសាសនា
- កសាង ៖ ប្រាសាទបក្សីចាំក្រុង និង ប្រាសាទក្រវ៉ាន់ (៩២១ )

៦- ឥសានវម៌្មទី២ (៩២៥-៩២៨) Iśānavarman II (r.925- 928 )
- រាជធានី ៖ យសោធរបុរៈ
- បុត្ររបស់ ៖ យសោវម៌្មទី ១ ជាអនុជរបស់ ហស៌វម៌្ម ទី១
- គោរព ៖ ព្រហ្មញ្ញសាសានា
- គេពុំបានដឹងថា ព្រះអង្គបានឡើងសោយរាជ្យពីឆ្នាំណាពិតប្រាកដទេ តែព្រះអង្គប្រហែលជាមានជម្លោះនឹង ព្រះបាទ ជយវម៌្មទី៤ ដែលជាគូប្រជែង

៧- ជយវម៌្មទី៤ (៩២៥-៩៤១) Jayavarman IV (r.925-941 )
- រាជធានី ៖ ឆោកគរគីរ "(ឆោកគរគ្យរ) Chok Gargyar (អូរគរគីរ?) សព្វថ្ងៃអ្នកស្រុកហៅ ថា កោះកេរ្តិ៍ (Koh Ker = Glorious Island កោះកិត្តិគុណ)

---

[201] Cf, Ak Puok inscrip. K 1051ដែលបញ្ជាក់ថា នៅក្នុងរាជ្យព្រះបាទ រុទ្រលោក (Rudraloka) គឺព្រះបាទ ហស៌វម៌្មទី១ នៅ ឆ្នាំ ៨២១នៃមហាសករាជ គឺគ.ស. ៨៩៩ មានមន្រ្តីសង្ឃជាន់ខ្ពស់ ម្នាក់ នាម ចន្រ្ទសិខរព្រាហ្មណ៍ (Vraḥ Kamrateṅ Añ Candraśikhara Vraḥhmaṇa) ស្ថាបនា ប្រាសាទឥដ្ឋមួយ ប្រតិស្ឋានអាទិទេពនារាយន (Vraḥ Kamratenæ Añ Nārāyana) និងថ្វាយ និធិជាច្រើន ដល់ប្រាសាទ។ ចារឹកនេះសព្វថ្ងៃរក្សាទុកនៅវត្តសម្តេច? (Vat Samdek) ខេត្ត បាត់ដំបង។

[202] អានថា ហាស់ សាក់ វ៉ាក់ បើសរសេរជា ហរស្សវរ្ម័ន បែបនេះមិនបានទេ ។ សម, រចប ឯកសារដដែល ទំព័រ ២០៤ ។

- ប្អូនថ្លៃ ឬជាក្មួយរបស់ យសោវម៌្មទី១ សោយរាជ្យប្រជែងគ្នាជាមួយព្រះបាទ ឥសានវម៌្មទី២។
- គោរព ៖ ព្រហ្មញ្ញសាសនា
- កសាង ៖ ប្រាសាទជាច្រើន និងបារាយណ៍រហាល់នៅតំបន់កោះកេរ្តិ៍ សព្វថ្ងៃ។ រចនាបថសិល្បៈ និងស្ថាបត្យកម្មនៅទីនោះ មានលក្ខណៈអស្ចារ្យប្រកបដោយការច្នៃប្រឌិត និងទឹកដៃអភិវឌ្ឍន៍យ៉ាងឆើត។

៨- ហស៌វម៌្មទី២ (៩៤១-៩៤៤) Harshavarman II (r.941- 944 )
- បុត្ររបស់ ៖ ជយវម៌្មទី ៤
- រាជធានី ៖ ឆោកគរគី សព្វថ្ងៃហៅថា កោះកេរ្តិ៍
- គោរព ៖ ព្រហ្មញ្ញសាសនា

៩- រាជេន្ទ្រវម៌្ម(ទី២) (៩៤៤-៩៦៨) Rājendravarman II (r.988- d.968) តាមឯកសារបណ្ឌិតរស់ ចន្ត្រាបុត្រ ទំព័រ២០៧ សរសេរថា រាជឥន្ទ្រវរ្ម័ន (មិនត្រឹមត្រូវទេ)។
- រាជធានី ៖ យសោធបុរៈ
- កូនប្រសារ?របស់ ៖ ជយវម៌្មទី ៤
- គោរព ៖ ព្រហ្មញ្ញសាសនា
- កសាងប្រាសាទ បាតជុំ (Prasat Bat Chum) នៅឆ្នាំ៩៤៦, បក្សីចាំក្រុង ឆ្នាំ៩៤៧, មេបុណ្យខាងកើត (East Mebon )ឆ្នាំ៩៥២, ប្រាសាទលាក់នាងនៅឆ្នាំ៩៦០, ប្រែរូប(Pre Rup) ឆ្នាំ៩៦១, បានអនុញ្ញាតឱ្យព្រាហ្មណ៍ យជ្ញវរាហៈ សាងប្រាសាទបន្ទាយស្រី (Banteay Srei ) នៅឆ្នាំ ៩៦៧ និងប្រាសាទភិមានអាកាស (Phimeanakas)។

១០- ជយវម៌្មទី៥ (៩៦៨-១០០១) Jayavarman V (r.968-d.1001)
- រាជធានី យសោធរបុរៈ
- បុត្ររបស់ រាជេន្ទ្រវម៌្ម (ទី២)
- គោរព ៖ ព្រហ្មញ្ញសាសនា
- កសាង ៖ បង្ហើយប្រាសាទបន្ទាយស្រី(ឥស្វរបុរៈ)នៅឆ្នាំ៩៦៧ ដែលឈរកសាងដោយព្រាហ្មណ៍ យជ្ញវរាហៈ Yajñavāraha ជារាជគ្រូ ដើម្បីឧទ្ទិស ចំពោះ ព្រះត្រៃកុវនមហេស្វរ ឬព្រះឥសូរ, បន្តសាងប្រាសាទកែវ ឬតាកែវ ឬ ភ្នំហេមស្រីង្គគិរី ដែលជាផ្ចិតនៃរាជធានីជយេន្ទ្រនគរី។

១១- ឧទយាទិត្យវម៌្មទី១[203] (១០០១-១០០២) Udayādityavarman I (r.1001- 1002) ឯកសារខ្លះសរសេរថា ឧទ័យទិត្តិយវរ្ម័ន ឬឧទ័យវរ្ម័នទី១ (មិនត្រឹម ត្រូវទេ)។
- រាជធានី ៖ យសោធរបុរៈ
- ក្មួយរបស់ ៖ ជយវម៌្ម ទី៥

---

[203] អានថា ឧ ទៃ យា ទិត ត្យាក់ វ ព្មក់ ព្រះអង្គជាឪពុកមាខាងម្ដាយរបស់ព្រះបាទ ជយវម៌្មទី៥ (cf, *SSIAC*, 40) ។ គេមិនអាច កែព្រះនាមនេះទៅជា ឧទ័យទិត្តិយវរ្ម័ន ឬ ឧទ័យវរ្ម័ន បែបនេះបានទេ ។ សម រចប ឯកសារដដែល ទំព័រ ២១១។

- សោយរាជ្យបានប្រមាណ៦ខែ ក៏ត្រូវបាត់ខ្លួន។

១២- ជយវីរវម៌្ម[204] (១០០២-១០១០) Jayavīravarman (1002-1010)
- អ្នកប្រាជ្ញបារាំងម្នាក់ បានសន្និដ្ឋានថា ព្រះអង្គប្រហែលជាបងប្រុសព្រះបាទឧទយាទិត្យវម៌្មទី១
- រាជធានី ៖ យសោធរបុរៈ
- ចម្បាំងផ្ទៃក្នុងតទល់នឹង ព្រះ សូរ្យវម៌្ម ទី១ អស់៩ឆ្នាំ បើតាមសិលាចារឹកទួលតាពេជ នៅកំពង់ធំ។

១៣- សូរ្យវម៌្មទី១[205] (១០០២-១០៥០) Sūryavarman I (r.1002/1010 – 1050)

ទោះបីពាក្យ សូរ្យ (ភាសាសំស្រ្កឹត) និង សុរិយា (ភាសាបាលី) មានន័យ ដូចគ្នា ក៏មិនត្រូវកែនាមដើមនេះទៅជា សុរិយាវរ្ម័ន តាមភាសាបាលីបែបនេះបានដែរ។ ក្នុងរាជ្យស្តេចនេះមានព្រះរាជាមួយអង្គទៀត នាមសូរ្យជយវម៌្ម? ឬ ឥស្វយ៌្យជយវម៌្ម Śūryajayavarman/Iśvaryyajayavarman (គ.ស.១០១២[206] -១០--) ដែលគេឃើញនាមនេះ នៅលើសិលាចារឹកមួយ នៅបុរីរម្យ។
- រាជធានី ៖ យសោធរបុរៈ (ជយេន្ទ្រនគរី)
- ញាតិវង្ស ៖ ព្រះបាទ ឥន្ទ្រវម៌្មទី១, យសោវម៌្មទី១ និងជាអ្នកដណ្តើមរាជ្យសម្បត្តិរបស់ជយវីរវម៌្ម
- គោរព ៖ ព្រហ្មញ្ញសាសនា
- ពង្រឹងអំណាច កូរ៉ាត-អាងទន្លេមេណាម-លាវភាគខាងជើង "លួងផ្រះបាង"
- កសាង ៖ រៀបចំប្លង់អង្គរឡើងវិញ កសាងកំពែងគោបុរៈ, ប្រាសាទព្រះវិហារ នៅភ្នំដងរែក, ប្រាសាទកែវ ឬ តាកែវ, ប្រាសាទភ្នំជីសូរ នៅខេត្តតាកែវ។

១៤- ឧទយាទិត្យវម៌្មទី២ (១០៥០-១០៦៨) Udayātiyavarman II (r.1050- 1068 )

---

[204] តាមចារឹកមួយ ដែលរកឃើញនៅប្រាសាទអំពិល ភូមិពងទឹក ស្រុកថ្មពួក ខេត្តឧត្តមានជ័យ ដោយបណ្ឌិត មីសែល ត្រាណេ និងបាន ចុះលេខ Ka 17 បានអោយដឹងថា នៅមហាសករាជ ៩២៩ ថ្ងៃព្រហស្បតិ ៩រោជខែផល្គុណ ព្រះបាទ ជយវីរវម៌្ម ស្តេចគង់ ប្រថាប់នៅព្រះ ស្រះស្រង់នៃជយេន្ទ្រគិរី ពេលនោះមានមន្ត្រីម្នាក់នាម វិជយេស្វរវម៌្ម ថ្វាយលិខិតមួយដល់ព្រះអង្គ បន្ទាប់មកទ្រង់ក៏បញ្ជាអោយគេចារឹក លិខិតនោះទុក គឺសិលាចារឹកនោះឯង។ ព្រះអង្គត្រូវជាប្អូនប្រុសព្រះបាទ ឧទយាទិត្យវម៌្មទី១ (cf, *Ibid*)។

[205] ច្បាប់ដើមគឺ សូយ៌្យវម៌្ម អាចសរសេរជា សូរ្យវម៌្ម បែបនេះបាន។ ប៉ុន្តែ បណ្ឌិត រស់ ចន្ទ្រាបុត្រ សរសេរថា សុរិយាវរ្ម័ន ទៅវិញ សម រចប ឯកសារដដែល ទំព័រ ២១២, ២២០ ដែលការសរសេរបែបនេះមិនត្រឹមត្រូវទេ។

[206] សិលាចារឹកគោកក្លាង K 1128 (or Ka 59 listed by Michel Tranet) ខេត្តបុរីរម្យ ប្រទេសថៃ ដែលទើបរកឃើញនៅឆ្នាំ ១៩៨៤ អោយដឹងថា នៅមហាសករាជ៩៣៤ គឺគ.ស.១០១២ មានព្រះមហាក្សត្រមួយអង្គ នាមសូយ៌្យជយវម៌្មទេវ ប្រើឲ្យឆ្លាក់? ធ្វើ ..។ ក៏ប៉ុន្តែ បើតាមបណ្ឌិត ពៅ សាវរស អានព្រះនាមព្រះរាជាអង្គនេះថា ឥស្វយ៌្យជយវម៌្ម ទៅវិញ។ ម្យ៉ាងទៀត យើងមិនដឹងថា ព្រះអង្គឡើងសោយរាជ្យពីឆ្នាំណាដល់ឆ្នាំណានោះទេ ប៉ុន្តែ ប្រហែលជា ស្តេចអង្គនេះហើយ ជាដើមវង្សព្រះរាជា នៅមហីធរបុរៈ ដែល អ្នកសោយរាជ្យ ជាបន្តបន្ទាប់មកមាន ជយវម៌្មទី៦ ធរណីន្ទ្រវម៌្មទី១ ជាដើម ។
ម្យ៉ាងទៀតប្រសិនបើ ព្រះបាទ ជយវីរវម៌្ម និងព្រះបាទសូរ្យវម៌្មទី១ ជាព្រះរាជាតែមួយអង្គ ដូចដែលលោក សេដេស តែងតែ ចោទជាសំណួរ និងវិភាគនាពេលកន្លងមក (ពីព្រោះតែ នាម អគ្គមហេសីរបស់ស្តេចទាំងពីរអង្គនេះដូចគ្នា នាមមន្ត្រីជំនិត មួយចំនួន ក៏ ដូចគ្នា) នោះឈ្មោះ សូយ៌្យជយវម៌្ម ឬ ឥស្វយ៌្យជយវម៌្ម ក្រែងជានាមបញ្ចូលគ្នារវាងឈ្មោះទាំងពីរ ឬក៏ជាព្រះរាជាមួយអង្គផ្សេងទៀត?

ឧទយាទិត្យវម៌្មទី២ Udayādityavarman II (គ.ស.១០៥០[207]-១០៦៨)បណ្ឌិត រស់ ចន្ទ្រាបុត្រ ថាឧទ័យវរ្ម័នទី២ ។

- រាជធានី ៖ យសោធរបុរៈ ទីក្រុងអង្គរទី២
- បុត្រារបស់ ៖ សូរ្យវម៌្ម ទី១
- គោរព ៖ ព្រហ្មញ្ញសាសនា

ព្រះអង្គបានកសាងប្រាសាទបាពួន (Baphuon ) នៅឆ្នាំ១០៦០ ធ្វើជាផ្ចិតទីក្រុងថ្មីមួយទៀត ក្រោយពីប្រាសាទតាកែវ ដែលជាផ្ចិតទីក្រុងថ្មីត្រូវសាងមិនសម្រេច ដោយសាររន្ទះបាញ់។ បន្ទាប់មក ស្ថាបនាប្រាសាទមេបុណ្យខាងលិចនៅកណ្តាល បារាយណ៍ទឹកថ្លា ដែលអ្នកប្រាជ្ញបារាំងហៅថា បារាយណ៍ខាងលិច ទំហំបណ្តោយ ៨គ.ម និងទទឹង ២,២គ.ម។

៥- ហស៌វម៌្មទី៣ (១០៦៨-១០៨៦) Harshavarman III (r.1068- 1086)

- បុត្រា ព្រះបាទ សូរ្យវម៌្ម ទី១
- រាជធានី ៖ យសោធរបុរៈ អង្គរទី២
- គោរព ៖ ព្រហ្មញ្ញសាសនា
- សកម្មប្រយុទ្ធក្នុងការធ្វើសង្គ្រាម៖ ចាម្ប(Champa)ឆ្នាំ១០៧៤, ដាយវៀត(Dai-Viet )ឆ្នាំ១០៧៥
- កសាងនឹងជួសជុលឡើងវិញ នៅគ្រប់តំបន់នឹងប្រាសាទទាំងឡាយដែលត្រូវរងការខូចខាត និងធ្វើឱ្យនគរមាន ការអភិវឌ្ឍន៍ឡើងវិញ។
- ព្រះរាជាសោយរាជ្យជាបន្ទាប់នៅរាជធានីអង្គរ ប្រហែលជា មាននាមថា នួបតីន្ទ្រវម៌្ម[208] Nṛpatīndravarman (គ.ស. ១០៨៥-១១១៣)(ដែលគេមិនអាចសរសេរជា នរិបតិន្ទ្រវម៌្ម បានទេ) ។

១៦-ជយវម៌្មទី៦ (១០៨០-១១០៧)[209] Jayavarman VI (r.1080- d.1107 )

- បុត្រ ៖ ហិរណ្យវម៌្ម និង ព្រះនាង ហិរណ្យលក្ស្មី នៃទីក្រុង មហីធរបុរៈ
- រាជធានី ៖ មហីធរបុរៈ ក្រោយមកដូរមក យសោធរបុរៈ អង្គរទី ២

[207] សិលាចារឹកស្តុកកក់ធំ K 235D: 81 ថា ព្រះអង្គឡើងសោយរាជ្យនៅមហាសករាជ៩៧១ (=គ.ស.១០៤៩) តាមចារឹកប្រាសាទរលុះ ខេត្តបន្ទាយមានជ័យ ក៏បានឱ្យដឹងដែរថា ព្រះអង្គ ឡើងសោយរាជ្យនៅមហាសករាជ៩៧១ថ្ងៃ៨រោជខែផល្គុណ (cf, K 219: 1-2, in *C VII:* 45.) ប៉ុន្តែ សិលាចារឹកភ្នំសណ្តក K 194: 9-10និយាយថា ព្រះអង្គឡើងសោយរាជ្យនៅមហាសករាជ៩៧២ (=គ.ស.១០៥០) ឃើញពត៌មានបានពីសិលាចារឹកទាំងពីរ ខុសគ្នាមួយឆ្នាំ ។ បើតាមការ កត់សម្គាល់របស់យើង ពត៌មានដែលបានពីសិលាចារឹកពីរខាងដើម ត្រឹមត្រូវជាង ព្រោះអត្ថបទនោះ យ៉ាងយឺតបំផុត គេចារឹកនៅឆ្នាំ១០៥២គ.ស. គឺ ៣ឆ្នាំបន្ទាប់ពីការឡើង សោយរាជ្យរបស់ព្រះអង្គ។ ម្ល៉ោះហើយ អ្នកចារឹកពិតជានៅចាំកាលបរិច្ឆេទ និងព្រឹត្តិការណ៍នោះច្បាស់ជាងអ្នកចារឹកនៅក្រោយពេលកើតព្រឹត្តិការណ៍នោះយូរឆ្នាំ ជាង។ ចំណែកពត៌មានទី៣ ដែលបានបង្ហាញត្រូវបានគេចារឹកយ៉ាងហោចណាស់ ក៏៣ក់កណ្តាលទី១សតវត្សរ៍ទី១២ ឃើញថា ក្រោយ រាជ្យព្រះអង្គ ជាង១០០ឆ្នាំ។ ដោយពិតនោះសិលាចារឹកប្រាសាទរលុះ ឲ្យពត៌មានច្បាស់ជាងគេ ព្រោះបានកត់សំគាល់តាំងអំពីថ្ងៃ និងខែ ដែលព្រះអង្គឡើងសោយរាជ្យ។ ដូច្នេះ យើងអាចគណនាដឹងថា ព្រះអង្គពិតជាឡើងសោយរាជ្យ នៅដើមខែមីនា ឆ្នាំ១០៥០។

[208] អានថា ន ឫ ប៉ាក់ តិន ទ្រាក់ វ រ្មក់ មិនត្រូវសរសេរជា នរិបតិន្ទ្រវរ្ម័ន នោះទេ , សម, រចប ឯកសារដដែល ទំព័រ ២១៧)

[209] សម, វង់ សុធារ៉ា ឯកសារដដែល ទំព័រ ៤៥

- គោរព ៖ ព្រហ្មញ្ញសាសនា

១៧-ធរណីន្ទ្រវរ្ម័ទី១ (១១០៧-១១១៣) Dharaṇīndravarman I (r.1107-1113)

- ព្រះរៀមព្រះបាទ ជយវរ្ម័ ទី៦
- រាជធានី ៖ យសោធរបុរៈ អង្គរទី២
- គោរព ៖ ព្រហ្មញ្ញសាសនា

១៨-សូរ្យវរ្ម័ទី២ (១១១៣[210]-១១៥០) Sūryavarman II (r.1113- d.c.1150)

- ចៅមីង ព្រះបាទ ជយវរ្ម័ទី៦ និង ធរណីន្ទ្រវរ្ម័ទី១[211]
- រាជធានី ៖ យសោធរបុរៈ អង្គរទី ២
- គោរព ៖ ព្រហ្មញ្ញសាសនា
- ពង្រីកទឹកដី ៖ ខាងជើង ទល់នឹងចាម្ប, ខាងកើត ទល់នឹងសមុទ្រ, ខាងលិច ទល់នឹងប៉ាហ្គន នៅភូមា, ខាងត្បូង ទល់នឹងម៉ាឡេ។ ព្រះអង្គ បញ្ជូនទ័ព ២០.០០០ នាក់វាយ ដាយវៀត និងទទួលជ័យជម្នះ។
- មានទំនាក់ទំនងការ ទូត ជាមួយចិន។
- កសាងប្រាសាទ ៖ អង្គរវត្ត "អង្គរតូច" –ភ្នំសណ្ដក (ក្នុងខេត្តព្រះវិហារសព្វថ្ងៃទីកន្លែងដែលពីបុរាណ គេហៅថា សិវបុរទន្ទេន, វត្តភូ(ខេត្តចម្ប៉ាសាក់ ប្រទេសលាវ) –ព្រះពិធូរ (ក្នុងបរិវេណអង្គរធំ ជ្រុងឦសាន)– ចៅសាយ ទេវតា និង ធម្មានន្ទ(ខាងក្រៅខ្លោងទ្វារជ័យ នៃក្រុងអង្គរធំ ជ្រុងខាងកើត )--បន្ទាយសំរ៉ែ (ក្នុងបរិវេណពោះ បារាយណ៍ យសោធរតដាក ខាងកើតភូមិប្រដាក)។

- មាន ឯកសារខ្លះថា ព្រះរាជាដែលសោយរាជ្យជាបន្ទាប់ គឺព្រះបាទហស៌វរ្ម័ទី៤ (Harsavarman IV) (គ.ស.. ១១៥០-១១៥១)[212]។ តែទោះជាយ៉ាងណា ជាទូទៅគេមិនបានបញ្ចូលនាមព្រះរាជាអង្គនេះ ទៅក្នុងរបាក្សត្រឡើយ។

១៩-ធរណីន្ទ្រវរ្ម័ទី២ (១១៥១-១១៦០) Dharaṇīndravarman II (r.1151- d.c.1160)

- ចៅរបស់ ជយវរ្ម័ទី៦ និង ធរណីន្ទ្រវរ្ម័ទី១
- រាជធានី ៖ អង្គរទី ២
- -គោរព ៖ ព្រះពុទ្ធសាសនា

២០-យសោវរ្ម័ទី២ (១១៦០-១១៦៥) Yaśovarman II (r.1160-1165)

- ជាញាតិវង្ស ព្រះបាទ ធរណីន្ទ្រវរ្ម័ទី ២

---

[210] សិលាចារឹកវត្តភូ K. 366 (CV, 292) បញ្ជាក់ពីឆ្នាំ១០៣៥ ឬ១១១៣គ.ស. ដែលព្រះអង្គឡើងសោយរាជ្យ បន្ទាប់ពីបានដណ្ដើមយកបាន និងសមាហរណព្រះរាជាណាចក្រពីរឱ្យរួមចូលគ្នា។ ត្រង់នេះលោក សឺដេសថាទំនង រាជាណាចក្រមួយនៅមហីធរបុរៈ និងមួយទៀតនៅអង្គរ ដែលជាកេរ្តិ៍បន្តពីព្រះបាទហស៌វរ្ម័ទី៣។

[211] សិលាចារឹកភ្នំរុង K. 384 (CV, 302) បញ្ជាក់ពីការជាប់ខ្សែស្រឡាយនេះយ៉ាងពិស្ដារ។ព្រះអង្គ(សូរ្យវរ្ម័ទី២) ជាចៅទួតរបស់ស្ដេចហិរណ្យវរ្ម័ និងហិរណ្យលក្ស្មី ដែលជាបិតាមាតារបស់ព្រះបាទជយវរ្ម័ទី៦,ធរណីន្ទ្រវរ្ម័ទី១ និងស្រីយុវរាជ, ជាបុត្រារបស់ស្ដេចក្សីតីន្ទ្រាទិត្យដែលជាចៅប្រុសរបស់ហិរណ្យវរ្ម័ ជាមួយចៅស្រី(កូនស្រីរបស់កូនស្រី)ព្រះនាងហិរណ្យលក្ស្មី។

[212] ព្រះអង្គត្រូវជាក្មួយព្រះបាទ សូរ្យវរ្ម័ទី២ (cf, *SSIAC:* 40.)

- រាជធានី ៖ អង្គរទី ២

២១-ត្រិភូវនាទិត្យវម៌្ម[213] (១១៦៥-១១៧៧) Tribhūvanādityavarman (r.1165- d.c.1177)

គេមិនអាចសរសេរជា ត្រីភុវនៃអាទិត្យវរ្ម័ន បានទេ ។

- អតីតមន្ត្រី ដែលក្បត់ច្បាំងដណ្តើមរាជ្យ
- រាជធានី ៖ អង្គរទី២

២២-ជយវម៌្មទី៧ (១១៨១-១២២០) Jayavarman VII (r.1181- d.c.1220)

- បុត្រ ៖ ធរណីន្ទ្រវម៌្ម ទី២
- រាជធានី ៖ យសោធរបុរៈ អង្គរទី ៣ ដែលមានប្រាសាទបាយ័ន ជាផ្ចិត មានកំពែងអង្គរធំ ជាសញ្ញា សម្គាល់រាជធានីនេះ។
- គោរព ៖ ព្រះពុទ្ធសាសនា
- មរណនាម ៖ មហាបរមសៅគតបទ
- ពង្រីកទឹកដី ៖ ខាងជើងទល់នឹងតំបន់វៀងច័ន្ទ នៃប្រទេសឡាវ, ខាងលិច ទល់នឹងខ្សែទឹកទន្លេមេណាម និង អាង ទន្លេ ឥរ៉ាវតី នៅប្រទេសភូមា, ខាងត្បូងទល់នឹងសមុទ្ទ។ ឃើញថា ទឹកដីធំទូលាយជាងរាជ្យស្តេច មុនៗទាំងអស់។
- កសាង ៖ កសាងបានច្រើនជាងស្តេចមុនៗ
- អាណាចក្រចំណុះ ៖ ១២ ៖ ភូមា- ចន្ទបុរី " សៀម " ម៉ាឡេ - ចាម ....
- កសាងសាលាសម្នាក់ ១២១ " សិលាចារឹកប្រាសាទព្រះខ័ន "
- មន្ទីរពេទ្យ រាយពាសពេញសម្រាប់ព្យាបាលប្រជាជន
- ប្រាសាទបាយ័ន, កំពែងអង្គរធំ, តាព្រហ្ម ឆ្នាំ១១៨៦, ព្រះខ័ន នៅឆ្នាំ១១៩១, នាគព័ន្ធ កណ្តាលបារាយណ៍ព្រះ ខ័ន, បន្ទាយក្តី និងស្រះស្រង់, តាសោម, ក្រោលគោ, វត្តនគរបាជ័យនៅខេត្ត កំពង់ចាម, ប្រាសាទជ្រុង , សួរព្រ័ត, តាព្រហ្ម-ទន្លេ បាទី, តានៃ, ព្រៃ, បន្ទាយព្រៃ, បន្ទាយឆ្មារនៅឆ្នាំ១២១៦(តាមសិលាចារឹកថ្មី១ ទើបរកឃើញ នៅក្បែរសិលាចារឹក K.227) ដែលសុទ្ធតែមានតួប៉មមុខ៤ហើយបែរទៅរកទិសទាំង បួន។ កសាងលានដល់ដំរី, មុខប្រាសាទបន្ទាយក្តី។

២៣-ឥន្ទ្រវម៌្មទី២ (១២២០-១២៤៣) Indravarman II (r.1220- d.c.1243)

- បុត្ររបស់ ព្រះបាទ ជយវម៌្មទី៧
- រាជធានី ៖ អង្គរទី ៣

២៤-ជយវម៌្មទី៨[214] (១២៤៣-១២៩៥) Javarman VIII (r.1243- 1295/96)

- មិនដឹងច្បាស់ គ្រាន់តែដឹងថា ជាញាតិស្តេចមុន មានស្រុកកំណើតនៅព្រះស្រុកឧមា នៃប្រមាណល្ងៅ។
- រាជធានី ៖ អង្គរទី ៣

---

[213] អានថា ត្រិ ភុ វាក់ នៀ ទិត ត្យាក់ វ រ្មក់ cf, K 418: 3, in *APK I:* 177 និង សម, រចប ឯកសារដដែល ទំព័រ២២៧។

[214] Cf, *SSIAC:* 41and K 569 op. cit.

២៥-ស្រីន្ទ្រវម៌្ម (១២៩៦[215]-១៣០៨) Śrīndravarman (គ.ស. ១២៩៥-១៣០៨) មិនមែន ឥន្រ្ទវរ្ម័នទី៣ នោះទេ ព្រះនាមពេញរបស់ព្រះអង្គ យើង បង្ហាញរួចហើយនៅទំព័រទី១០ ។

- កូនប្រសាររបស់ ព្រះបាទជយវម៌្ម ទី៨ និងជាបច្ឆាជនរបស់ព្រះបាទស្រេស្ឋវម៌្ម ដោយព្រះអង្គមានកំណើត ជាអ្នកស្នងមរតកពីស្រុករបស់ស្តេចបីកន្លែង គឺឈ្មោះព្រះស្រុកស្បោត, ស្រុកស្រីស្រីន្ទ្រវជបុរៈ និងកូតផ្វបុរៈ។
- រាជធានី ៖ អង្គរទី ៣

២៦-ស្រីន្ទ្រជយវម៌្ម[216] (១៣០៨-១៣២៧) Śrīndrajayavarman (r.1308-d.1327) នាមដើមរបស់ព្រះអង្គនៅក្នុង អត្ថបទភាសាខ្មែរ គឺ *ស្រីស្រីន្ទ្រជយពម៌្ម កុរុណាបពិត្រ*[217]។ ប៉ុន្តែ បើតាមអត្ថបទសំស្ក្រឹត នាមរបស់ព្រះអង្គគឺ ស្រីន្ទ្រជយវម៌្ម (រាជ្ញស្រ្តីស្រីន្ទ្រជយវម៌្មនះ)[218] ។

- ជាប់ញាតិនឹងស្តេចអង្គមុនៗ
- រាជធានី ៖ យសោធរបុរៈ អង្គរទី៣

២៧-ជយវម៌្មទី៩ (១៣២៧-១៣៣៩) (ជយវម៌្មាតិបរមេស្វរ ឬ ជយវម៌្មបរមេស្វរៈ)
Jayavarman IX (r.1327-d.1339)

មិនដឹងដឹងជាប់ជាញាតិបែបណាជាមួយស្តេចមុន? នាមរបស់ព្រះអង្គនៅក្នុងសិលាចារឹក តរាជ្យព្រះបាទ កម្រតេង *អញស្រីជយវម៌្មទេវបរមេស្វរ*[219] និងនាមនៅក្នុង សិលាចារឹកភាសាសំស្ក្រឹតមួយទៀតគឺ ជយវម៌្មបរមេស្វរ (ស្រីជយវម៌្មាទិ បរមេស្វរ)[220]។

សម័យអង្គរមិនមែនបញ្ចប់ត្រឹមរាជ្យព្រះបាទជយវម៌្មទី៩នេះទេ ដោយសារពត៌មានតាមរយៈសិលាចារឹក ស្តី អំពី ព្រះរាជាត្រូវដាច់ភាគត្រឹមនេះ គ្មានចារឹកសាស្ត្រណាមួយប្រកបដោយពត៌មានរលូនបន្ត បន្ទាប់គ្នាត្រូវបានគេចារ ឡើង ទើប អ្នកស្រាវជ្រាវបារាំងងាកមកជ្រើសយកឯកសារពង្សាវតារនានា មកដាក់ភ្ជាប់រជ្ជកាលខាងលើ ដែលភាគ ច្រើននៃអ្នកប្រាជ្ញ ទាំងនោះ និយមដាក់ព្រះបាទ ពញាជ័យ ឬតាត្រសក់ផ្អែម ដែលជាព្រះរាជាចេញ ពីវណ្ណៈកសិករ ឡើងសោយរាជ្យ បន្តវង្ស ស្តេចអង្គរ(---វម៌្មទេវ ឬ ---វម៌្មទេព)។ បន្ទាប់មក វង្សត្រកូលស្តេច អង្គនេះ បានឡើង សោយរាជ្យជាបន្តបន្ទាប់ រហូត ដល់សព្វថ្ងៃ។

ចំណែកព្រះរាជា ដែលបានសោយរាជ្យក្នុងអំឡុងពេល១០០ឆ្នាំ ក្រោយពីរាជ្យព្រះបាទជយវម៌្មទី៩ យើងក៏ មិន បានដឹងច្បាស់ថា មានប៉ុន្មានអង្គនោះដែរ ពីព្រោះឯកសារទាំងនោះ គ្មានចំណុចរួមគ្នាជាច្រើនអន្លើ។ អ្វីដែល បានឯកភាពគ្នា នោះ ចាប់ត្រឹមរាជ្យព្រះពញាយ៉ាត តែប៉ុណ្ណោះ។

---

215 Cf., *APK I:* 283.

216 Cf, *SSIAC, op. cit.* ចំណែក លោក សឺដេស ថា រាជ្យព្រះអង្គចាប់ផ្តើមពីឆ្នាំ ១៣០៧ នៃ គ.ស. cf, *APK I:* 159

217 Cf, K 144:1 in *C VII:* 34.

218 Cf, K 300B: 93, Abel Bergaigne, *Inscriptions Sanscrites du Cambodge*, 2e fascicule, p. 577, 583.

219 Cf, K 470: 11 dated probably 1327 A.D in *C II:* 187.

220 Cf, K 300B: 67, 101, *ibid*.

# នាមព្រះមហាក្សត្រចុងសម័យអង្គរ តាមពង្សាវតារសតវត្សរ៍ទី១៩

ស្តេចសោយរាជ្យ ចុងសម័យអង្គរ ១៣៣៦-១៤៣១ និងការចាកចោលរាជធានីអង្គរ តាមពង្សាវតារ

ត្រសក់ផ្អែម រាជធានីអង្គរធំ «១៣៣៦ - ១៣៤០»[221]

និព្វានបទ ៖ ១៣៤០-១៣៤៦

សិទ្ធានរាជា ១៣៤៦ « ៦ ខែ »

ស្រីលំពង់រាជា ១៣៤៧ - ១៣៥៣

ស្រីសុរិយោវង្ស ១៣៥៣ - ១៣--

ធម្មោរាជា បរមរាជាទី ១

ធម្មាសោករាជ ? (សិលាចារឹកព្រះធាតុខ្វាវ និងដុងម៉ែណាមមឿង នៅប្រទេសថៃ)[222]

ចៅពញាយ៉ាត បរមរាជាទី ២ (១៣៩៣ - ១៤៦៣)

រាជធានី ៖ អង្គរធំ- ទួលបាសាន- ចតុមុខ « ភ្នំពេញ » ១៣៦៩ - ១៣៧៣, ១៣៧៣ - ១៣៩៣

ចំណែករាជធានីមហានគរដ៏ស្តុកស្តម្ភ រហូតមកដល់រាជ្យព្រះបាទពញាយ៉ាត នាគ.ស.១៤៣២? ទើបព្រះអង្គ ចាកចោល។ ព្រោះតែទទួលការគំរាមកំហែងផ្នែកសន្តិសុខពីរដ្ឋអយុធ្យារបស់សៀមញឹកញាប់ពេក និងហេតុផលខាងសេដ្ឋកិច្ច ហើយការបោះបង់នេះក៏ត្រូវធ្វើឡើង នៅក្រោយពីបានរំដោះចេញពីការត្រួតត្រារបស់សៀម ក្នុងពេលថ្មីៗដែរ បើតាមការអះអាងនៅក្នុងរាជពង្សាវតារនៃប្រទេសកម្ពុជា នាសតវត្សរ៍ទី១៩។

បើគេពពិនិត្យមើល តាមឯកសារចិន ពង្សាវតារអយុធ្យា និងពង្សាវតារឡាវ នៅអង្គរ មានវត្តមានព្រះមហាក្សត្រព្រះបាទជយវម៌្មទី៩ សោយរាជ្យរហូតដល់ចុងទសវត្សរ៍ឆ្នាំ១៣៥០ និងគ្មានការវាយប្រហារដោយអយុធ្យានោះទេ។ ឯកសារចិន ថា គេបង្កើតទីក្រុងអយុធ្យា នៅ ឆ្នាំ១៣៤៩-៥០ ហើយពង្សាវតារអយុធ្យាថា គេបង្កើតទីក្រុងអយុធ្យានៅឆ្នាំ ១៣៥១-២។ ចំណែក ពង្សាវតារឡាវថា ព្រះបាទ ហ្វាងុម អាចបង្កើតប្រទេសឡានសាង ឯករាជ្យបាននៅឆ្នាំ១៣៥៣ ដោយសារស្តេចខ្មែរនៅអង្គរ ដែលជាបិតាក្មេក ឱ្យព្រះអង្គខ្ចីកងទ័ពទៅធ្វើចម្បាំងបង្រួបបង្រួមទឹកដីឡាវ និងនៅឆ្នាំ បន្តបន្ទាប់ បានបញ្ជូនប្រតិភូពុទ្ធសាសនាទៅផ្សព្វផ្សាយ ធម៌ពុទ្ធសាសនានៅទីនោះ។ បើតាមការសិក្សាពីប្រភពចិន ដោយ លោក អូលីវើរ វ៉ូលធ័រ បានឱ្យដឹងថា ចាប់ឆ្នាំ១៣៧១ - ៧៣ ទូតចិនកត់ត្រាថា រាជធានីរបស់ខ្មែរ នៅទួលបាសាន ក្នុងខេត្តស្រីសន្ធរ ហើយក៏មិនបានបញ្ជាក់ថា មកពីមានសឹកសង្គ្រាមនៅអំឡុងពេលនោះដែរ។

---

221 រឿងរ៉ាវស្តេចអង្គនេះមុនពេលបានឡើងសោយរាជ្យនៅអង្គរ មិនអាចឱ្យជឿបានសូម្បីបន្តិច។ ព្រោះរឿងនិទានអ្នកដាំត្រសក់ម្នាក់បានឡើងសោយរាជ្យជាស្តេចនេះ គេបានប្រឌិត និងនិទាននៅប្រទេសភូមាតាំងពីសតវត្សរ៍ទី១០មកម្ល៉េះ។ ដូច្នេះ ស្តេចអង្គនេះ ទំនងជាគ្មាននៅក្នុងប្រវត្តិសាស្ត្រពិតប្រាកដទេ។ បើមានមែន ក៏ប្រវត្តិនៃរឿងរ៉ាវបានឡើងសោយរាជ្យគាត់ មិនមែនដោយសារជំនាញក្នុងការដាំត្រសក់ដែរ។ គាត់អាចជាស្តេចជ្រែករាជ្យដ៏សំខាន់មួយអង្គ ដែលកាន់ពុទ្ធសាសនា ហើយបះបោរដណ្តើមរាជ្យអំណាចរបស់ស្តេចនៅតំបន់អង្គរ។ លោក ម៉ក់ភឺន (១៩៨៤) បានបញ្ជាក់ថា ព្រះអង្គ មានព្រះនាមក្នុងរាជ្យសម្បត្តិថា បរមរាជា ដែលសោយរាជ្យពីឆ្នាំ១២៩០ដល់១៣៤០គ.ស.។ Cf., Mak Phoeun, (1984). *Chroniques Royales du Cambodge (des origines légendaires jusqu'à Paramaraja 1er)*, EFEO, Paris, pp. 299-303, 370.

222 ទោះបីជាយ៉ាងណាក៏ដោយ នាមរបស់ព្រះរាជាចាប់ពីតាត្រសក់ផ្អែម រហូតដល់ ធម្មាសោករាជ នេះ គ្មានអ្នកណាអាចអះអាងបានថា ពិតជាមាន ឬមិនមានឱ្យច្បាស់លាស់បានឡើយ។

ហេតុដល់ឆ្នាំ១៨០៥ ទើបទូតចិន ឱ្យដឹងថា រាជធានីបានផ្លាស់ទៅនៅអង្គរវិញ។ ត្រង់ចំណុចនេះ ប្រហែលមកពីនៅតំបន់អង្គរជួបគ្រោះរាំងស្ងួតរយៈពេលយូរ ដូចការសិក្សាខាងរុក្ខកម្មលើស្រទាប់រង្វង់ឈើពាន់ឆ្នាំ នៅវៀតណាមកណ្ដាល របស់សាស្ត្រាចារ្យ មកពីសាកលវិទ្យាល័យកូឡុំប៊ូ និងបុរាណវិទូវៀតណាម ដែលបានរកឃើញ និងសន្និដ្ឋានថា តំបន់អង្គរក៏បានរងគ្រោះពីគ្រោះធម្មជាតិនេះដែរ ទើបព្រះរាជាលើករាជធានីទៅនៅស្រីសន្ធរ ដែលជាតំបន់សម្បូរទឹកសម្រាប់ប្រើប្រាស់ និងធ្វើកសិកម្ម។ ពីព្រោះ ទីនោះមាន ទីតាំងនៅក្បែរជេងទន្លេមេគង្គ និងបឹងពីធម្មជាតិ៕

# ព្រះមហាក្សត្រខ្មែរសម័យកណ្តាល និងអាណាព្យាបាល

| សម័យចតុមុខ (១៤៣២-១៥០៤) | | ញាតិវង្ស | រជ្ជកាល |
|---|---|---|---|
| 1. | ១-ពញាយ៉ាត-បរមរាជា១ | រំដោះអង្គរពីសៀម | 1417 - 1463 |
| 2. | ២-នារាយណ៍រាជា | បុត្រពញាយ៉ាត | 1463 - 1468 |
| 3. | ៣-ស្រីរាជា | បុត្រពញាយ៉ាត | 1468 - 1486 |
| 4. | ៤-មហាធម្មរាជា | បុត្រពញាយ៉ាត | 1476 - 1504 |
| 5. | ៥-ស្រីសុរិយោទ័យ | បុត្រនារាយណ៍រាជា | 1476 - 1486 |
| 6. | ៦-ពញាដាំខាត់-ស្រីសុគន្ធបទ[223] | បុត្រមហាធម្មរាជា | 1504 - 1512 |
| 7. | ៧-ហ្លួងព្រះស្តេចកន-ព្រះស្រីជេដ្ឋា | ជ្រែករាជ្យ | 1508 - 15xx |
| **សម័យលង្វែក** (១៥២៩-១៥៩៤) | | | |
| 8. | ៨-ពញាចន្ទរាជា-បរមរាជាទី២ | បុត្រមហាធម្មរាជា | 1516 - 1566 |
| 9. | ៩-បរមិន្ទរាជា-បរមរាជាទី៣ | បុត្រពញាចន្ទរាជា | 1566 - 1576 |
| 10. | ១០-សត្ថាទី១-បរមរាជាទី៤(ជយជេដ្ឋាទី១) | បុត្របរមិន្ទរាជា | 1576 - 1594 |
| 11. | ១១-ជយជេដ្ឋាទី១ (មរមរាជាទី៥?) | បុត្រសត្ថាទី១ | 1584 - 1594 |
| 12. | ១២-ពញាតន់-បរមរាជាទី៥ (រាជ្យទី១) | បុត្រសត្ថាទី១ | 1584 - 1594 |
| 13. | ១៣-រាមាជើងព្រៃ-រាមទី១ | ព្រះវង្សនៅជើងព្រៃ | 1594 - 1596 |
| 14. | ១៤-ពញានូ-រាមទី២ | បុត្ររាមជើងព្រៃ | 1596 - 1597 |
| 15. | ១៥-ពញាតន់-បរមរាជាទី៥ (រាជ្យទី២) | បុត្រសត្ថាទី១ | 1597 - 1599 |
| 16. | ១៦-ពញាអន-បរមរាជាទី៦ | បុត្របរមិន្ទរាជា | 1599 - 1600 |
| 17. | ១៧-ពញាញោម-ព្រះកែវហ្វ៉ាទី១ | បុត្រសត្ថាទី១ | 1600 - 1602 |
| 18. | ១៨-ស្រីសុរិយោពម៌-បរមរាជាទី៧ | បុត្របរមិន្ទរាជា | 1602 - 1619 |
| **សម័យឧដុង្គ** | | | |
| 19. | ១៩-ជយជេដ្ឋាទី២ | បុត្រសុរិយោពម៌ | 1619 - 1627 |
| 20. | ២០-ឧទយរាជា-បរមរាជា (ឧភយោរាជ) | បុត្រសុរិយោពម៌ | 1627 - 1642 |
| 21. | ២១-ពញាតូ-ធម្មរាជាទី១(?) | បុត្រជយជេដ្ឋាទី២ | 1627 - 1632 |
| 22. | ២២-ពញានូរ-អង្គទងរាជា | បុត្រជយជេដ្ឋាទី២ | 1632 - 1640 |
| 23. | ២៣-អង្គនន់-បទុមរាជាទី១ | បុត្រឧទយរាជា | 1640 - 1642 |
| 24. | ២៤-ពញាចន្ទ-រាមាធិបតីទី១ | បុត្រជយជេដ្ឋាទី២ | 1642 - 1658 |
| 25. | ២៥-អង្គសូរ-បរមរាជាទី៨ | បុត្រឧទយរាជា | 1659 - 1672 |
| 26. | អង្គតន់-រាមាធិបតី (ឧភយោរាជ) | បុត្រឧទយរាជា | 1664 - 1674 |

[223] Cf., Tableau généalogique des rois khmer, dans Khin Sok, (1991). *Le Cambodge entre le Siam et le Vietnam de 1775 à 1860*, EFEO, Paris.

| | | | |
|---|---|---|---|
| 27. | ២៦-ស្រីជយជេដ្ឋ-បទុមរាជាទី២ | បុត្រអង្គនន់ | 1672 - 1673 |
| 28. | ២៧-អង្គជី-ព្រះកែវហ្វ៊ាទី២ | បុត្រអង្គសូរ | 1673 - 1677 |
| 29. | ២៨-អង្គនន់-បទុមរាជា ( ឧភយោរាជ ) | បុត្រកែវហ្វ៊ាអង្គតម-ចៅឧទ័យ | 1674 - 1691 |
| 30. | ២៩-អង្គសូរ-ជយជេដ្ឋាទី៣ | បុត្រអង្គសូរ | 1677 - 1695 |
| 31. | ៣០-អង្គយ៉ង-រាមាធិបតីទី២ | បុត្រព្រះកែវហ្វ៊ាអង្គជី | 1695 - 1696 |
| 32. | អង្គសូរ-ជយជេដ្ឋាទី៣ (រាជ្យទី២ ) | | 1696 - 1700 |
| 33. | ៣១-អង្គតម-ព្រះកែវហ្វ៊ាទី៣ (រាជ្យទី១ ) | បុត្រអង្គនន់-ឧភយោរាជ | 1700 - 1701 |
| 34. | អង្គសូរ-ជយជេដ្ឋាទី៣ (រាជ្យទី៣ ) | | 1701 - 1702 |
| 35. | ៣២-ធម្មរាជាទី២( ជយជេដ្ឋាទី៤IMA39 )(រាជ្យទី១ ) | បុត្រជយជេដ្ឋាទី៣ | 1702 - 1704 |
| 36. | អង្គសូរ-ជយជេដ្ឋាទី៣ (រាជ្យទី៤ ) | | 1704 - 1707 |
| 37. | ធម្មរាជាទី២( ជយជេដ្ឋាទី៤ IMA39 )(រាជ្យទី២ ) | បុត្រជយជេដ្ឋាទី៣ | 1707 - 1714 |
| 38. | អង្គតម-ព្រះកែវហ្វ៊ាទី៣ (រាជ្យទី២ )[224] | បុត្រអង្គនន់-ឧភយោរាជ | 1714 - 1722 |
| 39. | ៣៣-អង្គជី-ព្រះសត្ថាទី២ (រាជ្យទី១ ) | បុត្រអង្គតម | 1722 - 1729 |
| 40. | អង្គតម–ព្រះកែវហ្វ៊ាទី៣ (រាជ្យទី៣ ) | | 1729 ( 7m. ) |
| 41. | អង្គជី-បរមរាជាទី១០ (រាជ្យទី២ ) | បុត្រអង្គតម | 1729 - 1738 |
| 42. | ធម្មរាជាទី២( ជយជេដ្ឋាទី៤-រាជ្យទី៣ ) | | 1738 - 1747 |
| 43. | ៣៤-អង្គតម-ស្រីធម្មរាជា | បុត្រជយជេដ្ឋាទី៤ | 1747 - 1748 |
| 44. | ៣៥-អង្គទង-រាមាធិបតី២ (រាជ្យទី១ ) | បុត្រអង្គយ៉ង-ឧទយរាជា | 1748 - 1749 |
| 45. | ៣៦-អង្គស្ងួន-ស្រីជយជេដ្ឋ | បុត្រជយជេដ្ឋាទី៤ | 1749 - 1755 |
| 46. | អង្គទង-រាមាធិបតី២ (រាជ្យទី២ ) | | 1756 - 1757 |
| 47. | ៣៧-អង្គតន់-ឧទយរាជា៣ ឬនារាយរាជា២ | ចៅអង្គទង-រាមាធិបតី២ | 1758 - 1775 |
| 48. | ៣៨-អង្គនន់-រាមាធិបតី៣ | បុត្រអង្គស្ងួន-ស្រីជយជេដ្ឋ | 1775 - 1779 |
| 49. | ៣៩-អង្គអេង-នារាយណ៍រាមា២ | អង្គតន់-នារាយរាជា២ | 1779 - 1796 |
| 50. | ៤០-អង្គច័ន្ទ-ឧទយរាជា៤ | បុត្រអង្គអេង | 1806 - 1834 |
| 51. | ៤១-អង្គម៉ីក្សត្រី | បុត្រីអង្គច័ន្ទ | 1834 - 1847 |
| 52. | ៤២-អង្គដួង-ហរិរក្សរាមាឥស្សរាធិបតី | បុត្រអង្គអេង[225] | 1848 - 1860 |
| | **សម័យភ្នំពេញ** | | |
| 53. | ៤៣-នរោត្តម | បុត្រអង្គដួង | 1864 - 1904 |
| 54. | ៤៤-ស៊ីសុវត្ថិ | បុត្រអង្គដួង | 1904 - 1927 |
| 55. | ៤៥-ស៊ីសុវត្ថិមុនីវង្ស | បុត្រស៊ីសុវត្ថិ | 1927 - 1941 |
| 56. | ៤៦-នរោត្តមសីហនុ( មេសា១៩៤១=១៨ព្រះវស្សា ) | ចៅទួតនរោត្តម | 1941 - 1955 |
| 57. | ៤៧-នរោត្តម សុរាម្រឹត | ចៅនរោត្តម-បិតាសីហនុ | 1955 - 1960 |

[224] Cf., Tableau génealogique des familles régnantes du Cambodge fin XVIe siècle au début XVIIIe siècle, dans Mal Phoeun, (1995). *Histoire du Cambodge de la fin du XVIe siècle au début du XVIII siècle,* EFEO, Paris, pp. 425-429.

[225] Cf., Khin Sok, loc. cit.,

| | | | |
|---|---|---|---|
| 58. | ៤៨-ស៊ីសុវត្ថិ កុសមៈ នារីរតន៍សិរីវឌ្ឍនា | អគ្គមហេសីព្រះសុរាម្រឹត | 1960 - 1970 |
| 59. | * *នរោត្តមសីហនុ | បុត្រសុរាម្រឹត | 1993 - 2004 |
| 60. | ៤៩-នរោត្តម សីហមុនី | បុត្រសីហនុ | 2004 -present |

# ឯកសារពិគ្រោះជម្រើស


1- Barth, Auguste, 1885. *Inscriptions Sanscrites du Cambodge*, t. 27e (1$^{re}$ fascicule), Paris, 180ps.

2- Bergaigne, Abel, 1893. *Inscriptions Sanscrites de Campâ et du Cambodge,* t. 27$^{e}$ (2$^{e}$ fascicule), Paris, pp. 181-629.

3- Brown, MacAlister and Zasloff, Joseph J., 1998. *Cambodia Confounds the Peacemakers, 1979-1998,* Cornell University Press, Ithaca & London

4- Chakravarti, Adhir, 1980. *THE SDOK KAK THOM INSCRIPTION*, part II, Calcutta.

5- Chandler, David,

2000 *A History of Cambodia*, 3rd edition, Silkworm Books, 296 pages.

2005 *ប្រវត្តិសាស្ត្រខ្មែរ, បកប្រែពីការបោះពុម្ពលើកទី៣, មជ្ឈមណ្ឌលខេមរសិក្សា,ភ្នំពេញ, ទំ.៣២០*

6- ហ្សក សឺដេស,

1937-1966 *Inscriptions du Cambodge*, Vol. 1-8 (8 volumes), Paris.

1989-92 *Articles sur le Pays Khmer*, tome I-II (2 volumes), éditée par Claude Jacques, Paris.

7- Gottesman, Evan, 2002. *Cambodia After the Khmer Rouge: inside the Politics of Nation Building*, Yale University Press.

8- Institut National de France,

1885–1 *Inscriptions Sanscrites du Cambodge*, (1$^{re}$ Partie) 1$^{re}$ fascicule, Paris.

1893-2 *Inscriptions Sanscrites de Campâ et du Cambodge*, (1$^{re}$ Partie) 2$^{e}$ fascicule, Paris. (Rubbing image books)

9- Jacques, Claude, Supplément au Tome VIII des Inscriptions du Cambodge, *BEFEO, t. LVIII,* Paris, pp. 177-95.

10- KAMALESWAR Bhattacharya, 1991. *Recherches sur le Vocabulaire des Inscriptions Sanskrites du Cambodge,* Paris.

11- Khin, Sok

1977 *Deux inscriptions Tardives du Phnom Bâkhêng K 465 et K 285,* dans *BEFEO t. LXV,* Paris, pp.271-80.

1980 *L'inscription de Vatta Romlok K 27 et L'inscription de Prah Thom du Kulên K 715,* dans *BEFEO t. LXVII,* Paris, pp.125-34.

1991 *Le Cambodge entre le Siam et le Vietnam de 1775 à 1860,* EFEO, Paris.

12- Finot, Louis, 1926-31, *Inscriptions du Cambodge,* tome 1-5 (5 volumes), sous les auspice d'Académie des Inscriptions et Belles-Lettres, Paris. (Rubbings)

13- Mak, Phoeun

1984 *Chroniques Royales du Cambodge (des origines légendaires jusqu'à Paramaraja 1$^{er}$),* EFEO, Paris.

1995 *Histoire du Cambodge de la fin du XVI$^{e}$ siècle au début du XVIII$^{e}$,* Paris, EFEO.

14- Mahabidûr, Krassem, 1958/1984. *Inscriptions Modernes d'Angkor,* 2$^{nd}$ edition-1958, the Buddhist Institute; 3$^{rd}$ edition, Cedoreck, Paris, 206 pages. (en Khmer)

12- Mahesh Kumar Sharan, 1974. *Studies in Sanskrit Inscriptions of Ancient CAMBODIA,* New Delhi.

13- Monier, Monier Williams, 1995. *A Sanskrit-English Dictionary,* New Delhi.

14- Osborne, Milton, 1994, *Prince ofLight, Prince of Darkness.*

15- POU, Saveros

1971 *Recherches sur le Vocabulaire Cambodgien (VII), les doublets d'origine indienne,* dans *Journal Asiatique,* année 1971, pp. 103-38.

1989 *Nouvelles des Inscriptions du Cambodge I,* Paris.

1992 *Dictionnaire Vieux Khmer-Fran©ais-Anglais,* Cedoreck, Paris.
1996 *Nouvelles des Inscriptions du Cambodge II,* Paris.
1998 *What is Khmerology?* (Address delivered at the Buddhist Institute and the Ministry of Cults and Religions, Phnom Penh, 1998) through *Kampuja SUrü Review,* Phnom Penh 53rd year, N° 1, 1999, pp. 27-43, and N° 2, pp. 36 -45.

16- R.C. Majumdar, *KAMBUJA-DESA or An Ancient Hindu Colony in CAMBODIA,* University of Madras.

17- SAHAI, Sachchidanand, 1970. *Les Institutions Politiques et L'Organisation Administrative du Cambodge Ancien (VIe-XIIIe siècles),* Paris EFEO, vol. LXXV.

18- Vickery Michael, 1998. *Society, Economics and Politics in Pre-Angkor CAMBODIA*, Tokyo Bunko, Japan.

19- Vong Sotheara
2002 *Ancient Inscriptions of Cambodia,* (joint writing), UNV-UNESCO, Phnom Penh..
2003 *Pre-Angkor Inscriptions of Cambodia,* Royal University of Phnom Penh-Buddhi Khmer Center, Phnom Penh.
2007 *Post-Angkor Inscriptions of Cambodia*, unpublished manuscripts.
2008 *Angkor Inscriptions of Cambodia,* unpublished manuscript.

20- ត្រឹង ងា
១៩៧៣ប្រវត្តិសាស្ត្រខ្មែរ ភាគ១ ភ្នំពេញ
១៩៧៤ ប្រវត្តិសាស្ត្រខ្មែរ ភាគ២ ភ្នំពេញ

21- មីសែល ត្រាណេ
១៩៩៨ ប្រវត្តិសាស្ត្រកម្ពុជា, អាណាចក្រចេនឡា (ស.វ. ទី៦ ដល់ ទី៨) ភ្នំពេញ រស់ ចន្ទ្រាបុត្រ
១៩៩៨ ប្រវត្តិសាស្ត្រខ្មែរ ភាគទី១ (ភាគរឿងព្រេងនិទាន និងតាមរយៈសិលាចារឹក) ឡាម៉ាត់តង់, ប៉ារី។

22- លី គឹមឡុង , ១៩៧២, អ្វីជាកំលាំងនៃសាមគ្គីខ្មែរសម័យអង្គរ ក្នុងទស្សនាវដ្តីអក្សរសាស្ត្រ-មនុស្សសាស្ត្រ ឆ្នាំទី២ លេខ៣ ភ្នំពេញ ទំព័រ ៤៨-៥៥ ។

23- សូរ អឿ, ១៩៩៧, ប្រវត្តិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា ជាមួយអាណ្ណាម និង សៀម ចាប់ពីសតវត្សទី១៦ ភ្នំពេញ

24- ហ្សក សឺដេស, ១៩៤៧, *ដើម្បីយល់កាន់តែច្បាស់អំពីអង្គរ,* បកប្រែជាភាសាខ្មែរដោយ ម៉ុញ សារី ភ្នំពេញ ១៩៩៩ ។

25- ***ទស្សនាវដ្តីអក្សរសាស្ត្រ-មនុស្សសាស្ត្រ,*** សាកលវិទ្យាល័យភូមិន្ទភ្នំពេញ, លេខពិសេស ខែធ្នូ ១៩៩៨ ទំព័រ ៣៩-៤៨ ។ ***ទស្សនាវដ្តីកម្ពុជសុរិយា,*** ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ លេខ១ ឆ្នាំ១៩៩៧ និង លេខ១-២ ឆ្នាំ ១៩៩៩ ។